ជេម ក្លាវែល

# អគ្គមហាសេនា

# SHŌGUN



ប្រែសម្រួលដោយ : ខៀវ កាញ្ញារីទ្ធ

និង ខៀវ ឆេព វច្ឆី

២

www.budinfo.gov.kh www.elibraryofcambodia.org

៣៣៩.១៧ គ

ជេម ក្លាវែល

# អគ្គមហាសេនា



# SHŌGUN

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE
១២៦៥/០៦

ប្រែសម្រួលដោយ : ខៀវ កាញ្ញារីទ្ធ
និង ខៀវ ឆេព រង្សី

## ២

www.budinst.gov.kh www.elibraryofcambodia.org

**ស្នាដៃនេះ**

កើតឡើងពីកិច្ចសហការគ្នា រវាង
**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**
ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត
ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ
សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់
**អង្គការរីហ្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**
**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**
ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh        www.elibraryofcambodia.org

www.budinst.gov.kh        www.elibraryofcambodia.org

ផាត់មុខអស់ហើយ ។ អីលូវនេះ លោកពាក់អាវគីម៉ូណូពណ៌ត្នោតយ៉ាងសាមញ្ញមួយពីលើអាវក្រោះរបស់លោក ។ ដាវលោកសៀតនៅនឹងចង្កេះ ។ ពេលលោកដើរទៅមុខ ចន្លោះនៅពីក្រោយខ្នងរបស់លោកត្រូវបិទជិតដោយអង្គរក្សរបស់លោកភ្លាម ហើយក្បួននេះក៏ចលនាសន្សឹមៗ តំរង់ទៅរកផែ ។

អាកូនមីចោរនេះ -*ប្លាក់ថន* គិតនៅក្នុងចិត្ត ។ អ្នែងសាហាវឃោរឃៅ ឥតចិត្តឥតថ្លើម តែអ្នែងចេះរៀបរឹកអោយហ៊ឹកហ៊ាក់មែន ។

មុននេះបន្តិច *ប្លាក់ថន* ឃើញនារីក្មេងម្នាក់ជួយគ្រាហ៍ *ម៉ារីកូ* ចុះទៅក្រោម ។ គេគិតថា *ម៉ារីកូ* ប្រហែលជាត្រូវរបួស ប៉ុន្តែមិនធ្ងន់ធ្ងរប៉ុន្មានទេ ។ ពីព្រោះពួក *សាមូរ៉ៃ* ដែលត្រូវរបួសធ្ងន់ធ្ងរសុទ្ធតែត្រូវសំលាប់ចោលទាំងអស់ បើសិនជាអ្នកនោះមិនហ៊ាន រឺមិនអាចសំលាប់ខ្លួនបាននោះ ។ ហើយ *ម៉ារីកូ* គឺជា *សាមូរ៉ៃ* ។

ដៃរបស់គេនៅខ្សោយនៅឡើយ ប៉ុន្តែគេប្រឹងស្រវាចាប់ដៃចង្កូតទូក ហើយប្រឹងយោងខ្លួនឡើង ដោយមានជំនួយរបស់នាវិកម្នាក់ផង ។ ខ្យល់រំភើយៗបានធ្វើអោយគេបានធូរស្រាលបន្តិច ។ គេឈរសំលឹងមើល *តូរ៉ាណាកា* ទាំងជើងនៅញ័រទទ្រើកនៅឡើយ ។

រំពេចនោះ នៅឯសើននៃវិមាន មានសញ្ញាអាសន្នបានលាន់ឡើង ហើយសំលេងខ្ទររបស់វាបានរត់មកដល់ត្រចៀករបស់ពួកគេទាំងអស់ដែលនៅឯមាត់ឆ្នេរនេះ ។ ភ្លើងកាំជ្រួចបាញ់ឡើងព្រាតៗ ទៅលើមេឃ ។ កាំជ្រួចសញ្ញា ។

ព្រះអើយ ពួកវាពិតជាបានដំណឹងស្តីពីការគេចខ្លួនរបស់ *តូរ៉ាណាកា* ហើយ ។

នៅក្នុងភាពស្ងប់ស្ងាត់ *ប្លាក់ថន* ឃើញ *តូរ៉ាណាកា* ងាកមើលទៅក្រោយ និងទៅលើមេឃ ។ កាំជ្រួចបានបំភ្លឺអស់ផ្ទៃមេឃដែលនៅពីលើទីក្រុង ។ ដោយនៅតែរក្សាភាព នឹងនរ និងដោយឥតរហន់អ្វីទាំងអស់ *តូរ៉ាណាកា* ត្រលប់ខ្លួន ហើយឡើងទៅលើទូកធំ ។

នៅឯទិសខាងជើង សំលេងល្វើយៗរសាត់មកតាមជំនោរខ្យល់ ។ ប្រហែលជា *ប៊ុនតារ៉ូ* ហើយនឹងអ្នកឯទៀតបានមកដល់ហើយ ។ ភ្នែករបស់ *ប្លាក់ថន* ប្រឹងមើលទំលុះកាត់ស្បៃរាត្រីទៅទីឆ្ងាយ ប៉ុន្តែគេឥតឃើញអ្វីទាំងអស់ ។ នៅឯខាងត្បូងចន្លោះរវាងពួកអាវ



www.budinst.gov.kh www.elibraryofcambodia.org

ប្រផេះដែលវាយលុក និងពួកអាវខ្មៅដែលចាំទប់ទល់កាន់តែរួញតូចទៅៗ ។ គេប្រមាណចំនួនមនុស្សទាំងសងខាង ។ គឺពួកគេមានកំលាំងប្រហាក់ប្រហែលគ្នា ។ ប៉ុន្តែតើអាចនៅស្មើគ្នាបានប៉ុន្មានពេល ?

- សូមគោរព !

ទាំងអស់គ្នាលុតជង្គង់ និងលំអោនខ្លួនគោរពយ៉ាងទាបនៅពេលដែល *តូរ៉ាណាកា* ឡើងដល់ទូក ។ *តូរ៉ាណាកា* ធ្វើសញ្ញាទៅ *យ៉ាប៊ូ* ដែលដើរតាមពីក្រោយ ។ រំពេចនោះ *យ៉ាប៊ូ* ទទួលដឹកនាំបញ្ជាទាំងអស់នៅលើទូក ដោយចាប់ផ្តើមស្រែកអោយគេស្រាវពួរចេញដំណើរភ្លាម ។ *សាមូរ៉ៃ* ហាសិបនាក់ដែលនៅក្នុងក្បួនទ័ព ក៏ស្ទុះឡើងទៅលើទូក ហើយរៀបចំស្ថានភាពប្រយុទ្ធភ្លាម ។ ពួកគេទាំងហាសិបនាក់ដំលើងព្រួញបែរមុខទៅរកឆ្នេរទាំងអស់គ្នាហើយជាស្រេច ។

អ្នកណាម្នាក់អង្រួនដៃអាវរបស់ *ប្លាក់ថន* :

- *អាន់ជីន-សាន !*

- *ហៃ ?*

គេងាកទៅ ប្រទះឃើញមេបញ្ជាការទូកដែលកំពុងសំលឹងមករកគេ ។ បុរសនោះនិយាយពាក្យប៉ុន្មានឃ្លា ហើយចង្អុលទៅចង្កូតផង ។ *ប្លាក់ថន* យល់បានថា មេបញ្ជាការគិតថារូបគេជាអ្នកទទួលខុសត្រូវបញ្ជាទូកនេះ ទើបគេមកសុំអនុញ្ញាតស្រាវពួរចេញដំណើរ ។

គេក៏តបវិញ :

- *ហៃ* មេបញ្ជាការ *-សាន !* ស្រាវពួរចេញ ! *អ៊ីសូគី !*

ពិតហើយ អោយលឿនឡើង *-ប្លាក់ថន* គិតនៅក្នុងចិត្តទាំងងឿងឆ្ងល់ថា ហេតុអ្វីបានជានៅពេលនេះ គេនឹកឃើញពាក្យនេះបានល្អម្ល៉េះ ?

អាស្រ័យដោយជំនោរខ្យល់ និងការប៉ិនប្រសប់របស់អ្នកចែវ ទូកបានចាកចេញពីផែយ៉ាងរហ័ស ។ ក្នុងពេលនោះ *ប្លាក់ថន* ក្រលេកឃើញពួកអាវប្រផេះបានមកដល់កន្លែងត្រៀមរបស់អាវខ្មៅជាស្រេច ហើយឆាកប្រយុទ្ធក៏បានផ្ទុះឡើងភ្លាមដែរ ។ ជាមួយគ្នានោះដែរ នៅ



www.budinst.gov.kh www.elibraryofcambodia.org

ជិតក្រុមនាវានេសាទ *ភ្លាក់ផន* ឃើញបុរសបីនាក់ និងនារីម្នាក់កំពុងជាប់ដៃប្រយុទ្ធដោះខ្លួន នឹងពួកអាវប្រផេះប្រាំបូននាក់ *ភ្លាក់ផន* ស្គាល់ *ប៊ុនតារ៉ូ* និងនារីអ្នកបំរើឈ្មោះ *សូណូ* ភ្លាម ។

*ប៊ុនតារ៉ូ* បាននាំគ្នាដកថយតំរង់មកផៃ ។ ដាវរបស់គេជិតដាមទៅដោយឈាម ។ នៅលើអាវក្រោះរបស់គេត្រង់ទ្រូងនិងខ្នងមានព្រួញជាច្រើន នៅដោតជាប់នៅឡើយ ។ *សូណូ* ប្រយុទ្ធដោយប្រើលំពែង ប៉ុន្តែដំណើរនាងទ្រេតទ្រោតទំនងដូចជាអស់ខ្យល់ហើយ ។ បុរសអាវត្នោតម្នាក់ឈប់នៅពាំងផ្លូវយ៉ាងអង់អាចក្លាហាន ដើម្បីការពារក្រុមរបស់ខ្លួន ។ ពួកអាវប្រផេះឡោមវាយលុកទៅលើបុរសនេះភ្លាម ។ *ប៊ុនតារ៉ូ* កាន់តែបង្កើនល្បឿន ដោយមាន នារីអ្នកបំរើ និង *សាមូរ៉ៃ* អាវត្នោតចុងក្រោយម្នាក់ក្បែរគេផង ។ រួច *ប៊ុនតារ៉ូ* ក៏ងាកខ្លួនផាំងហើយហក់ទៅរកពួកអាវប្រផេះម្តងទៀត ប្រៀបបីដូចជាដំរីចុះប្រេង ។ ពួកអាវប្រផេះដែលនៅមុខគេដាំដូងត្នោលពីលើផៃកំពស់ប្រហែលជាបូនម៉ែតនេះ ។ បុរសម្នាក់ត្រូវបាក់ឆ្អឹងខ្នងនៅពេលដែលធ្លាក់ទៅលើថ្មដែលនៅពីក្រោមផៃ ឯបុរសទីពីរត្រូវដាវ *ប៊ុនតារ៉ូ* កាប់ដាច់ដៃស្តាំធ្លាក់ទាំងស្រែករោទ៍ដូចក្របីទៅក្រោម ។ ឃើញបែបនេះ ពួកអាវប្រផេះញ្ញោចជើងបន្តិច ដែលអាចអោយ *សូណូ* លើកមុខលំពែងតំរង់ទប់ការពារខ្លួនបាន ។ ប៉ុន្តែមនុស្សទាំងអស់គ្នានៅលើទូកសុទ្ធតែដឹងថា នេះគ្មានអ្វីក្រៅតែជាកាយវិការមួយតែប៉ុននោះ ។ បុរសអាវត្នោតចុងក្រោយបង្ហស់ស្ទុះបោលសំរុកទៅមុន *ប៊ុនតារ៉ូ* សំដៅទៅរកពួកសត្រូវរបស់ខ្លួន តែត្រូវពួកអាវប្រផេះកាប់ដួលមួយរំពេច រួចហើយពួកវាហក់លុកទាំងដុលទៅរក *ប៊ុនតារ៉ូ* និង *សូណូ* បន្តទៀត ។

ខ្នាន់ធ្នូនៅលើទូកព្រលែងព្រួញព្រោងព្រាតបន្តបន្ទាប់ ធ្វើអោយពួកអាវប្រផេះទាំងប៉ុន្មានត្រូវស្លាប់ រឺត្រូវរបួសទាំងអស់ លើកលែងតែបុរសអាវប្រផេះពីរនាក់ ដែលបន្តវាយលុកទៅទៀត ។ ផ្លែដាវមួយវាត់ប៉ះមួកដែករបស់ *ប៊ុនតារ៉ូ* ហើយផ្លាតទៅត្រូវស្មាអាវក្រោះរបស់គេលាន់លឺឆាំង ។ *ប៊ុនតារ៉ូ* វាត់ដៃពាសដែករបស់ខ្លួនត្រូវចំក្រោមចង្ការបស់បុរសនោះមួយទំហឹង បំបាក់កបុរសនោះលាន់ផស់ រួចស្ទុះទៅរកបុរសចុងក្រោយដែលនៅសល់ ។

បុរសទីពីរនេះក៏ត្រូវស្លាប់ផងដែរ ។

*សូណូ* នៅលុតជង្គង់ដដែល ។ ដើមទ្រូវនាងឡើងដង្ហក់ ។ *ប៊ុនតារ៉ូ* ឥតខាតពេល



www.budinst.gov.kh www.elibraryofcambodia.org

នឹងពិនិត្យថា តើពួកអាវប្រផេះទាំងអស់មានស្លាប់រឺរស់ឡើយ ។ គេគ្រាន់តែកាត់ផ្ដាច់ក្បាលពួកនេះទាំងអស់ ដោយវាត់តែមួយដាវៗតែប៉ុននោះ ហើយនៅពេលដែលសន្តិសុខនៅលើផែមានការធានាហើយ គេក៏បែរទៅរកសមុទ្រ ហើយធ្វើសញ្ញាទៅរក *តួរ៉ាណាកា* ទាំងហេវហត់ប៉ុន្តែពោរពេញដោយភាពរីករាយ ។ *តួរ៉ាណាកា* ធ្វើសញ្ញាតបវិញទាំងចិត្តរីករាយ ។

ទូកនៅប្រហែលម្ភៃម៉ែតពីផែ ហើយចន្លោះនេះចេះតែរីកធំឡើងៗ ។

ឃើញបែបនេះ *ប្លាក់ថន* ស្រែកផង ធ្វើសញ្ញាទាំងរចល់ផងទៅមេបញ្ជាការទូក :

- មេបញ្ជាការ-*សាន* ! ត្រលប់ទៅផែវិញ ! *អ៊ីសូគី* !

មេបញ្ជាការស្រែកចេញបញ្ជាគោរពតាម *ប្លាក់ថន* ភ្លាម ។ ច្រវាទាំងអស់ឈប់បង្អង់ រួចចាប់ផ្ដើមកាយទឹកថយក្រោយវិញ ។ ភ្លាមនោះ *យ៉ាប៊ូ* ស្ទុះឡើងលើកិងហើយនិយាយយ៉ាងញាប់រន្ធាន់ទៅរកមេបញ្ជាការ ។ ច្បាស់ណាស់ ទូកនេះមិនបានត្រូវអនុញ្ញាតអោយបកក្រោយឡើយ ។

- យី ព្រះអើយព្រះ ! វាសល់ពេលម៉ាត់នរដែរតើ !

*ប្លាក់ថន* ចង្អុលបង្ហាញពីវាលដែលគ្មានមនុស្សម្នាក់ ហើយនឹងទៅទំនប់រលកខាងត្បូងដែលពួកអាវត្នោតកំពុងធ្វើអោយពួកអាវប្រផេះថយក្រោយទៅហើយ ។

ប៉ុន្តែ *យ៉ាប៊ូ* គ្រវីក្បាល ។

អីលូវនេះ ទូកនៅប្រហែលហាសិបម៉ែតពីផែទៅហើយៗ នៅក្នុងចិត្តរបស់ *ប្លាក់ថន* គឺជាសំរែករើបំរាស់នៃសតិសម្បជញ្ញៈរបស់គេ ។ រួចចុះពួកអ្នែងវាប្រកាច់រំបល់យក៏អីណឹង ? ក្រែងវាជា *ប៊ុនតារ៉ូ* ជាប្ដីរបស់ *ម៉ារីកូ* អ្ហ៎ ?

គេស្រែកតទៅ *យ៉ាប៊ូ* :

- លោកឯងមិនអាចទុកអោយគេស្លាប់ទេ ! វាគឺជា *ប៊ុនតារ៉ូ* ! វាគឺជាគ្នាយើងណា !

រួចគេងាកទៅរកមេបញ្ជាការទូក :

- ត្រលប់ទៅក្រោយភ្លាម ! *អ៊ីសូគី* !

ប៉ុន្តែលើកនេះ មេបញ្ជាការគ្រវីក្បាលទាំងអស់សង្ឃឹម ព្រមទាំងនៅតែរក្សាក្បាល



www.budinst.gov.kh www.elibraryofcambodia.org

ទូកអោយនៅតែទៅមុខដដែល ។ អ្នកកាន់ដងចែវនៅតែបន្តចែវទៅតាមសង្វាក់ស្គរដដែល ។

*ភ្លាក់ផន* ស្ទុះទៅរក *តូរ៉ាណាកា* ដែលកំពុងបែរខ្នងមករកគេ ។ លោកកំពុងសំលឹងមើលឆ្នេរនិងផៃយ៉ាងពិនិត្យពិច័យ ។ អង្គរក្សបួននាក់ស្ទុះចេញមកពាំងផ្លូវ *ភ្លាក់ផន* ដោយយារដាវយ៉ាងខ្ពស់ហើយជាស្រេច ។

*ភ្លាក់ផន* ដង្ហោយហៅឡើង :

- *តូរ៉ាណាកា-សាម៉ា ! ដូស្វ !* សូមលោកចេញបញ្ជាអោយទូកថយក្រោយវិញផងទាន ! ថយទៅកន្លែងនោះវិញ ! *ដូស្វ* ! សូមថយក្រោយទៅទាន !

- *អ៊ីយេ អាន់ជីន-សាន !*

*តូរ៉ាណាកា* លើកដៃចង្អុលទៅកាំជ្រួចដែលផ្ទុះព្រោងព្រាតពីវិមាន រួចចង្អុលទៅទំនប់រលក រួចបែរខ្នងទៅវិញ ជាសញ្ញាប្រាប់ថា លោកឥតកែប្រែបញ្ជារបស់លោកឡើយ ។

- រួចវាយ៉ាងម៉េច បានជាពូកកំសាក....

*ភ្លាក់ផន* បញ្ឈប់សំដីកណ្តាលទី រួចរត់ទៅតែមទូកចំកោងខ្នងស្រែកផង ធ្វើសញ្ញាផងទៅអ្នកទាំងពីរដែលនៅលើផៃ :

- **ហែលមក !**

*ប៊ុនតារ៉ូ* យល់បានភ្លាម ។ គេគ្រាប់នារី *ស្វាល្ហូ* ឡើង ហើយនិយាយបណ្តើររុញនាងបណ្តើរទៅកាន់ចុងផៃ ប៉ុន្តែ *ស្វាល្ហូ* ស្រែកប្រកែក ហើយដួលត្រឹបនៅពីមុខ *ប៊ុនតារ៉ូ* ។ ច្បាស់ណាស់ *ស្វាល្ហូ* ពិតជាហែលមិនរួចទេ ។

ភ្នែករបស់ *ភ្លាក់ផន* វាសចុះវាសឡើងទាំងអស់សង្ឃឹម ដើម្បីសំលឹងមើលអ្វីៗដែលមាននៅលើទូក ។ គ្មានពេលទំលាក់កូនទូកទេ ។ ចន្លោះរវាងទូកនឹងផៃនៅឆ្ងាយហួស ដើម្បីអាចបោះខ្សែទៅបាន ។ ខ្លួនគេទៀតសោតក៏គ្មានកំលាំងគ្រប់គ្រាន់ ដើម្បីហែលទៅហើយត្រលប់មកវិញដែរ ។ ពោងក៏គ្មានទៀត ។ នៅទីបញ្ចប់គេរត់ទៅរកអ្នកចែវដែលនៅជិតខ្លួនគេបំផុត ហើយចាប់បញ្ឈប់ដងចែវភ្លាម ។ ដងចែវទាំងអស់ដែលនៅចំហៀងខាងផៃនោះ ក៏បោកគ្នាឡើងច្របូកច្របល់អស់ភ្លាម ។ ទូកចាប់ផ្តើមឃ្លោង អ្នកវាយស្គរអោយសង្វាក់ចែវក៏ឈប់



www.budinst.gov.kh www.elibraryofcambodia.org

តាំង ហើយ *ភ្លាក់ថន* ក៏ចាប់ផ្តើមធ្វើសញ្ញាប្រាប់អ្នកចែវពីគោលបំណងរបស់គេភ្លាម ។

*សាមូរ៉ៃ* ពីរនាក់រត់មកប្រុងអូស *ភ្លាក់ថន* ចេញ ប៉ុន្តែ *តូរ៉ាណាកា* ស្រែកបញ្ជាអោយអ្នកទាំងពីរនោះដកខ្លួនថយចេញទៅវិញទៅ ។ ដោយមានជំនួយរបស់អ្នកជើងចែវបួននាក់ទៀត *ភ្លាក់ថន* ត្រវែងដងចែវដ៏ធំនោះរំលងទូក ប្រៀបបីដូចជាគេចោលស្នសំពៅទៅផៃ ។ ដងចែវហោះរំលងទឹកមួយសន្ទុះទើបប៉ះទឹក រួចអាស្រ័យដោយកំលាំងចំនោលនេះ ក៏រត់លឿនស្ទើរទៅផៃ ។

ក្នុងពេលជាមួយគ្នា សំរែកជ័យឃោសបានលាន់ឡើងពីទំនប់រលក ។ កងជំនួយរបស់ពួកអាវប្រផេះដែលមកពីទីក្រុង កំពុងលើកគ្នាសំដៅមកដូចទឹកបាក់ទំនប់ ហើយថ្វីបើពួក *រ៉ូនីន-សាមូរ៉ៃ* នៅតែអាចទប់ពួកអាវប្រផេះដែលមកពីសំពៅប៉ៃកទុយកាល់បានក្តី ក៏វាគ្រាន់តែជាបញ្ហាពេលវេលាតែប៉ុននោះ នៅមុនដែលជញ្ជាំងការពារនេះបាក់ ។

*ភ្លាក់ថន* ស្រែកតំរង់ទៅផៃ :

- លោតមក ! **អ៊ុសូគី គីគីគី !**

*ប៊ុនតារ៉ូ* លើក *សូណូ* ម្តងទៀត ហើយចង្អុលច្រវា ហើយនឹងទូកដល់នាង ។ *សូណូ* លំអោនខ្លួនគោរពយ៉ាងទន់ល្មើយ ។ *ប៊ុនតារ៉ូ* ធ្វើសញ្ញាអោយនាងចេញដំណើរ ហើយងាកជ្រែងជើងយ៉ាងមាំរបស់ខ្លួន ដើម្បីបង្វិលស្មារតីលើការប្រយុទ្ធវិញម្តង ។

*សូណូ* ស្រែកហៅទូក ។ សំលេងនារីម្នាក់ឆ្លើយតបទៅនាងវិញ ។ *សូណូ* លោតប្លូងទៅក្នុងទឹកសមុទ្រ រួចហែលទៅតោងច្រវាភ្លាម ។ ច្រវាធំល្មមទ្រទំងន់របស់នាងរួច ។ ជើងទាំងពីររបស់ *សូណូ* ប្រឹងទធាក់ទឹកហែលតំរង់មកទូក ។ រលកតូចមួយបានបោករុញច្រានទាងអោយកាន់តែខិតទៅជិតទូក ប៉ុន្តែការភ័យខ្លាចធ្វើអោយនាងរបូតដៃ ហាក់ដូចជាច្រានច្រវាចេញពីខ្លួននាងទេវិញ ។ នាងប្រវេប្រវាក្នុងទឹកមួយភ្លែតក៏លិចស្រិមបាត់ទៅ ។ ហើយនាងក៏ឥតផុសមកវិញសោះឡើយ ។

អីលូវនេះ *ប៊ុនតារ៉ូ* នៅតែម្នាក់ឯងតត់នៅលើផៃ ហើយគេតាមសំលឹងមើលចលនាលិចអណ្តែតៗនៃការប្រយុទ្ធ។ កងជំនួយរបស់ពួកអាវប្រផេះ ដែលរួមមានទាំងកងអាជានេយ្យ



www.budinst.gov.kh www.elibraryofcambodia.org

ផង បានចុះមកពីទិសខាងត្បូងដើម្បីរួមកំលាំងជាមួយពួកខ្លួនដែលកំពុងវាយលុកនេះ ហើយ *ប៊ុនតារ៉ូ* ដឹងយ៉ាងច្បាស់ថា ទំនប់រលកច្បាស់ជាត្រូវរលកសមុទ្រមនុស្សនេះបោកលិចមិនខាន ។ គេសំលឹងពិនិត្យពិច័យទិសខាងជើង ខាងលិច និងខាងត្បូង ។ រួចគេងាកមើលទៅនាកប្រយុទ្ធវិញ រួចដើរតំរង់ទៅចុងផែ ។ ទូកធំនៅប្រហែលជាចិតសិបម៉ែតពីច្រាំង ពោលគឺស្ថិតក្នុងទីកន្លែងផុតគ្រោះថ្នាក់ ហើយនៅទ្រឹងចាំនៅទីនោះ ។ ទូកនេសាទទាំងប៉ុន្មានបានបើកគេចឆ្ងាយពីកន្លែងប្រយុទ្ធតាំងពីដំបូងដៃម្លេះ ហើយអីលូវនេះនៅសងខាងច្រកចូលផែ ចង្កៀងទូកនេសាទទាំងនេះប្រៀបបីដូចជាពន្លឺភ្លើកភ្នែកឆ្មានៅក្នុងកណ្តាលអន្ធការយ៉ាងដូច្នោះដែរ ។

នៅពេលទៅដល់ចុងផែហើយ *ប៊ុនតារ៉ូ* ដកម្ជុលដែក ធ្នូ បំពង់ព្រួញ ហើយនិងអាវក្រោះរបស់ខ្លួនចេញ ហើយដាក់វានៅក្បែរស្រោមដាវ ។ ដាវផ្តាច់ជីវិត និងកាំបិតខ្លីត្រូវដាក់ចេញដាច់ដោយឡែក ។ រួចហើយគេប្រមូលយកអីវ៉ាន់ដែលគេបានដោះចេញអំបាញ់មិញនេះ ទៅបោះចោលក្នុងសមុទ្រដោយទុកខ្លួនគេនៅទទេ ។ គេសំលឹងថ្នាក់ថ្នមដាវវែងរបស់គេរួចហើយ ទើបគ្រវែងវាយ៉ាងអស់ទំហឹងទៅក្នុងទឹកជ្រៅ ។ ដាវជ្រែកទឹកលឺសូរភ្លុង ហើយលិចបាត់ភ្លាមមួយរំពេច ។

*ប៊ុនតារ៉ូ* ក៏លំអោនខ្លួនយ៉ាងគោរពតំរង់ទៅរកទូកធំ តំរង់ទៅរក *តូរ៉ាណាកា* ដែលបានឡើងទៅបង្ហាញខ្លួននៅពីលើកិងទូក ។ លោកលំអោនខ្លួនគោរពតបវិញ ។

*ប៊ុនតារ៉ូ* ក៏លុតជង្គង់ ហើយដាក់កាំបិតខ្លីយ៉ាងត្រឹមត្រូវពីលើថ្មនៅខាងមុខខ្លួន ។ ពន្លឺព្រះច័ន្ទដេញព្រិច១លើផ្លែកាំបិត ហើយគេនៅយ៉ាងស្ងៀមស្ងាត់ដូចកំពុងសមាធិដោយនៅតែបែរមុខតំរង់រកទូកធំដដែល ។

- ចុះវាធ្វើប្រកាច់យក៏អីហ្នឹង ?

*ប្លាក់ថន* និយាយខ្សឹប១ ។ សំពៅហាក់ដូចជានៅក្នុងស្ថានភាពស្ងប់ស្ងាត់មួយយ៉ាងចំលែកនៅពេលដែលគ្មានស្នូរស្គរបញ្ជាសង្វាក់ជងចែវយ៉ាងនេះ ។ គេបន្តសួរទៀត :

- ម៉េចក៏មិនលោតហែលទឹកមក ?

- គាត់រៀបចំធ្វើ *សិបពូគូ* ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ត្រូវនារីក្មេងម្នាក់គ្រាហ៍ឈរជិតក្បែរ *ប្លាក់ថន* ។

- យី ! *ម៉ារីកូ* ទេ ! តើនាងបានស្រួលបួលទេណឹង ?

- ចាស !

នាងឆ្លើយតបដោយឥតមានអារម្មណ៍នៅនឹងខ្លួនឡើយ ។ មុខនាងឡើងស្លក់ ប៉ុន្តែនៅតែបង្ហាញអោយឃើញសំរស់ដ៏ស្អាតរបស់នាងដដែល ។

*ប្លាក់ថន* ឃើញស្បៃរុំយ៉ាងតក់ក្រហល់មួយនៅស្មាខាងឆ្វេងនាង ដែលលេចចេញតាម *គីម៉ូណូ* ត្រង់កន្លែងដែលដាវវាត់ត្រូវនោះ ។ ដៃរបស់នាងត្រូវទ្រដោយក្រនាត់មួយផ្ទាំងដែលហែកពី *គីម៉ូណូ* ។ ឈាមនៅងាមជោកស្បៃរុំ ហើយស្រក់ចុះតាមបណ្តោយដៃនាងនៅឡើយ ។

- ខ្ញុំសប្បាយចិត្តណាស់ដែល......

រួចទើបសំដីដែល *ម៉ារីកូ* ទើបនិយាយប្រាប់មុននេះបន្តិច ជ្រាបចូលទៅក្នុងខួរក្បាលរបស់គេ :

- ថាម៉េច ? ធ្វើ *សិបពួគួ* ? គាត់ប្រុងសំលាប់ខ្លួនណឹង ? ហេតុអី ? គាត់មានពេលម៉ាគំនរដើម្បីឡើងទូក ! បើគាត់មិនចេះហែលទេ មានច្រវាសំរាប់គាត់តោងទេតើ ! នោះច្រវានៅក្បែរនោះ អ្នកស្រីឃើញទេ ? ឃើញរឺអត់ ?

- ចាសឃើញ ប៉ុន្តែប្តីខ្ញុំចេះហែលទឹកដែរតើ *អាន់ជីន-សាន* ។ មេទ័ពទាំងអស់របស់លោកម្ចាស់ *តូរ៉ាណាកា* ត្រូវតែចេះ ត្រូវតែរៀនហែលទឹក នេះគឺបញ្ជារបស់លោក ។ ប៉ុន្តែប្តីខ្ញុំបានសំរេចថាមិនហែលទឹកទេ ។

- ព្រះអើយព្រះ ចុះវាហេតុអីទៅ ?

នៅឯដីគោកសំលេងប្រយុទ្ធកាន់តែលាន់ឡើង លាយឡំនឹងស្នូរមូស្គេខ្លះផង ។ រនាំងការពារត្រូវបុកធ្លាយមួយរយ: ប៉ុន្តែពួក *រ៉ូនីន-សាមូរ៉ៃ* បានវាយបកទៅវិញដោយការប្រយុទ្ធខ្លួនទល់នឹងខ្លួនយ៉ាងសាហាវ បង្ខំអោយពួកអាវប្រផេះត្រូវដកថយទៅក្រោយវិញ ។

- ប្រាប់គាត់អោយហែលទឹកមកព្រះអើយ !

- គាត់ច្បាស់ជាមិនព្រមហែលមកទេ *អាន់ជីន-សាន* ។ គាត់រៀបចំការស្លាប់របស់



www.budinst.gov.kh www.elibraryofcambodia.org

គាត់រួចហើយ ។

- រួចបើចង់ស្លាប់ដដែលជាដដែល ម៉េចក៏មិនទៅខាងនោះវិញ ! -*ប្លាក់ថន* ចង្អុលទៅកន្លែងប្រយុទ្ធ - រួចម៉េចក៏គាត់មិនទៅជួយកូនចៅខ្លួនឯងទៅ ? បើចង់ស្លាប់ម៉េចក៏មិនស្លាប់ក្នុងការប្រយុទ្ធ អោយសមជា កូនប្រុសដើមទ្រូងប្រាំហត្ថទៅ ?

*ម៉ារីកូ* ឥតដកភ្នែកពីផៃឡើយ ។ ខ្លួននាងនៅតែផ្ចង់លើយុវនារីនោះនៅឡើយ :

- ពីព្រោះសត្រូវអាចចាប់គាត់បាន ហើយបើសិនជាគាត់ហែលទឹក ក៏ពួកវាអាចចាប់គាត់បានដែរ ហើយពេលនោះពួកសត្រូវអាចយកគាត់បណ្តើរអាក្រោសមុខប្រជាជនសាមញ្ញ អាចធ្វើអោយគាត់ទទួលភាពអាម៉ាស់ និងអាចធ្វើអំពើឃោរឃៅផ្សេងទៀតគ្រប់បែបយ៉ាងដល់រូបគាត់ ។ *សាមូរ៉ៃ* ដែលអោយគេចាប់បាន មិនមែនជា *សាមូរ៉ៃ* ទៀតទេ ។

ការបាត់បង់កិត្តិយសធ្ងន់ធ្ងរបំផុត គឺត្រូវខ្មាំងចាប់បាននេះឯង ។ ហេតុនេះហើយ ទើបប្តីខ្ញុំកំពុងតែធ្វើអ្វីដែលកូនប្រុសដើមទ្រូងប្រាំហត្ថ អ្វីដែល *សាមូរ៉ៃ* ត្រូវធ្វើ ។ *សាមូរ៉ៃ* ស្លាប់ក្នុងភាពថ្លៃថ្នូរ ។ តើជីវិតជាអ្វីទៅចំពោះ *សាមូរ៉ៃ* ? គ្មានអ្វីទាំងអស់ ។ ជីវិតគឺជាទុក្ខសោក មែនទេ ? នេះគឺជាសិទ្ធិ និង **ករណីយកិច្ច** របស់គាត់ដែលត្រូវស្លាប់ក្នុងកិត្តិយស និងនៅចំពោះមុខសាក្សី ។

*ប្លាក់ថន* រអ៊ូរទាំ :

- ចំជាការខ្ជះខ្ជាយដ៏ពន្លឺមែន !

- ជាមួយពួកយើង លោកត្រូវរៀនអត់ធ្មត់ចាស ។

- អត់ធ្មត់ដើម្បីអី ? ដើម្បីកុហកថែមទៀតមែនទេ ? ហេតុអីបានជាអ្នកស្រីមិនទុកចិត្តខ្ញុំ ? តើខ្ញុំមិនសក្តិសមនឹងជឿទុកចិត្តបាន រឺយ៉ាងម៉េច ? អ្នកស្រីបានកុហកខ្ញុំមែនរឺអត់ ? អ្នកស្រីធ្វើជាសន្ទប់ ហើយនេះគឺជាសញ្ញាមែនទេ ? មែនរឺអត់ ? ខ្ញុំបានសួរអ្នកស្រី តែអ្នកស្រីបានកុហកខ្ញុំទៅវិញ ។

- ខ្ញុំទទួលបញ្ហា....នេះជាបញ្ហាដើម្បីការពាររូបលោក ។ ចំពោះរូបខ្ញុំ សូមលោកជឿចុះ ខ្ញុំទុកចិត្តលោកទាំងស្រុង ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្នកស្រីកុហក !

*ប្លាក់ថន* ពោលពាក្យនេះជាថ្មី ទទឹមនឹងដឹងថា ខ្លួនគេដូចជាជ្រុលហួសបន្តិចហើយ ។ ប៉ុន្តែគេឥតខ្វល់អ្វីទាំងអស់ ដោយគេស្អប់ខ្ពើមនឹងការមើលស្រាលជីវិតដោយគេត្រូវការសំរាក និងភាពសុខសាន្ត ដោយគេត្រូវការម្ហូបរបស់គេ ស្រារបស់គេ សំពៅ ហើយនឹងអ្វីៗដែលជារបស់គេ ។

- ពួកអ្នកឯងសុទ្ធតែជាសត្វធាតុតែទាំងអស់ហ្នឹង !

*ប្លាក់ថន* និយាយជាភាសាអង់គ្លេស ដោយដឹងច្បាស់ថា សំដីដែលគេនិយាយនេះគឺមិនពិតទាល់តែសោះដែរ ។ រួចគេងាកខ្លួនដើរចេញទៅ ។

- តើគាត់និយាយរឿងអីហ្នឹង *ម៉ារីកូ-សាន* ?

យុវនារីសួរទាំងអាការៈខ្ពើមល្អើម ។ នាងមានឆ្អឹងធំៗ ហើយខ្ពស់ជាង *ម៉ារីកូ* មួយផុតក្បាល ។ នាងមានមុខផ្កាមខ្លា ហើយមានធ្មេញល្អិត ។ នាងឈ្មោះ *អ៊ូសាគី កូជីកូ* ។ នាងជាក្មួយរបស់ *ម៉ារីកូ* ហើយឆ្នាំនេះនាងមានអាយុដប់ប្រាំបួនឆ្នាំហើយ ។

*ម៉ារីកូ* និយាយប្រាប់ក្មួយស្រីពីអ្វីដែលបានជជែកគ្នាអំបាញ់មិញ។

- ចំជាមនុស្សគួរអោយល្អើមពេក ! រឹតពាក់ច្រងេងច្រងាងគួរអោយស្អប់ថែមទៀត ។ ជ្រិញមែនទែន មែនទេ ? ចុះហេតុអីបានជាមីងទ្រាំនៅជិតមនុស្សយ៉ាងនេះបាន ?

- ពីព្រោះគាត់បានជួយការពារកិត្តិយសរបស់លោកម្ចាស់ ។ បើគ្មានភាពអង់អាចក្លាហានរបស់គាត់ទេ លោកម្ចាស់ប្រាកដជាត្រូវគេចាប់បាន ពួកយើងទាំងអស់ ពិតជាត្រូវគេចាប់បានជាមិនខាន ។

នារីទាំងពីរគ្រវីក្បាលញញែងខ្លួន ។

- សូមព្រះជាម្ចាស់ជួយការពារពួកយើងខ្ញុំ សូមកុំអោយជួបនឹងភាពអាម៉ាស់បែបនេះអោយសោះ ។

*កូជីកូ* សំលឹងមើលទៅ *ប្លាក់ថន* ដែលកំពុងទ្រោបលើគែមទូកគយគន់ឆ្នេរសមុទ្រ ។ មួយសន្ទុះមកទើបនាងពោលបន្ត :



www.budinst.gov.kh www.elibraryofcambodia.org

- គាត់នេះរាងមើលដូចស្មារោមលឿងអីចឹង ។ រាងនេះគ្រាន់បន្ទាចក្មេងៗ បានដែរ មែនទេមីង ?

រួចនាងបែរមើលទៅ *ប៊ុនគារ៉ូ* មួយសន្ទុះ :

- ខ្ញុំកោតលោកពូហើយ !

*ម៉ារីកូ* ឆ្លើយតបយ៉ាងក្រៀមក្រំ !

- ពិតហើយ តែមីងចង់អោយពូឯងមានអ្នកណាម្នាក់ជាជំនួយផង ។

តាមប្រពៃណី នៅក្នុងពិធី *សិបពូគូ សាមូរ៉ៃ* ម្នាក់តែងនៅចាំជួយជានិច្ច ដោយគេឈរនៅពីក្រោយអ្នកដែលលុតជង្គង់ ដើម្បីកាត់ផ្ដាត់ក្បាលតែមួយដាវ ដើម្បីចៀសវាងកុំអោយភាពត្រដរខ្យល់ក្លាយជាការទ្រាំទ្រលែងបាន ដែលនឹងនាំភាពអាម៉ាស់ដល់សាមីខ្លួននៅនាទីចុងក្រោយនៃជីវិតរបស់ខ្លួន ។ គ្មានអ្នកជំនួយ មានមនុស្សតិចណាស់ដែលមានស្លាប់ទៅហើយ ដោយគ្មានអាម៉ាស់នោះ ។

*កូជីកូ* តប :

- នេះគឺ *កាម៉ា* ណាមីង ។

-អីចឹងហើយទើបមីងអាណិតពូឯងណា ។ តាំងពីដើមមកគាត់ខ្លាចតែរឿងមួយគត់ គឺខ្លាចគ្មានអ្នកចាំជំនួយនោះឯង ។

- គិតទៅគឺយើងជានារីទេ ដែលមានសំណាងជាងប្រុសៗនោះ មែនទេមីង ?

*សាមូរ៉ៃ* នារីធ្វើ *សិបពូគូ* ដោយប្រើកាំបិតបុះទំលុះបំពង់ក ហេតុនេះពួកគេមិនចាំបាច់ត្រូវការអ្នកជំនួយឡើយ ។

- ពិតហើយ ។

សំរែកឈឺចាប់ និងសំរែកប្រយុទ្ធដែលរសាត់មកល្វើយៗ តាមជំនោរខ្យល់នោះ បានបង្វែរអារម្មណ៍របស់នារីទាំងពីរមកលើបច្ចុប្បន្នភាពនេះវិញ ។ ខ្សែការពារត្រង់ទំនប់រលកត្រូវបុករបើកម្ដងទៀត ។ កង *រ៉ូនីន-សាមូរ៉ៃ* របស់ *តូរ៉ាណាកា* ចំនួនសាមសិបនាក់ ដោយមានរួមទាំងពួករាជានេយ្យប៉ុន្មាននាក់ផង នាំគ្នាចុះមកពីខាងជើង ដើម្បីបន្ថែមកំលាំង ។ ការ



www.budinst.gov.kh www.elibraryofcambodia.org

ដែលនៅតែតំរង់យ៉ាងនឹងមករកពោះទទេរបស់គេ ។ គេសែនស្រេកឃ្លានចំពោះមរណភាព ដែលនឹងអាចរំដោះរូបគេពីភាពអាម៉ាស់សព្វបែបយ៉ាងបាន ។ ពីភាពអាម៉ាស់នៃការលុតជង្គង់របស់ឪពុកគេចំពោះបញ្ជារបស់ *តូរ៉ាណាកា* ដោយបំភ្លេចពាក្យសច្ចាស្មោះត្រង់ចំពោះ *យែនមុ៊ន* ពីភាពអាម៉ាស់ចំពោះការកាប់សំលាប់មនុស្សជាច្រើនដែលបានបំរើយ៉ាងថ្លៃថ្នូរបុព្វហេតុរបស់ *តៃកូ* តទប់នឹងអ្នកជ្រែកអំណាច គឺ *តូរ៉ាណាកា* ពីភាពអាម៉ាស់ដោយ *ម៉ារីកូ* ជាកូនស្រីរបស់ *អាកេជី ជីនសៃ* មេឃាតកដ៏សាហាវឃោរឃៅ ពីភាពអាម៉ាស់ដែលឈ្មោះរបស់គេហើយនិងកូនប្រុសតែមួយគត់របស់គេត្រូវប្រលាក់ប្រលូសជារៀងរហូត ព្រោះតែសម្ព័ន្ធមេត្រីនេះ ។

ព្រលឹង សាច់ឈាមគេទាំងមូលដង្ហោយហៅភាពសូន្យសុង ។ នេះជាការបំភ្លេចអ្វីៗទាំងអស់មួយដែលនៅជិតដៃ ងាយស្រួល និងថ្លៃថ្នូរទៀតផង ។ ជីវិតនៅ ជាតិក្រោយពិតជានឹងល្អប្រសើរជាងនេះមិនខាន ព្រោះវាមិនអាក្រក់ជាងនេះទៀតទេ ។.

ទោះជាមានអារម្មណ៍យ៉ាងនេះក្តី ក៏ *ប៊ុនតារ៉ូ* ដាក់កាំបិតចុះ និងទទួលធ្វើតាមបញ្ជាហើយទាញខ្លួនគេអោយវិលមករកជ្រោះជីវិតវិញ ។ លោកម្ចាស់របស់គេបានបញ្ជាអោយទទួលការឈឺចាប់យ៉ាងកំពូល និងបានលុបបំបាត់ចោលការប៉ុនប៉ងឈានទៅរកឋានសុខរបស់គេ ។ តើចំពោះ *សាមូរ៉ៃ* មានអ្វីផ្សេងទៀតក្រៅពីគោរពតាមនោះ ?

*ប៊ុនតារ៉ូ* ស្ទុះក្រោកហក់ឡើងផែលសេះយ៉ាងរហ័ស ជើងគេទាំងពីរគោះឆ្អឹងជំនីសេះបំផាយគេចខ្លួនជាមួយបុរសអាវត្នោតម្នាក់ទៀតមួយរំពេច ។ ពួកអាជានេយ្យ *រ៉ូនីន-សាមូរ៉ៃ* ឯទៀតក៏បត់ក្បាលសេះបំផាយតាមក្រោយ ដើម្បីការពារផ្នែកក្រោយ និងទប់ទល់ពួកអាវប្រផេះដែលស្រូតមកដល់មុនគេនោះ ។ រួចពួកគេបំបោលសេះកប់បាត់ក្នុងស្បៃរាត្រី ដោយមានពួកអាជានេយ្យអាវប្រផេះមួយចំនួនដេញតាមក្រោយផង ។

សំនើចក្អាកក្អាយបានលាន់លឺឡើងនៅលើទូក ។

*តូរ៉ាណាកា* គប់តែមទូកដោយក្តីរីករាយ ។ *យ៉ាប៊ូ* និងពួក *សាមូរ៉ៃ* គ្រហឹមខ្វរ ។ សូម្បីតែ *ម៉ារីកូ* ក៏សើចរីករាយដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថុន* ស្រែកគំហកទាំងកំហឹង :

- មនុស្សម្នាក់គេចខ្លួនរួច រួចចុះអ្នកឯទៀតដែលស្លាប់អស់រលីងនោះ តើវាយ៉ាងម៉េចទៅវិញ ?

មើលទៅឆ្នេរមើល ! ខ្មោចយ៉ាងតិចបីបួនរយនាក់ដែលនៅគរនោះ ! មើលខ្មោចទាំងនោះមើល !

ប៉ុន្តែសំរែករបស់គេត្រូវសំនើចក្អាកក្អាយទាំងនោះលុបបំបាត់អស់ ។

រួចសំរែកប្រកាសអាសន្នរបស់អ្នកមើលផ្លូវនៅឯក្បាលទូកបានលាន់ឡើង ។ សំនើចក្អាកក្អាយទាំងអស់រលត់ឈឹងមួយរំពេច ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៦

*តូរ៉ាណាកា* សួរយ៉ាងនឹងនរ :

- តើយើងអាចបុកចេញរួចទេលោកមេបញ្ជាការ ?

លោកសំលឹងមើលទៅវ៉ាំងទូកទេសាទដែលនៅកកកុញ ចំងាយហាសិបម៉ែតពីទូកលោក ហើយនឹងចន្លោះដែលមានរវាំងទូកនីមួយៗ ។

- ទៅមិនកើតទេទាន ។

- យើងគ្មានផ្លូវណារើសទៀតទេ ( *យ៉ាប៊ូ* និយាយ ) យើងគ្មានធ្វើអ្វីបានផ្សេងទៀតក្រៅពីបុកចេញនោះទេ ។

*យ៉ាប៊ូ* ចោលភ្នែកសំលឹងមើលទៅពួកអាវប្រផេះដែលនៅកកកុញលើឆ្នេរ និងលើផែ។ សំលេងស្រែកជេរបន្ទុះបង្អាប់អណ្តែតមកល្វើយៗតាមខ្យល់ ។

*តូរ៉ាណាកា* និង *យ៉ាប៊ូ* កំពុងតែឈរនៅពីលើក្បាលទូក ។ ស្គរបានរលត់បាត់សំលេងទៅហើយៗទូកនៅបណ្តែតផ្លេងផ្លុងតិចៗតាមកំលាំងរលកនៃសមុទ្រស្ងប់ស្ងាត់ ។ អ្នកទាំងអស់គ្នានៅលើទូកកំពុងតែរង់ចាំការសំរេចចិត្តមួយ។ ពួកគេសុទ្ធតែដឹងថាពួកគេកំពុងតែជាប់ជុចហើយ។ ចុះទូកឡើងគោកគឺមហន្តរាយ នៅស្ងៀមរង់ចាំគឺ មហន្តរាយ ។ សំនាញ់នឹងចេះតែខិតចូលជិតបន្តិចម្តងៗ ហើយទីបំផុតពួកគេនឹងត្រូវក្របួចទាំងអស់ ។ បើសិនជាចាំបាច់ *អ៊ីស៊ីដូ* អាចនៅរង់ចាំរាប់ថ្ងៃក៏បានដែរ ។

*យ៉ាប៊ូ* សែនឆេះដុំ ។ បើសិនជាពេលឡើងទូកហើយ យើងបុកទូកចេញពីច្រកផែតែម្តង ដោយឥតចំនាយពេលឥតប្រយោជន៍ដើម្បី *ប៊ុនតារ៉ូ* ទេនោះ យើងពិតជាមានសុវត្ថិភាពគ្រប់គ្រាន់នៅឯលំហសមុទ្របាត់ទៅហើយនៅពេលនេះ - គេគិតនៅក្នុងចិត្ត - *តូរ៉ាណាកា* កំពុងតែឡប់ស្មារតីហើយ ។ *អ៊ីស៊ីដូ* ពិតជានឹងយល់ថាអញក្បត់គាត់ហើយ ។ គ្មានអ្វីដែលអញអាចកែកុនបានទេ លើកលែងតែរៃទំលាយចេញ ហើយបើរៃទំលាយចេញអញត្រូវប្រយុទ្ធជួយ *តូរ៉ាណាកា* ប្រឆាំង *អ៊ីស៊ីដូ* ទៅវិញ ។ គ្មានផ្លូវណាដើរទៀតទេ ។ លើកលែងតែកាត់ក្បាល *តូរ៉ាណាកា* ប្រគល់ជូន *អ៊ីស៊ីដូ* ។ បើធ្វើយ៉ាងនេះ អ្នែងនឹងទៅជាសមាជិកក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

អ្នែងនឹងបាន *ក្វាន់តូ* មិនខាននែមនទេ ? រួចក្នុងពេលវេលាប្រាំមួយខែហើយជាមួយនឹងពួកសាមូរ៉ៃ ដែលប្រើមូស្កេ ហេតុអ៊ីឡើងជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ មិនបាននោះ ? រឺក៏ហេតុអីមិនស៊ុំ អាធំ ? អញអាចកំចាត់ *អ៊ីស៊ីដូ* ហើយឡើងជាអគ្គមេបញ្ជាការរបស់ទាយាទ ជាអភិបាលវិមាន *អូសាកា* ជា មេអាល័ក្ស (* ) លើសម្បត្តិមហាសាល ដែលមាននៅក្នុងសើននៃវិមាន និងដែលមានអំនាចធំធេងនៅទូទាំងចក្រភព ក្នុងរយៈពេលដែល *យែនម៉ុន* មិនទាន់ពេញវ័យ រួចបន្ទាប់ពីនោះ ទឹង ជាអ្នកមានអំនាចទីពីរបន្ទាប់ពី *យែនម៉ុន* ដែរ ។ ហេតុអី មិនប្រថុយមើល ?

រឺមួយស៊ុំអាធំជាងគេក៏តែបាន ។ គឺឋានៈជាអគ្គមហាសេនា ជា *សូគុន*។ កំចាត់ *យែនម៉ុន* អ្នែងនឹងទៅជាអគ្គមហាសេនា ។

ទាំងអស់នេះអាចសំរេចបានអាស្រ័យដោយសារតែក្បាលមួយ និង ការប្រទានពរពីទេវតាតែប៉ុននោះ ។

ជង្គង់របស់ *យ៉ាប៊ូ* ឡើងញ័រ នៅពេលដែលមហិច្ឆតារបស់គេរីកធំឡើងៗនោះ ។ រឿងធ្វើគឺងាយសោះ - *យ៉ាប៊ូ* គិតនៅក្នុងចិត្ត - ប៉ុន្តែកាត់ក្បាលបានហើយគេចខ្លួនរួចទៀត គឺពិតជាគ្មានផ្លូវទេ ។ អាចថា មិនទាន់មានផ្លូវទេ ។

នៅទីបំផុត *តូរ៉ាណាកា* ក៏ចេញបញ្ជា :

- ត្រៀមរៀបចំប្រយុទ្ធភ្លាម !

នៅពេលដែល *យ៉ាប៊ូ* ចេញបញ្ជាបន្ត និង នៅពេលដែលពួក សាមូរ៉ៃ ចាប់ផ្តើមរៀបចំប្រយុទ្ធនោះ *តូរ៉ាណាកា* បានបង្វិលការយកចិត្តទុកដាក់របស់លោកទៅលើបុរសចុងស្រុកដែលនៅឯក្បាលទូកចាប់តាំងពីការប្រកាសសញ្ញាអាសន្ននោះម្ល៉េះ ហើយដែលអីលូវនេះកំពុងឈរផ្អែកលើដងក្តោងធំធ្វើព្រងើយ ។

អញបន់អោយតែមើលចិត្តវាធ្លុះទេ - *តូរ៉ាណាកា* រំពឹងគិត ។ ពេលខ្លះអង់អាចក្លាហាន ពេលខ្លះទន់ខ្សោយ ។ ពេលខ្លះសែនចាំបាច់ ពេលខ្លះឥតប្រយោជន៍ ។ ពេលខ្លះជាឃាតក ពេល

---

*(* ): អ្នកទទួលគ្រប់គ្រងរាជសម្បត្តិ ទ្រព្យផ្សេងៗ ( ក.អ.ប )*



www.budinst.gov.kh www.elibraryofcambodia.org

ខ្លះជាកំសាកញី ។ ពេលខ្លះស្លូតដូចកូនចៀម ពេលខ្លះសែនគ្រោះថ្នាក់ ។ វាជាប្រុសផង ជាស្រីផង ។ ជា *យ៉ាំង* ផង ជា *យីន* ផង (*) ។ វាជាភាពផ្ទុយហើយគ្មានអ្នកណាស្មានបានជាមុនសោះ ។

*តូរ៉ាណាកា* បានតាមពិនិត្យ *ភ្នាក់ផន* យ៉ាងយកចិត្តទុកដាក់តាំងពីពេលគេចខ្លួនពីវិមាននៅពេលមានការពួនស្ទាក់ និងក្រោយមកទៀត ។ លោកបានស្តាប់របាយការណ៍របស់ *ម៉ារីកូ* មេបញ្ជាការទូក និងអ្នកឯទៀត ពីការប្រយុទ្ធដែលកើតមានឡើងនៅលើទូក ។ លោកក៏បានឃើញផ្ទាល់ភ្នែកនូវកំហឹងដ៏អស្ចារ្យកាលពីប៉ុន្មានពេលមុននេះ ហើយនៅពេលដែល *ប៊ុនតារ៉ូ* ទទួលបញ្ជាអោយគេចខ្លួនចេញទៅនោះលោកបានលឺសំរែក និងទឹកមុខដ៏អាក្រក់របស់បុរសនេះ រួចនៅពេលដែលគួរមានសំនើចក្អាកក្អាយនោះ លោកបែរជាឃើញមានកំហឹងទៅវិញ ។

ហេតុអ្វីបានជាមិនសើចនៅពេលដែលសត្រូវដើរល្បិចចាញ់នោះ ? ហេតុអ្វីបានជាមិនសើចដើម្បីបំបាត់ភាពទុក្ខសោកពីក្នុងខ្លួននៅពេលដែល *កាម៉ា* បានបន្ទុចបង្អាក់មរណភាពយ៉ាងល្អស្រស់របស់សាមូរ៉ៃពិត១ម្នាក់ នៅពេលពេលដែល *កាម៉ា* បាននាំមកនូវមរណភាពដ៏ឥតប្រយោជន៍ដល់នារីដ៏ល្អស្អាតម្នាក់នោះ ? គឺមិនដោយសារសំនើចទេរី ដែលយើងអាចបន្ទុំខ្លួននឹងព្រះ ហើយអាចទ្រាំទ្រជំនះនូវទុក្ខវេទនាខ្មោចផ្សានៅលើផែនដីបាននោះ ? ដូចជាយប់នេះដែលយើងសំលឹងមើលបុរសដ៏អង់អាចទាំងនេះប្រឈមមុខនឹងវាសនារបស់ខ្លួននៅទីនេះ លើឆ្នេរនេះក្នុងយប់ដ៏ត្រកាលនេះតាមរយៈ *កាម៉ា* ដែលត្រូវបានចែងកាលពីរាប់ពាន់ជីវិតមុនមកម្ល៉េះនោះ ។

មិនគឺអាស្រ័យដោយសំនើចទេរីដែលយើងស្ថិតនៅជាមនុស្សនោះ ?

ហេតុអ្វីក៏តែកុងនេះមិនយល់ដឹងថាខ្លួនវាស្ថិតនៅក្រោមអំនាចនៃ *កាម៉ា* ដែរនោះផង? ដូចរូបអញ ដូចពួកយើងទាំងអស់គ្នារួមទាំងព្រះយេស៊ូអីនោះផង ព្រោះបើសិនជាពិតដូចដែលពួកយើងបានដឹងតាមអ្វីដែលពួកបព្វជិតចុងស្រុកនិយាយមែននោះ គឺពិតជា *កាម៉ា* នេះហើយដែលបានធ្វើអោយព្រះយេស៊ូនេះស្លាប់យ៉ាងអាម៉ាស់ដូចពួកចោរហារាយ ជាមួយពួកឧក្រិដ្ឋជនធម្មតានៅលើកំពូលភ្នំនោះ ។

---

*(*). យ៉ាំង និង យីន : សារធាតុឈ្មោល ញី ក្នុងទ្រឹស្តីតាវ ( ក.អ.ប. )*



www.budinst.gov.kh www.elibraryofcambodia.org

អ្វីៗជា *កាម៉ា* ទាំងអស់ ។

ពួកអស់នោះពិតជាព្រៃផ្សៃមែន ដែលយកមនុស្សទៅវាយដែកគោលភ្ជាប់នឹងក្តារ ហើយរង់ចាំរហូតដល់ពេលដាច់ខ្យល់យ៉ាងនេះ ។ ពួកនេះចំជាអាក្រក់ជាងពួកចិនដែលសប្បាយក្នុងការធ្វើទារុណកម្មទៅទៀត ។

*តូរ៉ាណាកា* និយាយឡើង :

- សួរវាមើល *យ៉ាប៉ូ-សាន* !

- បាទទាន ?

-សួរវាមើលថាតើត្រូវធ្វើយ៉ាងម៉េច? សួរតៃកុងណា។ ឈើងមិនមែនជាការប្រយុទ្ធលើសមុទ្រទេអ្វី ? ក្រែងលោកបានប្រាប់ខ្ញុំថា តៃកុងនេះស៊ីដាច់គេនៅលើសមុទ្រអ្វី ? ល្មចាំមើលតើលោកវាយតំលៃបានត្រឹមត្រូវទេ ? ទុកអោយវាបង្ហាញថ្វីដៃវាទៅមើលតើពិតជាយ៉ាងនោះមែនរឺអត់ ។

មាត់របស់ *យ៉ាប៉ូ* រួញតូច និងពោរពេញដោយភាពកំនាច ហើយ *តូរ៉ាណាកា* ទទួលបាននូវអារម្មណ៍ភ័យខ្លាចរបស់ *យ៉ាប៉ូ* ដែលរត់មកដល់ខ្លួនលោកផងដែរ ។ ប្រការនេះធ្វើអោយលោកសប្បាយចិត្តយ៉ាងខ្លាំង ។

*យ៉ាប៉ូ* តំហកឡើង :

- *ម៉ារីកូ-សាន* ! សួរតៃកុងមើល ថាតើធ្វើម៉េចចេញរួច គឺថាធើម៉េចទំលាយចេញតាមទូកទាំងអស់នោះបាន ?

*ម៉ារីកូ* ទទួលធ្វើតាមបញ្ជាភ្លាម ។ នាងដើរចេញពីគែមទូក ដោយមាន *ភូជីកូ* តាមជួយគ្រាហ៍នាងផង ។

- មិនបាច់ទេ *ភូជីកូ-សាន* ខ្ញុំបានធូរច្រើនហើយ ។ អរគុណនាងណាស់ ។

*ភូជីកូ* លែងដៃ តែនាងនៅតែតាមសំលឹងមើល *ប្លាក់ថន* ទាំងអាការៈខ្ពើមល្អើមដដែល ។

ចំលើយរបស់ *ប្លាក់ថន* ខ្លីហើយកំបុត ។



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* បក :

- គាត់និយាយថា " ប្រើកាណុង " *យ៉ាប៊ូ-សាន* ។

- ប្រាប់វាថាអោយរកអីអោយបានល្អជាងហ្នឹងសិនទៅ បើវាចង់អោយក្បាលវានៅជាប់នឹងខ្លួននោះ ។

*តូរ៉ាណាកា* លូកមាត់ចូល :

- យើងត្រូវចេះអត់ធ្មត់ជាមួយមនុស្សនេះ *យ៉ាប៊ូ-សាន* ។ *ម៉ារីកូ-សាន* សូមនាងបកប្រែយ៉ាងគួរសមថា " គួរអោយសោកស្តាយណាស់ពួកយើងគ្មានកាណុងទេ ។ តើមានមធ្យោបាយផ្សេងទៀត ដើម្បីវាយបំបែកចេញបានទេ ? ចេញទៅតាមដីគោកគឺពិតជាទៅមិនរួចទេ "។ សូមនាងបកចំលើយរបស់គេវិញអោយបានអស់ណាំ ។ អោយចំ និង អោយអស់ ។

*ម៉ារីកូ* ធ្វើតាមភ្លាម

- ខ្ញុំសូមអភ័យទោសលោកម្ចាស់ តែគាត់ឆ្លើយវិញថាគ្មានទេ ។ ចំលើយគឺ " គ្មានទេ " តែប៉ុនហ្នឹង ។ ដោយចំលើយមិនគួរសមអីទាំងអស់ ។

*តូរ៉ាណាកា* អេះខ្លួនរួចពោលតប :

- ល្អអញ្ចឹង ។ *អាន់ជីន-សាន* និយាយថាត្រូវប្រើកាណុង ហើយគាត់ជាអ្នកឯកទេស ។ បើអញ្ចឹងត្រូវប្រើកាណុងតាមគេប្រាប់ទៅ ។ មេបញ្ជាការទៅខាងនោះ !

ម្រាមដៃកិរិនរបស់ *តូរ៉ាណាកា* ចង្អុលយ៉ាងកំនាចទៅសំពៅពួក ប៉ក់ទុយកាល់ :

- ប្រាប់កូនទាហានទាំងអស់អោយប្រុងប្រៀបអោយហើយជាស្រេច *យ៉ាប៊ូ-សាន* ។ បើពួកចុងស្រុកខាងត្បូងមិនព្រមអោយយើងខ្ចីកាណុងពួកវាទេ ពេលនោះលោកត្រូវដណ្តើមយកអោយបាន លឺទេ ?

*យ៉ាប៊ូ* ឆ្លើយតបយ៉ាងស្រាល :

- ដោយរីករាយទាន ។

- តាមពិតលោកវាយតំលៃត្រូវមែន តែកុងនេះពិតជាស៊ីជាច់គេមែន ។

- ប៉ុន្តែលោកម្ចាស់ជាអ្នករកឃើញរបៀបដោះទាន ។



www.budinst.gov.kh www.elibraryofcambodia.org

- អោយតែមានចំលើយហើយ វាងាយរកឃើញរបៀបដោះទេ មិនអញ្ចឹង ? តើដោះវិមាន *អូសាកា* បែបណា ?

- គ្មានសោះ ។ នេះគឺ *វ៉ាកូ* អស្ចារ្យមែនតែម្តង ។

- ពិតហើយ ។ រួចចុះអំពើក្បត់ត្រូវដោះស្រាយបែបណាទៅវិញ ?

- ពិតជាការស្លាប់ដ៏ថោកទាបហើយលោកម្ចាស់ ។ ប៉ុន្តែខ្ញុំមិនយល់សោះថាហេតុអ្វីបានលោកមកសួរសំនួរនេះដល់ខ្ញុំអញ្ចឹង ?

- ខ្ញុំគ្រាន់តែសួរទៅទេ -*តូវ៉ាណាកា* សំលឹងមើលទៅ *ជួក់ថន* - ពិតណាស់មនុស្សនេះពិតជាមនុស្សឆ្លាតឆ្លៀល្អណាស់ ។ ខ្ញុំត្រូវការមនុស្សឆ្លាតឆ្លៀណាស់ ។ *ម៉ារីកូ-សាន* តើពួកចុងស្រុកយល់ព្រមប្រគល់កាណុងអោយមកខ្ញុំទេ ?

- ពិតជាអោយ ។ ហេតុអ្វីបានជាពួកគេមិនយល់ព្រមអោយនោះ ?

នៅក្នុងអារម្មណ៍របស់ខ្លួន *ម៉ារីកូ* មិនដែលនឹកគិតថាពួកគេមិនយល់ព្រមទេ ។ អារម្មណ៍ភ័យព្រួយចំពោះ *ប៊ុនតារ៉ូ* នៅដណ្តប់ជាប់លើអារម្មណ៍នាងនៅឡើយ ។ ស្តាយណាស់ជាការល្អគួរអនុញ្ញាតអោយគាត់បានស្លាប់នៅកន្លែងអំបាញ់មិញនេះឯង ។ ហេតុអ្វីបានជាយកកិត្តិយសរបស់គាត់ទៅផ្សងព្រេងយ៉ាងនេះ ? ហេតុអ្វីបានជាទើបដល់នាទីចុងក្រោយ ទើប *តូវ៉ាណាកា* បញ្ជាអោយប្តីនាងគេចខ្លួនតាមដីគោកយ៉ាងនេះ ? តាមពិត លោកម្ចាស់អាចបញ្ជាអោយ *ប៊ុនតារ៉ូ* ហែលទឹកមកឡើងទូកបានដែរតើ ។ ឡើងទូកគឺពិតជាមានសន្តិសុខជាង ហើយម្យ៉ាងទៀតនៅពេលនោះមានសល់ពេលសន្ទឹកសន្ធាប់ដែរតើ ។ លោកម្ចាស់ *តូវ៉ាណាកា* អាចចេញបញ្ជានេះតាំងពីពេលដែល *ប៊ុនតារ៉ូ* បានដើរមកម្លេះ ។ ហេតុម្តេច បានជាត្រូវរង់ចាំយ៉ាងដូចនេះ ? ចំលើយតែមួយគត់ដែល *ម៉ារីកូ* ប្រមាណមើល ។ គឺថាលោកម្ចាស់ *តូវ៉ាណាកា* មានមូលហេតុល្អបំផុតមួយនៅក្នុងការរង់ចាំ និងតំអក់ការចេញបញ្ជានេះ ។

*តូវ៉ាណាកា* សួរបន្ត :

- ចុះបើសិនជាពួកគេមិនព្រម តើនាងត្រៀមខ្លួនសំលាប់ពួកគ្រីស្តសាសនិករឺទេ *ម៉ារីកូ-សាន* ? ក្រែងអារឿងសំលាប់នេះជាច្បាប់បំពានមិនបានរបស់គ្រីស្តសាសនិកអ្វី ? ហាមមិន



www.budinst.gov.kh www.elibraryofcambodia.org

អោយសំលាប់នោះ ?

- ចាស គឺពិតមែនហើយលោកម្ចាស់ ។ តែដើម្បីលោកម្ចាស់ខ្ញុំសុខចិត្តចុះនរកទាំងរីករាយ ។ ទាំងប្តីខ្ញុំ ទាំងកូនខ្ញុំ និងទាំងរូបខ្ញុំផង ចាស ។

- ពិតហើយ ។ នាងជាសាមូរ៉ៃពិត១ម្នាក់ហើយខ្ញុំមិនភ្លេចដែរទេ ថានាងបានកាន់ដាវដើម្បីការពារខ្ញុំ ។

- នេះមិនមែនជាគុណប្រស្រ័យអ្វីទេ ចាស់។ បើសិនជាខ្ញុំបានជួយដោយស្តេចស្តើងនេះ។ នេះជាករណីយកិច្ចរបស់ខ្ញុំតែប៉ុននោះ។ បើត្រូវតូវរំលឹក គួររំលឹកប្តីខ្ញុំ និងកូនខ្ញុំទៅវិញទេ។ ពួកគេ ទើបសក្តិសមនឹងរំលឹកមែន ចាស ។

- ប៉ុន្តែនៅពេលនេះ នាងមានតំលៃចំពោះខ្ញុំជាង ។ ហើយអាចមានតំលៃខ្លាំងក្លាមែនទែនផង ។

- សូមលោកម្ចាស់ជួយណែនាំខ្ញុំផង ថាត្រូវធ្វើយ៉ាងម៉េច ហើយខ្ញុំនឹងធ្វើតាមភ្លាម ។

- ដាក់ព្រះស្រុកក្រៅអែបទៅម្ខាងទៅ !

មុខរបស់ *ម៉ារីកូ* ឡើងថ្លាំងតែម្តង :

- លោកម្ចាស់មានប្រសាសន៍ថាម៉េច ?

- បោះបង់ចោលព្រះនោះទៅ !

- លោកម្ចាស់ចង់អោយខ្ញុំឈប់ជាគ្រីស្តសាសនិក ?

- ពិតហើយ ។ នាងត្រូវដាក់ព្រះនេះនៅពីក្រោយស្មារតីរបស់នាង មិនមែនទៅពីមុខទេ ។

*ម៉ារីកូ* ឆ្លើយតបទាំងញាប់ញ័រ :

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផងចុះ ។ ប៉ុន្តែតាំងពីដើមរៀងមក ជំនឿសាសនារបស់ខ្ញុំមិនដែលមករំខានអ្វីដល់ភក្តីភាពរបស់ខ្ញុំចំពោះលោកម្ចាស់ម្តងណាឡើយ ។ ខ្ញុំតែងទុករឿងជំនឿសាសនារបស់ខ្ញុំជារឿងផ្ទាល់ខ្លួនតែប៉ុននោះ ។តើខ្ញុំមានដែលខ្វះខាតអ្វីចំពោះលោកម្ចាស់ទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- មិនដែលទេ ប៉ុន្តែនាងគង់តែឈានដល់ស្ថានភាពនេះទេនៅថ្ងៃមុខ ។

- សូមលោកម្ចាស់មានប្រសាសន៍មកចុះ តើខ្ញុំត្រូវធ្វើយ៉ាងម៉េចដើម្បីបំពេញចិត្តលោកម្ចាស់ ?

- ពួកគ្រីស្តសាសនិក អាចក្លាយជាសត្រូវរបស់ខ្ញុំ មែនទេ ?

- សត្រូវរបស់លោកម្ចាស់ គឺជាសត្រូវរបស់ខ្ញុំដែរ ចាស ។

-អីលូវនេះពួកបព្វជិតចេញមុខប្រឆាំងនឹងខ្ញុំ ហើយពួកវាអាចបញ្ជាអោយពួកគ្រីស្តសាសនិកទាំងអស់ធ្វើសង្គ្រាមប្រឆាំងនឹងខ្ញុំ ។

- ពួកគេមិនអាចធ្វើយ៉ាងនេះបានទេលោកម្ចាស់ ។ ពួកគេបំរើសុខសន្តិភាពទេតើ ។

- ចុះបើពួកនោះនៅតែប្រឆាំងនឹងខ្ញុំ ?ចុះបើពួកគ្រីស្តសាសនិកប្រកាសសង្គ្រាមនឹងខ្ញុំ?

- លោកម្ចាស់មិនបាច់កង្វល់នឹងភក្តីភាពរបស់ខ្ញុំឡើយ ។ សូមកុំកង្វល់អោយសោះចាស ។

- *អាន់ជីន-សាន* នេះអាចនិយាយការពិត ហើយពួកបព្វជិតរបស់នាងអាចនិយាយបោកប្រាស់ដែរ ។

- មានបព្វជិតល្អ ហើយក៏មានបព្វជិតអាក្រក់ដែរលោកម្ចាស់ ។ ប៉ុន្តែលោកម្ចាស់គឺជាអម្ចាស់របស់ខ្ញុំ ។

- ល្អណាស់ *ម៉ារីកូ-សាន* ។ ខ្ញុំសុខចិត្តយល់ព្រមចុះ ។ ខ្ញុំបញ្ជានាងអោយស្និទ្ធស្នាលជាមួយមនុស្សចុងស្រុកនេះ អោយរៀនសូត្រពីអ្វីទាំងអស់ដែលគេមានការយល់ដឹង អោយរាយការណ៍ពីអ្វីដែលដែលគេបាននិយាយ អោយរៀនគិតដូចរបៀបដែលគេគិត មិនអោយ "សារភាព" ប្រាប់ពួកបព្វជិតពីអ្វីដែលនាងធ្វើ អោយមានទំនាក់ទំនងប្រយ័ត្នប្រយែងជាមួយពួកបព្វជិតទាំងអស់ អោយរាយការណ៍ពីអ្វី១ទាំងអស់ដែលបព្វជិតសួរនាង រឺនិយាយប្រាប់នាង ។ព្រះរបស់នាងអាចនៅចន្លោះអ្វី១ទាំងអស់នេះ រឺនៅកន្លែងណាទៀត រឺក៏គ្មានវត្តមានតែម្តងក៏បាន ។

*ម៉ារីកូ* យកដៃក្បៀសសក់មួយដុំ ដែលបាំងភ្នែកនាង :

- ខ្ញុំអាចធ្វើការទាំងអស់នេះបាន ដោយនៅជាគ្រីស្តសាសនិកដដែលបាន ។ ខ្ញុំសូម



www.budinst.gov.kh www.elibraryofcambodia.org

ស្បថជូនលោកម្ចាស់ ចាស ។

- ល្អ ! សូមនាងស្បថដោយយកព្រះរបស់នាងជាបន្ទាល់ !

- ខ្ញុំសូមស្បថដោយយកព្រះជាបន្ទាល់

- ល្អ !

រួច *តូរ៉ាណាកា* បែរខ្លួន :

*- ភូជីកូ-សាន* !

- ចាស លោកម្ចាស់ ?

- នាងមានយកស្រីបំរើមកជាមួយទេ ?

- ចាស មានលោកម្ចាស់ ។ ពីរនាក់ ។

- អោយម្នាក់ទៅ *ម៉ារីកូ-សាន* ទៅ ។ ហើយអោយមួយទៅឆ្កុងតែ ។

- ស្រាសាកេក៏មានដែរ បើសិនជាលោកម្ចាស់ត្រូវការ ចាស ។

- តែ ! *យ៉ាប៊ូ-សាន* លោកចង់ហូបតែ រឺមួយស្រាសាកេ ?

- តែទាន ។

- យកមក អោយ *អាន់ជីន-សាន* ចុះ !

ពន្លឺភ្លើងដេញព្រិចៗលើបន្តោងឆ្លាងមាសតូចមួយដែល *ម៉ារីកូ* ពាក់នៅនឹងក ។ *តូរ៉ាណាកា* សំលឹងមើលបន្តោងនេះជាប់ ។ *ម៉ារីកូ* សួរឡើង :

- លោក....លោកម្ចាស់....មិន....ចង់អោយខ្ញុំពាក់បន្តោងនេះទេ រឺ អី ? ចង់អោយខ្ញុំបោះរបស់នេះចោល រឺ ?

- ទេ - *តូរ៉ាណាកា* ឆ្លើយ - សូមនាងពាក់របស់នេះចុះ ដើម្បីអោយនាងរំលឹកឃើញពីសំបថរបស់នាង ។

អីលូវនេះក្រសែភ្នែកមនុស្សទាំងអស់បានបាញ់សំលឹងទៅរកសំពៅ ។ *តូរ៉ាណាកា* មានអារម្មណ៍ថាមានគេកំពុងសំលឹងមើលរូបលោក ។ លោកក៏ចោលភ្នែកមើលជុំវិញខ្លួនលោក ហើយក៏បានប្រទះនឹងមុខដ៏មាំ និងភ្នែកខៀវដ៏ត្រជាក់ស្រើប ។ អារម្មណ៍លោកទទួលនូវចំហាយកំហឹង



www.budinst.gov.kh www.elibraryofcambodia.org

ទេមិនមែនជាកំហឹងទេ តែគឺភាពសង្ស័យមួយទៅវិញទេ ។ ហេតុអ្វីបានជាមនុស្សចុងស្រុកបាន សង្ស័យលើអញទៅវិញ - *តួរ៉ាណាកា* គិតនៅក្នុងចិត្ត :

- សួរ *អាន់ជីន-សាន* ទៅមើល ហេតុអ្វីបានជាគាត់មិននិយាយថានៅលើសំពៅពួក ចុងស្រុកមានកាណុងសំបូរពោរពាសតែម្តងទៅ ? ម៉េចគាត់មិននិយាយថា អោយពួកវានោះជូន យើងចេញពីការហ៊ុមព័ទ្ធនេះទៅ ?

*ម៉ារីកូ* បកសំនួរ *ប្លាក់ថន* ឆ្លើយតបវិញ ។

- គាត់ថា...- *ម៉ារីកូ* នៅអេះអុញបន្តិច រួចបកបន្តយ៉ាងញាប់តែម្តង - សូមលោកម្ចាស់ អភ័យទោស គាត់ថា " ប្រការល្អសំរាប់លោកម្ចាស់នាង គឺលោកម្ចាស់នាងប្រើខួរក្បាលរបស់ គាត់ផងទៅ " ។

*តួរ៉ាណាកា* ផ្ទុះសំណើច :

- អរគុណខួរក្បាលគាត់ផងទៅ ។ ខួរក្បាលគាត់ចំជាមានប្រយោជន៍មែន ។ ខ្ញុំសង្ឃឹម ថាវានៅជាប់លើស្មាគាត់រហូត ។ ប្រាប់គាត់ផងថា យើងអីលូវនេះស្មើគ្នាហើយ ។

- គាត់ថា : " ទេយើងមិនស្មើគ្នាទេ *តួរ៉ាណាកា-សាម៉ា* ។ សូមតែអោយសំពៅខ្ញុំ និង ពួកនាវិកមក ខ្ញុំនឹងបោសសំអាតសមុទ្រនេះអោយរលីងចេង ។ បោសសំអាតខ្លាំងទាំងអស់ " ។

- *ម៉ារីកូ-សាន* នាងសួរមើលថាខ្លាំងនេះបូកទាំងខ្ញុំជាមួយពួកអេស្ប៉ាញ និងពួកចុង ស្រុក ខាងត្បូងដែរទេ ?

សំនួរត្រូវបានសួរបែបវាហ៊ី ។

ជំនោរសមុទ្របក់ផាត់ សក់ *ម៉ារីកូ* មកបាំងភ្នែកនាងជាថ្មី ។ នាងយកដៃផាត់ចេញទាំង ឡើយហាត់ :

- ខ្ញុំមិនដឹងដែរ សូមលោកម្ចាស់អធ្យាស្រ័យ ។ អាចមែន អាចមិនមែន ។ តើលោក ម្ចាស់ចង់អោយខ្ញុំសួរគាត់ទេ ? ខ្ញុំសូមទោស តែគាត់....... គាត់..... គាត់ដូចជាចំលែកណាស់ ។ មែន ! ដល់ពេលណាមួយមនុស្សនេះនឹងពន្យល់ពីខ្លួនរបស់គេប្រាប់ពួកយើងជាមិនខាន ។

តាំងពីពេលដំបូងម្ល៉េះ *ប្លាក់ថន* ឃើញសំពៅស្រាវពួរតាំងពីពេលដែលពួកល្បាតអាវ



www.budinst.gov.kh www.elibraryofcambodia.org

ប្រផេះនាំគ្នាចេញតំរង់មករកទូករបស់ *តូរ៉ាណាកា* ម្ទេះ ។ អីលូវនេះ សំពៅនៅក្នុងទឹកជ្រៅប្រហែលបួន ប្រាំរយម៉ែតពីច្រាំង ក្នុងទីធានាសុវត្ថិភាពបាន និងដោយបែរតាមបណ្តោយឆ្នេរ ។ នេះគឺជារបៀបរៀបសំពៅរបស់ពួកជនជាតិអឺរុបទាំងអស់ នៅពេលណាដែលគេចូលចតនៅក្នុងផែចំណែក រឺពេលដែលមានភាពជាសត្រូវ ហើយនៅពេលដែលគ្រោះតំរាមកំហែងលេចចេញ ។ គេដឹងថា ថ្វីត្បិតតែតាំងពីដើមមកទល់ពេលនេះ គ្មានសកម្មភាពអ្វីគួរអោយសង្ស័យនៅលើសំពៅនេះក្តី ប៉ុន្តែពេលនេះកាណុងទាំងអស់ ត្រូវបានច្រកគ្រាប់ហើយស្រេច មូស្កេ ត្រូវបានបើកចែកគ្រប់ដៃ រំសេវនិងគ្រាប់ប៉ូលកាណុងត្រូវបានរៀបគរពោរពាស ដាវត្រូវដកហូតចេញ និងពួកប្រដាប់អាវុធនៅត្រៀមហើយស្រេចតាមខ្សែយោង ។ ភ្នែកទាំងអស់ត្រូវសំលឹងមើលទៅគ្រប់ទិស ។ ទូកចំប្រាកដជាត្រូវគេកត់សំគាល់ និង តាមដានតាំងពីពេលចាប់ផ្តើមដូរទិសភ្លាមម្ទេះ ។ កាណុងធុនសាមសិបមីលីម៉ែតទាំងពីរដែលនៅឯកន្សៃ ពិតជាកំពុងតំរង់មករកទូកធំនេះជាមិនខាន ។ ពួកបាញ់កាណុងប៉ុកទុយកាល់គឺជាអ្នកបាញ់ត្រង់បំផុតក្នុងពិភពលោកនេះ បន្ទាប់ពីពួកបាញ់កាណុងអង់គ្លេស ។

ហើយពួកវាសុទ្ធតែដឹងពីរឿង *តូរ៉ាណាកា - ប្លាក់ថន* គិតទាំងដូរចត់នៅក្នុងពោះ - ពីព្រោះពួកវាវាងវៃហើយពួកវាពិតជាសួរអ្នកលីសែងរបស់ពួកវា រឺ ពួកអាវប្រផេះឯទៀតៗពីមូលហេតុនៃរឿងរញ៉េរញ៉ៃនេះមិនខាន ។ រឺពុំនោះសោតពួកអាយេស៊ុីតរលត់រលាយ ដែលពូកែដឹងរឿងរ៉ាវសព្វគ្រប់ទាំងអស់នោះ ពិតជានឹងអោយពតិមានពីរឿងគេចខ្លួនរបស់ *តូរ៉ាណាកា* ហើយនឹងរឿងអញនេះមិនលែងឡើយ ។ *ប្លាក់ថន* មានអារម្មណ៍ដឹងថាសក់គេស្រៀវបះក្រញាង ព្រោះកាណុងណាតែមួយដើមនៅលើសំពៅនោះក៏អាចកំទេចទូកនេះអោយចុះឋានកុជង្គនាគបានដែរ ។ ប៉ុន្តែពេលនេះយើងមានសន្តិសុខទេ ព្រោះមាន *តូរ៉ាណាកា* នៅជាមួយយើង ។

*ម៉ារីកូ* បកប្រាប់ *ប្លាក់ថន* :

- លោកម្ចាស់ខ្ញុំសួរលោកថា តើលោកមានទំលាប់ធ្វើបែបណាបើលោកចង់ចូលអែបសំពៅចំបាំងនោះ ?

- បើយើងមានកាណុង យើងបាញ់ជាកិច្ចវន្ទនាការមួយ ។ រឺមួយយើងអាចធ្វើសញ្ញា



www.budinst.gov.kh www.elibraryofcambodia.org

ដោយទង់ សុំអនុញ្ញាតអែបសំពៅគេ ។

- លោកម្ចាស់ខ្ញុំសួរថា ចុះបើគ្មានទង់ ?

ថ្មីត្បិតតែពួកគេនៅឆ្ងាយផុតពីចំងាយដែលកាណុងអាចបាញ់ដល់ក្ដី និង ថ្មីត្បិតបង្ហូចកាណុងទៅបិតជិតនៅឡើយក្ដីតែ *ភ្លាក់ថន* មានអារម្មណ៍ដូចអង្គុយលើរសេវមួយចុងយ៉ាងដូចនោះដែរ ។ នៅខាងតួសំពៅ មានកាណុងប្រាំបីដើមម្ខាង ពីរដើមទៀតនៅខាងក្បាល និងពីរដើមទៀតនៅកន្សៃ ។ សំពៅ *អេភ៉ាស់* អញអាចស៊ីបានយ៉ាងងាយ - *ភ្លាក់ថន* គិតនៅក្នុងចិត្ត-អោយតែមានក្រុមសំពៅស្រួលបួល ។

- ប្រាប់មេបញ្ជាការអោយបង្ហូតទង់របស់ *តូរ៉ាណាកា*លើដងក្ដោងធំទៅ ។ប៉ុនណឹងគ្រប់គ្រាន់ហើយអ្នកស្រី ។ ធ្វើបែបនេះគឺមានលក្ខណៈជាផ្លូវការគ្រប់គ្រាន់ព្រមទាំងអោយពួកសំពៅដឹងថាជាអ្នកណានៅលើទូកនេះហើយ ។ ប៉ុន្តែមួយរយខ្ញុំស៊ីតែមួយទេគឺពួកវាដឹងបាត់ទៅហើយ ។

អ្វីៗត្រូវបានធ្វើតាមយ៉ាងរហ័ស ។ អីលូវនេះអ្នកនៅលើទូកទាំងប៉ុន្មានហាក់មានទំនុកចិត្តជាងមុនហើយ ។ *ភ្លាក់ថន* ក៏បានឃើញបំរែបំរួលនេះដែរ សូម្បីតែខ្លួនគេផ្ទាល់ក៏មានអារម្មណ៍គ្រាន់បើជាងមុនដែរនៅពេលដែលមានទង់ *តូរ៉ាណាកា* រលាស់នៅពីលើដងក្ដោងធំយ៉ាងនេះ ។

- លោកម្ចាស់ខ្ញុំសួរថា តើធ្វើម៉េចយើងអាចអែបទូកនឹងសំពៅគេបាន ?

- ប្រាប់គាត់ថា បើគ្មានទង់សញ្ញាគាត់មានជំរើសពីរ ។ វិមួយគាត់នៅចាំឆ្ងាយពីចំងាយរបស់កាណុង ហើយបញ្ជូនអ្នកតំនាងអោយជិះទូកតូចទៅឡើងសំពៅនោះ វិមួយចូលទូកទៅត្រង់តែម្ដង តែទៅត្រឹមម៉ាចំងាយស្រែកហៅគ្នាលឺតែប៉ុននោះ ។

- លោកម្ចាស់ខ្ញុំសួរថា តាមមតិរបស់លោកតើគួរជ្រើសរើសផ្លូវមួយណា ?

- ចូលតាមបណ្ដោយគ្នាទៅ ។ គ្មានមូលហេតុអ្វីដែលត្រូវប្រយ័ត្នហួសហេតុនោះទេ ។ លោក *តូរ៉ាណាកា* នៅលើទូកនេះហើយ ។ គាត់គឺជា *ដៃមីញ៉ូ* សំខាន់ជាងគេនៅក្នុងចក្រភពនេះ ។ គឺពិតជាសំពៅនឹងជួយយើង ហើយ.....ឱព្រះអើយព្រះ !

- មានបញ្ហាអ្វី វិលោក ?

*ភ្លាក់ថន* ឥតឆ្លើយតបឡើយ ។ *ម៉ារីកូ* ក៏រួសរាន់បកប្រែទៅ *តូរ៉ាណាកា* យ៉ាងញាប់ ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* សួរតបវិញ :

- លោកម្ចាស់ខ្ញុំសួរថាតើសំពៅណើងយ៉ាងម៉េច ? សូមលោកពន្យល់ពីគំនិតលោក និង ប្រាប់ពីហេតុដែលលោកឈប់និយាយកណ្តាលទីនោះផង ។

- ខ្ញុំទើបនឹងគិតឃើញថា គាត់ច្បាំងជាមួយ *អ៊ីស៊ីដូ* មែនទេ ? បើយ៉ាងនេះមែនសំពៅនេះប្រហែលជាមិនព្រមជួយគាត់ទេ ។

- ពួកនេះ ពិតជាព្រមជួយលោកម្ចាស់ ។

- ទេរវាង *តូរ៉ាណាកា* នឹង *អ៊ីស៊ីដូ* តើពួកប៉កទុយកាល់បានផលប្រយោជន៍ពីខាងណាច្រើនជាង? បើសិនជាបានពីខាង *អ៊ីស៊ីដូ* ច្រើនជាងពួកវាច្បាស់ជាបាញ់យើងប៉ុងពីទឹកមិនខានទេ ។

*ម៉ារីកូ* តបភ្លាម :

- មិនអាចពួកប៉កទុយកាល់ហ៊ានបាញ់លើទូកជប៉ុនទេ ។

- ជឿខ្ញុំចុះអ្នកស្រី ។ ពួកវាប្រាកដជាហ៊ាន ។ ខ្ញុំហ៊ានភ្នាល់ថាសំពៅនេះនឹងមិនព្រមអោយយើងអែបឡើយ ។ បើសិនជាខ្ញុំជាតៃកុងសំពៅណុង ខ្ញុំក៏ពិតជាមិនព្រមដែរ ។ ឱម្ចាស់ថ្លៃអើយ ។

*ប្លាក់ថន* លាន់មាត់ឃ្លាចុងក្រោយ នៅពេលដែលភ្នែករបស់គេចោលទៅមើលឯឆ្នេរ ។

ពួកអាវប្រផេះនៅតែបន្តស្រែកជេរបន្ទុះបង្អាប់ដដែល ប៉ុន្តែពួកវាបានចុះពីផែហើយនាំគ្នាពង្រាយតាមឆ្នេរពេញពាស ។ គ្មានផ្លូវចេញតាមនោះទេ -ប្លាក់ថនគិតក្នុងចិត្ត ។ ទូកនេសាទទាំងឡាយនៅតែរាំងច្រកចេញពីកំពង់ផែយ៉ាងកំនាចដដែល ។ តាមនេះក៏ទៅមិនរួចដែរ ។

- ប្រាប់ *តូរ៉ាណាកា* ថាមានផ្លូវមួយទៀតដើម្បីចេញផុតពីផែ គឺរង់ចាំព្យុះ ។ ពេលនោះយើងប្រហែលទប់រួច ឯទូកនេសាទទាំងអស់នោះទប់ព្យុះមិនរួចទេ ។ ដល់ពេលនោះយើងអាចរុលចេញបានហើយ ។

*តូរ៉ាណាកា* សួរទៅមេបញ្ជាការសំពៅដែលឆ្លើយតបវិញយ៉ាងវែង ។ រួច *ម៉ារីកូ* និយាយទៅ *ប្លាក់ថន* វិញម្តង :

- លោកម្ចាស់ខ្ញុំសួរថា តើលោកគិតថានឹងមានព្យុះ រឺអី ?



www.budinst.gov.kh www.elibraryofcambodia.org

- តាមច្រមុះខ្ញុំ គឺពិតជាមានព្យុះ ។ តែមិនមែនថ្ងៃនេះ គឺពីរបីថ្ងៃទៀត ។ តើយើងអាចរង់ចាំបានទេ ?

- លោកដឹងដោយសារច្រមុះលោក ? ព្យុះមានក្លិនដែរ ?

- គ្មានទេអ្នកស្រី ។ នេះគឺជាអារម្មណ៍មួយតែប៉ុននោះ ។

ក្រោយពីការថ្លឹងថ្លែងសព្វគ្រប់ *តូរ៉ាណាកា* ចេញបញ្ជាឡើង :

- យើងអែបទៅល្មមនឹងស្រែកហៅគ្នាលឺ *អាន់ជីន-សាន* ។

- បើអញ្ចឹងយើងចូលខាងកន្ទ្រៀសំពៅទៅ ព្រោះបើគេចង់បាញ់យើងក៏មុខទូកយើងវាតូចជាងទទឹងទូកទៅពេលដែលយើងចូលអែបបណ្តោយគេដែរ ។ ប្រាប់គាត់ថាពួកអស់នេះមានពោះវៀនបត់ចន្ទាសហើយអាក្រក់ណាស់ ហើយកាន់តែអាក្រក់ណាស់ទៅទៀតនៅពេលណាដែលផលប្រយោជន៍របស់ពួកវាត្រូវតំរាមកំហែងនោះ ។ ពួកវាអាក្រក់ជាងពួកអាហ្វូឡង់ទៅទៀត ។ បើសិនជាសំពៅនេះជួយ *តូរ៉ាណាកា* អោយគេចខ្លួនបាន *អ៊ីស៊ីដូ* ច្បាស់ជាយកពួកប៉ុកទុយកាល់ទាំងអស់ជាសត្រូវមិនខាន ហើយពួកវាពិតជាមិនចង់ប្រថុយស្បែកបែបនេះទេ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា បន្តិចទៀតយើងនឹងបានចំលើយជាមិនខាន ។

- ពួកយើងដូចដើរស្រាតអញ្ចឹង អ្នកស្រី ។ យើងគ្មានផ្លូវអីម៉ាសរសៃសក់ដើម្បីតទប់នឹងកាណុងទាំងអស់នេះទេ ។ បើសិនជាសំពៅនេះជាសត្រូវ រឺមួយគ្រាន់តែនៅត្រឹមតែជាអព្យាក្រឹត ក៏យើងច្បាស់ជាបានផឹកទឹកសមុទ្រហើយ ។

- លោកម្ចាស់ខ្ញុំថាលោកឯកភាពហើយ ប៉ុន្តែនេះគឺជាករណីយកិច្ចរបស់លោកក្នុងការបញ្ចុះបញ្ចូលពួកនោះអោយជួយពួកយើង ។

- ធ្វើម៉េចខ្ញុំធ្វើអញ្ចឹងបាន ? ខ្ញុំគឺជាសត្រូវរបស់ពួកវាណា៎ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា នៅក្នុងពេលសង្គ្រាម រឺនៅក្នុងសន្តិភាព សត្រូវគ្រាន់បើម្នាក់អាចមានតំលៃជាងសំព័ន្ធមិត្តគ្រាន់បើម្នាក់ផង ។ លោកម្ចាស់មានប្រសាសន៍ថាលោកយល់ដឹងពីផ្នត់គំនិតរបស់ពួកនោះ និងដឹងពីរបៀបបញ្ចុះបញ្ចូលពួកនោះបាន ។

- របៀបដែលច្បាស់ជាងគេគឺប្រើកំលាំងបាយ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់ខ្ញុំ ឯកភាពលើគំនិតនេះ ។ តែសូមលោកប្រាប់ពីរបៀបដែលត្រូវប្រើ ដើម្បីប្លន់យកសំពៅនេះផង ។

- ថាម៉េច ?

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា : " ល្អខ្ញុំឯកភាព ។ តែតើធ្វើម៉េចប្លន់សំពៅនេះបាន ធ្វើម៉េចយើងប្រាមប្រាបសំពៅនេះបាន ? ខ្ញុំត្រូវការកាណុងនេះ " ។ តើលោកយល់ហើយរឺនៅ *អាន់ជីន-សាន* ?

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំនិយាយម្តងទៀតណា ថាខ្ញុំត្រូវតែបាញ់អាទូកនេះអោយប៉ើងហើយ - *កៃរ៉ា* និយាយឡើងក្នុងសំលេងខ្លាំងៗ ។

- ទេ !

*វែឡាក្កា* ឆ្លើយតបទាំងតាមសំលឹងមើលទូកធំពីកន្សែសំពៅ ។

- ខ្ទាន់កាណុង តើទូកហ្នឹងចូលក្នុងចំងាយកាណុងហើយរឺនៅ ?

មេកងកាណុងឆ្លើយតប :

- នៅទេ *ដុនកៃរ៉ា* ។ មិនទាន់ទេ ។

- ព្រះតេជគុណ ខ្ញុំសូមសួរមើលថាបើពួកវាគ្មានបំនងអាក្រក់ទេ តើវាតំរង់ទូកមករកពួកយើងធ្វើអ្វី ? ម៉េចក៏វាមិនគេចខ្លួនទៅ ? ផ្លូវនៅស្រឡះទេតើ ។

តាមពិតទៅ ដោយសំពៅនៅឆ្ងាយពីច្រកចូលកំពង់ផែ ទើបពួកគេឥតឃើញរូងទូកនៃសាទដែលនៅស្ទាក់ផ្លូវខាងមុខឡើយ ។

*កៃរ៉ា* និយាយបន្ត :

- យើងគ្មានខាតអ្វីទាំងអស់ តែយើងចំនេញសព្វបែបសព្វយ៉ាង ។ យើងអាចនិយាយថាយើងឥតដឹងថា *តូរ៉ាណាកា* មាននៅលើទូកសោះ គឺវារួចទៅហើយ ។ យើងអាចនិយាយថាពួកយើងស្មានតែអ្នកនៅលើទូកនោះជាពួកចោរ .....ពួកចោរក្រោមការដឹកនាំរបស់អាទមិឡចង់វៃលុកពួកយើង ។ សូមព្រះតេជគុណកុំបារម្ភអី ពួកនេះងាយបញ្ឆោះទេ អោយតែពួកវាចូលដល់ចំងាយបាញ់របស់កាណុងយើងទៅ គឺស្រេចទៅហើយ ។

- ទេ !

*វែឡាក្កា* ចេញបញ្ជាយ៉ាងដាច់ណាត់ ។

បព្វជិត *អាល់វីតូ* បែរខ្នងដាក់ទូកធំម្តង :

- ទូកនេះបង្គួតទង់របស់ *តូរ៉ាណាកា* ណា លោកមេបញ្ជាការ ។

*កៃរ៉ា* និយាយតបយ៉ាងចំអក :

- ទង់ក្លែងក្លាយទេ ! អានេះជាល្បិចកញ្ចាស់អែក្នុងសមុទ្ទតែប៉ុននោះ ។ យើងមិន



www.budinst.gov.kh www.elibraryofcambodia.org

ដែលឃើញ *គូរ៉ាណាកា* ម្តងណាទេ អាចអាគាត់ណើងអត់ទាំងនៅលើទូកផងទេដឹង ។

- ទេ !

- ឱព្រះម្ចាស់ថ្លៃអើយ ! បើមានសង្គ្រាមមែន គឺពិតជាចង្រៃធំហើយ ។ បើវាមិនបំផ្លាញទេ ក៏វានឹងធ្វើអោយប៉ះពាល់ដល់ដំណើររបស់ *សំពៅខ្មៅ* នេះដែរ ។ អារឿងនេះខ្ញុំមិនអាចនៅស្ងៀមបានទេ ហើយខ្ញុំក៏មិនអោយមានអ្វីចូលមកជ្រៀតជ្រែកក្នុងរឿងនេះបានជាដាច់ខាត ។

- ស្ថានភាពហិរញ្ញវត្ថុរបស់ពួកយើងយ៉ាប់យ៉ឺនជាងលោកផង លោកមេបញ្ជាការ-*ដៃឡាក្កា* និយាយយ៉ាងកំបុត -នៅឆ្នាំនេះបើយើងមិនជួញដូរទេ ព្រះវិហារច្បាស់ជាឡុងចុងជាមិនខាន តើលោកយល់ហើយរឺនៅ ? យើងមិនដែលទទួលលុយកាក់អីពី *កូវ៉ា* រឺពី *លីស្បោន* ចំនួនបីឆ្នាំមកហើយៗថែមទាំងខាតកាលពីឆ្នាំទៅនេះទៀត....ឱព្រះអង្គអើយព្រះអង្គសូមអោយខ្ញុំ នៅតែរក្សាបានភាពខន្តីផង ! លោកមេបញ្ជាការ ខ្ញុំដឹងជាងលោកទៅទៀតថា អ្វីទៅដែលយើងកំពុងប្រថុយនេះ ។ ចំលើយគឺទេ !

*រ៉ូឌ្រិច* ដែលកំពុងអង្គុយទាំងចុកចាប់នៅលើកៅអី និងដែលមានជើងអបព្រួលដាក់នៅលើកូនកៅអីមួយនោះ ក៏លូកមាត់ចូល :

- លោកមេបញ្ជាការមានយោបល់ត្រឹមត្រូវណាស់ព្រះតេជគុណ ។ បើសិនជាពួកវាមិនមានបំនងចង់ធ្វើអីទេ ហេតុអ្វីបានជាវាបើកតំរង់មករកយើង? ម៉េចក៏មិនគិតរត់គេចខ្លួនទៅ? ព្រះតេជគុណ ពេលនេះគឺជាឱកាសមួយដ៏កំរណាស់ទាន ។

*កែរីវ៉ា* បន្ទរភ្លាម :

- ពិតហើយៗនេះគឺជាសេចក្តីសំរេចផ្នែកយោធាទេ ។

*អាល់វីតូ* តបវិញយ៉ាងតឹងសំលេង :

- ទេ ! ព្រះតេជគុណគណៈសង្ឃគឺជាអ្នកសំរេចនៅលើបញ្ហានេះ លោកមេបញ្ជាការ ។ យើងមិនត្រូវប៉ះពាល់ *គូរ៉ាណាកា* ទេ ផ្ទុយទៅវិញយើងត្រូវតែជួយគាត់ ។

*រ៉ូឌ្រិច* សងទៅ *អាល់វីតូ* វិញ :

- ជាច្រើនលើកច្រើនសារមកហើយ ព្រះតេជគុណតែងប្រាប់ខ្ញុំថាបើសង្គ្រាមផ្ទុះឡើង



www.budinst.gov.kh www.elibraryofcambodia.org

វានឹងបន្តជារឿងរហូត ។ អីលូវនេះសង្គ្រាមចាប់ផ្ដើមហើយ មែនទេ ? យើងបានឃើញវាចាប់ផ្ដើមហើយ ។ អានេះវានឹងប៉ះពាល់ដល់រឿងជួញដូរចៀសមិនផុត បើ *តូរ៉ាណាកា* ស្លាប់សង្គ្រាមនឹងត្រូវបញ្ចប់ហើយផលប្រយោជន៍យើងទាំងអស់នឹងមានការធានាដដែល ។ ខ្ញុំសូមឯកភាពថាបាញ់កំទេចទូកនេះទៅ ។

*ភែរីរ៉ា* និយាយបន្តដោយសំលឹងមើល *រ៉ូឌ្រិច* ជាប់ :

- ហើយយើងក៏អាចចាត់ការអាទមិឡនោះបានផង ។ ព្រះតេជគុណអាចបញ្ចៀសសង្គ្រាមដើម្បីកិត្តិស័ព្ទរបស់ព្រះជាម្ចាស់ និងដើម្បីចៀសវាងកុំអោយមានទូកទមិឡផ្សេងទៀតមករំខានថែមទៀត ។

*ដែឡាក្វា* ឆ្លើយតបវិញ ដោយចៀសវាងមិនប្រាប់ពីមូលហេតុពិត :

- នេះគឺជាការជ្រៀតជ្រែកដោយឥតត្រឹមត្រូវអ្វីសោះ ទៅក្នុងរឿងនយោបាយរបស់ពួកគេ ។

- យើងជ្រៀតជ្រែកតែរាល់ពេលណឹង ។ សមាគមព្រះយេស៊ូធ្លាប់ល្បីល្បាញក្នុងរឿងនេះហើយតើ ។ យើងមិនមែនជាប្រភេទអ្នកស្រែចំការដែលដឹងតែឲ្យលក្បាលទៅមុខឯណា ?

- ខ្ញុំមិនមែនចង់ថាលោកជាប្រភេទនោះទេ ។ ប៉ុន្តែដរាបណាខ្ញុំនៅលើសំពៅនេះលោកមិនត្រូវបាញ់ពន្លិចទូកនេះជាដាច់ខាត ។

- បើអញ្ចឹងសូមតេជគុណអញ្ជើញទៅច្រាំងចុះទាន ។

*រ៉ូឌ្រិច* និយាយបញ្ចុះបញ្ចូលថែមទៀត :

- អាមេឃាតកនេះស្លាប់កាន់តែឆាប់ពេលណា កាន់តែប្រសើរពេលនោះព្រះតេជគុណ ។ អាគាត់នេះ វី អា *អ៊ីស៊ីដូ* តើវាមានអីខុសគ្នាទៅ ? ពួកវាសុទ្ធតែជាពួកក្រៅសាសនាហើយព្រះតេជគុណមិនអាចទុកចិត្តពួកវាមួយណាបានទេ ។ លោកមេបញ្ជាការនិយាយត្រូវណាស់ ហើយយើងមិនមានឱកាសល្អបែបនេះទេ។ រួចចុះរឿង *សំពៅខ្មៅ* របស់យើង ព្រះតេជគុណមិនរវល់ទេអ្ហី ?

ជាតែកុង *សំពៅខ្មៅ រ៉ូឌ្រិច* ទទួលបានដប់ប្រាំភាគរយលើប្រាក់ចំនេញទាំងអស់ ។ តែ



www.budinst.gov.kh www.elibraryofcambodia.org

កុងពិតប្រាកដរបស់ *សំពៅខ្មៅ*បានស្លាប់ដោយរោគអុតនៅ *ម៉ាកាវ* កាលពីបីខែមុន ហើយ *រ៉ូទ្រិច* ក៏ត្រូវប្តូរពីតៃកុងសំពៅ *សាន់តា ថេរេសា* ទៅ *សំពៅខ្មៅ*វិញ ។ អុតគឺជាពាក្យផ្លូវការតែប៉ុណ្ណោះ -*រ៉ូទ្រិច* គិតទាំងមួម៉ង -ព្រោះមានមនុស្សច្រើនគ្នាណាស់ដែលនិយាយថាតៃកុងនោះត្រូវគេលួចចាក់ពីក្រោយដោយ *រ៉ូនីន* ម្នាក់ នៅពេលឈ្លោះគ្នាក្នុងបនស្រីពេស្យាមួយ ។ ព្រះអង្គអើយនេះបានចំជាស់នាងមែន ។ អញ្ចឹងហើយគ្មានអ្វីត្រូវមកជ្រៀតជ្រែករឿងនេះបានឡើយ ។

*កែរីក* និយាយ :

- ខ្ញុំសូមទទួលខុសត្រូវទាំងស្រុង ។ នេះជាការសំរេចផ្នែកយោធា ។ យើងត្រូវជ្រមុជចូលក្នុងសង្គ្រាមរបស់ពួកម្ចាស់ស្រុក ហើយសំពៅខ្ញុំត្រូវស្ថិតនៅចំពោះមុខគ្រោះថ្នាក់ ។

រួច *កែរីក* ងាកបែរទៅរកមេកងកាំភ្លើងធំម្តងវិញ :

- ពួកវាចូលក្នុងរង្វង់ចំងាយកាណុងហើយរឺនៅ ?

- បាទ *ដុនកែរីក* អីលូវនេះស្រេចតែលោកចង់ទេ ។

មេកងកាណុងអោនផ្លុំចុងដុំភ្លើង អោយឆេះក្របាមបែកផ្កាភ្លើងព្រាតឡើង ហើយនិយាយបន្ត :

- អីលូវនេះខ្ញុំអាចបេះយកខាងមុខ រឺ ខាងកន្សៃ រឺយកកណ្តាលតួ បានយ៉ាងងាយអោយតែលោកចង្អុលប្រាប់ចុះ ។ ប៉ុន្តែបើលោកចង់យកជីវិតមនុស្ស មនុស្សណាមួយដោយឡែកនោះ ទាល់តែចាំបន្តិចទៀតសិន ។

- ខ្ញុំចង់អោយ *តូរ៉ាណាកា* ងាប់ ។ ហើយអាទមិឡក៏អញ្ចឹងដែរ ។

- អា *អ៊ីញូគីលីស* អាតៃកុងណឹងមែនទេ ?

- ណឹងហើយ ។

- ទាល់តែអ្នកណាម្នាក់ចាំចង្អុលអាគយនោះប្រាប់ខ្ញុំ ។ អាតៃកុងនោះបើខ្ញុំឃើញខ្ញុំច្បាស់ជាមិនច្រលំទេ ។

*រ៉ូទ្រិច* លូកមាត់ :

- បើសិនជាតៃកុងនោះស្លាប់ទើបអាចសំលាប់ *តូរ៉ាណាកា* និងបញ្ចប់សង្គ្រាមបាននោះ



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំសូមគាំទ្រ លោកមេបញ្ជាការ ។ បើមិនយ៉ាងនោះទេ តែកុងនោះគួរតែស្នើរសប្រហើងដែរចុះ ។

- វាជាទមិឡ ជាសត្រូវនគរយើង ជាបិសាច ហើយវាបានបង្កទុក្ខដល់យើងច្រើនជាងពស់វែក ម៉ាកញ្ញេរទៅទៀត ។

- ខ្ញុំជំរាបលោករួចហើយ ថាដំបូងបង្អស់វាជាតែកុង ហើយជាតែកុងឯកនៅក្នុងលោកនេះ ។

-តើតែកុងសុទ្ធតែមានអភ័យឯកសិទ្ធិអញ្ចឹងអ្ហី?ទោះជាតែកុងទមិឡក៏ដោយមែនទេ?

- ពិតហើយ ។ យើងគួរប្រើវាដូចពួកវាប្រើយើងអញ្ចឹងដែរ ។ សំលាប់មនុស្សមានបទពិសោធន៍សំបូរហូរហៀរបែបនេះ គឺពិតជាខ្ជះខ្ជាយចង្រៃយក៏មែនទែន ។ គ្មានតែកុងគឺគ្មានចក្រភព គ្មានជំនួញជួញដូរ គ្មានអ្វី១ទាំងអស់ ។ គ្មានរូបខ្ញុំ គ្មាន *សំពៅខ្មៅ* គ្មានលាភសក្ការៈ អីទាំងអស់ ។ ហេតុនេះមតិរបស់ខ្ញុំក៏មានសារសំខាន់ណាស់ដែរ លោកមេបញ្ជាការ ។

សំរែកមួយបានលាន់លឺពីដងក្តោងធំ :

- អេ អ្នកនៅកន្សែ ! ទូកធំដូរទិសហើយ !

ទូកធំដែលអំបាញ់មិញតំរង់ក្បាលចំសំពៅនោះ បានដូរទិសបែរក្បាលតំរង់កំពង់ផែវិញ។

*វ៉ុទ្រិច* ស្រែកឡើងភ្លាម :

- ត្រៀមប្រយុទ្ធភ្លាម ! លើកក្តោងទាំងអស់ ហើយស្រាវយុថ្កាឡើង !

ទាំងអស់គ្នារត់ប្រសាចធ្វើតាមបញ្ជា *វ៉ុទ្រិច* ។

- មានរឿងអីហ្នឹង *វ៉ុទ្រិច* ?

- ខ្ញុំមិនដឹងដែរលោកមេបញ្ជាការ តែយើងកំពុងរសាត់ចេញទៅខាងលំហសមុទ្ទហើយ ១ទូកនេះកំពុងតែចាក់បញ្ច្រាស់ខ្យល់មកហើយ ។

- រួចចុះវាថី ? យើងអាចពន្លិចវាពេលណាក៏តែបានដែរ *-វ៉ាកវីរ៉ា* តប -យើងនៅសល់អីវ៉ែវអីវ៉ាន់មិនទាន់ជញ្ជូនឡើងសំពៅអស់ផង ហើយម្យ៉ាងទៀត ព្រះតេជគុណត្រូវត្រលប់ទៅ *អូសាកា* វិញផង ។



www.budinst.gov.kh www.elibraryofcambodia.org

LIBRARY BUDDHIST INSTITUTE

- ខ្ញុំដឹងហើយ ។ ប៉ុន្តែទូកសត្រូវមិនត្រូវចាក់បញ្ច្រាសខ្យល់មកសំពៅខ្ញុំទេ ។ អាទូកនេះវាមិនចាំបាច់ខ្យល់ទេ វារត់បញ្ច្រាសក៏តែបានដែរ ។ ពួកវាច្បាស់ជាព័ទ្ធក្រលឹងចូលពីខាងមុខសំពៅហើយ ព្រោះខាងមុខយើងមានតែកាណុងមួយ ងាយស្រួលវាបុកចូលណាស់ ។

*កែរីក* ស្រែកយ៉ាងធំអក :

- កាណុងនៅលើសំពៅយើងមានម្ភៃដើម ! ពួកវាតែម៉ាដើមក៏គ្មានផង ! លោកស្មានថាអាទូកត្រលោកបែបនេះហ៊ានវ៉ៃលុកយើងអ្វី ? លោកឯងចំជាគំនិតខ្ចីមែន !

- មែនហើយ លោកមេបញ្ជាការ ។ ព្រោះតែគំនិតខ្ចីអញ្ចឹងហើយ បានជាក្បាលខ្ញុំនៅជាប់នឹងស្មារហូតដល់ពេលនេះ ។ ខ្ញុំបញ្ជាសំពៅ *សាន់តា រេវរេសា* អោយចេញទៅលំហសមុទ្រហើយ ។

ខ្យល់បក់បំប៉ោងក្ដោង ធ្វើអោយដងក្ដោងលាន់លឺស្វរមឹត ប៉ុន្តែសំពៅនៅតែទៅមុខយ៉ាងតើម១នៅឡើយ ។

- អោយលឿនឡើង អាកូនមីចោរ -*វ៉ូទ្រិច* ប្រទេចរង៉ូវនៅក្នុងពោះ ។

មេកងកាណុងនិយាយឡើង :

- ពួកយើងរៀបចំរួចរាល់ហើយ *ដុនកែរីក* ។ ខ្ញុំមើលវាឃើញច្បាស់ហើយ តែក៏មិនអាចតំរង់ចំបានយូរទេណា ។ អ្នកណាមួយជា *តូរ៉ាណាកា* ? សុំចង្អុលប្រាប់ផង ។

នៅលើទូកធំគ្មានពន្លឺចន្លុះមួយដើមសោះឡើយ ។ ពន្លឺដែលមានគឺជាពន្លឺព្រះច័ន្ទតែប៉ុណ្ណោះ ។ ទូកនៅចំងាយជាងមួយរយម៉ែតខាងក្រោយតែក៏ចាប់ងាកក្បាលស្របតាមផ្នែកឆ្វេងរបស់សំពៅសំដៅទៅរកឯនាយសមុទ្រហើយដែរ ។ ច្រវាកាយទឹកក្នុងសង្វាក់ស្មើ១ ។

- អាម្នាក់ឈុងអ្វី ជាតៃកុងនោះ ? អាមួយមាឌធំនៅលើទូកឈុងមែនទេ ?

*វ៉ូទ្រិច* តប :

- ហ៊ឹងហើយ

- *ម៉ានុយអែល* និង *ពែឌ្រឹត* ! តំរង់វា ហើយនឹងកឹងទូក !

កាណុងដែលនៅជិតបំផុត ត្រូវបានបង្វែរបន្តិច ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្នកណាមួយជា *តូរ៉ាណាកា* ? អោយឆាប់ឡើង ! អ្នកចង្កូត កាច់ស្តាំពីរចំនុច ។

- អ្នកបាញ់កាណុង ពីរចំនុចខាងស្តាំ !

ដោយដឹងថានៅទីនេះបាតសមុទ្រច្រើនភក់នោះ *វ៉ូឌ្រិច* តាមសំលឹងខ្សែយោងយ៉ាងមិត់ចត់ដោយត្រៀមជាស្រេចនឹងជំនូសមេកងកាណុងភ្លាម ព្រោះជាទំលាប់នៅពេលបាញ់មេកងកាណុងជាអ្នកបញ្ជាសព្វគ្រប់នៅលើសំពៅ ។ កាណុងទាំងអស់ត្រូវបានរៀបចំហើយជាស្រេចហើយនៅពេលនេះភ្នែករបស់ម្នាក់ៗកំពុងតែបាញ់សំលឹងទៅរកមេបញ្ជាការរបស់ពួកគេ និងទៅបព្វជិតដែលកំពុងនៅលើសំពៅ ។

-ព្រះអើយព្រះ *ដុនភែរីរ៉ា* អ្នកណាជា *តូរ៉ាណាកា* នោះ ?

តាំងពីដើមមក *ភែរីរ៉ា* មិនដែលឃើញ *តូរ៉ាណាកា* ម្តងណាឡើយ :

- ព្រះតេជគុណ អ្នកណាមួយជា *តូរ៉ាណាកា* ?

*វ៉ូឌ្រិច* បានមើលឃើញយ៉ាងច្បាស់រូប *តូរ៉ាណាកា* ដែលកំពុងឈរនៅលើក្បាលទូកជាមួយពួកសាមូរ៉ៃមួយចំនួន ប៉ុន្តែខ្លួនគេក៏មិនចង់ក្លាយទៅជាអ្នករែកថ្មបាក់នោះឡើយ ។ ទុកអោយពួកបព្វជិតទទួលសំរេចរឿងនេះចុះ -*វ៉ូឌ្រិច* គិតនៅក្នុងចិត្ត ។

បព្វជិតទាំងពីរនៅស្ងៀមស្ងាត់ឥតមាននិយាយអ្វីទាំងអស់ ។

អ្នកកាន់កាណុងសួរបញ្ជាក់ម្តងទៀត :

- អ្នកណាមួយជា តូរ៉ាណាកា ?

ដោយធុញទ្រាន់ *វ៉ូឌ្រិច* ក៏លើកដៃចង្អុលឡើង :

- នោះ ! អាមួយនៅក្បាលទូក អាម្នាក់ធាត់ទាបនោះឯង ។

- បាទឃើញហើយបងតែកុង ។

ក្រុមកាណុងធ្វើការតំរង់ជាចុងក្រោយ ។

*ភែរីរ៉ា* កន្ត្រាក់ឈ្នួនពីដៃខ្ទាន់កាណុងមកកាន់ខ្លួនឯង ។

- មានតំរង់ចំអាទមិឡហើយរឺនៅ ?

- ចំហើយលោកមេបញ្ជាការ ។ លោកត្រៀមហើយរឺនៅ ? ពេលណាខ្ញុំទំលាក់ដៃគឺជា



www.budinst.gov.kh www.elibraryofcambodia.org

សញ្ញាហើយណា ។

- ល្អ !

- ឯងមិនត្រូវសំលាប់ទេ !

នេះគឺជាសំលេងរបស់ *ដែឡាក្វា* ។ *កែរីវ៉ា* ងាកផាំងទៅបព្វជិតនេះភ្លាម :

- ពួកវាជាពួកទមិឡក្រៅសាសនាទេតើ ។

- មានពួកខ្លះជាគ្រីស្តសាសនិកនៅលើទូកនោះដែរ ហើយទោះជាគ្មានក្តី.......

មេបញ្ជាការ *កែរីវ៉ា* គ្រហឹមខ្ញុំរ :

- កុំខ្វល់អីខ្មាន់កាណុង ។ ពេលណារៀបចំហើយយើងបាញ់ភ្លាម ។

*ដែឡាក្វា* ដើរទៅមុខកាណុង ហើយឈរពាំងចំមាត់កាណុងនោះតែម្តង ដៃរបស់លោកកាន់ជាប់រូបឆ្លាង :

- ខ្ញុំនិយាយហើយថា ឯងមិនត្រូវសំលាប់ទេ !

*កែរីវ៉ា* តប :

- តែយើងសំលាប់មនុស្សរាល់តែពេលតើ !

- ខ្ញុំដឹងហើយ១អញ្ចឹងហើយទើបខ្ញុំសែនខ្មាស់ ហើយខ្ញុំតែងបួងសួងសូមអោយព្រះខន្តិប្រណីទោសនោះ ។

តាំងពីដើមមក *ដែឡាក្វា* មិនដែលនៅលើសំពៅចំបាំងដែលមានកាណុង និង មូស្កេញាត់គ្រាប់ស្រេច និងម្រាមកាន់កែប្រុងប្រៀបប្រហារគ្នាយ៉ាងនេះទេ :

- ជរាបណាខ្ញុំនៅទីនេះ គ្មានរឿងសំលាប់ទេ ។

- រួចចុះលោតែពួកវាវៃលុកយើង ? លោតែពួកវាចង់វៃដណ្តើមយកសំពៅ ?

- ខ្ញុំនឹងបួងសួងសុំអោយព្រះជួយពួកយើងកំចាត់ពួកវា ។

- ចុះមុន និង ក្រោយវាមានទៅខុសគ្នាអី ?

*ដែឡាក្វា* ឥតមានឆ្លើយតបឡើយ ។ ឯងមិនត្រូវសំលាប់ទេ -លោកគិតនៅក្នុងចិត្ត ។ ហើយ *តូរ៉ាណាកា* បានសន្យាគ្រប់យ៉ាង ឯ *អ៊ីស៊ីដូ* វិញគ្មានអ្វីទាំងអស់ ។ មេកងកាណុងស្រែក



www.budinst.gov.kh www.elibraryofcambodia.org

ឡើង :

- រួចយ៉ាងម៉េចហើយ លោកមេបញ្ជាការ ? ដល់ពេលហើយណា ! ដល់ពេលហើយ !

*កែរីភ* បែរខ្នងដាក់បព្វជិតទាំងពីរយ៉ាងជូរចត់ រួចបោះផ្លូនចោល ហើយដើរទៅបង្កាន់ដៃកិងសំពៅស្រែកបញ្ជា :

- រៀបចំទប់ទល់ការវាយលុក ! បើទូកនោះហ៊ានចូលមកជិតត្រឹមហាសិបម៉ែតដោយគ្មានការអនុញ្ញាត ពួកឯងត្រូវបាញ់វាកំទេចអោយម៉ត់ ទោះជាពួកបព្វជិតនិយាយយ៉ាងម៉េចក៏ដោយ ។

*វ៉ុន្រ្ទិច* ក៏ឆេះដុំណាស់ដែរ ប៉ុន្តែគេក៏ដឹងថាគេដូចជា *កែរីភ* ដែរ ។ គ្មានអ្នកណាអាចជំទាស់នឹងបព្វជិតបានទេ ។ ឯងមិនត្រូវសំលាប់ទេ ? រួចចុះពួកបព្វជិតឯងនេះ ? -*វ៉ុន្រ្ទិច* ស្រែកនៅក្នុងពោះ ។ ចុះអារឿង *អូតូដាហ្វេ* (*) នោះ ? រួចចុះអារឿងតុលាការសាសនានោះ ? រួចចុះអារឿងពួកបព្វជិតឯងដែលវិនិច្ឆ័យគេថា " មានកំហុស " រឺ " សាគង់សណ្ឋិត " រឺ " បែកឆ្វេង " តាមអំពើចិត្តនោះ ? តើនៅចាំមនុស្សជាងពីរពាន់នាក់ដែលត្រូវដុតទាំងរស់តែនៅក្នុងប្រទេសប៉ុកទុយកាល់មួយផងនៅឆ្នាំដែលអញចុះសំពៅមកអាស៊ីនេះទេ ?

*វ៉ុន្រ្ទិច* ទុកអារម្មណ៍ភ័យខ្លាចទៅម្ខាង ហើយផ្តោតការយកចិត្តទុកដាក់របស់ខ្លួនទៅលើទូកវិញម្តង ។ គេប្រទះភ្នែកឃើញ *ភ្លាក់ថុន* ឈរនៅលើកិងទូក ។ អា *អ៊ីញ៉ាគីលើស* នេះ ។ ដូចជាសប្បាយចិត្តម៉្យាងដែរ ដែលឃើញឯងឈរបញ្ជាយ៉ាងជ្រងោនៅលើទូកនេះ ។ ប៉ុន្តែអញថប់តែអ្ហែងដើរចូលអន្ទាក់មរណៈទេ ។ បើអ្ហែងបានរួចខ្លួនអញជួយអរ តែទោះជាអញ៉ឹងក្តីក៏អ្ហែងអត់មានកាណុងម៉ាដើមសោះនៅលើទូក អញ៉ឹងហើយអញអាចបាញ់អ្ហែងប៉ើងហើយអ្ហា ។ បាញ់ប៉ើងខ្ទេចទោះជាបព្វជិតមានមតិយ៉ាងម៉េចក៏ដោយ !

(*)Auto da fé : *ការសំលាប់អ្នកបែកឆ្វេងនៅក្នុងសាសនាកាតូលិចដោយដុតទាំងរស់ (ក.អ.ប)* ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

- អូអ្ហេ ! *សាន់តា ថេរេសា* !

- អូអ្ហេ ! ម៉េច *អ៊ីញូគីលីស* ?

- អែងមែនទេ *វ៉ូត្រិច* ?

- ណឹងហើយ ។

- ជើងអែងម៉េចទៅហើយ ?

- ចោលម្រាយវា !

នៅក្នុងចិត្ត *វ៉ូត្រិច* មានការរីករាយពន់ពេកនៅពេលលឺសូរសំនើចបែបចំអកដែលលាន់ខ្ទរតាមផ្ទៃទឹកសមុទ្រដែលនៅចន្លោះនាវាទាំងពីរ ។

ក្នុងរយៈពេលជិតកន្លះម៉ោង នាវាទាំងពីរសាកល្បងបើកចុះបើកឡើងប្រដេញគ្នា ។ ទូកធំប្រឹងបុកបញ្ច្រាស់ខ្យល់ដើម្បីកៀងសំពៅផ្ទប់នឹងច្រាំង ឯសំពៅប្រឹងវាតយកទីឯលំហសមុទ្រដើម្បីបើកចេញពីឆកកំពង់ផែនេះបានភ្លាមនៅពេលណាដែលខ្លួនចង់ ។ ប៉ុន្តែគ្មានអ្នកណាមានប្រៀបជាងអ្នកណាឡើយ ហើយគឺនៅក្នុងពេលប្រដេញគ្នានេះហើយទើបអ្នកនៅលើសំពៅប្រទះឃើញជាលើកដំបូងនូវវ៉ូងទូកនេសាទដែលនៅបិទច្រកចូលកំពង់ផែ ហើយនឹងន័យរបស់វា ។

- អញ្ចឹងហើយទើបវាមករកពួកយើង ! វាមកអោយយើងជួយការពារទេតើ !

*កែវីរ៉ា* តប :

- ព្រោះតែអញ្ចឹងហើយទើបយើងត្រូវបាញ់ពន្លិចវាអោយហើយទៅទាន់វានៅជាប់ជុំចយ៉ាងនេះ ហើយ *អ៊ីស៊ីដូ* ពិតជានឹងដឹងគុណយើងម៉ាអាយុស ។

បញ្ចិត *ដៃឡាក្កា* នៅតែម៉ឹងម៉ាត់ដដែល :

- *តូរ៉ាណាកា* ជាមនុស្សសំខាន់ណាស់ ។ ខ្ញុំទាមទារជាដំបូងបង្អស់អោយយើងនិយាយជាមួយគាត់សិនទៅ ។ លោកនៅតែអាចបាញ់ពន្លិចគាត់ថ្ងៃណាក៏បានដែរ ។ គាត់គ្មានកាណុងម៉ាដើមផង ព្រោះមានតែកាណុងទេដែលអាចតទល់នឹងកាណុងបាន ។

ក្នុងស្ថានភាពនេះ *វ៉ូត្រិច* បង្អង់សំពៅដើម្បីមានឱកាសរង់ចាំ ។ នាវាទាំងពីរកំពុងនៅចំ



www.budinst.gov.kh www.elibraryofcambodia.org

កណ្តាលឆកកំពង់ផែក្នុងសន្តិសុខគ្រប់គ្រាន់ទាំងពីទូកនេសាទផង និង ទាំងពីរវាំងនាវាទាំងពីរផង ។សំពៅនៅញ៉រទទ្រេីតក្រោមកំលាំងខ្យល់ ដែលធ្វើអោយពួកគេត្រៀមបន្តចេញភ្លាមបាននៅគ្រប់ពេលវេលាចំណែកឯទូកធំលើកដងថែវផុតពីទឹក ហើយបណ្តែតគ្រឿនៗមកខាងទទឹងសំពៅដើម្បីខិតជិតល្មមស្រែកហៅគ្នាលឺបាន ។ នៅពេលដែលឃើញទូកលើកដងថែវដាក់បណ្តោយទូកហើយមកនៅចំមុខកាណុងចំហៀងសំពៅរបស់ខ្លួនហើយទើបគេបែរមុខរកខ្យល់ ហើយរង់ចាំអោយទូកខិតចូលមកជិតខ្លួនបាន ។ អរគុណព្រះជាម្ចាស់ ដែលបានធ្វើអោយអា *អ៊ីញគីលីស* អត់មានកាណុងបែបនេះ -*រ៉ូឌ្រិច* គិតនៅក្នុងចិត្ត ។ អាកូនមីចោរនេះ ឈ្លាសវៃមែនតែម្រង់ ។

ប៉ុន្តែម៉្យាងដែរ មានដៃគូសុទ្ធតែជាអ្នកថ្លឹក ជាអ្នកជើងចាស់យ៉ាងនេះ -រ៉ូឌ្រិច គិតក្នុងចិត្ត -វាធានាសន្តិសុខជាងព្រោះគ្មានអ្នកណានាំភ្លីភ្លើ នាំតែមានរឿងឥតប្រយោជន៍ផង

- សុំឡើងលើសំពៅផងបានទេ ?

- អ្នកណាសុំឡើង *អ៊ីញគីលីស* ?

- លោកម្ចាស់ *តូរ៉ាណាកា* អ្នកបកប្រែរបស់លោក និងពួកអង្គ្លេស ។

*វ៉េរីវ៉ា* និយាយយ៉ាងនឹងនរ :

- គ្មានអង្គ្លេសទេ !

*អាលវីតូ* តប :

- គាត់ត្រូវតែមាននាំយកមកជាមួយខ្លះហើយ ព្រោះអាណឹងជារឿងមុខមាត់ណា ។

- គ្មានមុខគ្មានមាត់រវល់យក៍អីទេ ។ គ្មានអង្គ្លេសអីទេ ។

*រ៉ូឌ្រិច* ងក់ក្បាលឯកភាព :

- ខ្ញុំមិនចង់អោយពួកសាមូរ៉ៃឡើងសំពៅទេ ។

- តើលោកឯកភាពលើចំនួនប្រាំនាក់ទេ ?-*អាលវីតូ* សួរ -ត្រឹមតែពួកអង្គ្លេសផ្ទាល់របស់គាត់តែប៉ុននោះ ។ លោកយល់ពីបញ្ហានេះហើយ *រ៉ូឌ្រិច* ។

រ៉ូឌ្រិច គិតមួយសន្ទុះ ទើបងក់ក្បាលឯកភាព :

- បាន ! ប្រាំនាក់ លោកមេបញ្ជាការ ។ យើងនឹងចាត់តាំងមនុស្សប្រាំនាក់ជា



www.budinst.gov.kh www.elibraryofcambodia.org

"អង្គរ័ក្សផ្ទាល់" ដោយអោយម្នាក់១កាំភ្លើងខ្លីពីរដើម ។ តេជគុណ សូមតេជគុណចាត់ចែងកំនត់រឿងរ៉ាវនេះជាលំអិតទៅទៀតចុះ ។ លោកមេបញ្ជាការ យកល្អទុកអោយព្រះតេជគុណចាត់ចែងរឿងពិធីការទាំងនេះចុះ លោកដឹងពីរបៀបធ្វើយ៉ាងម៉េច១ជាង ។ តេជគុណអញ្ជើញចុះ តែសូមប្រាប់ពួកយើងវិញពីរឿងនិយាយគ្នាយ៉ាងម៉េច១នោះ ។

*អាលវីតូ* ដើរទៅតែមសំពៅហើយស្រែកខ្លាំង១ :

- អែងកុហកយ៉ាងណាក៏គ្មានបានការដែរ ! ត្រៀមងាប់ទាំងអស់គ្នាទៅ ! នៅសល់ដប់នាទីទៀត លោកមេបញ្ជាការនឹងបាញ់កំទេចទូកពួកអែងអោយម៉ត់ហើយ ។

- ព្រះអើយព្រះ មិនឃើញយើងបង្ហូតទង់លោកម្ចាស់ *តូរ៉ាណាកា* ទេអ្វី !

- ទង់ក្លែងក្លាយទេ អាមេចោរសមុទ្ទ !

*កែរីរ៉ា* ដើរមកសួរ *អាលវីតូ* :

- តើតេជគុណកំពុងលេងល្បិចអីហ្នឹង ?

*អាលវីតូ* តប :

- សូមលោកអត់ធ្មត់សិនណា លោកមេបញ្ជាការ ។ នេះគឺគ្រាន់តែរបៀបចែចូវតែប៉ុននោះ ។ បើមិនអញ្ចឹងទេ *តូរ៉ាណាកា* អាចខឹងជារៀងរហូតព្រោះយើងមើលងាយទង់របស់គាត់ ។ នេះគឺជា *តូរ៉ាណាកា* ណា មិនមែនជា *ដៃមីញ៉ូ* ធម្មតានោះទេ ! លោកគួរចាំថា *តូរ៉ាណាកា* មានទ័ពផ្ទាល់ខ្លួនគាត់ច្រើនជាងទ័ពរបស់ព្រះរាជាប្រទេសអេស្ប៉ាញទៅទៀត ។

សំលេងខ្យល់ដែលជ្រែកកាត់ខ្សែក្តោង និងខ្សែយោងលាន់លឺដូចសំលេងថ្ងូរ ចន្លុះត្រូវបានបំភ្លឺឡើង នៅលើកិងទូកធំ ។ ពេលនេះគេអាចមើលឃើញ *តូរ៉ាណាកា* យ៉ាងច្បាស់ ។ សំលេងរបស់លោករត់កាត់ផ្ទៃសមុទ្ទមកដល់សំពៅ :

- *ឈូតូ-សាន* ហេតុអីបានជាលោកហ៊ានគេចពីទូកខ្ញុំយ៉ាងនេះ ? នៅទីនេះគ្មានចោរសមុទ្ទអីទាំងអស់ ។ ពួកចោរសមុទ្ទមានតែនៅលើទូកនេសាទដែលនៅឯមាត់កំពង់ផែឯនោះទេ ។ ខ្ញុំចង់ចូលអែបទូកអីលូវនេះ ។

*អាលវីតូ* ស្រែកតប ដោយធ្វើអាការៈដូចជាភ្ញាក់ផ្អើល :



www.budinst.gov.kh www.elibraryofcambodia.org

- សូមអភ័យទោស លោកម្ចាស់ *តូរ៉ាណាកា* តែពួកយើងឥតដឹងសោះមែនតែម្តង ។ ពួកយើងស្មានតែនេះជាល្បិចអីមួយហើយ ។ ពួកអាវប្រផេះបាននិយាយថាពួក *វ៉ូទីន*-ចោរព្រៃបានប្រើកំលាំងបាយដណ្តើមយកទូកធំនេះ ! អញ្ចឹងហើយ បានជាយើងស្មានថាអាចោរសមុទ្រអង់គ្លេសនេះបានដឹកនាំពួកចោរព្រៃដោយប្រើទង់ក្លែងក្លាយ ។ ខ្ញុំទៅទូកលោកម្ចាស់ អីលូវនេះហើយ ។

- ទេចាំខ្ញុំទៅអែបទូកក្បែរសំពៅនោះតែម្តង ។

- កុំអីលោកម្ចាស់ *តូរ៉ាណាកា* សូមអនុញ្ញាតអោយខ្ញុំទៅជូនដំណើរលោកមកទីនេះវិញ ។ ប្រធានខ្ញុំ គឺព្រះតេជគុណអធិការសង្ឃ និង លោកមេបញ្ជាការក៏នៅទីនេះដែរ ។ លោកទាំងពីរទាមទារអោយយើងខ្ញុំលុបលាងអំពើខុសឆ្គងនេះ ។ សូមលោកម្ចាស់អភ័យទោសដល់ពួកយើងខ្ញុំផង !

រួច *អាលវីតូ* ស្រែកជាភាសាប៉័កទុយកាលវិញម្តង :

- ទំលាក់ឡុងបុតចុះ !

រួចលោកងាកទៅរក *តូរ៉ាណាកា* ដោយប្រើភាសាជប៉ុន :

- ទូកត្រូវទំលាក់ចុះហើយ លោកម្ចាស់ !

*វ៉ូគ្រិច* ឈរស្តាប់នូវសំលេងពោរពេញដោយភាពទន់ភ្លន់ គួរអោយជ្រិញឆ្អើមរបស់ *អាលវីតូ* ហើយគិតក្នុងចិត្តថា ទំនាក់ទំនងជាមួយពួកជប៉ុនពិតជាយ៉ាប់ជាងទំនាក់ទំនងជាមួយចិនទៅទៀត ។ ពួកចិនយល់ពីសិល្បៈនៃការចរចា ការសំរបសំរួល យល់ពីសម្បទាន និងការផ្តល់រង្វាន់ ។ ចំនែកឯពួកជប៉ុនវិញគឺពេញហៀរដោយមោទនភាព ហើយនៅពេលដែលមោទនភាពរបស់បុរសម្នាក់ត្រូវប៉ះពាល់ហើយ ការស្លាប់គឺជាថ្លៃដ៏ថោកមួយដើម្បីជូសជុលការប្រមាថនេះ ។ ហើយមោទនភាពនេះមានសំរាប់ពួកជប៉ុនតែទាំងអស់មិនមែនសំរាប់តែពួកសាមូរ៉ៃប៉ុននោះទេ ។ អោយលឿនៗទៅ ដោះស្រាយកិច្ចការអោយចំៗតែម្រង់ទៅ -*វ៉ូគ្រិច* ស្រែកក្នុងពោះ ។

- លោកមេបញ្ជាការខ្ញុំទៅហើយ -*អាលវីតូ* និយាយ-តេជគុណ ! បើសិនជាតេជគុណអញ្ជើញមកជាមួយផងនោះការផ្តល់កិត្តិយសនេះ នឹងអាចធ្វើអោយ *តូរ៉ាណាកា* ស្ងប់ចិត្តបានហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំឯកភាព ។

*កែរីភ* លូកមាត់ :

- ក្រែងប្រថុយប្រថានពេកទេដឹង ? គេអាចយកតេជគុណទាំងពីរជាចំនាប់ខ្មាំងបាន ណា ។

*ដែឡាក្វា* តប :

- នៅពេលណាដែលមានសញ្ញាថាមានល្បិចកិច្ចកលអ្វី ខ្ញុំបញ្ជាក្នុងនាមព្រះជាម្ចាស់ អោយលោកបាញ់កំទេចទូកនេះ និងពួកដែលនៅជិះលើទូកនេះទាំងប៉ុន្មានចោលទាំងអស់ ទោះ ជាមានពួកយើងនៅលើទូកនោះ វីអត់ក្តី ។

រួចលោកចុះពីលើកិងទៅក្រោម ដើរតាមបណ្តោយសំពៅកាត់ជួរកាណុងដែលដាក់តំ រៀបតាមគែមសំពៅនោះ ។ នៅពេលទៅដល់ក្បាលជណ្តើរ លោកបែរខ្លួនមកវិញ ហើយធ្វើ សញ្ញាខ្វែង រួចទើបលោកចុះតាមជណ្តើរទៅអង្គុយក្នុងទូក ។

មេទូកចាប់ផ្តើមអោយសញ្ញាចេញដំណើរ ។ នាវិកទាំងអស់សុទ្ធតែប្រដាប់ដោយកាំ ភ្លើងខ្លីគ្រប់ៗគ្នា ហើយរំសេវមួយធុងត្រូវបានលាក់នៅក្រោមកន្លែងអង្គុយរបស់មេទូក ។

*កែរីភ* អោនរំលងគែមសំពៅហើយស្រែកយ៉ាងនឹងនរ :

- ព្រះតេជគុណនាំអាទមិឡនោះមកជាមួយផង ។

- ថាម៉េច ? លោកថាម៉េចណឹង ?

*ដែឡាក្វា* ឆ្លើយតបទាំងអស់សំនើចនៅក្នុងចិត្ត ដោយលោកចូលចិត្តបង្វិលមេបញ្ជាការ ដ៏ក្រអឺតក្រទមនេះ ។ សំនើរបស់ *កែរីភ* តាមពិតទៅជាបំនងដែលលោកមានជាយូរណាស់មក ហើយដែរ ហើយម្យ៉ាងទៀតនៅពេលនេះលោកលឺសំនើរបស់បុរសនេះច្បាស់ណាស់ ។ អ្វែងចំជា ស្ទក់មែន -លោកគិតនៅក្នុងចិត្ត ។

*កែរីភ* ស្រែកប្រាប់ម្តងទៀត :

- នាំអាទមិឡនោះមកជាមួយផងណា ?

នៅឯលើកិង *រ៉ូទ្រិច* លឺសូរសំលេងល្វើយៗថា : " បាទលោកមេបញ្ជាការ " ហើយគេ



www.budinst.gov.kh www.elibraryofcambodia.org

គិតនៅក្នុងចិត្តស្វែងរកពីល្បិចអ្វីដែល *រ៉េក់រីក* ប្រុងសំដែងក្នុងពេលនេះ ។

គេគំរើកខ្លួនលើកៅអីទាំងឈឺចាប់ និងទាំងមុខស្លេកស្លាំង ។ ការឈឺចាប់នៅក្នុងជើងរបស់គេមិនខុសពីច្នេញដ៏កំនាចមួយដែលកំពុងហែកហួរសាច់នោះឡើយ ហើយ *វ៉ូទ្រិច* ត្រូវប្រើអស់ថាមពលរបស់ខ្លួនដើម្បីតទល់នឹងការឈឺចាប់នេះ ។ គេស្រវាយកផ្លោកស្រាដែលនៅព្យួរក្បែរនោះ មកផឹកមួយក្អឹក ។

*រ៉េក់រីក* សំលឹងមើល *វ៉ូទ្រិច* ឥតដាក់ភ្នែក ៖

- ឈឺជើងខ្លាំងអ្វី ?

សុរាហាក់ដូចជួយរំងាប់ការឈឺចាប់បានបន្តិច ៖

- អត់ទេ ។

- មើលទៅ ធ្វើដំណើររួចទេពីណឹងរហូតដល់ *ម៉ាកាវ* ?

- បាន ! ធ្វើដំណើរក៏បាន ប្រយុទ្ធលើទឹកម៉ារហូតផ្លូវនេះក៏បានហើយត្រលប់មកទីនេះវិញនៅរដូវផ្ការីកនេះយ៉ាងទាន់ពេលវេលាទៀតផង ។ ក្រែងចង់និយាយអញ្ចឹងអ្វី ?

បបូរមាត់ *រ៉េក់រីក* ឡើងស្តើងហើយវាសជាស្នាមញញឹមមួយបែបចំអក ៖

- ណឹងហើយ ខ្ញុំចង់មានន័យថាអញ្ចឹង ។ ខ្ញុំត្រូវការតែកុងពូកែណា ។

*វ៉ូទ្រិច* ប្រឹងបំភ្លេចការឈឺចាប់នៅក្នុងជើងខ្លួន ៖

- សូមអភ័យទោស ។ ជើងខ្ញុំតវិញស្រួលបួលហើយ ។ ចំនែកៈរឿងលោកផ្តាំព្រះតេជគុណ *វែឡាកា* អំបាញ់មិញនេះ ខ្ញុំគិតថាអា *អ៊ុញតិលីស* វានឹងមិនឡើងសំពៅយើងទេ ។ បើសិនជាខ្ញុំវិញក៏ខ្ញុំមិនមកដែរ ។

- ខ្ញុំដាក់មួយរយ *តីទេ* បើដូចអែងថា !

- នេះគឺច្រើនលើសប្រាក់ខែខ្ញុំម៉ាឆ្នាំហើយណា !

- បើអែងឈ្នះ លុយនេះនឹងអោយអែងភ្លាមនៅពេលយើងទៅដល់ *លីស្បោន* ហើយខ្ញុំកាត់លុយនេះលើប្រាក់ចំនេញរបស់ *សំពៅខ្មៅ* ទៅចុះ ។

- យល់ព្រម ! គ្មានអ្វីអាចអោយវាព្រមមកឡើងទូកយើងដោយស្ម័គ្រចិត្តឡើយ ។ ខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

ច្បាស់ជាមានបានមួយរយ *ភីរេ* ទៀតហើយ ។

- ក្រែងខាតទេដឹង ? អែងភ្លេចហើយថា ពួកយេស៊ុតចង់អោយវាមកទីនេះ ខ្លាំងជាងខ្ញុំទៅទៀតណា ។

- ហេតុអ្វីបានជាពួកគាត់ចង់បែបនេះ ?

*កែរីកា* សំលឹងមើល *រ៉ូត្រិច* ដោយទឹកមុខធម្មតា ប៉ុន្តែឥតឆ្លើយនឹងសំនួររបស់ *រ៉ូត្រិច* ឡើយ ។ នៅស្ងៀមមួយសន្ទុះ ទើប *កែរីកា* និយាយ :

- ខ្ញុំសុខចិត្តជូន *តូរ៉ាណាកា* ចេញពីច្រកផែនេះ អោយតែបានអាទមិឡនោះជាថ្នូរ ។

*រ៉ូត្រិច* តបវិញ :

- ខ្ញុំសប្បាយចិត្តណាស់ដែលខ្ញុំជាមិត្តរបស់អែង ជាមនុស្សចាំបាច់សំរាប់អែង និងសំរាប់ *សំពៅខ្មៅ* ។ ខ្ញុំមិនចង់ក្លាយជាសត្រូវរបស់អែងទេ ។

- ខ្ញុំក៏សប្បាយចិត្តណាស់ដែរ ដែលយើងយល់ចិត្តគ្នាយ៉ាងនេះ តែកុង ។

*********

- ខ្ញុំចង់អោយគេជូនខ្ញុំចេញផុតពីច្រកសមុទ្រនេះ ។ ខ្ញុំត្រូវការបន្ទាន់ណាស់ ។

*តូរ៉ាណាកា* និយាយទៅកាន់ *ដែឡាក្វា* តាមរយៈបំនកប្រែរបស់ *អាល់វីតូ* ។ នៅក្បែរនោះ *ម៉ារីកូ* ឈរស្ដាប់យ៉ាងស្ងៀមស្ងាត់ដោយមាន *យ៉ាប៊ូ* នៅជិតនាងផង ។ *តូរ៉ាណាកា* ឈរលើរានក្បាលទូក *ដែឡាក្វា* និង *អាល់វីតូ* នៅលើតូកណ្ដាលនៃទូកតែទោះជាយ៉ាងនេះក្ដី ក៏ភ្នែករបស់អ្នកទាំងបី នៅក្នុងកំពស់ប្រហាក់ប្រហែលគ្នា ។

*តូរ៉ាណាកា* និយាយបន្ត :

- រឺមួយបើសិនជាលោកចង់ សំពៅចំបាំងរបស់លោកពិតជាអាចបំបែកទូកនេសាទទាំងនេះចេញផុតពីផ្លូវខ្ញុំបាន ។

- សូមលោកម្ចាស់អភ័យទោសផងចុះ ។ បើធ្វើយ៉ាងនេះគឺពិតជាអំពើជាសត្រូវឥតត្រឹមត្រូវមួយដែលលោកម្ចាស់មិនគួរមានសំនើដល់សំពៅនេះទេ ។



www.budinst.gov.kh www.elibraryofcambodia.org

*ដែឡាក្វា* និយាយទៅកាន់ *តូរ៉ាណាកា* ដោយផ្ទាល់តែម្តង ដោយលោករង្កៀសនឹងបំនកប្រែភ្លាម១របស់ *អាលរីតូ* ។ លោកបន្ត :

- ធ្វើយ៉ាងនេះមិនកើតទេ ។ នេះគឺជាសង្គ្រាមចេញមុខទៅហើយ ។

- បើអញ្ចឹង តើលោកមានយោបល់យ៉ាងម៉េច ?

- សូមលោកម្ចាស់អញ្ជើញទៅសំពៅដើម្បីសួរលោកមេបញ្ជាការ *វ៉េរីរ៉ា* ទៅទាន ។ អីលូវនេះពេលដែលពួកយើងយល់ពីបញ្ហារបស់លោកម្ចាស់ហើយ លោកមេបញ្ជាការពិតជារកឃើញរបៀបដោះជាមិនខាន ។ គាត់ជាយោធា ឯពួកយើងគឺមិនមែនទេ ។

- នាំគាត់មកលើទូកនេះមក ។

- បើសិនជាលោកម្ចាស់អញ្ជើញទៅសំពៅនោះ ប្រហែលជាចំនេញពេលជាង ។ ម្យ៉ាងទៀតដូចជាលោកម្ចាស់ផ្តល់កិត្តិយសដល់ពួកយើងខ្ញុំផង ។

*តូរ៉ាណាកា* យល់ច្បាស់ណាស់ពីស្ថានភាពពិតប្រាកដរបស់លោក ។ ថ្វីត្បិតតែអីលូវនេះពួកលោកស្ថិតក្នុងទីសុខប៉ុន្តែយ៉ាងយូរកន្លះម៉ោងទៀតមាត់ច្រកសមុទ្រនេះនឹងពេញស្ទះដោយបច្ចាមិត្តជាមិនខាន ។

ហើយលោកដឹងច្បាស់ណាស់ថា លោកគ្មានជំរើសអ្វីឡើយ ។

ប៉ុន្មានពេលមុននេះ *អាន់ជីន-សាន* បានប្រាប់លោករួចទៅហើយនៅក្នុងពេលប្រដេញគ្នាលើផ្ទៃទឹកនោះ :

- សូមអភ័យទោសទាន ! ខ្ញុំមិនអាចចូលជិតសំពៅបានទេ ។ *រ៉ូឌ្រិច* វាឆ្លាតមែន ។ បើសិនជាគ្មានខ្យល់ ខ្ញុំអាចបញ្ឈប់សំពៅនេះមិនអោយគេចបាន តែមិនអាចរុញវាអោយទ័លច្រកបានទេ លើកលែងតែ រ៉ូឌ្រិច វាភាន់ច្រលំ ។ មើលទៅយើងត្រូវចរចាជាមួយពួកវាហើយ ។

*តូរ៉ាណាកា* សួរទៅវិញតាមរយៈ *ម៉ារីតូ* :

- តើមានឃើញសញ្ញាភាន់ច្រលំទេ ? តើខ្យល់អាចឈប់រីទេ ?

រួច *ម៉ារីតូ* បកត្រលប់វិញ :

- *អាន់ជីន-សាន* និយាយថាមនុស្សវង្វេងវៃមិនត្រូវភ្ញាល់រឿងខ្យល់ទេ លើកលែងតែ



www.budinst.gov.kh www.elibraryofcambodia.org

យើងទៅឯលំហសមុទ្ទ ប៉ុន្តែកន្លែងនេះគឺជាឆកកំពង់ផែ ហើយភ្នំធ្វើអោយខ្យល់ប្រែប្រួលយ៉ាងងាយ ។ ហើយ *វ៉ុទ្រិច* ពិតជាមិនធ្វើអ្វីដែលជាការភាន់ច្រលំនោះទេ ។

*តូរ៉ាណាកា* បានតាមសង្កេតតែកុងទាំងពីរនៅក្នុងពេលប្រដេញឆ្មាអំបាញ់មិញនេះ ហើយលោកដឹងថាអ្នកទាំងពីរនេះគឺពិតជាកំពូលតៃកុងតែម្តង ។ នៅពេលនេះហើយ ទើបលោកចាប់ផ្តើមយល់ថាទាំងរូបលោក ទាំងតំបន់លោក ទាំងចក្រភពនេះនឹងពិតជាមិនបានសុខឡើយ បើសិនជាគ្មានសំពៅទំនើបៗរបស់ពួកចុងស្រុក ហើយតាមរយៈសំពៅទំនើបទាំងនេះ ទើបអាចត្រួតត្រាលើសមុទ្ទផ្ទាល់របស់ខ្លួនបាន ។ ការយល់ឃើញនេះ ស្រាប់តែក្លាយជាធ្ងន់ពាប់ចំពោះលោកតែម្តង ។

*អាល់ប៊ីតូ* និយាយទៅកាន់ *តូរ៉ាណាកា* ម្តងទៀត :

- លោកម្ចាស់ ខ្ញុំគិតថាយើងគួរចេញដំណើរក្នុងពេលអីលូវនេះទៅទាន ។

*តូរ៉ាណាកា* ឯកភាព :

- ល្អ ! *យ៉ាប៊ូ-សាន* លោកទទួលបញ្ជាទូក ។ *ម៉ារីកូ-សាន* នាងប្រាប់ទៅ *អាន់ជីន-សាន* អោយទៅកាន់ចង្កូតឯកិងទូកចុះ រួចនាងទៅជាមួយខ្ញុំ ។

- ចាស លោកម្ចាស់ ។

វាជាការច្បាស់ណាស់ទៅហើយចំពោះ *តូរ៉ាណាកា* ដែលថាទូកទំហំទូកឡុងបុតនេះអាចអោយលោកយកអង្គរក្សយ៉ាងច្រើនត្រឹមប្រាំនាក់នោះ ។ ប៉ុន្តែចំនុចនេះក៏ត្រូវបានព្យាករហើយស្រេចដែរ ហើយផែនការចុងក្រោយគឺសែនសាមញ្ញ : បើសិនជា *តូរ៉ាណាកា* មិនអាចនិយាយមេបញ្ជាការអោយជួយបានទេ អង្គរក្សលោកនឹងសំលាប់ *វ៉េរីរ៉ា* ពួកតៃកុង ហើយនឹងពួកបព្វជិតរួចពួកលោកខ្ទប់ខ្លួននៅក្នុងបន្ទប់ណាមួយ ។ ទន្ទឹមនេះទូកចំនឹងសំរុកចូលទៅរកសំពៅចំពីមុខដូចតាមផែនការដែល *អាន់ជីន-សាន* បានលើកឡើង ហើយនឹងពួតដៃគ្នាដណ្តើមកាន់កាប់សំពៅដោយកំលាំងបាយ ។ រឺមួយពួកគេដណ្តើមសំពៅបាន រឺមួយពួកគេដណ្តើមមិនបាន តែនេះគឺជាដំណោះស្រាយយ៉ាងឆាប់រហ័សបំផុត ។

- នេះគឺជាផែនការល្អមែន *យ៉ាប៊ូ-សាន -តូរ៉ាណាកា* និយាយ ។



www.budinst.gov.kh www.elibraryofcambodia.org

- សូមលោកអោយខ្ញុំទៅចរចាជំនួសលោកចុះទាន ។

- ពួកវាច្បាស់ជាមិនព្រមទេ ។

- ល្អ ! តែនៅពេលណាដែលយើងចេញផុតពីអន្ទាក់នេះហើយ ត្រូវតែបណ្ដេញពួកចុងស្រុកទាំងអស់ចេញពីនគរយើងទៅ បើលោកធ្វើយ៉ាងនេះលោកនឹងមាន *ដៃមីញ៉ូ* ជាច្រើនមកខាងលោកជាងអ្នកដែលបែកចេញពីលោកទាន ។

- ចាំខ្ញុំគិតពីរឿងនេះ !

*តូរ៉ាណាកា* ឆ្លើយតបទាំងដឹងច្បាស់នៅក្នុងចិត្តថា នេះចំជាភ្លីភ្លើមែនទែនតែម្ដង ព្រោះលោកត្រូវការពួក *ដៃមីញ៉ូ* គ្រីស្ដសាសនិក *អូណូស៊ី* និង *គីយ៉ាម៉ា* មកនៅខាងលោក ហើយតាមរយៈនេះពួក *ដៃមីញ៉ូ* គ្រីស្ដសាសនិកនឹងមកខាងលោក បើមិនយ៉ាងដូចនេះទេ លោកនឹងត្រូវតែព្រួចាក់លេបជាមិនខាន ។ ហេតុអីបានជា *យ៉ាប៊ូ* ចង់ឆ្លងទៅខាងសំពៅនោះ ? តើវាមានល្បិចកិច្ចកលអីទៅបើសិនជាមិនបានជំនួយនោះ ?

*អាលវីតូ* និយាយជំនួស *ដៃឡាក្កា* :

- លោកម្ចាស់ តើខ្ញុំអាចអញ្ជើញ *អាន់ជីន-សាន* ទៅឡើងសំពៅជាមួយទេទាន ?

- ហេតុអី ?

- ព្រោះខ្ញុំទើបគិតឃើញថា គាត់ប្រហែលជាពេញចិត្តនឹងជួបសហសេវិករបស់គាត់គឺ *អាន់ជីន-រ៉ូឌ្រិច* ។ បុរសនោះបាក់ជើងទើបមិនអាចមកទីនេះបាន ។ *រ៉ូឌ្រិច* មានបំណងចង់ជួបបុរសនេះម្ដងទៀត ដើម្បីថ្លែងអំណរគុណចំពោះប្រការដែលបុរសនេះបានជួយជីវិតខ្លួន ។ បើសិនជាលោកម្ចាស់មិនយល់ទាស់ទេ ។

*តូរ៉ាណាកា* យល់ថា គ្មានហេតុផលអីដែល *អាន់ជីន -សាន* ទៅមិនបានឡើយ ។ បុរសនេះស្ថិតនៅក្រោមកិច្ចគាំពាររបស់លោក ហេតុនេះគ្មានអ្នកណាហ៊ានប៉ះពាល់បានឡើយ :

- បើសិនជា *អាន់ជីន-សាន* ចង់ក៏ល្អ ។ *ម៉ារីកូ-សាន* ជូន *ឈូតូ-សាន* !

*ម៉ារីកូ* លំអោនខ្លួនគោរព ។ នាងដឹងថា ភារកិច្ចរបស់នាងគឺស្ដាប់និងរាយការណ៍ហើយអ្វីៗដែលបាននិយាយត្រូវតែបានរាយការណ៍យ៉ាងត្រឹមត្រូវឥតមានរំលង ឥតមានចោល



www.budinst.gov.kh www.elibraryofcambodia.org

កន្លែងណាឡើយ ។ អីលូវនេះ នាងបានស្រួលខ្លួនជាងមុនហើយ១សក់ និងមុខត្រូវបានរៀបចំស្អាតបាតឡើងវិញ ។ នាងពាក់អាវគីម៉ូណូដែលខ្ចីពី *ភូជីកូ* ហើយស្លាមរបួសត្រូវបានសំអាតនឹងរុំយ៉ាងស្រួលបួល ។

នាងអមដំណើរបព្វជិត *អាឈើវិតូ* ទៅកិងទូកនៅកន្សែ ។ បព្វជិត *អាឈើវិតូ* ប្រទះឃើញកាំបិតខ្លីស៊ៀតនឹងខ្សែក្រវ៉ាត់នៅនឹងចង្កេះរបស់ *ប្លាក់ថន* ព្រមទាំងអាវគីម៉ូណូប្រលាក់នោះផង ។ តើអានេះវាជ្រែកចូលក្នុងទំនុកចិត្តរបស់ *តូរ៉ាណាកា* ត្រឹមណាហើយអញ្ចេះ ?-លោកគិតនៅក្នុងចិត្ត ។

- ចំជាជូនត្លាល្អមែន លោកមេបញ្ជាការ តែកុង *ប្លាក់ថន* ។

*ប្លាក់ថន* តបវិញ ទាំងទឹកមុខរាក់ទាក់ :

- សូមតេជគុណ រលត់រលាយខ្លួនទៅស្ថាននរកចុះ !

- ប្រហែលជាយើងជួបគ្នាទៀតនៅកន្លែងនោះជាមិនខាន *អាន់ជីន-សាន* ។ ប្រហែលជានឹងជួបគ្នាមែនណា ។ *តូរ៉ាណាកា* និយាយថា អែងអាចឡើងទៅសំពៅនោះបានណា ។

- នេះជាបញ្ជារបស់គាត់អ្ហី ?

- គាត់ថា " បើអែងចង់ " ។

- ខ្ញុំមិនចង់ទេ ។

- *វ៉ូន្រ៊ិច* វាចង់អរគុណអែងម្តងទៀត ម្យ៉ាងទៀតវាចង់ជួបអែងផង ។

- ផ្តាំសួរសុខទុក្ខវាជំនួសខ្ញុំផង ហើយថាថ្ងៃមួយខ្ញុំជួបវានៅឋាននរក ថ្ងៃមួយនៅទីនេះ ។

- ជើងវាមិនអាចអោយវាមកទីនេះបានទេ ។

- ជើងវាយ៉ាងម៉េចទៅហើយ ?

- កំពុងសះហើយដោយបានអែងជួយ និងគុណបុណ្យព្រះ ។ ប៉ុន្មានអាទិត្យទៀតវាអាចដើរបានហើយ តែវាត្រូវខ្ចើចជើងម៉ាអាយ៉ូសហើយ ។

- ប្រាប់វាផងថា ខ្ញុំសូមជូនពរវា ។ អីលូវនេះព្រះតេជគុណល្មមត្រលប់ទៅវិញហើយកុំអោយខាតពេល ។



www.budinst.gov.kh www.elibraryofcambodia.org

- *វ៉ូត្រិច* វាចង់ជួបអែងណា ។ មានស្រាទៅលើតុ មាន់ក្រៀវរ៉ូទី មាននំបុ័ងថ្មី១ ហើយនំបីរក្តៅ១ផង ។ ម្ហូបឆ្ងាញ់យ៉ាងណឹង បោះបង់វាចោលគឺចំជាស្តាយមែន ។

- ថាម៉េច ?

- មាននំបុ័ងថ្មី១ លឿងដូចមាស នំទើបចំហុយ មានបឺរ មានសាច់គោម៉ាកំភ្លៅ ក្រួចស្រស់ពី *កូវ៉ា* ហើយនឹងមានស្រាទំពាំងបាយជូ មានប្រិនឌី ប៊ីយែរ សំរាប់អមម្ហូបនេះផង ។ រួចកុំភ្លេចមាន់ក្រៀវពី *ម៉ាកាវ* ខ្លាញ់រងើមយ៉ាងឆ្ងាញ់ណា ។

- សូមព្រះបញ្ជូនលោកអែងទៅចុះនរកអោយបាត់ទៅ !

- ព្រះលោកនឹងធ្វើ បើព្រះអង្គចង់ធ្វើ តែនេះខ្ញុំគ្រាន់តែប្រាប់អែងពីអីដែលមានទេតើ ។

ពេលនេះបព្វជិត *អាលវីតូ* បានមើលឃើញបំលាស់ប្តូរច្បាស់នៅលើផ្ទៃមុខរបស់ *ភ្លាក់ថន* ។ លោកស្ទើរតែឃើញទឹកមាត់ហូរធ្លាក់ពីមាត់ *ភ្លាក់ថន* ហើយស្ទើរតែលឺពោះកូរគ្រូកគ្រាក់របស់បុរសនេះថែមទៀត ។ លោកយល់ពីអារម្មណ៍នេះយ៉ាងច្បាស់ព្រោះថ្វីត្បិតតែលោកមិនខ្វះម្ហូប រឺលោកមិនមានទំលាប់ទទួលទានម្ហូបផប៉ុនក្តី ក៏នៅយប់នេះពេលដែលឃើញម្ហូបអាហារ ទីកន្លែងដែលរៀបចំយ៉ាងស្អាតនោះ លោកស្រក់ទឹកមាត់ឡើងទន់លោងទៅហើយដែរ ។

គិតទៅក្តាប់មនុស្សម្នាក់ងាយស្រួលមែនទែន -បព្វជិត *អាលវីតូ* គិតនៅក្នុងចិត្ត ។ អ្វីដែលសំខាន់គឺប្រើនុយអោយត្រូវតែប៉ុននោះ ។

- សូមលាហើយលោកមេបញ្ជាការតែកុង !

រួចលោកក៏ត្រលប់ខ្លួនដើរសំដៅទៅរកជណ្តើរចំហៀងតួទូក ។ *ភ្លាក់ថន* ដើរតាមពីក្រោយលោកភ្លាម ។

******************



www.budinst.gov.kh www.elibraryofcambodia.org

- រួចចុះអែងកើតអីហ្នឹង *អ៊ីញ៉ូតីលើស* ? -*វ៉ូទ្រិច* សួរ ។

*ប្លាក់ថន* កំពុងឈរយ៉ាងញ៉ូរទទ្រើតនៅកណ្ដាលតួសំពៅ :

- ឯណាគ្រឿងស៊ីចុក ? ស៊ីហើយសឹមនិយាយគ្នា តែដំបូងបង្អស់គឺម្ហូបអាហារដែលអែងសន្យានោះសិន ។

*អាលវីតូ* ពោលទៅកាន់ *ប្លាក់ថន* :

- សូមលោកអញ្ជើញមកតាមខ្ញុំមក ។

- តេជគុណចង់នាំវាទៅណា ?

- ទៅបន្ទប់ធំណា ។ *ប្លាក់ថន* អាចនៅស្រស់ស្រូបក្នុងពេលដែល *តូវ៉ាណាកា* និងលោកមេបញ្ជាការជជែកគ្នាបានដែរតើ ។

- ទេ វាទៅហូបនៅបន្ទប់ខ្ញុំបានហើយ ។

- ទៅកន្លែងដាក់ម្ហូបតែម្ដងទៅ វាស្រួលជាង ។

- មេកង ! មើលរៀបចំម្ហូបអោយតែកុងនេះភ្លាមទៅ ! យកគ្រប់ម្ហូបណាដែលវាចង់ទៅក្នុងបន្ទប់ខ្ញុំ យកតែទាំងអស់របស់ដែលនៅលើតុជប់លៀងនោះមក ។ *អ៊ីញ៉ូតីលើស* អែងចង់ផឹកស្រាខ្លាំង រឺស្រាទំពាំងបាយជូរ ប៊ីយែរ ?

- ដំបូងប៊ីយែរ រួចសិមស្រាខ្លាំងតាមក្រោយ ។

- មេកងនាំវាចុះទៅក្រោមទៅ ។ ហើយស្ដាប់ខ្ញុំណា *រប៉េសារ៉ូ* មើលខោអាវខ្ញុំនៅក្នុងទូហើយអោយវាខ្លះផង អោយស្បែកជើងកវែង និង អី១សព្វគ្រប់ណា ។ ហើយនៅជាមួយវារហូតដល់ពេលខ្ញុំហៅ ។

ដោយគ្មាននិយាយស្ដីអ្វីមួយមាត់ *ប្លាក់ថន* ដើរតាមមេកងឈ្មោះ *រប៉េសារ៉ូ* ចុះទៅក្រោម ។ *អាលវីតូ* ក៏វិលទៅរក *តូវ៉ាណាកា* និង *វ៉ៃឡាក្កា* ដែលកំពុងជជែកគ្នាតាមរយៈ *ម៉ារីតូ* ប៉ុន្តែ *វ៉ូទ្រិច* ឃាត់លោកភ្លាម :

- តេជគុណ ! តើតេជគុណនិយាយប្រាប់វាថាម៉េចខ្លះ ?

- មានប្រាប់ថាម៉េច ? គ្រាន់តែថា លោកចង់ជួបវាហើយនៅលើសំពៅមានម្ហូបពោរ



www.budinst.gov.kh www.elibraryofcambodia.org

ពាសតែប៉ុនណឹង ។

- រួចថាខ្ញុំចែកម្ហូបអាហារអោយវាអ្វី ?

- ទេ ! អត់ទេ *រ៉ូឌ្រិច* ! ខ្ញុំអត់មាននិយាយអញ្ចឹងទេ ។ តែតើលោកដាច់ចិត្តមិនរំលែកម្ហូបអាហារដល់តៃកុងគ្នាឯងដែលកំពុងឃ្លានដែរអ្វី ?

- អាប្រកាច់នេះមិនមែនឃ្លានទេគឺវាកំពុងដាច់ពោះតែម្រ៉ង ។ អត់បែបនេះបើបានស៊ីវិញវាត្របាក់លេបដូចចចកដាច់ពោះអញ្ចឹង រួចពេលនោះវានឹងក្អួតចេញវិញតែទាំងអស់ណឹង ។ តេជគុណគិតមើល តើយើងចង់អោយពួកយើង ទោះជាអ្នកនោះជាទមិឡក្ដី ក្អួតចាក់ទីងដូចសត្វធាតុមុខ *តូរ៉ាណាកា* អាកូនមីចោរសំ.....ណុងអ្វី ?

- លោកគួររៀនទប់មាត់ឥតគ្រប់របស់លោកខ្លះទៅ -*អាលវីតូ* ពោលឡើង -និយាយពាក្យអាសគ្រោមយ៉ាងនេះ នាំបាបណាកូនប្រុស ។ លោកគួរសូត្រខមាទោសមួយពាន់ដង ហើយតមម្ហូបអាហារអោយបានពីរថ្ងៃទៅ ។ ទទួលទានតែនំបុ័ង និងទឹកបានហើយ ដើម្បីលាងបាប ។

- អរគុណណាស់ ព្រះតេជគុណ ខ្ញុំនឹងធ្វើតាម ហើយខ្ញុំនឹងរៀនទប់មាត់ឥតគ្រប់របស់ខ្ញុំអោយបាន ។

*កែរីវ៉ា* ស្រែកហៅពីមាត់ជណ្ដើរក្រោមសំពៅ :

- *រ៉ូឌ្រិច* ចុះក្រោមទេ ?

- ខ្ញុំនៅលើនេះហើយ ដរាបណាអាទូកចោលម្រ៉ាយនោះនៅក្រវែលកន្លែងនេះ លោកមេបញ្ជាការ ។ បើលោកត្រូវការខ្ញុំ១នៅកន្លែងនេះ ។

*អាលវីតូ* ចាប់ផ្ដើមដើរទៅតាមអ្នកឯទៀត តែពេលនោះ *រ៉ូឌ្រិច* ប្រទះភ្នែកនឹង *ម៉ារីកូ*

- ឈប់មួយភ្លែតតេជគុណ ។ ស្រីនោះជាអ្នកណា ?

- *ដូណាម៉ារីយ៉ា តូដា* ។ ជាអ្នកបកប្រែម្នាក់របស់ *តូរ៉ាណាកា* ។

*រ៉ូឌ្រិច* ហួចក្ដៅ :

- នាងណើងបកល្អទេ ?

- ល្អណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- ចំជាឆោតមែនដែលយល់ព្រមអោយនាងឡើងសំពៅនេះ ។ ព្រះតេជគុណថាម៉េច អំបាញ់មិចនេះ ? ថា " *តូដា* " មែនទេ ? តើនាងជាប្រពន្ធចុងម្នាក់ក្នុងចំនោមប្រពន្ធចុងទាំងអស់របស់អាកញ្ញាស់ *តូដា ហ៊្សី-ម៉ាត់ស៊ី* អ្វី ?

- ទេ នាងជាកូនប្រសារគាត់ទេ ។

-អោយនាងនេះឡើងសំពៅចំជាឆ្កួតតែម្ដង ។

*វ៉ុន្ទ្រិច* ធ្វើសញ្ញាហៅនាវិកម្នាក់មកប្រាប់ :

- ដើរប្រាប់គ្រប់គ្នាភ្លាមទៅ ថាស្រីនោះចេះភាសាប៉័កទុយកាល់ ។

- បាទទាន ។

រួចនាវិកនោះរត់ចេញទៅភ្លាម ហើយ *វ៉ុន្ទ្រិច* ក៏ងាកទៅរកបព្វជិត *អាល់វីតូ* វិញ ។ *អាល់វីតូ* និយាយបន្តទៀតដោយឥតញ្ញោចអ្វីនឹងកំហឹងរបស់ *វ៉ុន្ទ្រិច* បន្តិចណាឡើយ :

- អ្នកស្រី *ម៉ារីយ៉ា* ក៏និយាយភាសាឡាតាំងផងដែរ ល្អដូចភាសាប៉័កទុយកាល់អញ្ចឹងដែរ ។ មានការអីទៀតទេ តៃកុង ?

- អត់ទេ មើលទៅខ្ញុំគិតទៅខមាទោសអោយហើយតែម្ដងទៅ ។

- ពិតហើយ លោកគួរតែធ្វើអោយហើយទៅ ។

ក្រោយពីធ្វើសញ្ញាខ្វែងរួច *អាល់វីតូ* ក៏ចាកចេញទៅ ។ *វ៉ុន្ទ្រិច* ស្ដោះទឹកមាត់ឆ្វាច់ដាក់តាមទបង្អៀវទឹកធ្វើអោយអ្នកកាន់ចង្កូតសំពៅដែលនៅក្បែរនោះជ្រួញចិញ្ចើម ហើយធ្វើសញ្ញាខ្វែងខ្លួនឯងទៅវិញ ។

******************



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៧

- វាពិតជាមានផ្លូវដោះរួចមែនទេលោកមេបញ្ជាការ ? - *ដែឡាក្វា* និយាយយ៉ាងអត់ធ្មត់ ។

- តើតេជគុណចង់មានសង្គ្រាមជាចំហជាមួយប្រទេសមួយដែលជាមិត្តអញ្ចឹងអ្វី ?

- ទេ ។

គ្រប់គ្នាដែលនៅក្នុងបន្ទប់ធំសុទ្ធតែដឹងយ៉ាងច្បាស់ថា ពួកគេកំពុងនៅក្នុងអង្គប់តែមួយហើយ ។ រាល់សកម្មភាពជាចំហ នឹងរុញពួកគេអោយទៅខាង *តូរ៉ាណាកា* ប្រឆាំងនឹង *អ៊ីស៊ីដូ* ភ្លាម ។ ប្រការនេះពួកគេត្រូវតែចៀសវាងជាដាច់ខាត ដើម្បីងាយមានច្រកចេញនៅក្នុង ករណីដែល *អ៊ីស៊ីដូ* ក្លាយទៅជាអ្នកឈ្នះ ។ អីលូវនេះ *អ៊ីស៊ីដូ* ក្តាប់ *អូសាកា* និងរាជធានី *ក្យូតូ* ហើយនឹងភាគច្រើននៃសមាជិកក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ។ ហើយពេលនេះ តាមរយៈ *ដៃមីញ៉ូ អូណូស៊ី* និង *គីយ៉ាម៉ា អ៊ីស៊ីដូ* វាតអំនាចស្ទើរតែពេញភាគខាងត្បូងនៃកោះ *ក្យូស៊ូ* ទៅហើយ ។ និយាយពី*ក្យូស៊ូ* គឺនិយាយពីផែ *ណាកាសាគី* ដែលជាមណ្ឌលធំនៃរាល់ជំនួញដូរ ហើយជាកន្លែងដែល *សំពៅខ្មៅ* នឹងចូលចតនៅឆ្នាំនេះផង ។

*តូរ៉ាណាកា* និយាយតាមរយៈ *អាលវីតូ* :

- ហេតុអីក៏លំបាកម្ល៉េះ ? ខ្ញុំគ្រាន់តែចង់អោយលោកបាញ់ទំលាយទូកពួកចោរសមុទ្រអស់នោះចេញពីច្រកកំពង់ផែទេតើ ?

*តូរ៉ាណាកា* អង្គុយយ៉ាងរសាប់រសល់នៅលើកៅអីកិត្តិយស ដែលមានបង្អែកយ៉ាងខ្ពស់មួយក្បែរតុធំ ។ *អាលវីតូ* នៅអង្គុយក្បែរលោក មេបញ្ជាការអង្គុយទល់មុខ *តូរ៉ាណាកា* ដោយមាន *ដែឡាក្វា* នៅក្បែរខ្លួនផង ។ *ម៉ារីកូ* ឈរពីក្រោយ *តូរ៉ាណាកា* ឯពួកសាមូរ៉ៃ ជាអង្គរក្សនៅរង់ចាំក្បែរទ្វទល់មុខគ្នានឹងពួកនាវិកប្រដាប់អាវុធ ។ ថ្វីត្បិតតែពួកអឺរ៉ុប នៅក្នុងបន្ទប់ទាំងអស់សុទ្ធតែដឹងថាបព្វជិត *អាលវីតូ* ជាអ្នកបកប្រែជូន *តូរ៉ាណាកា* នូវអ្វីៗដែលត្រូវបាននិយាយនៅក្នុងបន្ទប់នេះក្តី ក៏ *ម៉ារីកូ* មានវត្តមាននៅទីនេះដើម្បីធានាថាគ្មានអ្វីដែលពួកគេអាចជជែកគ្នាជាចំហប្រឆាំងនឹងផលប្រយោជន៍លោកម្ចាស់របស់នាងបានឡើយ ទទ្ទឹមនឹងធានាថាការបកប្រែគឺបាន



www.budinst.gov.kh www.elibraryofcambodia.org

ត្រឹមត្រូវហើយអស់សព្វគ្រប់ ។

*ដៃឡាកា* អោនខ្លួនពីលើតុ :

- រឺមួយលោកម្ចាស់អាចបញ្ជូនទីរសាររឡើងគោកទៅជូប *អ៊ីស៊ីដូ* ទៅ ? ជូនកាលច្រកចេញវានៅលើការចរចាគ្នាក៏មានដែរ ។ យើងខ្ញុំអាចជូនសំពៅនេះជាកន្លែងអព្យាក្រឹតសំរាប់កិច្ចចរចា ។ ធ្វើអញ្ចឹងលោកម្ចាស់អាចដោះស្រាយរឿងសង្គ្រាមនេះផងក៏មិនដឹង ។

*តូរ៉ាណាកា* ផ្ទុះសំនើចចំអក :

- សង្គ្រាមអីទៅ ? *អ៊ីស៊ីដូ* និងខ្ញុំឥតមានធ្វើសង្គ្រាមនឹងគ្នាឯណា ?

- តែពួកយើងបានឃើញការប្រយុទ្ធគ្នានៅលើច្រាំងអំបាញ់មិញនេះទេតើ ។

- កុំទ្រើកពេក ! អ្នកណាត្រូវគេសំលាប់ ? ពួក *រ៉ូនីន* កំទេចកំទីប៉ុន្មាននាក់ណឹង ? អ្នកណាវៃប្រហារអ្នកណា ? តែពួក *រ៉ូនីន* ពួកចោរព្រៃ ហើយនឹង ពួកឡប់ខូវតែប៉ុនណឹង ?

- រួចចុះរឿងពួនស្នាក់នោះ ? គេបានប្រាប់ពួកយើងថា ពួកអាវត្នោតប្រយុទ្ធគ្នានឹងពួកអាវប្រផេះណា ។

- ពួកចោរបានវៃលុកមកលើពួកយើងទាំងអស់គ្នាណឹង ទាំងពួកអាវត្នោតទាំងពួកអាវប្រផេះ ។ កូនចៅខ្ញុំប្រយុទ្ធដើម្បីការពារខ្ញុំតែប៉ុនណឹង ។ ក្នុងពេលយប់អញ្ចឹង ការប៉ះច្រលំគ្នាវាចៀសមិនរួចទេ ។ បើមានពួកអាវត្នោតសំលាប់ពួកអាវប្រផេះ រឺពួកអាវប្រផេះសំលាប់ពួកអាវត្នោតនេះ វាជាការភាន់ច្រលំមួយដ៏សោកស្តាយតែប៉ុននោះ ។ តើមនុស្សប៉ុន្មាននាក់ណឹងមានសារសំខាន់អីទៅចំពោះយើងនេះ ? គ្មានអីទាំងអស់ ។ ពួកយើងឥតមានសង្គ្រាមទេ ។

*តូរ៉ាណាកា* សំលឹងឃើញទឹកមុខគ្មានជំនឿរបស់អ្នកឯទៀត ។ លោកនិយាយបន្ថែម :

- *ឈូតូ-សាន* ប្រាប់ពួកគេទៅថានៅជប៉ុនទ័ពត្រូវធ្វើសង្គ្រាម ។ អារឿងប៉ះទង្គិចកំប៉ិចកំប៉ុក អារឿងប៉ងធ្វើឃាត អានេះវាជារឿងចាក់ក្រលេកសាកទេតើ បើវាមិនកើតទេគេចោលទៅ ។ សង្គ្រាមមិនមែនចាប់ផ្តើមនៅយប់នេះទេ វាចាប់ផ្តើមនៅពេលដែលអម្ចាស់ *តៃកូ* ស្លាប់ឯនោះ ។ រឺអាចថាមុននេះផងព្រោះគាត់ស្លាប់ដោយគ្មានកូនប្រុសធំណាម្នាក់នៅស្នងខ្លួនសោះ ។ រឺអាចថាតាំងពីពេលដែលលោកម្ចាស់ *គូរ៉ូដា* ត្រូវគេធ្វើឃាតម្លេះ ។ យប់នេះគ្មានអត្ថន័យអ្វីទាំង



www.budinst.gov.kh www.elibraryofcambodia.org

អស់ ។ ក្នុងពួកលោកទាំងអស់គ្នាគ្មានអ្នកណាម្នាក់យល់ពីនគរយើង រឺយល់ពីនយោបាយរបស់ពួកយើងឡើយ ។ តើធ្វើម៉េចលោកយល់បាន ? ពិតហើយ *អ៊ីស៊ីដូ* បានសាកល្បងសំលាប់ខ្ញុំមែន ។ ក៏ដូចជាពួក *វៃមីញូ* ដទៃទៀតជាច្រើនដែរ ។ ពួកវាបានធ្វើបែបនេះកាលពីអតីតកាល ហើយ វានឹងធ្វើទៀតនៅពេលអនាគត ។ *គីយ៉ាម៉ា* និង *អូណូស៊ី* គឺជាមិត្តផង និងជាសត្រូវផង ។ ស្តាប់ខ្ញុំណា បើគេសំលាប់ខ្ញុំបាននេះគឺអ្វី១ វាងាយស្រួលសំរាប់ *អ៊ីស៊ីដូ* ដែលជាសត្រូវពិតប្រាកដនោះហើយ តែបានតែមួយរយៈទេ ។ ខ្ញុំជាប់អន្ទាក់វាហើយនៅពេលនេះហើយបើអន្ទាក់នេះបានជោគជ័យ វាពិតជាមានប្រៀបមួយ រយៈ ។ បើខ្ញុំគេចរួច អន្ទាក់នេះគ្មានន័យអ្វីទាំងអស់ ។ ប៉ុន្តែអស់លោកទាំងអស់គ្នាត្រូវយល់ អោយច្បាស់ណា ! ការស្លាប់របស់ខ្ញុំ នឹងមិនអាចលុបចោលមូលហេតុនាំអោយមានសង្គ្រាមរឺ អាចបង្ការមិនអោយមានទំនាស់បន្តទៅទៀតនោះឡើយ ។ មានតែការស្លាប់របស់ *អ៊ីស៊ីដូ* ទេដែលអាចបញ្ចប់ទំនាស់បាន ។ហេតុនេះគ្មានរឿងសង្គ្រាមជាចំហឡើយ ។

*តូរ៉ាណាកា* ប្រែបង្គុយទៅលើកៅអី ។ នៅក្នុងចិត្ត លោកសែនស្អប់ក្លិនក្នុងបន្ទប់នេះដែលបង្កឡើងដោយម្ហូបសមុទ្ទសុទ្ធតែប្រេង និងខ្លួនប្រាណមនុស្សដែលមិនបានលុបលាងចេញនេះជាពន់ពេក ។ លោកបន្តទៅទៀត :

- ប៉ុន្តែយើងមានបញ្ហាចំពោះមុខជាបន្ទាន់ ។ ខ្ញុំត្រូវការកាណុងរបស់លោក ។ ខ្ញុំចង់បានវាអីលូវនេះ ។ ពួកចោរសមុទ្ទកំពុងស្ទាក់ផ្លូវខ្ញុំនៅឯច្រកកំពង់ផែ ។ មុននេះខ្ញុំបាននិយាយហើយ *ឈូតូ-សាន* ថាក្នុងពេលឆាប់ៗនេះ ម្នាក់ៗត្រូវជ្រើសរើសថាខ្លួនត្រូវនៅខាងណា ។ ពេលនេះតើរូបលោក អ្នកដឹកនាំលោក ហើយនឹងវិហារគ្រីស្តទាំងមូលឈរនៅខាងណា ?ហើយតើមិត្តប៊ិកទុយកាល់ខ្ញុំនេះនៅតែជាមិត្ត រឺក្លាយជាសត្រូវនឹងខ្ញុំ ?

*ដែឡាក្វា* តប :

- សូមលោកម្ចាស់ *តូរ៉ាណាកា* កុំព្រួយបារម្ភអី ពួកយើងគាំទ្រផលប្រយោជន៍របស់លោកទាំងអស់គ្នាណឹង ។

- ល្អ ! បើអញ្ចឹងចាត់ការអាចោរសមុទ្ទអស់នោះទៅ !

*វ៉េរីរ៉ា* និយាយ :



www.budinst.gov.kh www.elibraryofcambodia.org

- ណឹងគឺជាការប្រកាសសង្គ្រាមហើយវាគ្មានចំនេញអីទាំងអស់ ។ រឺមួយយើងអាចដាក់ផុកជាមួយគ្នាសិន អ្វី ?

*អាលីវីត្ត* ឥតបានបកស់ដីនេះទេ តែលោកពោលពន្យល់ទៅវិញ :

- លោកមេបញ្ជាការនិយាយថា ពួកយើងគ្រាន់តែមិនចង់លូកដៃចូលរឿងនយោបាយរបស់លោកតែប៉ុននោះ ។ ពួកយើងគ្រាន់តែជាឈ្មួញប៉ុននោះ ។

*ម៉ារីកូ* និយាយជាភាសាជប៉ុនទៅកាន់ *តូរ៉ាណាកា* ភ្លាម :

- សូមអភ័យទោសលោកម្ចាស់ បកនេះឥតត្រឹមត្រូវទេ ។ មិនមែនគេនិយាយបែបនេះទេ ។

*អាលីវីត្ត* ដកដង្ហើមធំ :

- ខ្ញុំគ្រាន់តែសំរួលពាក្យខ្លះរបស់គាត់តែប៉ុននោះ លោកម្ចាស់ ។ លោកមេបញ្ជាការជាអ្នកចំនួលថ្មី ដោយហេតុនេះគាត់មិនសូវយល់ដឹងពីរបៀបរបបខ្លះៗនៅឡើយ ។ គាត់ឥតទាន់យល់ដឹងអីពីប្រទេសជប៉ុននៅឡើយ ទាន ។

*តូរ៉ាណាកា* សួរតបទៅវិញ :

- ចុះលោកវិញ លោកយល់ហើយអ្វី ? *ឈូតូ-សាន* ?

- ខ្ញុំប្រឹងស្វែងយល់ ទាន ។

- ចុះអំបាញ់មិញ លោកមេបញ្ជាការនិយាយថាម៉េច ?

*អាលីវីត្ត* និយាយប្រាប់ *តូរ៉ាណាកា* ។

ក្រោយពីនៅស្ងៀមស្ងាត់បន្តិចមក លោកក៏និយាយឡើង :

- *អាន់ជីន-សាន* បានប្រាប់ខ្ញុំថា ពួកប័កទុយកាល់យកចិត្តទុកដាក់ពីរឿងជួញដូរហើយក្នុងរឿងជួញដូរពួកប័កទុយកាល់ឆ្អិនក្បាលស៊ីក្បាល ឆ្អិនកន្ទុយស៊ីកន្ទុយហើយ ។ ខ្ញុំយល់ពីរឿងនេះហើយខ្ញុំទទួលយកការបកស្រាយរបស់លោក *ឈូតូ-សាន* ។ តែចាប់ពីពេលនេះទៅសូមលោកបកអោយបានគ្រប់ម៉ាត់ដែលបាននិយាយចេញណោះ។

- បាទ ទាន ។



www.budinst.gov.kh www.elibraryofcambodia.org

- ជំរាបទៅលោកមេបញ្ជាការថា : នៅពេលដែលរឿងទំនាស់ត្រូវបានដោះស្រាយ ហើយខ្ញុំនឹងពង្រីករឿងជួញដូរហើយ ។ ខ្ញុំជាអ្នកគាំទ្ររឿងជួញដូរ ឯ *អ៊ីស៊ីដូ* គឺអត់ទេ ។

*ដៃឡាកា* លូកមាត់ចូលនិយាយ ដោយសង្ឃឹមថា *អាលវីតូ* ចេះនិយាយលប់លាងភាពល្ងាក់ល្ងើរបស់ *វ៉ែរីរ៉ា* នេះ :

- ពួកយើងមិនមែនជាអ្នកនយោបាយទេ ទាន ។ ពួកយើងជាសាសនិក ហើយពួកយើងតំនាងផ្លូវធម៌តែប៉ុននោះ ។ ប៉ុន្តែពួកយើងគាំទ្រផលប្រយោជន៍របស់លោកម្ចាស់ មែនណា ។

- ខ្ញុំឯកភាពហើយៗ ខ្ញុំកំពុងពិចារ......

*អាលវីតូ* ឈប់បកប្រែមួយខណៈដោយទុកអោយ *តូរ៉ាណាកា* និយាយជប៉ុនមួយប្រាវទៅមុន ។ ទឹកមុខរបស់លោកឡើងស្រស់បស់មួយរំពេច ។ រួចទើបលោកបន្តបកទៅទៀត :

- ខ្ញុំសូមអភ័យទោស ព្រះតេជគុណ ! *តូរ៉ាណាកា* មានប្រសាសន៍ថា " ខ្ញុំកំពុងពិចារណាពីរឿងស្នើរបស់លោក កសាងព្រះវិហារមួយ ។ ព្រះវិហារដ៏ធំមួយនៅឯ *យេដូ* ដែលជាសញ្ញានៃទំនុកចិត្តរបស់ខ្ញុំទៅលើផលប្រយោជន៍របស់លោក " ។

ជាច្រើនឆ្នាំមកហើយ គឺតាំងពី *តូរ៉ាណាកា* ឡើងជាស្តេចគ្រាញ់លើខេត្តទាំងប្រាំបីម្ល៉េះ *ដៃឡាកា* បានប្រើគ្រប់វិធីដើម្បីសម្បទាននេះ ។ អីលូវនេះការយល់ព្រមអោយមានព្រះវិហារនៅក្នុងទីក្រុងដ៏ធំទីបីនៃចក្រភព គឺចំជាសម្បទានកាត់ថ្លៃមិនបាន ។ ពេលនេះ ព្រះតេជគុណគណៈអធិការសង្ឃដឹងថា ពេលវេលាដោះស្រាយពីរឿងកាណុងបានមកដល់ហើយ ។

- អរគុណលោកម្ចាស់ផង *ម៉ាកតាំង លូតូ-សាន*.......

*ដៃឡាកា* ប្រើពាក្យសញ្ញាសំគាល់ដែលបានឯកភាពជាមួយ *អាលវីតូ* ក្នុងន័យថាខ្លួនលោកយល់ព្រមលូកដៃហើយ :

- ហើយជំរាបលោកម្ចាស់ថា ជានិច្ចកាលយើងតែងស្វះស្វែងបំរើផលប្រយោជន៍របស់លោក ។ អូមែន ! សួរលោកមើលតើលោកមានគំនិតយ៉ាងម៉េចពីរឿងព្រះវិហារនេះ ?

- មើលទៅ ទុកអោយខ្ញុំនិយាយខ្លួនឯងម៉ាក្លែតសិនចុះ ទាន ។

រួច *អាលវីតូ* ងាកទៅរក *តូរ៉ាណាកា* :



www.budinst.gov.kh www.elibraryofcambodia.org

- ព្រះតេជគុណខ្ញុំសូមអរគុណលោកម្ចាស់ ហើយមានប្រសាសន៍ថាអ្វីដែលលោកម្ចាស់បានស្នើពីពេលមុននេះអាចទៅរួច ទាន ។ ព្រះតេជគុណខ្ញុំមានប្រសាសន៍ថា លោកតែងប្រឹងប្រែងគាំទ្រលោកម្ចាស់ជានិច្ច ។

- ប្រឹងប្រែងជាសំដីអរូប ហើយក៏មិនគ្រប់គ្រាន់ដែរ ។

- ប្រាកដមែនហើយ !

*អាលវីតូ* ចោលភ្នែកសំលឹងទៅពួកអង្គរក្សដែលកំពុងផ្ទៀងត្រចៀកស្តាប់ ដោយធ្វើបែបវាហ៊ី :

- តែលោកម្ចាស់បានមានប្រសាសន៍ពីពេលមុនថា ជួនកាលក៏ជាការវាងវៃដែរ ដែលត្រូវយល់ពីភាពអរូបនេះ ។

*តូរ៉ាណាកា* យល់ភ្លាម ។ លោកលើកដៃ បណ្តេញអង្គរក្សរបស់លោក :

- ពួកឯងទាំងអស់គ្នា ទៅចាំនៅខាងក្រៅចុះ

អង្គរក្ស *តូរ៉ាណាកា* ទទួលធ្វើតាមទាំងទើសទាល់ ។ *អាលវីតូ* ក៏ងាកទៅរក *វ៉ាកឺរ៉ា* :

- អីលូវនេះយើងឥតត្រូវការឆ្មាំរបស់លោកទៀតទេ លោកមេបញ្ជាការ ។

នៅពេលដែលពួកសាមូរ៉ៃ និងពួកឆ្មាំប៉ិកទុយកាល់ចេញអស់ហើយ *វ៉ាកឺរ៉ា* ចោលភ្នែកសំលឹងមើល *ម៉ារីកូ* ម្តង ។ នៅនឹងចង្កេះរបស់លោកមានកាំភ្លើងខ្លីពីរដើម ហើយនឹងមួយដើមទៀតទៅស៊កនឹងស្បែកជើងកវែង ។

*អាលវីតូ* និយាយទៅរក *តូរ៉ាណាកា* :

- លោកម្ចាស់ អនុញ្ញាតអោយលោកស្រី *ម៉ារីកូ* អង្គុយទៅវីអី ?

*តូរ៉ាណាកា* យល់ភ្លាម ។ លោកសញ្ជឹងគិតមួយភ្លែត រួចងក់ក្បាលបន្តិចហើយនិយាយដោយឥតចាំបាច់ងាកក្រោយឡើយ ។

- *ម៉ារីកូ-សាន* យកអង្គរក្សខ្ញុំម្នាក់ទៅតាមរក *អាន់ជីន-សាន* ទៅ ។ រួចនៅជាមួយគាត់រហូតដល់ពេលខ្ញុំប្រើគេទៅហៅណា

- ចាស លោកម្ចាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

ទ្វារត្រូវបិទជិតទៅវិញនៅពេលដែល *ម៉ារីកូ* ចេញផុតទៅ ។

អីលូវនេះ ពួកគេនៅតទល់គ្នាតែបួននាក់គត់ ។

*កែវីរ៉ា* សួរភ្លាមតែម្តង :

- តើគាត់ដាក់អីជាថ្នូរ ? ជារបស់ស្អី ?

*វែឡាក្វា* ឆ្លើយដោយគោះរូបឆ្លាងរបស់លោកបណ្ឌើរ សូត្រធម៌ក្នុងពោះបណ្ដើរដើម្បីជ័យជំនះនៃផែនការរបស់លោក :

- ត្រូវចេះអត់ធ្មត់ខ្លះទៅ លោកមេបញ្ជាការ ។

*អាលវ៉ីតូ* ក៏ចាប់ផ្ដើមពោលទៅកាន់ *តូរ៉ាណាកា* :

- លោកម្ចាស់ ! តេជគុណគណៈរបស់ខ្ញុំមានប្រសាសន៍ថាអ្វីៗដែលលោកមានសំនូមពរលោកនឹងប្រឹងប្រែងធ្វើអោយអស់ពីលទ្ធភាព ។ ក្នុងរវាងសែសិបថ្ងៃ ។ លោកនឹងបញ្ជូនដំណឹងជាសំងាត់មកជំរាបលោកម្ចាស់ពីជំហានរីកចំរើននៅក្នុងការងារនេះ ។ បើសិនជាលោកម្ចាស់យល់ព្រម ខ្ញុំនឹងធ្វើជានារសារក្នុងរឿងនេះ ។

- រួចចុះបើគាត់ធ្វើមិនបានសំរេច ?

- ត្រូវតែបាន ទោះជាត្រូវប្រឹងប្រែង ត្រូវបញ្ចុះបញ្ចូល រឺ ប្រើកលល្បិចយ៉ាងណាក៏ដោយ ។ លោកគណៈសូមសន្យានឹងលោក ។

- នៅចំពោះមុខព្រះគ្រីស្ត ?

- បាទនៅចំពោះមុខព្រះគ្រីស្ត ។

- ល្អខ្ញុំចង់បានកិច្ចសន្យានេះជាលាយលក្ខណ៍អក្សរ ហើយត្រូវប្រថាប់ត្រាផង ។

- ជូនកាលកិច្ចព្រមព្រៀងមែនទែន កិច្ចព្រមព្រៀងសំខាន់ៗមិនស្ថិតនៅត្រឹមជាលាយលក្ខណ៍អក្សរទេ ទាន ។

- ក្រែងលោកបាននិយាយថាបើសិនជាខ្ញុំមិនធ្វើកិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរទេលោកនឹងមិនព្រមទេអ្វី ?

- សំខាន់ខ្ញុំចាំប្រសាសន៍លោកមួយឃ្លាដែលថា កិត្តិយសរបស់សាមូរ៉ៃគឺមានសារសំ



www.budinst.gov.kh www.elibraryofcambodia.org

ខាន់ជាងក្រដាសមួយសន្លឹកទៅទៀត ។ ព្រះតេជគុណគណៈអធិការសង្ឃបានផ្តល់សំដីរបស់លោក នៅចំពោះមុខព្រះជាម្ចាស់ នេះជាសំដីកិត្តិយសដូចកិត្តិយសរបស់សាមូរ៉ៃដែរ ។ កិត្តិយសរបស់លោកម្ចាស់គឺពិតជាគ្រប់គ្រាន់ចំពោះតេជគុណគណៈអធិការសង្ឃ ។ ខ្ញុំគិតថាបើយើងនៅតែមិនទុកចិត្តគ្នានោះគឺពិតជាការមួយគួរអោយស្តាយមែនទែន ។ តើលោកចង់អោយខ្ញុំសុំព្រះតេជគុណគណៈអធិការសង្ឃចុះហត្ថលេខាមែនរឺ ?

នៅទីបំផុត *តូរ៉ាណាកា* តបវិញ :

- ល្អ ! សំដីសន្យានៅចំពោះមុខព្រះភក្ត្រព្រះគ្រីស្តណា ?

- ខ្ញុំសូមសន្យាជំនួសព្រះតេជគុណគណៈអធិការសង្ឃ ទាន ។ ព្រះតេជគុណបានស្បថដោយយកព្រះជាបន្ទាល់ថានឹងប្រឹងជួយលោកហើយ ។

- លោកក៏អញ្ចឹងដែរ *ឈូតូ-សាន* ?

- ខ្ញុំសូមសន្យាដោយយកព្រះជាបន្ទាល់ ថាខ្ញុំនឹងធ្វើសព្វបែបយ៉ាងតាមលទ្ធភាពរបស់ខ្ញុំ ដើម្បីព្រះតេជគុណគណៈអធិការសង្ឃសំរេចបានក្នុងការបញ្ចុះបញ្ចូលលោកម្ចាស់ *អូណូស៊ី* និង *គីយ៉ាម៉ា* អោយក្លាយទៅជាសំព័ន្ធមិត្តរបស់លោកម្ចាស់ ។

- ខ្ញុំក៏សន្យានឹងធ្វើអ្វីដែលខ្ញុំបានសន្យាមុននេះដែរ ។ នៅថ្ងៃទីសែសិបមួយលោកអាចបញ្ចុះបឋមសិលាចាក់គ្រឹះវិហារគ្រីស្តសាសនាដ៏ធំបំផុតនៅក្នុងចក្រភពនេះបានហើយ ។

- តើយើងអាចនិយាយគ្នាពីទីកន្លែងសាងសង់នៅពេលនេះតែម្តងទៅបានទេ ទាន ?

- ចាំពេលខ្ញុំទៅដល់ *យេដូ* សិន ។ ចុះយ៉ាងម៉េចហើយរឿងអាពួកចោរសមុទ្រនោះ ? អាចោរសមុទ្រក្នុងទូកនេសាទនោះណា ? ដល់ពេលបណ្តេញពួកវាចេញហើយមែនទេ ?

- បើសិនជាលោកម្ចាស់មានកាណុង តើលោកអាចចាត់ការនេះដោយខ្លួនឯងបានទេ ទាន ?

- ពិតជាបាន *ឈូតូ-សាន* ។

- ខ្ញុំសូមអធ្យាស្រ័យចំពោះរឿងក្រវិចក្រវៀនយ៉ាងនេះ ប៉ុន្តែយើងត្រូវលើកផែនការជាមុនសិន ។ កាណុងទាំងនេះ មិនមែនជារបស់យើងខ្ញុំទេ ។ សូមលោកម្ចាស់ទុកពេលអោយខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

បានមួយភ្លែតសិនទាន ។

រួច *អាលវីតូ* ងាកទៅរក *ដៃឡាក្វា* :

- អ្វី១ទាក់ទិនទៅនឹងវិហារធំត្រូវបាននិយាយចែចូវត្រូវរ៉ូវគ្នាអស់ហើយ ទាន ។

ហើយលោកក៏និយាយទៅកាន់ *វែភីរ៉ា* តាមផែនការដែលបានឯកភាពជាមុនរវាងបព្ជិតទាំងពីរហើយ :

- លោកគួរតែសប្បាយចិត្តទៅ ដែលលោកមិនបានបាញ់ពន្លិចគាត់នោះ លោកមេបញ្ជាការ ។ លោកម្ចាស់ *តួរ៉ាណាកា* សួរថា តើលោកអាចដឹកមួយម៉ឺនឌុយកាតមាសអោយលោកបានទេនៅពេលដែលលោកចេញ*សំពៅខ្មៅ*ទៅ *គូវ៉ា* នោះ ព្រោះលោកចង់យកទៅវិនិយោគនៅឯផ្សារមាសឥណ្ឌា ។ ពួកយើងអាចប្រាប់បណ្ដាញពួកយើងដែលនៅទីនោះអោយជួយសំរួលការវិនិយោគមាសនេះសំរាប់លោកបាន ។ លោកម្ចាស់ *តួរ៉ាណាកា* និយាយថា លោកនឹងចែកប្រាក់ចំនេញពាក់កណ្ដាលជូនលោក ។

ទាំង *អាលវីតូ* ទាំង *ដៃឡាក្វា* សុទ្ធតែបានឯកភាពកំនត់ថា នៅពេលដែល*សំពៅខ្មៅ*ត្រលប់មកដល់ទីនេះវិញក្នុងរយៈពេលប្រាំមួយខែខាងមុខទៀតនេះ *តួរ៉ាណាកា* អាចរឹមួយឡើងកាន់កាប់ជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ហើយនៅពេលនោះពិតជារីករាយនឹងផ្ដល់ការអនុញ្ញាតរបស់លោកលើការជួញដូរដ៏បានផលសំបើមនេះ រឺមួយលោកនឹងត្រូវស្លាប់ជាមិនខាន ។

*អាលវីតូ* បន្ត :

- លោកអាចស៊ីប្រាក់ចំនេញបានបួនពាន់ឌុយកាតណា ! ហើយឥតចាំបាច់ប្រថុយស្បែកអីទាំងអស់ ។

- បានប៉ុនហ្នឹងដើម្បីប្ដូរយកស្អីទៅ ? លុយប៉ុនហ្នឹងវាលើសប្រាក់ឧបត្ថម្ភដែលព្រះចៅក្រុងអេស្ប៉ាញឧបត្ថម្ភសមាគមយេស៊ូរបស់ពួកព្រះតេជគុណនៅអាស៊ីទាំងមូលក្នុងមួយឆ្នាំ១ទៅទៀត ។ មើល តើជាថ្នូរនឹងអីទៅ ?

- លោកម្ចាស់ *តួរ៉ាណាកា* មានប្រសាសន៍ថាពួកចោរសមុទ្រនៅរាំងផ្លូវលោកមិនអោយចេញពីកំពង់ផែរួច ហើយលោកដឹងច្បាស់ជាងលោកមេបញ្ជាការទៅទៀតថា ពួកចោរសមុទ្ទ រឺ



www.budinst.gov.kh www.elibraryofcambodia.org

មិនមែននោះ ។

*កែរីភា* ឆ្លើយតបវិញដោយសំលេងយ៉ាងធម្មតា ហាក់ដូចជាជជែកគ្នាដើម្បីផលប្រយោជន៍របស់ *តួរ៉ាណាកា* តែប៉ុណ្ណោះ :

- មិនមែនជាគំនិតល្អប៉ុន្មានទេ ដែលតេជគុណដាក់សេចក្តីទុកចិត្តលើគាត់នេះ ។ សត្រូវរបស់វាកាន់សន្ទឹកអាត់អស់ហើយ ស្តេចគ្រីស្តសាសនិកទាំងប៉ុន្មានប្រឆាំងវាទាំងអស់ ។ច្បាស់ជាងគេគឺពួកអាធំ១ពីរនាក់នោះ ។ ខ្ញុំលឺអាពីរនាក់នោះនិយាយគ្នាដោយផ្ទាល់នឹងត្រចៀកខ្ញុំ ។ ពួកវានិយាយថាអាតយនេះទើបជាសត្រូវពិតប្រាកដ ។ ខ្ញុំជឿអាពីរនាក់នោះជាងអាកូនមីចោរម្រាយនេះ ។

*វ៉េឡាកា* លូកមាត់និយាយម្តង ដោយឥតញញោចនឹងសំដីរបស់ *កែរីភា* ឡើយ :

- ខ្ញុំជឿច្បាស់ណាស់ថាលោកម្ចាស់ *តួរ៉ាណាកា* ដឹងច្បាស់ជាងពួកយើងទៅទៀតថាពួកណាជាចោរសមុទ្ទ ពួកណាមិនមែននោះ ។ ខ្ញុំគិតថាលោកមេទ័ពគ្មានទំនាស់អ្វីនឹងរឿងដែល *តួរ៉ាណាកា* ចាត់ការពួកចោរសមុទ្ទដោយខ្លួនលោកផ្ទាល់ឡើយ មែនទេ ?

- ពិតជាអត់ទេ !

គណៈអធិការសង្ឃពោលបន្ត :

- នៅលើសំពៅនេះ លោកនៅមានកាណុងមួយគំនរគោកដែរ ។ ហេតុអីក៏មិនជូនទៅគាត់ខ្លះជាឯកជនទៅ ។ និយាយស្រួលស្តាប់ លក់ជូនគាត់ទៅណា ។ លោកលក់អាវុធរាល់តែពេលទេតើ ។ គាត់ទិញអាវុធ ។ កាណុងបួនគឺវាគ្រប់គ្រាន់ណាស់ទៅហើយ ។ សាងកាណុងទាំងនេះទៅដាក់លើឡុងបុតវាងាយទេ ។ ហើយលក់ទាំងរំសេវ និងគ្រាប់ជាឯកជនថែមទៀតទៅ ។ ដល់អញ្ចឹងទៅរឿងអី១វាដោះស្រាយរួចទៅហើយ ។

*កែរីភា* ដកដង្ហើមធំ :

- ព្រះតេជគុណមិនដឹងទេអ្វី ថាកាណុងយកទៅប្រើលើទូកចែវនោះមិនបានទេ ។ ពួកវាគ្មានចន្លោះបាញ់ គ្មានខ្សែ គ្មានជើងទ្រ ។ ពួកវាមិនអាចប្រើកាណុងបានទេទោះជាពួកវាមានអ្នកបាញ់ក្តី ទំរាំពេលនេះពួកវាគ្មានទាំងអ្នកបាញ់ម្នាក់ក៏គ្មានផង ។



www.budinst.gov.kh www.elibraryofcambodia.org

បញ្ជិតទាំងពីរដូចជាបាត់ដង្ហើមតែម្ដង ៖

- ប្រើកាណុងមិនបានទេ ?

- ពិតជាអត់បានមែនណា !

- *ដុន វ៉េរីកា* ក្រែងពួកវាអាចកែកុន.....

- ទូកនេះទាល់តែកែសំរួលវាទើបប្រើបាន ប៉ុន្តែស៊ីពេលយ៉ាងតិចបំផុតក៏មួយអាទិត្យដែរ ។

- *ណាន់ចា* ?

*តូរ៉ាណាកា* សួរទាំងមន្ទិលសង្ស័យ ដោយលោកបានកត់សំគាល់ថាមានអ្វីមិនប្រក្រតីបានកើតឡើងហើយ ទោះជាអ្នកឯទៀតប្រឹងលាក់បាំងយ៉ាងណាក្ដី ។

*អាល់វីតូ* បក ៖

- *តូរ៉ាណាកា* សួរថាមានរឿងអីណឹង ?

*វ៉េឡាកូ* ដឹងយ៉ាងច្បាស់ណាស់ថា ពេលវេលាចេះតែរត់ទៅមុខ ហើយបើនៅតែរុញរាយ៉ាងនេះ លោកពិតជាវិណ្ឌកជាមិនខាន ៖

- លោកមេបញ្ជាការ ខ្ញុំសូមលោកជួយខ្ញុំផង ។ ខ្ញុំស្នើលោកជួយដោយស្មោះណា ។ ពួកយើងបានសម្បទានធំណាស់សំរាប់សាសនាយើង ។ លោកត្រូវតែជឿខ្ញុំ លោកត្រូវតែទុកចិត្តខ្ញុំ ។ លោកត្រូវតែជួយលោកម្ចាស់ *តូរ៉ាណាកា* ធ្វើយ៉ាងម៉េចអោយចេញខាងតែពីរួចពីកំពង់ផែនេះ ។ ខ្ញុំយកព្រះនាមព្រះវិហារមកអង្វរលោក ។ គ្រាន់តែរឿងព្រះវិហារចំតែមួយនោះ ក៏ជាសម្បទានមួយធំសំបើមណាស់ទៅហើយ ។

*វ៉េរីកា* ប្រឹងលាក់ភាពសប្បាយរីករាយមិនអោយលេចចេញនៅលើផ្ទៃមុខរបស់ខ្លួនបានឡើយ ។ សំដីរបស់លោក កាន់តែមានភាពធ្ងន់ធ្ងរណាស់ទៅទៀត ៖

- បើព្រះតេជគុណយកព្រះនាមព្រះមកប្រើយ៉ាងនេះ ខ្ញុំត្រូវតែធ្វើតាមហើយ ។ ខ្ញុំនឹងនាំគាត់ចេញពីអង្គប់នេះ ប៉ុន្តែជាថ្នូរនឹងការងារនេះ ខ្ញុំចង់កាន់ជាមេបញ្ជាការ *សំពៅខ្មៅ* នៅឆ្នាំក្រោយម្ដងទៀត ទោះជាឆ្នាំនេះបានជោគជ័យរឺអត់ក្ដី ។



www.budinst.gov.kh www.elibraryofcambodia.org

- នេះគឺជាព្រះរាជប្រទានផ្ទាល់ របស់ព្រះចៅអេស្ប៉ាញ ។ តែព្រះអង្គមួយអង្គគត់ ។ មិនមែនខ្ញុំជាអ្នកសំរេចទេ ។

- មួយទៀត ខ្ញុំព្រមទទួលយកមាសរបស់គាត់ តែខ្ញុំចង់អោយព្រះតេជគុណធានាថា ខ្ញុំនឹងគ្មានរឿងរ៉ាវអ្វីទាំងអស់ទាំងជាមួយឧបរាជនៅ *គូវ៉ា* ទាំងនៅទីនេះ ។ គឺគ្មានរឿងអ្វីទាំង ដោយសាររឿងមាស ទាំងរឿង *សំពៅខ្មៅ* ។

- លោកចង់ដាក់ថ្លៃជាមួយខ្ញុំ និង ជាមួយព្រះវិហារអ្វី ?

-អារឿងនេះជារឿងសំរុះសំរួលរកស៊ីរវាងព្រះតេជគុណ រវាងខ្ញុំ និងអាស្វានេះទេតើ ។

- គាត់មិនមែនជាស្វាទេ លោកមេទ័ព ! លោកគួរតែចាំចំនុចនេះ ។

- មួយទៀត : ដប់ប្រាំភាគរយលើមុខទំនិញឆ្នាំនេះ មិនមែនដប់ទេ ។

- មិនកើតទេ ។

- មួយទៀត : ដើម្បីអោយជាប់របួត គឺសូមសំដីរបស់ព្រះតេជគុណជាបន្ទាល់នៅចំពោះមុខព្រះជាម្ចាស់ ហើយនៅក្នុងពេលនេះតែម្ដង ថាគ្មានបព្វជិតណាមួយ រឺតុលាការព្រះតេជគុណណាមួយ នឹងមិនគំរាមបណ្ដេញខ្ញុំចេញពីសាសនាទេ លើកលែងតែថ្ងៃក្រោយ ខ្ញុំបានបំពានព្រះធម៌ តែមិនមែនយករឿងពេលនេះជាលេសទេ ។ ហើយម្យ៉ាងទៀត សូមព្រះតេជគុណស្បថថាទាំងព្រះតេជគុណ ទាំងគណៈសង្ឃទាំងមូលនឹងគាំទ្រខ្ញុំយ៉ាងសកម្មហើយនឹងផ្ដល់ការគាំទ្រសព្វបែបយ៉ាងដល់ *សំពៅខ្មៅ* ទាំងពីរនេះ ។ សូមព្រះតេជគុណយកព្រះជាបន្ទាល់ណា ។

- នៅសល់អីទៀត លោកមេទ័ព ? ព្រោះមើលទៅមិនមែនតែប៉ុណ្ណឹងទេមែនទេ ? ពិតជានៅមានសល់អីទៀតមែនទេ ?

- ចុងក្រោយបង្អស់ ខ្ញុំចង់បានស្បែកអាទមិឡនោះ ។

***************

*ម៉ារីកូ* សំលឹងមើលទៅ *ប្លាក់ថន* ដែលកំពុងដេកក្ដួត សន្លប់សន្លិននៅលើគ្រែ ។ មេកងផ្អែកទៅនឹងជញ្ជាំងបន្ទប់សំលឹងមើល *ម៉ារីកូ* ដោយសើចពេញផ្ទៃញញឹមស្ញេញ ។



www.budinst.gov.kh www.elibraryofcambodia.org

- គាត់ត្រូវថ្នាំពុល រឺក៏គាត់ស្រវឹង ណឹង ?

នាងសួរទៅ *តូតូមី កាណា* ដែលជាសាមូរ៉ៃម្នាក់នៅឈរក្បែរនាង ទន្ទឹមនឹងខំដោយឥតបានផល ដើម្បីទប់នឹងក្លិនឈ្ងុលដិតដែលច្រាលឡើងពីបាតសំពៅ ហើយដែលបំពុលសំពៅទាំងមូលនោះ ។

នាងនិយាយបន្ត :

- ពាមមើលគាត់ដូចជាត្រូវថ្នាំបំពុលមែនទេ ?

- ប្រហែលហើយ *ម៉ារីកូ-សាន* ។ មើលតែគំរង់អស់នេះចុះ !

បុរសសាមូរ៉ៃចង្អុលទាំងខ្ពើមល្អើមទៅតុបាយដែលរាយពាសដោយចានឈើនានាដែលដាក់សំនល់ក្លៅគោអាំងមួយនៅមានឈាមស្រស់នៅឡើយ មាន់មួយដែលនៅសល់តែមួយចំហៀងនំបុំង ប្រ៊ូម៉ាស ប៊ីយែរ ហើយនឹងស្រាប្រ៊ែនឌី ដែលនៅសល់កន្លះដបនៅឡើយ។ តាំងពីដើមមកអ្នកទាំងពីរមិនដែលឃើញសាច់នៅលើតុបាយឡើយ ។

- រួចពួកឯងចង់យ៉ាងម៉េចណឹង ? -មេកងសួរ -គ្មានស្វាស្មោអីកន្លែងនេះទេ *វ៉ាកាវិម៉ាស៊ូ* ? គ្មានស្វាស្មោ-សានអីនៅក្នុងបន្ទប់នេះទេវ៉ី !

បុរសនេះ សំលក់សំលឹងមើលទៅសាមូរ៉ៃបណ្តើរ លើកដៃបក់បណ្តេញចេញបណ្តើរ :

- ទៅក្រៅ ! ទៅអោយស្រលះស្រលែងទៅ !

រួចបុរសនេះ ក៏ចោលភ្នែកសំលឹងមើល *ម៉ារីកូ* សាជាថ្មី ជាមួយនឹងសំដីបន្លឺឡើង :

- រួចអាស្រីឯងឈ្មោះអី អ្ហាស ?

សាមូរ៉ៃ ដែលមកជាមួយ *ម៉ារីកូ* សួរឡើង :

- អាចុងស្រុកនេះវានិយាយថាម៉េច *ម៉ារីកូ-សាន* ?

*ម៉ារីកូ* ដកក្រសែភ្នែកភាន់ភាំងរបស់នាងចេញពីតុបាយ ហើយផ្តោតទៅលើមេកងវិញម្តង :

- សូមទោសលោក ខ្ញុំស្តាប់មិនបានទេ ។ លោកមានប្រសាសន៍ថាម៉េច ?

- អ្ហាស ?



www.budinst.gov.kh www.elibraryofcambodia.org

មាត់របស់មេកងឡើងចំហធ្លុងតែម្តង ។ បុរសនេះរាងចាត់ខ្ពស់ មានភ្នែកស្រលៃរ ត្រចៀកដរ៏ និងចងសក់ក្រង ។ រូបឆ្លាងមួយនៅព្យួរតែកតោកនៅលើកជាផ្ចិតៗ ហើយនៅនឹងចង្កេះរបស់វាមានសៀតសំពៀងកាំភ្លើងខ្លីពីរ បីដើមផង :

- យី ? នាងអែងនេះនិយាយភាសាប៉កទុយកាល់ផង ? មីតយនេះនិយាយភាសាប៉កទុយកាល់ស្ទាត់តែម្រ៉ង ! អ្នកណាបង្រៀនអ្នកអែងអោយចេះនិយាយភាសាប៉កទុយកាល់បានល្អយ៉ាងនេះ ? អ្នកអែងរៀននិយាយភាសាអារ្យធម៌នេះនៅឯណា ?

- គឺ.....គឺបព្វជិតគ្រីស្តសាសនាជាអ្នកបង្រៀនខ្ញុំ ។

-អញចំជាកូនបំបង់បាយមែន!ព្រះអើយព្រះ បុប្ផា-សាន ចេះនិយាយភាសាអារ្យធម៌!

*ភ្ញាក់ថន* ភើរកចង្អោរម្តងទៀត ព្រមទាំងប្រឹងខំងើបយ៉ាងខ្សោយដាប ។

- តើលោក.......សូមទោស សូមលោកជួយលើកគាត់ទៅដាក់កន្លែងនោះបានទេ ?

*ម៉ារីកូ* ចង្អុលទៅដំណេកមួយ ។

- បាន ! បើសិនជាអាស្វានោះជួយ ។

- អ្នកណា ? សូមទោស លោកមានប្រសាសន៍ថាម៉េច ? អ្នកណាគេ ?

- អានោះ ! អាតយនោះណា ! គឺវានេះអែង !

សំដីនេះដូចដុំថ្មដែលគេចោលចំ *ម៉ារីកូ* ហើយនាងត្រូវប្រើអស់ពីឆន្ទៈរបស់ខ្លួនដើម្បីរក្សាអាកប្បកិរិយានឹងនរបាន ។ នាងធ្វើសញ្ញាទៅសាមូរ៉ៃ :

- *កាណា-សាន* សូមលោកជួយមនុស្សចុងស្រុកនេះបានទេ ព្រោះយើងត្រូវការដាក់ *អាន់ជីន-សាន* នៅកន្លែងនោះវិញ ។

- បាទ បានអ្នកស្រី ។

បុរសទាំងពីរនាក់សែង *ភ្ញាក់ថន* ទាំងតតេះតតះដាក់លើគ្រែភ្ជាប់ជញ្ជាំង ។

- ត្រូវជូតសំអាតគាត់ !

*ម៉ារីកូ* និយាយជាភាសាជប៉ុន តែអារម្មណ៍របស់នាងនៅតែស្រលាំងកាំងនឹងពាក្យដែលនាយកងហៅ *លាកា* នៅឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- បាទ *ម៉ារីកូ-សាន* ។ សូមអ្នកស្រីបញ្ជាអោយអ្នកចុងស្រុកនេះហៅអ្នកបំរើមក ។

- ចាស ។

ភ្នែករបស់ *ម៉ារីកូ* សំលឹងមើលម្តងទៀតទាំងមិនព្រមជឿ នូវម្ហូបអាហារដែលនៅពេរពាសលើតុ :

- ពួកគេពិតជាទទួលទានរបស់អស់នេះមែន ?

បុរសជាមេកងសំលឹងមើលតាមក្រសែភ្នែកនាង ហើយនៅទីបញ្ចប់ក៏អោនឈោងចាប់ហែកភ្លៅមាន់មួយហុចទៅអោយនាង :

- នាងឃ្លានអ្វី ? ហាក យកអានេះទៅ *ប៉ុន្តា-សាន* ។ ឆ្ងាញ់ណាស់ណា ។ នេះជារបស់ស្រស់ៗជាមាន់ក្រៀវមកពី *ម៉ាកាវ* ណា !

*ម៉ារីកូ* គ្រវីក្បាល ។

បុរសមេកងខំប្រឹងញញឹមស្ងួញស្ងាញ ហើយខំជ្រលក់ភ្លៅមាន់ទៅក្នុងទឹកជ្រលក់រួចហុចទៅមុខ *ម៉ារីកូ* :

- ថែមទឹកជ្រលក់ទៀតរឹតតែមានរសជាតិជាងទៅទៀត។ នាងដឹងទេ ? បាននិយាយត្រឹមត្រូវម្តងយ៉ាងនេះ ដូចជាសប្បាយចិត្តចូរច្រូងម្ល៉េះទេ ។តាំងពីមុនមកមិនដែលបានយ៉ាងនេះទេ ។នែនាងយកទៅវាជួយផ្តល់កំលាំងណា ! ខ្ញុំប្រាប់នាងហើយថានេះជាមាន់ក្រៀវ *ម៉ាកាវ* ណា ។

- ចាសទេ.....ទេ អរគុណហើយលោក ។ ហូប....សាច់គឺហាមឃាត់ ។ គឺខុសនឹងច្បាប់ខុសនឹងធម៌ព្រះពុទ្ធ ខុសនឹងសាសនាស៊ិនតូ ។

បុរសមេកងផ្ទុះសំនើចក្អាកក្អាយ

- តែនៅ *ណាកាសាគី* គឺអត់ទេ ។ ពួកតយម៉ាចំនួន ហូបសាច់រាល់តែពេលណឹង ។ តែពេលមានសាច់ពួកគេហូប ពេលណាមានស្រាពួកគេផឹក ។ ក្រែងនាងកាន់សាសនាគ្រីស្តអ្វី ? បើអញ្ចឹងទេមកសាកមើលទៅ ។ បើនាងមិនសាកទេធ្វើម៉េចនឹងដឹងបាន ?

- ទេ ! ទេ ! សូមអរគុណលោកហើយ ។

- គ្មានអ្នកណារស់នៅបានដោយមិនហូបសាច់នោះទេ ។ សាច់បានគេហៅថាម្ហូបពិត



www.budinst.gov.kh www.elibraryofcambodia.org

ប្រាកដ ។ សាច់បានវាធ្វើអោយយើងមានកំលាំងកំហែងបាន ។ ណោស.....

បុរសមេកងហុចភ្លៅមាន់ទៅរក *កាណា* :

- ម៉េចចង់សាកមើលទេ ?

*កាណា* គ្រវីក្បាលទាំងឆ្អែម

- *អ៊ីយេ* !

បុរសមេកងញាក់ស្មា ហើយគ្រវាត់ភ្លៅមាន់ទៅលើតុវិញ :

- បានតែ *អ៊ីយេ* ប៉ុណ្ណឹង ។ រួចចុះដៃនាងវាថី ? នាងមានរបួសពេលប្រកាប់ប្រចាក់គ្នាណឹងអ្វី ?

- ចាស ប៉ុន្តែមិនជាធ្ងន់ធ្ងរប៉ុន្មានទេ

*ម៉ារីកូ* ប្រឹងខាំមាត់កំរើកដៃបង្ហាញនាយកង

- ហ៊ឺ គួរអាណិតណាស់ ណ៎ ! តើនាងមកកន្លែងនេះរកអី ?

- មកមើល *អាន់*....មើលតែកុង ។ លោកម្ចាស់ *តូរ៉ាណាកា* បញ្ជូនខ្ញុំមក ។ តែកុងគាត់ស្រវឹងមែនទេ ?

- ស្រាផងម្ហូបផង ។ អាអន្ទិតនេះស៊ីលឿនពេក ហើយផឹកក៏លឿនណាស់ដែរ ។ ក្បើយម្តងកន្លះដបតែម្រឹង ។ ពួក *អ៊ិញគីលីស* មួយណា ក៏ដូចតែគ្នាដែរ ។ ពួកនេះទប់ស្រាមិនរួចទេ ។

រួចក្អែករបស់នាយកង បែរមករក *ម៉ារីកូ* វិញ :

- ខ្ញុំមិនដែលឃើញបុប្ផាណាតូចដូចជារូបនាងទេ ហើយក៏មិនដែលបាននិយាយជាមួយពួកតយណាដែលមានការចេះដឹងយ៉ាងណឹងដែរ ។

- អោយតែពួកនារីជប៉ុន និង សាមូរ៉ៃ លោកហៅតយទឹងស្វាតែទាំងអស់គ្នាអញ្ចឹងអ្វី?

បុរសដើរសមុទ្ទផ្ទុះសំនើចយ៉ាងខ្លី :

- អឺយ៉ា សូមទោសលោកស្រី ។ នេះជ្រុលមាត់ទេ ។ លោកស្រីដឹងទេ ពាក្យនេះយើងតែងហៅពួកអ្នកធម្មតា ដូចជាអ្នកទាក់ម៉ូយពួកស្រីសំផឹងនៅ *ណាកាសាគី* ជាដើម ។ មិនមែនមានគំនិតមើលងាយអីទេ ។ តាំងពីដើមរៀងមកខ្ញុំមិនដែលជួបនិយាយជាមួយនារីណាដែលមាន



www.budinst.gov.kh www.elibraryofcambodia.org

ការចេះដឹងទេ ហើយខ្ញុំក៏មិនដឹងថាមាននារីប្រភេទនេះផង ។

- ខ្ញុំក៏អញ្ចឹងដែរលោក ។ តាំងពីដើមរៀងមក ខ្ញុំមិនដែលបានជួបនិយាយជាមួយជនជាតិប៉ែកទុយកាល់ណាដែលមានវប្បធម៌ដែរ លើកលែងតែពួកបព្វជិតចេញ ។ ពួកយើងជាជនជាតិជប៉ុន មិនមែនជាពួកគយទេ ហើយស្មាគីជាសត្វណា លោកយល់ទេ ?

- ពិតហើយ១ -នាយកងនិយាយទាំងសើចចេញធ្មេញគ្រហុបផង -អ្នកស្រីនិយាយសមជាអ្នកខ្ពង់ខ្ពស់មែន ។ សូមអ្នកស្រីកុំប្រកាន់អីណាអ្នកស្រី ។

*ភ្លាក់ថន* ចាប់ផ្ដើមនិយាយរង៉ូវ ។ *ម៉ារីកូ* ដើរតំរង់ទៅរកគ្រែ ហើយអង្រួនរូបគេថ្នមៗ :

- *អាន់ជីន-សាន* ! *អាន់ជីន-សាន* !

- បាទ ! ហ្អាស ? -*ភ្លាក់ថន* ចាប់បើកភ្នែកឡើង -អូ ! សូស្ដី !....ខ្ញុំ....ខ្ញុំ...សូមអភ័យទោស.....ខ្ញុំ......

ទំងន់នៃការឈឺចាប់ និង ភាពឃ្លេងឃ្លោងបានបង្ខំអោយរូបគេដេកស្រទាងទៅវិញ ។

- សូមទោសលោក សូមលោកហៅអ្នកបំរើមកបន្តិច ព្រោះ *អាន់ជីន-សាន* ត្រូវការលាងសំអាតខ្លួន ចាស ។

- ពួកយើងមានតែពួកទាសករ ......តែ .....តែមិនមែនសំរាប់កិច្ចការនេះទេ អ្នកស្រី ។ ទុកអញ្ចឹងហើយ កំអួតបន្ដិចបន្តួចវាមិនងាប់ទេសំរាប់អាទមិឡនេះ ។

- គ្មានអ្នកបំរើទេ ? -*ម៉ារីកូ* សួរទាំងស្រលាំងកាំង ។

- ពួកយើងមានពួកទាសករ គឺពួកអាខ្មៅល្ងិតខ្វិលរលួយតែប៉ុនណឹង ។ ប្រើពួកអស់នោះគ្មានបានការអីទេ ។

*ម៉ារីកូ* ដឹងថាគ្មានជំរើសអ្វីទៀតឡើយ ។ *តូរ៉ាណាកា* អាចត្រូវការ *អាន់ជីន-សាន* ពេលណាមួយភ្លាមៗ ហើយនេះគឺជាភារកិច្ចរបស់នាងហើយ ។ នាងពោលបន្ត :

- បើអញ្ចឹង សូមយកទឹកអោយខ្ញុំម៉ាធុងមក ដើម្បីលាងគាត់ ។

- ក្រោមជណ្ដើរចុះទៅជាន់ក្រោមនេះ មានធុងហើយ ។

- សូមពឹងលោកទៅយកមកអោយខ្ញុំបន្តិចមក ចាស ។



www.budinst.gov.kh www.elibraryofcambodia.org

នាយកងចង្អុលទៅ *កាណា* :

- អោយម្នាក់នេះទៅយកទៅ !

- ទេ សូមលោកអញ្ជើញទៅយកមក ចាស។ យកអីល្ងូវនេះមក។

នាយកងសំលឹងមើលទៅ *ប្លាក់ថន*វិញ :

- នាងជាមេវាអ្វី ?

- ថាម៉េច ?

- នាងជាមេអា *អ៊ិញគីលីស* នេះអ្វី ?

- មេណឹងចង់និយាយថាម៉េចលោក ?

- គឺស្រីញី គឺព្រលឹងដួងចិត្ត គឺបេះដូងរបស់តែកុងនោះណា។

- ទេ ! ទេលោក ! ខ្ញុំមិនមែនមេរបស់តែកុងនេះទេ។

- អញ្ជឹងរបស់អាស្វ......របស់សាមូរ៉ៃនេះអ្វី ? រឺក៏ជារបស់ស្តេចដែលឡើងសំពៅមកអំបាញ់មិញនេះ ? ស្តេចឈ្មោះ *តូរ៉ា* -អីអញ្ចេះមិនដឹងទេ ! នាងជាពពូកស្នំរបស់គាត់ណុងមែនទេ ?

- ទេ !

- អត់ជារបស់អ្នកណាមួយដែលនៅលើសំពៅនេះទេ ?

*ម៉ារីកូ* គ្រវីក្បាល :

- សូមទោស សូមលោកជួយយកទឹកមកបន្តិចបានទេ ចាស ?

នាយកងងក់ក្បាល ហើយដើរចេញទៅ។

- អាគាត់នេះបានចំជាមនុស្សយ៉ាប់អាវនិងមានក្លិនអាក្រក់បំផុតដែលខ្ញុំបានជួបប្រទះ-បុរសសាមូរ៉ៃនិយាយទៅកាន់ *ម៉ារីកូ*-អំបាញ់មិញនេះ វានិយាយថាម៉េចខ្លះ ?

- វា......វា....បុរសណឹងសួរ.......សួរថា តើខ្ញុំនេះជាស្រីកំនាន់របស់តែកុងនេះអ្វី ?

បុរសសាមូរ៉ៃ ដើរតំរង់ទៅរកទ្វារ :

- *កាណា-សាន* !



www.budinst.gov.kh www.elibraryofcambodia.org

- ទុកអោយខ្ញុំតំនាងអោយប្តីអ្នកស្រី សងសឹកលើការប្រមាថកាតទានបែបនេះចុះ។ សងសឹកទាំងក្តៅៗនេះភ្លាម ។ គួរអីហ៊ាននិយាយថាអ្នកស្រីរួមរស់នៅជាមួយពួកចុងស្រុកបែបនេះ !

- *កាណា-សាន* ! សូមបិទទ្វារទៅ !

- អ្នកស្រីគឺជា *តូដា ម៉ារីកូ-សាន* ! ហេតុអីបានជាវាហ៊ានប្រមាថអ្នកស្រីបែបនេះ ? ត្រូវតែលុបលាងការប្រមាថនេះចេញ ។

- គង់តែលុបលាងទេ *កាណា-សាន*។ ហើយខ្ញុំសូមអរគុណលោកហើយ ។ ចាស ខ្ញុំប្រគល់សិទ្ធិនេះជូនលោក ។ ប៉ុន្តែយើងមកកន្លែងនេះ តាមបញ្ជាលោកម្ចាស់ *តូរ៉ាណាកា*។ លើកលែងតែមានការយល់ព្រមរបស់លោកម្ចាស់ *តូរ៉ាណាកា* បើមិនអញ្ចឹងទេ លោកធ្វើបែបនេះមិនត្រឹមត្រូវឡើយ ។

*កាណា* បិទទ្វារមកវិញទាំងមិនអស់ចិត្ត :

- ខ្ញុំឯកភាពហើយ ប៉ុន្តែខ្ញុំសូមអ្នកស្រីលើករឿងនេះជាផ្លូវការជំរាបលោកម្ចាស់ *តូរ៉ាណាកា* នៅមុនពេលយើងចាកចេញពីសំពៅនេះ បាទ ។

- ចាស សូមអរគុណចំពោះប្រការដែលលោកខ្វាយខ្វល់នឹងកិត្តិយសរបស់ខ្ញុំ ។

តើ *កាណា* នឹងមានប្រតិកម្មយ៉ាងណាទៅបើសិនជាគេដឹងពីសំដីដែលនិយាយអំបាញ់មិញនេះ - *ម៉ារីកូ* ដណ្តឹងសួរទាំងញាប់ញ័រនៅក្នុងចិត្ត ។ តើលោកម្ចាស់ *តូរ៉ាណាកា* នឹងប្រកាន់អាកប្បកិរិយាយ៉ាងណាទៅ ? រឺ *ហ៊្សូ-ម៉ាត់ស៊ុ* ? រឺប្តីខ្ញុំ ? ពួកស្វាទាំងឡាយ ? ឱព្រះជាម្ចាស់អើយ សូមជួយអោយខ្ញុំនៅនឹងនរ ហើយនឹងធ្វើអោយខួរក្បាលខ្ញុំរត់អោយបានរហ័សផងចុះ ។

ដើម្បីបំបាត់កំហឹងរបស់ *កាណា* នាងបែរទៅរឿងផ្សេងទៀតភ្លាម :

- *អាន់ជីន-សាន* បែបដល់សួរហើយ ។ ពេលនេះគាត់ដូចកូនង៉ែតអញ្ចឹង ។ តាមមើលទៅគាត់ទទួលស្រាមិនបាន ដូចពួកយើងខ្លះអញ្ចឹង ។

- ទេមិនមែនមកពីស្រាទេ ។ មិនអាចទេ ។ នេះមកពីម្ហូបទេ ។

*ប្លាក់ថន* កំរើកខ្លួនទាំងលំបាក ដោយគេខំប្រឹងជំនះអោយដឹងខ្លួនឡើងវិញ ។



www.budinst.gov.kh www.elibraryofcambodia.org

- ពួកនេះគ្មានអ្នកបំរើនៅលើសំពៅនេះទេ *កាណា-សាន*។ ខ្ញុំត្រូវធ្វើជំនួសនារីអ្នកបំរើរបស់ *អាន់ជីន-សាន* ហើយ ។

រួច *ម៉ារីកូ* ចាប់ផ្តើមដោះខោអាវរបស់ *ភ្លាក់ថន* ទាំងលំបាក ដោយហេតុដៃរបួសរបស់នាង ។

- ទុកខ្ញុំជួយអ្នកស្រី -*កាណា* ដោះខោអាវយ៉ាងប៉ិនប្រសប់ -ខ្ញុំធ្លាប់ដោះខោអាវឪពុកខ្ញុំ តែរាល់ពេលដែលគាត់ស្រវឹងស្រាសាកេទៅហើយ ។

- ជាការល្អដែរ ដែលមនុស្សប្រុសយូរៗម្តងស្រវឹងនោះ ។ អានេះវាដេញឧបទ្រពចេញអស់ ចាស ។

- ពិតហើយអ្នកស្រី ។ ប៉ុន្តែឪពុកខ្ញុំដល់ស្អែកឡើងទ្រមខ្លួន ។

- បើប្តីខ្ញុំវិញ គាត់ទ្រមខ្លួនប៉ុន្មានថ្ងៃឯណុះ ។

ក្រោយពីនៅស្ងៀមស្ងាត់មួយសន្ទុះ *កាណា* ពោលបន្ត :

- សូមព្រះអង្គលោកជួយលោកម្ចាស់ *ប៊ុនតារ៉ូ* អោយគេចខ្លួនរួចផងចុះ ។

- សាធុ -រួច *ម៉ារីកូ* សំលឹងមើលជុំវិញខ្លួន -ខ្ញុំមិនយល់សោះថាពួកនេះចេះរស់នៅក្នុងកន្លែងដូចទ្រុងជ្រូកនេះកើត ។ កន្លែងនេះយ៉ាប់ជាងផ្ទះអ្នករហេមរហាមស្រុកយើងទៅទៀត ។ នៅបន្ទប់មួយទៀតនោះ ខ្ញុំរិះសន្លប់ព្រោះតែក្លិនវា ។

- ល្មើមដល់ហើយ ។ តាំងពីដើមមក ខ្ញុំមិនដែលបានឡើងលើសំពៅពួកចុងស្រុកម្តងណាឡើយ ។

- បើខ្ញុំវិញ ខ្ញុំមិនដែលដើរសមុទ្ទតែម្តងណា ក៏អត់ដែរ ។

ទ្វាររបើកឡើង ហើយនាយកងក៏ដើរចូលមកដោយយួរធុងយកទៅដាក់ជិតកន្លែងរបស់ *ភ្លាក់ថន*។ បុរសនេះសែនភ្ញាក់ផ្អើលចំពោះភាពអាក្រាតរបស់ *ភ្លាក់ថន* ហើយគេក៏កន្ត្រាក់យកកន្សែងមួយពីក្រោមគ្រែមកគ្របអោយ *ភ្លាក់ថន* ដោយនិយាយថា :

- ទុកវាអញ្ចឹង វាដាច់ខ្យល់ស្លាប់មិនខានទេ....ម្យ៉ាងទៀត ចំពោះមនុស្សប្រុសធ្វើបែបនេះ គឺជាការអាម៉ាស់ណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកមានប្រសាសន៍ថាម៉េច ?

- អត់អីទេ ។អ្នកស្រីឈ្មោះអីដែរ ?

*ម៉ារីក្លូ* អត់ឆ្លើយតបឡើយ ។ នាងទាញកន្ទ្រេងចេញទៅម្ខាង ហើយចាប់ផ្តើមជូតសំអាត *ក្លាក់ថុន* អោយបានស្អាត និងដោយរីករាយសប្បាយនៅក្នុងចិត្តព្រោះនាងមានការមួយធ្វើផង ដោយនាងសែនធុញទ្រាន់នឹងវត្តមានរបស់នាយកងផង ទន្ទឹមនេះនាងដណ្តឹងសួរនៅក្នុងចិត្តអំពីអ្វីដែលគេកំពុងជជែកគ្នានៅឯបន្ទប់មួយទៀតនោះ ។ តើលោកម្ចាស់ *ភូរ៉ាណាកា* បានសុខសប្បាយជាទេ ?

នៅពេលដែលរួចរាល់ហើយនាងក៏មូរតីម្ហូណ្ហ និងស្បែនាទាមួយដុំ :

- យករបស់អស់នេះទៅគក់ផងបានទេ លោក ?

- ថាម៉េច ?

- របស់អស់នេះត្រូវតែបោកគក់វាភ្លាមណាលោក ។ តើលោកអាចហៅពួកទាសកមកមួយភ្លែតបានទេ ចាស ?

- ខ្ញុំបាននិយាយហើយថាពួកអាត្រាក់ត្រយឹងអស់នេះខ្ជិលរលួយខ្លួនហើយ ។ ប្រើពួកវាទាល់តែចាំម៉ោអាទិត្យ រីច្រើនជាងណឹងទៅទៀតក៏មាន ។ ត្រូវវាត់របស់អស់ណឹងចោលទៅ លោកស្រី វាគ្មានប្រើអីបានទៀតទេ ។ លោក *វ៉ូត្រិច* បានប្រាប់អោយទុកខោអាវសមរម្យសំរាប់គាត់ហើយ ។ នេះនែ ។

នាយកងបើកកូនហិបមួយហើយនិយាយបន្ត :

- លោក *វ៉ូត្រិច* ប្រាប់ថាអោយរើសយកមួយណាយកទៅ ។

- ខ្ញុំមិនចេះស្លៀកពាក់អោយគាត់នឹងខោអាវបែបនេះទេ ។

- គាត់ត្រូវការអាវ ខោ ស្រោមជើង ស្បែកជើងកវែង ហើយនឹងអាវគាត់សំរាប់ដើរសមុទ្ទ ។

នាយកងយករបស់ទាំងនោះចេញមកបង្ហាញនាងម្តងមួយៗ ។ រួច *ម៉ារីក្លូ* និង *កាណា* ក៏ចាប់ផ្តើម ស្លៀកពាក់ខោអាវអោយ *ក្លាក់ថុន* ដែលកំពុងនៅទទឹកស្លាបនៅឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- រួចចុះអានេះស្លៀកយ៉ាងម៉េច ?

*ម៉ារីកូ* លើកក្រណាត់មួយផ្ទាំងដូចថង់ និងមានរាងត្រីកោណ ដោយមានចំនងខ្សែនៅជាយផង ។

- អាណឹងគេស្លៀកពីខាងមុខបែបនេះ -រួចនាយកងធ្វើបង្ហាញទាំងអេះអុញពីរបៀបស្លៀកលើរាងកាយខ្លួន -ដាក់វាអញ្ចេះនែ ។

*ម៉ារីកូ* សំលឹងមើលរបៀបបង្ហាញរបស់នាយកង ធ្វើអោយឈាមឡើងច្រាលពេញផ្ទៃមុខរបស់បុរសនេះភ្លាម ។

នាងដាក់ផ្ទាំងក្រណាត់ពីលើគល់ភ្លៅរបស់ *ប្លាក់ថន* រៀបវាអោយចំកន្លែងស្រួលបួល ហើយដោយមាន *កាណេ* ជាជំនួយផងនាងក៏ក្រវាត់ខ្សែតាមចន្លោះភ្លៅរបស់ *ប្លាក់ថន* ហើយយកមកចងជុំវិញចង្កេះរបស់គេ ។ ធ្វើបណ្តើរនាងនិយាយយ៉ាងស្ងប់ស្ងៀមទៅកាន់ *កាណេ* បណ្តើរ :

- តាំងពីកើតមក ខ្ញុំមិនដែលឃើញរបៀបស្លៀកពាក់អីអាក្រក់អាក្រីយ៉ាងណឹងទេ ។

*កាណេ* ឆ្លើយតប :

- មើលទៅដូចជាយ៉ាប់ដល់ហើយ ។ រួចចុះពួកបព្វជិតស្លៀកអាណឹងដែរទេ *ម៉ារីកូ -សាន* ? ស្លៀកពីក្នុងអាវបំពង់ពួកគេណា ។

- ខ្ញុំមិនដឹងដែរ ។

*ម៉ារីកូ* ក្រវាសសក់ដែលបាំងភ្នែកនាងចេញ រួចក៏ងាកទៅសួរនាយកង :

- សូមលោកជួយមើលថាគាត់ស្លៀកពាក់បានត្រឹមត្រូវហើយ រឺនៅ ចាស ?

- បានហើយ នៅសល់តែស្បែកជើងកវែងទៀតទេ ។ ស្បែកជើងនៅកន្លែងនោះ តែចាំបន្តិចទៀតសឹមពាក់វាក៏បានដែរ ។

រួចនាយកងដើរមកកៀកនឹង *ម៉ារីកូ* ហើយនិយាយបន្ទាបសំលេងដោយបែរខ្លួនទៅរកសាមូរ៉ៃ :

- ម៉េចដាក់មួយអ្វី ?

- ថាម៉េច ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំចង់នាងណា អ្នកស្រី ។ នាងថាម៉េចដែរ ? នៅឯបន្ទប់ជាប់នេះមានគ្រែមួយទៀតដែរ ។ នាងអោយពូកម៉ាកនាងឡើងទៅលើទៅ ចំនែកអា *អ៊ិញគីលីស* នេះយ៉ាងតិចណាស់ក៏មួយម៉ោងទៀតដែរបានដឹងខ្លួន ។ ខ្ញុំអោយថ្លៃនាង ដូចគេដូចអែងអញ្ចឹង ។

- ថាម៉េច ?

- នាងអាចបានមួយកាស់ស្តាន់ណា ហើយបើនាងពូកែនាងអាចបានដល់បីកាស់ផង ។ បើនិយាយពីប្រដាប់វិញ គ្មានអ្នកណាគ្រាន់បើជាងខ្ញុំទេ តាំងពីនេះដល់ *លីវេរ្សាន*។ ម៉េច ? នាងព្រមទេ ?

*កាណា* ប្រទះឃើញភាពស្រលាំងកាំង និងរន្ធត់លេចឡើងលើផ្ទៃមុខ *ម៉ារីកូ* ភ្លាម :

- មានរឿងអី *ម៉ារីកូ-សាន* ?

*ម៉ារីកូ* ច្រាននាយកងចេញឆ្ងាយពីគ្រែ នាងនិយាយទាំងដង្ហិបដង្ហុប :

- វា......វា.....វា......វាថា......

*កាណា* ហូតដាវចេញខាកភ្លាម ប៉ុន្តែកាំភ្លើងខ្លីពីរដើមបានភ្ជង់មកលើរូបគេជាស្រេច ។ ទោះជាយ៉ាងនេះក្តី *កាណា* នៅតែស្ទុះហក់ទៅមុខដដែល ។

- ឈប់សិន *កាណា-សាន* -*ម៉ារីកូ* និយាយទាំងដង្ហក់ -លោកម្ចាស់ *តូរ៉ាណាកា* ហាមផ្តាច់ការវាយប្រហារអ្វីទាំងអស់រហូតដល់ពេលលោកចេញបញ្ជា ។

- ចូលមក អាស្វា ! មក ! ចូលមកអាអាច់ ! នែ ! ប្រាប់អាស្វានោះអោយស៊កដាវភ្លាមបើមិនអញ្ចឹងទេអញបាញ់បំបែកសន្ទះក្បាលវារកតែផោមក៏មិនទាន់ផងអីលូវហើយ ។

*ម៉ារីកូ* នៅឈរប្រហែលជាបីតឹកពីនាយកង ។ ដៃស្តាំរបស់នាងនៅតែឋិតក្នុង *អូប៊ី* ដដែល បាតដៃនាងក្តាប់ជាប់ដងកូនកាំបិតស្រួចរលែម ។ ប៉ុន្តែនាងនឹកឃើញពីករណីយកិច្ចរបស់នាង ហើយក៏លាដៃចេញវិញទៅ ។

- *កាណា-សាន* ស៊កដាវចូលវិញទៅ ។ យើងត្រូវគោរពតាមបញ្ជារបស់ លោកម្ចាស់ *តូរ៉ាណាកា* ។ យើងត្រូវស្តាប់តាមបញ្ជារបស់លោកម្ចាស់ ។

ដោយប្រឹងអស់ទំហឹងចិត្ត ទើប *កាណា* សំរេចធ្វើតាមសំដីរបស់ *ម៉ារីកូ* បាន ។



www.budinst.gov.kh www.elibraryofcambodia.org

- មើលទៅ អញបញ្ជូនអ្ហែងទៅស្រុកនរកហើយ អាតយ !

*ម៉ារីកូ* ប្រឹងទប់សំលេង អោយនៅតែមានលក្ខណៈរាបសារដដែល :

- សូមលោកប្រណីទោសអោយគាត់និងរូបខ្ញុំផងចុះ ។នេះគឺជាការភាន់ច្រលំទេ ចាស ។ ជាការភាន់.....

- អាកូនមីចោរមុខស្វានេះ វាជកដាវណា ។ អានេះគ្មានរឿងភាន់ច្រលំអីទេ ។

- សូមលោកអភ័យទោសផងចុះ ចាស ។

នាយកងលិទ្ធបប្ដូរមាត់ :

- បាន ! ខ្ញុំសុខចិត្តបំភ្លេចរឿងនេះចោល បើនាងព្រមចិត្តល្អជាមួយខ្ញុំ ។ យ៉ាងម៉េចដែរ ស្រីស្រស់ ? តសចូលទៅបន្ទប់ម្ខាងទៀតទៅ ហើយប្រាប់អាស្ទ....ប្រាប់អាគាត់នោះអោយទៅ កន្លែងនេះហើយ ។ រួចខ្ញុំសុខចិត្តបំភ្លេចរឿងរ៉ាវទាំងអស់ ។

- លោក......លោកឈ្មោះអីដែរ ចាស ?

- *ប៉េសារ៉ូ* ។ *ម៉ានុយអែល ប៉េសារ៉ូ*។ ហេតុអី ?

- ចាស អត់មានហេតុអីទេ ។ សូមលោក *ប៉េសារ៉ូ* អធ្យាស្រ័យលើការច្រលំគ្នាផងចុះ ចាស ។

- ចូលបន្ទប់ភ្លាមទៅ ! ចូលភ្លាម !

- មានរឿងអីហ្នឹង ? មាន.......មាន....រឿង....

*ប្លាក់ថន* ឥតដឹងថាខ្លួនគេភ្ញាក់ហើយរឺមួយក៏កំពុងតែបន្តនៅក្នុងការយល់សប្តិនៅឡើយ ទេ ប៉ុន្តែសភាវគតិរបស់គេហិតបានពីក្លិនគ្រោះថ្នាក់ ដែលកំពុងតែលេចរូបរាងឡើង :

- រួចចុះវាមានរឿងអីហ្នឹង ?

- អាតយតំរក់នេះ វាហូតដាវដាក់ខ្ញុំណា !

- នេះគឺ......នេះគឺជាការភាន់ច្រលំទេ *អាន់ជីន-សាន -ម៉ារីកូ* និយាយ-ខ្ញុំ....ខ្ញុំ.....បាន សូមទោសលោក *ប៉េសារ៉ូ* រួចហើយ ។

- *ម៉ារីកូ* ? គឺនាងទេអ្ហី ? នាងគឺ *ម៉ារីកូ-សាន* មែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- ហៃ *អាន់ជីន-សាន* ។ ហុនតូ ! ហុនតូ !

នាងខិតចូលកាន់តែជិត ។កាំភ្លើងខ្លីរបស់នាយកងនៅតែភ្ជង់លើ *កាណា* ជាប់ ។ ពេលដើរកាត់នាយកង នាងប្រឹងអត់សង្កត់ចិត្តទប់ដៃនាងមិនអោយលូកយកកាំបិតខ្លីមកចាក់ទំលុះបុរសនេះអោយស្លាប់សមនឹងកំហឹងរបស់នាង ។ នៅពេលនោះទ្វារក៏របើកឡើង ហើយតៃកុងជំនួយដ៏ក្មេងម្នាក់យួរទឹកមួយធុងដើរចូលមក ប៉ុន្តែនៅពេលក្រលេកឃើញកាំភ្លើងយុវបុរសនេះក៏ដាក់មេធាយប្រើបបាត់តែម្តង ។

*ប្លាក់ថន* បន្លឺពាក្យឡើង ដោយទាំងខំប្រមែប្រមូលអារម្មណ៍ខ្លួនអោយបានមូលឡើងវិញ :

- *វ៉ូទ្រិច* នៅឯណា ?

- នៅឯលើ ។ នៅកន្លែងណាដែលតៃកុងល្អត្រូវនៅ -នាយកងឆ្លើយតបទាំងចំអក - អាតយនេះហ៊ានហួតដាវដាក់ខ្ញុំ ។

- ជួយគ្រាហ៍ខ្ញុំឡើងទៅលើផង ។

*ប្លាក់ថន* ស្រវាចាប់ជាយគ្រែដើម្បីងើបខ្លួន ។ *ម៉ារីកូ* ស្ទុះទៅជួយភ្លាម ប៉ុន្តែនាងគ្មានកំលាំងគ្រប់គ្រាន់ដើម្បីនឹងលើកមាឌដ៏ធំរបស់ *ប្លាក់ថន* ឡើយ ។

នាយកងលើកកាំភ្លើងធ្វើសញ្ញាទៅ *កាណា* :

- ប្រាប់វាអោយទៅចូលជួយផងទៅ ។ ហើយប្រាប់វាផងថាថ្ងៃនេះសំនាងវាហើយ កុំអីបានត្រីស៊ីភ្នែកហើយ អាវ៉ា !

***************

មេបញ្ជាការជំនួយ *សាន់ត្យាកូ* ដកត្រចៀកខ្លួនចេញពីប្រហោងសំងាត់មួយដែលចោះនៅនឹងជញ្ជាំងបន្ទប់ធំ ។ សំដីចុងក្រោយរបស់ *វ៉ៃឡាក្កា* ដែលថា " ល្អ បើអញ្ចឹងគឺស្រេចបាច់អស់ហើយ " នោះនៅលាន់លឺខ្ទ័រនឹងត្រចៀករបស់ខ្លួននៅឡើយ ។ គេដើរយ៉ាងស្ងៀមស្ងាត់ និងយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

ថ្មមកាត់បន្ទប់ដែលមានពន្លឺព្រាល១នេះ ចេញទៅតាមរបៀងដោយទាញទ្វារបិទតាមក្រោយយ៉ាងថ្នម១។ *សាន់ត្យាក្លូ* ជាមនុស្សម្នាក់ មានធំស្គម ហើយសក់ខ្មៅរីងរបស់លោកត្រូវចងបួងទៅក្រោយមួយដុំតូចដូចកន្ទុយអណ្តើក ។ ទឹកមុខរបស់លោកមានភាពរហ័សរហួនសំលៀកបំពាក់ស្អាតបាត តែលោកដើរជើងទទេដូចអ្នក ដើរសមុទ្រភាគច្រើនដែរ។ នៅឯកន្លែងសំពៅ *វ៉ុគ្រិច* កំពុងតែនិយាយជាមួយ *ម៉ារីកូ*។ ពេលឡើង មកដល់ខាងលើសំពៅ *សាន់ត្យាក្លូ* ដើរតំរង់ទៅរកអ្នកទាំងពីរ សូមអធ្យាស្រ័យអ្នកទាំងពីរចំ ពោះការរំខានរបស់ខ្លួន ហើយឈាន ទៅជិតត្រចៀក *វ៉ុគ្រិច* ដើម្បីរាយរ៉ាប់ពីបេសកកម្មដែល *វ៉ុគ្រិច* បានបញ្ជូនខ្លួន ទៅលួចស្តាប់នោះ។ នៅខាងកន្លែ *ប្លាក់ថន* កំពុងអង្គុយត្របោមក្បាលអង្គង់ ខ្លួនគេផ្អែកទៅនឹងតួកាណុង ក្បាលគេងោកបិផ្ទក់។ *ម៉ារីកូ* កំពុងជង្គុយយ៉ាងត្រង់ខ្លួនរបៀប ជប៉ុនទល់មុខនឹង *វ៉ុគ្រិច* ចំនែកឯ *កាណា* អង្គុយឥតកំរើកនៅក្បែរនាង ។ នៅលើសំពៅពួកនាវិក ប្រដាប់ដោយអាវុធដើរចុះឡើងប្រវាត់ ។ បុរសពីរនាក់ទៀតនៅកាន់ចង្កូតសំពៅ ។ សំពៅនៅតែបែរក្បាលបណ្តោយខ្យល់នៅឡើយ ហើយនៅប្រហែលជាមួយរយម៉ែតពីនេះទូកធំកំពុងបណ្តែតខ្លួនប៉ែលប៉ាល១ នៅលើផ្ទៃសមុទ្រ ។ ទូកធំបែរខ្លួនទទឹងនឹងសំពៅដែលជាចំនីមួយយ៉ាងងាយសំរាប់កាណុង ពួកប៊ិកទុយកាល់ ។ ដងចែវទាំងអស់ត្រូវលើកផុតពីទឹក លើកលែងតែដងចែវពីរទៅសងខាងសំរាប់ទប់កុំអោយជំនោរសមុទ្ទផាត់ទូកចេញតែប៉ុននោះ ។ ទូកនេសាទពោរពេញទៅដោយពួកសាមូរ៉ៃខ្នាន់ធ្នូកាន់តែខិតជិតឡើង១ ប៉ុន្តែមិនទាន់ព័ទ្ធពួកគេនៅឡើយទេ។

*ម៉ារីកូ* តាមសំលឹងពិនិត្យ *វ៉ុគ្រិច* និងមេបញ្ជាការឥតដាក់ភ្នែក។ នាងឥតស្តាប់លឺសំដីដែលនិយាយនោះឡើយ ហើយបើទោះជានាងស្តាប់លឺក្តី ការអប់រំដែលនាងបានទទួលតំរូវអោយនាងត្រូវតែធ្វើថ្លង់មិនលឺអ្វីជាដដែល។ ភាពផ្ទាល់ខ្លួនមិនអាចមានបានទេនៅក្នុងផ្ទះក្រដាស បើសិនណាជាគ្មានការគួរសម និងការគោរពគ្នាទៅវិញទៅមក ។គ្មានភាពផ្ទាល់ខ្លួនទេ ជីវិតអារ្យធម៌ក៍មិនអាចមានឡើងបានដែរ ដោយហេតុនេះហើយទើបជនជាតិជប៉ុនទាំងអស់សុទ្ធតែបានទទួលការអប់រំអោយចេះស្តាប់ និងមិនទៅជិត។ នេះគឺដើម្បីសេចក្តីសុខសាន្តសំរាប់គ្រប់១គ្នា។

នៅពេលដែលនាងឡើងមកជាន់ខាងលើសំពៅ *វ៉ុគ្រិច* បានស្តាប់ពាក្យពន្យល់របស់



www.budinst.gov.kh www.elibraryofcambodia.org

នាយកង     ហើយនឹងពាក្យពន្យល់ទាំងតតាក់តតុបរបស់នាងដែលថាកំហុសគឺមកពីនាងទេដែលយល់ច្រលំពីស៍ដីរបស់នាយកង ហើយដែលជាហេតុនាំអោយ *កាណា* ត្រូវហូតដាវឡើងដើម្បីការពារកិត្តិយសរបស់នាង ។  នៅពេលស្តាប់ពាក្យពន្យល់របស់ *ម៉ារីកូ* កាំភ្លើងនាយកងនៅតែភ្ជង់ខ្លងរបស់ *កាណា* ជាប់ដដែល :

- ខ្ញុំគ្រាន់តែសួរថានារីណើងជាស្រីរបស់ *អ៊ិញ្ញគីលីស* រឺអី  ប៉ុនណឹងទេតើ។ ព្រោះខ្ញុំឃើញលាងខ្លួនប្រាណ និងកាន់ប្រដាប់ប្រដារ អា *អ៊ិញ្ញគីលីស* បែបស្និទ្ធស្នាលណាស់ ។

- ដាក់កាំភ្លើងចុះទៅ លោកមេកង ។

- អានេះគ្រោះថ្នាក់ណាស់ ។ យកល្ពចងក្រៀកវាទៅ ។

- ខ្ញុំឃ្លាំមើលហើយ ។ ដាក់កាំភ្លើងចុះទៅ ។

- អំបាញ់មិញ បើកុំតែខ្ញុំរហ័សដាង កុំអីអាស្វានេះសំលាប់ខ្ញុំបានបាត់ទៅហើយ ។ យកវាទៅព្យួរនៅដងក្តោង ដូចយើងធ្លាប់ព្យួរនៅ *ណាកាសាគី* អញ្ចឹងទៅ ។

- ពេលនេះ យើងមិនមែននៅ *ណាកាសាគី* ទេ ។ តស់ ដាក់កាំភ្លើងចុះទៅ ។

នៅពេលដែលនាយកងដើរចេញបាត់ទៅ *វ៉ូស្រិច* ក៏ងាកទៅរក *ម៉ារីកូ* ម្តងទៀត :

- តើវាថាអីខ្លះ ចំពោះអ្នកស្រី ?

- អត់....អត់មានអីទេ សូមលោកអធ្យាស្រ័យ ចាស ។

- អោយខ្ញុំសូមទោសចំពោះភាពច្រឡើសបើសរបស់វាចំពោះអ្នកស្រី  និងសាមូរ៉ៃនេះផងចុះ ។  សូមអ្នកស្រីជំរាបទៅសាមូរ៉ៃនេះផង  ថាខ្ញុំសូមទោស ។  ខ្ញុំសូមអ្នកទាំងពីរបំភ្លេចការប្រមាថកាតទានរបស់នាយកងនេះផងចុះ ។ ខ្ញុំសូមសន្យានឹងអ្នកស្រីថា ខ្ញុំនឹងចាត់ការតាមរបៀបខ្ញុំ និងតាមពេលវេលារបស់ខ្ញុំ បាទ ។

*ម៉ារីកូ* និយាយប្រាប់ទៅ  *កាណា*  ហើយក្រោយពីការបញ្ចុះបញ្ចូលអស់មួយរយៈមកទើបបុរសនេះយល់ព្រម ។

- *កាណា-សាន* និយាយថាល្អណាស់  ប៉ុន្តែគាត់ថាបើគាត់ជួបនឹងនាយកងនេះនៅលើដីគោក គាត់នឹងយកក្បាលនាយកងអោយបាន ។



www.budinst.gov.kh     www.elibraryofcambodia.org

- ពិតជាអញ្ចឹងហើយ ។ *ដូម៉ូ អារីកាតូ កាណា-សាន -រ៉ូឡឺច* បន្ទឹពាក្យទាំងញញឹម - ហើយសូម *ដូម៉ូ អារីកាតូ កូស៊ីអេម៉ាស៊ីតា ម៉ារីកូ-សាន*។

- លោកចេះភាសាជប៉ុនដែរ ?

- អត់ទេ ចេះតែបីបួនម៉ាត់ណឹង ។ ខ្ញុំមានប្រពន្ធនៅ *ណាកាសាគី* ណាអ្នកស្រី ។

- អញ្ចឹងផង ! លោកនៅជប៉ុនយូរហើយ ?

- លើកនេះ ជាជើងទីពីររបស់ខ្ញុំមកពី *លីវេរ្យាន* ។ ខ្ញុំរស់នៅប្រាំពីរឆ្នាំនៅផ្ទៃទឹកតំបន់នេះ គឺម៉្លុំស្រុកនេះ និងឡើងចុះទៅ *ម៉ាកាវ* និង *កូរ៉េ -រ៉ូឡឺច* ពោលបន្ថែម-សូមអ្នកស្រីកុំរីរវល់នឹងវាធ្វើអ្វី....វា ជាពូក *អេតា* ទេ ។ តែព្រះពុទ្ធព្រះអង្គត្រាស់ហើយថា សូម្បីតែ *អេតា* ក៏មានសិទ្ធិរស់នៅដែរមែន ទេ ?

- ចាសពិតហើយលោក ។

*ម៉ារីកូ* ឆ្លើយតប ប៉ុន្តែឈ្មោះនិងមុខអ្នកដែលប្រមាថនាងបានធ្លាក់ជាប់ក្នុងខួរក្បាលនាងរួចទៅហើយ ។

- ប្រពន្ធខ្ញុំនិយាយភាសាប៉ិកទុយកាល់បានខ្លះ១ដែរ តែបើប្រៀបនឹងអ្នកស្រីវិញហៅគ្នាមិនលីទេ ។ អ្នកស្រីជាគ្រីស្តសាសនិកមែនទេ ?

- ចាស ។

- ប្រពន្ធរបស់ខ្ញុំក៏ចូលសាសនាដែរ ។ ឪពុកគេជាសាមូរ៉ៃ តែឋានៈទាបទេ ហើយគាត់នៅបំរើ *គីយ៉ាម៉ា* ។

- នាងមានសំនាងណាស់ដែលមានប្ដីដូចជារូបលោកយ៉ាងនេះ- *ម៉ារីកូ* តបវិញយ៉ាងគួរសម ។ ប៉ុន្តែនៅក្នុងចិត្តនាងជណ្តើងសួរខ្លួនឯងទាំងងឿងឆ្ងល់ថាយ៉ាងម៉េចបានជាគេទៅរៀបការនិងរស់នៅជាមួយអ្នកចុងស្រុកយ៉ាងនេះ ?

ទ្រាំមិនបាន នាងថ្លោយមាត់សួរទៅ *រ៉ូឡឺច* :

- ចុះអ្នកស្រីប្រពន្ធលោក ហួបសាច់ដូច....ដូច.....ដូចនៅបន្ទប់ខាងក្រោមអញ្ចឹងដែរ ?

*រ៉ូឡឺច* សើចកក្អឹក បញ្ចេញធ្មេញសស្អុះ :



www.budinst.gov.kh www.elibraryofcambodia.org

- ទេ។ ហើយនៅឯផ្ទះខ្ញុំនៅ *ណាកាសាគី* ក៏ខ្ញុំមិនហូបសាច់ដែរ។ ពេលដើរសម្ពុទ្ធនឹងនៅអឺរ៉ុបខ្ញុំហូប។ នេះជាទំលាប់ពួកយើងខ្ញុំណាអ្នកស្រី។ កាលពីប៉ុន្មានពាន់ឆ្នាំមុនកំណើតព្រះពុទ្ធ ជនជាតិនាងក៏ហូបសាច់សត្វដែរមែនទេ? មុនពេលព្រះពុទ្ធព្រាស់ចង្អុលមាគ៌ា អ្នកណាក៏ហូបសាច់ដែរ។ ទាំងនៅក្នុងស្រុកនេះក៏តែអញ្ចឹង ។ ឥឡូវនេះ ពួកយើងយល់ដឹងផងគ្រាន់បើជាងមុនហើយ។

*ម៉ារីកូ* សញ្ជឹងគិតមួយសន្ទុះរួចបន្ត :

- តើពួកបិកខុយកាល់សុទ្ធតែហៅពួកជនជាតិខ្ញុំថា ស្វា ថាតយ នៅកំបាំងមុខពួកយើងអញ្ចឹងអ្វី ?

*វ៉ុទ្រិច* អង្អែលក្រវិលដែលខ្លួនពាក់នៅនឹងត្រចៀក :

- ចុះជនជាតិអ្នកស្រីមិនហៅពួកយើងថា អ្នកចុងស្រុកទេអ្វី ?រួចនេះនិយាយចំមុខពួកខ្ញុំផង ? ពួកយើងជាពួកអ្នកមានអារ្យធម៌ណាអ្នកស្រី រីយ៉ាងហោចណាស់យើងចាត់ខ្លួនថាយ៉ាងនេះដែរ។ នៅឥណ្ឌាដែលជាស្រុកព្រះពុទ្ធ ពួកនោះហៅជនជាតិជប៉ុនថាជា " បិសាចទិសបូព៌ា " ហើយបើជនជាតិជប៉ុនមានប្រដាប់អាវុធ គេមិនអនុញ្ញាតអោយឡើងគោកទេ ។ ជនជាតិអ្នកស្រីហៅពួកឥណ្ឌាវិញថាជាពួក "អាខ្មៅ " ហើយចាត់ពួកនេះមិនមែនជាមនុស្សផង។ រួចចុះពួកចិនហៅពួកជប៉ុនថាម៉េច ? រួចពួកជប៉ុនហៅពួកចិនថាម៉េច ? ហៅពួកកូរ៉េថាម៉េច ? ថាពួកអាស៊ីខ្ចិមមែនទេ ?

- ខ្ញុំយល់ថាលោកម្ចាស់ *តូរ៉ាណាកា* អាចមិនសប្បាយចិត្ត។ ហើយលោកម្ចាស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ុ* រីឪពុកក្មេកលោក ក៏ច្បាស់ជាមិនសប្បាយចិត្តដូចគ្នាហ្នឹង។

- ព្រះយេស៊ូតែងមានបន្ទូលថា " ដំបូងបង្អស់ត្រូវយកសំរាមចេញពីក្នុងភ្នែកឯងសិនសិមមកយករនូតចេញពីក្នុងភ្នែកខ្ញុំ " ។

*ម៉ារីកូ* សញ្ជឹងគិតពីសំដីនេះបណ្តើរ តាមសំលឹងមើលបញ្ហាការជំនួយខ្សែបយ៉ាងញាប់ដាក់ត្រចៀក *វ៉ុទ្រិច* បណ្តើរ។ ពិតណាស់យើងតែងចំអកអោយជនជាតិផ្សេងទៀត។ តែយ៉ាងម៉េច ? យើងជាពលរដ្ឋនៃដែនដីរបស់ព្រះ ពោលគឺព្រះលោកបានជ្រើសរើសជនជាតិយើង ជា



www.budinst.gov.kh www.elibraryofcambodia.org

ពិសេសតែម្តង។ មានតែពួកយើងទេ ដែលត្រូវបានការពារដោយបារមីរបស់ព្រះចៅអធិរាជ។ តើ មិនមានតែពួកយើងទេវឹ ដែលលើសលែងផ្តាច់គេលើជនជាតិឯទៀតនោះ ? រួចចុះបើអញជាជប៉ុនផង ជាគ្រីស្តសាសនិកផងនោះ តើយ៉ាងម៉េចទៅវិញ ? អញក៏មិនដឹងដែរ។ តែកុង *រ៉ូស្រ៊ិច* នេះចំលែកដូចតែកុងអង់គ្លេសដែរ។ ហេតុអីបានជាពួកនេះមានលក្ខណៈខុសគេយ៉ាងហ្នឹង ? តើមកពីការរៀនសូត្ររបស់ពួកគេ រឺយ៉ាងណា ? អ្វីៗដែលពួកនេះធ្វើរកជឿមិនបានទេ។ ពួកនេះធ្វើយ៉ាងម៉េចទើបអាចបើកសំពៅជុំវិញពិភពលោក ហើយនឹងដើរសមុទ្ទយ៉ាងងាយ ដូចយើងដើរលើដីគោកអញ្ចឹង ? តើប្រពន្ធ *រ៉ូស្រ៊ិច* ដឹងពីចំលើយនៃសំនួរទាំងនេះទេ ? អញចង់ជួបនាងហើយជជែកលេងជាមួយនាងណាស់។

អ្នកជំនួយការកាន់តែបន្ទាបសំលេងខ្លួនណាស់ទៅទៀត។

- វាថាម៉េច ?

*រ៉ូស្រ៊ិច* ឱទានឡើងដោយការភ្ញាក់ផ្អើលធ្វើអោយ *ម៉ារីកូ* មានចិត្តចង់ស្តាប់ពីការនិយាយរបស់បុរសទាំងពីរនាក់នេះភ្លាម ។ ប៉ុន្តែ នាងមិនអាចលឺបាននូវពាក្យដែលអ្នកជំនួយការនេះនិយាយឡើងវិញឡើយ។ រួចអ្នកទាំងពីរចោលភ្នែកសំលឹងមើលទៅ *ធ្លាក់ផង* ធ្វើអោយ *ម៉ារីកូ* ដែលមើលតាមក្រសែភ្នែកបុរសទាំងពីរនេះ មានការជ្រួលច្របល់ចំពោះការយកចិត្តទុកដាក់របស់អ្នកទាំងពីរនេះភ្លាម។

រួច *រ៉ូស្រ៊ិច* ក៏ពោលបន្តទៀតយ៉ាងប្រុងប្រយ័ត្នដោយគេទើបចាប់អារម្មណ៍ឡើងវិញពីវត្តមានរបស់ *ម៉ារីកូ*:

- រួចមានអីទៀត *សាន់ត្យាកូ* ?

មេបញ្ជាការជំនួយបន្តការខ្សឹបខ្សៀវរបស់ខ្លួនបន្តទៀត។

- តើពួកគេនៅខាងក្រោមប៉ុន្មានពេលទៀត ?

- ពួកគេកំពុងទម្លិចកែវត្លា និងតម្លៃត្លា ទាន ។

- អាកូនមីចោរ !-*រ៉ូស្រ៊ិច* គ្រហូចអារ *សាន់ត្យាកូ* -កុំនិយាយប្រាប់នរណាទាំងអស់ណា! តែនិយាយរលាយខ្លួនហើយអា !



www.budinst.gov.kh www.elibraryofcambodia.org

- មិនបាច់ប្រាប់ខ្ញុំទេ រឿងនេះ ។

- តែអារឿងនេះមានការចាំបាច់ត្រូវតែនិយាយជានិច្ច ។

រួច *រ៉ូឡើច* ចោលភ្នែកសំលឹងមើលទៅ *ប្លាក់ថន* :

- ដាស់វាអោយក្រោកឡើង ។

*សាន់ត្យាកូ* ដើរទៅអង្រួន *ប្លាក់ថន* ស្ទើរធ្លាក់ថ្នើម ។

- រួចចុះវាកើតអីណឹង ?

- ទះវាមើល !

*សាន់ត្យាកូ* ទះ *ប្លាក់ថន* ប៉ុន្មានដៃ :

- របល់យក៏ ! អញ..........

*ប្លាក់ថន* ស្ទុះក្រោកឡើងទាំងមុខក្រហមងាំង ប៉ុន្តែគេធេងធោងហើយដួលត្រឡប់ទៅវិញ ។

- អាប្រកាច់យក៏ ! ភ្ញាក់ឡើង អា *អ៊ិញគីលីស* !

ទាំងកំហឹងមួរម៉ៅ *រ៉ូឡើច* ចង្អុលទៅអ្នកកាន់ចង្កូតទាំងពីរនាក់ :

- នែ ! គ្រវែងវាចូលទឹកទៅ !

- ថាម៉េច ?

- ភ្នាមឡើង !

នៅពេលដែលអ្នកកាន់ចង្កូតទាំងពីរ ស្ទុះមកលើក *ប្លាក់ថន* យ៉ាងប្រញាប់ប្រញាល់នោះ *ម៉ារីកូ* និយាយឡើង :

- លោកតែកុង *រ៉ូឡើច* លោកមិនត្រូវ.........

ប៉ុន្តែនៅមុនពេលដែលរូបនាង រី *កាណា* អាចធ្វើអន្តរាគមន៍បាននោះ បុរសទាំងពីរបានគ្រវែង *ប្លាក់ថន* ពីលើតែមសំពៅទៅក្នុងទឹកសមុទ្របាត់ទៅហើយ ។ ពីក្នុងកំពស់ប្រាំពីរម៉ែតខ្ទួន *ប្លាក់ថន* ធ្លាក់បោកផ្កាប់មុខនឹងទឹកលាន់លឺសូរគ្រាំង ហើយលិចបាត់ភ្នាមតែម្តង។ មួយសន្ទុះក្រោយមកទើបគេផុសឡើងមកវិញ ទាំងក្អកគឃុសដោយឈ្លក់ទឹក ។ ប៉ុន្តែទឹកត្រជាក់ក៏



www.budinst.gov.kh www.elibraryofcambodia.org

បានធ្វើអោយគេបានស្គាល់បន្តិចហើយដែរ ។

*វ៉ុត្រិច* នៅអង្គុយព្រួសប្រាសលើកៅអីខ្លួន រួចទើបស្រែកហៅគេហៅឯងឡើង :

- របស់យក៏ ! មើលអាណាមកជួយអញបន្តិចមើល !

អ្នកកាច់ចង្កូតម្នាក់ស្ទុះមកជួយលើក *វ៉ុត្រិច* ចំនែកឯបញ្ជាការជំនួយទ្រក្បៀករបស់គេអោយក្រោកឈរហើយគ្រាហ៍ទៅតែមសំពៅ ។ *ប្លាក់ថន* នៅតែឈ្ងក់ទឹកកខក់នៅឡើយ ប៉ុន្តែគេបានហែលមកខាងសំពៅបណ្ដើរ ស្រែកជេរប្រទេចផ្ដាសាអ្នកដែលបោះរូបគេទំលាក់ទឹកបណ្ដើរ ។

*វ៉ុត្រិច* ស្រែកចេញបញ្ជា :

- កាច់ស្តាំពាក់កណ្តាល !

សំពៅងាកចេញពីទិសខ្យល់បន្តិច ហើយអណ្តែតចេញឆ្ងាយពី *ប្លាក់ថន* ។ *វ៉ុត្រិច* អោនលើគែមសំពៅហើយស្រែកយ៉ាងដាច់ណាត់ :

- ចេញអោយឆ្ងាយពីសំពៅអញវើយ !

រួចគេក៏និយាយយ៉ាងរូសរាន់ទៅកាន់បញ្ជាកាជំនួយការ :

- យកឡុងបុតមួយទៅស្រង់ អា*អ៊ិញគីលីស* ហើយយកវាទៅទូកធំវិញទៅ ។ លឿនឡើង ! ហើយប្រាប់វាថា..........

រួច *វ៉ុត្រិច* បន្ទាបសំលេងរបស់ខ្លួន ។

*ម៉ារីកូ* សែនរីករាយក្នុងចិត្តដោយឃើញថា *ប្លាក់ថន* មិនលង់ទឹកស្លាប់ ។ នាងពោលទៅកាន់ *វ៉ុត្រិច* :

- តែកុង ! *អាន់ជីន-សាន* ឋិតនៅក្រោមកិច្ចគាំពាររបស់អម្ចាស់ *តូរ៉ាណាកា*។ ខ្ញុំសូមអោយគេស្រង់គាត់ឡើងមកវិញភ្លាម ។

- សូមអ្នកស្រីរង់ចាំមួយភ្លែត !

*វ៉ុត្រិច* បន្តខ្សិបប្រាប់ *សាន់ត្យាកូ* ដែលងក់ក្បាលជាប់ ហើយនៅទីបញ្ចប់ស្ទុះចេញទៅភ្លាម ។ រួចទើប *វ៉ុត្រិច* បែរមកនិយាយជាមួយ *ម៉ារីកូ* វិញម្តង :

- សូមទោស *ម៉ារីកូ-សាន*។ *កូមិន តុដាសែ* រឿងនេះបន្ទាន់ណាស់ ។ អា *អ៊ិញគីលីស*



www.budinst.gov.kh www.elibraryofcambodia.org

ត្រូវតែភ្ញាក់ដឹងខ្លួនអោយបានរហ័ស ហើយខ្ញុំដឹងថាវាចេះហែលទឹកហើយ ។ វាត្រូវតែប្រមូលស្មារតីអោយបានលឿនបំផុត ។

- ហេតុអីទៅលោក ?

- ខ្ញុំជាមិត្តរបស់វា ។ អា *អ៊ិញគីលីស* មិនដែលនិយាយប្រាប់អ្នកស្រីទេអ្ហ ?

- ចាសប្រាប់ ។ ប៉ុន្តែ អង់គ្លេសច្បាំងជាមួយប៉កទុយកាល់ ហើយនឹងជាមួយអេស្ប៉ាញផងដែរ ។

- ពិតហើយអ្នកស្រី ។ ប៉ុន្តែពួកគេកុងត្រូវនៅពីលើសង្គ្រាម ។

- បើអញ្ចឹងលោកបំរើអ្នកណា ?

- បំរើទង់ជ័យរបស់ខ្ញុំ ។

- ណឹងមិនមានន័យថាបំរើព្រះរាជាលោកទេរី ?

- បាទផង ទេផង អ្នកស្រី ។ ខ្ញុំជំពាក់គុណអា *អ៊ិញគីលីស* -ភ្នែករបស់ *រ៉ូឌ្រិច* តាមសំលឹងមើលឡុងបុត រួចទើបចេញបញ្ជាទៅអ្នកកាន់ចង្កូត -ត្រង់ ! អីលូវនេះកាច់វាមកតាមបណ្ដោយខ្យល់វិញ ។

- បាទទាន ។

*រ៉ូឌ្រិច* នៅបន្តរង់ចាំ ដោយតាមសង្កេតមើលទៀតពីទិសខ្យល់បក់ ពីបាតខ្សាច់ហើយនឹងឆ្នេរសមុទ្ទដែលនៅទីឆ្ងាយ ។ រួចទើបគេនិយាយឡើង :

- សូមទោស អ្នកស្រីនិយាយថាម៉េចអំបាញ់មិញ ?

*រ៉ូឌ្រិច* ចោលភ្នែកសំលឹង *ម៉ារីកូ* មួយភ្លែត ហើយក៏ងាកទៅតាមពិនិត្យមើលទិសសំពៅរបស់ខ្លួន និងឡុងបុតដដែល ។ *ម៉ារីកូ* ក៏តាមសំលឹងមើលឡុងបុតដែរ ។ ពួកនាវិកបានស្រង់ *ប្លាក់ថន* ចេញពីទឹកទៅដាក់នៅលើឡុងបុត ហើយនាំគ្នាអុំខ្ទីតសំដៅទៅរកទូកធំ ។

*ម៉ារីកូ* មិនអាចមើលឃើញទឹកមុខរបស់ពួកគេបានច្បាស់ឡើយ ។ អីលូវនេះ *ប្លាក់ថន* នៅកំបាំងនឹងបុរសម្នាក់ដែលនៅអង្គុយក្បែរនឹងរូបគេតែម្ដង ។ បុរសនេះគឺជាម្នាក់ដែល *រ៉ូឌ្រិច* បានហៅមកខ្សឹបអំបាញ់មិញនេះឯង ។



www.budinst.gov.kh www.elibraryofcambodia.org

- តើលោកនិយាយប្រាប់ម្នាក់នោះថាម៉េចខ្លះ ?

- អ្នកណា ?

- ម្នាក់នោះ ! ម្នាក់ដែលលោកចាត់អោយទៅតាមមើល *ប្លាក់ថង* នោះណា ។

ចំលើយរបស់ *រ៉ូឡិច* ត្រជាក់ស្រិប :

- គ្មានអីទេ គ្រាន់តែជូនពរល្អដល់អា *អ៊ិញគីលីស* ហើយនឹងលៃលកយ៉ាងណាធ្វើអោយបានលឿនតែប៉ុននោះឯង ។

*ម៉ារីក្វ* ងាកទៅបកប្រែប្រាប់ *កាណា* ពីអ្វីដែលបាននិយាយគ្នានោះ ។

នៅពេលដែលឃើញឡុងបុតអែបខ្លួនទៅនឹងទូកធំហើយនោះទើប *រ៉ូឡិច* ដកដង្ហើមបន្ទូរទ្រូងឡើងយូរតែម្តង !

- ឱព្រះអង្គអើយព្រះអង្គ.......

លោកមេបញ្ជាការ ហើយនឹងពូកយេស៊ុតឡើងមកខាងលើសំពៅវិញ ដោយមាន *តូរ៉ាណាកា* និងអង្គរក្សលោកតាមប្រកិតពីខាងក្រោយផង ។

*កែរីរ៉ា* និយាយឡើង :

-*រ៉ូឡិច* ! ដាក់ឡុងបុតចុះ ! ព្រះតេជគុណត្រលប់ទៅប្រាំងវិញ ។

- រួចហើយ ធ្វើអីទៀត ?

-រួចហើយយើងចេញសំពៅ ។ទៅ *យេដូ*។

*រ៉ូឡិច* តបទៅវិញ ទាំងធ្វើមុខដូចជាមិនដឹងអ្វីទាំងអស់ :

- រួចយ៉ាងម៉េចបានជាទៅ *យេដូ*វិញ ? ក្រែងយើងទៅ *ម៉ាកាវ* អ្ហ ?

- យើងត្រូវជូន *តូរ៉ាណាកា* ត្រលប់ទៅ *យេដូ* សិន ។

- ថាម៉េច ? រួចចុះអាទូកធំនោះគិតយ៉ាងម៉េច ?

- វានៅកន្លែងហ្នឹង រឺមួយក៏វាវៃវៀកច្រកចេញខ្លួនវាទៅចុះ ។

*រ៉ូឡិច* កាន់តែមានការភ្ញាក់ផ្អើលខ្លាំងឡើងថែមទៀត ។ គេចោលភ្នែកសំលឹងមើលទៅទូកធំ រួចទៅ *ម៉ារីក្វ* ។ នៅក្នុងក្រសែភ្នែករបស់នាង *រ៉ូឡិច* បានប្រទះឃើញនូវការចោទប្រកាន់



www.budinst.gov.kh www.elibraryofcambodia.org

មួយយ៉ាងច្បាស់ក្រលែត ។

- *ម៉ាត់ស៊ី -វ៉ូឡិច* និយាយបន្ទាបសំលេងទៅកាន់ *ម៉ារីកូ*។

បព្វជិត *អាល់វីតូ* ជ្រែកសួរភ្លាម :

- ថាម៉េច ? អត់ធ្មត់ ? ហេតុអីបានជាត្រូវអត់ធ្មត់ អ្នកស *វ៉ូឡិច* ?

- ខ្ញុំគ្រាន់តែប្រាប់អ្នកស្រីនេះថាអោយអត់ធ្មត់ក្នុងការរៀនធម៌តែប៉ុននោះទេតេជគុណ ។

*កែវីរ៉ា* សំលឹងមើលទៅទូកធំភ្លែ :

- រួចចុះ ឡូងបុតយើងទៅធើអីនៅឯទូកធំនោះវិញ ?

- ខ្ញុំបញ្ជូនអាទមិឡនោះត្រលប់ទៅទូកនោះវិញណា ។

- លោកថាម៉េច ?

- ថាខ្ញុំបញ្ជូនអា *អ៊ិញគីលីស* នោះទៅទូកធំវិញហើយ ។ រួចវាមានបញ្ហាអីទៅលោកមេបញ្ជាការ ? អា *អ៊ិញគីលីស* ហ៊ានប្រមាថខ្ញុំ អញ្ចឹងហើយខ្ញុំត្រវែងវាទំលាក់ទឹកទៅ ។ ខ្ញុំចង់អោយវាលង់ទឹកងាប់ស្រលះបាត់ពីមុខពីមាត់ តែអានេះវាចេះហែលដែរ អញ្ចឹងហើយខ្ញុំក៏អោយពួកយើងស្រង់វា ហើយបញ្ជូនវាទៅទូកធំវិញទៅ ព្រោះមើលទៅអានេះដូចជាបានលោក *តូរ៉ាណាកា* ពេញចិត្តវាណាស់ ។ វាមានអីខុសទៅ ?

- ទៅយកវាមកសំពៅនេះវិញ ។

- បើអញ្ចឹងខ្ញុំមានតែបញ្ជូនកងវរៈលុកម៉ាកងតែម្តង លោកមេបញ្ជាការ ។ តើលោកចង់អញ្ចឹងអ្ហី ? វាបានជេរប្រមាថកាតមាន និងដាក់បណ្តាសាពួកយើងចាស់ដៃ ហើយអំបាញ់មិញនេះ ។ លើកនេះ បើអោយវាស្ម័គ្រចិត្តត្រលប់មកវិញនោះ គឺគ្មានផ្លូវទេ ។

- ខ្ញុំចង់បានវាមកនៅលើសំពៅនេះវិញ លឺទេ ?

- រួចចុះវាមានបញ្ហាអីទៅ ? ក្រែងលោកនិយាយថា អាទូកធំនោះវានៅទីណឹង រឺមួយប្រយុទ្ធ រឺចង់ទៅជាយ៉ាងណាអោយវាយ៉ាងម៉េចទៅចុះអញ្ចឹងអ្ហី ? បើអញ្ចឹងមែន វាយ៉ាងម៉េច? អីលូវនេះ អា *អ៊ិញគីលីស* វា ង ក ហើយ ។ ហើយណឹងល្អណាស់ទៅហើយ ។ ម៉្យាងទៀតអ្នកណាទៅចង់បានអាមនុស្សច្រលោងខាមបែបនេះមកធើអី ? ហើយខាងតេជគុណជាបព្វជិតវិញរិតតែ



www.budinst.gov.kh www.elibraryofcambodia.org

លែងចង់ឃើញមុខវាណាស់ទៅទៀត មិនអញ្ជើងអ្វី តេជគុណ ?

*ដៃឡាកា* ឥតឆ្លើយតបមួយម៉ាត់ ។ ទាំងបព្វជិត *អាលរីតូ* ក៏អញ្ចឹង ។ ហេតុការណ៍នេះបានបំផ្លាញនូវគំរោងការដែល *កែរីក* បានលើកឡើង ហើយដែលទាំងអស់គ្នាបានឯកភាពតាមដោយរួមទាំង *តូរ៉ាណាកា* ផងដែរ នោះគឺពួកបព្វជិតវិលត្រលប់ទៅដីគោកវិញហើយនិយាយលួងលោមបន្ថយកំហឹងរបស់ *អ៊ីស៊ីដូ គីយ៉ាម៉ា* និង *អូណូស៊ី* ដោយអះអាងថាពួកគេបានជឿតាមរឿងពួកចោរសមុទ្រដែល *តូរ៉ាណាកា* បានប្រឌិតឡើង ហើយពួកគេគ្មានដឹងពាក់ព័ន្ធចំណោះសោះពីរឿងគេចខ្លួនរបស់ *តូរ៉ាណាកា* នោះ ។ ក្នុងពេលទន្ទឹមគ្នានេះ សំពៅនឹងបើកបុកទំលាយមាត់ច្រកសមុទ្រដោយទុកចោលទូកធំនៅក្នុងកណ្ដាប់ដៃរឹងទូកទេសាទទាំងនោះ ។ បើសិនជាសំពៅត្រូវរងការវាយប្រហារជាចំហពួកគេអាចប្រើកាណុងវាយបំបែកចេញបានយ៉ាងងាយ ។

- ប៉ុន្តែពួកទូកនឹងមិនវៃប្រហារពួកយើងឡើយ -*កែរីក* បានខិតខំពន្យល់ម្ដងទៀត- ពួកសត្រូវឡោមចាប់ទូកធំឯនោះទេ គឺជាភារកិច្ចរបស់ព្រះតេជគុណហើយដែលត្រូវពន្យល់បញ្ចុះបញ្ចូល *អ៊ីស៊ីដូ* ថាយើងគ្មានជំរើសអ្វីក្រៅពីនេះទេ ។ ហើយបើគិតអោយសព្វ១ទៅ *តូរ៉ាណាកា* គឺជាប្រធាននៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិផង ។ ម្យ៉ាងវិញទៀតយើងបានអាទមិឡនេះនៅលើសំពៅយើងហើយ ។

ពេលនោះ គ្មានបព្វជិតអង្គណាមួយសួរថាហេតុអ្វីឡើយ ហើយ *កែរីក* ក៏មិនរវល់នឹងប្រាប់មូលហេតុដែរ ។

ព្រះតេជគុណគណៈអធិការសង្ឃកាន់ដៃរបស់លោកមេបញ្ជាការយ៉ាងថ្នម ហើយលោកបែរខ្នងទៅរកទូកធំវិញ :

- ប្រហែលជាប្រការល្អមួយដែរ ដែលអាទមិឡវានៅលើទូកធំនោះ

លោកពោលពាក្យបណ្ដើរ ថែមទាំងនឹកគិតនៅក្នុងចិត្តបណ្ដើរពីភាពចំលែកនៃការកំនត់របស់ព្រះជាម្ចាស់ ។

មិនមែនប្រការល្អទេ -*កែរីក* ស្រែកនៅក្នុងចិត្ត ។ អញចង់ឃើញវាលង់ទឹកងាប់ ។ ចង់អោយវាធ្លាក់ទឹកសមុទ្រនាពេលព្រលឹមអុរ ។គ្មានស្លាកស្នាម គ្មានសាក្សី ។ ចំជាងាយដូចបកចេក ។



www.budinst.gov.kh www.elibraryofcambodia.org

*តូវ៉ាណាកា* មិនអាចវាងវៃហួសណាស់ណាទេ។ យ៉ាងច្រើនអាគាត់ហ្នឹង ចាត់ថានេះជារឿងគ្រោះថ្នាក់មួយតែប៉ុណ្ណោះ ។ ហើយនេះជាវាសនារបស់អា *ធ្នាក់ផន* ដែលព្រះ លោកគូសមក។

*តូវ៉ាណាកា* សួរទៅអ្នកទាំងឡាយដែលមានមុខនៅទីនោះ :

- *ណាន* ចា ?

បព្វជិត *អាល់វីតូ* ក៏ចាប់ផ្ដើមពន្យល់ពីប្រការដែល *ធ្នាក់ផន* ស្ថិតនៅលើទូកធំ និងហេតុអ្វីគេបានទៅដល់ទីនោះ ។ *តូវ៉ាណាកា* ងាកបែរទៅរក *ម៉ារីកូ* ងក់ក្បាលឯកភាពតាមការពន្យល់នេះ ហើយនឹងពោលប្រាប់បន្ថែមពីសំដីរបស់ *រ៉ូឌ្រិច* ដែលបាននិយាយឡើងនៅពេលមុននេះថែមទៀតផង ។

*តូវ៉ាណាកា* ដើរទៅតែមសំពៅ ហើយប្រឹងបើកភ្នែកមើលកាត់ស្បៃរាត្រី ។ ទូកនេសាទត្រូវគេទំលាក់ចុះទឹកបន្ថែមទៀតពីច្រាំងខាងជើង ហើយមួយចំនួននឹងមកពង្រាយខ្លួនតាមទីតាំងដែលបានកំនត់នៅពេលខាងមុខបន្តិចទៀតនេះ ។ លោកយល់ច្បាស់ណាស់ថា *អាន់ជីន-សាន* គឺជាអ្នឹងនយោបាយមួយដែលនៅស្លាក់ក្នុងបំពង់ករបស់លោក ហើយនេះគឺជាផ្លូវដោះស្រាយយ៉ាងសាមញ្ញបំផុត ដែលទេវតាប្រទានអោយ បើសិនជាលោកចង់កុំអោយបុរសនេះនៅទើសទែងលោកទៀត ។ តើអញចង់អញ្ចឹងអ្វី ? ពួកបព្វជិតគ្រីស្ដសាសនិកពិតជាសប្បាយចិត្តអស្ចារ្យតែម្ដងហើយបើសិនជាតែកុងនេះអន្តរធានបាត់ទៅ -លោកគិតនៅក្នុងចិត្ត ។ ទាំង *អូណូស៊ី* និង *គីយ៉ាម៉ា* ក៏តែអញ្ចឹងដែរ ព្រោះដោយសារតែខ្លាចបុរសនេះហើយបានជាអ្នកណាម្នាក់ក្នុងចំនោមអ្នកទាំងពីរនេះ រឺ ទាំងពីរនាក់នេះតែម្ដងបានលើកផែនការធ្វើឃាតនោះឯង ។ ប៉ុន្ដែហេតុអីបានជាពួកនេះខ្លាចដល់ថ្នាក់ហ្នឹង ?

នេះពិតជា *កាម៉ា* ហើយដែលបណ្ដាលអោយ *អាន់ជីន-សាន* មិនស្ថិតនៅដោយសុខសាន្តលើសំពៅ ហើយបែរជាទៅនៅលើលើទូកធំវិញនោះ។ *អាន់ជីន-សាន* នឹងត្រូវលិចចុះទៅក្នុងសមុទ្ទជាមួយទូកធំ ជាមួយ *យ៉ាប៊ូ* ជាមួយអ្នកឯទៀត ជាមួយនឹងកាំភ្លើងទាំងឡាយហើយនេះក៏ជា *កាម៉ា* ដែរ ។ កាំភ្លើងអញអាចបាត់បង់បាន *យ៉ាប៊ូ* អញអាចបាត់បង់បាន ។ តែចុះ *អាន់ជីន-សាន* ?



www.budinst.gov.kh www.elibraryofcambodia.org

បាន ។

ពីព្រោះអញនៅមានពួកចុងស្រុកចំលែកទាំងនេះប្រាំបីនាក់ទៀតត្រៀមបំរុងទុកដែរ ។ អាចថាការចេះដឹងរបស់ពួកវាទាំងនេះផ្ទុយគ្នាទៅអាចលើស រឺក៏ស្មើនឹងមនុស្សនេះតែម្នាក់ឯងផង ក៏មិនដឹង ។រឿងដែលសំខាន់គឺវិលត្រលប់ទៅ *យេដូ* វិញអោយបានកាន់តែឆាប់ពេលណាល្អពេលនោះដើម្បីរៀបចំសង្គ្រាម ។ ព្រោះសង្គ្រាមមិនអាចចៀសផុតបានទេ ។ *គីយ៉ាម៉ា* និង *អូណូស៊ី* ? អ្នកណាទៅដឹងថាតើពួកវាទាំងពីរនាក់នេះនឹងគាំទ្រអញ រឺអត់អញ្ចេះ ។ អាចវាគាំទ្រ អាចវាអត់ ។ ដី ពីរបីអំពក ពាក្យសន្យាបួនដប់ម៉ាត់គ្មានប៉ុន្មានទេ បើសិនជាក្នុងសែសិបថ្ងៃអញបានការគាំទ្រពី ពួកគ្រីស្តសាសនិកនោះ ។

- នេះគឺជា *កាម៉ា* មែនទេ *ឈូតូ-សាន* ?

- ពិតមែនហើយ លោកម្ចាស់ ។

*អាលវីតូ* ចោលភ្នែកសំលឹងមើលលោកមេបញ្ជាការ ទាំងសែនរីករាយនៅក្នុងចិត្ត រួចទើបពោលបន្ត :

- លោកម្ចាស់ *តូរ៉ាណាកា* ជួយអោយយោបល់ថាអ្វី១មិនចាំបាច់កែប្រែទេ នេះគឺជាឆន្ទៈរបស់ព្រះជាម្ចាស់ហើយ ។

- មែនអ្វី ?

សំលេងស្គរនៅលើទូកចំលាន់ឡើងយ៉ាងថៃដន់ ។ ច្រវាចាប់ផ្តើមកាយទឹកយ៉ាងស្វាហាប់ផងដែរ ។

*ហ៊ីរ៉ូ* ស្រែកសួរឡើងយ៉ាងអស់សំលេង :

- រួចចុះវាប្រកាច់ធ្វើអីទៀតហើយណឹង ?

ពួកគេចោលភ្នែកឃើញទូកចំចាប់ផ្តើមចេញឃ្លាតពីសំពៅបណ្តើរ ទន្ទឹមនឹងទង់សំគាល់របស់ *តូរ៉ាណាកា* ត្រូវគេបង្ហូតចុះពីលើដងក្តោងបណ្តើរ ។

*រ៉ូឌ្រិច* និយាយ :

-មើលទៅ ទំនងជាវាកំពុងប្រាប់ទៅអាទូកនេសាទចោលម្រ៉ាយទាំងប៉ុន្មាននៅក្នុងឆក



www.budinst.gov.kh www.elibraryofcambodia.org

សមុទ្រនេះ ថាលោកម្ចាស់ *តូរ៉ាណាកា* មិនស្ថិតនៅលើទូកធំនោះទៀតទេ ។

- រួចចុះវាកំពុងតែធ្វើអីណឹង ?

- ខ្ញុំមិនដឹងដែរ ។

*វ៉េរីរ៉ា* សួររន្ថើន :

- លោកមិនដឹងមែន ?

- មិនដឹងមែន ។ តែបើខ្ញុំជាវាវិញ ខ្ញុំនឹងចេញទៅលំហសមុទ្រហើយទុកពួកយើងអោយនៅស៊ីអាច់កន្លែងនេះតែម្តង រឺយ៉ាងហោចណាស់ក៏សាកចេញទៅលំហសមុទ្រដែរ ។ អីលូវនេះ អា *អ៊ិញគីលីស* ស្រោចគល់អោយយើងវិញហើយ ។អីលូវនេះតើវានឹងទៅជាយ៉ាងណាទៅ ?

- លោកទទួលបញ្ជាអោយចេញទៅ *យេដូ* ណា !

មេបញ្ជាការ *វ៉េរីរ៉ា* និយាយ ។ ហើយបើអ្នែងបើកគិនកំទេចទូកធំនេះបានរិតតែល្អ - លោកគិតនៅក្នុងចិត្ត ហើយដែលលោកស្ទើរតែនិយាយចេញ ។ ប៉ុន្តែ *ម៉ារីកូ* នៅតែកំពុងស្តាប់ពួកលោកនិយាយគ្នានៅឡើយ ។

ពួកបព្វជិត ជិះឡុងបុតវិលទៅរកដីគោកវិញហើយ ។

- តំលើងក្តោងទាំងអស់ភ្លាម !

*វ៉ូត្រិច* ស្រែកចេញបញ្ជាយ៉ាងអស់ទំហឹង ។ ជើងរបស់គេនៅឈឺពើតនៅឡើយ ។

*វ៉េរីរ៉ា* និយាយទៅកាន់ *ម៉ារីកូ* :

- សូមអ្នកស្រី ជំរាបទៅលោកម្ចាស់ *តូរ៉ាណាកា* ថាសូមគាត់អញ្ជើញចុះទៅខាងក្រោមទៅ ព្រោះវាមានសន្តិសុខជាង ។

- លោកម្ចាស់ខ្ញុំសូមអរគុណលោកហើយ ប៉ុន្តែលោកមានប្រសាសន៍ថាលោកនៅខាងលើនេះហើយ ។

*វ៉េរីរ៉ា* ញាក់ស្មា ហើយដើរទៅផ្លុងកិងសំពៅ :

- ច្រកកាណុងហើយ ត្រៀមចាំបាញ់ ! ទាំងអស់គ្នាទៅកាន់កន្លែងប្រយុទ្ធភ្លាម ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៨

- *អ៊ីស៊ូតី !*

*ប្លាក់ថន* ស្រែកសន្ទាប់បង្គំអោយមេច្រវ៉ាបង្កើនល្បឿន ។ គេងាកក្រោយសំលឹងមើលសំពៅដែលកំពុងប្រដេញតាមពីក្រោយយ៉ាងអស់ល្បឿនរួចបែរមើលទៅខាងមុខ ដើម្បីប្រមាណពីទិសដែលសំពៅនេះនឹងប្រកាន់យក ។ គេដណ្ដឹងសួរនៅក្នុងចិត្តពីភាពត្រឹមត្រូវនៃការសំរេចរបស់គេដោយហេតុថា ច្រកនៅចន្លោះថ្មប៉ប្រះទឹកមានទំហំសែនតូចចង្អៀត ពោលគឺខុសគ្នាតែប៉ុន្មានម៉ែតនោះរវាងជោគជ័យ នឹងមហន្តរាយ ។ អាស្រ័យដោយទិសខ្យល់បក់សំពៅត្រូវកាច់កុងតាមទិសខ្យល់ដែរ ទើបចេញពីច្រកផែរួច ផ្ទុយស្រលះពីទូកចែវដែលអាចបត់បែនតាមចិត្តចង់របស់ខ្លួនបាន ។ ប៉ុន្តែសំពៅឈ្នះទូកនៅត្រង់ល្បឿន ។ ដោយហេតុនេះហើយទើបនៅពេលសំពៅស្ថិតនៅក្រោមខ្យល់ហើយ *រ៉ូឌ្រិច* បានសំញែងអោយទូកធំឃើញយ៉ាងច្បាស់ថាយកល្អមិនត្រូវមករវីមរវាមអីនៅពេលដែលសំពៅ *សាន់តា ថេរេសា* ត្រូវការទីដើម្បីបើកបរឡើយ ។

*យ៉ាប៊ូ* និយាយវ៉ូសវ៉ាសដាក់ *ប្លាក់ថន* ប៉ុន្តែគេឥតរវល់យកចិត្តទុកដាក់ស្ដាប់ឡើយ ។

- ស្ដាប់មិនយល់ទេ *វ៉ាការីម៉ាសេន យ៉ាប៊ូ-សាន !* ស្ដាប់ខ្ញុំណា *តូរ៉ាណាកា-សាម៉ា* បាននិយាយថា ខ្ញុំគឺ *អានជីន-សាន អ៊ីជី-បាន អ៊ិម៉ា !* ខ្ញុំជានាយសំពៅនៅពេលនេះ ! *វ៉ាការីម៉ាស៊ិកា យ៉ាប៊ូ-សាន ?*

រួច *ប្លាក់ថន* ចង្អុលទិសលើដែកឈានប្រាប់ទៅនាយកងទូកជប៉ុនដែលកំពុងលើកដៃគ្រវីគ្រវ៉ាត់ជាសញ្ញាដាក់សំពៅដែលនៅប្រហែលសែសិបម៉ែតពីក្រោយ ហើយដែលខិតកាន់តែជិតគំរង់មកបុកចំទូកធំដើម្បីដណ្ដើមច្រកចេញនេះ ។

- កុំបែរក្បាលទូក រិបល់យក៏ !

*ប្លាក់ថន* ស្រែកឡើង ។ ខ្យល់ជំនោរធ្វើអោយអាវទទឹកជោករបស់គេឡើងត្រជាក់ស្រិប ខ្លួនប្រាណគេឡើងញ័ររំប្រប់ប៉ុន្តែភាពត្រជាក់នេះ ជួយគេអោយមានស្មារតីភ្លឺស្រលះផងដែរ ។ គេងើយសំលឹងមើលមេឃ ។ គ្មានពពកមួយដុំណានៅក្បែរព្រះច័ន្ទដ៏ភ្លឺថ្លាឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

កំលាំងខ្យល់មានជាមធ្យម ។ ដូចនេះគ្មានបញ្ហាពីរឿងនេះទេ *-ប្លាក់ថន* គិតនៅក្នុងចិត្ត ។ ឱព្រះអើយព្រះ សូមអោយព្រះខែនៅតែភ្លឺរហូតយើងផុតច្រកចេញផងចុះ ។

- អេ មេបញ្ជាការ ! *-ប្លាក់ថន* ស្រែកហៅជាភាសាអង់គ្លេស ដោយគេដឹងថាទោះគេប្រើភាសាអង់គ្លេស រឺ ប៉កទុយកាល់ រឺ ហូឡង់ រឺ ឡាតាំង ក៏មិនខុសអីគ្នាដែរដោយថានៅលើទូកធំនេះមានតែរូបគេម្នាក់ឯងប៉ុននោះ -អោយអ្នកណាទៅយកស្រាសាកេមក ! *សាកេ ! វ៉ាកាវី-ម៉ាស៊ុ កា ?*

*- ហៃ អានជីន-សាន* ។

នាវិកម្នាក់ត្រូវបានប្រើទៅរកស្រាប្រញាប់ ។ *ប្លាក់ថន* ងាកសំលឹងមើលទៅរាងដ៏ធំស្បើមនៃតួសំពៅដែលកាន់តែខិតចូលមកក្នុងល្បឿនយ៉ាងលឿនគួរអោយស្ញើប ។ *ប្លាក់ថន* នៅតែរក្សាក្បាលទូកក្នុងទិសជាមួយសំពៅដដែល ក្នុងបំនងបង្ខំអោយសំពៅបែរក្បាលចេញមុនពេលដែលវាជក់ខ្យល់ជែងទូកទៅមុខបាន ។ ប៉ុន្តែសំពៅឥតញ្ញោចបន្តិចណាសោះឡើយ ហើយនៅតែបន្តរុលមកមុខតំរង់ចំតួទូកធំដដែល ។ នៅនាទីចុងក្រោយ គេងាកទូកចេញពីមុខសំពៅហើយ នៅពេលដែលក្បាលសំពៅមកស្ទើរតែនឹងសង្កត់កន្សៃទូកហើយនោះ សំលេងបញ្ជោរបស់ *វ៉ូគ្រិច* បានលាន់លឺឡើង :

- ទៅស៊ីក្រមរនរកអោយស្រលះស្រលែងទៅ *អាអ៊ិញគីលីស !*

-ម៉ែអ្ហែងទៅមុនអញហើយទេតើ *អាវ៉ូគ្រិច !*

ក្នុងមួយរយៈពេលយ៉ាងខ្លី នាវាទាំងពីរបានខិតចូលជិតស្ទើរប៉ះគ្នាតែម្តង ។ ទាំង *វ៉ូគ្រិច* ទាំង *តូរ៉ាណាកា ម៉ារីកូ* និង មេបញ្ជាការ ទប់ខ្លួនទាំងទ្រេតទ្រោតនៅលើកិងសំពៅ ។

រួចទើបសំពៅងាកចេញវិញបន្តិចធ្វើអោយសំពៅទាំងមូលលោតបំផ្លោតលើរលកដែលតួសំពៅបង្កឡើងនោះ ។

*- អ៊ីសូគី ! អ៊ីសូគី !*

ក្រុមចែវកាន់តែប្រឹងមួយជាទ្វេ ។ *ប្លាក់ថន* ធ្វើសញ្ញាអោយបន្ថែមអ្នកចែវរហូតដល់អស់ទាំងក្រុមបំរុងថែមទៀត ។ គេត្រូវទៅដល់ច្រកចេញមុនសំពៅ បើមិនដូចនោះទេ



www.budinst.gov.kh www.elibraryofcambodia.org

ពួកគេពិតជារលត់រលាយជាមិនខាន ។

ទូកធំកាន់តែរុលទៅមុខ តែសំពៅក៏មិនព្រមចាញ់ទីដែរ ។ *ភ្លាក់ថន* ឃើញ *រ៉ូទ្រិច* តំលើងក្តោងបន្ថែមទៀត :

- ពួកអាប៉ក់ទុយកាល់អស់នេះ មួយណាក៏សុទ្ធតែកន្ទុយខ្មៀនដូចគ្នាទាំងអស់តែម្តងមែន !

*សាកេ* ត្រូវបានយកមកដល់ ។ យុវនារីម្នាក់ដែលបានជួយ *ម៉ារីកូ* បានទទួលយកស្រាពីដៃនាវិកនោះយកមកចាក់ហើយប្រគល់យ៉ាងថ្នមៗទៅ *ភ្លាក់ថន* ។ នារីនេះនៅឈរយ៉ាងក្លាហាននៅលើកឹងទូក ទោះជាកន្លែងនេះមិនជាទីកន្លែងការងាររបស់នាងយ៉ាងណាក្តី ។ ដៃរបស់នាងរឹងមាំ សក់នាងសិតយ៉ាងស្អាតបាត ហើយ *គីម៉ូណូ* នាងមានភាពល្អស្រស់និងស្អាតភ្លឹង ។ ទូកហក់មួយវិបលើរលកធ្វើអោយនារីភ្ញាត់ជំហរធ្លាក់កែវពីលើដៃមួយរំពេច ។ ពិតមែនតែទឹកមុខនាងឥតប្រែប្រួលតែ *ភ្លាក់ថន* ឃើញយ៉ាងច្បាស់នូវភាពខ្មាសអៀនរបស់នាង ។ គេពោលទៅកាន់នាង :

- *ប៊ ណាដា* - មិនអីទេ ។ *ណាម៉ាអេ កា* ?

- *អ៊ូសាគិ ភូជីកូ អានជីន-សាន* ។

- *ភូជីកូ-សាន* ហុចស្រាមកអោយខ្ញុំ *ដូសូ* ។

រួច *ភ្លាក់ថន* ឈោងដៃទៅយកថូស្រាហើយក្រេបផឹកផ្ទាល់ ដើម្បីយកជាតិសុរាទៅកំដៅក្នុងខ្លួនរបស់គេផ្ទាល់តែម្តង ។ បន្ទាប់មកគេផ្តោតការយកចិត្តទុកដាក់ទៅលើមុខទិសរបស់ទូក ពិសេសទៅលើផ្លូកខ្សាច់ដែល *សានត្សាកូ* បាននិយាយប្រាប់គេតាមបញ្ជារបស់ *រ៉ូទ្រិច* ។ ខួរក្បាលរបស់គេឡើងភ្លឺថែស ហើយគេមានអារម្មណ៍ដូចជាខ្លាំងក្លាជាងមុន តែគេត្រូវមានការប្រយ័ត្នប្រយែងដោយថា រូបគេគ្មានសល់កំលាំងបំរុងណាដល់ពាក់តូចឡើយមិនខុសអ្វីពីទូកធំដែលបានប្រើអស់នូវកំលាំងបំរុងរបស់ខ្លួនយ៉ាងដូចនោះដែរទេ ។

- *សាកេ ដូសូ ភូជីកូ-សាន* ។

និយាយបណ្តើរគេហុចថូស្រាទៅនាងវិញបណ្តើរហើយភ្លេចនាងបាត់ទៅ ។ ដោយ



www.budinst.gov.kh www.elibraryofcambodia.org

ស្ថិតចំក្រោមជំនោរនៃខ្យល់សមុទ្រហើយនោះ សំពៅបោះពួយយ៉ាងលឿនតំរង់ទៅរកច្រកចេញ ដោយទុកទូកធំនៅពីក្រោយប្រហែលជិតមួយរយម៉ែត ។ សំលេងជេរបញ្ចោររបស់ *វ៉ុន្រ៉ិច* លាន់លឺល្វើយ១មកដល់ត្រចៀក *ប្លាក់ថន* ប៉ុន្តែគេឥតរវល់យកចិត្តទុកដាក់ដល់ឡើយដោយគេត្រូវប្រមូលផ្តុំថាមពលរបស់គេទៅលើរឿងផ្សេងវិញ :

- *អ៊ីស្ទូតី* ព្រះអើយព្រះ ពួកយើងចាញ់ទឹកគេហើយ !

ការរំភើបរីករាយនៅក្នុងចិត្តបណ្តាលមកពីការប្រដេញប្រជែងគ្នា និង ប្រការដែលគេនៅឈរបញ្ជាតែអង្គឯងដូចមុន បន្ថែមទៅលើបុព្វសិទ្ធិដ៏កំរដែលធ្វើអោយ *យ៉ាប៊ូ* ស្ថិតនៅក្រោមអំនាចរបស់ខ្លួននោះ ធ្វើអោយ *ប្លាក់ថន* សែនរីកឡើមប្រមាត់ ជាពន់ពេក-បើកុំតែអញមិនចង់អោយទូកនេះលិចងាប់ទាំងអញ កុំអីអញតំរង់ទូកនេះអោយចំផែនថ្មមើលមុខអាជ្រលក់អាច់ *យ៉ាប៊ូ* នេះលង់ទឹកសងសឹកអោយអាកញ្ចាស់ *គីតែស៊ូន* ម្តងហើយ ។

ប៉ុន្តែមិនគឺ *យ៉ាប៊ូ* នេះទេអ្វីដែលបានជួយយកអាសារ *វ៉ុន្រ៉ិច* នៅពេលដែលអ្នែងមិនអាចជួយបាននោះ ? មិនគឺវាទេអ្វីដែលបានកំចាយពួកចោរប្លន់នៅពេលដែលអ្នែងត្រូវតេពួនស្ងាក់នេះ ? ហើយយប់នេះទៀតសោតវាក៏ក្លាហានចំនាប់ណាស់ដែរ ។ គិត១ទៅ ពិតមែនតែវាជាមនុស្សពាល តែជាពាលក្លាហានម្នាក់ ។ ថូសាកេ ត្រូវបានចាក់ហុចមកទៀត ។ *ដូម៉ូ ប្លាក់ថន* ឆ្លើយទទួលយកស្រា ។ សំពៅលូនលឿនស្ទើរលើផ្ទៃទឹក ។

- អញក៏មិនគ្រាន់បើជាងហ្នឹងដែរ - *ប្លាក់ថន* និយាយខ្លាំង១កាត់ជំនោរខ្យល់ -តែបើអញមានសំពៅនេះវិញ អញនឹងទំលាយក្បួនទូកទាំងនេះចេញទៅ នាយសមុទ្រហើយស្បថលែងមកវិញរហូត ។ អញទៅដេកឯផ្ទះអញវិញ ហើយទុកស្រុកជប៉ុននេះ អោយពួកជប៉ុននិងពួកអារំបល់យក៏បិកទុយកាល់នេះចុះ ។

*ប្លាក់ថន* ប្រទះឃើញក្រសែភ្នែក *យ៉ាប៊ូ* និង នាយសំពៅលំលឹងផ្ទាំងមករកគេ ។

- ទេ មិនទាន់ទៅទេ ។ នៅរឿងចាប់ *សំពៅខ្មៅ* ប្រមូលទ្រព្យសិន ។ ហើយនៅរឿងសងគំនុំឈាមទៀតមែនទេ *យ៉ាប៊ូ-សាន* ?

- *ណានគេស៊ូកា អានជីនសាន ? ណានចា ?*



www.budinst.gov.kh www.elibraryofcambodia.org

- *អ៊ីជី-បាន !* លេខមួយ ! -*ប្លាក់ថន* ឆ្លើយតប ដោយគ្រវីដៃទៅរកសំពៅផង ។ រួចគេភ្ញើយ ថូអកស្រាទាំងអស់តែម្តង ។

*ភូជីកូ* ទទួលយកថូស្រាពីដៃ *ប្លាក់ថន* ជាមួយនឹងសំនួរ :

- *សាកេ អានជីន-សាន ?*

- *ដូម៉ូ អ៊ីយេ !*

នាវាទាំងពីរកាន់តែចូលទៅជិតរូងទូកនេសាទហើយ ។ សំពៅបែរក្បាលតំរង់ចំមាត់ច្រកខ្សែទូកដែលគេបើកទុកអោយជាស្រេច ។ នៅទីនេះខ្យល់មានភាពត្រជាក់ជាងមុនដោយហេតុគេបានចេញផុតពីទួលខ្ពស់ដែលបាំងការពាររឆកសមុទ្រនេះហើយ។ លំហសមុទ្រស្ថិតនៅក្នុងចំងាយប្រហែល ៨០០ម៉ែត ឯខាងមុខប៉ុននោះ ។ ក្រុមដងថៃវមានញើសដាបខ្លួន ។ បុរសម្នាក់ដួលខ្ពាកដោយការហេវហត់ ។ រួចម្នាក់ទៀត ។ ពួក *រ៉ូនីន-សាមូរ៉ៃ* ទាំងជាងហាសិបប្លាយនាក់បានត្រៀមខ្លួនប្រយុទ្ធហើយជាស្រេច ។ នៅឯលើទូកនេសាទទាំងសងខាងមាត់ច្រកឯខាងមុខនោះវិញ ពួកខ្មាន់ធ្នូក៏បានតំលើងធ្នូជាស្រេចហើយដែរ ។ *ប្លាក់ថន* ក្រលេកឃើញភ្លក់ភ្លើងតូចៗនៅលើទូកជាច្រើនដែលធ្វើអោយគេយល់បានថា នៅពេលដែលព្រួញត្រូវបាញ់ចេញគឺគេនឹងបាញ់ព្រួញភ្លើងហើយ ។

ពេលនេះគេត្រូវត្រៀមប្រយុទ្ធអោយបានល្អបំផុតតាមដែលអាចធ្វើបាន ។ *យ៉ាប៊ូ* ក៏បានយល់ពីស្ថានភាពដែលត្រូវតែប្រយុទ្ធចៀសមិនបាន ហើយនឹងចំនុចព្រួញភ្លើងនេះភ្លាមដែរ។ *ប្លាក់ថន* បានរៀបចំផ្ទាំងក្តារបិទបាំងការពារកន្លែងកាន់ចង្កូតយ៉ាងជុំជិត ។ គេគាស់កែសកាំភ្លើងមូស្គេហើយបំពាក់អោយអ្នកដែលចេះប្រើ ព្រមទាំងយករំសេវជាច្រើនចុងទៀតមកត្រៀមនៅឯកន្លែងជាស្រេច ។

☆ ☆ ☆

នៅពេលដែលបញ្ជាការរង *សានត្យាកូ* បានជួយគេឡើងទូកឡុងបុតនោះ *សានត្យាកូ* បានប្រាប់គេថា *វ៉ូឌ្រិច* នឹងជួយគេបើសិនជាគុណបុណ្យព្រះជួយ ។

- ជួយយ៉ាងម៉េចទៅ ? -*ប្លាក់ថន* សួរ ។



www.budinst.gov.kh www.elibraryofcambodia.org

- តៃកុងខ្ញុំអោយខ្ញុំប្រាប់លោកថា គាត់ត្រូវបោះលោកទំលាក់ទឹកដើម្បីអោយលោកស្វាងដឹងខ្លួនណា ។

- ដោយហេតុអីទៅ ?

- ព្រោះគាត់ថាមានគ្រោះថ្នាក់នៅលើសំពៅ *សាន់តា ថេរេសា* ។ គ្រោះថ្នាក់សំរាប់លោក ។

- គ្រោះថ្នាក់បែបណាទៅ ?

- គាត់បាននិយាយថា លោកត្រូវនៅទៀលរកច្រកចេញដោយខ្លួនឯង នេះបើលោកអាចទៅរួច ។ ប៉ុន្តែគាត់នឹងជួយលោក ។

- ជួយរបៀបម៉េចទៅ ?

- ព្រះអើយព្រះ លោកបិទមាត់ខ្លះហើយចាំស្តាប់ខ្ញុំទៅបានទេ ? ខ្ញុំមានពេលតិចណាស់ ។

រួចនាយរងក៏និយាយប្រាប់ *ប្លាក់ថន* ពីបាតខ្សាច់ ពីច្រកចេញ ហើយនឹងគំរោងផែនការទាំងមូល ។ រួចគេហុចកាំភ្លើងខ្លីពីរដើមអោយទៅ *ប្លាក់ថន* :

- តៃកុងខ្ញុំសួរថា លោកចេះបាញ់គ្រាន់បើទេ ?

- យ៉ាប់ណាស់ -*ប្លាក់ថន* កុហក ។

- រួចតៃកុងខ្ញុំផ្តាំជាចុងក្រោយថា សូមព្រះតាមថែរក្សាលោក ។

- ថែទាំងវា ថែទាំងអែងផង ។

- ខ្ញុំបន់អោយតែលោកចុះនរកទេ ។

- ទុកអោយប្អូនស្រីអែងចុះ ។

☆ ☆ ☆

*ប្លាក់ថន* បានរៀបចំដាក់ឈ្នួនភ្ជាប់ចុងរំសេវទាំងឡាយដើម្បីបង្ការករណីដែលសំពៅប្រើកាណុង រឺនៅពេលដែលផែនការដែលនាយរងប្រាប់នោះជាការក្លែងក្លាយទៅវិញ និងដើម្បីបង្ការពេលនាវាទាំងពីរអែបគ្នាប្រយុទ្ធ ។ ទោះជាចុងរំសេវនេះតូចក្តី តែបើគេបណ្តែតវាអោយ



www.budinst.gov.kh www.elibraryofcambodia.org

ទៅអែបជាប់នឹងសំពៅនោះ វាពិតជាអាចពន្លិចសំពៅនេះបានយ៉ាងប្រាកដមិនចាញ់កំលាំងកាណុងទាំងចិតសិបដើមឡើយ ។

- *អ៊ិស្ងតិ* យករស់វើយ !

*ប្លាក់ថន* ស្រែកបញ្ជាហើយស្រវាចាប់កាន់ចង្កូតទាំងក្នុងចិត្តដឹងគុណចំពោះព្រះដែលបានបន្ទន់ចិត្ត *រ៉ូត្រិច* និងដែលបានធ្វើអោយព្រះច័ន្ទមានពន្លឺភ្លឺច្បាស់នារាត្រីនេះ ។

ច្រកចេញកំពង់ផែមានរាងស្ទួចដូចមាត់ដប និងមានចន្លោះឃ្លាតពីគ្នាប្រហែលជិតបួនរយម៉ែតតែប៉ុននោះ ។ ទឹកនៅចន្លោះនេះជ្រៅគួរសម ។ នៅអមសងខាងគឺជាច្រាំងចោត ។

ខ្សែទូកនេសាទនៅចំងាយប្រហែលប៉ុន្មានរយម៉ែតប៉ុននោះពីនាវាទាំងពីរ ។

សំពៅ *សាន់តា ថេរេសា* កំពុងរត់ជក់ក្តោងបែកទឹកសស្វាចហើយកាន់តែដល្អើមទីបន្តិចម្តង១ ដើម្បីរំកិលយកចំច្រកកណ្តាលចេញទៅលំហសមុទ្រ ។ *ប្លាក់ថន* នៅតែរក្សាមុខទូកអោយនៅចំកណ្តាលមាត់ច្រកចេញដដែល ហើយគេធ្វើសញ្ញាអោយ *យ៉ាប៊ូ* ត្រៀមខ្លួន ។ ពួក *រ៉ូប៊ីន-សាមូរ៉ៃ* ទាំងអស់ត្រូវបានបញ្ជាអោយពួនក្បែរគែមទូកមិនអោយគេឃើញ រង់ចាំ *ប្លាក់ថន* អោយសញ្ញាថាត្រូវវាយលុកខាងណា ។ *យ៉ាប៊ូ* ជាអ្នកដឹកនាំការប្រយុទ្ធនេះ ។ នាយសំពៅជប៉ុនដឹងតែម្យ៉ាងគឺខ្មាន់ចែវរបស់ខ្លួនត្រូវស្តាប់តាមសង្វាក់ស្គរបញ្ជា ហើយអ្នកវាយស្គរបញ្ជាដឹងតែតាមបញ្ជា *ប្លាក់ថន* ហើយគឺមានតែ *ប្លាក់ថន* ម្នាក់ឯងគត់ដែលត្រូវបញ្ជាទូក ។

អីលូវនេះសំពៅនៅប្រហែលហាសិបម៉ែត ហើយតំរង់ក្បាលចំទូកធំបង្ហាញអោយឃើញច្បាស់ថា គេទាមទារច្រកផ្លូវនេះចេញមុន ។

នៅលើសំពៅ *រ៉ែកឺរ៉ា* ខ្សឹបស្ងាត់១ទៅ *រ៉ូត្រិច* ទាំងភ្នែកតាមមើលជាប់ *ម៉ារីកូ* ដែលឈរនៅជាមួយ *តូរ៉ាណាកា* ប្រហែលដប់ជំហានពីពួកគេ :

- បើកជាន់វាទៅ !

- ពួកយើងមិនហ៊ានទេ ។ មាន *តូរ៉ាណាកា* និងនារីនោះនៅទីនេះដែរណា ។

*រ៉ែកឺរ៉ា* បន្លឺឡើង :

- លោកស្រី ! យកល្អ សូមលោកស្រីអញ្ជើញចុះក្រោមជាមួយលោកម្ចាស់របស់



www.budinst.gov.kh www.elibraryofcambodia.org

លោកស្រីទៅ ។ ខាងក្រោមថានាសន្ថិសុខដល់គាត់ល្អជាងនៅលើកិង ។

*ម៉ារីក្លូ* បកប្រែប្រាប់ទៅ *គ្រូរ៉ាណាកា១* សញ្ជឹងគិតមួយសន្ទុះ រួចក៏ដើរចុះទៅក្រោម ។ *កែរីវ៉ា* និយាយម្តងទៀតទៅកាន់ *រ៉ូឌ្រិច* :

- កិនទូកធំនេះទៅ *រ៉ូឌ្រិច* !

- ហេតុអីចាំបាច់សំលាប់វាផ្ទាល់ដៃធ្វើអ្វី បើមានអ្នកផ្សេងចាំធ្វើជំនួសយើងហើយនោះ ?

- ព្រះអើយព្រះ ! អែងយ៉ាប់ជាងពួកបុព្វជិតនោះទៅទៀត ! អែងគ្មានបាតដៃប្រឡាក់ឈាមទេអ្ហី ?

- ពិតហើយ គ្មានបន្តិចណាសោះឡើយ - *រ៉ូឌ្រិច* ឆ្លើយតបជាភាសាអេស្ប៉ាញដូចគ្នា-ចុះលោក ? លោកពិតជាមានមែនទេ ? ប្រហែលឈាមពួកអេស្ប៉ាញមែនទេ ?

- អែងកិនទូកវានេះរឺក៏អត់អ្ហាស ? - *កែរីវ៉ា* ចាក់សួរជាភាសាប៉ក់ទុយកាល់វិញម្តង ។

- បើវានៅម៉ាកខ្លែង ចឹមិនកិន ។

- បើអញ្ជឹងអោយវានៅម៉ាកខ្លែងទៅណាំ !

- តើនៅក្នុងចិត្តលោកអែងចង់ធ្វើអីអា *អ៊ិញគិលីស* នេះ ? ហេតុអីបានជាលោកអែងខឹងដាច់ក្បាលដាច់កន្ទុយដោយគ្រាន់តែវាមិននៅលើសំពៅជាមួយយើង ?

- អីលូវនេះខ្ញុំមិនចូលចិត្តអែងហើយមិនទុកចិត្តអែងទេ *រ៉ូឌ្រិច* ។ ពីរដងហើយដែលអែងចូលដៃជើង រឺ ដូចចូលដៃចូលជើងជាមួយអាទមិឡនេះប្រឆាំងនឹងខ្ញុំ រឺ ប្រឆាំងនឹងពួកយើង ។ បើសិនជានៅម៉ាអាស៊ីនេះមានកែកុងណាសមល្មមគួរបាននោះ ខ្ញុំពិតជាព្រលែងអែងចោលហើយ *រ៉ូឌ្រិច* ។

- បើអញ្ជឹងមែនលោកប្រាកដជាលិចសំពៅងាប់ជាមិនខាន ព្រោះលោកអែងមានប្រផ្នូលតែហោងផងទាល់តែខ្ញុំទើបជួយស្រោចស្រង់ទើបរួច ។

*កែរីវ៉ា* លើកដៃធ្វើសញ្ញាខ្វែងបញ្ជៀសគ្រោះក្នុងជំនឿសិប់ :



www.budinst.gov.kh www.elibraryofcambodia.org

- ព្រះអង្គអើយ អែងអីក៏អណ្ដាតត្រិចម្ល៉េះ ? ហេតុអីអែងហ៊ានទិយាយបែបនេះ ?

- ម៉ែខ្ញុំមានសញ្ជាតិស៊ីបស៊ី (*) ហើយជាកូនទីប្រាំពីរក្នុងកូនទាំងប្រាំពីរនាក់ ហើយខ្ញុំក៏អញ្ចឹងដែរ ។

- កុហក !

*រំខ្មិច* ញញឹម :

- ប្រហែលដែរ ។

រួច *រំខ្មិច* ក្ដោបមាត់ស្រែកឡើង :

- ត្រៀម !

ហើយគេងាកប្រាប់ទៅខ្មាន់ចង្កូត :

- ត្រង់ទៅមុខ ហើយបើអាទូកលលាដ៏ដូងនេះវាមិនងាកចេញទេ ជាន់ពន្លិចវាទៅ !

☆ ☆ ☆

*ភ្នាក់ផន* កាន់ចង្កូតយ៉ាងរឹងមាំ ដៃនឹងជើងគេឡើងចុកចាប់ទ្រាំស្ទើរមិនបាន ។ អ្នកវាយស្គរបញ្ជាទូងស្គរស្ទើរបែក ឯអ្នកចែវក៏បានបញ្ចេញកំលាំងជាចុងក្រោយផងដែរ ។

អីលូវនេះសំពៅនៅប្រហែលម្ភៃម៉ែតពីកន្សៃទូកធំតែប៉ុននោះ ។ រួចដប់ប្រាំ រួចដប់ ។ រំពេចនោះ *ភ្នាក់ផន* កាច់ចង្កូតប្រះចេញមកខាងឆ្វេងចេញផុតពីក្បាលសំពៅ ដែលហៀបនឹងជាន់ពន្លិចទូកគេទៅហើយនោះ ។ អីលូវនេះ នាវាទាំងពីររត់ទន្ទឹមគ្នា ក្នុងចន្លោះប្រហែលដប់ម៉ែតពីគ្នាប៉ុននោះ ហើយទាំងពីរប្រឹងដេញគ្នាដើម្បីយកច្រកចេញតាមចន្លោះដែលពួកនាវានេសាទទុកជាចន្លោះអោយនោះ ។

- ប្រឹងឡើង កនយើង !

---

(*) *ស៊ីបស៊ី : ចរកជនដែលមានដើមកំណើតនៅតំបន់បូហែម ហើយដែលគេរមែងយល់ថា ជាជនជាតិដែលចេះមន្តអាគម រឺ ពូកែទាយ ( អង់គ្លេសហៅ Gipsy បារាំងហៅ Bohémien , Bohémienne ) ។*



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* ស្រែកបញ្ជាស្ទើរបែកបំពង់ក គេខំរុញទូកអោយនៅអែបនឹងសំពៅដើម្បីយកតួសំពៅ និងក្តោងធ្វើខែល ។ កាំភ្លើងមូស្កេលាន់រប៉េះរប៉ោះឡើង ហើយព្រួញភ្លើងត្រូវបាន បាញ់បង្ហើរមកដែរ ប៉ុន្តែក៏មិនបណ្តាលអោយមានការខូចខាតអ្វីឡើយ ។ ផ្ទុយទៅវិញព្រួញភ្លើងខ្លះបែរជាទៅត្រូវក្តោងក្រោមរបស់សំពៅទៅវិញ បណ្តាលអោយភ្លើងឆាបឆេះឡើងមួយរំពេច ។

ពួកមេបញ្ជាការ *សាមូរ៉ៃ* ដែលប្រចាំនៅលើទូកនេសាទទាំងប៉ុន្មានស្រែកបញ្ជប់កងខ្មាន់ធ្នូទាំងតក់ស្លុត ។ តាំងពីដើមរៀងមក មិនដែលមានអ្នកណាហ៊ានវាយប្រហារទៅលើនាវារបស់ពួកចុងស្រុកខាងត្បូងសោះឡើយ ។ មិនតឹនាវាទាំងនេះទេ រឺដែលបាននាំក្រទាត់សូតទាំងឡាយដែលធ្វើអោយគេទ្រាំទ្របាននឹងកំដៅខែប្រាំង ភាពរងានៃខែត្រជាក់ ហើយដែលបានប្រែរដូវស្លឹកឈើលាស់ និងរដូវស្លឹកឈើជ្រុះអោយក្លាយទៅជារដូវពោរពេញដោយភាពរីករាយនោះ ? មិនតឹពួកចុងស្រុកទាំងនេះ ត្រូវបានការពារដោយព្រះរាជអាជ្ញាទេរឺ ? បើសំពៅឆេះទៅ ពួកចុងស្រុកអាចខឹងច្រលោតហើយអាចលែងត្រលប់មកវិញជារហូត ។

ដោយហេតុនេះហើយ ទើបពួកមេបញ្ជាការទាំងឡាយបញ្ឈប់កងទ័ពរបស់ខ្លួនសិនក្នុងពេលដែលទូកធំរបស់ *តូរ៉ាណាកា* នៅអែបជាប់សំពៅយ៉ាងនេះ ព្រោះគ្មានអ្នកណាហ៊ានប្រថុយធ្វើខ្លួនអោយក្លាយទៅជាអ្នកនាំភ្លើង បណ្តាលអោយ *សំពៅខ្មៅ* លែងវិលត្រលប់មកវិញដោយគ្មានការបញ្ជាផ្ទាល់ពីមេទ័ព *អ៊ីស៊ីដូ* នោះឡើយ ។ ពួកគេចាប់ផ្តើមដកដង្ហើមធូរទ្រូងឡើងវិញនៅពេលដែលគេឃើញថាពួកនាវិកនៅលើសំពៅបានពន្លត់ភ្លើងរួចរាល់អស់ហើយ ។ ពេលដែលព្រួញលែងបាញ់មកទៀតហើយនោះ *ប្លាក់ថន* ក៏ចាប់ផ្តើមធូរស្រាលនៅក្នុងចិត្តដែរ ។ *វ៉ូទ្រិច* ក៏មានអារម្មណ៍ដូចគ្នាដែរ ។

ផែនការសំរេចទៅបានមែន ។ គេបានប្រមាណគិតថាតួសំពៅគឺជាច្រករស់សំរាប់ទូកធំ ។ ជាច្រករស់តែមួយគត់ ។

- ក្បៀងវាចេញ ! - *រ៉ែភីក* ស្រែកឡើង -ក្បៀងវាទៅកន្លែងពួកអាស្វានោះទៅ !

- ប្រាំចំនុច (**) ទៅច្វេង ! -*វ៉ូទ្រិច* ស្រែកបញ្ជាតាម ។

(**) *ចំនុច : វង្វាស់មុមស្មើនឹង ១១° ១៥' (Point)* ។



www.budinst.gov.kh www.elibraryofcambodia.org

- ប្រាំចំនុចទៅឆ្វេង ! - ខ្មាន់ចង្កូចស្រែកបន្តឡើង ។

*ប្លាក់ថន* លឺសំរែកបញ្ជាយ៉ាងច្បាស់ ។ គេបង្វែរក្បាលទូកទៅឆ្វេងក្នុងរង្វង់ប្រាំចំនុចជាបន្ទាន់ តែបើសិនជា *រ៉ូទ្រិច* នៅតែរក្សាទិសនេះ ទូកធំនឹងបុកជាមួយរ៉ូងទូកនេសាទខ្មៅខ្វីរជាមិនខាន ហើយបើសិនជាគេបន្ថយល្បឿនទៅក្រោយសំពៅនោះ ទូកសត្រូវទាំងប៉ុន្មាននឹងសំរុកវាយលុកមកលើទូកធំជាមិនខាន ទោះមាន *តូរ៉ាំណាកា* នៅលើទូកធំនេះរឺអត់ក្តី ។ ហេតុនេះហើយ គេមានផ្លូវតែមួយគត់គឺរក្សាទូកអោយនៅរត់ស្របគ្នានឹងសំពៅ ។

- ប្រាំចំនុចទៅស្តាំ !

*រ៉ូទ្រិច* ស្រែកបញ្ជាយ៉ាងទាន់ពេលវេលា ម្យ៉ាងទៀតគេក៏មិនចង់អោយមានព្រួញភ្លើងបាញ់មកទៀតដែរ ដោយនៅជាន់លើសំពៅនេះមានរំសេវច្រើនណាស់ ។

ជាថ្មីម្តងទៀត *ប្លាក់ថន* កាត់ចង្កូតប្រាំទៅស្តាំវិញដើម្បីរត់ស្របគ្នានឹងសំពៅ ។ ច្រវាទូកខាងស្តាំស្ទើរប៉ះសំពៅ ឯច្រវាខាងឆ្វេងបោកទឹកស្ទើរលិចទូកនេសាទ ។ ពេលនេះទាំងនាយទូក ទាំងនាយកងចែវ ទាំងខ្មាន់ចែវទើបយល់បានពីបំនងរបស់ *ប្លាក់ថន* ។ ពួកគេបានដាក់កំលាំងចុងក្រោយទាំងប៉ុន្មានទៅក្នុងដងចែវ ។ *យ៉ាប៊ូ* ស្រែកបញ្ជាអោយពួក *រ៉ូមីន-សាមូរ៉ៃ* ដាក់ធ្នូចុះហើយអោយម្នីម្នាទៅជួយចែវ ។ *យ៉ាប៊ូ* ខ្លួនឯងក៏ប្រឹងជួយចែវយ៉ាងខ្ទិតដែរ ។

នាវាទាំងពីរនៅរត់ទន្ទឹមគ្នាដដែល ។ នៅសល់តែប៉ុន្មានរយម៉ែតទៀតប៉ុណ្ណោះ ។

ពួក *សាមូរ៉ៃ* ដែលមានចិត្តអង់អាចជាងអ្នកដទៃនៅលើទូកនេសាទខ្លះបានបញ្ចេញទូកមកពាំងផ្លូវហើយ គ្រវែងក្រចាប់សំដៅមករកទូកធំ ប៉ុន្តែក្បាលទូកធំបានជាន់ពន្លិចទូកដែលរាំងមុខហើយ ក្រចាប់ទាំងប៉ុន្មានត្រូវបានគ្រវែងចុះទៅក្នុងសមុទ្ទមុនពេលដែលវាថ្កក់តែមទូកបាន ទាញទាំងពួក *សាមូរ៉ៃ* ដែលកាន់វានោះអោយលិចបាត់ទៅក្នុងទឹកថែមទៀត ។ ល្បឿនដងចែវឥតមានបង្អង់ឡើយនៅក្នុងខណៈនេះ ។

- ងាកទៅឆ្វេងថែមទៀត !

- ខ្ញុំមិនហ៊ានទេ លោកបញ្ជាការ ។ *តូរ៉ាំណាកា* មិនឆ្កួតទេណា ហើយម្យ៉ាងទៀត



www.budinst.gov.kh www.elibraryofcambodia.org

មើលនុះន៎ ! មានថ្មបប្រ៉ះទឹកនៅខាងមុខផង ។

*កែវីរ៉ា* ប្រទះឃើញចុងថ្មប៉ប្រ៉ះទឹកនៅខាងមុខក្បែរទូកនេសាទដែលស្ថិតនៅក្រោយគេបង្អស់ ។

- គៀងវាអោយចំថ្មនេះទៅ !

- ពីរចំនុចទៅឆ្វេង !

សំពៅកាច់ក្បាលម្តងទៀត ។ *ភ្លាក់ថន* កាច់តាមចលនានេះផងដែរ ។ អីលូវនេះនាវាទាំងពីរ កំពុងតំរង់ក្បាលទៅចំរ៉ូងទូកនេសាទតែម្តង ។ *ភ្លាក់ថន* ក៏បានឃើញថ្មប៉ប្រះទឹកទាំងនោះដែរ ។ ទូកនេសាទមួយទៀតត្រូវជាន់ពន្លិចហើយព្រួញត្រូវគេបាញ់ប្រសាចតំរង់មករកទូកធំ ។ *ភ្លាក់ថន* ប្រឹងរក្សាទិសទូកមួយរយៈតាមទំហំនៃចិត្តក្លាហានរបស់ខ្លួនរួចស្រែកខ្លាំង១ ដើម្បីអោយ *រ៉ូទ្រិច លី :*

- ប្រាំចំនុចទៅស្តាំ !

ស្រែកហើយភ្លាម គេកាច់ចង្កូតទូកងាកទៅស្តាំភ្លាម ។ ប៉ុន្តែលើកនេះ *រ៉ូទ្រិច* នៅតែរក្សាទិសគៀងរបស់សំពៅខ្លួនដដែល ហើយទង្វើនេះមិនមាននៅក្នុងផែនការឡើយ ។ ចិត្តរបស់ *រ៉ូទ្រិច* កំពុងពោរពេញទៅដោយការប្រដេញគ្នានេះផង ដោយចិត្តខ្លាចញាប់ញ័រផង :

- មកសាកលមើល អាកូនមីចោរ ! តើថ្នើមអែងប៉ុនណាទៅ ?

*ភ្លាក់ថន* ត្រូវសំរេចជាបន្ទាន់ថាតើរវាងពំនូកថ្ម នឹងសំពៅគេត្រូវយកមួយណាហើយ ។ គេសែនដឹងគុណខ្មាន់ចៃវដែលនៅតែកាន់ដងច្រវាជាប់ ក៏ដូចជាដឹងគុណដល់កងនាវិក និងអ្នកដែលនៅលើទូកទាំងអស់ ដែលប្រកាន់វិន័យខ្ជាប់ខ្ជួនធ្វើអោយគេមានបុព្វសិទ្ធិក្នុងការធ្វើសេចក្តីសំរេចចិត្ត ។ ហើយគេក៏បានធ្វើជំរើសភ្លាម ។

គេងាកទូកមកខាងស្តាំបន្តិចទៀត ដកកាំភ្លើងខ្លីតំរង់ទៅសំពៅជាមួយនឹងសំរែក :

- ចៀសផ្លូវ !

រួចគេកាច់កៃលាន់សូរផាំងឡើង ។ គ្រាប់រត់ជ្រែកខ្យល់លាន់សូរវីតពីលើកកិងកន្សែសំពៅចំប្រលោះ *កែវីរ៉ា* និង *រ៉ូទ្រិច* ។ ក្នុងពេលដែល *កែវីរ៉ា* ក្រាបចុះនោះ *រ៉ូទ្រិច* នៅ



www.budinst.gov.kh www.elibraryofcambodia.org

ជ្រៀញចិញ្ចើមពិចារណានៅឡើយ ។ អាកូនមីចោរ *អ៊ិញ្ញគីលីស* នេះ !

តើជាសំនាង រឺក៏អ្ហែងបាញ់ដៃត្រង់ រឺក៏អ្ហែងតំរង់ចង់បាញ់សំលាប់អញតែម្ដង ?

*រ៉ូទ្រិច* ឃើញ *ភ្លាក់ថន* ទាញយកកាំភ្លើងខ្លីមួយដើមទៀតចេញមកហើយគេក៏ឃើញ *គួរ៉ាណាកា* កំពុងសំលឹងមើលមកគេដែរ ។ គេធ្វើសញ្ញាប្រាប់ *គួរ៉ាណាកា* ថាគ្មានអ្វីសំខាន់ទេ ។

ឱ ព្រះអង្គអើយ ! អោយខ្ញុំធ្វើយ៉ាងម៉េចទៅ ? តើត្រូវអនុវត្តតាមផែនការ រឺ ក៏ត្រូវផ្លាស់ប្តូរ ? រឺមួយ យកល្អសំលាប់អា *អ៊ិញ្ញគីលីស* នេះចោលតែម្ដងទៅ ?

ប៉ុន្តែទោះជាសំលាប់អា *អ៊ិញ្ញគីលីស* នេះមិនសំលាប់ក្តី ក៏ពួកទមិឡងទៀតនឹងសំរុកមកតាមវាដូចចៃជាមិនខាន ។ អញជំពាក់ជីវិតវា ហើយអញបានស្បថថា មិនធ្វើឃាតមនុស្សផងគ្នាឡើយ ហើយរិតតែមិនធ្វើឃាតតៃកុងដូចគ្នាទៅទៀត ។

- ងាកចង្កូតទៅស្ដាំ !

*រ៉ូទ្រិច* ស្រែកបញ្ជាហើយងាកសំពៅចេញទៅម្ខាង ។

☆ ☆ ☆

- លោកម្ចាស់ខ្ញុំសួរថា ហេតុអីក៏លោកបើកសំពៅស្ទើរកិនទូកធំយ៉ាងនេះ ?

- នេះគឺជាល្បែងទេ អ្នកស្រី ។ ជាល្បែងរបស់ពួកតៃកុង ។ នេះគឺដើម្បីសាកល្បងកំលាំងចិត្តតៃកុងម្នាក់ៗ ។

- រួចចុះបាញ់កាំភ្លើង ?

- នោះក៏ជាល្បែងដែរ ។ ជាល្បែងដើម្បីល្បងកំលាំងចិត្តរបស់ខ្ញុំ ។ ថ្មីប៉ុរ្រ៉ះទឹកនៅជិតពេកហើយ បែបខ្ញុំតាបអា *អ៊ិញ្ញគីលីស* ជ្រុលបន្តិចផង ។ ប៉ុន្តែពួកយើងជាមិត្តនឹងគ្នាទេតើមិនថាអញ្ចឹង ?

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លេងល្បែងអញ្ចឹងគឺចំជាឆ្កួតមែនទែនតែម្ដង ។

- សូមអ្នកស្រីជំរាបគាត់ថាខ្ញុំសូមទោសផង ។ អ្វីដែលសំខាន់គឺប្រការដែលគាត់បានរួចខ្លួនហើយៗខ្ញុំក៏សប្បាយចិត្តដែរ ។ *ហុនតូ !*



www.budinst.gov.kh www.elibraryofcambodia.org

- លោករៀបចំល្បិចគេចខ្លួននេះជាមួយ *អាន់ជីន-សាន* រឺ ?

- ជាថៃជន់ល្អមួយដែល *អានជីន-សាន* ជាមនុស្សឆ្លាតឆ្លំ ចេះកំនត់ពេលវេលាច្បាស់លាស់ ព្រះច័ន្ទទៀតសោតជួយបំភ្លឺផ្លូវ សមុទ្ទអំនោយផលល្អ ហើយគ្មានអ្នកណាកាន់ច្រលំអ្វីបន្តិចណាឡើយ ។ តែហេតុអីបានជាពួកសត្រូវពន្លិចទូកនេះមិនបាន ខ្ញុំមិនដឹងសោះទេ ។ នេះជាឆន្ទះរបស់ព្រះ ។

- ពិតជាអញ្ចឹងមែនរឺ ?

*ក៏រីក៉* សួរទាំងចោលភ្នែកសំលឹងមើលទូកធំដែលកំពុងរត់នៅខាងមុខ រួចក៏លែងរំលឹករឿងនេះទៅ ។

អីលូវនេះពួកគេចេញឆ្ងាយផុតពីមាត់ច្រកផែហើយតំរង់ក្បាលចេញពី *អូសាកា* ដោយលែងបារម្ភអ្វីពីរឿងគ្រោះថ្នាក់ទៀតហើយ ។ ទាំងទូក ទាំងសំពៅលែងបង្ហំដំណើរដូចមុនទៀតហើយ ។ ច្រវាទូកធំមួយចំនួនត្រូវបានលើកបញ្ឈរឡើង ដើម្បីអោយពួកចែវបានសំរាកយកកំលាំង ។

*រ៉ូឡិច* ឥតរវល់យកចិត្តទុកដាក់នឹង *ក៏រីក៉* ឡើយ ។ ផ្ទុយទៅវិញគេផ្តោតការយកចិត្តទុកដាក់សង្កេតមើល *តូរ៉ាណាកា* មែនទែន ។ អញសប្បាយចិត្តណាស់ដែលបានមកនៅខាង *តូរ៉ាណាកា - រ៉ូឡិច* គិតនៅក្នុងចិត្ត ។ នៅក្នុងពេលប្រដេញគ្នាមុននេះ គេមានឱកាសដ៏កំរដើម្បីសង្កេតមើល *តូរ៉ាណាកា* ។ ពេលនោះភ្នែក *តូរ៉ាណាកា* សំលឹងមើលសព្វ តាំងពីអ្នកកាន់កាណុង កាណុង ក្តោង ការបាញ់កាំភ្លើង ហើយតាមរយៈ *ម៉ារីកូ* សួរនេះសួរនោះ ពីនាយរង រឺពីពួកនាវិកជាប់ ៖ តើអានេះសំរាប់ធ្វើអី ? តើច្រករំសេវចូលកាណុងយ៉ាងម៉េច ? ច្រករំសេវប៉ុន្មាន ? តើបាញ់យ៉ាងម៉េច ? តើខ្សែទាំងនេះសំរាប់ធ្វើអី ?

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា នេះប្រហែល *កាម៉ា* កំនត់ ។ លោកស្គាល់ពាក្យ *កាម៉ា* ទេ លោកតៃកុង ?

- ស្គាល់ !

- លោកម្ចាស់ខ្ញុំសូមអរគុណលោកដែលបានអោយប្រើប្រាស់សំពៅនេះ ។ អីលូវ



www.budinst.gov.kh www.elibraryofcambodia.org

នេះលោកចង់វិលទៅទូករបស់លោកវិញ ។

*វ៉េរីរ៉ា* ងាកផាំងមកភ្លាម :

- ថាម៉េច ? យើងនឹងទៅដល់ *យេដូ* មុនទូកនេះទៅទៀត ។ យើងស្វាគមន៍លោកម្ចាស់ *តូរ៉ាណាកា* អោយនៅលើសំពៅនេះបន្តទៀត ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គ្មានកិច្ចការអ្វីដែលត្រូវរំខានលោកទៀតទេ ហេតុនេះហើយទើបលោកចង់ត្រលប់ទៅទូកលោកវិញ ។

- សូមអ្នកស្រីជំរាបគាត់ថា នៅលើសំពៅនេះហើយ ។ ខ្ញុំសប្បាយចិត្តណាស់ បើសិនជាគាត់ព្រមនៅលើសំពៅជាមួយ ។

- លោកម្ចាស់ *តូរ៉ាណាកា* សូមអរគុណលោកណាស់ ប៉ុន្តែលោកមានបំនងចង់វិលត្រលប់ទៅទូករបស់លោកវិញអីលូវនេះ ។

- អញ្ចឹងក៏បាន ។ *រ៉ូឌ្រិច* ធ្វើតាមចិត្តគាត់ចុះ ។ អោយសញ្ញាទៅទូកធំ ហើយទំលាក់ឡុងបុតទៅ ។

*វ៉េរីរ៉ា* សែនខកទៅក្នុងចិត្ត ។ គេមានបំនងចង់ឃើញ *យេដូ* ហើយនឹងចង់ស្វែងយល់ពី *តូរ៉ាណាកា* ច្រើនជាងនេះដោយថា បច្ចុប្បន្ននេះអនាគតរបស់ពួកគេនឹងត្រូវផ្សារជាប់នឹងមនុស្សនេះហើយ ។ គេឥតជឿលើសំដី *តូរ៉ាណាកា* ដែលលើកពីមធ្យោបាយបញ្ចៀសសង្គ្រាមនោះបន្តិចណាឡើយ ។ ចង់រឺមិនចង់យើងត្រូវចូលជាមួយអាស្វានេះច្បាំងតទល់ជាមួយ *អ៊ីស៊ីដូ* ហើយ ។ ហើយអញមិនចូលចិត្តសោះរឿងនេះ ។

*វ៉េរីរ៉ា* លំអោនខ្លួនគោរពយ៉ាងសុភាព :

- ខ្ញុំស្តាយណាស់ដែលមិនបានរួមដំណើរជាមួយលោកម្ចាស់ *តូរ៉ាណាកា* ។

*តូរ៉ាណាកា* លំអោនខ្លួនគោរពតបវិញ ហើយនិយាយយ៉ាងខ្លី ។

- លោកម្ចាស់ខ្ញុំសូមអរគុណលោកណាស់ ។

រួច *ម៉ារីកូ* និយាយបន្ថែមទៅកាន់ *រ៉ូឌ្រិច* :

- លោកម្ចាស់សូមអរគុណរឿងទូកហើយ លោកមានប្រសាសន៍ថា នៅពេលលោក



www.budinst.gov.kh www.elibraryofcambodia.org

ប្រលប់មកវិញជាមួយនឹង *សំពៅខ្មៅ* លោកនឹងជូនរង្វាន់ខាន់ខៅដល់លោកជាមិនខាន ។

- ខ្ញុំគ្មានបានធ្វើអ្វីទេ ។ នេះគ្រាន់តែជាការកិច្ចទេតើ ។ សូមអភ័យទោសផងដែរ ខ្ញុំរើបមិនរួចពីកៅអី -ជើងខ្ញុំ *នេ ? - រ៉ូទ្រិច* ឆ្លើយតបបណ្តើរ លំអោនខ្លួនគោរពបណ្តើរ -សូមព្រះតាមជួយថែអ្នកស្រី ។

- ចាស សូមអរគុណ លោកតែកុង ។ សូមព្រះតាមជួយថែលោកផងដែរ ។

- សូមធ្វើដំណើរបានសុខសប្បាយ ។

នៅពេលដែលនាងចុះដណ្តើរទាំងល្អិតល្អៃនៅក្នុងប្រាណពីក្រោយរូប *គូរ៉ាណាកា* នោះ *ម៉ារីគូ* ចោលភ្នែកប្រទះឃើញនាយកង *របឺសាវ៉ូ* ដែលកំពុងបញ្ជាឡូងបុត ។ នាងឡើងព្រឺខ្លួនសំបុរគឺង្គក់ហើយចង់ចង្អោរមួយរំពេច ប៉ុន្តែនាងប្រឹងទប់ខ្លួនទាំងក្នុងចិត្តដឹងគុណ *គូរ៉ាណាកា* ដែលបានបញ្ជាអោយទាំងអស់គ្នាចាកចេញពីនាវាស្អុយគគ្រក់នេះ ។

- សូមមានខ្យល់ល្អ និងធ្វើដំណើរបានសុខសប្បាយ ។

*រ៉ែគីរ៉ា* ស្រែកលាពីលើសំពៅ ហើយលើកដៃជាសញ្ញាលាគ្នា ។ អ្នកឯទៀតលើកដៃតបហើយឡុងបុតក៏ចេញដំណើរទៅ ។

- បង្ហង់សំពៅរង់ចាំឡុងបុតមកវិញ និង អោយអាទូករំបល់យក៏នោះទៅបាត់ពីមុខពីមាត់សិន ។

*រ៉ែគីរ៉ា* បញ្ជា ។ នៅលើកិងសំពៅគេឈប់នៅពីមុខ *រ៉ូទ្រិច* លើកដៃចង្អុលទៅទូកធំ :

- ថ្ងៃក្រោយអែងនឹងស្តាយអស់មួយអាយុំស ចំពោះការដែលអែងលែងវាអោយរស់រានមានជីវិតនេះ ។

- រឿងនេះស្រេចលើព្រះកំនត់ ។ អា *អ៊ិញ្ញគីលីស* គឺជាតែកុងមួយ " ជើងគួរ " ដែរនេះបើសិនជាលោកកុំរវល់ពីរឿងសាសនារបស់វានោះ ។

- ចាំខ្ញុំគិតមើលសិន ។

- រួចយ៉ាងម៉េចទៀត ?



www.budinst.gov.kh www.elibraryofcambodia.org

នេះលោកចង់វិលទៅទូករបស់លោកវិញ ។

*វ៉េរីរ៉ា* ងាកផាំងមកភ្លាម :

- ថាម៉េច ? យើងនឹងទៅដល់ *រេយ៉េ* មុនទូកនេះទៅទៀត ។ យើងស្មានមន៏លោកម្ចាស់ *តូរ៉ាំណាកា* អោយនៅលើសំពៅនេះបន្តទៀត ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គ្មានកិច្ចការអ្វីដែលត្រូវរំខានលោកទៀតទេ ហេតុនេះហើយទើបលោកចង់ត្រលប់ទៅទូកលោកវិញ ។

- សូមអ្នកស្រីជំរាបគាត់ថា នៅលើសំពៅនេះហើយ ។ ខ្ញុំសប្បាយចិត្តណាស់ បើសិនជាគាត់ព្រមនៅលើសំពៅជាមួយ ។

- លោកម្ចាស់ *តូរ៉ាំណាកា* សូមអរគុណលោកណាស់ ប៉ុន្តែលោកមានបំនងចង់វិលត្រលប់ទៅទូករបស់លោកវិញអីលូវនេះ ។

- អញ្ចឹងក៏បាន ។ *វ៉ូវ៉ុច* ធ្វើតាមចិត្តគាត់ចុះ ។ អោយសញ្ញាទៅទូកធំ ហើយទំលាក់ឡុងបុតទៅ ។

*វ៉េរីរ៉ា* សែនខកនៅក្នុងចិត្ត ។ គេមានបំនងចង់ឃើញ *រេយ៉េ* ហើយនឹងចង់ស្វែងយល់ពី *តូរ៉ាំណាកា* ច្រើនជាងនេះដោយថា បច្ចុប្បន្ននេះអនាគតរបស់ពួកគេនឹងត្រូវផ្សារជាប់នឹងមនុស្សនេះហើយ ។ គេឥតជឿលើសំដី *តូរ៉ាំណាកា* ដែលលើកពីមធ្យោបាយបញ្ចៀសសង្គ្រាមនោះបន្តិចណាឡើយ ។ ចង់វីមិនចង់យើងត្រូវចូលជាមួយអាស្វានេះច្បាំងតទល់ជាមួយ *អ៊ីស៊ីដូ* ហើយ ។ ហើយអញមិនចូលចិត្តសោះរឿងនេះ ។

*វ៉េរីរ៉ា* លំអោនខ្លួនគោរពយ៉ាងសុភាព :

- ខ្ញុំស្តាយណាស់ដែលមិនបានរួមដំណើរជាមួយលោកម្ចាស់ *តូរ៉ាំណាកា* ។

*តូរ៉ាំណាកា* លំអោនខ្លួនគោរពតបវិញ ហើយនិយាយយ៉ាងខ្លី ។

- លោកម្ចាស់ខ្ញុំសូមអរគុណលោកណាស់ ។

រួច *ម៉ារីកូ* និយាយបន្ថែមទៅកាន់ *វ៉ូវ៉ុច* :

- លោកម្ចាស់សូមអរគុណរឿងទូកហើយ លោកមានប្រសាសន៍ថា នៅពេលលោក



www.budinst.gov.kh www.elibraryofcambodia.org

ប្រលប់មកវិញជាមួយនឹង *សំពៅខ្មៅ* លោកនឹងជូនរង្វាន់ខាន់ខៅដល់លោកជាមិនខាន ។

- ខ្ញុំគ្មានបានធ្វើអ្វីទេ ។ នេះគ្រាន់តែជាភារកិច្ចទេតើ ។ សូមអភ័យទោសផងដែរ ខ្ញុំមើបមិនរួចពីកៅអី -ជើងខ្ញុំ *ទេ ? - រ៉ូទ្រិច* ឆ្លើយតបបណ្តើរ លំអោនខ្លួនគោរពបណ្តើរ -សូមព្រះតាមជួយថែអ្នកស្រី ។

- ចាស សូមអរគុណ លោកតៃកុង ។ សូមព្រះតាមជួយថែលោកផងដែរ ។

- សូមធ្វើដំណើរបានសុខសប្បាយ ។

នៅពេលដែលនាងចុះដណ្តើរទាំងល្អិតល្អៃនៅក្នុងប្រាណពីក្រោយរូប *គូរ៉ាណាកា* នោះ *ម៉ារីកូ* ចោលភ្នែកប្រទះឃើញនាយកង *បេសាត្ស* ដែលកំពុងបញ្ជាឡុងបុត ។ នាងឡើងព្រឺខ្លួនសំបុរតឹង្គត់ហើយចង់ចង្អោរមួយរំពេច ប៉ុន្តែនាងប្រឹងទប់ខ្លួនទាំងក្នុងចិត្តដឹងគុណ *គូរ៉ាណាកា* ដែលបានបញ្ជាអោយទាំងអស់គ្នាចាកចេញពីនាវាស្អុយគគ្រក់នេះ ។

- សូមមានខ្យល់ល្អ និងធ្វើដំណើរបានសុខសប្បាយ ។

*ភៃរីរ៉ា* ស្រែកលាពីលើសំពៅ ហើយលើកដៃជាសញ្ញាលាគ្នា ។ អ្នកឯទៀតលើកដៃតបហើយឡុងបុតក៏ចេញដំណើរទៅ ។

- បង្អង់សំពៅរង់ចាំឡុងបុតមកវិញ និង អោយអាទូករបស់យក៏នោះទៅបាត់ពីមុខពីមាត់សិន ។

*ភៃរីរ៉ា* បញ្ជា ។ នៅលើគិងសំពៅគេឈប់នៅពីមុខ *រ៉ូទ្រិច* លើកដៃចង្អុលទៅទូកធំ :

- ថ្ងៃក្រោយអែងនឹងស្តាយអស់មួយអាយ៉ុស ចំពោះការដែលអែងលែងវាអោយរស់រានមានជីវិតនេះ ។

- រឿងនេះស្រេចលើព្រះកំនត់ ។ អា *អ៊ិញគីលីស* គឺជាតៃកុងមួយ " ជើងគួរ " ដែរនេះបើសិនជាលោកកុំរវល់ពីរឿងសាសនារបស់វានោះ ។

- ចាំខ្ញុំគិតមើលសិន ។

- រួចយ៉ាងម៉េចទៀត ?



www.budinst.gov.kh www.elibraryofcambodia.org

- ទៅដល់ *ម៉ាកាវ* កាន់តែឆាប់កាន់តែល្អ ។ ព្រលែងលើកនេះអោយស៊ីពេលតិចជាងគេបំផុតមើល *រ៉ូត្រិច* ។

*រូច* *កែរីកា* ចុះទៅជាន់ក្រោមបាត់ទៅ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ២៩

- *អាន់ជីន - សាន ?*

- *វៃ? - ក្លាក់ថន* បើកភ្នែកចេញពីការលង់លក់មួយដ៏សុខស្រួល ។

- នេះម្ហូបម្ហា ហើយនឹងតែ ។

មួយរយៈពេលដ៏ខ្លីនោះ *ក្លាក់ថន* លែងចាំថាគេជាអ្នកណា ហើយគេនៅទីណាហើយ ។ បន្ទាប់មកទើបគេស្គាល់បន្ទប់របស់គេដែលនៅលើទូកធំ ។ កាំរស្មីព្រះអាទិត្យមួយបានជ្រៀតចូលកាត់ជ្រែកភាពងងឹត ។*ក្លាក់ថន*មានអារម្មណ៍ថាបានសំរាកយ៉ាងសុខស្រួល ។ សំលេងស្គរលែងលាន់លឺទៀតហើយ ១ទោះជាពេលដែលគេកំពុងលង់លក់យ៉ាងស្កប់ស្កល់ក្តីក៏វិញ្ញាណរបស់គេបានប្រាប់អោយដឹងថាយុថ្កា ត្រូវបានទំលាក់ចុះ ហើយទូកនេះបានផុតពីគ្រោះថ្នាក់ និងនៅជិតឆ្នេរហើយ ។

*ក្លាក់ថន* ក្រលេកឃើញនារីអ្នកបំរើម្នាក់កាន់ថាសមួយ ហើយ *ម៉ារីកូ* ស្ថិតនៅក្បែរនារីអ្នកបំរើនោះដែរ ។ ដៃរបស់នាងលែងស្ពាយឈៀងទៀតហើយ ។ ខ្លួនគេផ្ទាល់កំពុងគេងនៅលើគ្រែភ្ជាប់ជញ្ជាំងមួយដូចគ្នានឹងគ្រែដែលគេបានប្រើនៅក្នុងដំណើរជាមួយ *រ៉ូឌ្រិច* ពី *អាន់ជីរ៉ូ* ទៅ *អូសាកា* យ៉ាងដូចនោះដែរ ហើយដែលអីលូវនេះ *ក្លាក់ថន* ស៊ាំបាននឹងគ្រែរបៀបនេះ ដូចគេស៊ាំនឹងគ្រែរបស់គេនៅលើសំពៅ *អេរ៉ាស* យ៉ាងនោះដែរ ។ *អេរ៉ាស* ! ពិតជាអស្ចារ្យណាស់ដែលបានឃើញសំពៅ និង មិត្តភក្តិឡើងវិញ ។

*ក្លាក់ថន* ពត់ខ្លួនយ៉ាងសុខស្រួល ហើយក៏ទទួលយកតែមួយពែងដែល *ម៉ារីកូ* ហុចមកអោយ ។

- សូមអរគុណ ។ ចំជាអស្ចារ្យ ។ តើដៃអ្នកស្រីយ៉ាងដូចម្តេចហើយ ?

- គ្រាន់បើជាងមុនហើយ ចាស ។ សូមអរគុណ - *ម៉ារីកូ* ពត់ដៃបង្ហាញ - គ្រាន់តែរបួសស៊ើស្បែកប៉ុននោះ ។

- ពេលនេះ *ម៉ារីកូ - សាន* មានទឹកមុខស្រស់គ្រាន់បើជាងមុនច្រើនណាស់ ។

- ចាស អីលូវនេះ ខ្ញុំគ្រាន់បើជាងមុនច្រើន ។

ពេលនាងឡើងមកលើទូកធំរបស់ *តូរ៉ាណាកា* នាពេលព្រលឹមឡើងនោះ *ម៉ារីកូ* ចង់



www.budinst.gov.kh www.elibraryofcambodia.org

សន្ទប់ទៅហើយ ។ *ប្លាក់ថន* បានណែនាំនាងនៅពេលនោះថា :

- យកល្អ អ្នកស្រីគួរនៅខាងលើទូកនេះហើយ ទើបឆាប់ស្វាងពុលរលក ។

- លោកម្ចាស់របស់ខ្ញុំសួរ... សួរថាហេតុអ្វីបានជាបាញ់កាំភ្លើង ?

- នេះគ្រាន់តែជាល្បែងពួកអ្នកបើកសំពៅតែប៉ុណ្ណោះ - *ប្លាក់ថន* ឆ្លើយ ។

- លោកម្ចាស់ខ្ញុំសូមសរសើរពីការប៉ិនប្រសប់ដើរសមុទ្ររបស់លោក ។

- នេះដោយសារយើងមានសំណាងតែប៉ុណ្ណោះ ។ ពន្លឺព្រះច័ន្ទបានជួយយើង ហើយក្រុមនាវិកក៏មានការប៉ិនប្រសប់អស្ចារ្យណាស់ដែរ ។ និយាយអញ្ចឹង *ម៉ារីកូ - សាន* សូមអ្នកស្រីសួរទៅមេបញ្ជាការ-សានមើល ថាតើគាត់ស្គាល់ដែនទឹកនេះទេ ? សូមទោសណាសូមជំរាប *តូរ៉ាណាកា - សាម៉ា* ផង ថាខ្ញុំទ្រាំងងុយមិនបានយូរទៀតទេ ។ លើកលែងតែយើងឈប់ទូកមួយម៉ោងពីរនៅកណ្ដាលលំហសមុទ្រនេះ ។ ខ្ញុំត្រូវតែដេកសិនហើយ ។

រួច *ប្លាក់ថន* ចាំយ៉ាងស្រពិចស្រពិលពីប្រការដែល *ម៉ារីកូ* ឆ្លើយតបមកខ្លួនគេវិញថា *តូរ៉ាណាកា* អនុញ្ញាតអោយគេចុះទៅសំរាកនៅខាងក្រោម ព្រោះមេបញ្ជាការស្គាល់ដែនទឹកនេះច្បាស់លាស់ណាស់ និង ព្រោះគេបើកសស្សៀរតាមឆ្នេរសមុទ្រ ដោយមិនងាកទៅលំហសមុទ្រឡើយ ។

*ប្លាក់ថន* ពត់ខ្លួនម្ដងទៀត រួចបើកបង្អួចទូកមើលចេញទៅក្រៅ ។ ច្រាំងសមុទ្ររងើបរងុបទៅដោយថ្មនៅប្រហែលជាពីរយម៉ែតពីទូក ។

- យើងនៅកន្លែងណាហ្នឹង ?

- នៅឆ្នេរច្រាំងនៃខេត្ត *តូតូមី* ។ លោកម្ចាស់ *តូរ៉ាណាកា* ចង់ហែលទឹកបន្តិចម៉្យាងទៀតលោកម្ចាស់ចង់អោយពួកអ្នកទូកសំរាកមួយរយៈផង ។ ស្អែកនេះយើងនឹងទៅដល់ *អាន់ជីរ៉ូ* ហើយ ។

- ទៅភូមិនេសាទហ្មុង ? ដូចជារកជឿមិនកើតទេ ។ ពេលទើបថ្ងៃត្រង់ប៉ុណ្ណឹងហើយយើងចេញពី *អូសាកា* មកពីព្រលប់នេះសោះ ។ រកជឿមិនកើតទេ ។

- នោះគឺកាលពីម្សិលម៉្ងៃទេ *អាន់ជីន - សាន* ។ លោកបានសំរាកពេញមួយថ្ងៃ



www.budinst.gov.kh www.elibraryofcambodia.org

មួយយប់ ហើយនឹងមួយកំនាត់ថ្ងៃនេះទៀត - *ម៉ារីកូ* តប - លោកម្ចាស់ *តូរ៉ាណាកា* បាន ប្រាប់កុំអោយគេរំខានលោកអោយសោះ ។ ទើបពេលនេះទេ ដែលលោកម្ចាស់គិតថា លោកគួរតែទៅហែលទឹកដើម្បីបានស្វាងពីភាពងោកងុយ ។ ក្រោយពីលោកពិសាបាយរួច ។

ម្ហូបដែលលើកមកនោះមានបាយពីរចានចង្កឹះ ត្រីអាំង និងទឹកជ្រលក់ពណ៌ខ្មៅ ប្រៃ បន្តិច ផ្អែមបន្តិច ហើយដែល *ម៉ារីកូ* ពន្យល់ប្រាប់ *ប្លាក់ថន* ថាជាទឹកជ្រលក់ធ្វើពីសណ្តែក សៀង ។

- សូមអរគុណ ។ ពិតហើយខ្ញុំចូលចិត្តហែលទឹកណាស់ ។ ខ្ញុំគេងជិតសាមសិប ប្រាំមួយម៉ោង ? អញ្ចឹងទេតើ បានជាខ្ញុំដូចជាស្រួលខ្លួនម្ល៉េះ ?

*ប្លាក់ថន* ទទួលយកថាសបាយពីនារីអ្នកបំរើ ប៉ុន្តែគេមិនទាន់បរិភោគភ្លាមទេ ។ គេ សួរទៅ *ម៉ារីកូ* :

- ហេតុអ្វីបានជានារីអ្នកបំរើនេះ ដូចជាភ័យៗអញ្ចឹង ?

- នាងមិនភ័យទេ *អាន់ជីន - សាន* តែគឺនាងមានអារម្មណ៍រសាប់រសល់ព្រោះនាង មិនដែលចូលជិតជនបរទេសណាម្នាក់ដូចពេលនេះទេ ។ សូមអភ័យទោសដល់នាងផង ចាស ។

- និយាយប្រាប់នាងទៅ ថាដល់ខែពេញបូរមី ពួកមនុស្សចុងស្រុកដុះចេញស្លែង ហើយព្រួសភ្លើងពីមាត់ដូចសត្វនាគអញ្ចឹង ។

*ម៉ារីកូ* សើចកក្អឹក :

- ខ្ញុំនឹងមិននិយាយយ៉ាងហ្នឹងទេ ។

រួចនាងចង្អុលទៅលើតុបណ្តើរ និយាយបណ្តើរ :

- នោះគឺជាម្សៅដុសធ្មេញ ច្រាស ទឹក និង កន្សែងថ្មី ។

រួចនាងដូរមកនិយាយភាសាឡាតាំងវិញ :

- ខ្ញុំមានការរីករាយណាស់ ដែលបានឃើញលោកស្រួលបួលឡើងវិញយ៉ាងដូចនេះ ។ លោកពិតជាមនុស្សក្លាហានមែន ។

ភ្នែកអ្នកទាំងពីរប្រទាក់ជាប់គ្នាមួយសន្ទុះ រួច *ម៉ារីកូ* ក៏អោនក្បាលគោរពយ៉ាងគួរសម



www.budinst.gov.kh www.elibraryofcambodia.org

បំផុត ។ អ្នកបំរើក៏លំអោនខ្លួនគោរពតាម រួចទាំងពីរនាក់ចេញទៅវិញដោយបិទទ្វារតាមក្រោយផង ។

កុំគិតគួរពីនាងអោយសោះ - *ភ្នាក់ផន* បញ្ជាដួងចិត្តរបស់ខ្លួន ។ គិតពី *គូរ៉ាណាកា* រឺពី *អាន់ជី្ញ* វិញ ។ ហេតុអ្វីបានជាយើងឈប់នៅ *អាន់ជី្ញ* នាថ្ងៃស្អែកនេះអញ្ចឹង ? ដើម្បីដាក់ *យ៉ាប៊ូ* ចុះរឺយ៉ាងម៉េច ? បើអញ្ចឹងមែន ធូរទ្រូងបន្តិច !

*អូមី* ពិតជានៅ *អាន់ជី្ញ* ។ តើគិតយ៉ាងម៉េចពី *អូមី* នេះ ?

ហេតុអីមិនសុំ *គូរ៉ាណាកា* អោយកាត់ក្បាល *អូមី* ? គាត់ជំពាក់គុណអ្នែងពីរបីដងដែរតើ ។ រឺមួយហេតុអីមិនសុំប្រយុទ្ធគ្នាជាមួយ *អូមី* ? ប្រើកាំភ្លើង រឺប្រើដាវ? ប្រើដាវអ្នែងពិតជាគ្មានផ្លូវគាត់តូចណាទេ តែបើប្រើកាំភ្លើងខ្លីវិញក៏មិនខុសអីពីអ្នែងធ្វើឃាតមនុស្សដែរ ។ យកល្អកុំធ្វើអ្វីទាំងអស់ ហើយនៅរង់ចាំវិញ ។ បន្តិចទៀតអ្នែងគង់មានផ្លូវអ៊ុត ហើយពេលនោះអ្នែងពិតជាអាចសងសឹកលើពួកវាទាំងពីរនាក់តែម្តង ។ ត្រូវចេះអត់ធ្មត់ ។ ត្រូវដណ្តឹងសួរខ្លួនអ្នែងវិញតើអ្នែងត្រូវការអីពី *គូរ៉ាណាកា* ? បន្តិចទៀតទូកនឹងទៅដល់ *យេដូ* ហើយ១ពេលនោះអ្នែងនឹងគ្មានពេលច្រើនទេ ។

*ភ្នាក់ផន* គិតបណ្តើរ ទទួលទានម្ហូបអាហារបណ្តើរតាមរបៀបដែលគេឃើញអ្នកទោសទទួលទាននៅក្នុងគុក គឺលើកចានបាយមកផ្ទាប់នឹងមាត់ ហើយប្រើចង្កឹះកាយបាយបញ្ចូល ។ តែការប្រើចង្កឹះចាប់សាច់ត្រីមានការលំបាកខ្លះដោយគេមិនទាន់ថ្មីកនៅឡើយ ហេតុនេះគេប្រើម្រាមដៃចាប់តែម្តង ។

នៅពេលដែលម្ហូបអាហារអស់រលីងពីចាសទៅហើយ *ភ្នាក់ផន* នៅតែរមូរពោះដដែល ។

- ទៅរកអីស៊ីថែមទៀតសិនទើបបាន - គេនិយាយតែម្នាក់ឯង - ព្រះអើយព្រះអញឃ្លានទំពុំាំងក្តៅ១ ឃ្លានពងទាចៀន ប៊ីរ និង ប្រូម៉ាស និងស្អី១ទៀតម្ល៉េះទេ !

ពេលគេឡើងទៅផ្នែកខាងលើទូក ស្ទើរតែទាំងអស់គ្នា នៅស្រោតនទលគកពាសពេញ ។ ខ្លះជូតសំអាតខ្លួន ខ្លះទៀតដេកអាំងថ្ងៃ ហើយខ្លះទៀតលោតទឹកពីលើទូក ។ នៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងទឹកពូក *សាមូរ៉ៃ* និងពួកនាវិកហែលជុំវិញទូក រីបាចទឹកដាក់គ្នាលេងយ៉ាងក្អាកក្អាយប្រៀបបីដូចជាកូនក្មេងដែរ ។

- *កូនីជីរ៉ា អាន់ជីនសាន* ។

- *កូនីជីរ៉ា តូរ៉ាណាកា - សាម៉ា* ។

*តូរ៉ាណាកា* និយាយគួរសមជាមួយ *ប្លាក់ថន* បណ្តើរ ឡើងជណ្តើរចំហៀងទូកទាំងទទលគកបណ្តើរ :

- *សួណាគាវ៉ា អូយ៉ូស៊ីគាម៉ូ កា ?*

ដោយឃើញ *តូរ៉ាណាកា* និយាយផងចង្អុលទៅសមុទ្រផង *ប្លាក់ថន* គាត់ស្មានថាសំនួរនេះគឺអញ្ជើញទៅហែលទឹកហើយ ។ គេក៏ឆ្លើយឡើង :

- *រ៉ៃហ តូរ៉ាណាកា - សាម៉ា ! ដូម៉ូ !*

*តូរ៉ាណាកា* ចង្អុលទៅសមុទ្រម្តងទៀត ហើយនិយាយពីរ បីម៉ាត់ រួចស្រែកហៅ *ម៉ារីកូ* មកបកប្រែ ។ នាងក៏ដើរពីកន្លែងតំរង់មកដោយបាំងឆ័ត្រពណ៌ក្រហមក្រមៅមួយ ។ គីម៉ូណូរបស់នាងពណ៌ស ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា លោកបានស្រស់បស់ហាក់មានកំលាំងកំហែងជាងមុន ។ សូមលោកអញ្ជើញហែលទឹកលេង ។

*តូរ៉ាណាកា* ផ្អែកបែបវាហ៊ីនៅលើគែមទូក ហើយកំពុងជូតត្រចៀកនឹងកន្សែងមួយ ។ *ប្លាក់ថន* ទើបបានឃើញថា តូរ៉ាណាកា ជាមនុស្សប្រកបទៅដោយសាច់ដុំ និងមានសាច់ហាប់ណែន លើកលែងតែនៅក្បាលពោះតែប៉ុណ្ណោះ ។ ទាំងក្នុងចិត្តរសាប់រសល់ដោយមានវត្តមានរបស់ *ម៉ារីកូ* នោះ *ប្លាក់ថន* បានចាប់ផ្តើមដោះខោអាវរហូតដល់នៅខ្លួនអាក្រាតដូចគេដូចឯង ។

- លោកម្ចាស់ *តូរ៉ាណាកា* សួរថា តើពួកជនជាតិអង់គ្លេសមានខ្លួនដុះរោមច្រើនដូចលោកអញ្ចឹងរឺ ? ហើយសក់សុទ្ធតែពណ៌លឿងអញ្ចឹងគ្រប់គ្នារឺ ?

- ខ្លះមាន ខ្លះអត់ - *ប្លាក់ថន* តប ។

- ពួកយើង អូស ! សូមទោស ! ប្រុស១ជាតិយើងមិនមានរោមច្រើននៅលើដៃ



www.budinst.gov.kh www.elibraryofcambodia.org

រីលើដើមទ្រូងដូចលោកទេ ។ លោកម្ចាស់មានប្រសាសន៍ថា លោកមាឧល្អណាស់ ។

- គាត់ក៏អញ្ជើងដែរ ។ សូមអ្នកស្រីជំរាបគាត់ថាខ្ញុំអរគុណ ។

ដោយមិនអាចនៅឈរអាក្រាតមុខគេទាំងអស់គ្នាយ៉ាងនេះ ជាពិសេស *ម៉ារីកូ* យុវនារី *កូជីកូ* ដែលកំពុងអង្គុយលុតជង្គង់នៅឯកន្លែងទូកក្រោមឆ័ត្រពណ៌លឿង និងមានស្រីបំរើម្នាក់នៅក្បែរហើយដែលកំពុងសំលឹងមើលមកផងនោះ *ប្លាក់ថន* ក៏លោតផ្លុងទៅក្នុងទឹករំលងគែមទូកតែម្តង ។ នោះគឺជាការលោតដាំក្បាលទៅមុនយ៉ាងល្អ ហើយភាពត្រជាក់នៃទឹកសមុទ្របានជ្រែកចូលទៅក្នុងរាងកាយគេយ៉ាងរញ្ជួយសស្រិប ។ បាតសមុទ្រមានជំរៅប្រហែលជាប្រាំម៉ែត និងពោរពេញទៅដោយសារ៉ាយ និងមច្ឆជាតិយ៉ាងច្រើនដែលហែបហែលដោយឥតខ្លាចញញើតអ្វីនឹងមនុស្សទាំងឡាយដែលហែលទឹកជាមួយវានោះឡើយ ។ ពេលមុជជិតដល់បាតកំលាំងជំរុញរបស់ *ប្លាក់ថន* ក៏ត្រូវបញ្ឈប់ ហើយគេក៏បង្វិលខ្លួនហែលប្រលែងលេងក្នុងវង្វង់ត្រីវិញមួយសន្ទុះទើបធាក់ឡើងលើវិញ ។ បន្ទាប់មក គេក៏ហែលបោះដៃមួយៗ ប៉ុន្តែក្នុងល្បឿនដ៏លឿនសំដៅទៅច្រាំង តាមរបៀបដែលតា *អាល់បាទកាហ៊ុក* បានបង្រៀនគេ ។

ឆកសមុទ្រដ៏តូចនេះស្ងាត់ជ្រងំ ប្រកបដោយផ្ទាំងថ្មធំៗ មានឆ្នេរមួយសំបូរដោយគ្រួស ប៉ុន្តែគ្មានសញ្ញាពីវត្តមានមនុស្សឡើយ ។ ភ្នំទាំងឡាយយោងឡើងទៅលើមេឃពណ៌ខៀវស្រងាត់ និង ដ៏គ្មានព្រំដែន ក្នុងកំពស់ជាងបីរយម៉ែត ។

*ប្លាក់ថន* ផ្អែកខ្លួនលើផ្ទាំងថ្មដើម្បីអាំងថ្ងៃ ។ សាមូរ៉ៃទាំងបួននាក់ដែលបានហែលទឹកជាមួយគេនោះ នៅមិនឆ្ងាយពីកន្លែងដែលគេសំរាកនោះឡើយ ។ ពួកទាំងបួននាក់ញញឹមដាក់ *ប្លាក់ថន* ព្រមទាំងលើកដៃជាសញ្ញាផង ។ មួយរយៈក្រោយមកទៀត ទើប *ប្លាក់ថន* ហែលត្រលប់ទៅទូកវិញ ដោយមានសាមូរ៉ៃទាំងបួនហែលតាមក្រោយដដែល ។ *ទី ហ៊ាណាកា* នៅតាមឃ្លាំមើលរូបគេរហូត ។

ពេល *ប្លាក់ថន* ឡើងទៅលើទូក ខោអាវរបស់គេមិនដឹងជាបាត់ទៅណាអស់ ។ *កូជីកូ ម៉ារីកូ* និង ស្រីបំរើទាំងពីរនៅទីងទីកន្លែងដដែល ។ ស្រីអ្នកបំរើម្នាក់លំអោនខ្លួនគោរពរួចហុចកន្សែងកំប៉ិតឡិតមួយមកអោយ ។ *ប្លាក់ថន* ទទួលយកកន្សែងនោះមកជូតខ្លួន



www.budinst.gov.kh www.elibraryofcambodia.org

ដោយបែរមុខទៅរកតែមទូក ព្រោះតែទើសទាល់នឹងនារីទាំងនេះ ។

អញថាអោយធ្វើដូចចម្មតាទៅមើល - *ក្លាក់ថន* និយាយនៅក្នុងចិត្ត ។ ពួកគេមិនទាំងសំគាល់ រឺ យកចិត្តទុកដាក់លើភាពអាក្រាតនេះផង ។ អ្អែងនៅជប៉ុនណា ! អ្អែងត្រូវធ្វើតាមគេតាមឯង ។ អ្អែងត្រូវធ្វើអោយដូចពួកវាអញ្ចឹង ។

សំលេង *ម៉ារីកូ* បន្លឺឡើង :

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថាលោកហែលបានល្អណាស់ ។ តើលោកអាចបង្រៀនពីរបៀបហែលទឹកនេះបានទេ ?

- ខ្ញុំមានការរីករាយណាស់នឹងបង្រៀន ។

*ក្លាក់ថន* ឆ្លើយតប ទន្ទឹមនឹងបង្ខំចិត្តបែរមុខទៅរកគេវិញ ។ *ម៉ារីកូ* ញញឹមពព្រាយមករកគេ ។ នាងចំជាស្អាតមែន - គេនឹកក្នុងចិត្ត ។

- របៀបដែលលោកហក់ចូលក្នុងទឹកក៏អញ្ចឹងដែរ ។ ពួកយើង... ពួកយើងមិនដែលឃើញរបៀបហក់បែបនេះទេ ។ ពួកយើងលោតទៅបែបចម្មតាតែប៉ុននោះ ។ លោកម្ចាស់ចង់រៀនពីរបៀបហក់នេះដែរ ។

- អីលូវណឹង ?

- ចាស លោក ។

- ខ្ញុំអាចបង្ហាត់គាត់បាន រឺបើនិយាយស្រួលស្តាប់ទៅ ខ្ញុំនឹងសាកល្បងបង្ហាត់គាត់ ។

ស្រីបំរើម្នាក់ហុចតីម៉ូល្ញូអំបោះមួយមកដល់ *ក្លាក់ថន* ដែលទទួលយកមកស្លៀកទាំងរីករាយ ។ ក្រោយពីចងតីម៉ូញូ និងក្រវាត់គ្រណាត់រួចហើយ គេដូចជាធូរទ្រូងជាងមុនហើយគេក៏ចាប់ពន្យល់ពីរបៀបផ្លុងទឹក :

- យកល្អ គួររៀនផ្លុងទឹកនៅនឹងជើងជណ្តើរតែម្តង ហើយចាប់ផ្តើមពីរៀនផ្លុងយកក្បាលទៅមុនសិន ដោយមិនចាំបាច់រត់ រឺ លោតឡើយ ។ នេះគឺរបៀបដែលយើងបង្រៀនក្មេង ១ ។

*តូរ៉ាណាកា* ស្តាប់ការពន្យល់ សាកសួរពីនោះពីនោះ រួចនៅពេលដែលលោកយល់



www.budinst.gov.kh www.elibraryofcambodia.org

ថាលោកពេញចិត្តហើយនោះ លោកក៏និយាយឡើងតាមរយៈ *ម៉ារីកូ* :

- ល្អ ! ខ្ញុំយល់ហើយមើលទៅ ។

រួចលោកក៏ដើរទៅក្បែរជណ្តើរចំហៀងទូក ។ នៅមុនពេលដែល *ប្លាក់ថន* ស្រែកឃាត់នោះ លោកក៏ហក់ប្រូងទៅក្នុងទឹកពីក្នុងកំពស់ជាងបីម៉ែត ។ ខ្លួនលោកប៉ះទឹកលឺស្វូរខ្លាក ប៉ុន្តែគ្មានអ្នកណាសើចមួយឃឺសឡើយ ។ *តូរ៉ាណាកា* ឡើងមកលើទូកវិញហើយសាកម្តងទៀត ។ ម្តងនេះ លោកធ្លាក់លឺខ្លាកទៀត ។ ពួកសាមូរ៉ៃឯទៀតក៏ទទួលបរាជ័យដូចលោកដែរ ។

*ប្លាក់ថន* ពោលឡើង :

- រឿងនេះមិនមែនងាយទេ ។ ខ្ញុំចំនាយពេលយូរណាស់ទំរាំរៀនវាចេះ ។ យកល្អយើងសំរាកសិនទៅ ហើយស្អែកសឹមសាកទៀត ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា " ស្អែកគឺស្អែក ។ ថ្ងៃនេះខ្ញុំនឹងរៀនពីរបៀបលោតផ្ងងទឹកនេះ " ។

*ប្លាក់ថន* ដោះគីម៉ូណូទៅម្ខាង ហើយចាប់បង្ហាញណែនាំម្តងទៀត ។ ពួកសាមូរ៉ៃធ្វើត្រាប់តាមគេ តែពួកគេនៅតែបរាជ័យដដែល ។ *តូរ៉ាណាកា* ក៏យ៉ាងដូចនោះដែរ ។ បរាជ័យប្រាំមួយដង ។

ក្រោយពីការលោតបង្ហាញម្តងទៀតមក *ប្លាក់ថន* ក៏តោងជណ្តើរឡើងមកទូកធំវិញយ៉ាងហត់គយូស ។ ពេលនោះ គេក៏ប្រទះឃើញ *ម៉ារីកូ* ដែលមានខ្លួនប្រាណអាក្រាតឈរនៅលាយឡំពួកសាមូរ៉ៃ បំរុងខ្លួននឹងហក់ចុះទឹកជាមួយគេជាមួយឯងដែរ ។ ខ្លួនប្រាណនាងស្អាតគួរអោយគយគន់ ។ ស្បែដែលរុំដៃនាងនៅថ្មីៗនៅឡើយ ។

- ឈប់សិន *ម៉ារីកូ* ! សាកដំបូងដៃអញ្ចឹង យកល្អគួរសាកពីកន្លែងនេះទៅវិញ ។

- ល្អណាស់ ! *អាន់ជីន - សាន* ។

នាងដើរចុះមករក *ប្លាក់ថន* ។ រូបព្រះឆ្លងកាន់តែរំលេចភាពអាក្រាតរបស់នាងអោយកាន់តែស្រស់ទៅទៀត ។ *ប្លាក់ថន* បង្ហាញនាងពីរបៀបពត់ខ្លួន និង លោតចុះទៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសមុទ្រដោយដាក់ក្បាលទៅមុនរបៀបយ៉ាងម៉េច ។ ដៃរបស់គេកាន់ខ្លួននាងបង្ហាញអំពីកាយវិការដែលត្រូវធ្វើ ។

រួចបន្ទាប់មក លោក *តូរ៉ាណាកា* សាកលោតពីកាំជណ្ដើរក្បែរទឹកម្ដង ហើយក៏បានទទួលជោគជ័យបន្តិចបន្តួច ។ *ម៉ារីកូ* ក៏ចាប់ផ្ដើមសាកល្បងម្ដង ប៉ុន្តែការដែលដៃរបស់គេប៉ះសាច់របស់នាង ធ្វើអោយ *ប្លាក់ថន* ក្ដៅខ្លួនគគុករហូតទ្រាំលែងបានតែម្ដង ។ គេក៏លោតចុះទៅក្នុងទឹក ហើយណែនាំពួកគេពីក្រោមទៅវិញម្ដងរហូតដល់អារម្មណ៍គេលែងរំជួលទៀត ទើបគេឡើងទៅលើទូកចវិញ ហើយឈរលើគែមទូកដើម្បីបង្ហាញពីរបៀបលោតផ្លុងខ្មោច ដែលគេយល់ថាជារបៀបលោតផ្លុងដ៏ងាយស្រួលជាងគេ ។ គេយល់ច្បាស់ណាស់ថា គឺជាការសំខាន់បំផុតចំពោះ *តូរ៉ាណាកា* ក្នុងការសំរេចលោតផ្លុងនេះ ។

- សំខាន់ លោកម្ចាស់ធ្វើខ្លួនអោយរឹងណា *វ៉ៃ ?* រឹងត្រង់ដូចដាវអញ្ចឹង ។ ធើរបៀបណឹង លោកម្ចាស់ពិតជាសំរេចបានហើយ ។

និយាយរួចគេក៏លោតចុះយ៉ាងស្អាតទៅក្នុងទឹក រួចគេនៅរង់ចាំងទីនោះតែម្ដង ។

ពួកសាមូរ៉ៃមួយចំនួនដើរតំរង់មករកគែមទូកដើម្បីសាកល្បង ប៉ុន្តែ *តូរ៉ាណាកា* គ្រវាសដៃបណ្ដេញទៅម្ខាង ។ លោកលើកដៃត្រង់ឡើងទៅលើ ខ្លួនប្រាណរបស់លោកត្រង់ស្ដូករួចទំលាក់ខ្លួនទៅក្រោមតាមរបៀបដែល *ប្លាក់ថន* បង្ហាញ ។ ក្បាលរបស់លោកប៉ះទឹកមុនដងខ្លួន ជើងរបស់លោកអង្កុញបន្តិច ប៉ុន្តែទោះជាយ៉ាងនេះក្ដីក៏ជាការផ្លុងប្រកបដោយជោគជ័យលើកដំបូងដែរ ហើយនៅពេលដែលលោកផុសចេញពីផ្ទៃទឹកមកវិញនោះ សំរែកជ័យឃោសន៍ក៏លឺឡើងស្វាគមន៍ដល់រូបលោកដែរ ។ រួចលោកក៏សាកល្បងម្ដងទៀតប្រកបដោយជោគជ័យជាងមុន ។ អ្នកឯទៀតក៏បានសាកល្បងតាមដោយខ្លះបានជោគជ័យ ខ្លះក៏អត់ទៅ ។ រួច *ម៉ារីកូ* ក៏សាកល្បងម្ដង ។

*ប្លាក់ថន* សំលឹងមើលដើមទ្រូងដ៏ណែនក្បំ និងតូចច្រលឹង ចង្កេះរៀវស្ដួច និងជើងដ៏ស្រលូនរបស់ *ម៉ារីកូ* ។ នាងជ្រួញចិញ្ចើមដោយការឈឺចាប់មួយភ្លែតនៅពេលដែលនាងលើកដៃឡើងផុតពីក្បាល ប៉ុន្តែនាងនៅរក្សាដងខ្លួនអោយត្រង់ដដែល រួចនាងក៏ហក់ទៅមុខយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

ក្លាហាន ។ ខ្លួននាងទាំងមូលជ្រែកទឹកដោយគ្មានខ្វាយទឹកបន្តិចណាឡើយ ។ ប៉ុន្តែក្រៅពី *ភ្លាក់ផន* ហាក់ដូចគ្មានអ្នកណាយកចិត្តទុកដាក់ រឺ កត់សំគាល់អ្វីឡើយ ។

- ល្អណាស់ ។ ផ្លុងបានល្អមែនទែន ។

*ភ្លាក់ផន* និយាយសរសើរបណ្ដើរឈោងដៃចាប់យោង *ម៉ារីកូ* ចេញពីទឹកមកដាក់ឈរនៅលើក្បាលជណ្ដើរឡើងទៅលើទូកបណ្ដើរ រួចគេនិយាយបន្ត :

- អ្នកស្រីគួរឈប់ហើយ បើមិនអញ្ចឹងទេ របួសនៅលើដៃអ្នកស្រីអាចរហែកវិញបាន ។

- ចាស អរគុណ *អាន់ជីន - សាន* ។

នាងឈរនៅក្បែរ *ភ្លាក់ផន* ក្បាលនាងស្ទើរមិនដល់ស្មាគេផង នៅលើមុខនាង មានបង្ហាញភាពរីករាយច្បាស់ក្រលែត :

- នេះគឺជាអារម្មណ៍មួយដ៏កំរដែលបានមកពីការលោតផ្លុងនេះ ការរក្សាខ្លួនអោយនៅត្រង់ ហើយពិសេសប្រការដែលត្រូវយកឈ្នះលើការភ័យខ្លាចរបស់ខ្លួនឯងនេះ គឺពិតជាអារម្មណ៍ដ៏កំរមែន ។

រួចនាងក៏ឡើងទៅលើទូក ស្លៀកគីម៉ូណូដែលស្រីបំរើយកមកអោយ ហើយក៏ចុះទៅក្នុងទូកដោយជូតមុខខ្លួនយ៉ាងថ្នម១បណ្ដើរ ។

ឱព្រះជាម្ចាស់អើយ សក្តិសមជាស្រីដ៏ល្អម្ល៉េះ - *ភ្លាក់ផន* គិតនៅក្នុងចិត្ត ។

នៅពេលព្រះសុរិយាអស្តង្គត *តូរ៉ាណាកា* បានប្រើគេអោយមកហៅ *ភ្លាក់ផន* ។ លោកអង្គុយនៅឯកន្សៃទូក ។ នៅក្បែររូបលោកមានកូនចង្ក្រានមួយដែលគេដុតគ្រឿងក្រអូបសំរាប់ធ្វើអោយបរិយាកាសនៅទីនោះឈ្ងុយឈ្ងប់ផង សំរាប់ដេញមូសនិងអំពិលអំពែកផង ។ *យ៉ាប៉ូ* និង *ម៉ារីកូ* ប្រកបដោយសំលៀកបំពាក់យ៉ាងស្រស់សង្ហា ។ *កូជីកូ* ក្មួយស្រីរបស់ *ប៊ុនតារ៉ូ* ក៏ស្ថិតនៅទីនោះដែរ ។ សាមូរ៉ៃម្ភៃនាក់អង្គុយការពារយ៉ាងស្ងៀមស្ងាត់ក្រោមពន្លឺចន្លុះដែលដុតពង្រាយនៅលើទូក ។

- អញ្ជើញសាកេ *អាន់ជីន - សាន* ?



www.budinst.gov.kh www.elibraryofcambodia.org

- *ដូម៉ូ តូរ៉ាណាកា - សាម៉ា*

*ប្លាក់ថន* លំអោនខ្លួនគោរព ហើយទទួលយកកូនពែងស្រាពីដៃ *ភូជីកូ* លើកជូនពរ *តូរ៉ាណាកា* រួចក៏ក្រេបអស់ភ្លាម ។ ពែងក៏ត្រូវបានបំពេញភ្លាមវិញដែរ ។ *ប្លាក់ថន* ស្លៀកពាក់ឯកសណ្ឋានគីម៉ូណូពណ៌ត្នោតហើយគេមានអារម្មណ៍ថាគេហាក់ដូចជាងាយស្រួល មិនសូវទើសទាល់ដូចគេស្លៀកខោអាវតាមបែបអឺរ៉ុបនោះឡើយ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា យប់នេះយើងស្នាក់នៅទីនេះហើយ ។ ស្អែកយើងនឹងទៅដល់ *អាន់ជីរ៉ូ* ។ អីលូវនេះលោកម្ចាស់ចង់ស្ដាប់លោកនិយាយពីប្រទេសលោក និង ពីពិភពលោកនៅខាងក្រៅនេះ ។

- បានមានអី ។ តើលោកម្ចាស់គាត់ចង់ដឹងពីអ្វី ? យប់នេះគួរអោយត្រេកត្រអាលណាស់ មែនទេ ?

*ប្លាក់ថន* រៀបចំខ្លួនសមរម្យ ដោយមានអារម្មណ៍នឹងវត្តមានរបស់ស្ត្រីនៅក្បែរខ្លួន រឺថាមានអារម្មណ៍ហួសក៏សឹងថាបាន ។ ចំណែកមែន ។ អញដូចមានអារម្មណ៍ពីនាងនៅពេលនាងគ្រងសំលៀកបំពាក់ ជាងកាលនាងនៅខ្លួនទទេទៅទៀត ។

- ចាស យប់នេះពិតជាគួរអោយត្រេកត្រអាលមែន ។ បន្តិចទៀត សន្សើមចាប់ធ្លាក់ហើយ *អាន់ជីន - សាន* ។ រដូវផ្ការីកមិនទាន់ជារដូវល្អនៅឡើយទេ - រួចនាងបកប្រែទៅ *តូរ៉ាណាកា* នូវអ្វីដែលនាងបាននិយាយ - លោកម្ចាស់ខ្ញុំប្រាប់ខ្ញុំអោយជំរាបលោកថា *រយ៉ដូ* ជាកន្លែងមានបឹងបួរច្រើន ហើយនៅរដូវផ្ការីក សំបូរមូសណាស់ ប៉ុន្តែរដូវស្លឹកលាស់ និងរដូវស្លឹកឈើជ្រុះ គឺត្រកាលណាស់ ។ ចាសពិតហើយ រដូវនៃពេលប្រសូត និងនៃពេលត្រជរឱ្យល់គឺពិតជាល្អស្រស់ណាស់ ។

- ប្រទេសអង់គ្លេសមានអាកាសធាតុល្មម ។ យើងមានរដូវធ្លាក់ទឹកកកយ៉ាប់យ៉ឺនម្តងក្នុងប្រាំពីររដូវ ។ ទាំងរដូវផ្ការីកក៏យ៉ាងដូចនោះដែរ ។ យើងមានទុរ្ភិក្សរាល់ប្រាំមួយឆ្នាំម្តង ថ្វីត្បិតតែនៅពេលខ្លះយើង ៧ រដូវមានម្តង មិនបានផលពីរឆ្នាំជាប់គ្នាក្តី ។

- យើងក៏មានទុរ្ភិក្សដែរ ។ រាល់ទុរ្ភិក្សមិនដែលល្អទេ ។ ចុះអីលូវនេះនៅប្រទេស



www.budinst.gov.kh www.elibraryofcambodia.org

របស់លោកយ៉ាងម៉េចហើយ ?

- ក្នុងពេលដប់ឆ្នាំចុងក្រោយនេះ យើងមានការប្រមូលផលមិនល្អបីដង ។ គ្មានពន្លឺថ្ងៃគ្រប់គ្រាន់ដើម្បីនឹងធ្វើអោយស្រូវសាលីទុំបាន ។ តែនេះគឺជាវាសនា ។ ឥលូវនេះប្រទេសអង់គ្លេសបានក្លាយជាប្រទេសមួយខ្លាំងក្លា ហើយសំបូររុងរឿងទៀតផង ។ ប្រជារាស្ត្រយើងធ្វើការស្វិតស្វាញ ។ យើងផលិតផ្ទាល់ខ្លួនយើងទាំងខោអាវទាំងអាវុធ ។ យើងផលិតក្រណាត់ឡែនស្ទើរតែសំរាប់អឺរ៉ុបទាំងមូល ។ ក្រណាត់សូត្រខ្លះត្រូវនាំចូលពីប្រទេសបារាំង ប៉ុន្តែនោះគឺជាក្រណាត់ដែលមានគុណភាពអន់ហើយវាក៏សំរាប់តែអ្នកមានៗ តែប៉ុននោះ ។

*ឆ្លាក់ថន* បានសំរេចចិត្តថានឹងមិននិយាយផងទេអំពីជំងឺប៉េស ( * ) វិពីកុប្បកម្មវិពីការបះបោរដែលបណ្តាលមកពីការ " ព័ទ្ធរបង " នៃដីធ្លី ( ** ) ហើយនឹងចំនោលជនបទរបស់កសិករសំដៅទីក្រុង និងទីប្រជុំជន ប៉ុន្តែគេបានលើកដំណាលពីព្រះមហាក្សត្រ និងមហាក្សត្រិយានីដ៏សប្បុរសធម៌ ពីអ្នកដឹកនាំល្អ ពីអ្នកតំណាងរាស្ត្រដ៏វាងវៃ ហើយនឹងសង្គ្រាមនានាប្រកបដោយជោគជ័យទាំងឡាយវិញ ។

- លោកម្ចាស់ *តូវ៉ាណាកា* ចង់ច្បាស់នៅក្នុងចិត្តបន្តិច ។ លោកបាននិយាយថាមានតែមហិទ្ធិរិទ្ធិផ្នែកសមុទ្រទេវី ដែលអាចការពារប្រទេសលោកទល់នឹងប្រទេសអេស្ប៉ាញ និង ប៉ុកទុយកាល់បាន មែនទេ ?

- ពិតហើយ ។ តែមហិទ្ធិរិទ្ធិនេះមួយគត់ ។ ភាពធ្វើម្ចាស់លើសមុទ្ទយើងនេះហើយដែលធ្វើអោយយើងមានសេរីភាព ។ ប្រទេសរបស់លោកម្ចាស់ក៏ជាកោះដូចប្រទេសយើងខ្ញុំដែរ ។ បើមិនអាចធ្វើម្ចាស់លើសមុទ្ទរបស់លោកម្ចាស់បានទេ គឺមិនមានន័យថា

---

*(*) នៅក្នុងពាក់កណ្តាលសតវត្សទី១៤ ( ១៣៤៧-១៣៥២ ) ជំងឺប៉េសខ្មៅបានធ្វើអោយមនុស្សម្ភៃប្រាំលាននាក់នៅអឺរ៉ុបត្រូវស្លាប់ ។*

*(**) អាស្រ័យដោយការរីកចំរើនកម្មន្តសាលតំបាញពិសេសក្រណាត់ឡែន ច្បាប់ "ព័ទ្ធរបង" ( Enclosures Acts ) បើកអោយពួក អភិជន និងពួកអ្នកមានព័ទ្ធយកដីស្រែសហគមន៍ធ្វើជាវាលស្មៅចិញ្ចឹមចៀមយករោមវិញ ។*



www.budinst.gov.kh www.elibraryofcambodia.org

មិនអាចការពារខ្លួនបានចំពោះមុខសត្រូវមកពីក្រៅទេរឺ ?

- លោកម្ចាស់របស់ខ្ញុំ ឯកភាពនឹងគំនិតរបស់លោក ។

- អូ ! បើអញ្ចឹងប្រទេសលោកម្ចាស់ធ្លាប់ត្រូវគេឈ្លានពានដែរ ។

*ប្លាក់ថន* ក្រលេកឃើញចិញ្ចើមរបស់ *តូរ៉ាណាកា* ជ្រួញបន្តិច នៅពេលដែល *ម៉ារីកូ* បកសំនួររបស់គេប្រាប់ ហើយគេរំលឹកខ្លួនអោយស្ថិតនៅត្រឹមតែឆ្លើយតបនឹងសំនួរតែមិនត្រូវសួរនាំអ្វីទាំងអស់ ។

នៅពេលដែលនាងនិយាយមករក *ប្លាក់ថន* ជាថ្មី *ម៉ារីកូ* មានលក្ខណៈមុតមាំជាងមុន ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា ខ្ញុំត្រូវឆ្លើយនឹងសំនួររបស់លោក ។ ជាការពិតហើយ ប្រទេសយើងត្រូវគេឈ្លានពានចូលពីរដង ។ កាលពីជាងបីរយឆ្នាំមុន ពោលបើរាប់តាមប្រតិទិនរបស់ជនជាតិលោក គឺនៅឆ្នាំ ១២៧៤ ពួកម៉ុងកូលរបស់ឃូភីឡៃខាន់ ដែលទើបប្រាមប្រាបប្រទេសចិន និង ប្រទេសកូរ៉េហើយនោះ បានធ្វើសង្គ្រាមនឹងយើងនៅពេលដែលប្រទេសយើងមិនព្រមខ្លបខ្លាចអំនាចរបស់ពួកវា ។ កងទ័ពប៉ុន្មានពាន់នាក់បានមកចុះនៅ *ក្យូស៊ូ* ប៉ុន្តែពួកសាមូរ៉ៃទប់ពួកវាជាប់ ហើយមួយរយៈមកពួកវាក៏ថយទៅ ។ ប៉ុន្តែប្រាំពីរឆ្នាំក្រោយមកពួកវាបានវិលត្រលប់មកម្តងទៀត ។ ម្តងនេះពួកវាបានបើកការឈ្លានពានដោយប្រើសំពៅចិន និង កូរ៉េរាប់ពាន់គ្រឿង និងមានកងទ័ពទាំងម៉ុងកូលទាំងចិន ទាំងកូរ៉េ ប្រហែលម្ភៃម៉ឺននាក់ ក្នុងនោះភាគច្រើនជាទ័ពសេះ ។ នៅក្នុងប្រវត្តិប្រទេសចិននេះគឺជាកំលាំងឈ្លានពានដ៏ធំបំផុតដែលគេបានប្រមូលផ្តុំ ។ ពួកយើងគឺពិតជាមិនអាចទប់ទល់បាននឹងចំនួនទ័ពដ៏សន្ធឹកសន្ធាប់បែបនេះបានឡើយ *អាន់ជីន - សាន* ។ ពួកវាដាក់ទ័ពចុះនៅច្រកសមុទ្រ *ហាកាតា* តំបន់ *ក្យូស៊ូ* ដដែល ។ ប៉ុន្តែនៅមុនពេលដែលពួកវាវាយទ័ពរួចស្រេចបាច់នោះព្យុះកំបុតត្បូង គឺ *តៃភូន* បានបក់បោកមកពីខាងត្បូង ហើយបានបំផ្លាញទាំងសំពៅ ទាំងអ្វីៗដែលនៅលើនោះ ។ នោះគឺជាខ្យល់ទេព ជា *កាមីកាស៊ី* ណា *អាន់ជីន - សាន - ម៉ារីកូ* ពោលពាក្យទាំងនេះក្នុងជំនឿយ៉ាងមុតមាំនៅក្នុងចិត្ត - ជា *កាមីកាស៊ី* ដែលព្រះលោកបានបញ្ជូនមកដើម្បីការពារទឹកដីរបស់ព្រះអង្គអោយផុតពីការឈ្លាន



ពុទ្ធសាសនបណ្ឌិត្យ បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

ពានបរទេស ។ ពួកម៉ុងកូលមិនដែលវិលត្រលប់មកវិញទៀតទេ ហើយក្រោយពីសន្តិវង្ស *យឺញ* របស់ពួកវាសោយរាជ្យបានប្រហែលប៉ែតសិបឆ្នាំជាងមកនោះ ពួកវាក៏ត្រូវគេរឺខ្ចាត ចេញពីប្រទេសចិនទៅ ។

រូច *ម៉ារីកូ* បន្ថែមទៀតនៅក្នុងការពេញចិត្ត :

- ព្រះការពារពួកយើងតទល់នឹងពួកវាអស់នោះ ។ ព្រះតែងតែការពារពួកយើង ជានិច្ចតទល់នឹងការឈ្លានពាន ។ និយាយអោយស្រួលស្តាប់ គឺទឹកដីនេះជាទឹកដីរបស់ព្រះ *វេ?*

*ប្លាក់ថន* សញ្ជឹងគិតពីចំនួនដ៏សន្ធឹកសន្ធាប់នៃសំពៅ និងទ័ពនៅក្នុងការឈ្លានពាន នេះ ។ បើយកចំនួនកងនាវាអេស្ប៉ាញដែលវាយប្រឆាំងនឹងប្រទេសអង់គ្លេសមកប្រៀបធៀបវិញ គឺថាហៅមិនលើទេ ។

*ប្លាក់ថន* ឆ្លើយតបវិញក្នុងលក្ខណៈម៉ឺងម៉ាត់ដូចគ្នា :

- ប្រទេសយើងខ្ញុំក៏បានទទួលជំនួយពីព្យុះសង្ឃរាដែរអ្នកស្រី ។ មនុស្សជាច្រើន ណាស់បានជឿថានេះគឺជាបារមីរបស់ព្រះជាម្ចាស់ ហើយពិតណាស់នេះគឺជាអព្ភូតហេតុមួយ ។

*ប្លាក់ថន* ចោលភ្នែកសំលឹងមើលរងើកភ្លើងដែលកំពុងមានអណ្តាតភ្លើងរេរាំ ហើយ ពោលបន្តទៀត :

- ពួកម៉ុងកូល ក៏វិះតែនឹងលេបអឺរ៉ុបទាំងមូលដែរ ។

រូចគេដំណាលប្រាប់ *ម៉ារីកូ* ពីប្រការកងទ័ពរបស់ *សង់ស៊ីខាន់* ( Gengis Khan ) ( * ) ដែលជាជីតារបស់ស្តេច *យូប៊ីឡៃខាន់* បានវាយលុកមកដល់មាត់ទ្វារទីក្រុង *វីយែន* ទើបអាចទប់បាន ហើយពួកនេះក៏បកថយក្រោយវិញដោយទុកឆ្អឹងមនុស្សដែលពួកនេះសំលាប់ គរដូចភ្នំ :

- កាលពីសម័យនោះ គេតែងមានជំនឿថា *សង់ស៊ីខាន់* និងទ័ពរបស់គាត់គឺត្រូវ ព្រះបញ្ជូនមកដើម្បីផ្តន្ទាលោកនេះ ដែលប្រព្រឹត្តបាបកម្មច្រើនពេក ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា គាត់គ្រាន់តែជាមនុស្សចុងស្រុកម្នាក់

---

(*) *គេមុយជិន ភាសាម៉ុងកូល ( គ.អ.ប )*



www.budinst.gov.kh www.elibraryofcambodia.org

ដែលប៉ិនប្រសប់អស្ចារ្យក្នុងការធ្វើសង្គ្រាម តែប៉ុណ្ណោះ ។

- បាទ ។ ទោះជាយ៉ាងនេះក្តី នៅឯប្រទេសអង់គ្លេស យើងមានសំនាងដោយប្រទេសយើងជាកោះ ។ យើងដឹងគុណព្រះជាម្ចាស់ យើងដឹងគុណកងនាវាចរយើង ។ ប្រទេសជប៉ុនមានសង្គ្រាមជាមួយប្រទេសចិន ហើយប្រទេសចិនជាប្រទេសមានមហិទ្ធិរិទ្ធិផង នៅក្បែកផង ខ្ញុំសែនឆ្ងល់ណាស់ដែលប្រទេសជប៉ុនមិនមានកងនាវាមួយដ៏ខ្លាំងក្លានោះ ។ តើនាងមិនខ្លាចថានឹងមានការវាយលុកមួយទៀតទេអ្វី ?

*ម៉ារីកូ* មិនឆ្លើយនឹងសំនួរនេះទេ ។ នាងងាកបែរទៅបកជូន *តូរ៉ាណាកា* នូវសំដីរបស់ *ប្លាក់ថន* ។ ពេលនាងបកចប់ *តូរ៉ាណាកា* និយាយទៅកាន់ *យ៉ាប៊ូ* ១ងក់ក្បាល ហើយឆ្លើយតបវិញក្នុងលក្ខណៈម៉ឺងម៉ាត់ ។ អ្នកទាំងពីរនិយាយជាមួយគ្នាមួយសន្ទុះ ហើយងាកមកសួរ *ម៉ារីកូ* មួយសំនួរទៀត ។ នៅពេលឆ្លើយចប់ហើយ នាងក៏និយាយមកកាន់ *ប្លាក់ថន* ម្តងទៀត :

- ដើម្បីម្ចាស់ការលើផ្ទៃសមុទ្ររបស់លោក តើលោកត្រូវការនាវាប៉ុន្មាន ?

- ខ្ញុំមិនដឹងច្បាស់ទេ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះ ព្រះមហាក្សត្រិយ៍មានសំពៅដែលកំពុងប្រើប្រាស់ទាំងអស់មួយរយហាសិប ហើយនេះគឺគិតតែពីសំពៅសំរាប់ធ្វើសង្គ្រាមតែប៉ុណ្ណោះ ។

- លោកម្ចាស់ខ្ញុំសួរថា ក្នុងមួយឆ្នាំ១ តើព្រះមហាក្សត្រិយ៍របស់លោកសាងសង់សំពៅប៉ុន្មាន ?

- ពីរម្ភៃទៅសាមសិបសំពៅធំៗ ។ ហើយនេះជាសំពៅដែលល្អបំផុត និង លឿនបំផុតនៅក្នុងលោក ។ ប៉ុន្តែជាធម្មតាសំពៅទាំងនេះត្រូវបានកសាងឡើងដោយក្រុមឈ្មួញឯកជន រួចទើបគេលក់ថ្វាយព្រះរាជបល្ល័ង្ក ។

- លក់យកចំនេញ ?

*ប្លាក់ថន* នឹកឃើញភ្លាមពីទស្សនៈរបស់ពួកសាមូរ៉ៃ ស្តីពីរឿងចំនេញ និងពីរឿងលុយកាក់ :

- ព្រះមហាក្សត្រិយ៍រមែងផ្តល់អោយយ៉ាងសប្បុរសធម៌ លើសពីតំលៃពិតប្រាកដទៅ



www.budinst.gov.kh www.elibraryofcambodia.org

ទៀត ដើម្បីលើកទឹកចិត្តដល់ការស្រាវជ្រាវ និងការបង្កើតក្បាច់សាងសង់ថ្មី ។ បើគ្មានព្រះរាជទាននេះទេ ការសាងសង់ពិតជាមានការលំបាក ។ ឧទាហរណ៍ដូចជាសំពៅ *អេរ៉ិស* របស់ខ្ញុំជាដើម ។ នេះជាប្រភេទសំពៅថ្មី ដែលគូសគ្រោងឡើងដោយអង់គ្លេស ហើយដែលត្រូវបានចុះកុងត្រាសាងសង់នៅប្រទេសហូឡង់ ។

- តើលោកអាចសង់សំពៅបែបនេះនៅទីនេះបានទេ ?

- បាទ បាន ។ បើសិនជាខ្ញុំមានជាងឈើ មានអ្នកបកប្រែ មានសំភារៈ និងពេលវេលាគ្រប់គ្រាន់ ។ ដំបូងខ្ញុំត្រូវសាងសង់នាវាតូច១ជាងនេះសិន ព្រោះតាំងពីដើម១មកខ្ញុំមិនដែលធ្វើសំពៅមួយទាំងមូលតែម្នាក់ឯងយ៉ាងនេះទេ ហេតុនេះខ្ញុំសាកពិសោធន៍សិន... ជាការពិតហើយ - *ត្លាក់ថន* និយាយបន្ថែមដោយខំទប់នូវអារម្មណ៍រំភើបបណ្តាលមកពីការគិតដល់លទ្ធភាពខាងមុខផង - ជាការពិតហើយ បើលោកម្ចាស់ *តូរ៉ាណាកា* ចង់បានសំពៅមួយរឺក៏ច្រើនជាងមួយនោះ យើងអាចរកស៊ីជាមួយគ្នាបាន ។ នោះលោកម្ចាស់អាចបញ្ជាអោយគេសាងសង់សំពៅចំបាំងមួយចំនួននៅឯប្រទេសអង់គ្លេសតែម្តងក៏បាន ។ រួចយើងអាចបញ្ជូនសំពៅទាំងនោះមកជូនលោកម្ចាស់ បំពាក់ដោយសំភារៈនិងយុទ្ធោបករណ៍កុំប្លេទាំងអស់ ។

*ម៉ារីកូ* បកប្រែសំដីទាំងនេះ ។ ទាំង *តូរ៉ាណាកា* ទាំង *យ៉ាប៊ូ* បង្ហាញនូវការយកចិត្តទុកដាក់យ៉ាងខ្លាំង ។

- លោកម្ចាស់សួរថា តើពួកនាវិករបស់យើងអាចទទួលការរ៉ឹករ៉ឺនអោយបើកសំពៅទាំងអស់នេះបានទេ ?

- បាន អោយតែមានពេល ។ ពួកយើងអាចរៀបចំអោយពួកគ្រូបង្ហាត់មកទីនេះចំនួនមួយឆ្នាំបាន ដើម្បីរៀបចំកម្មវិធីបណ្តុះបណ្តាលសំរាប់នាវិកជប៉ុន ។ តែក្នុងប៉ុន្មានឆ្នាំប៉ុននោះ លោកម្ចាស់នឹងមានកងនាវាចរផ្ទាល់ខ្លួនជាស្រេច ។ ជាកងនាវាចរទំនើបឥតចាញ់នរណាមួយឡើយ ។

*ម៉ារីកូ* បកប្រែរួចហើយ *តូរ៉ាណាកា* ក៏ដេញដោលសួរនាងមួយសន្ទុះ ។ *យ៉ាប៊ូ* ក៏សួរដេញដោលបន្ថែមដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់ *យ៉ាប៊ូ* សួរថា ឥតចាញ់នរណាមួយមែនរឺ ?

- បាទ ពិតមែន ។ ល្អជាងអ្វីដែលពួកអេស្ប៉ាញ រឺ ពួកប៉ិកខុយកាល់ មានទៅទៀត ។

ភាពស្ងៀមស្ងាត់បានកើតមានឡើងមួយសន្ទុះ ។ *តូរ៉ាណាកា* មានការទាក់ទាញអារម្មណ៍លើគំនិតនេះយ៉ាងច្បាស់ក្រលែត ថ្វីត្បិតតែលោកខំលាក់វាយ៉ាងណាក្តី ។

- លោកម្ចាស់ខ្ញុំសួរថា តើលោកច្បាស់ថារឿងហ្នឹងអាចនិយាយគ្នាបានមែនរឺទេ ?

- បាទ ។

- តើត្រូវស៊ីពេលប៉ុន្មានទៅ ?

- ដើម្បីវិលទៅដល់ស្រុកខ្ញុំវិញត្រូវស៊ីពេលពីរឆ្នាំ ។ ត្រូវចំណាយពេលពីរឆ្នាំទៀតដើម្បីសាងសង់សំពៅទាំងឡាយនេះ ហើយពីរឆ្នាំទៀតដើម្បីនាំវាមកដល់ទីនេះវិញ ។ តំលៃសាងសង់ពាក់កណ្តាលត្រូវបង់មុន ពាក់កណ្តាលទៀតបង់នៅពេលទទួលរបស់ ។

*តូរ៉ាណាកា* អោនទៅចាប់ឈើក្រអូបដាក់បន្ថែមទៅលើភ្លើងចង្រ្កានទាំងសញ្ជប់សញ្ជឹង ។ ទាំងអស់គ្នាតាមសំលឹងមើលកាយវិការរបស់លោកក្នុងការរង់ចាំ ។ បន្ទាប់មកលោកក៏និយាយជាមួយ *យ៉ាប៊ូ* អស់មួយរយៈធំ ។ *ម៉ារីកូ* ឥតបកប្រែនូវអ្វីដែលអ្នកទាំងពីរកំពុងនិយាយគ្នានោះប្រាប់ *ប្លាក់ថន* ឡើយ ហេតុនេះគេមិនអាចយល់បានថាតើអ្នកទាំងពីរពិភាក្សាពីអ្វីនោះទេ ។ ប៉ុន្តែអ្វីដែលគេដឹង គឺថាជាគំនិតមួយដ៏ភ្លឺស្វាងដែលអាចនាំនូវលាភសក្ការៈដ៏ធំសំបើមផង ធានាការវិលត្រលប់ទៅប្រទេសអង់គ្លេសរបស់គេដោយសុវត្ថិភាពផង ។

- *អាន់ជីន - សាន* តើលោកអាចនាំសំពៅមកបានប៉ុន្មាន ?

- ល្អបំផុតប្រាំគ្រឿង ។ ក្នុងនោះ ត្រូវត្រៀមថាបាត់មួយ ដោយសារព្យុះ ដោយការជ្រៀតជ្រែកពួកអេស្ប៉ាញ ពួកប៉ិកខុយកាល់ផង ។ ខ្ញុំដឹងច្បាស់ណាស់ថាពួកនេះ នឹងប្រឹងធ្វើសព្វគ្រប់បង្ការមិនអោយលោកម្ចាស់មានសំពៅចំបាំងជាដាច់ខាត ។ លោកម្ចាស់ *តូរ៉ាណាកា* អាចនឹងមានសំពៅចំបាំងពីដប់ប្រាំទៅម្ភៃគ្រឿង - *ប្លាក់ថន* ឈប់មួយភ្លែតរង់ចាំ *ម៉ារីកូ* បកអស់រួចបន្តទៅទៀត - កងនាវាទីមួយអាចដឹកយកមកនូវពួកជាងឈើ ពួកជាងគ្រឿងដំបូល ពួកកាំភ្លើងធំ ពួកនាវិក និងពួកគ្រូបង្ហាត់ ។ ក្នុងរវាងដប់ទៅដប់ប្រាំឆ្នាំ ប្រទេសអង់គ្លេសអាចផ្គត់ផ្គង់



www.budinst.gov.kh www.elibraryofcambodia.org

ជូនលោកម្ចាស់ *ត្វរ៉ាណាកា* នូវសំពៅចំបាំងទំនើបចំនួនសាមសិបគ្រឿងបាន ។ ចំនួននេះគឺល្មមគ្រប់គ្រាន់នឹងម្ចាស់ការនៅលើដែនសមុទ្ររបស់លោកម្ចាស់បានហើយ ។ ដល់ពេលនោះ បើសិនជាលោកម្ចាស់មានបំណង លោកម្ចាស់អាចសាងសង់សំពៅដោយផ្ទាល់នៅទីនេះដើម្បីជំនួសសំពៅចាស់បានហើយ ។ ម្យ៉ាងទៀត - *ឡាក់ថុន* ហៀបនឹងនិយាយពាក្យ " លក់" ប៉ុន្តែគេទប់ទាន់ - ម្យ៉ាងទៀត ព្រះមហាក្សត្រិយ៍ខ្ញុំពិតជាសព្វព្រះរាជហឫទ័យនឹងជួយលោកម្ចាស់កសាងនាវាចររបស់លោកម្ចាស់ ហើយពិតណាស់ បើសិនជាលោកម្ចាស់មានសំនូមពរពួកយើងនឹងជួយបង្វឹកហាត់ និង ផ្គត់ផ្គង់សំភារៈបរិក្ខារថែមទៀត ។

ពិតហើយ - *ឡាក់ថុន* គិតនៅក្នុងចិត្តដោយក្ដីរំភើបរីករាយចំពោះផែនការដែលកំពុងលេចចេញជារូបរាងមកនេះ - យើងរៀបចំអោយ យើងតែងតាំងមេទ័ពជើងទឹកអោយ ហើយព្រះមហាក្សត្រិយ៍នឹងចងសំព័ន្ធមេត្រីភាពភ្ជាប់គ្នានឹងកិច្ចសន្យាពាណិជ្ជកម្មនេះ ។ ហើយនេះគឺជាផលប្រយោជន៍សំរាប់លោកផង សំរាប់យើងផង ។ ជាមួយគ្នាយើងនឹងបណ្ដេញពួកអាផ្គែអេស្ប៉ាញ និង ប៉ក់ទុយកាល់ចេញផុតពីដែនសមុទ្ទទាំងនេះ ហើយយើងនឹងធ្វើជាម្ចាស់តំបន់នេះជារៀងរហូត។ នេះគឺជាកិច្ចព្រមព្រៀងដ៏ធំបំផុតមិនដែលមានប្រទេសណាធ្វើបានឡើយ ។ មានកងនាវាចរអង់គ្លេស - ជប៉ុន ធ្វើម្ចាស់លើដែនសមុទ្ទនេះហើយ ពួកអង់គ្លេសយើងនឹងបំបាវផ្ដាច់ជំនួញសូត្ររវាងចិន នឹង ជប៉ុន ហើយនោះគឺលុយរាប់លានរៀងរាល់ឆ្នាំ ។

បើអញធ្វើរឿងនេះចេញ អញពិតជាបង្វែរទិសប្រវត្តិសាស្ត្របានតែម្ដង ។ អញនឹងមានទ្រព្យសម្បត្តិហើយនឹងកិត្តិយសលើសពីអញដេកយល់សប្តិទៅទៀត ។ អញនឹងក្លាយទៅជាបុព្វជន ។ ហើយដើម្បីក្លាយខ្លួនទៅជាបុព្វជន មនុស្សត្រូវប្រឹងធ្វើអ្វីដែលប្រសើរបំផុតទោះជាត្រូវបរាជ័យនៅក្នុងការប្រឹងប្រែងនេះក៏ដោយ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គឺជាការគួរអោយស្ដាយណាស់ ដែលលោកមិនចេះភាសាយើង ។

- ពិតហើយ ប៉ុន្តែខ្ញុំជឿថា អ្នកស្រីបកបានល្អណាស់ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា នេះមិនមែនជាការរិះគន់ខ្ញុំនោះទេ តែគ្រាន់តែជា



www.budinst.gov.kh www.elibraryofcambodia.org

កំនត់សំគាល់មួយតែប៉ុននោះ ។ ជាការពិតណាស់ បើសិនជាលោកម្ចាស់ខ្ញុំអាចនិយាយផ្ទាល់មាត់ជាមួយលោកបាន ដូចខ្ញុំនិយាយជាមួយលោកនោះ គឺល្អប្រសើរជាង ។

- តើអ្នកស្រីមានវចនានុក្រមទេ ? និងក្បួនវេយ្យាករណ៍ ។ ក្បួនវេយ្យាករណ៍ប៉ិកទុយកាល់-ជប៉ុនក៏បាន វេយ្យាករណ៍ ឡាតាំង-ជប៉ុនក៏បាន ។ បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* អាចជួយផ្តល់សៀវភៅ និងគ្រូបង្រៀនដល់ខ្ញុំៗនឹងប្រឹងប្រែងរៀនភាសាជប៉ុនជាមិនខាន ។

- ពួកយើងគ្មានសៀវភៅបែបនេះទេ ។

- ប៉ុន្តែពួកយេស៊ុីតមាន ។ អ្នកស្រីនិយាយខ្លួនឯងទេតើ ។

*ម៉ារីកូ* ងាកទៅនិយាយជាមួយ *តូរ៉ាណាកា* ហើយ *ប្លាក់ថន* ប្រទះឃើញនូវពន្លឺនៅក្នុងកែវភ្នែក និង ភាពញញឹម ដែលលេចឡើងពីក្នុងរង្វង់មុខ ទាំងរបស់ *តូរ៉ាណាកា* ទាំងរបស់ *យ៉ាប៊ូ* ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គាត់នឹងជួយលោក *អាន់ជីន - សាន* ។

តាមបញ្ជារបស់ *តូរ៉ាណាកា ភូជីកូ* ចាក់ស្រាសាកេបន្ថែមទៀតដល់ *ប្លាក់ថន* និង *យ៉ាប៊ូ* ។

*តូរ៉ាណាកា* និង *ម៉ារីកូ*ទទួលទានតែ ។ ដោយមិនអាចរង់ចាំបាន *ប្លាក់ថន*ក៏សួរទៅ *ម៉ារីកូ*

-តើលោកម្ចាស់មានប្រតិកម្មយ៉ាងម៉េចដែរចំពោះសំនើរបស់ខ្ញុំ ? ចំលើយគាត់យ៉ាងម៉េច ?

- *អាន់ជីន-សាន* យកល្អលោកគួរតែចេះអត់ធ្មត់ ។ លោកម្ចាស់នឹងផ្តល់ចំលើយនៅក្នុងពេលណាមួយដែលលោកម្ចាស់ជ្រើសរើស ។

- សូមអ្នកស្រី សួរគាត់អីលូវនេះតែម្តងទៅ ។

*ម៉ារីកូ* ងាកទៅសួរ *តូរ៉ាណាកា* ទាំងអល់អែក :

- សូមលោកម្ចាស់អភ័យទោសដល់នាងខ្ញុំផង ចាស ប៉ុន្តែ *អាន់ជីន-សាន* សូមសួរយ៉ាងគោរពថាតើលោកម្ចាស់យល់យ៉ាងម៉េចដែរ ពីផែនការរបស់គាត់ ? គាត់សូមស្នើយ៉ាងគោរព សូមលោកម្ចាស់អធ្យាស្រ័យផ្តល់ចំលើយដល់គាត់វិញផង ចាស ។

- គាត់នឹងទទួលចំលើយពីខ្ញុំនៅក្នុងពេលដ៏សមរម្យមួយ ។



www.budinst.gov.kh www.elibraryofcambodia.org

ជូនលោកម្ចាស់ *តូរ៉ាណាកា* នូវសំពៅចំបាំងទំនើបចំនួនសាមសិបគ្រឿងបាន ។ ចំនួននេះគឺល្មមគ្រប់គ្រាន់នឹងម្ចាស់ការនៅលើដែនសមុទ្ររបស់លោកម្ចាស់បានហើយ ។ ដល់ពេលនោះ បើសិនជាលោកម្ចាស់មានបំណង លោកម្ចាស់អាចសាងសង់សំពៅដោយផ្ទាល់នៅទីនេះដើម្បីជំនួសសំពៅចាស់បានហើយ ។ ម្យ៉ាងទៀត - *ប្លាក់ថន* ហៀបនឹងនិយាយពាក្យ " លក់" ប៉ុន្តែគេទប់ទាន់ - ម្យ៉ាងទៀត ព្រះមហាក្សត្រិយ៍ខ្ញុំពិតជាសព្វព្រះរាជហឫទ័យនឹងជួយលោកម្ចាស់កសាងនាវាចររបស់លោកម្ចាស់ ហើយពិតណាស់ បើសិនជាលោកម្ចាស់មានសំនូមពរពួកយើងនឹងជួយបង្វឹកហាត់ និង ផ្គត់ផ្គង់សំភារៈបរិក្ខារថែមទៀត ។

ពិតហើយ - *ប្លាក់ថន* គិតនៅក្នុងចិត្តដោយក្តីរំភើបរីករាយចំពោះផែនការដែលកំពុងលេចចេញជារូបរាងមកនេះ - យើងរៀបចំអោយ យើងតែងតាំងមេទ័ពជើងទឹកអោយ ហើយព្រះមហាក្សត្រិយ៍នឹងចងសំព័ន្ធមេត្រីភាពភ្ជាប់គ្នានឹងកិច្ចសន្យាពាណិជ្ជកម្មនេះ ។ ហើយនេះគឺជាផលប្រយោជន៍សំរាប់លោកផង សំរាប់យើងផង ។ ជាមួយគ្នាយើងនឹងបណ្តេញពួកអាផ្គៃអេស្ប៉ាញ និង ប៉័កទុយកាល់ចេញផុតពីដែនសមុទ្ទទាំងនេះ ហើយយើងនឹងធ្វើជាម្ចាស់តំបន់នេះជារៀងរហូត។ នេះគឺជាកិច្ចព្រមព្រៀងដ៏ធំបំផុតមិនដែលមានប្រទេសណាធ្វើបានឡើយ ។ មានកងនាវាចរអង់គ្លេស - ជប៉ុន ធ្វើម្ចាស់លើដែនសមុទ្ទនេះហើយ ពួកអង់គ្លេសយើងនឹងបារផ្តាច់ជំនួញសូត្ររវាងចិន នឹង ជប៉ុន ហើយនោះគឺលុយរាប់លានរៀងរាល់ឆ្នាំ ។

បើអញធ្វើរឿងនេះចេញ អញពិតជាបង្វែរទិសប្រវត្តិសាស្ត្របានតែម្តង ។ អញនឹងមានទ្រព្យសម្បត្តិហើយនឹងកិត្តិយសលើសពីអញដេកយល់សប្តិទៅទៀត ។ អញនឹងក្លាយទៅជាបុព្វជន ។ ហើយដើម្បីក្លាយខ្លួនទៅជាបុព្វជន មនុស្សត្រូវប្រឹងធ្វើអ្វីដែលប្រសើរបំផុតទោះជាត្រូវបរាជ័យនៅក្នុងការប្រឹងប្រែងនេះក៏ដោយ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គឺជាការគួរអោយស្តាយណាស់ ដែលលោកមិនចេះភាសាយើង ។

- ពិតហើយ ប៉ុន្តែខ្ញុំជឿថា អ្នកស្រីបកបានល្អណាស់ ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា នេះមិនមែនជាការរិះគន់ខ្ញុំនោះទេ តែគ្រាន់តែជា



www.budinst.gov.kh www.elibraryofcambodia.org

កំនត់សំគាល់មួយតែប៉ុននោះ ។ ជាការពិតណាស់ បើសិនជាលោកម្ចាស់ខ្ញុំអាចនិយាយផ្ទាល់មាត់ជាមួយលោកបាន ដូចខ្ញុំនិយាយជាមួយលោកនោះ គឺល្អប្រសើរជាង ។

- តើអ្នកស្រីមានវចនានុក្រមទេ ? និងក្បួនវេយ្យាករណ៍ ។ ក្បួនវេយ្យាករណ៍ប៉កខុយកាល់-ជប៉ុនក៏បាន វេយ្យាករណ៍ ឡាតាំង-ជប៉ុនក៏បាន ។ បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* អាចជួយផ្តល់សៀវភៅ និងគ្រូបង្រៀនដល់ខ្ញុំ១នឹងប្រឹងប្រែងរៀនភាសាជប៉ុនជាមិនខាន ។

- ពួកយើងគ្មានសៀវភៅបែបនេះទេ ។

- ប៉ុន្តែពួកយេស៊ុឥតមាន ។ អ្នកស្រីនិយាយខ្លួនឯងទេតើ ។

*ម៉ារីកូ* ងាកទៅនិយាយជាមួយ *តូរ៉ាណាកា* ហើយ *ប្លាក់ថន* ប្រទះឃើញនូវពន្លឺនៅក្នុងកែវភ្នែក និង ភាពញញឹម ដែលលេចឡើងពីក្នុងរង្វង់មុខ ទាំងរបស់ *តូរ៉ាណាកា* ទាំងរបស់ *យ៉ាប៊ូ* ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គាត់នឹងជួយលោក *អាន់ជីន - សាន* ។

តាមបញ្ជារបស់ *តូរ៉ាណាកា* *គូជីកូ* ចាក់ស្រាសាកេបន្ថែមទៀតដល់ *ប្លាក់ថន* និង *យ៉ាប៊ូ* ។

*តូរ៉ាណាកា* និង *ម៉ារីកូ*ទទួលទានតែ ។ ដោយមិនអាចរង់ចាំបាន *ប្លាក់ថន*ក៏សួរទៅ *ម៉ារីកូ*:

-តើលោកម្ចាស់មានប្រតិកម្មយ៉ាងម៉េចដែរចំពោះសំនើរបស់ខ្ញុំ ? ចំលើយគាត់យ៉ាងម៉េច ?

- *អាន់ជីន-សាន* យកល្អលោកគួរតែចេះអត់ធ្មត់ ។ លោកម្ចាស់នឹងផ្តល់ចំលើយនៅក្នុងពេលណាមួយដែលលោកម្ចាស់ជ្រើសរើស ។

- សូមអ្នកស្រី សួរគាត់អីលូវនេះតែម្តងទៅ ។

*ម៉ារីកូ* ងាកទៅសួរ *តូរ៉ាណាកា* ទាំងអល់អែក :

- សូមលោកម្ចាស់អភ័យទោសដល់នាងខ្ញុំផង ចាស ប៉ុន្តែ *អាន់ជីន-សាន* សូមសួរយ៉ាងគោរពថាតើលោកម្ចាស់យល់យ៉ាងម៉េចដែរ ពីផែនការរបស់គាត់ ? គាត់សូមស្នើយ៉ាងគោរព សូមលោកម្ចាស់អធ្យាស្រ័យផ្តល់ចំលើយដល់គាត់វិញផង ចាស ។

- គាត់នឹងទទួលចំលើយពីខ្ញុំនៅក្នុងពេលដ៏សមរម្យមួយ ។



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ងាកមកបកអោយ *ច្ហាក់ថុន* វិញ :

-លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកនឹងពិនិត្យលើគំរោងរបស់លោក ហើយនឹងគិតអោយបានល្អិតល្អន់ពីអ្វីដែលលោកបានពោលអំបាញ់មិញនេះ ។ លោកម្ចាស់ខ្ញុំស្នើសូមអោយលោកអត់ធ្មត់សិន ។

- *ដូម៉ូ តូរ៉ាណាកា - សាម៉ា* ។

-ខ្ញុំទៅសំរាកហើយ ។ យើងចេញដំណើរនៅពេលព្រលឹម ។

*តូរ៉ាណាកា* ងើបឈរឡើង ។ ទាំងអស់គ្នាអមដំណើរលោកចុះទៅក្នុងទូក លើកលែងតែ *ច្ហាក់ថុន* ដែលអង្គុយត្រមង់ត្រមោចកណ្តាលរាត្រីស្ងាត់ ។

* * *

នៅពេលព្រលឹមស្រាង១ *តូរ៉ាណាកា* ព្រលែងព្រាបនាំសារបួន ដែលហើរព័ទ្ធសំពៅពីរជុំ រួចទើបទទះស្លាបហើរតំរង់ទៅ *អូសាកា* ពីរ និង ពីរក្បាលទៀតហើរតំរង់ទៅ *យេដូ* ។

សារដែលសរសេរជាភាសាសំងាត់ទៅអោយ *គីរីស៊ីបូ* គឺជាបញ្ជាទៅដល់ *ហ៊ីរ៉ូម៉ាត់ស៊ី* អោយនាំគ្នាចាកចេញពី *អូសាកា* ដោយស្ងប់ស្ងៀម ។ បើសិនជាពួកគេត្រូវខាឃាំងមិនអោយចេញ ពួកគេត្រូវចាក់សោនៅក្នុងទីកន្លែងរបស់ពួកគេ ។ បើសិនជាគេទំលាយទ្វារចូល ពួកគេត្រូវដុតមួយផ្នែកនៃវិមានដែលពួកគេរស់នៅនេះចោល ហើយធ្វើ *សិបពូគូ* ទាំងអស់គ្នា ។

សារភាសាសំងាត់មួយទៀត គឺសំរាប់កូនប្រុសរបស់លោកឈ្មោះ *ស៊ូដារ៉ា* នៅឯ *យេដូ* ដើម្បីអោយដឹងថារូបលោកបានគេចចេញពី *អូសាកា* ប្រកបដោយសុវត្ថិភាព ហើយនឹងបញ្ជាអោយ *ស៊ូដារ៉ា* បន្តត្រៀមរៀបចំសង្គ្រាមយ៉ាងសំងាត់ទៅទៀត ។

នាពេលថ្ងៃត្រង់ពួកគេបានឆ្លងផុតឆកសមុទ្រដែលនៅចន្លោះខេត្ត *តូតូមី* នឹងខេត្ត *អ៊ីស៊ូ* ហើយបានមកដល់ជ្រោយ *អ៊ីតូ* ដែលនៅចុងខាងជើងខេត្ត *អ៊ីស៊ូ* ។ ខ្យល់បក់ក្នុងកំរិតមធ្យម សមុទ្រស្ងប់គ្មានរលក ហើយក្តោងធំតែមួយគឺគ្រប់គ្រាន់នឹងធ្វើដំណើរបាន ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែលទូកធំ ចូលតាមច្រកសមុទ្រដែលព័ទ្ធព្រែកដីគោក និងកោះថ្មតូចៗទាំងឡាយ ដើម្បីងាកក្បាលបែរទៅខាងជើងនោះ សំលេងខ្ទរមួយបានលឺឡើងនៅឯនាយសមុទ្រ ។

ច្រវាំទាំងអស់ឈប់នៅស្ងៀមទ្រឹង ។

- រួចចុះវាយ៉ាងម៉េច ...

ភ្លែករបស់ *ភួក់ថន* សំលឹងជាប់ទៅឯលំហសមុទ្រ ។

រំពេចនោះ ជញ្ជាំងថ្មក៏រហែកប្រេះចេញទំលាក់ដុំថ្មរាប់លានតោនទៅក្នុងសមុទ្រ ។

ក្នុងមួយរយៈនោះ ទឹកសមុទ្រកញ្ជ្រោកបោកបក់ប្រៀបបីដូចជាទឹកកំពុងពុះ ។ រលកកំរិតតូចល្មមបោកបក់មកលើទូកធំហើយរត់ហួសទៅ ។ បន្តិចមកថ្មឈប់ធ្លាក់ ហើយសំលេងខ្ទរពិតមែនតែនៅលឺគ្រហឹមនៅឡើយក្តី ប៉ុន្តែហាក់ដូចជានៅឆ្ងាយទៅៗ ។ ម្នាក់ៗនៅលើទូកផ្ទៀងត្រចៀកស្តាប់យ៉ាងយកចិត្តទុកដាក់ ភ្នែកសំលឹងជាប់ច្រាំងថ្ម ត្រចៀកផ្ទៀងស្តាប់ស្នូរ ។ បន្ទាប់មក *តូរ៉ាណាកា* ធ្វើសញ្ញាទៅនាយកងស្ករ ដែលចាប់ផ្តើមវាយសង្វាក់បន្តទៀត ។ ច្រវាំចាប់ផ្តើមធ្វើសកម្មភាពខ្លួនឡើងវិញ ។ ជីវិតនៅទូកធំ ចាប់ផ្តើមមានសកម្មភាពដូចធម្មតាឡើងវិញ ។

- អាណឹង ស្អីគេណឹង ? - *ភួក់ថន* សួរឡើង ។

*ម៉ារីកូ* តបទាំងងឿងឆ្ងល់ :

- ចាស គ្មានអីទេ គ្រាន់តែរញ្ជួយផែនដីទេតើ ។ ស្រុកលោកមិនដែលរញ្ជួយផែនដីទេអី ?

- ទេ ។មិនដែលមានទាល់តែសោះ ។ ខ្ញុំមិនដែលជួបសោះហើយនេះ ។

- ស្រុកយើងមានរញ្ជួយផែនដីញឹកញាប់ណាស់ *អាន់ជិន-សាន* ។ ប៉ុនៗនេះគឺឥតការទេ ព្រោះចំនុចរញ្ជួយរបស់វានៅកន្លែងផ្សេងពីនេះ ប្រហែលជានៅក្នុងបាតសមុទ្រហើយមើលទៅ ។ លោកសំនាងហើយដែលជួបនឹងអាចុនតូចបែបនេះ ។

- អំបាញ់មិញនេះដូចផែនដីទាំងមូលរញ្ជួយតែម្តង ។ ខ្ញុំធ្លាប់លឺគេនិយាយពីរឿងរញ្ជួយ



www.budinst.gov.kh www.elibraryofcambodia.org

នេះដែរ ។ នៅឯផែនដីព្រះ (*) និងនៅឯចក្រភព អូតូម៉ាន ( ** ) គេមានរញ្ជួយម្ដងម្កាលដែរ ។ ប៉ុន្តែលើកនេះ ខ្ញុំមើលទៅ ឃើញច្រាំងថ្មរញ្ជួយដូចគេអង្រួនតែម្ដង ។

- ចាស វារញ្ជួយមែន *អាន់ជីន-សាន* ។ បើសិនជានៅលើដីគោកវិញនោះបានគួរអោយរន្ធត់ញាក់សាច់តែម្ដង ។ នោះអត់មានអីអោយដឹងមុនទេ *អាន់ជីន-សាន* ។ រលករញ្ជួយមកទាំងផ្ទាំង១តែម្ដង ជួនកាលមកទាំងផ្ទាំង១ ជួនកាលឡើងចុះ១ ជួនកាលរញ្ជួយបីបួនដងផ្ទួន១គ្នា ជួនកាលអាតូចមួយថ្ងៃនេះ ថ្ងៃបន្ទាប់មានអាធំមួយមកទៀត ។ ពោលគឺគ្មានអ្វីដូចគ្នាទេ ។ សាហាវជាងគេដែលខ្ញុំជួប គឺនៅពេលយប់កាលពីប្រាំមួយឆ្នាំមុននៅជិតទីក្រុង *អូសាកា* កាលនោះគឺថ្ងៃទីបីនៃខែស្លឹកឈើជ្រុះ ។ ផ្ទះយើងទាំងមូលបាក់រលំសង្កត់លើពួកយើង ។ ខ្ញុំនិងកូនប្រុសខ្ញុំត្រូវរបួស ហើយពួកយើងត្រូវប្រឹងកកាយទាំងវេទនាដើម្បីវារចេញមកក្រៅបាន ។ កាលនោះរញ្ជួយដីមានប្រហែលមួយអាទិត្យ រឺ លើសពីហ្នឹងផងក៏មិនដឹង ។ មហាវិមានថ្មីរបស់*តៃកូ* នៅ *ភូជីមី* ត្រូវខ្ទេចខ្ទីរទាំងស្រុង ។ មនុស្សរាប់សែននាក់ត្រូវបាត់បង់ជីវិតនៅក្នុងការរញ្ជួយផែនដីនេះផង នៅក្នុងអគ្គីភ័យដែលឆាបឆេះឡើងដោយការរញ្ជួយផែនដីនេះផង ។ ហើយរឿងភ្លើងឆេះបណ្ដាលមកពីការរញ្ជួយផែនដីនេះហើយ ដែលជាគ្រោះថ្នាក់ធំបំផុតនោះ *អាន់ជីន-សាន* ។ បន្ទាប់ពីរញ្ជួយដីហើយគឺមានអគ្គីភ័យតាមក្រោយជានិច្ច ។ នេះធ្វើអោយក្រុងនិងភូមិទាំងឡាយរបស់យើងរលាយរលត់យ៉ាងងាយបំផុត ។ ជួនកាលមានរញ្ជួយផែនដីនៅឯនាយសមុទ្ទ តែតាមការនិទានតៗគ្នា គេថានោះគឺមូលហេតុនៃមហារលក ។ មហារលកនោះមានកំពស់ពីបីម៉ែត្រខ្លះដល់ប្រាំពីរម៉ែត្រខ្លះក៏មានដែរ ។ ទាំងអស់នេះគឺគ្មានអីអោយសញ្ញាមុនហើយក៏គ្មានរដូវដែរ ។ មហារលកបក់បោកពីខាងសមុទ្ទ ហើយសង្គ្រប់មកលើដីគោកតែម្ដង ។ ទីក្រុងទាំងមូលត្រូវរលាយក៏មានដែរ ។ កាលពីប៉ុន្មានឆ្នាំមុន ពាក់កណ្ដាលទីក្រុង

---

*( * ) តំបន់ប៉ាលេស្ទីន ( Holy Land ) ដែលគេកំនត់ជាកន្លែងប្រសូត ធ្វើសកម្មភាព និងមរណភាពរបស់ព្រះយេស៊ូ ( ក.អ.ប. )*

*( ** ) ចក្រភពតួគី ដែលបង្កើតឡើងដោយស៊ុលតង់ អូស្មាន់ទី ១ ។*



www.budinst.gov.kh www.elibraryofcambodia.org

*យេជ្ជ* ត្រូវខ្ទេចដោយមហារលកបែបនេះឯង ។

- ហើងជារឿងធម្មតាសំរាប់ជនជាតិជប៉ុនអ្វី ? រាល់ឆ្នាំតែអញ្ចឹង ?

- ចាស រាល់ឆ្នាំនៅលើទឹកដីព្រះជាម្ចាស់នេះយើងមានការរញ្ជួយផែនដី មានអគ្គីភ័យ មានទឹកជំនន់ និងមានមហារលកហើយក៏មានព្យុះកំបុតត្បូង គឺ *តៃហ្វុន* ផងដែរ ។ ធម្មជាតិតឹតឹងតែងនឹងជនជាតិយើងណាស់ - ភ្នែក *ម៉ារីកូ* ឡើងរលីងរលោង-ប្រហែលដោយហេតុនេះហើយទើបយើងស្រលាញ់ជីវិតយ៉ាងខ្លាំងក្លាបែបនេះ *អាន់ជីន-សាន* ។ លោកយល់ទេយើងត្រូវតែបែបនេះ ។ ការស្លាប់នៅលាយឡំនឹងខ្យល់ នឹងសមុទ្ទ នឹងទឹកដីនេះ ។ លោកគួរយល់ថា នៅលើទឹកដីនៃទឹកភ្នែកនេះ ការស្លាប់គឺជាកេរមរតករបស់យើងណា *អាន់ជីន-សាន* ។

* * *



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៣០

- អែងច្បាស់ថាអ្វីៗរៀបចំអស់ហើយរឺ *មូរ៉ា* ?

-បាទ *អូមី-សាន* ខ្ញុំគិតថារួចរាល់អស់ហើយទាន ។យើងខ្ញុំបានធ្វើតាមបញ្ជារបស់លោកម្ចាស់ និង លោកម្ចាស់ *អ៊ីកូរ៉ាជី* ទាំងស្រុងឥតមានខ្វះកន្លែងណាទេ ទាន ។

"យកល្អកុំអោយមានភ្លាំងភ្លាត់អ្វីទាំងអស់ បើមិនយ៉ាងដូចនេះទេ ពេលព្រលប់នេះភូមិនេះនឹងមានមេភូមិថ្មីមិនខាន" នេះគឺជាសំដីយ៉ាងចត់ដែល *អ៊ីកូរ៉ាជី* មេទ័ពរបស់ *យ៉ាប៊ូ* បានពោលទៅកាន់ *មូរ៉ា* ទាំងភ្នែកក្រហមតែតដោយភាពអត់ងងុយ ។ *អ៊ីកូរ៉ាជី* បានចេញដំណើរពី *យេដូ* ហើយបានមកដល់ទីនេះតាំងពីម្សិលមិញជាមួយកងសាមូរ៉ៃទីដំបូងរបស់គេដើម្បីបេសកកម្មមួយជាកំនត់ ។

*មូរ៉ា* ឥតមានឆ្លើយតបនឹងបញ្ហានេះឡើយ គេគ្រាន់តែងក់ក្បាលទទួលដោយភ្នែកអោនសំលឹងដីរហូត ។

ពួកគេឈរនៅលើច្រាំងក្បែរទំនប់រលក ទល់មុខអ្នកស្រុកដ៏កុះករ ទាំងក្មេង ទាំងចាស់ ទាំងប្រុស ទាំងស្រី លើកលែងតែអ្នកងើបពីគ្រែមិនរួចតែប៉ុននោះ ហើយដែលកំពុងលុតជង្គង់យ៉ាងស្ងៀមស្ងាត់ យ៉ាងខ្លបខ្លាច និងយ៉ាងហត់នឿយ ដើម្បីរង់ចាំការមកដល់នៃទូកធំ ។ ទាំងអស់គ្នាគ្រងទៅដោយ សំលៀកបំពាក់ដ៏ល្អប្រណីតរបស់ខ្លួន ។

" អ្វីៗប្រាកដជាប្រព្រឹត្តទៅយ៉ាងល្អជាមិនខាន *អ៊ីកូរ៉ាជី-សាន* " - *អូមី* និយាយ ។ ក្នុងអាទិត្យចុងក្រោយនេះ គេទទួលទានដំណេកបានតិចតួចណាស់ ពិសេសចាប់ពីទទួលបានបញ្ជារបស់ *យ៉ាប៊ូ* ដែលបានផ្ញើពី *អូសាកា* តាមរយៈព្រាបនាំសាររបស់ *តូរ៉ាណាកា* នោះមក ។គ្រាន់តែទទួលបញ្ជានេះភ្លាមកាលណា *អូមី* បានកែនអ្នកភូមិទាំងអស់ព្រមទាំងប្រុសៗពេញកំលាំងទាំងឡាយក្នុងរង្វង់ម្ភៃលីដើម្បីរៀបចំភូមិទទួលការមកដល់របស់ *យ៉ាប៊ូ* និងពួកសាមូរ៉ៃទាំងឡាយ ។ ហើយនៅពេលដែល *អ៊ីកូរ៉ាជី* បានលួចខ្សិបជាសំងាត់ប្រាប់តែគេម្នាក់ថាមហា *ដៃមីញ៉ូ* *តូរ៉ាណាកា* បានរួមដំណើរជាមួយពួរបស់គេ ហើយបានគេចផុតពីអន្ទាក់របស់ *អ៊ីស៊ីដូ* ទៀតនោះ គេរឹតតែសប្បាយចិត្តនឹងចំនាយប្រាក់រៀបចំការងារបដិសណ្ឋារកិច្ចនេះថែមទៀត ។" គ្មានបញ្ហាអ្វីដែលត្រូវព្រួយបារម្ភទេលោកម្ចាស់ *អ៊ីកូរ៉ាជី-សាន*។ ទីនេះគឺជាតំបន់របស់ខ្ញុំៗត្រូវទទួលខុសត្រូវ ទាន " ។



www.budinst.gov.kh www.elibraryofcambodia.org

" អញ្ចឹងហើយ ។ វាត្រូវតែអញ្ចឹង ។ អែងត្រូវទទួលខុសត្រូវអញ្ចឹងហើយ ។ មិនមែនខ្ញុំប្រមាថអែងទេណា ប៉ុន្តែអែងមិនឃើញលោកម្ចាស់ពេលណាដែលមានរឿងមិនត្រូវចិត្តនោះទេរឺអី ? បើសិនជាមានរឿងអ្វីៗកើតឡើង រឺបើសិនជាពួកអាប់បង់បាយទាំងនេះធ្វើមិនស្រួលវិញ នោះម៉ាយ៉ុរបស់អែងនេះនឹងក្លាយជាជីនៅស្ពែកល្ងាចនេះជាមិនខានឡើយ " ។

រួច *អ៊ីកូរ៉ាជី* បក់ដៃបណ្តេញ *អូមី* អោយចេញទៅទាំងធុញទ្រាន់ ។

នៅពេលព្រឹកនេះ កងសាមូរ៉ៃចុងក្រោយដែលបានបំផ្លាយសេះតាំងពី *មីស៊ីម៉ា* ដែលជាទីក្រុងភាគខាងជើងរបស់ *យ៉ាប៊ូ* នោះបានមកដល់រួចរាល់អស់ហើយដែរ ។ អីលូវនេះ ពួកនេះកំពុងរួមក្បួនទ័ពជាមួយពួកមុនៗ ត្រៀមនៅតាមមាត់ឆ្នេរ តាមទីថ្លា និង នៅតាមកូនភ្នំទាំងឡាយ ។ ទង់របស់ពួគេបក់រវិចៗទៅតាមជំនោរខ្យល់ ឯផ្លែលំពែងរបស់ពួកគេក៏ចាំងព្រាតៗក្រោមពន្លឺព្រះសុរិយាផងដែរ ។ នេះគឺជាទ័ពសាមូរ៉ៃដ៏អេីតទាំងបីពាន់នាក់នៃកងកំលាំងរបស់ *យ៉ាប៊ូ* បូកបន្ថែមដោយទ័ពសេះចំនួនប្រាំរយនាក់ថែមទៀតផង ។

ចំពោះ *អូមី* វិញគេគ្មានការភ័យខ្លាចណាបន្តិចសោះឡើយ ។ គេបានធ្វើសព្វបែបយ៉ាងនូវអ្វីដែលត្រូវធ្វើ ហើយបានពិនិត្យសព្វគ្រប់នូវអ្វីដែលត្រូវពិនិត្យ ។ បើនៅមានអ្វីខុសទៀតនោះគឺមកតែពី *កាម៉ា* តែប៉ុណ្ណោះ ។ តែគ្មានរឿងអ្វីដែលទាស់ទៀតនោះទេ ។ គេបានចំនាយប្រាំរយ *កូកូ* ដើម្បីរៀបចំបដិសណ្ឋារកិច្ចនេះ ពោលគឺជាចំនាយដែលលើសពីចំនូលប្រចាំឆ្នាំរបស់គេមុនពេលដែល *យ៉ាប៊ូ* ពង្រីកដែនត្រួតត្រាអោយគេទៅទៀត ។ គេក៏ភ្ញាក់ផ្អើលនឹងទំហំនៃការចំនាយនេះដែរ ប៉ុន្តែ *មីដូរី* ប្រពន្ធរបស់គេបានទូន្មានគេអោយដៃធំបន្តិចទៅចុះ ព្រោះថាចំនាយនេះវាតិចតួចណាស់បើប្រៀបទៅនឹងកិត្តិយសដែល *យ៉ាប៊ូ* បានផ្តល់ដល់គេនោះ ។ នាងនៅខ្សិបដាក់គេបន្ថែមទៀតថា :

-ម្យ៉ាងទៀត មានលោកម្ចាស់ *តូរ៉ាណាកា* មកជាមួយថែមទៀតផង អ្នកណាអាចទៅដឹងបានថា តើបងមានឱកាសធំធេងយ៉ាងណាទៅ ?

គិតទៅនាងយល់ត្រូវមែន ។ *អូមី* គិតនៅក្នុងចិត្ត ។

គេត្រួតពិនិត្យតាមបណ្តោយឆ្នេរ និងតាមទីថ្លាភូមិឡើងវិញ ។ អ្វីៗហាក់ល្អឥតខ្ចោះ ។



www.budinst.gov.kh www.elibraryofcambodia.org

*មីដូរ៉ា* និងម្តាយរបស់គេកំពុងឈររង់ចាំនៅក្រោមដំបូលក្រណាត់ដែលត្រូវបានរៀបចំឡើងដើម្បីទទួល *យ៉ាប៊ូ* និង *តូវ៉ាណាកា*។ គេតំរែតំរង់ពីម៉ូណូដ៏ស្អាតក្លឹងស្រាប់របស់គេម្តងទៀត រៀបចំដាវអោយបានត្រឹមត្រូវ ហើយសំលឹងមើលទៅឯលំហសមុទ្រ។

*មូរ៉ា* គិតរំពឹងយ៉ាងឡើយណាយនៅក្នុងចិត្តថា គេមិនបានភ្លេចចន្លោះប្រហោងណាមួយឡើយ។ ក្រសែភ្នែកគេរេសំលឹងទៅខាងកូនភ្នំ វាសមើលកំផែងរីស្សីដែលហ៊ុមព័ទ្ធបន្ទាយបណ្តោះអាសន្នមួយដែលគេបានធ្វើទាំងប្រញាប់ប្រញាល់និងយ៉ាងបង្ខំ។មនុស្សបីរយនាក់ត្រូវបានប្រើប្រាស់ដើម្បីជីក សាងសង់ និងដឹកជញ្ជូនវាំនេះ។ ឯការសាងសង់ផ្ទះថ្មីមួយទៀតវិញនោះ គឺពិតជាងាយស្រួលជាង។ នោះគឺជាផ្ទះដែលនៅលើដីទួលក្រោមផ្ទះ *អូមី* បន្តិច ហើយដែលខ្លួនគេអាចមើលឃើញបាន។ ពិតមែនតែផ្ទះថ្មីនេះតូចជាងផ្ទះរបស់ *អូមី* មែនក្តី តែជាផ្ទះប្រក់ក្បឿងមានសួនច្បារមួយក្រវិច ហើយមានផ្ទះមុជទឹកតូចមួយផង។ អញគិតថា *អូមី* នឹង រើទៅនៅផ្ទះថ្មីនេះហើយទុកផ្ទះវាជូនលោកម្ចាស់ *យ៉ាប៊ូ* វិញមិនខាន - *មូរ៉ា* គិតនៅក្នុងចិត្ត។

គេបែរក្បាលងាកទៅមើលឯជ្រោយខ្ពស់ដែលជាចំនុចទុកត្រូវចូល ។ បន្តិចទៀតនេះ *យ៉ាប៊ូ* នឹងឡើងគោកហើយពេលនោះវាសនាទាំងអស់គ្នាគឺស្ថិតក្នុងកណ្តាប់ដៃព្រះជាម្ចាស់ហើយ។ ឱព្រះជាម្ចាស់អើយ សូមព្រះអង្គជួយថែរក្សាភូមិ*អាន់ជីរ៉ូ* នេះផង យ៉ាងម៉េចយ៉ាងម៉ាជួយអោយរួចផុតប៉ុន្មានថ្ងៃនេះទៅចុះ ខ្ញុំនឹងអុជទៀនបាសិបថ្វាយព្រះអង្គ ហើយខ្ញុំនឹងប្រដៅប្រដៅកូនចៅអោយវាលុះដោយធមិជាមិនខាន - *មូរ៉ា* ប្រតិស្ឋាននៅក្នុងចិត្ត។

*មូរ៉ា* បានចូលសាសនាគ្រិស្តតាំងពីក្មេងម្ល៉េះ ដោយកាលនោះអម្ចាស់របស់គេបានចូលសាសនាគ្រិស្ត ហើយបានបញ្ជាអោយបរិវារទាំងអស់របស់លោកចូលសាសនានេះដែរ។ ចំនេរមកទៀតនៅពេលដែលអម្ចាស់របស់ *មូរ៉ា* បាត់បង់ជីវិតនៅក្នុងសង្គ្រាមតទល់ជាមួយ *វ៉ែកូ* ដើម្បីគាំទ្រ *តូវ៉ាណាកា* កាលពីម្ភៃឆ្នាំមុននោះ *មូរ៉ា* ក៏នៅតែកាន់សាសនានេះដដែលជាប់មកដើម្បីជាការបង្ហាញភក្តីភាពរបស់ខ្លួនចំពោះម្ចាស់ ។ ព្រោះចំពោះរូបគេ១យល់ឃើញថា ទាហានល្អមានម្ចាស់តែមួយគត់។ គឺម្ចាស់ដ៏ពិតប្រាកដ។

*នីនជីន* បុរសមុខមូល និងមានធ្មេញជំពើសជាអ្នកញាប់ញ័រជាងគេទាំងអស់នៅចំពោះ



www.budinst.gov.kh www.elibraryofcambodia.org

វត្តមានសាមូរ៉ៃ ដ៏សន្ទឹកសន្ទាប់បែបនេះ :

- *មូរ៉ា* សូមទោសណា តែអ្វីដែលអែងបានធ្វើនេះគឺគ្រោះថ្នាក់ណាស់។ គ្រោះថ្នាក់យកតែមែនទែនតែម្ដង។ អារឿងរញ្ជួយដីបន្តិចពីព្រឹកមិញនេះ ក៏ជាប្រផ្នូលមួយដែរ។ អែងធ្វើការភាន់ច្រលំមួយធ្ងន់ណាស់ *មូរ៉ា-សាន*។

- អ្វីដែលបានធ្វើរួចទៅហើយ គឺវារួចទៅហើយ *នីនជីន*។ បំភ្លេចវាចោលទៅ ។

- ខ្ញុំបំភ្លេចម៉េចបាន ? បើវានៅក្នុងឧម្មង្គខ្ញុំតែម្ដង ហើយ .........

- នៅក្នុងឧម្មង្គអែងតែបន្តិចបន្តួចតើ ឯឧម្មង្គខ្ញុំវិញពេញតែម្ដង -*អ៊ីយូ* អ្នកភូមិម្នាក់ទៀតឆ្លើយតប។

- អត់មាននៅទីណាទាំងអស់។ គ្មានអីទាំងអស់ -*មូរ៉ា* ឆ្លើយឡើងយ៉ាងប្រុងប្រយ័ត្ន។

ក្រោមបញ្ជារបស់ *មូរ៉ា* ពួកគេបានលួចស្រូវសាមសិប *កូគូ* ពីឃ្លាំងពួកសាមូរ៉ៃ ហើយបានយកមកចែកគ្នាលាក់យ៉ាងសំងាត់នៅក្នុងភូមិជាមួយនឹងសំភារៈផ្សេងៗ រួមទាំងអាវុធយុទ្ធភ័ណ្ឌផង។ កាលនោះ *អ៊ីយូ* ប្រកែកញ៉ាញ :

- មិនត្រូវការអាវុធទេ។ អង្ករយក តែមិនយកអាវុធទេ។

- សង្គ្រាមជិតមកដល់ហើយណា។

*នីនជីន* បន្ទរតាម :

- មានអាវុធគឺខុសច្បាប់ណា។

*មូរ៉ា* តំហាកឡើង :

-នោះគឺជាច្បាប់ថ្មីដែលទើបប្រកាសចេញកាលពីប្រហែលដប់ពីរឆ្នាំតែប៉ុណ្ណឹង។ពីមុននេះ ពួកយើងចង់មានអាវុធអ្វីស្រេចតែចិត្តយើងចង់ ហើយពួកយើងក៏មិនជាប់ជើងនៅនឹងភូមិដែរ។ យើងចង់ទៅណាតាមចំនង់ចិត្តយើង ចង់ធ្វើអ្វីស្រេចតែចិត្តយើងចង់ធ្វើ។ យើងចង់ធ្វើជាយុទ្ធ-កសិករក៏បាន ជាអ្នកនេសាទក៏បាន ជាឈ្មួញក៏បាន ហើយជាសាមូរ៉ៃក៏តែបាន ចំពោះអ្នកខ្លះទៀតអែងដឹងហើយទេតើរឿងណឹង។

- អញ្ចឹងហើយ តែអីលូវនេះវាផ្សេង *មូរ៉ា-សាន*។ អីលូវនេះវាផ្សេង។ *តែគូ* ចេញ



www.budinst.gov.kh www.elibraryofcambodia.org

បញ្ហាអោយធ្វើផ្សេង ណា ។

- បន្តិចទៀត អ្វីៗនឹងវិលត្រលប់ទៅដូចដើមអញ្ចឹង ។ ពួកយើងនឹងធ្វើទំពាំងវៃដែល ។

*នីទជីន* ប្រឹងបញ្ចុះបញ្ចូល :

- បើអញ្ចឹងរង់ចាំសិនទៅ ។ តែអីឡូវនេះ គឺរឿងខុសច្បាប់ណា ។ បើសិនជាច្បាប់ប្រែប្រួលមែននោះ គឺជា *កាម៉ា* ទេ ។ ពេលនេះគឺ *វ៉ៃតូ* បានចេញច្បាប់ហាមមិនអោយមានអាវុធ បើមានត្រូវប្រហារជីវិតភ្លាម ។

- ពួកឯងទាំងអស់គ្នាត្រូវបើកភ្នែកមើលផង ។ អីឡូវនេះ *វ៉ៃតូ* ស្លាប់បាត់ទៅហើយ! ហើយចាំអញប្រាប់ពួកឯង ។ បន្តិចទៀត *អូមី-សាន* នឹងត្រូវការមនុស្សដែលមានវិជ្ជាគុណ ហើយពួកយើងសុទ្ធតែធ្លាប់ធ្វើសង្គ្រាមស្រាប់ *ទេ* ? យើងធ្លាប់ទេសាទ យើងធ្លាប់ធ្វើសង្គ្រាមមិនចាំអញ្ចឹង ?

*អ៊ុយ៉ូ* យល់ស្របទាំងក្នុងអារម្មណ៍ភ័យខ្លាច :

- ពិតមែនហើយ *មូរ៉ា-សាន* កាលពីសម័យមុន *វ៉ៃតូ* ពួកយើងមិននៅចងជើងបែបនេះឡើយ ។

*នីទជីន* និយាយទាំងពេបស្បែប :

- ពួកវានឹងចាប់យើងបានជាមិនខាន ។ ពួកវាពិតជាចាប់យើងបាន ។ ពួកវាគ្មានមេត្តាធម៌ជាក់តូចណាឡើយនៅក្នុងចិត្ត ។ ពួកវាច្បាស់ជាស្អោរពួកយើងទាំងរស់ ដូចពួកវាស្អោរពួកចុងស្រុកអញ្ចឹង ។

- ឈប់និយាយពីរឿងពួកចុងស្រុកទៅ ។

- ស្តាប់ខ្ញុំសិន សំលាញ់ *-មូរ៉ា* ពោលឡើង -យើងកំរមានសំណាងរបៀបនេះណាស់ ។ នេះជាសំនាងព្រះលោកប្រទានអោយហើយ ។ ទាំងកាំបិត ព្រួញ លំពែង ដាវ មូស្កេ ខែល ធ្នូ យើងត្រូវយកទាំងអស់អោយតែយើងយកបាន ។ ពួកសាមូរ៉ៃនឹងគិតថា ពួកសាមូរ៉ៃគ្នាវានោះហើយជាអ្នកលួចរបស់ទាំងនោះ ។ យើងត្រូវដណ្តើមយកសិទ្ធិធ្វើសង្គ្រាមរបស់ពួកយើងមកវិញ *ទេ* ? ឪពុកខ្ញុំបានបាត់បង់ជីវិតនៅក្នុងការប្រយុទ្ធ ។ ឪពុកឯងក៏អញ្ចឹង ឪពុកឯងខាងនេះក៏អញ្ចឹង ។



www.budinst.gov.kh www.elibraryofcambodia.org

*នីនជីន* អែងធ្លាប់ចូលប្រលូកក្នុងសង្គ្រាមប៉ុន្មានដងហើយ ជាងប៉ុន្មានដណ្ដប់ដងដែរមែនទេ ? រួចអែងវិញ *អ៊ូយ៉ូ* ? ម្ដេដង ? សាមសិបដង ?

ពេលនេះ *មូវ៉ា* មានជំនឿជាក់នៅក្នុងខ្លួនថាអ្វីដែលខ្លួនធ្វើនេះពិតជាត្រឹមត្រូវ ហើយសង្គ្រាមថ្មីនេះពិតជាបន្តទៅជារៀងរហូត ។

" មើលនុះ " *អ៊ូយ៉ូ* និយាយដោយព្រមទាំងលើកដៃចង្អុលជាសភាវគតិ ។

ទូកធំកំពុងបត់ក្បាលកាត់តាមជ្រោយខ្ពស់តំរង់ចូលមកហើយ ។

**************

*ភូជីកូ* លុតជង្គង់កំប្រោន១នៅពីមុខ *តូរ៉ាណាកា* ក្នុងបន្ទប់ធំដែលលោកបានប្រើសំរាប់ស្នាក់នៅក្នុងពេលធ្វើដំណើរ ។ គ្មានអ្នកណាផ្សេងនៅក្នុងបន្ទប់នេះ ក្រៅពីអ្នកទាំងពីរឡើយ ។

*ភូជីកូ* និយាយអង្វរ *តូរ៉ាណាកា* :

- សូមលោកម្ចាស់ មេត្តាលុបការដាក់ទោសបែបនេះមកលើរូបនាងខ្ញុំម្ចាស់ផង ចាស ។

- នេះមិនមែនជាការដាក់ទោសទេ តែជាបញ្ជា ។

- ចាស នាងខ្ញុំត្រូវតែគោរពតាមហើយ ប៉ុន្តែ នាងខ្ញុំមិនអាច........

- មិនអាច ? -*តូរ៉ាណាកា* ចាប់ផ្ដើមឆេះដុំ -ម៉េចនាងហ៊ានប្រកែកបែបណឹង ? យើងប្រាប់នាងអោយធ្វើជាស្រីកំនាន់របស់នាយតៃកុងហើយ នាងបែរជាព្រហើនហ៊ានតវ៉ាជាមួយយើងផង ?

-អោយនាងខ្ញុំសូមអភ័យទោសដោយអស់ពីពោះពីពុងផង លោកម្ចាស់ ។ មិនមែននាងខ្ញុំប្រកែកតវ៉ានោះទេ ។ នាងខ្ញុំគ្រាន់តែចង់ជំរាបប្រសាសន៍លោកម្ចាស់ថា នាងខ្ញុំមិនអាចធ្វើតាមរបៀបដែលលោកម្ចាស់ប្រាប់នោះបានទេតែប៉ុននោះ ។ សូមលោកម្ចាស់យល់អធ្យាស្រ័យនាងខ្ញុំផង ។សូមលោកម្ចាស់ប្រណីទោសដល់នាងខ្ញុំផង ប៉ុន្តែនាងខ្ញុំមិនអាចមានសុភមង្គលបានទេ



www.budinst.gov.kh www.elibraryofcambodia.org

ហើយក៏រិតតែមិនអាចធ្វើជាមានសុភមង្គលបានដែរ -*ភូជីកូ* អោនក្បាលដល់ម៉ក់ -នាងខ្ញុំសូមលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំបានធ្វើ *សិបពុគូ* ទៅចុះ ចាស ។

- ខ្ញុំបាននិយាយហើយថា ខ្ញុំមិនអនុញ្ញាតអោយមានការស្លាប់ដោយអត់ន័យនោះទេ ។ ខ្ញុំមានការងារផ្សេងអោយនាងធ្វើ ។

- សូមលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំបានស្លាប់ទៅចុះ ។ នាងខ្ញុំសូមអង្វរលោកម្ចាស់ សូមលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំបានស្លាប់ទៅតាមប្តី និងកូននាងខ្ញុំផងចុះ ។

សំលេងគំហករបស់ *តូរ៉ាណាកា* លុបបាត់អស់សំលេងរបស់ទូកធំ :

- ខ្ញុំបានជំទាស់ផ្តល់កិត្តិយសនេះដល់នាងរួចហើយ ។ នាងមិនសក្តិសមទទួលបាននូវកិត្តិយសនេះទេ ។ នេះដោយសារខ្ញុំយោគយល់ដល់ជីតានាង គឺលោកម្ចាស់ *ហ៊ិរ៉ូ-ម៉ាត់ស៊ី* ដែលជាមិត្តចាស់របស់ខ្ញុំ ហើយ ដែលខ្ញុំទ្រាំស្តាប់យ៉ាងអត់ធ្មត់នូវសំដីប៉ិប៉ាច់ប៉ិប៉ោចរបស់នាងនោះ ។ ឈប់ធ្វើរឹកមើលតែមនុស្សសំវែរមិនដឹងខ្យល់អីបែបណឹងទៅ ។

- បើអញ្ចឹងសូមលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំកោរសក់បួសជាដូនជីទៅ ។ ព្រោះលោកនឹង.........

- ទេ ។ ខ្ញុំបានចេញបញ្ជាហើយ នាងត្រូវគោរពធ្វើតាមណឹង ។

- គោរព ?

*ភូជីកូ* នៅតែរក្សាមុខដ៏ត្រជាក់ស្រិប និងដ៏រឹងមាំរបស់ខ្លួនអោយទៅអោនដដែល ។ នាងនិយាយតិច១ហាក់ដូចពោលសំរាប់ខ្លួនឯង :

- នាងខ្ញុំនឹកស្មានថា នាងខ្ញុំត្រូវទទួលបញ្ជាអោយទៅ *រយដូ* ទេតើ ។

- ខ្ញុំបានបញ្ជាអោយនាងមកតាមទូកធំនេះ ! នាងភ្លេចពីឋានៈនាទីខ្លួន នាងភ្លេចពីវង្សត្រកូលខ្លួន នាងភ្លេចពីកាតព្វកិច្ចខ្លួន ខ្ញុំស្អប់អែងណាស់ ។ ចេញពីមុខពីមាត់យើងហើយត្រៀមខ្លួនអោយហើយទៅ ។

- ខ្ញុំសូមលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំបានស្លាប់ទៅតាមពួកគេផង លោកម្ចាស់ ។

- ប្តីនាងអែងច្រលំកើតមកជាសាមូរ៉ៃតែប៉ុននោះ ។ វាកើតមកមិនគ្រប់លក្ខណៈ កូនវា



www.budinst.gov.kh www.elibraryofcambodia.org

កំច្បាស់ជាមិនគ្រប់លក្ខណៈដូចគ្នាណឹង។ អាចំកូតណឹងវិះធ្វើអោយខ្ញុំវលាយតែម្តង។ អញ្ចឹង ហើយនាងអែងចង់ស្លាប់តាមវាទៀត។ ផ្តេសផ្តាស់មែនទែនតែម្តង។ យើងហាមមិនអោយនាង ធ្វើ *សិបព្វូ* ទេ។ អីលូវនេះចេញទៅ !

*ភូជីភូ* នៅស្ងៀមឥតកំរើកដដែល។

- មើលទៅ ខ្ញុំគួរតែបញ្ជូននាងអែងទៅអោយអាពួក *អេតា* វិញទើបត្រូវ។ ទាល់តែ អញ្ចឹងទើបនាងអែងយល់ពីកាតព្វកិច្ចខ្លួន និងយល់ថាខ្លួនត្រូវមានអាកប្បកិរិយាយ៉ាងណានោះ។

*ភូជីភូ* បង្ហាញអាការៈរុញរាមួយភ្លែត រួចនាងតបវិញយ៉ាងមានៈ :

- យ៉ាងហោចណាស់កំពួកនោះជាជនជាតិជប៉ុនដែរ។

- ***យើងជាអម្ចាស់របស់អែងណា ! ខាង ត្រូវ ធ្វើ តាម បញ្ជា របស់ យើង !***

*ភូជីភូ* អេះអុញ រួចនាងញាក់ស្មា :

- ចាស លោកម្ចាស់។ នាងខ្ញុំសូមទោសចំពោះអាការៈមិនសមរម្យរបស់នាងខ្ញុំ។

នាងដាក់ដៃទាំងពីរទ្រោបលើម៉ក់ ហើយលំអោនក្បាលយ៉ាងទាប។ សំលេងនាងសំ ដែងនូវការសោកស្តាយ ប៉ុន្តែនៅក្នុងជំរៅនៃដួងចិត្តរបស់នាង។ឥតមានសារភាពសោះឡើយ ហើយទាំង *តូរ៉ាណាកា* ទាំងរូបនាងសុទ្ធតែដឹងយ៉ាងច្បាស់ណាស់ថា តើនាងមានបំនងចង់ធ្វើអ្វី នោះ :

- នាងខ្ញុំសូមលោកម្ចាស់អភ័យទោសដល់នាងខ្ញុំដែលបានរំខានលោកម្ចាស់ ដែលបាន បំផ្លាញ *វ៉ា* របស់លោកម្ចាស់ ភាពសុខដុមរមនារបស់លោកម្ចាស់ ហើយនឹងសូមអភ័យទោសចំ ពោះអាកប្បកិរិយាមិនសមរម្យរបស់នាងខ្ញុំនេះ ។ លោកម្ចាស់ពិតជាយល់ត្រឹមត្រូវមែនគឺនាងខ្ញុំ ទេ ដែលយល់ខុសនោះ។

រួចនាងងើបឡើង ហើយដើរយ៉ាងស្ងៀមស្ងាត់សំដៅទ្វារ ។ *តូរ៉ាណាកា* បន្លឺសំលេង ឡើង :

- បើសិនជាខ្ញុំ ព្រមអោយអ្វីដែលនាងចង់បានមែននោះ តើនាងព្រមធ្វើតាមបំនងខ្ញុំ ដោយស្មោះពីពោះពីពុងទេ ?



www.budinst.gov.kh www.elibraryofcambodia.org

*ភូជីក្វ* ងាកសំលឹងបកក្រោយយឺតៗ :

- សំរាប់ប៉ុន្មានពេល លោកម្ចាស់ ? នាងខ្ញុំចង់ដឹងថាតើលោកម្ចាស់អោយនាងខ្ញុំទៅធ្វើកំនាន់មនុស្សចុងស្រុកនេះ ប៉ុន្មានពេលទៅលោកម្ចាស់ ?

- មួយឆ្នាំ ។

*ភូជីក្វ* បែរខ្លួនហើយលោងដៃប្រុងបើកទ្វារចេញទៅក្រៅ ។ *តូរ៉ាណាកា* និយាយ :

- កន្លះឆ្នាំ ។

ដៃ *ភូជីក្វ* នៅទ្រឹង ខ្លួនប្រាណនាងឡើងញ័រចំប្រប់ នាងផ្ដេកក្បាលនាងទៅនឹងសន្លឹកទ្វារ :

- ចាស សូមអរគុណលោកម្ចាស់ ។ សូមអរគុណជាអនេកកប្បការចំពោះលោកម្ចាស់ ។

*តូរ៉ាណាកា* ងើបឡើងហើយដើរសំដៅទៅរកទ្វារ ។ *ភូជីក្វ* អោនក្បាលគោរពហើយបើកទ្វារចំហជូន *តូរ៉ាណាកា* ចេញ ។

រួចរាល់ហើយនាងទាញទ្វារបិទមកវិញ ។ ដល់ពេលនោះទើបនាងបណ្ដោយអោយទឹកភ្នែកនាងស្រក់ធ្លាក់ចុះយ៉ាងស្ងៀមស្ងាត់ ។ នាងគឺជាសាមូរ៉ៃម្នាក់ ។

*************

*តូរ៉ាណាកា* ចេញមកឈរនៅផ្នែកខាងក្រៅលើទូកធំប្រកបដោយការរីករាយសោមនស្សនៅក្នុងចិត្ត ។ លោកបានសំរេចនូវអ្វីដែលលោកចង់បានដោយចំនាយការលំបាកយ៉ាងតិចតែប៉ុណ្ណោះ ។ បើសិនជាលោកនៅតែបង្ខំ *ភូជីក្វ* ខ្លាំងជាងនេះទៅទៀតនោះ នាងអាចប្រកែកមិនធ្វើតាមលោក ហើយនាងអាចនឹងធ្វើអត្តឃាតដោយមិនសុំការអនុញ្ញាតអំពីលោក ។ តែពេលនេះនាងនឹងខិតខំបំពេញបំនងរបស់លោក ហើយជាការមួយសំខាន់ណាស់ដែលនាងព្រមធ្វើជាកំនាន់របស់នាយតៃកុងដោយចិត្តរីករាយ រឺ យ៉ាងហោចណាស់ដោយបង្ហាញអាការៈរីករាយនៅខាង



www.budinst.gov.kh www.elibraryofcambodia.org

ក្រៅ ។ ហើយប្រាំមួយខែពិតជាថេរវេលាមួយគ្រប់គ្រាន់ណាស់ទៅហើយ ។ គិតទៅស្រី១ស្រួលចរចាគ្នាជាងប្រុស១មែន -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត ។

រួចលោកក៏ចោលភ្នែកក្រលេកឃើញពួកសាមូរ៉ៃរបស់ *យ៉ាប៊ូ* ដែលនៅកកកុញឯលើឆ្នេរ ។ ចិត្តសប្បាយរីករាយរបស់លោកក៏រលាយបាត់ឈឹងទៅដែរ ។

*យ៉ាប៊ូ* ពោលទៅកាន់ *តូរ៉ាណាកា* :

- សូមស្វាគមន៍លោកម្ចាស់ ដែលបានអញ្ជើញមកដល់ *អ៊ីស៊ូ* ។ ខ្ញុំបាទបានបញ្ជាអោយនាំកូនចៅមួយចំនួនមកកាន់ទីនេះ ដើម្បីជាកងដង្ហែរការពារលោកម្ចាស់ ទាន ។

- ល្អ ។

ទូកចំសំដៅចូលច្រាំងដែលនៅប្រហែលជិតពីររយម៉ែតទៀតនោះក្នុងល្បឿនដ៏លឿន ។ ពួកគេអាចមើលឃើញ *អូមី* និង *អ៊ីកូរ៉ាជី* ព្រមទាំងដំបូលសំពត់សំរាប់រៀបចំបដិសណ្ឋារកិច្ចនោះយ៉ាងច្បាស់ ។ *យ៉ាប៊ូ* ពោលបន្ថែម :

- អ្វី១ត្រូវបានរៀបចំដូចកាលយើងបានពិភាក្សាគ្នានៅឯ *អូសាកា* អញ្ចឹង ។ ប៉ុន្តែហេតុអ្វីបានជាលោកម្ចាស់មិននៅជាមួយខ្ញុំបាទ ប៉ុន្មានថ្ងៃសិនទៅ ទាន ? ខ្ញុំបាទពិតជាមានកិត្តិយសណាស់ហើយ ម្យ៉ាងទៀតខ្ញុំបាទយល់ថាក៏មានសារសំខាន់ណាស់ដែរ ។ ពេលកម្ចាស់អាចផ្តល់ការឯកភាពរបស់លោកម្ចាស់ក្នុងការជ្រើសរើសមនុស្សទាំងពីររយហាសិបនាក់ សំរាប់ជាកងមួស្តេ ហើយនឹងជួបមេបញ្ជាការពួកវាតែម្តង ។

- គ្មានអ្វីធ្វើអោយខ្ញុំសប្បាយជាងនេះទៀតទេ ប៉ុន្តែខ្ញុំត្រូវទៅអោយដល់ *យេដូ* កាន់តែឆាប់កាលណាល្អកាលនោះ *យ៉ាប៊ូ-សាន* ។

- មួយថ្ងៃ រឺ ពីរថ្ងៃទៅអ្វី លោកម្ចាស់ ? ទំនេរខួរក្បាលម៉ាថ្ងៃ ពីរ អាចជួយបន្ធូរអារម្មណ៍លោកម្ចាស់ខ្លះដែរ *ទេ* ? សុខភាពលោកម្ចាស់សំខាន់ណាស់ចំពោះរូបខ្ញុំ និងចំពោះសព័ន្ធមិត្តរបស់លោកម្ចាស់ទាំងអស់ ។ សំរាក ទទួលទានអោយបានឆ្អាញ់ រឺ ដើរបរបាញ់សិនទៅ ។

*តូរ៉ាណាកា* ប្រឹងគិតរកមធ្យោបាយដោះទាំងអស់សង្ឃឹម ។ ស្លាក់នៅទីនេះដោយមានអង្គរ័ក្សតែហាសិបនាក់គឺពិតជាលេលាតែម្តង ព្រោះលោកនឹងនៅក្នុងកណ្តាប់ដៃ *យ៉ាប៊ូ* ទាំង



www.budinst.gov.kh www.elibraryofcambodia.org

ស្រុង ហើយនេះគឺជាស្ថានភាពមួយដ៏អាក្រក់ជាងស្ថានភាពនៅ *អូសាកា* ទៅទៀត ។ ចំពោះ *អ៊ីស៊ីដូ* យ៉ាងហោចណាស់ ក៏ជាមនុស្សអាចកាត់ស្មានយល់បានខ្លះ ហើយក៏ជាមនុស្សគោរពច្បាប់ទំលាប់ខ្លះដែរ ឯ *យ៉ាប៊ូ* វិញគឺមានល្បិចក្រលិចក្រលុចជាងឆ្មាមទៅទៀត ។ ហើយគេមិនត្រូវជន្លលលេងជាមួយឆ្មាមឡើយ ពិសេសទៅទៀតនៅក្នុងរង្វង់ដែនទឹករបស់វាហើយដោយយកជីវិតខ្លួនឯងទៅលនោះទេ ។ លោកដឹងយ៉ាងច្បាស់ណាស់ថា ពាក្យសន្យានៅឯ *អូសាកា* ជាមួយ *យ៉ាប៊ូ* នោះមានទំងន់ត្រឹមតែទឹកម៉ូត ដែលគេទាំងពីរនាក់បង្ហូរទៅលើដីតែប៉ុននោះនៅពេលណាដែល *យ៉ាប៊ូ* យល់ថាគេអាចទទួលសម្បទានច្រើនជាងពី *អ៊ីស៊ីដូ* នោះ ។ ហើយប្រការដែល *យ៉ាប៊ូ* ប្រគល់ក្បាលលោកនៅលើថាសអោយទៅ *អ៊ីស៊ីដូ* ពិតជាផ្តល់ផលដល់ *យ៉ាប៊ូ* ច្រើនជាងអ្វីដែលលោកប្រុងប្រៀបអោយទៅមនុស្សនេះទៅទៀត ។

តើសំលាប់ *យ៉ាប៊ូ* នៅទីនេះ រឺក៏ឡើងច្រាំង ? នេះជាជំរើសដែលលោកត្រូវជ្រើសរើស ។

*តូរ៉ាណាកា* តបសំដី :

- លោកពិតជាចិត្តល្អមែន ។ ប៉ុន្តែខ្ញុំត្រូវប្រញាប់វិលទៅ *យេដូ* វិញជាបន្ទាន់ -អញមិននឹកស្មានថា *យ៉ាប៊ូ* មានពេលវេលាដើម្បីប្រមូលមនុស្សមកទីនេះបានច្រើនកុះករយ៉ាងនេះសោះ វាអាចបំបែកពាក្យសំងាត់របស់ពួកយើងបានទេដឹង ( *តូរ៉ាណាកា* គិតនៅក្នុងចិត្ត ) ។

- សូមលោកម្ចាស់អនុញ្ញាតអោយខ្ញុំលើកសំនើម្តងទៀតទៅចុះ *តូរ៉ាណាកា-សាម៉ា*។ នៅជិតៗនេះអាចមានកន្លែងបរបាញ់ ល្អណាស់ ខ្ញុំក៏បានយកពួកប្រមាញ់ស្ទាំងមកជាមួយដែរ ។ បន្ទាប់ពីជាប់នៅ *អូសាកា* បែបនេះហើយ បានដើរបរបាញ់ខ្លះៗពិតជាជួយបន្ធូរអារម្មណ៍ខ្លះជាមិនខាន *ទេ* ?

- ពិតហើយ ថ្ងៃនេះបានដើរបរបាញ់ ពិតជារីករាយមែន ។ ស្តាយណាស់ដែលខ្ញុំត្រូវចោលស្ទាំងខ្ញុំនៅ *អូសាកា* នោះ ។

- ស្ទាំងទាំងនោះពិតជាមិនបាត់ទេ ។ *ហ៊ីរ៉ូ-ម៉ាត់ស៊ុ* ពិតជានឹងយកវាទៅ *យេដូ* ជាមិនខាន មែនទេ ?

- ខ្ញុំបានបញ្ជាថានៅពេលណាដែលពួកយើងបានចេញផុតពីគ្រោះថ្នាក់ហើយ ត្រូវលែង



www.budinst.gov.kh www.elibraryofcambodia.org

វាទាំងអស់ទៅ ព្រោះថាទំរាំវាទៅដល់ *យេដូ* នោះ វាបាត់ការរីកហាត់អស់ហើយ ។ នេះគឺជាទំលាប់មួយក្នុងចំនោមប៉ុន្មានទំលាប់របស់ខ្ញុំ គឺខ្ញុំប្រើតែស្ទាំងដែលខ្ញុំបង្វឹកដោយផ្ទាល់ដៃតែប៉ុននោះ ហើយក៏មិនអោយវាមានម្ចាស់ផ្សេងទៀតដែរ ។ ធ្វើបែបនេះ វាមិនធ្វើអ្វីខុសក្រៅតែពីតាមការរកាន់ច្រលំរបស់ខ្ញុំតែប៉ុននោះ ។

- នេះគឺពិតជាទំលាប់ល្អមួយ ។ ខ្ញុំចង់ស្តាប់លឺពីទំលាប់ផ្សេង១ទៀតរបស់លោកម្ចាស់ណាស់ តើលោកម្ចាស់អាចនិយាយប្រាប់ខ្ញុំបានទៀតទេ នៅពេលបាយល្ងាចនេះ ?

អញ្ចៀវត្រូវការអាសត្តផ្លូវនេះ -*តូរ៉ាណាកា* គិតទាំងជូរចត់នៅក្នុងចិត្ត ។ សំលាប់វានៅពេលនេះគឺប្រញាប់ប្រញាល់ពេកហើយ ។

ខ្សែពួរត្រូវបានបោះពីលើទូកទៅអោយអ្នកនៅឯច្រាំងចាប់ ហើយទូកធំក៏បានអែបចូលច្រាំងយ៉ាងប៉ិនប្រសប់ ។ ច្រវាត្រូវបានលើកឡើង ហើយក្តារជណ្តើរក៏ត្រូវបានដាក់ចុះ បន្ទាប់មកទើប *យ៉ាប៊ូ* ចេញទៅឈរនៅមាត់ជណ្តើរតែម្តង ។

រំពេចនោះភ្លាម រួងពួកសាមូរ៉ៃបានបន្លឺសំរែកយុទ្ធជ័យរបស់ខ្លួនព្រម១គ្នាឡើងថា " *កាស៊ុគី ! កាស៊ុគី !* " ។

សំលេងរបស់ពួកគេឡើងខ្លរធ្វើអោយរួងរំពេទាំងឡាយផ្អើលខ្សៀវខ្វាហើរឡើងពេញផ្ទៃមេឃ ។ បន្ទាប់មកពួកគេក៏លំអោនក្បាលគោរពក្នុងកាយវិការស្របគ្នាដូចមនុស្សតែម្នាក់ ។

*យ៉ាប៊ូ* លំអោនក្បាលគោរពតបវិញ រួចហើយទើបងាកទៅរក *តូរ៉ាណាកា* ដោយកាយវិការអញ្ជើញយ៉ាងទូលាយបែបម្ចាស់ផ្ទះ :

- សូមអញ្ជើញឡើងច្រាំង ទាន ។

*តូរ៉ាណាកា* សំលឹងមើលទៅក្រុមពួកសាមូរ៉ៃដ៏កុះករ មើលអ្នកភូមិដែលនៅក្រាបស្រប៉ាបលើដី ហើយដណ្តឹងសួរខ្លួនឯងថា ពិតជាកន្លែងនេះរឺដែលហោរទាយថាអញត្រូវស្លាប់នោះ ? ផ្នែកទីមួយនៃទំនាយបានឃើញច្បាស់ហើយ គឺឈ្មោះអញត្រូវបានឆ្លាក់នៅលើជញ្ជាំងកំពែង *អូសាកា* មែន ។

តែលោកសំរេចដាក់កង្វល់នេះទៅម្ខាងសិន ។ លោកស្រែកបញ្ជាយ៉ាងលឺ១និងយ៉ាងម៉ាត់១



www.budinst.gov.kh www.elibraryofcambodia.org

ទៅពួកអង្គរក្សទាំងហាសិបនាក់ ហើយដែលគ្រងឯកសណ្ឋានតីម៉ូហ្វប្រផេះដូចលោកដែរថា :

- ពួកឯងទាំងអស់គ្នា នៅលើទូកនេះហើយ ! លោកមេបញ្ជាការទូក ត្រូវត្រៀមលក្ខណៈប្រុងប្រៀបចេញដំណើរអោយហើយស្រេចគ្រប់ពេល ! *ម៉ារីកូ-សាន* នាងត្រូវនៅ *អាន់ជីរ៉ូ* បីថ្ងៃ។ នាំតែកុង និង *ភូជីកូ-សាន* ចុះទៅចាំខ្ញុំនៅឯផ្លាភូមិមុនទៅ។

នៅក្រោមភាពភ្ញាក់ផ្អើលរបស់ *យ៉ាប៊ូ* *តូរ៉ាណាកា* បែរងាកទៅរកច្រាំងហើយបំពងសំលេងបន្ថែម :

- អីលូវនេះ *យ៉ាប៊ូ-សាន* ខ្ញុំនឹងចុះទៅត្រួតពិនិត្យទ័ពរបស់លោកហើយ។

និយាយចប់ភ្លាម លោកដើរកាត់មុខ *យ៉ាប៊ូ* តំរង់ទៅកាន់ជណ្តើរចុះប្រកបដោយភាពទំនុកចិត្តជាមេទ័ពជើងចាស់មួយ។ ជាការពិតណាស់ គ្មានមេទ័ពណាឈ្នះសង្គ្រាមច្រើនជាងគេ មានល្បិចកលច្រើនជាងគេដូច *តែកូ* ឡើយ។ តែពេលនេះ *តែកូ* ស្លាប់បាត់ទៅហើយ។ អីលូវនេះគ្មាននរណាក្រៅពី *តូរ៉ាណាកា* ទេដែលធ្លាប់ធ្វើសង្គ្រាមច្រើនជាងគេ មានអំនត់ជាងគេ ហើយដែលបាត់បង់ទ័ពតិចជាងគេ ពិសេសទៅទៀត លោកមិនដែលចាញ់សង្គ្រាមសោះឡើយ។

ភាពភ្ញាក់ផ្អើល បានលេចឡើងនៅលើច្រាំងភ្លាម នៅពេលដែលមានមនុស្សស្គាល់លោក។ ការត្រួតទ័ពនេះឥតមាននៅក្នុងគំរោងកម្មវិធីឡើយ។ ឈ្មោះលោកត្រូវបានគេខ្សឹបបន្តគ្នាពីមាត់មួយទៅមាត់មួយ ហើយសំលេងខ្សឹបខ្សាវនៃការខ្សិបក៏ដូចជាការគោរពភ័យខ្លាចដោយវត្តមានលោកនេះ ធ្វើអោយ *តូរ៉ាណាកា* រីកថ្លើមប្រមាត់ជាខ្លាំង។ លោកមានអារម្មណ៍ថា *យ៉ាប៊ូ* កំពុងដើរតាមពីក្រោយលោក ប៉ុន្តែលោកឥតងាកក្រោយទេ។ លោកបន្លឺសំលេងប្រកបដោយភាពរីករាយមួយដែលបេះដូងលោកមិនបានលោតតាមផងទេ :

- អា្ហ *អ៊ីកូរ៉ាជី-សាន* ! រីករាយណាស់ដែលបានជួបលោក។ មក យើងដើរត្រួតពលជាមួយគ្នាតែម្តងទៅ។

- បាទ លោកម្ចាស់។

- ចំនែកអែងនេះ ប្រហែលជា *កាស៊ីគី អូមី-សាន* ហើយមែនទេ ? ឪពុកអែងជាមិត្តរួមអាវុធជើងចាស់ម្នាក់ជាមួយខ្ញុំដែរ។ មក យើងដើរត្រួតពលទាំងអស់គ្នាតែម្តងទៅ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* តបទាំងទ្រូងប៉ោងឡើងដោយកិត្តិយសដែល *តូរ៉ាណាកា* បានផ្តល់អោយ :

- បាទ លោកម្ចាស់ ។ សូមអរគុណលោកម្ចាស់ ទាន ។

*តូរ៉ាណាកា* ដើរក្នុងជំហានមួយដ៏លឿន ។ លោកហៅមនុស្សទាំងនេះអោយដើរជាមួយលោកប្រយោជន៍ខាឃាំងពួកនេះមិនអោយនិយាយស្ងាត់ៗជាមួយ *យ៉ាប៊ូ* បាន ហើយលោកដឹងច្បាស់ថា នៅក្នុងពេលនេះជីវិតរបស់លោកស្ថិតនៅលើប្រការដែលលោកផ្តើមគំនិតមុនរហូតនេះឯង ។

- លោកមានបានចូលរួមប្រយុទ្ធនៅឯ *អូដាវ៉ារ៉ា* ទេ *អ៊ីកូរ៉ាជី-សាន* ?

តាមពិត *តូរ៉ាណាកា* គ្រាន់តែសួរជាសំនួរតែប៉ុណ្ណោះ ព្រោះលោកដឹងច្បាស់ណាស់ថា គឺនៅទីនោះហើយដែល *អ៊ីកូរ៉ាជី* បានបាត់បង់ភ្នែកម្ខាងរបស់គេនោះ ។

- បាទ លោកម្ចាស់ ។ ខ្ញុំបាទមានកិត្តិយសធ្វើសង្គ្រាមនៅទីនោះដែរ ទាន ។ កាលនោះខ្ញុំបាទនៅជាមួយលោកម្ចាស់ *យ៉ាប៊ូ* ហើយរ៉ាប់ទទួលស្លាបស្តាំរបស់កងទ័ពលោកម្ចាស់ *វ៉ាកូ*។

- ស្លាបស្តាំជាផ្នែកតានតឹងបំផុត បានន័យថាលោកបានកាន់កន្លែងកិត្តិយសតែម្តង ។ ខ្ញុំត្រូវតែអរគុណលោក និង អម្ចាស់លោកក្នុងការជួយជ្រោមជ្រែងនេះ ។

- យើងបានកំទេចសត្រូវជាមួយគ្នា លោកម្ចាស់ ។ ពួកយើងខ្ញុំគ្រាន់តែបំពេញកាតព្វកិច្ចរបស់ខ្លួនតែប៉ុណ្ណោះ ។

ថ្វីត្បិតតែ *អ៊ីកូរ៉ាជី* ស្អប់ *តូរ៉ាណាកា* យ៉ាងណាក្តី ក៏ប្រការដែល *តូរ៉ាណាកា* រំលឹកពីស្នាដៃរបស់គេ និងអរគុណរូបគេនេះ បានធ្វើអោយគេមានមោទនភាពជាពន់ពេកដែរ ។

*តូរ៉ាណាកា* និយាយកាន់តែលឺជាងមុនទៅទៀតនៅពេលដែលទាំងអស់គ្នាបានមកដល់មុខជួរកងទីមួយ :

- ពិតណាស់ លោកព្រមទាំងកូនចៅអ្នក *អ៊ីស៊ូ* របស់លោកបានជួយពួកយើងច្រើនសំបើមមែនទែន ។ មើលទៅ កាលនោះបើសិនជាគ្មានពួកលោក ប្រហែលជាខ្ញុំវ៉ៃយក *ក្វាន់តូ* មិនបានទេ ។ មិនអញ្ចឹងមែនទេ *យ៉ាប៊ូ-សាម៉ា* ?

*តូរ៉ាណាកា* ឈប់ម៉ង់នៅពេលដែលលោកបន្ថែមសំនួរចុងក្រោយនេះ ដោយផ្តល់បន្ថែម



www.budinst.gov.kh www.elibraryofcambodia.org

ជាសាធារណៈនូវកិត្តិយសមួយក្រឹតទៀតដល់ *យ៉ាប៊ូ*។

ជាថ្មីម្តងទៀត*យ៉ាប៊ូ* ត្រូវបាត់ម្ចាស់ការទាំងស្រុងនៅចំពោះមុខការបញ្ចើចបញ្ចើរនេះ។ គេដឹងថានេះគឺមកពីសមត្ថភាពរបស់គេ ដែលសមនឹងទទួលបាន តែគេមិននឹកស្មានថា ការសរសើរនេះចេញពីមាត់របស់ *តូរ៉ាណាកា* សោះតែម្តង។ ហើយ *យ៉ាប៊ូ* មិនដែលមានបំនងចង់អោយ *តូរ៉ាណាកា* ធ្វើការត្រួតពលជាផ្លូវការសោះឡើយ។

*យ៉ាប៊ូ* តប :

- អាចអញ្ចឹងដែរ ប៉ុន្តែមិនជឿជាក់ណាស់ណាទេ។ កាលនោះលោកម្ចាស់ *តែគូ* បានបញ្ជាអោយកំទេចបក្ខពួក *របេ្ហ* ហេតុនេះ បក្ខពួក *របេ្ហ* ក៏ត្រូវបានកំទេចម៉ត់ទៅ។

រឿងនេះបានកន្លងទៅដប់ឆ្នាំហើយ។ កាលនោះពួក *របេ្ហ* ដ៏ខ្លាំងក្លានិងដ៏មានវ័យចំនាស់ដឹកនាំដោយ *របេ្ហ កេនសេម៉ុន* បានធ្វើការតទប់នឹងកំលាំងទ័ពធំរុះរបស់លោកមេទ័ព *ណាកាមូរ៉ា* ដែលជាអនាគត *តែគូ* និងរបស់ *តូរ៉ាណាកា* ។ បក្ខពួក*របេ្ហ* កាលនោះជាឧបស័គ្គចុងក្រោយ និង ដ៏សំខាន់ក្នុងការទប់ស្កាត់លោកមេទ័ព *ណាកាមូរ៉ា* មិនអោយត្រួតត្រាចក្រភពទាំងស្រុងបាន។ រាប់សតវត្សមកហើយ បក្ខពួក*របេ្ហ* កាន់កាប់ *ក្វាន់តូ* ដែលរួមមានប្រាំបីខេត្ត។ នៅពេលនោះបក្ខបួក *របេ្ហ* ដាក់ពង្រាយ កងទ័ពចំនួនមួយរយហាសិបពាន់នាក់ ព័ទ្ធជុំវិញទីក្រុង-បន្ទាយ*អូដាវ៉ារ៉ា*នៅពាំងច្រកភ្នំដែល នាំទៅដល់វាលទំនាបដ៏មហាសំបូរស្រូវអង្ករដែលនៅឯម្ខាងទៀតនោះ។ ការហ៊ុមព័ទ្ធទីក្រុង-បន្ទាយនេះបានប្រព្រឹត្តទៅអស់រយៈពេលដប់មួយខែ ។ កាលនោះប្រពន្ធចុងថ្មីរបស់លោក *ណាកាមូរ៉ា* គឺជំទាវ *អូជីបា* ដែលនៅពេលនោះទើបអាយុបានដប់ប្រាំបីឆ្នាំបន្តិចបន្តួច បានមកតាមស្វាមីរបស់នាងដោយនាំមកជាមួយនូវទារកទើបនឹងកើតហើយដែលជាកូនប្រុសទីមួយរបស់ *ណាកាមូរ៉ា* ។ ជំទាវ *អូជីបា* ក៏បាននាំមកជាមួយនូវប្អូនស្រីរបស់នាងគឺ *គិនជីកូ* ហើយលោកមេទ័ព *ណាកាមូរ៉ា* បានស្នើ *តូរ៉ាណាកា* រៀបការជាមួយនាង។

នៅពេលនោះ *តូរ៉ាណាកា* បាននិយាយទៅ *ណាកាមូរ៉ា* ថា :

- លោកម្ចាស់ ខ្ញុំបាទពិតជាមានកិត្តិយសណាស់ ដែលបានធ្វើអោយវង្សត្រកូលយើងទាំងពីរកាន់តែខិតចូលជិតគ្នាថែមទៀតនេះប៉ុន្តែមិនមែនរូបខ្ញុំរៀបការជាមួយនាងនោះទេ គឺសូម



www.budinst.gov.kh www.elibraryofcambodia.org

អោយនាងរៀបការជាមួយកូនប្រុសច្បង និងជាទាយាទរបស់ខ្ញុំបាទឈ្មោះ *ស៊ូដាភ៊ា* វិញទាន។

កាលនោះ *តូរ៉ាណាកា* ត្រូវចំណាយពេលជាច្រើនថ្ងៃដើម្បីបញ្ចុះបញ្ចូល *ណាកាមូរ៉ា* អោយទទួលការយល់ព្រមតាមគំនិតនេះ ។ នៅពេលដែលការសំរេចនេះត្រូវបានប្រាប់ទៅដល់ជំទាវ *អូជីកា* នាងបានតបភ្លាមមួយរំពេច :

-នាងខ្ញុំសូមលំអោនកាយគោរពលោកម្ចាស់ នាងខ្ញុំសូមជំទាស់នឹងអពាហ៍ពិពាហ៍នេះ។

*ណាកាមូរ៉ា* អស់សំណើច :

- ខ្ញុំក៏អញ្ចឹងដែរ។ *ស៊ូដាភ៊ា* មានអាយុទើបបានដប់ឆ្នាំ ឯ *គិនជីកូ* អាយុដប់បីឆ្នាំទៅហើយ។ ទោះជាយ៉ាងនេះក្តីពួកវាត្រូវភ្ជាប់ពាក្យហើយដល់ពេល *ស៊ូដាភ៊ា* អាយុបានដប់ប្រាំ ពួកវារៀបការនឹងគ្នាទៅ។

- ប៉ុន្តែ *តូរ៉ាណាកា* សព្វថ្ងៃនេះជាប្អូនថ្លៃរបស់លោកម្ចាស់ទៅហើយ *នេ* ? ប៉ុណ្ណឹងហើយមិនមានទំនាក់ទំនងនឹងគ្នាទៀត រឺអី ? លោកម្ចាស់ត្រូវតែមានទំនាក់ទំនងជិតស្និទ្ធថែមទៀតជាមួយត្រកូល *ភូជីម៉ូតូ* និង *តាកាស៊ីម៉ា* វិញ.......អាចមានទំនាក់ទំនងជាមួយព្រះរាជវង្សានុវង្សក៏តែបាន។

- នៅក្នុងវាំងមានតែពួកខ្វះបង្គង ហើយពួកទាំងនោះសុទ្ធតែជាប់បញ្ចាំតែប៉ុណ្ណឹង - *ណាកាមូរ៉ា* តបទាំងសំដីគ្រោតគ្រាតក្នុងទំលាប់ជាកសិករ -ស្តាប់បងណា : *តូរ៉ាណាកា* មានសាមូរ៉ៃនៅក្នុងដៃចិតសិបពាន់នាក់។ នៅពេលដែលយើងកំទេច *បេព្វ* វានឹងក្តោបក្តាប់តំបន់ *ក្វាន់តូ* ហើយកំលាំងទ័ពវាក៏កើនឡើង។ កូនប្រុសបងនឹងត្រូវការមេដឹកនាំរបៀបដូចជា *យ៉ូស៊ី តូរ៉ាណាកា* នេះ ដូចជាបងត្រូវការពួកគេនេះអញ្ចឹង។ ពិតណាស់ ថ្ងៃណាមួយកូនប្រុសបងនឹងត្រូវការ *យ៉ូស៊ី ស៊ូដាភ៊ា* ជាការល្អ ដែល *ស៊ូដាភ៊ា* ក្លាយជាឪពុកមារបស់កូនប្រុសបង។ ប្អូនស្រីអូនភ្ជាប់ពាក្យជាមួយ *ស៊ូដាភ៊ា* តែ *ស៊ូដាភ៊ា* នឹងរស់នៅជាមួយយើងបួនប្រាំឆ្នាំ *នេ*?

- ពិតណាស់ហើយ លោកម្ចាស់។

*តូរ៉ាណាកា* បានឯកភាពយល់ព្រមភ្លាម ហើយក៏បានទុកកូនប្រុស និងទាយាទខ្លួននោះនៅជាមួយ *ណាកាមូរ៉ា* ជាការធានាភក្តីភាពរបស់ខ្លួន។



www.budinst.gov.kh www.elibraryofcambodia.org

- ល្អណាស់ ។ ប៉ុន្តែដំបូងបង្អស់ លោកនិង *ស៊ូដាវ៉ា* ត្រូវធ្វើការស្បថស្បែពីភក្តីភាពជាអនន្តចំពោះកូនប្រុសខ្ញុំ ។

ពួកគេក៏បានធ្វើតាម ប៉ុន្តែនៅក្នុងខែទីដប់នៃការហ៊ុមព័ទ្ធនេះ កូនដំបូងរបស់ *ណាកាមូរ៉ា* បានទទួលមរណភាព ដែលអ្នកខ្លះថាមកពីគ្រុន ខ្លះថាមកពីឈាមមិនល្អ ខ្លះថាមកពី *កាមី* កំនាចឃោរឃៅ ។

នៅពេលនោះ ជំទាវ *អូជីបា* ខឹងដាច់ក្បាលដាច់កន្ទុយ :

- សូមព្រះទាំងអស់ដាក់បណ្តាសាទាំង *អូដាវ៉ារ៉ា* ទាំង *តូរ៉ាណាកា* ផងចុះ ។ នេះគឺជាកំហុស *តូរ៉ាណាកា* ទាំងស្រុងដែលយើងមកនៅទីនេះ ។ វាគិតតែចង់បាន *ក្វាន់តូ*។ កូនយើងស្លាប់មកតែពីរូបវាណឹង ។ វាទើបជាសត្រូវពិតប្រាកដរបស់លោកម្ចាស់ ។ វាចង់អោយលោកម្ចាស់ស្លាប់ ។ វាចង់អោយខ្ញុំស្លាប់ ។ សំលាប់វាចោលទៅ រឺ អោយវាចេញធ្វើការទៅ ។ អោយវានាំមុខការវាយលុកទៅ ។ អោយវាទទួលសងដោយជីវិតវានូវការស្លាប់របស់កូនយើងនេះ ។ ខ្ញុំម្ចាស់សូមការសងសឹក........

ហើយដោយអញ្ចឹងហើយ *តូរ៉ាណាកា* ត្រូវដឹកនាំមុខការវាយលុក ។ លោកវាយកាន់កាប់វិមាន *អូដាវ៉ារ៉ា* បានអាស្រ័យការប្រើរំសេវផ្ទុះធ្វើអោយរលំកំផែង និងការវាយបុកចំពីមុខ ។ បន្ទាប់មក *ណាកាមូរ៉ា* បានកំទេចទីក្រុងនេះអោយទៅជាផេះ ។ អាស្រ័យការធ្លាក់ចុះនៃវិមាន *អូដាវ៉ារ៉ា* និងការតាមកំចាត់រាល់ពួក *បេជូ* នោះមក ចក្រភពទាំងមូលត្រូវបានប្រាមប្រាប ហើយ *ណាកាមូរ៉ា* ក៏បានក្លាយទៅជា *ក្វាមប៉ាគូ* ជាលើកទីមួយ ហើយបន្ទាប់មកទៀតជា *តៃកូ*។ ប៉ុន្តែមនុស្សច្រើនណាស់ដែលបានបាត់បង់ជីវិតនៅ *អូដាវ៉ារ៉ា* ។

មនុស្សច្រើនពេក - *តូរ៉ាណាកា* គិតនៅក្នុងចិត្តក្នុងពេលដែលលោកស្ថិតនៅលើផ្លូវ *អាន់ជ្ញី* ។ ក្រសែភ្នែករបស់លោកឃ្លាំមើល *យ៉ាប៊ូ* ជានិច្ច :

- ជាការស្តាយណាស់ដែល *តៃកូ* បានទទួលមរណភាពទៅ *នេ*?

- ពិតមែនហើយ ។

- បងថ្លៃខ្ញុំជាមេដឹកនាំមួយដ៏មហិមា ។ ហើយក៏ជាមហាគ្រូមួយផងដែរ ។ ខ្ញុំដូចគាត់



www.budinst.gov.kh www.elibraryofcambodia.org

ត្រង់ខ្ញុំមិនចេះភ្លេចមិត្តឡើយ ។ ជាមួយសត្រូវ ក៏អញ្ចឹង ។

- បន្តិចទៀតនេះលោកម្ចាស់ *វ៉ៃយេនមុំន* នឹងដល់អាយុពេញវ័យហើយ ។ ចិត្តព្រលឹងរបស់គេគឺជាចិត្ត និងព្រលឹងរបស់ *វ៉ៃគូ* នោះឯង ។ លោកម្ចាស់ *តូរ៉ា* .........

ប៉ុន្តែនៅមុនពេលដែល *យ៉ាំប៊ូ* ឃាត់លោកមិនអោយបន្តត្រួតពលទៀតនោះ *តូរ៉ាណាកា* បានបន្តដំណើរទៅមុខទៀតទៅហើយដែលបង្ខំអោយ *យ៉ាំប៊ូ* គ្មានជំរើសអ្វីក្រៅពីដើរតាមតុក្រុកនោះឡើយ ។ លោកដើរត្រួតពលពីកងមួយទៅកងមួយ ជូនកាលលោកឈប់និយាយជាមួយអ្នកនេះ រឺអ្នកនោះនៅពេលដែលលោកប្រទះឃើញអ្នកដែលលោកស្គាល់ ។ ភ្នែករបស់លោកឥតនៅស្ងៀមឡើយក្នុងខណៈដែលលោកខំរំលឹកនៅក្នុងខួរក្បាលរបស់លោកនូវឈ្មោះ និងមុខមនុស្សទាំងឡាយនោះ ។ លោកមានលក្ខណសម្បត្តិដ៏កំរមួយនៃមេទ័ពពិសេស ពោលគឺនៅពេលត្រួតពល លោកធ្វើអោយគ្រប់ៗគ្នាមានអារម្មណ៍យ៉ាងហោចណាស់មួយភ្លែតដែរ ថាមេទ័ពនោះសំលឹងមើលតែខ្លួនឯងមួយគត់ រឺថានិយាយមកកាន់តែខ្លួនម្នាក់ក្នុងចំនោមមិត្តភក្តិទាំងអស់របស់ខ្លួន ។ *តូរ៉ាណាកា* បានធ្វើនូវអ្វីដែលនិស្ស័យតាំងពីកំនើតតំរូវអោយលោកធ្វើ និងបានធ្វើអ្វីដែលលោកតែងធ្វើរាប់ពាន់ដងមកហើយ នោះគឺការត្រួតមនុស្សតាមរយៈកំលាំងឆន្ទៈរបស់លោក ។

នៅពេលដែលលោកត្រួតពលចប់សព្វគ្រប់ហើយនោះ ទាំង *យ៉ាំប៊ូ* ទាំង *អ៊ីកូរ៉ាជី* និងទាំង *អូមី* សុទ្ធតែដង្ហក់រកខ្យល់រៀងខ្លួន ប៉ុន្តែ *តូរ៉ាណាកា* នៅតែខ្លាំងក្លាដដែល ហើយក៏ដូចពេលមុនដែរ គឺនៅមុនពេលដែល *យ៉ាំប៊ូ* ហាមាត់ឃាត់នោះ លោកបានដើរយ៉ាងលឿនសំដៅទៅទួលខ្ពស់មួយហើយឈរនៅលើទីនោះតែមួយអង្គឯង រួចបន្លឺសំលេងក្រអៅខ្លាំងៗឡើង :

- សាមូរ៉ៃនៃតំបន់ *អ៊ីស៊ូ* ទាំងឡាយដែលជាអណ្តាប់ *កាស៊ីគី យ៉ាំប៊ូ-សាម៉ា* ដែលជាមិត្តនិងជាសំព័ន្ធមិត្តរបស់ខ្ញុំនៅទីនេះ ។ ខ្ញុំមានកិត្តិយសណាស់ដែលបានមានវត្តមាននៅទីនេះ ។ ខ្ញុំមានកិត្តិយសណាស់ដែលបានឃើញមួយផ្នែកនៃកំលាំងតំបន់ *អ៊ីស៊ូ* ដែលជាផ្នែកមួយនៃកំលាំងរបស់មហាសំព័ន្ធមិត្តរបស់ខ្ញុំ ។ សូមស្តាប់ខ្ញុំ សាមូរ៉ៃទាំងអស់គ្នា ! ពពកខ្មៅងងឹតកំពុងគ្របដណ្តប់មហាចក្រភព និងគំរាមកំហែងសន្តិភាពដែលលោកម្ចាស់ *វ៉ៃគូ* បានទុកអោយយើងនោះហើយ ។ យើង ត្រូវការពារនូវចំនងដៃដែល *វ៉ៃគូ* បានចងទុកអោយយើងនេះតទល់នឹងរាល់អំពើក្បត់ទាំង



www.budinst.gov.kh www.elibraryofcambodia.org

ឡាយរបស់ថ្នាក់លើ ! សាមូរ៉ៃគ្រប់ៗរូបត្រូវត្រៀមខ្លួនជាស្រេចចំពោះស្ថានភាពនេះ ! អាវុធទាំងឡាយត្រូវសំលៀងត្រៀមចាំជានិច្ច ! យើងត្រូវប្ដេជ្ញាការពារឆន្ទៈរបស់លោកម្ចាស់ *តៃកូ* ទាំងអស់គ្នា ! ហើយយើងទាំងអស់គ្នាពិតជាមានជ័យជំនះ ! សូមព្រះថែរក្សាប្រទេសជប៉ុនយើង ទាំងអង្គធំ ទាំងអង្គតូច ជួយថែរក្សាពួកយើង និងជួយកំទេចកុំត្រាប្រណីពួកណាដែលប្រឆាំង នឹងបញ្ជា *តៃកូ* ។

រួច *តូរ៉ាណាកា* លើកដៃទាំងពីររបស់ខ្លួនខ្ពស់ត្រង់ទៅលើហើយស្រែកឡើងនូវសំរែកសង្គ្រាម " ***គាស៊ូគី !*** " របស់ពួកសាមូរ៉ៃទាំងនោះ រួចដោយគ្មានអ្នកណាជឿបាននឹងក្រសែភ្នែកខ្លួន លោកអោនក្បាលគោរពកងពលទាំងអស់ដែលនៅត្រៀបត្រាពីមុខលោក ហើយលោករក្សាស្ថានភាពនេះនៅនឹងថ្កល់ ។

ពួកសាមូរ៉ៃទាំងអស់សំលឹងធ្មឹងទៅរកលោក បន្តិចមកទើបសំរែក " ***តូរ៉ាណាកា !*** " បានលាន់លឺខ្ទរឡើងឆ្លើយតបនឹងលោកវិញ ។ នោះគឺជាសំលេងរំពង និងឥតដាច់របស់ពួកកងពលទាំងអស់ ហើយទាំងអស់គ្នាក៏លំអោនខ្លួនគោរពតបទៅលោកវិញដែរ ។

សូម្បីតែ *យ៉ាប៊ូ* ក៏ត្រូវឥទ្ធិពលនៃបរិយាកាសបង្ខំអោយលំអោនខ្លួនគោរពទៅ *តូរ៉ាណាកា* វិញដែរ ។

នៅពេលដែល *យ៉ាប៊ូ* មិនទាន់ទាំងងើបខ្លួនត្រង់ផងនោះ *តូរ៉ាណាកា* បានដើរចុះយ៉ាងលឿនពីដីទួលទៅហើយ ។

- *អូមី-សាន* អែងទៅតាមគាត់ទៅ ។

*យ៉ាប៊ូ* ចេញបញ្ជាទៅ *អូមី* ដោយយល់ថាគឺជាការមួយមិនសមរម្យចំពោះខ្លួនទេដែលត្រូវរត់តាម *តូរ៉ាណាកា* គគ្រុកនោះ ។

- បាទ ទាន ។

ពេល *អូមី* ចេញទៅហើយ *យ៉ាប៊ូ* ពោលទៅកាន់ *អ៊ីគូរ៉ាជី* :

- តើមានដំណឹងអ្វីពី *យេដូ* ទេ ?

- លោកជំទាវ *យូរីកូ* របស់លោកម្ចាស់ បានផ្ដាំមកលោកម្ចាស់ជាដំបូងគឺមានកំនែន



www.budinst.gov.kh www.elibraryofcambodia.org

ទ័ពសំបើមដែលហើយនៅតំបន់ *ក្វាន់តូ* ទាំងមូល ។ បើមើលសើៗហាក់ដូចជាអ្វីៗគ្មានការប្រែប្រួលប៉ុន្មានទេ តែធាតុពិតបើមើលអោយដល់ជំរៅទៅអ្វីៗកំពុងពុះកញ្ជ្រោលសំបើមណាស់ ។ លោកជំទាវជឿថា *តូរ៉ាណាកា* កំពុងរៀបចំធ្វើសង្គ្រាមហើយៗអាចបើកការវៃលុកភ្លាមៗមើលទៅប្រហែលសំដៅលើ *អូសាកា* ផងក៏មិនដឹង ។

- ចុះ *អ៊ីស៊ីដូ* ?

- ដូចជាគ្មានអ្វីប្លែកទេមុនពេលពួកយើងខ្ញុំចេញដំណើរមកនេះ ។ តែនោះគឺកាលពីប្រាំថ្ងៃមុនម្ល៉េះ ។ ហើយក៏គ្មានអ្វីទាក់ទិនដល់ការគេចខ្លួនរបស់ *តូរ៉ាណាកា* ដែរ ។ ខ្ញុំទើបដឹងរឿងនេះកាលពីម្សិលមិញនេះ គឺនៅពេលដែលលោកជំទាវបញ្ជូនព្រាបនាំសារពី *យេដូ* មកនោះឯង ។

- អើ បើអញ្ចឹង *ស៊ូគីម៉ូតូ* ចាត់ចែងការងារនាំសារនេះហើយ រឺ ?

- បាទ ទាន ។

- ល្អ ។

- សារលោកជំទាវសរសេរថា " *តូរ៉ាណាកា* បានគេចចេញតាមទូកដោយជោគជ័យពីអូសាកា ជាមួយលោកម្ចាស់យើងហើយ ។ សូមត្រៀមរៀបចំទទួលពួកគេនៅឯ *អាន់ជីរ៉* " ។ ខ្ញុំបាទគិតថាត្រូវរក្សាការសំងាត់ក្នុងរឿងនេះ លើកលែងតែ *អូមី-សាន* ម្នាក់ប៉ុននោះ ដែលខ្ញុំបាទអោយដឹង តែពួកយើងទាំងអស់គ្នារៀបចំស្រេចបាច់អស់ហើយ ទាន ។

- ស្រេចបាច់យ៉ាងម៉េចទៅ ?

- ខ្ញុំបាទ បានបញ្ជាជា " សមយុទ្ធ " មួយនៅទូទាំង *អ៊ីស៊ូ* ទាន ។ ក្នុងរង្វង់តែបីថ្ងៃ រាល់ផ្លូវនិងរាល់ច្រកចេញចូល *អ៊ីស៊ូ* ទាំងប៉ុន្មាននឹងត្រូវខ្ទប់ជិតឈឹងភ្លាម បើសិនជាលោកម្ចាស់ចេញបញ្ជា ។ នៅឯខាងជើង ពួកយើងបន្លំធ្វើជាកងសំពៅចោរសមុទ្រហើយអាចកំទេចគ្រប់ទូកក្ដារទាំងអស់ណាដែលគ្មានកំលាំងអមការពារ ទោះយប់ក្ដី ទោះថ្ងៃក្ដី អោយតែលោកម្ចាស់ចេញបញ្ជា ។ ហើយនៅទីនេះទៀតសោត ក៏មានកន្លែងសំរាប់ទទួលលោកម្ចាស់ និងភ្ញៀវលោកម្ចាស់ទោះជាសំខាន់ប៉ុនណាក៏ដោយ បានម្នាក់ទៀតដែរ ។

- ល្អ ។ មានស្អីទៀតទេ ? មានដំណឹងអីទៀតទេ ?



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ីកូវ៉ាជី* មានការរារែកនៅក្នុងចិត្តក្នុងការផ្ដល់ដំណឹងអ្វីដែលគេមិនទាន់វាស់ស្ទង់បាននូវផលវិបាករបស់វាណាស់ :

- ពួកយើងបានត្រៀមប្រឈមមុខនឹងគ្រប់ហេតុការណ៍ទាំងអស់ហើយ ទាន ។ ប៉ុន្តែពីព្រឹកមិញនេះ សារសំងាត់មួយត្រូវបានបញ្ជូនមកពី *អូសាកា*។ សារនោះសរសេរថា " *តូរ៉ាណាកា* បានសុំលាលែងពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិហើយ "។

- មិនអាចទៅជាយ៉ាងណឹងកើតទេ ។ ហេតុអ្វីបានជាគាត់ទៅធ្វើបែបណឹងនោះ ?

- ខ្ញុំបាទមិនដឹងដែរ ទាន ។ ខ្ញុំបាទគិតរឿងណឹងមិនយល់ដែរ តែរឿងហ្នឹងអាចជារឿងពិតមែន ទាន ។ តាំងពីដើមមកប្រភពនេះ មិនដែលផ្ដល់ពត៌មានខុសអោយយើងម្ដងណាឡើយ ។

- ជំទាវ *សាស៊ូកូ* មែនទេ ?

*យ៉ាប៊ូ* សួរឈ្មោះយ៉ាងប្រយ័ត្នប្រយែង ។ *សាស៊ូកូ* ជាប្រពន្ធចុងក្មេងជាងគេបំផុតរបស់ *តូរ៉ាណាកា* ហើយស្រីបំរើរបស់នាងគឺជាអ្នកយកការណ៍របស់ *យ៉ាប៊ូ* នោះឯង ។

*អ៊ីកូវ៉ាជី* ងក់ក្បាល :

- បាទ ទាន ។ តែខ្ញុំបាទមិនយល់សោះតែម្ដងហើយ ។ ពេលនេះ ក្រុមប្រឹក្សាពិតជានឹងប្រកាសថ្កោលទោសគាត់ជាមិនខានមែនទេ លោកម្ចាស់ ? គេពិតជាកាត់ទោសប្រហារជីវិតគាត់ជាមិនខាន ។ គាត់ពិតជាឆ្កួតលេលាមែន នៅសុខៗទៅសុំលាលែងបែបនេះ មែនទេ លោកម្ចាស់?

- *អ៊ីស៊ីដូ* ពិតជាគាបសង្កត់គាត់អោយធ្វើបែបនេះហើយ ។ តែតើគាបតាមបែបណា ឬ ? គ្មានលឺពាក្យចចាមអារ៉ាមអីគាត់តូចសោះ ។ *តូរ៉ាណាកា* ដាច់ខាតមិនសុំលាលែងដោយចិត្តឯងឡើយ ! អែងយល់ត្រូវណាស់ដែលថាការសុំលាលែងគឺជាអំពើលេលាមួយនោះ ។ គាត់នឹងបង់ចាញ់ច្រើនបើគាត់សុំលាលែងមែននោះ ។ នេះប្រហែលជាមិនពិតទេ ។

*យ៉ាប៊ូ* ចុះពីលើកូនភ្នំទាំងក្នុងចិត្តជ្រួលច្របល់ ភ្នែកគេតាមសំលឹង *តូរ៉ាណាកា* ដែលកំពុងឆ្លងកាត់ផ្លាភូមិតំរង់ទៅរក *ម៉ារីកូ* និងបុរសចុងស្រុក ។ *ភូជីកូ* នៅឈរអែបអ្នកទាំងពីរដែរ ។ បន្ទាប់មកទៀតគេឃើញ *ម៉ារីកូ* ដើរទន្ទឹម *តូរ៉ាណាកា* ឯអ្នកឯទៀតនៅឈររង់ចាំនៅកន្លែងដដែល ។នៅពេលឃើញ *តូរ៉ាណាកា* ហុចកូនក្រដាសមួយសន្លឹកទៅអោយ *ម៉ារីកូ* *យ៉ាប៊ូ* សែនចង់



www.budinst.gov.kh www.elibraryofcambodia.org

ដឹងពីអត្ថន័យនៃសំបុត្រនេះ ក៏ដូចជាចង់ដឹងពីអ្វីដែលអ្នកទាំងពីរបាននិយាយគ្នាផងដែរ។ តើ *តូរ៉ាណាកា* កំពុងលេងល្បិចអីណឹង ? -*យ៉ាប៊ូ* ដណ្តឹងសួរក្នុងចិត្ត។ គេមានបំណងចង់អោយ *យូរីកូ* ប្រពន្ធរបស់គេមកជិតរូបគេយ៉ាងខ្លាំង ព្រោះថានាងច្បាស់ជាអាចជួយផ្តល់យោបល់ដ៏វាងវៃជាច្រើនដល់រូបគេជាមិនខាន។

*តូរ៉ាណាកា* បញ្ឈប់ដំណើរនៅលើកំពង់ផែ។ លោកមិនឡើងទៅលើទូកធំដើម្បីស្ថិតនៅក្រោមកិច្ចការពាររបស់អង្គរក្សរបស់លោកឡើយ ដោយលោកយល់ច្បាស់ថា ការសំរេចចុងក្រោយគឺនឹងត្រូវធ្វើនៅលើច្រាំងនេះឯង។ រូបលោកមិនអាចគេចចេញពីស្ថានភាពនេះទេ។ អ្វី១ទាំងអស់មិនទាន់ត្រូវបានដោះស្រាយនៅឡើយ។ លោកសំលឹងមើល *យ៉ាប៊ូ* និង *អ៊ីកូរ៉ាជី* ដើរតំរង់មករកលោក។ ទឹកមុខរបឹងរបស់ *យ៉ាប៊ូ* បានបកស្រាយយ៉ាងច្បាស់នូវអ្វីដែលមាននៅក្នុងចិត្តរបស់គេ។

- យ៉ាងម៉េចដែរ *យ៉ាប៊ូ-សាន* ?

- លោកម្ចាស់នៅសំរាកទីនេះប៉ុន្មានថ្ងៃសិនទៅរឺ ទាន ?

- បើខ្ញុំចេញដំណើរនៅពេលនេះគឺល្អជាង

*យ៉ាប៊ូ* ចេញបញ្ជាអោយអ្នកឯទៀតចេញឆ្ងាយទុកតែខ្លួនគេ និង *តូរ៉ាណាកា* តែពីរនាក់ប៉ុននោះនៅមាត់ឆ្នេរ :

- ខ្ញុំមានដំណឹងគួរអោយព្រួយបារម្ភមួយពី *អូសាកា*។ លោកម្ចាស់បានសុំលាលែងពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិមែនរឺ ?

- ពិតមែនហើយ ខ្ញុំបានសុំលាលែងចេញពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិមែន។

- បើអញ្ចឹងមែន ដូចលោកម្ចាស់សំលាប់ខ្លួនឯងផង សំលាប់បុព្វហេតុលោកម្ចាស់ផងរាប់ទាំងអណ្តាប់លោកម្ចាស់ សំព័ន្ធមិត្តលោកម្ចាស់ និងមិត្តភក្តិទាំងអស់របស់លោកម្ចាស់តែម្តង ! នេះគឺលោកម្ចាស់កប់តំបន់ *អ៊ីស៊ូ* ហើយអារកខ្ញុំបាទតែម្តងហើយ ទាន។

- ពិតហើយ ក្រុមប្រឹក្សាអាចរឹបអូសយកដីលោក ហើយនឹងជីវិតរបស់លោកផង បើគេចង់នោះ។



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* ប្រឹងទប់ចិត្តក្តៅក្រហាយរបស់ខ្លួន :

- ឱព្រះអើយព្រះ ខ្ញុំសូមលោកម្ចាស់អាធ្យាស្រ័យចំពោះអាកប្បកិរិយាមិនសមរម្យផង..... ប៉ុន្តែជំហរមិនអាចជឿបានរបស់លោកម្ចាស់.......អោយខ្ញុំសូមទោស -*យ៉ាប៊ូ* ប្រឹងសង្កត់ចិត្តដោយគេយល់ថាការបង្ហាញចេញនូវអារម្មណ៍របស់ខ្លួនពិតជាខ្វះសុជីវធម៌ និងនាំអោយបាក់មុខបាក់មាត់តែប៉ុននោះ -តែខ្ញុំយល់ថាលោកនៅក្នុងក្រុមប្រឹក្សាគឺចំនេញច្រើនជាងខាត ទាន ។

- ខ្ញុំយល់ថាខ្ញុំគួរចេញវិញល្អជាង ។

- នៅទីនេះ រឺ នៅ *យេដូ* វាមានទៅខុសគ្នាអី ? បញ្ហារបស់ក្រុមប្រឹក្សានឹងមកដល់ភ្លាមណឹង ។ ខ្ញុំបាទគិតថាលោកម្ចាស់មានបំនងធ្វើ សិបពូគូ នៅពេលទទួលបញ្ហាភ្លាមតែម្តង ។ ដោយថ្លៃថ្នូរ ដោយស្ងប់ស្ងាត់ ។ ខ្ញុំពិតជាមានកិត្តិយសណាស់បើសិនជាបានធ្វើជាជំនួយលោកម្ចាស់នៅក្នុងពេលនោះ ។

- សូមអរគុណណាស់ ។ តែពេលនេះគ្មានបញ្ហាផ្លូវការណាមួយបានមកដល់ទីនេះនៅឡើយទេ បើអញ្ជឹងហើយក្បាលខ្ញុំវានៅកន្លែងណាអោយវាបន្តនៅកន្លែងហ្នឹងទៀតចុះ ។

- តើមួយថ្ងៃ រឺ ពីរថ្ងៃមានទៅខុសគ្នាអី ? បញ្ហាត្រូវតែមកដល់ទីនេះដោយចៀសមិនរួច ។ ខ្ញុំបាទនឹងចាត់ចែងកិច្ចការគ្រប់បែបយ៉ាងសំរាប់ពិធីនេះ ហើយខ្ញុំបាទធានារៀបចំមិនខ្វះទេទាន ។ លោកម្ចាស់ទុកចិត្តលើរូបខ្ញុំបាទចុះ ។

- អរគុណណាស់ ។ ខ្ញុំយល់ដែរថាហេតុអ្វីលោកចង់បានក្បាលខ្ញុំនោះ ។

- ក្បាលខ្ញុំបាទក៏ប្រហែលជាមិនគង់ដែរទេ ។ បើសិនជាខ្ញុំបាទបញ្ជូនក្បាលលោកម្ចាស់ទៅអោយ *អ៊ីស៊ីដូ* រឺ ខ្ញុំបាទកាត់ក្បាលលោកម្ចាស់ហើយសូមអោយ *អ៊ីស៊ីដូ* លើកលែងទោសអោយនោះ ខ្ញុំបាទអាចបន្ទន់ចិត្តគាត់បានខ្លះ តែនេះក៏មិនប្រាកដប៉ុន្មានដែរទេ *នេ*?

- បើខ្ញុំនៅក្នុងស្ថានភាពដូចលោកវិញនោះ ខ្ញុំប្រហែលជាសុំក្បាលលោកហើយ ។ តែគួរអោយស្តាយដោយក្បាលខ្ញុំមិនអាចជួយលោកបាន ។

- ខ្ញុំបាទចង់ឯកភាពតាមដែរ តែសោកទៅក៏មិនខាតអីដែរ ។ ខ្ញុំបាទសមតែស្លាប់មែនដែលល្ងើពេកថ្វាសមកជាប់ទទាក់ទទាមក្នុងរឿងនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- *អ៊ីស៊ីដូ* មិនដែលរុញរានឹងយកក្បាលលោកនោះទេ។ តែដំបូងគឺវាត្រូវយក *អ៊ីស៊ូ*សិន។ មែនហើយ *អ៊ីស៊ីដូ* កាន់អំនាច *អ៊ីស៊ូ* ត្រូវតែបាត់បង់ផងដែរ។

- លោកម្ចាស់កុំសាកទាក់ខ្ញុំបាទ។ ខ្ញុំបាទដឹងច្បាស់ណាស់ថារឿងហ្នឹងត្រូវតែរបៀបហ្នឹង។

- ខ្ញុំមិនសាកល្បងទាក់លោកទេ។ ខ្ញុំគ្រាន់តែនិយាយថាបើ *អ៊ីស៊ីដូ* កាន់អំនាច លោកនឹងត្រូវរលំរលាយហើយ *អ៊ីស៊ូ* នឹងត្រូវបាត់បង់ដែរ ព្រោះបងប្អូនរបស់ *អ៊ីស៊ីដូ* គឺ *អ៊ីកាវ៉ា ជីគីយូ* ក៏ចង់បាន *អ៊ីស៊ូ* នេះដែរ *ទេ* ?តែស្តាប់ខ្ញុំណា *យ៉ាប៊ូ-សាន* *អ៊ីស៊ីដូ* មិនទាន់ក្តាប់បានអំនាចនៅឡើយទេ។

រួចលោក *តូរ៉ាណាកា* និយាយប្រាប់ *យ៉ាប៊ូ* ក្នុងឋានៈជាមិត្ត នូវមូលហេតុអ្វីខ្លះ ដែលលោកបានសំរេចចាកចេញពីក្រុមប្រឹក្សានោះ។

*យ៉ាប៊ូ* ស្ទើរតែមិនជឿត្រចៀករបស់ខ្លួន :

- ក្រុមប្រឹក្សាត្រូវស្លុះ ?

*តូរ៉ាណាកា* សើចញញឹម :

- ***គ្មានក្រុមប្រឹក្សាទៀតទេ*** ។ ក្រុមប្រឹក្សាអាចដំណើរការឡើងវិញបាន ទាល់តែមានសមាជិកគ្រប់ប្រាំនាក់វិញ។ គិតមើល *យ៉ាប៊ូ-សាន*។ ពេលនេះ ខ្ញុំខ្លាំងជាងពេលណាៗទាំងអស់ *ទេ* ? *អ៊ីស៊ីដូ* ត្រូវអស់ធ្មុងហើយ អា *ជីគីយូ* ក៏យ៉ាងនោះដែរ។ អីលូវនេះ លោកមានពេលគ្រប់គ្រាន់ដើម្បីបង្ហិកទ័ពលោកអោយចេះប្រើកាំភ្លើងបានហើយ ។ ពេលនេះ លោកជាម្ចាស់លើ *ស៊ូរ៉ូកា* និង *តូតូមី* ហើយក្បាល *ជីគីយូ* ក៏នៅក្នុងកណ្តាប់ដៃលោកទៀត។ ក្នុងប៉ុន្មានខែខាងមុខទៀតនេះ លោកនឹងឃើញក្បាលវាជាមួយនឹងក្បាលញាតិសាច់សាលោហិតវាទាំងអស់នៅលើផ្លែលំពែង ហើយលោកនឹងដើរចូលតំបន់ថ្មីរបស់លោកក្នុងឋានៈជាម្ចាស់ជាមិនខាន។

រួចរំពេចនោះលោកបែរខ្លួនទៅក្រោយហើយស្រែកខ្លាំងៗឡើងថា " *អ៊ីកូរ៉ាជី-សាន* " ។ សំលេងរបស់លោកលាន់លឺសំរាប់មនុស្សទាំងប្រាំរយនាក់យ៉ាងច្បាស់។

*អ៊ីកូរ៉ាជី* រត់តំរង់មករកភ្លាម ។ តែគេទើបបោះជើងបានបីជំហាន *តូរ៉ាណាកា* ស្រែក



www.budinst.gov.kh www.elibraryofcambodia.org

បញ្ជាថែមទៀត :

- យកកងកិត្តិយសមកជាមួយផង ។ ហាសិបនាក់ ! យកមកភ្លាម !

លោកមិនហ៊ានទុកអោយ *យ៉ាប៊ូ* មានពេលវេលាគ្រប់គ្រាន់ដើម្បីមើលឃើញចន្លោះប្រហោងនៃទឡ្ហីករណ៍របស់លោកឡើយ នោះគឺថាបើ *អ៊ីស៊ីដូ* ត្រូវរាំងស្ទះហើយគ្មានអំនាចនៅក្នុងពេលនេះមែន ពេលនោះក្បាលរបស់លោកនៅលើថាសឈើពិតជាមានតំលៃដ៏លើសលប់ចំពោះ *អ៊ីស៊ីដូ* ហើយនឹងចំពោះ *យ៉ាប៊ូ* នេះផងដែរ ។ ហើយអ្វីដែលពិសេសទៅទៀតនោះប្រការដែល រូបលោកត្រូវចងបណ្តើរដូចជាចោរយកទៅប្រគល់ទាំងរស់នៅឯក្លោងទ្វារវិមាន *អូសាកា* ពិតជា នឹងផ្តល់ដល់ *យ៉ាប៊ូ* នូវអមតភាព និងសោសំរាប់ *ក្វាន់តូ* ជាមិនខាន ។

ក្នុងពេលដែលកងកិត្តិយសកំពុងរៀបជួរនៅចំពោះមុខលោកនោះ *តូរ៉ាណាកា* និយាយលឺៗបន្តទៀត :

- ដើម្បីជាកិត្តិយសនៅក្នុងឱកាសនេះ *យ៉ាប៊ូ-សាម៉ា* សូមលោកទទួលរបស់នេះទុកជាចំនងដៃមិត្តភាពផងចុះ ។

និយាយចប់ *តូរ៉ាណាកា* ហូតដាវវែងរបស់លោកចេញមកដោយកាន់ផ្តេកនៅលើដៃទាំងពីរ ហើយហុចទៅអោយ *យ៉ាប៊ូ* ។

*យ៉ាប៊ូ* ទទួលយកដាវដូចនៅក្នុងការយល់សប្តិ ។ នេះជាដាវគ្មានតំលៃប្រៀបឡើយ ។ នេះជាដាវរតនវត្ថុ *មីណូវ៉ារ៉ា* ហើយល្បីល្បាញទូទាំងប្រទេស ។ *តូរ៉ាណាកា* កាន់ដាវនេះដប់ប្រាំឆ្នាំហើយ ។ នេះជាដាវដែល *ណាកាមូរ៉ា* បានជូនដល់លោកនៅចំពោះមុខមហាប្រជុំនៃ *ដៃមីញ៉ូ* ទាំងអស់ទូទាំងចក្រភព លើកលែងតែមេទ័ព *បេក្កូ រកទរសេម៉ុន* ។ ដាវនេះគឺជាផ្នែកមួយនៃការទូទាត់លើកិច្ចព្រមព្រៀងជាសំងាត់រវាង *ណាកាមូរ៉ា* នឹង *តូរ៉ាណាកា*។

រឿងនេះបានកើតឡើងក្រោយសមរភូមិ *ណាកាគូដេ* បន្តិច មុនពេលដែលមានរឿងជំទាវ *អូជីបា* ។ *តូរ៉ាណាកា* ទើបតែបានវាយបំបាក់កំលាំងមេទ័ព *ណាកាមូរ៉ា* អោយទទួលបរាជ័យ ។ លោកមេទ័ព *ណាកាមូរ៉ា* ពេលនោះគឺគ្រាន់តែទើបឈានជើងចូលក្នុងឆាកអំនាចដោយមិនទាន់មានអំនាច រឺ ឋានៈផ្លូវការណាមួយនៅឡើយទេ ហើយបំនងប្រាថ្នាចង់ក្តាប់អំនាចទាំង



www.budinst.gov.kh www.elibraryofcambodia.org

ស្រុងរបស់លោកក៏មិនទាន់លេចចេញជារូបរាងពិតប្រាកដនៅឡើយដែរ ។ ផ្ទុយពីយុទ្ធសាស្ត្ររាល់សព្វដងរបស់ខ្លួនដែលប្រមូលផ្តុំក្បៀវដើម្បីពន្លិចសត្រូវរបស់ខ្លួន នៅលើកនេះ *ណាកាមូរ៉ា* បានសំរេចប្រកាន់យកយុទ្ធសាស្ត្រសំរុះសំរួលជាមួយ *តូរ៉ាណាកា* ទៅវិញ ។ លោកបានស្នើទៅ *តូរ៉ាណាកា* នូវសន្ធិសញ្ញាមិត្តភាព និងសម្ព័ន្ធភាពឥតប្រែក្រលាស់រវាងគេទាំងពីរនាក់ ហើយដើម្បីផ្សារសន្ធិសញ្ញា និងសម្ព័ន្ធភាពនេះ *ណាកាមូរ៉ា* បានលើកប្អូនស្រីម្តាយទីទៃខ្លួនអោយ *តូរ៉ាណាកា* ទោះជាប្អូនស្រីមេទ័ពនេះមានប្តីរួចទៅហើយ១មានអាយុពាក់កណ្តាលចំនាស់ហើយក្តី ក៏ប្រការនេះមិនមែនជារឿងសំខាន់នោះទេ ។ *តូរ៉ាណាកា* បានឯកភាពលើកិច្ចព្រមព្រៀងនេះ ហើយបុរសដែលជាស្វាមីរបស់ប្អូនស្រី *ណាកាមូរ៉ា* និងដែលជាអណ្តាប់របស់មេទ័ពនេះត្រូវបានគេស្នើអោយលែងប្រពន្ធ និង បញ្ជូននាងមកអោយ *ណាកាមូរ៉ា* វិញ ដើម្បីរៀបការភ្លាមជាមួយ *តូរ៉ាណាកា* ហើយក្នុងថ្ងៃជាមួយគ្នានោះ *តូរ៉ាណាកា* ក៏បានសំរេចកិច្ចព្រមព្រៀងមិត្តភាពសំងាត់ជាមួយបក្ខសម្ព័ន្ធ *របេ្លូ* ដ៏មានមហិទ្ធិរិទ្ធនោះភ្លាមដែរ ។

បន្ទាប់មក *តូរ៉ាណាកា* បាននៅរង់ចាំការវាយលុករបស់ *ណាកាមូរ៉ា* ទៅលើបក្ខសម្ព័ន្ធ *របេ្លូ*។ ប៉ុន្តែគ្មានចលនាទ័ពអ្វីទាំងអស់ ហើយអ្វីដែលគួរអោយភ្ញាក់ផ្អើលគឺ *ណាកាមូរ៉ា* បានបញ្ជូនម្តាយជាទីគោរព និងជាទីស្រលាញ់របស់ខ្លួនមកជំរំទ័ពរបស់ *តូរ៉ាណាកា* ក្រោមហេតុផលថ្លៃការជាមកមើលកូនស្រីចិញ្ចឹមរបស់ខ្លួនដែលជាភរិយាថ្មីរបស់លោក តែធាតុពិតគឺមកធ្វើជាចំនាប់ខ្មាំងតែប៉ុននោះ ។ ជាថ្នូរនឹងរូបម្តាយខ្លួននេះ *ណាកាមូរ៉ា* បានអញ្ជើញ *តូរ៉ាណាកា* ទៅក្នុងពិធីជួបជុំពុក *ដៃមីញ៉ូ* ដ៏ធំសំបើមមួយដែលលោកបានចាត់ចែងរៀបចំឡើងនៅ *អូសាកា*។ ក្រោយពីការគិតគូរពិចារណាយ៉ាងល្អិតល្អន់ និងយ៉ាងយូរមក *តូរ៉ាណាកា* បានយល់ព្រមទៅចូលរួមក្នុងពិធីជួបជុំនេះដោយប្រាប់ទៅសម្ព័ន្ធមិត្តរបស់ខ្លួនគឺមេទ័ព *របេ្លូ* *រកនសេមុំន* ថាប្រការល្អបំផុតពួកគេមិនត្រូវទៅចូលរួមពិធីនេះទាំងពីរនាក់ទេ ។ បន្ទាប់មកទៀត ដើម្បីត្រៀមតទល់នឹងអំពើក្រលិចក្រលុចណាមួយរបស់ *ណាកាមូរ៉ា* លោក *តូរ៉ាណាកា* បានបញ្ជូនជាសំងាត់នូវសាមូរ៉ៃរបស់លោកចំនួនហុកសិបពាន់នាក់ទៅទីក្រុង *អូសាកា*។ លោកទុកកូនប្រុសច្បងរបស់លោកឈ្មោះ *ណូប៊ូ* អោយទទួលមើលថែទាំភរិយាថ្មីរបស់លោកហើយនឹងម្តាយ *ណាកាមូរ៉ា*។ កាលនោះ *ណូប៊ូ* បាន



www.budinst.gov.kh www.elibraryofcambodia.org

ប្រមូលអុសស្ងួតមកគរជាគំនរជុំវិញកន្លែងស្នាក់នៅរបស់អ្នកទាំងពីរ ដោយប្រាប់យ៉ាងច្បាស់ថា បើសិនជាមានហេតុការណ៍អីកើតឡើងទៅលើឪពុករបស់គេ១ នឹងដុតកន្លែងនេះរួមទាំងអ្នកស្នាក់នៅផងអោយឆេះតែម្តង ។

*តូរ៉ាណាកា* ញញឹមនៅពេលនឹកឃើញពីរឿងនេះ ។ នៅយប់មុនពេលដែលលោកត្រូវចូលទៅក្នុងទីក្រុង *អូសាកា ណាកាមូរ៉ា* បានមកជួបលោកតែម្នាក់ឯង យ៉ាងសំងាត់ និងដោយគ្មានយកអាវុធមកជាប់នឹងខ្លួនឡើយ ។

- សួស្តី *តូរ៉ា-សាន*។

- សួស្តី លោកម្ចាស់ *ណាកាមូរ៉ា* ។

- សូមលោកស្តាប់ខ្ញុំ : យើងបានប្រយុទ្ធលើសមរភូមិរាប់មិនអស់ យើងបានដឹងរឿងសំងាត់រាប់មិនអស់ ហេតុនេះយើងមិនគួរអីមកជាន់ជើងគ្នានោះទេ ។

- ខ្ញុំឯកភាពណាស់លើរឿងនេះ -*តូរ៉ាណាកា* តបវិញយ៉ាងប្រយ័ត្នប្រយែង ។

- ស្តាប់ខ្ញុំណា : ខ្ញុំនៅតែបន្តិចទៀតនឹងដណ្តើមបានចក្រភពនេះហើយ ។ ដើម្បីក្តាប់បានអំនាចទាំងស្រុង ខ្ញុំត្រូវការការគោរពពីពួកបក្ខសំព័ន្ធចាស់ ពីពួកក្តម្ពីរាប់តំន ពីពួកទាយាទនៃត្រកូល *ភូជីម៉ូតូ* ត្រកូល *តាកាស៊ីម៉ា* និង *មីណូវ៉ារ៉ា* ជាដើម ។ នៅពេលណាដែលខ្ញុំបានអំនាចហើយ ទោះពួក *ដៃមីញ៉ូ* ណាមួយ រឺ អាត្រកូលទាំងបីនេះទៅប្រកាច់ប្រកិនឯណាក៏ខ្ញុំមិនទៅឈឺក្បាលអីដែរ ។

- លោកម្ចាស់ទទួលបាននូវការគោរពអំពីខ្ញុំហើយ ។ លោកម្ចាស់តែងទទួលបានជានិច្ច ។

- លោកសក្តិសមនឹងទទួលបានជ័យជំនះនៅ *ណាកាតូរ៉េ*។ លោកជាមេទ័ពដ៏ពូកែឆើតបំផុតដែលខ្ញុំបានស្គាល់ ហើយលោកជា *ដៃមីញ៉ូ* ដ៏មហិមាបំផុតនៅក្នុងនគរនេះ ។ ប៉ុន្តែនៅពេលនេះ យើងឈប់លេងល្បិចអីទៀតជាមួយគ្នា ។

ស្តាប់ខ្ញុំណា : នៅថ្ងៃស្អែកនេះ ខ្ញុំចង់អោយលោកអោនគោរពខ្ញុំក្នុងឋានៈជា *អណ្តាប់* នៅចំពោះមុខ *ដៃមីញ៉ូ* ទាំងអស់ ។ លោក *យ៉ូស៊ី-តូរ៉ាណាកា-ណូ-មីណូវ៉ារ៉ា* ខ្ញុំចង់អោយលោក



www.budinst.gov.kh www.elibraryofcambodia.org

ធ្វើជាអណ្តាប់ខ្ញុំដោយស្ម័គ្រចិត្ត ។ នៅជាសាធារណៈ ។ បើសិនជាលោកព្រមក្លាយខ្លួនជាអណ្តាប់ខ្ញុំហើយ ពួកអា *វៃមីញ៉ូ* ឯទៀតនឹង ចំតិតតូចដាក់ក្បាលជ្រមុជក្រោមធូលីទៅទៀត ។ ហើយបើមាននៅសល់បន្តិចបន្តួចដែលមិនព្រមចុះចូល អាពួកនោះចាំតែប្រុងខ្លួនទៅ ។

- បើអញ្ចឹង លោកម្ចាស់មិនក្លាយទៅជាអម្ចាស់លើម៉ាប្រទេសជប៉ុនទៅហើយ ?

- ពិតមែនហើយ ។ ជាអម្ចាស់ទីមួយបំផុតនៅក្នុងប្រវត្តិសាស្ត្រ ។ ហើយនេះគឺលោកជាអ្នកប្រគល់អោយខ្ញុំ ។ ខ្ញុំសូមទទួលស្គាល់ថាខ្ញុំមិនអាចសំរេចការងារនេះបានដោយគ្មានរូបលោកនោះទេ ។ តែស្តាប់ខ្ញុំណា : បើលោកធ្វើបានដូចដែលខ្ញុំបានស្នើមែន លោកគឺជាមនុស្សទីមួយបន្ទាប់ពីខ្ញុំ ។ លោកនឹងមានកិត្តិយសខ្ពង់ខ្ពស់តាមបំនង ។ លោកនឹងមានអ្វី១សព្វបែបយ៉ាង ។ ហើយអ្វី១នឹង មានគ្រប់គ្រាន់សំរាប់យើងទាំងពីរនាក់ហ្នឹង ។

- ពិតមែនរឺ ?

- ពិតណាស់ ។ ដំបូងខ្ញុំកាន់កាប់ជប៉ុន បន្ទាប់មកចិន ។ ខ្ញុំបានប្រាប់ *តូរ៉ែង* ហើយថាខ្ញុំចង់យ៉ាងនេះហើយខ្ញុំត្រូវតែបានដូចអ្វីដែលខ្ញុំប៉ង ។ ហើយលោកអាចយកជប៉ុនចុះ ព្រោះនេះនឹងទៅជាខេត្តមួយរបស់ចិន ដែលខ្ញុំគ្រប់គ្រង ។

- តែចុះអីលូវនេះ លោកម្ចាស់ *ណាកាម៉ូរ៉ា* ? អីលូវនេះ ខ្ញុំត្រូវតែដាក់ខ្លួនចំនុះលោក*ទេ* ? ខ្ញុំនៅក្រោមអំនាចរបស់លោកមិនអញ្ចឹង ? លោកម្ចាស់មានអំនាចឥទ្ធិពលដ៏លើសលប់នៅចំពោះមុខខ្ញុំ ឯពួក *របេរូ* វិញសំញេញធ្មេញកំទេចខ្ញុំពីក្រោយថែមទៀត ។

- ខ្ញុំចាត់ការពួកវាតែបន្តិចទៀតនេះឯង ។ ពួកអាសំអុយអស់នោះបានប្រកែកមិនមកតាមការអញ្ជើញរបស់ខ្ញុំអោយមកទីនេះ នៅវេលាស្អែកនេះទេ ។ ពួកវាថែមទាំងបង្វិលសំបុត្រអញ្ជើញរបស់ខ្ញុំប្រលាក់សុទ្ធតែអាចម៍សត្វថែមទៀត ។ លោកចង់បានទឹកដីពួកវាមែនទេ ? ចង់បានតំបន់ *ក្វាន់តូ* ទាំងមូលតែម្តងរឺ ?

- ដីពួកវាខ្ញុំមិនចង់បាន ដីអ្នកឯទៀតក៏មិនខ្ញុំមិនចង់បានដែរ -លោកតប ។

- កុហក -*ណាកាមូរ៉ា* តបយ៉ាងរាងរៃ -ស្តាប់ខ្ញុំ *តូរ៉ា-សាន* : ខ្ញុំអាយុជិតហាសិបឆ្នាំហើយ ។ ប្រពន្ធខ្ញុំមួយណាក៏គ្មានកូនដែរ ហើយនេះខ្ញុំរួមដំណេកស្រីមួយរយ ពីររយនាក់ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

មានគ្រប់ប្រភេទ គ្រប់អាយុ តាមគ្រប់បែប តែគ្មានអ្នកណាមានកូនសោះឡើយ។ នេះជា *កាម៉ា* ខ្ញុំ។ លោកមានកូនបួននាក់ដែលនៅរស់ ហើយមិនដឹងជាមានកូនស្រីប៉ុន្មានផងទេ។ លោកទើបតែអាយុសែសិបបី ហេតុនេះលោកអាចនៅមានកូនប្រុសម៉ាឡូតីថែមទៀតក៏តែបានដែរ ហើយនេះជា *កាម៉ា* លោក។ ម្យ៉ាងទៀតលោកជាត្រកូល *មីណូវ៉ាក់* ថែមទៀត។ នេះក៏ជា *កាម៉ា*។ ចុះបើខ្ញុំសុំកូនប្រុសលោកណាម្នាក់មកចិញ្ចឹមហើយទុកវាជាទាយាទខ្ញុំតែម្តងទៅ។

- អីលូវនេះ ?

- ឆាប់ៗនេះ។ ថាក្នុងបីឆ្នាំទៀតទៅចុះ។ កាលពីមុនមានទាយាទ រឺអត់មិនសំខាន់ទេ តែអីលូវនេះវាផ្សេង។ លោកម្ចាស់មុនរបស់យើង គឺ *តូរ៉ាដា* ទៅល្ងាក់ល្ងើអោយគេធ្វើឃាតបាន។ អីលូវនេះ ដែនដីនេះជារបស់ខ្ញុំ រឺថាអាចទៅជារបស់ខ្ញុំ ៗយ៉ាងម៉េចដែរ ?

- លោកម្ចាស់នឹងធ្វើកិច្ចព្រមព្រៀងជាផ្លូវការ និងជាសាធារណៈក្នុងរវាងពីរឆ្នាំទេ ?

- ពិតហើយ ក្នុងពីរឆ្នាំ។ លោកទុកចិត្តខ្ញុំចុះ។ ផលប្រយោជន៍យើងទាំងពីរដូចគ្នាទេ។ អីលូវនេះ ដំបូងបង្អស់គឺ *ក្វាន់តូ* មិនអញ្ចឹង ?

- តែតិចនៅពេលដែលខ្ញុំចុះចំនុះលោកម្ចាស់ *របេូ កេនសេម៉ុន* នឹងចុះចំនុះលោកម្ចាស់ដែរទៅ ?

- ខ្ញុំមិនអាចអោយមានរឿងបែបនេះបានទេ *តូរ៉ា-សាន*។ លោកចង់បានទឹកដីវ៉ាទៅហើយនោះ ។

- ខ្ញុំគ្មានចង់បានទឹកដីអ្នកណាទាំងអស់។

*ណាកាមូរ៉ា* ផ្ទុះសំនើច :

- ខ្ញុំដឹងហើយ។ ប៉ុន្តែ លោកគួរតែយក។ តំបន់ *ក្វាន់តូ* សក្តិសមនឹងលោកហើយ។ តំបន់នេះមានសន្តិសុខគ្រប់គ្រាន់ ព្រោះមានជញ្ជាំងភ្នំបាំងងាយដល់កិច្ចការពារ។ ឯផ្ទៃកដីសណ្តូវិញនឹងអាចអោយលោកត្រួតត្រាដីសំបូរស្រូវអង្ករជាងគេបំផុតក្នុងចក្រភពនេះ។ លោកនឹងមានខ្នងទល់នឹងសមុទ្ទ ហើយនឹងមានចំនួលពីរលាន *កូគូ*។ តែសូមលោកកុំយក *កាម៉ាកូរ៉ា* រឺ *អ្នដាវ៉ារ៉ា* ជាទីក្រុងសំរាប់លោកអោយសោះ។



www.budinst.gov.kh www.elibraryofcambodia.org

- តាំងពីដើមរៀងមក *កាម៉ាកូរ៉ា* ជាទីក្រុងនៃតំបន់ *ក្វាន់តូ* នេះឯង ។

- ហេតុអ្វីបានជាលោកចង់បាន *កាម៉ាកូរ៉ា តូរ៉ា-សាន* ? តើដោយសារតែមានអាស្រម របស់ *កាមី* ថែរក្សាគ្រួសារលោកនៅទីនោះអស់រយៈពេលប្រាំមួយរយឆ្នាំមកហើយនោះ រឺ ? តើជាអាស្រមរបស់ *ហាជីម៉ាន* ទេវតាសង្គ្រាមដែលត្រកូល *មីណូរ៉ាំរ៉ា* តែងតែគោរពទុកជាសក្ការៈនោះ រឺ ? បុព្វបុរសរបស់លោកចំជាវាងវៃមែនដែលជ្រើសរើសយក *កាមី* សង្គ្រាមសំរាប់ជាទីសក្ការៈយ៉ាងនេះ ។

- ខ្ញុំឥតចង់បានអ្វី ហើយក៏មិនគោរពបូជាអ្វីដែរ ។ អាស្រមគឺគ្រាន់តែជាអាស្រមប៉ុណ្ណោះ ហើយអ្នកណាក៏ដឹងដែរថា *កាមី* សង្គ្រាមមិនដែលស្ថិតនៅក្នុងអាស្រមណាមួយទេ ។

- ខ្ញុំសប្បាយចិត្តណាស់ដែលលោកមិនលោភលន់ចង់បានអ្វីនោះ *តូរ៉ា-សាន* ព្រោះដល់អញ្ចឹងទៅគ្មានអ្វីដែលធ្វើអោយលោកខកចិត្តនោះឡើយ ។ ត្រង់កន្លែងនេះលោកដូចជាខ្ញុំដែរតែម្តង ។ តែ *កាម៉ាកូរ៉ា* មិនមែនជាទីក្រុងសំរាប់លោកឡើយ ។ កន្លែងនេះមានច្រកភ្នំប្រាំពីរ ហេតុនេះលោកត្រូវការពារច្រើនកន្លែងហួសហេតុ ។ ហើយម្យ៉ាងទៀត វាមិនចេញទៅសមុទ្ទផង ។ បើតាមខ្ញុំ *កាម៉ាកូរ៉ា* មិនល្អទេ ។ ស្តាប់ខ្ញុំណា ៖ ល្អបំផុត និងសុខបំផុតគឺទៅឆ្ងាយឯនាយភ្នំវិញ ។ លោកក៏ត្រូវការកំពង់ផែសមុទ្ទផងដែរ ។ មានកន្លែងមួយដែលខ្ញុំឃើញម្តង គឺ *យេដូ* ។ អីលូវនេះកន្លែងនេះជាភូមិនេសាទទេ តែលោកអាចកែប្រែវាទៅជាទីក្រុងធំមួយបាន ។ កន្លែងនោះងាយការពារ ហើយត្រូវម៉ាច់រឿងជួញដូរនេះតែម្តង ។ លោកតែងលើកស្ទួយរឿងជួញដូរ ។ ខ្ញុំក៏លើកស្ទួយរឿងជួញដូរ ។ នេះល្អ ។ ហេតុនេះហើយ លោកត្រូវតែមានកំពង់ផែ ។ ឯក្រុង *អូដាវ៉ារ៉ា* វិញ យើងនឹងកំទេចវាអោយម៉ត់តែម្តង ដើម្បីទុកជាមេរៀនដល់អ្នកឯទៀត ។

- អារឿងនេះដូចជាពិបាកបន្តិចហើយ ។

- ពិតហើយ តែនេះនឹងជាមេរៀនដ៏ល្អមួយសំរាប់ពួក *ដៃមីញ៉ូ* ឯទៀត *នេ* ?

- វៃយកទីក្រុងនេះទាំងដុលយ៉ាងនេះពិតជាត្រូវចំនាយច្រើនណាស់ ។

*ណាកាមូរ៉ា* ផ្ទុះសំនើចម្តងទៀត ៖

- អាចអញ្ចឹងមែន ចំពោះរូបលោក ។ បើសិនជាលោកមិនរួមដៃជាមួយខ្ញុំ ។ ខ្ញុំត្រូវតែ



www.budinst.gov.kh www.elibraryofcambodia.org

ឆ្លងកាត់ដែនដីរបស់លោកដើម្បីទៅដល់ទីនោះ ។ តើលោកមានដឹងទេថាលោកគឺជាខ្សែជូរមុខរបស់ពួក *របក្ខ* ? បើលោករួមជាមួយពួក *របក្ខ* ពួកលោកអាចរារាំងខ្ញុំបានមួយឆ្នាំ រឺពីរឆ្នាំ រឺបីឆ្នាំ។ តែនៅទីបំផុតខ្ញុំនៅតែដណ្តើមយកបានដដែល ។ពេលនេះខ្ញុំដឹងថាលោកបានចងសំព័ន្ធភាពជាមួយពួកវា តែសំព័ន្ធភាពនេះមិនមានតំលៃប៉ុនអាច់សេះមួយពែងផងទេ។ ម៉េច តើលោកមានចំលើយយ៉ាងណាដែរ ? របស់ដែលត្រូវបានគឺធំធេងណាស់ ។ ដំបូងគឺ *ក្វាន់តូ* ហើយនេះជារបស់លោក។ បន្ទាប់មកខ្ញុំយកជប៉ុនទាំងមូល ។ រួចកូរ៉េ ។ អានេះងាយទេ ។ រួចស្រុកចិន ។ នេះយ៉ាប់តែទៅរួច ។ អីលូវនេះ ដល់ពេលសំរេចហើយ ។ តើចំលើយរបស់លោកយ៉ាងម៉េចដែរ *យ៉ូស៊ី តូរ៉ាណាកា-ណូ-មីណូវ៉ារ៉ា* ជាអណ្តាប់ រឺ អត់ ?

- បើអញ្ចឹង យើងនោមជាមួយគ្នា ។

*តូរ៉ាណាកា* ឆ្លើយ ដោយថាអ្វីៗដែលលោកចង់បាន និងមានផែនការជាយូរមកហើយនោះបានសំរេចហើយ ។

ហើយនៅវេលាស្អែកឡើង នៅចំពោះភាពស្រលាំកាំងរបស់ពួក *ដៃមីញ៉ូ* ទាំងអស់ *តូរ៉ាណាកា* បានប្រគល់ជូនយ៉ាងរាបសារនូវដាវ ដី កិត្តិយស កេរអាករទាំងអស់របស់ខ្លួនជូនទៅ *ណាកាមូរ៉ា* ។បានទទួលយកនូវជំនូននេះ ហើយបានប្រកាសផ្តល់តំបន់ *ក្វាន់តូ* ដល់រូបលោកទៅពេលណាដែលប្រាមប្រាបបានហើយទន្ទឹមនឹងប្រកាសធ្វើសង្គ្រាមទាំងស្រុងនឹងពួក *របក្ខ* ដែលហ៊ានប្រមាថព្រះចៅអធិរាជ ។ លោក *ណាកាមូរ៉ា* ក៏បានជូនមកលោកវិញនូវដាវដែលលោកទើបយកចេញពីឃ្លាំងព្រះរាជទ្រព្យផងដែរ ។ នោះគឺជាដាវដែលធ្វើដោយកំពូលជាងស្មិតដាវ *មីយ៉ូស៊ី-កូ* កាលពីប៉ុន្មានសតវត្សមុនមកម្ល៉េះ ហើយដែលជាកម្មសិទ្ធិរបស់យុទ្ធជនដ៏ល្បីល្បាញបំផុតក្នុងប្រវត្តិសាស្ត្រ គឺ *មីណូវ៉ារ៉ា យ៉ូស៊ីតូម៉ូ* ដែលជាអគ្គមហាសេនាដំបូងបង្អស់នៃត្រកូល *មីណូវ៉ារ៉ា*។

*តូរ៉ាណាកា* នៅចាំច្បាស់ណាស់ថ្ងៃនោះ ។ ហើយលោកក៏ចាំពីថ្ងៃផ្សេងៗទៀតដែរ ។ ប៉ុន្មានឆ្នាំក្រោយមកទៀតពេលដែលជំទាវ *អូជីបា* កើតបានកូនប្រុស ។ និងថ្ងៃមួយទៀត នៅក្រោយពេលដែលកូនប្រុសទីមួយរបស់លោកម្ចាស់ *កៃគូ* ទទួលមរណភាពយ៉ាងមិនគួរអោយជឿនោះមក កូនប្រុសទីពីរគឺ *យែខមុ៊ន* បានចាប់កំណើត ។ ហើយផែនការទាំងប៉ុន្មានក៏ត្រូវរលាយសាប



www.budinst.gov.kh www.elibraryofcambodia.org

សូន្យទៅ ។ ចំជា *កាទ៉ា* មែន ។

ពេលនេះលោកសំលឹងមើល *យ៉ាកូ* កាន់ដាវបុព្វបុរសខ្លួន ដោយទឹកចិត្តគោរពយ៉ាងជ្រាលជ្រៅ ។

*យ៉ាកូ* សួរឡើង :

- តើដាវនេះពិតជាមុតដូចគេថាមែនទេ ?

- ពិតមែន ។

- លោកម្ចាស់បានផ្តល់កិត្តិយសធំធេងណាស់មកដល់ខ្ញុំ ។ ខ្ញុំនឹងថ្នាក់ថ្នមអំនោយលោកម្ចាស់អោយដូចជាកែវភ្នែកខ្ញុំ ។

*យ៉ាកូ* លំអោនក្បាលគោរព *តូរ៉ាណាកា* ភ្លាម ដោយគេយល់យ៉ាងច្បាស់ណាស់ថាតាមរយៈអំនោយនេះ គេគឺជាមនុស្សទីពីរ បន្ទាប់ពី *តូរ៉ាណាកា* ហើយនៅលើដែនដីនេះ ។

*តូរ៉ាណាកា* លំអោនខ្លួនគោរពតបវិញ ហើយដើរតំរង់ទៅរកជណ្តើរទូកធំ ។ លោកត្រូវប្រើអស់នូវកំលាំងចិត្តរបស់លោក ដើម្បីលាក់កំហឹងដែលកំពុងពុះពោរនៅក្នុងខ្លួនលោកនិងដើម្បីរក្សាល់និងជើងលោកអោយបានស្ងើដដែល ។ នៅក្នុងដួងចិត្តលោក១បន់ស្រន់អោយចិត្តលោកលន់របស់ *យ៉ាកូ* នៅគ្រប់ចិត្តគំនិតគេបានមួយស្របក់ទៀត ។

- ចេញដំណើរ !

*តូរ៉ាណាកា* ចេញបញ្ជានៅពេលដែលជើងរបស់លោកជាន់លើក្តារទូកធំភ្លាម ។ រួចលោកបែរទៅរកច្រាំង ហើយបក់ដៃលាយ៉ាងរីករាយ ។

សំលេងបុរសម្នាក់បានស្រែកជ័យឃោសន៍ឈ្មោះរបស់លោកឡើង ហើយអ្នកឯទៀតក៏បានបំបែកភាពស្ងៀមស្ងាត់ដោយបន្ទរឡើងតាម ។ នោះគឺជាសំលេងគាំទ្ររបស់សមូហភាពចំពោះកិត្តិយសដែលម្ចាស់របស់គេទើបទទួលបាន អំបាញ់មិញនេះ ។

ខ្ទាន់ច្រវាចាប់អុំឡើងយ៉ាងខ្ទឹត ហើយទូកក៏ចេញដំណើរបន្តិចម្តង១ទៅរកសមុទ្រ ។

- លោកមេបញ្ជាការ ចេញដំណើរទៅ *យេដូ* ជាបន្ទាន់ !

- បាទ ទាន ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* បែរសំលឹងមើលទៅច្រាំង តែគកលោកវេរ៉ៃពិនិត្យមើលតាមឆ្នេរ ។ គ្រោះថ្នាក់អាចលេចចេញមកនៅគ្រប់ពេលវេលា ។ *យ៉ាប៊ូ* នៅឈរក្បែរទំនប់រលក អារម្មណ៍នៅជិតជាប់នឹងដាវនៅឡើយ ។ *ម៉ារីកូ* និង *ភូជីកូ* នៅឈរក្បែរដំបូលក្រណាត់ជាមួយនារី១ឯទៀត ។ *អាន់ជីន-សាន* នៅឈរឯជាយទីធ្លាភូមិ ដែលគេបានប្រាប់អោយរង់ចាំនៅទីនោះប្រកបដោយអាកប្បកិរិយាក្តៅក្រហាយ ។ តែគកអ្នកទាំងពីរបានប៉ះប្រទះគ្នា ហើយ *តូរ៉ាណាកា* ក៏ញញឹមដាក់ព្រមទាំងលើកដៃជាសញ្ញាលាគ្នាផង ។

*ប្លាក់ថន* លើកដៃតបវិញតែក្នុងអាការៈដ៏ត្រជាក់ស្រឹប ហើយកាយវិការនេះធ្វើអោយ *តូរ៉ាណាកា* សែនអស់សំណើចជាពន់ពេក ។

*****************



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* ដើរតំរង់ទាំងមួម៉ងទៅរកទំនប់រលក ៖

- អង្កាល់ទើបគាត់ត្រលប់មកវិញ *ម៉ារីកូ-សាន* ?

- ខ្ញុំមិនដឹងដែរ *អាន់ជីន-សាន*។

- បើអញ្ចឹងយើងធ្វើម៉េចបានទៅដល់ *យេដូ* កើតទៅ ?

- ពួកយើងនៅទីនេះសិន ។ ចំពោះខ្ញុំៗនៅទីនេះបីថ្ងៃ ហើយទើបខ្ញុំត្រូវទៅ *យេដូ* ។

- ទៅតាមសមុទ្រអ្វី ?

- ទៅតាមផ្លូវគោក ។

- ចុះខ្ញុំ ?

- លោកត្រូវនៅទីនេះ ។

- ហេតុអីទៅ ?

- លោកបាននិយាយថាលោកចង់ចេះភាសាពួកយើង ហើយម្យ៉ាងទៀតលោកមានកិច្ចការដែលត្រូវធ្វើនៅទីនេះផង ។

- កិច្ចការអីទៅ ?

- ខ្ញុំមិនដឹងដែរ អោយខ្ញុំសូមទោសផងចុះ ។ លោកម្ចាស់ *យ៉ាប៊ូ* នឹងនិយាយប្រាប់លោកពីកិច្ចការនេះ ។ លោកម្ចាស់ខ្ញុំអោយខ្ញុំនៅទីនេះដើម្បីបកប្រែចំនួនបីថ្ងៃតែប៉ុណ្ណោះ ។

នៅក្នុងអារម្មណ៍របស់ *ប្លាក់ថន* គឺពោរពេញដោយប្រផ្នូលមិនល្អសោះតែម្តង ។ កាំភ្លើងខ្លីទាំងគូនៅសៀតនឹងចង្កេះគេដដែលទេ ប៉ុន្តែគេគ្មានកាំបិត គ្មានរំសេវ ហើយនឹងគ្មានសល់គ្រាប់អ្វីទាំងអស់ ។ របស់ទាំងនេះស្ថិតនៅលើទូកទាំងអស់ ។ គេសួរបន្ត ៖

- ហេតុអ្វីក៏នាងមិនប្រាប់ខ្ញុំអោយបានដឹងជាមុនផងថាពួកយើងត្រូវស្ថិតនៅទីនេះ ? នាងគ្រាន់តែប្រាប់ខ្ញុំថាអោយឡើងគោកតែប៉ុណ្ណោះ ទេតើ ។

*ម៉ារីកូ* តប ៖

- ខ្ញុំក៏មិនដឹងថាលោកត្រូវស្ថិតនៅទីនេះផងដែរទេ ។ លោកម្ចាស់ *តូរ៉ាណាកា* ទើបប្រាប់ខ្ញុំអំបាញ់មិញនៅឯទីផ្លាភូមិ តែប៉ុណ្ណោះ ។



www.budinst.gov.kh www.elibraryofcambodia.org

- អញ្ចឹងម៉េចគាត់មិនប្រាប់ខ្ញុំផ្ទាល់ខ្លួនគាត់តែម្តងទៅ ?

- ចាស ខ្ញុំមិនដឹងដែរ ។

- ខ្ញុំមានផែនការត្រូវទៅ *យេដូ*។ ព្រោះក្រុមនាវិកខ្ញុំនៅទីនោះ ។ ព្រោះសំពៅខ្ញុំនៅទីនោះ ។ តើពួកនោះទៅជាយ៉ាងម៉េចទៅ ?

- លោកម្ចាស់គ្រាន់តែមានប្រសាសន៍ថា លោកត្រូវនៅទីនេះតែប៉ុណ្ណឹង ។

- នៅប៉ុន្មានពេលទៅ ?

- គាត់ឥតបានប្រាប់ខ្ញុំទេ *អាន់ជីន-សាន*។ ប្រហែលលោកម្ចាស់ *យ៉ាប៊ូ* ដឹងមើលទៅ។ សូមអត់ធ្មត់បន្តិចទៅ *អាន់ជីន-សាន*។

*ប្លាក់ថន* នៅមើលឃើញរូប *តូរ៉ាណាកា* ឈរនៅផ្នែកខាងក្រោយសំពៅសំលឹងមើលមកច្រាំងដដែលនៅឡើយ ។

- ខ្ញុំគិតថាគាត់ដឹងតាំងពីដើមទីមកហើយថាខ្ញុំត្រូវនៅទីនេះ មែនទេ ?

*ម៉ារីកូ* ឥតមានឆ្លើយតបនឹងសំនួរនេះទេ។ ចំជាមិនដឹងអីមែន -នាងគិតនៅក្នុងចិត្ត - អ្នកណាដែលនិយាយពីអ្វីដែលខ្លួនគិតនៅក្នុងចិត្តយ៉ាងនេះ។ ទន្ទឹមនេះ នាងកោតប្រាជ្ញាវាងវៃរបស់ *តូរ៉ាណាកា* ដែលអាចគេចរួចពីអន្ទាក់នេះបាន ។

*ប្លាក់ថន* នៅតែរន្ថើនសួរ :

- មែនទេ ? មែនទេ ?

- ថាម៉េច ? អូ សូមទោស ចាស ។ ខ្ញុំមិនដឹងទេ *អាន់ជីន-សាន*។ អ្វីដែលខ្ញុំជំរាបលោកបាន គឺលោកម្ចាស់ *តូរ៉ាណាកា* ជាមនុស្សមានប្រាជ្ញាវាងវៃណាស់ ។ វាងវៃលើសមនុស្សទាំងអស់ ។ហេតុនេះទោះគាត់មានមូលហេតុអ្វីក៏ដោយ គឺប្រាកដជាមូលហេតុល្អជាមិនខាន ។

នាងសំលឹងមើលភ្នែកខៀវ និងមុខដ៏រឹងមាំរបស់ *ប្លាក់ថន* នៅក្នុងចិត្តនាងៗយល់ច្បាស់ណាស់ថា *ប្លាក់ថន* មិនអាចយល់បានពីអ្វីដែលបានកើតឡើងនៅកន្លែងនេះទេ ។ នាងបន្ត :

- សូមអត់ធ្មត់សិនចុះ *អាន់ជីន-សាន*។ គ្មានរឿងអ្វីដែលត្រូវខ្លាចនោះឡើយ ។ លោកជាអណ្តាប់ដែលលោកម្ចាស់ពេញចិត្តជាងគេបំផុត ហើយនៅក្រោមការ.........



www.budinst.gov.kh www.elibraryofcambodia.org

- មិនមែនខ្ញុំខ្លាចទេ *ម៉ារីកូ-សាន*។ តែខ្ញុំធ្លាប់ឮរឿងឈាយណាស់ដែលគេនាំបណ្ដើរស្រេចតែចិត្តដូចកូនអុកនោះ ។ ហើយខ្ញុំមិនមែនជាអណ្ដាប់របស់អ្នកណាទាំងអស់ ។

- បើអញ្ចឹងប្រើពាក្យថា " អ្នកសំនព្វ " វិញ ? រីលោកប្រើពាក្យយ៉ាងម៉េចដើម្បីហៅអ្នកណាម្នាក់ដែលធ្វើការសំរាប់អ្នកណាម្នាក់ រី ក៏នៅជាមួយអ្នកណាម្នាក់សំរាប់........

និយាយបានត្រឹមនេះ *ម៉ារីកូ* ឈប់មំក់ដោយឃើញមុខ *យ៉ាប៊ូ* ឡើងក្រហមងាំង :

- កាំភ្លើង ! កាំភ្លើងនៅលើទូកនៅឡើយ ! *យ៉ាប៊ូ* ស្រែកភ្ញាត់សំលេង ។

ពេលនេះ *ម៉ារីកូ* ដឹងថាជាពេលដែលនាងត្រូវដើរតួហើយ ។ នៅពេលដែល *យ៉ាប៊ូ* ងាកប្រុងស្រែកអោយបញ្ជាទៅ *អ៊ីគូរ៉ាជី* នោះ នាងបានស្ទុះទៅយ៉ាងប្រញាប់ទៅក្បែរ ហើយនិយាយកាត់មុនភ្លាម :

- សូមលោកម្ចាស់អាធ្យាស្រ័យអោយនាងខ្ញុំផងចុះ ។ លោកម្ចាស់មិនចាំបាច់ខ្វល់ខ្វាយពីរឿងកាំភ្លើងលោកម្ចាស់នោះឡើយ ។ លោកម្ចាស់ *តូរ៉ាណាកា* បានប្រាប់អោយនាងខ្ញុំសូមលោកម្ចាស់អភ័យទោសផងទៅចុះ ចំពោះភាពប្រញាប់ប្រញាល់នេះ ប៉ុន្តែលោកមានការងារបន្ទាន់ដែលលោកត្រូវបំពេញ ក្នុងនាមរួមគ្នាជាមួយលោកម្ចាស់ផងនៅឯ *យេដូ* ។ លោកបានអោយនាងខ្ញុំជំរាបលោកម្ចាស់ផងដែរថាលោកនឹងបញ្ជូនទូកមកវិញភ្លាមនៅពេលទៅដល់ *យេដូ*។ បញ្ជូនទាំងកាំភ្លើងទាំងអស់ ចាស ។ ហើយលោកនឹងបញ្ជូនទូវសេរ មកជូនលោកម្ចាស់បន្ថែមទៀតផង ។ មិនតែប៉ុណ្ណោះ លោកនឹងបញ្ជូនមនុស្សទាំងពីររយហាសិបនាក់ដែលលោកម្ចាស់បានស្នើនោះមកជាមួយទូកនេះ ។ ទាំងអស់នេះនឹងមកដល់ទីនេះក្នុងរង្វង់ប្រហែលប្រាំ រីប្រាំមួយថ្ងៃនេះឯង ។

*ម៉ារីកូ* ធ្វើការពន្យល់យ៉ាងអត់ធ្មត់ និងយ៉ាងរាបសារដល់ *យ៉ាប៊ូ* តាមការណែនាំរបស់ *តូរ៉ាណាកា* ។ នៅពេលដែល *យ៉ាប៊ូ* យល់ពីសភាពការណ៍ហើយ នាងយកសារមួយរមូរពីក្នុងដៃអាវនាងដោយពោលថា :

- លោកម្ចាស់នាងខ្ញុំ សូមលោកម្ចាស់មេត្តាអានសារនេះ ចាស ។ នេះជាសារទាក់ទិននឹង *អាន់ជីន-សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

និយាយរួចនាងក៏លំអោនខ្លួនប្រគល់សារនោះជូនទៅ *យ៉ាប៊ូ* ។ ប៉ុន្តែ *យ៉ាប៊ូ* មិនបាន ទទួលយកសារនោះទេ។ ភ្នែកគេតាមសំលឹងមើលទូកធំដែលពេលនេះបានរសាត់ទៅឆ្ងាយណាស់ ទៅហើយ។ តែមិនបញ្ហាទេ -គេគិតនៅក្នុងចិត្ត។ អញនឹងបានកាំភ្លើងវិញនៅក្នុងពេលដ៏ខ្លីខាង មុខនេះ ហើយពេលនេះអញក៏បានចេញផុតពីអង្គប់របស់ *អ៊ីស៊ីវ្ហ* ហើយដែរ មិនតែប៉ុននោះអញ ថែមទាំងបានដាវ ដ៏ល្បីល្បាញបំផុតរបស់ *តូរ៉ាណាកា* មកនៅក្នុងដៃអញទៀត។ ហើយមិនយូរ ប៉ុន្មាន *វ៉ៃមីញ៉ូ* ទូទាំងប្រទេសនឹងដឹងពីឋានៈថ្មីរបស់អញនៅក្នុងកងទ័ពបូពា គឺមនុស្សទីពីរបន្ទាប់ ពី *តូរ៉ាណាកា* ! *យ៉ាប៊ូ* នៅមើលឃើញរូបរាងកាយរបស់ *តូរ៉ាណាកា* ពីចំងាយនៅឡើយ គេ លើកដៃជាសញ្ញាទៅរក ហើយ *តូរ៉ាណាកា* ក៏លើកដៃបក់មកវិញរួចទើបលោកដើរចូលកិងកន្សៃ ទូកបាត់ទៅ។

បន្ទាប់នោះទើប *យ៉ាប៊ូ* ទទួលយកសារនោះមក ហើយផ្ដោតអារម្មណ៍លើបច្ចុប្បន្នភាព និងលើ *អាន់ជីន-សាន* វិញម្ដង។

*ប្លាក់ថន* នៅឈរសំលឹងមើលអ្នកទាំងពីរចំងាយប្រហែលសាមសិបជំហានពីគ្នា ។ គេ មានអារម្មណ៍មួម៉ៅយ៉ាងខ្លាំងនៅពេលដែលគេឃើញក្រសែភ្នែក *យ៉ាប៊ូ* សំលឹងមើលគេមិនដាក់ ភ្នែកនោះ។ ថ្វីត្បិតតែគេលឺសំលេង *ម៉ារីកូ* និយាយក្នុងភាពដ៏ស្រទន់ និងដ៏ពិរោះយ៉ាងណាក្ដីក៏គេ ហាក់មិនទុកចិត្តសោះ។ ដៃរបស់គេក្ដាប់ណែនដងកាំភ្លើងខ្លី។ សំលេង *ម៉ារីកូ* លាន់លឺឡើង :

- *អាន់ជីន-សាន* ! សូមលោកអញ្ជើញមកទីនេះមួយភ្លែតបានទេ ?

នៅពេលដែល *ប្លាក់ថន* ដើរចូលមក *យ៉ាប៊ូ* អានសារមួយគ្រួសដោយងក់ក្បាលជាការ ពេញចិត្តផង។ នៅពេលអានរួច *យ៉ាប៊ូ* ហុចសារទៅ *ម៉ារីកូ* វិញ ហើយនិយាយយ៉ាងខ្លីមួយភាគ ទៅ *ម៉ារីកូ* មួយភាគទៅ *ប្លាក់ថន* ។

*ម៉ារីកូ* ប្រគល់សារយ៉ាងគោរពទៅអោយ *ប្លាក់ថន* ។ គេទទួលយកហើយពិនិត្យមើល អក្សរក្រវែមក្រវាមទាំងនោះនៅនឹងថ្ងាស ។

*ម៉ារីកូ* និយាយពន្យល់ :

- លោកម្ចាស់ *យ៉ាប៊ូ* មានប្រសាសន៍ថាលោកសូមស្វាគមន៍លោកទៅក្នុងភូមិនេះ សារ



www.budinst.gov.kh www.elibraryofcambodia.org

នេះគឺជាសារដែលមានត្រាសំគាល់របស់លោកម្ចាស់ *តូរ៉ាណាកា* ណា *អាន់ជីន-សាន*។ លោកត្រូវរក្សាវាអោយបានជាប់ ។ លោកម្ចាស់បានផ្តល់កិត្តិយសដ៏កំរមួយជូនលោកហើយ ។ លោកម្ចាស់ *តូរ៉ាណាកា* បានតែងតាំងលោកជា *ហាតាម៉ូតូ*។ នេះគឺជាតួនាទីរបស់មនុស្សសំនព្វពិសេសក្នុងអ្នកហែហមលោកទាំងអស់ ។លោកស្ថិតនៅក្រោមកិច្ចគាំពារទាំងស្រុងរបស់លោកម្ចាស់ *តូរ៉ាណាកា*។ ជាការពិតហើយ លោកម្ចាស់ *យ៉ាប៊ូ* ទទួលដឹងលឺពីរឿងនេះ ។ នៅពេលក្រោយទៀតខ្ញុំនឹងពន្យល់លោកពីបុព្វសិទ្ធិនៃឋានៈនេះ តែខ្ញុំគ្រាន់តែជំរាបពេលនេះថាលោកម្ចាស់ *តូរ៉ាណាកា* បានជូនប្រាក់បំនាច់លោកក្នុងមួយខែម្តៃ *កូតូ* ។ នេះជារឿង.....

*យ៉ាប៊ូ* និយាយកាត់នាងបណ្តើរដោយធ្វើកាយវិការបណ្តើរចង្អុលទៅ *ប្លាក់ថន* រួចមកចង្អុលទៅរកភូមិ ។

*ម៉ារីកូ* បក :

- លោកម្ចាស់ *យ៉ាប៊ូ* មានប្រសាសន៍ស្វាគមន៍លោកម្តងទៀតនៅទីនេះ ។ លោកសង្ឃឹមថាអ្វីៗនឹងត្រូវរៀបចំបានគ្រប់គ្រាន់ដើម្បីធានាអោយលោកស្នាក់នៅប្រកបដោយផាសុខភាព ។ គេនឹងប្រគល់ផ្ទះមួយជូនលោកស្នាក់នៅ ។ គេនឹងរកគ្រូៗមកបង្រៀនលោក ។ លោកមានប្រសាសន៍ថា សូមលោកខិតខំរៀនភាសាជប៉ុនអោយបានឆាប់ចេះជាទីបំផុត ។ នៅយប់នេះលោកនឹងសាកសួរសំនួរខ្លះដល់លោកហើយនឹងជំរាបលោកពីការងារពិសេសខ្លះ ។

- សូមលោកស្រីសួរគាត់ទៅមើលថាការងារស្អីទៅ ?

- ខ្ញុំសូមលោករក្សាភាពអត់ធ្មត់បន្តិចទៅមើល *អាន់ជីន-សាន*។ ពេលនេះមិនមែនជាពេលដែលត្រូវសួរទេ។

- អញ្ចឹងក៏បាន ។

- *វ៉ាការីម៉ាស៊ី កា អាន់ជីន-សាន ? -យ៉ាប៊ូ* និយាយ ។ លោកយល់ទេ ។

- *វៃហ យ៉ាប៊ូ-សាន* ។ *ដូម៉ូ* ។

*យ៉ាប៊ូ* បញ្ជាអោយ *អ៊ីកូរ៉ាជី* រំសាយទ័ពហើយក៏រលះរលាំងដើរតំរង់ទៅរកអ្នកភូមិដែលកំពុងក្រាបក្រញោននៅលើឆ្នេរខ្សាច់នៅឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅទីនោះ *យ៉ាប៊ូ* ឈរនៅពីមុខអ្នកភូមិហើយនិយាយក្នុងសំដីម៉ាត់ៗស្ទើរដាច់សាច់ព្រមទាំងលើកដាវដែល *តូរ៉ាណាកា* ទើបប្រគល់អោយនោះចង្អុលតំរង់ទៅ *ប្លាក់ថន* ផង។ ក្រោយពីបាននិយាយបំផុសអ្នកស្រុកបន្តិចមក គេក៏បញ្ចប់សេចក្តីរបស់គេយ៉ាងកំបុត។ ភាពរន្ធត់ញាប់ញ័រមួយបានមកសណ្ឋិតក្នុងអ្នកភូមិគ្រប់ៗរូប។ *មូរ៉ា* លំអោនខ្លួនហើយពោលពាក្យ " *វ៉ៃ* " ជាច្រើនដងទៅរក *ប្លាក់ថន* ។

" *វ៉ាការីម៉ាស៊ី កា* ? " *មូរ៉ា* ស្រែកសួរទៅអ្នកភូមិ ហើយអ្នកទាំងអស់ក៏ស្រែកតបវិញ " *វ៉ៃ* "។ សំរែកគេលាន់លាយឡំនឹងសំលេងរលកដែលបក់បោកមកលើឆ្នេរខ្សាច់។

" មានរឿងអីណឹង ? " *ប្លាក់ថន* សួរទៅ *ម៉ារីកូ* ប៉ុន្តែពេលនោះ *មូរ៉ា* ស្រែកបញ្ជាឡើង ហើយអ្នកភូមិទាំងអស់ក៏លំអោនខ្លួនយ៉ាងទាបគោរព *យ៉ាប៊ូ* ម្តង និង គោរព *ប្លាក់ថន* ម្តង។ រួចហើយ *យ៉ាប៊ូ* ក៏ដើរយ៉ាងប្រញាប់ប្រញាល់ចេញទៅដោយឥតងាកត្រលប់មើលក្រោយវិញឡើយ។

- មានរឿងអីណឹង *ម៉ារីកូ-សាន* ?

- លោកម្ចាស់ *យ៉ាប៊ូ* ប្រាប់អ្នកភូមិទាំងអស់គ្នាថាលោកគឺជាភ្ញៀវកិត្តិយសរបស់គាត់។ ហើយថាលោកក៏ជាមនុស្សសំនព្វចិត្តរបស់លោកម្ចាស់ *តូរ៉ាណាកា* ផងដែរ។ ថាលោកមកទីនេះដើម្បីរៀនភាសារបស់យើង ហេតុនេះលោកប្រគល់អោយអ្នកភូមិទាំងអស់នេះទទួលនូវកិត្តិយស និងការទទួលខុសត្រូវក្នុងការបង្រៀនលោក។ ភូមិទាំងមូលទទួលខុសត្រូវណា *អាន់ជីន-សាន*។ អ្នកភូមិគ្រប់ៗរូបត្រូវតែជួយបង្រៀនលោក។ លោកបាននិយាយថាបើសិនជាក្នុងប្រាំមួយខែការរៀនរបស់លោកមិនបានគួរជាទីពេញចិត្តទេនោះ ភូមិទាំងមូលនឹងត្រូវដុតកំទេចចោល ហើយអ្នកភូមិទាំងអស់ ទាំងប្រុស ទាំងស្រី ទាំងកុមារាកុមារីទាំងអស់ នឹងត្រូវសំលាប់លើឈើឆ្កាង។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក៣១

ព្រះសុរិយាកំពុងហៀបអស្តង្គតជះស្រមោលអោយអូសអន្លាយ ប្រែទឹកសមុទ្រអោយប្រែពណ៌ក្រហមច្រាល ។ វាយោបក់រំភើយៗ ។

*ភ្នាក់ថន* ដើរកាត់តាមផ្លូវដែលចេញពីភូមិសំដៅទៅរកផ្ទះមួយដែលមុននេះ *ម៉ារីកូ* បានប្រាប់ថាជាទីកន្លែងដែលគេត្រូវស្នាក់នៅនោះ ។ នាងមានបំនងចង់ជូនរូបគេទៅដល់ផ្ទះនោះដែរ ប៉ុន្តែ *ភ្នាក់ថន* បានប្រកែក ហើយក៏ដើរតែម្នាក់ឯងតំរង់ទៅជ្រោយខ្ពស់មួយដើម្បីពិចារណា ។

ប៉ុន្តែគេបានឃើញថា ការប្រឹងគិតនេះ ពិតជាការប្រឹងប្រែងមួយធំធេងពេកណាស់ចំពោះរូបគេ ។ អ្វីៗទាំងអស់ហាក់ដូចជាមិនស៊ីគ្នាសោះ ។ គេប្រឹងក្បង់ទឹកមកស្រោចក្បាលក្រែងលោថ្វាត់និតខ្លះ ប៉ុន្តែនៅតែអត់បានផលដដែល ។ នៅទីបំផុត ដោយទ័លចំនេះ គេក៏ដើរត្រលប់ក្រោយដោយគ្មានទិសដៅសរសៀរតាមបណ្តោយឆ្នេរ បង្ហួសទំនប់រលក ទីវាល និង ភូមិរហូតទៅដល់ផ្ទះដែលគេស្នាក់នៅ ។ នៅឯលើភ្នំទល់មុខ មានផ្ទះរកេតរកូតមួយចំនួន ខ្លះប្រក់ស្បូវ ខ្លះប្រក់ក្បឿងហ៊ុមព័ទ្ធដោយរបងចរឹងយ៉ាងខ្ពស់ ហើយដែលមានឆ្នាំយ៉ាងច្រើនទៅឈរយាមមាត់ច្រកចូលដ៏រឹងមាំមួយ ។

នៅក្នុងភូមិ ពួកសាមូរ៉ៃដើរសំញែង រឺក៏នៅជជែកគ្នាជាក្រុមៗ ។ ខ្លះទៀតដើរប្រកបដោយវិន័យពីក្រោយមេបញ្ជាការខ្លួនសំដៅទៅកន្លែងសំរាក ។ នៅពេលជួបពួកសាមូរ៉ៃទាំងនេះ *ភ្នាក់ថន* បានសំដែងការគួរសមចំពោះពួកគេ ហើយពួកគេក៏បានសំដែងការគួរសមត្រលប់មកវិញដែរ ។ តែ *ភ្នាក់ថន* ឥតប្រទះភ្នែកឃើញអ្នកភូមិណាម្នាក់ឡើយ ។

*ភ្នាក់ថន* ឈប់នៅមាត់ទ្វាររបង ដែលមានតំនួរអក្សរយ៉ាងចំលែកនៅពីលើធ្នឹមទ្វារចូល ។ នេះគឺជាទ្វារដែលត្រូវសាងសង់យ៉ាងប៉ិនប្រសប់សំដៅលាក់ផង បង្ហាញផង នូវសួនច្បារមួយដែលនៅពីខាងក្រោយនោះ ។

ពេលដែល *ភ្នាក់ថន* ហៀបនឹងរុញទ្វារចូល សន្ទឹកទ្វារក៏របើកឡើងហើយបុរសចំនាស់ម្នាក់បានលេចចេញមកគោរពគេទាំងញ័រចំប្រប់ :

- *កូនបានរ៉ា អាន់ជីន-សាន* -សំលេងតាចាស់ញ័រៗគួរអោយអាណិត- រាត្រីសួស្តី ។



www.budinst.gov.kh www.elibraryofcambodia.org

- *កូនបានវ៉ា -ប្លាក់ថន* តប -តា....អឺ....*អូ ណាមេអេ កា?*

- *ណាម៉ាអេ វ៉ាតាស៊ីវ៉ា អាន់ជីន-សាម៉ា?* អូហ៍ ! *វ៉ាតាស៊ី អ៊ូឃីគី-យ៉ា...អ៊ូឃីគី-យ៉ា*។

តាចាស់ស្ទើរផើតជើងពីដីដោយធូរទ្រូងសន្ធឹក ។

*ប្លាក់ថន* ទន្ទេញឈ្មោះដើម្បីកុំអោយភ្លេច ដោយថែមទាំងពាក្យ *សាន* ពីក្រោយផង ប៉ុន្តែតាចាស់គ្រវីក្បាលប្រកែកស្ទើរដាច់ :

- *អ៊ីយេ ! កូម៉ីនណាសៃ! អ៊ីយេ "សាន" អាន់ជីន-សាម៉ា -យ៉ា ! អ៊ូគីឃី -យ៉ា !*

- អញ្ចឹងក៏បាន *អ៊ូគីឃី -យ៉ា* !

ទោះជានិយាយយ៉ាងនេះក្តីក៏ *ប្លាក់ថន* នៅតែងឿងឆ្ងល់ក្នុងចិត្តថាហេតុអីបានមិនដាក់ "*សាន*" ដូចអ្នកឯទៀតផងទៅ ? គេលើកដៃធ្វើសញ្ញាអោយតាចាស់ដកខ្លួនថយ ។ តាចាស់ដកខ្លួនថយទាំងក្នុងដំណើរបុំងខ្មើច ។

អញត្រូវតែប្រយ័ត្នប្រយែងអោយបានច្រើនជាងមុន។ អញត្រូវតែជួយពួកគេ *-ប្លាក់ថន* និយាយតែម្នាក់ឯង ។

នារីបំរើម្នាក់បង្ហាញខ្លួនក្រោមសំយាបផ្ទះទាំងភាពភ័យខ្លាច ហើយលំអោនខ្លួនគោរព យ៉ាងទាប :

- *កូនបានវ៉ា អាន់ជីន-សាន !*

- *កូនបានវ៉ា !*

*ប្លាក់ថន* ឆ្លើយតបដោយចាំព្រាលៗថាធ្លាប់ឃើញនាងនៅលើទូកធំដែរ ។ គេលើកដៃធ្វើសញ្ញាអោយនាងថយទៅវិញ ។ ស្នូរស្វូតលាន់ស្រៀវស្រោក ។ *ភូជីកូ* លេចខ្លួនពីក្នុងផ្ទះ ដោយមានវត្តមាន *ម៉ារីកូ* ជាមួយដែរ ។

- ដើរកំសាន្តសប្បាយទេ *អាន់ជីន-សាន?*

- បាទ សប្បាយ *ម៉ារីកូ-សាន -ប្លាក់ថន* ឆ្លើយដោយឥតយកចិត្តទុកដាក់លើរូបនាង លើរូប *ភូជីកូ* លើផ្ទះ រឺ លើសួនច្បារឡើយ ។

- លោកត្រូវការតែទេ ? រឺ ត្រូវការ *សាកេ* ? រឺ ត្រូវការមុជទឹក ? ទាន់ទឹកនៅកំពុង



www.budinst.gov.kh www.elibraryofcambodia.org

ក្តៅ ចាស!

*ម៉ារីគូ* បញ្ចេញសំនើចទាំងរសាប់រសល់នៅចំពោះក្រសែភ្នែករបស់ *ភ្លាក់ថន* ហើយពោលបន្ត :

- បន្ទប់ទឹកមិនទាន់ធ្វើហើយស្រួលបួលនៅឡើយទេ ប៉ុន្តែពួកយើងសង្ឃឹមថាលោកនឹងពេញចិត្ត ។

- *សាកេ* ។ ណើងហើយ ដំបូងបង្អស់សុំ *សាកេ* មកសិន *ម៉ារីគូ-សាន*។

*ម៉ារីគូ* ងាកទៅនិយាយប្រាប់ *ភូជីកូ*។ នាងក៏ដើរចូលទៅក្នុងផ្ទះម្តងទៀត។ នារីអ្នកបំរើយកម៉ក់បីមកដាក់រួចដកខ្លួនចេញទៅវិញយ៉ាងស្ងៀមស្ងាត់។ *ម៉ារីគូ* អង្គុយយ៉ាងសមរម្យលើម៉ក់មួយ :

- សូមអញ្ជើញអង្គុយ *អាន់ជីន-សាន* ។ លោកប្រហែលជានឿយហត់ណាស់ហើយ ។

- អរគុណ ។

*ភ្លាក់ថន* ដាក់បង្គុយលើកាំជណ្តើររានហាលដោយឥតដកស្បែកជើងសង្រែករបស់ខ្លួនឡើយ ។ *ភូជីកូ* លើក *សាកេ* ពីរថូចេញមក ហើយដោយធ្វើតាមការណែនាំរបស់ *ម៉ារីគូ* នោះនាងបានយកពែងតែមកដាក់ស្រាជំនួសកូនពែងប៉ុកសីឡែនតូច១ ដែលគេធ្លាប់ប្រើវិញ ។

កាលនោះ *ម៉ារីគូ* បានពន្យល់ប្រាប់ *ភូជីកូ* ថា :

- យកល្អ បង្អកអោយគាត់ពិសារ *សាកេ* អោយច្រើនទៅ ។ យកល្អធ្វើយ៉ាងណាអោយគាត់ឆាប់ស្រវឹងព្រោះលោកម្ចាស់ *យ៉ាហ្វ៊ូ* ត្រូវការគាត់នៅយប់នេះ ។ ញុំាស្រាហើយទៅមុជទឹកពិតជាធ្វើអោយគាត់បានស្រួលខ្លួនជាមិនខាន ។

*ភ្លាក់ថន* លើកកែវស្រាក្តៅអ៊ុណ្ហ១អកដោយឥតចាំបាច់ចិបភ្លក់មើលឡើយ ។ រួចពែងទីពីរ ។ រួចទីបី ។

នៅពេលដែលគេឡើងតាមចង្កេះភ្នំសំដៅមកផ្ទះនោះ នារីទាំងពីរបានតាមលបសង្កេតមើលអាការៈរបស់ *ភ្លាក់ថន* តាមចន្លោះក្តារជញ្ជាំង ។



www.budinst.gov.kh www.elibraryofcambodia.org

*ភូជីកូ* បានសួរទៅ *ម៉ារីកូ* ទាំងក្ដីបារម្ភ :

- គាត់មានរឿងអីហ្នឹង ?

- គាត់ស្ដុតនឹងអ្វីដែលលោកម្ចាស់ *យ៉ាហ្គូ* បាននិយាយណា៎។ គឺពាក្យសន្យាដែលលោកម្ចាស់ *យ៉ាហ្គូ* នឹងអនុវត្តចំពោះអ្នកភូមិ។

- រួចចុះគាត់ទៅខ្វល់អីរឿងហ្នឹង ? មិនមែនគេគំរាមគាត់ឯណា ? ជីវិតរបស់គាត់មានគ្រោះថ្នាក់ឯណា ?

- ពួកអ្នកចុងស្រុកខុសពីពួកយើង *ភូជីកូ-សាន*។ ជាឧទាហរណ៍ *អាន់ជីន-សាន* យល់ថាអ្នកភូមិក៏ជាមនុស្សដែរ ជាមនុស្សដូចអ្នកឯទៀត ដូចសាមូរ៉ៃ ហើយជួនកាលអាចគ្រាន់បើជាងពួកសាមូរ៉ៃផង។

*ភូជីកូ* លាន់សំនើចទាំងរសាប់រសល់ :

- ចំជាផ្ដាសមែនតែម្ដង *នេ* ? តើធ្វើម៉េចយកពួកសំរែមកផ្ទឹមជាមួយពួកសាមូរ៉ៃបាននោះ ?

*ម៉ារីកូ* ឥតឆ្លើយតប។ នាងពាមសំលឹងមើល *ប្លាក់ថន* ហើយពោលឡើង :

- មនុស្សនេះគួរអោយអាណិតណាស់។

*ភូជីកូ* តបទាំងពេបមាត់ :

- ភូមិកំសត់។ *កាស៊ីគី -យ៉ាហ្គូ* ចំជាឆ្លាតមែន។ តើធ្វើម៉េចអោយមនុស្សចុងស្រុកនេះរៀនភាសាយើងបានតែក្នុងកន្លះឆ្នាំនោះ ? គិតមើល តើមនុស្សចុងស្រុក *ឈូតូ-សាន* រៀនភាសាយើងប៉ុន្មានឆ្នាំទើបចេះ ? ជាងម្ភៃឆ្នាំ *នេ* ? ហើយហ្នឹងគឺជាមនុស្សចុងស្រុកតែម្នាក់គត់ដែលអាចនិយាយភាសាជប៉ុនម៉ាល្មមបានផងនោះ។

- ទេ មិនមែនតែម្នាក់គត់នោះទេ តាមខ្ញុំលឺគេនិយាយ គ្រាន់តែគាត់នោះគ្រាន់បើជាងគេប៉ុននោះ។ ពិតហើយភាសាយើងលំបាកមែនសំរាប់ពួកគេ។ ប៉ុន្តែ *អាន់ជីន-សាន* ជាមនុស្សមានប្រាជ្ញាវៀងវៃ ហើយលោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា ក្នុងអំលុងពេលកន្លះឆ្នាំដោយអត់មានទាក់ទងជាមួយអ្នកចុងស្រុកឯទៀតដោយហូបចុកម្ហូបអាហារយើង រស់នៅរបៀបយើង



www.budinst.gov.kh www.elibraryofcambodia.org

ដឹកតែដូចយើង មុជទឹករាល់ថ្ងៃ *អាន់ជីន-សាន* នឹងក្លាយខ្លួនដូចយើងជាមិនខាន ។

មុខ *ភូជីកូ* ឡើងក្រញូវ :

- មើលគាត់មើល *ម៉ារីកូ-សាន*......ចំជាអាក្រក់សុទ្ធសាធតែម្តង ។ ប្រផេះប្រផង់ខុសគេ ។ តែខ្ញុំដូចជាធ្លាប់ដល់ហើយ ទោះជាខ្ញុំស្អប់ពួកចុងស្រុកយ៉ាងណាក្តី តែនៅពេលគាត់នេះដើរកាត់ខ្លោងទ្វារចូលមក នៅក្នុងចិត្តខ្ញុំ១ទទួលគាត់ជាចៅហ្វាយ ជាម្ចាស់ ស្រេចទៅហើយ ។

- គាត់ជាមនុស្សក្លាហាន ។ ក្លាហានណាស់ *ភូជីកូ*។ ហើយគាត់បានជួយសង្គ្រោះជីវិតលោកម្ចាស់ *តូរ៉ាណាកា* ហើយគាត់មានសារសំខាន់ណាស់ចំពោះលោកម្ចាស់ ។

- ចាស ខ្ញុំដឹងហើយ១រឿងនេះគួរតែបន្ថយចិត្តស្អប់ខ្ពើមរបស់ខ្ញុំ តែហាក់ដូចជាទៅមិនរួចសោះ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំនឹងប្រឹងអស់ពីកំលាំងកាយចិត្តដើម្បីអោយគាត់ក្លាយដូចពួកយើង ។ ខ្ញុំបួងសួងសូមព្រះអង្គលោកជួយខ្ញុំផង ។

នៅពេលនេះ *ម៉ារីកូ* ប្រុងតែសួរក្មួយស្រីរបស់នាងពីបំរែបំរួលដ៏ឆាប់រហ័សនេះ ។ ហេតុអ្វីបានជានៅពេលនេះ នាងត្រៀមខ្លួនទទួលបំរើ *អាន់ជីន-សាន* និងទទួលគោរពទាំងស្រុងតាមបញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* ដែលកាលពីព្រឹកមិញនេះសោះនាងបានប្រកែកមិនធ្វើតាមបញ្ជានេះ ហើយថែមទាំងប្តេជ្ញាធ្វើអត្តឃាតដោយមិនចាំបាច់សុំការអនុញ្ញាត រឺពុំនោះទេនឹងធ្វើឃាតបុរសចុងស្រុកនេះនៅពេលណាដែលគេលង់លក់ក្នុងដំណេកនោះ ? តើលោកម្ចាស់ *តូរ៉ាណាកា* បាននិយាយអ្វីខ្លះដែលអាចអោយនាងផ្លាស់ប្តូរចិត្តបានយ៉ាងនេះទៅ *ភូជីកូ* ?

ប៉ុន្តែ *ម៉ារីកូ* យល់ច្បាស់ណាស់ថាយកល្អនាងមិនត្រូវសួរទេ ។ *តូរ៉ាណាកា* មិនបានប្រាប់រឿងសំងាត់នេះដល់នាងទេ ។ *ភូជីកូ* ពិតជាមិននិយាយអ្វីប្រាប់នាងដែរ ។ *ភូជីកូ* ជានារីម្នាក់ដែលបានទទួលការរៀនសូត្រយ៉ាងម៉ត់ចត់ពីម្តាយនាងដែលត្រូវជាប្អូនស្រីរបស់ *ប៊ុនតារ៉ូ* ហើយដែលបានទទួលការបង្ហាត់បង្រៀនយ៉ាងធ្ងន់ពីឪពុករបស់នាងគឺលោកមេទ័ព *ហ៊ីរ៉ូ-ម៉ាត់ស៊ី* នោះ ។

អញ្ចឹងចង់ដឹងណាស់ថាតើលោកម្ចាស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* អាចគេចខ្លួនពីវិមាន អូសាកា បានដែររឺអត់ -នាងដណ្តឹងសួរនៅក្នុងចិត្ត ទាំងពោរពេញដោយមោទនភាពចំពោះមេទ័ពចំនាស់ដែលត្រូវជាឪពុកក្មេកនាងនេះ ។ហើយតើលោកជំទាវ *គីរី-សាន* និង *សាស៊ូកូ* នឹងទៅជាយ៉ាងណាទៅ?



www.budinst.gov.kh www.elibraryofcambodia.org

រួចចុះ *ប៊ុនតៀវ៉* ប្តីរបស់អញ ? តើគាត់ត្រូវគេចាប់ខ្លួនបានរឺទេ ? រឺមួយគាត់មានពេលគ្រប់គ្រាន់ដើម្បីស្លាប់ ?

*ម៉ារីកូ* សំលឹងមើល *ភូជីកូ* ចាក់បង្ហើយស្រា *សាកេ* និងប្រការដែល *ប្លាក់ថន* យកមកលើកអកដោយគ្មានចាប់អារម្មណ៍អ្វីទាំងអស់ ។

*ប្លាក់ថន* និយាយឡើង :

- *ដូស្ទូ សាកេ*។

*សាកេ* ត្រូវបានយកមកបន្ថែមទៀត ។ ហើយអស់ទៀត ។

- *ដូស្ទូ សាកេ*។

*ភូជីកូ* និយាយ :

- *ម៉ារីកូ-សាន* ! លោកម្ចាស់មិនគួរពិសារទៀតទេ *នេ* ? គាត់នឹងស្រវឹងជាមិនខាន ។ សូមសួរគាត់ទៅមើលតើគាត់ចង់មុជទឹកអីលូវណើងរឺ ? ខ្ញុំនឹងអោយគេទៅហៅ *ស៊ូរ៉ូ* មក ។

*ម៉ារីកូ* សួរទៅ *ប្លាក់ថន* រួចបកប្រាប់វិញ :

- គាត់ថាបន្តិចទៀតទើបមុជ ។

ក្នុងសភាពយ៉ាងអត់ធ្មត់ *ភូជីកូ* បញ្ជាអោយគេយកស្រា *សាកេ* មកទៀត ហើយ *ម៉ារីកូ* ក៏ប្រាប់បន្ថែមទៅអ្នកបំរើ :

- សូមយកត្រីឆ្អើរមកផង ។

ស្រាមួយថូថ្មីត្រូវបានបង្ហើយយ៉ាងក្នុងភាពដាច់ណាត់យ៉ាងស្ងៀមស្ងាត់ដូចមុនៗដែរ ។ គេមិនទាក់អារម្មណ៍នឹងម្ហូបប៉ុន្មានទេ តែដោយមានការបញ្ចុះបញ្ចូលយ៉ាងត្រជាក់ចិត្តរបស់ *ម៉ារីកូ* គេក៏ចាប់យកមួយដុំទៅ ប៉ុន្តែគេមិនទទួលទានវាឡើយ ។

ស្រាពីរថូថ្មីទៀតបានបង្ហើយជាបន្តទៅដែរ ។

*ភូជីកូ* បន្ទឺឡើង :

- សូមជំរាបទៅ *អាន់ជីន-សាន* ថាខ្ញុំសូមទោសផង ដោយថាក្នុងផ្ទះនេះគ្មានសល់ស្រាទៀតទេ ។ ជំរាបគាត់ថាខ្ញុំសូមទោសចំពោះកង្វះខាតនេះ ។ ខ្ញុំនឹងអោយអ្នកបំរើទៅរកស្រាថែម



www.budinst.gov.kh www.elibraryofcambodia.org

ទៀតនៅឯភូមិ ។

- ល្អហើយអញ្ចឹង ។ គាត់ក៏បែបដល់ហើយដែរ ទោះជាពីខាងក្រៅមើលទៅដូចធម្មតា ក្តី ។ នាងគួរទុកអោយពួកយើងនៅតែពីរនាក់ទៅបានទេ ? ពេលនេះគឺជាឱកាសល្អហើយដើម្បីនឹងលើកសំនើទាក់ទិននឹងរូបនាងនោះ ។

*ភូជីកូ* លំអោនខ្លួនគោរព *ប្លាក់ថន* ហើយដកខ្លួនថយទាំងពេញចិត្តចំពោះទំលាប់ដែលចែងថារឿងសំខាន់ៗត្រូវទទួលដោះស្រាយដោយភាគីទីបី ។ ធ្វើបែបនេះកិត្តិយសទាំងសងខាងនៅតែរក្សាបានដដែល ។

*ម៉ារីកូ* និយាយប្រាប់ *ប្លាក់ថន* ពីរឿងស្រា ។

- អង្កាល់ទើបបានស្រា ?

- មិនយូរប៉ុន្មានទេ ។ រឺមួយលោកមុជទឹកអីលូវនេះសិនទៅអ្ហី ? ខ្ញុំនឹងចាត់ចែងបញ្ជូន *សាកេ* ទៅជូនលោកភ្លាមពេលណាគេយកមកដល់ ។

- តើ *តូរ៉ាណាកា* មាននិយាយអីពីរឿងផែនការខ្ញុំមុនពេលគាត់ចេញទៅទេ ? ពីរឿងនាវានោះណាំ ។

- ចាសទេ ។ សូមទោស គាត់គ្មាននិយាយពីរឿងនោះឡើយ ។

*ម៉ារីកូ* តាមសង្កេតមើលយ៉ាងយកចិត្តទុកដាក់នូវសញ្ញានៃភាពស្រវឹង ។ ប៉ុន្តែនាងសែនឆ្ងល់ដោយមិនឃើញសញ្ញាអ្វីប្លែកសោះ សូម្បីតែមុខក្រហម រឺនិយាយត្រដិតអីបន្តិចបន្តួចក៏គ្មានតែម្តង ។ ចំពោះជនជាតិជប៉ុនណាក៏ដោយ ស្រាចំនួនប៉ុនណឹង ហើយផឹកលឿនយ៉ាងណឹងគឺពិតជាស្រវឹងបាត់ទៅហើយ ។

- ស្រាបែបមិនត្រូវមាត់រឺ *អាន់ជីន-សាន* ?

- មិនមែនរឿងណឹងទេ ។គ្រាន់តែវាខ្សោយពេក ។ដាក់ចូលទៅដូចអត់ដឹងអីទាំងអស់ ។

- លោកមានបំនងចង់បំភ្លេចអីរឺ ?

- ទេ ។ ចង់រកដំណោះស្រាយ ។

- អ្វីក៏ដោយដែលអាចជួយលោកបានពិតជានឹងត្រូវធ្វើ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំត្រូវការសៀវភៅ ក្រដាស និង ដងប៉ាកា ។

- ស្អែកខ្ញុំនឹងរកយកមកជូនលោក ។

- ទេ ។ យប់នេះ *ម៉ារីក្វ-សាន*។ ខ្ញុំត្រូវចាប់ផ្តើមអីលូវនេះ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា លោកនឹងបញ្ជូនសៀវភៅ.....លោកហៅសៀវភៅអីអញ្ចេះ ?.....ណើងហើយសៀវភៅវេយ្យាករណ៍ និងសៀវភៅចមិមកជូនលោក ។

- តើអង្កាល់ទើបមកដល់ ?

- ខ្ញុំមិនដឹងដែរ ។ប៉ុន្តែខ្ញុំនឹងនៅទីនេះបីថ្ងៃ ហើយប្រហែលជាខ្ញុំអាចជួយលោកបានខ្លះ។ ហើយ *ក្វជីក្វ-សាន* នឹងនៅទីនេះដើម្បីជួយលោក ។

*ម៉ារីក្វ* ញញឹមរីករាយជំនួស *ប្លាក់ថន*។ នាងបន្តទៀត :

- ខ្ញុំមានកិត្តិយសនឹងជំរាបលោកថានាងត្រូវបានប្រគល់ជូនលោកដើម្បីធ្វើជាស្រីកំនាន់ ហើយនាង......

- **ថាម៉េច ?**

- លោកម្ចាស់ *តូរ៉ាណាកា* បានសួរនាងថាតើនាងយល់ព្រមធ្វើជាស្រីកំនាន់របស់លោកទេ នាងបានជំរាបលោកម្ចាស់វិញថា នាងមានកិត្តិយសណាស់ហើយនាងយល់ព្រម ។ នាងនឹង....

- ប៉ុន្តែខ្ញុំមានយល់ព្រមឯណា ?

- ចាស ? សូមទោស ខ្ញុំមិនយល់ទេ ។

- ខ្ញុំមិនត្រូវការនាងនោះទេ ។ ជាស្រីកំនាន់ក្តី នៅក្រវែលជុំវិញខ្ញុំក្តី ។ ខ្ញុំមើលទៅគ្មានចូលភ្នែកបន្តិចណាទេ ។

*ម៉ារីក្វ* ឡើងស្រឡាំងកាំង :

- រួចចុះមានទាស់អីរឿងធ្វើស្រីកំនាន់នោះ ?

- ប្រាប់នាងអោយចេញឆ្ងាយទៅចុះ ។

- ប៉ុន្តែ *អាន់ជីន-សាន* លោកមិនអាចប្រកែកបានទេ ! នេះគឺជាការប្រមាថយ៉ាងធ្ងន់ធ្ងរបំផុតចំពោះលោកម្ចាស់ *តូរ៉ាណាកា* ចំពោះនាង ចំពោះគ្រប់១គ្នា ! តើនាងបានធ្វើអីអាក្រក់



www.budinst.gov.kh www.elibraryofcambodia.org

ទៅលើរូបលោក ? គ្មានទាំងអស់ ! *អ៊ុសាគី-ភូជីកូ* យល់ព្រម......

សំលេង *ភ្លាក់ថន* លាន់ផ្ទប់ជញ្ជាំងខ្ទំរពេញផ្ទះ :

- នាងត្រូវស្តាប់តាមខ្ញុំ ! ប្រាប់នាងនោះអោយចេញឆ្ងាយទៅ !

*ម៉ារីកូ* តប :

- សូមអភ័យទោស *អាន់ជីន-សាន* ។ ចាស ជាការត្រឹមត្រូវហើយដែលលោកខឹងនោះ។ ប៉ុន្តែ......

*ភ្លាក់ថន* តបយ៉ាងត្រជាក់ស្រេប :

- ខ្ញុំឥតខឹងសំបាអីទេ។ តើពួកនាង....ពួកនាងល្មមមានខួរក្បាលយល់ថាខ្ញុំធុញនឹងធ្វើជាអាយ៉ងនេះទេ ? ខ្ញុំមិនត្រូវការនារីនេះមកនៅញ៉ុញញ៉ុញទីនេះទេ។ ខ្ញុំត្រូវការសំពៅខ្ញុំវិញ ខ្ញុំត្រូវការពួកនាវិកខ្ញុំវិញ ហើយវាចប់រឿងទៅហើយ ! ខ្ញុំមិនត្រូវការនៅទីនេះប្រាំមួយខែធើម៉ាំអីខ្ញុំទេ ហើយខ្ញុំសែនស្អប់ប្រពៃណីពួកនាងណាស់។ អាណាដែលលី មនុស្សម្នាក់អាចតំរាមកំទេចម៉ាភូមិព្រោះតែដើម្បីអោយខ្ញុំរៀនជប៉ុនយ៉ាងនេះ ? ហើយអារឿងស្រីកំនាន់ស្អីគេនេះទៀត....វាយ៉ាប់ជាងទាសកម្មទៅទៀត.... ហើយវាដូចជាប្រមាថគេពេកហើយដែលរៀបចំរឿងនេះដោយគ្មានសួរអីជាមុនបែបនេះ។

ចុះវាធីហើយអីលូវនេះ ? *ម៉ារីកូ* ដណ្តឹងសួរខ្លួនឯងទាំងជ្រួលច្របល់ ។ចុះវាមានរឿងអីអាក្រក់ទៅអារឿងស្រីកំនាន់នេះ ? ហើយទោះជាយ៉ាងណាក៏ *ភូជីកូ* មិនមែនជាស្រីរូបអាក្រក់ឯណា ? ម៉េចបានជាបុរសនេះពិបាកយល់ម្ល៉េះ ? នាងនឹកឃើញសំដីរបស់ *តូរ៉ាណាកា* ដែលបានប្រាប់នាងថា :

- *ម៉ារីកូ-សាន* នាងជាអ្នកទទួលខុសត្រូវផ្ទាល់លើ ទីមួយគឺ *យ៉ាប៊ូ-សាន* មិនត្រូវជ្រៀតជ្រែកក្នុងរឿងចេញដំណើររបស់ខ្ញុំក្រោយពីខ្ញុំប្រគល់ដាវអោយវានោះទេ និង ទីពីរនាងទទួលខុសត្រូវទាំងស្រុងក្នុងការរៀបចំអោយ *អាន់ជីន-សាន* ស្នាក់នៅយ៉ាងសុខចិត្ត សុខកាយនៅ *អាន់ជីរ៉ូ* នេះ។

- នាងខ្ញុំនឹងប្រឹងប្រែងអោយអស់ពីសមត្ថភាព។ ប៉ុន្តែនាងខ្ញុំខ្លាចតែ *អាន់ជីន-សាន* ធ្វើ



www.budinst.gov.kh www.elibraryofcambodia.org

អោយច្រលំបល់ទេ។

- ត្រូវចាត់ទុកវាដូចជាស្មាំងអញ្ចឹង។ នេះហើយជាគន្លឹះជាមួយវា។ ខ្ញុំផ្សាំងស្មាំងតែពីរថ្ងៃទេ ឯនាងវិញមានពេលដល់ទៅបីថ្ងៃឯណោះ។

*ម៉ារីកូ* បែរភ្នែកចេញពី *ភ្លាក់ថុន* ដើម្បីរិះរកច្រកចេញ។ គាត់នេះពេលឆេះដុំមិនខុសអីពីសត្វស្មាំងមែន -នាងគិតនៅក្នុងចិត្ត។ គាត់នេះមានសំលេងគ្រលូចឡើងហ៊ឹងត្រចៀក មានភាពសាហាវឥតញញើច ហើយនៅពេលគ្មានកំហឹងវិញមានក្រសែភ្នែកមុតនឹងថ្កល់ និងពោរពេញដោយមោទនភាពចំពោះខ្លួនឯង ព្រមទាំងបង្កប់ដោយភាពសាហាវដែលអាចផ្ទុះចេញមកគ្រប់ពេលវេលា។

នាងនិយាយថ្នមៗ :

- ចាស ខ្ញុំយល់ស្របតាមលោក។ លោកមានប្រសាសន៍ត្រូវណាស់។ លោកបានត្រូវគេប្រើប្រាស់យ៉ាងហួសហេតុ។ លោកខឹងនេះសមហេតុសមផលល្អណាស់។ ជាការពិតណាស់ លោកម្ចាស់ *តូរ៉ាណាកា* គួរតែសួរនាំលោកសិន ទោះជាលោកម្ចាស់មិនបានយល់ដឹងពីទំនៀមទំលាប់របស់លោកក្តី។ ប៉ុន្តែលោកម្ចាស់មិនបានគិតថាលោកនឹងប្រកែកចំពោះរឿងនេះឡើយ។ លោកម្ចាស់ខិតខំផ្តល់កិត្តិយសជូនលោក ដូចដែលលោកបានធ្វើចំពោះសាមូរ៉ៃសំនព្វឯទៀតអញ្ចឹង។ លោកម្ចាស់តែងតាំងលោកជា *ហាតាម៉ូតូ* គឺដូចជាអ្នកជាប់ខ្សែសាច់សារលោហិតយ៉ាងដូចនោះដែរ។ នៅម៉ា *ក្វាន់តូ* នេះ មាន *ហាតាម៉ូតូ* តែប្រហែលមួយពាន់នាក់ប៉ុននោះ។ ក៏ដូចជារឿងនាង *កូជីកូ* ដែរ លោកម្ចាស់គ្រាន់តែខិតខំជួយលោកទេតើ។ *អ៊ូសាគី-កូជីកូ* នឹងត្រូវ...មានមុខមានមាត់ក្នុងចំនោមពួកយើងណាំ *អាន់ជីន-សាន*។ ហើយនេះចាត់ទុកជាកិត្តិយសធំណាស់។

- ហេតុអី ?

- ពីព្រោះត្រកូលនាងជាត្រកូលមានចំនាស់យូរយារមកហើយ។នាងក៏ជានារីមានការអប់រំយ៉ាងប្រពៃផងដែរ។ ឪពុកនិងជីតានាងគឺជា *ដៃមីញ៉ូ*។ រូបនាងទៀតសោតក៏ជាសាមូរ៉ៃដែរ ហើយលោកទទួលយកនាងគឺលោកផ្តល់កិត្តិយសដល់នាង។ ម្យ៉ាងទៀតនាងត្រូវការទ្រព្យថ្មី និងជីវិតថ្មីផងដែរ។



www.budinst.gov.kh www.elibraryofcambodia.org

- ហេតុអី ?

- នាងទើបក្លាយជាមេម៉ាយនៅពេលថ្មីៗនេះ ។ នាងទើបមានអាយុដប់ប្រាំបួនឆ្នាំទេ *អាន់ជីន-សាន*។ នាងអភ័ព្វណាស់ ។ នាងបាត់បង់ប្តី ហើយបាត់បង់កូនប្រុសទៀត ។ នៅក្នុងចិត្តនាងពោរពេញដោយវិប្បដិសារី ។ បើនាងក្លាយជាកំនាន់របស់លោក នាងនឹងមានជីវិតថ្មីមួយទៀត ។

- ប្តី និងកូនប្រុសនាងមានរឿងយ៉ាងម៉េច ?

*ម៉ារីកូ* រុញរាក្នុងចិត្ត នាងសែនប៉ក់ល្មើយនឹងសំនួរត្រង់ៗគ្មានសុជីវធម៌របស់ *ភ្លាក់ថន*។ ប៉ុន្តែនាងបានស្គាល់ *ភ្លាក់ថន* ច្រើនល្មមហើយដែរនៅពេលនេះ ដែលអាចអោយនាងយល់បានថាទំលាប់ **របស់គេ** មិនមែនជាភាពជំលើយនោះទេ ។

- ទាំងពីរនាក់ត្រូវទទួលទោសប្រហារជីវិត *អាន់ជីន-សាន*។ ក្នុងពេលដែលលោកនៅទីនេះលោកពិតជាត្រូវការអ្នកមើលថែទាំផ្ទះសំបែងលោក ។ *ភូជីកូ* នឹង......

- ហេតុអីពួកគេត្រូវទទួលទោសប្រហារជីវិត ?

- ព្រោះតែប្តីនាង លោកម្ចាស់ *តូរ៉ាណាកា* រិះនឹងអស់ជីវិត ។ សូមលោក.....

- *តូរ៉ាណាកា* បញ្ជាអោយប្រហារជីវិតពួកគេរឺ ?

- ចាស ។ប៉ុន្តែលោកម្ចាស់ធ្វើត្រូវ ។លោកសួរនាងចុះ នាងពិតជាឯកភាពលើរឿងនេះ ។

- កូនប្រុស *ភូជីកូ* អាយុប៉ុន្មាន ?

- ប្រហែលប៉ុន្មានខែហើយ *អាន់ជីន-សាន*។

- *តូរ៉ាណាកា* ប្រហារជីវិតកូនង៉ែតមួយព្រោះតែអំពើរបស់ឪពុកវា ?

- ចាស នេះគឺជាទំនៀមទំលាប់ពួកយើង ។ សូមលោកចេះអត់ធ្មត់ជាមួយពួកយើងខ្លះទៅ ។ មានរឿងខ្លះយើងមិនចេះតែសេរីបានទេ ។ ទំនៀមទំលាប់ពួកយើងខុសពីទំនៀមទំលាប់របស់ពួកលោក ។ លោកត្រូវដឹងថា តាមច្បាប់ពួកយើងជាកម្មសិទ្ធិរបស់អម្ចាស់យើង ។ តាមច្បាប់ឪពុកជាម្ចាស់កម្មសិទ្ធិលើជីវិតកូនចៅខ្លួន ប្រពន្ធ ប្រពន្ធចុងនិងអ្នកបំរើទាំងប៉ុន្មានរបស់ខ្លួន ។ តាមច្បាប់ជីវិតរបស់ឪពុក នេះជាកម្មសិទ្ធិរបស់អម្ចាស់ខ្លួន ។ នេះគឺជាច្បាប់ទំលាប់របស់យើង ។



www.budinst.gov.kh www.elibraryofcambodia.org

- អញ្ចឹងឪពុកអាចសំលាប់អ្នកដែលនៅក្នុងផ្ទះរបស់ខ្លួនមួយណាក៏បានដែរ ?

- ចាស ។

- បើអញ្ចឹងស្រុកនាងជាស្រុកពួកឃាតកតែម្រ៉ង ។

- មិនមែនទេ ។

- មិនមែនទេយ៉ាងម៉េច បើច្បាប់ទំលាប់នាងបើកដៃដល់ការធ្វើឃាតបែបនេះ ?ខ្ញុំគិតថានាងជាអ្នកកាន់សាសនាគ្រីស្តដែរ ។

- ចាស ខ្ញុំកាន់សាសនាគ្រីស្ត *អាន់ជីន-សាន* ។

- បើអញ្ចឹងឯណាទៅវិន័យព្រះ ?

- និយាយដោយត្រង់ទៅ ខ្ញុំមិនអាចពន្យល់បានទេ ។ ប៉ុន្តែខ្ញុំជាអ្នកកាន់សាសនាគ្រីស្តជាសាមូរ៉ៃ និងជាជនជាតិជប៉ុន ។ ហើយចំនុចទាំងបីនេះមិនប្រឆាំងនឹងគ្នាទេ ។ ចំពោះរូបខ្ញុំគ្មានទាល់តែសោះ ។ សូមលោកចេះអត់ធ្មត់សង្កត់ចិត្តខ្លះជាមួយពួកយើងផងទៅ ។

- តើនាងដាច់ចិត្តប្រហារជីវិតកូននាងទេ បើ *ភូរ៉ាណាកា* បញ្ជា ?

- ចាស ដាច់ចិត្ត ។ថ្វីបើខ្ញុំមានកូនតែមួយក្តី ខ្ញុំជឿថាដាច់ចិត្ត ។ នេះគឺជាករណីយកិច្ចដែលខ្ញុំត្រូវបំពេញ ។ នេះគឺជាច្បាប់ ហើយបើសិនជាប្តីខ្ញុំយល់ព្រម ។

- ខ្ញុំសង្ឃឹមថាព្រះនឹងប្រោសពួកនាង ។ ពួកនាងទាំងអស់គ្នាហ្នឹង ។

- ព្រះអង្គយល់ *អាន់ជីន-សាន*។ ព្រះអង្គពិតជានឹងយល់ ។ ព្រះអង្គប្រហែលជានឹងជួយបើកបញ្ញាញាណលោកអោយយល់បានផងដែរ ។ ខ្ញុំស្តាយណាស់ដែលខ្ញុំមិនអាចពន្យល់លោកអោយបានក្បោះក្បាយ *រេ* ? ខ្ញុំសូមទោសចំពោះគុណវិបត្តិនេះ ។

*ម៉ារីកូ* សំលឹងមើល *ប្លាក់ថន* យ៉ាងស្ងៀមស្ងាត់ដោយមឹងម៉ាំងនឹងអាកប្បកិរិយារបស់គេ ។

- ខ្ញុំក៏មិនយល់ពីលោកដែរ *អាន់ជីន-សាន*។ លោកធ្វើអោយខ្ញុំវង្វេងស៊ុងតែម្តង ។ ទំនៀមទំលាប់លោកធ្វើអោយខ្ញុំវង្វេងអស់ ប្រសិនបើយើងទាំងពីរនាក់មានការអត់ធ្មត់យើងអាចរៀនសូត្រពីគ្នាទៅវិញទៅមកបាន ដូចរឿង *ភូជីកូ* ជាដើម ។ ក្នុងឋានៈជាកំនាន់នាងនឹងមើលថែទាំផ្ទះសំបែងនិងពួកអ្នកបំរើរបស់លោក ។ ហើយនឹងសេចក្តីត្រូវការនានារបស់លោក -សេចក្តី



www.budinst.gov.kh www.elibraryofcambodia.org

ត្រូវការអ្វីក៏ដោយ ។ លោកត្រូវមានអ្នកណាម្នាក់ទទួលការងារនេះ ។ នាងនឹងទទួលចាត់ចែងការងារគ្រប់បែបយ៉ាងនៅក្នុងផ្ទះរបស់លោក លោកមិនចាំបាច់ត្រូវតែរួមដំណេកជាមួយនាងទេ បើសិននេះជាកង្វល់របស់លោក រឺ បើសិនជាលោកមិនពេញចិត្តនឹងរូបនាង ។ លោកក៏មិនចាំបាច់ត្រូវតែគួរសមជាមួយនាងទេថ្វីត្បិតតែនាងស័ក្តិសមនឹងទទួលបាននូវការគួរសមមួយក្តី ។ នាងនៅបំរើលោកតាមចំនង់ចិត្តលោក និងតាមរបៀបណាក៏ដោយដែលលោកចង់ ។

- ខ្ញុំអាចចាត់ចែងនាងស្រេចចិត្តខ្ញុំចង់បានមែនរឺ ?

- ចាស ។

- ខ្ញុំអាចរួមដំណេកជាមួយនាង រឺមិនរួមស្រេចលើខ្ញុំមែនរឺ ?

- ពិតប្រាកដហើយ ។ នាងនឹងរកអ្នកណាដែលលោកពេញចិត្តដើម្បីបំពេញតំរូវការនៃរូបរាងកាយលោកបាន បើសិនជាលោកត្រូវការ រឺ នាងនឹងមិនលូកលាន់ជ្រៀតជ្រែកឡើយ ។

- ខ្ញុំអាចចាត់នាងដូចជាអ្នកបំរើ រឺ ដូចជាទាសីបានទេ ?

- ចាស បាន ប៉ុន្តែនាងគួរទទួលបាននូវការរាប់អានគ្រាន់បើជាងនេះ ។

- តើខ្ញុំអាចបណ្តេញនាងចេញមិនអោយនៅជាមួយខ្ញុំបានទេ?

- ចាស បាន បើសិនជានាងប្រមាថមើលងាយលោក ។

- តើពេលនោះនាងនឹងមានរឿងអីដែរទៅ ?

- ធម្មតានាងនឹងវិលត្រលប់ទៅផ្ទះឪពុកម្តាយនាងវិញទាំងបាក់មុខបាក់មាត់ ហើយឪពុកម្តាយនាងអាចទទួលរឺមិនទទួលនាងអោយរស់នៅជាមួយបាន ។ អ្នកខ្លះដូច *ភូជីកូ* ជាដើមសុខចិត្តជ្រើសរើសយកអត្តឃាតជាជាងទទួលយកភាពអាម៉ាស់នេះ ។ ប៉ុន្តែនាង... .លោកគួរតែដឹងហើយថា សាមូរ៉ៃពិតប្រាកដមិនអាចធ្វើអត្តឃាតដោយគ្មានការអនុញ្ញាតពីម្ចាស់របស់ខ្លួនឡើយ ។ ពិតហើយមានអ្នកខ្លះបំពានធ្វើដែរ ប៉ុន្តែនេះគឺជាការបោះបង់ចោលនូវកាតព្វកិច្ចរបស់ខ្លួនហើយមិនសក្តិសមនឹងចាត់ទុកជាសាមូរ៉ៃឡើយ ។ ដូចខ្ញុំៗមិនអាចសំលាប់ខ្លួនបានដោយគ្មានការអនុញ្ញាតពីលោកម្ចាស់ *តូរ៉ាណាកា* រឺ ពីប្តីរបស់ខ្ញុំបានឡើយ ទោះជាក្តីអាម៉ាស់នោះមានទំហំប៉ុនណាក្តី ។ លោកម្ចាស់ *តូរ៉ាណាកា* បានដាក់បញ្ជាមិនអោយនាងធ្វើអត្តឃាតឡើយ ។ បើលោក



www.budinst.gov.kh www.elibraryofcambodia.org

បណ្ដេញនាងចេញ នាងនឹងក្លាយជាមនុស្សក្រៅសង្គមហើយ ។

- ហេតុអី ? ហេតុអីបានជាគ្រួសារនាងមិនទទួលនាងវិញ ?

*ម៉ារីកូ* ដកដង្ហើមធំ :

- សូមអភ័យទោស *អាន់ជីន-សាន* បើលោកបណ្ដេញនាងចេញ ភាពអាម៉ាស់នេះមានទំហំធំធេងណាស់ ហើយគ្មានអ្នកណាម្នាក់អាចទទួលយកនាងបានទេ ។

- ព្រោះនាងប្រលាក់ប្រលូសដោយបានរស់នៅជិតមនុស្សចុងស្រុកមែនទេ ?

*ម៉ារីកូ* ប្រកែកញ៉ាញ :

- ចាស មិនមែនទេ ។ តែនេះគឺនាងគ្មានសមត្ថភាពបំពេញករណីយកិច្ចរបស់នាងចំពោះលោកបាន ។ នាងជាកំនាន់របស់លោកហើយនៅពេលនេះ ។ លោកម្ចាស់ *តូរ៉ាណាកា* បានបញ្ជាយ៉ាងនេះ ហើយរូបនាងបានយល់ព្រមហើយដែរ ។ លោកគឺជាម្ចាស់ផ្ទះហើយអីលូវនេះ ។

- មែនអ្ហី ?

- ចាស សូមលោកជឿខ្ញុំចុះ ។ លោកជាម្ចាស់ផ្ទះដែលមានបុព្វសិទ្ធិគ្រប់បែបយ៉ាង ។ ហើយក្នុងឋានៈជា *ហាតាម៉ូតូ* លោកមានការគាំពារហើយនឹងទ្រព្យសម្បត្តិគ្រប់គ្រាន់ ។ លោកម្ចាស់ *តូរ៉ាណាកា* បានផ្ដល់ប្រាក់បំនាច់ប្រចាំខែចំនួនម្ភៃ *កូកូ* ជូនលោក ។ ក្នុងចំនួននេះ សាមូរ៉ៃម្នាក់អាចចិញ្ចឹមបំពាក់អាវុធនិងជំនិះខ្លួនឯងផង សាមូរ៉ៃពីរនាក់ហើយនឹងគ្រួសាររបស់គេក្នុងពេញមួយឆ្នាំទៀតផង ។ប៉ុន្តែលោកមិនចាំបាច់រវល់ដល់យ៉ាងនោះទេ ។ខ្ញុំសូមអង្វរលោក *អាន់ជីន-សាន* សូមលោកទុក *ភូជីកូ* ជាមនុស្សម្នាក់នឹងគេផង ខ្ញុំសូមលោកមានសប្បុរសធម៌របស់ព្រះគ្រីស្ទនៅក្នុងដួងចិត្តរបស់លោក ។ *ភូជីកូ* ជានារីល្អម្នាក់ហើយសូមលោកអធ្យាស្រ័យចំពោះរូបអាក្រក់របស់នាងផងចុះ ។ នាងនឹងជាកំនាន់ដ៏សក្ដិសមម្នាក់ជាមិនខាន ។

- នាងឥតមានផ្ទះសំបែងទេអ្ហី ?

*ម៉ារីកូ* ប្រឹងទប់ការធុញទ្រាន់របស់នាង :

- ចាស ទីនេះហើយជាផ្ទះរបស់នាង ។ ខ្ញុំសូមលោកទទួលនាងដោយពេញមុខពេញមាត់ផងចុះ ។ នាងអាចជួយលោកច្រើនណាស់ ហើយថែមទាំងអាចជួយបង្រៀនលោកបានថែម



www.budinst.gov.kh www.elibraryofcambodia.org

ទៀតបើសិនជាលោកចង់រៀន ម៉្យាងទៀតបើលោកមិនចូលចិត្តនាង សូមលោកចាត់ទុកនាងដូចសេសរ រឺ ដូចឡប់ឡែ រឺ ដូចថូនៅក្នុងសួនរបស់លោក រឺ ដូចអ្វីទៀតក៏បានតាមចិត្តលោក ប៉ុន្តែសូមលោកអនុញ្ញាតអោយនាងនៅជាមួយផងចុះ ។ បើលោកមិនចង់បាននាងជាកំនាន់ទេក៏សូមលោកមានករុណាធម៌ផងទៅចុះ សូមលោកទទួលនាងហើយបន្ទាប់មកទៀតអនុលោមតាមច្បាប់របស់យើងនិងក្នុងឋានៈជាម្ចាស់ផ្ទះសំបែងលោកប្រហារជីវិតនាងចោលទៅ ។

- អញ្ចឹងចំលើយនាងមានតែមួយណឹងគត់ គឺសំលាប់ មែនទេ ?

- មិនមែនទេ *អាន់ជីន-សាន* ។ ប៉ុន្តែស្លាប់និងរស់គឺជារឿងតែមួយទេតើ ។ អ្នកណាដឹងបានថា ការដែលលោកផ្តាច់ជីវិត *ភូជីកូ* ជូនកាលអាចជាការជួយនាងទេវិញផងក៏មិនដឹង ។ នេះគឺជាសិទ្ធិរបស់លោកដែលច្បាប់បានទទួលស្គាល់ ។ ជាសិទ្ធិ ***របស់លោក*** ប៉ុន្តែបើលោកចង់អោយនាងក្លាយទៅជាមនុស្សក្រៅសង្គម នោះក៏ជាសិទ្ធិរបស់លោកដែរ ។

*ប្លាក់ថន* ឆ្លើយតប :

- បើអញ្ចឹង ខ្ញុំមិនជាប់ផុងដដែលជាដដែលទៅហើយ ។ ទោះជាគេចទៅខាងណាក៏នាងត្រូវតែស្លាប់ ។ បើខ្ញុំមិនរៀនភាសាពូកនាង មនុស្សម៉ាភូមិនេះនឹងត្រូវក្របែលចោល ។ បើខ្ញុំមិនធ្វើអីតាមបំនងពួកនាងមនុស្សស្លូតត្រង់ឯទៀតនឹងត្រូវប្រហារជីវិតតែដដែល ។ នេះជាផ្លូវបិទគ្មានច្រកចេញសោះតែម្តង ។

- មានដំណោះស្រាយមួយយ៉ាងងាយបំផុត *អាន់ជីន-សាន* នោះគឺស្លាប់ ។ លោកមិនចាំបាច់ទ្រាំទ្រនូវអ្វីដែលមិនអាចទ្រាំទ្របាននោះទេ ។

- សំលាប់ខ្លួនគឺជាការលេលាបំផុត ហើយជាបាបកម្មថែមទៀត ។ ខ្ញុំគិតថានាងជាអ្នកកាន់គ្រីស្តសាសនាដែរតើ ។

- ខ្ញុំបានប្រាប់លោកហើយតើ ។ ប៉ុន្តែ *អាន់ជីន-សាន* លោកមានរបៀបច្រើនយ៉ាងដើម្បីស្លាប់ក្នុងភាពថ្លៃថ្នូរដោយមិនចាំបាច់ធ្វើអត្តឃាត ។ លោកបានចំអកអោយប្តីខ្ញុំព្រោះតែគាត់មិនចង់ស្លាប់ក្នុងការប្រយុទ្ធ *នេ* ? នេះមិនមែនទំលាប់របស់ពួកយើងទេ តែតាមមើលទៅគឺជាទំលាប់របស់ពួកលោកហើយ ។ បើអញ្ចឹងដែរម៉េចក៏លោកមិនសំលាប់ *យ៉ាប៊ូ* ទៅ ? លោក



www.budinst.gov.kh www.elibraryofcambodia.org

មានកាំភ្លើងខ្លីដែរតើ ។ សំលាប់ *យ៉ាប៊ូ* ទៅ ។ លោកយល់ថាគាត់ជាមនុស្សឃោរឃៅ *ទេ* ? សាក សំលាប់គាត់ទៅមើល ហើយថ្ងៃនេះបើលោកមិនឡើងស្ថានសួគ៌ ក៏ចុះនរកដែរ ។

*ប្លាក់ថន* សំលឹងមើល *ម៉ារីកូ* ទាំងឃ្លាន់ខ្លាញ់នៅក្នុងចិត្តចំពោះភាពនឹងនរបស់នាង :

- ជាការកំសោយបំផុតដែលស្លាប់របៀបនេះដោយគ្មានមូលហេតុនោះ ។ បើហៅថាភ្លឺ ភ្លើនោះត្រូវជាង ។

- លោកបាននិយាយថាលោកជាគ្រីស្តសាសនិក ។ បើអញ្ចឹងលោកជឿព្រះកុមារយេស៊ូ លោកជឿព្រះ លោកជឿស្ថានសួគ៌ដែរ ការស្លាប់ពិតជាមិនធ្វើអោយលោកខ្លាចនោះទេ ។ ចំពោះ រឿង " គ្មានមូលហេតុ " នោះ គឺរូបលោកដែលជាអ្នកអោយតំលៃ រឺ មិនអោយតំលៃ ។ លោក អាចមានមូលហេតុគ្រប់គ្រាន់ដើម្បីនឹងស្លាប់បាន ។

- ខ្ញុំនៅក្នុងកណ្តាប់ដៃនាងទេតើ ។ នាងដឹងរឿងនេះហើយតើ ។ ខ្ញុំក៏ដឹងខ្លួនដែរ ។

*ម៉ារីកូ* អោនខ្លួនមកឈោងចាប់ដៃ *ប្លាក់ថន* ទាំងអាណិតអាសូរ :

- *អាន់ជីន-សាន* សូមបំភ្លេចរឿងអ្នកភូមិនេះចោលទៅ ។ មុនកំនត់ប្រាំមួយខែនេះ មានរាប់លានរឿងដែលអាចកើតមានឡើង ។ អាចមានរលករញ្ជួយដី រឺ រញ្ជួយដី អាចលោកបាន សំពៅមកវិញ ហើយចេញដំណើរទៅបាត់ទៅ អាច *យ៉ាប៊ូ* ស្លាប់ រឺ យើងទាំងអស់គ្នាស្លាប់ អ្នក ណាអាចដឹងបាន ? ទុករឿងព្រះថ្វាយព្រះ រឿង *កាម៉ា* អោយ *កាម៉ា* ទៅ ។ អីលូវនេះគឺលោកនៅ ទីនេះ ហើយទោះលោកធ្វើអ្វី ក៏លោកមិនអាចប្រែប្រួលអ្វីបានដែរ ។ អីលូវនេះលោកនៅមាន ដង្ហើមដក លោកនៅកន្លែងនេះហើយប្រកបដោយកិត្តិយស និងសំនាងល្អ ។ លោកសំលឹងមើល ព្រះអាទិត្យរៀបលិចនោះមើល ល្អណាស់មែនទេ ? ព្រះអាទិត្យរៀបលិចនេះគឺជាអត្ថិភាព ។ គ្មានថ្ងៃស្អែកទេ មានតែ *ពេលនេះ* មួយគត់ ។ សូមលោកសំលឹងមើល ថ្ងៃអស្តង្គតនេះល្អណាស់ ហើយគ្មានថ្ងៃអស្តង្គត *នេះ* ទៀតទេ គ្មានជារៀងរហូត ។ សូមលោកបញ្ចូលខ្លួនទៅក្នុងថ្លាំង ទស្សនីយភាពនេះ រំលាយខ្លួនសាច់មួយជាមួយនឹងធម្មជាតិ ហើយលុបចោលនូវរាល់កង្វល់ពីរឿង *កាម៉ា* ពីរឿងលោក ពីរឿងខ្ញុំ រឺ ពីរឿងអ្នកភូមិអី១ទាំងអស់ចោលទៅ ។

*ប្លាក់ថន* មានអារម្មណ៍ហាក់ដូចត្រូវសណ្តំដោយភាពនឹងនរនិងសំដីរបស់នាង ។ គេងាក



www.budinst.gov.kh www.elibraryofcambodia.org

សំលឹងមើលទៅទិសខាងលិច ដែលមាន ស្លាមក្រហមជាំ និង ខ្មៅឆ្នូតកាត់ជាកង់១ រហូតដល់ពេលដែលព្រះអាទិត្យលិចបាត់សូន្យឈឹង។

- ខ្ញុំពេញចិត្តរូបនាងជាកំនាន់ខ្ញុំវិញ......

- ខ្ញុំជារបស់លោកម្ចាស់ *ប៊ុនកាវ៉ូ* ហើយ ដរាបណាគាត់មិនទាន់អស់ជីវិត ខ្ញុំមិនអាចគិត រឺ និយាយអ្វីដែលគួរគិត រឺ និយាយបានទេ។

*កាម៉ា - ប្លាក់ថន* គិតនៅក្នុងចិត្ត។

តើអញត្រូវទទួលយក *កាម៉ា* ដែរ រឺទេ ? *កាម៉ា* របស់អញ ? របស់នាង ? របស់ពួកគេទាំងអស់គ្នា ?

រាត្រីសែនល្អត្រចះ។

ហើយរូបនាងក៏ល្អយ៉ាងដូចនោះដែរ តែនាងជារបស់អ្នកផ្សេងទៅវិញ។

ពិតណាស់ នាងមានសំរស់ល្អមែន។ ហើយក៏វាងវៃណាស់ដែរ : ទុករឿងព្រះថ្វាយព្រះ ហើយរឿង *កាម៉ា* អោយ *កាម៉ា* ។ អែងមកទីនេះដោយគ្មានការអញ្ជើញទេ។ អែងនៅទីនេះ។ អែងនៅក្នុងកណ្ដាប់ដៃរបស់ពួកគេទាំងស្រុង។

ប៉ុន្តែចំលើយទៅជាយ៉ាងណាទៅ ?

ចំលើយពិតជានឹងមកដល់ -គេគិតនៅក្នុងចិត្ត។ ពីព្រោះមានព្រះនៅលើមេឃ មានព្រះនៅទីកន្លែងណាមួយជាពិតប្រាកដ។

ស្នូរសិរបជើងបានរសាត់មកដល់ត្រចៀក *ប្លាក់ថន*។ ពន្លឺភ្លើងផ្លុង១បានរំកិលឡើងមកលើកូនភ្នំ។ ពួកសាមូរ៉ៃម្តនាក់កំពុងដើរតំរង់មក។ នៅពីមុខ គឺ *អូមី* ។

**************

- ខ្ញុំសូមអភ័យទោស *អាន់ជីន-សាន* ប៉ុន្តែ *អូមី-សាន* បញ្ជាអោយលោកប្រគល់កាំភ្លើងខ្លីដល់គាត់។



www.budinst.gov.kh www.elibraryofcambodia.org

- ប្រាប់វាអោយទៅប្រកាច់ងាប់ឯណាឯណីទៅ !

- ខ្ញុំមិនអាចនិយាយអ៊ីចឹងបានទេ *អាន់ជីន-សាន*។ ខ្ញុំមិនហ៊ានទេ។

*ប្លាក់ថន* ដាក់ដៃបន្ថើរលើដងកាំភ្លើងខ្លីរបស់ខ្លួនក្តែកគេស់លើងមើល *អូមី* ឥតដាក់។ គេនៅអង្គុយផ្តើនលើជណ្តើររានហាលដដែល ។សាមូរ៉ៃដប់នាក់ស្ថិតនៅក្នុងសួនច្បារក្រោយខ្នង *អូមី* អ្នកឯទៀតនៅឈរក្បែររំគ្រស្លែង ។នៅពេលដែល *អូមី* ចូលមកក្នុងបរិវេណផ្ទះដោយគ្មានអ្នកណាអញ្ជើញនេះភ្លាម *ភូជីកូ* បានចេញមកពីក្នុងផ្ទះមកឈរទាំងទឹកមុខស្លេកស្លាំងក្រោយ *ប្លាក់ថន* ។

- លោកម្ចាស់ *តូរ៉ាណាកា* មិនដែលជំទាស់ផងទេ ខ្ញុំកាន់អាវុធនៅជិតគាត់ និង *យ៉ាប៊ូ-សាន* រាប់ថ្ងៃហើយតើ។

*ម៉ារីកូ* និយាយទាំងមួម៉ៅ :

- ចាស ពិតមែនហើយ *អាន់ជីន-សាន* ប៉ុន្តែសូមលោកយល់ថាអ្វីដែល *អូមី-សាន* និយាយគឺជាការពិត ។ ច្បាប់ទំលាប់របស់យើងមិនអនុញ្ញាតអោយលោកមានអាវុធនៅចំពោះមុខ *វ៉ៃមីញ៉ូ* បានទេ។ គ្មានរឿងអ្វីដែលលោកត្រូវព្រួយបារម្ភនោះឡើយ។ *យ៉ាប៊ូ-សាន* ជាមិត្តរបស់លោក។ លោកជាភ្ញៀវរបស់គាត់នៅទីនោះ។

- ប្រាប់ទៅ *អូមី-សាន* ថាខ្ញុំមិនអោយកាំភ្លើងរបស់ខ្ញុំទេ។

ប៉ុន្តែនៅពេលដែល *ម៉ារីកូ* នៅស្ងៀមឈឹងនោះ *ប្លាក់ថន* ក៏ឆេះដុំឡើង ហើយនិយាយទាំងគ្រវីក្បាលទៅកាន់ *អូមី* :

- *អ៊ីយេ អូមី-សាន ! វ៉ាការីម៉ាស៊ី កា ? អ៊ីយេ !*

ទឹកមុខ *អូមី* ឡើងមាំភ្លាម។ គេស្រែកចេញបញ្ជាឡើង។ សាមូរ៉ៃពីរនាក់ដើរចេញមក។ *ប្លាក់ថន* ហូតកាំភ្លើងទាំងពីរដើមចេញតំរង់ចំមុខ *អូមី*។ សាមូរ៉ៃទាំងពីរឈប់នៅស្ងៀម។

- *អ៊ីយេ !*

*ប្លាក់ថន* និយាយ។ រួចគេប្រាប់ទៅ *ម៉ារីកូ* :

- ប្រាប់គាត់អោយឃាត់ពួកអស់នេះភ្លាម បើមិនអ៊ីចឹងទេខ្ញុំកាច់កែអីលូវហ្នឹង។

*ម៉ារីកូ* បកតាមសំដី *ប្លាក់ថន* ។ គ្មានអ្នកណាមួយកំរើកខ្លួនឡើយ។ *ប្លាក់ថន* ងើបឈរ



www.budinst.gov.kh www.elibraryofcambodia.org

ឡើងយឺតៗចុងកាំភ្លើងនៅតែឥតងាករេពីចំនុចដៅរបស់ខ្លួនបន្តិចណា សោះឡើយ ។ អូមី ទៅ ឈរថ្មឹងឥតញ្ញោច ភ្នែករបស់គេតាមសំលឹងកាយវិការប្រៀបដូចសត្វឆ្មា របស់ ភូជីកូ ជាប់មិនដាក់ភ្នែក ។

BUDDHIST INSTITUTE LIBRARY

- ខ្ញុំសូមអង្វរ *អាន់ជីន-សាន*។ ធ្វើបែបនេះគឺគ្រោះថ្នាក់ណាស់ ។ លោកត្រូវអញ្ជើញទៅជួបលោកម្ចាស់ *យ៉ាប៊ូ* ។ លោកមិនអាចយកកាំភ្លើងខ្លីទាំងនេះទៅជាមួយខ្លួនបានទេ ។ លោកគឺជា *ហាតាម៉ូតូ* លោកមានការគាំពារទាំងស្រុងហើយលោកគឺជាភ្ញៀវរបស់លោកម្ចាស់ *យ៉ាប៊ូ* ថែម ទៀត ។

- ប្រាប់ *អូមី-សាន* ថាបើសិនជាវា រឺកូនចៅវាចូលមកជិតខ្ញុំក្នុងរង្វង់ដប់ជំហាន ខ្ញុំបាញ់បំបែកសន្ទះក្បាលវាភ្លាម ។

- *អូមី-សាន* បានមានប្រសាសន៍យ៉ាងគួរសមថា " ជាលើកចុងក្រោយ សូមលោកប្រគល់កាំភ្លើងខ្លីទាំងនេះមកខ្ញុំ " ។

- *អ៊ីយេ* ។

- ហេតុអីក៏លោកមិនទុកកាំភ្លើងខ្លីរបស់លោកនៅទីនេះសិនទៅ *អាន់ជីន-សាន* ? គ្មានអ្វីដែលគួរអោយលោកត្រូវខ្លាចសោះ ។ គ្មានអ្នកណាម្នាក់ហ៊ានប៉ះ.....

- នាងស្មានថាខ្ញុំឆ្កួតមិនដឹងអីសោះរឺអី ?

- បើអីចឹងអោយកាំភ្លើងទាំងនេះទៅ *ភូជីកូ-សាន* ថែទុកទៅ!

- រួចនាងអាចធ្វើអីកើតទៅ ? អាគាត់នេះច្បាស់ជាដណ្តើមយកពីនាង អ្នកឯទៀតនឹងយកពីនាង ហើយពេលនោះខ្ញុំនឹងនៅតែដៃទទេគ្មានអ្វីការពារខ្លួនទេ ។

*ម៉ារីកូ* បន្លឺសំលេង :

- ហេតុអីក៏លោកមិនព្រមស្តាប់សោះអ៊ីចឹង *អាន់ជីន-សាន* ? *ភូជីកូ-សាន* ជាកំនាន់របស់លោក ។ បើលោកចេញបញ្ជាអោយនាងៗយកជីវិតនាងការពារកាំភ្លើងទាំងនេះ ។ នេះគឺជាកាតព្វកិច្ចរបស់នាង ។ ខ្ញុំនឹងមិនរំលឹកលោកទៀតទេ តែ *ភូដា-ណូ-អ៊ូសាគី ភូជីកូ* គឺជាសាមូរ៉ៃណាំ ។



www.budinst.gov.kh www.elibraryofcambodia.org

តែ *ប្លាក់ថន* មិនរវល់ស្តាប់ *ម៉ារីកូ* ប៉ុន្មានទេ អារម្មណ៍របស់គេផ្តោតជាប់តែលើ *អូមី* ម្នាក់ប៉ុននោះ :

- ប្រាប់ *អូមី-សាន* ថាខ្ញុំមិនចូលចិត្តអោយគេបញ្ជាទេ។ ខ្ញុំជាក្មេងរបស់លោកម្ចាស់ *តូរ៉ាណាកា* ។ ខ្ញុំជាក្មេងរបស់លោកម្ចាស់ *យ៉ាប៊ូ* ។ លោក " សូម " ក្មេងអោយធ្វើនេះ អោយធ្វើនោះ មិនមែនចេញបញ្ជាទេ។ ហើយក៏លោកមិនត្រូវចូលផ្ទះគេដោយគ្មានការអញ្ជើញរបស់ម្ចាស់ផ្ទះផងទេ។

*ម៉ារីកូ* បកតាមសំដី *ប្លាក់ថន* ។ *អូមី* ស្តាប់បំនកប្រែដោយទឹកមុខនឹងថ្កល់ រួចនិយាយតបយ៉ាងខ្លី ភ្នែកគេនៅតាមមើលជាប់ចុងកាំភ្លើងដែលឥតងាករេមួយចង្អាមណាឡើយ។

- គាត់និយាយថា " ខ្ញុំ *កាស៊ីគី អូមី* សូមកាំភ្លើងរបស់លោក និង សូមលោកអញ្ជើញទៅជាមួយខ្ញុំ ពីព្រោះ *កាស៊ីគី យ៉ាប៊ូ-សាម៉ា* បញ្ជាអោយអញ្ជើញទៅជួបលោក។ ប៉ុន្តែ *យ៉ាប៊ូ-សាន* បញ្ជាខ្ញុំអោយមកបញ្ជាលោកអោយប្រគល់អាវុធរបស់លោក មកអោយខ្ញុំ។ ហេតុនេះ សូមអភ័យផងទៅចុះ *អាន់ជីន-សាន* ជាលើកចុងក្រោយបង្អស់ខ្ញុំបញ្ជាអោយលោកប្រគល់អាវុធទាំងនេះមកអោយខ្ញុំ។

ទ្រូង *ប្លាក់ថន* ឡើងតឹងផ្អឹះ។ គេដឹងថាពួកទាំងនេះនឹងបើកការវាយលុកអីឡូវនេះហើយៗគេសែនមួម៉ៅនឹងភាពល្ងាក់ល្ងើរបស់គេនេះ។ ប៉ុន្តែវាមានពេលណាមួយនោះដែលវាដល់កអីចឹងទៅដែរ ដល់ពេលហ្នឹងម្នាក់ៗតាំងដកកាំភ្លើង ដកកាំបិតហើយឈាមត្រូវហូរព្រោះតែរឿងមោទនភាពដ៏លេលាមួយតែប៉ុននោះ។ ជាញឹកញយ គឺជារឿងលេលា។ បើអញត្រូវស្លាប់អា *អូមី* ស្លាប់មុន។

គេមានអារម្មណ៍ខ្លាំងក្លាស់បើមក្នុងមោហចិត្តរបស់ខ្លួន ។ ប៉ុន្តែបន្ទាប់មកសំដី *ម៉ារីកូ* បានលាន់លឺឡើងនៅក្នុងត្រចៀករបស់គេ " *ភូជីកូ* ជាសាមូរ៉ៃ នាងជាកំនាន់របស់លោក ! "។ ខួរក្បាលគេចាប់កំរើកធ្វើសកម្មភាពឡើងវិញ។

- សូមចាំមួយភ្លែត ! *ម៉ារីកូ-សាន* សូមនាងបកប្រាប់ទៅ *ភូជីកូ-សាន* បន្តិច។ បកអោយចំពាក្យណា ។ ប្រាប់នាងថា " ខ្ញុំប្រគល់កាំភ្លើងអោយនាងរក្សាទុក ។ ក្រៅពីខ្ញុំហាមមិន



www.budinst.gov.kh www.elibraryofcambodia.org

អោយអ្នកណាប៉ះពាល់វាជាដាច់ខាត ” ។

*ម៉ារីកូ* បកតាមការប្រាប់ហើយ *ប្លាក់ថន* លឺចំលើយ “ *ហៃ !* ” របស់ *កូជីកូ* លាន់ពីក្រោយខ្នងរបស់គេ ។

- *វ៉ាកាវីម៉ាស៊ី កា កូជីកូ-សាន ?* -*ប្លាក់ថន* សួរ ។

- *វ៉ាកាវីម៉ាស៊ី អានជីន-សាន* -*កូជីកូ* ឆ្លើយតបវិញក្នុងសំលេងតូចឆ្មារ និងប្រកបដោយភាពរចល់ ។

- *ម៉ារីកូ-សាន* សូមប្រាប់ទៅ *អូមី-សាន* ថាខ្ញុំនឹងទៅជាមួយគាត់ហើយ ។ ខ្ញុំស្តាយណាស់ដែលមានការយល់ច្រលំបែបនេះ ។ មែនណាំ ខ្ញុំសែនស្តាយចំពោះការភាន់ច្រលំនេះ ។

*ប្លាក់ថន* ថយក្រោយហើយបែរងាកហុចកាំភ្លើងខ្លីរបស់ខ្លួនទៅអោយ *កូជីកូ* ដែលកំពុងបែកញើសពេញថ្ងាសនៅឡើយ ។ រួចរាល់ហើយគេក៏ងាកមកទល់មុខ *អូមី* វិញ :

- យើងអាចចេញដំណើរបានហើយ រឺនៅ ?

*អូមី* និយាយទៅកាន់ *កូជីកូ* ដោយថែមទាំងហុចដៃទៅជាមួយផង ។ *កូជីកូ* គ្រវីក្បាល ។ *អូមី* ចេញបញ្ជាយ៉ាងខ្លី ។សាមូរ៉ៃពីរនាក់ដើរតំរង់ទៅរកនាងភ្លាម ។ *កូជីកូ* សូកកាំភ្លើងមួយទៅក្នុងក្រវាត់ក្រណាត់នៅនឹងចង្កេះយ៉ាងរហ័ស រួចលើកកាំភ្លើងមួយទៀតដោយដៃទាំងពីរតំរង់ទៅរក *អូមី*។ កៃកិបកាំភ្លើងត្រូវបានទាញមកក្រោយបន្តិចហើយជាស្រេច ។ នាងនិយាយឡើង :

- *អ៊ីកូតូ ណា ! ដូសូ !*

សាមូរ៉ៃទាំងពីរឈប់ង៉ក់តាមបញ្ជានាងភ្លាម ។

*អូមី* និយាយយ៉ាងញាប់ និងទាំងកំហឹងហើយនៅពេលដែល *កូជីកូ* ស្តាប់ចប់ហើយនាងក៏តបវិញក្នុងសំដីយ៉ាងទន់ភ្លន់ និងយ៉ាងគួរសម ប៉ុន្តែកាំភ្លើងនាងឥតងាកបន្តិចសោះឡើយពីមុខរបស់ *អូមី*។ កៃកំប្រុកត្រូវបានទាញមកក្រោយពាក់កណ្តាលហើយជាស្រេច ។ នាងបញ្ចប់សំដីថា :

- *អ៊ីយេ គូមេន ណាសៃ អូមី-សាន !* ទេ ខ្ញុំសូមទោស *អូមី-សាន !*

*ប្លាក់ថន* នៅឈរចាំមើលដោយឥតលូកលាន់អ្វីទាំងអស់ ។

សាមូរ៉ៃម្នាក់ធ្វើចលនាបន្តិច កៃកំប្រុកត្រូវបានទាញទៅក្រោយដល់គន្លាក់ដ៏មានគ្រោះ



www.budinst.gov.kh www.elibraryofcambodia.org

ថ្ពាក់ភ្លាម តែដៃរបស់ *ភូជីកូ* ឥតញ្ញោចបន្តិចសោះណាឡើយ ។ នាងស្រែកបញ្ជាឡើង :

- *អូកូតូ ណា* !

គ្មានអ្នកណាមួយសង្ស័យថានាងមិនហ៊ានកាច់កៃនោះឡើយ សូម្បីតែ *ប្លាក់ថន* ក៏យល់យ៉ាងដូចនោះដែរ *អូមី* និយាយយ៉ាងកំបុតទៅកាន់ *ភូជីកូ* និងកូនចៅរបស់ខ្លួន ។ ពួកសាមូរ៉ៃថយទៅក្រោយវិញ ឯ *ភូជីកូ* ក៏ដាក់កាំភ្លើងរបស់នាងចុះដែរ តែទោះជាយ៉ាងនេះក្តី ក៏នាងស្ថិតនៅក្នុងស្ថានភាពត្រៀមជានិច្ច ។

*ប្លាក់ថន* សួរ *ម៉ារីកូ* :

- តើ *អូមី* ថាម៉េច ?

- គាត់គ្រាន់តែថាគាត់នឹងយករឿងនេះទៅជំរាប *យ៉ាប៊ូ-សាន* ហើយ ។

- ល្អ ! ប្រាប់វាទៅ ថាខ្ញុំក៏នឹងធ្វើដូចគ្នាដែរ ។

រួចគេបែរទៅរក *ភូជីកូ* :

- *ដូម៉ូ ភូជីកូ-សាន* ។

រួចទើបគេនឹកឃើញពីរបៀបដែល *តូរ៉ាណាកា* និង *យ៉ាប៊ូ* និយាយទៅកាន់ស្ត្រី គេក៏គ្រហឹមបញ្ជា *ម៉ារីកូ* យ៉ាងដាច់ណាត់ :

- មក *ម៉ារីកូ ....អ៊ីកាម៉ាសូ* !

និយាយចប់គេដើរសំដៅទៅរកទ្វារចេញភ្លាម ។ តែ *ភូជីកូ* ស្រែកបន្លឺឡើង :

- *អាន់ជីន-សាន* !

- *ហៃ* ?

*ប្លាក់ថន* ឈប់ងាក់ ។ *ភូជីកូ* លំអោនខ្លួនគោរពហើយនិយាយយ៉ាងរន្ធើនទៅកាន់ *ម៉ារីកូ*។

ភ្នែក *ម៉ារីកូ* ឡើងក្រលង់ដូចប្រាក់កាក់ រួចនាងងក់ក្បាលហើយឆ្លើយតបទៅវិញ បន្ទាប់មកនាងនិយាយជាមួយនឹង *អូមី* ដែលថ្មីបើឈ្មួលឆេវក្នុងចិត្តយ៉ាងណាក្តីក៏ទីបំផុតបានទប់ចិត្តហើយងក់ក្បាលទទួលយល់ព្រមជាមួយផងដែរ ។

- ចុះមានរឿងអីហ្នឹង ?



www.budinst.gov.kh www.elibraryofcambodia.org

- ចាស សូមលោកអត់ធ្មត់បន្តិចទៅ *អាន់ជីន-សាន* ។

*ភូជីកូ* ស្រែកហៅអ្វីមួយ ។ សំលេងមួយបានលាន់តបមកវិញពីក្នុងផ្ទះ ។ នារីអ្នកបំរើម្នាក់បានលេចបញ្ចេញខ្លួនទៅឯរានហាល នៅនឹងដៃនាងមានដាវពីរ ។ ជាដាវសាមូរ៉ៃ ។

*ភូជីកូ* កាន់ដាវទាំងពីរយ៉ាងគោរពហើយលំអោនខ្លួនហុចដាវទាំងពីរទៅអោយ *ប្លាក់ថន* ដោយពោលពាក្យយ៉ាងស្រទន់ ។

*ម៉ារីកូ* ពោល :

- កំនាន់របស់លោកបានលើកឡើងត្រឹមត្រូវណាស់ក្នុងឋានៈជា *ហាតាម៉ូតូ* លោកមានកាតព្វកិច្ចកាន់ដាវទាំងពីររបស់សាមូរ៉ៃ ។ អាចថានេះជាករណីយកិច្ចរបស់លោកតែម្តង ។ នាងយល់ថាគឺជាការមិនសមរមសោះដែលលោកទៅជួបលោកម្ចាស់ *យ៉ាប៊ូ* ដោយគ្មានដាវជាប់នឹងខ្លួននោះ ។ ប្រការនេះទុកដូចជាភាពជំលើយមួយ ។ តាមច្បាប់ទំលាប់យើងគឺជាករណីយកិច្ចមួយដែលត្រូវយកដាវជាប់តាមខ្លួននោះ ។ នាងសួរថាតើលោកយល់ព្រមប្រើដាវទាំងពីរនេះសិនទេ ទោះជាវាមិនសក្តិសមនឹងលោកក្តី ទំរាំលោករកទិញដោយខ្លួនឯងបាន ។

*ប្លាក់ថន* សំលឹងផ្ទាំងមើលទៅ *ម៉ារីកូ* រួចមើល *ភូជីកូ* រួចមើលមកនាងវិញ :

- តើនេះមានន័យថាខ្ញុំជាសាមូរ៉ៃរឺ ? មានន័យថាលោក *តូរ៉ាណាកា* តែងតាំងខ្ញុំជាសាមូរ៉ៃរឺ ?

- ខ្ញុំមិនដឹងដែរ *អាន់ជីន-សាន* ប៉ុន្តែមិនដែលមាន *ហាតាម៉ូតូ* ណាដែលមិនមែនជាសាមូរ៉ៃនោះទេ ។ មិនដែលសោះតែម្តង ។

*ម៉ារីកូ* ងាកបែរទៅសួរ *អូមី* ។ គ្រវីក្បាលហើយឆ្លើយតបទាំងធុញទ្រាន់ ។

- *អូមី-សាន* និយាយថាគាត់ក៏មិនដឹងដែរ ។ ប៉ុន្តែជាការពិតដែល *ហាតាម៉ូតូ* មានបុព្វសិទ្ធិមានដាវជាប់នៅនឹងខ្លួនទោះជានៅចំពោះមុខលោកម្ចាស់ *តូរ៉ាណាកា* ក្តី ។ នេះគឺជាកាតព្វកិច្ចពីព្រោះ *ហាតាម៉ូតូ* ជាអង្គរក្សដ៏ទុកចិត្តបំផុត ម្យ៉ាងទៀតមានតែ *ហាតាម៉ូតូ* ទេដែលមានសិទ្ធិជួបម្ចាស់ខ្លួនបានភ្លាមៗនោះ ។

*ប្លាក់ថន*យកដាវខ្លីមកស៊កនៅចង្កេះមុនបន្ទាប់មកទើបគេសៀតដាវវែងជាក្រោយតាម



www.budinst.gov.kh www.elibraryofcambodia.org

តាមរបៀបដែល *អូមី* បានធ្វើ។ មានអារុំចនៅនឹងខ្លួនហើយ គេដូចជានឹងនរចិត្តជាងមុន។ គេពោលឡើង :

- *អារីកាតូ កូសាម៉ាស៊ីតា កូជីកូ-សាន*។

*កូជីកូ* សំលឹងមើលក្រោមហើយនិយាយតបវិញយ៉ាងស្រទន់។ *ម៉ារីកូ* បក :

- *កូជីកូ-សាន* សូមអនុញ្ញាតពីលោកម្ចាស់ខ្លួនជំរាបថាដោយលោកត្រូវតែរៀនភាសារបស់ពួកយើងអោយបានត្រឹមត្រូវនិងរប៉ាសប់ផុតនោះ នាងមានបំនងជំរាបលោកថាប្រើពាក្យ *ដូម៉ូ* គឺគ្រប់គ្រាន់ណាស់ទៅហើយចំពោះមនុស្សប្រុស មិនចាំបាច់ពាក្យ *អារីកាតូ* ទេ ហើយប្រើពាក្យ *កូសាម៉ាស៊ីតា* ស្រេចចិត្តលោកប្រើ រឺមិនប្រើ ព្រោះនេះជាការគួរសមមិនចាំបាច់ ហើយជាពាក្យដែលនារី១ប្រើតែប៉ុននោះ។

- *ហៃ ដូម៉ូ ភីការីម៉ាស៊ី កូជីកូ-សាន*។

ជាមួយនឹងចំនេះដឹងថ្មី *បា្លក់ថន* ចាប់ផ្ដើមសំលឹងមើល *កូជីកូ* ច្បាស់លាស់ជាងមុន។ ញើសនៅថ្ពិតជាប់លើថ្ងាស់នាងនៅឡើយ។

- សូមប្រាប់ទៅនាងថាក្នុងករណីនេះមួយ ខ្ញុំមិនចាត់ទុកពាក្យ *អារីកាតូ កូសាម៉ាស៊ីតា* ជាពាក្យគួរសមមិនចាំបាច់ចំពោះនាងទេ។

******************

*យ៉ាប៊ូ* សំលឹងមើលជាវម្ដងទៀត។ *បា្លក់ថន* នៅអង្គុយពែនភ្នែនលើម៉ក់មួយទល់មុខ *យ៉ាប៊ូ* ដែលជាកន្លែងកិត្តិយស។ *ម៉ារីកូ* និង *អ៊ីកូរ៉ាស៊ី* នៅអមសងខាង។ ទាំងអស់គ្នាស្ថិតនៅក្នុងបន្ទប់ធំនៃបន្ទាយ។

*អូមី* បានបញ្ចប់ការនិយាយរបស់ខ្លួន។

*យ៉ាប៊ូ* ញាក់ស្មា :

- ក្មួយអែងចាត់ចែងការងារនេះមិនល្អសោះ។ ជាការត្រឹមត្រូវហើយ ដែលក់នាន់ត្រូវមានកាតព្វកិច្ចការពារ *អាន់ជីន-សាន* និងសម្បត្តិទ្រព្យរបស់គេនោះ ។ ជាការត្រឹមត្រូវហើយ



www.budinst.gov.kh www.elibraryofcambodia.org

ដែលគេមានសិទ្ធិសៀតដាវអីលូវនេះ។ ពិតណាំ ក្មួយអែងចាត់ចែងការនេះមិនល្អទាល់តែសោះ តែម្តង។ ខ្ញុំបានប្រាប់ច្បាស់ហើយថា *អាន់ជីន-សាន* ជាភ្ញៀវកិត្តិយសរបស់ខ្ញុំនៅទីនេះ។ សូមទោសគេភ្លាមទៅ។

*អូមី* ងើបឡើងជាបន្ទាន់ទៅលុតជង្គង់មុខ *ប្លាក់ថន* ហើយលំអោនខ្លួនគោរព :

- ខ្ញុំសូមលោកអភ័យទោសចំពោះការភាន់ច្រលំរបស់ខ្ញុំផង *អាន់ជីន-សាន*។

*អូមី លី ម៉ារីកូ* បកប្រាប់ថាបុរសចុងស្រុកទទួលយកការសូមទោសហើយ។ គេលំអោនខ្លួនគោរពម្តងទៀតទើបវិលត្រលប់យ៉ាងនឹងនរទៅអង្គុយកន្លែងដដែលរបស់ខ្លួនវិញ។ ប៉ុន្តែក្នុងដួងចិត្តគេឥតបាននឹងនរដូចអាការៈខាងក្រៅឡើយ ។ អីលូវនេះរូបគេទាំងមូលត្រូវដុតរោលដោយគំនិតតែមួយគត់ គឺសំលាប់ *យ៉ាប៊ូ* អោយខាងតែបាន។

ពោលគឺ *អូមី* បានសំរេចចិត្តធ្វើអ្វីដែលគ្មានអ្នកណាគិតដល់ : សំលាប់អម្ចាស់ និងមេបក្ខសំព័ន្ធរបស់ខ្លួន។

តែនេះមិនមែនដោយហេតុថា គេត្រូវទទួលបញ្ជាអោយសុំទោសបុរសចុងស្រុកនោះទេ។ ក្នុងរឿងនេះ *យ៉ាប៊ូ* បានធ្វើត្រូវ។ គេទទួលស្គាល់ថាគេចាត់ចែងមិនសមស្របមែនថ្វីត្បិតតែ *យ៉ាប៊ូ* បានចេញបញ្ជាយ៉ាងល្ងាក់ល្ងើពេកថ្វាស់អោយដកហូតកាំភ្លើងខ្លី ចេញពី *ប្លាក់ថន* នៅវេលាយប់នេះក្តី ព្រោះថាគេអាចប្រើល្បិចអោយ *ប្លាក់ថន* ទុកកាំភ្លើងនៅឯផ្ទះរួចចាំអែកលួចយក រឺក៏បំផ្លាញវាចោលនៅពេលក្រោយក៏តែបានដែរ។

ហើយ *អាន់ជីន-សាន* ពិតជាធ្វើការសំរេចយ៉ាងត្រឹមត្រូវនៅពេលដែលគេប្រគល់កាំភ្លើងខ្លីទៅអោយកំនាន់របស់គេ ក៏ដូចជាទំរើរបស់ *ភូជីកូ* ផងដែរ។ ហើយនាងពិតជានឹងហ៊ានកាច់កៃ ព្រោះអ្នកណាក៏ដឹងដែរថា *អ៊ូសាគី ភូជីកូ* កំពុងស្វែងរកសេចក្តីស្លាប់ ហើយព្រោះហេតុអ្វីនោះ។ ហើយ *អូមី* ក៏ដឹងដែរថាបើសិនជាពីពេលព្រឹកមិញនេះគេមិនបានសំរេចចិត្តសំលាប់ *យ៉ាប៊ូ* ទេនោះគេប្រាកដជាបោះជំហានដើរទៅមុខប្រឈមនឹងសេចក្តីស្លាប់ ហើយពេលនោះកូនចៅរបស់គេពិតជានឹងអាចដកកាំភ្លើងចេញពីនាងបានជាមិនខាន។ ពេលនោះគេមុខជាស្លាប់ដោយថ្លៃថ្នូរ ហើយនាងនឹងត្រូវទទួលបញ្ជាអោយបញ្ចប់ជីវិតយ៉ាងថ្លៃថ្នូរដូចគ្នាដែរ។ ហើយទាំងប្រុសទាំង



www.budinst.gov.kh www.elibraryofcambodia.org

ស្រីមុខជាដំណាលរឿងដ៏កំសត់នេះតកូនតចៅជាមិនខាន។ ទាំងចំរៀង ទាំងកំនាព្យ រួមទាំងល្ខោន *ណូ* (*) ផង មុខជានឹងលើកឡើងនូវរឿងដ៏ជក់ចិត្ត ដ៏កំសត់ និងពោរពេញដោយវីរភាពរបស់ពួកគេទាំងបីនាក់ជាមិនខាន នោះគឺជារឿងស្រីកំនាន់ និង សាមូរ៉ៃដ៏មានស្វាមីភក្តិដែលបានស្លាប់ក្នុងករណីយកិច្ចរបស់ខ្លួនទាំងពីរនាក់ ព្រោះតែមនុស្សចុងស្រុកម្នាក់ដែលមកពីសមុទ្ទខាងកើត។

ខេសេចក្តីសំរេចរបស់ *អូមី* មិនទាក់ទងអ្វីទៅនឹងការសូមទោសជាសាធារណៈនេះទេ។ មូលហេតុសំខាន់គឺនៅថ្ងៃនេះ យ៉ាប៊ូ បានប្រមាថមើលងាយម្តាយ និងប្រពន្ធ អូមី នៅមុខពួកអ្នកស្រែទាំងអស់ដោយបានអោយអ្នកទាំងពីរនៅឈរចាំកណ្តាលថ្ងៃរាប់ម៉ោង រួចហើយអោយគេត្រលប់ទៅវិញដោយឥតរវីរវល់អ្វី ហាក់ដូចអ្នកស្រែកំប៉ិកកំប៉ុកតែប៉ុននោះ។

ម្តាយ *អូមី* និយាយប្រាប់កូនថា :

- មិនជាការអ្វីទេកូន។ នេះជាបុព្វសិទ្ធិរបស់គាត់។

*មីដូរី* ប្រពន្ធរបស់ *អូមី* ពោលទាំងទឹកភ្នែករហាមដោយភាពអាម៉ាស់ :

- គាត់ជាអម្ចាស់របស់យើង។ សូមលោកប្តីអភ័យទោសដល់ខ្ញុំផង។

*អូមី* និយាយបន្ត :

- ហើយវាមិនទាំងអញ្ជើញម៉ែ និងអូនទៅចូលរួមទទួលវានិងមេទ័ពវានៅឯបន្ទាយថែមទៀត។ ហើយម៉ែនិងអូនជាអ្នករៀបចំម្ហូបអាហារទាំងនេះសោះ ។ គ្រាន់តែម្ហូបនិងស្រាអស់មួយ *កូកូ* ទៅហើយ។

- នេះជាភារកិច្ចរបស់យើងណាកូន។ នេះជាភារកិច្ចរបស់យើងដែលត្រូវបំពេញគ្រប់បំនងរបស់លោកម្ចាស់ *យ៉ាប៊ូ*។

- រួចចុះរឿងបញ្ហារបស់លោកឪនោះ។

- មិនទាន់ជាបញ្ហានៅឡើយទេ។ គ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុននោះ។

- សារពីលោកឪមកបានប្រាប់ថា លោកឪបានលឺថា *យ៉ាប៊ូ* នឹងបញ្ជាលោកឪអោយកោរក្បាលបួសបើមិនអញ្ចឹងទេត្រូវវះពោះខ្លួនឯង ។ ប្រពន្ធ *យ៉ាប៊ូ* ណឹងតែម្តងដែលដើរនិយាយ



www.budinst.gov.kh www.elibraryofcambodia.org

អូតរឿងនេះ។

- នេះគឺអ្នកយកការណ៍ដែលមកលួចខ្សិបប្រាប់ឪពុកអែងតែប៉ុននោះ។ កុំជឿពួកយកការណ៍ទាំងនោះពេក។ តែសូមទោសទៅចុះ លោកកូន ឪពុកអែងមានពេលខ្លះមិនវាងវៃសោះតែម្តង។

- រួចចុះបើរឿងនេះមិនមែនជាពាក្យចចាមអារ៉ាមទេវិញ តើម៉ែអាចមានរឿងរ៉ាវអីដែរទៅ ?

- ទោះមានរឿងអីកើតឡើងក៏ដោយ នេះជា *កាម៉ា* ណាកូន។ យើងត្រូវទទួលយក *កាម៉ា* របស់យើង។

- ទេ ការប្រមាថទាំងនេះមិនអាចទទួលយកបានទេ។

- ម៉ែសូមអង្វរកូន សូមកូនទទួលយកទៅ។

- ខ្ញុំជាអ្នកអោយសំពៅ អោយ *អាន់ជីន-សាន* និងពួកចុងស្រុកថ្មីទៅអោយ *យ៉ាប៊ូ* ហើយខ្ញុំជាអ្នកដែលបានអោយគន្លឹះទៅ *យ៉ាប៊ូ* ដើម្បីអាចដកខ្លួនចេញផុតពីអន្ទាក់របស់ *តូរ៉ាណាកា*។ ការជួយរបស់ខ្ញុំធ្វើអោយ *យ៉ាប៊ូ* ឡើងកិត្យានុភាពសំបើមណាស់។ អីលូវនេះគាត់បានទទួលជារង្វាន់មិត្តរួបបញ្ជាក់ថាគាត់ជាមនុស្សទីពីរនៅក្នុងកងទ័ពបូព៌ាបន្ទាប់ពី *តូរ៉ាណាកា* ហើយតើគាត់បានអីសងមកយើងវិញទៅ ? ការប្រមាថមើលងាយដ៏ថោកទាបមួយ។

- ទទួលយក *កាម៉ា* យើងទៅចុះ។

- លោកប្តី ខ្ញុំសូមអង្វរ សូមស្តាប់លោកម៉ែទៅ។

- ខ្ញុំមិនអាចរស់ក្នុងក្តីអាម៉ាស់យ៉ាងនេះបានទេ ។ ខ្ញុំត្រូវតែសងសឹកអោយបានបន្ទាប់មកខ្ញុំនិងធ្វើអត្តឃាតជាក្រោយ ធ្វើយ៉ាងនេះទើបខ្ញុំអាចលុបលាងក្តីអាម៉ាស់នេះបាន។

- ម៉ែសូមអង្វរកូនជាចុងក្រោយ សូមកូនទទួលយក *កាម៉ា* ខ្លួនទៅ។

- *កាម៉ា* ខ្ញុំគឺត្រូវសំលាប់ *យ៉ាប៊ូ* អោយខាងតែបាន។

លោកយាយដកដង្ហើមធំ :

- ល្អ កូនជាប្រុសដើមទ្រូងប្រាំហត្ថ កូនមានសិទ្ធិធ្វើការសំរេច។រឿងវាយ៉ាងម៉េចវាទៅ



www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងនោះឯង ។ ប៉ុន្តែសំលាប់ *យ៉ាប៊ូ* មិនមែនជារឿងលេងធេងនោះទេ ។ យើងត្រូវរៀបចំគំរោងការ ។ កូនប្រុសវាក៏ត្រូវតែកំចាត់ចេញដែរ ។ ទាំង *អ៊ីកូរ៉ាជី* ក៏ដូចគ្នាដែរ ពិសេស *អ៊ីកូរ៉ាជី* នេះតែម្តង ។ រួចរាល់ហើយឪពុកអែងនឹងមានសិទ្ធិដឹកនាំក្រុមសំព័ន្ធយើងស្របច្បាប់ហើយ ។

- តើយើងត្រូវចាត់ចែងរបៀបណាទៅម៉ែ ?

- យើងទាំងពីរនាក់នឹងរៀបចំផែនការ ។ ហើយត្រូវចេះអត់ធ្មត់ *វេ* ? ហើយយើងត្រូវពិគ្រោះជាមួយឪពុកអែងផង ។

- ចុះលោកម្ចាស់ *តូរ៉ាណាកា* ? គាត់បានប្រគល់ដាវគាត់ទៅអោយ *យ៉ាប៊ូ* ណាំ ។

- ម៉ែយល់ថា លោកម្ចាស់ *តូរ៉ាណាកា* គ្រាន់តែចង់បាន *អ៊ីស៊ូ* មួយខ្លាំងរឹងមាំ និងជាវង្ស ***អណ្តូរាជ*** មួយតែប៉ុននោះ ។ មិនមែនលោកចង់បានវង្សសំព័ន្ធមិត្តនោះទេ ។ *យ៉ាប៊ូ* គិតថាខ្លួនជាសំព័ន្ធមិត្តរបស់លោកម្ចាស់ *តូរ៉ាណាកា*។ តែម៉ែយល់ថា *តូរ៉ាណាកា* ស្អប់ណាស់រឿងសំព័ន្ធមិត្តនេះ ។ ក្រុមយើងនឹងរីកចំរើនក្នុងឋានៈជាអណ្តាប់ *តូរ៉ាណាកា* វិក្នុងឋានៈជា ***អណ្តូរាជអ៊ីស៊ីដូ*** ។ តើធ្វើការជ្រើសរើសយកអ្នកណាមួយ ? ហើយតើធ្វើឃាតយ៉ាងម៉េច ?

*អូមី* នៅចាំបានពីភាពរីករាយរបស់គេដែលច្រាលចេញមកនៅពេលដែលគេបានធ្វើការសំរេចជាចុងក្រោយនេះ ។ ហើយគេនៅចាំពីអារម្មណ៍នេះនៅឡើយនៅពេលនេះ ។ ប៉ុន្តែអារម្មណ៍ទាំងនេះឥតលេចចេញនៅលើផ្ទៃមុខរបស់គេឡើយ ក្នុងពេលដែលគេតាមសំលឹងមើល *យ៉ាប៊ូ អាន់ជីន-សាន ម៉ារីកូ* និង *អ៊ីកូរ៉ាជី* ។ តែ និង ស្រា ត្រូវបានបំរើដោយពួកនារីអ្នកបំរើដែលត្រូវបានជ្រើសរើសយ៉ាងម៉ត់ចត់ពី *មីស៊ីម៉ា* សំរាប់ *យ៉ាប៊ូ*។ ទាំងអស់គ្នារង់ចាំ *យ៉ាប៊ូ* ចាប់ផ្តើម ។

បន្ទប់ដែលគេកំពុងជួបជុំគ្នានេះមានខ្យល់ចេញចូលល្អ ហើយចំល្មមអាចមនុស្សសាមសិបនាក់អង្គុយទទួលទានបាយជុំគ្នាបាន ។ នៅមានបន្ទប់ និងជើងក្រានជាច្រើនទៀតសំរាប់ពួកការពារនិងអ្នកបំរើ ។ ទាំងអស់នេះថ្មីត្បិតតែត្រូវបានសាងសង់ដោយប្រញាប់ប្រញាល់ និង ក្នុងលក្ខណៈបណ្តោះអាសន្នក្តី ក៏ប៉ុន្តែជាសំនង់មាំទាំ និងងាយស្រួលការពារ ។ ថ្វីត្បិតតែការចំនាយនេះត្រូវយកចេញពីដែនដីដែលទើបត្រូវបានពង្រីកអោយគេក្តី ក៏ *អូមី* មិនខ្វាយខ្វល់ដែរ ។ ព្រោះនេះជាករណីយកិច្ចរបស់គេ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលទទួលបានបញ្ជាពី *យ៉ាប៊ូ* *អូមី* បានដើរកែនប្រមូលសំភារៈអស់បួនភូមិដើម្បីយកមកសាងសង់អគារទាំងប៉ុន្មាននេះ ហើយ *អ៊ីកូរ៉ាជី* ជាអ្នកផ្តល់ម៉ក់ និងកំរាល ល្អៗ ដែលរកគ្មាននៅតាមភូមិទាំងនេះ ។

*អូមី* សែនពេញចិត្ត និងកិច្ចការដែលគេបានធ្វើនេះ ។ អីលូវនេះបន្ទាយជ្រកសំរាប់សាមូរ៉ៃទាំងបីពាន់នាក់ត្រូវបានសាងសង់ហើយជាស្រេចនៅពីលើកូនភ្នំហើយជាប់នឹងផ្លូវទៅភូមិ និងសមុទ្រតែម្តង ។ អីលូវនេះទីភូមិត្រូវបានការពារយ៉ាងជិតជុំតាមផ្លូវគោក ។ បើសិនជាមានគ្រោះអាសន្នមកពីផ្លូវសមុទ្រវិញនោះ លោកម្ចាស់របស់គេមុខជានឹងទទួលសញ្ញាប្រកាសអាសន្នយ៉ាងគ្រប់គ្រាន់ដើម្បីគេចខ្លួន ។

ប៉ុន្តែអញគ្មានអម្ចាស់ទៀតទេ ។ តើអញប់រើអ្នកណាវិញអីលូវនេះ ?-*អូមី* ដណ្តឹងសួរខ្លួនឯង ។ *អ៊ីកាវ៉ា ជូគីយូ* ? រឺមួយ *តូរ៉ាណាកា* ផ្ទាល់តែម្តង ? តើ *តូរ៉ាណាកា* នឹងផ្តល់តបមកវិញនូវអ្វីដែលអញចង់បានរឺទេ ? រឺមួយ *អ៊ីស៊ីដូ* វិញ ? *អ៊ីស៊ីដូ* ពិបាកទាក់ទងមែនទែន *ទេ* ?

នៅរសៀលនេះ *យ៉ាប៊ូ* បានកោះហៅ *អ៊ីកូរ៉ាជី អូមី* ហើយនឹងមេទ័ពទាំងបួនដើម្បីដាក់អនុវត្តផែនការសំងាត់របស់លោកក្នុងការបម្រើកពួកសាមូរ៉ៃខ្មាន់កាំភ្លើងទាំងប្រាំរយនាក់ ។*អ៊ីកូរ៉ាជី* និងទទួលធ្វើជាមេបញ្ជាការ ឯ *អូមី* ទទួលភារកិច្ចជានាយកងរយ ។ ពួកគេបានពិភាក្សាពីរបៀបធ្វើយ៉ាងម៉េចដើម្បីបញ្ចុះបញ្ចូលមនុស្សរបស់ *តូរ៉ាណាកា* អោយចូលក្នុងកងឯកភាពរបស់គេហើយនឹងចាត់ការពួកនេះយ៉ាងម៉េចបើសិនជាពួកនេះចង់ក្បត់នោះ ។

*អូមី* បានលើកជាសំនើអោយរៀបចំជាសំងាត់បំផុតនូវកងរយបីកងថែមទៀតដើម្បីរឹកហាត់ដោយលួចលាក់នៅឯចុងជ្រោយម្ខាងទៀត គ្រាន់ទុកជាកងជំនួយ ជាកងបំពេញបន្ថែម និងជាកងត្រៀមបង្ការតទប់នឹងសកម្មភាពដ៏ប៉ិនប្រសប់ និងដ៏មានពិសពុលរបស់ *តូរ៉ាណាកា* ។

*អ៊ីកូរ៉ាជី* បានលើកជាសំនួរឡើង :

- អ្នកណាជាអ្នកបញ្ជាទ័ពរបស់ *តូរ៉ាណាកា* ? ហើយ *តូរ៉ាណាកា* ចាត់អ្នកណាអោយធ្វើមេបញ្ជាការរង ?

*យ៉ាប៊ូ* ឆ្លើយតប :



www.budinst.gov.kh www.elibraryofcambodia.org

- អត់សំខាន់ទេរឿងហ្នឹង ។ ខ្ញុំបានចាត់បញ្ហាមេទ័ពជំនួយការទាំងប្រាំរបស់វាអោយទទួលភារកិច្ចអារកវាចោល បើសិនជាមានការចាំបាច់ ។ ពាក្យសំងាត់ដើម្បីសំលាប់ *តូរ៉ាណាកា* និងពួកចំនួលក្រៅទាំងអស់គឺ " *ដើមពុទ្រា* " ។ *អ៊ីកូរ៉ាជី-សាន* ស្អែកនេះលោករៀបចំជ្រើសរើសមនុស្ស ខ្ញុំនឹងពិនិត្យឯកភាពលើម្នាក់ម្តង១ដោយផ្ទាល់ខ្លួនខ្ញុំ ។ ហើយពួកវាទាំងអស់មិនត្រូវដឹងពីយុទ្ធសាស្ត្ររបស់ខ្ញុំក្នុងការរឹកបាត់អង្គភាពកាំភ្លើងនេះជាដាច់ខាត ។

*អូមី* សំលឹងមើល *យ៉ាប៊ូ* ទាំងអារម្មណ៍ថ្មីក្នុងភាពត្រេកអរណ្តែតអណ្តូងនៃការសងសឹកនេះ ។ សំលាប់ *យ៉ាប៊ូ* ជាការងាយទេ ប៉ុន្តែការសំលាប់នេះត្រូវតែមានកិច្ចប្រទាក់ក្រឡាអោយបានល្អ ។ ទាល់តែយ៉ាងនេះទើបឪពុកគេ រី បងច្បងរបស់គេអាចទទួលដឹកនាំក្រុមបក្សព័ន្ធ និង តំបន់ *អ៊ីស៊ូ* បាន ។

រួចទើប *យ៉ាប៊ូ* ចូលសាច់រឿងសំខាន់ :

- *ម៉ារីកូ-សាន* សូមប្រាប់ទៅអ្នកចុងស្រុកនេះផង ថាចាប់ពីពេលស្អែកនេះទៅខ្ញុំចង់អោយគាត់ចាប់ផ្តើមបង្ហាត់ទ័ពខ្ញុំអោយចេះបាញ់កាំភ្លើងដូចពួកអ្នកចុងស្រុកអ៊ីចឹង ហើយប្រាប់ថាខ្ញុំចង់រៀនអោយដឹងទាំងអស់ពីរបៀបធ្វើសង្គ្រាមរបស់អ្នកចុងស្រុក ។

*ម៉ារីកូ* រំលឹក *យ៉ាប៊ូ* :

- សូមទោសលោកម្ចាស់ កាំភ្លើងទាល់តែប្រាំមួយថ្ងៃទៀតទើបមកដល់ ចាស ។

*យ៉ាប៊ូ* ឆ្លើយតប :

- ទ័ពរបស់ខ្ញុំមានគ្រប់គ្រាន់ដើម្បីចាប់ផ្តើមរៀនហើយ ។ ខ្ញុំចង់អោយគាត់ផ្តើមបង្ហាត់ពីស្អែកនេះទៅ ។

*ម៉ារីកូ* បកប្រែប្រាប់ទៅ *ប្លាក់ថន* ១សួរតបមកវិញ :

- តើគាត់ចង់ដឹងពីរឿងសង្គ្រាមត្រង់ចំនុចណា ?

- គាត់ចង់ដឹងទាំងអស់ ។

- ប៉ុន្តែចំនុចណាពិសេសនោះ ?

*ម៉ារីកូ* សួរទៅ *យ៉ាប៊ូ*។



www.budinst.gov.kh www.elibraryofcambodia.org

- *យ៉ាប៊ូ-សាន* មានប្រសាសន៍ថា តើលោកធ្លាប់ចូលរួមការប្រយុទ្ធណាមួយលើគោកដែរ រឺទេ ?

- បាទ ធ្លាប់នៅហ្វូឡង់ និង ម្តងនៅបារាំង ។

- *យ៉ាប៊ូ-សាន* មានប្រសាសន៍ថាល្អណាស់ ។ លោកចង់យល់ពីយុទ្ធសាស្ត្ររបស់ជនជាតិអឺរ៉ុប ។ លោកចង់ដឹងថាតើនៅស្រុកលោកគេធ្វើសង្គ្រាមបែបណា ? លោកចង់ដឹងលំអិត ។

*ប្លាក់ថន* គិតមួយសន្ទុះទើបឆ្លើយតប :

- ជំរាប *យ៉ាប៊ូ-សាន* ថាខ្ញុំអាចបង្ហាត់មនុស្សអោយគាត់ប៉ុន្មាននាក់ក៏បានដែរ ហើយខ្ញុំយល់ច្បាស់លាស់ណាស់នូវអ្វីដែលគាត់ចង់ដឹងនោះ ។

គេបានដឹងមួយចំនួនធំដែរពីរបៀបធ្វើសង្គ្រាមរបស់ជនជាតិជប៉ុន អាស្រ័យដោយបព្វជិត *ដូមិញ្ញូ* ដែលជាអ្នកឯកទេសមួយក្នុងរឿងនេះ ហើយដែលបានពន្យល់គេថា :

- គិតសព្វ១ទៅ ការយល់ដឹងពីរឿងនេះសំខាន់ណាស់ ។ បព្វជិតម្នាក់១ត្រូវចេះការពារសាវ៉ករបស់ខ្លួន មិនអីចឹង ? ហើយមិនគឺពួក *កុងគីស្តាឌ័រ* ដ៏ជាញជ័យរបស់យើងទេអ្វី ដែលជាមុខលំពែងរបស់វិហារយើងនោះ ? ហើយមិនគឺខ្ញុំទេអ្វីដែលនៅជាមួយពួកនេះក្នុងការប្រយុទ្ធនៅភពថ្មី និងនៅភីលីពីន ហើយដែលបានសិក្សាពួកនេះអស់រយៈពេលម្ភៃឆ្នាំមកហើយនេះ ? ខ្ញុំយល់ដឹងពីសង្គ្រាមណាលោក ។ ខ្ញុំយល់ដឹងពីសង្គ្រាម ។នេះគឺជាភារកិច្ចរបស់ខ្ញុំ ។នេះគឺជាឆន្ទៈរបស់ព្រះជាម្ចាស់ដែលអោយរូបខ្ញុំត្រូវយល់ដឹងពីសង្គ្រាម ។ ប្រហែលព្រះជាម្ចាស់ហើយដែលបញ្ជូនលោកមកអោយខ្ញុំបង្រៀន បង្ការក្រែងខ្ញុំស្លាប់បាត់ទៅ ។ សូមលោកស្តាប់ខ្ញុំណា៎ ពួកដែលនៅក្នុងគុកទាំងនេះគឺជាគ្រូរបស់ខ្ញុំពីរឿងយុទ្ធសាស្ត្រសង្គ្រាមរបស់ជនជាតិជប៉ុនហើយ ។ អីចឹងហើយទើបពេលនេះខ្ញុំអាចដឹងបានថាម៉េចពួកនេះធ្វើសង្គ្រាមរបៀបម៉េច ហើយធ្វើម៉េចបង្ក្រាបពួកនេះបាន និងរបៀបម៉េចពួកនេះអាចបង្ក្រាបយើងបាន ។ សូមលោកត្រូវចងចាំអោយច្បាស់ណា៎ ខ្ញុំសូមជំរាបលោកនូវអាថិកំបាំងមួយ : សូមលោកកុំយកអាវុធទំនើប និងវិធីសាស្ត្រទំនើបទៅផ្គុំជាមួយនិងភាពសាហាវរបស់ពួកជប៉ុនអោយសោះ បើមិនអីចឹងទេពួកវានឹងកំទេចយើងម៉ត់នៅលើដីគោកជាមិនខាន ។



www.budinst.gov.kh www.elibraryofcambodia.org

*ភ្លាក់ថន* សំរេចថារឿងនេះទុកអោយព្រះជាអ្នកកំនត់ទៅចុះ ។ គោពោលបន្ត :

- សូមជំរាបលោកម្ចាស់ *យ៉ាប៊ូ* ថាខ្ញុំអាចជួយគាត់បានយ៉ាងច្រើន ។ ទាំងលោកម្ចាស់ *តូរ៉ាណាកា* ក៏អីចឹងដែរ ខ្ញុំអាចធ្វើអោយកងទ័ពរបស់ពួកគាត់គ្មានអ្នកណាយកឈ្នះបានឡើយ ។

- លោកម្ចាស់ *យ៉ាប៊ូ* មានប្រសាសន៍ថាបើព័តិមានរបស់លោកបង្ហាញអោយឃើញថាពិតជាមានប្រយោជន៍មែននេះ លោកនឹងតំលើងប្រាក់បៀវត្សរបស់លោកពីពីររយសែសិប *កូគូ* ដែលលោកម្ចាស់ *តូរ៉ាណាកា* ផ្តល់អោយនោះទៅដល់ប្រាំរយ *កូគូ* ក្នុងរយៈពេលតែមួយខែក្រោយនេះ ។

-សូមអរគុណគាត់ផង ។ ប៉ុន្តែសូមជំរាបគាត់ថាបើសិនជាខ្ញុំបំពេញកិច្ចការទាំងអស់នេះសំរាប់គាត់ ខ្ញុំសូមកិច្ចអនុគ្រោះមួយចំនួនជាសំនងវិញ នោះគឺខ្ញុំចង់អោយគាត់លុបអាជ្ញាសឹកលើភូមិនេះ ហើយក្នុងរយៈពេលប្រាំខែខ្ញុំសុំយកសំពៅ និងនាវិករបស់ខ្ញុំមកវិញ ។

*ម៉ារីកូ* តប :

- *អាន់ជីន-សាន* លោកមិនអាចតថ្លៃជាមួយលោកម្ចាស់ដូចតថ្លៃជាមួយឈ្មួញលក់ដូរបានទេ ។

- សូមអ្នកស្រីមេត្តាសួរគាត់សាកទៅមើល ។ ថានេះជាសំនូមពរដ៏តូចមួយទៅចុះ ។ ជាសំនូមពររបស់ភ្ញៀវកិត្តិយស និងជាអនាគតអណ្តាប់ម្នាក់ ។

*យ៉ាប៊ូ* ជ្រួញចិញ្ចើមហើយឆ្លើយតបយ៉ាងវែង :

- *យ៉ាប៊ូ-សាន* មានប្រសាសន៍ថា រឿងភូមិគ្មានអ្វីសំខាន់ទេ ។ ពួកអ្នកភូមិនេះទាល់តែភ្លើងដេញគូថទើបធ្វើកើត ។ សូមលោកកុំទៅខ្វល់ខ្វាយអីពីរឿងហ្នឹង ។ ចំនែកសំពៅវិញគឺជាការទទួលខុសត្រូវរបស់ *តូរ៉ាណាកា* តែលោកម្ចាស់ជឿថា លោកនឹងបានសំពៅលោកវិញក្នុងពេលឆាប់ៗខាងមុខនេះ ។ លោកម្ចាស់ស្នើអោយខ្ញុំលើកសំនូមពរលោកជូនទៅលោកម្ចាស់ *តូរ៉ាណាកា* នៅពេលណាដែលខ្ញុំទៅដល់ *យេដូ* ។ ខ្ញុំនឹងធ្វើរឿងនេះ *អាន់ជីន-សាន*។

- សូមជួយសូមទោសលោកម្ចាស់ *យ៉ាប៊ូ* ផង ប៉ុន្តែសុំអោយគាត់លុបបញ្ជារបស់គាត់ចោលចេញ ។ លុបនៅយប់នេះតែម្តង ។



www.budinst.gov.kh www.elibraryofcambodia.org

- គាត់ទើបឆ្លើយថាទេអំបាញ់មិញនេះឯង *អាន់ជីន-សាន*។ នៅចចេសទៀត គឺមិនសមរម្យទេ ។

- បាទ ខ្ញុំយល់ហើយ ប៉ុន្តែសូមស្នើគាត់ម្តងទៀតទៅមើល ។ នេះជារឿងសំខាន់ណាស់សំរាប់ខ្ញុំ ។

- លោកម្ចាស់មានប្រសាសន៍ថា លោកត្រូវតែចេះអត់ធ្មត់ ។ សូមលោកកុំរវីរវល់ខ្វល់ខ្វាយពីរឿងពួកអ្នកភូមិនេះធ្វើអី ។

*ប្លាក់ថន* ងក់ក្បាល រួចគេស់រេចចិត្តឡើង :

- សូមអរគុណ ។ ខ្ញុំយល់ហើយ បាទ ។ សូមអ្នកស្រីអរគុណ *យ៉ាប៊ូ-សាន* ផង ប៉ុន្តែសូមអ្នកស្រីជំរាបគាត់ថាខ្ញុំមិនអាចរស់នៅក្នុងភាពអាម៉ាស់នេះបានឡើយ ។

*ម៉ារីកូ* ឡើងមុខស្លាំង :

- លោកថាម៉េច ?

- ខ្ញុំមិនអាចរស់ក្នុងក្តីអាម៉ាស់ដោយសារតែទំងន់នៃភូមិនេះលើមនសិការរបស់ខ្ញុំបានទេ ។ កិត្តិយសរបស់ខ្ញុំត្រូវរលាយសាបសូន្យអស់ហើយ ។ ខ្ញុំមិនអាចទ្រាំនឹងសភាពនេះបានទេ ។ នេះគឺផ្ទុយនឹងជំនឿជាគ្រីស្តសាសនិករបស់ខ្ញុំ ។ ខ្ញុំត្រូវតែធ្វើអត្តឃាតអោយហើយទៅ ។

- ធ្វើអត្តឃាត ?

- បាទ ។ នេះគឺជាការសំរេចរបស់ខ្ញុំ ។

*យ៉ាប៊ូ* និយាយកាត់

*- ណាន ចា ម៉ារីកូ-សាន ?*

*ម៉ារីកូ* បកប្រែប្រាប់យ៉ាងរដាក់រដុបនូវអ្វីដែល *ប្លាក់ថន* បាននិយាយ ។ *យ៉ាប៊ូ* លើកសំនួរសួរ ហើយ *ម៉ារីកូ* ឆ្លើយតបទៅវិញ រួច *យ៉ាប៊ូ* ក៏និយាយឡើង :

- នេះបើសិនជានាងមិនមានប្រតិកម្មទេនោះ រឿងនេះអាចគ្រាន់តែជារឿងកំប្លែងមួយប៉ុណ្ណោះ *ម៉ារីកូ-សាន*។ ម៉េចបានជានាងខ្វល់ខ្វាយម្ល៉េះ ? ម៉េចបានជានាងហ៊ាននិយាយថាវាពិតជាហ៊ានធ្វើមែន ?



www.budinst.gov.kh www.elibraryofcambodia.org

*ប្លាក់ថន* សំរេចថារឿងនេះទុកអោយព្រះជាអ្នកកំនត់ទៅចុះ ។ គោពោលបន្ត :

- សូមជំរាបលោកម្ចាស់ *យ៉ាប៊ូ* ថាខ្ញុំអាចជួយគាត់បានយ៉ាងច្រើន ។ ទាំងលោកម្ចាស់ *តូរ៉ាណាកា* ក៏អ៊ីចឹងដែរ ខ្ញុំអាចធ្វើអោយកងទ័ពរបស់ពួកគាត់គ្មានអ្នកណាយកឈ្នះបានឡើយ ។

- លោកម្ចាស់ *យ៉ាប៊ូ* មានប្រសាសន៍ថាបើព័តិមានរបស់លោកបង្ហាញអោយឃើញថាពិតជាមានប្រយោជន៍មែននេះ លោកនឹងតំលើងប្រាក់បៀវត្សរបស់លោកពីពីររយសែសិប *កូគូ* ដែលលោកម្ចាស់ *តូរ៉ាណាកា* ផ្តល់អោយនោះទៅដល់ប្រាំរយ *កូគូ* ក្នុងរយៈពេលតែមួយខែក្រោយនេះ ។

-សូមអរគុណគាត់ផង ។ ប៉ុន្តែសូមជំរាបគាត់ថាបើសិនជាខ្ញុំបំពេញកិច្ចការទាំងអស់នេះសំរាប់គាត់ ខ្ញុំសូមកិច្ចអនុគ្រោះមួយចំនួនជាសំនងវិញ នោះគឺខ្ញុំចង់អោយគាត់លុបអាជ្ញាសឹកលើភូមិនេះ ហើយក្នុងរយៈពេលប្រាំខែខ្ញុំសុំយកសំពៅ និងនាវិករបស់ខ្ញុំមកវិញ ។

*ម៉ារីកូ* តប :

- *អាន់ជីន-សាន* លោកមិនអាចតថ្លៃជាមួយលោកម្ចាស់ដូចតថ្លៃជាមួយឈ្មួញលក់ដូរបានទេ ។

- សូមអ្នកស្រីមេត្តាសួរគាត់សាកទៅមើល ។ ថានេះជាសំនូមពរដ៏តូចមួយទៅចុះ ។ ជាសំនូមពររបស់ភ្ញៀវកិត្តិយស និងជាអនាគតអណ្តាប់ម្នាក់ ។

*យ៉ាប៊ូ* ជ្រួញចិញ្ចើមហើយឆ្លើយតបយ៉ាងវែង :

- *យ៉ាប៊ូ-សាន* មានប្រសាសន៍ថា រឿងភូមិគ្មានអ្វីសំខាន់ទេ ។ ពួកអ្នកភូមិនេះទាល់តែភ្លើងដេញតូចទើបធ្វើកើត ។ សូមលោកកុំទៅខ្វល់ខ្វាយអីពីរឿងហ្នឹង ។ ចំនែកសំពៅវិញគឺជាការទទួលខុសត្រូវរបស់ *តូរ៉ាណាកា* តែលោកម្ចាស់ជឿថា លោកនឹងបានសំពៅលោកវិញក្នុងពេលឆាប់ៗខាងមុខនេះ ។ លោកម្ចាស់ស្នើអោយខ្ញុំលើកសំនូមពរលោកជូនទៅលោកម្ចាស់ *តូរ៉ាណាកា* នៅពេលណាដែលខ្ញុំទៅដល់ *យេដូ* ។ ខ្ញុំនឹងធ្វើរឿងនេះ *អាន់ជីន-សាន*។

- សូមជួយសូមទោសលោកម្ចាស់ *យ៉ាប៊ូ* ផង ប៉ុន្តែសុំអោយគាត់លុបបញ្ជារបស់គាត់ចោលចេញ ។ លុបនៅយប់នេះតែម្តង ។



www.budinst.gov.kh www.elibraryofcambodia.org

- គាត់ទើបឆ្លើយថាទេអំបាញ់មិញនេះឯង *អាន់ជីន-សាន*។ នៅចចេសទៀត គឺមិនសមរម្យទេ។

- បាទ ខ្ញុំយល់ហើយ ប៉ុន្តែសូមស្នើគាត់ម្តងទៀតទៅមើល។ នេះជារឿងសំខាន់ណាស់សំរាប់ខ្ញុំ។

- លោកម្ចាស់មានប្រសាសន៍ថា លោកត្រូវតែចេះអត់ធ្មត់។ សូមលោកកុំរវីរវល់ខ្វល់ខ្វាយពីរឿងពួកអ្នកភូមិនេះធ្វើអី។

*ភ្លាក់ថន* ងក់ក្បាល រួចគេសំរេចចិត្តឡើង :

- សូមអរគុណ។ ខ្ញុំយល់ហើយ បាទ។ សូមអ្នកស្រីអរគុណ *យ៉ាប៊ូ-សាន* ផង ប៉ុន្តែសូមអ្នកស្រីជំរាបគាត់ថាខ្ញុំមិនអាចរស់នៅក្នុងភាពអាម៉ាស់នេះបានឡើយ។

*ម៉ារីកូ* ឡើងមុខស្លាំង :

- លោកថាម៉េច ?

- ខ្ញុំមិនអាចរស់ក្នុងក្តីអាម៉ាស់ដោយសារតែទំងន់នៃភូមិនេះលើមនសិការរបស់ខ្ញុំបានទេ។ កិត្តិយសរបស់ខ្ញុំត្រូវរលាយសាបសូន្យអស់ហើយ។ ខ្ញុំមិនអាចទ្រាំនឹងសភាពនេះបានទេ។ នេះគឺផ្ទុយនឹងជំនឿជាគ្រិស្តសាសនិករបស់ខ្ញុំ។ ខ្ញុំត្រូវតែធ្វើអត្តឃាតអោយហើយទៅ។

- ធ្វើអត្តឃាត ?

- បាទ។ នេះគឺជាការសំរេចរបស់ខ្ញុំ។

*យ៉ាប៊ូ* និយាយកាត់

- *ណាន ដា ម៉ារីកូ-សាន* ?

*ម៉ារីកូ* បកប្រែប្រាប់យ៉ាងរដាក់រដុបនូវអ្វីដែល *ភ្លាក់ថន* បាននិយាយ។ *យ៉ាប៊ូ* លើកសំនួរសួរ ហើយ *ម៉ារីកូ* ឆ្លើយតបទៅវិញ រួច *យ៉ាប៊ូ* ក៏និយាយឡើង :

- នេះបើសិនជានាងមិនមានប្រតិកម្មទេនោះ រឿងនេះអាចគ្រាន់តែជារឿងកំប្លែងមួយប៉ុណ្ណោះ *ម៉ារីកូ-សាន*។ ម៉េចបានជានាងខ្វល់ខ្វាយម្ល៉េះ ? ម៉េចបានជានាងហ៊ាននិយាយថាវាពិតជាហ៊ានធ្វើមែន ?



www.budinst.gov.kh www.elibraryofcambodia.org

- នាងខ្ញុំមិនដឹងដែរ លោកម្ចាស់ ។ គាត់បាក់ដូច........នាងខ្ញុំមិនដឹងដែរ.......

សំលេងនាងអូស១ ។

- *អូមី-សាន* ?

- ការធ្វើអត្តឃាតគឺផ្ទុយនឹងជំនឿគ្រីស្តសាសនាហើយលោកម្ចាស់ ។ ពួកវាមិនដែលធ្វើអត្តឃាតដូចពួកយើងទេ ។ គឺមិនដូចរបៀបពួកយើងជាសាមូរ៉ៃនោះទេ ។

- *ម៉ារីកូ-សាន* នាងជាអ្នកកាន់សាសនាគ្រីស្តដែរ មែនទេ ?

- ចាស លោកម្ចាស់ ។ ធ្វើអត្តឃាតគឺជាបាបកម្មធ្ងន់ណាស់ ។ នេះគឺផ្ទុយនឹងពាក្យប្រដៅរបស់ព្រះជាម្ចាស់ ។

- *អ៊ីកូរ៉ាជី-សាន* ? តើលោកយល់យ៉ាងម៉េច ?

- នេះគឺជាការបំភាន់ទេ ។ អានេះមិនមែនជាគ្រីស្តសាសនិកអីទេ ។ លោកម្ចាស់នៅចាំបានថ្ងៃជួបវាដំបូងទេ ទាន ? លោកម្ចាស់មានចាំទេថាតើវាធ្វើម៉េចខ្លះដាក់បព្វជិតនោះ ? ហើយតើលោកម្ចាស់នៅចាំទេថាវាសុខចិត្តអោយ *អូមី-សាន* ធ្វើអីខ្លះលើរូបវាដើម្បីជួយសង្គ្រោះក្មេងប្រុសម្នាក់នោះ ?

*យ៉ាប៊ូ* ញញឹមរំលឹកដល់ថ្ងៃ និងយប់នោះ :

- ពិតហើយ ខ្ញុំឯកភាព ។ វាមិនមែនជាគ្រីស្តសាសនិកទេ *ម៉ារីកូ-សាន*។

- នាងខ្ញុំសូមលោកម្ចាស់អភ័យទោស តែនាងខ្ញុំមិនយល់ទេ ។ តើរឿងបព្វជិតនោះវាយ៉ាងម៉េច ?

*យ៉ាប៊ូ* និយាយប្រាប់នាង ពីថ្ងៃដែល *ប្លាក់ថន* និង បព្វជិតជួបគ្នាលើកទីមួយ ។

*ម៉ារីកូ* ពោលសួរទាំងស្រលាំងកាំង :

- គាត់ប្រមាថសញ្ញាខ្វែង ?

- ហើយកាច់ខ្វែចកាច់ខ្ទីរបោះចោលទៅលើដីទៀតផង -*អ៊ីកូរ៉ាជី* បន្ថែម-ទាំងអស់នេះសុទ្ធតែជាការបំភាន់តែប៉ុននោះ ទាន ។ បើរឿងទាក់ទិននឹងភូមិនេះប៉ុនណឹងធ្វើអោយវាបាត់បង់កិត្តិយសនោះមែន ចុះវានៅឈរជ្រងោរកន្លែងនេះធ្វើអីទៀតបើ *អូមី-សាន* បាញ់នោមច្រាស់



www.budinst.gov.kh www.elibraryofcambodia.org

បំបាក់មុខវាយ៉ាងណឹងទៅហើយនោះ ?

*ម៉ារីកូ* បន្ថែម :

- លោកម្ចាស់ថាម៉េច ? អោយនាងខ្ញុំសូមទោសផងចុះ តែនាងខ្ញុំស្តាប់មិនយល់ទេ ។

*យ៉ាហ្វ៊ូ* ពោលទៅកាន់ *អូមី* :

- ពន្យល់ប្រាប់រឿងណឹងទៅនាងទៅ ។

*អូមី* ពន្យល់តាមបញ្ហា ។ *ម៉ារីកូ* សែនស្អប់ខ្ពើមនូវអ្វីដែលនាងបានលឺ តែនាងឥតបញ្ចេញអោយឃើញនៅលើមុខនាងបន្តិចបន្តួចណាឡើយ ។

រួច *អូមី* បញ្ចប់ :

- តាំងពីពេលនោះមក អា *អាន់ជីន-សាន* នេះបាក់ស្បាតតែម្តង ។ តែកាលណាគ្មានអាវុធគាត់នេះទំលាក់កន្ទុយហើយ ។

*យ៉ាហ្វ៊ូ* ក្រេបស្រា *សាកេ* បន្តិច :

- *ម៉ារីកូ-សាន* នាងប្រាប់ទៅគាត់ថា ការធ្វើអត្តឃាត មិនមែនជាទំលាប់របស់ពួកអ្នកចុងស្រុកទេ ។ម្យ៉ាងទៀតនេះគឺផ្ទុយនឹងព្រះគ្រីស្តថែមទៀត ។ បើអញ្ចឹងតើគាត់ចង់ធ្វើអត្តឃាតបែបម៉េច ?

*ម៉ារីកូ* បកប្រែត្រលប់ទៅវិញ ។ *យ៉ាហ្វ៊ូ* ពិនិត្យមើលយ៉ាងយកចិត្តទុកដាក់នូវទឹកមុខរបស់ *ប្លាក់ថន* ដែលឆ្លើយតបវិញ ។

- *អាន់ជីន-សាន* ក្រាបលំអោនខ្លួនសូមទោសលោកម្ចាស់ ប៉ុន្តែគាត់និយាយថា ទំលាប់រឺមិនទំលាប់ ព្រះរឺមិនព្រះ ក៏ការអាម៉ាស់បណ្តាលមកពីភូមិនេះសែនធ្ងន់ធ្ងរពេករហូតដល់មិនអាចទ្រាំទ្របានទេ ។ គាត់និយាយថា....ថាគាត់នៅក្នុងប្រទេសជប៉ុន ថាគាត់ជា *ហាតាម៉ូតូ* ហើយគាត់មានសិទ្ធិរស់នៅតាមច្បាប់របស់ពួកយើង-ដៃ *ម៉ារីកូ* ឡើងញ័រ-នេះគឺជាអ្វីដែលគាត់បាននិយាយ *យ៉ាហ្វ៊ូ-សាន* ។ សិទ្ធិរស់នៅតាមទំលាប់របស់យើង ច្បាប់របស់យើង ។

- ពួកអ្នកចុងស្រុកគ្មានសិទ្ធិអ្វីទាំងអស់ ។

*ម៉ារីកូ* តប :



www.budinst.gov.kh www.elibraryofcambodia.org

- នាងខ្ញុំមិនដឹងដែរ លោកម្ចាស់ ។ គាត់ហាក់ដូច........នាងខ្ញុំមិនដឹងដែរ.......

សំលេងនាងអួស១ ។

- *អូមី-សាន* ?

- ការធ្វើអត្តឃាតគឺផ្ទុយនឹងជំនឿគ្រីស្តសាសនាហើយលោកម្ចាស់ ។ ពួកវាមិនដែលធ្វើអត្តឃាតដូចពួកយើងទេ ។ គឺមិនដូចរបៀបពួកយើងជាសាមូរ៉ៃនោះទេ ។

- *ម៉ារីកូ-សាន* នាងជាអ្នកកាន់សាសនាគ្រីស្តដែរ មែនទេ ?

- ចាស លោកម្ចាស់ ។ ធ្វើអត្តឃាតគឺជាបាបកម្មធ្ងន់ណាស់ ។ នេះគឺផ្ទុយនឹងពាក្យប្រដៅរបស់ព្រះជាម្ចាស់ ។

- *អ៊ីកូរ៉ាជី-សាន* ? តើលោកយល់យ៉ាងម៉េច ?

- នេះគឺជាការបំភាន់ទេ ។ អានេះមិនមែនជាគ្រីស្តសាសនិកអីទេ ។ លោកម្ចាស់នៅចាំបានថ្ងៃជួបវាដំបូងទេ ទាន ? លោកម្ចាស់មានចាំទេថាតើវាធ្វើម៉េចខ្លះដាក់បព្វជិតនោះ ? ហើយតើលោកម្ចាស់នៅចាំទេថាវាសុខចិត្តអោយ *អូមី-សាន* ធ្វើអីខ្លះលើរូបវាដើម្បីជួយសង្គ្រោះក្មេងប្រុសម្នាក់នោះ ?

*យ៉ាប៊ូ* ញញឹមរំលឹកដល់ថ្ងៃ និងយប់នោះ :

- ពិតហើយ ខ្ញុំឯកភាព ។ វាមិនមែនជាគ្រីស្តសាសនិកទេ *ម៉ារីកូ-សាន*។

- នាងខ្ញុំសូមលោកម្ចាស់អភ័យទោស តែនាងខ្ញុំមិនយល់ទេ ។ តើរឿងបព្វជិតនោះវាយ៉ាងម៉េច ?

*យ៉ាប៊ូ* និយាយប្រាប់នាង ពីថ្ងៃដែល *ប្លាក់ថន* និង បព្វជិតជួបគ្នាលើកទីមួយ ។

*ម៉ារីកូ* ពោលសួរទាំងស្រលាំងកាំង :

- គាត់ប្រមាថសញ្ញាខ្វែង ?

- ហើយកាច់ខ្វែងកាច់ខ្ចីរបោះចោលទៅលើដីទៀតផង -*អ៊ីកូរ៉ាជី* បន្ថែម-ទាំងអស់នេះសុទ្ធតែជាការបំភាន់តែប៉ុននោះ ទាន ។ បើរឿងទាក់ទិននឹងភូមិនេះប៉ុណ្ណឹងធ្វើអោយវាបាត់បង់កិត្តិយសនោះមែន ចុះវានៅឈរជ្រងោរកន្លែងនេះធ្វើអីទៀតបើ *អូមី-សាន* បាញ់នោមច្រាស់



www.budinst.gov.kh www.elibraryofcambodia.org

បំបាក់មុខវាយ៉ាងណឹងទៅហើយនោះ ?

*ម៉ារីកូ* បន្ថែម :

- លោកម្ចាស់ថាម៉េច ? អោយនាងខ្ញុំសូមទោសផងចុះ តែនាងខ្ញុំស្តាប់មិនយល់ទេ ។

*យ៉ាប៊ូ* ពោលទៅកាន់ *អូមី* :

- ពន្យល់ប្រាប់រឿងណឹងទៅនាងទៅ ។

*អូមី* ពន្យល់តាមបញ្ជា ។ *ម៉ារីកូ* សែនស្អប់ខ្ពើមនូវអ្វីដែលនាងបានលឺ តែនាងឥតបញ្ចេញអោយឃើញនៅលើមុខនាងបន្តិចបន្តួចណាឡើយ ។

រួច *អូមី* បញ្ចប់ :

- តាំងពីពេលនោះមក អា *អាន់ជីន-សាន* នេះបាក់ស្បាតតែម្តង ។ តែកាលណាគ្មានអាវុធគាត់នេះទំលាក់កន្ទុយហើយ ។

*យ៉ាប៊ូ* ក្រេបស្រា *សាកេ* បន្តិច :

- *ម៉ារីកូ-សាន* នាងប្រាប់ទៅគាត់ថា ការធ្វើអត្តឃាត មិនមែនជាទំលាប់របស់ពួកអ្នកចុងស្រុកទេ ។ ម្យ៉ាងទៀតនេះគឺផ្ទុយនឹងព្រះគ្រីស្តថែមទៀត ។ បើអញ្ចឹងតើគាត់ចង់ធ្វើអត្តឃាតបែបម៉េច ?

*ម៉ារីកូ* បកប្រែត្រលប់ទៅវិញ ។ *យ៉ាប៊ូ* ពិនិត្យមើលយ៉ាងយកចិត្តទុកដាក់នូវទឹកមុខរបស់ *ប្លាក់ថន* ដែលឆ្លើយតបវិញ ។

- *អាន់ជីន-សាន* ក្រាបលំអោនខ្លួនសូមទោសលោកម្ចាស់ ប៉ុន្តែគាត់និយាយថា ទំលាប់រឺមិនទំលាប់ ព្រះរឺមិនព្រះ ក៏ការអាម៉ាស់បណ្តាលមកពីភូមិនេះសែនធ្ងន់ធ្ងរពេករហូតដល់មិនអាចទ្រាំទ្របានទេ ។ គាត់និយាយថា....ថាគាត់នៅក្នុងប្រទេសជប៉ុន ថាគាត់ជា *ហាតាម៉ូតូ* ហើយគាត់មានសិទ្ធិរស់នៅតាមច្បាប់របស់ពួកយើង-ដែ *ម៉ារីកូ* ឡើងញ័រ-នេះគឺជាអ្វីដែលគាត់បាននិយាយ *យ៉ាប៊ូ-សាន* ។ សិទ្ធិរស់នៅតាមទំលាប់របស់យើង ច្បាប់របស់យើង ។

- ពួកអ្នកចុងស្រុកគ្មានសិទ្ធិអ្វីទាំងអស់ ។

*ម៉ារីកូ* តប :



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់ *គូរ៉ាណាកា* បានតែងតាំងគាត់ជា *ហាតាម៉ូតូ* លោកម្ចាស់។ ឋានៈនេះអាចអោយគាត់មានសិទ្ធិហើយ *ទេ*?

- តើគាត់ចង់ធ្វើអត្តឃាតយ៉ាងម៉េចទៅ? អ្នាស? សួរគាត់ទៅមើល។

*ប្លាក់ថន* ហូតយកកាំបិតខ្លីដ៏មុតស្រួចចេញហើយដាក់យ៉ាងថ្នមទៅលើ *កាតាមី* (** ) ដោយបែរចុងតំរង់មករកខ្លួន។

*អ៊ីកូរ៉ាជី* និយាយយ៉ាងព្រងើយ:

- នេះជាការបំភាន់ទេ ! អាណាដែលលឺអ្នកចុងស្រុកធ្វើដូចជាមនុស្សមានអារ្យធម៌នោះ?

*យ៉ាប៊ូ* ជ្រួញចិញ្ចើម បេះដូងរបស់លោកលោតឃឹតៗ បណ្តាលដោយអារម្មណ៍រំភើប:

- គាត់នេះជាមនុស្សក្លាហាន ណា *អ៊ីកូរ៉ាជី-សាន*។ រឿងនេះមួយមិនបាច់សង្ស័យទេ។ ហើយជាមនុស្សចំលែកទៀតផង។ តែរឿងនេះវិញមិនដឹងជាយ៉ាងម៉េច ហ្ន៎?

តាមជំរៅចិត្ត *យ៉ាប៊ូ* មានបំនងចង់ឃើញទំរើ ចង់ឃើញដោយផ្ទាល់ភ្នែកនូវអាការៈរបស់មនុស្សចុងស្រុកនេះ ចង់ឃើញថាតើមនុស្សនេះប្រឈមមុខនឹងមរណៈរបៀបម៉េច ចង់រួមអារម្មណ៍ស្រើមស្រួលនៃការរលត់បាត់បង់ជីវិត តែលោកប្រឹងរំងាប់ចិត្តារម្មណ៍របស់លោក ហើយសួរឡើងដោយសំលេងគ្រហឹមខ្ទរ:

- *អូមី-សាន* តើអែងមានយោបល់យ៉ាងណាដែរ?

- លោកម្ចាស់បានប្រាប់អ្នកភូមិថា បើសិនជា *អាន់ជីន-សាន* រៀនមិនបាន " *គួរជាទីពេញចិត្ត* " ហេតុនេះខ្ញុំមានយោបល់ថា លោកម្ចាស់អាចធ្វើសម្បទានយ៉ាងតូចមួយបាន ដោយលោកម្ចាស់ពោលប្រាប់គាត់ថាទោះជាក្នុងប្រាំខែនេះគាត់រៀនយ៉ាងម៉េចក៏ដោយក៏សុទ្ធតែ " គួរជាទីពេញចិត្ត " ទាំងអស់ហើយ តែជាការឆ្លើយតបគាត់ត្រូវតែស្បថដោយយកព្រះជាបន្ទាល់ថាគាត់នឹងមិនទំលាយការសំងាត់នេះដល់អ្នកភូមិជាដាច់ខាត។

---

(** ) : *កំរាលជប៉ុន ( គ.អ.ប )*



www.budinst.gov.kh www.elibraryofcambodia.org

- តែគាត់នេះមិនមែនជាគ្រីស្តសាសនិកផង តើសំបថនេះចងគាត់ម៉េចនឹងបាន ?

- ខ្ញុំយល់ថាគាត់នេះជាគ្រីស្តសាសនិកមួយបែបផ្សេង ទាន ។ គាត់នេះប្រឆាំងនឹងបព្ជិតស្បង់ខ្មៅ ហើយនេះគឺជាប្រការសំខាន់ ។ ខ្ញុំយល់ថាបើគាត់ស្បថដោយយកព្រះជាបន្ទាល់នេះ គឺចងគាត់បាន ។ ហើយគាត់គួរស្បថដោយយកព្រះគាត់ជាបន្ទាល់ផងដែរ ថាគាត់នឹងផ្ចង់អារម្មណ៍គាត់ទាំងមូលដើម្បីរៀនសូត្រ និងនៅបំរើលោកម្ចាស់ទាំងស្រុង ។ ព្រោះគាត់នេះឆ្លាតវាងវៃណាស់ ហេតុនេះគាត់ពិតជារៀនបានច្រើនណាស់ក្នុងរវាងប្រាំខែនេះ ។ ធ្វើបែបនេះ កិត្តិយសលោកម្ចាស់ពិតជាអាចរក្សាបាន ហើយកិត្តិយសរបស់គាត់នេះ បើសិនជាមាន ក៏អាចរក្សាបានដែរ ។ លោកម្ចាស់ឥតខាតបង់អ្វីទាំងអស់ តែលោកម្ចាស់បានចំនេញគ្រប់សព្វទាំងអស់ ។ អ្វីដែលសំខាន់ទៅទៀតនោះ គឺលោកម្ចាស់ទទួលបាននូវភក្តីភាព ដែលចេញមកពីទឹកចិត្តផ្ទាល់របស់មនុស្សនេះតែម្តង ។

- អែងជឿថាមនុស្សនេះហ៊ានធ្វើអត្តឃាតទេ ?

- ជឿ ទាន ។

- *ម៉ារីកូ-សាន ?*

- នាងខ្ញុំមិនដឹងទេ *យ៉ាប៊ូ-សាន* ។ អោយនាងខ្ញុំសូមអភ័យទោសទៅចុះ ដែលនាងខ្ញុំមិនអាចជូនយោបល់លោកម្ចាស់បាន ប៉ុន្មានម៉ោងមុននេះ នាងខ្ញុំពិតជានិយាយថាមនុស្សនេះមិនហ៊ានធ្វើអត្តឃាតទេ តែឥឡូវនេះខ្ញុំលែងដឹងហើយ ។ គាត់ជា.......តាំងពី *អូមី-សាន* ទៅហៅគាត់យប់មិញម្ល៉េះ គាត់ហាក់ដូច....ហាក់ដូច ជាប្លែកជាងមុន ។

- *អ៊ីគូរ៉ាជី-សាន ?*

- បើលោកម្ចាស់យល់ព្រមតាមវា ហើយបើនេះគ្រាន់តែជាល្បិចបំភាន់ភ្នែករបស់វា វានឹងប្រើល្បិចនេះទៀតនៅគ្រប់តែពេលហ្នឹង ។ អាគាត់នេះមានល្បិចកិច្ចកលដូចបិសាចកញ្ជ្រោងអញ្ចឹង យើងឃើញស្រាប់ហើយ *ទេ ?* ថ្ងៃណាមួយលោកម្ចាស់ត្រូវតែឆ្លើយថា "ទេ" ជាមិនខាន ។ ខ្ញុំមានយោបល់ថា លោកម្ចាស់គួរតែពោលពាក្យនេះអោយហើយទៅ ។ នេះគឺជាល្បិចបំភាន់ទេលោកម្ចាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* អោនខ្លួនទៅមុខត្រីក្បាល :

- សូមលោកម្ចាស់អភ័យទោស តែខ្ញុំសូមនិយាយម្តងទៀតទៅចុះ ទាន។ បើសិនជាលោកម្ចាស់ឆ្លើយថាទេនោះលោកម្ចាស់ពិតជាប្រថុយប្រថានខាតធំណាស់។ បើសិនទេះជាការប៉ាន់មែននោះ -ហើយនេះអាចជាការពិត-ពេលនោះក្នុងឋានៈជាមនុស្សមានមោទនភាពមនុស្សនេះនឹងមានចិត្តពោរពេញដោយកំហឹង ព្រោះតែការអាម៉ាស់ដ៏ជ្រាលជ្រៅរបស់ខ្លួនទៅពេលនេះ ហើយនឹងមិនអាចជួយលោកម្ចាស់បានដោយអស់ពីកំលាំងកាយចិត្ត តាមបំនងរបស់លោកម្ចាស់បានទេ។ គាត់នេះបានស្នើសុំលោកម្ចាស់នូវសំនូមពរមួយក្នុងឋានៈជា*ហាតាម៉ូតូ* ពេញសិទ្ធិ ហើយគាត់និយាយថាគាត់ចង់រស់នៅតាមបែបទំលាប់របស់យើង ដោយចិត្តស្មុគ្រស្មោះរបស់គាត់។ តើនេះមិនជាជំហានវិជ្ជមានមួយយ៉ាងធំធេងទេរឺ លោកម្ចាស់ ? នេះគឺអស្ចារ្យណាស់សំរាប់លោកម្ចាស់ សំរាប់គាត់។ ខ្ញុំសូមលោកម្ចាស់ប្រយ័ត្នប្រយែង ទាន។ សូមលោកម្ចាស់ប្រើមនុស្សនេះដើម្បីទាញយកផលប្រយោជន៍សំរាប់លោកម្ចាស់វិញ។

*យ៉ាប៊ូ* ឆ្លើយតបក្នុងសំលេងយ៉ាងស្អិត :

- ខ្ញុំក៏មានបំនងអញ្ចឹងដែរ។

*អ៊ីកូរ៉ាជី* តប :

- ពិតហើយថាគាត់នេះមានតំលៃណាស់។ ពិតហើយដែលខ្ញុំត្រូវការចំនេះដឹងរបស់វា។ ប៉ុន្តែយើងត្រូវតែត្រួតវាអោយបាន។ លោកបាននិយាយប៉ុន្មានដងហើយ *អូមី-សាន*។ វាជាមនុស្សចុងស្រុក។ ហើយវាតែប៉ុនណឹង។ ខ្ញុំដឹងហើយថាថ្ងៃនេះវាជា*ហាតាម៉ូតូ* ហើយពិតហើយថា ចាប់ពីថ្ងៃនេះទៅវាមានសិទ្ធិកាន់ដាវទាំងពីរបាន។ តែនេះក៏មិនអាចអោយវាក្លាយទៅជាសាមូរ៉ៃបានដែរ។ វាមិនមែនជាសាមូរ៉ៃ ហើយមិនអាចក្លាយជាសាមូរ៉ៃរហូតណឹង។

*ម៉ារីកូ* យល់ដឹងយ៉ាងច្បាស់ណាស់ថាក្នុងចំនោមមនុស្សទាំងអស់នេះ នាងគួរជាមនុស្សដែលអាចយល់ពីជំរៅចិត្តរបស់ *អាន់ជីន-សាន* បានច្បាស់ជាងគេ។ តែនាងមិនអាចមើលជំរៅចិត្តមនុស្សនេះបានទេ ។ ពេលខ្លះនាងអាចយល់ពីគេបាន តែពេលខ្លះនាងលែងយល់ពីគេតែម្តង ។ ពេលខ្លះនាងចូលចិត្តមនុស្សនេះ ពេលខ្លះនាងបែរជាស្អប់មនុស្សនេះទៅវិញ។ ហេតុអ្វីទៅហ្នំ ?



www.budinst.gov.kh www.elibraryofcambodia.org

ភ្នែកទ័លច្រករបស់ *ប្លាក់ថន* ចោលសំលឹងទៅឆ្ងាយ ។ គំនក់ញើសនៅពាសលើថ្ងាស់របស់គេ ។

តើនេះបណ្តាលមកពីការភ័យខ្លាចទេដឹង ? *យ៉ាប៊ូ* ដណ្តឹងសួរខ្លួនឯង ។ ភ័យខ្លាចដោយការបំភាន់របស់ខ្លួនត្រូវគេលលេងសាកល្បង ? តើមនុស្សនេះបំភាន់មែន រឺ ?

- *ម៉ារីកូ-សាន* ?

- ចាស លោកម្ចាស់ ?

- ប្រាប់ទៅគាត់ថា......សំលេងរបស់ *យ៉ាប៊ូ* ស្រាប់តែឡើងស្អូត ទ្រូងរបស់លោកឡើងចុកពើត -ប្រាប់ទៅ *អាន់ជីន-សាន* ថាខ្ញុំនៅរក្សាបទបញ្ជារបស់ខ្ញុំដដែល ។

- លោកម្ចាស់ អោយនាងខ្ញុំសូមអភ័យទោស នាងខ្ញុំសូមអង្វរលោកម្ចាស់សូមឆ្លើយតាមមតិរបស់ *អូមី-សាន* ទៅ ។

ក្រសែភ្នែករបស់ *យ៉ាប៊ូ* ឥតសំលឹងមើល *ម៉ារីកូ* ទេ តែបានផ្តោតជាប់ទៅលើ *ប្លាក់ថន* ទៅវិញ ។ សរសៃនៅលើថ្ងាស់របស់លោកឡើងតឹង :

- *អាន់ជីន-សាន* បាននិយាយថាគាត់បានសំរេចចិត្តរួចហើយ ។ អញ្ចឹងក៏វាអញ្ចឹងទៅចុះ ។ ចាំមើលទៅមើល ថាតើគាត់នេះជាមនុស្សចុងស្រុក រឺជា *ហាតាម៉ូតូ* ។

សំលេង *ម៉ារីកូ* ស្តាប់ស្ទើរមិនលឺ :

- *អាន់ជីន-សាន* លោកម្ចាស់ *យ៉ាប៊ូ* មានប្រសាសន៍ថា បញ្ជានៅរក្សាទុកដដែល ។ អោយខ្ញុំសូមអភ័យទោសផងទៅចុះ ។

*ប្លាក់ថន* លឺសំដីរបស់ *ម៉ារីកូ* ហើយប៉ុន្តែគេឥតរញ្ជួយញាប់ញ័រអ្វីទាំងអស់ ។ គេមានអារម្មណ៍ថាខ្លួនគេរឹងប៉ឹងជាងមុន ហើយមានអារម្មណ៍ស្ងប់ស្ងាត់លើសពេលណា១ទាំងអស់ ។ ១ខ្ទឹមនេះអារម្មណ៍ចំពោះជីវិតក៏មានលក្ខណៈច្បាស់លាស់ជាទីបំផុតជាងសព្វដងផងដែរ ។

នៅក្នុងពេលដែលកំពុងរង់ចាំនោះ គេឥតរវល់ស្តាប់កិច្ចសន្ទនា រឺ ឃ្លាំមើលអ្នកទាំងនោះឡើយ ។ គេបានធ្វើការសំរេចចិត្តរួចជាស្រេចទៅហើយ ។ រឿងអ្វី១ផ្សេងទៀតនោះ គឺទុកអោយព្រះជាអ្នកចាត់ចែងទៅចុះ ។ នៅក្នុងខួរក្បាលរបស់គេ១នៅច្បាមជាប់ លឺជាប់ នូវសំដីតែ



www.budinst.gov.kh www.elibraryofcambodia.org

មួយឃ្លាដែលបានបង្កើបផ្លូវរស់នៅទីនេះ ។ នោះគឺជាសំដីដែលពិតជាព្រះបានបញ្ជូនមកអោយគេតាមរយៈ *ម៉ារីកូ* " ដំណោះស្រាយងាយស្រួលបំផុតគឺ ....ស្លាប់ ។ ចង់ប្រជែងរស់នៅទីនេះបានលោកត្រូវតែរស់នៅតាមទំនៀមទំលាប់របស់ពួកយើង......" ។

"......បញ្ហានៅរក្សាទុកដដែល " ។

បើអញ្ចឹងដល់ពេលដែលអញត្រូវស្លាប់ហើយ ។

អញគួរតែរន្ធត់ញាប់ញ័រ ។ ប៉ុន្តែអញបែរជាគ្មានអារម្មណ៍នេះសោះ ។

តើមកពីហេតុអ្វីទៅ ហ្ន៎ ?

អញមិនដឹងដែរ ។ អញដឹងតែម៉្យាងគត់ : គឺនៅពេលដែលអញសំរេចចិត្តមែនទែនថាផ្លូវតែមួយគត់ដែលរស់បាននៅទីនេះ គឺត្រូវរស់នៅតាមទំនៀមទំលាប់របស់ពួកវា ត្រូវហ៊ានប្រថុយស្លាប់ ហើយអាចប្រហែលស្លាប់ផងក៏តែថាបាន នៅពេលនេះស្រាប់តែការតក់ស្លុតចំពោះសេចក្តីស្លាប់បានរលាយបាត់បង់អស់តែម្តង ។ " ជីវិត និង មរណភាពគឺដូចគ្នា.....ចេញពី *កាម៉ា* ឈានទៅរក *កាម៉ា* " ។

អញឥតខ្លាចស្លាប់ទេ ។

នៅឯម្ខាងទ្វារ ភ្លៀងរលឹមចាប់ផ្តើមធ្លាក់រ៉ុយៗ ។ គេអោនសំលឹងមើលកាំបិត ។

អញមានជីវិតសុខដុមណាស់ -គេគិតនៅក្នុងចិត្ត ។

ភ្នែករបស់គេបែរទៅរក *យ៉ាំកូ* វិញ ។ " *ភិកាវីម៉ាស៊ុ* " គេនិយាយយ៉ាងច្បាស់ៗ ។ ពិតមែនតែបបូរមាត់គេកំរើកដើម្បីពោលពាក្យនេះក្តី តែគេមានអារម្មណ៍ហាក់ដូចជាមនុស្សផ្សេងជាអ្នកនិយាយទេវិញ ។

គ្មានអ្នកណាម្នាក់កំរើកខ្លួនឡើយ ។

គេសំលឹងមើលដៃស្តាំរបស់គេដែលលូកចាប់យកកាំបិតឡើង ។ បន្ទាប់មកដៃឆ្វេងរបស់គេក៏ច្បាមជាប់ដងកាំបិត ។ ចុងផ្លែកាំបិតតំរង់ឥតញញើតទៅរកបេះដូងគេ ។ អីលូវនេះពុំគ្មានសឺស្នូរអ្វីក្រៅពីសំលេងនៃជីវិតរបស់គេដែលកាន់តែរន្ថើនឡើង និងខ្លាំងឡើងៗ រហូតដល់រូបគេមិនអាចស្តាប់បានតទៅទៀតបានឡើយ ។ ព្រលឹងរបស់គេដង្ហោយហៅរកភាពស្ងប់ស្ងាត់ជា



www.budinst.gov.kh www.elibraryofcambodia.org

អមតៈហើយ ។

សំរែកដែលលាន់ឡើងបានក្រោចសភាវគតិរបស់គេភ្លាម ។ ដៃទាំងពីររបស់គេបុះផ្ទៃកាំបិតសំដៅទិសដៅរបស់ខ្លួនដោយគ្មានញញើតបន្តិចណាឡើយ ។

*អូមី* បានត្រៀមខ្លួនជាស្រេចដើម្បីជួយសង្គ្រោះ *ប្លាក់ថន* ប៉ុន្តែគេមិនបានត្រៀមខ្លួននឹងភាពដ៏រហ័ស និងដ៏សាហាវនៃកាយវិការរបស់ *ប្លាក់ថន* នេះទេ ។ នៅពេលដែលដៃឆ្វេងរបស់ *អូមី* ច្បាមចាប់ផ្ទៃកាំបិត ហើយដៃស្តាំរបស់គេច្បាមចាប់ដងនោះ ការចុកចាប់បានលុកទន្ទ្រានខ្លួនគេមួយរំពេចបណ្តាលមកពីឈាមដែលហូរខ្វាយចេញពីដៃឆ្វេងរបស់គេ ។ គេប្រឹងអស់ពីកំលាំងនៅក្នុងខ្លួនដើម្បីបង្អាក់ថាមពលរុញបុកទៅមុខរបស់ *ប្លាក់ថន* ប៉ុន្តែគេថមថយកំលាំងបន្តិចម្តងៗទៅហើយ ។ ពេលនោះ *អ៊ីកូវ៉ាជី* ចេញមុខចូលជួយបន្ថែមទៀតភ្លាម ។ គេទាំងពីរសំរេចទប់ទល់បានហើយផ្ទៃកាំបិតក៏ត្រូវបានយកចេញឆ្ងាយទៅ ។ ខ្សែលោហិតយ៉ាងឆ្អារហូរស្រក់តក់ៗ ពីផ្នែកខាងលើបេះដូងរបស់ *ប្លាក់ថន* ជាកន្លែងដែលកាំបិតចាក់ចូលអំបាញ់មិញនេះឯង ។

*ម៉ារីកូ* និង *យ៉ាប៊ូ* នៅស្ងៀមឥតកំរើកខ្លួនសោះឡើយ ។

*យ៉ាប៊ូ* ពោលឡើង :

- ប្រាប់ទៅគាត់ថា.....ថាទោះគាត់រៀនយ៉ាងម៉េចក៏សុទ្ធតែគ្រប់គ្រាន់ហើយ *ម៉ារីកូ-សាន* ។ បញ្ជាថា....ទេ ស្តើ គឺ......ស្តើទៅ *អាន់ជីន-សាន* សូមអោយគាត់ស្បថដូច *អូមី* បាននិយាយអំបាញ់មិញអញ្ចឹង ។ អ្វីៗទាំងអស់ដូចដែល *អូមី* បាននិយាយ ។

*************

ប្លាក់ថន ដកខ្លួនចេញពីមរណភាពយ៉ាងយឺតៗ ។ គេសំលឹងមើលដោយឥតយល់អ្វីទាំងអស់ទូវមនុស្សទាំងអស់គ្នានេះហើយនឹងផ្ទៃកាំបិតដែលហាក់ដូចជានៅយ៉ាងឆ្ងាយសន្ធឹម ។ រូបចរន្តនៃជីវិតបានហូរចូលគគុកទៅក្នុងខ្លួនគេវិញ ប៉ុន្តែគេនៅមិនទាន់ច្បាមជាប់នូវន័យពិតប្រាកដរបស់វាបាននៅឡើយទេ ដោយគេនៅតែជឿនៅក្នុងចិត្តថារូបគេស្លាប់បាត់បង់ជីវិតទៅហើយ ។

- *អាន់ជីន-សាន* ? *អាន់ជីន-សាន* ?



www.budinst.gov.kh www.elibraryofcambodia.org

គេឃើញបបូរមាត់នាងកំរើក គេលឺសូរសំលេងស្រែករបស់នាង ប៉ុន្តែវិញ្ញាណគេបានផ្តោតទៅលើភ្លៀង និងជំនោរវាយោរកើយៗ ទៅវិញ ។

- បាទ ?

សំលេងរបស់គេហាក់លាន់លឺមកពីទីឆ្ងាយ ប៉ុន្តែច្រមុះគេធុំក្លិនទឹកភ្លៀង ត្រចៀករបស់គេលឺសូរតំនក់ទឹកភ្លៀងធ្លាក់ ហើយគេមានអារម្មណ៍នឹងរសជាតិប្រៃនៃអំបិលដែលវាយោបានបក់ជញ្ជូនមក ។

អញនៅរស់ទេ ។ គេគិតទាំងរំភើបក្នុងចិត្ត ។ អញនៅរស់ទេ ហើយភ្លៀងនៅខាងក្រៅ និង វាយោដែលបក់បោកមកពីខាងជើងនេះក៏សុទ្ធតែជារបស់ពិតៗមែនដែរ ។

អ្នកឯទៀតនៅអង្គុយស្ងៀមស្ងាត់ រង់ចាំយ៉ាងអត់ធ្មត់ និងពោរពេញដោយអាការៈគួរសមជាទីបំផុត ដែលជាការគោរពចំពោះភាពក្លាហានរបស់គេ ។ គ្មានអ្នកណាម្នាក់នៅក្នុងប្រទេសជប៉ុននេះបានឃើញនូវអ្វីដែលគេបានឃើញអំបាញ់មិញនេះទេ ។ ម្នាក់ៗ ចោទសួរយ៉ាងស្ងៀមស្ងាត់នៅក្នុងចិត្ត ថាតើឥឡូវនេះ *អាន់ជីន-សាន* នឹងធ្វើអ្វីទៅ ? តើ *អាន់ជីន-សាន* អាចក្រោកឈរ និង ដើរចេញទៅដោយខ្លួនឯងបាន រឺ ក៏ព្រលឹងព្រលះបានចេញបាត់ពីខ្លួនគេទៅហើយ ? បើសិនជាអញជា *អាន់ជីន-សាន* វិញ តើអញនឹងធ្វើយ៉ាងម៉េចទៅ ?

អ្នកបំរើម្នាក់បានយកក្រណាត់មករុំយ៉ាងស្ងៀមស្ងាត់នូវមុខរបួសនៅលើដៃ *អូមី* ដែលត្រូវមុខកាំបិតយ៉ាងជ្រៅនោះ ដើម្បីទប់ឈាមមិនអោយហូរចេញមកទៀតបាន ។ យូរៗម្តង *ម៉ារីកូ* ហៅឈ្មោះ *ប្លាក់ថន* យ៉ាងថ្នមៗ ក្នុងពេលដែលទាំងអស់គ្នានៅអង្គុយចិបតែ រឺ ស្រា *សាកេ* ដើម្បីរង់ចាំមើល ដើម្បីសង្កេតមើល និងដើម្បីចងចាំទុក ។

ចំពោះ *ប្លាក់ថន* វិញ ភាពមិនរស់មិនស្លាប់នេះហាក់ដូចស្ថិតនៅជាអលជ្ជីតែម្តង ។ ទីបំផុតភ្នែកគេចាប់ផ្តើមមើលឃើញ ត្រចៀកគេចាប់ផ្តើមលឺ ។

- *អាន់ជីន-សាន* ?

- *ហៃ* ?

គេឆ្លើយតបក្នុងស្ថានភាពដ៏ហត់នឿយមួយដែលគេមិនធ្លាប់ជួបប្រទះសោះឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* និយាយប្រាប់ឡើងវិញនូវអ្វីដែល *អូមី* បាននិយាយហាក់ដូចជាពាក្យដែលចេញពីមាត់ *យ៉ាប៊ូ* ផ្ទាល់យ៉ាងដូចនោះដែរ ។ នាងត្រូវនិយាយជាច្រើនលើកច្រើនសារហួតដល់នាងច្បាស់នៅក្នុង ចិត្តថា *ភ្វាក់ថន* បានយល់ច្បាស់លាស់ហើយទើបឈប់ ។

*ភ្វាក់ថន* ប្រឹងប្រមែប្រមូលកំលាំងដែលនៅសេសសល់ប៉ុន្មាននៅក្នុងខ្លួន ។ ជ័យជំនះសែនផ្អែមល្ហែមទេ ចំពោះរូបគេ :

- សំដីខ្ញុំគ្រប់គ្រាន់ហើយ ដូចជាសំដីរបស់ *យ៉ាប៊ូ-សាន* យ៉ាងនោះដែរ ។ ទោះជាយ៉ាងនេះក្តី ខ្ញុំសូមស្បថដោយយកព្រះជាបន្ទាល់តាមបំនងរបស់គាត់ថែមទៀតចុះ ។ ពិតមែន ណាំ ។ ហើយក៏ដូចជា *យ៉ាប៊ូ-សាន* ត្រូវតែស្បថដោយយកព្រះគាត់ជាបន្ទាល់ដែរថា គាត់នៅតែរក្សាពាក្យគាត់ក្នុងការដាក់ថ្នូរជាមួយគ្នានេះដែរ ។

- លោកម្ចាស់ *យ៉ាប៊ូ* ឆ្លើយថាយល់ព្រម ។ លោកសូមស្បថដោយយកព្រះពុទ្ធជាម្ចាស់ជាបន្ទាល់ ។

*ភ្វាក់ថន* ក៏ស្បថតាមសំនូមពររបស់ *យ៉ាប៊ូ*។គេទទួលយកតែមកគ្រេប ។ មិនដែលមានពេលណាដែលតែមានរសជាតិឆ្ងាញ់ដូចពេលនេះទេ ។ ពែងតែហាក់មានទំងន់ធ្ងន់ពាប់ធ្វើអោយគេមិនអាចកាន់វានៅនឹងដៃបានយូរពេលឡើយ ។

- លោកសំរាកសិនទៅអ្ហ៎ *អាន់ជីន-សាន* ? លោកម្ចាស់ *យ៉ាប៊ូ* សូមអរគុណលោកហើយលោកមានប្រសាសន៍ថាលោកនឹងជួបនិយាយជាមួយលោកនៅថ្ងៃស្អែកនេះ ។ អីលូវនេះលោកគួរសំរាកសិនទៅ ។

- បាទ ស្រួលហើយអញ្ចឹង ។ សូមអរគុណ ។

- តើលោកអាចក្រោកឈរបានទេ?

- បែបមិនអីទេ មើលទៅ ។

- លោកម្ចាស់ *យ៉ាប៊ូ* សួរថាតើលោកត្រូវការស្នែងទេ ?

*ភ្វាក់ថន* គិតមួយសន្ទុះ រួចគេសំរេចចិត្តថាសាមូរ៉ៃត្រូវដើរដោយជើងខ្លួនឯង រឺ គួរសាកដើរដោយខ្លួនឯង ។



www.budinst.gov.kh www.elibraryofcambodia.org

- បាទទេ អរគុណហើយ ។

គេឆ្លើយតប ថ្វីបើគេសែនចង់ទំរេតខ្លួនចុះ អោយគេសែងត្រលប់ទៅវិញដើម្បីចូលដំណេកជាបន្ទាន់ភ្លាមក្តី ។ គេឈោងចាប់យកកាំបិតយ៉ាងយឺត១ ហើយពិនិត្យវាយ៉ាងយកចិត្តទុកដាក់ រួចទើបសិកទៅក្នុងស្រោម ។ ទង្វើទាំងនេះស៊ីពេលវេលាយ៉ាងយូរ ។ គេនិយាយថ្នម១ក្នុងបំពង់ក :

- សូមទោសដែលខ្ញុំយឺតយ៉ាវពេក ។

- លោកមិនបាច់សូមទោសអីទេ *អាន់ជីន-សាន* ។ យប់នេះគឺលោកបានចាប់កំនើតថ្មីហើយ ។ នេះគឺជាជីវិតមួយផ្សេងទៀតជាជីវិតថ្មី ណាំ *-ម៉ារីកូ* តបប្រកបដោយមោទនភាព និងកិត្តិយសចំពោះរូបគេ-មានមនុស្សតិចណាស់ដែលត្រលប់មកវិញបាន ។ លោកមិនបាច់សូមទោសទេ ។ យើងខ្ញុំដឹងថាការនេះទាមទារសេចក្តីក្លាហានសំបើមណាស់ ។ មនុស្សជាច្រើននៅពេលក្រោយហេតុការណ៍នេះសឹងតែគ្មានកំលាំងក្រោកឈរផង ។ តើអោយខ្ញុំជួយលោកទេ ?

- ទេ ទេ អរគុណហើយ ។

- អោយគេជួយមិនមែនជាការនាំអោយបាត់បង់កិត្តិយសអីទេ ។ បើលោកអនុញ្ញាតអោយខ្ញុំជួយលោក នោះគឺជាកិត្តិយសខ្ញុំទៅវិញទេ ។

- សូមអរគុណ អ្នកស្រី ។ តែខ្ញុំចង់សាកមើលសិន ។

ប៉ុន្តែគេមិនអាចងើបត្រង់ខ្លួនបានភ្លាមនោះទេ ។ គេត្រូវប្រើដៃច្រត់ដើម្បីលុតជង្គង់សិនរួចសំរាកមួយភ្លែតដើម្បីយកកំលាំងបន្ថែម ។ ក្រោយមកទៀតទើបគេស្ទុះងើបឈរបានតែគេវិលដួលចុះទៅវិញ ។ គេនៅទ្រេតទ្រោតមែន តែគេមិនដួលឡើយ ។

*យ៉ាប៊ូ*អោនខ្លួនគោរព ។ទាំង *ម៉ារីកូ* ទាំង *អូមី* ទាំង *អ៊ីកូរ៉ាស៊ី* ក៏អោនខ្លួនគោរពតាមដែរ ។

*ប្លាក់ថន*ដើរចេញទៅដូចមនុស្សប្រមឹកក្នុងប៉ុន្មានជំហានដំបូងរបស់គេ ។គេច្បាមសរសរមួយហើយនៅតោងទីនោះមួយសន្ទុះ រួចទើបបន្តដំណើរទៅទៀតដោយភាពទ្រេតទ្រោតតែម្នាក់ឯង ។ ដើរក្នុងឋានៈជាកូនប្រុសម្នាក់ ។ដៃគេម្ខាងដាក់លើដងដាវវែង ក្បាលគេងើយខ្ពស់ទៅលើ ។

***************



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* បញ្ចេញដង្ហើមលាន់ឃូរ រួចទើបលើកស្រា សាកេ ក្រេបយ៉ាងវែង។ នៅពេលដែលលោកនិយាយចេញបានហើយ ទើបលោកនិយាយទៅកាន់ *ម៉ារីកូ* :

- សូមអ្នកស្រីអធ្យាស្រ័យជួយតាមមើលគាត់អោយបានទៅដល់ផ្ទះដោយសុវត្ថិភាពផងចុះ ។

- ចាស លោកម្ចាស់ ។

ពេល *ម៉ារីកូ* ចេញទៅបាត់ទើប *យ៉ាប៊ូ* ងាកទៅរក *អ៊ីកូរ៉ាជី* វិញម្តង :

- អាចំកូតមិនគ្រប់ដប់ !

*អ៊ីកូរ៉ាជី* អោនក្បាលដល់កំរាលជាកិច្ចទទួលកំហុសភ្លាម ។

- ស្អី ? ល្បិចបំភាន់ *នេ* ? ភាពពភ្លីពភ្លើរបស់អែង ធ្វើអោយអញវិះបាត់របស់ដ៏កាត់ថ្លៃមិនបានមួយ ។

- ប្របាទ លោកម្ចាស់ពិតជាយល់ត្រូវមែន ទាន ។ ខ្ញុំសូមលោកម្ចាស់អនុញ្ញាតអោយខ្ញុំបញ្ចប់ជីវិតខ្ញុំត្រឹមនេះចុះ ។

- ធ្វើយ៉ាងនេះដូចជាល្អពេកសំរាប់អែងហើយ ! អីលូវនេះ អែងចេញទៅរស់នៅឯរោងសេះរហូតដល់ពេលយើងប្រើគេទៅហៅអែងមកវិញសឹមមក ! ទៅដេកជាមួយសេះទ្រមក់អស់នោះទៅ ។ ព្រោះអែងនេះក៏ទ្រមល់ទប់ដូចតែសេះដែរទេ !

- បាទ ទាន ។ ខ្ញុំសូមអភ័យទោស ទាន ។

- ចេញទៅអោយបាត់ទៅ ! អីលូវនេះ *អូមី-សាន* ជាអ្នកបញ្ជាកងកាំភ្លើងវិញម្តង ។ ចេញទៅ !

ពន្លឺភ្លើងទៀនរវាំ និងបែកផ្កាភ្លើងលាន់សូផែះៗ។ អ្នកបំរើម្នាក់ជ្រុលដៃធ្វើអោយកំពប់ស្រា *សាកេ* ទៅលើកូនតុខ្នុកម្រ័ក្សណ៍មួយដែលនៅពីមុខ *យ៉ាប៊ូ* ធ្វើអោយ *យ៉ាប៊ូ* កាន់តែច្រលោតផ្តាសារបន្ថែមទៀត ។ អ្នកបំរើទាំងអស់អោនសូមទោសព្រមៗគ្នា ធ្វើអោយ *យ៉ាប៊ូ* បានត្រជាក់ចិត្តឡើងវិញហើយយល់ព្រមទទួលស្រាបន្ថែមទៀត :

- ល្បិចបំភាន់ ? ល្បិចបំភាន់ ? ចំជាឆ្កួតមែនតែម្តង ! ម៉េចបានជាអញមានតែមនុស្ស



www.budinst.gov.kh www.elibraryofcambodia.org

ចំកូតបែបនេះនៅជុំវិញអញអញ្ចឹង ?

*អូមី* ឥតមាននិយាយស្តីអ្វីទាំងអស់ តែនៅក្នុងចិត្តគេគឺពោរពេញដោយសំនើចស្ទើរទប់មិនបាន ។

- តែអែងគឺមិនឆ្គួតទេ *អូមី-សាន*។ មតិអែងចំជាមានតំលៃមែន ។ ចាប់ពីថ្ងៃនេះតទៅយើងពង្រីកដែនដីគ្រប់គ្រងរបស់អែងអោយឡើងទ្វេថែមទៀត ។ ឆ្នាំក្រោយអែងនឹងទទួលបានប្រាំមួយរយ *កុគុ*។ ពង្រីកដីជុំវិញតំបន់ *អាន់ជ៉ូ* នេះសាមសិបលីថែមទៀតទៅសំរាប់ជាដែនគ្រប់គ្រងរបស់អែង ។

*អូមី* លំអោនក្បាលដល់កំរាល ។ *យ៉ាប៉ូ* សមនឹងស្លាប់មែន ។ អាគាត់នេះស្រួលបញ្ឆិលមែនទែន :

- លោកម្ចាស់សរសើរខ្ញុំពេកហើយ ទាន ។ ខ្ញុំគ្រាន់តែបំពេញកាតព្វកិច្ចខ្ញុំតែប៉ុននោះ ។

- អញ្ចឹងហើយ ។ តែនាយចៅវ៉ាយត្រូវតែផ្តល់រង្វាន់ចំពោះភាពស្មោះត្រង់ និងកាតព្វកិច្ច ។

យប់នេះ *យ៉ាប៉ូ* កាន់ដាវ *យ៉ូស៊ីម៉ូតូ* នៅជាប់នឹងខ្លួន ហើយលោកសែនរីករាយនឹងកាន់ស្ទាបវាជាពន់ពេក ។ លោកស្រែកហៅអ្នកបំរើម្នាក់ឡើង :

- *ស៊ូស៊ូ* ! ហៅ *ស៊ូគីម៉ូតូ* មកនេះ !

*អូមី* សួរ :

- តើសង្គ្រាមនឹងផ្ទុះឡើងនៅពេលណា ?

- ឆ្នាំនេះ ។ អែងអាចមានពេលប្រាំមួយខែ រីជួនកាលមិនដល់ផង ។ ចឹបានសួរអញ្ចឹង ?

- ប្រហែលជាលោកស្រី *ម៉ារីកូ* គួរនៅលើសពីបីថ្ងៃថែមទៀតទៅ ។ នៅដើម្បីការពារលោកម្ចាស់ ។

- ហ៊ឹស ? ហេតុអី ?

- នាងគឺជាមាត់របស់ *អាន់ជីន-សាន*។ ក្នុងរវាងកន្លះខែ ដោយមាននាងនៅជាមួយ *អាន់ជីន-សាន* អាចបង្ហាត់មនុស្សម្តែនាក់បាន ហើយម្តែនាក់នេះអាចបង្ហាត់មួយរយនាក់ ។ នេះ



www.budinst.gov.kh www.elibraryofcambodia.org

អាចបង្អាត់បន្តថែមទៀត ។ ដល់ពេលនោះ ទោះជា *អាន់ជីន-សាន* ស្លាប់ រឺរស់ក៏គ្មានសារសំខាន់អ្វីទៀតដែរ ។

- ហេតុអ្វីបានជាវាគួរត្រូវស្លាប់ ?

- លោកម្ចាស់នឹងត្រូវការមនុស្សនេះទៀតនៅពេលខាងមុខហើយលោកម្ចាស់នឹងត្រូវប្រឈមមុខនឹងវាម្តងទៀត ។ តែលទ្ធផលអាចខុសពីពេលនេះ ក៏តែថាបាន ។ អ្នកណាទៅដឹង ? លោកម្ចាស់អាចចង់អោយវាស្លាប់ក៏តែថាបាន ។

ទាំងពីរនាក់ ក៏ដូចជា *ម៉ារីកូ* និង *អ៊ីតូរ៉ាជី* ផងដែរ សុទ្ធតែដឹងយ៉ាងច្បាស់ណាស់ថា ទោះជា *យ៉ាប៊ូ* ស្បថដោយយកព្រះណាជាបន្ទាល់យ៉ាងណាក្តី ក៏ *យ៉ាប៊ូ* មិនដែលមានបំនងរក្សាពាក្យសំបថរបស់ខ្លួនដែរ ។ *អូមី* បន្ត :

- លោកម្ចាស់អាចដាក់ការគាបសង្កត់ទៅលើវាក៏តែបាន ។ លោកម្ចាស់បានសាច់ទៅហើយតើទៅរវល់រឿងសំបកធ្វើអ្វីទៀត ?

- ពិតហើយ សំបកពិតជាមិនបានការអីទេ ។

- លោកម្ចាស់ចង់រៀនសូត្រពីរបៀបធ្វើសឹករបស់ពួកចុងស្រុក តែលោកម្ចាស់ត្រូវតែរៀនពីវាអោយបានរហ័សមែនទែន ព្រោះលោកម្ចាស់ *តូរ៉ាណាកា* អាចប្រើគេអោយមកយកវាទៅវិញ ។ ដោយហេតុនេះ លោកម្ចាស់ត្រូវតែរក្សាលោកស្រី *ម៉ារីកូ* អោយនៅកាន់តែបានយូរពេលណា ល្អពេលនោះ ។ កន្លះខែគឺពិតជាគ្រប់គ្រាន់ ដើម្បីពួតច្របាច់យកអស់នូវអ្វីដែលវាចេះបានហើយ ដោយថាអីលូវនេះលោកម្ចាស់បានទទួលនូវការយកចិត្តទុកដាក់ពីវាហើយ ។ លោកម្ចាស់នឹងត្រូវសាកល្បង ត្រូវសំរបរបៀបធ្វើសឹករបស់ពួកវាអោយមកតាមរបៀបយើងថែមទៀត ។ បាទ គឺយ៉ាងតិចបំផុតក៏ត្រូវស៊ីពេលប្រហែលកន្លះខែដែរ *ទេ* ?

- ចុះ *តូរ៉ាណាកា-សាន* ?

- គាត់ពិតជានឹងយល់ព្រម បើសិនណាជាយើងចេះពន្យល់អោយបានស្រួលបួល ដល់គាត់ ។គាត់ត្រូវតែយល់ព្រម ។កាំភ្លើងទាំងអស់ជារបស់គាត់ក៏ដូចជារបស់លោកម្ចាស់ដែរ ។ម្យ៉ាងទៀត វត្តមានរបស់លោកស្រី *ម៉ារីកូ* ក៏អាចមានប្រយោជន៍នៅក្នុងផ្នែកផ្សេងៗទៀតផងដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិតមែនហើយ ។

*យ៉ាប៊ូ* តបទាំងពេញចិត្ត ដោយថាគំនិតចង់ទុកនាងជាចំណាប់បានលេចនៅក្នុងអារម្មណ៍របស់លោកតាំងពីពេលលោកមានផែនការប្រគល់ *តូរ៉ាណាកា* ទៅអោយ *អ៊ីស៊ីដូ* ទុកជាកិច្ចពលីម្សិល ។ លោកបន្ត :

- ពិតហើយដែលថា *តូដា ម៉ារីកូ* គួរតែទទួលបាននូវកិច្ចគាំពារ ។ បើសិនជានាងធ្លាក់ចុះក្នុងកណ្ដាប់ដៃមនុស្សអាក្រក់នោះគឺពិតជាស័យសៀវធំហើយ ។

- បាទ ពិតមែនហើយ ទាន ។ ហើយនាងអាចជាមធ្យោបាយមួយដើម្បីក្ដាប់ *ហ្ស៊ី-ម៉ាត់ស៊ី ប៊ុនតារ៉ូ* និងពួកបក្ខសម្ព័ន្ធវាទាំងអស់ថែមទៀត រួមទាំង *តូរ៉ាណាកា* ផង ។

- អែងព្រាងសារមួយពីរឿងនាងផង ។

- ថ្ងៃនេះ ម្ដាយខ្ញុំបានទទួលដំណឹងមួយពី *យេដូ* មកទាន ។គាត់បានប្រាប់ខ្ញុំអោយជំរាបលោកម្ចាស់ផងថា ជំទាវ *កិនជីកូ* បានផ្ដល់កំណើតដល់ចៅប្រុសទីមួយរបស់ *តូរ៉ាណាកា* ហើយ ។

យ៉ាប៊ូ ចាប់យកចិត្តទុកដាក់នឹងដំណឹងនេះភ្លាម ។ ចៅប្រុសរបស់ *តូរ៉ាណាកា* ! តើអាចប្រើក្មេងនេះដើម្បីក្ដាប់ *តូរ៉ាណាកា* បានដែរ រឺទេ ? ចៅប្រុសនឹងធានានិរន្តភាពនៃសន្តិវង្សរបស់ *តូរ៉ាណាកា* *ទេ* ? តើធ្វើយ៉ាងម៉េចអាចយកក្មេងនេះមកជាចំណាប់របស់អញបាន ? លោកសួរទៅ *អូមី* វិញ :

- ចុះជំទាវ *អូជីបា* ?

- គាត់បានចាកចេញពី *យេដូ* ជាមួយពួកបរិពារគាត់អស់ហើយ ទាន ។ ចេញតាំងពីបីថ្ងៃមុនម្សិល ។ ពេលនេះគាត់ស្ថិតនៅដោយសុវត្ថិភាពលើទឹកដីរបស់លោកម្ចាស់ *អ៊ីស៊ីដូ* ហើយ ។

*យ៉ាប៊ូ* រំពឹងគិតពីជំទាវ *អូជីបា* និងប្អូនស្រីរបស់គាត់គឺជំទាវ *កិនជីកូ*។ មនុស្សពីរនាក់នេះខុសគ្នាដូចមេឃ និង ដី ។ *អូជីបា* ជានារីម្នាក់ប្រកបដោយថាមពល មានសំរស់ស្រស់ស្អាតពោរពេញដោយល្បិចកិច្ចកល មិនចេះនៅស្ងៀម ហើយក៏ជានារីគួរជាទីចាប់ចិត្តប្រតិព័ទ្ធជាងគេនៅក្នុងមហានគរនេះ និងជាម្ដាយលើទាយាទថែមទៀតផង ។ *កិនជីកូ* មានលក្ខណៈស្រគត់ស្រគំស្ងៀមស្ងាត់ មានចិត្តមេត្តាករុណាចមិដ៏ល្បីល្បាញដូចម្ដាយ ។ នារីទាំងពីរនាក់ស្រលាញ់គ្នាណាស់



www.budinst.gov.kh www.elibraryofcambodia.org

តែ *អូជីបា* ស្អប់ *តូរ៉ាណាកា* និងពូជពង្ស *តូរ៉ាណាកា* ទាំងមូល ក៏ដូចជា *កិនជីកូ* ស្អប់លោកម្ចាស់ *តែកូ* និង *យែនមុ៉ន* ជាកូន *តែកូ* អញ្ចឹងដែរ។

*យ៉ាប៊ូ* និយាយស្ទាបស្ទង់ :

- បើអញ្ចឹងអីលូវនេះ ជំទាវ *អូជីបា* លែងជាចំនាប់គេនៅឯ *យេដូ* ទៀតហើយ.....នេះ អាចថាល្អក៏បាន អាក្រក់ក៏បាន។

- ល្អ មានតែល្អមួយគត់។ អីលូវនេះ *អ៊ីស៊ីដូ* និង *តូរ៉ាណាកា* នឹងចាប់ផ្តើមប្រឈមមុខ ឆ្លាឆាប់ៗនេះហើយ -*អូមី* មិនប្រើដោយចេតនានូវពាក្យ "*សាម៉ា*" ភ្ជាប់ទៅនឹងនាមអ្នកទាំងពីរ នេះ -ហេតុនេះ លោកស្រី *ម៉ារីកូ* ត្រូវតែស្ថិតនៅទីនេះ ដើម្បីសុវត្ថិភាពរបស់លោកម្ចាស់។

- ធ្វើតាមណឹងទៅចុះ។ ព្រាងសំបុត្រមួយសំរាប់ផ្ញើទៅ *តូរ៉ាណាកា* ផង។

អ្នកបំរើឈ្មោះ *ស៊ូស៊ូ* គោះទ្វារថ្នមៗ រួចទើបបើកទ្វារឡើង។ *ស៊ូគីម៉ូតូ* ក៏ចូលមកក្នុង បន្ទប់ :

- ឯណាវត្ថុអនុស្សាវរីយ៍ដែលខ្ញុំបញ្ជាអោយយកមកពី *មីស៊ីម៉ា* សំរាប់ *អូមី-សាន* នោះ?

- នៅក្នុងឃ្លាំងទាំងអស់ណឹង លោកម្ចាស់។ នេះគឺជាបញ្ជីរបស់របរ ទាន។ សេះទាំង ពីរអាចជ្រើសយកនៅក្នុងក្រោលបាន រឺ មួយក៏លោកម្ចាស់ចង់អោយខ្ញុំបាទចាត់ចែងអីលូវនេះ រឺ ទាន ?

- មិនអីទេ *អូមី-សាន* នឹងជ្រើសរើសសេះមួយគូនេះនៅពេលស្អែក -*យ៉ាប៊ូ* គ្រវាស ភ្នែកទៅលើបញ្ជីដែលមានអក្សរសរសេរយ៉ាងស្អាត : គីម៉ូណូម្តៃ ( គុណភាពលេខពីរ ) ដាវពីរ (ជូសជុលតែនៅក្នុងស្ថានភាពល្អនៅឡើយ ) សេះពីរ អាវុធសំរាប់សាមូរ៉ៃមួយរយនាក់រួមមាន ដាវមួយ មួកមួយ ក្បាំងការពារទ្រូងមួយ ធ្នូមួយ ព្រួញម្តៃ និងលំពែងមួយ សំរាប់ម្នាក់ៗ ( គុណ ភាពលេខមួយ ) ។ តំលៃទាំងអស់ : បួនរយម្តៃប្រាំមួយ កូគូ ។ និងថ្មមួយដុំឈ្មោះ "ថ្មរង់ចាំ" ។ តំលៃ : មិនអាចកាត់ថ្លៃបាន -អូហ៍ មែនហើយ -*យ៉ាប៊ូ* រំលឹកទាំងក្នុងអារម្មណ៍រីករាយជាង ពេលមុននេះបន្តិច នូវរាត្រីនោះ -គឺដុំថ្មដែលខ្ញុំប្រទះឃើញនៅឯ *គីយូស៊ូ* នោះឯង។ អែងនឹងដូរ ឈ្មោះវាទៅជា " អ្នកចុងស្រុករង់ចាំ " វិញមែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- បាទ ទាន បើសិនជាលោកម្ចាស់នៅពេញចិត្តនឹងឈ្មោះថ្មីនេះ -*អូមី* តប -តែសូមលោកម្ចាស់អធ្យាស្រ័យផ្តល់កិត្តិយសដល់រូបខ្ញុំទៅវេលាស្អែក ដោយជួយសំរេចដាក់ថ្មនេះនៅកន្លែងណាក្នុងសួន ? ខ្ញុំគិតថា ខ្ញុំមិនមានកន្លែងសមសួនសំរាប់ដាក់ថ្មនេះទេ ទាន ។

- បាន ស្អែកខ្ញុំនឹងសំរេចរឿងនេះ ។

រួច *យ៉ាប៊ូ* ទុកអោយអារម្មណ៍របស់ខ្លួននៅស្ងៀមស្ងាត់ពីជុំថ្មនេះ ។ ភាពស្រងេះស្រងោចបានទន្ទ្រានរសិបនៅក្នុងខ្លួនលោក ។ ជីវិតសែនខ្លី សែនសោកសៅ និងឃោរឃៅម្ល៉េះទេ - លោកគិតនៅក្នុងចិត្ត ។ រួចលោកក្រលេកឃើញ *ស៊ូតីម៉ូតូ* :

- រួចអែងនៅចាំអីទៀត អ្នាស ? ចេញទៅក្រៅទៅ !

- ប្របាទម្ចាស់ លោកម្ចាស់បានអោយខ្ញុំបាទរំលឹកពីរឿងពន្ធដារ ទាន ។

រួច *ស៊ូតីម៉ូតូ* ក៏ងើបខ្លួនដ៏ធាត់ស្មៀច និង ប្រកបដោយញើសជោកនោះ ប្រញាប់ប្រញាល់ចេញទៅក្រៅភ្លាមទៅ ។ *យ៉ាប៊ូ* ក៏ពោលឡើង :

- *អូមី-សាន* ចាប់ពីពេលនេះទៅ អែងត្រូវតំលើងពន្ធមួយជាពីរ ណា៎ ។

- បាទ លោកម្ចាស់ ។

- ពួកអាស់វែកំជិលនេះ ! ពួកវាមិនប្រឹងប្រែងធ្វើការសោះតែម្រ៉ង ។ អោយកំជិលរលួយតែទាំងអស់គ្នាហ្នឹង ។ អញការពារកុំអោយមានចោរឃ្មួញតាមសព្វផ្លូវ ការពារសុវត្ថិភាពលើផ្ទៃសមុទ្រ រៀបចំការងាររាជការល្អត្រឹមត្រូវ រួចមើលតើពួកវាធ្វើអីខ្លះ ? ម៉្ងៃ១គិតតែផឹកតែផឹកស្រា ច្រាស់បាយ ។ ល្មមដល់ពេលដែលពួកនេះត្រូវបំពេញកាតព្វកិច្ចវាអោយបានត្រឹមត្រូវម្តងហើយ ។

- បាទ ទាន -*អូមី* ឆ្លើយតប ។

រួចទើប *យ៉ាប៊ូ* និយាយដល់រឿងដែលដក់ជាប់នៅក្នុងអារម្មណ៍របស់ខ្លួន :

- យប់នេះ *អាន់ជីន-សាន* ធ្វើអោយខ្ញុំភ្ញាក់ផ្អើលសំបើមតែម្តង ។ តើអែងឥតមានភ្ញាក់ផ្អើលទេ អ្អី ?

- ភ្ញាក់ដែរហ្នឹង លោកម្ចាស់ ។ ភ្ញាក់ផ្អើលជាងលោកម្ចាស់ទៅទៀត ។ តែលោកម្ចាស់ចំ



www.budinst.gov.kh www.elibraryofcambodia.org

ជាវាងវៃមែនដែលធ្វើអោយមនុស្សនេះធ្វើសកម្មភាពដោយស្ម័គ្រចិត្តតែម្តង។

- អែងថា *អ៊ីកូរ៉ាជី* និយាយត្រូវទេ ?

- ខ្ញុំសូមសរសើរភាពវាងវៃរបស់លោកម្ចាស់តែម្តង។ លោកម្ចាស់គង់តែត្រូវនិយាយថា "ទេ" ជាមួយមនុស្សនេះ នៅពេលណាមួយជាមិនខាន។ ខ្ញុំគិតថាជាការវាងវៃណាស់ដែលលោកម្ចាស់និយាយពាក្យនេះ នៅយប់នេះ ទាន។

- ខ្ញុំគិតថាអាគាត់នេះនឹងសំលាប់ខ្លួនឯងហើយ។ មែន ណាំ។ ខ្ញុំអរដែរដែលអែងបានប្រុងប្រៀបហើយជាស្រេចនោះ ។ ខ្ញុំផ្អែកលើគំនិតដែលថាអែង ត្រៀមខ្លួនរួចហើយណឹងដែរ។ ចំពោះមនុស្សចុងស្រុក *អាន់ជីន-សាន* ចំជាមនុស្សមួយដ៏អស្ចារ្យ មែន *នេ* ? គួរអោយអាណិតដែរ ដែលវាជាមនុស្សចុងស្រុកហើយល្ងិតល្ងង់យ៉ាងនេះ។

- ពិតមែនហើយ ទាន។

*យ៉ាំប៊ូ* ស្ងាប ហើយទទួលយកស្រា *សាកេ* ពីដៃរបស់ *ស៊ូស៊ូ* :

- អែងនិយាយថាពាក់កណ្តាលខែទៀតអ្វី ? *ម៉ារីកូ* ត្រូវតែស្ថិតនៅយ៉ាងតិចណាស់ក៏ម៉ារយៈដែរ *អូមី-សាន* ។ រួចចាំខ្ញុំសំរេចរឿងនាង និង *អាន់ជីន-សាន* ។ បន្តិចទៀតវាត្រូវតែទទួលបានមេរៀនខ្លះ -*យ៉ាំប៊ូ* លាន់សំនើច -បើ *អាន់ជីន-សាន* បង្រៀនយើង យើងគួរតែបង្រៀនគាត់វិញ *នេ* ? បង្រៀនអោយចេះធ្វើ *ស៊ិបពូគូ* អោយបានត្រឹមត្រូវ។ អាណឹងបានល្អគួរគយគន់មើលមែន *នេ* ? អញ្ចឹង ក៏អញ្ចឹងទៅចុះ ! ខ្ញុំឯកភាពហើយថាមនុស្សចុងស្រុកនេះជិតដល់ថ្ងៃអន្សារហើយ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៣២

ដប់ពីរថ្ងៃក្រោយមក អ្នកនាំសារពី *អូសាកា* បានមកដល់នៅវេលារសៀល ។ សាមូរ៉ៃដប់នាក់បានអមដំណើរអ្នកនាំសារនេះ ។ សេះរបស់ពួកគេដាបទៅដោយញើស និង បែកពពុះមាត់ស្កុល បង្ហាញថាវាដាបកំលាំងណាស់ទៅហើយ ។ ចុងលំពែងរបស់ពួកគេបានដោតទង់ដែលមានសញ្ញាក្រុមប្រឹក្សាអាជ្ញានុសិទ្ធិដំពោរពេញទៅដោយអំនាច ។ មេឃមានពពកដេរដាសធាតុអាកាសក្តៅ និងប្រកបដោយសំណើម ។

អ្នកនាំសារដែលជាមេទ័ពម្នាក់របស់ *អ៊ីស៊ីដូ* នេះ មានរាងស្គម ខ្ពស់ស្រលះ ហើយជាមនុស្សជើងឆើតម្នាក់ ក្នុងចំនោមសាមូរ៉ៃថ្នាក់ខ្ពស់បំផុត ។ គេមានឈ្មោះ *នេបារ៉ា ចូស៊ីន* ហើយមានឈ្មោះល្បីល្បាញខាងចិត្តកំនាចឥតប្រណី ។ ឯកសណ្ឋានពីម៉ូណូពណ៌ប្រផេះរបស់គេឡើងទក់ខ្ទុកខ្ទេរ តែគេឡើងក្រហមដោយការនឿយហត់ ។ គេប្រកែកមិនព្រមទទួលម្ហូប រឺ ទឹកអ្វីទាំងអស់ ហើយទាមទារយ៉ាងច្រណែងខាមសុំជួបជាមួយ *យ៉ាប៊ូ*។

គេពោលទៅកាន់ *យ៉ាប៊ូ* :

- សូមអភ័យទោសចំពោះការស្លៀកពាក់របស់ខ្ញុំផង *យ៉ាប៊ូ-សាន*។ តែដោយកិច្ចការរបស់ខ្ញុំវាបន្ទាន់ពេក ។ ម្ចាស់របស់ខ្ញុំសូមសួរលោកថា ទីមួយ ហេតុអ្វីក៏លោកបង្ហាត់បង្រៀនទ័ព *តូរ៉ាណាកា* ជាមួយទ័ពរបស់លោក ហើយទីពីរ ហេតុអីក៏ពួកទាំងនេះ ហាត់ដោយប្រើកាំភ្លើងច្រើនម្លេះ ?

*យ៉ាប៊ូ* ឡើងក្រហមមុខង៉ាំងនឹងភាពឥតសុជីវធម៌នេះ ប៉ុន្តែលោកខិតខំប្រឹងទប់សង្កត់ចិត្តរបស់លោកអោយនៅនឹងនរ ដោយលោកដឹងថា *ចូស៊ីន* ពិតជាបានទទួលការណែនាំពីខាងលើមកហើយ ។ ភាពឥតសុជីវធម៌នេះបានបង្ហាញយ៉ាងច្បាស់ក្រលែតនូវការបញ្ចេញអានុភាពមួយដ៏គួរអោយក្តៅក្រហាយ ។ ហើយម៉្យាងទៀត លោកក៏ក្តៅក្រហាយនឹងការធ្លាយចេញការសំងាត់ជាថ្មីម្តងទៀតនេះផងដែរ ។

លោកពោលតបប្រកបដោយភាពគួរសមមួយដែលមិនអាចបំភាន់អ្នកណាម្នាក់សោះឡើយ :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំសូមស្វាគមន៍ *ចូស៊ិន-សាន*។ លោកអាចទៅជំរាបម្ចាស់របស់លោកបានថាខ្ញុំតែង តែការពារផលប្រយោជន៍របស់អម្ចាស់លោកជានិច្ច ។

ពួកគេទាំងអស់គ្នានៅលើរានហាលនៃបន្ទាយ ។ *អូមី* នៅអង្គុយជាប់ពីខាងក្រោយ *យ៉ាប៊ូ*។ *អ៊ីតូរ៉ាជី* ដែលទើបត្រូវបានទទួលការអភ័យទោសកាលពីប៉ុន្មានថ្ងៃមុននេះ នៅអង្គុយជិត *ចូស៊ិន*។ នៅជុំវិញ គឺសុទ្ធសឹងតែជាសេនាជំនិតរបស់ពួកគេ ។

- តើម្ចាស់លោកមានបាននិយាយអ្វីទៀតទេ ?

*ចូស៊ិន* តប :

- លោកម្ចាស់របស់ខ្ញុំពិតជាមានការរីករាយណាស់ដែលផលប្រយោជន៍របស់លោកគឺជាផលប្រយោជន៍លោកម្ចាស់ខ្ញុំនោះ ។ ចំពោះរឿងកាំភ្លើង និង ការរឹកបាត់នេះ លោកម្ចាស់ខ្ញុំចង់ដឹងថា ហេតុអ្វីក៏កូនប្រុសរបស់ *តូរ៉ាណាកា* ឈ្មោះ *ណាកា* ត្រូវបានតែងតាំងជាមេបញ្ជាការរង ? មេបញ្ជាការរងស្អី ? លោកមេទ័ព *អ៊ីស៊ីដូ* សូមសួរយ៉ាងគួរសមបំផុតថា តើមានអ្វីសំខាន់ណាស់ទៅរឺបានជាកូនរបស់ *តូរ៉ាណាកា* ត្រូវស្ថិតនៅទីនេះ ? រឿងនេះមានសារសំខាន់ណាស់ចំពោះលោកម្ចាស់ខ្ញុំ ។ បាទ មានសារសំខាន់មែន ព្រោះថាអ្វី១ដែលសព័ន្ធមិត្តរបស់លោកម្ចាស់ខ្ញុំធ្វើសុទ្ធតែមានសារសំខាន់ចំពោះលោកទាំងអស់ ឧទាហរណ៍ ដូចជាបញ្ហាដែលថាហេតុអ្វីបានជាមនុស្សចុងស្រុកនេះជាអ្នកទទួលបន្ទុកបង្វឹកបង្ហាត់ទៅវិញ ? បង្វឹកបង្ហាត់ស្អី ? បាទ *យ៉ាប៊ូ-សាម៉ា* រឿងទាំងនេះក៏សុទ្ធតែមានសារសំខាន់ណាស់ដែរ ។

*ចូស៊ិន* បង្វិលដាវរបស់ខ្លួនដើម្បីងាយអង្គុយជាង ចិត្តគេសែនរីករាយដែលគេមានសេនារបស់គេនៅការពារពីក្រោយខ្នងបែបនេះ ។ គេបន្ត :

- មួយវិញទៀត គឺក្រុមប្រឹក្សាអាជ្ញាធរសិទ្ធិនឹងជួបប្រជុំម្តងទៀតនៅថ្ងៃមួយកើតខាងមុខនេះ ។ គឺនៅម្ភៃថ្ងៃទៀត ។ លោកត្រូវបានអញ្ជើញជាផ្លូវការទៅស្បថសាជាថ្មីនូវភក្តីភាពរបស់លោកនៅឯទីក្រុង *អូសាកា*។

ពោះវៀនពោះតាំងរបស់ *យ៉ាប៊ូ* ឡើងរមួរចូលគ្នា :

- តាមខ្ញុំដឹង *តូរ៉ាណាកា-សាម៉ា* បានសុំឈប់លាលែងហើយ មែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- គាត់បានសុំលាលែងមែន *យ៉ាប៊ូ-សាន*។ បាទ សុំលាលែងមែន។ ប៉ុន្តែលោកម្ចាស់ *អ៊ិតូ តេរូស៊ូមី* បានមកជំនួសកន្លែងគាត់ហើយ ។ លោកម្ចាស់ខ្ញុំនឹងក្លាយទៅជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនេះ ។

*យ៉ាប៊ូ* ជ្រួលច្របល់យកតែមែនទែនតែម្តង។ *តូរ៉ាណាកា* បាននិយាយថាអ្នកនៅសល់ទាំងបួននាក់នឹងមិនអាចឯកភាពគ្នារើសអ្នកទីប្រាំបានឡើយ។ *អ៊ិតូ តេរូស៊ូមី* ជា *ដៃមីញ៉ូ* ដ៏ល្អិតល្អោចមួយនៅក្នុងខេត្ត *នេកាតូ* ភាគខាងលិចតំបន់ *ហុងស៊ូ* តែជាត្រកូលមួយដ៏មានចំនាស់យូរលង់មកហើយ ១ ក៏ជាប់ខ្សែត្រកូល *ភូជីម៉ូតូ* ផងដែរ ហេតុនេះមនុស្សនេះអាចចូលក្នុងក្រុមប្រឹក្សាអាជ្ញានុសិទ្ធិបានទោះបីជាមនុស្សនេះមិនមានប្រសិទ្ធភាព រឹកពារដូចស្រី និងគ្រាន់តែជាអាយ៉ងគេក្តី។

*យ៉ាប៊ូ* ឆ្លើយតបយ៉ាងប្រុងប្រយ័ត្ន ក្នុងបំនងមានពេលវេលាគ្រប់គ្រាន់ដើម្បីគិតគូរពិចារណា :

- ខ្ញុំមានកិត្តិយសណាស់ដែលទទួលបានការអញ្ជើញពីក្រុមប្រឹក្សាយ៉ាងនេះ។

-លោកម្ចាស់របស់ខ្ញុំគិតថាលោកប្រហែលមានបំនងធ្វើដំណើរចេញទៅអីលូវនេះភ្លាមដើម្បីបានទៅដល់ *អូសាកា* ទាន់ពេលប្រជុំផ្លូវការតែម្តង។ លោកម្ចាស់ខ្ញុំអោយខ្ញុំជំរាបលោកម្ចាស់ផងដែរថា *ដៃមីញ៉ូ* ទាំងអស់សុទ្ធតែនឹងបានទទួលនូវសេចក្តីអញ្ជើញដូចគ្នានេះ ក្នុងពេលជាមួយគ្នានេះ។នេះដើម្បីអាចអោយ***នាំចសស់គ្នា*** បានទៅដល់ទាន់ពេលវេលាក្នុងថ្ងៃទីម្ភៃមួយ។ ដើម្បីជាកិត្តិយសដល់ពិធីនេះ ព្រះចៅអធិរាជ *គូ-នីចូ* បានអនុញ្ញាតអោយមានពិធីមើលផ្កាក្នុងពេលនោះផងដែរ។

*រូច ចូសិន* ក៏ហុចសារត្រាទៅ *យ៉ាប៊ូ*។

- ហេតុអ្វីបានជាមិនមានត្រារបស់ក្រុមប្រឹក្សារអាជ្ញានុសិទ្ធិអញ្ចឹង ?

-លោកម្ចាស់ខ្ញុំបានចេញសេចក្តីអញ្ជើញក្នុងពេលនេះ ក្នុងឋានៈជាអណ្តាប់ដ៏ស្មោះត្រង់របស់លោកម្ចាស់ *តៃកូ* ក្នុងឋានៈជាអណ្តាប់ដ៏ស្មោះត្រង់របស់ *យ៉ែយមុំន* ដែលជាកូនរបស់លោកម្ចាស់ *តៃកូ* និង ជាទាយាទ ហើយដែលនឹងក្លាយជាអ្នកគ្រប់គ្រងចក្រភពនេះស្របច្បាប់នៅ



www.budinst.gov.kh www.elibraryofcambodia.org

ពេលណាដែលលោកត្រូវវិយ ហេតុនេះ លោកពិតជានឹងយល់បានហើយថា ក្រុមប្រឹក្សាថ្មីពិតជាឯកភាពទំនើរបស់ម្ចាស់ខ្ញុំជាមិនខាន *ទេ* ?

*យ៉ាប៉ូ* ប្រឹងទប់ទឹកមុខខ្លួនយ៉ាងលំបាក :

-គឺពិតជាកិត្តិយសពិសេសណាស់ដែលបានចូលរួមជាសាក្សីនៃកិច្ចប្រជុំជាផ្លូវការនេះ។

-ល្អណាស់-*ចូសិន* តប រួចគេយករមូរសារមួយថ្មីទៀតចេញមកបើក និងលើកបង្ហាញឡើង -នេះគឺជាលិខិតចំលងការតែងតាំងលោកម្ចាស់ *អ៊ីតូ* ដោយមានការចុះហត្ថលេខាទទួលស្គាល់ និង អនុញ្ញាតពីសមាជិកក្រុមប្រឹក្សាទាំងអស់ គឺលោកម្ចាស់ *អ៊ីស៊ីដូ . គីយ៉ាម៉ា . អូណូស៊ី* និងលោកម្ចាស់ *ស៊ូគីយ៉ាម៉ា*។

*ចូសិន* មិនរវល់នឹងខិតខំលាក់បាំងនូវទឹកមុខជាភាពអ្នកឈ្នះនោះទេ ដោយគេយល់ថាអង្គប់បានដាក់ជាប់ទាំងស្រុងនូវរូប *តូរ៉ាណាកា* និង សំព័ន្ធមិត្តទាំងប៉ុន្មានរបស់លោក ទន្ទឹមនេះសារត្រានេះ បានការពារខ្លួនគេនិងកូនចៅគេមិនអោយអ្នកណាប៉ះពាល់បាន ជាដាច់ខាតទៅហើយ ។

*យ៉ាប៉ូ* ទទួលយកសារត្រា។ ម្រាមដៃលោកញ័រទទ្រើត។ គ្មានអ្វីដែលត្រូវសង្ស័យថាសារត្រានេះក្លែងក្លាយឡើយ ។ នៅលើសារត្រាមានចុះការបញ្ជាក់របស់ជំទាវ *យ៉ូដូកូ* ភរិយារបស់សព *តៃកូ* ដែលថាឯកសារនេះពិតហើយដែលបានចុះហត្ថលេខានៅចំពោះមុខលោកជំទាវហើយដែលបានចំលងចេញជាប្រាំមួយច្បាប់ សំរាប់បញ្ជូនទៅទូទាំងចក្រភព។ សារចំលងមួយច្បាប់នេះត្រូវបានធ្វើសំរាប់ពួកអម្ចាស់តំបន់ *អ៊ីរ៉ាំរី. មីកាវ៉ា. តូតូមី. ស៊ូតូរ៉ា. អ៊ីស៊ូ* និង *ក្វាន់តូ*។ ថ្ងៃខែបញ្ជាក់ថាគេបានធ្វើវាតាំងពីដប់មួយថ្ងៃមុនម្ល៉េះ។

- លោកម្ចាស់តំបន់ *អ៊ីរ៉ាំរី . មីកាវ៉ា . តូតូមី* និង *ស៊ូតូរ៉ា* បានទទួលយល់ព្រមអស់ហើយ។ នេះគឺជាត្រារបស់អស់លោកទាំងនេះ។ លើបញ្ជីខ្ញុំ លោកគឺជាអ្នកជាប់នឹងអ្នកចុងក្រោយគេហើយ ។ អ្នកចុងក្រោយគឺលោកម្ចាស់ *តូរ៉ាណាកា*។

*យ៉ាប៉ូ* ឆ្លើយតប :

- សូមជួយអរគុណលោកម្ចាស់របស់លោកជំនួសខ្ញុំផង ហើយសូមជំរាបលោកថា ខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

នឹងរៀបចំខ្លួនទៅអបអរ និង ជូនពរលោកហើយ ។

- ល្អណាស់ ។ ខ្ញុំសូមលោកសរសេរវិញទៅ ។ សរសេរអីលូវនេះតែម្តងទៅ ក៏ស្រួលដែរ ។

- ចាំយប់នេះទៅ *ចូសិន-សាន* ។ ចាំបាយល្ងាចហើយ ។

- ល្អណាស់ ។ តើអីលូវនេះ យើងអាចទៅមើលការរ៉ិកហាត់នោះបានទេ ?

- ថ្ងៃនេះគេអត់ហាត់ទេ ។ កងទ័ពខ្ញុំកំពុងស្រូតក្បួនដំណើរទ័ព ។

*យ៉ាប៊ូ* ឆ្លើយតប ។ គ្រាន់តែ *ចូសិន* និង ក្រុមគេបានចូលដល់តំបន់ *អ៊ីស៊ូ* ភ្លាម ដំណឹងក៏ត្រូវបានបញ្ជូនមកដល់ដៃ *យ៉ាប៊ូ* ភ្លាមដែរ ។ *យ៉ាប៊ូ* បានបញ្ជាជាបន្ទាន់អោយកងទ័ពរបស់លោកបញ្ឈប់រាល់ការបាញ់កាំភ្លើងទាំងអស់ ហើយអោយបន្តរ៉ិកហាត់តែអាវុធដែលគ្មានសំលេងនៅឆ្ងាយ១ពី *អាន់ជិរ៍* ប៉ុននោះ ។ លោកបន្ត :

- ស្អែកលោកអាចអញ្ជើញទៅជាមួយខ្ញុំបាន ។ ទៅពេលថ្ងៃត្រង់ទៅ បើសិនជាលោកចង់ ។

*ចូសិន* ងើយសំលឹងមើលមេឃ ។ ពេលនេះគឺល្ងាចណាស់ទៅហើយ :

- ល្អ ។ ខ្ញុំគិតទំរេតខ្លួនបន្តិចសិន ។ តែដល់ពេលក្បាលព្រលប់ខ្ញុំនឹងត្រលប់មកវិញម្តងទៀត បើសិនជាលោកមិនយល់ទាស់ទេនោះ ។ ហើយពេលនោះ លោក និង មេបញ្ជាការលោកគឺ *អូមី-សាន* ហើយនឹង បញ្ជាការរងគឺ *ណាកា-សាន* នឹងរ៉ាយរ៉ាប់ប្រាប់ខ្ញុំ ដើម្បីជាគុណប្រយោជន៍របស់លោកម្ចាស់ខ្ញុំ អំពីរឿងរ៉ិកហាត់ រឿងកាំភ្លើងកាំភ្លាំង និងគ្រប់រឿងឯទៀតដែលមាន ។ រាប់ទាំងរឿងអាមនុស្សចុងស្រុកផង ។

- គាត់គឺ.........បាទ ។ អញ្ចឹងក៏បាន -*យ៉ាប៊ូ* ធ្វើសញ្ញាទៅ *អ៊ីកូរ៉ាជី* -មើលរៀបចំកន្លែងសំរាកសំរាប់ភ្ញៀវកិត្តិយស និង កូនចៅរបស់គាត់ផង ។

*ចូសិន* ឆ្លើយភ្លាម :

- សូមអរគុណណាស់ តែមិនចាំបាច់ទេ ។ ដីគឺជាកំរាលមួយគ្រប់គ្រាន់ហើយសំរាប់សាមូរ៉ៃ ហើយកែបសេះខ្ញុំនេះក៏អាចជំនួសខ្នើយបានដែរហើយ ។ បើលោកអធ្យាស្រ័យ សុំតែ



www.budinst.gov.kh www.elibraryofcambodia.org

ទឹកមុជបានហើយ.......សំនើមបែបនេះ *ទេ* ? បើសិនជាលោកអនុញ្ញាត ខ្ញុំសូមបោះទីតាំងនៅលើទួលនេះចុះ ។

- តាមចិត្តលោកចុះ ។

*ចូសិន* លំអោនខ្លួនទាំងរឹងឆ្អឹត ហើយដើរចេញទៅដោយមានកូនចៅរបស់គេអមជាមួយផង ។ អ្នកទាំងនេះមានអាវុធយុទ្ធភ័ណ្ឌពេញខ្លួន ។ ខ្មាន់ធ្នូពីរនាក់ជាអ្នកនៅយាមសេះ ។

នៅពេលដែលអ្នកទាំងនេះចេញបាត់ហើយនោះ ទើប *យ៉ាប៊ូ* បង្ហាញនូវទឹកមុខនេះប្រលោតរបស់ខ្លួន :

- អាណាក្បត់អញ ? អាណា ? ពួកយកការណ៍វានៅឯណា ?

*អ៊ីកូវ៉ាជី* លើកដៃធ្វើសញ្ញាបណ្ដេញពួកឆ្មាំអោយចេញឆ្ងាយដើម្បីកុំអោយស្ដាប់លឺ ។ ទឹកមុខគេឡើងស្លេក ។ គេតប :

- *យេដូ* ទាន ។ អានេះអាច ។ នៅខាងយើងនេះ សន្តិសុខចានាល្អណាស់ ។

*យ៉ាប៊ូ* ស្ទើរតែហែកអាវខ្លួនខ្ទេចខ្ទី

- អញត្រូវគេក្បត់ហើយ ។ យើងពិតជាឯកោ ។ *អ៊ីស៊ូ* និង *ក្វាន់តូ* ត្រូវឯកោ ។ *អ៊ីស៊ីដូ* ឈ្នះហើយ ។ វាឈ្នះហើយ ។

- វាមិនទាន់ឈ្នះទេ -*អូមី* និយាយយ៉ាងញាប់ស្មេញ-នៅសល់ម្ដៃថ្ងៃទៀតដែរ ទាន ។ គួរបញ្ជូននារសារជាបន្ទាន់ទៅលោកម្ចាស់ *តូរ៉ាណាកា* ដើម្បីជំរាបលោកថា..........

- អាចំកួត ! -សំលេង *យ៉ាប៊ូ* ប្រៀបដូចពស់អោយសំលេង -*តូរ៉ាណាកា* ច្បាស់ជាដឹងរួចទៅហើយ ។ កន្លែងដែលអញមានអ្នកយកការណ៍ម្នាក់ គាត់មានហាសិបនាក់ឯណោះ ។ គាត់ទុកអញក្នុងអង្គប់តែម្ដង ។

*អូមី* និយាយតបវិញដោយឥតមានញញើច :

- ខ្ញុំមិនយល់ឃើញបែបនេះទេ ទាន ។ *អ៊ីកិរី . មីកាវ៉ា . តូតូមី* និង *ស៊ូតូរ៉ា* សុទ្ធសឹងតែជាអ្នកមិនត្រូវរ៉ូវគ្នាជាមួយលោកម្ចាស់ *តូរ៉ាណាកា ទេ* ? ហើយក៏ចងសត្រូវនឹងអ្នកណាដែលជាសំព័ន្ធមិត្តនឹងគាត់ដែរ ។ ពួកគេពិតជាមិនប្រាប់គាត់ជាមុនទេ ហេតុនេះប្រហែលជាគាត់មិន



www.budinst.gov.kh www.elibraryofcambodia.org

ទាន់ដឹងរឿងរ៉ាវនេះនៅឡើយទេ។ គួរជូនដំណឹងគាត់ និង ស្នើ.......

*យ៉ាប៊ូ* ស្រែកតំហកគប :

- អែងមិនលឺទេ អ្វី ? សមាជិកក្រុមប្រឹក្សាទាំងបួនបានឯកភាពលើការតែងតាំង *អ៊ីតូ* នេះមានន័យថាក្រុមប្រឹក្សាមានលក្ខណៈស្របច្បាប់វិញហើយ ។ ក្នុងម្តៃថ្ងៃទៀត ក្រុមប្រឹក្សានេះនឹងបើកប្រជុំហើយ !

- ដំណោះស្រាយរឿងណឹងគឺងាយទេ ទាន។ គួរស្នើទៅ *តូរ៉ាណាកា* អោយគាត់ចាត់ចែងធ្វើឃាត *អ៊ីតូ តេរូស៊ូមី* រឺ សមាជិកណាម្នាក់នៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិចោលភ្លាមទៅ។

មាត់ *យ៉ាប៊ូ* ឡើងចំហធ្មុងម្ដែង :

- ថាម៉េច ?

- បើលោកម្ចាស់មិនចង់ធ្វើរឿងនេះទេ សូមបញ្ជូនខ្ញុំទៅ។ អោយខ្ញុំសាកលមើលម្តងមើល។ រឺ បញ្ជូន *អ៊ីកូរ៉ាជី-សាន* ក៏បាន។ បើលោកម្ចាស់ *អ៊ីតូ* ស្លាប់ *អ៊ីស៊ីដូ* ពិតជាខ្វះបង្អែកទៀតជាមិនខាន។

*យ៉ាប៊ូ* និយាយទាំងអស់សង្ឃឹម :

- ខ្ញុំមិនដឹងថាតើពួកអែងនេះឆ្កួតហើយរឺក៏នៅទេ។ ពួកអែងមានយល់ពីអ្វីដែលពួកអែងនិយាយនេះទេ ?

- លោកម្ចាស់ ខ្ញុំសូមអង្វរសូមលោកម្ចាស់អធ្យាស្រ័យស្តាប់ខ្ញុំសិន ។ *អាន់ជីន-សាន* បានផ្តល់ដល់លោកម្ចាស់នូវចំនេះដឹងដ៏មានតំលៃលើសលប់ *ទេ* ? ផ្តល់លើសពីអ្វីដែលសូម្បីតែក្នុងយល់សប្តិក៏យើងមិននឹកឃើញដល់ផង។ ក្នុងពេលនេះលោកម្ចាស់ *តូរ៉ាណាកា* ក៏ដឹងពីរឿងនេះដែរ អាស្រ័យដោយរបាយការណ៍របស់លោកម្ចាស់ ហើយម្យ៉ាងទៀតក៏ប្រហែលតាមរបាយការណ៍ផ្ទាល់ខ្លួនរបស់ *ណាកា* ដែរហើយមើលទៅ។ បើយើងអាចអូសបន្លាយពេលវេលាគ្រប់គ្រាន់កាំភ្លើងទាំងប្រាំរយដើមរបស់យើងបូកនឹងកាំភ្លើងផ្សេងទៀតបីរយដើមអាចផ្តល់ជូនលោកម្ចាស់នូវអានុភាពប្រយុទ្ធដាច់គេ ។ តែនេះ បានតែម្តងទេ។ នៅពេលដែលសត្រូវរបស់លោកម្ចាស់ ទោះជាអ្នកណាមួយក៏ដោយចុះ ឃើញនូវរបៀបលោកម្ចាស់ប្រើមនុស្ស និង សក្តានុពល



www.budinst.gov.kh www.elibraryofcambodia.org

អារ៉ុចនេះ គេនឹងរៀនតាមយ៉ាងរហ័ស ។ តែពួកអ្នកទាំងនោះត្រូវតែចាញ់នៅក្នុងការប្រយុទ្ធទីមួយនេះ ។ ការប្រយុទ្ធតែម្តង ហើយបើសិនជានេះជាការប្រយុទ្ធចំកៅអូវនោះ នឹងផ្តល់អោយ *តូរ៉ាណាកា* នូវជ័យជំនះទាំងស្រុងតែម្តង ។

- *អ៊ីស៊ីដូ* ឥតត្រូវការការប្រយុទ្ធទេ ។ ក្នុងម្ងៃថ្ងៃទៀតវានឹងទទួលបាននូវអំនាចរបស់ព្រះចៅអធិរាជហើយ ។

- *អ៊ីស៊ីដូ* គ្រាន់តែជាអ្នកសំរេចប៉ុននោះ ។ វាជាកូនអ្នកស្រែ ជាមនុស្សកុហកបោកប្រាស ហើយវារត់ចោលមិត្តនៅក្នុងពេលប្រយុទ្ធថែមទៀតផង ។

*យ៉ាប៊ូ* សំលឹងត្មៃទៅរក *អូមី* ប្រកបដោយទឹកមុខមាំ :

- អែង....តើអែងដឹងថាអែងកំពុងនិយាយពីស្អីទេហ្ហ៎ង ?

- នេះគឺជាអំពើគាត់ធ្វើមែនកាលនៅកូរ៉េ ។ខ្ញុំនៅទីនោះដែរ ។ខ្ញុំឃើញដោយផ្ទាល់ភ្នែកខ្ញុំ ។ ឪពុកខ្ញុំក៏ឃើញដែរ ។ *អ៊ីស៊ីដូ* **ពិតជា** បានចោល *ប៊ុនតារ៉ូ-សាន* ហើយនឹងពួកយើងអោយនៅរៀ រំដោះខ្លួនតាមយថាកម្មមែន ។ គាត់នេះជាមនុស្សសំរេចក្រលិចក្រលុចម្នាក់ ជាឆ្កែរបស់*តៃកូ* ។ ពិតមែនណា ។ លោកមិនអាចទុកចិត្តពួកអ្នកស្រែនេះបានទេ ។ ៦ *តូរ៉ាណាកា* វិញគឺជាមនុស្សត្រកូល *មីណូវ៉ារ៉ា* ។ លោកម្ចាស់អាចទុកចិត្តគាត់បាន ។ ខ្ញុំសូមជូនយោបល់ថាលោកម្ចាស់គួរគិតតែពីផលប្រយោជន៍របស់ *តូរ៉ាណាកា* តែមួយបានហើយ ។

*យ៉ាប៊ូ* គ្រវីក្បាលដោយហួសចិត្ត :

- អែងថ្លង់ហើយទេដឹង ? អែងមិនលឺ *នេបារ៉ា ចូស៊ិន* ទេអ្វី ? *អ៊ីស៊ីដូ* វាឈ្នះហើយ ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ នឹងកាន់អំនាចនៅក្នុងម្ងៃថ្ងៃទៀតនេះ ។

- **អាចនឹង** កាន់អំនាច ។

- ទោះបីជា *អ៊ីតូ* .......តើអែងអាចធ្វើបែបម៉េចបាន ? ទៅមិនរួចទេ រឿងហ្នឹង ។

- ពិតហើយខ្ញុំអាចសាកមើល តែខ្ញុំពិតជាមិនអាចធ្វើបានអោយទាន់ពេលនោះទេ ។ គ្មានអ្នកណាម្នាក់អាចធ្វើបានទេ ។ក្នុងម្ងៃថ្ងៃនេះគឺពិតជាគ្មានអ្នកណាធ្វើបានឡើយ ។ ប៉ុន្តែ *តូរ៉ាណាកា* អាចធ្វើបាន- *អូមី* ដឹងខ្លួនថាពេលនេះគេកំពុងដើរចូលមាត់នាគហើយ-ខ្ញុំសូមលោកម្ចាស់



www.budinst.gov.kh www.elibraryofcambodia.org

ពិចារណាលើរឿងនេះមើល ទាន។

*យ៉ាប៊ូ* យកដៃជូតថ្ងាស់។ ខ្លួនលោកទាំងមូលឡើងសើមជោក :

- ក្រោយពីទទួលការកោះហៅនេះហើយ បើសិនជាក្រុមប្រឹក្សាប្រជុំហើយខ្ញុំមិនមានវត្តមានវិញនោះ ទាំងខ្ញុំ ទាំងញាតិសន្តានខ្ញុំនឹងត្រូវស្លាប់ទាំងអស់ រួមទាំងអែងផង។ ខ្ញុំត្រូវការយ៉ាងហោចណាស់ក៏ពីរខែដែរដើម្បីរឹកហាត់ទាហានមួយកងធំបាន ។ ហើយបើទោះជាយើងបង្ហាត់ពួកវារួចរាល់នៅពេលនេះហើយក្តី ក៏ *តូរ៉ាណាកា* និង ខ្ញុំពិតជាមិនអាចយកឈ្នះលើពួកវាទាំងអស់គ្នាបាននោះទេ។ ទេ អែងគិតខុសហើយ។ ខ្ញុំត្រូវតែគាំទ្រ *អ៊ីស៊ីដូ* វិញ។

*អូមី* តប :

- លោកម្ចាស់អាចនៅទីនេះទៀតបានដប់ថ្ងៃទើបចេញទៅ *អូសាកា* ហើយបើលោកម្ចាស់ធ្វើដំណើរបន្ទិចវិញនោះ លោកម្ចាស់អាចមានពេលដល់ដប់បួនថ្ងៃឯណុះ។ ប្រាប់ *តូរ៉ាណាកា* ពីរឿង *នេចារ៉ា ចូសិន* ភ្លាមទៅ។ លោកម្ចាស់នឹងអាចជួយសង្គ្រោះទាំងត្រកូល *អ៊ីស៊ី* ទាំងត្រកូល *កាស៊ីគី*។ ខ្ញុំសូមអង្វរលោកម្ចាស់។ *អ៊ីស៊ីដូ* ពិតជាក្បត់លោកម្ចាស់ ហើយនឹងត្របាក់លេបរូបលោកម្ចាស់ជាមិនខាន។ ក្រែង *អ៊ីកាវ៉ា ជីគីយ៉ូ* ជាសាច់ញាតិគាត់អ្វី *ទេ*?

- រួចចុះ *ចូសិន* គិតយ៉ាងម៉េចដែរ? - *អ៊ីកូរ៉ាជី* ឧទានឡើង - អ្នកស? រួចរឿងកាំភ្លើង? រឿងមហាយុទ្ធសាស្រ្ត? វាចង់ដឹងទាំងអស់នៅយប់នេះតែម្តង។

*អូមី* តប :

- ប្រាប់ទៅចុះ។ ប្រាប់យ៉ាងលំអិតតែម្តង។ វាគ្មានអ្វីក្រៅតែជាបរិវារគេតែប៉ុណ្ណោះ។ បើកបង្ហាញផែនការយើងអោយវាដឹងផងចុះ។

ពេលនេះ *អូមី* ចាប់ផ្តើមលេងល្បិចហើយ។ គេដឹងថាគេកំពុងប្រថុយប្រថានជាទីបំផុត តែគេត្រូវតែបញ្ចៀស *យ៉ាប៊ូ* កុំអោយទៅខាង *អ៊ីស៊ីដូ* អោយបាន។ *អ៊ីកូរ៉ាជី* ប្រកែកញ៉ាញ់ :

- នៅពេលណាដែល *ចូសិន* ដឹងថាយើងកំពុងធ្វើអ្វីនោះ វានឹងបញ្ជូនសារទៅអោយ *អ៊ីស៊ីដូ* វិញជាមិនខាន។ រឿងនេះសំខាន់ណាស់ វានៅស្ងៀមមិនបានទេ។ ពេលនោះ *អ៊ីស៊ីដូ* នឹងលួចយកគំរោងរបស់យើងហើយពួកយើងច្បាស់ជាចប់ត្រឹមណឹង។



www.budinst.gov.kh www.elibraryofcambodia.org

- យើងអាចតាមដានពួកនាំសារហើយសំលាប់វាពេលណាតាមចិត្តយើងទេតើ ។

មុខ *យ៉ាប៉ូ* ឡើងក្រហមងាំង :

- សារត្រាត្រូវបានចុះហត្ថលេខាដោយអាជ្ញាធរថ្នាក់ខ្ពស់បំផុតក្នុងនគរនេះ ! ពួកវាទាំងអស់សុទ្ធតែធ្វើដំណើរក្រោមកិច្ចគាំពាររបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ! អែងឆ្កួតមែនទែនហើយដែលអោយអញធ្វើរបៀបនេះ! ធ្វើបែបនេះនឹងដាក់អញអោយនៅក្រៅច្បាប់ភ្លាម !

*អូមី* គ្រវីក្បាល ដោយរក្សាភាពជឿជាក់នៅលើទឹកមុខខ្លួនរហូត :

- ខ្ញុំជឿថា *យ៉ូដូកូ-សាម៉ា* និងអ្នកឯទៀតត្រូវអាក្បត់ *អ៊ីស៊ីដូ* បោកប្រាស់ហើយ ។ព្រះវាជាក់អញ្ចឹងដែរ ។ យើងត្រូវការពារកាំភ្លើងទាំងនេះ ។ យើងត្រូវបញ្ឈប់គ្រប់អ្នកនាំសារ.....

- ស្ងៀមទៅ ! យោបល់អែងនេះឆ្កួតសុទ្ធតែម្តងហើយ!

*អូមី* លំអោនខ្លួនក្រោមរន្ទះសំដី តែគេងើបក្បាលឡើងវិញហើយនិយាយយ៉ាងនឹងនំ :

- បើយ៉ាងនេះមែន សូមអនុញ្ញាតអោយខ្ញុំធ្វើ *សិបពូគូ* ទៅចុះ ទាន ។ តែដំបូងបង្អស់សូមអនុញ្ញាតអោយខ្ញុំបានបញ្ចប់គំនិតខ្ញុំសិន ព្រោះបើខ្ញុំមិនប្រឹងប្រែងការពារលោកម្ចាស់ទេនោះមានន័យថាខ្ញុំមានការខ្វះខាតក្នុងការបំពេញករណីយកិច្ចខ្ញុំដែរ ។ ខ្ញុំសូមសំនូមពរចុងក្រោយនេះ ក្នុងឋានៈខ្ញុំជាអណ្តាប់ដ៏ស្មោះត្រង់ម្នាក់តែប៉ុននោះ ។

- បញ្ចប់ទៅ !

- ***បច្ចុប្បន្ននេះ*** មិនអាចមានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិទេ ដោយហេតុនេះគ្មានការគាំពារស្របច្បាប់ណាមួយសំរាប់អាមនុស្សព្រហើនឥតសុជីវធម៌បែបអា *តូសិន* និងកូនចៅវានោះទេ លើកលែងតែលោកម្ចាស់អោយតំលៃទៅលើឯកសារមិនស្របច្បាប់នេះដោយហេតុ....-*អូមី* ហៀបនឹងប្រើពាក្យ "*ភាពកំសោយ*" ទៅហើយតែគេដូរពាក្យវិញដោយនៅតែរក្សាសំលេងដ៏ម៉ឺងម៉ាត់ប្រកបដោយអំនាចនិងយ៉ាងនឹងនំ - ការចាញ់បោកគេដូចអ្នកឯទៀតតែប៉ុននោះ ។ ***ពេលនេះគ្មានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិទេ*** ។ ពួកនេះមិនអាច " បញ្ជា " លោកម្ចាស់អោយធ្វើនេះរឺ ធ្វើនោះបានទេ ។ ពិតមែនហើយ នៅពេលណាគេចាប់ប្រជុំហើយ នោះគឺបាន ។ ពេលនោះពួកគេអាចចេញបញ្ជាហើយលោកម្ចាស់ត្រូវតែគោរពតាម ។ តែនៅពេលនេះតើមាន *ដៃមីញ៉ូ*



www.budinst.gov.kh www.elibraryofcambodia.org

ប៉ុន្មាននាក់ដែលនឹងគោរពតាមមុនពេលដែលមានបញ្ហា ***ស្រមឡាប់*** ? មានតែពួកសំព័ន្ធមិត្ត *អ៊ីស៊ីដូ* តែប៉ុននោះ *ទេ*? តំបន់ *អ៊ីវ៉ារី* . *មីកាវ៉ា* . *តូតូមី* និង *ស៊ូតូវ៉ា* មិនសុទ្ធតែគ្រប់គ្រងដោយសាច់ញាតិគាត់ និងដែលចងសំព័ន្ធភាពជាមួយគាត់ជាចំហទេរឺ ? ពិតហើយដែលថាឯកសារនេះមានន័យថាសង្គ្រាមប៉ុន្តែខ្ញុំសូមអង្វរលោកម្ចាស់ សូមធ្វើសង្គ្រាមតាមលក្ខខណ្ឌរបស់លោកម្ចាស់ មិនមែនតាមលក្ខខណ្ឌ *អ៊ីស៊ីដូ* ទេ។ សូមលោកម្ចាស់ចាត់ទុកការគំរាមកំហែងនេះដូចជាសំរាមទៅចុះ ! *តូរ៉ាណាកា* មិនដែលចាញ់ការប្រយុទ្ធម្តងណាទេ ឯ *អ៊ីស៊ីដូ* ធ្លាប់។ *តូរ៉ាណាកា* បានចៀសមិនចូលរួមក្នុងការវាយប្រហារទៅលើប្រទេសកូរ៉េ ដែលនាំមកនូវមហន្តរាយដ៏សំបើមនោះបាន *អ៊ីស៊ីដូ* អត់ទេ។ *តូរ៉ាណាកា* គាំទ្ររឿងនាវាចរណ៍ និង ជំនួញជួញដូរ *អ៊ីស៊ីដូ* អត់គាំទ្រទេ។ តូរ៉ាណាកា ចង់បានសំពៅរបស់មនុស្សចុងស្រុក *អ៊ីស៊ីដូ* ឥតចង់ទេ។ *អ៊ីស៊ីដូ* នឹងបិទចក្រភព *តូរ៉ាណាកា* នឹងរក្សាអោយនៅបើកដដែល។ បើសិនជា *អ៊ីស៊ីដូ* ឈ្នះ គាត់នឹងប្រគល់តំបន់ *អ៊ីស៊ូ* ដែលជាតំបន់កេរដូនតាលោកម្ចាស់នេះទៅអោយ *អ៊ីកាវ៉ា ជីគីយូ* ឯ *តូរ៉ាណាកា* នឹងអោយលោកម្ចាស់នូវខេត្ត របស់ *ជីគីយូ* ទាំងមូល។ លោកម្ចាស់ជាសំព័ន្ធមិត្តចំបងរបស់លោកម្ចាស់ *តូរ៉ាណាកា* ។លោកម្ចាស់មិនឃើញគាត់ប្រគល់ដាវគាត់ជូនដល់លោកម្ចាស់ទេអ្វី ? មិនឃើញគាត់អោយលោកម្ចាស់ជាអ្នកគ្រប់គ្រងកាំភ្លើងទេ អ្វី ? មិនតឹកាំភ្លើងហ្នឹងទេរឺដែលនឹងធានាជ័យជំនះបានម្តង បើសិនជាប្រើវា ***មិនអោយគេស្គាល់ជាមុន*** នោះ ? តើ *អ៊ីស៊ីដូ* នឹងអោយអ្វីជូនលោកម្ចាស់ដើម្បីជាសំនងវិញទេ ? វាបញ្ជូនពួក *រ៉ូនីន*-សាមូរ៉ៃដែលគ្មានសុជីវធម៌អីបន្តិចដោយបញ្ជាយ៉ាងចេតនាអោយមកបំបាក់មុខលោកម្ចាស់នៅក្នុងអាណាខេត្តលោកម្ចាស់តែម្តង ! ខ្ញុំយល់ថា *តូរ៉ាណាកា មីណូវ៉ារ៉ា* គឺជាជំរើសតែមួយគត់សំរាប់លោកម្ចាស់។ លោកម្ចាស់ត្រូវតែរួមដៃជាមួយគាត់។

និយាយរួច *អូមី* លំអោនខ្លួនគោរពហើយនៅរង់ចាំយ៉ាងស្ងៀមស្ងាត់។ *យ៉ាប៊ូ* ងៀងភ្នែកមើលទៅ *អ៊ីកូរ៉ាជី*:

- យ៉ាងម៉េចដែរ ?

- ខ្ញុំឯកភាពជាមួយ *អូមី-សាន* ដែរ ទាន -មុខរបស់ *អ៊ីកូរ៉ាជី* បង្ហាញយ៉ាងច្បាស់នូវ



www.budinst.gov.kh www.elibraryofcambodia.org

ភាពកង្វល់របស់ខ្លួន -តែអារឿងសំលាប់អ្នកនាំសារនេះ.......គឺអាចគ្រោះថ្នាក់ណាស់។ ពេលនោះគឺឥតដកថយបានវិញទេ ទាន។ ស្អែកនេះ *ចូសិទ* ពិតជាបញ្ជូនអ្នកនាំសារមួយ រឺ ពីរនាក់ចេញទៅដែរ។ ពួកនេះអាចបាត់ខ្លួន ដោយត្រូវពួកចោរព្រៃសំលាប់ក៏បាន.........

*អ៊ីកូវ៉ាជី* ឈប់ង៉ក់កណ្តាលឃ្លា រួចលាន់មាត់ឡើង :

- ព្រាបនាំសារ ! មានព្រាបនាំសារពីរទ្រុងនៅលើសេះដឹកអីវ៉ាន់របស់ *ចូសិទ* !

*អូមី* ពោលឡើង :

- យប់នេះយើងត្រូវបំពុលវាអោយអស់។

- បំពុលយ៉ាងម៉េចទៅ ? ពួកវាច្បាស់ជាដាក់ឆ្មាំយាមមិនខានទេ។

- ខ្ញុំមិនដឹងដែរ។ តែព្រាបអស់នេះត្រូវតែកំចាត់ចោល រឺ ត្រូវតែធ្វើកុំអោយវាហើររួចមុនពេលព្រឹកនេះ។

*យ៉ាប៊ូ* និយាយ :

- *អ៊ីកូវ៉ាជី* បញ្ជូនមនុស្សទៅឃ្លាំមើល *ចូសិទ* ភ្លាមទៅ។ មើលក្រែងវាបញ្ជូនព្រាបវាក្នុងពេលនេះ។

*អូមី* បន្ថែមយ៉ាងប្រញាប់ :

- ខ្ញុំស្នើអោយលោកបញ្ជូនស្ទាំង និងខ្លាទន់ស្ទាំងទាំងអស់ទៅនៅទិសខាងកើតភ្លាមទៅដែរ ទាន។

*អ៊ីកូវ៉ាជី* ពោលឡើង :

- បើសិនជាវាឃើញព្រាបវាត្រូវស្លាប់ រឺ ប៉ះពាល់ *ចូសិទ* អាចមានសង្ស័យលើល្បិចកិច្ចកលអីមួយមិនខាន។

*អូមី* ញាក់ស្មា :

- ត្រូវវាវាំងដំណើរព្រាបនេះអោយខាងតែបាន។

*អ៊ីកូវ៉ាជី* សំលឹងមើលទៅ *យ៉ាប៊ូ* ។

*យ៉ាប៊ូ* ពោលទាំងទ័លចំនេះ :



www.budinst.gov.kh www.elibraryofcambodia.org

- ធ្វើតាមហ្នឹងទៅ។

នៅពេលដែលគេត្រលប់មកវិញ *អ៊ីកូរ៉ាជី* សួរឡើង :

- *អូមី-សាន* មានរឿងមួយដែលធ្វើអោយខ្ញុំចាប់អារម្មណ៍។ ភាគច្រើននៃអ្វីដែលលោកនិយាយគឺពិតជាត្រឹមត្រូវ ទាំងរឿង *ជីគីយូ* ក្តី ទាំងរឿងលោកម្ចាស់ *អ៊ីស៊ីដូ* ក្តី។ តែបើលោកមានយោបល់ថាត្រូវតែធ្វើអោយអ្នកនាំសារ "បាត់ខ្លួន" ដែរ ម៉េចចាំបាច់ប្រលែងលេងនឹង *ចូស៊ិន* ធ្វើអី ? ម៉េចចាំបាច់ប្រាប់រឿងរ៉ាវសព្វគ្រប់ដល់វាធ្វើអី ? ម៉េចមិនសំលាប់វាចោលតែម្តងអោយហើយទៅ។

*អូមី* តប :

- ពិតមែន ចាំបាច់ទុកធ្វើអីហ្ន៎ ? លើកលែងតែ *យ៉ាប៊ូ-សាម៉ា* ចង់លលេង។ ខ្ញុំឯកភាពថាផែនការលោកល្អប្រសើរជាងមែន *អ៊ីកូរ៉ាជី-សាន*។

អីលូវនេះ អ្នកទាំងពីរសំលឹងមើលទៅ *យ៉ាប៊ូ* ១ ក៏សួរត្រលប់ទៅវិញ :

- តើធ្វើយ៉ាងម៉េចដើម្បីលាក់រឿងកាំភ្លើងនេះបាន ?

- សំលាប់ *ចូស៊ិន* និង កូនចៅវាចោល - *អូមី* ឆ្លើយតប។

- គ្មានផ្លូវណាផ្សេងទៀតទេអី ?

*អូមី* គ្រវីក្បាល។ *អ៊ីកូរ៉ាជី* ក៏គ្រវីក្បាល។ *យ៉ាប៊ូ* ក៏និយាយឡើងដោយញ័ររញ្ជួយនៅក្នុងចិត្ត ខួរក្បាលប្រឹងរិះរកមធ្យោបាយដើម្បីគេចផុតពីអង្គប់នេះ :

- ខ្ញុំប្រហែលជាអាចតថ្លៃជាមួយ *អ៊ីស៊ីដូ* បានដែរ។ អែងនិយាយត្រូវណាស់ពីរឿងពេលវេលានេះ។ ខ្ញុំមានសល់ពេលដប់ថ្ងៃ រឺ ច្រើនបំផុតដប់បួនថ្ងៃ។ តើត្រូវប្រកាន់ជំហរបែបណាជាមួយ *ចូស៊ិន* ដើម្បីនឹងមានពេលគ្រប់គ្រាន់ដើម្បីដើរក្រលាអោយបានល្អ ?

*អូមី* តប :

- ជាការវាងវៃមួយដែរ ដែលលោកម្ចាស់ធ្វើជាធ្វើដំណើរទៅ *អូសាកា* ។ ប៉ុន្តែ ក៏មិនជាការខាតបង់អ្វីដែរ ដែលត្រូវផ្តល់ដំណឹងទៅលោកម្ចាស់ *តូរ៉ាណាកា* ភ្លាមនេះ *ទេ* ? ព្រោះនាំសារយើងមួយណាក៏សុទ្ធតែនឹងទៅដល់ *យេដូ* មុនព្រលប់ដែរ។ ហើយនេះក៏គ្មានទៅខាតអីដែរ។



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ិកូរ៉ាជី* និយាយឡើង ៖

- លោកអាចជំរាបលោកម្ចាស់ *តូរ៉ាណាកា* បានពីរឿង *ចូស៊ិន* ដែលនឹងទៅរកគាត់ ពីរឿងក្រុមប្រឹក្សាដែលនឹងប្រជុំនៅក្នុងម្ភៃថ្ងៃទៀត។ នេះគឺបាន។ តែរឿងផ្សេងទៀត រឿងធ្វើឃាតលោកម្ចាស់ *អ៊ិតូ* អី១នេះ គឺគ្រោះថ្នាក់ណាស់ដែលត្រូវសរសេរលើក្រដាសនោះទោះបីជា... គ្រោះថ្នាក់តែមែនទែនតែម្តង *ទេ*?

- ខ្ញុំឯកភាព។ អត់និយាយអីទាំងអស់រឿង *អ៊ិតូ*។ *តូរ៉ាណាកា* ត្រូវពិចារណារឿងនេះដោយផ្ទាល់ខ្លួនលោកចុះ *ទេ*?

- ពិតហើយ។ រឿងនេះគិតមិនដល់មែន តែវាត្រូវតែអញ្ចឹង។

*អូមី* រង់ចាំយ៉ាងស្ងៀមស្ងាត់ ខួរក្បាលរបស់គេរន្ធើនស្វែងរកដំណោះស្រាយ។ ភ្នែករបស់ *យ៉ាប៊ូ* ផ្តោតជាប់មកលើរូបគេតែគេឥតមានរន្ធត់ញាប់ញ័រអ្វីទាំងអស់។ យោបល់របស់គេគឺត្រឹមត្រូវ និងលើកឡើងក៏ដើម្បីតែការពារបក្សសម្ព័ន្ធគ្រួសារនិង *យ៉ាប៊ូ* ដែលបច្ចុប្បន្ននេះជាមេសម្ព័ន្ធគេតែប៉ុណ្ណោះ។ ប្រការដែល *អូមី* សំរេចផ្តល *យ៉ាប៊ូ* និងប្អូនមេកើយខ្លួននោះមិនបានរាំងគេ មិនអោយផ្តល់យោបល់ដ៏វាងវៃនោះឡើយ។ ហើយក្នុងពេលនេះគេត្រៀមខ្លួនជាស្រេចដើម្បីស្លាប់។បើសិនជា *យ៉ាប៊ូ* ល្ងីល្ងើពកថ្លាសមិនព្រមទទួលស្គាល់ភាពត្រឹមត្រូវនៃគំនិតរបស់គេទេនោះបន្តិចទៀតក៏នឹងគ្មានបក្សសម្ព័ន្ធអ្វីទៀតដើម្បីនឹងដឹកនាំដែរ។ *កាម៉ា*។

*យ៉ាប៊ូ* អោនខ្លួនទៅមុខ អារម្មណ៍ទៅមិនទាន់ដាច់ស្រេច ៖

- តើមានផ្លូវណាដែលអាចកំចាត់ *ចូស៊ិន* និង កូនចៅវាដោយគ្មានគ្រោះថ្នាក់ដល់ខ្ញុំនិងដោយយើងអាចស្ថិតនៅអព្យាក្រឹតក្នុងរវាងដប់ថ្ងៃនេះបានទេ?

*អូមី* តបយ៉ាងធូរល្ហុយ

- *ណាកា*។ យក *ណាកា* ធ្វើថ្នាក់។

*************



www.budinst.gov.kh www.elibraryofcambodia.org

- ធ្វើតាមហ្នឹងទៅ ។

នៅពេលដែលគេត្រលប់មកវិញ *អ៊ីក្វាំជី* សួរឡើង :

- *អូមី-សាន* មានរឿងមួយដែលធ្វើអោយខ្ញុំចាប់អារម្មណ៍ ។ ភាគច្រើននៃអ្វីដែលលោកនិយាយពិតជាត្រឹមត្រូវ ទាំងរឿង *ជីតិយូ* ក្តី ទាំងរឿងលោកម្ចាស់ *អ៊ុស៊ុំ* ក្តី ។ តែបើលោកមានយោបល់ថាត្រូវតែធ្វើអោយអ្នកនាំសារ "បាត់ខ្លួន" ដែរ ម៉េចចាំបាច់ប្រលែងលេងនឹង *ចូសិន* ធ្វើអី ? ម៉េចចាំបាច់ប្រាប់រឿងរ៉ាវសព្វគ្រប់ដល់វាធ្វើអី ? ម៉េចមិនសំលាប់វាចោលតែម្តងអោយហើយទៅ ។

*អូមី* តប :

- ពិតមែន ចាំបាច់ទុកធ្វើអីហ្នំ ? លើកលែងតែ *យ៉ាហ្ស៊ូ-សាម៉ា* ចង់លលេង ។ ខ្ញុំឯកភាពថាផែនការលោកល្អប្រសើរជាងមែន *អ៊ីក្វាំជី-សាន*។

អីលូវនេះ អ្នកទាំងពីរសំលឹងមើលទៅ *យ៉ាហ្ស៊ូ* ។ ក៏សួរត្រលប់ទៅវិញ :

- តើធ្វើយ៉ាងម៉េចដើម្បីលាក់រឿងកាំភ្លើងនេះបាន ?

- សំលាប់ *ចូសិន* និង កូនចៅវាចោល -*អូមី* ឆ្លើយតប ។

- គ្មានផ្លូវណាផ្សេងទៀតទេអី ?

*អូមី* គ្រវីក្បាល ។ *អ៊ីក្វាំជី* ក៏គ្រវីក្បាល ។ *យ៉ាហ្ស៊ូ* ក៏និយាយឡើងដោយញ័ររញ្ជួយនៅក្នុងចិត្ត ខួរក្បាលប្រឹងរិះរកមធ្យោបាយដើម្បីគេចផុតពីអង្គប់នេះ :

- ខ្ញុំប្រហែលជាអាចតថ្លៃជាមួយ *អ៊ុស៊ុំ* បានដែរ ។ អែងនិយាយត្រូវណាស់ពីរឿងពេលវេលានេះ ។ ខ្ញុំមានសល់ពេលដប់ថ្ងៃ រឺ ច្រើនបំផុតដប់បួនថ្ងៃ ។ តើត្រូវប្រកាន់ជំហរបែបណាជាមួយ *ចូសិន* ដើម្បីនឹងមានពេលគ្រប់គ្រាន់ដើម្បីដើរក្រលាអោយបានល្អ ?

*អូមី* តប :

- ជាការរាងវៃមួយដែរ ដែលលោកម្ចាស់ធ្វើជាធ្វើដំណើរទៅ *អូសាកា* ។ ប៉ុន្តែ ក៏មិនជាការខាតបង់អ្វីដែរ ដែលត្រូវផ្តល់ដំណឹងទៅលោកម្ចាស់ *តូរ៉ាណាកា* ក្នុងមនេះ *ទេ* ? ព្រោះនាំសារយើងមួយណាក៏សុទ្ធតែនឹងទៅដល់ *យេដូ* មុនព្រលប់ដែរ ។ ហើយនេះក៏គ្មានទៅខាតអីដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ីកូវ៉ាជី* និយាយឡើង :

- លោកអាចជំរាបលោកម្ចាស់ *តូវ៉ាណាកា* បានពីរឿង *ចូស៊ិន* ដែលនឹងទៅរកគាត់ ពីរឿងក្រុមប្រឹក្សាដែលនឹងប្រជុំនៅក្នុងម្តៃថ្ងៃទៀត។ នេះគឺបាន។ តែរឿងផ្សេងទៀត រឿងធ្វើឃាតលោកម្ចាស់ *អ៊ីតូ* អី១នេះ គឺគ្រោះថ្នាក់ណាស់ដែលត្រូវសរសេរលើក្រដាសនោះទោះបីជា... គ្រោះថ្នាក់តែមែនទែនតែម្តង *ទេ?*

- ខ្ញុំឯកភាព។ អត់និយាយអីទាំងអស់រឿង *អ៊ីតូ*។ *តូវ៉ាណាកា* ត្រូវពិចារណារឿងនេះដោយផ្ទាល់ខ្លួនលោកចុះ *ទេ?*

- ពិតហើយ។ រឿងនេះគិតមិនដល់មែន តែវាត្រូវតែអញ្ចឹង។

*អូមី* រង់ចាំយ៉ាងស្ងៀមស្ងាត់ ខួរក្បាលរបស់គេរន្ថើនស្វែងរកដំណោះស្រាយ។ ភ្នែករបស់ *យ៉ាប៊ូ* ផ្តោតជាប់មកលើរូបគេតែគេឥតមានរន្ធត់ញាប់ញ័រអ្វីទាំងអស់។ យោបល់របស់គេគឺត្រឹមត្រូវ និងលើកឡើងក៏ដើម្បីតែការពារបក្សសព័ន្ធគ្រួសារនិង *យ៉ាប៊ូ* ដែលបច្ចុប្បន្ននេះជាមេសព័ន្ធគេតែប៉ុណ្ណោះ។ ប្រការដែល *អូមី* សំរេចផ្តួល *យ៉ាប៊ូ* និងប្តូរមេកើយខ្លួននោះមិនបានរារាំងគេ មិនអោយផ្តល់យោបល់ដ៏វាងវៃនោះឡើយ។ ហើយក្នុងពេលនេះគេត្រៀមខ្លួនជាស្រេចដើម្បីស្លាប់។បើសិនជា *យ៉ាប៊ូ* ល្ងីល្ងើពេកថ្វាសមិនព្រមទទួលស្គាល់ភាពត្រឹមត្រូវនៃគំនិតរបស់គេទេនោះបន្តិចទៀតក៏នឹងគ្មានបក្សសព័ន្ធអ្វីទៀតដើម្បីនឹងដឹកនាំដែរ។ *កាម៉ា*។

*យ៉ាប៊ូ* អោនខ្លួនទៅមុខ អារម្មណ៍នៅមិនទាន់ដាច់ស្រេច :

- តើមានផ្លូវណាដែលអាចកំចាត់ *ចូស៊ិន* និង កូនចៅវាដោយគ្មានគ្រោះថ្នាក់ដល់ខ្ញុំនិងដោយយើងអាចស្ថិតនៅអព្យាក្រឹតក្នុងរវាងដប់ថ្ងៃនេះបានទេ ?

*អូមី* តបយ៉ាងធូរល្ហុយ

- *ណាកា*។ យក *ណាកា* ធ្វើធ្នាក់។

************



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលព្រលប់ *ក្លាក់ថន* និង *ម៉ារីក្លូ* បានជិះសេះមកដល់មាត់របងផ្ទះរបស់គេវិញ ដោយមានអ្នកជិះសេះឯទៀតតាមពីក្រោយមកផង ។ ទាំងពីរនាក់មានការហេវហត់យ៉ាងខ្លាំង។ *ម៉ារីក្លូ* ជិះសេះដូចមនុស្សប្រុស ។ នាងស្លៀកខោរលុង ពាក់អាវក្រៅស៊ុលគឃុល ។ មួកហាមធំមួយ ហើយនឹងស្រោមដៃការពារនាងនឹងពន្លឺថ្ងៃ ។ សូម្បីតែនារីកសិករក៏ប្រឹងប្រែងការពារមុខនិងដៃកុំអោយប៉ះពន្លឺថ្ងៃដែរព្រោះតាំងពីណាពីណីអើយមកម៉្លេះ គេតែងយល់ថាអ្នកណាសាច់កាន់តែខ្មៅអ្នកនោះកាន់តែអន់ តែបើសាច់កាន់តែសកាន់តែមានតំលៃ ។

បុរស១អ្នកបំរើទទួលយកបង្ហៀរហើយដឹកសេះចេញទៅ ។ *ក្លាក់ថន* និយាយប្រាប់អ្នកជិះសេះឯទៀតអោយត្រលប់ទៅវិញជាភាសាជប៉ុនមួយដែលអាចស្តាប់បាន រួចទើបគេគួរសមជាមួយ *ភូជីក្លូ* ដែលនៅចាំទទួលគេប្រកបដោយមោទនភាពក្រោមយ៉ាបផ្ទះដូចសព្វដង ។

ដូចសព្វដងដែរនាងលើកសំនួរយ៉ាងសែនគួរសម :

- តើលោកត្រូវការអោយខ្ញុំបំរើតែលោកទេ *អាន់ជីន-សាន* ?

ដូចសព្វដងដែរ *ក្លាក់ថន* ឆ្លើយតប :

- ទេ ។ ដំបូងបង្អស់ខ្ញុំនឹងទៅមុជទឹកសិន ។ បន្ទាប់មក *សាកេ* និងម្ហូប ។

ហើយដូចសព្វដង គេលំអោនខ្លួនគោរពតប *ភូជីក្លូ* រួចដើរតាមរបៀងផ្ទះទៅរហូតដល់ខាងក្រោយ ឆ្លងកាត់សួនច្បាររហូតដល់បន្ទប់មុជទឹក ។ នៅទីនោះ *ក្លាក់ថន* ដោះខោអាវខ្លួនប្រគល់ទៅអោយអ្នកបំរើម្នាក់ រួចចូលទៅអង្គុយខាងក្នុងបន្ទប់ដោយខ្លួនទទេ ។អ្នកបំរើម្នាក់ទៀតក៏ចាប់ផ្តើមដុសក្បាល ដុសសាប៊ូ និង កក់សក់ ហើយនឹងស្រោចទឹកគេជំរះសំអាតពពុះសាប៊ូ និងធូលីទាំងឡាយចេញ ។ នៅពេលដែលសព្វសាពាង្គកាយគេត្រូវបានសំអាតហើយនោះ ទើបគេចូលទៅទំរេតត្រាំទឹកក្តៅក្នុងអាងដែកដ៏ក្រាស់ឃ្មឹកមួយ ។

- ឱ ព្រះអើយ ! ស្រួលម៉្លេះទេ !

គេលាន់មាត់ឡើងទាំងបិទភ្នែកស្រិម ដោយបណ្តោយអោយធាតុក្តៅរត់រសិបចូលទៅក្នុងសាច់ដុំ ។ ញើសស្រក់តក់១ពីលើថ្ងាសរបស់គេ ។

គេលឺសូរទ្វាររបើកឡើង និង សំលេង " រាត្រីសួស្តី លោកម្ចាស់" របស់ *ស៊ូរ៉ូ* ព្រមទាំង



www.budinst.gov.kh www.elibraryofcambodia.org

ក្លាប់ដោយភាសាជប៉ុនមួយឃ្លាយ៉ាងវែងទៀតដែលគេស្តាប់មិនបាន។ តែយប់នេះ គេស្ទើរតែហត់មិនមានសេសសល់កំលាំងអ្វីនឹងសាកល្បងរៀននិយាយជាមួយ *ស៊ូរី* ឡើយ។ ម្យ៉ាងទៀតការត្រាំទឹកនេះ ដូច *ម៉ារីកូ* បានពន្យល់គេជាច្រើនដងមកហើយ គឺ "មិនសំខាន់សំរាប់តែសំអាតស្បែកនោះទេ តែនេះជារង្វាន់ដែលព្រះ វិ ពពួកព្រះបានប្រទានអោយសំរាប់យើងហើយដែលត្រូវតែទទួលប្រើយ៉ាងសក្តិសមជាទីបំផុត"។ គេពោលឡើង :

- អត់និយាយ *ស៊ូរី*។ យប់នេះ ចង់ គិត។

- បាទ លោកម្ចាស់។ សូមលោកអធ្យាស្រ័យ ប៉ុន្តែលោកគួរនិយាយថា " យប់នេះខ្ញុំចង់គិត "វិញ។

- យប់នេះ ខ្ញុំចង់គិត។

*ប្លាក់ថន* ថាតាមឃ្លាត្រឹមត្រូវរបស់ភាសាជប៉ុនទទឹមនឹងខិតខំចងចាំសំនៀងដ៏លំបាកទាំងប៉ុន្មាននៅក្នុងខួរក្បាល។ គេរីករាយណាស់ដែលការនិយាយរបស់គេត្រូវបានការជួយតំរែតំរង់ តែគេក៏សែននឿយណាយផងដែរ។

តាំងពីព្រឹកព្រលឹមម្ល៉េះ គេបានសួរទៅ *ម៉ារីកូ* :

- ឯណាសៀវភៅវចនានុក្រម និង វេយ្យាករណ៍ ? *យ៉ាប៊ូ-សាម៉ា* មានអោយគេទៅរកទៀតទេ ?

- ចាស។ សូមអត់ធ្មត់បន្តិច *អាន់ជីន-សាន*។ សៀវភៅណឹងជិតមកដល់ហើយ។

- មុនសន្យាថាសៀវភៅនឹងមកដល់ជាមួយទូកធំ និង កងទ័ព។ តែអត់មានមកសោះ។ មានកងទ័ព មានកាំភ្លើង តែអត់សៀវភៅ។ ខ្ញុំមានសំនាងហើយដែលមាននាងនៅទីនេះ។ អត់នាងធ្វើអ្វីក៏មិនកើតដែរ។

- គ្រាន់តែលំបាកប៉ុនោះ មិនមែនធ្វើអ្វីមិនកើតនោះទេ *អាន់ជីន-សាន*។

- តើខ្ញុំត្រូវនិយាយជាជប៉ុនថាម៉េច ពាក្យ "ទេ ធ្វើអញ្ចឹងខុសហើយ ! ត្រូវរត់ជាក្រុមឈប់ជាក្រុម តំរង់ហើយបាញ់ព្រមៗគ្នាជាក្រុម " ?

*ម៉ារីកូ* សួរបញ្ច្រាសទៅវិញ :



LIBRARY BUDDHIST INSTITUTE

www.budinst.gov.kh www.elibraryofcambodia.org

- តើនិយាយនេះជាមួយអ្នកណា ?

*ក្លាក់ថន* មានអារម្មណ៍ថាគេមានកំហកចិត្តយ៉ាងខ្លាំងតែម្តង :

- ស្តី ១ យ៉ាប់តែទាំងអស់មែនតែម្តង *ម៉ារីកូ-សាន*។

- មិនមែនទេ *អាន់ជីន-សាន*។ ភាសាជប៉ុនតឹងាយបំផុតបើផ្ទឹមជាមួយភាសាឯទៀត។ គ្មាន " The ", "a" រឺ "an " អីទាំងអស់។ កិរិយាស័ព្ទក៏មិនចាំបាច់ផ្លាស់ប្តូរ គឺនៅដដែលគ្រាន់តែបញ្ចប់ដោយពាក្យ *ម៉ាស៊ុ* ហើយប្រើតែក្នុងបច្ចុប្បន្នកិរិយាទាំងអស់ក៏បាន បើសិនជាលោកចង់ ។ ចំពោះសំនួរលោកគ្រាន់តែបន្ថែមពាក្យ *កា* ពីក្រោយកិរិយាស័ព្ទតែប៉ុននោះគឺហើយស្រេច។ ចំពោះអ្វីដែលបដិសេធ លោកគ្រាន់តែប្តូរពី *ម៉ាស៊ុ* ទៅជា *ម៉ាសេន* វិញតែប៉ុននោះ។ មើលមានអីងាយជាងនេះទៅទៀតនោះ ? *យូគីម៉ាស៊ុ* ប្រែថាខ្ញុំទៅតែអាចជា You, he, she, it, we ទៅ រឺ នឹងទៅ រឺ ទៅហើយក៏តែបាន។ នាមទៀតក៏មិនបាច់ផ្លាស់ប្តូរដែរទោះជាឯកវចនៈ រឺពហុវចនៈក្តី។ *ឈូម៉ា* គឺប្រពន្ធ រឺ ប្រពន្ធទាំងឡាយក៏តែបាន។ ងាយណាស់។

- បើអញ្ចឹង ថាទៅមើលតើ *យូគីម៉ាស៊ុ* ខ្ញុំទៅ វាខុសគ្នាយ៉ាងម៉េចនឹង *យូគីម៉ាស៊ុ* ដែលចង់មានន័យថា ពួកគេទៅហើយ ?

- តាមរយៈការលើកដាក់សំលេង *អាន់ជីន-សាន*។

- តែស្តាប់ទៅលឺដូចតែគ្នាហ៊ឹង។

- *អាន់ជីន-សាន* នេះពីព្រោះលោកគិតតាមភាសារបស់លោក។ ដើម្បីយល់ភាសាជប៉ុនលោកត្រូវគិតតាមជប៉ុន ។ សូមលោកកុំភ្លេចថាភាសាជប៉ុនជាភាសាអានន្ត ។ ងាយទេ *អាន់ជីន-សាន*។ លោកគ្រាន់តែផ្លាស់ប្តូរបញ្ញត្តិស្តីពីលោកនេះចេញទៅ។ រៀនភាសាជប៉ុនគឺដូចជារៀនសិល្បៈថ្មីមួយដែលដាច់ចេញពីលោកនេះ.......គឺងាយទេ។

- អាច់នែ ! -*ក្លាក់ថន* រអ៊ូជាអង់គ្លេស ហើយគេក៏ដូចជាចូរទ្រូងទៅដែរ។

- ថាម៉េច ? លោកថាម៉េចអំបាញ់មិញ ?

- អត់អីទេ។ តែអ្វីដែលអ្នកស្រីនិយាយនេះដូចគ្មានន័យអីសោះតែម្តង។

- រៀនសរសេរទៅអញ្ចឹង។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំទៅមិនរួចទេ ហើយវាស៊ីពេលច្រើនផង ។មើលទៅមិនដឹងចង់ថាម៉េច ។

- ស្តាប់ខ្ញុំ *អាន់ជីន-សាន* តាមពិតទៅនេះជាគំនូរដ៏សាមញ្ញប៉ុននោះទេតើ ។ ពួកចិន ឆ្លាតណាស់ ។ យើងបានខ្ចីអក្សរពួកគេកាលពីមួយពាន់ឆ្នាំមុន ។ មើលអក្សរនេះនែ៎ នេះជានិមិត្ត សញ្ញាមានន័យថាជ្រូក ។

- អត់ដូចជ្រូកផង ។

- ពីមុនដូច *អាន់ជីន-សាន*។ ចាំខ្ញុំបង្ហាញលោក ។ នេះនែ៎ ។ អីលូវនេះខ្ញុំដាក់និមិត្ត សញ្ញា " ដំបូល " នៅពីលើនិមិត្តសញ្ញា " ជ្រូក " ។ ដល់អញ្ចឹងតើលោកបានជាអីទៅ ?

- បានជ្រូក និង ដំបូល ។

- ចាស ដឹងហើយ ។ តែតើនេះមានន័យថាម៉េច ? សញ្ញាថ្មីហ្នឹង ណា៎ ?

- ខ្ញុំអត់ដឹងដែរ ។

- មានន័យថា "ផ្ទះ " ។ កាលពីជំនាន់ដើម ពួកចិនគិតថាមានជ្រូកក្រោមដំបូលនោះ គឺផ្ទះហើយ ។ពួកចិនមិនមែនកាន់ពុទ្ធសាសនាទេ ។ពួកនោះទទួលទានសាច់ដោយហេតុនេះចំពោះ ពួកគេ ចំពោះពួកកសិករ ជ្រូកគឺជាទ្រព្យធនគេហើយ១ហ្នឹងគឺជាផ្ទះដ៏ល្អបំផុតរបស់គេហើយ ។

- តែតើសំនៀងយ៉ាងម៉េចទៅ ?

- នេះអាស្រ័យតែលោកជាជាតិចិន រឺ ជាតិជប៉ុន ។

- *អ្ហូ* !

- ពិតហើយ គឺ *អ្ហូ -ម៉ារីក្ហូ* សើចហើយបន្ត -ហើយនេះគឺអក្សរមួយទៀត ។ នេះជា និមិត្តសញ្ញា " ដំបូល " និមិត្តសញ្ញា " ជ្រូក" និង និមិត្តសញ្ញា " ស្រី " ។ " ដំបូល " មាន "ជ្រូក" ពីរ នៅពីក្រោមមានន័យថា "ការរីករាយក្នុងចិត្ត" ។ "ដំបូល"មានស្រីពីរនៅពីក្រោមមានន័យ ថា " ឈ្លោះគ្នា " ។ *នេ*?

- ពិតជាអញ្ចឹងហើយ !

- ពិតមែនហើយ ។ ពួកចិន១ល្ងង់ច្រើនរឿងណាស់ ហើយស្រីចិនមិនចេះហាត់រៀនដូច ពួកស្រីយើងនៅឯនេះទេ ។ នៅផ្ទះលោកគ្មានរឿងឈ្លោះគ្នាទេ មែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

គឺរឿងនេះហើយដែល *ប្លាក់ថន* ចង់ប្រាប់ទៅ *ស៊ូរ៉ូ* ថាគេរវល់គិតនៅក្នុងថ្ងៃទីដប់ពីរនៃការរស់រានមានជីវិតជាថ្មីរបស់គេវិញនោះ ។ ទេ គឺគ្មានជំលោះនៅក្នុងផ្ទះនេះមែន ។ តែនេះក៏មិនមែនជាទ្រទ់សុខសាន្តរបស់គេក៏ទេដែរ ។ *កូជីកូ* គឺគ្រាន់តែជាអ្នកមើលថែផ្ទះដ៏ជាទីទុកចិត្តម្នាក់តែប៉ុននោះ ហើយល្ងាចនេះពេលគេចូលសំរាន្ត នាងនឹងអង្គុយលុតជង្គង់យ៉ាងអត់ធ្មត់និងដោយគ្មានបង្ហាញអារម្មណ៍អ្វីទាំងអស់នៅក្បែរគេ ។ នាងនឹងស្លៀកគីម៉ូណូពេលរាត្រីរបស់នាងដែលប្រហាក់ប្រហែលនឹងគីម៉ូណូពេលថ្ងៃរបស់នាងដែរ គ្រាន់តែមានលក្ខណៈទន់ជាងនិងមានខ្សែចងចង្កេះធូររលុងជាងតែប៉ុននោះ ។ រួចគេនឹងនិយាយទៅកាន់នាងថា:

- អរគុណនាងណាស់ ។ រាត្រីសួស្តី ។

ហើយនាងនឹងលំអោនគោរពរួចចេញទៅបន្ទប់នាង ដែលនៅរបៀងទល់មុខជាប់នឹងបន្ទប់ *ម៉ារីកូ* យ៉ាងស្ងៀមស្ងាត់ ឯខ្លួនគេនឹងចូលទៅក្នុងមុងធ្វើពីសូត្រយ៉ាងទន់ល្មើយ ដែលតាំងពីមុនមកដល់ទីនេះ គេមិនដែលស្គាល់មុងថាយ៉ាងម៉េចទេតែប៉ុននោះ ហើយគេនឹងប្រះខ្លួនយ៉ាងរីករាយ ព្រមទាំងត្រងត្រាប់សំលេងសត្វល្អិតក្នុងរាត្រីកាលទន្ទឹមនឹងគិតពិចារណាពីរឿង *សំពៅខ្មៅ* ហើយនឹងសារសំខាន់នៃសំពៅនេះចំពោះប្រទេសជប៉ុន ។

គ្មានពួកប៉ិកទុយកាល់ គឺគ្មានពាណិជ្ជកម្មជាមួយប្រទេសចិន ។ ហើយក៏គ្មានសូត្រសំរាប់ខោអាវ និងស្បៃមុងដែរ ។ សូម្បីតែនៅពេលនេះគ្រាន់តែជារដូវចាប់ផ្តើមសំនើមផង *ប្លាក់ថន* អាចយល់បានពីតំលៃរបស់ទាំងនេះបានហើយ ។

នៅពេលយប់ទៀតសោត បើសិនជាគេតេងបំរះព្រួសប្រាស់ អ្នកបំរើនឹងបើកទ្វារស្វូភ្លាមខ្លាចក្រែងគេត្រូវការអ្វី ។ មានម្តងនោះដោយគេស្តាប់ភាសាជប៉ុនមិនបាន គេបានបណ្តេញអ្នកបំរើអោយចេញទៅវិញចំនែកខ្លួនគេក៏ងើបទៅអង្គុយមើលព្រះច័ន្ទនៅឯសួនច្បារ ។ តែមួយភ្លែតប៉ុននោះ *កូជីកូ* បានចេញមកទាំងសំពីងសំពោង និង យ៉ាងសស្លើតសស្លក់មកអង្គុយយ៉ាងស្ងៀមស្ងាត់នៅពីក្រោយខ្នងគេ :

- តើលោកម្ចាស់ត្រូវការអ្វីទេ ?

- អត់ទេ សូមអរគុណហើយ ។ នាងទៅគេងវិញទៅ ។



www.budinst.gov.kh www.elibraryofcambodia.org

នាងនិយាយតបមកវិញ តែគេស្តាប់មិនយល់សោះ ។ គេក៏ធ្វើសញ្ញាអោយនាងត្រលប់ទៅវិញម្តងទៀតដែលនាំអោយ *ភូជីកូ* និយាយយ៉ាងមុត១ ទៅកាន់អ្នកបំរើ ។ បន្តិចក្រោយមក *ម៉ារីកូ* ក៏មកដល់ ។

- លោកអត់អីទេរឺ *អាន់ជីន-សាន* ?

- បាទ ខ្ញុំអត់មានអីទេ តែមិនដឹងហេតុអីបានជាពួកនាងខ្វល់ខ្វាយម្ល៉េះ ? ព្រះអើ្ហយ ! ខ្ញុំគ្រាន់តែចង់មកអង្គុយមើលលោកខែទេតើ ។ ព្រោះខ្ញុំដេកមិនលក់ ។ ខ្ញុំចង់អង្គុយយកខ្យល់បន្តិច ។

*ភូជីកូ* និយាយដាច់១ បង្ហាញនូវការលំបាកចិត្តចំពោះសំដីមួម៉ៅរបស់ *ប្លាក់ថន*។

- នាងនិយាយថាលោកបានបញ្ជាអោយនាងទៅគេងវិញដែរ តែនាងចង់ជំរាបលោកអោយលោកដឹងថាតាមប្រពៃណីរបស់ពួកយើង មិនអាចប្រពន្ធ រឺ កំនាន់ចូលគេងមុនប្តីរបស់ខ្លួនទេ ។ គ្រាន់តែប៉ុណ្ណឹងទេ *អាន់ជីន-សាន*។

- បើអញ្ចឹង *ភូជីកូ* គួរប្តូរប្រពៃណីនាងទៅ ព្រោះខ្ញុំឧស្សាហ៍ក្រោកយប់ណាស់ ។ នេះជាទំលាប់ដោយធ្លាប់នៅតែលើសមុទ្ទ ដល់មកដល់លើគោក ខ្ញុំដេកតិចណាស់ ។

- ចាស *អាន់ជីន-សាន*។

ក្រោយពីនាងពន្យល់ចប់ហើយ នារីទាំងពីរក៏ត្រលប់ទៅវិញទៅ ។ តែ *ប្លាក់ថន* ដឹងយ៉ាងច្បាស់ណាស់ថា *ភូជីកូ* នឹងមិនត្រលប់ទៅគេងវិញឡើយ ហើយនឹងរង់ចាំរហូតគេចូលគេងជាមុនសិន ។ ទោះជាគេចូលផ្ទះធ្វើរណាក៏ដោយ នាងតែងនៅរង់ចាំគេរហូត ។ នៅយប់ខ្លះគេក្រោកចេញទៅដើរនៅឯមាត់ច្រាំងតែម្នាក់ឯង ។ ថ្វីបើគេបញ្ជាក់ហើយបញ្ជាក់ទៀតថាគេចង់នៅតែម្នាក់ឯងក្តីក៏គេដឹងថាមានមនុស្សដើរតាមមើលរូបគេជានិច្ច ។ មិនមែនដោយអ្នកទាំងនោះខ្លាចក្រែងគេរត់នោះទេ តែគឺជាប្រពៃណីរបស់ពួកគេដែលមិនត្រូវដើរចោលអ្នកធំនោះឡើយ ។ ហើយនៅ *អាន់ជិរ* នេះគេគឺជាអ្នកធំម្នាក់ ។

យូរ១ទៅរូបគេបានទទួលយកនូវវត្តមានរបស់នាង ។ ដូចដែល *ម៉ារីកូ* បាននិយាយពីដំបូងទីអោយ " ចាត់ទុកនាងដូចជាជុំផ្ទះ ជាទ្វារ រឺជាជញ្ជាំងទៅចុះ ។ នាងមានភារកិច្ចត្រូវបំរើ



www.budinst.gov.kh www.elibraryofcambodia.org

លោក ៉ អញ៉ែង ។

តែជាមួយ *ម៉ារីកូ* វិញ គឺមិនដូចគ្នាទេ។

គេសប្បាយចិត្តណាស់ដែលនាងស្ថិតនៅទីនេះ ។ បើសិនជាគ្មានវត្តមាននាងទេ គេច្បាស់ជាមិនចាប់ផ្តើមការបង្ហឹកបង្រៀននេះទេ នោះកុំទៅនិយាយដល់ការពន្យល់ពីភាពស្មុគស្មាញនៃយុទ្ធសាស្ត្រផង។ គេតែងជូនពរដល់បព្វជិត *ដូមិញកូ* និង *អាល់បាទ កាវ៉ាដុក* ហើយនឹងអ្នកឯទៀតៗដែលបានជួយបង្រៀនគេ។

អញមិនដែលនឹកស្មានថា សមរភូមិប្រយុទ្ធអាចប្រើប្រាស់វាដើម្បីជាផលប្រយោជន៍ល្អសោះតែម្តងហើយ -គេគិតនៅក្នុងចិត្ត។ មានម្តងនៅពេលដែលសំពៅគេដឹករោមឡែនពីអង់គ្លេសទៅ *អង់វ៉ែ* នោះ ពួកអេស្ប៉ាញបានវាយសង្គ្រប់ទៅលើទីក្រុងហើយបុរសទាំងអស់ត្រូវតែចេញទៅប្រយុទ្ធទៅតាមគ្រឿងទស់ទ័ព ( Barricades ) និង តាមខ្លងទំនប់នានា។ ការវាយឆ្មក់នេះ បានវាយបំបាក់កងទ័ពរបស់អេស្ប៉ាញបានដោយកំលាំងអាវុធខ្លាំងក្លាផង ដោយការចល័តទ័ពរហ័សរហួនជាងផង។ នោះគឺជាលើកទីមួយហើយដែល *ប្លាក់ថន* បានឃើញលោក *វីល្យ៉ាម* យុវននៃតំបន់អូរ៉ង់ ដែលបានចល័តកងទ័ពដូចគេចល័តកូនអុក។ ជូនទ័ពចល័តទៅមុខជូនធ្វើជាដកថយហាក់ដូចជាតក់ស្លុតដើម្បីមកផ្តុំទ័ពវាយសំរុកសាជាថ្មី ទំលាយទ័ពដែលធ្លាប់ល្បីថាមិនចេះចាញ់នេះដោយទុកអោយនៅដេកត្រដរខ្យល់ស្រែកទ្រហោអឹងអាប់ លាយឡំនឹងក្លិនឆ្អាបនៃឈាម ក្លិនរំសេវ ក្លិនទឹកនោម ក្លិនសេះ និង ក្លិនលាមក នៅពេញច្រមុះ ទន្ទឹមនឹងភាពសប្បាយក្រពុលមុខក្នុងការកាប់សំលាប់ និង អារម្មណ៍ថាដៃដែលកំពុងធ្វើសកម្មភាពជាដៃយុវជនទើបតែពេញវ័យម្ភៃឆ្នាំនោះ បានរុករានទន្ទ្រានពេញខួរក្បាលរបស់គេ។

- ព្រះអើយ។ សប្បាយម្ល៉េះទេដែលបានឈ្នះគេ -*ប្លាក់ថន* និយាយភ្លាត់មាត់ទាំងនៅកំពុងត្រាំទឹក។

- លោកម្ចាស់ ? -*ស្ទីវ* ពោលសួរ។

- អត់អីទេ -*ប្លាក់ថន* តបជាភាសាជប៉ុន -ខ្ញុំរបូតមាត់.......ខ្ញុំកំពុងគិត។ គិតលឺៗ ប៉ុណ្ណឹងទេ។



www.budinst.gov.kh www.elibraryofcambodia.org

- បាទ ខ្ញុំបាទយល់ហើយ ។ សូមលោកម្ចាស់អភ័យទោសផង ទាន ។

*ក្វាក់ថន* បណ្ដោយអោយអារម្មណ៏របស់គេអណ្ដែតត្រសែតបន្តទៅទៀត ។

*ម៉ារីកូ*។ ពិតហើយ នាងពិតជាមានតំលៃស្មានមិនបានមែន ។

តាំងពីយប់ដំបូងនៃការហៀបសំលាប់ខ្លួនគេមក គ្មានរឿងអ្វីដែលត្រូវបានលើកទៀតដែរ ។ តើមានរឿងអ្វីដែលត្រូវនិយាយទៀតនោះ ?

អញសប្បាយចិត្តណាស់ដែលមានការច្រើនដែលត្រូវធ្វើ -គេគិតនៅក្នុងចិត្ត ។ ច្រើនរហូតដល់គ្មានពេលឯណាដើម្បីគិតនោះឡើយ លើកលែងតែនៅក្នុងពេលត្រាំទឹកប៉ុន្មាននាទីតែប៉ុននោះ ។ អញមិនដែលមានពេលគ្រប់គ្រាន់ដើម្បីនឹងធ្វើសព្វធ្វើគ្រប់នោះឡើយ ។ ត្រូវទទួលបញ្ហាអោយផ្ដោតអារម្មណ៏តែលើការរ៉ឺកហាត់និងការបង្រៀន គឺមិនមែនផ្ដោតលើការរៀននោះឡើយ តែអញចង់រៀន ប្រឹងប្រែងរៀន ត្រូវការរៀន ដើម្បីបំពេញពាក្យសន្យាជាមួយ *យ៉ាប៊ូ*។ មិនដែលមានម៉ោងពេលគ្រប់គ្រាន់សោះតែម្ដង ។ រាល់ពេលកំលាំងទាំងប៉ុន្មានត្រូវបញ្ចេញអស់មកដល់ផ្ទះបាក់កំលាំងលក់ភ្លាម ហើយត្រូវក្រោកពីព្រលឹមប្រញាប់ប្រញាល់បំផាយសេះអោយទៅដល់ខ្លង់រាប ។ នៅទីនោះត្រូវបង្វឹកបង្ហាត់ពេញមួយព្រឹក ហើយបន្ទាប់មកទទួលទានអាហារកំរនឹងបានគ្រប់គ្រាន់ ហើយមិនដែលមានសាច់សត្វសោះតែម្ដង ។ រួចតាំងពីពេលរសៀលទៅរហូតដល់ពេលព្រលប់ -ជួនកាលស្ទើរដល់អាធ្រាតទៀតផង - ត្រូវជួបប្រជុំជាមួយ *យ៉ាប៊ូ, អូមីអ៊ិកូរ៉ាជី, ណាកា, ស៊ូគីម៉ូតូ* និង មេទ័ពមួយចំនួនតូចទៀត ដើម្បីឧទ្ទេសនាមពីរឿងសង្គ្រាមនិងឆ្លើយសំនួរទាក់ទិននឹងរឿងសង្គ្រាម ។ ពីរឿងថាតើដឹកនាំសង្គ្រាមយ៉ាងម៉េច តើសង្គ្រាមពួកអ្នកចុងស្រុកយ៉ាងម៉េច ជប៉ុនយ៉ាងម៉េច ។ ពួកស្មៀនកត់ត្រារហូត ។ កត់ ច្រើនមែនទែន ។

ជួនកាលជួប *យ៉ាប៊ូ* តែពីរនាក់តទល់តែប៉ុននោះ ។

តែទោះជាយ៉ាងនេះក្ដី ក៏ *ម៉ារីកូ* នៅជាមួយគេជានិច្ច ។ នាងជាផ្នែកមួយរបស់គេ ។ នាងនិយាយអោយគេ ។ និងអោយ *យ៉ាប៊ូ* ផងដែរ ។ អីលូវនេះ *ម៉ារីកូ* មានអាកប្បកិរិយាផ្សេងជាមួយគេហើយ ពោលគឺគេមិនមែនជាមនុស្សចំលែកសំរាប់រូបនាងទៀតទេ ។

ថ្ងៃខ្លះទៀត ពួកស្មៀនបានអានឡើងវិញនូវកំនត់ត្រាដើម្បីផ្ទៀងផ្ទាត់យ៉ាងម៉ត់ចត់



www.budinst.gov.kh www.elibraryofcambodia.org

ហើយកែ ពិនិត្យសាចុះសាឡើងរហូតដល់ពេលនេះ គឺដប់ពីរថ្ងៃ និងរាប់រយម៉ោងនៃការពន្យល់យ៉ាងល់អិត និង យ៉ាងខ្សោះទឹកមាត់ ទើបក្បួនសង្គ្រាមមួយត្រូវបានចងក្រងឡើង។ ក្បួនមួយយ៉ាងប្រាកដប្រជា។ និងយ៉ាងផ្តាច់ជីវិត។

ផ្តាច់ជីវិតអ្នកណា ? មិនមែនចំពោះអង់គ្លេសយើង រឺ ពួកហូឡង់ដែលនឹងមកទីនេះដោយសន្តិភាព និងក្នុងឋានៈតែជាអ្នកជំនួញនោះទេ។ នេះគឺផ្តាច់ជីវិតចំពោះសត្រូវរបស់ *យ៉ាប៊ូ* សត្រូវរបស់ *តូរ៉ាណាកា* និងសត្រូវយើងគឺពួកប៉ិកទុយកាល់ និងពួកអេស្ប៉ាញនៅពេលណាដែលពួកវាចង់ឈ្មានពានត្រួតត្រាជប៉ុនតែប៉ុននោះ ។ ដូចដែលពួកវាធ្លាប់ឈ្លានពាននៅគ្រប់កន្លែងឯទៀតដែរអញ្ចឹង។ គឺនៅតែគ្រប់ដែនដីដែលទើបរកឃើញថ្មីៗហ្នឹង។ ដំបូងពួកបព្វជិតមក រួចបន្ទាប់មកពួកកុងគីស្តាឌ័រ។

តែកុំសង្ស័យមកន្លែងនេះអោយសោះ អាវ៉ា -*ប្លាក់ថន* គិតទាំងក្នុងអារម្មណ៍ត្រេកអាលរីករាយ។ កុំសង្ស័យមកន្លែងនេះអោយសោះ។ ក្បួនសង្គ្រាមពិតជាដ៏សែនផ្តាច់ជីវិត ហើយបានបង្ការរឿងនេះជាស្រេច។ ក្នុងប៉ុន្មានឆ្នាំទៀតពេលដែលក្បួននេះ ត្រូវបានផ្សព្វផ្សាយទូលំទូលាយហើយនោះ កុំសង្ស័យថាប្រាមប្រាបប្រទេសនេះបានអោយសោះ។

- *អាន់ជីន-សាន* ? -*ម៉ារីកូ* លំអោនខ្លួនគោរពគេ -*យ៉ាប៊ូ-កូ វ៉ាគីដេន ណូ គូស៊ីសេគីអូ កូន យ៉ា វ៉ា ហ៊ីតសូ តូ សេនូ តូ អូសេរ៉ារើ អាន់ជីន-សាន*។

ពាក្យទាំងប៉ុន្មានបានផ្តុំគ្នាឃឹតៗនៅក្នុងខួរក្បាលរបស់គេ : លោកម្ចាស់ *យ៉ាប៊ូ* មិនបានអោយលោកទៅជួបនៅវេលាយប់នេះទេ។ គេតបទាំងសប្បាយរីករាយទៅវិញ :

- *អ៊ីជី-បាន*។ *ដូម៉ូ*។

- *កូមេន ណាសៃ អាន់ជីន-សាន*។ *អាណាតាវ៉ា*........

*ប្លាក់ថន* និយាយកាត់នាងភ្លាម។ កំដៅទឹកហាក់ដូចជាបឺតយកអស់នូវថាមពលរបស់គេ :

- ពិតហើយ *ម៉ារីកូ-សាន*។ ខ្ញុំដឹងថាខ្ញុំត្រូវនិយាយក្នុងបែបផ្សេងដែរ តែពេលនេះខ្ញុំមិនចង់និយាយភាសាជប៉ុនទៀតទេ។មិនចង់និយាយយប់នេះតែម្តង។ អីលូវនេះខ្ញុំមានអារម្មណ៍



www.budinst.gov.kh www.elibraryofcambodia.org

ដូចសិស្សសាលាដែលបានសំរាករៀនក្នុងពេលឈប់ ពេលល្ងាអែលយ៉ាងដូចនោះដែរ ។ តើអ្នកស្រីដឹងទេ នេះគឺជាលើកទីមួយហើយដែលខ្ញុំមានម៉ោងទំនេរ តាំងពីខ្ញុំមកដល់ស្រុកនេះ ?

- ចាស ខ្ញុំដឹងហើយ -*ម៉ារីក្វ* តបទាំងក្នុងភាពញញឹមហួសចិត្ត -ហើយតើលោកនាយបញ្ជាការ -តៃកុង *បាឡាក់ថន* ដឹងទេថានេះជាលើកទីមួយហើយដែលខ្ញុំមានម៉ោងទំនេរតាំងពីខ្ញុំមកដល់ទីនេះ ?

គេផ្ទុះសំនើចឡើង ។ នាងស្លៀកសំពត់មុជទឹកធ្វើពីក្រណាត់ក្រាស ។ កន្សែងមួយត្រូវបានរុំជុំវិញក្បាលនាងដើម្បីការពារសក់ ។ ជារៀងរាល់យប់ នៅពេលណាដែលគេចាប់ផ្ដើមធ្វើសរសៃ នាងតែងចូលមុជទឹក ជួនកាលម្នាក់ឯង ជួនកាលជាមួយ *ភូជីក្វ*។

*បាក់ថន* ងើបចេញពីអាងដោយនិយាយឡើងៈ

- អ្នក ! ដល់វេនអ្នកស្រីមុជម្ដងហើយ ។

- ទេ ខ្ញុំមិនរំខានលោកទេ ។

- បើអញ្ជើញមុជជាមួយគ្នាតែម្ដងទៅ ។ នោះពិតជាសប្បាយមែនទែន តែម្ដង ។

- អរគុណលោកហើយ ។ ចាំខ្ញុំជូតខ្លួនប្រាណហើយសិន ។

រួចនាងក៏ដោះសំពត់មុជទឹកចេញហើយក៏ទៅអង្គុយលើជើងម៉ាតូចមួយ ។ អ្នកបំរើចាប់ផ្ដើមជុសលាងសំអាតខ្លួនប្រាណនាង ។ *ស៊ូរ៉ូ* នៅរង់ចាំយ៉ាងអត់ធ្មត់ក្បែរតុធ្វើសរសៃ ។

នៅពេលដែលគេឃើញនាងស្រាតជាលើកដំបូងនាថ្ងៃដែលពួកគេហែលទឹកនោះ គេសែនញ្ញោចអារម្មណ៍ជាពន់ពេក ។ អីឡូវនេះ ភាពអាក្រាតរបស់នាង មិនបានមកប៉ះពាល់កាយវិញ្ញាណរបស់គេទេ ។ ការរស់នៅជិតគ្នាតាមបែបជប៉ុននៅក្នុងផ្ទះជប៉ុនដែលមានជញ្ជាំងក្រដាសគេធ្លាប់ឃើញនាងដោះសំពត់អាវ រឺស្លៀកតែបន្តិចបន្តួចជាច្រើនដងណាស់ទៅហើយ ។

- តើមានរឿងអីធម្មតាជាងនេះទៀត *អាន់ជីន-សាន* ? សពាង្គកាយគឺធម្មតា ការខុសប្លែកគ្នារវាងបុរសនឹងនារីគឺធម្មតា *នេ* ?

- ជាការពិត ប៉ុន្តែ អឺ..... គឺពួកយើងបានទទួលការអប់រំខុសពីនេះ ។

- ចាស ប៉ុន្តែនៅពេលនេះលោកនៅទីនេះ ហើយទំលាប់យើងគឺជាទំលាប់លោកហើយ



www.budinst.gov.kh www.elibraryofcambodia.org

ធម្មតាតិធម្មតា *ទេ* ? បន្តិចទៀតលោកនឹងចូលចិត្តត្រីនៅ និង សារាយសមុទ្រស្រស់ ហើយនៅពេលនោះលោកនឹងទៅជា *មហាតាម៉ូត្ត* ពិតប្រាកដហើយ ។

នៅពេលដែលខ្លួនប្រាណនាងត្រូវបានសំអាតហើយនោះនាងក៏ចុះទៅក្នុងអាងហើយក៏ទំរេតខ្លួនទល់មុខគ្នានឹង *ប្លាក់ថន* ដោយដកដង្ហើមយ៉ាងវែងសំដែងពីអារម្មណ៍សុខស្រួលរបស់ខ្លួន ។ បន្ទោងឈើឆ្កាងយោលតែកពោកនៅចន្លោះដើមទ្រូងនាង ។ *ប្លាក់ថន* សួរ :

- អ្នកស្រីធ្វើយ៉ាងម៉េចបានហ៊ឹង ?

- ថាម៉េច ?

- ទឹកក្តៅយ៉ាងនេះ ហេតុអ្វីក៏អ្នកស្រីចុះត្រាំបានភ្លាមអញ្ចឹង ?

- ខ្ញុំមិនដឹងដែរ *អាន់ជីន-សាន*។ ខ្ញុំគ្រាន់តែអោយគេបន្ថែមភ្លើងបង្កើនកំដៅទឹកថែមទៀតតែប៉ុននោះ ។ ចំពោះលោកវិញ *ភូជីក្ល* រមែងដាំទឹកដែលពួកយើងហៅថាអ៊ុណ្ណ១តែប៉ុននោះ ។

កំដៅទឹក ធ្វើអោយពួកគេមានអារម្មណ៍ស្រឹមទៅឆ្ងាយ ។ គេនៅបណ្តែតត្រាំខ្លួនក្នុងភាពស្រឹមស្រួលនេះដោយឥតនិយាយសាសងគ្នាមួយសន្ទុះ ។ យូរពេលក្រោយមក ទើបនាងចាប់ផ្តើមនិយាយ :

- យប់នេះ តើលោកចង់ធ្វើអ្វីទេ *អាន់ជីន-សាន* ?

- បើសិនជាពួកយើងនៅទីក្រុងឡុងវិញ ពួកយើងនឹង........

*ប្លាក់ថន* បញ្ឈប់ភ្លាម ។ ឈប់គិតពីរឿងពួកនោះទៀត -គេគិតនៅក្នុងចិត្ត ។ ទីក្រុងឡុងក៏អញ្ចឹងដែរ ។ រឿងទាំងនេះវាកន្លងផុតទៅហើយ ។ វាគ្មានទៀតទេ ។ មានតែនៅទីនេះទេដែលមានពិតប្រាកដមែន ។ *ម៉ារីកូ* តាមសំលឹងមើលទឹកមុខ *ប្លាក់ថន* ដោយសំគាល់ឃើញពីភាពប្រែប្រួលនេះ :

- បើសិន យ៉ាងម៉េច ?

- ពួកយើងនឹងទៅមើលល្ខោន - *ប្លាក់ថន* និយាយដោយប្រឹងទប់សង្កត់ចិត្តរបស់ខ្លួន- តើស្រុកនាងមានល្ខោនដែរទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- ចាស មាន *អាន់ជីន-សាន*។ល្ខោនមានប្រជាប្រិយភាពណាស់នៅស្រុកយើង ។លោកម្ចាស់ *វ៉េគូ* ចូលចិត្តអោយពួកនេះសំដែងសំរាប់ជូនភ្ញៀវរបស់លោកកំសាន្តណាស់ ។ សូម្បីតែលោកម្ចាស់ *តូរ៉ាណាកា* ក៏ចូលចិត្តណាស់ដែរ ។ ហើយមានក្រុមល្ខោនចល័តសំរាប់លេងអោយប្រជាជនទូទៅកំសាន្តផងដែរ ។ តែខ្ញុំជឿថាល្ខោនពួកយើងមិនដូចល្ខោនរបស់លោកទេ ។ នៅស្រុកយើងខ្ញុំ តួសំដែងទាំងប្រុសទាំងស្រី សុទ្ធតែពាក់មុខ ។ ល្ខោនពួកយើងនេះគេហៅ " ណូ "គឺមានលាយភ្លេងផង របាំផង ហើយភាគច្រើនគឺសំដែងរឿងកំសត់ រឿងប្រវត្តិសាស្ត្រ ។ មានរឿងកំប្លែងខ្លះដែរ ។ តើលោកចង់មើលរឿងកំប្លែង រឺ រឿងទាក់ទិននឹងសាសនា ?

- ទេ យើងគួរទៅរោងល្ខោនឈ្មោះ " ភូគោល "( Globe Theater ) ហើយមើលរឿងដែលសរសេរដោយសេកស្ពៀ ( Shakespeare ) វិញ ព្រោះខ្ញុំចូលចិត្តគាត់ជាង បេន ជនសុន ( Ben jonson ) រឺ ម៉ាឡូវ (Marlowe )ទៅទៀត ។ ខ្ញុំបាននាំប្រពន្ធខ្ញុំទៅមើលរឿងរ៉ូម៉េអូ និង ជូលីយែត (Romeo and Juliet) ហើយនាងចូលចិត្តរឿងនេះសំបើមហើយ ។

រួច *ចាក់ជន* ពន្យល់សាច់រឿងនេះប្រាប់នាង ។

ចំពោះ *ម៉ារីកូ* ឈ្មោះទាំងនេះគឺមិនមានន័យថាម៉េចទាំងអស់ចំពោះនាង :

- នៅទីនេះពិតជារឿងមួយដែលគ្មានអ្នកណាគិតដល់ទេ ដែលកូនស្រីមិនស្តាប់ឪពុកខ្លួនបែបនេះ ។ តែរឿងនេះពិតជាកំសត់មែន *ទេ*? កំសត់ទាំងចំពោះយុវនារី ទាំងចំពោះ បុរស ។ នាងមានអាយុទើបតែដប់បីឆ្នាំ ? តើនារីស្រុកលោករៀបការពីក្មេង អញ្ចឹង រឺ ?

- ទេ ។ ជាទូទៅ ការអាយុដប់ប្រាំ រឺ ដប់ប្រាំមួយ ។ ប្រពន្ធខ្ញុំពេលរៀបការជាមួយខ្ញុំនាងមានអាយុដប់ប្រាំពីរឆ្នាំហើយ ។ អ្នកស្រីអាយុប៉ុន្មានហើយ ?

- ខ្ញុំទើបបានដប់ប្រាំឆ្នាំប៉ុននោះ *អាន់ជីន-សាន*។

ស្នាមទុក្ខសោកលេចចេញមួយភ្លែតនៅលើថ្ពាសនាង តែ *ចាក់ជន* ឥតបានសង្កេតទាន់ឡើយ ។ *ម៉ារីកូ* សួរបន្ត :

- រួចក្រោយពីមើលល្ខោនហើយ តើទៅណាទៀត ?

- ទៅទទួលទានអាហារ ។



www.budinst.gov.kh www.elibraryofcambodia.org

- តើលោកទទួលទានអីទៅ ?

- ខ្ញុំមិនត្រូវរំលឹកវាទេ -*ប្លាក់ថង* តបដោយលាយនឹងញញឹមខ្ចិលច្រអូស -ខ្ញុំនឹកមិនឃើញទេ។ យើងកំពុងនៅទីនេះហើយយើងទទួលទាននៅទីនេះ ហើយខ្ញុំចូលចិត្តត្រីឆៅ ហើយ *កាម៉ា*គឺ *កាម៉ា*។

*ប្លាក់ថង* ជ្រមុជខ្លួនជ្រៅទៅក្នុងអាងថែមទៀត ហើយបន្ត :

- *កាម៉ា* គឺជាពាក្យមួយធំធេងមែនទែន។ ហើយជាគំនិតមួយដ៏អស្ចារ្យណាស់ដែរ។ ការជួយរបស់អ្នកស្រីពិតជាធំធេងណាស់សំរាប់រូបខ្ញុំ *ម៉ារីកូ-សាន*។

- គឺជាការរីករាយណាស់ដែលខ្ញុំបានជួយបន្តិចបន្តួចដល់លោកនេះ។ យប់នេះ *ភូជីកូ* មានម្ហូបពិសេសសំរាប់លោកផង ណា៎ ។

- មែនអ្វី ?

- នាងទិញបាន....ខ្ញុំគិតថាអាណឹងលោកហៅវាថាមាន់ទោនោះឯង ។ជាសត្វស្លាបធំ។ អ្នកប្រមាញ់ដោយស្ទាំងម្នាក់ចាប់វាយកមកអោយនាង។

- មាន់ទោ ? លោកស្រីនិយាយមែនអ្វី ? *ហុនតូ* ?

- *ហុនតូ* -នាងតប -*ភូជីកូ* បានសូមអោយគេជួយរកអោយនាង។ នាងអោយខ្ញុំប្រាប់លោក ណា៎។

- ហើយចាត់ចែងចំអិនមាន់ណឹងយ៉ាងម៉េចទៅ ?

- ពលទាហានម្នាក់ធ្លាប់ឃើញពួកប៉ិកទុយកាល់ធ្វើមាន់ទោនេះហើយក៏បានប្រាប់ *ភូជីកូ-សាន*។ នាងសូមអោយលោកអត់ធ្មត់ខ្លះបើសិនជាមាន់នេះធ្វើមិនបានត្រឹមត្រូវ ។

- តែតើនាងធ្វើវាយ៉ាងម៉េច......តើមាន់ទោណឹងដណ្តាំស្លវាបែបម៉េច ?-*ប្លាក់ថង* កែសំដីដោយថាមានតែអ្នកបំរើទេដែលមានភារកិច្ចដាំស្ល និង លាងសំអាតនោះ។

- គេប្រាប់នាងថា ដំបូងអោយបោចរោមចេញអោយអស់ រួច.... រួចយកពោះវៀនពោះតាំងចេញ - *ម៉ារីកូ* ប្រឹងទប់ភាពរអើមរបស់នាង - បន្ទាប់មក រឺមួយយកសត្វនេះទៅកាត់ជាដុំៗហើយចៀនជាមួយប្រេង រឺមួយយកទៅស្ងោរជាមួយអំបិល និងគ្រឿងទេសផ្សេងៗ។ ជូន



www.budinst.gov.kh www.elibraryofcambodia.org

កាលគេយកវាទៅខ្ទប់ក្នុងកក់ហើយដុតវាតែម្តង ។ ពួកយើងគ្មានឡទេ *អាន់ជីន-សាន* ដោយហេតុនេះហើយប្រហែលជាយើងត្រូវចៀនមាន់ទោនោះហើយ ។

- ខ្ញុំពិតថាច្បាស់ជាលេខមួយហើយ -គេតបដោយជឿច្បាស់នៅក្នុងចិត្តថាមាន់នេះពិតជាលេបមិនចូលឡើយ ។

*ម៉ារីកូ* សើច :

- មានពេលខ្លះ លោកដូចជាងាយយល់ណាស់ *អាន់ជីន-សាន*។

- អ្នកស្រីមិនយល់ថាតើម្ហូបមានសារសំខាន់យ៉ាងម៉េចទេ ! អ្នកស្រីពិតជាយល់ត្រូវណាស់ ។ ខ្ញុំមិនគួរខ្វល់ខ្វាយពីរឿងហូបចុកបុកទំពារសោះ ។ តែខ្ញុំមិនអាចត្រួតត់លានបានទេ ។

- បន្តិចទៀតលោកនឹងអាចធ្វើបាន ។ លោកនឹងរៀនហូបទឹកតែពីក្នុងពែងទទេយ៉ាងម៉េចបានទៀតផង ។

- ថាម៉េច ?

- នេះមិនមែនជាទីកន្លែង រឺ ពេលវេលាដើម្បីពន្យល់ពីរឿងនេះទេ *អាន់ជីន-សាន*។ សំរាប់រឿងអញ្ចឹងៗលោកត្រូវតែមានស្មារតីវាងវៃ និង ភ្នែកថៃសទើបបាន ។ ពេលព្រលប់ រឺ ពេលព្រលឹម គឺជាការចាំបាច់ ។ ថ្ងៃណាមួយ ខ្ញុំនឹងបង្ហាញលោកថាតើធ្វើយ៉ាងម៉េច ព្រោះនេះជាគំរូនៃមុខងាររបស់លោក ។ ហ៊ឺ ចំជាស្រួលមែនដែលបានសំរាកក្នុងទីនេះ មែនទេ ?

*ប្លាក់ថន* លឺពួកអ្នកបំរើនៅឯក្រៅជញ្ជាំងកំពុងរុញភ្លើង ។ គេទ្រាំនឹងកំដៅភ្លើងរហូតទប់ទល់លែងរួចទើបរើបចេញពីក្នុងអាងដោយមាន *ស៊ូរ៉ូ* ជួយជាជំនួយផង ។ គេប្រះខ្លួនទាំងដង្កក់លើកន្ទ្រេងដ៏ក្រាសមួយ ។ ដៃរបស់តាចាស់ចាប់ផ្តើមច្នៃសរសៃភ្លាម ធ្វើអោយគេសែនស្រួលក្រៃលែង ។

- ក្នុងប៉ុន្មានថ្ងៃក្រោយនេះ លោកបានផ្លាស់ប្តូរច្រើនណាស់ *អាន់ជីន-សាន*។

- មែនអ្វី ?

- ចាស តាំងពីលោកចាប់កំនើតថ្មីមក.....ចាស ពិតមែន ។ ផ្លាស់ប្តូរច្រើន ។

គេប្រឹងរំលឹកឡើងវិញនូវយប់ដំបូងនោះតែគេចាំបានតិចតួចណាស់ ។ តែហោចណាស់



www.budinst.gov.kh www.elibraryofcambodia.org

ក៏គេចាំបានថាគេបានដើរមកដល់ផ្ទះដោយខ្លួនឯងដែរ។ *ភូជីកូ* និង ពួកអ្នកបំរើបានជួយគេចូលទទួលទានដំណេក ។ក្រោយពីការគេងដោយគ្មានយល់សប្តិអីទាំងអស់មួយយប់មកគេបានក្រោកពីព្រលឹមចេញទៅហែលទឹក រួចហើយគេនៅសំងួតខ្លួនក្រោមពន្លឺថ្ងៃទាំងក្នុងចិត្តអរគុណដល់ព្រះជាម្ចាស់ដែលបានផ្តល់កំលាំងចិត្តដល់រូបគេ និង ដែលអោយ *ម៉ារីកូ* ផ្តល់គំរុយដល់គេ។ បន្ទាប់មកពេលដែលដើរវិលត្រលប់មកភូមិវិញ គេបានជួបរាក់ទាក់ជាមួយអ្នកភូមិ ដោយក្នុងជំរៅចិត្តរបស់គេ១បានដឹងថាអ្នកទាំងនេះបានរួចពីបណ្តាសារបស់ *យ៉ាប៊ូ* ហើយ។ ពួកអ្នកទាំងនេះមានសេរីភាពឡើងវិញដូចរូបគេដែរហើយ ។

ហើយនៅពេលដែល *ម៉ារីកូ* មកដល់ គេបានអោយទៅហៅ *អូរ៉ា* មកជួប ។

- *ម៉ារីកូ-សាន* សូមអ្នកស្រីមេត្តាប្រាប់ *អូរ៉ា* ដូចតទៅនេះ : " លោកនិងខ្ញុំ មានបញ្ហា។ យើងរួមគ្នាដោះស្រាយវា។ ខ្ញុំចង់ចូលរៀនសាលាក្នុងភូមិនេះ។ ចង់រៀននិយាយជាមួយក្មេង១ "។

- ពួកគេអត់មានសាលារៀនទេ *អាន់ជីន-សាន*។

- តែមួយក៏គ្មានដែរ ?

- អត់មានទេ។*អូរ៉ា* ថានៅខាងលិច ប្រហែលប៉ុន្មានលីពីទីនេះមានវត្តមួយហើយពួកលោកសង្ឃអាចជួយបង្រៀនលោកអោយចេះអាន និង ចេះសរសេរបានបើលោកចង់។ ឯទីនេះវិញគ្រាន់តែជាភូមិមួយតែប៉ុននោះ *អាន់ជីន-សាន*។ ក្មេង១នៅទីនេះ រៀនតែរបៀបចាប់ត្រី ធ្វើមងសំនាញ់ រៀនដកស្ទូងតែប៉ុននោះ។ មានពេលតិចតួចណាស់សំរាប់ធ្វើអីផ្សេងទៀត លើកលែងតែអំនាន និងសំនេរតែប៉ុននោះ។ ហើយតាំងពីដើមរៀងមក គឺឳពុកម្តាយ រឺជីដូនជីតាដែលជាអ្នកបង្រៀនដោយផ្ទាល់ដៃតែម្តង ។

- បើអញ្ចឹងអោយខ្ញុំរៀនយ៉ាងម៉េចទៅដល់ពេលលោកស្រីចាកចេញទៅនោះ ?

- លោកម្ចាស់ *តូរ៉ាណាកា* នឹងបញ្ជូនសៀវភៅមកជូនលោក។

- អ្វីដែលខ្ញុំត្រូវការគឺលើសពីសៀវភៅទាំងនោះ។

- អ្វី១នឹងបានជាទីពេញចិត្តជាមិនខាន *អាន់ជីន-សាន*។



www.budinst.gov.kh www.elibraryofcambodia.org

- បាទ អាចដែរ តែសូមជំរាបលោកមេភូមិថារាល់ពេលដែលខ្ញុំនិយាយខុស គ្រប់ៗគ្នា គឺថាសូម្បីតែកូនក្មេងក្តី ត្រូវតែកែតំរូវខ្ញុំភ្លាម ។ ខ្ញុំបញ្ជាយ៉ាងណឹង ។

- គាត់ថាសូមអរគុណលោកហើយ *អាន់ជីន-សាន*។

- តើនៅទីនេះមានអ្នកណាចេះនិយាយភាសាប៉ត់ទុយកាល់ទេ ?

- គាត់ថាគ្មានទេ ។

- មានអ្នកណាចេះនៅក្បែរៗភូមិនេះទេ ?

- *អ៊ីយេ អាន់ជីន-សាន*។

- *ម៉ារីកូ-សាន* ខ្ញុំត្រូវការមានអ្នកណាម្នាក់នៅជាមួយខ្ញុំពេលអ្នកស្រីចាកចេញទៅនោះ ។

- ខ្ញុំនឹងជំរាប *យ៉ាប៊ូ-សាន* នូវអ្វីដែលលោកបានប្រាប់នេះ ។

- *មូរ៉ា-សាន* លោក......

- គាត់ថាលោកមិនត្រូវប្រើពាក្យ " *សាន* " សំរាប់គាត់ រឺ សំរាប់អ្នកភូមិណាម្នាក់ឡើយ ។ ពួកគេនៅក្រោមលោក ។ ប្រើពាក្យ " *សាន* " ចំពោះអ្នកទាំងនោះ រឺ ចំពោះអ្នកដែលនៅក្រោមយើង នោះគឺមិនត្រឹមត្រូវឡើយ ។

តាំងពីថ្ងៃដំបូងនោះមេ្ល៎ះ *ភូជីកូ* បានលំអោនខ្លួនគោរពគេដល់ដី ។

-*ភូជីកូ-សាន* សូមស្វាគមន៍លោកដែលបានមកដល់ផ្ទះ *អាន់ជីន-សាន*។ នាងនិយាយថាលោកបានផ្តល់កិត្តិយសយ៉ាងធំធេងដល់នាង ហើយនាងសូមលោកអភ័យទោសចំពោះភាពមិនសមរម្យរបស់នាងកាលនៅលើទូកធំ ។នាងមានកិត្តិយសណាស់ដែលបានក្លាយជាកំនាន់ និងជាមេផ្ទះរបស់លោក ។ នាងសួរថាបើសិនជាលោកនៅបន្តកាន់ដាវទាំងនេះទៅទៀតមែននោះនាងនឹងសែនសប្បាយចិត្តជាពន់ពេក ។ ដាវទាំងនេះជារបស់ឪពុកនាង តែលោកបានធ្វើមរណកាលទៅហើយៗនាងឥតបានប្រគល់ដាវទាំងនេះទៅប្តីនាងទេ ដោយថាប្តីនាងមានដាវផ្ទាល់ខ្លួនរួចទៅហើយ ។

- សូមអរគុណនាង ហើយប្រាប់នាងវិញផងថា ខ្ញុំមានកិត្តិយសណាស់ដែលបាននាងជា



www.budinst.gov.kh www.elibraryofcambodia.org

កំនាន់ -*ប្លាក់ថន* តប ។

*ម៉ារីកូ* ក៏លំអោនខ្លួនគោរពដែរ ។ គោរពជាផ្លូវការ :

- អីលូវនេះ លោកមានជីវិតថ្មីមួយផ្សេងទៀតហើយ *អាន់ជីន-សាន*។ ពួកយើងសឹងមើលលោកក្នុងក្រសែភ្នែកមួយថ្មីផ្សេងហើយ ។ លោកបានបើកភ្នែករបស់ខ្ញុំដែរ ។ ពីមុនចំពោះខ្ញុំលោកគ្រាន់តែជាមនុស្សចុងស្រុកម្នាក់ប៉ុននោះ ។ សូមលោកអធ្យាស្រ័យចំពោះភាពល្ងាក់ល្ងើរបស់ខ្ញុំផង ។ អ្វីដែលលោកបានធ្វើកន្លងមកនេះបានបង្ហាញថាលោកគឺជាសាមូរ៉ៃម្នាក់ ។ សូមលោកអធ្យាស្រ័យចំពោះអាកប្បកិរិយាមិនសមរម្យរបស់ខ្ញុំកាលពីពេលមុននេះផង ។

ថ្ងៃនោះគេឡើងអឿសំបើមតែម្តង ។ ប៉ុន្តែការធ្វើឃាតរិះតែនឹងស្លាប់ខ្លួនឯងនេះបានផ្លាស់ប្តូរគេច្រើនជាងអ្វីដែលគេស្មានទៅទៀត ហើយទង្វើនេះបានធ្វើអោយគេញាក់សាច់ជាវៀងរហូត ។

- នេះគឺជាជីវិតទីប្រាំបួនរបស់អញហើយ ( * ) ។ ជាជីវិតចុងក្រោយហើយ ។

ប្លាក់ថនលាន់មាត់ខ្លាំងៗ។ម្រាមដៃរបស់ *ស៊ូរ៉ៃ* នៅទ្រឹងមួយរំពេច ។ *ម៉ារីកូ* សួរឡើង :

- ថាម៉េច ? តើលោកនិយាយថាម៉េច *អាន់ជីន-សាន* ? ។

- អត់ទេ ។ អត់មានថាម៉េចទេ -គេតបទាំងសោប់រសល់នៅក្នុងចិត្ត ។

*ស៊ូរ៉ៃ* សួរម្តង :

- ខ្ញុំធ្វើអោយលោកម្ចាស់ឈឺ រឺ ?

- ទេ ។

*ស៊ូរ៉ៃ* និយាយមួយប្រាវតែគេស្តាប់មិនទាន់សោះ ។ គេក៏សួរឡើង :

- *ដូស្ទ* ?

---

*( * ) តាមជំនឿរបស់ជនជាតិអឺរ៉ុប គេថាឆ្មាមិនងាយស្លាប់ផ្តាស់ទេ ព្រោះឆ្មាមានជីវិតដល់ទៅប្រាំបួន ។ ទាល់តែស្លាប់ប្រាំបួនដងទើបឆ្មាស្លាប់ជាវៀងរហូត ។*



www.budinst.gov.kh www.elibraryofcambodia.org

- គាត់ថាគាត់ចង់ធ្វើសរសៃនៅថ្ពែកខ្នងវិញម្តង -*ម៉ារីកូ* តបដោយហាក់ស្ថិតនៅឯទីឆ្ងាយ ។

*ប្លាក់ថន* ដេកផ្កាប់មុខម្តងដោយប្រឹងទន្ទេញពាក្យជប៉ុនអំបាញ់មិញនេះ តែគេក៏ភ្លេចវាវិញមទៅដែរ ។ គេនៅអាចមើលនាងឃើញនៅឡើយទោះជាមានចំហាយអ័ព្ទយ៉ាងណាក្តី ។ នាងដកដង្ហើមវែង១ ក្បាលនាងផ្អែកទៅក្រោយបន្តិច សាច់នាងឡើងក្រហមព្រឿង ១ ។

តើនាងធ្វើយ៉ាងម៉េចទើបអាចទ្រាំនឹងកំដៅយ៉ាងនេះបាន ហ្ន៎ ? គេឆ្ងល់ងសួរក្នុងចិត្ត ។ តាមអញស្មាននេះគឺអាស្រ័យការរ៉ឹកហាត់តែម្តង ។ រ៉ឹកហាត់តាំងពីតូចមក ។

ម្រាមដៃ *ស៊ូវ៉ា* ធ្វើអោយគេមានភាពសុខស្រួលជាពន់ពេក ។ គេលង់លក់អារម្មណ៍មួយកាំងទៅដែរ ។

អំបាញ់មិញនេះ អញកំពុងគិតពីអីអញ្ចេះ ?

អែងកំពុងគិតពីជីវិតទីប្រាំបួនរបស់អែង ពីជីវិតចុងក្រោយរបស់អែង ហើយអែងខ្លាចដោយរឿងជំនឿ ។ តែចំជាឆ្កួតមែន ដែលទៅជឿអបិយជំនឿពេលដែលអែងស្ថិតនៅលើទឹកដីពុកព្រះហើយនោះ ។ នៅទីនេះ រឿងវាផ្សេង ហើយវានឹងស្ថិតនៅបែបនេះជារៀងរហូត ។ ថ្ងៃនេះគឺជាអលជ្ជីហើយ ។

ស្អែក អាចមានរឿងច្រើនណាស់ដែលកើតឡើងបាន ។

ថ្ងៃនេះ អញត្រូវដើរតាមបញ្ញត្តិរបស់ពួកគេ ។

អញនឹងដើរតាម ។

***********

នារីអ្នកបំរើបានលើកម្ហូបដោយមានគ្របជិតចូលមក ។ នាងលើកម្ហូបខ្ពស់ផុតពីលើក្បាលទៅតាមប្រពៃណីដែលបង្ការមិនអោយដង្ហើមនាង ធ្វើអោយប្រលាក់ប្រលូសដល់ម្ហូបចំនីបាន ។ នាងលុតជង្គង់ហើយដាក់ម្ហូបយ៉ាងប្រុងប្រយ័ត្ននៅលើកូនតុដែលនៅពីមុខ *ប្លាក់ថន*។ លើ



www.budinst.gov.kh www.elibraryofcambodia.org

កូនតុទីមួយៗមានចានចង្កឹះ និង ចង្កឹះ ពែងសំរាប់ស្រា *សាកេ* កន្សែងដៃ ហើយនឹង ផ្កាវៀបជាកូនកញ្ចុំមួយផង។ *ភូជីកូ* និង *ម៉ារីកូ* នៅអង្គុយទល់មុខ *ប្លាក់ថន*។ សក់របស់នារីទាំងពីរមានដោតផ្កា និង សៀតក្រាសប្រាក់ទៀតផង។ គីម៉ូណូរបស់ *ភូជីកូ* មានរំលេចដោយរូបត្រីពណ៌បៃតងខ្ចីលើផ្ទៃពណ៌ស។ *អូប៊ី* ( ក្រណាត់ចងចង្កេះ ) នាងមានពណ៌ទឹកមាស។ *ម៉ារីកូ* ពាក់គីម៉ូណូខ្មៅលាយក្រហមរំលេចដោយរូបផ្កាស្មៅរឿងស្រាល ១ ។ *អូប៊ី* នាងពណ៌ទឹកមាសលាយទឹកប្រាក់។ ដូចសព្វដង អ្នកទាំងពីរលាបទឹកអប់ក្រអូបឈ្ងុយ។ ធូបត្រូវបានអុជដើម្បីបណ្ដេញសត្វល្អិតពេលរាត្រី អោយចេញទៅឆ្ងាយ។

ជាយូរពេលក្រែលមកហើយដែល *ប្លាក់ថន* បានរៀនពីរបៀបរៀបរីករបស់ខ្លួន។ គេដឹងថាបើគេបង្ហាញចេញនូវភាពមិនសប្បាយចិត្តណាមួយហើយ រាត្រីរបស់ពួកគេនឹងត្រូវកករល្អក់ខូចអស់ជាមិនខាន។ បើសិនជាគេអាចចាប់មាន់ទោបាន មានន័យថាក៏អាចមានល្បែងច្រើនផ្សេងទៀតដែរ។ គេមានកាំភ្លើង មានសេះ ពេលគឺគេអាចចេញទៅបរបាញ់ដោយខ្លួនឯងបានដែរបើសិនណាជាគេមានពេលនោះ។

*ភូជីកូ* ឈោងដៃទៅលើកគំរបម្ហូបឡើង។ សាច់ចៀនមានពណ៌ពងក្រលាត ហើយមើលទៅឃើញគួរអោយឆ្ងាញ់។ គ្រាន់តែធុំក្លិន *ប្លាក់ថន* ស្រក់ទឹកមាត់ប្រោកតែម្ដង។

គេយកចង្កឹះទៅចាប់យកសាច់យ៉ាងយឺតៗ ដោយខ្លាចធ្លាក់ហើយដាក់ចូលក្នុងមាត់ទំពារ។ សាច់នេះស្វិតហើយស្ងួតឥឡូវតែដោយគេអត់សាច់សត្វយូរមកហើយនោះ វាបែរជាមានជាតិមហាអស្ចារ្យតែម្ដង។ រួចគេដាក់មួយដុំទៀត។ គេដកដង្ហើមដោយភាពត្រអាល :

- *អ៊ីជី-បាន ! អ៊ីជី-បាន* ! ឱព្រះអង្គអើយ ព្រះអង្គ !

*ភូជីកូ* មុខឡើងក្រហម ។នាងក៏ចាក់ស្រា *សាកេ* ជូនទៅ *ប្លាក់ថន* ដើម្បីបិទបាំងទឹកមុខនាង។ *ម៉ារីកូ* នៅអង្គុយបក់ផ្លិត *ប្លាក់ថន* លើកពែងស្រាក្រេបទាល់តែអស់ រួចទើបយកសាច់មួយដុំទៀតមកទំពារហើយចាក់ស្រាមួយកែវទៀតលើកហុចទៅ *ភូជីកូ* ហើយដូចរាល់តែដងដែរនាងប្រកែកមិនទទួលយកឡើយ។ ប៉ុន្តែនៅក្នុងយប់នេះដោយ *ប្លាក់ថន* នៅតែចចេសនោះនាងក៏ទទួលយកមកទទួលទានអស់មួយពែងទោះជានាងឈ្លក់បន្តិចបន្តួចក្ដី។ *ម៉ារីកូ* ក៏យ៉ាងដូចនោះ



www.budinst.gov.kh www.elibraryofcambodia.org

ដែរទោះជានាងប្រកែកពីដំបូងទីក្តី ក៏នាងត្រូវតែទទួលទានតាមការទទូចរបស់ *ប្លាក់ថន* ទាល់តែបាន ។ រួចទើបគេវាយលុកមាន់ទោបន្តទៀតដោយប្រឹងលាក់ភាពរីករាយរបស់គេតាមការដែលអាចទៅរួច ។ នារីទាំងពីរលួកម្ហូបធ្វើអំពីត្រីនិងបន្លែដ៏តិចតួចរបស់ខ្លួនតែប៉ុន្មានម៉ាត់តែប៉ុណ្ណោះ តែនេះមិនបានអោយគេព្រួយបារម្ភនោះទេ ដោយគេដឹងថាជាទំលាប់នារីទទួលទានមុនរឺក្រោយបុរសដើម្បីក្នុងពេលបាយគេអាចប្រមូលផ្តុំការយកចិត្តទុកដាក់របស់គេ ទៅលើម្ចាស់ផ្ទះបានដោយពេញលេញ ។

*ប្លាក់ថន* ទទួលទានអស់មាន់ទោមួយបាយអស់បីចានហើយក្រេបស្រា*សាកេ* លាន់សូរគ្រូកដោយថាការក្រេបស្រាដោយអោយលាន់សូរនេះក៏ជាសុជីវធម៌មួយរបស់ជប៉ុនដែរ ។ នេះជាលើកទីមួយហើយក្នុងរយៈពេលប៉ុន្មានខែនេះដែលគេមានអារម្មណ៍ថាបានហូបឆ្អែត ។ មួយពេលបាយនេះ គេហូបស្រា *សាកេ* អស់ប្រាំមួយដប ឯ *ម៉ារីកូ* និង *ភូជីកូ* ទាំងពីរនាក់នេះហូបអស់ពីរដប ។ អីលូវនេះពួកគេឡើងមុខក្រហម សើចកក្អិក ហើយចូលដល់ដំណាក់កាលស្រវឹង១ហើយ ។

*ម៉ារីកូ* សើចក្នុងដើមកដោយទាំងយកដៃបាំងមាត់ផង :

- ខ្ញុំប្រាថ្នាពូកែហូបស្រាដូចលោកណាស់ *អាន់ជីន-សាន*។ ក្នុងចំនោមមនុស្សទាំងអស់ដែលខ្ញុំស្គាល់ មានតែលោកទេដែលពូកែហូបស្រាជាងគេ ។ ខ្ញុំហ៊ានភ្នាល់ថាលោកពិតជាពូកែហូបស្រាជាងគេម៉ាក្នុងតំបន់ *អ៊ីស៊ូ* នេះ ! បើសិនជាភ្នាល់គ្នាវិញ ខ្ញុំពិតជាបានលុយច្រើនជាមិនខានដោយចាក់លើលោកនោះ ។

- ក្រែងសាមូរ៉ៃមិនគាំទ្ររឿងល្បែងទេ អ្ហី ?

- ចាស ពិតហើយ ។ ពិតជាត្រឹមត្រូវមែន ។ ពួកគេមិនមែនជាឈ្មួញជួញដូរ រឺ ជាអ្នកស្រែទេ ។ តែមិនមែនសាមូរ៉ៃណាសុទ្ធតែខ្លាំងដូច១គ្នានោះទេ ហើយមួយចំនួនក៏.....ក៏ភ្នាល់ដូចពួកបិកខុយកាល់អញ្ចឹងដែរ ។

- តើស្រី១ចេះភ្នាល់ដែរ ?

- ចាស ច្រើនណាស់ ។ តែគេភ្នាល់ជាមួយស្រី១គ្នាគេហើយក្នុងចំនួនទឹកប្រាក់តែមួយ



www.budinst.gov.kh www.elibraryofcambodia.org

ចំនួនណាទេដើម្បីកុំអោយប្តី១នឹង !

នាងបកប្រែទាំងកក្អិកប្រាប់ទៅ *ភូជីកូ* ដែលកំពុងឡើងពណ៌ជាងនាងទៅទៀត ។

- កំនាន់របស់លោកសួរថាតើពួកអង់គ្លេសចេះលេងល្បែងភ្នាល់ដែរ រឺទេ ? តើលោកចូលចិត្តភ្នាល់ដែរ ?

- នេះគឺជាល្បែងកំសាន្តរបស់ជាតិយើងខ្ញុំតែម្តង

*ភូជីកូ* លូកមាត់ :

- បើអញ្ចឹងលោកមានពេលឯណាចិញ្ចឹមជីវិតរស់នៅផង ធ្វើសង្គ្រាមផង ហើយនឹងរួមដំណេកផងទៅ ?

- វាតែងតែមានពេលសំរាប់កិច្ចការអស់ទាំងហ្នឹងហើយ ។

ភ្នែកគេទាំងពីរបានទាក់គ្នាមួយរយៈដែរ ប៉ុន្តែ *ប្លាក់ថន* មិនអាចមើលឃើញអ្វី១ទាំងអស់នៅក្នុងក្រសែភ្នែកនាងក្រៅតែភាពសុភមង្គលតែប៉ុននោះ ។

*ម៉ារីកូ* អង្វរអោយ *ប្លាក់ថន* ច្រៀងចំរៀងដើរសមុទ្រដើម្បីអោយ *ភូជីកូ* ស្តាប់ ។ គេក៏ធ្វើតាមហើយនៅពេលដែលគេច្រៀងចប់ទាំងអស់គ្នាបាននាំគ្នាកោតសរសើរគេ ដោយថានេះជាលើកទីមួយហើយដែលគេបានស្តាប់អ្នកច្រៀងដ៏ពិរោះយ៉ាងនេះ ។

- មក៏ ញ៉ាំ *សាកេ* ទៀត !

- ទេ លោកមិនត្រូវចាក់ស្រាទេ *អាន់ជីន-សាន*។ នេះជាភារកិច្ចស្រី១ទេ ។ ក្រែងខ្ញុំបានជំរាបលោកហើយអ្វី ?

- បាទ ។ ដាក់បន្តិចទៀតទៅ *ដូស្ហូ*។

- ខ្ញុំគិតថា ខ្ញុំមិនត្រូវញ៉ាំទៀតទេ ។ ខ្ញុំដួលអីលូវហ្នឹងហើយ ។

*ម៉ារីកូ* បក់ផ្ចិតយ៉ាងញាប់ដៃ ។ *ប្លាក់ថន* ពោលឡើង :

- អ្នកស្រីមានត្រចៀកល្អណាស់ ។

- លោកក៏អញ្ចឹងដែរ ។ ពួកយើងពោលគឺ *ភូជីកូ* និង ខ្ញុំគិតថាច្រមុះលោកល្អឥតខ្ចោះសក្តិសមជា *ដៃមីញ៉ូ* មែន។



www.budinst.gov.kh www.elibraryofcambodia.org

គេគ្រហឹមហើយលំអោនខ្លួនយ៉ាងស្បើតចំពោះនារីទាំងពីរ ។ នារីទាំងពីរលំអោនខ្លួនតបវិញ។

- *សាកេ* ទៀត *អាន់ជីន-សាន* ?

គេលើកពែងស្រាឡើង ម្រាមដៃរបស់គេនៅនឹងឥតញ្ញោច។ *ម៉ារីកូ* ចាក់ស្រាយ៉ាងប្រុងប្រយ័ត្ន បបូរមាត់នាងខាំចុងអណ្តាតដោយការប្រុងផ្តោតអារម្មណ៍។

*កូជីកូ* ក៏ទទួលយកស្រាទៀតទាំងតុញ្ញតុះ ថ្វីបើនាងនិយាយថានាងលែងដឹងជើងនាងទៅហើយក្តី ។ ភាពស្រងេះស្រងោចដ៏ស្ងាត់ស្ងៀមរបស់នាងបានរលាយអស់នៅក្នុងយប់នេះហើយនាងបានក្លាយទៅជាយុវនារីឡើងវិញ។ *ប្លាក់ថន* កត់សំគាល់ថានាងមិនមែនមានរូបអាក្រក់ដូចដែលគេយល់ឃើញពីមុននោះទៀតទេ។

***************

ក្បាលរបស់ *ចូសិន* ឡើងណែនម៉ឹងតែម្តង។ នេះមិនមែនមកពីស្រា *សាកេ* នោះទេ តែគឺមកពីយុទ្ធសាស្ត្រសង្គ្រាមដ៏មិនគួរជឿបានដែល *យ៉ាប៊ូ. អូមី និង អ៊ីកូវ៉ាជី* បានធ្វើអត្ថាធិប្បាយយ៉ាងចំហឥតលាក់លៀមអ្វីទាំងអស់ប្រាប់ដល់រូបគេ។ មានតែ *ណាកា* ជាមេបញ្ជាការរងនិងជាកូនប្រុសរបស់មហាបច្ចាមិត្តស៊ីសាច់នោះទេ ដែលមិនបានហើបមាត់សោះនៅក្នុងយប់នេះនិងនៅតែមានអាកប្បកិរិយាត្រជាក់ស្រេប ក្រអឺតក្រទម គ្មានអោនលំទោនគួរសមអ្វីបន្តិចណាសោះនោះ។

*ចូសិន* ពោល :

- អស្ចារ្យណាស់ *យ៉ាប៊ូ-សាម៉ា*។ អីលូវនេះខ្ញុំយល់ហើយពីហេតុផលដែលលោកត្រូវរក្សាការសំងាត់នេះ។ លោកម្ចាស់ខ្ញុំពិតជាយល់ដូចខ្ញុំដែរ។ វាងវៃ ចំជាវាងវៃមែន។ ចំនែកលោកវិញ*ណាកា-សាន* លោកនៅស្ងាត់ស្ងៀមម៉ាយប់ទៅហើយ ខ្ញុំចង់ដឹងពីយោបល់លោកផងដែរ។ តើលោកចូលចិត្តភាពចល័តថ្មីនេះ.....យុទ្ធសាស្ត្រថ្មីនេះទេ ?

យុវបុរសឆ្លើយតបវិញ :



www.budinst.gov.kh www.elibraryofcambodia.org

- ឪពុកខ្ញុំជឿថារាល់លទ្ធភាពនៃសង្គ្រាមទាំងអស់ ត្រូវតែយកមកពិនិត្យពិចារណា *ចូសិន-សាន*។

- ចុះលោក តើលោកមានយោបល់យ៉ាងណាដែរ ?

- ខ្ញុំត្រូវបញ្ជូនមកទីនេះដើម្បីទទួលបញ្ជា ដើម្បីសង្កេត ដើម្បីរៀនសូត្រ និង សាកល្បង មិនមែនមកអោយយោបល់នោះទេ ។

- អញ្ចឹងហើយ តែក្នុងឋានៈជាមេបញ្ជាការរង.....រឺក៏ខ្ញុំអាចនិយាយថាមេបញ្ជាការរងដ៏ល្បីល្បាញ.....តើការសាកល្បងនេះ តាមលោកយល់ អាចជាជោគជ័យមួយបានទេ ?

- សំនួរនេះគួរតែត្រូវបាន *យ៉ាប៊ូ-សាម៉ារី អូម៉ី-សាន* ឆ្លើយទើបត្រូវ ។ រឺមួយឪពុកខ្ញុំតែម្តង ។

- តែ *យ៉ាប៊ូ-សាម៉ា* បានមានប្រសាសន៍ថា យប់នេះម្នាក់ៗអាចនិយាយបានដោយសេរី ។ តើមានអីត្រូវលាក់បាំងទៀត ? ពួកយើងសុទ្ធតែជាមិត្តនឹងគ្នាទេតើ *រេ* ? កូនប្រុសដ៏ល្បីល្បាញរបស់ឪពុកដ៏ល្បីល្បាញយ៉ាងនេះច្បាស់ជាមានយោបល់អីជាមិនខាន *រេ* ?

ភ្នែករបស់ *ណាកា* ឡើងតូចព្រឹមក្រោមការប្រមាថ តែគេឥតតបវិញឡើយ ។ *យ៉ាប៊ូ* និយាយ :

- ទាំងអស់គ្នាមានសិទ្ធិនិយាយដោយសេរី *ណាកា-សាន*។ តើលោកមានយោបល់យ៉ាងណា ?

- ខ្ញុំគិតថា បើមិនអោយគេដឹងមុន គំនិតនេះអាចអោយយើងឈ្នះមួយប្រាវ រឺ មានលទ្ធភាពឈ្នះការប្រយុទ្ធមួយ ។នេះបើមិនអោយគេដឹងមុន គឺពិតជាឈ្នះ ។តែបន្ទាប់មកទៀត ? *-ណាកា* បន្តក្នុងសំលេងដ៏ត្រជាក់ស្រេប -ពេលនោះទាំងអស់គ្នានឹងប្រើក្បួនតែមួយហើយមនុស្សច្រើននឹងត្រូវស្លាប់ដោយឥតប្រយោជន៍ ស្លាប់ដោយឥតកិត្តិយស ដោយគូសត្រូវមួយដែលមិនទាំងដឹងថាខ្លួនបានសំលាប់អ្នកណាទៅទៀត ។ អីលូវនេះខ្ញុំមិនជឿថាឪពុកខ្ញុំនឹងអនុញ្ញាត អោយប្រើយុទ្ធវិធីនេះនៅក្នុងពេលមានប្រយុទ្ធគ្នាមែនទែនឡើយ ។

- គាត់និយាយអញ្ចឹងមែន ?



www.budinst.gov.kh www.elibraryofcambodia.org

សំនួរ *យ៉ាប៊ូ* មុតៗ ដោយគ្មានកង្វល់អ្វីនឹងវត្តមានរបស់ *ចូសិន* ឡើយ ។

- អត់ទេ *យ៉ាប៊ូ-សាម៉ា*។ ខ្ញុំគ្រាន់តែជូនយោបល់របស់ខ្ញុំផ្ទាល់តែប៉ុននោះ ។

*យ៉ាប៊ូ* បន្តសំនួរក្នុងសំលេងដ៏ព្រឺព្រួច :

- ចុះរឿងកងមូស្កេនេះ.......លោកមិនឯកភាពទេ រឺ ?

*ណាកា* សំលឹងមើល *យ៉ាប៊ូ* ក្នុងក្រសែភ្នែកនឹងថ្កល់ដូចភ្នែកពស់ :

- ដោយលោកបានជាសួរខ្ញុំទៅហើយនោះ ខ្ញុំសូមឆ្លើយយ៉ាងគោរពថា ខ្ញុំមិនឯកភាពមែន។ បាទ គឺជាការពិត ខ្ញុំយល់ថានេះគឺជាការគួរអោយស្អប់ខ្ពើមណាស់ ។ ជីដូនជីតាយើងតែងដឹងថាគាត់សំលាប់អ្នកណា រឺ ក៏អ្នកណាជាអ្នកប្រយុទ្ធឈ្នះគាត់ ។ គឺជា *ប៊ូស៊ីដូ* ជាមាគ៌ាយើង ជាមាគ៌ានៃអ្នកចំបាំង ជាមាគ៌ារបស់សាមូរ៉ៃពិតប្រាកដ ។ អ្នកខ្លាំងពូកែឈ្នះ *វេ*? តែចុះនេះគឺជាស្អីទៅវិញ ? តើលោកធ្វើយ៉ាងម៉េចដើម្បីបង្ហាញនូវថ្វីដៃរបស់លោកជូន អម្ចាស់លោកបាន ? តើលោកម្ចាស់ផ្តល់រង្វាន់លើសេចក្តីក្លាហានរបៀបណាទៅ ? រត់កាត់គ្រាប់គឺជាអំពើក្លាហានមួយហើយ តែក៏ជាអំពើកំលៅមួយផងដែរ ។ តើវាមានតំលៃត្រង់ណាទៅ ? កាំភ្លើងគឺផុយពីក្រមតំលៃរបស់ពួកសាមូរ៉ៃយើង ។ ពួកអ្នកចុងស្រុកច្បាំងរបៀបនេះឯង ពួកអ្នកស្រែច្បាំងរបៀបហ្នឹងដែរ ។ តើលោកមានបានគិតថាពួកឈ្មួញដ៏សំអុយ ពួកអ្នកស្រែ ប៉ើយសូម្បីតែពួក *វេតា* ក៏អាចច្បាំងតាមរបៀបហ្នឹងបានដែរទេ រឺ ?

*ចូសិន* អស់សំណើច ហើយ *ណាកា* ក៏បន្តទៀតក្នុងអាការៈយ៉ាងគំរាម :

- ពួកអ្នកស្រែតែមួយក្តាប់តូច ក៏អាចសំលាប់ពួកសាមូរ៉ៃយ៉ាងច្រើនបានយ៉ាងងាយអោយតែពួកវាមានកាំភ្លើង ! ពិតមែនណា ពួកនេះអាចសំលាប់ពួកយើងមួយណាក៏បាន សូម្បីតែលោកម្ចាស់ *អ៊ីស៊ីដូ* ដែលចង់មកអង្គុយកៅអីជំនួសឪពុកខ្ញុំក៏ដោយ ក៏ពួកវាអាចធ្វើបានដែរ ។

*ចូសិន* ច្រលោតតួង :

- លោកម្ចាស់ *អ៊ីស៊ីដូ* ឥតមានបំនងចង់បានដែនដីរបស់ឪពុកលោកទេ ។ លោកម្ចាស់គ្រាន់តែប្រឹងប្រែងការពារចក្រភពសំរាប់ទាយាទស្របច្បាប់តែប៉ុននោះ ។

- ឪពុកខ្ញុំមិនមែនជាគ្រោះគំរាមកំហែងចំពោះលោកម្ចាស់ *វ៉ាយនមុ៊ន* រឺ ចំពោះនគរ



www.budinst.gov.kh www.elibraryofcambodia.org

នេះឡើយ ។

- ពិតហើយ តែលោកបានលើកឡើងពីរឿងអ្នកស្រែ ។ លោកម្ចាស់ *រ៉ែកូ* ពីមុនគឺជាអ្នកស្រែ ។ លោកម្ចាស់ *អ៊ីស៊ីដូ* ពីមុនក៏ជាអ្នកស្រែដែរ ។ ខ្លួនខ្ញុំពីមុនក៏ជាអ្នកស្រែ ។ ហើយជា *រ៉ូនីន* ទៀតផង ។

*ណាកា* ឥតមានចេតនាចង់បង្កជំលោះឡើយ ។ គេដឹងថាគេមិនមែនជាដៃគូរបស់ *ចូសិន* ដែលល្បីល្បាញខាងប្រើដាវ និងពូថៅ ពេញសុះសាយមួយនគរទៅហើយនោះទេ ។គេបន្ត :

-ខ្ញុំគ្មានចេតនាចង់ប្រមាថម្ចាស់របស់លោកវីរូបលោកវីអ្នកណាមួយឡើយ *ចូសិន-សាន*។ ខ្ញុំគ្រាន់តែចង់និយាយថាពួកយើងជាសាមូរ៉ៃនេះត្រូវតែធ្វើយ៉ាងណាដើម្បីកុំអោយពួកអ្នកស្រែមានកាំភ្លើងអោយសោះបើមិនយ៉ាងដូចនោះទេ ពួកយើងគ្មានអ្នកណាម្នាក់មានសុវត្ថិភាពឡើយ ។

*ចូសិន* តប:

- ពួកឈ្មួញក្តី ពួកអ្នកស្រែក្តី យើងឥតមានបារម្ភអ្វីទាំងអស់ ។

- ខ្ញុំឯកភាព -*យ៉ាប៊ូ* បន្ថែម -ហើយ *ណាកា-សាន* ខ្ញុំឯកភាពមួយចំនួនលើអ្វីដែលលោកបាននិយាយអំបាញ់មិញនេះ ។ ពិតមែន ណាំ ។ តែកាំភ្លើងគឺវាទំនើប ណាំ ។ បន្តិចទៀតនេះរាល់ការប្រយុទ្ធនឹងត្រូវធ្វើដោយប្រើកាំភ្លើងជាពុំខាន ។ ខ្ញុំឯកភាពហើយថាវាគួរអោយស្អប់ខ្ពើមណាស់ តែនេះជារបៀបធ្វើសង្គ្រាមសម័យ ។ ហើយបន្ទាប់មកវានឹងនៅតែដដែលហ្នឹងពោលគឺសាមូរ៉ៃណាដែលអង់អាចជាងគេនឹងបានជាញជ័យ ។

-ទេ ខ្ញុំសូមទោសតែលោកយល់ច្រលំហើយ *យ៉ាប៊ូ-សាម៉ា* !តើអាអ្នកចុងស្រុកប្រកាច់យក៏នេះវាប្រាប់យើងថាម៉េច ពីរឿងសារជាតិនៃយុទ្ធសាស្ត្រធ្វើសង្គ្រាមរបស់ពួកវានោះ ?វាបានទទួលស្គាល់ដោយខ្លួនវាតែម្តងថាទ័ពពួកវាជាទ័ពរបស់ពួកជាប់កំនែន និងពួកស៊ីឈ្នួលច្បាំងតែប៉ុននោះ*ទេ* ?ពួកស៊ីឈ្នួលច្បាំងពោលគឺគ្មានស្មារតីពីរឿងកាតព្វកិច្ចចំពោះអម្ចាស់ខ្លួនបន្តិចណាទេ ។ពួកទាហានទាំងនោះច្បាំងដើម្បីលុយដើម្បីឆក់ប្លន់ដើម្បីរំលោភ និងច្រាស់ច្រំតែប៉ុននោះ ។ មិនវានិយាយថាកងទ័ពពួកវាជា *កងទ័ពកសិករ* អ្វី ? អាណឹងហើយមើលទៅ តើកាំភ្លើងនាំអ្វីខ្លះដល់ពិភពរបស់ពួកវា ហើយវានឹងនាំអីខ្លះដល់ពិភពយើង ។ បើសិនជាខ្ញុំមានអំនាចវិញ ខ្ញុំនឹង



www.budinst.gov.kh www.elibraryofcambodia.org

កាត់ក្បាលអាមនុស្សចុងស្រុកនេះអោយបានក្នុងយប់នេះ ហើយខ្ញុំនឹងដាក់កាំភ្លើងអោយនៅក្រៅច្បាប់ជារៀងរហូតជាមិនខាន។

*ចូសិន* សួរយ៉ាងលឿន :

- តើនេះជាការយល់ឃើញរបស់ឪពុកលោក រឺ ?

- ឪពុកខ្ញុំមិនដែលប្រាប់ខ្ញុំ រឺ ប្រាប់អ្នកណាទៀតពីអ្វីដែលគាត់គិតនោះទេ។លោកដឹងច្បាស់ហើយតើ។ ខ្ញុំមិនមែននិយាយជំនួសឪពុកខ្ញុំ ហើយក៏គ្មានអ្នកណានិយាយជំនួសគាត់ដែរ - *ណាកា* តបទាំងក្តៅក្រហាយនៅក្នុងចិត្តដោយចាញ់កលតេហាមាត់និយាយទាល់តែបាន -ខ្ញុំត្រូវបានបញ្ជូនមកទីនេះដើម្បីទទួលបញ្ជា ដើម្បីស្តាប់ មិនមែនមកនិយាយនោះទេ។ ខ្ញុំសូមទោសចំពោះការនិយាយស្តីរបស់ខ្ញុំនេះ។ ខ្ញុំមិនគួរនិយាយទេបើលោកមិនបានអនុញ្ញាតអោយនោះ។ បើសិនជាការនិយាយស្តីរបស់ខ្ញុំបានប៉ះពាល់លោក រឺ លោក *យ៉ាប៊ូ-សាម៉ា* រឺ ក៏លោក *អូមី* នោះខ្ញុំសូមអភ័យទោស។

*យ៉ាប៊ូ* ពោលតប :

- មិនចាំបាច់សូមទោសសូមពៃរ៍អីទេ។ ខ្ញុំបានសួរយោបល់របស់លោក។ ចុះមានអ្នកណាត្រូវប៉ះពាល់ពីរឿងអីទៅ ? នេះគឺជាការពិគ្រោះពិភាក្សាគ្នា *នេ* ? ពិគ្រោះពិភាក្សាវវាងមេៗតែប៉ុននោះ។ បើអញ្ចឹង លោកដាក់កាំភ្លើងអោយនៅក្រៅច្បាប់មែន ?

- ពិតមែន។ ខ្ញុំគិតថាលោកគួរតែវាងវៃធ្វើការត្រួតពិនិត្យអោយបានជិតដល់លើកាំភ្លើងដែលមានទាំងប៉ុន្មាននៅលើដែនតំបន់ដែលលោកត្រួតត្រានេះអោយមែនទែន។

- កសិករទាំងអស់សុទ្ធតែត្រូវបានហាមមិនអោយមានអាវុធគ្រប់ប្រភេទ។ កសិករខ្ញុំនិងមនុស្សម្នារបស់ខ្ញុំត្រូវបានត្រួតពិនិត្យជាប់លាប់ល្អណាស់។

*ចូសិន* ញញឹមទៅរកយុវបុរសទាំងក្នុងចិត្តប្រមាថមាក់ងាយ :

- លោកមានគំនិតគួរចាប់អារម្មណ៍មែន *ណាកា-សាន*។ តែលោកយល់ច្រលំហើយអំពីអ្នកស្រែ។ ពួកនោះគ្រាន់តែជាអ្នកផ្គត់ផ្គង់ដល់ពួកសាមូរ៉ៃតែប៉ុននោះ។ ពួកវាមិនអាចជាគ្រោះកំហែងអ្វីបានឡើយ។



www.budinst.gov.kh www.elibraryofcambodia.org

- ក្នុងពេលឥឡូវនេះវាអញ្ចឹងមែនហើយ-*ណាកា* តប ។ មោទនភាពបានគ្របដណ្តប់អសវិចារណញ្ញាណរបស់គេ - ដោយហេតុនេះហើយទើបខ្ញុំចង់ដាក់កាំភ្លើងអោយនៅក្រៅច្បាប់នេះ ។លោកមានយោបល់ត្រូវណាស់*យ៉ាប៊ូ-សាន* ដែលថាសម័យថ្មីទាមទារនូវវិធីថ្មីនោះ ។ តែដោយអ្វីដែលអា*អាន់ជីន-សាន* នេះបាននិយាយនោះទើបខ្ញុំត្រូវធ្វើអោយលើសពីអ្វី ដែលច្បាប់យើងបច្ចុប្បន្នបានចែងទៅទៀត ។ នោះគឺខ្ញុំនឹងចេញអាជ្ញាកំនត់ថា ក្រៅពីសាមូរ៉ៃចេញអ្នកណាដែលរកឃើញថាមានអាវុធ រឺ ដែលជួញដូរអាវុធនឹងត្រូវប្រហារជីវិតទាំងប្រាំពីរសន្តានតែម្តង ។ បន្ថែមលើនេះទៀតខ្ញុំនឹងដាក់ការហាមប្រាមមិនអោយផលិតអាវុធ រឺនាំចូលអាវុធឡើយ ។ខ្ញុំនឹងហាមឃាត់ពួកមនុស្សចុងស្រុកមិនអោយកាន់អាវុធ រឺក៏នាំវាចូលមកក្នុងស្រុកយើងឡើយ ។ ពិតណាស់ នេះបើសិនជាខ្ញុំមានអំនាចមែន ខ្ញុំនឹងរាំងមិនអោយពួកអ្នកចុងស្រុកអស់នេះមកជាន់ដីស្រុកយើងបានជាដាច់ខាតលើកលែងតែពួកបព្វជិតមួយចំនួនតូចហើយនឹងកំពង់ផែមួយគ្រាន់ធ្វើជំនួញតែប៉ុននោះ ហើយកំពង់ផែនេះទៀតសោតខ្ញុំនឹងហ៊ុមព័ទដោយរបងខ្ពស់ៗ និងដាក់សុទ្ធតែមនុស្សទុកចិត្តអោយនៅយាមថែមទៀត ។ ហើយខ្ញុំនឹងប្រហារជីវិតអា *អាន់ជីន-សាន* នេះភ្លាមដើម្បីកុំអោយចំនេះដឹងដ៏គគ្រិចរបស់វារីកសាយភាយទៅបាន ។

*ចូស៊ិន* និយាយឡើង :

- *ណាកា-សាន*។ នៅក្មេងតិ៍ល្អអញ្ចឹង ។ លោកដឹងទេ លោកម្ចាស់ខ្ញុំឯកភាពលើច្រើនចំនុចដែលលោកបានលើកឡើងពីពួកមនុស្សចុងស្រុកនេះណាស់ ។ ខ្ញុំតែងលឺលោកមានប្រសាសន៍ញឹកញាប់ណាស់ថា : " កុំអោយវាចូល -ធាក់ពួកវាចេញទៅវិញទៅ -ធាក់ពួកវាអោយនៅមួលក្បាលនៅឯ *ណាកាសាគី* ទៅ ! "។ លោកនឹងសំលាប់ *អាន់ជីន-សាន* មែនអ្ហី ? នេះគួរដែរ ។ លោកម្ចាស់ខ្ញុំក៏មិនចូលចិត្ត *អាន់ជីន-សាន* នេះដែរ ។ តែចំពោះរូបលោក.....-*ចូស៊ិន* អាក់បន្តិច -ឱមែនហើយ លោកមានគំនិតល្អម្យ៉ាងអំពីរឿងកាំភ្លើង ។ ខ្ញុំកាន់តែច្បាស់ហើយក្នុងរឿងហ្នឹង ។ តើខ្ញុំអាចយករឿងនេះទៅ ជំរាបលោកម្ចាស់ខ្ញុំបានទេ ? គឺគំនិតរបស់លោកស្តីពីអារឿងកាំភ្លើងហ្នឹង ណាស់ ?

- ប្រាកដជាបាន ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែលគេបានបញ្ចេញនូវអ្វីដែលនៅពុះកញ្ជ្រោលក្នុងចិត្តគេ តាំងពីថ្ងៃដំបូងអស់ហើយនោះ *ណាកា* ក៏បានត្រជាក់ចិត្តជាងមុនច្រើនដែរ។ *យ៉ាប៊ូ* សួរបន្ត :

- តើលោកមានបានជូនយោបល់នេះទៅលោកម្ចាស់ *តូវ៉ាណាកា* ទេ ?

- លោកម្ចាស់ *តូវ៉ាណាកា* ឥតមានបានសួរយោបល់ខ្ញុំទេ។ ខ្ញុំសង្ឃឹមថាថ្ងៃណាមួយគាត់នឹងផ្តល់កិត្តិយសដល់ខ្ញុំតាមការសាកសួរ ដូចដែលលោកបានធ្វើចំពោះខ្ញុំអំបាញ់មិញជាមិនខាន។

*ណាកា* ឆ្លើយតបទាំងក្នុងចិត្តគិតសួរខ្លួនឯងថាតើមានអ្នកណាម្នាក់នៅទីនេះដឹងថាគេនិយាយកុហក រឺទេ ?

*អូមី* ពោលឡើង :

- ដោយថានេះជាការពិភាក្សាគ្នាដោយសេរីនោះ ខ្ញុំមានយោបល់ថាមនុស្សចុងស្រុកនេះគឺជាកំនប់មហាសាលមួយ។ ខ្ញុំយល់ថាយើងគួររៀនសូត្រពីមនុស្សចុងស្រុកនេះ។ យើងត្រូវយល់ដឹងពីកាំភ្លើង និង ពីសំពៅចំបាំងពីព្រោះពួកនេះយល់ដឹងពីរឿងនេះ។ យើងត្រូវយល់ដឹងទាំងអស់ពីអ្វីដែលពួកនេះយល់ដឹង។ ហើយយល់ដឹងអោយបានរហ័សបំផុត។ ហើយនៅពេលនេះទៀតសោត មនុស្សយើងមួយចំនួនត្រូវចាប់ផ្តើមរៀនគិតដូចពួកវានោះទើបយើងអាចឈានលើសពួកនេះបាន។

*ណាកា* និយាយទាំងក្នុងទំនុកចិត្ត :

- តើពួកអស់នេះអាចយល់ដឹងអីខ្លះទៅ *អូមី-សាន* ? ពិតហើយ រឿងកាំភ្លើង រឿងសំពៅ។ តែចុះក្រៅពីហ្នឹង ?តើពួកវាអាចកំទេចពួកយើងដោយរបៀបណាទៅ ? ពួកវាគ្មានសាមុរ៉ៃណាមួយគ្រាប់ទេ។ មិនអា *អាន់ជីន-សាន* ទទួលស្គាល់ថាស្តេចពួកវាជាឃាតក និងជាអ្នកឯប់សាសនាជ្រុលទេ រឺ ? ពួកយើងមានរាប់លាននាក់ ពួកវាវិញមានមិនដល់មួយក្តាប់ផង ពួកយើងប្រើតែដៃមួយក៏បោសពួកវារាបដែរ។

*-អាន់ជីន-សាន* នេះជាអ្នកធ្វើអោយខ្ញុំបានភ្លឺភ្នែក *ណាកា-សាន*។ខ្ញុំទើបមើលឃើញថាស្រុកយើង ហើយនឹងស្រុកចិនមិនមែនជាពិភពលោកទាំងមូលនោះទេ នេះគ្រាន់តែជាមួយ



www.budinst.gov.kh www.elibraryofcambodia.org

ភាគតូចនៃពិភពលោកតែប៉ុននោះ ។ ដំបូងខ្ញុំគិតថាអ្នកចុងស្រុកនេះគ្រាន់តែជារបស់ចំណែកមួយប៉ុននោះ ។ តែអីលូវនេះខ្ញុំមិនមានគំនិតយ៉ាងនេះទៀតទេ ។ ខ្ញុំសូមអរគុណព្រះជាម្ចាស់ដែលបានបញ្ជូនវាមកនេះ ។ ខ្ញុំគិតថាវានឹងជួយយើងបានហើយខ្ញុំដឹងថាយើងអាចរៀនសូត្រអំពីវាបាន ។ អីលូវនេះ វាបានអោយយើងនូវឥទ្ធិពលមួយគ្របលើពួកចុងស្រុកខាងត្បូង.....ហើយនឹងលើប្រទេសចិនថែមទៀតផង ។

- ថាម៉េច ?

- លោកម្ចាស់ *តែកូ* ទទួលបរាជ័យពីព្រោះពួកចិនមានចំនួនច្រើនលើសលប់ បើរាប់ជាទ័ពទល់ទ័ព ព្រួញទល់ព្រួញ *នេ* ? បើយើងប្រើកាំភ្លើង និង ជំនាញរបស់អ្នកចុងស្រុកនេះ យើងអាចកាន់កាប់ទីក្រុងប៉េកាំងបាន ។

- ត្រូវថាប្រើល្បិចកំសាករបស់មនុស្សចុងស្រុកវិញទើបត្រូវ *អូមី-សាន* !

-គឺប្រើចំនេះដឹងរបស់មនុស្សចុងស្រុកយើងអាចកាន់កាប់ប៉េកាំងបាន *ណាកា-សាន* ។ អ្នកណាដែលកាន់កាប់ប៉េកាំងបានគឺពិតជាត្រួតត្រាស្រុកចិនបាន ។ ហើយអ្នកណាត្រួតត្រាស្រុកចិនបានពិតជាត្រួតត្រាពិភពលោកទាំងមូលបាន ។ យើងត្រូវរៀនទំលាប់ចិត្តមិនខ្មាស់អៀននឹងទទួលយកចំនេះវិជ្ជាទោះជាមកពីណាក៏ដោយ ។

- ខ្ញុំយល់ថាយើងឥតត្រូវការអ្វីទាំងអស់ពីខាងក្រៅ ។

- មិនមែនខ្ញុំប្រមាថលោកទេ *ណាកា-សាន* ប៉ុន្តែខ្ញុំយល់ឃើញថាយើងត្រូវការពារទឹកដីយើងនេះតាមគ្រប់វិធី ។ ភារកិច្ចចំបងរបស់យើងគឺការពារទីតាំងតែមួយគត់ដែលយើងមាននៅលើផែនដីនេះ ។ មិនតែទឹកដីនេះជាទឹកដីរបស់ព្រះទេអ្វី *នេ* ? មានតែព្រះចៅអធិរាជយើងប៉ុននោះទេដែលមានធាតុជាព្រះនោះ ។ ខ្ញុំឯកភាពថាយើងគួរបំបិទមាត់មនុស្សចុងស្រុកនេះ ។តែមិនមែនដោយសំលាប់វានោះទេ គឺដោយឯកោវាអោយនៅជាអចិន្ត្រៃយ៍ក្នុងតំបន់ *អាន់ជីរ* នេះ រហូតដល់យើងរៀនចេះចប់ចេះគ្រប់ពីអ្វីដែលវាចេះដឹងនោះ ។

*ទូរ៉ាណាហ្គា* អេះក្បាលក្នុងការត្រិះរិះពិចារណា :

- ខ្ញុំនឹងរាយការណ៍ ជូនលោកម្ចាស់ខ្ញុំពីទស្សនៈនានារបស់ពួកលោក ។ ខ្ញុំឯកភាពនៅ



www.budinst.gov.kh www.elibraryofcambodia.org

លើប្រការដែលមនុស្សចុងស្រុកត្រូវតែបានឯកោ។ ហើយការរុឹកហាត់ក៏ត្រូវតែបញ្ឈប់ជាបន្ទាន់ភ្លាមដែរ។

*យ៉ាប៊ូ* យករមូរឯកសារចេញពីក្នុងដៃរបស់ខ្លួនដោយពោលថា :

- នេះគឺជារបាយការណ៍ទាំងស្រុងទាក់ទិននឹងការហាត់ដកពិសោធន៍នេះ សំរាប់ជូនលោកម្ចាស់ *អ៊ីស៊ុជូ*។ ពិតហើយ បើសិនជាលោកម្ចាស់ *អ៊ីស៊ីជូ* សំរេចចង់អោយបញ្ឈប់ការរុឹកហាត់នេះ យើងនឹងឈប់ភ្លាម។

*ចូស៊ិន* ទទួលយកសារ :

- ចុះលោកម្ចាស់ *តូរ៉ាណាកា*? តើគាត់យ៉ាងម៉េចដែរ?

មាត់ *ចូស៊ិន* សួរ តែភ្នែកលោកសំលឹងមើលទៅ *ណាកា*។ *ណាកា* ឥតនិយាយអ្វីទាំងអស់ ភ្នែកគេសំលឹងមើលសារជាប់។ *យ៉ាប៊ូ* តប :

- លោកនឹងមានពេលអាចជួបសួរយោបល់លោកផ្ទាល់តែម្តងបាន។ គាត់បានទទួលរបាយការណ៍មួយដូចគ្នានេះដែរ។ខ្ញុំគិតថាលោកនឹងធ្វើដំណើរចេញទៅ *យេដូ* ស្អែកនេះ មែនទេ? រឺ មួយក៏លោកចង់ទៅមើលការរុឹកហាត់សិន ? ខ្ញុំសឹងតែមិនបាច់ប្រាប់លោកផងទេ ថាពួកទ័ពមិនទាន់ហាត់បានស្ទាត់ប៉ុន្មានទេ។

- ខ្ញុំចង់មើលរបៀបវៃលុកមួយ មើល៍។

- *អូមី-សាន* រៀបចំទៅ។ អែងដឹកនាំការវៃលុកនេះ។

- ទទួលបញ្ជា ទាន។

*ចូស៊ិន* ងាកទៅមេបញ្ជាការរងរបស់ខ្លួន ហើយហុចសារទៅអោយកាន់ដោយពោលថា :

- *ម៉ាស៊ូម៉ូតូ* លោកយករបាយការណ៍នេះទៅជូនលោកម្ចាស់ *អ៊ីស៊ីជូ*។ លោកចេញដំណើរនៅពេលនេះភ្លាម។

- បាទ *ចូស៊ិន-សាន*។

*យ៉ាប៊ូ* និយាយទៅកាន់ *អ៊ីកូរ៉ាជី* :



www.budinst.gov.kh www.elibraryofcambodia.org

- លោកចាត់ចែងរៀបចំសេះដែលពេញកំលាំង ហើយនឹងអ្នកនាំផ្លូវដើម្បីជូនភ្ញៀវរហូតទៅដល់ព្រំតំបន់ ។

*អ៊ីកូរ៉ាជី* ហើយនឹងសាមូរ៉ៃនោះបានចាកចេញទៅភ្លាម ។ *ចូសិន* ពត់ខ្លួន ស្វាប :

- សូមអភ័យទោសផងទៅចុះ តែនេះមកពីប៉ុន្មានថ្ងៃនេះខ្ញុំបំផាយសេះជាប់រហូត ។ ខ្ញុំត្រូវតែអរគុណលោកចំពោះរាត្រីដ៏សែនអស្ចារ្យនេះ *យ៉ាប៊ូ-សាម៉ា* ។ គំនិតរបស់លោកគឺវែងឆ្ងាយណាស់ ។ គំនិតលោកក៏អញ្ចឹងដែរ *អូមី-សាន*។ លោកក៏អញ្ចឹង *ណាកា-សាន*។ ខ្ញុំនឹងលើកពីគុណសម្បត្តិរបស់លោកជំរាបជូនលោកម្ចាស់ *តូរ៉ាណាកា* និង ម្ចាស់ខ្ញុំគឺលោកម្ចាស់ *អ៊ីស៊ីដូ* ដើម្បីលោកបានជ្រាប ។ អីលូវនេះ ខ្ញុំសូមអស់លោកអភ័យទោសផងចុះ ដោយខ្ញុំហត់នឿយណាស់ហើយ១ទំរាំទៅដល់ *អូសាកា*វិញក៏ឃើញថាផ្លូវទៅឆ្ងាយណាស់ដែរ ។

*យ៉ាប៊ូ* បន្ទរតាម :

- ពិតជាអញ្ចឹងមែនហើយ ។ តើ *អូសាកា* យ៉ាងម៉េចហើយ អីលូវនេះ ?

- ស្រួលបួលណាស់ ។ លោកចាំពីពួកចោរដែលព័ទ្ធវ៉ៃប្រហារលោកទាំងផ្លូវគោក និងផ្លូវទឹកផងនោះទេ ?

- ពិតជាចាំ ។

- យប់នោះ យើងកាត់ក្បាលពួកវាបានបួនរយហាសិប ។ ពួកវាភាគច្រើនស្លៀកពាក់ឯកសណ្ឋានទ័ពលោកម្ចាស់ *តូរ៉ាណាកា*។

- ពួកអា *រ៉ូនីន* ទាំងនេះចំជាគ្មានការថ្លៃថ្នូរអីសោះមែន ។ គ្មានទាល់តែសោះតែម្តង ។

- *រ៉ូនីន* ខ្លះចេះរក្សាកិត្តិយសគេបានដែរ -ចូសិន ឆ្លើយតបដោយញញោចខ្លួននឹងការប្រមាថនេះ ។ មួយជីវិតនេះ លោកត្រូវតែរស់នៅដោយទទួលភាពអាម៉ាស់ដែលធ្លាប់ក្លាយខ្លួនជា *រ៉ូនីន* ម្តងរួចមកហើយ -អាពួកខ្លះទៀតក៏មានស្លៀកពាក់ពាក់ឯកសណ្ឋានពណ៌ប្រផេះរបស់ទ័ពខ្ញុំដែរ ។ តែគ្មានអ្នកណាគេចខ្លួនរួចឡើយ ។ ពួកវាស្លាប់ទាំងអស់ ។

- រួចចុះ *ប៊ុនតារ៉ូ-សាន* ?

- ទេ គាត់...... -*ចូសិន* ឈប់ង៉ក់ តែដោយបានជាជ្រុលថាទេទៅហើយនោះ គេក៏



www.budinst.gov.kh www.elibraryofcambodia.org

លែងរស់ទៅតាមនោះដែរ -ទេ។ យើងខ្ញុំមិនច្បាស់ដែរ តែគ្មានអ្នកណាម្នាក់កាត់ក្បាលគាត់បានទេ។ លោកអត់មានបានដឹងដំណឹងអីពីគាត់ទេរឺ ?

- ទេ -*ណាកា* ឆ្លើយតប។

- អាចគាត់ត្រូវគេចាប់ខ្លួនបានក៏មិនដឹង ។ អាចគាត់ត្រូវគេកាប់ចិញ្ច្រាំចោលរាយប៉ាយអស់ទៅហើយក៏មិនដឹង។ លោកម្ចាស់ខ្ញុំចង់ដឹងផងដែរនៅពេលណាដែលលោកបានដឹងដំណឹងនេះ។ អីលូវនេះ នៅឯ *អូសាកា* គេកំពុងប្រញាប់ដៃជើងរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា។ នៅក្នុងពិធីនេះ នឹងមានពិធីបុណ្យគគ្រឹកគគ្រេងដើម្បីអបអរក្រុមប្រឹក្សាថ្មី ហើយនឹង *ដៃមីញ៉ូ ទាំងអស់* ថែមទៀតផង។

*ណាកា* សួរយ៉ាងសុភាពរាបសារ :

- រួចចុះលោកម្ចាស់ *តូដា ហ៊ីរ៉ូ-ម៉ាត់ស៊ឺ* យ៉ាងម៉េចទៅហើយ ?

- កញ្ចាស់ដៃដែកនោះនៅតែមាំមួន ហើយចិត្តខ្លាំងតែងដែលណឹង។

- គាត់នៅ *អូសាកា* នៅឡើយទេរឺ ?

- ទេ គាត់បានចេញពី *អូសាកា* ជាមួយកូនទ័ពឪពុកលោកទាំងអស់មុនខ្ញុំចេញដំណើរប៉ុន្មានថ្ងៃម្លេះ។

- រួចគ្រួសារឪពុកខ្ញុំ ?

- ខ្ញុំបានលឺថាលោកជំទាវ *គីរីស៊ូប៊ូ* និងជំទាវ *សាស៊ូកូ* បានសុំស្នាក់នៅជាមួយលោកម្ចាស់របស់ខ្ញុំ។ គ្រូពេទ្យបានមានមតិថា លោកជំទាវគួរស្នាក់នៅទីនោះមួយរយៈសិន។ នេះទាក់ទិននឹងរឿងសុខភាពគាត់។ លោកដឹងហើយតើ។ គ្រូពេទ្យថាលោកជំទាវមានទំងន់យ៉ាងនេះធ្វើដំណើរអាចប៉ះពាល់សុខភាពទារកដែលនៅក្នុងផ្ទៃបាន។

រួច *តូស៊ិន* ងាកទៅនិយាយបន្ថែមជាមួយ *យ៉ាប៊ូ* :

- នៅយប់ដែលលោកចេញមកនោះ លោកជំទាវដួលមែនទេ ?

- មែនហើយ។

- មើលទៅប្រហែលជាគ្មានអីធ្ងន់ធ្ងរទេមើលទៅ ? -*ណាកា* សួរទាំងព្រួយបារម្ភ។



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ណាកា-សាន។ មិនមានអីចូនចូរទេ -រួចគេងាកទៅ យ៉ាប៊ូ ជាថ្មីម្តងទៀត -លោកបានជូនដំណឹងពីការមកដល់របស់ខ្ញុំទៅលោកម្ចាស់ តូរ៉ាណាកា ហើយមែនទេ ?

- ពិតហើយ ។

- ល្អណាស់អញ្ចឹង ។

- ដំណឹងដែលលោកបាននាំមកនេះ ពិតជានឹងទាក់ទាញការយកចិត្តទុកដាក់របស់គាត់មែនទែន ។

- ពិតហើយ ។ ខ្ញុំបានឃើញព្រាបនាំសារឆ្វែលហើយហើរទៅទិសខាងត្បូង ។

- អីលូវនេះ ខ្ញុំមានសេវានេះដែរហើយ ។

យ៉ាប៊ូ ឥតនិយាយបន្ថែមថាពួកលោកក៏ឃ្លាំមើលចលនាព្រាបនាំសាររបស់ ទូសិន ដែរទេ ។ លោកក៏ឥតនិយាយប្រាប់ពីរឿងដែលស្ទាំងលោកបានស្ទាក់ចាប់បានព្រាបនេះ ដណ្តើមយកសារដែលក្រោយពីដោះពាក្យសំងាត់បានហើយនោះបានសរសេរថា : " នៅ អាន់ជីរ៉ូ។ របាយការណ៍គឺពិត ។ យ៉ាប៊ូ, ណាកា, អូមី, និងបុរសចុងស្រុកនៅទីនេះទាំងអស់ " ផងទេ ។

- បើសិនជាលោកអនុញ្ញាតខ្ញុំនឹងចេញដំណើរស្អែកនេះក្រោយពីសមយុទ្ធ "វាយលុក" រួចហើយ ។ លោកផ្តល់សេះពេញកំលាំងអោយខ្ញុំផងបានទេ ? ខ្ញុំមិនត្រូវទុកអោយលោកម្ចាស់ តូរ៉ាណាកា រង់ចាំទេ ។ ខ្ញុំមានបំនងចង់ឃើញគាត់ទៅដល់ អូសាកា ឆាប់ៗនេះ ។ លោកម្ចាស់ខ្ញុំក៏អញ្ចឹងដែរ ។ ខ្ញុំសង្ឃឹមថាលោកនឹងរួមដំណើរជាមួយលោកទៅ អូសាកា ដែរ ណាកា-សាន។

- បើសិនជាខ្ញុំទទួលបញ្ជាអោយទៅ ខ្ញុំនឹងទៅដល់ទីនោះដែរ ។

ណាកា គបទាំងឥតងើយមុខ តែក្នុងចិត្តគេសែនពុះកញ្ជ្រោលជាពន់ពេក ។

ទូសិន ក៏ដើរចេញតំរង់ទៅទីទួលដែលគេបោះជំរុំស្នាក់នៅដោយមានកងការពាររបស់លោកតាមជាប់ជាមួយផង ។ ក្រោយពីបានរៀបចំអ្នកយាម និងចាត់ចែងអោយអ្នកឯទៀតចូលនិទ្រារួចហើយ លោកក៏ចូលទៅក្នុងជំរកប្រក់ស្លឹកឈើតូចមួយ ដែលគេបានសង់ឡើងសំរាប់បង្ការទឹកភ្លៀង ។ នៅទីនោះ អាស្រ័យដោយពន្លឺទៀន លោកសរសេរទៅក្នុងមុងរបស់លោកនូវខ្លឹមសារដែលលោកបានធ្វើពីលើកមុននោះឡើងវិញទៅលើក្រដាស់ដ៏ស្តើងមួយ ដោយបន្ថែម



www.budinst.gov.kh www.elibraryofcambodia.org

សេចក្ដីថា : " កាំភ្លើងទាំងប្រាំរយដើមសាហាវ ផ្ដាច់ជីវិត ។ ត្រៀមវាយលុកដោយកាំភ្លើងដោយមិនអោយដឹងមុន ។ របាយការណ៍ទាំងស្រុងបញ្ជូនតាម *ម៉ាស៊ូម៉ូតូ* " ។ ក្រោយពីដាក់ថ្ងៃខែហើយលោកផ្ដុំពន្លត់ភ្លើងទៀនរួចទើបចេញពីក្នុងមុងក្នុងភាពងងឹតឈឹង ទៅយកព្រាបពីក្នុងទ្រុងដើម្បីដាក់សារចូលទៅក្នុងបំពង់តូចមួយដែលនៅជាប់នឹងជើងវានោះ ។ រួចរាល់ហើយទើបលោកដើរលបលាក់ខ្លួនទៅរកកូនចៅរបស់លោកម្នាក់ហើយហុចព្រាបទៅអោយដោយនិយាយខ្សឹបៗថា :

- យកព្រាបនេះទៅដាក់ក្នុងគុម្ពោតព្រៃ ។ ទៅលាក់វាកន្លែងណាដែលវាអាចនៅសំងំបានដោយសុវត្ថិភាពរហូតដល់ពេលព្រឹកព្រលឹមបាន ។ លាក់អោយបានឆ្ងាយពីទីនេះបំផុតតាមដែលអាចធ្វើបាន ។ តែត្រូវប្រយ័ត្នប្រយែងព្រោះមានភ្នែកចាំឃ្លាំមើលច្រើនណាស់ ។ បើសិនមានគេឃាត់អែងៗប្រាប់គេថាអញអោយអែងដើរល្បាត តែត្រូវលាក់ព្រាបនេះអោយជិត ។

បុរសនោះក៏ចេញដំណើរទៅយ៉ាងស្ងៀមស្ងាត់ប្រៀបដូចកន្ធាត ។

ដោយពេញចិត្តនឹងអ្វីដែលបានធ្វើរួចហើយនេះ *ចូសិន* ចោលភ្នែកគយគន់មើលភូមិដែលនៅឯខាងក្រោមកូនភ្នំនេះវិញម្ដង ។ ពន្លឺភ្លើងនៅមានឆេះនៅឡើយនៅក្នុងបន្ទាយ និងក្នុងផ្ទះមួយទៀតដែលនៅឯចំហៀងម្ខាងនៃកូនភ្នំ ហើយដែលលោកស្គាល់ថាជាផ្ទះរបស់ *អូមី*។ មានពន្លឺខ្លះទៀតជះចេញពីផ្ទះមួយដែលនៅពីក្រោមផ្ទះ *អូមី* បន្តិចពោលគឺជាផ្ទះដែលមនុស្សចុងស្រុកនោះកំពុងស្នាក់នៅ ។

អាស្មាវ *ណាកា* នេះយល់ត្រូវមែន ។ *ចូសិន* គិតនៅក្នុងចិត្តបណ្ដើរ យកដៃបក់មូសបណ្ដើរ ។ អាមនុស្សចុងស្រុកនេះចំជាមេក្រមីតែម្ដងមែន ។

*************



www.budinst.gov.kh www.elibraryofcambodia.org

- រាត្រីសួស្តី *ភូជីកូ-សាន*។

- រាត្រីសួស្តី *អាន់ជីន-សាន*។

ទ្វារត្រូវបានទាញបិទនៅពេលដែល *ភូជីកូ* ចេញទៅវិញ ។ *ធាក់ថន* ដោះគីម៉ូណូនិងខោខ្លី ចេញហើយពាក់គីម៉ូណូសំរាប់ដេកដែលស្រាលជាងវិញ ។គេបង្អើបមុងរួចចូលទៅប្រាសខ្លួនដេក ។

គេផ្លុំពន្លត់ភ្លើងទៀន ។ ភាពងងឹតសូន្យសុងបានហ៊ុមព័ទ្ធខ្លួនគេជុំជិត ។ ក្នុងផ្ទះទាំងមូល មានភាពស្ងាត់ជ្រងំ ។ បង្អួចបង្អួចត្រូវបិទជិត តែសំលេងសមុទ្រនៅលើឆ្នេរបានរសាត់មកដល់គេបាន ។ នៅឯលើមេឃា ដុំពពកបានបាំងបិទពន្លឺព្រះច័ន្ទ្រាជិតឈឹង ។

សុរា និង សំនើចក្អាកក្អាយបានធ្វើអោយគេមានអារម្មណ៍ស្រើង១ ហើយគេក៏បណ្តោយអារម្មណ៍គេ អណ្តែតត្រសែតទៅតាមសំលេងរលកសមុទ្រ ដែលបោកផ្ទប់ច្រាំងនេះ ។ ស្មារតីគេហាក់ដូចទៅក្នុងស្រទាប់អ័ព្ទយ៉ាងក្រាស់ដូចនោះដែរ យូរ១ម្តងសំលេងឆ្កែព្រុសលាន់ស្ងួរ ល្វើយ១ពីក្នុងភូមិដែលនៅឯជើងកូនភ្នំ។ អញគួរតែមានឆ្កែមួយ -គេគិតនៅក្នុងចិត្តដោយនឹកឃើញឆ្កែដែលគេមាននៅឯផ្ទះ។ មិនដឹងជាឆ្កែនោះនៅរស់ រឺ ស្លាប់ ហ្ន៎ ? ឆ្កែនោះមានឈ្មោះក្រុក តែកូនប្រុសរបស់គេឈ្មោះ *ទូន៉ុរ* តែងហៅវាថា ˝ អុក១ ˝ទៅវិញ។

ហ៊ឺ១ *ទូន៉ុរ* និងពូកស្រី១ទាំងឡាយអើយ ។ រឿងទាំងនោះហាក់ដូចជាកន្លងមកជាយូរណាស់ហើយអញ្ចឹង ។ សង្ឃឹមថាថ្ងៃណាមួយខ្ញុំនឹងបានជួបអ្នកទាំងអស់គ្នាវិញ ។ រឺក៏សង្ឃឹមថាយ៉ាងហោចណាស់បានសរសេរសំបុត្រផ្ញើទៅផ្ទះផងទៅចុះ។ គិតមើល -គេគិតនៅក្នុងចិត្ត -តើអញគួរចាប់ផ្តើមសរសេរពីរឿងអីអញ្ចេះ ?

˝អូនសំលាញ់ : នេះជាសំបុត្រទីមួយហើយដែលបងអាចមានលទ្ធភាពផ្ញើមកផ្ទះបានតាំងពីពួកយើងបានឡើងច្រាំងនៅប្រទេសជប៉ុនមក។ អ្វី១ក៏បានស្រួលបួលដែរទេតាំងពីបងចេះរស់នៅតាមបែបបទពួកគេមកម្លបតឹយ៉ាប់មែនទែន តែយប់មិញនេះបងបានមាន់ទោមួយទទួលទានហើយបន្តិចទៀតនេះបងនឹងបានសំពៅមកវិញហើយ។ តើអោយបងចាប់ផ្តើមរៀបរាប់រឿងរ៉ាវបងពីកន្លែងណាទៅ ? សព្វថ្ងៃនេះ បងប្រៀបដូចជាស្តេចគ្រាញ់សក្តិភូមិនៅក្នុងប្រទេសដ៏ចំលែកនេះអញ្ចឹង។ បងមានផ្ទះមួយ មានសេះ មានអ្នកបំរើប្រាំបីនាក់ មានអ្នកថែផ្ទះមានជាងកាត់សក់



www.budinst.gov.kh www.elibraryofcambodia.org

និងអ្នកបកប្រែផ្ទាល់ខ្លួន។ អីលូវនេះ បងកាត់កោរស្អាតបាតហើយបងកោរពុកមាត់ជារៀងរាល់ថ្ងៃ ។ បងយល់ថាដែកកាំបិតកោរដែលពួកជប៉ុនផលិតនៅទីនេះគឺពិតជាដែកថែបល្អលើគេមួយក្នុងលោកនេះ ។បងមានប្រាក់បំនាច់ច្រើនសំបើម ។ គឺគ្រប់នឹងចិញ្ចឹមគ្រួសារជប៉ុនចំនួនពីររយហាសិបគ្រួរបានក្នុងរយៈពេលមួយឆ្នាំ ។ នៅអង់គ្លេសវិញនេះគឺស្មើនឹងទឹកប្រាក់ចំនួនប្រហែលមួយពាន់គីនេមាសក្នុងមួយឆ្នាំហើយ ! ពោលគឺស្មើនឹងប្រាក់ខែដែលបងបានពីក្រុមហ៊ុនហូឡង់ចំនួនដប់ដង.......” ។

សន្លឹកទ្វារត្រូវបានរុញទៅម្ខាង។ ដៃរបស់ *ប្លាក់ថន* រាវស្រវាកាន់កាំភ្លើងខ្លីដែលនៅពីក្រោមខ្នើយ ទន្ទឹមនោះគឺគេរំកិលខ្លួនទៅម្ខាងត្រៀមខ្លួនជាស្រេច។ នៅពេលនោះគេស្តាប់លឺនូវសំលេងក្រណាត់សូតដែលកកិតគ្នាយ៉ាងស្រាល១ហើយច្រមុះគេក៏ធំក្លិនគ្រឿងក្រអូបភាយ១។

- *អាន់ជីន-សាន* ? -សំលេងខ្សិបមួយពោរពេញដោយក្តីសន្សាបានលាន់លឺឡើង ។

- *រ៉ៃហ* ?

គេឆ្លើយតបយ៉ាងស្រាលដោយប្រឹងបើកភ្នែកសំលឹងទំលុះភាពងងឹតនៃរាត្រី ។

ស្នូរជើងបានរសាត់មកកាន់តែជិត។ ស្នូរលុតជង្គង់បានលាន់នៅក្បែរខ្លួនគេ។ ស្បៃមុងត្រូវបានសើយឡើងហើយនារីម្នាក់ក៏បានចូលមកក្នុងមុងជាមួយនឹងរូបគេ។ នាងទាញដៃគេដាក់លើដើមទ្រូងនាង រួចអូសបង្អូសទៅលើបបូរមាត់នាង។

- *ម៉ារីកូ-សាន* ?

នៅក្នុងភាពងងឹត ម្រាមដៃត្រូវបានលើកដាក់លើបបូរមាត់គេភ្លាមជាសញ្ញាអោយរក្សាស្ងៀមស្ងាត់។ គេងក់ក្បាលយល់ពីភាពប្រថុយប្រថាននៃស្ថានភាពរបស់គេ។ ដៃគេម្ខាងស្រវាអោបនាងហើយដៃម្ខាងទៀតគេស្រវាអង្អែលមុខនាងក្នុងស្បៃងងឹត។ នាងថើបម្រាមដៃគេមួយ១ ។សក់នាងត្រូវបានរំសាយ ហើយធ្លាក់រហូតដល់ចង្កេះ។

ក្លិននាងមានភាពប្រហើរ។ គេជញ្ជក់មាត់នាង ខាំញ្ចេញត្រចៀកនាង ហើយនឹងគ្រប់ទីកន្លែងនៃខ្លួនប្រាណនាង។ នាងបន្ធូរអាវរ៉ូបរបស់នាងហើយប្រះខ្លួនគេងក្បែរខ្លួនគេ ក្នុងជង្រុំមដ៏សែនល្ងឹងល្ងើយ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៣៣

*ប្លាក់ថន* ភ្ញាក់ពីដំណេកនៅពេលព្រឹកព្រលឹម ។ ភ្ញាក់ពីដំណេកតែម្នាក់ឯង ។ ដំបូងគេជឿជាក់ថាគេយល់សប្តិតែប៉ុណ្ណោះ ប៉ុន្តែក្លិនក្រអូបរបស់នាងដែលនៅតែជាមជាប់នោះបានធ្វើអោយគេដឹងថាអ្វីៗដែលបានកើតឡើងពីយប់មិញនោះមិនមែនជាការយល់សប្តិឡើយ ។

ស្នូរគោះទ្វារយ៉ាងស្រាលមួយបានលាន់ឡើង ។

- *វែហ?*

- *អូហៃយ៉ូ អាន់ជីន-សាន។ គូមែនណាសៃ*។

នារីអ្នកបំរើរុញទ្វារទៅម្ខាងដើម្បីអោយ *គូជីកូ* ចូល ។ នាងកាន់ថាសមួយដែលមានទឹកតែ បបរស និង នំ ចូលមកជាមួយផង ។ *ប្លាក់ថន* តបទៅវិញដោយឆ្ងៀតអរគុណនាងផង :

- *អូហៃយ៉ូ គូជីកូ-សាន។ ដូម៉ូ*។

ជារៀងរាល់ពេល *គូជីកូ* តែងយកម្ហូបពេលព្រឹកមកអោយគេដោយផ្ទាល់ដៃ ។ នាងតែងបើកមុងអោយហើយតែងនៅអង្គុយចាំរហូតដល់គេស្រស់ស្រូបរួច ។ នារីបំរើបានយកគីម៉ូណូ និង ទ្រនាប់ថ្មីមករៀបចំទុកដាក់អោយជាស្រេច ។

*ប្លាក់ថន* ចិបតែបណ្តើរ ដណ្តឹងសួរនៅក្នុងចិត្តបណ្តើរថាតើ *គូជីកូ* ដឹងពីរឿងរ៉ាវដែលកើតឡើងកាលពីយប់ម៉្សិលនោះរឺក៏អត់ ព្រោះទឹកមុខនាងឥតមានបង្ហាញអ្វីទាំងអស់ ។ គេសួរទៅនាង :

- *អ៊ីកាកា ដេស៊ូ កា?* នាងសុខសប្បាយទេ ?

- *អូកាកា សាម៉ា ដេ កិនគី ដេស៊ូ អាន់ជីន-សាន។ អាណាកាតាវ៉ា?* សុខសប្បាយ ។ សូមអរគុណ ចុះលោក ?

- *អាណាកាតា វ៉ា យ៉ូគូ នេមុរ្តា កា?* នាងគេងលក់ស្រួលបួលទេរឺ ?

- *វែហ អាន់ជីន-សាន។ អារីកាតូ គូសាំម៉ាស៊ីតា* !-នាងញញឹមហើយយកដៃដាក់លើក្បាល ធ្វើសញ្ញាថាឈឺ ព្រមទាំងកាយវិការស្រវឹង និង លក់លង់ដូចអង្កត់អុស - *អាណាកាតា វ៉ា?*

- *វ៉ាតាស៊ី យូគូ នេមួរ* - ខ្ញុំគេងស្រួលមែនទែន ។



www.budinst.gov.kh www.elibraryofcambodia.org

នាងកែតេភ្លាម ៖

*- ភិតាស៊ី ភា យ៉ូតូ នេមុត្តា។*

*- ដូម៉ូ។ ភិតាស៊ី ភា យ៉ូតូ នេមុត្តា។*

*- យ៉យ ! តែហិនយ៉យ* ! ល្អ ! ល្អណាស់ !

សំលេង *ម៉ារីកូ* លាន់ឡើងនៅឯរបៀង ៖

*- ហៃ ម៉ារីកូ-សាន ?*

*ភូជីកូ* ឆ្លើយតបហើយក៏ងើបទៅទាញទ្វារក្រោក ។ គេមើលមិនឃើញ *ម៉ារីកូ* ទេ ហើយគេក៏ស្តាប់មិនយល់ថាតើនារីទាំងពីរនាក់និយាយពីរឿងអ្វីដែរ ។

សង្ឃឹមថាគ្មានអ្នកណាដឹងរឿងនេះ ។ គេគិតនៅក្នុងចិត្ត ។ សូមបន់អោយរឿងនេះជារឿងសំងាត់ទៅចុះ ។ អោយដឹងតែយើងពីរនាក់ប៉ុននោះ ។ បើសិនជារឿងនេះជាការយល់សប្តិនោះប្រហែលជាល្អទេវិញទេមើលទៅ ។

គេចាប់ផ្តើមស្លៀកពាក់ ។ *ភូជីកូ* មកលុតជង្គង់ជួយស្លៀកពាក់អោយគេ ។

*- ម៉ារីកូ-សាន ? ណាន ចា ?*

*- ណានេ មូ អាន់ជីន-សាន* -នាងឆ្លើយតប -គ្មានអីសំខាន់ទេ ។

រួចនាងដើរតំរង់ទៅ *តាកូណាម៉ា* ពោលគឺកូនបន្ទប់មួយដែលមានលំអដោយបេផ្កា និងផ្ទាំងអក្សរមួយព្យួរនៅនឹងជញ្ជាំង ។ ដាវរបស់ *ត្លាក់ថន* តែងទុកនៅទីនោះជានិច្ច ។ នាងយកដាវនេះប្រគល់ទៅអោយ *ត្លាក់ថន* ដែលទទួលយកទៅស៊កនឹងខ្សែក្រវាត់របស់ខ្លួន ។ អីលូវនេះគេមិនមានអារម្មណ៍ថាស្តាយដាវនេះទៅវាដូចជាត្លុកល្ងោនទៀតហើយ តែទោះជាយ៉ាងនេះក្តីគេមានបំនងអោយអារម្មណ៍របស់គេលែងដោតទៅលើរឿងដាវនេះតែម្តង ។

*ភូជីកូ* បានដំណាលប្រាប់គេថា ឪពុកនាងបានទទួលដាវទាំងពីរនេះអាស្រ័យដោយសេចក្តីអង់អាចក្លាហានរបស់លោកនៅក្នុងការប្រយុទ្ធស៊ីសាច់ហុតឈាមមួយ នៅតំបន់ភាគខាងជើងបំផុតនៃប្រទេសកូរ៉េ នាពេលវាយលុកប្រទេសនេះដំបូងកាលពីប្រាំពីរឆ្នាំមុននេះ ។ កងទ័ពជប៉ុននៅពេលនោះ បានរាតត្បាតប្រកបដោយជោគជ័យលើប្រទេសកូរ៉េតំរង់ទៅភាគខាងជើង ។ នៅ



www.budinst.gov.kh www.elibraryofcambodia.org

ពេលដែលពួកគេបានទៅជិតដល់ទន្លេ *យ៉ាលូ* ហើយនោះ ស្រាប់តែទ័ពចិនបានលេចមុខឆ្លងកាត់ព្រំដែនដូចទឹកបាក់ទំនប់មកចូលរួមប្រយុទ្ធតទល់នឹងទ័ពជប៉ុន ហើយអាស្រ័យដោយចំនួនដ៏ច្រើននៃទ័ពរបស់ខ្លួនក៏បានវាយកងទ័ពជប៉ុនអោយបរាជ័យទៅ។ ឪពុក *ភូជីកូ* ពេលនោះគឺស្ថិតនៅក្នុងទ័ពផ្នែកក្រោយ ដែលមានភារកិច្ចការពារការដកថយរបស់ទ័ពធំតំរង់ទៅរកភ្នំទាំងឡាយដែលនៅភាគខាងជើងទីក្រុងសេអ៊ូល។ នៅតំបន់ភ្នំនោះទ័ពជប៉ុនបានវាយបកត្រលប់វិញហើយក៏ស្ថិតក្នុងស្ថានភាពមិនឈ្នះមិនចាញ់ត្រង់កន្លែងនោះទៅ។ ការវាយលុកប្រទេសកូរ៉េលើកនោះ និងលើកទីពីរមកទៀតគឺជាបេសនកម្ម ( expedition ) យោធាដែលត្រូវបង់ថ្លៃខ្ពស់បំផុតមិនដែលធ្លាប់មាន។ នៅពេលដែលលោកម្ចាស់ *តៃកូ* បានទទួលអានិច្ចកម្មកាលពីឆ្នាំទៅនេះ *តូរ៉ាណាកា* ក្នុងនាមក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ បានបញ្ជាអោយកងទ័ពដែលនៅសល់ទាំងប៉ុន្មានវិលត្រលប់មកស្រុកវិញជាបន្ទាន់ ធ្វើអោយពួក *ដៃមីញ៉ូ* ភាគច្រើនដែលស្អប់ការធ្វើសង្គ្រាមនៅកូរ៉េនោះធូរទ្រូងសន្ធឹក។

*ប្លាក់ថន* ដើរចេញទៅឈរនៅលើរានហាល។ គេងក់ក្បាលដាក់អ្នកបំរើទាំងប៉ុន្មានរបស់គេដែលបានឈរជាជួរត្រង់ភ្លឹងដើម្បីជូនដំណើរគេដូចសព្វដង។ បរិយាកាសថ្ងៃនេះហាក់ដូចជាមិនស្រលះសោះ។ មេឃមានពពកដេរដាស ខ្យល់ក្តៅសើមបានបក់មកពីខាងសមុទ្រ។ ថ្មក្រាលទាំងឡាយនៅតាមផ្លូវធ្វើដំណើរសុទ្ធតែសើមជោក ដោយទឹកភ្លៀងដែលបានធ្លាក់កាលពីយប់មិញនេះ។

នៅឯមាត់ទ្វាររបងមានសេះ ហើយនឹងពួកសាមូរ៉ៃទាំងដប់សំរាប់អមដំណើរគេ។ ហើយនឹង *ម៉ារីកូ*។

នាងនៅអង្គុយលើខ្នងសេះហើយជាស្រេច។ ខ្លួននាងគ្របដណ្តប់ដោយក្រណាត់ពណ៌លឿងខ្ចីមួយ។ នាងស្លៀកខោពណ៌បៃតងខ្ចី ពាក់មួកហាមធំមួយដែលមានខ្សែចងពណ៌លឿង។ ដៃនាងទាំងពីរពាក់ស្រោមដៃជិត ។ ឆ័ត្រមួយត្រូវបានសៀតហើយស្រេចនៅនឹងថង់កែបសេះរបស់នាង។ *ប្លាក់ថន* និយាយដោយសំដីផ្លូវការ :

- *អូហាយ៉ូ*។ *អូហាយ៉ូ ម៉ារីកូ-សាន*។



www.budinst.gov.kh www.elibraryofcambodia.org

- *អូហាយ៉ូ អាន់ជីន-សាន។ អ៊ីកាកា ដេស៊ូ កា?*

- *អូកាកេសាម៉ា ដេ គិនគី ដេស៊ូ ។ អាណាតាវ៉ា?*

នាងញញឹម :

- *យ៉ូគី អារីកាតូ កូសៃម៉ាស៊ីតា។*

នាងឥតបង្ហាញអោយឃើញថាមានអ្វីខុសប្លែករវាងពួកគេទាំងពីរនាក់ឡើយ ។ តែគេក៏ឥតនឹកថានឹងមានសញ្ញាអ្វីនឹងត្រូវបង្ហាញចេញអោយឃើញក៏ទេដែរ ។ជាពិសេសនៅកណ្តាលវាលមុខគេមុខឯងយ៉ាងនេះ ព្រោះស្ថានភាពពួកគេកំពុងស្ថិតក្នុងគ្រោះថ្នាក់បំផុត ។ ក្លិនក្រអូបរបស់នាងនៅជាប់នឹងច្រមុះគេនៅឡើយហើយគេសែនចង់ថើបនាងជាពន់ពេក ។គឺថើបនៅទីនេះតែម្តង ។ នៅមុខអ្នកផងទាំងពួងនេះឯង ។

- *អ៊ីតឺម៉ាស៊ូ!*

គេនិយាយតបហើយលោតឡើងផែលសេះរបស់គេ ហើយធ្វើសញ្ញាអោយពួកសាមូរ៉ៃចេញដំណើរនាំមុខ ។ គេបណ្តោយសេះអោយដើរត្រឹក១យ៉ាងរំភើយ ដោយមាន *ម៉ារីកូ* នៅជាប់ពីក្រោយគេ ។ពេលដែលអ្នកឯទៀតដាច់ចេញឆ្ងាយហើយ ទើប *ព្លាក់ថន* មានអារម្មណ៍ចូរទ្រូងបន្តិច :

- *ម៉ារីកូ*។

- ហៃ?

គេនិយាយជាភាសាឡាតាំង :

- នាងស្អាតណាស់ហើយខ្ញុំស្រលាញ់នាង ។

- សូមអរគុណ លោក ។ តែដោយទទួលទានស្រាពីម្សិលមិញច្រើនពេកធ្វើអោយខ្ញុំមិនមានអារម្មណ៍ថាស្អាតអីត្រង់ណាសោះហើយ ។ ឯពាក្យ ស្រលាញ់ គឺជាពាក្យអ្នកកាន់សាសនាគ្រិស្តហើយ ។

- នាងស្អាត ហើយជាគ្រីស្តសាសនិកទៀត ។ សុរាមិនអាចធ្វើបាបនាងបានទេ ។

- អរគុណចំពោះការកុហកនេះ *អាន់ជីន-សាន*។ សូមអរគុណ ។



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ខ្ញុំត្រូវតែអរគុណនាងវិញទេទើបត្រូវ ។

- អូហ៎ ? ហេតុអីទៅ ?

- មិនត្រូវសួរថា " ហេតុអី " ទេ ។ គ្មាន "ហេតុអី " ទេ ។ ខ្ញុំសូមអរគុណនាងយ៉ាងស្មោះអស់ពីដួងចិត្ត ។

*ម៉ារីកូ* តប :

- បើសិនជាស្រា ហើយនឹង សាច់ ធ្វើអោយលោកមានភាពកក់ក្ដៅ និងចេះគួរសមយ៉ាងនេះ ខ្ញុំនឹងអោយកំនាន់លោកជ្រែកមេឃជ្រែកដីដើម្បីរកវាមកជូនលោករាល់យប់តែម្ដង ។

- ពិតហើយ ។ ខ្ញុំនឹងបានអ្វីៗសព្វគ្រប់ដដែល ។ បានជារៀងរហូត ។

- លោកហាក់ដូចជារីករាយលើសសព្វដងនៅថ្ងៃនេះ ។ គឺល្អមែនទែន ។ តែ តើមកពីហេតុអីទៅ ?

- គឺដោយសារនាងណឹង ណាំ ។ នាងដឹងថាហេតុអីហើយតើ ។

- ខ្ញុំឥតដឹងរឿងអីទាំងអស់ណឹង *អាន់ជីន-សាន*។

- អត់ដឹងអីទាំងអស់មែន ? -*ក្វាក់ថន* ចាក់ចុចនាងលេង ។

- អត់ដឹងអីទាំងអស់មែន ។

ដល់ពេល *ក្វាក់ថន* ភ្ញាក់ផ្អើលម្ដងវិញហើយ ។ ពួកគេនៅតែពីរនាក់ប្រកបដោយសុវត្ថិភាពទេតើ *ម៉ារីកូ* សួរ :

- ហេតុអីបានជាពាក្យ " អត់ដឹងអីទាំងអស់ " មួយម៉ាត់នេះ ធ្វើអោយលោកញញឹមលែងសមអស់អញ្ចឹង ?

- ល្ងីល្ងើ ! ចំជាល្ងីល្ងើមែន ! អញភ្លេចគិតពីរឿងត្រូវប្រយ័ត្នប្រយែងអោយឈឹង ។ អញគ្រាន់តែចង់ចង់និយាយពីរឿងនេះ ដោយឃើញថានៅស្ងាត់តែពីរនាក់ ។ មែនទែនទៅ អញចង់និយាយច្រើនពីរឿងនេះ ។

- លោកនិយាយសុទ្ធតែប្រស្នាតែម្ដង ។ ខ្ញុំស្ដាប់លោកមិនយល់ទេ ។

ជាថ្មីម្ដងទៀត គេហាក់ដូចជាវង្វេងស៊ុងតែម្ដង :



www.budinst.gov.kh www.elibraryofcambodia.org

- នាងមិនចង់និយាយពីរឿងណុងទេ ? មិនចង់តែម្ដង អ្វី ?

- រឿងអី *អាន់ជីន-សាន* ?

- ពីរឿងយប់មិញនោះ ណា ។

- យប់មិញខ្ញុំដើរកាត់មុខទ្វាររបស់លោកពេលដែលលោកកំពុងនៅជាមួយនាង *កយ* បំរើរបស់ខ្ញុំ ។

- ថាម៉េច ?

-ពួកយើង ពោលគឺកំនាន់លោកនិងខ្ញុំ គិតថានាងជាជំនួនជាទីរីករាយមួយសំរាប់លោក ។ លោកពេញចិត្តនាង មែនទេ ?

*ប្លាក់ថន* ប្រឹងប្រមែប្រមូលស្មារតីទាំងអស់របស់ខ្លួនឡើងវិញ ។ នារីបំរើរបស់ *ម៉ារីកូ* ពិតជាមានកំពស់កំពរដូចនាងមែនតែនាងនៅក្មេងជាង និងមិនមានសំរស់ និងសាច់សដូច *ម៉ារីកូ* ទេ ។ តែយប់មិញគឺចំជាងងឹតឈ្លប់ហើយគេក៏ស្រវឹងជោគណាស់ទៅផង ។ តែទេ គឺមិនមែននារីបំរើនោះទេ ។ គេនិយាយជាភាសាប៊កទុយកាល់ :

- ទេ មិនអាចទៅជាយ៉ាងហ្នឹងកើតទេ ។

នាងសួរតបវិញក្នុងភាសាដដែល

- អ្វីដែលមិនអាចទៅជាយ៉ាងហ្នឹងនោះ ?

គេបែរមកនិយាយជាភាសាឡាតាំងវិញដោយថាក្រុមសេះដែលចេញមកមុននេះ នៅមិនឆ្ងាយពីពួកគេទាំងពីរនាក់ទេ ហើយពួកទាំងនោះនៅពីក្រោមខ្យល់ថែមទៀតផង :

- សូមមេត្តាកុំលេងជាមួយខ្ញុំអី ។ គ្មានអ្នកណាលឺយើងនិយាយនេះទេ ។ ខ្ញុំដឹងពីវត្តមានហើយនឹងក្លិនក្រអូបរបស់នាង ។

- លោកគិតថាជារូបខ្ញុំ មែនទេ ? អូទេ *អាន់ជីន-សាន* ។ នោះពិតជាកិត្តិយសរបស់ខ្ញុំណាស់ តែខ្ញុំមិនអាច....ទោះជាចិត្តខ្ញុំចង់យ៉ាងណាក្ដី ។ ទេ *អាន់ជីន-សាន* ។ មិនមែនខ្ញុំទេ តែគឺនាង *កយ* នារីបំរើរបស់ខ្ញុំទេ ។ បើសិនជារូបខ្ញុំមែន នោះគឺពិតជាកិត្តិយសណាស់ តែខ្ញុំជារបស់អ្នកផ្សេងទោះជាអ្នកនោះបាត់បង់ជីវិតហើយក្ដី ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិតហើយ តែយប់មិញមិនមែនជានារីបំរើនោះទេ -គេលេបកំហឹងរបស់គេ -តែឈប់និយាយរឿងនេះតាមចិត្តនាងចុះ ។

- យប់មិញ គឺពិតជានារីបំរើខ្ញុំមែន *អាន់ជីន-សាន* -នាងនិយាយលួងលោមគេ -ពួកយើងបានលាបគ្រឿងក្រអូបរបស់ខ្ញុំអោយនាងហើយបានណែនាំនាងមិនអោយនិយាយស្តីអ្វីទាំងអស់គឺប្រើតែដៃបានហើយ ។ ពួកយើងឥតមានបានគិតបន្តិចណាឡើយថាលោកនឹងច្រលំថាជារូបខ្ញុំនោះ ! នេះមិនមែនមានន័យថាពួកយើងចង់បោកប្រាស់លោកនេះទេ តែពួកយើងដឹងថាលោកនៅមានការលំបាកក្នុងការនិយាយពីរឿងខ្វល់ខ្វាយនេះនៅឡើយ -នាងសំលឹងមើលគេក្នុងក្រសែភ្នែកយ៉ាងស្មោះត្រង់ -នាងបានធ្វើអោយលោករីករាយនៅក្នុងចិត្តទេ ? លោកវិញ លោកបានអោយនាងមានការរីករាយណាស់ ។

- ការកំប្លែងលេងចំពោះរឿងសំខាន់យ៉ាងណឹង រកសើចមិនឃើញទេ ។

- រឿងសំខាន់ជានិច្ចកាលត្រូវដោះស្រាយជាសំខាន់ ។ តែពេលយប់ នារីបំរើម្នាក់នៅជាមួយបុរសម្នាក់ មិនមែនជារឿងសំខាន់ទេ ។

- ខ្ញុំមិនចាត់ទុករឿងនេះជារឿងគ្មានសារសំខាន់នោះទេ ។

- សូមអរគុណ លោក ។ ខ្ញុំក៏គិតដូចលោកដែរ ។ តែនារីបំរើម្នាក់នៅជាមួយបុរសម្នាក់នៅពេលយប់ ជារឿងឯកជន ហើយមិនមានសារសំខាន់អីទេ ។ នេះជាជំនួនរបស់នាងជូនបុរសនោះហើយជួនកាលគឺជាជំនួនបុរសនោះជូននាងផងដែរ គឺគ្មានអីក្រៅពីនេះទៀតទេ ។

- គ្មានសោះតែម្តង ?

- លើកលែងតែបុរសនិងស្ត្រីនោះរួមគ្នាប្រឆាំងនឹងច្បាប់ ។ ***នេះហើយគឺកជីនេះ !***

*ប្លាក់ថន* បន្ថយល្បឿនសេះ ទីបំផុតគេបានយល់ពីមូលហេតុនៃការប្រកែករបស់នាងហើយ ។ គេនិយាយឡើង :

- ខ្ញុំសូមទោស ។ ជាការពិតហើយនាងនិយាយត្រូវមែន គឺខ្ញុំទេដែលខុសនោះ ។ ខ្ញុំមិនគួរលើកនិយាយពីរឿងនេះសោះ ។ អោយខ្ញុំសូមទោសផងទៅចុះ ។

- ហេតុអីបានជាសូមទោស ? សូមទោសរឿងអី ? ប្រាប់ខ្ញុំមើល *អាន់ជីន-សាន* តើ



www.budinst.gov.kh www.elibraryofcambodia.org

នារីនោះមានពាក់ព្រះឆ្លាងទេ ?

- ទេ ។

- ខ្ញុំតែងពាក់ព្រះឆ្លាងជានិច្ច ។ ជានិច្ច ។

គេតបវិញជាភាសាបិតុខុយកាល់ដោយស្វ័យប្រវត្តិ :

- បន្តោងឆ្លាងនោះអាចដោះចេញបានតើ ។ នេះមិនមែនជាការបញ្ជាក់អ្វីទាំងអស់ ។ អាណឹងនាងក៏អាចអោយនារីនោះខ្ចីដូចជាគ្រឿងក្រអូបរបស់នាងអញ្ចឹង ។

- សូមប្រាប់ការពិតជាចុងក្រោយមកខ្ញុំ : តើលោកបានឃើញនាងពិតប្រាកដទេ ? ឃើញពិតមែនទែន ទេ ?

- ពិតណាស់ ។ តែអ្ហើយ បំភ្លេចថាខ្ញុំបាន........

- យប់ងងឹតឈ្លប់ហើយគ្មានពន្លឺខែទៀតផង ។ សូមលោកនិយាយតាមត្រង់ទៅមើល *អាន់ដឹន-សាន* ។ គិតទៅមើល ! តើលោកពិតជាបានឃើញនារីនោះមែន រឺទេ ?

ពិតហើយថាខ្ញុំបានមើលមិនឃើញនាង ។ គេគិតទាំងចិត្តតវ៉ា ។

វិបល់យក៍ ។ គិតមែនទែនទៅ អញអត់បាន *មើល* នាងទេ ។ ក្បាលអញនៅអ័ព្ទដាស់នៅឡើយ ។ នារីនោះអាចជាអ្នកបំរើ តែអញយល់ថា *ម៉ារីកូ* ព្រោះអញចង់បាន *ម៉ារីកូ* ហើយមើលឃើញតែ *ម៉ារីកូ* ប៉ុននោះនៅក្នុងក្បាលឯង ហើយក៏គិតថា *ម៉ារីកូ* ក៏ចង់បានអញដែរ ។ ចំជាឆ្កួតមែន ។ ឆ្កួតកែមិនឡើងតែម្តង ។ គេតប :

- មែនទែន អ្ហ ? មែនទែន ខ្ញុំត្រូវតែសូមទោស ។ តើអោយខ្ញុំសូមទោសដោយរបៀបណាទៅ ?

*ម៉ារីកូ* តបយ៉ាងនឹងនំ :

- មិនចាំបាច់សូមទោសទេ *អាន់ដឹន-សាន* ។ ជាច្រើនលើកហើយដែលខ្ញុំបានជំរាបលោកថា មនុស្សប្រុសមិនសូមទោសជាដាច់ខាត ទោះជាខុសក៏ដោយ -ភ្នែករបស់នាងសំលឹងបែបកំប្លែងលេងជាមួយ ប្លាក់ថន -នារីអ្នកបំរើខ្ញុំមិនចាំបាច់សូមទោសទេ ។

គេតបទាំងសើចក្អាកក្អាយ :



www.budinst.gov.kh www.elibraryofcambodia.org

- សូមអរគុណ ។ នាងធ្វើអោយខ្ញុំមានអារម្មណ៍មិនសូវជាឡប់ប៉ុន្មានទៀត ។

- ពេលលោកសើចអញ្ចឹង ខែឆ្នាំហើរចេញតាមសំនើចលោកអស់តែម្តង ។ *អាន់ជីន-សាន* ដ៏ចាស់ទុំក្លាយជាយុវជនវិញហើយ ។

- ឪពុកខ្ញុំគាត់ថាខ្ញុំកើតមកចាស់តែម្តង ។

- អញ្ចឹងមែន ?

- គាត់យល់ថាអញ្ចឹង ។

- តើគាត់ជាមនុស្សបែបណាទៅ ?

- គាត់ជាមនុស្សល្អណាស់ ។ គាត់ជានាយសំពៅ ជាបញ្ជាការ ។ ពួកអេស្ប៉ាញសំលាប់គាត់នៅកន្លែងមួយឈ្មោះ *អង់វែ* ( Antwerp )( * ) នៅពេលដែលពួកវាចូលកាប់សំលាប់នៅទីនោះ ។ ពួកវាថែមទាំងដុតសំពៅគាត់ចោលខ្ទេចថែមទៀត ។ កាលនោះ ខ្ញុំមានអាយុប្រាំមួយឆ្នាំ តែខ្ញុំចាំបានថាគាត់មានមាឌធំ ខ្ពស់ មានសក់ពណ៌មាស និង ជាមនុស្សមានចរិតល្អ ។ បងប្រុសខ្ញុំឈ្មោះ *អាកុចូ* កាលនោះមានអាយុប្រាំបីឆ្នាំ......ពេលនោះយើងឆ្លងកាត់សម័យកាលមួយដ៏លំបាកវេទនាមែនទែន *ម៉ារីកូ-សាន*។

- ហេតុអីទៅ ? សូមលោកប្រាប់ខ្ញុំផងបានទេ ។

- វាជារឿងធម្មតា ។ លុយមួយកាក់មួយសេនត្រូវចំនាយទៅលើសំពៅនោះ ហើយសំពៅត្រូវបាត់បង់.....ហើយមិនយូរប៉ុន្មានទៀត បងស្រីខ្ញុំក៏ស្លាប់ទៅទៀត ។ ស្លាប់ដោយដាច់ពោះស្លាប់តែម្តង ។ កាលពីឆ្នាំ ៧១ នោះមានទុរ្ភិក្ស ហើយមានរោគរាតត្បាតម្តងទៀត ។

- យើងមានរោគរាតត្បាតម្តងម្កាលដែរ ។ តឹអុតធំ ។ លោកមានបងប្អូនប៉ុន្មាននាក់ ?

- យើងមានគ្នាបីនាក់ - គេពោលតប ទាំងចិត្តរីករាយក្នុងការព្រោកប្រាជ្ញនេះដើម្បីបំភ្លេចចោលនូវការឈឺចាប់ផ្សេងទៀត - បងស្រីខ្ញុំឈ្មោះ *វីល្ម៉ា* គាត់ស្លាប់ទៅក្នុងអាយុប្រាំបួនឆ្នាំ ។ បន្ទាប់មកគឺ *អាកចូ* ។ គាត់ចង់ក្លាយទៅជាសិល្បករ ជាអ្នកចំលាក់ តែដើម្បីចិញ្ចឹមគ្រួសារយើង គាត់ក៏ទៅធ្វើជាកូនជាងដាប់ថ្ម ។គាត់ត្រូវស្លាប់នៅក្នុងកងនាវាចរណ៍ ។ កាលនោះគាត់ទើប

---

*( * ) តំបន់កំពង់ផែមួយនៅក្នុងប្រទេសបែលស៊ិច បច្ចុប្បន្ន ( ក.អ.ប. ) ។*



www.budinst.gov.kh www.elibraryofcambodia.org

មានអាយុម្ភៃប្រាំឆ្នាំ។ គួរអោយអាណិតគាត់ដែរ គាត់ទើបចូលដើរសំពៅទាំងមិនទាន់បានរីកហាត់អីបន្តិច ចំជាអាសារបង់មែន។ ខ្ញុំជាកូនចុងក្រោយនៃត្រកូល *ភ្លាក់ថន* ហើយ។ សព្វថ្ងៃនេះប្រពន្ធនិងកូនរបស់ *អាកធូ* រស់នៅជាមួយប្រពន្ធខ្ញុំ។ ម្តាយខ្ញុំនៅរស់នៅឡើយទេ ហើយជីដូនខ្ញុំឈ្មោះ *យ៉ាកូបា* ក៏អញ្ចឹងដែរ។ ជីដូនខ្ញុំអាយុចិតសិបប្រាំឆ្នាំហើយៗនៅតែមាំដូចស្រល់អង់គ្លេសអញ្ចឹងទោះជាមានកាត់សញ្ញាតិអៀកឡង់ក្តី ។ រីនិយាយថាយ៉ាងហោចណាស់ក៏ពួកគាត់នៅរស់នៅឡើយនៅពេលខ្ញុំចេញសំពៅមកកាលពីជាងពីរឆ្នាំមុននេះ។

ការឈឺចាប់បានវិលត្រលប់មកវិញ ។ អញនឹងនឹកគិតពីពួកគេនៅពេលណាអញចេញដំណើរត្រលប់ទៅស្រុកវិញ -គេសន្យានៅក្នុងចិត្ត ។តែមិនមែននៅពេលនេះទេ។ គេសំលឹងមើលទៅសមុទ្ទ ហើយនិយាយឡើង :

- ស្អែកនេះនឹងមានព្យុះហើយ។ ជាព្យុះខ្លាំងទៅទៀត *ម៉ារីកូ-សាន*។ ហើយបន្ទាប់មកពីនេះបីថ្ងៃយើងនឹងមានមេឃស្រលះល្អ។

- រដូវនេះជារដូវភ្លៀងខ្យល់ សំបូរពពកដេរដាស និងសំបូរភ្លៀង។ ពេលណាអស់ភ្លៀងគឺសើម រួចមាន *វ៉ៃកូន* ទៀត។

អញបន់អោយបានដើរសមុទ្ទទៀត -គេបន់គិតនៅក្នុងចិត្ត ។ តើអញបានចុះសមុទ្ទទៀតរឺអត់ ?តើរឿងសំពៅនោះជារឿងពិតរឺទេ ?អីទៅដែលជាតថភាព នោះ ? *ម៉ារីកូ* រីឯរីអ្នកបំរើ ?

- លោកមិនសូវសើចលេងសប្បាយច្រើនទេ មែនទេ *អាន់ជីន-សាន*?

- ខ្ញុំដើរសមុទ្ទយូរពេលពេក។ អ្នកដើរសមុទ្ទច្រើនតែម៉ត់ចត់។ ពួកយើងរៀនមើលសមុទ្ទ។ យើងតែងតែឃ្លាំមើល និងត្រៀមជានិច្ចចំពោះមុខភ័យន្តរាយទាំងឡាយ។ អ្នកឯងប៉ានត្រលៀសភ្លែកតែមួយវិនាទី សមុទ្ទនេះនឹងច្បាមច្របាច់សំពៅអ្នកឯងអោយទៅជាឈើគូសជាមិនខាន។

នាងតប :

- ខ្ញុំខ្លាចសមុទ្ទណាស់។



www.budinst.gov.kh www.elibraryofcambodia.org

-ខ្ញុំក៏អញ្ចឹងដែរ ។អ្នកនេសាទចាស់ម្នាក់ធ្លាប់បាននិយាយប្រាប់ខ្ញុំថា:"អ្នកណាដែលមិនខ្លាចសមុទ្រនឹងត្រូវលង់ស្លាប់ព្រោះអ្នកនោះចេញទៅសមុទ្រនៅថ្ងៃដែលមិនគួរចេញ ។ ប៉ុន្តែពួកយើងខ្លាចសមុទ្រដូចនេះពួកយើងលង់ទឹកម្តងម្កាលតែប៉ុណ្ណោះ"-គេសំលឹងមើលមុខនាង- *ម៉ារីក្ខ-សាន*..

- ចាស ?

- ប៉ុន្មាននាទីមុននេះ នាងបានធ្វើអោយខ្ញុំជឿថា....ទេ ថាតើខ្ញុំជឿនៅក្នុងចិត្ត ។ តែអីលូវនេះអត់ទេវិញ ។ តើឯណាទៅការពិត ? ការ *ហុនតូ* ? ខ្ញុំត្រូវតែដឹងរឿងនេះ ។

- ត្រចៀកសំរាប់ស្តាប់ណាលោក ។ ពិតហើយថាតើជានារីបំរើ ។

- នារីនោះ ។ តើខ្ញុំអាចហៅរកនាងបាននៅពេលណាដែលខ្ញុំត្រូវការវីទេ ?

- ពិតហើយ ។ មនុស្សវាងវៃមិនដែលថាមិនហៅទេ ។

- ពីព្រោះថាខ្ញុំអាចខកចិត្ត ? នៅពេលក្រោយ ?

- អាចដែរ ។

- ចំពោះខ្ញុំគឺជាការលំបាកដែលបាននារីបំរើម្នាក់រួចបាត់បង់នាងទេវិញ ។ គឺជាការលំបាកណាស់ដែលមិននិយាយអីទាំងអស់នោះ......

- ការរួមរ័ក្សគឺជាការរីករាយ ។ ជាការរីករាយនៃសរីរាង្គកាយ ។ គ្មានអ្វីដែលត្រូវនិយាយនោះទេ ។

-តែតើធ្វើម៉េចខ្ញុំអាចនិយាយប្រាប់នារីបំរើថានាងស្អាតទៅបាន ?ថាខ្ញុំស្រលាញ់នាង ? ថានាងបានបំពេញអារម្មណ៍រំភើបរីករាយដល់ខ្ញុំបាន ?

- ស្រលាញ់នារីបំរើបែបនេះមិនត្រូវទំនងទេ ។ មិនត្រូវតាមរបៀបរបបស្រុកនេះទេ *អាន់ជីន-សាន*។ ទឹកចិត្តស្រើបស្រាលបែបនេះក៏មិនសមទំនងសំរាប់ភរិយា រឺតូកំនាន់ ផងដែរ ។ តែចំពោះអ្នកផ្សេងដូចជា *គីតូ-សាន* ដែលមានរូបស្រស់ជាង និងជំនាញខាងហ្នឹងតែម្តងនោះទើបសមជាង ។

- តើអោយខ្ញុំទៅរកស្រីយ៉ាងហ្នឹងឯណាទៅ ?

- នៅឯភូមិ ។ គឺជាកិត្តិយសរបស់ខ្ញុំណាស់បើសិនជាលោកព្រមអោយខ្ញុំធ្វើជាអ្នកចៃថ្ងៃ



www.budinst.gov.kh www.elibraryofcambodia.org

ជូនលោកនោះ ។

- ព្រះអើយ ! នាងនិយាយមែនទែនតែម្តង ។

- ចាស ពិតហើយ ។ បុរសត្រូវការភាពត្រេកត្រអាលគ្រប់បែបយ៉ាង ។ នារីនោះសម និងបណ្តែតមនោសញ្ចេតនាជាមួយបានអោយតែលោកទ្រោលជាមួយនាងរួច ។

- តើនេះមានន័យថាម៉េច ?

- គឺថានាងស៊ីថ្លៃណាស់ ។

- គេមិនដែលទិញស្នេហាទេ ។ នោះគឺគ្មានន័យអីទាំងអស់ ។ " ស្នេហា " កាត់ថ្លៃមិនបានទេ ។

*ម៉ារីក* ញញឹម :

- ជានិច្ចកាលរឿងរូមរ័ក្សតែងតែមានតំលៃរបស់វា ។ជានិច្ចកាល ។ មិនមែនតែរឿងលុយទាំងអស់នោះទេ *អាន់ដឺន-សាន* ។ តែជានិច្ចកាលបុរសត្រូវតែបង់ថ្លៃទោះមិនដោយបែបនេះក៏ដោយបែបនោះដែរនៅក្នុងរឿងរួមរ័ក្សនេះ ។ ស្នេហាពិតប្រាកដដែលពួកយើងហៅថាភារកិច្ចនោះ គឺជារឿងព្រលឹងនឹងព្រលឹង ហើយក៏មិនចាំបាច់មានការសំដែងអ្វីផ្សេងទៀតដែរ ពោលគឺមិនចាំបាច់រូបភាពសំដែងនោះទេ ប្រហែលលើកលែងតែអំនោយមរណៈប៉ុននោះ ។

- នាងយល់ច្រលំហើយ ។ ខ្ញុំបន់សូមអោយខ្ញុំអាចបង្ហាញនូវពិភពលោកពិតប្រាកដមួយដល់នាង ។

- ខ្ញុំស្គាល់ពិភពលោករបៀបនេះជារៀងដរាបមក ហើយវានឹងនៅតែរបៀបនេះជារៀងរហូត ។ លោកនៅចង់បានស្រីបំរើ ដ៏អន់នេះ ទៀត រឺ ?

- ពិតមែន ។ នាងដឹងទេថាខ្ញុំ.........

*ម៉ារីក* សើចយ៉ាងរីករាយ :

- អញ្ចឹងពួកយើងនឹងបញ្ជូននាងទៅជូនលោក ។ នៅវេលាថ្ងៃលិច ។ *កូជីកូ* និងខ្ញុំ នឹងជូននាងទៅ !

*ក្លាក់ថន* ផ្ទុះសំនើចតាមនាង :



www.budinst.gov.kh www.elibraryofcambodia.org

- ចង្រៃយក៍ ! ខ្ញុំក៏គិតថានាងនឹងធ្វើយ៉ាងដូចនោះដែរ ។

- អ្ហា *អាន់ជីន-សាន* គឺជាការរីករាយណាស់ ដែលឃើញលោកសើចសប្បាយយ៉ាងនេះ ។ តាំងពីលោកវិលត្រលប់មក *អាន់ជ្វី* វិញលើកនេះ លោកមានការផ្លាស់ប្តូរច្រើនណាស់ ។ ផ្លាស់ប្តូរច្រើនមែនទែន ។

- ទេ មិនច្រើនប៉ុន្មានទេ ។ តែយប់មិញនេះ ខ្ញុំបានយល់សប្តិឃើញសប្តិមួយ ។ សប្តិនោះគឺសុក្រិត ។

- ព្រះជាម្ចាស់គឺសុក្រិត ។ ហើយជូនកាលអរុណោទ័យ រឺពេលច័ន្ទរះ រឺ ពេលផ្ការីកដើមឆ្នាំក៏ជាសុក្រិតភាពផងដែរ ។

- ខ្ញុំមិនយល់នាងសោះតែម្តង ។

*ម៉ារីកូ* ផាត់ស្បៃទៅខាងក្រោយហើយសំលឹងចំភ្នែករបស់ *ប្លាក់ថន* តែម្តង :

- មានម្តងនោះ បុរសម្នាក់បាននិយាយមកកាន់ខ្ញុំថា : " ខ្ញុំមិនយល់នាងសោះតែម្តង " ហើយប្តីខ្ញុំនិយាយថា : " សូមលោកម្ចាស់អាធ្យាស្រ័យផងទៅចុះ តែគ្មានបុរសណាយល់នាងបានទេ ។ ឪពុកនាងមិនយល់នាង ព្រះយើង ព្រះពូកអ្នកចុងស្រុកក៏មិនយល់នាង សូម្បីតែម្តាយរបស់នាងក៏រកយល់ពីនាងមិនឃើញដែរ " ។

- នោះគឺ *តូរ៉ាណាកា* ? លោកម្ចាស់ *តូរ៉ាណាកា* មែនទេ ?

- ទេ មិនមែនទេ *អាន់ជីន-សាន*។ នោះគឺលោកម្ចាស់ *រ៉ែតូ* ។ លោកម្ចាស់ *តូរ៉ាណាកា* យល់ខ្ញុំបាន ។ គាត់យល់សព្វយល់គ្រប់ ។

- យល់ទាំងរូបខ្ញុំដែរ ?

- យល់លោកច្បាស់ណាស់ ។

- នាងច្បាស់លាស់ពីរឿងនេះហើយ មែនទេ ?

- ចាស ច្បាស់ណាស់ ។

- តើគាត់នឹងឈ្នះសង្គ្រាមទេ ?

- ឈ្នះ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំជាអណ្តាប់សំនព្វរបស់គាត់មែន ?

- មែន។

- តើគាត់នឹងយកសំពៅខ្ញុំទេ ?

- យក។

- តើពេលណាខ្ញុំនឹងបានសំពៅខ្ញុំមកវិញ ?

- លោកយកវិញមិនបានទេ។

- ហេតុអី ?

ភាពម៉ឺងម៉ាត់របស់នាងរលាយបាត់អស់ :

- ពីព្រោះលោកមាន " នារីបំរើ "របស់លោកនៅ *អាន់ជ៊ីរ* ហើយលោករូមវ័ក្សច្រើនពេកទាល់តែលោកគ្មានកំលាំងនឹងចាកចេញពីទីនេះទោះជាវ៉ារទៅក៏មិនរួចផង ទោះជានាងអង្វរលោកអោយឡើងសំពៅក្តី ទោះលោកម្ចាស់ *តូរ៉ាណាកា* ស្នើសុំអោយលោក ចុះសំពៅចេញអោយផុតពីពួកយើងក្តី !

- នាងតាំងអញ្ចឹងទៀតហើយ។ ម្តងម៉ឺងម៉ាត់ ម្តងអត់ !

- នេះគឺដើម្បីឆ្លើយតបនឹងលោកទេតើ *អាន់ជីន-សាន*។ ម្យ៉ាងទៀតគឺដើម្បីនិយាយអោយចំៗសេចក្តីតែម្តង។ អូមែន នៅមុនពេលដែលលោកបែកពីពួកយើងទៅលោកគួរជួបអ្នកស្រី *គីតូ* ។ គាត់សមនឹងទទួលបាននូវអារម្មណ៍ត្រេកត្រអាលបំផុតមែន។ គាត់ស្អាតហើយប៉ិនប្រសប់ថែមទៀត។ ដើម្បីសក្តិសមនឹងគាត់លោកទាល់តែអស្ចារ្យណាស់។

- ដល់អញ្ចឹងចង់សាកល្បងដែរ។

- ខ្ញុំគ្មានបំនងអុចអាលសាកល្បងអ្នកណាទេ។ តែបើសិនជាលោកត្រៀមខ្លួនជាសាមូរ៉ៃ ហើយមិនមែន...មិនមែនជាជនបរទេសទេនោះ...បើសិនជាលោកត្រៀមចាត់ទុករឿងរួមវ័ក្សជារឿងមួយតាមបែបជាធម្មតារបស់វ៉ានោះ ខ្ញុំពិតជាមានកិត្តិយសទទួលធ្វើជាអ្នកចែចូវជូន។

- ណឹងមានន័យថាម៉េច ?

- នៅពេលណាដែលលោករីករាយសប្បាយចិត្តហើយ នៅពេលណាដែលលោកត្រៀម



www.budinst.gov.kh www.elibraryofcambodia.org

ទទួលបាននូវការសប្បាយពិសេសហើយ សូមលោកអោយគំនាន់លោកមកហៅខ្ញុំចុះ ។

- ហេតុអី ចាំបាច់ *ភូជីកូ* ?

- ព្រោះនេះជាភារកិច្ចរបស់ស្រីកំនាន់ដែលត្រូវតែដឹងថាលោកសប្បាយ ។ ទំលាប់របស់យើងគឺចូលចិត្តធ្វើអោយជីវិតរស់នៅបានក្នុងភាពងាយស្រួលធម្មតា ។ យើងទទួលស្គាល់ពីភាពសាមញ្ញ ដើម្បី ***នារីខ្ទួស នារីខ្វស៊ី*** អាចរួមរ័ក្សក្នុងបំនងពិតប្រាកដរបស់វា នោះគឺពិតមែនតែការរួមរ័ក្សជាផ្នែកមួយដ៏សំខាន់នៃជីវិតរស់នៅក្តី តែរវាងបុរសនឹងនារីមានអ្វីដែលសំខាន់ជាងនេះទៅទៀត ។ ដូចជាសុភាពរាបសារ ការគោរព ភារកិច្ច ជាដើម ។ រឺដូចជា " សេចក្តីស្នេហា របស់លោកជាដើម ។ *ភូជីកូ* " ស្រលាញ់លោក ណាំ " ។

- ទេ នាងអត់ស្រលាញ់ខ្ញុំទេ ។

-នាងហ៊ានប្តូរជីវិតនាងសំរាប់លោក តើមានអ្វីដែលត្រូវអោយលើសពីនេះទៅទៀត ?

នៅទីបំផុត គេត្រូវដកភ្នែកគេចេញពីនាងហើយបែរទៅសំលឹងមើលទឹកសមុទ្រវិញ ។ រលកកំពុងរុញពូនឆ្នេរខ្សាច់ក្នុងពេលដែលខ្យល់ចាប់ផ្តើមត្រជាក់ ។ រួចគេងាកមុខមករកនាងជាថ្មីម្តងទៀតដោយបន្លឺសំនួរ :

- បើអញ្ចឹងអត់មានអ្វីដែលត្រូវនិយាយទៀតទេរឺ ? រវាងយើងទាំងពីរនាក់ ?

- គ្មានទេ ។ នេះគឺវាងវៃបំផុត ។

- ចុះបើខ្ញុំមិនឯកភាព ?

- លោកត្រូវតែឯកភាព ។ លោកកំពុងនៅទីនេះ ហើយទីនេះជាទ្រនំរបស់លោក ។

*************

ពួកវាយលុកទាំងប្រាំរយ បំផាយសេះទាំងច្របូកច្របល់ចុះពីលើទីទួលសំដៅទៅជ្រលងភ្នំពោរពេញដោយថ្មរដិបរដុបដែលនៅទីនោះ "ពួកការពារ" ចំនួនពីរពាន់នាក់កំពុងត្រៀមចាំក្នុងលក្ខណៈប្រយុទ្ធហើយស្រេច ។ ពួកទ័ពសេះម្នាក់ៗ សុទ្ធតែមានស្ពាយកាំភ្លើងមួស្គេមួយ



www.budinst.gov.kh www.elibraryofcambodia.org

ដើមនៅក្រោយខ្លួង ឯនៅចង្កេះសុទ្ធតែមានថង់គ្រាប់ ថ្មពិត និងស្លែងរំសេវ ។ ដូចសាមូរ៉ៃជាភាគច្រើនដែរ សំលៀកបំពាក់របស់ពួកគេមានចំរុះដោយគីម៉ូណូ និងកន្ទប តែអាវុធរបស់ពួកគេគឺជាប្រភេទល្អបំផុតដែលគេអាចរកបាន ។ មានតែ *តូរ៉ាណាកា* ហើយនឹង *អ៊ីស៊ីដូ* ដែលលួចចំលងតាមនោះទេ ដែលត្រូវអោយទ័ពរបស់លោកមានឯកសណ្ឋាន និងមានការប្រិតប្រៀបក្នុងរឿងសំលៀកបំពាក់ ។ ពួក *វ៉ៃមីកូ* ឯទៀតតែងចាត់ទុកថាភាពសង្ហាខាងក្រៅបែបនេះជាការជះលុយចោល ជាការច្នៃប្រឌិតថ្មីដែលមិនចាំបាច់ ។ សូម្បីតែ *ប្លាក់ថន* ក៏ឯកភាពនឹងគំនិតនេះដែរ ព្រោះថាកងទ័ពនៅអឺរ៉ុបក៏មិនដែលមានឯកសណ្ឋានដែរទេ ។ មានស្តេចណាមានលុយទៅធ្វើបែបនេះបាន លើកលែងតែសំរាប់រាជរក្សប៉ុននោះ ?

គេស្ថិតនៅលើទីខ្ពស់មួយជាមួយ *យ៉ាប៊ូ* និងពួកជំនួយការលោក ជាមួយ *ចូស៊ិន* និងកូនចៅរបស់គេ ហើយនឹងជាមួយ *ម៉ារីកូ* ។នេះគឺជាការសមរាំយលុកពេញខ្នាតជាលើកទីមួយហើយ ។ គេមានអារម្មណ៍រសាប់រសល់នៅក្នុងខ្លួនជាពន់ពេក ។ *យ៉ាប៊ូ* ក៏មានអារម្មណ៍តឹងតែងខុសពីធម្មតាដែរ ចំណែក *អូមី* និង *ណាកា* វិញក៏មួម៉ៅស្ទើរតែនឹងប៉ះគ្នាម្តង១ ពិសេស *ណាកា*។ *ប្លាក់ថន* សួរទៅ *អូមី*:

- ចុះម្នាក់១វាយ៉ាងម៉េចណឹង ?

- ប្រហែលពួកគេចង់ធ្វើអោយបានល្អនៅចំពោះមុខលោកម្ចាស់របស់គេ និងចំពោះមុខភ្ញៀវហើយមើលទៅ ។

- គាត់ណឹងជា *វ៉ៃមីកូ* ដែរ ?

- ទេ តែជាអ្នកសំខាន់ ។ ជាមេទ័ពរបស់ *អ៊ីស៊ីដូ* ។ ថ្ងៃនេះ បើសិនជាអ្វី១ប្រព្រឹត្តទៅឥតខ្ចោះនោះពិតជាល្អមែនទែន ។

- គេគួរតែប្រាប់ខ្ញុំថាមានសមយុទ្ធនៅថ្ងៃនេះ ។

- បើប្រាប់មុនវាមានទៅបានអីលើសប៉ុន្នានទៅ ? អ្វី១ដែលលោកអាចធ្វើបានលោកបានធ្វើអស់ហើយទេតើ ។

មែនហើយ - *ប្លាក់ថន* គិតនៅក្នុងចិត្តបណ្តើរ សំលឹងមើលទ័ពវាយលុកទាំងប្រាំរយ



www.budinst.gov.kh www.elibraryofcambodia.org

បណ្ដើរ។ តែពួកនេះមិនទាន់ដល់គិតនៅឡើយទេ។ *យ៉ាហ្វ៊ូ* ច្បាស់ជាយល់បានពីរឿងនេះ។ អ្នកឯទៀតក៏យ៉ាងដូចនោះដែរ។ អញ្ចឹងហើយបើសិនជាមានមហន្តរាយណាមួយនោះគឺជា *កាម៉ា* ទៅចុះ គេគិតទាំងដោយមានទំនុកចិត្តខ្លួនឯងជាងមុន ហើយក៏ធូរស្រាលក្នុងចិត្តតាមគំនិតនេះទៅ។

ក្រុមវាយលុកបានបង្កើនល្បឿនរបស់ខ្លួន ឯពួកអ្នកការពារវិញនៅតែឈររង់ចាំក្រោមទង់របស់មេបញ្ជាការខ្លួនដោយជេរបញ្ចោរ " ពួកសត្រូវ " ដូចដែលគេបានធ្វើនៅក្នុងពេលប្រយុទ្ធមែនទែនយ៉ាងនោះដែរ។ ពួកគេឈរជាបី រឺ បួនជួរវាយប៉ិយពីគ្នា។ ជាធម្មតានៅពេលដែលពួកគេចូលជិតដល់ ពួកវាយលុកត្រូវចុះពីលើខ្នងសេះនៅក្នុងចំងាយមួយដែលផុតពីកំលាំងព្រួញហើយសេនាទាំងឡាយដែលក្លាហានជាងគេនៅក្នុងទ័ពទាំងពីរខាងនេះ ចេញមុខហៅគ្នាប្រកួតដោយនិយាយប្រាប់ពីពូជពង្សវង្សត្រកូលរបស់ខ្លួន និង ពីប្រៀបរបស់ខ្លួន។ ការប្រយុទ្ធតតូត្រូវចាប់ផ្ដើមឡើងហើយចំនួននេះ ចេះតែកើនឡើងជាលំដាប់រហូតដល់មេទ័ពខាងណាមួយចេញបញ្ជាអោយវាយលុកជាទូទៅតែម្ដង។ នៅពេលនោះគឺម្នាក់ៗស្រេចលើខ្លួនឯងតែម្ដង ហើយជាទូទៅគឺទ័ពធំឈ្នះទ័ពតូច ហើយពេលនោះទ័ពបំរុងត្រូវបញ្ចេញទៅក្នុងសមរភូមិបន្ថែមទៀត។ ការប្រយុទ្ធបន្តរហូតទាល់តែខាងណាម្ខាងបាក់ទឹកចិត្តហើយរត់បាក់ទ័ពតែម្ដង។ ការប្រើល្បិចក៏មិនមែនជារឿងចំលែកដែរទេ។ ជួនកាលកងទ័ពទាំងកងត្រូវបានទទួលបញ្ជាពីមេរបស់គេអោយទៅចុះចូលរួមជាសំព័ន្ធមិត្តជាមួយទ័ពជាសត្រូវ ។ ការចូលរួមបែបនេះតែងតែត្រូវបានគេស្វាគមន៍ជានិច្ចតែក៏គេមិនដែលទុកចិត្តដែរទេ។ ជួនកាលមេទ័ពដែលបរាជ័យបានរត់គេចដើម្បីផ្ដុំទ័ព វាយលុកឡើងវិញ ។ ជួនកាលគេមិនខ្វីរត់ហើយនៅប្រយុទ្ធទាល់ស្លាប់ ជួនកាលគេធ្វើ *សិបពុគូ* យ៉ាងហ៊ឹកហ៊ាក់របស់គេ។ កំរមានពេលដែលពួកគេត្រូវចាប់ខ្លួនបានណាស់។ អ្នកខ្លះបានសុំបំរើអ្នកដែលបានឈ្នះ។ មានពេលខ្លះសំនូមពរនេះត្រូវបានយល់ព្រមទទួលយក តែភាគច្រើនត្រូវគេច្រានចោល។ ការស្លាប់គឺជាចំនងដៃសំរាប់អ្នកចាញ់។ ស្លាប់រហ័សសំរាប់អ្នកក្លាហាន ស្លាប់ពោរពេញដោយការអាម៉ាស់សំរាប់មនុស្សកំសាកញី។ ហើយនេះគឺជាដំណើរជាប្រវត្តិនៃរាល់ការប៉ះទង្គិចនៅលើទឹកដីនេះ ទោះជាក្នុងការប្រយុទ្ធធំបែបណាក៏ដោយ ហើយយុទ្ធជននៅទីនេះក៏ដូចជា



www.budinst.gov.kh www.elibraryofcambodia.org

យុទ្ធជននៅគ្រប់ទីកន្លែងទាំងអស់ដែរ គ្រាន់តែនៅទីនេះពួកគេសាហាវជាងនិងមានមនុស្សច្រើនជាងដែលស្ម័គ្រស្លាប់ដើម្បីម្ចាស់ខ្លួនតែប៉ុណ្ណោះ ។

ស្គរជើងសេះលាន់ខ្ទរជ្រលងភ្នំ ។ *ចូសិន* សួរឡើង :

- រូចឯណាមិនឃើញមេបញ្ជាការវាយលុក ? *អូមី-សាន* នៅឯណា ?

*យ៉ាប៊ូ* តប :

- វានៅក្នុងចំណោមពួកទ័ព ។ សូមលោកអត់ធ្មត់បន្តិចទៅ ។

- តែចុះទង់គេនៅឯណា ? រូចម៉េចក៏មិនពាក់អាវក្រោះនិងស្លាបសត្វ ? ម៉េចមិនឃើញទង់មេបញ្ជាការ ? ពួកនេះមើលទៅដូចវង្វេងចោរហារយទៅវិញទេ ។

- សូមអត់ធ្មត់បន្តិចទៅ ។ ពួកមេទ័ពទាំងអស់ត្រូវទទួលបញ្ជាអោយនៅជាអនាមិក ។ ខ្ញុំបាននិយាយប្រាប់លោកហើយតើ ។ ម្យ៉ាងទៀតសូមលោកកុំភ្លេចថានេះគឺយើងធ្វើហាក់ដូចជានៅក្នុងការប្រយុទ្ធយ៉ាងជាប់ដៃមែនទែន ធ្វើដូចជានៅក្នុងផ្នែកមួយនៃការប្រយុទ្ធដ៏ធំដោយមានទាំងទ័ពបំរុង មានទាំងអាវុធ.....

*ចូសិន* និយាយភ្លាត់សំលេង :

- រូចចុះដាវពួកវានៅឯណា ? គ្មានអ្នកណាមួយកាន់ដាវសោះ ! សាមូរ៉ៃអត់ដាវ ? ពួកវាច្បាស់ជាត្រូវសំលាប់រលេជាមិនខាន ។

- សូមអត់ធ្មត់សិនទៅ !

អីលូវនេះពួកវាយលុកបានចុះពីលើខ្នងសេះហើយ ។ ពួកយុទ្ធជនមួយចំនួនស្ទុះចេញពីជួរដើម្បីបង្ហាញពីភាពក្លាហានរបស់ពួកគេ ។ ខាងជួរកងការពារក៏មានយុទ្ធជនក្នុងចំនួនដូចគ្នាស្ទុះចេញមកតទល់អ្នកទាំងនេះភ្លាមដែរ ។ រំពេចភ្លាមនោះ កងវាយលុកដែលនៅច្របូកច្របល់គ្នានោះបានស្ទុះចូលជាកងឯកភាពដ៏មានវិន័យចំនួនប្រាំកងភ្លាមដែលក្នុងមួយកង១មានបួនជួរ និងមួយជួរមានម្ភៃប្រាំនាក់ ។ កងឯកភាពបីកងដើរទៅខាងមុខ ឯកងត្រៀមបំរុងពីរទៀតនៅពីក្រោយប្រហែលសែសិបជំហាន ។ពួកគេវាយលុកដូចមនុស្សតែម្នាក់ ។នៅពេលទទួលបញ្ជាពួកគេឈប់ងំហើយពួកនៅជួរមុខបាញ់ព្រម១គ្នាភ្លាម ។ស្គរកាំភ្លើងលាន់លឺស្ទើរបែកក្រដាស់ត្រចៀក ។



www.budinst.gov.kh www.elibraryofcambodia.org

សំរែកលាន់លឺឡើងហើយមនុស្សក៏ដួលស្លាប់រលេ។ *ចូសិន* និងកូនចៅរបស់លោកអោនក្បាលជាសភាវគតិរួចក៏សំលឹងមើលទាំងភាន់ភាំង ពួកជួរទីមួយលុតជង្គង់ចុះដើម្បីញាត់រំសេវនិងគ្រាប់ឡើងវិញ ចំនែកកងជួរទីពីរក៏ចាប់ផ្តើមបាញ់ពីលើក្បាលពួកជួរមុខព្រម១គ្នាភ្លាមដែរ។ រួចជួរទីបីជួរទីបួន បន្តបន្ទាប់គ្នា។ នៅពេលបាញ់មួយប្រាវ១ពួកការពារមួយចំនួនចេះតែដួលបន្តបន្ទាប់ថែមទៀត ហើយនៅក្នុងជ្រលងភ្នំទាំមូលគេលឺសូរតែសំលេងស្រែក សំលេងធ្ងូញថ្ងូរ និងភាពជ្រួលច្របល់ពេញបន្ទុក។

*ចូសិន* ប្រឹងស្រែកទៅ *យ៉ាប៊ូ* កាត់សំលេងដ៏លាន់រំពងនេះ :

- លោកឯងសំលាប់កូនចៅឯង !

- នេះជាគ្រាប់បញ្ឆោតទេ។ មិនមែនបាញ់គ្រាប់មែនទែនឡើយ។ ពួកគេធ្វើដូចការប្រយុទ្ធមែនទែនតែប៉ុននោះ តែលោកស្រមៃថាបើសិនជាការវាយលុកមែនទែនដោយប្រើគ្រាប់មែនទែនទៅមើល ! មើលនុះ !

អីលូវនេះ ពួកការពារបាន " ភ្ញាក់ស្មារតី " ពីការភាន់ភាំងដំបូងនេះហើយ។ ពួកគេចាប់ផ្តើមផ្ទុំទ័ពឡើងវិញហើយចាប់ផ្តើមវាយបុកទៅវិញ ។ ប៉ុន្តែក្នុងរយៈពេលនេះ ពួកជួរទីមួយបានច្រកគ្រាប់រំសេវហើយជាស្រេចហើយក្រោយពីបានទទួលបញ្ជាហើយនោះ ក៏ចាប់ផ្តើមបាញ់ព្រម១គ្នាទាំងនៅលុតជង្គង់ រួចជួរទីពីរបាញ់ដោយឈររួចទើបលុតជង្គង់យ៉ាងរហ័សដើម្បីច្រកគ្រាប់ ដើម្បីទុកអោយជួរទីបី រួចជួរទីបួនបាញ់ជាបន្តបន្ទាប់ដូចនៅលើកមុនដែរ។ ថ្វីត្បិតតែពួកខ្មាន់កាំភ្លើងនៅឃើតយ៉ាវ និងជួរទ័ពមិនបានស្មើល្អក្តី ក៏គេអាចយល់បានយ៉ាងងាយថាតើការខូចខាតនឹងមានទំហំប៉ុនណាទៅ បើសិនជាខ្មាន់កាំភ្លើងជាមនុស្សមានការរឹកហាត់ស្ទាត់ជំនាញវិញនោះ ។ ការវាយបកវិញត្រូវបរាជ័យហើយត្រូវដកថយឡើងតាមជំរាលកូនភ្នំមកឈប់នៅពីក្រោមអ្នកសង្កេតការណ៍តែម្តង។ " ខ្មោច " ត្រូវនៅចោលរកេតរកូតពាសពេញដី។

*ចូសិន* និងកូនចៅរបស់លោកឡើងញាក់សាច់តែម្តង។

- កាំភ្លើងអស់នេះអាចទំលាយខ្សែការពារណាក៏បានតែទាំងអស់ហ្នឹង។

- ឈប់សិន។ ការប្រយុទ្ធមិនទាន់ចប់ទេ !



www.budinst.gov.kh www.elibraryofcambodia.org

ពួកការពារបានផ្គុំគ្នាឡើងវិញជាថ្មីម្តងទៀត ។ ម្តងនេះក្រោមការបំផុសស្មារតីពីមេបញ្ជាការរបស់គេផង និងដោយមានការចូលរួមរបស់ទ័ពបំរុងផង ពួកគេទទួលបញ្ជាវាយបកម្តងទៀតជាចុងក្រោយ ។ ពួកសាមូរ៉ៃទាំងអស់រត់ចុះតាមជំរាលដោយបន្លឺសំរែកប្រយុទ្ធដ៏គួរអោយព្រឺព្រួចតំរង់ទៅរកពួកសត្រូវ ។

- ម្តងនេះទៀត ពួកសត្រូវស្លាប់ដូចគេបោលជាមិនខាន ។

*ចូសិន* ពោលឡើងក្នុងអារម្មណ៍ត្រូវតូចចូលទៅក្នុងឥទ្ធិភាពនៃសមយុទ្ធនេះដែរ ។

ហើយដូចគេបាននិយាយមែន ។ កងឯកភាពឥតតទប់បាននឹងការវាយសំរុកនេះបានឡើយ ។ ពួកគេបែកខ្ញែកជូរនៅចំពោះមុខសំរែកប្រយុទ្ធរបស់សាមូរ៉ៃពិតប្រាកដប្រកបដោយជារ និងលំពែងទាំងនេះ ។ *ចូសិន* និងកូនចៅរបស់លោកជួយស្រែកបន្ទរពោរពេញដោយភាពមាក់ងាយបន្ថែមទៀតក្នុងពេលដែលក្រុមការពារចូលវាយកាប់សំលាប់នេះ ។ ពួកខ្មាន់កាំភ្លើងចែកផ្លូវគ្នារត់រំញ៉ៅដូចពួកស៊ីខ្ចីម ( * ) ។ រត់មួយរយជំហាន ពីររយ បីរយ ហើយរំពេចនោះក្រោមសំរែកបញ្ជា ពួកគេបានផ្គុំគ្នាវិញភ្លាមជារាងមុខព្រួញ ហើយកាំភ្លើងក៏បានផ្ទុះបណ្តាក់គ្នាជាថ្មីម្តងទៀត ។ ការវាយបកត្រូវរង្គោះរង្គើ ហើយត្រូវបញ្ឈប់ស្ងៀមតែកាំភ្លើងនៅតែបន្តបាញ់តទៅទៀតមួយសន្ទុះទើបស្ងប់ទៅវិញ ។ ការសមយុទ្ធត្រូវបញ្ចប់ ប៉ុន្តែអ្នកទាំងអស់គ្នាដែលនៅលើទីទួលសុទ្ធតែដឹងយ៉ាងច្បាស់ណាស់ថា នៅក្នុងស្ថានភាពដូចនេះពួកទាំងពីរពាន់នាក់ពិតជាត្រូវកំទេចអស់ជាមិនខាន ។

អីលូវនេះ ទាំងអ្នកវាយលុក ទាំងអ្នកការពារ នាំគ្នារៀបរយទីកន្លែងនិងរបស់របរឡើងវិញ ។ " សាកសព " ក៏ងើបឡើងវិញ អាវុធយុទ្ធភ័ណ្ឌក៏ត្រូវបានប្រមែប្រមូលក្រោមសំនើចក្អាកក្អាយ និងការថ្ងូចថ្ងូរដោយអ្នកខ្លះត្រូវគ្រេចរឺខ្លះទៀតរបួសជាដំណាំផងដែរ ។

*ចូសិន* និយាយយ៉ាងស្មោះត្រង់ :

- ខ្ញុំសូមសរសើរហើយលោក *យ៉ាប៊ូ-សាម៉ា* ។ អីលូវនេះខ្ញុំយល់បានទាំងអស់នូវអ្វីដែល

( * ) *ពួកកូរ៉េ តាមការហៅរបស់ជប៉ុនជំនាន់នោះ ។ ( ក.អ.ប. )*



www.budinst.gov.kh www.elibraryofcambodia.org

សំរែកលាន់លឺឡើងហើយមនុស្សក៏ដួលស្លាប់រលេ។ *ចូសិន* និងកូនចៅរបស់លោកអោនក្បាលជាសភាវគតិរួចក៏សំលឹងមើលទាំងភាន់ភាំង ពួកជួរទីមួយលុតជង្គង់ចុះដើម្បីញាត់រំសេវនិងគ្រាប់ឡើងវិញ ចំនែកកងជួរទីពីរក៏ចាប់ផ្ដើមបាញ់ពីលើក្បាលពួកជួរមុខព្រម១គ្នាភ្លាមដែរ។ រួចជួរទីបី ជួរទីបួន បន្តបន្ទាប់គ្នា។ នៅពេលបាញ់មួយប្រាវ១ពួកការពារមួយចំនួនចេះតែដួលបន្តបន្ទាប់ថែមទៀត ហើយនៅក្នុងជ្រលងភ្នំទាំមូលគេលឺសូរតែសំលេងស្រែក សំលេងធូញថ្ងូរ និងភាពជ្រួលច្របល់ពេញបន្ទុក។

*ចូសិន* ប្រឹងស្រែកទៅ *យ៉ាហ៊ូ* កាត់សំលេងដ៏លាន់រំពងនេះ :

- លោកឯងសំលាប់កូនចៅឯង !

- នេះជាគ្រាប់បញ្ឆោតទេ។ មិនមែនបាញ់គ្រាប់មែនទែនឡើយ។ ពួកគេធ្វើដូចការប្រយុទ្ធមែនទែនតែប៉ុននោះ តែលោកស្រមៃថាបើសិនជាការវាយលុកមែនទែនដោយប្រើគ្រាប់មែនទែនទៅមើល ! មើលនុះ !

អីលូវនេះ ពួកការពារបាន " ភ្ញាក់ស្មារតី " ពីការភាន់ភាំងដំបូងនេះហើយ។ ពួកគេចាប់ផ្ដើមផ្ទុំទ័ពឡើងវិញហើយចាប់ផ្ដើមវាយបុកទៅវិញ ។ ប៉ុន្តែក្នុងរយៈពេលនេះ ពួកជួរទីមួយបានច្រកគ្រាប់រំសេវហើយជាស្រេចហើយក្រោយពីបានទទួលបញ្ជាហើយនោះ ក៏ចាប់ផ្ដើមបាញ់ព្រម១គ្នាទាំងនៅលុតជង្គង់ រួចជួរទីពីរបាញ់ដោយឈររួចទើបលុតជង្គង់យ៉ាងរហ័សដើម្បីច្រកគ្រាប់ ដើម្បីទុកអោយជួរទីបី រួចជួរទីបួនបាញ់ជាបន្តបន្ទាប់ដូចនៅលើកមុនដែរ។ ថ្វីត្បិតតែពួកខ្មាន់កាំភ្លើងនៅយឺតយ៉ាវ និងជួរទ័ពមិនបានស្មើល្អក្ដី ក៏គេអាចយល់បានយ៉ាងងាយថាតើការខូចខាតនឹងមានទំហំប៉ុនណាទៅ បើសិនជាខ្មាន់កាំភ្លើងជាមនុស្សមានការវ៉ឹកហាត់ស្ទាត់ជំនាញវិញនោះ ។ ការវាយបកវិញត្រូវបរាជ័យហើយត្រូវដកថយឡើងតាមជំរាលកូនភ្នំមកឈប់នៅពីក្រោមអ្នកសង្កេតការណ៍តែម្ដង។ " ខ្មោច " ត្រូវនៅចោលរកេតរកូតពាសពេញដី។

*ចូសិន* និងកូនចៅរបស់លោកឡើងញាក់សាច់តែម្ដង។

- កាំភ្លើងអស់នេះអាចទំលាយខ្សែការពារណាក៏បានតែទាំងអស់ហ្នឹង។

- ឈប់សិន។ ការប្រយុទ្ធមិនទាន់ចប់ទេ !



www.budinst.gov.kh www.elibraryofcambodia.org

ពួកការពារបានផ្តុំគ្នាឡើងវិញជាថ្មីម្តងទៀត ។ ម្តងនេះក្រោមការបំផុសស្មារតីពីមេបញ្ជាការរបស់គេផង និងដោយមានការចូលរួមរបស់ទ័ពបំរុងផង ពួកគេទទួលបញ្ជាវាយបកម្តងទៀតជាចុងក្រោយ ។ ពួកសាមូរ៉ៃទាំងអស់រត់ចុះតាមជំរាលដោយបន្លឺសំរែកប្រយុទ្ធដ៏គួរអោយព្រឺព្រួចតំរង់ទៅរកពួកសត្រូវ ។

- ម្តងនេះទៀត ពួកសត្រូវស្លាប់ដូចគេហាលជាមិនខាន ។

*ចូសិន* ពោលឡើងក្នុងអារម្មណ៍ត្រូវកួចចូលទៅក្នុងតថភាពនៃសមយុទ្ធនេះដែរ ។

ហើយដូចគេបាននិយាយមែន ។ កងឯកភាពឥតតទប់បាននឹងការវាយសំរុកនេះបានឡើយ ។ ពួកគេបែកខ្ញែកជួរនៅចំពោះមុខសំរែកប្រយុទ្ធរបស់សាមូរ៉ៃពិតប្រាកដប្រកបដោយជាវ និងលំពែងទាំងនេះ ។ *ចូសិន* និងកូនចៅរបស់លោកជួយស្រែកបន្ថែរពោរពេញដោយភាពមាក់ងាយបន្ថែមទៀតក្នុងពេលដែលក្រុមការពារចូលវាយកាប់សំលាប់នេះ ។ ពួកខ្មាន់កាំភ្លើងចែកផ្លូវធ្លារត់វៀចដូចពួកស៊ីខ្ទិម ( * ) ។ រត់មួយរយជំហាន ពីររយ បីរយ ហើយរំពេចនោះក្រោមសំរែកបញ្ជា ពួកគេបានផ្តុំគ្នាវិញភ្លាមជារាងមុខព្រួញ ហើយកាំភ្លើងក៏បានផ្ទុះបណ្តាក់គ្នាជាថ្មីម្តងទៀត ។ ការវាយបកត្រូវរង្គោះរង្គើ ហើយត្រូវបញ្ឈប់ស្ងៀមតែកាំភ្លើងនៅតែបន្តបាញ់តទៅទៀតមួយសន្ទុះទើបស្ងប់ទៅវិញ ។ ការសមយុទ្ធត្រូវបញ្ចប់ ប៉ុន្តែអ្នកទាំងអស់គ្នាដែលនៅលើទីទួលសុទ្ធតែដឹងយ៉ាងច្បាស់ណាស់ថា នៅក្នុងស្ថានភាពដូចនេះពួកទាំងពីររពាន់នាក់ពិតជាត្រូវកំទេចអស់ជាមិនខាន ។

ឥឡូវនេះ ទាំងអ្នកវាយលុក ទាំងអ្នកការពារ នាំគ្នារៀបរយទីកន្លែងនិងរបស់របរឡើងវិញ ។ " សាកសព " ក៏ងើបឡើងវិញ អាវុធយុទ្ធភ័ណ្ឌក៏ត្រូវបានប្រមែប្រមូលក្រោមសំនើចក្អាកក្អាយ និងការថ្ងូចថ្ងូរដោយអ្នកខ្លះត្រូវគេច រីខ្លះទៀតរបួសជាដំណាំផងដែរ ។

*ចូសិន* និយាយយ៉ាងស្មោះត្រង់ :

- ខ្ញុំសូមសរសើរហើយលោក *យ៉ាប៊ូ-សាម៉ា* ។ ឥឡូវនេះខ្ញុំយល់បានទាំងអស់នូវអ្វីដែល

( * ) *ពួកតួរ៉េ តាមការហៅរបស់ជប៉ុនជំនាន់នោះ ។ ( ក.អ.ប. )*



www.budinst.gov.kh www.elibraryofcambodia.org

លោកចង់មានប្រសាសន៍នោះហើយ ។

- ការបាញ់នេះមិនទាន់ស្មើដៃនៅឡើយ -*យ៉ាប៊ូ* តបទាំងរីករាយនៅក្នុងចិត្ត -ពួកនេះត្រូវការរ៉ឹកហាត់ច្រើនខែទៀត ។

*ចូសិន* គ្រវីក្បាល :

- ទោះជាអីលូវនេះក្ដីក៏ខ្ញុំមិនចង់វាយប្រយុទ្ធនឹងពួកនេះដែរ ។ ជាពិសេស បើពួកនេះមានគ្រាប់មែនទែននោះ ។ គ្មានទ័ពណាទប់ទល់វាបានទេ ។ គ្មានតែម្ដង ។ លោកមិនអាចរក្សាខ្សែទ័ពអោយនៅជិតគ្នាបានឡើយ នៅពេលនោះលោកបញ្ជូនតែទ័ពធម្មតានិងទ័ពសេះ មកជ្រៀតតាមចន្លោះនេះមកហើយវាយបញ្ជ្រាសឡើងទាំងសងខាងដូចមូរក្រដាស់តែម្ដង ។ គ្រាន់តែមើលនេះ ក៏គួរអោយស្ញើបណាស់ដែរ ។ មួយភ្លែតដំបូង ខ្ញុំស្មានតែជាការប្រយុទ្ធមែនទែន ។

- ពួកវាទទួលបញ្ជាអោយធ្វើដូចមែនទែនតែម្ដង ។ អីលូវនេះបើលោកមានបំណងលោកអាចត្រួតពួកខ្មាន់កាំភ្លើងខ្ញុំបានហើយ ។

- អរគុណ ។ នេះគឺជាកិត្តិយសណាស់ ។

ពួកក្រុមការពារដើរសំដៅទៅជំរំរបស់ខ្លួនដែលនៅជំរាលកូនភ្នំមួយឯនាយ ។ នៅខាងក្រោម ខ្មាន់កាំភ្លើងទាំងប្រាំរយនាក់នៅឈររង់ចាំក្បែរផ្លូវដែលចុះទៅភូមិ ។ ពួកគេឈរនៅតាមក្រុមដោយមាន *អូមី* និង *ណាកា* នៅឈរពីមុខ ។ អ្នកទាំងពីរសៀតដាវរបស់ខ្លួនឡើងវិញហើយ ។

- *យ៉ាប៊ូ-សាម៉ា* ?

- បាទ *អាន់ជីន-សាន* ?

- ល្អ មែនទេ ?

- ពិតហើយ ល្អ ។

- អរគុណ *យ៉ាប៊ូ-សាម៉ា* ។ ខ្ញុំរីករាយ ។

*ម៉ារីកូ* កែតំរូវនាយជាស្វ័យប្រវត្តិ :

- ខ្ញុំមានការរីករាយណាស់ ។



www.budinst.gov.kh www.elibraryofcambodia.org

- អ្នា ? សូមទោស ។ ខ្ញុំមានការរីករាយណាស់ ។

*ចូសិន* ទាញ *យ៉ាប៊ូ* ទៅម្ខាង :

- តើទាំងអស់ហ្នឹងចេញពីគំនិតអា *អាន់ជីន-សាន* នេះអ្វី ?

- ទេ -*យ៉ាប៊ូ* កុហក -តែនេះជារបៀបធ្វើសង្គ្រាមរបស់ពួកចុងស្រុក ។ វាគ្រាន់តែបង្រៀនទ័ពអោយចេះច្រកគ្រាប់និងចេះបាញ់តែប៉ុននោះ ។

- ហេតុអីមិនធ្វើតាមមតិរបស់ *ណាកា-សាន* ទៅ ? អីលូវនេះ លោកបានចំនេះដឹងរបស់មនុស្សចុងស្រុកហើយ ។ ហេតុអីប្រថុយប្រថានអោយចំនេះដឹងនេះរាលដាលធ្វើអី ? វាជាមេរោគប៉េសតែម្តង ។ គ្រោះថ្នាក់ណាស់ *យ៉ាប៊ូ-សាម៉ា*។ *ណាកា-សាន* យល់ត្រូវណាស់ ។ គឺជាការពិត.........ពួកអ្នកស្រែក៏ *អាច* ប្រយុទ្ធតាមរបៀបនេះបានដែរ ។ យ៉ាងងាយបំផុតទៀតផង ។ ចាត់ការអាមនុស្សចុងស្រុកនេះអោយហើយទៅ ។

- បើសិនជាលោកម្ចាស់ *អ៊ីស៊ីដូ* ចង់បានក្បាលវា លោកគ្រាន់តែហើបមាត់សុំមកគឺបានភ្លាម ។

- ខ្ញុំសុំក្បាលវា ។ ក្នុងពេលនេះ -*ចូសិន* តំលើងសំលេង -ខ្ញុំនិយាយក្នុងនាមលោកម្ចាស់ *អ៊ីស៊ីដូ*។

- ខ្ញុំនឹងពិចារណារឿងនេះ *ចូសិន-សាន*។

- ម្យ៉ាងទៀត ក្នុងនាមលោកម្ចាស់ដែរ ខ្ញុំ *សូម* អោយលោកដកហូតកាំភ្លើងទាំងអស់ពីពួកទ័ពទាំងនេះភ្លាម ។

*យ៉ាប៊ូ* ជ្រួញចិញ្ចើម រួចលោកបែរមកយកចិត្តទុកដាក់លើពួកកងទ័ពវិញ ។ ពួកគេបានខិតមកជិតទីទួលក្នុងជួរក្បួនមួយដ៏ស្អាត និងដ៏មានវិន័យគួរអោយចង់អស់សំណើច ព្រោះថាពួកនេះមិនដែលមានរបៀបស្អាតភ្លឹងបែបនេះទេ ។ មកដល់ត្រឹមហាសិបជំហានពួកគេក៏ឈប់នៅទីនោះ ។ *អូមី* និង *ណាកា* ក៏ដើរបន្តមកទៀតតែពីរនាក់រួចគោរព ។ *យ៉ាប៊ូ* និយាយឡើង :

- សមដៃដំបូងបានប៉ុននេះ គឺល្អហើយ ។

*អូមី* តប :



www.budinst.gov.kh www.elibraryofcambodia.org

- សូមអរគុណ លោកម្ចាស់ ។

*អូមី* ថ្ពោះជើងស្រាលហើយមុខគេប្រលាក់ប្រលូសដោយដីដូចប៉ាតម្សៅនិងមានស្នាមជាំទៀតផង ។ *ចូសិន* និយាយ :

- *យ៉ាប៊ូ-សាម៉ា* កងទ័ពរបស់លោកនឹងកាន់ដាវទៅក្នុងសមរភូមិមែនទែន *ទេ* ? សាមូរ៉ៃត្រូវតែកាន់ដាវ.......យ៉ាងហោចបង្ការពេលអស់គ្រាប់ដែរ *ទេ* ?

- ដាវនឹងរំខានពួកវានៅពេលវាយលុក និងពេលដកថយ ។ អូ ពួកវានឹងកាន់ដាវដូចធម្មតាដើម្បីកុំអោយសត្រូវដឹងជាមុន តែនៅមុនពេលវាយសំរុកចូលនោះ ពួកវានឹងដោះដាវចេញហើយ ។

- សាមូរ៉ៃជានិច្ចកាលត្រូវមានដាវ ។ នៅក្នុងសមរភូមិមែនទែន ។ ទោះជាយ៉ាងណាក្តី ក៏ខ្ញុំរីករាយដែរដែលលោកមិនប្រើកំលាំងវាយលុកនេះជាដាច់ខាតនោះ បើមិនយ៉ាងដូចនោះ.....

*ចូសិន* ហៀបនឹងពោលថា " របៀបធ្វើសង្គ្រាមដ៏ថោកទាបនិងដ៏គគ្រិចនេះ " ទៅហើយ តែលោកទប់ទាន់ហើយបន្តថា :

- បើមិនយ៉ាងដូចនោះទេពួកយើងទាំងអស់គ្នាត្រូវគ្រវាត់ដាវចោលអស់ហើយ ។

- អាចដែរ *ចូសិន-សាន* ។ នៅពេលណាដែលយើងប្រលូកក្នុងសង្គ្រាម ។

- លោកបោះបង់ដាវ *មូរ៉ាសាម៉ា* របស់លោក ? បោះបង់ទាំងដាវដែលជាអំនោយរបស់ *តូរ៉ាណាកា* ?

- ពិតមែន ដើម្បីឈ្នះសង្គ្រាម ។ ក្រៅពីនេះ គ្មានផ្លូវទេ ។

- បើអញ្ចឹងមែន លោកត្រូវដាក់មេដាយលឿនណាស់ដើម្បីរក្សាជីវិតរបស់លោកទៅពេលណាដែលកាំភ្លើងលោកតាំង រឺនៅពេលណាដែលរំសេវលោកទទឹកនោះ ។

រួច *ចូសិន* ផ្ទុះសំនើចក្អាកក្អាយនឹងគំនិតឆ្លាតឆ្លៃរបស់ខ្លួន ។ *យ៉ាប៊ូ* ឥតសើចសោះ តែលោកចេញបញ្ជាឡើង :

- *អូមី-សាន* ! បង្ហាញលោក *ចូសិន* មើលទៅ !

*អូមី* ស្រែកចេញបញ្ជាភ្លាម ។កងទ័ពរបស់គេក៏ដកហូតកាំបិតចំពុះទុងដែលសៀតនៅពី



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយខ្នងមកចាប់នៅក្បែរមាត់កាណុងកាំភ្លើងមួយរំពេច ។

- សំរុកចូល !

រំពេចនោះ កងសាមូរ៉ៃក៏សំរុករត់ចូលដោយបន្លឺសំលេងប្រយុទ្ធគួរអោយញាក់សាច់របស់គេ : *គាស៊ុគីគីគីគី* !

ព្រៃដែកថែបបានមកឈប់នៅត្រឹមតែមួយជំហានពីពួកគេ ។ *ចូសិន* និងកូនចៅរបស់លោកស្ទើរតែទាំងរសាប់រសល់នៅចំពោះមុខភាពឃោរឃៅដែលឥតបានគិតទុកជាមុន និងយ៉ាងប្រផុចប្រញ៉ុចនេះ ។

- ល្អ ! ល្អណាស់ !

*ចូសិន* និយាយ ។ គេលូកដៃទៅស្ទាបកាំបិតចំពុះទុង ។ កាំបិតចំជាមុតអស្ចារ្យមែន :

- មើលទៅ លោកប្រហែលជាយល់ត្រឹមត្រូវមែន *យ៉ាប៉ូ-សាម៉ា*។ សង្ឃឹមថាយើងនឹងមិនត្រូវការសាកល្បងវាឡើយ ។

*យ៉ាប៉ូ* បញ្ជាឡើង :

- *អូមី-សាន* ! រៀបចំទ័ពឡើងវិញ ។ *ចូសិន-សាន* នឹងត្រួតពលអីលូវនេះឯង ។ រួចនាំឱ្យត្រលប់ទៅជំរំវិញ ។ *ម៉ារីកូ-សាន អាន់ជីន-សាន* លោកមកតាមខ្ញុំ !

រួចលោកក៏ជិះសេះចុះទៅវិញដោយកាត់ជួរកងទ័ពទាំងនោះ ។ កងជំនួយ *ប្លាក់ថន* និង *ម៉ារីកូ* ជិះតាមពីក្រោយ ។

- ចូលជួរ នៅឯខាងផ្លូវ ។ ដកចំពុះទុងចេញ ។

ទាហានពាក់កណ្ដាលបានគោរពតាមបញ្ជា ហើយបានវិលត្រលប់ចុះតាមជំរាលកូនភ្នំទៅក្រោមវិញ ។ *ឈាកា* និងកងសាមូរ៉ៃរបស់គេចំនួនពីររយហាសិបនាក់ទៀតនៅឈរនៅកន្លែងដែលប្រកបដោយអាកប្បកិរិយាដ៏គ្រោះថ្នាក់ ។ ចំពុះទុងរបស់ពួកគេនៅជាប់នឹងចុងកាណុងកាំភ្លើងនៅឡើយ ។

*ចូសិន* ឆេះតួង :

- ចុះមានរឿងអីណឹង ?



www.budinst.gov.kh www.elibraryofcambodia.org

- សូមអរគុណ លោកម្ចាស់ ។

*អូមី* ថ្ងោះជើងស្រោលហើយមុខគេប្រលាក់ប្រលូសដោយដីដូចប៉ាតម្សៅនិងមានស្នាមជាំទៀតផង ។ *ចូសិន* និយាយ :

- *យ៉ាប៊ូ-សាម៉ា* កងទ័ពរបស់លោកនឹងកាន់ដាវនៅក្នុងសមរភូមិមែនទែន *ទេ* ? សាមូរ៉ៃត្រូវតែកាន់ដាវ.......យ៉ាងហោចបង្ការពេលអស់គ្រាប់ដែរ *ទេ* ?

- ដាវនឹងរំខានពួកវានៅពេលវាយលុក និងពេលដកថយ ។ អូ ពួកវានឹងកាន់ដាវដូចធម្មតាដើម្បីកុំអោយសត្រូវដឹងជាមុន តែនៅមុនពេលវាយសំរុកចូលនោះ ពួកវានឹងដោះដាវចេញហើយ ។

- សាមូរ៉ៃជានិច្ចកាលត្រូវមានដាវ ។ នៅក្នុងសមរភូមិមែនទែន ។ ទោះជាយ៉ាងណាក៏ខ្ញុំរីករាយដែរដែលលោកមិនប្រើកំលាំងវាយលុកនេះជាដាច់ខាតនោះ បើមិនយ៉ាងដូចនោះ.....

*ចូសិន* ហៀបនឹងពោលថា " របៀបធ្វើសង្គ្រាមដ៏ថោកទាបនិងដ៏គគ្រិចនេះ " ទៅហើយ តែលោកទប់ទាន់ហើយបន្តថា :

- បើមិនយ៉ាងដូចនោះទេពួកយើងទាំងអស់គ្នាត្រូវគ្រវាត់ដាវចោលអស់ហើយ ។

- អាចដែរ *ចូសិន-សាន*។ នៅពេលណាដែលយើងប្រលូកក្នុងសង្គ្រាម ។

- លោកបោះបង់ដាវ *ម្ហូរ៉ាសាម៉ា* របស់លោក ?បោះបង់ទាំងដាវដែលជាអំនោយរបស់*តូរ៉ាណាកា* ?

- ពិតមែន ដើម្បីឈ្នះសង្គ្រាម ។ ក្រៅពីនេះ គ្មានផ្លូវទេ ។

- បើអញ្ចឹងមែន លោកត្រូវដាក់មេធាយលឿនណាស់ដើម្បីរក្សាជីវិតរបស់លោកនៅពេលណាដែលកាំភ្លើងលោកគាំង រឺនៅពេលណាដែលរំសេវលោកទទឹកនោះ ។

រួច *ចូសិន* ផ្ទុះសំនើចក្អាកក្អាយនឹងគំនិតឆ្លាតឆ្លំរបស់ខ្លួន។ *យ៉ាប៊ូ* ឥតសើចសោះ តែលោកចេញបញ្ជាឡើង :

- *អូមី-សាន* ! បង្ហាញលោក *ចូសិន* មើលទៅ !

*អូមី* ស្រែកចេញបញ្ជាភ្លាម ។កងទ័ពរបស់គេក៏ដកហូតកាំបិតចំពុះទុងដែលសៀតនៅពី



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយខ្នងមកចាប់នៅក្បែរមាត់កាណុងកាំភ្លើងមួយរំពេច ។

- សំរុកចូល !

រំពេចនោះ កងសាមូរ៉ៃក៏សំរុករត់ចូលដោយបន្លឺសំលេងប្រយុទ្ធគួរអោយញាក់សាច់របស់គេ : *កាស៊ីគីគីគី* !

ព្រៃដែកថែបបានមកឈប់នៅត្រឹមតែមួយជំហានពីពួកគេ ។ *ចូស៊ិន* និងកូនចៅរបស់លោកសើចទាំងរសាប់រសល់នៅចំពោះមុខភាពឃោរឃៅដែលឥតបានគិតទុកជាមុន និងយ៉ាងប្រថុចប្រញ៉ុចនេះ ។

- ល្អ ! ល្អណាស់ !

*ចូស៊ិន* និយាយ ។ គេលូកដៃទៅស្ទាបកាំបិតចំពុះទុង ។ កាំបិតចំជាមុតអស្ចារ្យមែន :

- មើលទៅ លោកប្រហែលជាយល់ត្រឹមត្រូវមែន *យ៉ាប៊ូ-សាម៉ា*។ សង្ឃឹមថាយើងនឹងមិនត្រូវការសាកល្បងវាឡើយ ។

*យ៉ាប៊ូ* បញ្ជាឡើង :

- *អូមី-សាន* ! រៀបចំទ័ពឡើងវិញ ។ *ចូស៊ិន-សាន* នឹងត្រួតពលអីលូវនេះឯង ។ រួចនាំឱ្យត្រលប់ទៅជំរំវិញ ។ *ម៉ារីកូ-សាន អាន់ជីន-សាន* លោកមកតាមខ្ញុំ !

រួចលោកក៏ជិះសេះចុះទៅវិញដោយកាត់ជួរកងទ័ពទាំងនោះ ។ កងជំនួយ *ប្លាក់ថន* និង *ម៉ារីកូ* ជិះតាមពីក្រោយ ។

- ចូលជួរ នៅឯខាងផ្លូវ ។ ដកចំពុះទុងចេញ ។

ទាហានពាក់កណ្ដាលបានគោរពតាមបញ្ជា ហើយបានវិលត្រលប់ចុះតាមជំរាលកូនភ្នំទៅក្រោមវិញ ។ *ណាកា* និងកងសាមូរ៉ៃរបស់គេចំនួនពីររយហាសិបនាក់ទៀតនៅឈរនៅកន្លែងដដែលប្រកបដោយអាកប្បកិរិយាដ៏គ្រោះថ្នាក់ ។ ចំពុះទុងរបស់ពួកគេនៅជាប់នឹងចុងកាណុងកាំភ្លើងនៅឡើយ ។

*ចូស៊ិន* ឆេះតួង :

- ចុះមានរឿងអីណឹង ?



www.budinst.gov.kh www.elibraryofcambodia.org

*ណាកា* ឆ្លើយតបទាំងចត់ :

- ខ្ញុំចាត់ទុកការប្រមាថរបស់លោកជាការមិនអាចទទួលយកបានឡើយ ។

- ចំជាផ្កាសមែន ។ ខ្ញុំឥតមានប្រមាថលោក រឺ ប្រមាថអ្នកណាម្នាក់ឡើយ ! ចំពុះទុង ពួកលោកទេដែលប្រមាថឋានៈរបស់ខ្ញុំ ! *យ៉ាប៊ូ-សាម៉ា* !

*យ៉ាប៊ូ* ងាកបែរមកក្រោយ ។ ពេលនេះលោកនៅឯចុងក្បួនទ័ពរបស់ *គូវ៉ាណាកា* ទៅហើយ ។ លោកស្រែកសួរយ៉ាងត្រជាក់ស្រិប :

- *ណាកា-សាន* ! តើនេះមានន័យថាម៉េច ?

- ខ្ញុំមិនអត់ទោសអោយមនុស្សនេះដែលបានជេរប្រមាថឪពុកខ្ញុំ.....រឺខ្ញុំ បានទេ ។

- គេមានការគាំពារ ណា៎ ។ លោកមិនអាចប៉ះពាល់គេបានទេ នៅពេលនេះ ! គេស្ថិតនៅក្រោមកិច្ចគាំពារនៃត្រាសាររបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ !

- សូមលោកអភ័យទោសផងចុះ *យ៉ាប៊ូ-សាម៉ា* តែនេះជារឿងរវាង *ចូសិន-សាន* នឹងខ្ញុំតែប៉ុននោះ ។

- ទេ លោកអែងនៅក្រោមបញ្ជារបស់ខ្ញុំ១បញ្ជាអោយលោកប្រាប់កូនចៅលោកអោយវិលត្រលប់ទៅជំរិញ ។

គ្មានអ្នកណាម្នាក់កំរើកខ្លួនសោះឡើយ ។ ភ្លៀងចាប់ផ្តើមធ្លាក់ ។

- សូមអភ័យទោស *យ៉ាប៊ូ-សាន*។ សូមលោកអធ្យាស្រ័យសន្តោសទោសដល់ខ្ញុំផងចុះ តែនេះជារឿងរវាងគាត់នេះនឹងរូបខ្ញុំ ហើយទោះជាមានរឿងអ្វីកើតឡើងក៏ដោយ ក៏ខ្ញុំមិនអោយលោកទទួលខុសត្រូវចំពោះទង្វើរបស់ខ្ញុំនិងកូនទ័ពរបស់ខ្ញុំឡើយ ។

នៅពីក្រោយ *ណាកា* បុរសម្នាក់របស់ *ចូសិន* ហូតដាវឡើងបំរុងកាប់ខ្នងរបស់គេដែលគ្មានអ្វីការពារនោះ ។ គ្រាប់កាំភ្លើងម្តៃគ្រាប់បានបាញ់បំបែកក្បាលបុរសនោះភ្លាម ។ ពួកទាំងម្ភៃដែលបាញ់អំបាញ់មិញនេះ លុតជង្គង់ច្រកគ្រាប់និងរំសេវភ្លាមក្នុងពេលដែលជួរទីពីរត្រៀមហើយជាស្រេច ។ *យ៉ាប៊ូ* សួរឡើង :

- អ្នកណាអោយប្រើគ្រាប់មែនទែន ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំ ! ខ្ញុំ *យ៉ូស៊ី ណាកា -ណូ-តូរ៉ាណាកា* !

- *ណាកា-សាន* ! ខ្ញុំបញ្ជាអោយលោកលែងលោក *នេចារ៉ា ចូសិន* និងកូនចៅរបស់លោកចេញពីទីនេះដោយសេរី ។ ខ្ញុំបញ្ជាអោយលោកនៅតែក្នុងជំរំរបស់លោករហូតដល់ខ្ញុំអាចពិគ្រោះជាមួយលោកម្ចាស់ *តូរ៉ាណាកា* ពីការដែលលោកមិនព្រមស្ដាប់បញ្ជារបស់ខ្ញុំ ។

- ជាការពិតហើយ លោកនឹងរាយការណ៍ជូនលោកម្ចាស់ *តូរ៉ាណាកា* ហើយ *កាម៉ា* គឺ *កាម៉ា* ។ តែខ្ញុំស្ដាយណាស់ លោកម្ចាស់ *យ៉ាប៊ូ* ដែលដំបូងបង្អស់អាគាត់នេះត្រូវតែស្លាប់សិន ។ ពួកវាទាំងអស់ហ្នឹងត្រូវតែស្លាប់ ។ ស្លាប់ក្នុងថ្ងៃនេះតែម្ដង !

*ចូសិន* ស្រែកឡើងភ្លាត់សំលេង :

- ខ្ញុំមានការគាំពាររបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ! លោកសំលាប់ខ្ញុំគឺគ្មានបានចំនេញអីទាំងអស់ ។

- ខ្ញុំចំនេញបានកិត្តិយសខ្ញុំមកវិញ *នេ ? -ណាកា* តប - ខ្ញុំអោយលោកអែងសងការជេរមជាមឪពុកខ្ញុំនិងការប្រមាថរបស់លោកអែងមកលើខ្ញុំ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោកអែងគង់តែស្លាប់ដដែល *នេ ?* ពីយប់មិញខ្ញុំបានធ្វើអោយយល់ច្បាស់ហើយតើ ។ អីលូវនេះលោកបានឃើញពីការវាយលុករួចហើយ ។ ខ្ញុំមិនអាចប្រថុយប្រថានអោយ *អ៊ីស៊ីដូ* យល់ដឹងពី...ពី... - ដៃរបស់ *ណាកា* វាសទៅទីលានសមរភូមិ - ពីការគួរអោយខ្មាចនេះទេ !

-លោកដឹងរួចទៅហើយ!-*ចូសិន* ភ្លាត់និយាយឡើងទាំងក្នុងចិត្តសរសើរពីការប្រមើលជាមុនរបស់ខ្លួនគេពីយប់ម្សិល -លោកដឹងរួចទៅហើយ ! ពេលព្រឹកព្រលឹមមិញនេះ ខ្ញុំបានបញ្ជូនសារជាសំងាត់តាមរយៈព្រាបនាំសារទៅបាត់ទៅហើយ ! អែងសំលាប់ខ្ញុំគឺគ្មានបានចំនេញអីទាំងអស់ *ណាកា-សាន* !

*ណាកា* ធ្វើសញ្ញាទៅសាមូរ៉ៃចំនាស់ម្នាក់ដែលជាកូនទ័ពរបស់ខ្លួន ។ បុរសចំនាស់ដើរចេញមកខាងមុខហើយបោះព្រាបស្លាប់មួយទៅក្បែរជើង *ចូសិន* ។ រួចក្បាលមនុស្សម្នាក់ក៏ត្រូវបានបោះទៅលើដីផងដែរ ។ នោះគឺជាក្បាលរបស់ *ម៉ាស៊ូម៉ូតូ* សាមូរ៉ៃដែល *ចូសិន* បានប្រើអោយបញ្ជូនសារចេញពីម្សិលមិញនេះ ។ ភ្នែករបស់ *ម៉ាស៊ូម៉ូតូ* បើកក្រលោត បបូរមាត់ខ្មៅ



www.budinst.gov.kh www.elibraryofcambodia.org

ឡើងទៅលើក្នុងភាពសំញែញដោយកំហឹង ។ ក្បាលរមៀលគុក១តាមផ្លូវទ័ពហើយឈប់ទំក់នឹងដុំថ្មមួយដុំ។

សំលេងថ្ងូចថ្ងូរបានលាន់លឺឡើងចេញពីបបូរមាត់ *ចូសិន*។ *ណាកា* និងកូនចៅរបស់គេផ្ទុះសំណើចក្អាកក្អាយ។ សូម្បីតែ *យ៉ាប៉ូ* ក៏ញញឹមដែរ។ កូនចៅ *ចូសិន* ម្នាក់ទៀតហក់សំដៅទៅរក*ណាកា*។ កាំភ្លើងទាំងម្ភៃដើមបានកំទេចគេម៉ត់មួយរំពេច។ សាមូរ៉ៃម្នាក់ទៀតដែលឈរនៅស្មៀមក្បែរនោះក៏ត្រូវគ្រាប់ដួលប្រកាច់ពេញនោះដែរ។

សំណើចបានរលត់ភ្លាម។

*អូមី* សួរ ទៅ *យ៉ាប៉ូ*:

- តើខ្ញុំត្រូវបញ្ជាអោយកងទ័ពខ្ញុំវាយលុករឺ លោកម្ចាស់ ?

គិតទៅ លេងល្បិចជាមួយ *ណាកា* ងាយស្រួលមែន។ *យ៉ាប៉ូ* យកដៃជូតទឹកភ្លៀងចេញពីមុខ :

- ទេ។ ធ្វើអញ្ចឹងគ្មានបានផលអីទាំងអស់។ ទោះខ្ញុំធ្វើយ៉ាងណា ក៏ *ចូសិន* និងកូនចៅរបស់គេស្លាប់បាត់ទៅហើយ។ នេះគឺ *កាម៉ា* របស់គាត់ទេ ក៏ដូចជា *កាម៉ា* របស់ *ណាកា-សាន* ដែរ -រួចលោកស្រែកហៅ *ណាកា- ណាកា-សាន* ! ជាលើកចុងក្រោយ ខ្ញុំបញ្ជាអោយលោកដោះលែងពួកគេអោយចេញទៅចុះ !

- សូមលោកម្ចាស់អភ័យទោស តែខ្ញុំត្រូវប្រកែកនឹងបញ្ជានេះ។

- ល្អ អញ្ចឹង។ កាលណារឿងរ៉ាវចប់សព្វគ្រប់ហើយ រាយការណ៍អោយខ្ញុំ។

- បាទ។ តែរឿងនេះត្រូវមានសាក្សី *យ៉ាប៉ូ-សាម៉ា*។ សំរាប់លោកម្ចាស់ *តូរ៉ាណាកា* និងលោកម្ចាស់ *អ៊ីស៊ីដូ* ។

- *អូមី-សាន* ត្រូវនៅទីនេះហើយ។ អែងត្រូវចុះហត្ថលេខាលើលិខិតបញ្ជាក់មរណភាពហើយនឹងទទួលផ្សព្វផ្សាយដំណឹងពីរឿងនេះ។ *ណាកា-សាន* នឹងខ្ញុំ នឹងចុះហត្ថលេខាទទួលបញ្ជាក់។

*ណាកា* ចង្អុលទៅ *ភ្លាក់ថន* :



www.budinst.gov.kh www.elibraryofcambodia.org

- អោយគាត់នេះនៅដែរទៅ។ នៅជាសាក្សីដែរ។ គាត់ជាអ្នកទទួលខុសត្រូវលើការស្លាប់របស់ពួកនេះ។ គាត់គួរតែធ្វើជាសាក្សីអោយពួកនេះ។

- *អាន់ជីន-សាន* ទៅខាងនោះទៅ ! ទៅខាង *ណាកា-សាន* ! លោកស្តាប់យល់ទេ ?

- បាទ *យ៉ាប៊ូ-សាន* ។ ខ្ញុំយល់ ។ តែសូមទោស ហេតុអី ?

- ធ្វើសាក្សី ។

- សូមទោស អត់យល់ ។

- *ម៉ារីកូ-សាន* ពន្យល់រឿង "សាក្សី " នេះប្រាប់គាត់ គឺថាគាត់ជាសាក្សីលើរឿងអ្វី១ដែលនឹងកើតឡើងបន្តិចទៀតនេះ រួចនាងមកតាមខ្ញុំ។

ដោយលាក់បាំងយ៉ាងជិតនូវការពេញចិត្តដ៏សំបើមរបស់ខ្លួន *យ៉ាប៊ូ* បង្វែរសេះហើយចាកចេញទៅ។ *ចូស៊ីន* ស្រែកជំទាលឡើងភ្លាត់សំលេង :

- *យ៉ាប៊ូ-សាម៉ា* ! *យ៉ាប៊ូូូូូូូ-សាម៉ាម៉ាម៉ាម៉ាម៉ា* !

***********

*ប្លាក់ថន* សង្កេតមើលនូវអ្វី១ដែលបានកើតឡើង។ ពេលដែលអ្វី១បានចប់សព្វគ្រប់ហើយនោះគេក៏វិលត្រលប់ទៅផ្ទះរបស់គេវិញដែរ។ ផ្ទះមានភាពស្ងាត់ជ្រងំ។ ទឹកដែលគេត្រាំមិនបានអោយអារម្មណ៍ជ្រះស្រលះសោះឡើយ។ ស្រា *សាកេ* មិនបានកំចាត់ចេញនូវភាពឆ្អើមចេញពីមាត់ ហើយក្លិនធូបក៏មិនបានបំបាត់ក្លិនឆ្អាបដែលនៅឈ្ងួលច្រមុះគេនៅឡើយដែរ។

បន្តិចក្រោយមក *យ៉ាប៊ូ* បានប្រើមនុស្សអោយមកហៅគេ។ ការវាយលុកត្រូវបានវិភាគមួយដំណាក់កាលម្តង១។ *អូមី* និង *ណាកា* ក៏នៅទីនោះជាមួយ *ម៉ារីកូ* ផងដែរ។ *ណាកា* ដែលរហូតមកដល់ពេលនេះនៅត្រជាក់ស្រិបជាអលង្វី មានមតិយូរ១ម្តង និងនៅតែជាមេបញ្ជាការរងដដែល។ ពួកគេទាំងអស់គ្នាហាក់ដូចឥតមានអារម្មណ៍អ្វីប៉ះពាល់នឹងព្រឹត្តការណ៍ដែលទើបនឹងបានកើតឡើងនោះឡើយ។



www.budinst.gov.kh www.elibraryofcambodia.org

ពួកគេធ្វើការហួសព្រះសុរិយាអស្តង្គតទៅទៀត។ *យ៉ាប៊ូ* បានចេញបញ្ជាអោយបង្កើនល្បឿននៃការរ៉ឹកហាត់បន្ថែមទៀតហើយកងទ័ពប្រាំរយនាក់ទៀតត្រូវទទួលការរ៉ឹកហាត់ភ្លាមៗ។ ប្រាំរយនាក់ទៀតនឹងទទួលការរ៉ឹកហាត់មួយអាទិត្យក្រោយនេះទៀតដែរ។

*ប្លាក់ថន* ដើរមកផ្ទះវិញតែម្នាក់ឯង ទទួលទានម្នាក់ឯង។ ក្នុងចិត្តរបស់គេសែនច្របូកច្របល់បណ្តាលមកពីអ្វីដែលគេទើបបានប្រទះ : *នោះគឺពួកទាំងនេះមិនមានសញ្ញាណបន្តិចណាសោះឡើយអំពីបាបធម៌។ ពួកនេះគ្មានមនសិការអ្វីបន្តិចអំពីរឿងនេះ ។ សូម្បីតែ ម៉ារីកូក៏ដោយ។*

យប់នេះគេគេងមិនលក់សោះ។ គេដើរចេញទៅក្រៅផ្ទះ។ ជំនោរខ្យល់បានបក់បោកមកលើរូបរាងកាយរបស់គេនិងបានធ្វើអោយសមុទ្រមានរលកបែកផ្កាគ្រែង។ តំនក់ទឹកភ្លៀងបានមកបោកទង្គិចខ្លួននៅលើផ្ទះសំបែងនានានៅក្នុងភូមិ។ ដំបូលស្បូវនានាពត់ពែនខ្លួនប្រៀបដូចវត្ថុមានជីវិត។ ជំនោរសមុទ្របោកច្រាំងលាន់លឺខ្ទរខ្ទារ។ ទូកនេសាទទាំងប៉ុន្មានត្រូវបានអូសយកទៅទុកដាក់នៅកន្លែងមានសុវត្ថិភាពក្នុងកំពស់មួយលើសពីសព្វដង។

*ប្លាក់ថន* ដើរតាមបណ្តោយឆ្នេរមួយរយៈទើបវិលត្រលប់ទៅដល់ផ្ទះរបស់ខ្លួនវិញដោយប្រឹងចំកោងខ្នងទប់នឹងកំលាំងខ្យល់ ។ គេឥតបានជួបអ្នកណាម្នាក់សោះឡើយ ។ ខ្លួនប្រាណគេទាំងមូលទទឹកជោក។

*ភូជីកូ* បានរង់ចាំគេនៅក្រោមសំយ៉ាបផ្ទះ។ ខ្យល់បានបក់បោកវាយវាត់លើរូបរាងកាយនាង និង ធ្វើអោយពន្លឺគោមរេរ៉េរពើត។ គ្រប់ៗគ្នាបានភ្ញាក់ពីដំណេកអស់រលីង។ អ្នកបំរើទាំងឡាយរូតរះជញ្ជូនរបស់របរមានតំលៃទៅទុកនៅឃ្លាំងថ្មមួយដែលនៅពីក្រោយសួន។

ប៉ុន្តែព្យុះមិនទាន់ក្លាយជាគ្រោះថ្នាក់នៅឡើយទេ។

ខ្យល់បក់មួយវិបទៀតបានធ្វើអោយដំបូលក្បឿងឡើងរង្គើរណ្តំគ្នា។ រួចសន្លឹកក្បឿងក៏ធ្លាក់បែកលីសូរច្រាវ។ អ្នកបំរើប្រញាប់ដៃជើង ខ្លះរត់ទៅយកយោងមកដាក់ត្រងទឹកភ្លៀង ខ្លះវ៉ាសរវៃជួសជុលដំបូល។ តាឆ្នាំសួន *អូគីយ៉ា* ដោយមានជំនួយពីពួកក្មេងៗផងនោះ បានប្រឹងចងកូនឈើ និង គុម្ពផ្កានានាផ្ទោបនឹងពឹងពង់រឹស្សី។

ខ្យល់មួយវិបទៀត បានធ្វើអោយតួផ្ទះទាំងមូលញ័ររញ្ជួយ។



www.budinst.gov.kh www.elibraryofcambodia.org

- មើលទៅផ្ទះនេះត្រូវប៉ើងដូចស្បូវកណ្ដបជាមិនខានទេ *ម៉ារីកូ-សាន*។

នាងឥតមាននិយាយអ្វីមួយម៉ាត់ឡើយ។ កំលាំងខ្យល់កំពុងខ្ទារខ្ទាមនាងនិង *ភូជីកូ*។ តែចោលភ្នែកសំលឹងមើលទៅភូមិ។ កំនាត់នានាត្រូវខ្យល់បក់ប៉ើងសព្វទិសទី។ ទឹកភ្លៀងបានហូរធ្លាក់តាមប្រហោងដំបូលជ្រាបតាមជញ្ជាំង ហើយមួយសន្ទុះក្រោយជញ្ជាំងក្រដាស់មួយផ្ទាំងនៃគេហដ្ឋានក៏រលាយបាត់នៅសល់តែគំរោងឆ្អឹង ហើយបន្ទាប់មកទៀតដំបូលត្រូវធ្លាក់ចុះរាបដល់ដី។

*ភ្ញាក់ថន* បែរសំលឹងមើលទាំងអស់សង្ឃឹម នៅពេលដែលជញ្ជាំងបន្ទប់គេត្រូវប៉ើងទៅបាត់នោះ។ បន្ទាប់មកទៀត គឺជាវេនជញ្ជាំងទល់មុខគ្នា។ មួយសន្ទុះក្រោយមកទៀត ជញ្ជាំងទាំងមូលប្រែក្លាយទៅជាចំរៀកទាំងអស់តែម្តង។ គេអាចមើលផ្ទះគេឃើញពីម្ខាងទៅម្ខាងតែទំរដំបូលរបស់គេនៅទ្រាំទ្របាននៅឡើយហើយគ្រឿងនៅពីលើនោះក៏ឥតរខិតទៅណាដែរ។ គោមកំរាល ភួយ ត្រូវខ្យល់បក់ប៉ើងខ្ចាត់ខ្ចាយ ធ្វើអោយពួកអ្នកបំរើត្រូវរត់រវៀរដើម្បីប្រឹងចាប់យករបស់ទាំងនេះមកវិញ។

ព្យុះបានបំផ្លាញជញ្ជាំងផ្ទះមួយភូមិតែម្តង។ផ្ទះខ្លះត្រូវរលំរលាយដល់ដី តែគ្មានអ្នកណាមួយទទួលគ្រោះថ្នាក់ធ្ងន់ធ្ងរទេ។ ខ្យល់នៅមាននៅឡើយនាពេលព្រឹកព្រលឹមឡើង តែទាំងប្រុសទាំងស្រីបានចាប់ផ្តើមកសាងផ្ទះខ្លួនជាថ្មីវិញភ្លាមហើយ។

នៅវេលាថ្ងៃត្រង់ ជញ្ជាំងផ្ទះរបស់ *ភ្ញាក់ថន* ត្រូវបានធ្វើឡើងវិញហើយរួចរាល់ជាស្រេច។ ជាងពាក់កណ្តាលភូមិបានវិលត្រលប់ទៅរកប្រក្រតីភាពវិញហើយ ដោយថាជញ្ជាំងប្រដឹសមិនលំបាកធ្វើនោះទេ។ គ្រឿងនិងដំបូលស្បូវមានការលំបាកបន្តិចមែន តែ *ភ្ញាក់ថន* បានឃើញអ្នកភូមិខិតខំជួយគ្នាទាំងទឹកមុខញញឹមរីករាយ យ៉ាងរហ័សរហួននិងយ៉ាងប្រសប់។ *មូរ៉ា* ដើរខ្ទិចខ្ទិលពេញភូមិ ជួយអោយយោបល់ ជួយដឹកនាំ ជួយជំរុញ និង ត្រួតមើលការងារ រួចគេឡើងមកឈរពីលើកំពូលកូនភ្នំដើម្បីពិនិត្យល្បឿនការងារ។

- *មូរ៉ា* លោកប៉ុនធ្វើអោយ......- *ភ្ញាក់ថន* ប្រឹងគិតរកពាក្យ -ធ្វើអោយអ្វីៗមានភាពទូរល្មុយតែម្តង។



www.budinst.gov.kh www.elibraryofcambodia.org

- អូ អរគុណ *អាន់ជីន-សាន*។ បាទ សូមអរគុណ តែលើកនេះយើងហេងដោយអត់មានភ្លើងឆេះ ។

- លោកភ្លើងឆេះញឹកញាប់ ?

- សូមទោស លោកត្រូវមានប្រសាសន៍ថា " តើលោកមានភ្លើងឆេះញឹកញាប់ទេ ?" ទើបត្រូវ ។

*ភ្លាក់ថន* និយាយថាតាម :

- តើលោក មានភ្លើងឆេះញឹកញាប់ទេ ?

- បាទ ញឹកញាប់ ។ តែខ្ញុំបានអោយភូមិត្រៀមជាមុន ។ *ត្រៀមជាមុន* លោកយល់ទេ?

- យល់ ។

- នៅពេលណាដែលមានព្យុះបែបនេះ មក........

ខ្លួនរបស់ *មូរ៉ា* ឡើងរឹងឆ្អឹតភ្នែករបស់គេសំលឹងមើលទៅអ្វីដែលនៅពីក្រោយ *ភ្លាក់ថន*។ រួចគេលំអោនខ្លួនយ៉ាងទាប ។

*អូមី* កំពុងដើរក្នុងដំណើរខ្ញើចៗមកពីក្រោយ *ភ្លាក់ថន*។ ភ្នែកពោរពេញដោយមិត្តភាពរបស់គេផ្តោតតែទៅលើ *ភ្លាក់ថន* ម្នាក់ប៉ុននោះ ហាក់ដូចជា *មូរ៉ា* គ្មានវត្តមាននៅទីនេះបន្តិចណាឡើយ ។ គេពោលឡើង :

- អរុណសួស្តី *អាន់ជីន-សាន*។

- អរុណសួស្តី *អូមី-សាន*។ ផ្ទះលោកស្រួលបួលទេ ?

- ស្រួលបួលទេ ។ អរគុណ ។

រួចគេងាកសំលឹងមើលទៅ *មូរ៉ា* ហើយនិយាយយ៉ាងកំបុតកំបុយ :

- ពួកប្រុសៗគួរតែទៅចាប់ត្រី រឺទៅស្រែចំការ ។ ស្រីៗក៏អញ្ចឹងដែរ ។ *យ៉ាប៊ូ-សាម៉ា* ត្រូវការហួតពន្ធរបស់លោក ។ អែងចង់បំបាក់មុខខ្ញុំនៅមុខគាត់ដោយភាពច្រអូសអញ្ចឹង អ្វី ?

- មិនមែនទេ *អូមី-សាម៉ា*។ សូមលោកអភ័យទោសផងចុះ ។ ខ្ញុំនឹងទៅចាត់ចែងរឿងនេះភ្លាម ។



www.budinst.gov.kh www.elibraryofcambodia.org

- រឿងអញ្ចឹង១ដូចជាមិនបាច់ប្រាប់ទេ។ លើកក្រោយយើងមិនបាច់ប្រាប់អែងទៀតទេ។

- ខ្ញុំសូមលោកអត់ទោសដល់ភាពពក្លីពភ្លើរបស់ខ្ញុំផង ទាន។

រួច *ម្ងក៌* ក៏ប្រញាប់ប្រញាល់ចេញដំណើរទៅ។ *អូមី* ក៏បែរមកនិយាយជាមួយ *ប្លាក់ថន* ម្តង :

- ថ្ងៃនេះលោកស្រួលបួលហើយ។ យប់មិញអត់មានបញ្ហាអីទេ ?

- ថ្ងៃនេះស្រួលបួលទេ។ សូមអរគុណលោក។ ចុះលោកវិញ ?

*អូមី* និយាយយ៉ាងវែង តែ *ប្លាក់ថន* ស្តាប់មិនបានអស់ឡើយដោយគេអាចយល់បានតែបន្តិចបន្តួចពីអ្វីដែល *អូមី* បាននិយាយទៅកាន់ *ម្ងក៌* មុននេះបន្តិចនោះ។

- សូមទោស ខ្ញុំមិនយល់ទេ។

- សប្បាយទេ ? ពីម្សិលមិញលោកចូលចិត្តទេ ? ការវាយលុក នោះអី ? ការសាកប្រយុទ្ធនោះ ?

- អូហ៎ ខ្ញុំយល់ហើយ។ បាទ ខ្ញុំយល់ថាល្អណាស់។

- រួចចុះរឿងធ្វើសាក្សី ?

- ថាម៉េច ?

- ធ្វើសាក្សី ! រឿងអា *រ៉ូនីន នេចាក៌ ចូសិន* និង កូនចៅវានោះណា ? -*អូមី* ធ្វើត្រាប់ការវាយលុកដោយចំពុះទុងទាំងសំនើចក្អាកក្អាយ -លោកធ្វើសាក្សីនៃការស្លាប់របស់ពួកវានោះ។ ស្លាប់ ! លោកយល់ទេ ?

- អូ មែនហើយ។ និយាយត្រង់ អូ *មី-សាន*។ អត់ចូលចិត្តសំលាប់។

- *កាម៉ា អាន់ជីន-សាន*។

- *កាម៉ា*។ ថ្ងៃនេះហាត់ ?

- ណឹងហើយ។ តែ *យ៉ាប៊ូ-សាម៉ា* ចង់ជជែកតែប៉ុននោះ។ ចាំក្រោយ។ យល់ទេ *អាន់ជីន-សាន* ? ជជែកគ្នាទទេ បន្តិចទៀត -*អូមី* និយាយចុះឡើងយ៉ាងអត់ធ្មត់។



www.budinst.gov.kh www.elibraryofcambodia.org

- ជម្រៅកត្តាតែប៉ុណ្ណោះ ។ យល់ហើយ ។

- លោកចាប់ផ្ដើមនិយាយភាសាយើងបានល្អណាស់ហើយ ។ មែនណា ។ ល្អណាស់ ។

- អរគុណលោក ។ លំបាក ។ ពេលតូច ។

- ពិតហើយ តែលោកជាមនុស្សល្អហើយលោកប្រឹងប្រែងខ្លាំងក្លាមែនទែន ។ នេះសំខាន់ ។ ពួកយើងនឹងផ្ដល់ពេលវេលាជូនលោក *អាន់ជីន-សាន*។ សូមលោកកុំព្រួយបារម្ភអី ។ ខ្ញុំនឹងជួយលោក ។

ថ្វីត្បិត *អូមី* មើលឃើញថាមួយភាគធំនៃអ្វីដែលគេបាននិយាយនេះត្រូវ *ប្លាក់ថន* ស្ដាប់មិនបានយ៉ាងណាក៏ដោយ ក៏គេមិនរវល់ដែរ សំខាន់អោយតែ *អាន់ជីន-សាន* យល់ន័យទៅបានហើយ ។ គេនិយាយបន្ត :

- ខ្ញុំចង់ធ្វើជាមិត្តរបស់លោក -គេនិយាយឡើងវិញយ៉ាងច្បាស់ៗនូវឃ្លានេះម្ដងទៀត ទើបសួរឡើង -លោកយល់ទេ ?

- មិត្ត ? ខ្ញុំយល់បានពាក្យ " មិត្ត " ។

*អូមី* ចង្អុលទៅខ្លួនឯង រួចចង្អុលទៅ *ប្លាក់ថន* :

- ខ្ញុំចង់ធ្វើជាមិត្តរបស់លោក ។

- អ្ហា ! អរគុណ ។ មានកិត្តិយសណាស់ ។

*អូមី* ញញឹមម្ដងទៀតរួចលំអោនគោរពរបៀបស្ទើរត្រាហើយដើរចេញទៅ ។

- មិត្តជាមួយអ្អែង ? -*ប្លាក់ថន* ពោលរង៉ូវៗ -អែងភ្លេចហើយរឺ ? អញមិនទាន់ភ្លេចទេ ។

*ភូជីកូ* ប្រញាប់ប្រញាល់ដើរសំដៅមករកគេ :

- *អាន់ជីន-សាន* តើលោកចង់ទទួលទានបាយទេ ? បន្តិចទៀត *យ៉ាហ្គូ-សាម៉ា* នឹងអោយគេមកហៅលោកទៅហើយ ។

- បាទ អរគុណ ។ បែកច្រើនទេ ? -គេសួរដោយលើកដៃចង្អុលទៅផ្ទះ ។

- សូមទោស លោកគួរមានប្រសាសន៍ថា "តើមានការបែកបាក់ច្រើនទេ?" ទើបត្រូវ ។



www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

- មានការបែកបាក់ច្រើនទេ ?

- គ្មានការខូចខាតធំដុំទេ *អាន់ជីន-សាន*។

- ល្អ ។ អត់របួសទេ ?

- អត់ទេ *អាន់ជីន-សាន*។ តែលោកគួរមានប្រសាសន៍ថា ៉អត់មានអ្នកណាត្រូវរបួសទេ៉ វិញ ។

*ប្លាក់ថន* មានការនឿយណាយយ៉ាងខ្លាំងនឹងប្រការដែលត្រូវតែកែខ្លួនជាប់យ៉ាងនេះ តែក៏បញ្ចប់កិច្ចសន្ទនាដោយចេញបញ្ជា :

- ខ្ញុំតំលាន ។ ម្ហូប !

- ចាស យកមកភ្លាម ។ សូមទោសប៉ុន្តែលោកគួរមានប្រសាសន៍ថា ៉ ខ្ញុំឃ្លាន ៉ ។ មនុស្សមានតំលាន គឺឃ្លាន ។

នាងរង់ចាំរហូតទាល់តែ *ប្លាក់ថន* និយាយត្រូវហើយទើបចេញទៅ ។

*ប្លាក់ថន* អង្គុយក្រោមសំយ៉ាបរានហាលសំលឹងមើលតាំថៃសួនច្បារ *អ៊ូគីយ៉ា* ជួសជុលការខូចខាត និង ប្រមែប្រមូលស្លឹកឈើដែលធ្លាក់រាយប៉ាយពាសពេញដី ។ គេមើលឃើញពួកស្ត្រី និង កុមារៗកំពុងជួសជុលភូមិ ហើយនឹងទូកទាំងឡាយដែលចេញទៅឯនាយសមុទ្រកាត់រលកសមុទ្របាក់ប៉ើកៗ ។ អ្នកភូមិឯទៀតដើរតើមៗទៅស្រែចំការរបស់ខ្លួន ។ នៅពេលនេះខ្យល់បានបន្ថយកំលាំងហើយ ។ តើពួកនេះត្រូវបង់ពន្ធអ្វីទៅអញ្ចេះ ? គេដណ្តឹងសួរនៅក្នុងចិត្ត ។ អញមិនចង់ធ្វើជាអ្នកស្រែនៅទីនេះទេ ។ មិនមែនតែនៅទីនេះទេ គឺនៅគ្រប់កន្លែងតែទាំងអស់ណឹង ។

នៅពេលភ្លឺស្រាងៗភ្លាមនោះ តែសែនស្ងួតចិត្តនឹងរូបភាពក្រៅនៃទំហំខូចខាតនៅក្នុងភូមិនេះ ។ គេពោលទៅកាន់ *ម៉ារីកូ* :

- ព្យុះបែបនេះមិនងាយធ្វើអោយខូចខាតផ្ទះអង់គ្លេសទេ ។ ព្យុះគឺព្យុះហើយ តែមិនមែនធំណាស់ណាទេ ។ ម៉េចបានជាពួកអ្នកស្រុកនាងមិនសង់ផ្ទះថ្មវិញ ?

- ពីព្រោះរញ្ជួយផែនដីណា *អាន់ជីន-សាន*។ ផ្ទះថ្មអាចប្រេះនិងបាក់ហើយអាចធ្វើអោយរបួសរឺ មានគ្រោះថ្នាក់ដល់ស្លាប់ដល់អ្នកនៅក្នុងផ្ទះបាន ។ សង់ផ្ទះរបៀបយើងនេះនាំ



www.budinst.gov.kh www.elibraryofcambodia.org

អោយមានការខូចខាតតែបន្តិចបន្តួចតែប៉ុណ្ណោះ ។ លោកនឹងអាចឃើញបន្តិចទៀតនេះ ថាតើយើងនឹងជួសជុលផ្ទះយើងរហ័សយ៉ាងណា ។

- អញ្ចឹងហើយ តែនាងក៏មានគ្រោះភ្លើងឆេះដែរ ។ រួចនៅពេលដែលមានខ្យល់ធំគឺ *វ៉ៃភូន* នោះ តើវានឹងទៅជាយ៉ាងណា ?

- ពេលណុងចំជាយ៉ាប់មែនទែនហើយ ។

នាងបានពន្យល់ពីរឿង *វ៉ៃភូន* និងពីរដូវរបស់វា ពោលគឺពីខែមិថុនាដល់ខែកញ្ញា ជូនកាលមកយឺតបន្តិច ។ នាងក៏បានពន្យល់គេពីមហន្តរាយផ្សេងៗទៀតដែរ ។

ប៉ុន្មានថ្ងៃមុននេះ មានការរញ្ជួយមួយដែរ ។ នោះគឺការរញ្ជួយដ៏តូចមួយប៉ុណ្ណោះ ។ កំសៀវមួយបានរលំទៅទាំងចង្ក្រាន ។ ជាសំណាងល្អ រងើកភ្លើងត្រូវបានពន្លត់អស់ ។ ផ្ទះមួយទៀតនៅក្នុងភូមិត្រូវភ្លើងឆេះតែមិនបានរាលឆ្លងទៅផ្ទះផ្សេងទៀតឡើយ ។ *ប្លាក់ថន* មិនដែលឃើញរបៀបពន្លត់ភ្លើងឯណាដែលមានប្រសិទ្ធិភាពដូចនៅទីនេះទេ ។ ក្រៅពីរឿងរ៉ាវខូចខាតនេះ គ្មានអ្នកភូមិណាមួយរវីរវល់លើអ្វីទៀតសោះឡើយ ។ គេគ្រាន់តែនាំគ្នាសើចហើយបន្តការរស់នៅជាធម្មតារបស់គេទៅ ។

- ហេតុអ្វីបានជាពួកគេសើចអញ្ចឹង ?

- ពួកយើងតែងចាត់ទុកថាជាការអាម៉ាស់ និង ជាការមិនសមរម្យទេដែលត្រូវបង្ហាញនូវចេតនាអារម្មណ៍ខ្លាំងក្លា ពិសេសការភ័យខ្លាច ។ ដោយហេតុនេះហើយយើងតែងបិទបាំងវាក្រោមភាពនៃសំណើច រឺ ញញឹមទៅវិញ ។ ពិតហើយ ពួកយើងភ័យខ្លាច ថ្វីត្បិតតែពួកយើងមិនដែលបង្ហាញវាចេញមកក្តី ។

តែមានពួកនាងខ្លះបានបង្ហាញចេញដែរ -*ប្លាក់ថន* គិតនៅក្នុងចិត្ត ។

*ទេពារ៉ា ចូសិន* បានបង្ហាញភាពភ័យខ្លាចរបស់ខ្លួន ។ គេបានស្លាប់យ៉ាងអន់ជាទីបំផុត ។ គេស្លាប់ទាំងយំសស្រិចសស្រាក់ទាំងតក់ស្លុត ទាំងអង្វរសុំការប្រោសប្រណី ហើយការសំលាប់បានប្រព្រឹត្តទៅយ៉ាងយឺតៗ និង យ៉ាងសាហាវ ។ គេត្រូវបានទទួលការអនុញ្ញាតអោយរត់ រួចត្រូវគេចាក់នឹងចំពុះទុងយ៉ាងប្រុងប្រយ័ត្ន ក្រោមសំណើចសើចក្អាកក្អាយ រួចត្រូវគេបង្ខំអោយរត់ទៀត



www.budinst.gov.kh www.elibraryofcambodia.org

ទើបពួកគេកាត់សរសៃកំភួនជើង។ *ចូសិន* ត្រូវលូនលើដីរួចត្រូវគេវះពោះបន្តិចម្តង១ក្រោមសំរែកយ៉ាងគ្រលូច ឈាមរបស់គេហូរតក់១លាយឡំនឹងសំបោរនិងកំហាក ទើបគេទុកអោយនៅរបៀបនេះទៅ។

បន្ទាប់មកទៀតទើប *ណាកា* ងាកទៅរកពួកសាមូរ៉ៃឯទៀត។ កូនចៅ *ចូសិន* បីនាក់លុតជង្គង់ចុះភ្លាមហើយទាញអាវអោយពោះនៅកណ្តាលវាល ដាក់ដាវខ្លីនៅចំពីមុខដើម្បីធ្វើ *សិបពួគូ* តាមទំនៀមទំលាប់។ មិត្តរួមអាវុធរបស់គេបីនាក់ទៀតនៅឈរពីក្រោយដើម្បីធ្វើជាអ្នកជំនួយ ដៃទាំងពីរកាន់ដាវវែងលើកឡើងខ្ពស់ទៅលើ។ ពួកគេមិនត្រូវបានធ្វើបាបដោយកូនចៅរបស់ *ណាកា* ទៀតទេក្នុងពេលនោះ។ ពេលដែលអ្នកលុតជង្គង់ចាប់កាំបិតខ្លីរបស់ខ្លួនហើយផ្ទៃដាវក៏វាត់ផ្តាច់ក្បាលទាំងបីដាច់ត្រឹមភ្លាម។ សំលេងច្មេញទៅលាន់រណ្តំនៅក្នុងក្បាលដែលធ្លាក់ចុះ រួចទើបស្ងាត់ឈឹង។ រុយចាប់រោមជុំគ។

បន្ទាប់មកសាមូរ៉ៃពីរនាក់ទៀតលុតជង្គង់ចុះ ដោយទុកអ្នកចុងក្រោយគេម្នាក់ជាអ្នកជំនួយ។ បុរសដែលលុតជង្គង់ទីមួយត្រូវបានមិត្តខ្លួនកាត់ក្បាលភ្លាមនៅពេលដែលគេកាន់ដាវខ្លី។ បុរសម្នាក់ទៀត និយាយឡើង :

- ទេ ខ្ញុំ *ហ៊ីរ៉ាសាគី កិនកូ* ខ្ញុំដឹងថាតើត្រូវស្លាប់របៀបម៉េច......ពីរបៀបដែលសាមូរ៉ៃត្រូវស្លាប់។

*កិនកូ* ជាយុវជនម្នាក់រហ័សរហួន ខ្លួនប្រាណលាបគ្រឿងក្រអូបហើយអាចចាត់ទុកថាជាយុវជនម្នាក់ស្រស់ស្អាតមានសំបុរសស្លាំង សក់លាបប្រេង និងចងស្អាតបាត។ គេចាប់យកកាំបិតរបស់គេក្នុងអាការៈគោរពហើយរុំផ្ទៃកាំបិតមួយភាគនឹងក្រណាត់ចង្កេះរបស់គេដើម្បីកាន់បានណែនល្អ។ គេលំអោនគោរព *ណាកា* ហើយនិយាយយ៉ាងម៉ឺងម៉ាត់ថា :

- ខ្ញុំតវ៉ានឹងការស្លាប់របស់ *ទេពារ៉ា ចូសិន* ហើយនឹងមនុស្សទាំងអស់របស់លោក។

គេសំលឹងមើលមេឃជាចុងក្រោយរួចទើបញញឹមជាការលួងលោមចុងក្រោយ ទៅមិត្តជំនួយរបស់ខ្លួន :

- *សាយ៉ូណារ៉ា តាដេអូ*។



www.budinst.gov.kh www.elibraryofcambodia.org

រួចគេបុះកាំបិតយ៉ាងជ្រៅចំផ្ចិតខាងឆ្វេងពោះរបស់គេ ហើយអូសកាំបិតនេះកាត់មួយទទឹងពោះដោយដៃទាំងពីរ រួចទើបដកកាំបិតចេញហើយបុះម្តងទៀតចំពីលើផ្ចិតនោមហើយអូសឡើងមកលើយ៉ាងស្ទៀមស្ទាត់ ។ ពោះវៀនពោះតាំងដែលដាច់ដោចទាំងប៉ុន្មានធ្លាក់គរលើជង្គង់របស់គេ ។ នៅពេលដែលមុខក្រវៀចក្រវូរដោយការឈឺចាប់របស់គេទោរទៅមុខហើយនោះ ជំនួយរបស់គេក៏វាត់ដាវដាច់ក្បាលត្និលភ្លាម ។

*ណាកា* ច្បាមសក់យួរក្បាល *កិនកូ* ឡើងដោយដៃខ្លួនផ្ទាល់ ។ គេបោសដីចេញពីមុខសពហើយបិទភ្នែកទាំងគូរបស់សព បន្ទាប់មកគេប្រាប់កូនចៅរបស់គេអោយចាត់ចែងសំអាតសព់ខ្ទប់ក្បាលនេះអោយបានស្អាតបាតដើម្បីបញ្ជូនទៅអោយ *អ៊ីស៊ីដូ* ក្នុងកិត្តិយសដោយភ្ជាប់ជាមួយនូវរបាយការណ៍ពេញលេញស្តីពីភាពអង់អាចក្លាហានរបស់ *ហ៊ូរ៉ាសាគីកិនកូ* ទៅជាមួយផង ។

សាមូរ៉ៃចុងក្រោយក៏លុតជង្គង់ចុះ ។ គេក៏ជាយុវជនម្នាក់ដែរ ។ គ្មានអ្នកណាម្នាក់នៅសល់ដើម្បីជាជំនួយដល់រូបគេឡើយ ។ ដៃគេឡើងញ័រហើយខ្លួនគេទាំងមូលត្រូវលុកទន្រ្ទានដោយការតក់ស្លុត ។ ពីរដងហើយដែលគេបំពេញភារកិច្ចរបស់គេចំពោះមិត្តរួមអាវុធរបស់ខ្លួន ។ ពីរដងហើយដែលគេបានកាត់ក្បាលមិត្តគេយ៉ាងស្អាត និងយ៉ាងថ្លៃថ្នូរ បញ្ចៀសអោយពួកគេបានផុតពីការឈឺចាប់ និង ភាពអាម៉ាស់ពីការភ័យខ្លាច ។ គេមិនដែលសំលាប់អ្នកណាម្នាក់ទេ តាំងពីដើមមក ។

ភ្នែករបស់គេសំលឹងមើលកាំបិតផ្ទាល់ខ្លួនឯង ។ គេដោះសំដិលពោះនៅកណ្តាលវាលទាំងបន់ស្រន់នៅក្នុងចិត្តសូមសេចក្តីក្លាហានពីអ្នកដែលគេស្រលាញ់ ។ ទឹកភ្នែកមាននៅក្នុងរង្វង់ភ្នែករបស់គេតែគេបានបង្កកទឹកមុខរបស់គេអោយនៅជារបាំងមុខញញឹមកំព្រើសមួយ ។ គេដោះយកក្រណាត់ខ្សែចង្កេះមករុំផ្ចិតកាំបិតមួយភាគ ។ *ណាកា* ដោយឃើញយុវជននេះបានបំពេញភារកិច្ចរបស់ខ្លួនយ៉ាងល្អនោះ ក៏បានធ្វើសញ្ញាអោយជំនួយការរបស់ខ្លួនម្នាក់មកធ្វើជំនួយ ។

ជំនួយការនេះឈានដើរមកខាងមុខ លំអោនខ្លួនគោរពហើយឧទ្ទេសនាមខ្លួនឯងយ៉ាងត្រឹមត្រូវ :

- *អូសាវ៉ាគី ណាំប៉ូ* មេបញ្ជាការកងពលទីប្រាំបួននៃកងទ័ពរបស់លោកម្ចាស់ *តូរ៉ា*



www.budinst.gov.kh www.elibraryofcambodia.org

*ណាកា* ។ ខ្ញុំមានកិត្តិយសណាស់ដែលបានមកធ្វើជាជំនួយលោក ។

- *អ៊ីតូម៉ូ តាដេអូ* នាយកងទីមួយ អណ្ដាប់របស់លោកម្ចាស់ *អ៊ីស៊ីដូ* -យុវបុរសតប-សូមអរគុណលោក ។ ខ្ញុំមានកិត្តិយសនឹងទទួលលោកជាជំនួយរបស់ខ្ញុំណាស់ ។

ការស្លាប់របស់គេគឺរហ័ស គ្មានការឈឺចាប់ និងប្រកបដោយកិត្តិយស ។

ក្បាលរបស់ *តាដេអូ* ត្រូវគេរើសទុកដាក់ស្រួលបួល ។ ក្រោយនោះបន្តិច *ចូស៊ិន* បានភ្ញាក់ដឹងស្មារតីឡើងវិញ ។ ដៃគេខិតខំទាំងអស់សង្ឃឹមប្រមែប្រមូលពោះវៀនពោះតាំងញាត់ចូលទៅក្នុងពោះវិញ ។

ពួកគេបានទុក *ចូស៊ិន* អោយឆ្កែទាំងឡាយដែលកំពុងបោលមកពីភូមិ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៣៤

នៅយាមមមី ពេលគឺនៅវេលាម៉ោងដប់មួយព្រឹក ដប់ថ្ងៃក្រោយមរណភាពរបស់ *ចូសិន* និងកូនចៅរបស់គេទាំងអស់មក ទូកធំចំនួនបីគ្រឿងបានបត់ក្បាលតាមជ្រោយឆ្នេរសមុទ្រមកឈប់សំចតនៅ *អាន់ជីរ៉ូ* ។ ទូកធំនីមួយៗផ្ទុកទាហានណែនក្តន់ ។ *តូរ៉ាណាកា* ចុះមកលើដីដោយមាន *ប៊ុនតារ៉ូ* ដើរតាមពីក្រោយផង ។ លោកបន្លឺសំដី :

- *យ៉ាប៊ូ-សាន* ដំបូងបង្អស់ខ្ញុំចង់មើលសមយុទ្ធវាយលុកដោយប្រើកំលាំងពួកទាំងប្រាំរយនាក់ដែលហាត់ពីដើមទីតែ ។ មើលអីលូវហ្នឹងឯង ។

-តើអាចចាំស្អែកទៅបានទេ ទាន ? ធ្វើស្អែកដើម្បីខ្ញុំមានពេលវេលារៀបចំបានផង ។

*យ៉ាប៊ូ* និយាយយ៉ាងផ្អែម តែនៅក្នុងចិត្តលោកសែនឆេះដុំជាពន់ពេកនឹងប្រការដែល *តូរ៉ាណាកា* មកដល់ថ្មីមរបៀបនេះផង ឆេះដុំនឹងពួកយកការណ៍របស់ខ្លួនដែលមិនបានជូនដំណឹងអ្វីណាបន្តិចអោយលោកបានដឹងជាមុនពីរឿងនេះផង ។ លោកស៊ីងតែគ្មានពេលគ្រប់គ្រាន់ដើម្បីនឹងយកពួកកងកិត្តិយសទៅឯមាត់សមុទ្ទផង ។ លោកបន្ត :

- លោកម្ចាស់ប្រហែលនឿយហត់....

- ខ្ញុំឥតមាននឿយហត់អីទេ សូមអរគុណ - *តូរ៉ាណាកា* និយាយយ៉ាងកំបុត និងយ៉ាងចេតនា - ខ្ញុំមិនត្រូវការរៀបឆាកជា " ពួកការពារ " រឺតុបតែងមិត់ចត់ធ្វើស្រែក រឺធ្វើស្លាប់នោះទេ ។ សំលាញ់ចាស់ ! មិត្តឯងភ្លេចថា ខ្ញុំធ្លាប់បានសំដែងល្ខោន *ណូ* ច្រើនល្មម នឹងអាចប្រើការស្រមៃគិតរបស់ខ្ញុំបានហើយតើ ។ ខ្ញុំមិនមែនជា *រ៉ូនីន-* កសិករឯណា ! សូមមិត្តមេត្តាចាត់ចែងរៀបចំភ្លាមទៅ ។

ពួកគេកំពុងឈរនៅលើមាត់ឆ្នេរសមុទ្រ ក្បែរកំពង់ផែ ។ នៅជុំវិញ *តូរ៉ាណាកា* មានសុទ្ធតែជាកងការពារជើងឆើតៗ ហើយមួយចំនួនទៀតកំពុងតែចុះរពុយពីលើទូកធំ ដែលបានអែបផែនេះជាហូរហែ ។ *សាមូរ៉ៃ* ប្រដាប់អាវុធស្រោចខ្លួនមួយពាន់នាក់ទៀត នៅកកកុញលើទូកធំពីរទៀត ដែលកំពុងរង់ចាំនៅឆ្ងាយពីផែនៅឡើយ ។ ថ្ងៃនេះអាកាសធាតុក្តៅល្មម មេឃស្រលះ គ្មានពពកមួយដុំ ។ ផ្ទៃសមុទ្ទមានរលកតូចល្មម ហើយនៅឯនាយមាន



www.budinst.gov.kh www.elibraryofcambodia.org

លេចចេញចំហាយទឹកព្រាល១ ។

- *អ៊ីកូរ៉ាជី* មើលចាត់ចែងការងារនេះភ្លាម !

*យ៉ាប៊ូ* ប្រឹងលេបក់ហឹងមូម៉ៅរបស់លោក ។ តាំងពីពេលលោកបានបញ្ជូនសារស្តីពីការមកដល់របស់ *ចូស៊ិន* កាលពីដប់មួយថ្ងៃមុននោះមក លោកមិនដែលបានទទួលដំណឹងសំខាន់អ្វីមួយពីពួកអ្នកយកការណ៍របស់លោក ដែលនៅឯ *យេដូ* នោះសោះ ក្រៅតែពីចំលើយដ៏គួរអោយមួម៉ៅរបស់ *តូរ៉ាណាកា* មួងម្កាលចំពោះការផ្តល់សញ្ញាដ៏កាន់តែរន្ទាន់របស់លោកតែប៉ុណ្ណោះ ដូចជា : " បានទទួលសារលោកហើយ ។ កំពុងពិនិត្យពិចារណាយ៉ាងម៉ត់ចត់ " " ភ្ញាក់ផ្អើលនឹងដំណឹងរបស់លោកស្តីពីកូនប្រុសរបស់ខ្ញុំ ។ សូមរង់ចាំការណែនាំបន្ថែមពីខ្ញុំ " ជាដើម ។ រួចបួនថ្ងៃមុននេះ : " អ្នកណាដែលទទួលខុសត្រូវក្នុងរឿងមរណភាពរបស់ *ចូស៊ិន* និងត្រូវផ្តន្ទាទោស ។ អ្នកទាំងនោះត្រូវនៅប្រចាំកន្លែងក្នុងស្ថានភាពជាប់ទោសរហូតដល់ខ្ញុំអាចពិគ្រោះជាមួយ *អ៊ីស៊ីដូ* " ។ ហើយនៅពីម្សិលមិញនេះ គឺជាដំណឹងផ្ទុះដូចគ្រាប់បែកតែម្តង : " ថ្ងៃនេះខ្ញុំបានទទួលសំបុត្រអញ្ជើញជាផ្លូវការទៅចូលរួមពិធីបុណ្យមើលផ្កានៅឯ *អូសាកា* ពីក្រុមប្រឹក្សាអាជ្ញានុសិទ្ធិថ្មី ។ តើលោកមានផែនការចេញទៅពេលណា ? សូមផ្តល់យោបល់ជាប្រញាប់ផង " ។

*យ៉ាប៊ូ* លើកជាសំនួរទាំងភ័ន្តភាំង :

- នេះមិនមែនមានន័យថា *តូរ៉ាណាកា* កំពុងចេញដំណើរទៅទេឬ ?

- គាត់បង្ខំអោយលោកម្ចាស់ធ្វើការជ្រើសរើសដោយខ្លួនឯង -*អ៊ីកូរ៉ាជី* តប-ទោះជាលោកមានប្រសាសន៍យ៉ាងម៉េចក៏ជាប់ដែរ ។

- ខ្ញុំឯកភាព -*អូមី* ពោលបន្ថែ ។

- ហេតុអីបានជាយើងមិនដែលបានដឹងដំណឹងពី *យេដូ* សោះអ៊ីចឹង ? តើពួកយកការណ៍យើងវាយ៉ាងម៉េចទៅហើយ ?

-នេះហាក់ដូចជា *តូរ៉ាណាកា* គ្រប់គ្រងណាត់បាំងជិតតំបន់ *ក្វាន់តូ* ទាំងមូលអ៊ីចឹង- *អូមី* ពោល - ប្រហែលជាគាត់ដឹងថា ពួកយកការណ៍របស់លោកជាអ្នកណាខ្លះហើយមើលទៅ !



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ីកូរ៉ាជី* ពោលរំលឹកទៅ *យ៉ាប៊ូ* :

- ថ្ងៃនេះជាថ្ងៃទីដប់ហើយ ទាន ។ អ៊ី១ត្រូវបានរៀបចំជាស្រេចដើម្បីចេញដំណើររបស់លោកម្ចាស់ទៅឯទីក្រុង *អូសាកា* ។ តើលោកម្ចាស់មានបំនងធ្វើដំណើរទៅវិអត់ ?

អ៊ីលូវនេះពេលដែលគេកំពុងឈរនៅលើឆ្នេរសមុទ្រនេះ គេនឹកគុណ *កាមី* ដែលថែទាំគេ ហើយដែលបណ្ដាលអោយចិត្តគេស្ដាប់តាមយោបល់របស់ *អូមី* ដែលសូមអោយគេបន្តនៅរហូតដល់ថ្ងៃបំផុត ពោលគឺគេនៅបានបីថ្ងៃទៀតដែរ ។ គេពោលទៅកាន់ *តូរ៉ាណាកា* :

- និយាយអ៊ីចឹង *តូរ៉ាណាកា -សាម៉ា* រឿងសារចុងក្រោយរបស់លោក ពោលគឺសារដែលបានមកដល់កាលពីម្សិលមិញនេះ ។ លោកនឹងមិនទៅ *អូសាកា* ទេ មែនទេ ?

- ចុះលោកវិញ ?

- ខ្ញុំបានចាត់ទុកលោកជាមេ អ៊ីចឹងហើយខ្ញុំត្រូវរង់ចាំការសំរេចរបស់លោក ។

- ការសំរេចរបស់ខ្ញុំងាយទេ ។ តែការសំរេចរបស់លោក គឺពិតជាពិបាក ។ បើលោកទៅ ក្រុមប្រឹក្សាពិតជានឹងចិញ្ច្រាំលោកជាមិនខាន ព្រោះតែលោកបានកំទេច *ចូស៊ីន* និងកូនចៅរបស់គេ ។ ហើយ *អ៊ីស៊ីដូ* កំពុងតែខឹងសំបើមណាស់ ហើយ ខឹងនោះពិតជាត្រូវទៅទៀត *ទេ* ?

- ខ្ញុំឥតបានប្រព្រឹត្តអំពើនោះទេ លោកម្ចាស់ *តូរ៉ាណាកា* ។ ការកំទេចរូប *ចូស៊ីន* ថ្វីបើសមហេតុសមផលយ៉ាងណាក្ដី គឺបានធ្វើឡើងផ្ទុយនឹងបញ្ជារបស់ខ្ញុំ ។

- ល្អដែរដែល *ណាកា* ជាអ្នកធ្វើ *ទេ* ? បើមិនអ៊ីចឹងទេលោកច្បាស់ជាត្រូវធ្វើដោយផ្ទាល់ដៃហើយ ។ ខ្ញុំដោះស្រាយរឿង *ណាកា* នៅពេលក្រោយចុះ ។ តែមកយើងជជែកបណ្ដើរដើរបណ្ដើរទៅកន្លែងសមតែម្ដងទៅ ដើម្បីកុំអោយខាតពេល ។

រួច *តូរ៉ាណាកា* ក៏ចេញដំណើរទៅក្នុងជំហានញាប់ស្ទេញ និងដោយមានកងការពារនៅប្រកិតជាមួយ ។ លោកពោល :

- ពិតណាស់ ។ លោកពិតជានៅក្នុងស្ថានភាពពិបាកជ្រើសរើសមែនទែន ។ បើលោកទៅ លោកត្រូវកំបុតក្បាល លោកត្រូវបាត់បង់ *អ៊ីស៊ូ* ហើយប្រាកដជាម៉ាពូដ *កាស៊ីគី*



www.budinst.gov.kh www.elibraryofcambodia.org

របស់លោកត្រូវប្រហារជីវិតជាក់ជាមិនខាន ។ បើលោកនៅទីនេះវិញ ក្រុមប្រឹក្សាក៏នឹងចេញសេចក្ដីសំរេចដូចគ្នានេះដដែល - *តូរ៉ាណាកា* ងើយភ្នែកសំលឹងមើល *យ៉ាប៊ូ* - រឺមួយលោកគួរធ្វើដូចកាលពីលោកស្នើអោយខ្ញុំធ្វើនៅ *អាន់ជីរ៉ូ* នេះទៅអ្វី ? ខ្ញុំពិតជារីករាយធ្វើជាអ្នកជំនួយជូនលោក ។ អាចថាក្បាលរបស់លោកអាចជួយបន្ថយការមួម៉ៅរបស់ *អ៊ីស៊ីដូ* បាននៅពេលខ្ញុំជួបវាផងក៏មិនដឹង ។

- ក្បាលខ្ញុំមិនមានតំលៃអ្វីសំរាប់ *អ៊ីស៊ីដូ* ទេ ។

- ខ្ញុំមិនយល់ស្របតាមលោកទេ ។

*ប៊ុនតារ៉ូ* បានមកកាត់ការសន្ទនារបស់អ្នកទាំងពីរ :

- សូមទោសទាន តើអោយពួកទ័ពបោះទីតាំងនៅឯណាទៅ ?

- លើខ្ពង់រាប ។ ចាត់ចែងជំរអចិន្ត្រៃយ៍របស់លោកនៅទីនោះតែម្ដងទៅ ។ ពួកអង្គរក្សពីររយនាក់នៅជាមួយខ្ញុំឯក្នុងបន្ទាយ ។ ពេលណាលោកចាត់ចែងរួចហើយ មកតាមខ្ញុំមក ។ ខ្ញុំចង់អោយលោកបានមើល ឃើញសមយុទ្ធនេះដែរ ។

*ប៊ុនតារ៉ូ* ក៏រួតរះចេញដំណើរទៅ ។ *យ៉ាប៊ូ* សួរភ្លាម :

- ជំរអចិន្ត្រៃយ៍ ? លោកស្ថិតនៅទីនេះ រឺ ?

- ទេ ។ នេះគឺសំរាប់កូនទ័ពរបស់ខ្ញុំតែប៉ុននោះ ។ បើសិនជាការសមយុទ្ធវាយលុកនេះល្អដូចដែលខ្ញុំលឺនោះមែន យើងនឹងចាត់តាំងការវាយលុកប្រាំរយនាក់ ប្រាំបួនកងតែម្ដង ។

- ថាម៉េច ?

- មែនណា ។ ខ្ញុំបានយកមកជាមួយនូវពួក *សាមូរ៉ៃ* ជំរើសចំនួនមួយពាន់នាក់មកអោយលោកទៀតនៅពេលនេះ ។ លោកជួយបន្ថែមមួយពាន់នាក់ទៀតផងចុះ ។

- តែកាំភ្លើងមានមិនគ្រប់គ្នាទេ ហើយការហ្វឹក.....

- សូមទោស លោកច្រលំហើយ ។ ខ្ញុំបានយកមកជាមួយនូវមូស្គេចំនួនមួយពាន់ដើម ហើយនឹងរំសេវ គ្រាប់បរិបូរណ៏ ។ សំភារៈនៅសេសសល់ទាំងប៉ុន្មានទៀតនឹងមកដល់ក្នុងអាទិត្យនេះ ជាមួយនឹង *សាមូរ៉ៃ* មួយពាន់នាក់ទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

- យើងនឹងមានកងវាយលុកប្រាំបួនកង ?

- ពិតហើយ ។ ពួកនេះនឹងត្រូវរៀបចំជាកងពលធំមួយ ។ *ប៊ុនតាប៊ូ* ទទួលបញ្ជាកងនេះ ។

- យកល្អ គួរទុកអោយខ្ញុំជាអ្នកបញ្ជាកងពលធំនេះវិញ ។ *ប៊ុនតាប៊ូ*.....

- អ៊ីចឹង ? លោកភ្លេចថា ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងបើកការប្រជុំក្នុង ប៉ុន្មានថ្ងៃនេះហើយ ។ បើលោកត្រូវទៅ *អូសាកា* តើលោកបញ្ជាទ័ពយ៉ាងម៉េចទៅ ? ក្រែងលោករៀបចំចេញដំណើរហើយអ្ហ ?

*យ៉ាប៊ូ* ឈប់ងក់ :

- យើងជាសម្ព័ន្ធមិត្តនឹងគ្នា ។ យើងបានឯកភាពគ្នាថា លោកជាមេ ហើយបានព្រមព្រៀងជាមួយគ្នាទៀត ។ ខ្ញុំបានប្រកាន់នូវកិច្ចព្រមព្រៀងនេះ ហើយខ្ញុំនឹងនៅតែប្រកាន់វាជាប់ ។ អីលូវនេះខ្ញុំសូមសួរលោក ។ តើលោកមានផែនការយ៉ាងណា ? តើយើងធ្វើសង្គ្រាមរឺមិនធ្វើ ?

- គ្មានអ្នកណាប្រកាសសង្គ្រាមជាមួយខ្ញុំផង ។ មិនទាន់មានទេ ។

*យ៉ាប៊ូ* រមាស់ដៃទ្រាំស្ទើរមិនបាន ។ លោកចង់តែហូតដាវយ៉ូស៊ីតូម៉ូចេញ ហើយបង្ហូរឈាមរបស់ *តូរ៉ាណាកា* ចោលអោយជ្រះស្រលះតែម្តង ទោះជាត្រូវបង់ថ្លៃប៉ុនណាក៏ដោយ ។ លោកស្ទើរតែទទួលខ្យល់ដង្ហើមរបស់ពួកអង្គរក្សដែលនៅព័ទ្ធជុំជិតខ្លួន តែលោកឈានដល់ការិតដែលលែងរីរវល់អីទាំងអស់ហើយ ។

- មិនគឺក្រុមប្រឹក្សាជាផ្នូងមរណៈសំរាប់លោកផងដែរទេ ? លោកបាននិយាយរឿងនេះខ្លួនឯងណាំ ។ នៅពេលណាដែលពួកគេប្រជុំគ្នា លោកត្រូវតែគោរព *នេ* ?

- ពិតជាអីចឹង ។

*តូរ៉ាណាកា* បក់ដៃអោយពួកអង្គរក្សថយទៅក្រោយ យកដៃសង្កត់បែបវាយលើដងដាវរបស់ខ្លួន ជើងខ្លីៗរបស់លោកឈប់បង់ជំហែងយ៉ាងរឹងមាំនៅលើដី ។ *យ៉ាប៊ូ* សួរ :

- បើអីចឹង តើលោកសំរេចចិត្តយ៉ាងម៉េច ? តើលោកមានគំនិតយ៉ាងណាដែរ ?



www.budinst.gov.kh www.elibraryofcambodia.org

- ដំបូងបង្អស់ ទៅមើលគេសមវាយលុក ។

- រួច ?

- រួចទៅបរបាញ់ ។

- លោកអញ្ជើញទៅ *អូសាកា* ទេ ?

- ពិតជាទៅ ។

- អង្កាល់ ?

- ពេលណាខ្ញុំសប្បាយចិត្ត ។

- មានន័យថា មិនមែន នៅពេលណាដែល *អ៊ីស៊ីដូ* សប្បាយចិត្តទើរ ?

- មានន័យថា នៅពេលណាដែលខ្ញុំសប្បាយចិត្ត ។

- យើងនឹងត្រូវឯកោជាមិនខាន - *យ៉ាប៊ូ* តប - យើងមិនអាចប្រយុទ្ធតទល់ម៉ានគរជប៉ុនបានទេ ទោះជាយើងមានកងវាយលុកមួយកងពលធំក្តី ។ ហើយយើងក៏មិនមានលទ្ធភាពបង្អាត់ពួកនេះតែក្នុងដប់ថ្ងៃបានដែរ ។

- អីចឹងមែន ។

- បើអីចឹងតើលោកមានផែនការយ៉ាងណាទៅ ?

- និយាយអោយត្រង់ទៅមើល តើមានរឿងអីកើតឡើងរវាង *ចូស៊ិន* នឹង *ណាកាសាន* ?

*យ៉ាប៊ូ* និយាយរ៉ាយរ៉ាប់រឿងរ៉ាវទាំងអស់ដោយឥតលាក់លៀមអ្វីទាំងអស់ លើកលែងតែចំនុចដែល *ណាកា* ត្រូវ *អូមី* ជាអ្នកដឹកច្រមុះតែប៉ុននោះ ។

- រួចចុះអ្នកចុងស្រុកខ្ញុំវិញ ? តើបុរសចុងស្រុកនេះមានអាកប្បកិរិយាយ៉ាងណាដែរ ?

- ល្អ ។ ល្អណាស់ ។

*យ៉ាប៊ូ* ក៏និទានប្រាប់ពីរឿងដែល *ធ្លាក់ថន* សាកល្បងធ្វើ *ស៊ិបពូតូ* នៅវេលាយប់ដំបូង ហើយនឹងការដែលគេបានពត់ *អាន់ជិន-សាន* អោយបំរើផលប្រយោជន៍របស់ពួកគេ



www.budinst.gov.kh www.elibraryofcambodia.org

បាន ។ *តូរ៉ាំណាកា* និយាយចេញយឺតៗ :

- ចំជាវ៉ាងវ៉ៃមែន ។ ខ្ញុំមិនដែលនឹកគិតស្មានដល់ទាល់តែសោះថា មនុស្សនេះសាក់ធ្វើ *សិបពូក* ។ គួរចាប់អារម្មណ៍មែន ។

- សំនាងដែរ ដែលខ្ញុំប្រាប់ *អូមី* អោយត្រៀមខ្លួនហើយជាស្រេចនោះ ។

- ពិតមែន ។

*យ៉ាប៊ូ* រង់ចាំយ៉ាងអន្ទះអន្ទែងដើម្បី *តូរ៉ាំណាកា* និយាយច្រើនទៅទៀត ប៉ុន្តែលោកនៅស្ងៀមស្ងាត់ឈឹង ។ ទីបំផុត *យ៉ាប៊ូ* ក៏ពោលបន្តទៀត :

- រឿងដែលខ្ញុំបានបញ្ជូនទៅលោកពីប្រការដែលលោកម្ចាស់ *អ៊ីតូ* ក្លាយជាសមាជិកក្រុមប្រឹក្សានោះ តើលោកបានដឹងរឿងនេះជាមុនទេ ?

*តូរ៉ាំណាកា* នៅស្ងៀមមួយសន្ទុះ :

- ខ្ញុំបានលឺពាក្យចចាមអារ៉ាមដែរ ។ លោកម្ចាស់ *អ៊ីតូ* ជាជំរើសល្អបំផុតសំរាប់ *អ៊ីស៊ីដូ* ។ អាឡប់នេះដឹងតែពីរឿងលេងកូនជីងតែប៉ុណ្ណឹង ។ ពួកវាពីរនាក់ណឹងធ្វើត្លូវមដំណេកជាមួយគ្នាសមផុតលេខហើយ ។

- ទោះជាយ៉ាងនេះក្តី ក៏សំលេងឆ្នោតរបស់គាត់អាចបំផ្លាញយើងបានណាំ ។

- នោះនៅពេលណាដែលមានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិតែប៉ុននោះ ។

- អ្ហា ! បើអ៊ីចឹងលោកម្ចាស់មានគំរោងផែនការហើយរឺ ?

- ខ្ញុំតែងមានផែនការមួយ រឺច្រើនយ៉ាងជានិច្ច ហើយ លោកមិនដឹងទេអ្ហី ? តែលោកវិញ តើផែនការរបស់លោកយ៉ាងណាទៅ ? បើលោកចង់ចេញដំណើរ ចេញ ។ បើលោកចង់នៅទីនេះ នៅទៅ ។ រើសចុះ !

រួច *តូរ៉ាំណាកា* បន្តដំណើររបស់ខ្លួនតទៅទៀត ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ហុចរមូរសារដែលមានសរសេរអក្សរជាប់ៗគ្នាស្នេញទៅ *តូរ៉ាណាកា* ។ លោកសួរឡើង :

- តែប៉ុណ្ណឹងទេ ?

- ចាស លោកម្ចាស់ ។

នាងឆ្លើយតបទាំងក្នុងចិត្តធុញថប់នឹងភាពផ្អុះៗរបស់បន្ទប់នៅលើទូកនេះផង ទាំងមិនចូលចិត្តឡើងមកលើទូកធំនេះវិញផង ទោះជាទូកនេះចតនៅនឹងផែក៏ដោយ ។ នាងបន្ត :

- អ្វីៗជាច្រើនដែលមានចែងនៅក្នុងក្បួនសង្គ្រាមត្រូវបាននិយាយឡើងវិញនៅក្នុងកំនត់ត្រានេះ តែនាងខ្ញុំបានកត់ត្រារាល់យប់ និងសរសេររ៉ាយរ៉ាប់ទាំងអស់ រឺស្ទើរតែទាំងអស់នូវអ្វីដែលកើតមានឡើងនៅទីនេះ ។ នេះដូចជាសៀវភៅទិនានុលេខន៍ នៃអ្វីដែលបាននិយាយ និងកើតឡើងចាប់តាំងពីលោកម្ចាស់ចាកចេញទៅអីចឹង ។

- ល្អ ។ មានអ្នកណាបានអានវាទេ ?

- បើតាមនាងខ្ញុំដឹង គឺគ្មានទេ - នាងនិយាយបណ្តើរបក់ផ្ចិតបណ្តើរ -*អាន់ជីន-សាន* និងកំនាន់របស់គាត់ក៏ដូចជាពួកបំរើបានឃើញនាងខ្ញុំសរសេរដែរ តែនាងខ្ញុំ តែងចាក់សោកំនត់ត្រានេះជាប់លាប់ទេ ។

- តើការសន្និដ្ឋានរបស់នាងយ៉ាងម៉េចដែរ ?

*ម៉ារីកូ* រួញរា ។ នាងចោលភ្នែកសំលឹងមើលទៅទ្វារបន្ទប់ និងបង្អួចដែលនៅបិទជិតនោះ ។ *តូរ៉ាណាកា* និយាយ :

- មានតែកូនចៅរបស់ខ្ញុំទេនៅលើទូកនេះ ហើយក៏គ្មានអ្នកណានៅខាងក្រោមដែរ ។ មានតែយើងប៉ុននោះ ។

- ចាស លោកម្ចាស់ ។ នាងខ្ញុំចាំសំដីរបស់ *អាន់ជីន-សាន* ដែលថា នៅលើទូកសំពៅគ្មានរឿងអ្វីដែលសំងាត់ទេ ។ សូមលោកម្ចាស់អភ័យទោសផងចុះ ចាស -នាងគិតមួយសន្ទុះ ទើបពោលឡើងទាំងក្នុងទំនុកចិត្តខ្លួន - កងមូស្កេនឹងឈ្នះការប្រយុទ្ធមួយ ។ ពួកអ្នកចុងស្រុកអាចកំទេចយើងបាន បើសិនជាពួកនេះប្រើកំលាំងធំឡើងតោកដោយមានទាំងកាំ



www.budinst.gov.kh www.elibraryofcambodia.org

ភ្លើងនិងកាណុងផងនោះ ។ លោកម្ចាស់ត្រូវតែមានសំពៅដូចពួកអ្នកចុងស្រុកនេះ ។ មកដល់ពេលនេះ ចំនេះដឹងបុរសចុងស្រុកនេះពិតជាមានសារសំខាន់ដ៏ធំធេងណាស់សំរាប់លោកម្ចាស់ ។ មានសារសំខាន់មែនទែន រហូតដល់យើងត្រូវរក្សាការណ៍សំងាត់មែនទែន ហើយទុកសំរាប់តែលោកម្ចាស់តែប៉ុននោះ ។ បើនៅក្នុងកណ្ដាប់ដៃសត្រូវវិញ ចំនេះដឹងរបស់បុរសនេះ ពិតជាអាចផ្ដាច់ជីវិតលោកម្ចាស់បាន ។

- អីលូវនេះ អ្នកណាខ្លះដែលបានទទួលចំនេះដឹងពីគាត់ខ្លះ ?

- *យ៉ាប៊ូ -សាន* ដឹងច្រើន តែ *អូមី - សាន* ដឹងច្រើនជាង.... គាត់នេះឆាប់ចាប់បានណាស់ ។ នៅមាន *អ៊ីតូរ៉ាជី កាណេ - សាន* និងពួកកងទ័ព ។ ពិតហើយថា ពួកកងទ័ពយល់បានពីយុទ្ធសាស្ត្រ តែមិនអាចយល់បានពីចំនុចល់អិត១ អស់ទេ ហើយរឹតតែមិនយល់បានទៅទៀតពីចំនេះនយោបាយ និងចំនេះដឹងទូទៅរបស់ *អាន់ជីន - សាន* ។ នាងខ្ញុំយល់បានច្រើនជាងគេ ។ នាងខ្ញុំបានកត់ត្រានូវរាល់អ្វី១ដែលគាត់បាននិយាយ បានសួរ ធ្វើអធិប្បាយ ។ កត់គ្រប់ទៅតាមដែលអាចធ្វើទៅបាន ។ ជាការពិតហើយគាត់គ្រាន់តែនិយាយប្រាប់យើងពីរឿងមួយចំនួនតែប៉ុណ្ណោះ តែវិសាលភាព គឺទូលំទូលាយ ហើយលំនឹកគឺស្ទើរតែសុក្រិតតែម្ដង ។ បើសិនជាមានការអត់ធ្មត់ គាត់អាចផ្ដល់ជូនលោកម្ចាស់នូវរូបភាពដ៏ជាក់លាក់មួយនៃពិភពលោក នូវទំលាប់និងគ្រោះថ្នាក់ទាំងឡាយរបស់លោកនេះបានថែមទៀតផង ។ នោះបើសិនជាគាត់និយាយការពិត ។

- គាត់និយាយពិតទេ ?

- នាងខ្ញុំជឿងថា គាត់និយាយពិត ។

- តើនាងយល់ថា *យ៉ាប៊ូ* ម៉េចដែរ ?

- *យ៉ាប៊ូ - សាន* ជាមនុស្សឆៅឆាវ ហើយគ្មានមេត្តាធម៌ទេ ។ គាត់គ្មានរវល់ពីអ្វីទាំងអស់ ក្រៅតែពីផលប្រយោជន៍ផ្ទាល់ខ្លួនរបស់គាត់តែប៉ុណ្ណោះ ។ ភារកិច្ច ភាពស្មោះត្រង់ ប្រពៃណី គ្មានន័យអ្វីទាំងអស់សំរាប់គាត់ ។ គំនិតរបស់គាត់ជូនកាលក៏មានលេចចេញភាពក្រលិចក្រលុចដ៏ឆ្នើម រហូតដល់គួរសរសើរទៀតផង ។ គាត់ជាមនុស្សមួយគ្រោះថ្នាក់ណាស់



www.budinst.gov.kh www.elibraryofcambodia.org

ទោះគាត់ជាសត្រូវ រឺជាសព័ន្ធមិត្តក្តី ។

- ទាំងអស់នេះជាគុណសម្បត្តិដ៏ល្អវិញទេ ។ តើមានអ្វីដែលអវិជ្ជមានទេ ?

- ជាអ្នកគ្រប់គ្រងដ៏អន់មួយ ។ កសិករគាត់ធ្វើការបះបោរភ្លាម បើសិនជាពួកគេមានអាវុធនោះ ។

- ហេតុអី ?

- ការជាន់កយកពន្ធ ។ យកពន្ធខុសច្បាប់ ។ គាត់យកចិតសិបប្រាំភាគលើត្រី និងផលិតផលអ្វីទាំងអស់ ។ គាត់យកពន្ធលើមនុស្ស លើដី លើទូក.... លើរាល់ការលក់ដូរ លើរាល់ធុងស្រា ។ អ្វីៗក៏ត្រូវជាប់ពន្ធទាំងអស់នៅតំបន់ *អ៊ីស៊ូ* នេះ ។

- មើលទៅខ្ញុំប្រហែលជាត្រូវប្រើ *យ៉ាប៊ូ* រឺមេឃ្លាំងវាអោយទៅយកពន្ធនៅឯ *ក្វាន់តូ* ហើយ ។ អ្ហើយ អ្វីដែលវាធ្វើនៅទីនេះ គឺជារឿងផ្ទាល់ខ្លួនរបស់វា ។ កសិករវាក៏មិនអាចមានអាវុធបានជាដាច់ខាត ហេតុនេះគ្មានរឿងអ្វីដែលត្រូវឈឺក្បាលនោះទេ ។ ខ្ញុំនៅតែអាចប្រើអគ្រានេះជាមូលដ្ឋានគិតគូរក៏បានបើចាំបាច់ ។

- តែលោកម្ចាស់ ហុកសិបភាគ គឺជាកិរិតស្របច្បាប់ ចាស ។

- នេះគឺជាកិរិតស្របច្បាប់ពីមុន ។ លោកម្ចាស់ *រ៉ែគូ* បានកំនត់ថា នោះគឺស្របច្បាប់ តែពេលនេះលោកស្លាប់បាត់ទៅហើយ ។ តើមានរឿងអីទាក់ទិននឹង *យ៉ាប៊ូ* ទៀតទេ ?

- គាត់ទទួលទានតែបន្តិចបន្តួចទេ ។ សុខភាពគាត់មើលទៅឃើញដូចជាល្អស្រួលបួលទេ តែ *ស៊ូរ៉ៃ* គាធ្វើសរសៃយល់ថា គាត់មានជំងឺតំរងទឹកនោម ។ ម្យ៉ាងទៀតគាត់ក៏មានទំលាប់ប្លែកៗណាស់ដែរ ។

- ទំលាប់យ៉ាងម៉េចទៅ ?

នាងក៏ជំរាបទៅ *តូរ៉ាណាកា* ពីរាត្រីសំរែក ពោលគឺពេលដែលគេស្មោរនារីក *ភ្ជាក់ផន* ទាំងរស់នោះ ។

- អ្នកណានិយាយប្រាប់នាងពីរឿងនេះ ?

- *ស៊ូរ៉ៃ* ហើយម្តាយ និងប្រពន្ធ *អូមី* ក៏និយាយរឿងនេះដែរ ។



www.budinst.gov.kh www.elibraryofcambodia.org

- ឪពុករបស់ *យ៉ាប៊ូ* ក៏មានទំលាប់ស្មោរសត្រូវរបស់គាត់អីចឹងដែរ ។ នេះចំជាខ្ទះខ្ទាយពេលមែន ។ តែខ្ញុំយល់ពីសេចក្តីត្រូវការរបស់វាដែលត្រូវធ្វើដូចនេះម្តងម្កាល ។ ចុះ *អូមី* ក្មួយរបស់វាវិញ ?

- ឆ្លៀវឆ្លាតណាស់ ហើយប្រកបដោយគតិបណ្ឌិតណាស់ទៀតផង ។ គឺជាអ្នកដែលស្មោះត្រង់បំផុតចំពោះពួករបស់គេ ។ ជាអណ្តាប់មួយដ៏មានសមត្ថភាព និងគួរអោយស្ញើម ។

- ចុះគ្រួសារ *អូមី ?*

- ម្តាយរបស់គាត់ គឺ.... ចាក់ចេកចាក់ស្ករជាមួយ *មីស៊ី* ជាប្រពន្ធរបស់ *អូមី* នោះណាស់.... ។ ប្រពន្ធនេះក៏ជា *សាមូរ៉ៃ* ដែរ ហើយនាងមានចរិតស្លូតបូត រឹងប៉ឹង និងជាមនុស្សល្អណាស់ ។ ពួកគេទាំងអស់គ្នាសុទ្ធតែជាអ្នកស្មោះត្រង់របស់ *យ៉ាប៊ូ - សាន* ។ ពេលនេះ *អូមី-សាន* មិនមានគូកំនាន់ទេ ។ ថ្វីត្បិតតែនាង *គីគូ* ដែលជានារីកំដរដ៏ល្បីឈ្មោះនៅ *អ៊ីស៊ូ* នេះត្រូវបានគេចាត់ទុកដូចជាកំនាន់គាត់ក្តី ។ នាងខ្ញុំគិតថា បើសិនជា *អូមី - សាន* អាចទិញកិច្ចសន្យារបស់នាង *គីគូ* បាននោះ គាត់ប្រហែលជានាំនាងទៅនៅផ្ទះជាមួយគាត់ជាមិនខាន ។

- បើសិនជាខ្ញុំមានបំនង តើ *អូមី* នឹងជួយខ្ញុំតទល់នឹង *យ៉ាប៊ូ* រឺទេ ?

នាងគិតពិចារណាយ៉ាងម៉ត់ចត់ រួចគ្រវីក្បាល :

- មិនអាចទេលោកម្ចាស់ ។ នាងខ្ញុំគិតថា គាត់នឹងមិនជួយទេ ។ ខ្ញុំយល់ថា គាត់ជាអណ្តាប់របស់ពួគាត់ទៅហើយ ។

- ចុះ *ណាកា* ?

- សក្តិសមជា *សាមូរ៉ៃ* ពិតៗ គាត់ឃើញភ្លាមថាតើ *ចូស៊ិន* និងកូនចៅរបស់គេអាចជាគ្រោះយ៉ាងណាចំពោះលោកម្ចាស់ ។ ថ្វីត្បិតតែគាត់ស្អប់កងមូស្តេយ៉ាងណាក្តី ក៏គាត់ខិតខំបង្វឹកទ័ពគាត់យ៉ាងខ្លាំងក្លា ដើម្បីអោយក្លាយជាកងទ័ពសុក្រឹតដែរ ។

- ខ្ញុំគិតថា វាភ្លើមែនទែន...... ទៅធ្វើអាយ៉ង *យ៉ាប៊ូ* បែបនេះ ។

*មារីកូ* រៀបចំជាយគីម៉ូណូរបស់នាងដោយឥតនិយាយតបតអ្វីទាំងអស់ ។ *តូរ៉ាណាកា* បក់ផ្ចិត ហើយសួរឡើង :



www.budinst.gov.kh www.elibraryofcambodia.org

- រួចចុះ *អាន់ជីន - សាន* ?

នាងរង់ចាំសំនួរនេះជាយូរមកហើយ ។ តែនៅពេលដែល *គូរ៉ាណាកា* សួរការសង្កេតដ៏ឈ្លាសវៃទាំងប៉ុន្មានដែលនាងបានត្រៀមរៀបចំនៅក្នុងខួរក្បាលនាងនោះ បានរលាយបាត់អស់រលីង ។

- យ៉ាងម៉េច ?

- ចាស លោកម្ចាស់អាចវាយតំលៃបានតាមអំនាន រមូរសារនេះ ។ នៅចំនុចខ្លះគឺយើងមិនអាចយល់ពីគាត់បានតែម្តង ។ ជាការពិតហើយដែលថា ការរៀនសូត្រនិងកេរដំណែលរបស់គាត់មិនដូចពួកយើងទេ ។ គាត់ជាមនុស្សពិបាកយល់ហើយហួសពីការយល់របស់យើង.....របស់នាងខ្ញុំចាស ។ គាត់ច្រើនមិនសូវលាក់លៀមអីទេ តែក្រោយពីគាត់សាកល្បងថ្ងៃ *ស៊ីបពួគូ* មក គាត់កែប្រែច្រើន ។ គាត់មិនសូវបញ្ចេញអីអោយដឹងដូចមុនទៀតទេ ។

រួចនាងក៏និយាយប្រាប់ពីអ្វីដែល *អូមី* បាននិយាយ និងបានធ្វើនៅយប់ដំបូងនោះ ។ ហើយនឹងការសន្យារបស់ *យ៉ាប៊ូ* ទៀតផង ។

- អ្នក អីចឹង *អូមី* ទេដែលជាអ្នកបញ្ឈប់ *អាន់ជីន - សាន*... មិនមែន *យ៉ាប៊ូ* ទេ ?

- ចាស

- ហើយ *យ៉ាប៊ូ* ធ្វើតាមយោបល់របស់ *អូមី ?*

- ពិតហើយលោកម្ចាស់ ។

- អីចឹង *អូមី* ជាទីប្រឹក្សាទៅវិញ ។ សំខាន់ដែរ ។ តែច្បាស់ណាស់ហើយ ដែល *អាន់ជីន - សាន* មិនសង្ស័យថា *យ៉ាប៊ូ* នឹងប្រកាន់ពាក្យសន្យារបស់វានោះ ?

- ប្រាកដណាស់លោកម្ចាស់ ។

*គូរ៉ាណាកា* ផ្ទុះសំនើច :

-ចំជាក្មេងបៀមដៃមែន !

- " មនសិការ " គ្រិស្តសាសនានៅជិតជាប់នឹងខ្លួនគេទៅហើយ ។ គាត់មិនអាច



www.budinst.gov.kh www.elibraryofcambodia.org

គេចផុតពី *កាម៉ា* របស់គាត់ដែលគ្របដណ្តប់ដោយកំហឹងចំពោះមរណភាពនៃពួកអ្នកដែលគាត់ហៅថាជា " អ្នកស្លូតត្រង់ " នោះឡើយ ។ សូម្បីតែមរណភាពរបស់ *ចូសិន* ក្តី ក៏បានប៉ះទង្គិចសតិអារម្មណ៍របស់គាត់យ៉ាងសំបើមណាស់ដែរ ។ គាត់ដេកមិនលក់ជាច្រើនយប់ ហើយគាត់លែងសូវនិយាយស្តីអស់ជាច្រើនថ្ងៃ ។

- តើវា " មនសិការ " បែបនេះមានគ្រប់តែពួកអ្នកចុងស្រុកវឹ ?

- ចាសទេ ថ្វីត្បិតតែអ្នកចុងស្រុកដែលកាន់គ្រិស្តសាសនាទាំងអស់ត្រូវតែមានក៏ដោយ ។

- តើគាត់នឹងបាត់បង់ " មនសិការ " នេះទេ ?

- នាងខ្ញុំគិតថាមិនបាត់ទេ ។ តែបើគាត់នៅតែមាន " មនសិការ " បែបនេះ គាត់ជាមនុស្សមួយគ្មានអ្វីការពារខ្លួនបានដូចកូនតុកត្តាមួយអ៊ីចឹង ។

- ចុះកំនាន់គាត់វិញ ?

នាងនិយាយរ៉ាយរ៉ាប់សព្វគ្រប់ទាំងអស់ ។

- ល្អ ។

*គូរ៉ាណាកា* សែនសប្បាយនៅក្នុងចិត្ត ដោយជំរើសរបស់លោកនិងផែនការរបស់លោកមានដំណើរការល្អឥតខ្ចោះយ៉ាងនេះ ។ លោកបន្ត :

- ល្អណាស់ ។ នាងធ្វើបានល្អក្នុងរឿងកាំភ្លើងនេះ ។ តើទំលាប់ *អាន់ជីន - សាន* យ៉ាងម៉េចដែរ ?

- ជាទូទៅធម្មតា លើកលែងតែគាត់មានការអេះអុញគួរអោយភ្ញាក់ផ្អើលពីរឿងរូបរាក្យ ហើយនឹងការតុញតុះដ៏ចំលែកក្នុងការជជែកពីរឿងដ៏សែនធម្មតានេះ ។

នាងក៏បាននិយាយពីតំរូវការដ៏ចំលែករបស់ *ប្លាក់ថន* ចំពោះភាពឯកោ និងចំនូលចិត្តដ៏គួរអោយឆ្ងើមរបស់គេលើរឿងម្ហូបអាហារ ។ នាងបន្តទៀត :

- ក្នុងរឿងផ្សេងៗទៀត គាត់ជាមនុស្សមានការយកចិត្តទុកដាក់ មានវិចារណញ្ញាណល្អ ប្រាជ្ញាមុតវាងវៃ ជាសិស្សពូកែ ហើយចូលចិត្តចង់ដឹងយល់ពីប្រពៃណី និងទំនៀម



www.budinst.gov.kh www.elibraryofcambodia.org

ទំលាប់របស់ពួកយើង ។ ទាំងអស់នេះមាននៅក្នុងរបាយការណ៍របស់នាងខ្ញុំដោយគ្រួសៗហើយ ។ នាងខ្ញុំបានពន្យល់គាត់ពីរបៀបរបបរស់នៅរបស់ពួកយើង ពីរឿងពួកយើងបន្តិច ពីប្រវត្តិសាស្ត្រយើង ពីលោកម្ចាស់ *វ៉េកូ* និងពីបញ្ហាដែលមានចោទឡើងចំពោះនគរយើងនេះ ។

- ពីរឿងទាយាទ ?

- ចាស លោកម្ចាស់ ។ មានអីទាស់ខុសរឺ ?

- អត់ទេ ។ នាងត្រូវបានទទួលភារកិច្ចអោយបង្ហាត់បង្ហាញគេអ៊ីចឹងហើយ ។ តើគាត់រៀនភាសាជប៉ុនយ៉ាងម៉េចដែរហើយ ?

- ល្អណាស់ ។ តែប៉ុន្មានពេលទៀត គាត់នឹងនិយាយភាសាយើងបានស្ទាត់ហើយ ។ គាត់ជាសិស្សល្អណាស់លោកម្ចាស់ ។

- ចុះរឿងខ្ពល់ខ្ពើយ ?

- ជាមួយនារីអ្នកបំរើម្នាក់ - នាងឆ្លើយយ៉ាងរហ័ស ។

- គាត់រើសនាងណុងអ្អី ?

- គំនាន់គាត់បញ្ជូននាងនោះទៅគាត់ចាស ។

- រួច ?

- ទាំងពីរនាក់មានការពេញចិត្តគ្នាទៅវិញទៅមក បើតាមការស្មានយល់របស់នាងខ្ញុំ ។

- នារីនោះអត់មានលំបាកអីទេ ?

- ចាសអត់ទេលោកម្ចាស់ ។

- ប្រដាប់វាគ្រាន់បើដែរទេ ?

- នារីនោះថា " គ្រាន់បើ " ។ នាងប្រើពាក្យ " ហំ " ។

- ល្អបំផុត ។ យ៉ាងហោចណាស់ក៏នៅក្នុងរឿងនេះមួយ *កាម៉ា* របស់គាត់ល្អដែរ ។ ព្រោះអានេះនាំរឿងបំផុតជាមួយប្រុសជាច្រើន ។ ដូចជា *យ៉ាប៊ូ* នេះមួយ *គីយ៉ាម៉ា* នេះពីរ ។ ខ្សៀវតូចច្រមក់ៗ ។ ចំជាស័យមែនកើតមកប្រដាប់តូច ។ ស័យមែន ។



www.budinst.gov.kh www.elibraryofcambodia.org

លោកចោលភ្នែកសំលឹងមើលទៅរមូរសារ រួចបិទផ្ចិតរបស់លោកលឺខ្ទាប់ ។ លោកបន្តសួរ :

- រួចចុះនាងវិញ *ម៉ារីកូ - សាន ?* នាងយ៉ាងម៉េចដែរ ?

- ល្អស្រួលបួលទេ សូមអរគុណលោកម្ចាស់ ។ នាងខ្ញុំសប្បាយចិត្តណាស់ ដែលឃើញលោកម្ចាស់មានសុខភាពល្អយ៉ាងនេះ ។ នាងខ្ញុំសូមអនុញ្ញាតរួមសំដែងគារវកិច្ចជូនលោកម្ចាស់ក្នុងឱកាសកំនើតចៅប្រុសរបស់លោកម្ចាស់ផងចាស ។

- សូមអរគុណ ។ ពិតហើយ ខ្ញុំសប្បាយចិត្តណាស់ ។ ចៅនេះមានរូបរាងល្អហើយសុខភាពហាក់ដូចជាមាំទាំណាស់ ។

- ចុះលោកជំទាវ *កិនជីកូ ?*

*តូរ៉ាណាកា* គ្រហឹម :

- នាងនៅតែខ្លាំងក្លាដូចសព្វដងអ៊ីចឹង - លោកក្របួចមាត់ នៅត្រិះរិះយ៉ាងស្ងៀមស្ងាត់មួយសន្ទុះ -នាងប្រហែលជាជួយរកមេទឹកដោះម្នាក់សំរាប់ក្មេងនេះផង ។

ជាទំលាប់ កូន *សាមូរ៉ៃ* សំខាន់ៗរមែងត្រូវមានមេទឹកដោះដើម្បីអាចអោយម្តាយបង្កើតរបស់ខ្លួនជួយកិច្ចការប្តី មើលរាល់កិច្ចការក្នុងផ្ទះ ទុកអោយមេទឹកដោះទទួលប្រមូលផ្តុំតែលើការចិញ្ចឹមបីបាច់ ធ្វើយ៉ាងណាអោយទារករឹងមាំសក្តិសមនឹងឪពុកម្តាយរបស់ខ្លួនតែប៉ុណ្ណោះ ។ លោកបន្ត :

- ខ្ញុំបារម្ភតែមិនងាយរកមនុស្សអោយបានសក្តិសមទេ ព្រោះជំទាវ *កិនជីកូ* មិនមែនជាចៅហ្វាយស្រីស្រួលផ្គាប់ប៉ុន្មានទេ *នេ ?*

- នាងខ្ញុំជឿជាក់ថា លោកម្ចាស់ពិតជារកមេដោះល្អបាន ។ នាងខ្ញុំនឹងគិតរកមើលជូនលោកម្ចាស់ផងដែរ ។

*ម៉ារីកូ* ឆ្លើយតបទាំងដឹងច្បាស់នៅក្នុងចិត្តថា អោយយោបល់រឿងនេះគឺពិតជាឡប់សតិមែនទែនតែម្តង ព្រោះគ្មានស្រីណាអាចទ្រាំនឹង *តូរ៉ាណាកា* ផង កូនប្រសាស្រីផង បានទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- អរគុណនាង ។ តែរូបនាងវិញយ៉ាងម៉េចដែរ ?

- ស្រួលបួលទេ ។ សូមអរគុណលោកម្ចាស់ ។

- ចុះមនសិការគ្រិស្តសាសនារបស់នាង ?

- គ្មានអ្វីធំនាស់គ្នាទេលោកម្ចាស់ ។ គ្មានសោះតែម្តង ។ នាងខ្ញុំបានធ្វើអ្វីៗសព្វបែបយ៉ាងតាមបំនងប្រាថ្នារបស់លោកម្ចាស់ទាំងអស់ ។ ដោយស្មោះស្ម័គ្របំផុត ។

- តើមានពួកសង្ឃកាតូលិចណាម្នាក់មកទីនេះទេ ?

- គ្មានទេលោកម្ចាស់ ។

- នាងមានត្រូវការទេ ?

- ពិតជាល្អបំផុតបើសិនជានាងខ្ញុំបានខមាទោស និងទទួលបានការអោយធមិនោះ ។ ចាស និយាយតាមត្រង់ទៅ នាងខ្ញុំចង់បានម្នាក់គ្រាន់បានខមាទោសដែលអាចអនុញ្ញាតបាន និងបានទទួលធមិផង ។

*តូរ៉ាំណាកា* សំលឹងមើលមុខនាងយ៉ាងពិនិត្យពិច័យ ។ ភ្នែករបស់នាងពោរពេញដោយភាពស្មោះត្រង់ឥតលាក់លៀម :

- នាងធ្វើបានល្អណាស់ *ម៉ារីកូ - សាន* ។ សូមនាងបន្តធ្វើទៅទៀតចុះ ។

- ចាស សូមអរគុណលោកម្ចាស់ ។ នៅមានរឿងមួយទៀត គឺ *អាន់ជីន - សាន* ត្រូវការយ៉ាងខ្លាំងនូវសៀវភៅវេយ្យាករណ៍ និងវចនានុក្រម ។

- ខ្ញុំបានអោយ *ឈូគូ - សាន* ចាត់ចែងរឿងណឹងហើយ - *តូរ៉ាំណាកា* ឃើញនាងជ្រួញចិញ្ចើម -នាងគិតថា *ឈូគូ-សាន* មិនធ្វើសៀវភៅនេះមកទេអ្ហេះ ?

- គាត់ពិតជាគោរពតាមបញ្ជារបស់លោកម្ចាស់ តែមិនមែនក្នុងល្បឿនដែលលោកម្ចាស់ចង់បាននោះទេ ។

- ខ្ញុំទើបដឹងរឿងនេះក្នុងពេលឆាប់ៗនេះឯង - រួចលោកពោលបន្ថែមក្នុងសំលេងដ៏គួរអោយស្រៀវឆ្អឹងខ្នង -គាត់នៅសល់ពេលតែដប់បីថ្ងៃទៀតតែប៉ុននោះ ។

*ម៉ារីកូ* ស្រលាំងកាំង ។ នាងសួរដោយមិនយល់អ្វីទាំងអស់ :



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់មានប្រសាសន៍ថាម៉េច ចាស ?

- ដប់បីថ្ងៃណឹង ? អ្ហូ -*តូរ៉ាណាកា* និយាយបែបវាហី ដើម្បីលុបការធ្វេសមាត់របស់លោក- កាលយើងនៅឯលើសំពៅពួកប៊ីកទុយកាល់នោះ គាត់បានសុំការអនុញ្ញាតទៅលេង *យេដូ* ។ ខ្ញុំក៏យល់ព្រម តែអោយគាត់ទៅតែសែសិបថ្ងៃទេ ។ អីលូវនេះនៅសល់តែដប់បីថ្ងៃទៀតទេ ។ មិនតីសែសិបថ្ងៃទេអ្ហី ដែលលោកសង្ឃអីតេមួយឈ្មោះ *ម៉ូអ៊ីស* (១) បានចំនាយពេលនៅលើភ្នំដើម្បីទទួលយកបញ្ញារបស់ " ព្រះអាទិទេព " ចារលើថ្ម នោះ ?

- ចាស គឺពិតមែនហើយ ។

- តើនាងជឿថា រឿងអីចឹងអាចកើតមានបានទេ ?

- ចាសជឿ គ្រាន់តែនាងខ្ញុំមិនយល់ថា វាកើតឡើងដោយរបៀបណា និងហេតុអ្វីតែប៉ុណ្ណោះ ។

- ជាការខ្ជះខ្ជាយពេលដែលនាំគ្នាជជែកពី " របស់របរព្រះ " *ទេ* ?

- ចាសពិតហើយ បើសិនជាជជែកដើម្បីស្វែងរកការជាក់ស្តែងនោះ ។

- ក្នុងពេលដែលនាងរង់ចាំវចនានុក្រមនេះ តើនាងមានបានសាកល្បងចងក្រងខ្លួនឯងមួយទេ ?

---

*(១) ឈ្មោះអ្នករំដោះ និងជាអ្នកច្បាប់របស់អ៊ីស្រាអែលម្នាក់នៅក្នុងគម្ពីរសាសនាប៊ីប ( Bible ) ។ ពេលនៅទារកលោកត្រូវម្តាយដាក់កន្ត្រកយកទៅបណ្តែតទឹក ហើយត្រូវបុត្រីស្តេច ផារ៉ាអុង នៃប្រទេសអេស៊ីបរើសបាន ហើយដាក់ឈ្មោះម៉ូអ៊ីស ដែលមានន័យថា " ជួយរួចផុតពីទឹក " ( ភាសាហេប្រឺអានថា Mosche និងអង់គ្លេសអានថា Moses តែដោយជាគោលការណ៍ខេមរយានកម្មឈ្មោះអសាធារណនាមត្រូវយកតាមបារាំង ទើបប្រើហៅ ម៉ូអ៊ីស វិញ ) ។ លោកត្រូវបានទទួលបេសកកម្មពីព្រះនាំពួកហេប្រឺ រឺ អ៊ីស្រាអែលនេះចាកចេញពីទាសភាពនៃប្រទេសអេស៊ីប ស្វែងរកសេរីភាពនៅតំបន់កាណាន់ ។ ក្នុងដំណើរនេះ លោកបានឡើងលើភ្នំស៊ីណៃ ហើយក៏ទទួលបានពីព្រះអាទិទេពនូវ " បញ្ញាទាំងដប់ " ដែលជាមូលដ្ឋានគ្រឹះនៃសាសនាគ្រិស្តនោះឯង ( កំនត់អ្នកបកប្រែ ) ។*



www.budinst.gov.kh www.elibraryofcambodia.org

- ចាស *តូរ៉ាណាកា - សាម៉ា* ។ ខ្ញុំខ្លាចតែវាមិនបានល្អទេ ។ ជាអកុសលទៅទៀត គឺនាងខ្ញុំមានពេលតិចតួចពេក ហើយរឿងរ៉ាវមានច្រើនមែនទែន ។ នៅទីនេះផង.... នៅគ្រប់កន្លែងផង ។

*តូរ៉ាណាកា* ងក់ក្បាលឯកភាពដោយលោកដឹងថា *ម៉ារីកូ* ពិតជាអន្ទះអន្ទែងចង់សួរនូវសំនួរជាច្រើន : រឿងក្រុមប្រឹក្សាថ្មីនិងការតែងតាំងលោកម្ចាស់ *អ៊ីតូ* ការវិនិច្ឆ័យទោស *ណាកា* ហើយនឹងប្រការដែលសង្គ្រាមនឹងផ្ទុះឡើងឆាប់ៗនេះរឺទេ ។ លោកនិយាយ :

- យើងមានវាសនាល្អណាស់ដែលបានប្តីនាងវិលមកវិញជាមួយពួកយើងវិញ *ទេ ?*

ផ្ទៃតរបស់ *ម៉ារីកូ* ឈប់បក់ភ្លាម :

- នាងខ្ញុំមិនដែលនឹកស្មានថា គាត់អាចរស់រានមានជីវិតគេចរួចឡើយ ។ មិននឹកស្មានទាល់តែសោះ ។ នាងខ្ញុំតែងសូត្រធម៌ និងអុជធូបឧទ្ទិសជូនព្រលឹងគាត់ជារៀងរាល់ថ្ងៃ ។

ពីពេលព្រឹកមិញនេះ *ប៊ុនតារ៉ូ* បាននិយាយប្រាប់នាងពីប្រការដែលកង *សាមូរ៉ៃ* របស់ *តូរ៉ាណាកា* មួយកងបានការពារការដកថយរបស់ខ្លួន ហើយបន្ទាប់មកគេក៏បានដើរតាមជាយតំបន់ *អូសាកា* ដោយឥតមានបញ្ហាអ្វីទាំងអស់ ។ បន្ទាប់មក ដោយរួមនឹងកូនទ័ពចំនួនហាសិបនាក់និងសេះមួយចំនួន លោកបានក្លែងខ្លួនជាពួកចោរ ដោយនាំគ្នាគេចតាមភ្នំនិងដោយធ្វើដំណើរតាមផ្លូវតូចៗសំដៅឆ្ពោះទៅ *យេដូ* វិញ ។ ពួកសត្រូវបានដេញតាមពួកលោកទាន់ពីរដង តែដោយពួកសត្រូវមិនមានចំនួនលើសលប់ទេនោះ លោកបានវាយទំលាយចេញរួច ។ មានម្តងទៀតពួកលោកត្រូវបានធ្លាក់ចូលក្នុងការពួនស្ទាក់មួយ ហើយកូនទ័ពរបស់លោកត្រូវគេសំលាប់ស្ទើរអស់ សល់តែប្អូននាក់ប៉ុននោះ តែលោកនៅតែរំដោះខ្លួនគេចរួចចូលទៅក្នុងព្រៃកាន់តែជ្រៅ ។ ចាប់ពីពេលនោះមក លោកធ្វើដំណើរតែពេលយប់ ហើយសំរាកនៅពេលថ្ងៃទៅវិញ ដោយបរិភោគតែផ្លែឈើព្រៃ ផឹកទឹកជ្រោះ ជូនកាលបានបាយបន្តិចបន្តួចដែលលួចឆក់តាមខ្ទមដាច់សង្វែង និងដោយពួកសត្រូវដេញតាមជាប់ប្រកិត ។ លោកត្រូវប្រើពេលវេលាម្ភៃថ្ងៃទើបទៅដល់ *យេដូ* ។ មនុស្សតែពីរនាក់គត់ ដែលបានរស់រានមានជីវិតជា



www.budinst.gov.kh www.elibraryofcambodia.org

មួយនឹងលោកនៅពេលទៅដល់ទីនៅ ។

*ម៉ារីកូ* និយាយឡើង :

- នេះស្ទើរតែជាអព្ភូតហេតុមួយតែម្តង ។ នាងខ្ញុំនឹកស្មានតែ *កាមី* លងនាងខ្ញុំទេ នៅពេលដែលនាងខ្ញុំឃើញគាត់នៅក្បែរលោកម្ចាស់កាលនៅឯឆ្នេរសមុទ្រនោះ ។

- គាត់ជាមនុស្សឆ្លាត ។ ខ្លាំងក្លាបំផុត និងឆ្លៀវឆ្លាតបំផុត ។

- តើនាងខ្ញុំអាចសួរដំណឹងពីលោកម្ចាស់ *ហ្ស៊ី - ម៉ាត់ស៊ី* បានទេ លោកម្ចាស់ ? ហើយរឿង *អូសាកា* ? រឿងលោកជំទាវ *គីរីស៊ូបូ* និងលោកជំទាវ *សាស៊ូកូ* ?

ដោយបែបវាហើ *តូរ៉ាណាកា* បាននិយាយប្រាប់នាងពីប្រការដែល *ហ្ស៊ី - ម៉ាត់ស៊ី* បានត្រលប់ទៅដល់ *យេដូ* វិញមួយថ្ងៃ មុនពេលដែលលោកចាកចេញមក *អាន់ជីរ៉ូ* នេះ តែពីកិរិយារបស់លោកទាំងប៉ុន្មានបានសំរេចបន្តស្នាក់នៅក្នុងទីក្រុង *អូសាកា* ដោយគេបានលើកពីមូលហេតុសុខភាពរបស់ជំទាវ *សាស៊ូកូ* ។ លោកមិននិយាយបូរបាច់ពីរឿងនេះទេ ដោយទាំងរូបលោកទាំងរូប *ម៉ារីកូ* សុទ្ធតែបានដឹងថា នេះជារូបមន្តកុំអោយបាក់មុខតែប៉ុណ្ណោះ ដោយថាមេទ័ព *អ៊ីស៊ីដូ* ពិតជាមិនព្រមអនុញ្ញាតអោយចំនាប់ខ្មាំងដ៏មានតំលៃយ៉ាងនេះចាកចេញដំណើរក្រោយពេលដែល *តូរ៉ាណាកា* គេចរួចពីក្រញាំរបស់ខ្លួននោះទេ ។ លោក ពោល :

- *ស៊ីកាតា កា ណៃ* ។ *កាម៉ា នេ* ? គ្មានអ្វីដែលអាចធ្វើទៅបានទេ ។ នេះជា *កាម៉ា* មិនអីចឹង ?

- ចាស ។

លោកចាប់យករមូរសារឡើង :

- អីលូវនេះខ្ញុំត្រូវអានកំនត់ត្រានេះ ។ សូមអរគុណ *ម៉ារីកូ - សាន* ។ នាងធ្វើការបានល្អណាស់ ។ នៅពេលព្រឹកព្រលឹមនេះ សូមនាងនាំ *អាន់ជី - សាន* ទៅជួបខ្ញុំនៅឯបន្ទាយ ។

- លោកម្ចាស់ អីលូវនេះមានលោកម្ចាស់របស់នាងខ្ញុំនៅទីនេះ នាងខ្ញុំត្រូវ....

- ប្តីរបស់នាងបានយល់ព្រមហើយថា ក្នុងពេលដែលខ្ញុំនៅទីនេះ នាងត្រូវនៅក្នុង



www.budinst.gov.kh www.elibraryofcambodia.org

តួនាទីដូចមុនរបស់នាង ហើយនឹងមានភារកិច្ចជាអ្នកបកប្រែងដែល ។ ភារកិច្ចចំបងរបស់នាងក្នុងពេលប៉ុន្មានថ្ងៃខាងមុខនេះ គឺ *អាន់ជីន - សាន* ។

- ប៉ុន្តែលោកម្ចាស់ នាងខ្ញុំត្រូវរៀបចំផ្ទះសំបែងដើម្បីលោកប្តីរបស់នាងខ្ញុំ ។ គាត់នឹងត្រូវការអ្នកបំរើ ត្រូវការផ្ទះ ។

- អារឿងហ្នឹងនាំតែអស់លុយ ខាតពេលវេលា ហើយនឹងកំលាំងចោលទេ នៅពេលនេះ ។ ប្តីនាងស្នាក់នៅជាមួយពួកទ័ពទៅ រឺមួយទៅនៅជាមួយ *អាន់ជីន - សាន* ក៏តែបាន ។ គាត់ពេញចិត្តមួយណា សំរេចមួយហ្នឹងទៅ - លោកកត់សំគាល់ឃើញភាពមួម៉ៅមួយខ្ទាច់ - *ណាន់ចា* ?

- តួនាទីរបស់នាងខ្ញុំគឺនៅជាមួយលោកប្តីរបស់នាងខ្ញុំ ។ នៅដើម្បីបំរើគាត់ ។

- តួនាទីរបស់នាង គឺនៅកន្លែងណាដែលខ្ញុំចង់អោយនៅ ។ *ទេ* ?

- ចាស ពិតប្រាកដហើយ ។ សូមលោកម្ចាស់សណ្តោសទោសដល់នាងខ្ញុំផង ។

- ពិតជាសណ្តោស ។

រួចនាងក៏ចាកចេញទៅ ។

*តូរ៉ាណាកា* ក៏អានកំនត់ត្រាយ៉ាងយកចិត្តទុកដាក់ ។ រួចលោកអានក្បួនសង្គ្រាម ។ បន្ទាប់មកទៀត លោកអានសារឡើងវិញផ្នែកខ្លះនៃកំនត់ត្រា ។ ចប់សព្វគ្រប់ហើយលោកទុកឯកសារទាំងពីរយ៉ាងគត់មត់ ដាក់ទាហានអោយនៅចាំយាមបន្ទប់ រួចក៏ចេញមកក្រៅ ។

ពេលនេះជាពេលព្រលឹមទៅហើយ ។ មេឃច្បាស់ជាក្តៅ ហើយមានពពកដេរដាស ។ លោកអោយគេលុបចោលគំរោងដែលត្រូវជួប *អាន់ជីន - សាន* ហើយក៏ជាយសេះឡើងទៅលើខ្ពង់រាបដោយមានកងការពារមួយរយនាក់អមទៅជាមួយផង ។ នៅទីនោះលោកអោយគេហៅអ្នកកាន់ស្ទាំងរបស់លោក ហើយនឹងយកស្ទាំងបីក្បាលចេញទៅបរបាញ់ក្នុងចំងាយម្តែលី ។ រហូតដល់ថ្ងៃត្រង់លោកចាប់បានមាន់ទោបី មាន់ព្រៃធំ១ ពីរ ទន្សាយមួយ និងក្អែកមួយតួ ។ លោកផ្ញើមាន់ទោមួយ និងទន្សាយមួយទៅ *ព្វាក់ថូន* ឯសត្វនៅសល់លោកអោយគេយកទៅបន្ទាយ ។ ពួក *សាមូរ៉ៃ* របស់លោកមួយចំនួនមិនមែនជាពុទ្ធសាសនិក



www.budinst.gov.kh www.elibraryofcambodia.org

ទេ ហើយ *ភូវ៉ាណាកា* រមែងមានការអនុគ្រោះចំពោះទំលាប់ហូបចុករបស់ពួកនេះផងដែរ ។ ចំពោះរូបលោកវិញ លោកទទួលទានតែបាយត្រជាក់បន្តិចជាមួយនឹងត្រី សារ៉ាយត្រាំអំបិល ហើយនឹងខ្ទឹមមួយចំនិតពីរតែប៉ុណ្ណោះ ។

☆ ☆ ☆

ស្នូរជើងសេះលាន់លឺឡើងនៅឯច្រកទ្វារចូល ។ *ប៊ុនគារ៉ូ* ចុះពីលើខ្នងសេះ ហើយធ្វើសញ្ញាអោយកូនចៅរបស់ខ្លួនត្រលប់ទៅវិញ ។ លោកដើរចូលមកក្នុងផ្ទះដោយមានតែអង្គរក្សផ្ទាល់ខ្លួនអមមកជាមួយតែប៉ុណ្ណោះ ។ ខ្លួនប្រាណរបស់លោកសុទ្ធតែធូលី និងញើសជោក ។ ដៃរបស់លោកកាន់ធ្នូដ៏ធ្ងន់មួយ នៅឯខ្នងគឺជាបំពង់ព្រួញ ។ *ភូជីកូ* និងនារីបំរើរបស់នាងលំអោនខ្លួនគោរពយ៉ាងកក់ក្ដៅផង ទាំងយ៉ាងចិត្តសែនស្អប់ផង ។ ព្រោះថ្វីបើ *ប៊ុនគារ៉ូ* ជាឪពុកមារបស់នាងក្ដី ក៏ *ភូជីកូ* ដឹងច្បាស់ថាឪពុកមានាងល្បីល្បាញបំផុតខាងនេះដុំទាំងមិនត្រូវរឿង និងទាំងមិនអាចស្មានបានជាមុន ដែលជាហេតុនាំអោយ *ប៊ុនគារ៉ូ* មានទំនាស់ជាមួយគេឯងស្ទើរគ្រប់គ្នា ។ ជាភាគច្រើន អ្នកដែលត្រូវឈឺសាច់ជាងគេ គឺពួកអ្នកបំរើនិងប្រពន្ធទាំងឡាយរបស់គេនោះឯង ។ នាងនិយាយ :

- សូមអញ្ជើញចូលលោកពូ ។ លោកពូមានសន្ដានចិត្តល្អមែន ដែលមកដល់ភ្លាមមកលេងក្មួយភ្លាមយ៉ាងនេះ ។

- អ្ហា *ភូជីកូ - សាន* ។ ចុះ....ចុះធុំក្លិនស្អីអាក្រក់ម្ល៉េះ ?

- គឺលោកម្ចាស់ខ្ញុំគាត់ចំអិនសាច់សត្វដែលលោកម្ចាស់ *ភូវ៉ាណាកា* បានផ្ញើមកគាត់... អីលូវនេះគាត់កំពុងបង្រៀនចុងភៅរម៉ិករម៉ក់ខ្ញុំអោយចេះចំអិនវា ។

- បើសិនជាគាត់ចង់ដាំស្ល គាត់ចេះតែដាំស្លបានហើយ ថ្វីត្បិតតែ.....- *ប៊ុនគារ៉ូ* យកដៃច្របាច់ច្រមុះក្នុងភាពល្ងើម -ហ៊ឹងហើយម្ចាស់ផ្ទះចង់ធ្វើអីក្នុងផ្ទះខ្លួនឯងយ៉ាងម៉េច ក៏ចេះតែបានហើយ អោយតែនៅក្នុងក្របខ័ណ្ឌច្បាប់ កុំអោយតែរំខានអ្នកជិតខាង ។

តាមច្បាប់ ក្លិនម្ហូបដែល *ថ្លាក់ថុន* កំពុងធ្វើនេះ ពិតជានាំមកនូវការរអ៊ូរទាំតវ៉ាជាមិនខាន ហើយជាការមិនល្អទេ ដែលគេធ្វើអោយអ្នកជិតខាងមានការលំបាកនោះ ។ អ្នក



www.budinst.gov.kh www.elibraryofcambodia.org

ថ្នាក់ក្រោមមិនត្រូវធ្វើអ្វីដែលរំខានដល់ថ្នាក់លើរបស់ខ្លួនឡើយ បើមិនដូច្នោះទេ ក្បាលច្បាស់ជារមៀលធ្លាក់ដល់ដីជាមិនខាន ។ គឺដោយប្រការនេះហើយ ទើបនៅទូទាំងនគរ *សាមូរ៉ៃ* រមែងរស់នៅយ៉ាងប្រុងប្រយ័ត្ន និងយ៉ាងគួរសមជិតគ្នានឹង *សាមូរ៉ៃ* ដែលមានឋានៈស្មើនឹងខ្លួនបំផុតតាមដែលអាចធ្វើទៅបាន ហើយកសិករស់ក្បែរកសិករ ពួកអ្នករកស៊ីជួញដូរនៅជួរផ្លូវជាមួយគ្នា ហើយពួក *អេតា* ក៏រស់នៅដាច់ដោយឡែកឯខាងក្រៅភូមិទៅទៀតទៅ ។ នៅទីនេះ *អូមី* ជាអ្នកភូមិផងរបងជាមួយ ឯ *ប៊ុនតារ៉ូ* មានឋានៈខ្ពស់ជាង ។ គិតយ៉ាងនេះហើយទើបនាងឆ្លើយទៅវិញ :

- ក្មួយគិតយ៉ាងត្រង់ថា គ្មានអ្នកណាត្រូវបានរំខានទេ ។

នៅក្នុងចិត្ត *ភូជីកូ* សែនតុញតុះដោយមិនដឹងថា តើ *ប៊ុនតារ៉ូ* មានល្បិចអីទៀត ។

- លោកពូចង់ជួបលោកម្ចាស់របស់ក្មួយរឺ ?

រួចនាងក៏ងើបឡើង តែ *ប៊ុនតារ៉ូ* ឃាត់នាងភ្លាម :

- ទេ ! សូមកុំរំខានគាត់អី ។ ខ្ញុំនៅរង់ចាំគាត់ចុះ ។

សំដី *ប៊ុនតារ៉ូ* សែនគួរសម ។ បេះដូង *ភូជីកូ* ហាក់ធ្លាក់ស្រ៊ុបតែម្តង ព្រោះអ្នកណាក៏ដឹងដែរថា មនុស្សនេះជាមនុស្សច្រងេងច្រងាងផុតលេខ ហើយកាលណាមនុស្សនេះកាន់តែគួរសម គឺកាន់តែគ្រោះថ្នាក់ ។ *ប៊ុនតារ៉ូ* និយាយបន្ត :

- អោយខ្ញុំសូមទោសផងដែលមកដោយមិនបានអោយអ្នកនាំសារមកសាកសួរពាត់ជួបជាមុន ប៉ុន្តែលោកម្ចាស់ *តូរ៉ាណាកា* បានប្រាប់ខ្ញុំថា ខ្ញុំអាចនឹងបានអនុញ្ញាតអោយប្រើអាងទឹក និងស្នាក់អាស្រ័យនៅទីនេះបាន ។ គឺម្តងម្កាល ។ សូមក្មួយសាកសួរ *អាន់ជីន - សាន* នៅពេលបន្តិចទៀតថា តើគាត់យល់ព្រមទេ ?

- ពិតជាបាន - នាងតបដោយយ៉ាងពិធីការដូចគ្នា ទាំងក្នុងចិត្តសែនមហាស្អប់ចំពោះវត្តមាន *ប៊ុនតារ៉ូ* នៅក្នុងផ្ទះនាងនេះ -ក្មួយជឿជាក់ថា គាត់ពិតជាមានកិត្តិយសណាស់ ។ ក្នុងពេលរង់ចាំ លោកពូពិសាតែ រឺ សាកេសិនទៅអ្វី ?

- សាកេ ។ សូមអរគុណក្មួយ ។



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ុនតារ៉ូ* ហុចធ្នូហើយនិងបំពង់ព្រួញទៅអោយអង្គរក្សរបស់ខ្លួនដោះស្បែកជើងស៊ុទ តែដីចេញ ទើបឡើងមកលើរានហាល បន្ទាប់មកទើបលោកហូតដាវចេញពីចង្កេះអង្គុយ ពែនភ្នែន ហើយដាក់ដាវនៅលើភ្លៅរបស់ខ្លួន ។

- ប្រពន្ធខ្ញុំនៅឯណា ? នៅជាមួយ *អាន់ជីន -សាន* មែនទេ ?

- មិនមែនទេ *ប៊ុនតារ៉ូ - សាម៉ា* ។ សូមទោសទៅចុះ តែនាងទទួលបញ្ជាអោយ ទៅបន្ទាយដែល.....

- ទទួលបញ្ជា ? អ្នកណាបញ្ជា ? *កាស៊ីគី យ៉ាប៊ូ* បញ្ជាអី ?

- ទេ មិនមែនទេ ។ គឺបញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* នៅពេលដែលលោក ត្រលប់មកពីបរបាញ់រសៀលនេះវិញ ។

- អូ លោកម្ចាស់ *តូរ៉ាណាកា* ទេអ្ហ៎ ។

*ប៊ុនតារ៉ូ* បន្ធូរអារម្មណ៍ក្តៅក្រហាយ ហើយបែរសំលឹងមើលទៅបន្ទាយដែលនៅឯ ម្ខាងឈូងសមុទ្ទទាំងមុខក្រញូវ ។ ទង់របស់ *តូរ៉ាណាកា* បក់រវិចក្បែរទង់របស់ *យ៉ាប៊ូ* នៅទី នោះ ។

- លោកពូចង់អោយខ្ញុំទៅហៅ *ម៉ារីកូ* មកអី ?

*ប៊ុនតារ៉ូ* គ្រវីក្បាល : .

- គង់តែមានពេលជួបគ្នាទេ ។

លោកដកដង្ហើមបន្ធូរទ្រូង សំលឹងមើល *ភូជីកូ* ។ នាងជាកូនស្រីរបស់ប្អូនស្រីពៅ របស់លោក :

- ខ្ញុំមានសំនាងណាស់ដែលបានប្រពន្ធដ៏ឥតខ្ចោះយ៉ាងនេះ *ទេ* ?

- ចាសពិតហើយ ។ ពិតជាអ៊ីចឹងមែន ។ នាងចំជាមានតំលៃកាត់ថ្លៃមិនបានក្នុង ការបកប្រែចំនេះដឹងរបស់ *អាន់ជីន -សាន* ។

*ប៊ុនតារ៉ូ* សំលឹងត្មែរទៅបន្ទាយរួចហិតខ្យល់ ។ ក្លិនម្ហូបបានជះមកជាថ្មីម្តងទៀត :

- ក្លិនមើលតែនៅ *ណាកាសាគី* រី នៅកូវ៉េអ៊ីចឹង ។ នៅទីនោះពួកវាធ្វើម្ហូបសាច់



www.budinst.gov.kh www.elibraryofcambodia.org

រាល់តែពេល ជូនស្ងោរ ជូនដុត ។ ស្អុយសំបើមតែម្តង ។ មិនដែលមានក្លិនណាអាក្រក់ជាង ហ្នឹងទៀតទេ ។ ពួកកូរ៉េនេះសត្វជាត្មា ។ គ្រាន់តែក្លិនខ្ទឹមពួកវាជាប់តាំងពីខោអាវនិងសក់ ។

- មើលទៅប្រហែលជាយ៉ាប់មែនទែន ។

- សង្គ្រាមប្រព្រឹត្តទៅបានល្អទេ ។ ពួកយើងអាចយកជ័យជំនះបានយ៉ាងស្រួល ហើយវាយចូលចិនបានទៀត ដើម្បីនឹងជួយអោយប្រទេសពីរនេះមានអារ្យធម៌ឡើង -មុខ *ប៊ុនតារ៉ូ* ឡើងក្រហម សំលេងលោកឡើងខ្ទ័រ - តែផ្ទុយវិញយើងត្រូវបរាជ័យ ហើយវិលមកស្រុកវិញទាំងអាម៉ាស់ ព្រោះដោយសារតែយើងត្រូវរងអំពើក្បត់ ។ អំពើក្បត់ដែលដោយសារពួកអាចោកទាបខ្លះដែលនៅថ្នាក់លើនោះឯង ។

- ចាស គួរអោយស្រណោះមែន ។ តែនេះគឺពិតជាត្រូវមែន ។ ត្រូវសែនត្រូវ *ប៊ុនតារ៉ូ - សាម៉ា* ។

*ភូជីកូ* និយាយយកចិត្តប្តីរបស់ខ្លួនទាំងកុហក ព្រោះនាងដឹងថា គ្មានទ័ពណាមួយនៅលើដីនេះ អាចប្រាមប្រាបប្រទេសចិនបានទេ ហើយក៏គ្មានអ្នកណាទៅធ្វើអោយចិនមានអារ្យធម៌ដែរ ដោយថាចិនមានអារ្យធម៌តាំងពីបរមបុរាណមកម្ល៉េះ ។

សរសៃរថ្ងាសរបស់ *ប៊ុនតារ៉ូ* ប៉ោងរវាម ហើយលោកនិយាយហាក់សំរាប់ខ្លួនលោកតែប៉ុននោះ :

- ពួកវាត្រូវតែសង ។ ពួកវាទាំងអស់ត្មាណើង ។ ពួកអាក្បត់ទាំងអស់ណឹង ។ អានេះគ្រាន់តែជារឿងឈរនៅលើច្រាំងទន្លេអោយបានយូរ ដើម្បីមើលសពសត្រូវយើងវាអណ្តែតមកតែប៉ុននោះទេតើ *នេ*? ពូនឹងនៅឈរចាំ ហើយពូនឹងស្តោះទឹកមាត់លើក្បាលរបស់វាជាមិនខានទៅពេលខាងមុខ ។ ពេលខាងមុខយ៉ាងខ្លីនេះ ។ ពូបានសន្យាខ្លួនឯងអ៊ីចឹង -រួចលោកសំលឹងមើលនាង - ពូស្អប់រឿងក្បត់និងរឿងផិតណាស់ ។ ហើយស្អប់ពួកភូតភរកុហកទាំងអស់ !

- ចាស នាងខ្ញុំឯកភាពណាស់ ។ ពិតជាយោបល់ត្រឹមត្រូវណាស់ *ប៊ុនតារ៉ូ* -



www.budinst.gov.kh www.elibraryofcambodia.org

*សាម៉ា* ។

*កូជីកូ* និយាយទាំងស្រៀវឆ្អឹងខ្នងខ្នាក ដោយនាងដឹងថា ភាពសាហាវឃោរឃៅរបស់ *ប៊ុនតារ៉ូ* គ្មានព្រំដែនកំនត់ទេ ។ នៅពេលដែលខ្លួនមានអាយុដប់ប្រាំមួយឆ្នាំ *ប៊ុនតារ៉ូ* បានសំលាប់ម្តាយបង្កើតរបស់ខ្លួនដែលជាប្រពន្ធចុងថ្នាក់ទាបមួយរបស់ *ហ៊ីរ៉ូ-ម៉ាត់ស៊ី* ព្រោះបទសង្ស័យថា បានលួចផិតឪពុករបស់ខ្លួន ដែលពេលនោះកំពុងជាប់ដៃធ្វើសង្គ្រាម ដើម្បីមេផ្តាច់ការ *ក្លូរ៉ាដា* ។ ប៉ុន្មានឆ្នាំក្រោយមកទៀត លោកបានសំលាប់កូនប្រុសច្បងនៃប្រពន្ធទីមួយរបស់លោកទៀត ដោយបទចោទថា ប្រមាថ ព្រមទាំងបណ្តេញម្តាយទៅនៅគ្រួសារដើមរបស់ខ្លួនវិញថែមទៀត ។ នារីជាម្តាយនេះដោយមិនអាចទ្រាំទ្រនឹងភាពអាម៉ាស់នេះបាន ក៏បានធ្វើអត្តឃាតទៅនៅពេលក្រោយមកទៀត ។ *ប៊ុនតារ៉ូ* តែងធ្វើបាបមហាអស្ចារ្យលើប្រពន្ធចុងទាំងឡាយរបស់ខ្លួននិងលើ *ម៉ារីកូ* ។ លោកនៅបានឈ្លោះទាស់ទែងយ៉ាងសំបើមអស្ចារ្យជាមួយឪពុក *កូជីកូ* ហើយបានចោទឪពុកនាងថា ជាមនុស្សកំសាកញីពីពេលសង្គ្រាមនៅកូរ៉េ ហើយបានមកប្តឹងបង្កាច់បង្ខូចឪពុក *កូជីកូ* នៅចំពោះមុខលោកម្ចាស់ *តៃកូ* ធ្វើអោយលោកម្ចាស់ *តៃកូ* ចេញបញ្ជាអោយឪពុកនាងកោរក្បាលបួសជាសង្ឃ និងស្លាប់ក្នុងភាពអាម៉ាស់ និងអសោចកេរ្តិ៍ ។

*កូជីកូ* ត្រូវប្រើអស់ទូវកំលាំងចិត្តរបស់ខ្លួនដើម្បីរក្សាអាកប្បកិរិយាអោយនៅជាធម្មតា ។ នាងពោល :

- ពួកយើងមានមោទនភាពណាស់ ដែលបានដឹងថាលោកពូគេចរួចពីពួកសត្រូវ ។ *សាកេ* ត្រូវបានលើកមកដល់ ។ *ប៊ុនតារ៉ូ* ចាប់ផ្តើមផឹកដូចផឹកទឹកតែម្តង ។ ក្រោយពីចាន់ប្រមាណថា ពេលវេលាសមគួរហើយ *កូជីកូ* ក៏ងើបក្រេសឡើង :

- សូមលោកពូអត់ទោសអោយក្មួយមួយភ្លែត ។

រួចនាងក៏ដើរទៅចង្ក្រានដើម្បីប្រាប់ *ក្លាក់ថន* អោយប្រុងប្រយ័ត្នជាមុន និងសុំការអនុញ្ញាតអោយ *ប៊ុនតារ៉ូ* បានស្នាក់នៅក្នុងផ្ទះជាមួយផង ។ ទន្ទឹមនោះនាងក៏ប្រាប់ *ក្លាក់ថន* និងពួកអ្នកបំរើទាំងអស់ពីអ្វីដែលត្រូវធ្វើសព្វគ្រប់ ។



www.budinst.gov.kh www.elibraryofcambodia.org

*ភ្នាក់ថន* សួរទាំងមូម៉ៅ ៖

- ម៉េចចាំបាច់យកកន្លែងនេះ ? ម៉េចចាំមកស្នាក់នៅទីនេះទៅវិញ ? វាចាំបាច់ណាស់ទៅអ្វី ?

*ភូជីកូ* សូមទោស *ភ្នាក់ថន* ព្រមទាំងខិតខំពន្យល់គេថា គេពិតជាមិនអាចប្រកែកមិនអោយ *ប៊ុនតារ៉ូ* ស្នាក់នៅបាននោះទេ ។ *ភ្នាក់ថន* ក៏ត្រលប់ទៅដាំស្លវិញទាំងមុខក្រញូវៗ *ភូជីកូ* ក៏វិលត្រលប់ទៅគួរសមជាមួយ *ប៊ុនតារ៉ូ* វិញ ទាំងតឹងទ្រូងស្ទើរបែក ៖

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា គាត់មានកិត្តិយសណាស់ដែលលោកពូស្នាក់នៅទីនេះ ។ ផ្ទះគាត់គឺជាផ្ទះរបស់លោកពូហើយ ។

- ធ្វើកំនាន់អ្នកចុងស្រុកយ៉ាងម៉េចដែរ ?

- ជាមួយអ្នកចុងស្រុកឯទៀត តាមខ្ញុំស្មានប្រហែលធុនធ្ងរណាស់ ។ តែចំពោះ *អាន់ជីន - សាន* ដែលជា *ហាតាម៉ូតូ* និងជា *សាមូរ៉ៃ* វិញនេះ ខ្ញុំគិតថា គាត់ដូចជាបុរសឯទៀតអ៊ីចឹង ។ នេះជាលើកទីមួយហើយដែលខ្ញុំធ្វើកំនាន់គេ ។ ខ្ញុំចង់ដើរតួជាប្រពន្ធវិញ តែជាមួយ *អាន់ជីន -សាន* ខ្ញុំមិនមានបញ្ហាអ្វីទេ គ្រាន់តែរបៀបគាត់មានពេលខ្លះចំលែកមែនទែនតែម្តង ។

- អ្នកណានៅទីកឃើញថា មនុស្សនៅក្នុងត្រកូលយើងអាចក្លាយជាកំនាន់របស់មនុស្សចុងស្រុកទៅកើត ។ ហើយមានឋានៈជា *ហាតាម៉ូតូ* ទៅទៀត ។

- ខ្ញុំគ្មានជំរើសទេ ។ ខ្ញុំគ្រាន់តែគោរពតាមទាំងស្រុងបញ្ជារបស់លោកម្ចាស់ *តូរ៉ាណាកា* និងលោកម្ចាស់ *ហ៊ីរ៉ូ - ម៉ាត់ស៊ី* ដែលជាជីតា និងជាមេដឹកនាំសំព័ន្ធត្រកូល យើងតែប៉ុននោះ ។ តួនាទីរបស់នារី គឺគោរពតាមបញ្ជាតែប៉ុននឹងឯង ។

- អ៊ីចឹងហើយ - *ប៊ុនតារ៉ូ* លើកពែងសាកេផឹកបង្ហើយ ។ *ភូជីកូ* ក៏ចាក់បំពេញពែងឡើងវិញ - ការគោរពតាមបញ្ជា គឺជាការសំខាន់បំផុតសំរាប់នារី ។ ហើយ *ម៉ារីកូ - សាន* ក៏ស្តាប់តាមបញ្ជាណាស់ដែរមែនទេ ?

- ចាសមែន លោកម្ចាស់ - នាងសំលឹងមើលមុខដ៏អាក្រក់ដូចស្វារបស់ *ប៊ុនតារ៉ូ* -



www.budinst.gov.kh www.elibraryofcambodia.org

នាងមានតែនាំជូនលោកម្ចាស់នូវកិត្តិយស បើគ្មាន *ម៉ារីកូ* លោកម្ចាស់ *តូរ៉ាណាកា* ពិតជា មិនទទួលបាននូវចំនេះដឹងរបស់ *អាន់ជីន - សាន* បានទេ ។

*ប៊ុនតារ៉ូ* ញញឹមយ៉ាងមានល្បិច :

- ពូលឺថា ឯងភ្ជង់កាំភ្លើងដាក់មុខ *អូមី - សាន* ផង ?

- ខ្ញុំគ្រាន់តែបំពេញភារកិច្ចរបស់ខ្ញុំតែប៉ុននោះ ។

- ឯងរៀនចេះប្រើកាំភ្លើងពីណាមក ?

- ខ្ញុំមិនដែលកាន់កាំភ្លើងសោះរហូតដល់ថ្ងៃប្រើវានោះតែម្តង ។ ខ្ញុំមិនទាន់ដឹងថាកាំភ្លើងណុងមានគ្រាប់រឺអត់ផងទេ តែបើចាំបាច់ខ្ញុំនឹងកាច់កៃហើយ ។

*ប៊ុនតារ៉ូ* ផ្ទុះសំនើច :

- *អូមី - សាន* ក៏គិតយ៉ាងណុងដែរ ។

*ភូជីកូ* បំពេញពែងជាថ្មី :

- ខ្ញុំមិនយល់ទាល់តែសោះថា ថ្ងៃនោះហេតុអីក៏ *អូមី -សាន* មិនសាកដកហូតកាំភ្លើងពីខ្ញុំអីចឹង ។ លោកម្ចាស់របស់គាត់បានបញ្ជាអោយគាត់ដកកាំភ្លើងពីខ្ញុំ តែគាត់អត់ធ្វើតាមទេវិញ ។

- បើពូវិញ ពូច្បាស់ជាធ្វើតាមបញ្ជាហើយ ។

- ចាស លោកពូខ្ញុំដឹងហើយ ។ តែសូមអភ័យទោសទៅចុះ ទោះថាពេលនោះជាលោកពូក៏ដោយ ក៏ខ្ញុំច្បាស់ជាកាច់កៃដែរ ។

- អីចឹងមែន តែឯងអាចបាញ់ខុស !

- ប្រហែលជាអីចឹងមែន ។ តែតាំងពីពេលនោះមកខ្ញុំរៀនចេះបាញ់ហើយ ។

- វាបង្ហាត់ឯងរឺ ?

- ទេ តែគឺមេទ័ពម្នាក់របស់លោកម្ចាស់ *ណាកា* បង្ហាត់ខ្ញុំ ។

- ហេតុអីទៅ ?

- ឪពុកខ្ញុំមិនអនុញ្ញាតអោយកូនស្រីៗរបស់គាត់ហាត់ដាវនិងលំពែងឡើយ ។ តាម



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំគិត គាត់មានការយល់ឃើញដ៏ល្អមួយថា ស្រី១ត្រូវរៀនពីរឿងអ្វីដែលទន់ភ្លន់ជាង ។ តែមានពេលខ្លះនារីត្រូវការពារម្ចាស់របស់ខ្លួន និងផ្ទះរបស់ខ្លួនផងដែរ ។ កាំភ្លើងជាអាវុធមួយដ៏ល្អសំរាប់នារី ។ ល្អមែនទែន ។ នេះមិនចាំបាច់មានកំលាំង ហើយក៏មិនចាំបាច់ចំនាយពេលច្រើនដើម្បីហាត់ដែរ ។ អ៊ីចឹងហើយទើបអីលូវនេះ ខ្ញុំប្រហែលមានប្រយោជន៍តិចតួចដែរចំពោះលោកម្ចាស់ខ្ញុំ ព្រោះថា ខ្ញុំអាចបាញ់បំបែកសន្ទះក្បាលបុរសទាំងអស់ណាក៏បានដើម្បីការពារគាត់ និងដើម្បីកិត្តិយសរបស់ត្រកូលយើង ។

*ប៊ុនភារ៉ូ* បង្ហើយពែងស្រារបស់ខ្លួន ៖

- ពូសែនមានមោទនភាពនៅពេលដែលលឺថា ឯងហ៊ានតទល់របៀបនេះជាមួយ*អូមី -សាន* ។ ឯងធ្វើនេះត្រឹមត្រូវណាស់ ។ លោកម្ចាស់ *ហ្គ៊ី - ម៉ាត់ស៊ី* ក៏ពិតជាមានមោទនភាពណាស់ដែរ ។

- សូមអរគុណលោកពូ ។ តែនេះគឺខ្ញុំគ្រាន់តែបំពេញភារកិច្ចជាធម្មតាមួយតែប៉ុននោះ - នាងលំអោនខ្លួនយ៉ាងផ្លូវការ - លោកម្ចាស់របស់ខ្ញុំសួរលោកពូថា តើលោកពូផ្តល់កិត្តិយសអោយគាត់បានជជែកជាមួយពូបានទេ បើលោកពូមិនប្រកែប្រកាន់អីនោះ ។

*ប៊ុនភារ៉ូ* លំអោនខ្លួនគោរពតបវិញ ៖

- សូមអរគុណគាត់ផង តែដំបូងបំផុតអោយខ្ញុំមុជទឹកសិនបានទេ ? បើគាត់មិនប្រកាន់ទេ ខ្ញុំនឹងជួបគាត់ក្រោយពេលដែលប្រពន្ធរបស់ខ្ញុំត្រលប់មកវិញ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៣៥

*ប្លាក់ថន* រង់ចាំនៅឯក្នុងសួនច្បារ ។ ពេលនេះគេពាក់ឯកសណ្ឋាន *គំម៉ូណូ* ពណ៌ប្រផេះ ដែល *តូរ៉ាណាកា* បានប្រគល់អោយគេ និងដោយមានសៀតដាវនឹងខ្សែក្រណាត់រុំចង្កេះទៀតផង ។ កាំភ្លើងខ្លីមួយដើមដែលមានញាត់គ្រាប់ហើយស្រេច ក៏ត្រូវបានគេលាក់ទុកនៅក្នុងក្រណាត់ចង្កេះនេះដែរ ។ តាមការពន្យល់យ៉ាងរហ័សរបស់ *តូជីកូ* និងពួកអ្នកបំរើ គេយល់ថា គេត្រូវទទួល *ប៊ុនតារ៉ូ* ជាផ្លូវការ ដោយថា *សាមូរ៉ៃ* នេះ ជាមេទ័ពម្នាក់ដ៏សំខាន់ និងជា *ហាតាម៉ូតូ* ហើយក៏ជាភ្ញៀវទីមួយនៅក្នុងផ្ទះនេះផង ។ ដោយហេតុនេះហើយ ទើបគេប្រញាប់ប្រញាល់មុជទឹកនិងផ្លាស់ខោអាវជាបន្ទាន់ ។ រួចរាល់ហើយ គេក៏ដើរទៅកាន់កន្លែងដែលត្រូវបានរៀបចំហើយជាស្រេចនោះ ។

កាលពីម្សិលមិញ គេបានឃើញ *ប៊ុនតារ៉ូ* មួយភ្លែតដែរ នៅពេលដែលបុរសនេះមកដល់ ។ ហើយពេញមួយថ្ងៃ *ប៊ុនតារ៉ូ* ជាប់រវល់ពេញជាមួយ *តូរ៉ាណាកា យ៉ាប៊ូ* និង *ម៉ារីកូ* ទុកអោយ *ប្លាក់ថន* នៅតែម្នាក់ឯងដើម្បីរៀបចំសមយុទ្ធវាយលុកដ៏រហ័សជាមួយនឹង *អូមី* និង *ណាកា* ។ ការវាយលុកនេះបានល្អសមរម្យ ។

ល្ងាចនេះ *ម៉ារីកូ* វិលមកផ្ទះវិញនៅពេលយប់ណាស់ទៅហើយ ។ នាងបាននិយាយប្រាប់គេយ៉ាងៗ ពីការគេចខ្លួនរបស់ *ប៊ុនតារ៉ូ* ពីការប្រដេញរបស់កូនចៅ *អ៊ីស៊ីដូ* ពីការគេចពីពួកនេះ និងពីការឆ្លងកាត់ខេត្តនានាដែលជាសត្រូវដើម្បីទៅដល់ *ក្វាន់តូ* ដោយសុខសាន្ត ៖

- នេះគឺចំជាលំបាកលំបិនណាស់ តែមិនមែនលំបាកហួសហេតុនោះទេ *អាន់ជីន - សាន* ។ ប្តីខ្ញុំខ្លាំងក្លាហើយក្លាហានណាស់ ។

- តើអីលូវនេះនឹងមានរឿងអីទៀតទៅ ? នាងចាកចេញនៅពេលនេះរឺ ?

- លោកម្ចាស់ *តូរ៉ាណាកា* បានបញ្ជាអោយអ្វីៗនៅដដែលដូចមុនអីចឹង ។ គ្មានអ្វីដែលត្រូវផ្លាស់ប្តូរនោះទេ ។

- នាងបានផ្លាស់ប្តូរណា *ម៉ារីកូ* ។ ពន្លឺហាក់បានរលត់បាត់ពីខ្លួននាងទៅហើយ ។

- ទេ ។ នោះគឺជាការស្រមើស្រមៃរបស់លោកតែប៉ុននោះ *អាន់ជីន - សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

នោះគ្រាន់តែជាការធូរទ្រូងដែលឃើញគាត់នៅរស់ ក្នុងពេលដែលខ្ញុំនឹកគិតជាក់នៅក្នុងចិត្តថា គាត់ទទួលមរណភាពបាត់ទៅហើយតែប៉ុននោះ ។

- អីចឹងហើយ តែនេះក៏បង្ហាញពីភាពខុសគ្នាដែរ មិនអីចឹង ?

- ពិតមែនហើយ ។ ខ្ញុំសូមអរគុណព្រះជាម្ចាស់ដែលលោកម្ចាស់ខ្ញុំមិនបានត្រូវគេចាប់បាន ដែលបានអោយគាត់នៅរស់រានមានជីវិតដើម្បីបំរើលោកម្ចាស់ *តូរ៉ាណាកា* ។ តែពេលនេះសូមអត់ទោសអោយខ្ញុំផងចុះ *អាន់ជីន - សាន* ខ្ញុំហត់ណាស់ ខ្ញុំសូមទោសណាំ ។ ខ្ញុំបាក់ប្បែមែនទែនហើយ ។

- តើមានអីអោយខ្ញុំជួយធ្វើបានទេ ?

- តើលោកមានអីគួរធ្វើទៅ *អាន់ជីន - សាន* ? ក្រៅពីជួយសប្បាយដល់ខ្ញុំ និងដល់គាត់នោះ ។ តាមពិតទៅ គ្មានអ្វីផ្លាស់ប្តូរទេ ។ គ្មានអ្វីដែលត្រូវបញ្ចប់ព្រោះគ្មានអ្វីដែលបានចាប់ផ្តើមផងដែរ ។ អ្វីៗនៅដូចគ្រាមុន ។ ប្តីខ្ញុំនៅរស់ទេ ។

មិនតឹអញ្ជបន់អោយប្តីនាងស្លាប់ទេអ្ហី ? *-ប្លាក់ថន* ដណ្តឹងសួរនៅក្នុងចិត្តនៅពេលនេះដែលគេកំពុងនៅក្នុងសួនច្បារ ។ ទេ ។

បើទេ ម៉េចចាំបាច់លាក់កាំភ្លើងខ្លីធ្វើអី ? រឺអ្ហែងមានខ្លួនដែរទេដឹង ?

ទេ ។ គ្មានអ្វីដែលបានចាប់ផ្តើមផងទេ ។

គ្មានអ្វីចាប់ផ្តើមមែន ?

គ្មាន ។

អ្ហែងគិតថាអ្ហែងបានរូបនាង ។ តើអាណឹងវាដូចគ្នានឹងបានរូបនាងមែនទែន រឺ ទេ ?

គេឃើញ *ម៉ារីកូ* ដើរចេញពីផ្ទះសំដៅមកសួនច្បារ ។ នាងមានរូបរាងហាក់បីដូចជាកូនក្រមុំប៉ិកសឺឡែនដ៏តូចច្រលឹងមួយ ។ នៅពីមុខនាងកន្លះជំហាន គឺ *ប៊ុនតារ៉ូ* ដែលមានមាឌគួរស្បើមថែមទៀតពេលដែលនៅជិតនាងយ៉ាងដូចនេះ ។ *កូជីកូ* និង ពួកនារីបំរើក៏មកជាមួយគេដែរ ។ គេលំអោនខ្លួន :

- *យ៉ូកូសូ អូអ៊ីដេ គូដាសារេតា ប៊ុនតារ៉ូ - សាន* សូមស្វាគមន៍ដែលបានមកផ្ទះខ្ញុំ



www.budinst.gov.kh www.elibraryofcambodia.org

នេះ *ប៊ុនតារ៉ូ - សាន* ។

ទាំងអស់គ្នាលំអោនខ្លួនគោរព ។ *ប៊ុនតារ៉ូ* និង *ម៉ារីកូ* អង្គុយលើម៉ក់ទល់មុខនឹង *ឡាក់ថន* ។ *ភូជីកូ* ដាក់បង្គុយពីក្រោយកំនាន់នាង ។ *នីកាតស៊ុ* និង *កយ* នារីអ្នកបំរើ ចាប់ផ្តើមបំរើតែ និង សាកេ ។ *ប៊ុនតារ៉ូ* យកសាកេ ។ *ឡាក់ថន* ក៏ធ្វើតាមដែរ ។

- *ដូម៉ូ អាន់ជីន - សាន* ។ *អ៊ីកាកា តេស៊ូ កា ?*

- *អ៊ីអ៊ី* ។ *អ៊ីកាកា តេស៊ូ កា ?*

- *អ៊ីអ៊ី* ។ *កូវ៉ា ចូស៊ូនី សាបេរេវូ យ៉ូនី ណាកា ណា* - ល្អ ។ លោកចាប់ផ្តើមនិយាយភាសាជប៉ុនបានល្អណាស់ ។

តែបន្តិចក្រោយមក *ឡាក់ថន* ចាប់ផ្តើមវង្វេងវង្វាន់ ដោយ *ប៊ុនតារ៉ូ* និយាយលេបពាក្យផង និងនិយាយញាប់ដោយឥតរវល់ថាគេស្តាប់បានរឺមិនបានផង ។

- សូមទោស *ម៉ារីកូ - សាន* ។ កន្លែងហ្នឹងខ្ញុំស្តាប់មិនបានទេ ។

- ប្តីខ្ញុំគាត់សូមអរគុណលោកដែលបានសាកល្បងជួយសង្គ្រោះគាត់ដោយបោះច្រវាអោយគាត់នោះ ។ លោកមានចាំទេ ? កាលយើងគេចខ្លួនពី *អូសាកា* នោះណា ។

- អ្ហា ! *សូតេស៊ូ ! ដូម៉ូ* ។ សូមជំរាបគាត់ផងថា មកដល់ពេលនេះខ្ញុំនៅតែគិតថា យើងគួរត្រលប់ទៅច្រាំងវិញ ។ កាលនោះយើងនៅសល់ពេលគ្រប់គ្រាន់ ។ នារីបំរើលង់ទឹកស្លាប់ទទេ ។

- គាត់ថានេះជា *កាម៉ា* ។

- នេះជាការស្លាប់មួយដោយឥតប្រយោជន៍ ។

*ឡាក់ថន* តប រួចគេក៏ទឹកស្តាយនឹងភាពរឹងត្អឹងរបស់គេភ្លាម ។ គេឃើញ *ម៉ារីកូ* ឥតបកស់ជីរបស់គេនេះទេ ។

- ប្តីរបស់ខ្ញុំមានប្រសាសន៍ថា យុទ្ធសាស្ត្រវាយលុកនេះល្អណាស់ ។ ល្អមែនទែនតែម្តង ។

- *ដូម៉ូ* ។ សូមជំរាបទៅគាត់ផងថា ខ្ញុំសប្បាយចិត្តណាស់ដែលឃើញគាត់គេចខ្លួន



www.budinst.gov.kh www.elibraryofcambodia.org

រួចដោយឥតមានរងគ្រោះអី ។ ហើយអរចំពោះប្រការដែលគាត់ទទួលកាន់កងពលធំនេះ ។ម្យ៉ាងទៀតក៏សូមជំរាបគាត់ថា ខ្ញុំសូមស្វាគមន៍គាត់ស្នាក់នៅទីនេះ ។

- *ជូមូ អាន់ជីន - សាន* ។ *ប៊ុនតារ៉ូ - សាម៉ា* មានប្រសាសន៍ថា ឬង់វាយលុកនេះល្អណាស់ ។ តែចំពោះគាត់វិញ គាត់នឹងកាន់ធ្នូ ហើយនឹងដាវរបស់គាត់ជានិច្ច ។ គាត់អាចសំលាប់បានពីទីឆ្ងាយជាង ត្រង់ជាង និងរហ័សជាង *មូរស្គេ* ។

- ស្អែកនេះខ្ញុំនឹងបាញ់តទល់គ្នាជាមួយគាត់ ហើយយើងនឹងដឹងជាមិនខាន ។ នេះបើគាត់ចង់ ។

- លោកនឹងចាញ់ *អាន់ជីន - សាន* ។ សូមទោសទៅចុះ ។ ខ្ញុំសូមដាស់លោកកុំចង់សាកល្បងអោយសោះ ។

*ម៉ារីកូ* ពោលតប ។ *ប្លាក់ថន* ឃើញភ្នែករបស់ *ប៊ុនតារ៉ូ* រត់សំលឹងពីគេទៅនាងពីនាងមកគេ :

- សូមអរគុណ *ម៉ារីកូ - សាន* ។ សូមជំរាបទៅគាត់ថា ខ្ញុំចង់ឃើញគាត់បាញ់ធ្នូណាស់ ។

- គាត់សួរថា លោកចេះបាញ់ធ្នូទេ ?

- ចេះ តែមិនជំនាញទេ ។ ធ្នូវាហួសសម័យសំរាប់ពួកយើង ។ លើកលែងតែស្ពា ។ ខ្ញុំហាត់រៀនជាអ្នកដើរសមុទ្រ នៅសមុទ្រពួកយើងប្រើតែកាណុង *មូរស្គេ* រឺកាំបិតមុខធំតែប៉ុណ្ណឹង ។ម្តងម្កាលយើងប្រើព្រួញភ្លើងដែរ តែសំរាប់តែពេលណាដែលក្តោងសត្រូវចូលកៀកជិតយើងប៉ុននោះ ។

- លោកប្តីខ្ញុំសួរថា តើលោកប្រើវាយ៉ាងម៉េច ? ហើយលោកធ្វើវាយ៉ាងម៉េចទៅព្រួញភ្លើងនេះ ? តើព្រួញភ្លើងរបស់ពួកលោកខុសពីព្រួញភ្លើងដែលពួកគេប្រើតទល់នឹងទូកធំយើងនៅឯ *អូសាកា* រឺក៏អត់ ?

*ប្លាក់ថន* ក៏ចាប់ផ្តើមពន្យល់ ដោយមានការផ្តាច់នឹងសំនួរបញ្ជាក់ដ៏ច្រើនគួរអោយធ្ងឿយណាយជាប្រក្រតីលាយឡំផង ។ តែពេលនេះ *ប្លាក់ថន* ស៊ាំនឹងការយកចិត្តទុកដាក់



www.budinst.gov.kh www.elibraryofcambodia.org

ឈ្លេចសួរពីគ្រប់ទិដ្ឋភាពនៃសង្គ្រាមនេះហើយ គ្រាន់តែគេហាក់ដូចជាហត់នឿយជាពន់ពេក នឹងនិយាយតាមរយៈអ្នកបកប្រែយ៉ាងនេះណាស់ ។ ថ្វីត្បិតតែ *ម៉ារីកូ* ស្ទាត់ជំនាញយ៉ាងណាក្តី ក៏អ្វីដែលនាងនិយាយក៏រអោយបានត្រឹមត្រូវទាំងស្រុងណាស់ ។ ចំលើយវែងត្រូវបានបំព្រួញ ហើយមានពាក្យខ្លះទៀតត្រូវបានកែសំរួលបន្តិចបន្តួច ដែលនាំអោយមានការស្តាប់ច្រលំ ។ យ៉ាងនេះហើយ ការពន្យល់នានាត្រូវតែនិយាយឡើងវិញឥតប្រយោជន៍ ។

ប៉ុន្តែគេបានដឹងច្បាស់ណាស់ថា បើគ្មាន *ម៉ារីកូ* ទេ ខ្លួនគេក៏មិនអាចក្លាយជាមានតំលៃយ៉ាងនេះដែរ ។ គឺចំនេះដឹងនេះហើយដែលបានជួយអញអោយចេញផុតពីអន្លង់បាន - គេរំលឹកនៅក្នុងចិត្ត ។ តែនេះមិនមែនជាបញ្ហានោះទេ ព្រោះនៅមានរឿងដែលត្រូវនិទានច្រើនទៀត និងនៅមានការប្រយុទ្ធ ជាច្រើនដែលត្រូវដណ្តើមយកជ័យជំនះផងដែរ ។ ការប្រយុទ្ធមែនទែនដែលត្រូវជំនះ យកឈ្នះអោយបាន ។ ឯងនៅមានសុវត្ថិភាពគ្រប់គ្រាន់នៅឡើយទេរហូតដល់ពេលនោះ ។ ឯងនៅមានផែនការរៀបចំនាវាថែមទៀត ។ រួចទៅផ្ទះ ។ ទៅដោយសុវត្ថិភាព ។

គេបានឃើញដាវរបស់ *ប៊ុនតារ៉ូ* ។ គេបានឃើញដាវរបស់ពួកអង្គរក្ស ។ គេបានស្គាល់ដាវរបស់គេ ស្គាល់ភាពក្តៅខ្លួនៗនៃកាំភ្លើងប្រលាក់ប្រេងរបស់គេ ហើយគេដឹងយ៉ាងច្បាស់ថា គេនឹងមិនមានសុវត្ថិភាពជាដាច់ខាតនៅលើទឹកដីនេះ ។ ទាំងរូបគេ ទាំងរូបអ្នកណាផ្សេងទៀតក៏ដោយ រួមទាំងខ្លួន *តូរ៉ាណាកា* ផង ពិតជាមិនបានសុខឡើយ ។

- *អាន់ជីន - សាន ប៊ុនតារ៉ូ - សាម៉ា* សួរថា បើសិនជាថ្ងៃស្អែកនេះគាត់បញ្ជូនមនុស្សគាត់ទៅរកលោក តើលោកអាចប្រាប់ពួកនោះពីរបៀបធ្វើព្រួញនោះបានទេ ?

- តើយើងទៅរកដីរចុងឯណាបានទេ ?

- ខ្ញុំមិនដឹងទេ ។

*ម៉ារីកូ* ក៏សួរដេញដោលចុះឡើងពីកន្លែងដែលធ្លាប់បានរាល់ដង ហើយតើដីរចុងនោះរាងវៅ វិក្លិនដូចម្តេច ហើយនឹងលទ្ធភាពរកដីរផ្សេងមកជំនួស ។ រួចនាងក៏និយាយប្រាប់ *ប៊ុនតារ៉ូ* យ៉ាងវែង ។ *ភូជីកូ* នៅអង្គុយយ៉ាងស្ងៀមស្ងាត់ក្នុងរយៈពេលនេះ ប៉ុន្តែភ្នែកនិង



www.budinst.gov.kh www.elibraryofcambodia.org

ក្រចៀកនាងឥតអោយអ្វីរលងផុតបានឡើយ ។ តាមរយៈសញ្ញាថ្មីតដ៏ស្រាលដែលនាងបញ្ជាពួកនារីបំរើបានចាក់បំពេញស្រាសាកេមិនអោយពែងនៅស្ងួតបានឡើយ ។

- លោកប្តីខ្ញុំថា គាត់នឹងពិភាក្សារឿងនេះជាមួយលោកម្ចាស់ *តូរ៉ាណាកា* ។ អាចជំរនេះមាននៅក្នុងកន្លែងណាមួយក្នុងតំបន់ *ក្វាន់តូ* នេះក៏បាន ។ ពួកយើងមិនដែលលឺពីរឿងជំរចុងនេះទេតាំងពីដើមរៀងមក ។ បើសិនជាគ្មានជំរចុងនោះទេ យើងមានប្រេងខាប់ គឺប្រេងត្រីបាឡែន ។ នោះប្រហែលយើងប្រើជំនួសបាន ។ លោកប្តីខ្ញុំសួរថា តើម្តងម្កាលលោកមានប្រើកាំជ្រួចដូចពួកចិនទេ ។

- មាន តែនេះមិនមានសារប្រយោជន៍ប៉ុន្មានទេ លើកលែងតែនៅពេលយើងឡោមព័ទ្ធទីតាំងតែប៉ុននោះ ។ ពួក *ទួគី* ប្រើវិធីនេះនៅពេលដែលពួកវាធ្វើសង្គ្រាមតទល់នឹងពួក *ស៊ីវ៉ាល្យេ* (១) សាំងចននៅទីក្រុងម៉ាល់ ។ ភាគច្រើនកាំជ្រួចត្រូវបានប្រើដើម្បីបង្កអគ្គីភ័យនិងបង្កអោយមានភាពស្ងួនស្ងោតែប៉ុននោះ ។

- គាត់មានប្រសាសន៍ថា សូមលោកមានអធ្យាស្រ័យរ៉ាយរ៉ាប់លំអិតពីការប្រយុទ្ធនោះផង ។

- នោះគឺកើតមានឡើងកាលពីសែសិបឆ្នាំមុន នៅក្នុងមហា......

រូប *ប្លាក់ថន* នៅឈប់ស្ងៀមឈឹង ។ ខួរក្បាលរបស់គេធ្វើសកម្មភាពយ៉ាងពេញល្បឿន ។ កាលនោះគឺជាការវាយហ៊ុមព័ទ្ធដ៏មានសារៈសំខាន់ស្លាប់រស់នៅអឺរ៉ុប ។ ពួកអ៊ីស្លាម *ទួគី* ប្រាំមួយម៉ឺននាក់ដែលជាកងឆើតផុតលេខនៃចក្រភព *អុតូម៉ាន់* (២) បានហ៊ុមព័ទ្ធពួក *ស៊ីវ៉ា*

---

*(១) ស៊ីវ៉ាល្យេក្នុងនេះ គឺជាអង្គភាពទ័ពដែលមានភារកិច្ចការពារបូជនីយដ្ឋានសាសនា ( បារាំងហៅ Chevalier អង់គ្លេសហៅ Kinght ) ( ក.ប.អ. ) ។*

*(២ ) Ottoman Empire . ចក្រភពដែលស្ថិតក្រោមការត្រួតត្រារបស់ ស៊ុលតង់ ដែលមានប្រភពចេញពីកុលសម្ព័ន្ធតួគីមួយក្នុងសតវត្សរ៍ទីដប់បី ដឹកនាំដោយឈ្មោះ អែតូគ្រល់ ហើយដែលបុត្រឈ្មោះ អូស្មាន់ រឺ អុត្មាន់ ( ១២៨១ ដល់ ១៣២៦ ) ដែលចំនេរមកទៀតគេហៅពួកនោះជាពួកអុតូម៉ាន់ទាំងអស់តែម្តង ( ក.អ.ប. ) ។*



www.budinst.gov.kh www.elibraryofcambodia.org

ល្បេ គ្រិស្តចំនួនប្រាំមួយរយនាក់ហើយដែលមានការគាំទ្រពីពួកជំនួយ ម៉ាល់ ជាងពាន់នាក់ទៀត នៅក្នុងមហាបន្ទាយមួយនៅ *សាំងអេលម៉ូ* ( Saint Elmo ) លើកោះ *ម៉ាល់* ដ៏តូចមួយក្នុងសមុទ្រ *មេឌីទែរ៉ាណេ* ។ ពួក *សឺរ៉ាល្បេ* ទាំងនោះបានទប់ទល់បានដោយជោគជ័យការហ៊ុមព័ទ្ធអស់រយៈពេលប្រាំមួយខែ ហើយថែមទាំងបានធ្វើអោយសត្រូវបង្ខំចិត្តដកថយទាំងអាម៉ាស់ស្ទើរមិនអាចជឿបាន ។ ជ័យជំនះនេះបានជួយសង្គ្រោះតំបន់ *មេឌីទែរ៉ាណេ* ទាំងមូល ពោលគឺពិភពលោកគ្រិស្តអោយចាកផុតពីការបំផ្លិចបំផ្លាញរបស់ពួកអ៊ីស្លាមបាន ។

មួយរំពេចនោះ *ប្លាក់ថន* ទើបប្រទះឃើញថា សង្គ្រាមនេះអាចផ្តល់នូវសោសំរាប់ដណ្តើមកាន់កាប់វិមាន *អូសាកា* បាន ៖ ពោលគឺតើត្រូវវាយលុកយ៉ាងម៉េច វាយសម្រុកយ៉ាងម៉េច វាយទំលាយទ្វារយ៉ាងម៉េច ហើយនឹងប្រាមប្រាបវិមាននេះយ៉ាងម៉េច ។

-លោកនិយាយថាម៉េច ?

-គឺរឿងនេះកើតឡើងកាលពីសែសិបឆ្នាំមុន នៅឯសមុទ្រដ៏មហាធំជាងគេនៅអឺរ៉ុប *ម៉ារីកូ - សាន* ។ សមុទ្រនោះឈ្មោះ *មេឌីទែរ៉ាណេ* ។ នោះគឺគ្រាន់តែជាការហ៊ុមព័ទ្ធមួយដូចជាការហ៊ុមព័ទ្ធឯទៀតៗដែរតែប៉ុននោះ ។ គ្មានអ្វីដែលគួរត្រូវនិយាយផងទេ ។

គេកុហក ។ ចំនេះដឹងនេះកាត់ថ្លៃមិនបានទេ ហើយក៏មិនត្រូវតែផ្សាយចេញងាយៗនោះដែរ ពិសេសនៅក្នុងពេលនេះរឹតតែដាច់ខាតតែម្តង ។ *ម៉ារីកូ* បាននិយាយពន្យល់គេជាច្រើនលើកច្រើនសាមកហើយថា វិមាន *អូសាកា* ស្ថិតនៅយ៉ាងណែនប៉ែសចន្លោះ *តូរ៉ាណាកា* នឹងជ័យជំនះតែម្តង ។ គេជឿជាក់នៅក្នុងចិត្តថា ដំណោះស្រាយវិមាន *អូសាកា* គឺជាលិខិតឆ្លងដែនអាចអោយគេចាកចេញពីចក្រភពនេះជាមួយនឹងមហាទ្រព្យទាំងប៉ុន្មាន ដែលគេត្រូវការមួយជីវិតនេះបាន ។

គេកត់សំគាល់ថា *ម៉ារីកូ* ហាក់មានកង្វល់អ្វីមួយ ៖

- អ្នកស្រី ?

- អត់មានអ្វីទេលោក ។

រួចនាងក៏ចាប់ផ្តើមបកនូវអ្វីដែលគេនិយាយ តែគេយល់ថា *ម៉ារីកូ* ដឹងថា គេលាក់



www.budinst.gov.kh www.elibraryofcambodia.org

អ្វីមួយដែលមិនបញ្ចេញ ។ ក្លិនសាច់ខបានធ្វើអោយអារម្មណ៍របស់គេរវាតមួយភ្លែតទៅដែរ ។

- *ភូជីកូ !*

- *បៃ អាន់ជីន - សាន ?*

- *សូតូជី វ៉ា ម៉ាដាកា ? គីយ៉ាតូ វ៉ា.... សាសូតូកូតូ រេ អូរ៉ូ នេ ?* - តើមានអ្វីសំរាប់បាយល្ងាច ? ភ្ញៀវប្រហែលឃ្លានហើយ ។

- អ្ហា ! *កូមេនណាសៃ ហ៊ីកាតូរេតេនកាក៏ ទី អ៊ីតាស៊ីម៉ាស៊ី* ។

*ប្លាក់ថន* ឃើញនាងចង្អុលទៅព្រះអាទិត្យ គេកាត់យល់ថា នាងនិយាយ " ក្រោយព្រះអាទិត្យលិច " តេងក់ក្បាល ហើយគ្រហឹមបន្តិច ដែលចំពោះជនជាតិជប៉ុនគេចាត់ទុកជាបាននិយាយយ៉ាងគួរសមថា : " អរគុណ ។ ខ្ញុំយល់ហើយ " អ៊ីចឹងដែរ ។

*ម៉ារីកូ* ងាកមករកគេម្តងទៀត :

- លោកប្តីខ្ញុំចង់អោយលោកនិទានពីការប្រយុទ្ធដែលលោកធ្លាប់ចូលរួម ។

- ទាំងអស់នោះមានកត់ទុកក្នុងក្បួនសង្គ្រាមហើយតើ *ម៉ារីកូ - សាន* ។

- គាត់មានប្រសាសន៍ថា គាត់បានអានក្បួននោះដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំង តែក្បួននោះមានចំនុចលំអិតខ្លះៗ តែប៉ុណ្ណោះ ។ ប៉ុន្មានថ្ងៃខាងមុខនេះគាត់មានបំនងចង់រៀនសូត្រលើគ្រប់ចំនុចនៃការប្រយុទ្ធរបស់លោកទាំងអស់ ។ ក្នុងពេលនេះ បើលោកមិនប្រកាន់ទេ សូមលោកនិទានវគ្គមួយអោយស្តាប់ផងចុះ ។

- អ្វីៗមាននៅក្នុងក្បួនអស់ហើយ ។ រឺមួយចាំស្អែកទៅ *ម៉ារីកូ - សាន* ។

ចំពោះ *ប្លាក់ថន* នៅពេលនេះ គឺគេចង់មានពេលវេលាដើម្បីពិនិត្យពិចារណាលើគំនិតដ៏អស្ចារ្យរបស់គេស្តីពីវិមាន *អូសាកា* ហើយនឹងការប្រយុទ្ធនេះ ។ ម្យ៉ាងទៀតគេក៏មានការហត់នឿយនឹងការនិយាយព្រោកប្រាជ្ញ ហត់នឿយនឹងសំនួរដេញដោលហើយលើសពីនេះទៅទៀត គេក៏ឃ្លានណាស់ហើយផង ។

- *អាន់ជីន - សាន* សូមលោកនិទានរឿងនេះម្តងទៀតទៅ ។ ខ្ញុំសូមអង្វរលោកសូមតែម្តងទៀតសំរាប់ប្តីខ្ញុំ ។



www.budinst.gov.kh www.elibraryofcambodia.org

សំលេងអង្វរករដ៏ប្រុងប្រយ័ត្នរបស់ *ម៉ារីកូ* បានពញ្ញាក់ស្មារតីរបស់ *ប្លាក់ថន* អោយប្រែគំនិតឡើងវិញ :

- អីចឹងក៏បាន ។ តាមនាង តើគាត់ចូលចិត្តរឿងប្រយុទ្ធណាមួយ ?

- រឿងដែលកើតឡើងនៅហ្វូឡង់ ។

*ប្លាក់ថន* ក៏ចាប់ផ្តើមនិយាយពីការប្រយុទ្ធរបស់គេ ដែលជាការប្រយុទ្ធមួយដូចស្ទើរតែរាល់ការប្រយុទ្ធឯទៀតៗដែរ ដែលមនុស្សបានស្លាប់បាត់បង់ជីវិតភាគច្រើនបណ្តាលមកពីការភាន់ច្រលំ និងអំពើល្ងីល្ងើរបស់ពួកនាយទាហានដែលទទួលបញ្ជាទ័ពនោះឯង ។

- លោកប្តីខ្ញុំមានប្រសាសន៍ថា មិនមែនដូចនៅទីនេះទេ *អាន់ជីន - សាន* ។ នៅទីនេះ នាយទាហានដែលបញ្ជាទ័ពត្រូវតែល្អណាស់ បើមិនយ៉ាងដូច្នោះទេ អ្នកនោះត្រូវស្លាប់យ៉ាងរហ័សជាទីបំផុត ។

- ពិតមែនហើយ ការរិះគន់របស់ខ្ញុំ គឺចំពោះតែពួកមេដឹកនាំអឺរ៉ុបតែប៉ុននោះ ។

- *ប៊ុនតារ៉ូ - សាម៉ា* មានប្រសាសន៍ថា ក្នុងប៉ុន្មានថ្ងៃខាងមុខនេះ លោកនឹងនិទានជូនលោកពីសង្គ្រាមរបស់ពួកយើង ហើយនឹងអំពីមេដឹកនាំទាំងឡាយរបស់ពួកយើង ពិសេសអំពីលោកម្ចាស់ *តែកូ* ។ នេះជាការផ្លាស់ប្តូរគ្នាដោយយុត្តិធម៌ជាមួយនឹងពត៌មានដែលលោកបានផ្តល់អោយ ។

- *ដូម៉ូ* ។

*ប្លាក់ថន* លំអោនខ្លួនបន្តិចដើម្បីគោរព ។ គេមានអារម្មណ៍ដឹងថា ក្រសែភ្នែករបស់ *ប៊ុនតារ៉ូ* ហាក់ចាក់ឆ្មៀលទៅក្នុងខ្លួនគេតែម្តង ។

តើអ្នែងចង់បានអីអំពីអញ អាកូនមីចោលម្រាយ ?

☆ ☆ ☆

ការទទួលអាហារពេលល្ងាចចំជាចោលលុយតែម្តង ។

មុនពេលដែលគេចាកចេញពីសួនច្បារសំដៅទៅរានហាលដើម្បីទទួលទានអាហារម្ល៉េះប្រផ្នូលមិនល្អបានលេចចេញមកជាស្រេច ។



www.budinst.gov.kh www.elibraryofcambodia.org

- សូមទោស *អាន់ជីន - សាន* តើនោះជាស្អីទៅ - *ម៉ារីកូ* លើកដៃចង្អុល - នៅទីនោះ ។ លោកប្តីខ្ញុំគាត់សួរថាស្អីហ្នឹង ?

- នៅឯណា ? អូហ៍ អាណុងអ្វី ? ណុងគឺជាមាន់ទោ -*ភូក់ជីន* តប - លោកម្ចាស់ *តូរ៉ាណាកា* បញ្ជូនវាមកអោយខ្ញុំជាមួយនឹងទន្សាយមួយក្បាលទៀតផង ។ ពួកយើងរៀបចំវាដើម្បីធ្វើម្ហូបទទួលទានល្ងាចនេះឯង ។ ម្ហូបស្អីលអង់គ្លេស.... រីខ្ញុំញ៉ាំបាយម្ហូបនេះតែម្នាក់ឯងទេមើលទៅ តែទោះជាយ៉ាងណាក៏មានល្មមគ្រប់គ្រាន់សំរាប់គ្រប់គ្នាដែរ ។

- សូមអរគុណលោក តែ.....ពួកយើង គឺលោកប្តីខ្ញុំនិងខ្ញុំមិនទទួលទានសាច់ទេ ។ តែម៉េចក៏ចាំបាច់ព្យួរមាន់ទោនេះនៅកន្លែងណុង ។ អាកាសធាតុក្តៅអីចឹង ម៉េចមិនយកវាធ្វើអីទៅ ?

- នេះជារបៀបធ្វើមាន់ទោ ។ ព្យួរអីចឹងគឺដើម្បីភ្ញាំសាច់វាណាំ ។

- ថាម៉េច ? ធ្វើបែបហ្នឹង ? សូមទោស *អាន់ជីន - សាន* -នាងនិយាយទាំងរំចល់ - សូមទោស ។ តែធ្វើបែបនេះនាំតែធ្វើអោយមាន់កាន់តែឆាប់រលួយស្អុយថែមទៀតទេ ។ មាន់នេះនៅមិនទាន់បោចរោម ហើយមិនទាន់សំអាតពោះពុងនៅឡើយផង ។

- សាច់មាន់ទោស្ងួតណាស់ *ម៉ារីកូ - សាន* ។ អីចឹងហើយទើបគេត្រូវព្យួរសំងិលវាច្រើនថ្ងៃ ជួនកាលច្រើនអាទិត្យទៅតាមអាកាសធាតុ ។ បន្ទាប់មកទើបគេបោចរោមវះសំអាតវា ហើយចំអិនវាទៅ ។

- លោក..... លោកសំងិលវាចោល ? ទុកអោយរលួយ ? ដូច.... ដូច.....

- *ណាន់ថា ?*

*ប៊ុនតារ៉ូ* សួរយ៉ាងធុញទ្រាន់ ។ នាងនិយាយប្រាប់ទៅ *ប៊ុនតារ៉ូ* ១ អត់ដង្ហើមហើយដើបដើរទៅសំលឹងមើលមាន់ទោ ព្រមទាំងយកដៃទៅចុចមើលប្រហើ ១ថែមទៀត ។ រុយជាច្រើនហើរចេញម្ហូង រួចត្រលប់មកទំវិញដដែល ។ ទាំងញញើតញញើម *ភូជីកូ* និយាយទៅកាន់ *ប៊ុនតារ៉ូ* ធ្វើអោយ *ប៊ុនតារ៉ូ* មានមុខឡើងក្រហម ។ *ម៉ារីកូ* សួរឡើង :

- កំនាន់លោកបាននិយាយថា លោកបានហាមឃាត់មិនអោយអ្នកណាប៉ះមាន់នេះ



www.budinst.gov.kh www.elibraryofcambodia.org

ទេ ក្រៅតែពីរូបលោកចេញ ?

- ពិតមែន ។ ក្រែងពួកនាងមិនព្យូរសត្វព្រៃទេអ្វី ? ទាំងអស់គ្នាមិនមែនសុទ្ធតែកាន់ពុទ្ធសាសនាឯណាអ្វី ?

- អត់ទេ *អាន់ជីន - សាន* នេះបើតាមការគិតរបស់ខ្ញុំ ។

- មានអ្នកខ្លះគេយល់ថា ត្រូវព្យូរមាន់ទោតាមកន្ទុយរហូតដល់ពេលណាដែលវារបូតកន្ទុយធ្លាក់ តែអានេះគ្រាន់តែជាជំនឿតៗគ្នាប៉ុននឹងឯង ។ តាមក្បួនវាត្រឹមត្រូវគេត្រូវព្យូរក នោះទើបជាតិវាប៉ុន្មាននៅតាមកន្លែងដើមរបស់វា ។ អ្នកខ្លះទៀតព្យួរទាល់តែដាច់ករបូតធ្លាក់ តែខ្ញុំវិញខ្ញុំមិនចូលចិត្តរបៀបហ្នឹងទេ ព្រោះសាច់វាបាក់ហួស ។ យើងច្រើនតែ .....

*ប្លាក់ថន* ឈប់កណ្ដាលទី ដោយឃើញ *ម៉ារីកូ* មានមុខឡើងខៀវ ។ *កូជីកូ* សួរភ្លាម :

- *ណានគេស៊ី កា ម៉ារីកូ - សាន ?*

*ម៉ារីកូ* និយាយពន្យល់ ហើយទាំងអស់គ្នាក៏នាំគ្នាសើចទាំងរសាប់រសល់ ។ រួច *ម៉ារីកូ* ក៏ក្រោកឡើង ហើយវាសដៃជូតញើសដែលនៅលើថ្ងាសរបស់នាងចេញ :

- សូមទោសណា *អាន់ជីន - សាន* ។ សូមទោសមួយភ្លែត .....

ម្ហូបពួកនាងក៏ចំលែកណាស់ដែរ - *ប្លាក់ថន* ចង់និយាយចេញនូវគំនិតរបស់គេ ។ រួចស៊ីពីម្សិលមិញនោះ ។ មីកឆៅសស្លែត អត់ជាតិអត់ចូវ ដូចកៅស៊ូគ្មានលាយជាមួយស៊ីទាំងអស់ ក្រៅតែជាមួយទឹកស៊ីអ៊ីវគ្រាន់គ្រលៀសលេបនោះអ្វី ? រឺក៏ប្រមោយមីកឆៅជាមួយបាយត្រជាក់ និងសារាយ ? រួចចុះអាពពុះទឹកសមុទ្រស្រស់នឹងសំលតៅហ៊ូមើលទៅដូចកំអួតឆ្កែនោះ ? ពិតមែនតែសំលតៅហ៊ូនោះដាក់ក្នុងចានចង្កឹះដ៏ស្អាតគួរអោយគយគន់យ៉ាងណាក្ដីក៏នៅតែដូចកំអួតឆ្កែដដែលហ្នឹង ! ដូចមែនទែន គ្រាន់តែឃើញចង់ឈឺមុខបាត់ទៅហើយ ។

នៅទីបំផុត ពួកគេបានមកដល់បន្ទប់រានបាល ហើយបន្ទាប់ពីការលំអោនគោរពនិងនិយាយពីនេះពីនោះមិនចេះចប់នោះមក ម្ហូបត្រូវបានគេចាប់ផ្ដើមលើកចេញមក ។

ដូចរាល់សព្វដងដែរ គឺជាថាសតូចៗ ដែលនៅលើនោះមានសំលត្រី មានបាយ និង



www.budinst.gov.kh www.elibraryofcambodia.org

ត្រីឆៅ ។ ហើយបន្ទាប់មកគឺម្ហូបខរបស់ *ប្លាក់ថន* ។

តេបើកគំរបថូ ។ ចំហាយផុសចេញខ្មៅលឡើង ។ ខ្លាញ់នៅពុះគគ្រុកលើផ្ទៃម្ហូបនៅឡើយ ។ សំលពេញដោយសាច់ដ៏ផុយ និងមើលទៅគួរអោយស្រក់ទឹកមាត់ ។ *ប្លាក់ថន* ដួសសំល ហើយហុចទៅអោយអ្នកផងទាំងពួងទាំងពោរពេញដោយមោទនភាពតែទាំងអស់គ្នាបានប្រកែក ហើយអង្វរអោយ *ប្លាក់ថន* ទទួលទានម្នាក់ឯងចុះ ។

- *ដូម៉ូ* - គេឆ្លើយតប ។

សុជីវធម៌នៅទីនេះ គឺហុតសំលពីក្នុងកូនចានខ្ទុកម្រ័ក្យ ហើយប្រើចង្កឹះចាប់យករបស់រឹងនៅក្នុងសំលទៅវិញ ។ វ៉ែកមួយត្រូវបានគេដាក់នៅលើថាស ។ ដោយទ្រាំទ្រនឹងតំណានរបស់ខ្លួនលែងបានទៅទៀតហើយនោះ *ប្លាក់ថន* ដួសខចេញមួយចាន ហើយចាប់ផ្តើមពន្លះតែម្តង ។ រួចទើបគេប្រទះឃើញភ្នែករបស់អ្នកឯទៀត ។

នោះគឺអ្នកទាំងអស់សំលឹងមើល *ប្លាក់ថន* ទាំងក្នុងភាពភាន់ភាំង និងចំអើមមួយដែលពួកគេមិនអាចលាក់ជិតបាន ។ *ប្លាក់ថន* បាត់ការឃ្លានអស់រលីង ។ គេប្រឹងមិនរវល់នឹងអ្នកទាំងនោះដែរ តែគេទៅមិនរួចសោះ ។ ទោះជាពោះគេកញ្ជ្រោកយ៉ាងណាក្តី ក៏គេខំបិទបាំងភាពមួម៉ៅរបស់គេ ហើយដាក់ចានចុះនិងបិទគំរបថូទៅវិញ ដោយនិយាយទាំងមូម៉ងប្រាប់អ្នកឯទៀតថា ម្ហូបមិនត្រូវមាត់របស់គេឡើយ ។ បន្ទាប់មកគេបញ្ជាអោយ *នីកាគស៊ុ* លើកម្ហូបចេញទៅវិញ ។

*ម៉ារីកូ* សួរទាំងក្នុងចិត្តសង្ស័យ ៖

- *ភូជីកូ* សួរថា បើអ៊ីចឹងចាក់វាចោលទៅអ្ហី ?

- ណឹងហើយ ។

ទាំង *ភូជីកូ* ទាំង *ប៊ុនតារ៉ូ* ធូរទ្រូងខ្យាក ។ *ភូជីកូ* សួរ ៖

- តើលោកត្រូវការថែមបាយទៀតទេ ?

- ទេ ។ សូមអរគុណហើយ ។

*ម៉ារីកូ* បក់ផ្លិតទាំងទឹកមុខញញឹមលើកទឹកចិត្ត ព្រមទាំងចាក់ស្រាសាកេបំពេញពែង



www.budinst.gov.kh www.elibraryofcambodia.org

របស់គេផង ។ តែ *ភ្លាក់ផន* មិនបានត្រជាក់ចិត្តបន្តិចណាឡើយ គេសំរេចថាទៅលើកក្រោយទៀតគេនឹងទៅធ្វើម្ហូបតែម្នាក់ឯងនៅឯលើកូនភ្នំ ដើម្បីហូបតែម្នាក់ឯង និងដើម្បីចេញបរបាញ់ជាចំហតែម្តង ។

ពួកអស់នេះកុំមករញ៉េរញ៉ៃ - គេគិតនៅក្នុងចិត្ត ។ *តូរ៉ាណាកា* បរបាញ់បាន ម៉េចក៏អញបរបាញ់មិនបាន ។ តើអង្កាល់ទើបអញបានជួបគាត់ទៀត ? តើអញត្រូវរង់ចាំប៉ុន្មានពេលទៀត ?

- រំបល់យក់រឿងចាំ ហើយ រំបល់យក់ *តូរ៉ាណាកា* ផងដែរ !

គេប្រទេចជាភាសាអង់គ្លេស ហើយក៏បានធូរទ្រូងជាងមុនសន្ធឹកទៅដែរ ។

*ម៉ារីកូ* ក៏សួរជាប៊កទុយកាល់ :

- ថាម៉េច *អាន់ជីន - សាន ?*

- អត់មានថាម៉េចទេ - គេតប -ខ្ញុំគ្រាន់តែគិតថាអង្កាល់ទើបបានជួបលោកម្ចាស់ *តូរ៉ាណាកា ?*

- គាត់អត់បានប្រាប់ខ្ញុំផង តែបើតាមខ្ញុំគិតប្រហែលជាឆាប់ៗនេះហើយ ។

*ប៊ុនតារ៉ូ* កំពុងតែហុតសាកេ និងសំលរបស់ខ្លួនលឺគ្រូកៗ ដែលជាទំលាប់របស់ជនជាតិគេ ។ ទាំងនេះបានចាប់ផ្តើមនាំអោយ *ភ្លាក់ផន* មានការធុញទ្រាន់យ៉ាងខ្លាំង ។ *ម៉ារីកូ* និយាយយ៉ាងរីករាយជាមួយនឹងប្តីរបស់ខ្លួន ដែលគ្រាន់តែគ្រហឹមតបបាក់ដូចមិនមានរូបនាងនៅទីនោះអីចឹង ។

នាងមិនទទួលទានម្ហូបម្ហារអ្វីទាំងអស់ ហើយគេរឹតតែរង្កៀសចិត្តណាស់ទៅទៀត នៅពេលគេឃើញទាំង *ម៉ារីកូ* ទាំង *ភូជីកូ* ខិតខំយកចិត្តយកថ្លើម *ប៊ុនតារ៉ូ* ចំនែកឯរូបគេទៀតក៏ត្រូវ ប្រឹងគួរសមជាមួយនឹងភ្ញៀវជូរនេះដែរ ។ គេលើកពែងស្រារបស់គេជាមួយនឹងការញញឹមដ៏គោកមួយ :

- ជំរាបទៅ *ប៊ុនតារ៉ូ - សាម៉ា* ថា នៅក្នុងប្រទេសខ្ញុំ ម្ចាស់ផ្ទះលើកស្រាជូនពរភ្ញៀវកិត្តិយសរបស់ខ្លួន ។ សូមមានអាយុយឺនយូរ និងសូមប្រកបដោយសុភមង្គល ។



www.budinst.gov.kh www.elibraryofcambodia.org

រួចគេក៏ក្រេបស្រាអស់ភ្លាម ។ *ប៊ុនតារ៉ូ* ស្តាប់ការពន្យល់របស់ *ម៉ារីកូ* ហើយងក់ក្បាលជាកិច្ចយល់ស្របតាម រួចក៏លើកពែងរបស់ខ្លួនតបវិញទាំងញញឹម ហើយក្រេបស្រាអស់ភ្លាម ។ *ធ្លាក់ថន* ជូនពរម្តងទៀត :

- សុខភាព !

រួចម្តងទៀត ។

រួចម្តងទៀត ។

- សុខភាព !

លើកនេះ *ប៊ុនតារ៉ូ* ឥតផឹកទេ ។ លោកដាក់ពែងចុះ ហើយភ្នែកតូច១របស់លោកសំលឹងមើល *ធ្លាក់ថន* ជាប់ ។ បន្ទាប់មកលោកហៅអ្នកណាម្នាក់ដែលនៅឯខាងក្រៅ ។ ទ្វារត្រូវរុញទៅម្ខាង ហើយអង្គរក្សរបស់ *ប៊ុនតារ៉ូ* បានចូលមកលំអោនខ្លួនគោរព រួចហុចធ្នូដ៏ធំមួយជាមួយនឹងព្រួញមួយបំពង់ ។ *ប៊ុនតារ៉ូ* ទទួលយកមកកាន់ ហើយនិយាយយ៉ាងក្បៀវក្លានិងយ៉ាងញាប់ទៅកាន់ *ធ្លាក់ថន* :

- លោកប្តីខ្ញុំ ..... លោកប្តីខ្ញុំថា លោកចង់ឃើញគាត់បាញ់ធ្នូ *អាន់ជិន - សាន* ។ គាត់គិតថា ថ្ងៃស្អែកយូរណាស់ ។ ពេលនេះចំជាពេលល្អ ។ គាត់សូមអោយលោករើសទៅមើលថា តើបង្គោលទ្វាររបងផ្ទះរបស់លោកមួយណា ?

- ខ្ញុំមិនយល់ទេ ។

*ធ្លាក់ថន* តប ។ ទ្វាររបងផ្ទះនៅឯនាយសួនច្បារក្នុងចំងាយប្រហែលសែសិបជំហានតែទ្វារមួយនៅខាងស្តាំដៃគេបានបិទបាំងមិនអោយទាំងអស់គ្នាអាចមើលវាឃើញឡើយ ។

- បង្គោលឆ្វេង រឺស្តាំ ? សូមលោកជ្រើសរើសយកមួយណាទៅ ។

អាកប្បកិរិយារបស់ *ម៉ារីកូ* ហាក់ដូចជាបន្ទាន់មែនទែនតែម្តង ។ ដោយប្រុងប្រយ័ត្នគេសំលឹងមើលទៅ *ប៊ុនតារ៉ូ* ។ បុរសនេះនៅព្រងើយ មិនរវីរវល់នឹងអ្នកណាទាំងអស់ មើល១ទៅមិនខុសអ្វីពីម្រេញគង្វាលដ៏អាក្រក់មួយដែលកំពុងអង្គុយច្រងុក១នោះទេ ។ គេពោលទាំងអារម្មណ៍ភ្ញាក់ភ្លឹង :



www.budinst.gov.kh www.elibraryofcambodia.org

- ចេង !

- *ហ៊ីងារី !*

*ម៉ារីកូ* ពោលឡើង ។ វេលាពេលនោះ *ប៊ុនតារ៉ូ* ហូតព្រួញមួយពីក្នុងបំពង់ ហើយដោយនៅរក្សាបង្អុយរបស់ខ្លួនដដែលនោះ ក៏ផ្ទាប់ព្រួញលើកធ្នូឡើងយឹតខ្សែត្រឹមត្រចៀករបស់ខ្លួន ហើយព្រលែងខ្សែយ៉ាងសាហាវតែម្តង ។ ផ្លែព្រួញជ្រែកខ្យល់ឆិតមុខរបស់ *ម៉ារីកូ* កាត់តាមសរសៃរសក់របស់នាង ហើយទំលុះក្រដាសដែលពាសទ្វារទៅបាត់ឈឹង ។ ព្រួញទីមួយស្ទើរតែមិនទាន់បាត់ស្រមោលផង ព្រួញទីពីរក៏ត្រូវបានបង្ហើរចេញទៅភ្លាមដែរ ហើយបន្ទាប់មកព្រួញទីបី ។ ផ្លែព្រួញនីមួយៗហោះឃ្លាតពីមុខ *ម៉ារីកូ* ប្រហែលមួយស្លឹកស្រូវប៉ុណ្ណោះ ។ ក្នុងពេលនេះ *ម៉ារីកូ* នៅអង្គុយលុតជង្គង់យ៉ាងស្ងៀមស្ងាត់ឥតកំរើកហាក់ដូចជាធម្មតា ។

ព្រួញទីបួនត្រូវបានព្រលែងចេញ ហើយបន្ទាប់មកព្រួញចុងក្រោយ ។ ភាពស្ងប់ស្ងាត់ត្រូវបានបំពេញដោយសូរខ្ទ័រនៃខ្សែធ្នូ ។ *ប៊ុនតារ៉ូ* បន្ធូរដង្ហើម ហើយហាក់ដូចមានវិញ្ញាណបន្តិចម្តងៗឡើងវិញ ។ លោកដាក់ធ្នូនៅទទឹងភ្លៅរបស់ខ្លួន *ម៉ារីកូ* និង *ភូជីកូ* ប្រឹងដកដង្ហើមអោយបានជាធម្មតាវិញ ហើយញញឹមលំអោនខ្លួនគោរព និងពោលសរសើរ *ប៊ុនតារ៉ូៗ* ងក់ក្បាល និងលំអោនខ្លួនបន្តិចតបវិញផងដែរ ។ ទាំងអស់គ្នាសំលឹងមើល *ប្លាក់ថន* ។ គេបានដឹងច្បាស់ណាស់ទៅហើយថា អ្វីដែលគេទើបបានឃើញអំបាញ់មិននេះ គឺសឹងតែជាវេទមន្តតែម្តង ។ ព្រួញទាំងអស់បានរត់ចេញតាមប្រហោះតែមួយគត់ ។

*ប៊ុនតារ៉ូ* ប្រគល់ធ្នូទៅអោយអង្គរក្សរបស់ខ្លួន រួចទើបយកកូនពែងរបស់ខ្លួនឡើង ។ លោកសំលឹងមើលពែងមួយសន្ទុះ រួចទើបលើកឡើងចំពោះមុខ *ប្លាក់ថន* បន្ទាប់មកលោកក្រេបផឹកអស់ភ្លាម ។ ហើយលោកក៏ចាប់ផ្តើមនិយាយម៉ាត់ៗ បង្ហាញឡើងវិញនូវចរិតឃោរឃៅដ៏សាហាវរបស់ខ្លួនដដែល ។

- គាត់ .... លោកប្តីខ្ញុំសូមអញ្ជើញលោកទៅពិនិត្យមើលចុះ ។

*ប្លាក់ថន* សញ្ជឹងគិតមួយសន្ទុះ ទន្ទឹមនឹងខិតខំសំរួលបេះដូងរបស់គេអោយបានដើរជាប្រក្រតីវិញផង :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំគិតថាមិនបាច់ទេ ។ គាត់ច្បាស់ជាបាញ់ត្រូវគោលដៅហើយ ។

- គាត់មានប្រសាសន៍ថា ចង់អោយលោកឃើញជាក់តែម្តង ។

- ខ្ញុំជាក់ហើយ ។

- សូមអធ្យាស្រ័យផងទៅចុះ *អាន់ជីន - សាន* ។ ផ្តល់កិត្តិយសដល់គាត់បន្តិចទៅ ។

- ខ្ញុំអត់ត្រូវការផ្តល់កិត្តិយសដល់គាត់ទេ ។

- ពិតមែនហើយ តែតើលោកអាចទទួលយកទាំងសំនូមពររបស់ខ្ញុំផងបានទេ ?

ជាថ្មីម្តងទៀត គេបានឃើញភាពអង្វរករជិតជាប់ក្នុងក្រសែភ្នែករបស់នាង ។

- តើពាក្យ : " ខ្ញុំបានឃើញនេះចំជាអស្ចារ្យមែន " និយាយជាជប៉ុនថាម៉េច ? "

នាងនិយាយប្រាប់ ។ គេក៏និយាយតាមនាង ហើយលំអោនខ្លួនគោរព ។ *ប៊ុនតារ៉ូ* លំអោនខ្លួនតបវិញយ៉ាងលំ១ ។

- ប្រាប់គាត់ថា សូមគាត់ទៅមើលព្រួញជាមួយខ្ញុំ ។

- គាត់មានប្រសាសន៍ថា សូមលោកអញ្ជើញទៅមើលតែម្នាក់ឯងចុះ ។ គាត់មិនចង់ទៅទេ *អាន់ជីន - សាន* ។

- ហេតុអីទៅ ?

- បើគាត់បាញ់ត្រង់ចំគោលដៅមែននោះ លោកអាចមើលឃើញដោយផ្ទាល់ភ្នែកលោក ។ បើសិនជាមិនចំគោលដៅវិញ ក៏លោកបានឃើញតែម្នាក់ឯងដែរ ។ ធ្វើយ៉ាងនេះទាំងលោក ទាំងគាត់មិនមានការរង្កៀសចិត្តផង ។

- ចុះបើគាត់បាញ់ខុស ?

- គាត់បាញ់មិនខុសទេ ។ ប៉ុន្តែតាមប្រពៃណីរបស់យើង បាញ់ត្រូវវឺមិនត្រង់ក្នុងកាលៈទេសៈដ៏លំបាកបែបនេះមិនសំខាន់ទេ បើគេប្រៀបទៅសោភ័ណដែលខ្មាន់ធ្នូបានបង្ហាញភាពថ្លៃថ្នូរនៃចលនា កំលាំងបាញ់ ហើយនឹងការផ្តាច់អារម្មណ៍ចេញផុតពីរឿងឈ្នះ រឿងចាញ់នោះ ។



www.budinst.gov.kh www.elibraryofcambodia.org

ផ្ទៃព្រួញដោតចំកណ្ដាលបង្គោលរបងខាងឆ្វេង ឃ្លាតតែមួយសង់ទីម៉ែតពីគ្នាតែប៉ុណ្ណោះ ។ *ប្លាក់ថន* ងាកសំលឹងមើលទៅផ្ទះដែលនៅប្រហែលសែសិបជំហានពីគេហើយ គេឃើញយ៉ាងច្បាស់នូវកូនប្រហោងក្រដាសពាសទ្វារដែលជះពន្លឺច្រាលក្នុងភាពអន្ធការ ។

ត្រង់យ៉ាងនេះពេក មិនអាចទៅរួច - គេគិតនៅក្នុងចិត្ត ។ ពីកន្លែងដែល *ប៊ុនតារ៉ូ* អង្គុយនោះ គេមិនអាចមើលឃើញសួនច្បារ រឺបង្គោលទ្វាររបងបានទេ ម្យ៉ាងទៀតខាងក្រៅងងឹតឈ្លប់ថែមទៀត ។ *ប្លាក់ថន* បែរខ្លួន ហើយលើកចង្កៀងឡើងខ្ពស់ដើម្បីពិនិត្យបង្គោលរបងទ្វារម្ដងទៀត ។ គេយកដៃម្ខាងទៅសាកល្បងដកព្រួញចេញពីសាច់ឈើ ប៉ុន្តែក្បាលព្រួញដែលធ្វើពីដែកថែបនោះបានកប់ជ្រៅពេក ។ គេអាចកាច់បំបាក់ដកព្រួញ ដែលធ្វើពីឈើនោះបានដែរ តែគេមិនមានបំណងបែបនេះទេ ។

ឆ្នាំម្នាក់នៅតាមសំលឹងមើល *ប្លាក់ថន* ជាប់ ។

ដោយឃើញ *ប្លាក់ថន* នៅរវើរវក្នុងចិត្តដូចនេះ ឆ្នាំនេះក៏ដើរមកដើម្បីជួយគេតែគេគ្រវីក្បាលដោយនិយាយថា : " *អ៊ីយេដូម៉ូ* " រួចក៏ដើរត្រលប់មកក្នុងផ្ទះវិញទៅ ។

- *ម៉ារីកូ - សាន* សូមប្រាប់ទៅកំនាន់របស់ខ្ញុំថា ខ្ញុំចង់ទុកព្រួញទាំងនេះនៅលើសសរខ្លោងទ្វាររបងជារៀងរហូត ។ ទុកព្រួញទាំងអស់ ។ នេះដើម្បីរំលឹកខ្ញុំពីគ្រូធ្នូ ។ ខ្ញុំមិនដែលឃើញការបាញ់ធ្នូរបៀបណឹងទេ ។

និយាយចប់ គេលំអោនខ្លួនគោរព *ប៊ុនតារ៉ូ*

- សូមអរគុណ *អាន់ជីន - សាន* ។

រួច *ម៉ារីកូ* ក៏បកទៅតាមសំដីរបស់ *ប្លាក់ថន* ។ *ប៊ុនតារ៉ូ* លំអោនខ្លួនតប ហើយអរគុណពាក្យសរសើររបស់គេ ។ *ប្លាក់ថន* ចេញបញ្ជា :

- សាកេ !

រួចគេក៏ទទួលទានស្រាទៀត ។ ទទួលទានហើយទទួលទានទៀត ។ *ប៊ុនតារ៉ូ* អកស្រាឥតបើគិត ហើយកាន់តែស្រវឹងបន្តិចម្ដងៗទៅហើយដែរ ។ *ប្លាក់ថន* លួចសំលឹងមើល *ប៊ុនតារ៉ូ* ហើយបណ្ដោយអោយអារម្មណ៍របស់គេអណ្ដែតវិលវល់លើចំងល់ដែលថា តើបុរសនេះ



www.budinst.gov.kh www.elibraryofcambodia.org

ធ្វើយ៉ាងម៉េចអាចបាញ់ព្រួញបានត្រង់យ៉ាងនេះ ។ មិនអាចទៅរួចទេ - គេគិតនៅក្នុងចិត្ត -តែអញបានឃើញដោយផ្ទាល់ភ្នែកតែម្តង ។ រួចអារម្មណ៍របស់គេដណ្តឹងសួរថា តើធ្វើរនេះ អាវិញ អា *ពាគួស* ហើយនិងពួកនារីកឯទៀតកំពុងធ្វើអីទៅហ្នំ ? *គួរ៉ាណាកា* បានប្រាប់គេថាពួកនារីកទាំងអស់ត្រូវបានរៀបចំអោយស្នាក់នៅឯយេដូ ក្បែរសំពៅអេរ៉ាស់ហើយ ។

ព្រះម្ចាស់អើយ អញចង់ជួបពួកវា និងចង់ដើរសំពៅវិញ ម្ល៉េះទេ ។

គេចោលភ្នែកសំលឹងមើលទៅ *ម៉ារីកូ* ដែលកំពុងជជែកជាមួយ *ប៊ុនតារ៉ូ* ។ មុនពេលដែលគេងាកភ្នែកចេញមកវិញនោះ *ប៊ុនតារ៉ូ* ក៏ងាកមកវាក់នឹងខ្សែភ្នែករបស់គេតែម្តង ។

- *ណានី គេ ស៊ូ កា ?*

សំលេង *ប៊ុនតារ៉ូ* ហាក់ដូចជាការចោទសួរមួយអ៊ីចឹង ។

- *ណានី ម៉ូ ប៊ុនតារ៉ូ - សាន* ។

គ្មានអ្វីទេ ។ *ប្លាក់ថន* ក៏ចាក់ស្រាដល់គ្រប់ៗគ្នា ដើម្បីបិទបាំងភាពអណ្តែតអណ្តូងរបស់គេអំបាញ់មិញ ។ នារីៗក៏ទទួលស្រាដែរ តែពួកនាងគ្រាន់ទទួលទានចិបៗតែប៉ុននោះ ។ *ប៊ុនតារ៉ូ* លើកពែងអកក្អឿកអស់ភ្លាម ។ អាកប្បកិរិយារបស់គេកាន់តែអាក្រក់ទៅៗ ។ បន្ទាប់មក លោកក៏និយាយបញ្ចុះបញ្ចូល *ម៉ារីកូ* យ៉ាងយូរ ។

*ប្លាក់ថន* ឆ្លោយមាត់សួរ :

- តើគាត់មានរឿងអីហ្នុង ? តើគាត់និយាយថាម៉េច ?

- ចាស សូមទោសផងទៅចុះ *អាន់ជីន - សាន* ។ លោកប្តីកំពុងសួរពីរឿងលោកប្រពន្ធលោក និងកំនាន់របស់លោក ។ ហើយលោកសួរពីរឿងកូនចៅរបស់លោក ពីហេតុការណ៍ផ្សេងៗក្រោយដែលយើងចាកចេញពី *អូសាកា* មក ។ គាត់....-នាងឈប់បន្តិច ដូរគំនិតហើយបន្តប្រយោគក្នុងសំលេងបែបផ្សេងទៅវិញ - គាត់យកចិត្តទុកដាក់លើរូបលោកនិងទស្សនៈរបស់លោក ។

- ខ្ញុំយកចិត្តទុកដាក់លើរូបគាត់ និងទស្សនៈរបស់គាត់ដែរ *ម៉ារីកូ - សាន* ។ តើយ៉ាងម៉េចបាននាងជួបគាត់ ? តើនាងរៀបការពីអង្កាល់ ? តើ....



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ុនតារ៉ូ* កាត់សំដី *ឆ្កាក់ថន* ដោយនិយាយភាសាជប៉ុនបែបតឿនតែម្តង ។ *ម៉ារីកូ* ក៏បកប្រែភ្លាមនូវអ្វីដែលបាននិយាយ ។ *ប៊ុនតារ៉ូ* ក៏ឈោងទៅចាក់ស្រាសាកេពីរពែងពេញខ្វាយ ហើយហុចមួយទៅ *ឆ្កាក់ថន* ព្រមទាំងបក់ដៃជាសញ្ញាអោយនារី១ញ៉ាំស្រារបស់ខ្លួនផង ។

- គាត់ ..... លោកប្តីខ្ញុំមានប្រសាសន៍ថា មានពេលខ្លះពែងសាកេដូចជាតូចដល់ហើយ ។

*ម៉ារីកូ* ចាក់ស្រាបំពេញពែង ។ នាងលើកពែងស្រាមួយយកមកចិប ហើយ *ភូជីកូ* ក៏យកមួយពែងដែរ ។ សំដី *ប៊ុនតារ៉ូ* លាន់លឺយ៉ាងរករឿងថែមទៀត ធ្វើអោយស្នាមញញឹមរបស់ *ម៉ារីកូ* នៅតាំងលើផ្ទៃមុខរបស់នាង ។ *ភូជីកូ* ក៏យ៉ាងដូច្នេះដែរ ។ *ម៉ារីកូ* ចាប់ផ្តើមនិយាយ :

- *អ៊ីយេ ដូស្វូ កូមេនណាសៃ ប៊ុនតារ៉ូ - សាម៉ា* ។

- *អ៊ីម៉ា !*

*ប៊ុនតារ៉ូ* ចេញបញ្ជា ។ ទាំងរសាប់រសល់ *ភូជីកូ* ចាប់ផ្តើមនិយាយ តែក្រសែភ្នែក *ប៊ុនតារ៉ូ* បានបិទមាត់នាងភ្លាម ។ នាងនិយាយសូមទោសខ្សាវ១ :

- *កូមេនណាសៃ ។ ដូស្វូ កូមេនណាសៃ ។*

- តើគាត់និយាយថាម៉េច *ម៉ារីកូ -សាន ?*

*ម៉ារីកូ* ហាក់មិនលឺសំនួររបស់ *ឆ្កាក់ថន* ឡើយ :

- *ដូស្វូ កូមេនណាសៃ ប៊ុនតារ៉ូ - សាម៉ា ។ វ៉ាតាស៊ី......*

មុខរបស់ *ប៊ុនតារ៉ូ* ឡើងក្រហមងាំង :

- *អ៊ីម៉ា !*

- សូមទោស *អាន់ជីន - សាន* តែលោកប្តីខ្ញុំបញ្ជាអោយខ្ញុំជំរាប ..... អោយឆ្លើយនឹងសំនួររបស់លោក...... អោយខ្ញុំនិយាយពីរឿងខ្ញុំជូនលោក ។ ខ្ញុំជំរាបទៅគាត់ថា ខ្ញុំយល់ថារឿងគ្រួសារមិនគួរលើកមកនិយាយនៅពេលយប់ជ្រៅអ៊ីចឹងទេ តែគាត់បញ្ជាថា ត្រូវតែ



www.budinst.gov.kh www.elibraryofcambodia.org

និយាយ ។ សូមលោកអត់ធ្មត់បន្តិចសិនចាស ។

នាងក្រេបស្រាសាកេមួយក្រេបយ៉ាងវែង ។ រួចមួយក្រេបទៀត ។ សក់ដែលធ្លាក់ក្បែរត្រចៀករបស់នាងផាយផាត់តាមជំនោរខ្យល់ថ្មីតរបស់ *ភូជីកូ* ។ ទីបំផុតនាងក្រេបស្រាបង្ហើយរួចដាក់ពែងចុះ :

- ឈ្មោះក្រមុំរបស់ខ្ញុំ គឺ *អាកេស៊ី* ។ ខ្ញុំជាកូនស្រីរបស់មេទ័ពឃាតក *អាកេស៊ី ជីនសៃ* ។ ឪពុកខ្ញុំបានលួចធ្វើឃាតលោកម្ចាស់របស់គាត់ គឺមេផ្កាច់ការ *ក្លូដា* ។

- ឱ ព្រះជាម្ចាស់អើយ ! ម៉េចបានជាគាត់ធ្វើអីចឹង ?

- ទោះជាដោយមូលហេតុអ្វីក៏ដោយ ក៏មិនគ្រប់គ្រាន់ដែរ *អាន់ជីន - សាន* ។ ឪពុករបស់ខ្ញុំបានប្រព្រឹត្តអំពើដ៏អាក្រក់ជួជាតិបំផុតនៅក្នុងលោកយើងនេះ។ ឈាមរបស់ខ្ញុំត្រូវប្រលាក់ប្រលូស ក៏ដូចជាឈាមរបស់កូនប្រុសខ្ញុំដែរ ។

- បើអីចឹង ហេតុអីក៏ ....-*ធ្លាក់ថន* ឈប់និយាយតទៅទៀត ។

- យ៉ាងម៉េច *អាន់ជីន - សាន ?*

- ខ្ញុំហៀបនិយាយថា ខ្ញុំយល់បានថា តើការសំលាប់លោកម្ចាស់ឯងមានន័យយ៉ាងម៉េចនោះ ។ ខ្ញុំឆ្ងល់នឹងប្រការដែលគេទុកនាងអោយនៅរស់រានមានជីវិតទៀត ។

- លោកប្ដីខ្ញុំបានផ្ដល់កិត្តិយសដល់ខ្ញុំ.......

*ប៊ុនតារ៉ូ* កាត់សំដីនាងយ៉ាងគគ្រើន ។ *ម៉ារីកូ* សូមទោសប្ដី ហើយពន្យល់ពីអ្វីដែល *ធ្លាក់ថន* បាននិយាយ ។ *ប៊ុនតារ៉ូ* ក៏បក់ដៃទាំងប្រមាថអោយនាងនិយាយបន្ត :

-លោកប្ដីខ្ញុំបានផ្ដល់កិត្តិយសដល់ខ្ញុំដោយបំបរបង់នាងខ្ញុំ ។ ខ្ញុំបានអង្វរគាត់ដើម្បីធ្វើ *សិបពុគួ* តែគាត់មិនព្រមផ្ដល់បុព្វសិទ្ធិនេះសោះ ។ ខ្ញុំតែងតែទទូចសុំគាត់ជារៀងរាល់ឆ្នាំពោលគឺនៅរាល់ខួបនៃអំពើក្បត់នេះ ។ តែលោកប្ដីខ្ញុំគាត់តែងតែប្រកែកសំនូមពររបស់ខ្ញុំជានិច្ច -ស្នាមញញឹមរបស់ *ម៉ារីកូ* គួរអោយស្រលាញ់ - ប្ដីខ្ញុំបានផ្ដល់កិត្តិយសជារៀងរាល់ថ្ងៃរៀងរាល់វេលាដល់រូបខ្ញុំ *អាន់ជីន - សាន* ។ បើខ្ញុំជាគាត់វិញ ខ្ញុំពិតជាមិនអាចនិយាយរកមនុស្សគំរក់បែបនេះបានទេ ។ ខ្ញុំ *អាកេស៊ី ម៉ារីកូ* ត្រូវគេទុកអោយរស់រានមានជីវិតដោយ



www.budinst.gov.kh www.elibraryofcambodia.org

ខ្ញុំមានប្ដី ហេតុនេះខ្ញុំជាមនុស្សនៅក្នុងគ្រួសាររបស់លោកប្ដីខ្ញុំ ។ កាលនោះយើងរស់នៅឯក្យូតូ ។ ពេលឪពុកខ្ញុំស្លាប់ ខ្ញុំនៅឯក្យូតូ ។ ការក្បត់និងការបះបោររបស់ឪពុកខ្ញុំមានរយៈពេលបានតែដប់បីថ្ងៃប៉ុណ្ណោះ *អាន់ជីន - សាន* ។ តែដរាបណាមានមនុស្សរស់នៅលើកោះទាំងនេះ ឈ្មោះ *អាកេស៊ី* គឺជាឈ្មោះដ៏ថោកទាបមួយ ។

- រឿងនេះកើតឡើងពេលនាងរៀបការបានប៉ុន្មានពេល ?

- ពីរខែនិងបីថ្ងៃ *អាន់ជីន - សាន* ។

- អ៊ីចឹងពេលនោះនាងទើបបានដប់ប្រាំឆ្នាំ ?

- ចាស ។ លោកប្ដីខ្ញុំបានផ្ដល់កិត្តិយសដល់ខ្ញុំដោយមិនលែងខ្ញុំ រឺបណ្ដេញខ្ញុំចេញទេ ខ្ញុំត្រូវគេបំបរបង់អោយទៅនៅឯភូមិមួយនៅឯតំបន់ខាងជើង ។ នោះគឺនៅក្នុងខេត្ត *ស្ទូរ៉ែ* ។ នៅទីនោះត្រជាក់ណាស់ *អាន់ជីន - សាន* ។ ត្រជាក់មែនទែនតែម្ដង ។

- នាងនៅទីនោះប៉ុន្មានពេល ?

- ប្រាំបីឆ្នាំ ។ លោកម្ចាស់ *តូរ៉ាណា* មានអាយុសែសិបប្រាំបួននៅពេលដែលលោកធ្វើ *សិបពូគូ* ដើម្បីចៀសមិនអោយគេចាប់រូបលោកបាន ។ រឿងនេះកើតឡើងតាំងពីដប់ប្រាំមួយឆ្នាំមុនម្ល៉េះ *អាន់ជីន - សាន* ហើយត្រកូលរបស់គាត់.....

*ប៊ុនតារ៉ូ* និយាយកាត់ម្ដងទៀត ។ សំដីរបស់លោកម៉ាត់ៗ ។ *ម៉ារីកូ* និយាយទៅកាន់ *ប្លាក់ថន* :

- លោកប្ដីខ្ញុំមានប្រសាសន៍យ៉ាងត្រឹមត្រូវថា ល្មមគ្រប់គ្រាន់ហើយចំពោះរឿងរ៉ាយរ៉ាប់ប្រាប់ថាខ្ញុំជាកូនមនុស្សក្បត់នោះ ហើយថា ការពន្យល់វែងអន្លាយពេកជាការមិនចាំបាច់ទេ ។ តាមពិត ការពន្យល់ខ្លះជាការចាំបាច់ -រួចនាងពោលបន្ថែមយ៉ាងប្រយ័ត្នប្រយែង - សូមលោកអភ័យទោសដល់អាកប្បកិរិយាច្រងេងច្រងាងរបស់ប្ដីខ្ញុំផង ។ ខ្ញុំសូមអង្វរ សូមលោកចងចាំពាក្យដែលខ្ញុំនិយាយថា ត្រចៀកសំរាប់ស្ដាប់ ហើយនឹងរបងប្រាំបីទិសនោះផង ។ អោយខ្ញុំសូមទោសផងទៅចុះ *អាន់ជីន - សាន* តែខ្ញុំត្រូវទទួលបញ្ជាអោយចាកចេញទៅហើយ ។ លោកមិនអាចចេញមុនពេលដែលគាត់ចាកចេញ រឺស្រវឹងសន្លប់នោះទេ ។ សូមកុំ



www.budinst.gov.kh www.elibraryofcambodia.org

រឺវវល់លូកលាន់អោយសោះ ។

នាងក៏លំអោនខ្លួនគោរព *ភូជីកូ* ៖

- *ដូស្ទិ គូរមេន ណាសៃ* ។

- *ដូ អ៊ីតាស៊ីម៉ាស៊ុតេ* ។

*ម៉ារីកូ* លំអោនក្បាលគោរព *ប៊ុនតារ៉ូ* ហើយក៏ចាកចេញទៅ ។ ក្លិនក្រអូបរបស់នាងនៅអណ្តែតប្រហើរ ។

- សាកេ !

*ប៊ុនតារ៉ូ* និយាយទាំងញញឹមសី ។ *ប្លាក់ថន* ចាក់ស្រាបំពេញពែង ហើយនិយាយទាំងអាម្មរណ៍ជ្រួលច្របល់ ៖

- សុខភាព !

ក្នុងរយៈពេលជាងមួយម៉ោងដែលគេលើកពែងជូនពរ *ប៊ុនតារ៉ូ* រហូតដល់ខ្លួនគេផ្ទាល់ឡើងងឿងក្បាល ។ ទីបំផុត *ប៊ុនតារ៉ូ* ក៏ដួលដេកសន្លប់កណ្តាលគំនរពែងដែលនៅបែករាយប៉ាយ ។ ទ្វារត្រូវបានរុញបើកឡើងភ្លាម ។ ឆ្មាំម្នាក់ក៏ដើរចូលមកជាមួយ *ម៉ារីកូ* ។ ជាមួយនិងអ្នកបំរើឯទៀតដែលហាក់ដូចជាផុសចេញមកពីសព្វកន្លែងនោះ ពួកគេបានលើក *ប៊ុនតារ៉ូ* ទៅបន្ទប់ *ម៉ារីកូ* ដែលនៅទល់មុខបន្ទប់នេះ ។ ដោយមានជំនួយរបស់នាង *កយ* ផងនោះ *ម៉ារីកូ* ចាប់ផ្តើមដោះខោអាវអោយប្តី ។ ឆ្មាំក៏បានទាញទ្វារបិទ ហើយនៅអង្គុយយាមខាងក្រៅបន្ទប់ ដៃរបស់គេដាក់លើពាក់កណ្តាលដងដាវដែលរង្កៀកចេញហើយជាស្រេច ។

*ភូជីកូ* នៅអង្គុយតាមសំលឹងមើល *ប្លាក់ថន* ។ ពួកនារីបំរើបានមករៀបចំទុកដាក់សំអាតទីកន្លែងឡើងវិញ ។ *ប្លាក់ថន* ច្រៀងសក់ដ៏វែងរបស់ខ្លួនយ៉ាងខ្ជិលណាយហើយស្រាយខ្សែចងសក់កន្ទុយសេះរបស់គេចេញ ។ រួចគេក៏ងើបឡើងទាំងទ្រេតទ្រោត ហើយដើរចេញទៅរានហាលដោយមាន *ភូជីកូ* តាមជាប់ពីក្រោយ ។

ខ្យល់ហាក់នាំមកនូវក្លិនមួយគួរអោយឆ្ងាញ់ ហើយប្រការនេះក៏បានជួយកំចាត់ភាពស្រវឹងរបស់គេខ្លះដែរ ។ គេដាក់បង្គុយលាន់ទឹស ហើយក៏បន្តផឹកនៅកណ្តាលពេលអធ្រាត្រ



www.budinst.gov.kh www.elibraryofcambodia.org

នោះទៀតទៅ ។

*ភូជីដូ* លុតជង្គង់នៅពីក្រោយ *ភ្លាក់ថន* ហើយក៏អោនទៅរកគេដោយនិយាយខ្សឹប១ និងដោយភ្ញើយក្បាលជាសញ្ញាចង្អុលទៅផ្ទះផង :

- *វ៉ាការីម៉ាស៊ី កា ?* - លោកយល់ទេ ?

- *វ៉ាការីម៉ាស៊ី ស៊ុការ៉ា កា ណៃ* ។

ទៅពេលដែលឃើញភាពភ័យខ្លាចរបស់នាង គេក៏យកដៃទះក្បាលនាងបន្តើរ១ ។

- *អារីកាតូ អារីកាតូ អាន់ជីន - សាន* ។

- *អាណាតាវ៉ា ស៊ូអ៊ីមីន អ៊ីម៉ា ភូជីតូ - សាន -* គេប្រឹងរកពាក្យនិយាយទាំងពិបាក - នាងទៅគេងទៅ ។

- *ដូស្ទូកូ មេសណាសៃ អាន់ជីន - សាម៉ា ស៊ូអ៊ីមីន នេ ?* នាងនិយាយតបព្រមទាំងចង្អុលប្រាប់បន្ទប់របស់គេ ។

- *អ៊ីយេ* ។ *វ៉ាតាស៊ី អូយ៉ូតូ អ៊ីម៉ា* - ទេ ខ្ញុំទៅហែលទឹក ។

- *ហៃ អាន់ជីន - សាន - សាម៉ា* ។

នាងវិលត្រលប់ទៅក្រោយយ៉ាងស្លូតបូត ហើយស្រែកហៅអ្នកបំរើពីរនាក់អោយរត់ខ្ទឹតគំរង់មករកពួកគេ ។ នោះគឺយុវជនទៅក្នុងភូមិពីរនាក់ដែលពោរពេញដោយកំលាំងខ្លាំងក្លា ហើយដែលល្បីល្បាញខាងពូកែហែលទឹកផង ។

*ភ្លាក់ថន* ឥតបានប្រកែកចំពោះទំរើនេះទេ ។ យប់នេះគេដឹងយ៉ាងច្បាស់ណាស់ថាការប្រកែកទាំងប៉ុន្មានរបស់គេគ្មានបានផលអ្វីទាំងអស់ ។

- អ៊ីចឹងក៏អ៊ីចឹងទៅ - គេនិយាយខ្លាំង១ ក្នុងពេលដែលគេដើរចុះជំរាលកូនភ្នំទាំងទ្រេតទ្រោត ដោយមានយុវជនទាំងពីរតាមជាប់ជាមួយផង ។ ខួរក្បាលគេនៅអណ្តែតក្នុងចំហាយអ័ព្ទនៃសុរានៅឡើយ - យ៉ាងម៉េចយ៉ាងម៉ាអញបានអោយវាផឹកដេកលក់បាត់ទៅហើយដែរ ។ វាមិនអាចធ្វើបាបនាងបានទេ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

ក្រោយពីហែលទឹកបានមួយម៉ោងមក *ប្លាក់ថន* មានអារម្មណ៍គ្រាន់បើជាងមុន ។ ពេលគេត្រលប់មកផ្ទះវិញ *ភូជីកូ* នៅរង់ចាំគេនៅឯរានហាល ដោយមានតែឆុងថ្មី១មួយប៉ាន់ផង ។ គេទទួលក្រេបទឹកតែបន្តិច ហើយក៏ចូលដំណេកលង់លក់ភ្លាមមួយរំពេចទៅដែរ ។

សំលេងរបស់ *ប៊ុនតារ៉ូ* បានដាស់អោយគេភ្ញាក់ក្រញាង ។ ដៃស្តាំរបស់គេច្បាមជាប់រួចស្រេចដងកាំភ្លើងខ្លីដែលមានច្រកគ្រាប់ហើយ១ ដែលគេតែងតែដាក់នៅពីក្រោមកំរាលជាប់ជានិច្ចនោះ ។ បេះដូងរបស់គេលោតរន្ថាន់ដូចស្គរបណ្តាលដោយការភ្ញាក់ក្រញាងពីដំណេកយ៉ាងដូចនេះ ។

សំលេង *ប៊ុនតារ៉ូ* រលត់បាត់ ។ *ម៉ារីកូ* ចាប់ផ្តើមនិយាយម្តង ។ *ប្លាក់ថន* អាចស្តាប់បាននេះមួយមាត់នោះមួយម៉ាត់តែប៉ុននោះមែន តែគេអាចមានអារម្មណ៍ពីភាពប្រកបដោយវិចារញ្ញាណ និងភាពអង្វរករ តែមិនមែនជាភាពថោកទាប តំអូញតំអែ រឺស្ទើរចង់ពេបនោះទេ ពោលគឺភាពស្ងប់ស្ងាត់នឹងនរជាភរាល់ដងរបស់នាង ។ ជាថ្មីម្តងទៀតសំលេងរបស់ *ប៊ុនតារ៉ូ* ផ្ទុះឡើងដូចឈាច ។

*ប្លាក់ថន* ប្រឹងមិនរវល់ស្តាប់សំដីប្រកែកគ្នានេះទេ ។

" សូមកុំរវីរវល់លូកលាន់អោយសោះ " នេះគឺជាសំដីដែលនាងបានប្រាប់គេហើយនាងចំជារាងរៃមែន ។ គេគ្មានសិទ្ធិអ្វីទាំងអស់ ឯ *ប៊ុនតារ៉ូ* វិញមានសំបូរហូរហៀរ ។ " ខ្ញុំសូមអោយលោកប្រយ័ត្នប្រយែង *អាន់ជីន -សាន* ។ សូមលោកចងចាំពាក្យដែលខ្ញុំនិយាយថា ត្រចៀកស្តាប់ និងរបងប្រាំបីទិសនោះផង " ។

គេប្រះខ្លួនដេកទៅវិញយ៉ាងស្ងួត ។ ខ្លួនប្រាណគេទទឹកជោកដោយញើស ហើយគេខិតខំបង្វែរគំនិតរបស់គេទៅពិចារណាពីសំដីដែលនាងបាននិយាយ ។

នៅយប់ដ៏ពិសេសមួយនោះ នៅពេលដែលពួកគេបានបង្ហើយស្រាសាកេជាច្រើនថូ ហើយនៅពេលដែលគេនិយាយសើចលេងពីកង្វះភាពសំងាត់ផ្ទាល់ខ្លួននៅគ្រប់កន្លែង ពោលគឺកន្លែងណាក៏មានសុទ្ធតែមនុស្សនៅជុំវិញខ្លួន ជញ្ជាំងធ្វើពីក្រដាស ភ្នែកនិងត្រចៀកចាំស្តាប់គ្រប់ពេលមកនោះ *ម៉ារីកូ* បានពោលមកកាន់គេថា :



www.budinst.gov.kh www.elibraryofcambodia.org

- លោកដឹងទេ *អាន់ជីន - សាន* ។ នៅទីនេះ លោកត្រូវរៀនបង្កើតភពសំងាត់របស់លោកដោយខ្លួនលោកផ្ទាល់ ។ តាំងពីតូចម្ល៉េះ ពូកយើងត្រូវបានគេបង្រៀនអោយបំបាំងខ្លួនបាត់នៅក្នុងខ្លួនរបស់យើង អោយសង់ជញ្ជាំងដែលគ្មានអ្នកណាទំលាយរួចដើម្បីយើងអាចរស់នៅក្នុងរង្វង់នោះបាន ។ បើសិនជាយើងមិនអាចធ្វើបានយ៉ាងនេះទេ ពូកយើងមុខជាឆ្កួតឡប់ ហើយសំលាប់គ្នាឯង និងសំលាប់ខ្លួនស្លាប់អស់ហើយ ។

- ជញ្ជាំងយ៉ាងម៉េចទៅ ?

- អូ ពូកយើងមានក្បួនព័ទ្ធដ៏ឥតព្រំដែនមួយដែលអាចអោយយើងលាក់ខ្លួនពួនទៅទីនោះបាន *អាន់ជីន - សាន* ។ យើងមានពីធី មានទំនៀមទំលាប់ មានត្រណមគ្រប់បែប យ៉ាង ។ ចាស គឺពិតមែនណាំ *អាន់ជីន - សាន* ។ សូម្បីតែភាសានិយាយរបស់ពូកយើងក៏មានភាពលាំគ្នាជាច្រើន ខុសពីភាសារបស់លោកដែលគ្មានភាពនេះ ហើយប្រការនេះអាចអោយយើងចៀសវាងបានយ៉ាងគួរសម នូវរាល់សំនួរទាំងឡាយដែលយើងមិនចង់ឆ្លើយទៀតផង ។

- តែតើនាងបិទត្រចៀកនាងយ៉ាងម៉េចបាន *ម៉ារីកូ - សាន ?* រឿងនេះពិតជាមិនអាចទៅរួចទេ ។

- អូ អោយតែរ៉ុកហាត់ទៅ គឺងាយទេ ។ ជាការពិតហើយ ការរ៉ុកហាត់នេះត្រូវចាប់ផ្តើមតាំងពីក្មេងចេះនិយាយទៅ ទើបវាក្លាយទៅជាចរិតកំនើតទីពីររបស់យើងបានយ៉ាងរហ័ស ។ ព្រោះបើមិនអីចឹងទេ តើពូកយើងទ្រោលរស់នៅម្តេចនឹងបានទៅ ? ដំបូងលោកត្រូវចាប់ផ្តើមសំអាត **មនុស្សឆ្លាតវៃទាំងឡាយ** ចេញពីអារម្មណ៍លោកអោយអស់ ដើម្បីលោកអាចដាក់រូបលោកនៅក្នុងភពថ្មីមួយ ។ សំលឹងមើលព្រះអាទិត្យលិច រឺក៏ស្តាប់សំលេងទឹកភ្លៀងក៏ជាជំនួយមួយយ៉ាងល្អដែរ ។ *អាន់ជីន - សាន* តើលោកមានដែលកត់សំគាល់ទេថាសំលេងទឹក ភ្លៀងខុសៗគ្នា ? បើសិនជាលោក **ស្តាប់** ដោយពិតប្រាកដមែននោះ បច្ចុប្បន្ននឹងរលាយបាត់ឯង *ទេ ?* **ស្តាប់** សំលេងផ្គាំធ្លាក់ ស្តាប់សំលេងថ្មដុះ ទាំងអស់នេះគឺជាលំហាត់ដ៏ល្អពិសេស ។ ពិតហើយ លោកត្រូវតែមិន **ឃើញ** រូបាឡើយ ព្រោះនោះគ្រាន់តែជាសញ្ញា



www.budinst.gov.kh www.elibraryofcambodia.org

ជាសារសំរាប់ *ហាភ៊ា* សំរាប់មណ្ឌលរបស់លោកដើម្បីរំលឹកលោកពីជីវិត ដើម្បីជួយលោកអោយទទួលបាន *ភ៊ា* ពោលគឺភាពសុខដុមដ៏សុក្រិតដែលជាគុណភាពគេតាមស្វែងរកបំផុត នៅក្នុងរាល់ជីវភាពជប៉ុន រាល់សិល្បៈ រាល់....-នាងផុះសំនើច-លោកឃើញទេ ខ្ញុំតែញ៉ាំសាកេច្រើន តឹអ៊ីចឹង -នាងយកចុងអណ្តាតផ្សើមបបូរមាត់របស់ខ្លួនគួរអោយរំភើប -ខ្ញុំនឹងខ្សឹបប្រាប់រឿងសំងាត់មួយដល់លោក នោះគឺលោកមិនត្រូវចាញ់បោកនឹងស្នាមញញឹម ភាពគួរសម ភាពពិធីការ ការលំអោនគោរព និងការយកចិត្តទុកដាក់របស់ពួកយើងអោយសោះ ។ នៅពីក្រោមរូបភាពទាំងនេះ ចិត្តយើងអាចស្ថិតនៅរាប់លានលី ដោយសុវត្ថិភាព និងយ៉ាងឯកោ ។ ព្រោះអ្វីដែលយើងចង់ស្វែងរកនោះ គឺការភ្លេច ។ សំនេរកំនាព្យដើមដំបូងដែលមាននៅក្នុងសៀវភៅប្រវត្តិសាស្ត្រដំបូងគេឈ្មោះ *កូជីកូ* ហើយដែលត្រូវបានចងក្រងកាលពីប្រហែលមួយពាន់ឆ្នាំមុននេះ ប្រហែលជាអាចពន្យល់បានពីអ្វីដែលខ្ញុំបាននិយាយនេះ :

*ដុំពពកប្រាំបីកួចបក់ឡើង*

*បំប៉ុងបិទជិតស្នេហ៍ទាំងគូ*

*របងប្រាំបីទិសខេត្ត អ៊ីស៊ូម៉ូ*

*ព័ទ្ធដុំពពកទាំងប្រាំបី*

*សែនអស្ចារ្យក្រៃរបងប្រាំបីទិស ។*

ពួកយើងនឹងពិតជាវង្វេងវង្វាន់ឡប់អស់ជាមិនខាន បើសិនជាគ្មានរបងប្រាំបីទិសនេះទេនោះ ។ ចាស ប្រាកដមែនណាំ !

នឹកឃើញពីរបងប្រាំបីទិស -គេទន្ទេញនៅក្នុងខ្លួនរបស់គេ ក្នុងពេលដែលសំលេងពោរពេញដោយកំហឹងរបស់ *ប៊ុនតារ៉ូ* បន្លឺលាន់ឡើងដូចពស់ព្រួសពិសនោះ ។ អញមិនដឹងអីទាំងអស់ពីរូបនាង ។ រឺពីរូបប្តីនាង បើនិយាយតាមត្រង់ទៅនោះ ។ ត្រូវគិតពីរឿងកងពល *ម៉ាស្គេ* រឺពីរឿងផ្ទះ រឺថាតើត្រូវធ្វើយ៉ាងម៉េចដើម្បីបានសំពៅមកវិញ រឺគិតពីរឿង អា *បាតូស* រឿង *តូរ៉ាណាកា* រឺ *អូមី - សាន* វិញ ។ ចុះអា *អូមី* គិតយ៉ាងម៉េចដែរ ? តើអញត្រូវការសងសឹកនឹងវាវិញទេ ? វាចង់ចងមិត្តនឹងអញ ហើយវាបានប្រែល្អ និងគួរសមណាស់តាំងពីរឿង



www.budinst.gov.kh www.elibraryofcambodia.org

កាំភ្លើងខ្លីមក ហើយ.....

សំលេងវាយបានលាន់ឡើងខ្ទ័រនៅក្នុងក្បាលរបស់គេ ។ សំលេង *ម៉ារីក្លូ* ក៏បានលាន់លឺឡើង ហើយស្គរវាយជាលើកទីពីរបានបន្លឺឡើងជាថ្មី ធ្វើអោយ *ភ្លាក់ថន* ស្ទុះងើបយ៉ាងរហ័ស ហើយទាញទ្វារបើកខ្ទាកឡើង ។ នៅទល់មុខគេមានឆ្មាំម្នាក់ប្រកបដោយទឹកមុខម៉ាំនៅឈរយាមក្នុងរបៀងទល់មុខបន្ទប់ *ម៉ារីក្លូ* ។ ដាវរបស់ឆ្មាំនេះត្រៀមហើយជាស្រេច ។

នៅពេលដែល *ភ្លាក់ថន* ហៀបនឹងហក់ទៅដាក់ *សាមូរ៉ៃ* នេះទៅហើយនោះ ទ្វារដែលនៅឯចុងរបៀងបានត្រូវបើកឃ្វាំងឡើង ។ *ភូជីកូ* ដែលមានសក់ធ្លាក់សំយាកលើ *គីម៉ូណូ* ពេលរាត្រីរបស់ខ្លួនបានដើរតំរង់មក ។ ស្គរអាវដែលត្រូវរហែក និងសំលេងវាយដំហាក់ដូចជាឥតមានប៉ះពាល់អ្វីដល់នាងមួយចំរៀកណាសោះឡើយ ។ នាងលំអោនខ្លួនគោរពយ៉ាងគួរសមចំពោះអ្នកយាម ហើយនៅឈរចំកណ្តាលអ្នកទាំងពីរ ។ បន្ទាប់មកនាងលំអោនខ្លួនយ៉ាងស្រាលគោរព *ភ្លាក់ថន* ទើបចាប់ដៃគេធ្វើសញ្ញាអោយចូលទៅក្នុងបន្ទប់វិញ ។ គេបានឃើញយ៉ាងច្បាស់នូវការត្រៀមយ៉ាងតឹងតែងជាស្រេចរបស់ឆ្មាំ ។ ក្នុងពេលនេះគេមានកាំភ្លើងតែមួយដើមនិងគ្រាប់មួយគ្រាប់តែប៉ុននោះ ដោយហេតុនេះគេក៏ថយក្រោយចូលក្នុងបន្ទប់វិញទៅ ។ *ភូជីកូ* ចូលទៅតាម ហើយទាញទ្វារបិទពីក្រោយនាង ។ ទាំងភ័យខ្លាច នាងគ្រវីក្បាល ហើយយកម្រាមដៃមកដាក់លើបបូរមាត់របស់នាងជាការព្រមាន ក្រសែភ្នែកនាងពោរពេញដោយភាពអង្វរករ ។ នាងនិយាយខ្សាវៗ :

- *កូមេនណាសៃ វ៉ាការរីម៉ាស៊ុ កា ?*

ប៉ុន្តែអារម្មណ៍របស់ *ភ្លាក់ថន* នៅផ្តោតជាប់លើបន្ទប់ឯម្ខាងទៀត ដែលបិទពាសដោយក្រដាស ហើយដែលគេអាចកំទេចចោលយ៉ាងងាយ ។

*ភូជីកូ* ក៏ងាកមើលជញ្ជាំងក្រដាសនៃបន្ទប់ដែរ ។ រំភ្លេតនោះ នាងទៅឈរចន្លោះ *ភ្លាក់ថន* និងជញ្ជាំងរួចដាក់បង្គុយចុះ ព្រមទាំងធ្វើសញ្ញាអោយ *ភ្លាក់ថន* ធ្វើដូចនាងដែរ ។

ប៉ុន្តែគេមិនអាចធ្វើដូចនាងបានទេ ។ គេឈរត្រៀមខ្លួនជាស្រេចដើម្បីធ្វើការវាយលុក ដែលនឹងបំផ្លាញពួកគេអោយវិនាសទាំងអស់គ្នា ។ សំលេងថ្ងូរក្រោមស្គរវាយជាថ្មីបាន



www.budinst.gov.kh www.elibraryofcambodia.org

កាន់តែបញ្ឆេះគេថែមទៀត ។ *ភូជីកូ* គ្រវីក្បាលទាំងរន្ធត់ញាប់ញ័រ :

- *អ៊ុយេ !*

គេគ្រវាសដៃធ្វើសញ្ញាអោយនាងចៀសផ្លូវ ។ នាងអង្វរជាថ្មីម្តងទៀត :

- *អ៊ុយេ ! អ៊ុយេ !*

- ***អ៊ុម៉ា !***

ភ្លាមនោះ *ភូជីកូ* ក៏ស្ទុះងើបឡើង ហើយធ្វើសញ្ញាអោយ *ប្លាក់ថន* រង់ចាំ ។នាងដើរយ៉ាងប្រញាប់ប្រញាល់ដោយគ្មានលឺសូរីបជើងអ្វីបន្តិចណាសោះ ទៅយកដាវដែលដាក់នៅលើ *តូកូណាម៉ា* ពោលគឺហ៊ឹងកិត្តិយស ។ នាងទាញយកដាវវែង ហើយហូតផ្លែចេញពីស្រោមទាំងដៃញ័រទទ្រើតដើម្បីត្រៀមទៅតាមជាមួយគេដែរ ។ ក្នុងពេលនោះ ស្គរវាយក៏លាន់លឺឡើងជាថ្មី លាយឡំនឹងសំលេងមូម៉ៅក្តៅក្រហាយមួយប្រាវយ៉ាងវែង ។ រួចទ្វារឯម្ខាងទៀតក៏របើកលាន់គ្រាំង ហើយសំលេងជើង *ប៊ុនតារ៉ូ* ក៏បន្លឺឡើងសំដៅទៅទ្វារចេញដោយមានទាំងស្គរជើងឆ្មាំតាមពីក្រោយផង ។ នៅក្នុងផ្ទះគ្មានលឺសំលេងអ្វីទាំងអស់ទៀតឡើយ ហើយបន្តិចក្រោយមក សំលេងទ្វាររបងផ្ទះត្រូវបានបិទលឺគ្រាំង ។

*ប្លាក់ថន* ដើរសំដៅទៅកាន់ទ្វារ ។ *ភូជីកូ* ក៏ស្ទុះមកពាំងសាជាថ្មីទៀត តែត្រូវគេរុញអោយទៅម្ខាង ហើយគេក៏រុញទ្វារទៅម្ខាង ។

នៅឯជ្រុងបន្ទប់ម្ខាងទៀត *ម៉ារីកូ* នៅតែលុតជង្គង់នៅឡើយ ។ ឈ្នាមរំពាត់មួយគូសនៅជាប់លើថ្ពាល់ សក់នាងក្រញេងក្រញាង អាវគីម៉ូណូរហែករយ៉ៃ ភ្លៅនិងខ្លួននាងមានស្នាមជាំពាសពេញ ។

គេស្ទុះទៅជួយលើកនាង តែ *ម៉ារីកូ* ស្រែកឡើង :

- ចេញទៅ ! សូមលោកអញ្ជើញចេញទៅ *អាន់ជីន - សាន* !

គេក្រលេកឃើញស្នាមឈាមរឹម១នៅគៀនបបូរមាត់របស់នាង :

- ព្រះអើយ នាងធ្ងន់ណាស់......

- ខ្ញុំបានប្រាប់លោកថា កុំអោយវីរវល់លូកលាន់អោយសោះហើយតើ ។ សូម



www.budinst.gov.kh www.elibraryofcambodia.org

លោកអញ្ជើញទៅវិញចុះ ។

សំលេងនាងនៅតែមានភាពស្ងប់ស្ងាត់ និងផ្ទុយស្រលះពីភាពហឹង្សាដែលជះចេញតាមពន្លឺភ្នែករបស់នាង ។ រួចនាងក៏ប្រទះឃើញ *ភូជីកូ* ដែលឈរនៅឯមាត់ទ្វារ ។ នាងនិយាយប្រាប់ *ភូជីកូ១* ក៏មកទាញដៃរបស់ *ឡាក់ថន* ដើម្បីនាំគេចេញទៅវិញ ប៉ុន្តែគេរបះដៃនាងចេញ !

- ទេ ! *អ៊ីយេ !*

*ម៉ារីកូ* និយាយឡើង

- វត្តមានរបស់លោកនៅទីនេះ ធ្វើអោយខ្ញុំបាក់មុខបាក់មាត់អស់ហើយ១ថែមទាំងមិនបានផ្តល់មកអោយខ្ញុំនូវភាពស្ងប់ស្ងាត់ រឺជួយលួងខ្ញុំទេ ។ លោកមានតែធ្វើអោយខ្ញុំមានការខ្មាសអៀនថែមទៀត ។ សូមលោកចេញទៅ !

- ខ្ញុំចង់ជួយនាងណា ។ តើនាងយល់ទេ ?

- តើលោកយល់ទេ ? លោកគ្មានសិទ្ធិនៅទីនេះទេ ។ នេះជាជំលោះរវាងប្តីនឹងប្រពន្ធរបស់គេទេតើ ។

- តែនេះមិនមែនជាលេសដើម្បីធ្វើការវាយដំ.......

- ហេតុអីក៏លោកមិនព្រមស្តាប់សោះអ៊ីចឹង *អាន់ជីន -សាន ?* គាត់អាចវាយខ្ញុំរហូតដល់ស្លាប់ក៏បានដែរបើសិនជាគាត់ចង់ ។ គាត់មានសិទ្ធិ ហើយខ្ញុំក៏មានបំនងអោយគាត់មានសិទ្ធិនេះ....... ទោះជាបែបនេះក៏ដោយ ។ ទាល់តែយ៉ាងនេះទើបខ្ញុំមិនទទួលនូវភាពអាម៉ាស់របស់ខ្ញុំ ។ លោកស្មានថាជីវិតស្រួលណាស់ទៅរឺ ដែលត្រូវរស់នៅក្នុងភាពអាម៉ាស់នោះ ? លោកមិនលឺខ្ញុំនិយាយប្រាប់លោកទេរឺ? ***ខ្ញុំជាកូនស្រីរបស់ អាកេស៊ី ជីនសៃណា !***

- តែនេះមិនមែនជាកំហុសរបស់នាងទេ ។ នាងឥតបានធ្វើអីទាំងអស់ !

- នេះជាកំហុសខ្ញុំ ហើយខ្ញុំជាកូនស្រីរបស់ឪពុកខ្ញុំ ។

*ម៉ារីកូ* ចង់បញ្ឈប់ត្រឹមនេះ តែនៅពេលដែលនាងក្រលេកឃើញភាពករុណា ភាព



www.budinst.gov.kh www.elibraryofcambodia.org

កង្វល់ និងភាពស្នេហ៍របស់គេ និងដោយដឹងថាគេជាមនុស្សដែលគោរពសច្ចធម៌ផងនោះ នាងក៏សំរេចទំលាក់ស្បែបិទបាំងរបស់នាងចេញខ្លះ ។ នាងពោលឡើង :

- យប់នេះគឺជាកំហុសរបស់ខ្ញុំទេ *អាន់ដ្រេ - សាន* ។ បើសិនជាខ្ញុំយំដូចបំនងប្រាថ្នារបស់គាត់ អង្វរលន់តួតាមបំនងប្រាថ្នារបស់គាត់ ថ្នាក់ថ្នមលួងលោមគាត់តាមបំនងប្រាថ្នារបស់គាត់ បើកភ្លៅអោយគាត់តាមបំនងប្រាថ្នារបស់គាត់ ធ្វើអ្វីៗដែលជាភារកិច្ចនារីនោះ គាត់ប្រៀបដូចជាកូនក្មេងនៅក្នុងកណ្តាប់ដៃខ្ញុំអ៊ីចឹង ។ តែខ្ញុំមិនព្រម ។

- ហេតុអីទៅ ?

- ព្រោះនេះជាការសងសឹករបស់ខ្ញុំ ។ ដើម្បីតបទៅនឹងការដែលគាត់ទុកអោយខ្ញុំនៅរស់បន្ទាប់ពីអំពើក្បត់នេះ ។ ដើម្បីតបនឹងការដែលគាត់បំបរបង់ខ្ញុំអស់រយៈពេលប្រាំបីឆ្នាំ ។ ដើម្បីតបនឹងការដែលគាត់បញ្ជាអោយខ្ញុំវិលត្រលប់មកវិញ ហើយនៅតែទុកអោយខ្ញុំរស់នៅតទៅទៀតនេះ ។

នាងអង្គុយទាំងឈឺចាប់ ហើយរៀបចំសំរួលគីម៉ូណូដែលរហែករយ៉ៃគ្របដណ្តប់ខ្លួននាង ។ នាងពោលបន្ត :

- ខ្ញុំមិនដែលព្រមខ្លួនជាមួយគាត់ទៀតទេ ។ មានម្តង ខ្ញុំបានព្រមព្រៀងដោយស្ម័គ្រចិត្ត ថ្វីត្បិតតែខ្ញុំស្អប់គាត់តាំងពីខ្ញុំឃើញគាត់ដំបូងម្ល៉េះក្តី ។

- បើអ៊ីចឹងម៉េចបានជានាងសុខចិត្តរៀបការជាមួយគាត់ ? នាងបាននិយាយថា នារីមានសិទ្ធិប្រកែកបាន នាងបានថា គេមិនត្រូវអោយនារីរៀបការទាំងបង្ខំទេ ។

- ខ្ញុំរៀបការជាមួយគាត់ ដើម្បីអោយលោកម្ចាស់ *តូរ៉ាណា* សប្បាយចិត្ត ដើម្បីអោយឪពុកខ្ញុំសប្បាយចិត្ត ។ កាលនោះខ្ញុំនៅក្មេងពេក ហើយខ្ញុំមិនស្គាល់ *តូរ៉ាណា* ទេ ។ តែបើលោកចង់ដឹងការពិត ខ្ញុំសូមជំរាបលោកថា *តូរ៉ាណា* ជាមនុស្សសាហាវឃោរឃៅបំផុត គួរអោយស្អប់ខ្ពើមបំផុត ។ គាត់ជាអ្នកជំរុញអោយឪពុកខ្ញុំក្បត់ ។ ហើយនេះគឺជាការពិតទាំងស្រុង ! *តូរ៉ាណា !* - នាងនិយាយឈ្មោះទាំងស្អប់ខ្ពើម - ខ្ញុំបួងសួងសូមអោយ *តូរ៉ាណា* នៅវេទនាឋាននរកជារៀងរហូត ។ រវាងប្តីខ្ញុំនឹងខ្ញុំមានតែគំនុំគុំកួននឹងគ្នា ។ នេះជា *កាម៉ា* របស់



www.budinst.gov.kh www.elibraryofcambodia.org

យើង ។ តាមពិតជាការងាយស្រួលបំផុតចំពោះគាត់ក្នុងការអនុញ្ញាតអោយខ្ញុំបានស្លាប់នោះ ។

- ហេតុអ្វីបានជាគាត់មិនព្រមដោះលែងនាងទៅ ? រឺលែងនាង ? រឺក៏យល់ព្រមតាមសំនូមពរនាងអីចឹង ?

- ព្រោះគាត់ជាបុរស ។

មុខនាងឡើងជ្រួញដោយចរន្តចុកចាប់បានរត់កាត់ខ្លួនប្រាណរបស់នាង ។ *ភ្លាក់ថន* លុតជង្គង់ចុះក្បែរនាង ហើយសាកជួយលួងលោមនាង តែនាងរុញគេចេញទៅម្ខាង ។ *ភូជីកូ* នៅតែឈររឹងនៅឯមាត់ទ្វារដដែល ។

- ខ្ញុំមិនអីទេ *អាន់ជីន - សាន* ។ សូមលោកទុកអោយខ្ញុំនៅម្នាក់ឯងបានហើយ ។ លោកមិនត្រូវធ្វើអីចឹងទេ ។ លោកត្រូវតែប្រយ័ត្នប្រយែង ។

- ខ្ញុំមិនខ្លាចគាត់ទេ ។

*ម៉ារិកូ* យកដៃកៀសសក់ចេញពីភ្នែកទាំងប៉ក់ល្ងើយ ។ ភ្នែកនាងសំលឹងមើលទៅលើក្នុងការប្រឹងគិតពិចារណា ។ ហេតុអីមិនទុកអោយ *អាន់ជីន - សាន* ទទួល *កាម៉ា* របស់ខ្លួនទៅ - នាងដណ្ដឹងសួរនៅក្នុងចិត្ត ។ គាត់មិនមែននៅក្នុងភពរបស់ពួកយើងទេ ។ *ប៊ុនតារ៉ូ* អាចសំលាប់គាត់បានយ៉ាងងាយ ។ មកដល់ពេលនេះ កុំតែបានកិច្ចគាំពាររបស់ *តូរ៉ាណាកា* ទេ ដែលជួយគាត់ ។ *យ៉ាប៊ូ . អូមី . ណាកា . ប៊ុនតារ៉ូ* ...... ពួកនេះណាមួយក៏ងាយច្រលោតអាចអោយគេសំលាប់គាត់ភ្លាមដែរ ។

តាំងពីមកដល់ បុរសនេះគ្មាននាំអ្វីក្រៅពីរឿងរ៉ាវតែប៉ុននោះ ។ ទាំងចំនេះដឹងរបស់គេក៏យ៉ាងដូចនោះដែរ ។ *ណាកា* យល់ត្រឹមត្រូវមែន : *អាន់ជីន - សាន* នេះអាចកំទេចភពយើងបានបើយើងមិនខ្ទប់គេមុនទេនោះ ។

រួចចុះបើសិនជា *ប៊ុនតារ៉ូ* ដឹងការពិតវិញនោះ ? រឺ *តូរ៉ាណាកា ?* នោះគឺរឿងរួមខ្លើយ......

នៅយប់ដំបូងនោះ *ភូជីកូ* បានសួរនាង :

- មីងឡប់សតិហើយទេអី ?



www.budinst.gov.kh www.elibraryofcambodia.org

- ទេ ។

- បើអ៊ីចឹងម៉េចបានជាទៅជំនួសនារីបំរើធ្វើអី ?

- នេះគឺព្រោះសោកេ និងដើម្បីសប្បាយ *ភូជីកូ - សាន* ។ ម្យ៉ាងទៀតដើម្បីចង់ដឹងផង ។

តាមពិតនោះជាការកុហកតែប៉ុនោះ ។ មូលហេតុពិតប្រាកដនាងបានលាក់មិនអោយ *ភូជីកូ* ដឹងឡើង ។ នោះគឺ *ប្លាក់ថន* បានកន្ត្រាក់អារម្មណ៍នាង ហើយនាងក៏ស្រលាញ់ចង់បានគេដែរ ។ នាងមិនដែលមានគូស្នេហ៍នឹងគេទេ ។ ហើយបើសិនជានាងមិនបានគេនៅយប់នោះទេ គឺច្បាស់ជាអត់រហូតហើយ ។ ហើយគូនាងត្រូវតែ *អាន់ជីន - សាន* ។ តែ *អាន់ជីន - សាន* ម្នាក់គត់ ។

ហើយនាងបានទៅរកគេ ហើយគេបានធ្វើអោយនាងមានការពេញចិត្តយ៉ាងខ្លាំង ។ កាលពីម្សិលមិញ នៅពេលដែលទូកធំមកដល់ *ភូជីកូ* បានសួរនាងដោយស្ងាត់ៗថា :

- បើសិនជាមីងដឹងថាប្តីមីងនៅរស់ តើមីងទៅរកគេទេ ?

- ទេ ។ ពិតជាទេ ? - នាងកុហក ។

- តែពេលនេះមីងនឹងប្រាប់ *ប៊ុនតារ៉ូ - សាម៉ា* *ទេ ?* ប្រាប់ពីរឿងគេងជាមួយ *អាន់ជីន - សាន ?*

- ហេតុអ្វីបានជាខ្ញុំត្រូវប្រាប់គាត់ ?

- ខ្ញុំគិតថា នោះប្រហែលជាផែនការរបស់មីង ។ បើមីងប្រាប់ *ប៊ុនតារ៉ូ - សាម៉ា* ចំពេលនេះ គាត់នឹងអេះច្រលោតនឹងមីងហើយ មីងអាចស្លាប់យ៉ាងស្រួលមុននឹងគាត់ដឹងថាគាត់បានធ្វើអ្វីផង ។

- ទេ *ភូជីកូ - សាន* ។ គាត់មិនសំលាប់ខ្ញុំទេ ។ ហើយនេះគឺអភ័ព្វណាស់ ។ គាត់នឹងបញ្ជូនខ្ញុំទៅពួក *អេតា* នេះបើគាត់មានលេសគ្រប់គ្រាន់.....បើគាត់បានការយល់ព្រមរបស់លោកម្ចាស់ *តូរ៉ាណាហ្គា* ។ តែដាច់ខាតគាត់មិនសំលាប់ខ្ញុំទេ ។

- សាហាយស្មន់ជាមួយ *អាន់ជីន -សាន*....... តើគ្រប់គ្រាន់ទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- គ្រប់ហើយ ។

- តើពេលនោះកូនប្រុសមីងនឹងទៅជាយ៉ាងណាទៅ ?

- វានឹងទទួលបន្តនូវភាពអសោចរបស់ខ្ញុំ ។

- សូមមីងជួយប្រាប់ខ្ញុំផងនៅពេលណាដែល *ប៊ុនតារ៉ូ - សាម៉ា* មានការសង្ស័យពីអ្វីដែលបានកើតឡើងនេះ ។ ក្នុងឋានៈខ្ញុំជាកំនាន់របស់គាត់ ខ្ញុំមានភារកិច្ចការពារ *អាន់ជីន-សាន* ។

សំលេង *ប្លាក់ថន* លាន់លឺជាថ្មីម្តងទៀត :

- ខ្ញុំអត់ខ្លាចគាត់ទេ ?

- ខ្ញុំដឹងហើយ - នាងតបទាំងក្នុងការចុកចាប់ - តែខ្ញុំសូមអង្វរ សូមលោកខ្លាច គាត់ជំនួសខ្ញុំផងទៅចុះ ។

*ប្លាក់ថន* ដើរសំដៅទៅរកទ្វារ ។

☆ ☆ ☆

*ប៊ុនតារ៉ូ* នៅរង់ចាំគេនៅកណ្តាលផ្លូវដែលចុះទៅភូមិ ។ រូបរាងកន្ទ្រើមាំរបស់គេហាក់ដូចមច្ចុរាជតែម្តងនៅពេលនេះ ។ អ្នកការពារនៅឈរម្ខាងខ្លួនរបស់លោក ។ ព្រលឹមនេះមេឃដេរដាសដោយដុំពពក ។ សមុទ្រមានភាពស្ងប់ស្ងាត់ ។ ទូកនេសាទនានាកំពុងធ្វើសកម្មភាពចាប់ត្រីជាធម្មតា ។

*ប្លាក់ថន* ប្រទះឃើញធ្នូនៅនឹងដៃ *ប៊ុនតារ៉ូ* ហើយនឹងដាវទាំងគូ ។ ព្រមទាំងដាវរបស់អ្នកការពារផងដែរ ។ *ប៊ុនតារ៉ូ* មានលក្ខណៈទ្រេតទ្រោតបន្តិចហើយនេះធ្វើអោយ *ប្លាក់ថន* សង្ស័យថា មនុស្សនេះពិតជាមិនអាចតំរង់បានល្អណាស់ណាទេ ដែលអាចអោយគេមានឱកាសចូលកៀកជិតបានល្មម ។ ក្រៅតែពីផ្លូវដើរនេះ គ្មានកន្លែងអាចធ្វើជាជំរកបានទាំងអស់ ។ ដោយលែងគិតខ្វល់ពីអ្វីទាំងអស់ គេកាច់ក្តក់ប្រុកកាំភ្លើងខ្លីទាំងពីររបស់គេហើយជាស្រេច ហើយដើរតាមផ្លូវលំចុះតំរង់ទៅរកអ្នកទាំងពីរ ។

កុំទៅខ្វល់អារឿងរកជំរក - គេគិតនៅក្នុងចិត្ត ។ ទន្ទឹមនេះ គេដឹងថាអ្វី១ដែលគេ



www.budinst.gov.kh www.elibraryofcambodia.org

កំពុងធ្វើនេះ ចំជាពេលាមួយរយភាគរយតែម្ដង ព្រោះគេគ្មានសង្ឃឹមបន្តិចណាឡើយ ។ ក្នុងការតទល់ជាមួយ *សាមូរ៉ៃ* ពីរនាក់ រឺតទល់ជាមួយព្រួញស៊ីឆ្ងាយនេះ ។ ហើយគេដឹងថា គេគ្មានសិទ្ធិនឹងលូកដៃទៅក្នុងរឿងរបស់គេឡើយ ។ រួចក្នុងពេលដែល *ប៊ុនតារ៉ូ* នៅឆ្ងាយពីកាំភ្លើងខ្លីរបស់គេនៅឡើយ ស្រាប់តែបុរសនេះលំអោនខ្លួនគោរពគេយ៉ាងទាប ។ អ្នកការពារក៏យ៉ាងដូចនោះដែរ ។ *ប្លាក់ថន* ឈប់ងឹក ដោយគេមានអារម្មណ៍ចំពោះអន្ទាក់ណាមួយ ។ គេសំលឹងមើលជុំវិញខ្លួន តែគ្មានអ្នកណាម្នាក់នៅជិតនេះទេ ។ គេសំលឹងមើលហាក់ដូចជានៅក្នុងការយល់សប្តិ ឃើញ *ប៊ុនតារ៉ូ* លុតជង្គង់យ៉ាងធ្ងន់កណ្តុកដាក់ព្រួញទៅម្ខាង ដាក់ដៃទ្រាបទៅលើដី ហើយលំអោនខ្លួនគោរពគេយ៉ាងទាបដូចជាកសិករលំអោនខ្លួនគោរពលោកម្ចាស់គេអ៊ីចឹង ។ អ្នកការពារក៏ធ្វើតាមម្ចាស់របស់ខ្លួនឥតខ្ចោះ ។

*ប្លាក់ថន* សំលឹងមើលពួកគេទាំងពីរនាក់ទាំងស្រលាំងកាំង ។ នៅពេលដែលគេច្បាស់នៅក្នុងចិត្តថា ភ្នែកគេមិនច្រលំហើយនោះ គេក៏ធ្វើដំណើរតំរង់ទៅយ៉ាងយឺតៗ កាំភ្លើងខ្លីនៅតែត្រៀមជាប់ តែគេមិនបានលើកវាតំរង់ទេ ។ នៅក្នុងចិត្ត គេនៅតែសង្ស័យពីល្បិចកិច្ចកលណាមួយនៅឡើយ ។ នៅក្នុងចំងាយមួយសមសួនហើយនោះគេក៏ឈប់ ។ *ប៊ុនតារ៉ូ* នៅតែឥតកំរើកខ្លួននៅឡើយ ។ តាមទំលាប់គេត្រូវតែលុតជង្គង់ចុះ ហើយគោរពតបវិញបែបគ្នា ព្រោះថាគេស្មើឋានៈគ្នា រឺថាមានឋានៈប្រហាក់ប្រហែលគ្នា ប៉ុន្តែគេមិនយល់សោះថា ហេតុអ្វីក៏ចាំបាច់មានពិធីអីម៉ាទាំម្លេះក្នុងស្ថានភាពដែលឈាមហៀបនឹងចាប់ហូរទៅហើយនោះ ។

- ក្រោកឡើង អាកូនមីចោលម្រាយ !

ដៃរបស់គេត្រៀមជាស្រេចនឹងកាច់កៃកាំភ្លើង ។ តែ *ប៊ុនតារ៉ូ* អត់និយាយអីទាំងអស់ ។ លោកនៅតែរក្សាក្បាលអោនជាប់ជានិច្ច ។ បាតដៃទាំងពីរនៅតែទ្រាបលើដីដដែល ។ ខ្នងអាវគីម៉ូណូរបស់លោកជោកដោយញើស ។

- *ណាន ដា ?*

*ប្លាក់ថន* ប្រើសំនួរដ៏ប្រមាថ -ស្អីណឹង ? - ដើម្បីទាក់ *ប៊ុនតារ៉ូ* អោយក្រោកឈរឡើងនិងអោយចាប់ផ្ដើមឡើង ព្រោះគេមិនអាចបាញ់មនុស្សដែលនៅក្រាបស្រប៉ាបលើដីបែប



LIBRARY BUDDHIST INSTITUTE
www.budinst.gov.kh www.elibraryofcambodia.org

នេះបានឡើយ ។

រួចដោយចាប់អារម្មណ៍ថា ជាការជំលើយមួយដែលខ្លួននៅឈរក្នុងពេលដែលគេលុតជង្គង់ ហើយនឹងពាក្យ " *ណាទេចា* " ជាពាក្យសឹងតែមិនអាចទ្រាំទទូលបាន ហើយក៏ជាការជេរប្រមាថដោយឥតចាំបាច់សោះផងនោះ *ប្លាក់ថន* ក៏លុតជង្គង់ចុះដោយដាក់ដៃដែលនៅតែកាន់កាំភ្លើងខ្លីជាប់នោះទៅលើដី ហើយលំអោនខ្លួនគោរពតបវិញ ។

បន្ទាប់មក គេក៏ងើបអង្គុយលើកែងជើងវិញ ហើយសួរក្នុងសំលេងមួយដែលគេប្រឹងធ្វើជាគួរសម :

- *វ៉េហ ?*

ភ្លាមនោះ *ប៊ុនតារ៉ូ* ក៏ចាប់ផ្តើមនិយាយរង្វំរង្វ៉ាងចោកទាបខ្ញុំការសូមទោសរបស់ខ្លួន ។ សូមទោសពីរឿងអី ហើយហេតុអីនោះ *ប្លាក់ថន* មិនអាចដឹងបានទេ ។ គេអាចស្តាប់បានឯនេះមួយម៉ាត់ ឯនោះមួយម៉ាត់ ហើយនឹងពាក្យសាកេជាញឹកញាប់តែអ្វីដែលច្បាស់ គឺជាការដាក់ខ្លួនដាក់ប្រាណសូមទោស និងសូមការប្រោសប្រណី ។ *ប៊ុនតារ៉ូ* និយាយរ៉ាយរ៉ាប់យ៉ាងយូរ រួចលោកឈប់នៅស្ងៀម ហើយក្រាបក្បាលរាបដល់ដីវិញដដែល ។

មកដល់ពេលនេះ កំហឹងឆេះមេឃទាំងប៉ុន្មានរបស់ *ប្លាក់ថន* រលាយបាត់អស់ហើយ :

- *ស៊ីកាតា កាណៃ ។ ហាតឹរី វ៉ាការ៉ានូ កា ស៊ីនប៉ាយ ស៊ូរុកូតូវ៉ាណៃ* - មិនជាអ្វីទេ ។ ខ្ញុំមិនយល់ច្បាស់ទេ តែសូមកុំមានការបារម្ភថ្វី ។

*ប៊ុនតារ៉ូ* ងើយមុខឡើង ហើយក្រោកអង្គុយ :

- *អារីកាតូ ! អារីកាតូ អាន់ជីន - សាន* ។ - *ដូម៉ូ កូមេន ណាសៃ* ។

- *ស៊ីកាតា កា ណៃ* ។

*ប្លាក់ថន* និយាយឡើងវិញ ។ នៅពេលដែលគេឃើញថា ការសូមទោសនេះជាកាយវិការស្មោះពិតៗនោះ គេថ្លែងអំនរគុណដល់ព្រះដែលបានជួយពង្វាងការប្រឈមមុខគ្នានេះ ។ គេដឹងច្បាស់ណាស់ថា គេគ្មានសិទ្ធិអីចូលលួកលាន់ទេ ហើយគេបានធ្វើសកម្មភាពដូច



www.budinst.gov.kh www.elibraryofcambodia.org

ជាមនុស្សលេលាម្នាក់ ហើយវិធីតែមួយគត់ដើម្បីដោះស្រាយទំនាស់ជាមួយ *ប៊ុនតារ៉ូ* គឺធ្វើតាមបញ្ញត្តិដែលមានចែង ពោលគឺ *គូរ៉ាណាកា* ។

តែហេតុអីបានជាមានការសូមទោសយ៉ាងដូចនេះ ? *ច្ចាក់ថន* ដណ្ដឹងសួរនៅក្នុងចិត្ត ។ គិតទៅមើល ! ឯងត្រូវតែរៀនគិតដូចពួកវា ។

រួចចំលើយបានជះភ្លែតនៅក្នុងខួរក្បាលរបស់គេ ។ នេះអាចមកពីអញជា *ហាតាម៉ូតូ* ហើយ *ប៊ុនតារ៉ូ* ជាភ្ញៀវបានមករំខាន *វ៉ា* ពោលគឺភាពសុខដុមរបស់លំនៅស្ថានអញ ។ ដោយមានទំនាស់ជាចំហ និងយ៉ាងខ្លាំងក្លានៅក្នុងផ្ទះ**របស់អញ** វាបានប្រមាថ**អញ** ហេតុនេះវាខុសទាំងស្រុងហើយ វាត្រូវតែសូមទោស ទោះជាចង់រឺមិនចង់ក្ដី ។ ជាការសូមទោសជាដាច់ខាតចៀសមិនបាន ពី *សាមូរ៉ៃ* ម្នាក់ចំពោះ *សាមូរ៉ៃ* ម្នាក់ទៀត ពីភ្ញៀវចំពោះម្ចាស់ផ្ទះ...

ឈប់សិន ! មិនត្រូវភ្លេចទេថា តាមប្រពៃណីពួកនេះ បុរសទាំងអស់ត្រូវបានអនុញ្ញាតអោយស្រវឹង ហើយត្រូវត្រៀមថា ពួកគេនឹងស្រវឹងម្ដងម្កាល ហើយនៅពេលស្រវឹងពួកគេមិនទទួលខុសត្រូវលើសកម្មភាពរបស់ពួកគេទេ បើសិនជាសកម្មភាពនោះមិនហួសហេតុពេកទេនោះ ។ ហើយមិនត្រូវភ្លេចទេថា គ្មានការបាក់មុខបាក់មាត់អីទេ បើសិនជាគេស្រវឹងលិចថ្លើមនោះ ។

- *សាកេ* - *ច្ចាក់ថន* និយាយដោយដាច់ណាត់ - *ស៊ីកាតា កា រ៉ៃណៃ* ។ *សាកេ !*

*ប៊ុនតារ៉ូ* លំអោនខ្លួនគោរពសូមអរគុណជាថ្មី ។ *ច្ចាក់ថន* គោរពតបហើយក្រោកឈរឡើង ។ *ប៊ុនតារ៉ូ* ក៏ក្រោក ។ អ្នកការពារក៏យ៉ាងដូចនោះដែរ ។ អ្នកទាំងពីរលំអោនខ្លួនគោរព *ច្ចាក់ថន* ជាថ្មី ។ *ច្ចាក់ថន* លំអោនគោរពតបវិញ ។

នៅទីបំផុត *ប៊ុនតារ៉ូ* ក៏ត្រលប់ខ្លួនធ្វើដំណើរទាំងទ្រេតទ្រោតចេញទៅ ។ *ច្ចាក់ថន* នៅរង់ចាំរហូតដល់គេផុតពីចំងាយកំលាំងព្រួញដោយទាំងដណ្ដឹងសួរក្នុងចិត្តថា តើការស្រវឹងរបស់ *ប៊ុនតារ៉ូ* ជាការស្រវឹងមែន រឺជាការធ្វើស្រវឹងទេ ។ រួចគេក៏បកត្រលប់ទៅកាន់ផ្ទះគេវិញទៅ ។

*ភូជីកូ* នៅឈររង់ចាំគេឯរានហាល ក្នុងសភាពគួរសមជានិច្ច ។ តើតាមពិតទៅ



www.budinst.gov.kh www.elibraryofcambodia.org

នាងកំពុងគិតពីរឿងអីទៅ - គេសួរខ្លួនគេក្នុងពេលដែលមាត់គេពោលពាក្យគួរសមជាមួយនាង ។

ទ្វារបន្ទប់ *ម៉ារីកូ* នៅតែបិទជិតឈឹងនៅឡើយ ។ នារីបំរើរបស់នាងឈរនៅក្បែរនោះ ។

- *ម៉ារីកូ - សាន ?*

- ចាស *អាន់ជីន - សាន ?*

គេនៅរង់ចាំ តែទ្វារនៅតែបិទជិតដដែល :

- នាងស្រួលបួលទេ ?

- ចាស ស្រួលបួលទេ ។ សូមអរគុណលោកហើយ - នាងគ្រហែមបន្តិចទើបបន្តក្នុងសំលេងយ៉ាងទន់ខ្សោយ - *ភូជីកូ* បានអោយគេទៅជំរាប *យ៉ាប៊ូ - សាន* និងលោកម្ចាស់ *តូរ៉ាណាកា* ហើយ ថាខ្ញុំមិនស្រួលខ្លួនថ្ងៃនេះ ហេតុនេះបកមិនបានទេ ។

- យកល្អនាងគួរទៅអោយគ្រូពេទ្យពិនិត្យមើលទៅ ។

- ចាស អរគុណលោក ។ តែហៅ *ស៊ូរ៉ូ* វិញបានល្អ ។ ខ្ញុំបានអោយគេទៅហៅគាត់មកហើយ ។ ខ្ញុំ.....ខ្ញុំប្រហែលជាថ្ងោះហើយ តែជារូមខ្ញុំមិនអីទេ ។ លោកមិនចាំបាច់ពារម្ភអីទេ ។

- ស្តាប់ខ្ញុំណា ។ ខ្ញុំចេះរឿងពេទ្យបន្តិចបន្តួចដែរ ។ នាងមិនមានក្អកធ្លាក់ឈាមអីទេអ្ហី ?

- អត់មានទេ ។ ពេលខ្ញុំរអិលជើងដួលក៏បោកនឹងថ្កាល់ទៅ ។ មែនណាខ្ញុំស្រួលបួលទេ ។

ក្រោយពីនៅស្ងៀមស្ងាត់មួយសន្ទុះ គេពោលឡើង :

- *ប៊ុនតារ៉ូ* បានសូមទោស ។

- ចាស់ *ភូជីកូ* បានតាមមើលពីមាត់របងទៅ ។ ខ្ញុំសូមអរគុណលោកដែលបានយល់ព្រមទទួលយកការសូមទោសរបស់គាត់ ។ សូមអរគុណចាស ។ ហើយ *អាន់ជីន -*



www.budinst.gov.kh www.elibraryofcambodia.org

*សាន* ខ្ញុំសោកស្តាយណាស់ដែលលោកត្រូវរំខានយ៉ាងនេះ ......សូមលោកទទួលយកការសូមទោសរបស់ខ្ញុំផង ។ ខ្ញុំមិនគួរនិយាយស្តីឥតបើគិតយ៉ាងនេះទេ ។ នេះចំជាគ្មានសុជីវធម៌មែន ។ សូមលោកទទួលអធ្យាស្រ័យដល់ខ្ញុំផងដែរ ។ ជំលោះនេះកើតបណ្តាលមកពីខ្ញុំ ។ អោយខ្ញុំសូមទោស ។

- សូមទោសរឿងត្រូវប្តីវៃហ៊ើង ?

- សូមទោសរឿងដែលខ្ញុំមិនបានគោរពតាមបញ្ជារបស់ប្តីខ្ញុំ រឿងដែលខ្ញុំមិនបានអោយគាត់បានរួមជំណោកដោយរីករាយ រឿងដែលខ្ញុំធ្វើអោយប្តីខកចិត្តហើយនឹងរំខានម្ចាស់ផ្ទះ ។ ហើយនឹងសូមទោសលើអ្វីដែលខ្ញុំបាននិយាយ ។

- នាងច្បាស់ហើយថា គ្មានអ្វីដែលខ្ញុំអាចជួយទេអ្ហី ?

- ទេ ! ទេ សូមអរគុណលោកហើយ *អាន់ជីន - សាន* ។ តែមួយថ្ងៃនេះទេ ។

តែ *ភ្នាក់ថន* ឥតបានឃើញនាងរហូតដល់ទៅប្រាំបីថ្ងៃ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៣៦

- ខ្ញុំហៅឯងមកដើម្បីបរបាញ់ *ណាកា -សាន* មិនមែនហៅមកអោយនិយាយដដែល ១ពីទស្សនៈដែលពុកធ្លាប់លឺនោះទេ - *គូរ៉ាណាកា* និយាយ ។

- អោយខ្ញុំសូមអង្វរពុកជាលើកចុងក្រោយទៅចុះ ។ សូមបញ្ឈប់ការរ៉ឺកហាត់នេះទៅ ដាក់កាំភ្លើងទាំងអស់អោយនៅក្រៅច្បាប់ កំទេចអាមនុស្សចុងស្រុក ប្រកាសថា ការសាកល្បងនេះទទួលបរាជ័យហើយ១បញ្ឈប់អំពើដ៏ខ្ពើមនេះទៅ ។

- ទេ ។ ហើយនេះជាលើកចុងក្រោយដែរ ។

ស្លាំងញីដែលត្រូវគេគ្របមុខជិត ហើយដែលនៅទំលើដៃពាក់ស្រោមរបស់ *គូរ៉ាណាកា* នោះ បានប្តូរទីតាំងរបស់វាដោយវាមិនដែលធ្លាប់លឺសំលេងពោរពេញដោយការគំរាមកំហែងរបស់ម្ចាស់វា ។ ពួកគេកំពុងនៅក្នុងព្រៃគុម្ពោត ពួកដើរក្បៀងសត្វនិងពួកការពារកំនៅឆ្ងាយមិនអាចស្តាប់លឺការជជែករបស់អ្នកទាំងពីរបានឡើយ ។ ថ្ងៃនេះមេឃមានពពកដាស អាកាសធាតុសើមហើយស្អុះស្អាប់ ។

- អ៊ីចឹងក៏បាន ។ តែនេះនៅតែជាភារកិច្ចរបស់ខ្ញុំដែលត្រូវរំលឹកពុកថា នៅទីនេះពុកអាចមានគ្រោះថ្នាក់ ហើយខ្ញុំសូមអង្វរយ៉ាងគោរពបំផុត និងជាចុងក្រោយ សូមពុកចាកចេញពី *អាន់ជីន្ស៊ូ* នៅថ្ងៃនេះតែម្តងទៅ ។

- ទេ ។ ហើយអាហ្នឹងក៏ជាចុងក្រោយដែរ ។

- បើអ៊ីចឹងយកក្បាលខ្ញុំតែម្តងទៅ !

- ក្បាលឯងពុកមានហើយទេតើ !

- អ៊ីចឹងយកវាថ្ងៃនេះតែម្តងទៅ ។ យកពេលនេះតែម្តង ។ រឺមួយអោយខ្ញុំបញ្ចប់ជីវិតខ្ញុំទៅចុះ បើពុកមិនទទួលយកមតិល្អ១ដដែលនោះ ។

- អាតូច រៀនចេះអត់ធ្មត់ខ្លះទៅ ។

- តើអោយខ្ញុំរៀនអត់ធ្មត់ម៉េចនឹងកើតទៅ បើខ្ញុំឃើញពុកកំពុងតែបំផ្លាញខ្លួនឯងយ៉ាងនេះ ? នេះគឺជាភារកិច្ចរបស់ខ្ញុំដែលត្រូវតែជំរាបពុក ។ ពុកនៅទីនេះដើម្បីបរបាញ់ និង



www.budinst.gov.kh www.elibraryofcambodia.org

បំផ្លាញពេលវេលាចោល ក្នុងពេលដែលសត្រូវរបស់ពុកកំពុងទាញផែនដីទាំងមូលអោយសង្កត់ពុក ។ ស្អែកនេះ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងបើកការប្រជុំហើយ ។ បូនភាគប្រាំនៃ *វ៉ៃមីញ៉* មួយប្រទេសជប៉ុនវីមួយកំពុងនៅ *អូសាកា* វីមួយកំពុងធ្វើដំណើរទៅ ។ ពុកជាមនុស្សសំខាន់**តែមួយគត់**ដែលមិនព្រមទៅ។ ពេលនេះពុកនឹងត្រូវផ្តន្ទាទោស។ ដល់ពេលនោះគ្មានអ្វីអាចជួយសង្គ្រោះពុកបានទេ ។ យ៉ាងហោចណាស់ ពុកគួរតែនៅឯផ្ទះឯ *យេដូ* ការពារដោយកងទ័ពវិញ ។ នៅទីនេះ ពុកឧទលគក ។ ពួកយើងមិនអាចការពារពុកបានទេ ។ ពុកយើងមានគ្នាតែជាងពាន់នាក់បន្តិចបន្តួច ហើយនេះគឺ *យ៉ាប៊ូ - សាន* មិនកេណ្ឌអស់ម៉ាត់បន់ *អ៊ីស៊ូ* នេះ ទេអ្វី ? គាត់មានទ័ពជាងប្រាំបីពាន់នាក់ក្នុងរង្វង់ម្តៃលីនេះ ។ ហើយនៅមានប្រាំមួយពាន់នាក់ទៀតដែលនៅចាំបិទតាមព្រំដែន ។ ពុកដឹងទេ ពួកយកការណ៍ទាំងប៉ុន្មានបានរាយការណ៍ថា គាត់មានកងជើងទឹកបង្កប់នៅខាងជើងរង់ចាំពន្លិចពុកក្នុងករណីដែលពុកចង់គេចខ្លួនតាមទូកចំណា ! អីលូវនេះពុកក្លាយជាអ្នកទោសរបស់គាត់ដដែល ។ ពុកឃើញហើយវីនៅ ? អោយតែមានព្រាបនាំសារពី *អ៊ីស៊ីដូ* តែមួយក្បាលមក *យ៉ាប៊ូ* អាចកំទេចពុកភ្លាម នៅពេលដែលណាគាត់ចង់ ។ តើធ្វើម៉េចពុកដឹងបានថា *យ៉ាប៊ូ - សាន* មិនមានផែនរួមក្បត់ជាមួយ *អ៊ីស៊ីដូ* នោះ ?

- ពុកជឿជាក់ថា វាកំពុងគិតលើបញ្ហានេះ ។ បើពុកជាវាវិញក៏ពុកធ្វើដូចវាដែរ ។ ចុះឯងវិញ ?

- ទេ ! ខ្ញុំមិនធ្វើយ៉ាងហ្នឹងទេ ?

- បើអីចឹងឯងមុខជាស្លាប់ ហើយសមនឹងស្លាប់ទៅទៀត ។ តែទន្ទឹមនេះក្រុមគ្រួសារឯង ត្រកូលសំព័ន្ធឯង និងរាល់អណ្តាប់ឯងទាំងអស់នឹងត្រូវស្លាប់ដែរ ហើយនេះជាប្រការមិនអាចអត់អោនអោយបានទេ ។ ឯងជាមនុស្សភ្លីភ្លើ និងជាមនុស្សចំកួតមួយដ៏កាចសាហាវ ! ឯងមិនព្រមប្រើសតិបញ្ញា ឯងមិនព្រមស្តាប់គេ ឯងមិនព្រមរៀនពីគេ ឯងមិនព្រមទប់មាត់ វីទប់ចរិតខ្លួនឯងសោះ ! ឯងបណ្តោយអោយគេបង្វិលបានដូចក្មេងបៀមដៃហើយនៅតែជឿថា ស្ពានសុទ្ធតែដោះស្រាយបានដោយមុខដាវ ។ មូលហេតុតែមួយគត់ដែល



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៣៦

- ខ្ញុំហៅឯងមកដើម្បីបរបាញ់ *ណាកា -សាន* មិនមែនហៅមកអោយនិយាយដដែល ១ពីទស្សនៈដែលពុកធ្លាប់លឺនោះទេ - *តូរ៉ាណាកា* និយាយ ។

- អោយខ្ញុំសូមអង្វរពុកជាលើកចុងក្រោយទៅចុះ ។ សូមបញ្ឈប់ការរឹកហាត់នេះទៅ ដាក់កាំភ្លើងទាំងអស់អោយនៅក្រៅច្បាប់ កំទេចអាមនុស្សចុងស្រុក ប្រកាសថា ការសោកល្បងនេះទទួលបរាជ័យហើយ១បញ្ឈប់អំពើដ៏ខ្លើមនេះទៅ ។

- ទេ ។ ហើយនេះជាលើកចុងក្រោយដែរ ។

ស្ទាំងញីដែលត្រូវតែគ្របមុខជិត ហើយដែលនៅទំលើដៃពាក់ស្រោមរបស់ *តូរ៉ាណាកា* នោះ បានប្តូរទីតាំងរបស់វាដោយវាមិនដែលធ្លាប់លឺសំលេងពោរពេញដោយការគំរាមកំហែងរបស់ម្ចាស់វា ។ ពួកគេកំពុងនៅក្នុងព្រៃគុម្ពោត ពួកដើរក្បៀងសត្វនិងពួកការពារក៏នៅឆ្ងាយមិនអាចស្តាប់លឺការជជែករបស់អ្នកទាំងពីរបានឡើយ ។ ថ្ងៃនេះមេឃមានពពកដាស អាកាសធាតុសើមហើយស្អុះស្អាប់ ។

- អ៊ីចឹងក៏បាន ។ តែនេះនៅតែជាភារកិច្ចរបស់ខ្ញុំដែលត្រូវរំលឹកពុកថា នៅទីនេះពុកអាចមានគ្រោះថ្នាក់ ហើយខ្ញុំសូមអង្វរយ៉ាងគោរពបំផុត និងជាចុងក្រោយ សូមពុកចាកចេញពី *អាន់ជីន្ញ៉* នៅថ្ងៃនេះតែម្តងទៅ ។

- ទេ ។ ហើយអាណឹងក៏ជាចុងក្រោយដែរ ។

- បើអ៊ីចឹងយកក្បាលខ្ញុំតែម្តងទៅ !

- ក្បាលឯងពុកមានហើយទេតើ !

- អ៊ីចឹងយកវាថ្ងៃនេះតែម្តងទៅ ។ យកពេលនេះតែម្តង ។ រឺមួយអោយខ្ញុំបញ្ចប់ជីវិតខ្ញុំទៅចុះ បើពុកមិនទទួលយកមតិល្អ១ដដែលនោះ ។

- អាតូច រៀនចេះអត់ធ្មត់ខ្លះទៅ ។

- តើអោយខ្ញុំរៀនអត់ធ្មត់ម៉េចនឹងកើតទៅ បើខ្ញុំឃើញពុកកំពុងតែបំផ្លាញខ្លួនឯងយ៉ាងនេះ ? នេះគឺជាភារកិច្ចរបស់ខ្ញុំដែលត្រូវតែជំរាបពុក ។ ពុកនៅទីនេះដើម្បីបរបាញ់ និង



www.budinst.gov.kh www.elibraryofcambodia.org

បំផ្លាញពេលវេលាចោល ក្នុងពេលដែលសត្រូវរបស់ពុកកំពុងទាញផែនដីទាំងមូលអោយសង្កត់ពុក ។ ស្អែកនេះ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនឹងបើកការប្រជុំហើយ ។ បួនភាគប្រាំនៃ *វៃមីញ៉ូ* មួយប្រទេសជប៉ុនរឺមួយកំពុងនៅ *អូសាកា* រឺមួយកំពុងធ្វើដំណើរទៅ ។ ពុកជាមនុស្សសំខាន់**តែមួយគត់**ដែលមិនព្រមទៅ។ ពេលនេះពុកនឹងត្រូវផ្តន្ទាទោស។ ដល់ពេលនោះគ្មានអ្វីអាចជួយសង្គ្រោះពុកបានទេ ។ យ៉ាងហោចណាស់ ពុកគួរតែនៅឯផ្ទះឯ *រយេដូ* ការពារដោយកងទ័ពវិញ ។ នៅទីនេះ ពុកនឹងលគក ។ ពួកយើងមិនអាចការពារពុកបានទេ ។ ពួកយើងមានគ្នាតែជាងពាន់នាក់បន្តិចបន្តួច ហើយនេះគឺ *យ៉ាប៊ូ - សាន* មិនកេណ្ឌអស់ម៉ាត់បន់ *អ៊ីស៊ូ* នេះ ទេអ្វី ? គាត់មានទ័ពជាងប្រាំបីពាន់នាក់ក្នុងរង្វង់ម្ភៃលីនេះ ។ ហើយនៅមានប្រាំមួយពាន់នាក់ទៀតដែលនៅចាំបិទតាមព្រំដែន ។ ពុកដឹងទេ ពួកយកការណ៍ទាំងប៉ុន្មានបានរាយការណ៍ថា គាត់មានកងជើងទឹកបង្កប់នៅខាងជើងរង់ចាំពន្លិចពុកក្នុងករណីដែលពុកចង់គេចខ្លួនតាមទូកចំណា ! អីលូវនេះពុកក្លាយជាអ្នកទោសរបស់គាត់ដដែល ។ ពុកឃើញហើយរឺនៅ ? អោយតែមានព្រាបនាំសារពី *អ៊ីស៊ីដូ* តែមួយក្បាលមក *យ៉ាប៊ូ* អាចកំទេចពុកភ្លាម នៅពេលដែលណាគាត់ចង់ ។ តើធ្វើម៉េចពុកដឹងបានថា *យ៉ាប៊ូ - សាន* មិនមានផែនរួមគ្បត់ជាមួយ *អ៊ីស៊ីដូ* នោះ ?

- ពុកជឿជាក់ថា វាកំពុងគិតលើបញ្ហានេះ ។ បើពុកជាវាវិញក៏ពុកធ្វើដូចវាដែរ ។ ចុះឯងវិញ ?

- ទេ ! ខ្ញុំមិនធ្វើយ៉ាងណឹងទេ ?

- បើអីចឹងឯងមុខជាស្លាប់ ហើយសមនឹងស្លាប់ទៅទៀត ។ តែទន្ទឹមនេះក្រុមគ្រួសារឯង ត្រកូលសព័ន្ធឯង និងរាល់អណ្តាប់ឯងទាំងអស់នឹងត្រូវស្លាប់ដែរ ហើយនេះជាប្រការមិនអាចអត់អោនអោយបានទេ ។ ឯងជាមនុស្សភ្លីភ្លើ និងជាមនុស្សចំកួតមួយដ៏កាចសាហាវ ! ឯងមិនព្រមប្រើសតិបញ្ញា ឯងមិនព្រមស្តាប់គេ ឯងមិនព្រមរៀនពីគេ ឯងមិនព្រមទប់មាត់ រឺទប់ចរិតខ្លួនឯងសោះ ! ឯងបណ្តោយអោយគេបង្វិលបានដូចក្មេងបៀមដៃ ហើយនៅតែជឿថា ស្ពឹ១សុទ្ធតែដោះស្រាយបានដោយមុខដាវ ។ មូលហេតុតែមួយគត់ដែល



www.budinst.gov.kh www.elibraryofcambodia.org

អញមិនយកក្បាលពភ្លើរបស់ឯង រឺយល់ព្រមអោយឯងបញ្ចប់ជីវិតដ៏គ្មានតំលៃរបស់ឯងនោះ ក៏ព្រោះតែឯងនៅក្មេង ព្រោះអញយល់ថា ឯងនៅមានលទ្ធភាពច្រើនខ្លះដែរ ។ ការភាន់ច្រលំរបស់ឯងគ្មានគំនិតអាក្រក់ទេ ឯងក៏គ្មានពោះវៀនបត់ចទ្វាស ហើយគ្មានអ្នកណាសង្ស័យពីទឹកចិត្តស្មោះត្រង់របស់ឯងទេ ។ តែបើសិនជាឯងមិនព្រមរៀនសូត្រអោយបានឆាប់រហ័សពីការអត់ធ្មត់ និងស្ម័យវិន័យទេនោះ អញដកឋានៈជា *សាមូរ៉ៃ* ពីឯង ហើយដាក់ឯងនិងត្រកូលឯងទាំងអស់អោយទៅជាកសិករវិញ !

កណ្តាប់ដៃស្តាំរបស់ *តូរ៉ាណាកា* ទះកែបសេះលាន់ផាំង ធ្វើអោយស្ទាំងបញ្ចេញសំលេងដ៏គ្រលួច ។ លោកគំហក :

- **ឯងស្តាប់បានហើយរឺនៅ** ?

*ណាកា* សែនភ្ញាក់ផ្អើលយ៉ាងខ្លាំង ។ ក្នុងមួយជីវិតរបស់ខ្លួន *ណាកា* មិនដែលឃើញឪពុករបស់ខ្លួនស្រែកក្រេវក្រោធ រឺកំរោលចូលទេ សូម្បីតែលឺគេនិយាយក៏មិនដែលផង ។ ជាច្រើនដង គេតែងទទួលការស្តីបន្ទោសយ៉ាងចាស់ដៃពីឪពុក តែដោយមូលហេតុត្រឹមត្រូវ ។ គេដឹងថា គេបានធ្វើការភាន់ច្រលំជាច្រើន តែឪពុកគេតែងជួយសំរួលអោយជានិច្ច ដោយហេតុនេះទើបអ្វីដែលគេបានធ្វើមើលទៅហាក់ដូចជាមិនសូវខុសប៉ុន្មានដូចកាលពីពេលចាប់ផ្តើមឡើយ ។ ដូចជានៅពេលដែល *តូរ៉ាណាកា* បានបង្ហាញអោយគេមើលឃើញថា គេបានធ្លាក់ចូលក្នុងអន្ទាក់របស់ *អូមី* រឺក៏របស់ *យ៉ាប៊ូ* ទាក់ទិននឹងរឿង *ចូស៊ិន* នោះ បើកុំតែមានគេចាប់ឃាត់ណាស់ទេនោះ គេនឹងទៅប្រហារអ្នកទាំងពីរនោះភ្លាមជាបន្ទាន់បាត់ទៅហើយ ។ តែ *តូរ៉ាណាកា* បានបញ្ជាអោយអង្គរក្សផ្ទាល់ស្រោចទឹកត្រជាក់ទាល់តែ *ណាកា* ត្រជាក់ចិត្តវិញទើបលោកពន្យល់យ៉ាងនឹងនរថា ខ្លួនគេ *ណាកា* នេះ បានជួយឪពុកខ្លួនយ៉ាងច្រើន អាស្រ័យដោយបានជួយកំចាត់គ្រោះតំរាមកំហែងដែលចេញពី *ចូស៊ិន* " តែវាល្អជាងដែលឯងត្រូវដឹងថា ខ្លួនឯងត្រូវគេលេងល្បិចអោយហក់ចូលទៅក្នុងសកម្មភាពនេះ ។ កូនឯងត្រូវរៀនអត់ធ្មត់ ។ អ្វីៗនឹងមកដល់ អាស្រ័យដោយការអត់ធ្មត់ ។ នៅថ្ងៃក្រោយកូនអាចនឹងបង្វិលពួកវាបានវិញជាមិនខាន ។ អ្វីដែលឯងបានធ្វើគឺល្អណាស់ ។ តែឯងត្រូវតែរៀន



www.budinst.gov.kh www.elibraryofcambodia.org

វិភាគតាមចិត្តគំនិតរបស់មនុស្សម្នាក់ៗ បើសិនជាឯងចង់ជួយខ្លួនឯង....រឺជួយលោកម្ចាស់ឯង ។ ពុកចង់បានក្រុមអ្នកដឹកនាំ ។ ព្រោះពុកមានអ្នកដើរតាមយ៉ាងងងឹតងងល់គ្រប់គ្រាន់ហើយ ។

ជានិច្ចកាល ឪពុកគេតែងតែនឹងន ហើយសណ្ដោសណាស់ តែថ្ងៃនេះ...... *ណាកា* លោតចុះពីលើខ្នងសេះ ហើយក្រាបស្រប់ៗនៅលើដី :

- សូមពុកអត់ទោសអោយកូនផងចុះ ។ កូនគ្មានបំនងធ្វើអោយពុកខឹងនោះទេ... នេះព្រោះតែកូនស្ញប់ស្ញែងនឹងរឿងសុវត្ថិភាពរបស់ពុកតែប៉ុណ្ណោះ ។ សូមពុកអធ្យាស្រ័យដែលកូនរំខានភាពសុខដុមរមនា.......

- ឈប់មាត់ទៅ !

*គូរ៉ាណាកា* គ្រហឹមឡើង ដែលជាហេតុនាំអោយសេះភ្ញាក់ញ្ញោចទៅម្ខាង ។ លោកខំប្រឹងអស់ពីកំលាំងដើម្បីគាបសេះ ព្រមទាំងទាញបង្ហៀរសេះយ៉ាងតឹងដៃស្ដាំ ។ ភាពឃ្លេងឃ្លោង និងភាពមិនប្រក្រតីនៃស្ថានភាពនេះបានបណ្ដាលអោយស្ទាំងទទះស្លាបហើរចេញពីដៃរបស់លោកដោយបញ្ចេញសំលេងយ៉ាងគ្រលូចស្ទើរបែកក្រដាសត្រចៀក ។ ក្នុងពេលដែលលោកប្រឹងទាំងអស់សង្ឃឹមលួងស្ទាំងកុំអោយផ្អើលផង ទប់សេះអោយនៅស្ងៀមវិញផងនោះ *ណាកា* ក៏ស្ទុះក្ដែតសំដៅទៅរកក្បាលសេះ ។ គេច្បាមចាប់បង្ហៀរ ហើយសំរេចទប់សេះកុំអោយផ្អើលទាល់តែបាន ។ ស្ទាំងនៅតែបន្តស្រែកគ្រលូចដដែល ។ ទីបំផុតទើបវាព្រមមកទំទាំងរូញរាគនៅលើស្រោមដៃរបស់ *គូរ៉ាណាកា* វិញ ។ ទោះជាយ៉ាងនេះក្ដី ក៏វានៅតែទទះស្លាបតិចៗយ៉ាងរអើល កណ្ដឹងនៅលើជើងវាលាន់ទ្រហឹង ។

- មិនអីទេ ! មិនអីទេ !

*គូរ៉ាណាកា* ប្រឹងនិយាយយ៉ាងថ្នមៗ ដើម្បីរំងាប់ភាពរចល់របស់ស្ទាំង ។ ទឹកមុខលោកនៅជិតដាមដោយកំហឹងក្រេវក្រោធនៅឡើយ ។ លោកនិយាយទៅកាន់ *ណាកា* ដោយប្រឹងប្រើសំលេងធម្មតាដើម្បីកុំអោយផ្អើលស្ទាំង :

- បើសិនជាឯងភិរំឆានវាទៀត អញនឹង....អញនឹង.....

សំលេងប្រកួកហៅរបស់អ្នកកៀងសត្វម្នាក់បានលាន់លឺឡើង ។ ភ្លាមនោះ *គូរ៉ាណាកា*



www.budinst.gov.kh www.elibraryofcambodia.org

ក៏បើកក្រណាត់គ្របមុខរបស់ស្ទាំងចេញ ហើយទុកអោយសត្វសាំក្រែកនឹងបរិស្ថានជុំវិញវាបន្តិច រួចទើបលោកបង្ហោះវាចេញទៅ ។

ស្ទាំងញីនេះឈ្មោះ *រេណូក្ូ* - នារីដែកថែប - ជាស្ទាំងមានស្លាបយ៉ាងវែង ។ វាបោះពួយទៅលើ ហើយហើរជារង្វង់មូលលើក្បាល *តូរ៉ាណាកា* ក្នុងកំពស់ប្រហែលពីររយម៉ែត ភ្នែកវាវិពែរកមើលសត្វ ។ នៅពេលដែលវាកំពុងឆាបពីក្រោមខ្យល់នោះ វាក៏ប្រទះឃើញ រ៉ូងភ្លែដែលកំពុងដេញមាន់ទោមួយវ៉ូងហើរប្រសាច ។ ក្រោយពីជ្រើសរើសសត្វរួចហើយ ស្ទាំងក៏ផ្តោបស្លាបដាក់ក្បាលឆាបត្រង់មាន់ទោមួយភ្លាម ។ តែមាន់ទោចំនាស់ដែលមានមាឌធំជាងស្ទាំងនេះពីរដងទៅទៀតនោះ បានងាកគេចទៅម្ខាង ហើយបោះពួយស្ទេរសំដៅជំរកក្នុងគុម្ពោតព្រៃ ។ *រេណូក្ូ* ទប់ខ្លួនដោយបើកត្រដាងស្លាប ហើយងាកទៅដេញតាមគោលដៅខ្លួនយ៉ាងប្រញាប់ប្រញាល់ ។ វាហោះឡើងទៅលើ ហើយនៅពេលដែលវានៅចំពីលើមាន់ទោនោះ វាក៏ឆាបចុះម្តងទៀត ហើយខុសទៀត ។ *តូរ៉ាណាកា* ស្រែកលើកទឹកចិត្តស្ទាំងទាំងអារម្មណ៍ត្រេកត្រអាល លែងវិរវល់នឹង *ណាកា* ទៀត ។

ក្នុងស្ទួរទទះស្លាបយ៉ាងរន្ថាន់ មាន់ទោបានហោះលឿនស្ទេរទៅរកជំរកនៃដើមឈើ ។ ស្ទាំងបោះពួយម្តងទៀតសំយុងចុះមកក្រោម តែវាយឺតណាស់ទៅហើយ ។ មាន់ទោបានលាក់ខ្លួនបាត់ក្នុងម្ជប់ព្រៃឈើ ។ សត្វស្ទាំងក៏បោះពួយកាត់តាមមែកនិងស្លឹកឈើនានាតាមរកមាន់ទោយ៉ាងសាហាវ ដោយគ្មានគិតពីសុវត្ថិភាពរបស់វាឡើយ ។ រួចវាក៏ហោះឡើងទៅលើវិញ ដោយបញ្ចេញសំរែកក្តៅក្រហាយ ហើយឆ្វែលក្រលឹងពីលើគុម្ពោតព្រៃនោះឯង ។

ក្នុងពេលនោះ ទទាមួយវ៉ូងបានស្ទុះហើរព្រួលចេញមកដោយបន្ទាបខ្លួនហោះតាមសណ្ឋានដីដើម្បីគេចពីគ្រោះថ្នាក់ ។ *រេណូក្ូ* កំនត់ជ្រើសរើសមុខសញ្ញាខ្លួនបានហើយ ក៏ក្តោបស្លាប ហើយទំលាក់ខ្លួនរឹបដូចដុំថ្ម ។ ម្តងនេះវាឥតខុសគោលដៅវាទៀតទេ ។ ក្រញ៉ាំដ៏ខ្លាំងក្លារបស់វាបានបំបាក់កទទាភ្លាមមួយរំពេច ធ្វើអោយបក្សីនេះធ្លាក់ក្អុកទៅលើដីជាមួយនឹងរោមដែលហុយផ្ទោង ។ តែម្តងនេះ *រេណូក្ូ* មិនបានតាមសំលាប់ទទានេះទៅដល់ដី រឺក៏ច្បាមជាប់នឹងក្រញ៉ាំរបស់ខ្លួនទេ វាបែរជាហើរឡើងខ្ពស់ទៅៗទៅលើមេឃដោយ



www.budinst.gov.kh www.elibraryofcambodia.org

បញ្ចេញសំរែកយ៉ាងគ្រលួចឥតអាក់ទេវិញ ។

ក្នុងសភាពយ៉ាងកង្វល់ *តូរ៉ាំណាកា* ក៏ដកយកខ្មោចកូនសត្វស្លាបតូចមួយមកចងនឹងខ្សែដ៏តូចឆ្មារ ហើយត្រវីវាជាប់ពីលើក្បាលដើម្បីធ្វើជាធ្នាក់ ។ តែ *រកេឈ្វូកូ* ឥតចាញ់កលវិលត្រលប់មកក្រោយវិញឡើយ ហើយពេលនេះវាគ្រាន់តែជាដុំមួយដ៏តូចនៅឯលើមេឃតែប៉ុននោះ។ លើកនេះ *តូរ៉ាំណាកា* ជឿច្បាស់នៅក្នុងចិត្តថា លោកនឹងបាត់បង់ស្ទាំងប្រមាញ់របស់លោកជារៀងរហូតហើយ១ *រកេឈ្វូកូ* បានសំរេចវិលត្រលប់ទៅរកធម្មជាតិវិញដើម្បីសំលាប់សត្វនានាតាមឆន្ទៈរបស់ វាមិនមែនតាមឆន្ទៈរបស់លោក គឺ *តូរ៉ាំណាកា* ទៀត ដើម្បីស៊ីចុកតាមពេលវាចង់ មិនមែនតាមពេលដែលលោកសំរេច ហើយនឹងហោះហើរតាមជំនោរវាយោនិងតាមចិត្តចង់របស់វា ដោយគ្មានម្ចាស់និងដោយក្នុងសេរីភាពជារៀងរហូត ។

*តូរ៉ាំណាកា* តាមសំលឹងមើលស្ទាំងរបស់ខ្លួន មិនមែនក្នុងទឹកចិត្តទុក្ខព្រួយនោះទេ តែលោកហាក់ដូចជាស្ថិតនៅឯកោបន្តិច ។ វាគឺជាសត្វព្រៃ ហើយ *តូរ៉ាំណាកា* ក៏ដូចជាអ្នកលេងស្ទាំងឯទៀតដែរ សុទ្ធតែដឹងយ៉ាងច្បាស់ណាស់ថា លោកគ្រាន់តែជាម្ចាស់បណ្តោះអាសន្នដែលមានជើងជាប់ដីតែប៉ុននោះ ។ លោកបានឡើងតែម្នាក់ឯងទៅដល់សំបុកស្ទាំងនេះនៅលើភ្នំ *ហាកូនេ* ហើយបានយកវាតាំងពីនៅតូច ហើយបានបង្ហាត់វាថ្នាក់ថ្នមវា និងបង្វឹកវាអោយចេះចាប់សំលាប់សត្វជាលើកដំបូង ។ ពេលនេះលោកមើលស្ទាំងរបស់លោកស្ទើរលែងឃើញទៅហើយ១ នៅក្នុងចិត្តរបស់លោក១មានបំនងយ៉ាងអូលអាក់ចង់ស្ថិតនៅក្នុងឋានព្រៃត្រឹង្សមួយដែលគេចចេញផុតពីអំពើបាបកម្មទាំងឡាយនៃភពផែនដីនេះ ។

មាន់ទោចំនាស់នៅពេលឃើញស្ថានភាពស្ងាត់ហើយនោះ ក៏បានលេចចេញពីក្នុងគុម្ពោតព្រៃស្វែងរកចំនីឡើងវិញ ។ នោះជាពេលដែល *រកេឈ្វូកូ* បោះពួយមកពីលើហាក់ដូចជាអាវុធមរណៈដ៏គំនាចមួយដែលធ្លាក់មកពីលើមេឃ ក្រញ៉ាំរបស់វាបើកចំហជាស្រេច ។

មាន់ទោត្រូវស្លាប់ភ្លាមមួយរំពេច ដោយមានរោមហុយសំពោង ។ *រកេឈ្វូកូ* ឡាមមាន់នេះជាប់ ហើយចាប់ផ្តើមចឹកបោចរោមដើម្បីស៊ីជាអាហារ ។ ប៉ុន្តែមុននឹងសំរេចបានបំនងរបស់វា *តូរ៉ាំណាកា* ក៏បានទៅដល់ជាស្រេច ធ្វើអោយវាផ្អាកចំនីរបស់វាទៅ



www.budinst.gov.kh www.elibraryofcambodia.org

ដែរ ។ ភ្នែកពណ៌ត្នោតឥតមេត្តារបស់វាតាមសំលឹងមើល *តូរ៉ាណាកា* ដែលចុះពីលើខ្នងសេះ ត្រចៀករបស់វាស្តាប់សំដីសរសើរថ្នមៗរបស់លោក ។ ដោយគំលានផង ដោយ *តូរ៉ាណាកា* ជាអ្នកចិញ្ចឹមវាផង និងដោយលោកបានលុតជង្គង់ចុះយ៉ាងថ្នមឥតមានប្រើអាកប្បកិរិយាកញ្ឆក់កញ្ឆៀតណាមួយផងនោះ ស្ទាំងក៏នៅយ៉ាងស្ងៀមបណ្តោយអោយលោកចូលជិតខ្លួនវាបាន ។

ដោយនៅតែពោលពាក្យលួងលោមយ៉ាងថ្នមៗដដែល *តូរ៉ាណាកា* យកកាំបិតប្រមាញ់របស់លោកចេញមក ហើយពុះក្បាលមាន់ទោដើម្បីអោយស្ទាំងចឹកស៊ីខួររបស់វា ។ នៅពេលដែលស្ទាំងកំពុងចឹកស៊ីខួរ លោកក៏កាត់ក្បាលមាន់ទោទាំងមូលចេញ ហើយស្ទាំងនេះក៏បានឡើងមកទំយ៉ាងស្រួលនៅលើដៃរបស់លោក ដែលជាកន្លែងវាធ្លាប់ទំស៊ីចំណីនេះ ។

ដោយឃើញស្ទាំងហោះប្រមាញ់យ៉ាងល្អបែបនេះ *តូរ៉ាណាកា* សំរេចថា ទុកអោយវានៅស៊ីចំណីបន្តទៅចុះ មិនចាំបាច់ប្រើវាអោយដេញសត្វទៀតទេ ។ លោកបោចស្លាបខ្មោចសត្វស្លាបតូចសំរាប់ជានុយនោះ ហើយវះវាយ៉ាងស្រួលបួល រួចទើបហុចទៅអោយស្ទាំង ។ នៅពេលដែលស្ទាំងស៊ីបានពាក់កណ្តាលហើយនោះ ទើបលោកយកក្រណាត់គ្របមុខវាឡើងវិញ តែប្រការនេះមិនបានរំខានវាក្នុងការបន្តចឹកស៊ីចំណីនោះទេ ។ នៅពេលដែលវាស៊ីឆ្អែតហើយចាប់ផ្តើមច្បូតស្លាបរបស់ខ្លួនហើយនោះ ទើបលោកហុចមាន់ទោទៅអោយអ្នកថែស្ទាំងរបស់លោកដែលកំពុងឈររង់ចាំលោកជាមួយពួកក្មេងសត្វឯទៀតៗ ។ ផលប្រមាញ់ពេលនេះ មានទន្សាយមួយ ក្រួចមួយគូ ហើយនឹងមាន់ទោ ។ *តូរ៉ាណាកា* ប្រាប់អោយអ្នកថែស្ទាំង និងពួកក្មេងសត្វទាំងប៉ុន្មានវិលត្រលប់ទៅជំរំវិញ ដោយនាំយកស្ទាំងទាំងអស់ទៅជាមួយផង ។ ពួកការពាររបស់លោកនៅរង់ចាំខាងក្រោមខ្យល់ ។

មកដល់ពេលនេះ ទើបលោកផ្តោតការយកចិត្តទុកដាក់របស់លោកទៅលើ *ណាកា* វិញម្តង :

- រួចយ៉ាងម៉េច ?

*ណាកា* លុតជង្គង់អោនខ្លួនគោរពនៅក្បែរសេះរបស់ខ្លួន :



www.budinst.gov.kh www.elibraryofcambodia.org

- លោកពុកពិតជាយល់ត្រូវមែន..... ពីអ្វីដែលពុកនិយាយពីខ្ញុំនេះ ។ ខ្ញុំសូមទោសដែលបានធ្វើអោយពុកខឹង ។

- តែមិនមែនរឿងអោយយោបល់ខុសមកពុកទេអ្វី ?

- ខ្ញុំ.....ខ្ញុំសូមពុកអោយខ្ញុំទៅនៅជាមួយអ្នកណាដែលអាចបង្ហាត់បង្ហាញខ្ញុំបាន ដើម្បីថ្ងៃក្រោយខ្ញុំមិនធ្វើបែបនេះទៀត ។ ខ្ញុំមិនដែលមានបំនងជូនយោបល់មិនល្អទៅពុកទេ ។

- ល្អ ។ ជារៀងរាល់ថ្ងៃ ឯងត្រូវចំនាយពេលមួយភាគរបស់ឯងដើម្បីនិយាយជាមួយ *អាន់ជីន - សាន* ។ រៀនពីអ្វីដែលវាចេះ ព្រោះវានោះអាចជាគ្រូមួយក្នុងចំនោមគ្រូនានារបស់ឯងបាន ។

- *អាន់ជីន - សាន* ណឹង ?

- ណឹងហើយ ។ នេះអាចបង្រៀនឯងអោយមានវិន័យខ្លះ ។ ហើយបើសិនជាឯងអាចគាស់ដុំថ្មដែលនៅញ៉ុកត្រចៀកឯងចេញរួចដើម្បីស្តាប់បាននោះ ឯងច្បាស់ជាអាចរៀនបានអីខ្លះគ្រាន់មានប្រយោជន៍ដល់ខ្លួនឯងបាន ។ ហើយឯងអាចរហូតរៀនបានអ្វីផ្សេងទៀតដែលអាចមានប្រយោជន៍ដល់ពុកបានផងក៏មិនដឹង ។

*ណាកា* ឈ្ងោកមុខមើលដីទាំងមុខក្រញូវ ។

- ពុកចង់អោយឯងចេះទាំងអស់នូវចំនេះទាំងប៉ុន្មានដែល *អាន់ជីន - សាន* មានពីរឿងកាំភ្លើង ពីរឿងកាណុង និងពីរបៀបធ្វើសឹកសង្គ្រាម ។ ឯងនឹងក្លាយទៅជាអ្នកជំនាញការរបស់ពុក ។ មែនណា ។ ហើយពុកចង់អោយឯងជាអ្នកជំនាញការមួយដ៏ពូកែបំផុត ។

*ណាកា* នៅតែឥតនិយាយមួយម៉ាត់ ។

- ហើយពុកចង់អោយឯងក្លាយជាមិត្តជាមួយវា ។

- តើខ្ញុំធ្វើយ៉ាងម៉េចនឹងកើតទៅពុក ?

- ចុះហេតុអីក៏ឯងមិនរកមធ្យោបាយ ? ហេតុអីក៏ឯងមិនប្រើខួរក្បាលរបស់ឯង ?

- ខ្ញុំនឹងសាកល្បង ។ ខ្ញុំសូមសន្យាថានឹងសាកល្បង ។



www.budinst.gov.kh www.elibraryofcambodia.org

ដែរ ។ ភ្នែកពណ៌ត្នោតឥតមេត្តារបស់វាតាមសំលឹងមើល *តូរ៉ាំណាកា* ដែលចុះពីលើខ្នងសេះ ត្រចៀករបស់វាស្ដាប់សំដីសរសើរថ្មីៗរបស់លោក ។ ដោយតំលាន់ផង ដោយ *តូរ៉ាំណាកា* ជាអ្នកចិញ្ចឹមវាផង និងដោយលោកបានលុតជង្គង់ចុះយ៉ាងថ្នមឥតមានប្រើអាកប្បកិរិយាកញ្ឆក់កញ្ឆៀតណាមួយផងនោះ ស្ទាំងក៏នៅយ៉ាងស្ងៀមបណ្ដោយអោយលោកចូលជិតខ្លួនវាបាន ។

ដោយនៅតែពោលពាក្យលួងលោមយ៉ាងថ្នមៗដដែល *តូរ៉ាំណាកា* យកកាំបិតប្រមាញ់របស់លោកចេញមក ហើយពុះក្បាលមាន់ទោដើម្បីអោយស្ទាំងចឹកស៊ីខួររបស់វា ។ នៅពេលដែលស្ទាំងកំពុងចឹកស៊ីខួរ លោកក៏កាត់ក្បាលមាន់ទោទាំងមូលចេញ ហើយស្ទាំងនេះក៏បានឡើងមកទំយ៉ាងស្រួលនៅលើដៃរបស់លោក ដែលជាកន្លែងវាធ្លាប់ទំស៊ីចំណីនេះ ។

ដោយឃើញស្ទាំងហោះប្រមាញ់យ៉ាងល្អបែបនេះ *តូរ៉ាំណាកា* សំរេចថា ទុកអោយវានៅស៊ីចំណីបន្តទៅចុះ មិនចាំបាច់ប្រើវាអោយដេញសត្វទៀតទេ ។ លោកបោចស្លាបខ្មោចសត្វស្លាបតូចសំរាប់ជានុយនោះ ហើយវះវាយ៉ាងស្រួលបួល រួចទើបហុចទៅអោយស្ទាំង ។ នៅពេលដែលស្ទាំងស៊ីបានពាក់កណ្ដាលហើយនោះ ទើបលោកយកក្រណាត់គ្របមុខវាឡើងវិញ តែប្រការនេះមិនបានរំខានវាក្នុងការបន្តចឹកស៊ីចំណីនោះទេ ។ នៅពេលដែលវាស៊ីឆ្អែតហើយចាប់ផ្ដើមច្បូតស្លាបរបស់ខ្លួនហើយនោះ ទើបលោកហុចមាន់ទោទៅអោយអ្នកថែស្ទាំងរបស់លោកដែលកំពុងឈររង់ចាំលោកជាមួយពួកក្មេងសត្វឯទៀតៗ ។ ផលប្រមាញ់ពេលនេះ មានទន្សាយមួយ ក្រួចមួយគូ ហើយនឹងមាន់ទោ ។ *តូរ៉ាំណាកា* ប្រាប់អោយអ្នកថែស្ទាំង និងពួកក្មេងសត្វទាំងប៉ុន្មានវិលត្រលប់ទៅជំរំវិញ ដោយនាំយកស្ទាំងទាំងអស់ទៅជាមួយផង ។ ពួកការពាររបស់លោកនៅរង់ចាំខាងក្រោមខ្យល់ ។

មកដល់ពេលនេះ ទើបលោកផ្ដោតការយកចិត្តទុកដាក់របស់លោកទៅលើ *ណាកា* វិញម្ដង :

- រួចយ៉ាងម៉េច ?

*ណាកា* លុតជង្គង់អោនខ្លួនគោរពនៅក្បែរសេះរបស់ខ្លួន :



www.budinst.gov.kh www.elibraryofcambodia.org

- លោកពុកពិតជាយល់ត្រូវមែន..... ពីអ្វីដែលពុកនិយាយពីខ្ញុំនេះ ។ ខ្ញុំសូមទោសដែលបានធ្វើអោយពុកខឹង ។

- តែមិនមែនរឿងអោយយោបល់ខុសមកពុកទេអី្វ ?

- ខ្ញុំ.....ខ្ញុំសូមពុកអោយខ្ញុំទៅនៅជាមួយអ្នកណាដែលអាចបង្ហាត់បង្ហាញខ្ញុំបាន ដើម្បីថ្ងៃក្រោយខ្ញុំមិនធ្វើបែបនេះទៀត ។ ខ្ញុំមិនដែលមានបំនងជូនយោបល់មិនល្អទៅពុកទេ ។

- ល្អ ។ ជារៀងរាល់ថ្ងៃ ឯងត្រូវចំនាយពេលមួយភាគរបស់ឯងដើម្បីនិយាយជាមួយ *អាន់ជីន - សាន* ។ រៀនពីអ្វីដែលវាចេះ ព្រោះវានោះអាចជាគ្រូមួយក្នុងចំនោមគ្រូនានារបស់ឯងបាន ។

- *អាន់ជីន - សាន* ណឹង ?

- ណឹងហើយ ។ នេះអាចបង្រៀនឯងអោយមានវិន័យខ្លះ ។ ហើយបើសិនជាឯងអាចគាស់ដុំថ្មដែលនៅញ៉ុកត្រចៀកឯងចេញរួចដើម្បីស្តាប់បាននោះ ឯងច្បាស់ជាអាចរៀនបានអីខ្លះគ្រាន់មានប្រយោជន៍ដល់ខ្លួនឯងបាន ។ ហើយឯងអាចរហូតរៀនបានអ្វីផ្សេងទៀតដែលអាចមានប្រយោជន៍ដល់ពុកបានផងក៏មិនដឹង ។

*ណាកា* ឈ្ងោកមុខមើលដីទាំងមុខក្រញូវ ។

- ពុកចង់អោយឯងចេះទាំងអស់នូវចំនេះទាំងប៉ុន្មានដែល *អាន់ជីន - សាន* មានពីរឿងកាំភ្លើង ពីរឿងកាណុង និងពីរបៀបធ្វើសឹកសង្គ្រាម ។ ឯងនឹងក្លាយទៅជាអ្នកជំនាញការរបស់ពុក ។ មែនណា ។ ហើយពុកចង់អោយឯងជាអ្នកជំនាញការមួយដ៏ពូកែបំផុត ។

*ណាកា* នៅតែឥតនិយាយមួយម៉ាត់ ។

- ហើយពុកចង់អោយឯងក្លាយជាមិត្តជាមួយវា ។

- តើខ្ញុំធ្វើយ៉ាងម៉េចនឹងកើតទៅពុក ?

- ចុះហេតុអីក៏ឯងមិនរកមធ្យោបាយ ? ហេតុអីក៏ឯងមិនប្រើខួរក្បាលរបស់ឯង ?

- ខ្ញុំនឹងសាកល្បង ។ ខ្ញុំសូមសន្យាថានឹងសាកល្បង ។



www.budinst.gov.kh www.elibraryofcambodia.org

- ពុកចង់អោយឯងធ្វើបានប្រសើរជាងនេះ ។ ពុកដាក់បញ្ជាអោយឯងត្រូវតែធ្វើអោយបានសំរេច ។ ប្រើ " សប្បុរសធម៌គ្រិស្ត " ខ្លះទៅណា ។ ឯងប្រហែលជារៀនរឿងនេះច្រើនគួរសមហើយដែរតើ *ទេ ?*

*ណាកា* ធ្វើមុខឡើងច្របូញ :

- អានេះរៀនមិនចេះតែម្តង ទោះជាខ្ញុំប្រឹងយ៉ាងណាក៏ដោយ ។ ហើយនេះជាការពិតណាពុក ។ ពួក *ល្វូក្វ - សាន* ហាឡើងតែរឿងធម៌ រឿងអត់ន័យឆ្កួតៗ បុរសណាក៏ដោយក៏ត្រូវតែក្លួតដែរ ។ គ្រិស្តសាសនា គឺសំរាប់តែពួកសំរែទេ មិនមែនសំរាប់ *សាមូរ៉ៃ* ឡើយ ។ កុំសំលាប់ កុំយកប្រពន្ធលើសពីមួយ ហើយនៅមានរឿងពក្លីពក្លើរាប់សិបទៀត ! ខ្ញុំបានគោរពតាមបញ្ជារបស់ពុកនៅពេលនោះ ហើយខ្ញុំនឹងគោរពតាមបញ្ជាពុកនៅពេលនេះទៀត..... ខ្ញុំគោរពតាមបញ្ជាពុកជានិច្ច ! ហេតុអីក៏ពុកមិនទុកអោយខ្ញុំធ្វើអ្វីដែលខ្ញុំអាចធ្វើបានផង ? ខ្ញុំអាចក្លាយជាគ្រិស្តសាសនិកបាន បើសិននេះជាបំណងប្រាថ្នារបស់ពុក តែខ្ញុំមិនជឿសាសនានេះបានទេ ។ ព្រោះនេះជា.... ជាអាច់តែម្តង ហើយ..... អោយខ្ញុំសូមទោសដែលពោលពាក្យយ៉ាងដូចនេះ ។ ខ្ញុំនឹងក្លាយជាមិត្តរបស់ *អាន់ជីន - សាន* ។ ខ្ញុំពិតជាធ្វើបាន ។

- ល្អ ។ ហើយឯងត្រូវចាំថា វាមានតំលៃពីរម៉ឺនដងនៃទំងន់ខ្លួនវាគិតជាសូត្រសុទ្ធ ហើយវាមានចំនេះដឹងជាងឯងម្តេជាតិទៅទៀត ។

*ណាកា* ប្រឹងទប់ចិត្ត ហើយងក់ក្បាលយល់ស្របយ៉ាងគោរព ។

- ល្អ ។ ឯងទទួលដឹកនាំកងពីរកង ។ *អូមី - សាន* ដឹកនាំពីរដែរ ឯទ័ពមួយកងទៀតដែលទុកបំរុងត្រូវនៅជាមួយ *ប៊ុនតារ៉ូ* ។

- ចុះបួនកងទៀត ?

- យើងគ្មានកាំភ្លើងគ្រប់គ្រាន់សំរាប់ពួកវាទេ ។ នេះគ្រាន់តែជាល្បិចដើម្បីបំភាន់ *យ៉ាប៊ូ* ទេតើ ។

- ថាម៉េច ?

- នេះគ្រាន់តែជាលេស ដើម្បីបញ្ចូលទ័ពមួយពាន់នាក់មកថែមទៀតទេតើ ។



www.budinst.gov.kh www.elibraryofcambodia.org

ស្អែកមិនពូកនោះ មកដល់ទីនេះទេអ្វី ? មានទ័ពពីរពាន់នាក់ពុកអាចកាន់កាប់ *អាន់ជ៉ូ* និង គេចខ្លួនបានហើយបើសិនជាចាំបាច់ ។ *ទេ ?*

- តែ *យ៉ាប៊ូ - សាន* នៅតែ.... -*ណាកា* ទប់មិនធ្វើអធិប្បាយវិញ ដោយដឹងថា គេពិតជានឹងធ្វើការវិនិច្ឆ័យភាន់ច្រលំមួយទៀតជាមិនខាន ។ គេនិយាយយ៉ាងជូរចត់- ហេតុអី បានជាខ្ញុំល្ងីល្ងើម្ល៉េះ ? ម៉េចបានជាខ្ញុំមើលរឿងអី១ មិនដូចពុក ? រឺមិនដូច *ស៊ូម៉ា - សាន* អីចឹង ? ខ្ញុំចង់ជួយមួយដៃមួយជើង ចង់អោយមានប្រយោជន៍ដល់គេដល់ឯង ។ ខ្ញុំមិនចង់ធ្វើនាំអោយពុកមួម៉ៅគ្រប់ពេលអីចឹងទេ ។

- បើអីចឹងត្រូវរៀនអត់ធ្មត់ និងចេះសង្កត់ចិត្តឆេវឆាវរបស់ឯងអោយបាន ។ ពេលវេលារបស់ឯងនឹងមកដល់ក្នុងពេលឆាប់ៗ ខាងមុខនេះជាមិនខាន ។

- ពុកមានប្រសាសន៍ថាម៉េច ?

អីលូវនេះដល់ពេល *តូរ៉ាណាកា* ហត់នឿយនឹងភាពអត់ធ្មត់នេះម្តងហើយ ។ លោកងើយសំលឹងមើលមេឃ :

- ពុកគិតគេងមួយភ្លែតសិនហើយ ។

*ណាកា* ស្ទុះភ្លែតទៅដោះកែប និងកំរាលខ្នងសេះយកទៅក្រាលនៅលើដី ។ *តូរ៉ាណាកា* និយាយអរគុណកូន ហើយសំលឹងមើលកូនប្រុសខ្លួនចាត់ចែងដាក់អ្នកយាម ។ នៅពេលដែលឃើញថាអ្វី១បានត្រឹមត្រូវ និងមានសុវត្ថិភាពហើយ ទើបលោកទំរេតខ្លួនបិទភ្នែកទៅ ។

ប៉ុន្តែលោកមិនមែនចង់សំរានឯណា តាមពិតលោកចង់គិតត្រិះរិះពិចារណាទៅវិញទេ ។ លោកដឹងច្បាស់ណាស់ថា ការដែលលោកច្រលោតខឹងបែបនេះមិនមែនជាសញ្ញាល្អទេ ។ នេះជាសំនាងល្អហើយដែលអញច្រលោតខឹងតែនៅមុខ *ណាកា* តែម្នាក់ ហើយដែលមិនយល់ការអីទាំងអស់នោះ ។ បើសិនជាហេតុការណ៍អំបាញ់មិញកើតឡើងនៅក្បែរ *អូមី រឺ យ៉ាប៊ូ* វិញនេះ ពួកវាពិតជាដឹងភ្លាមថា ឯងស្ទើរឡប់សតិដោយកង្វល់ជាមិនខាន ។ ហើយបើពួកវាដឹងប៉ុននេះ អាចពួកវាងាយឈានទៅក្បត់ណាស់ ។ ឯងពិតជាហេងមែនលើក



www.budinst.gov.kh www.elibraryofcambodia.org

- ពុកចង់អោយឯងធ្វើបានប្រសើរជាងនេះ ។ ពុកដាក់បញ្ហាអោយឯងត្រូវតែធ្វើអោយបានសំរេច ។ ប្រើ " សប្បុរសធម៌គ្រិស្ត " ខ្លះទៅណា ។ ឯងប្រហែលជារៀនរឿងនេះច្រើនគួរសមហើយដែរតើ *នេ* ?

*ណាកា* ធ្វើមុខឡើងច្រមូញ :

- អានេះរៀនមិនចេះតែម្តង ទោះជាខ្ញុំប្រឹងយ៉ាងណាក៏ដោយ ។ ហើយនេះជាការពិតណាពុក ។ ពូក *ល្ហុត - សាន* ហាឡើងតែរឿងធម៌ រឿងអត់ន័យឆ្កួតៗ បុរសណាក៏ដោយក៏ត្រូវតែក្អួតដែរ ។ គ្រិស្តសាសនា គឺសំរាប់តែពួកសំរែទេ មិនមែនសំរាប់ *សាមូរ៉ៃ* ឡើយ ។ កុំសំលាប់ កុំយកប្រពន្ធលើសពីមួយ ហើយនៅមានរឿងពក្លីពក្លើរាប់សិបទៀត ! ខ្ញុំបានគោរពតាមបញ្ជារបស់ពុកនៅពេលនោះ ហើយខ្ញុំនឹងគោរពតាមបញ្ជាពុកនៅពេលនេះទៀត..... ខ្ញុំគោរពតាមបញ្ជាពុកជានិច្ច ! ហេតុអីក៏ពុកមិនទុកអោយខ្ញុំធ្វើអ្វីដែលខ្ញុំអាចធ្វើបានផង ? ខ្ញុំអាចក្លាយជាគ្រិស្តសាសនិកបាន បើសិននេះជាបំនងប្រាថ្នារបស់ពុក តែខ្ញុំមិនជឿសាសនានេះបានទេ ។ ព្រោះនេះជា.... ជាអាច់តែម្តង ហើយ..... អោយខ្ញុំសូមទោសដែលពោលពាក្យយ៉ាងដូចនេះ ។ ខ្ញុំនឹងក្លាយជាមិត្តរបស់ *អាន់ជីន - សាន* ។ ខ្ញុំពិតជាធ្វើបាន ។

- ល្អ ។ ហើយឯងត្រូវចាំថា វាមានតំលៃពីរម៉ឺនដងនៃទំងន់ខ្លួនវាគិតជាថ្លឹងជាសុទ្ធ ហើយវាមានចំនេះដឹងជាងឯងម្តែជាតិទៅទៀត ។

*ណាកា* ប្រឹងទប់ចិត្ត ហើយងក់ក្បាលយល់ស្របយ៉ាងគោរព ។

- ល្អ ។ ឯងទទួលដឹកនាំកងពីរកង ។ *អូមី - សាន* ដឹកនាំពីរដែរ ឯទ័ពមួយកងទៀតដែលទុកបំរុងត្រូវនៅជាមួយ *ប៊ុនតារ៉ូ* ។

- ចុះបូនកងទៀត ?

- យើងគ្មានកាំភ្លើងគ្រប់គ្រាន់សំរាប់ពួកវាទេ ។ នេះគ្រាន់តែជាល្បិចដើម្បីបំភាន់ *យ៉ាប៊ូ* ទេតើ ។

- ថាម៉េច ?

- នេះគ្រាន់តែជាលេស ដើម្បីបញ្ចូលទ័ពមួយពាន់នាក់មកថែមទៀតទេតើ ។



www.budinst.gov.kh www.elibraryofcambodia.org

ស្អែកមិនពូកនោះ មកដល់ទីនេះទេអ្វី ? មានទ័ពពីរពាន់នាក់ពុកអាចកាន់កាប់ *អាន់ជឺរ* និង
គេចខ្លួនបានហើយបើសិនជាចាំបាច់ ។ *ទេ ?*

- តែ *យ៉ាថ៊ូ - សាន* នៅតែ.... -*ណាកា* ទប់មិនធ្វើអធិប្បាយវិញ ដោយដឹងថា គេ
ពិតជានឹងធ្វើការវិនិច្ឆ័យភាន់ច្រលំមួយទៀតជាមិនខាន ។ គេនិយាយយ៉ាងជូរចត់- ហេតុអី
បានជាខ្ញុំល្ងីល្ងើម្ល៉េះ ? ម៉េចបានជាខ្ញុំមើលរឿងអី១ មិនដូចពុក ? រឺមិនដូច *ស៊ូហ្គា - សាន*
អីចឹង ? ខ្ញុំចង់ជួយមួយដៃមួយជើង ចង់អោយមានប្រយោជន៍ដល់គេដល់ឯង ។ ខ្ញុំមិនចង់
ធ្វើនាំអោយពុកមួម៉ៅគ្រប់ពេលអីចឹងទេ ។

- បើអីចឹងត្រូវរៀនអត់ធ្មត់ និងចេះសង្កត់ចិត្តឆេវឆាវរបស់ឯងអោយបាន ។
ពេលវេលារបស់ឯងនឹងមកដល់ក្នុងពេលឆាប់១ ខាងមុខនេះជាមិនខាន ។

- ពុកមានប្រសាសន៍ថាម៉េច ?

អីលូវនេះដល់ពេល *តូរ៉ាណាកា* ហត់នឿយនឹងភាពអត់ធ្មត់នេះម្តងហើយ ។ លោក
ងើយសំលឹងមើលមេឃ :

- ពុកគិតគេងមួយភ្លែតសិនហើយ ។

*ណាកា* ស្ទុះភ្លែតទៅដោះកែប និងកំរាលខ្នងសេះយកទៅក្រាលនៅលើដី ។ *តូរ៉ា
ណាកា* និយាយអរគុណកូន ហើយសំលឹងមើលកូនប្រុសខ្លួនចាត់ចែងដាក់អ្នកយាម ។ នៅ
ពេលដែលឃើញថាអ្វី១បានត្រឹមត្រូវ និងមានសុវត្ថិភាពហើយ ទើបលោកទំរេតខ្លួនបិទភ្នែក
ទៅ ។

ប៉ុន្តែលោកមិនមែនចង់សំរានឯណា តាមពិតលោកចង់គិតត្រិះរិះពិចារណាទៅវិញ
ទេ ។ លោកដឹងច្បាស់ណាស់ថា ការដែលលោកច្រលោតខឹងបែបនេះមិនមែនជាសញ្ញាល្អ
ទេ ។ នេះជាសំនាងល្អហើយដែលអញច្រលោតខឹងតែនៅមុខ *ណាកា* តែម្នាក់ ហើយដែល
មិនយល់ការអីទាំងអស់នោះ ។ បើសិនជាហេតុការណ៍អំបាញ់មិញកើតឡើងនៅក្បែរ *អូមី* រឺ
*យ៉ាប៊ូ* វិញនេះ ពួកវាពិតជាដឹងភ្លាមថា ឯងស្ទើរឡប់សតិដោយកង្វល់ជាមិនខាន ។ ហើយ
បើពួកវាដឹងប៉ុននេះ អាចពួកវាងាយឈានទៅក្បត់ណាស់ ។ ឯងពិតជាហេងមែនលើក



www.budinst.gov.kh www.elibraryofcambodia.org

នេះ ។ *គេល្មូក* បានធ្វើអោយអ្វីៗស្ថិតនៅក្នុងខ្នាតរបស់វាវិញ ។ ការហោះហើររបស់វា កន្លងនេះចំជាល្អមែន ! ត្រូវរៀនសូត្រពីស្ទាំងនេះ : ត្រូវចាត់ទុក *ណាកា* ដូចជាស្ទាំង អីចឹង ។ បញ្ហាតែមួយរបស់ *ណាកា* គឺវាត្រូវបានគេបង្ហោះក្នុងល្បែងដ៏ខុសឆ្គងមួយតែប៉ុន នោះ ។

ភាពកង្វល់បានមកលុកលុយលោកជាថ្មី ។ តើមានរឿងអីខ្លះនៅ *អូសាកា* ? អញ បានគន់គួរខុសតែម្តងពីរឿងពួក *វ៉ៃមីញ៉ូ* ទាំងនេះ - ពីអ្នកដែលទទួលនិងមិនទទួលការកោះ ហៅនេះ ។ ហេតុអីបានជាអញមិនបានលឺរឿងនេះជាមុន ? តើមានគេក្បត់អញទេដឹង ? មានគ្រោះថ្នាក់ច្រើនណាស់នៅជុំវិញខ្លួនអញ......

រួចចុះ *អាន់ជីន - សាន* វិញ ? វាក៏ជាស្ទាំងមួយដែរ ។ តែវាមិនទាន់សាំងដូច *យ៉ាប៊ូ* និង *ម៉ារីកូ* អះអាងនោះទេ ។ តើស្អីទៅដែលជាមុខសញ្ញារបស់វា ? មុខសញ្ញា របស់វា គឺ *សំពៅខ្មៅ* និង *រ៉ូឌ្រិច - អាន់ជីន* ហើយនឹងមេបញ្ជាការដ៏អាក្រក់ និងដ៏គោងកាច ដែលរស់នៅលើភពផែនដីនេះមិនបានយូរពេលទៀតទេ ព្រមទាំងពួកបព្វជិតស្បង់ខ្មៅ និង ពួកបព្វជិតសំអុយទាំងអស់ ពួកប៉កទុយកាល់និងអេស្ប៉ាញ ពួកតូកម៉េន[១] ពួកកាន់សាស នាអ៊ីស្លាម ហើយក៏មិនត្រូវភ្លេច *អូមី . យ៉ាប៊ូ . ប៊ុនតារ៉ូ . អ៊ីស៊ីដូ* និងរូបអញផងដែរទេ ។

*តូរ៉ាណាកា* ប្រែត្រលប់ខ្លួនទៅម្ខាងទៀតដើម្បីសំរួលអង្គប្រាណ ហើយញញឹមតែ ម្នាក់ឯង ។ តែ *អាន់ជីន - សាន* មិនមែនជាប្រភេទស្ទាំងស្លាបវែងនោះទេ ។ វាជា ប្រភេទស្ទាំងវាយលុកដែលគេប្រើវាអោយទៅសំលាប់គ្រប់អ្វីៗដែលមានចលនា ។ ជាប្រភេទ ស្ទាំងដែលសំលាប់ទទា វីទទ្បាយដែលមានមាឌធំជាងវាបីដង រីក៏ឆ្មា ឆ្កែ កណ្តុរ មាន់ព្រៃ ដោយកំលាំងក្រញ៉ាំជើងដ៏ខ្លាំងក្លារបស់វា ។ ជាប្រភេទស្ទាំងដែលស្អប់ក្រណាត់ ឃ្លុំមុខហើយ ដែលមិនព្រមអោយគេឃ្លុំមុខ តែដោយគ្រាន់តែទំលើដៃឯងយ៉ាងពើងឡូង យ៉ាងគ្រោះថ្នាក់ យ៉ាងគ្រប់គ្រាន់ និងគ្មានមេត្តា ជាមិត្តដ៏ល្អ និងបើមួម៉ៅវិញពិតជាចុងរំសេវតែម្តង ។

---

*(១) ជនជាតិតួគីមួយក្រុមដែលរស់ក្នុងតំបន់ តួមេនី អ៊ូស្បេគីស្ថាន និង អ៊ីរ៉ង់ សព្វថ្ងៃនេះ*



www.budinst.gov.kh www.elibraryofcambodia.org

ពិតហើយ *អាន់ជីន - សាន* ជាស្នាំងស្លាបខ្ចី ។ តើអញត្រូវព្រលែងវាទៅចិកអ្នកណាគេហ្ន៎ ?

*អូមី ?* មិនទាន់ដល់ពេលទេ ។

*យ៉ាប៊ូ ?* ក៏មិនទាន់ដែរ ។

*ប៊ុនតារ៉ូ ?*

ហេតុអីបាន *អាន់ជីន -សាន* ទៅរក *ប៊ុនតារ៉ូ* ដោយកាន់ទាំងកាំភ្លើងទៅជាមួយយ៉ាងដូចនេះ ? ពិតជាមកពីរឿង *ម៉ារីកូ* តែម្តង ។ តែតើពីរនាក់មានបានរួមខ្នើយជាមួយគ្នារឺអត់ ? ពួកគេមានឱកាសយ៉ាងគ្រប់គ្រាន់ ។ អញយល់ថា ពួកវាទាំងពីរនាក់ពិតជាបានរួមខ្នើយជាមួយគ្នា ។

មិននាងនិយាយនៅថ្ងៃដំបូងថា " ហ៎ " វីអី ? ល្អ ។ គ្មានរឿងអីខុសទេចំពោះដែលវាទាំងពីរនាក់រួមខ្នើយគ្នា ព្រោះកាលនោះអ្នកណាក៏នឹកស្មានថា *ប៊ុនតារ៉ូ* ស្លាប់ដែរ ហើយម្យ៉ាងទៀតអោយតែរឿងនេះគ្មានអ្នកណាដឹងជារៀងរហូត ។ តែ *អាន់ជីន - សាន* ចំជាល្ងិល្ងើមែនដែលប្រថុយប្រថានជាមួយស្រីរបស់អ្នកដទៃបែបនេះ ។ ទៅខ្វះអីស្រីរាប់ពាន់នាក់ដែលទំនេរ គ្មានជំពាក់វាសនា ស្អាតដូចគ្នា មានតូចមានធំ មានច្រលឹង មានថ្នាក់ទាប មានថ្នាក់ខ្ពស់ ហើយមិនរវល់ជាប់កម្មសិទ្ធិអ្នកណាទេផង ? តែគាត់នេះធ្វើល្ងិល្ងើបែបពួកអ្នកចុងស្រុកមែន ។ មិនតឺអា *រ៉ូឌ្រិច - អាន់ជីន* ហៅគេប្រកួតហើយសំលាប់អាអ្នកចុងស្រុកម្នាក់ទៀតដើម្បីគ្រាន់តែចង់បានកូនស្រីឈ្មួញថ្នាក់ទាបម្នាក់យកទៅរៀបការនៅឯ *ណាកាសាគី* ទេអ្វី ? មិនតឺលោកម្ចាស់ *តែកូ* មិនបានស្តាប់តាមមតិអញ ហើយបានយល់ព្រមមិនអោយមានការសងសឹកលើការ សំលាប់គ្នានេះ ព្រោះនេះជាទំលាប់ពួកអ្នកចុងស្រុកផង ហើយដោយអ្នកស្លាប់ជាពួកអ្នកចុងស្រុកផងទៀត ? ចំជាភ្លីពភ្លើមែន ដែលមានច្បាប់ពីរ មួយសំរាប់ពួកយើងមួយសំរាប់ពួកគេដូចនេះ ។ ច្បាប់គួរមានតែមួយ ។ ច្បាប់ត្រូវតែមានតែមួយ ។

ទេ អញមិនព្រលែង *អាន់ជីន - សាន* ដាក់ *ប៊ុនតារ៉ូ* ទេ ។ អញត្រូវការអាចំកួត



www.budinst.gov.kh www.elibraryofcambodia.org

ណឹង ។ តែទោះជាពួកវារួមខ្ញើយរីអត់ អញសង្ស័យថា គំនិតនេះនឹងមិនកើតមាននៅក្នុងចិត្ត *ប៊ុនតារ៉ូ* ជាដាច់ខាត ។ ព្រោះបើមិនអីចឹងទេ អញត្រូវតែសំលាប់ *ប៊ុនតារ៉ូ* យ៉ាងលឿនបំផុត ព្រោះគ្មានអីក្រោមមេឃលើដីនេះ ដែលអាចឃាត់វាមិនអោយសំលាប់ *អាន់ជីន - សាន* និង *មារីកូ* បានទេ ។ ហើយអញត្រូវការពួកវាទាំងពីរនាក់នេះច្រើនជាងត្រូវការ *ប៊ុនតារ៉ូ* ។ តើអញគួរកំចាត់ *ប៊ុនតារ៉ូ* អីលូវនេះតែម្តងទៅអ្វី ?

នៅពេលដែល *ប៊ុនតារ៉ូ* ស្ងាងស្រាបន្តិចហើយនោះ *តូរ៉ាណាកា* បានបញ្ជាអោយគេទៅហៅបុរសនេះមក :

- លោកថ្លើមធំមែនដែលហ៊ានដាក់ផលប្រយោជន៍លោកធំជាងផលប្រយោជន៍ខ្ញុំយ៉ាងនេះ ! តើ *ម៉ារីកូ* ត្រូវខានបករប្រែអោយខ្ញុំប៉ុន្មានថ្ងៃទៅ ?

- គ្រូពេទ្យថានាងត្រូវការពីរបីថ្ងៃទាន ។ ខ្ញុំសូមទោសដែលបានបង្ករឿងរ៉ាវអស់ទាំងនេះឡើង ។

- ខ្ញុំបានបញ្ជាក់ច្បាស់ណាស់ថា ខ្ញុំត្រូវការនាងជួយខ្ញុំម្តៃថ្ងៃទៀត ។ ក្រែងលោកចាំដែរអ្វី ?

- បាទ ចាំ ។ អោយខ្ញុំសូមទោសទាន ។

- បើនាងធ្វើអោយលោកមិនសប្បាយចិត្ត ទះកំប៉េះគូថប៉ុន្មានដៃទៅវាគ្រប់គ្រាន់ណាស់ទៅហើយ ។ ស្រី១យូរ១ទាល់តែប្រដៅម្តង តែខ្លាំងលើសនេះគឺវាបាតផ្សារពេកហើយ ។ អត្តទត្តបុគ្គលលោកបានធ្វើអោយមានគ្រោះថ្នាក់ដល់ការរឹកបាត់ ហើយធ្វើអោយលោកល្ងង់ដូចគោតែម្តង ។ គ្មាននាង ខ្ញុំមិនអាចនិយាយជាមួយ *អាន់ជីន - សាន* បានទេ !

- បាទ ខ្ញុំដឹងហើយទាន ។ ខ្ញុំសូមទោស ។ នេះជាលើកទីមួយហើយដែលខ្ញុំវាយនាង ។ នេះគ្រាន់..... ជូនកាលនាងធ្វើអោយខ្ញុំឡប់សតិតែម្តង ដែលធ្វើ.....ធ្វើអោយខ្ញុំលែងដឹងទិសតំបន់អីតែម្តង ។

- បើអីចឹង ម៉េចក៏មិនលែងនាងទៅ ? រឺបញ្ជូននាងទៅឆ្ងាយទៅ ? រឺក៏សំលាប់នាងចោលទៅ រឺក៏បញ្ជាអោយនាងអារកខ្លួនឯងនៅពេលណាដែលខ្ញុំលែងត្រូវការប្រើនាង



www.budinst.gov.kh www.elibraryofcambodia.org

ហើយនោះទៅ ?

- ខ្ញុំទៅមិនរួច ! ខ្ញុំទៅមិនរួចទេលោកម្ចាស់ ។ នាង...ខ្ញុំស្រលាញ់នាងតាំងពីឃើញនាងដំបូងភ្លាមម្ល៉េះ ។ នៅពេលដែលយើងរៀបការហើយ នាងគឺជាអ្វីសព្វយ៉ាងដែលបុរសគ្រប់រូបចង់បាន ។ ខ្ញុំតែងគិតថា ខ្ញុំជាបុរសមានសំនាងណាស់ ។ លោកចាំបានទេ ថាតើ ពួក *ដៃមីញ៉ូ* មួយណាក្នុងមួយនគរនេះដែលថាមិនចង់បាននាង ? រួច...រួចខ្ញុំត្រូវបំបរបង់នាងដើម្បីការពារនាងបន្ទាប់ពីមានរឿងអំពើក្បត់ដ៏អាស្រូវនោះមក ដោយយកលេសប្រាប់គេឯងថា ខ្ញុំស្អប់ខ្ពើមរូបនាង ។ រួចនៅពេលដែលលោកម្ចាស់ *រ៉ែកូ* ប្រាប់ខ្ញុំអោយនាំនាងមកវិញក្រោយប៉ុន្មានឆ្នាំហើយនោះ នាងរឹតតែធ្វើអោយខ្ញុំត្រេកត្រអាលកាន់តែខ្លាំងក្លាថែមទៀត ។ ការពិតទៅ ខ្ញុំគិតថា នាងត្រូវតែដឹងគុណខ្ញុំ ហើយខ្ញុំក៏ទុកនាងដូចជារបស់បំរើឆន្ទៈបុរសតែប៉ុននោះ ដោយលែងរវីរវល់ពីរឿងតូចតាចខ្លះដែលស្ត្រីរមែងចង់បាន ដូចជាកំនាព្យ និងផ្កាជាដើមទៀត ។ តែនាងបានប្រែប្រួលទៅហើយ ។ នាងនៅតែមានភក្តីភាពនឹងខ្ញុំដូចធម្មតា តែនាងគឺជាដុំទឹកកកតែប៉ុននោះ ហើយនាងតែងទាមទារសុំស្លាប់ រឺក៏សុំអោយខ្ញុំសំលាប់នាងចោល - *ប៊ុនកា្វ* ឡើងរចល់ - ខ្ញុំមិនអាចសំលាប់នាងបានទេ ។ នាងបានធ្វើអោយ កូនប្រុសខ្ញុំអសោចឈ្មោះ នាងធ្វើអោយខ្ញុំស្អប់ស្រី១ឯទៀត តែខ្ញុំមិនអាចដកខ្លួនចេញពីនាងបានទេ ។ ខ្ញុំ...ខ្ញុំបានប្រឹងធ្វើល្អជាមួយនាង តែនោះគឺជាទឹកកករហូត ហើយប្រការនេះហើយដែលធ្វើអោយខ្ញុំឡប់ម្តង១នោះ......

ទឹកភ្នែកនៃកំហឹងបានហូរកាត់ថ្ពាល់ *ប៊ុនកា្វ* ។ បុរសនេះបន្ត :

- ខ្ញុំមិនអាចសំលាប់នាងបានទេ ទោះជាខ្ញុំចង់យ៉ាងណាក្តី ។ ខ្ញុំមិនអាចសំលាប់កូនស្រីរបស់ *អាកេស៊ី ជីនសៃ* បានទេ ទោះជានាងសមស្លាប់យ៉ាងណាក៏ដោយ......

*តូរ៉ាណាកា* នៅស្តាប់ *ប៊ុនកា្វ* និយាយបួរបាច់ទាល់តែអស់កំលាំង ទើបលោកបញ្ជាអោយចេញទៅវិញ ដោយដាក់កំហិតមិនអោយមនុស្សនេះទៅជិត *ម៉ារីកូ* រហូតដល់លោកសំរេចចិត្តសាជាថ្មី ។ លោកបានបញ្ជាអោយគ្រូពេទ្យផ្ទាល់ខ្លួនរបស់លោកទៅពិនិត្យ *ម៉ារីកូ* ហើយរបាយការណ៍គ្រូពេទ្យមិនគួរអោយព្រួយបារម្ភណាស់ណាទេ ដោយនាងមិនមានរបួស



www.budinst.gov.kh www.elibraryofcambodia.org

ដល់គ្រឿងក្នុងណាមួយឡើយ ។

ដើម្បីសុវត្ថិភាពរបស់ខ្លួនលោកផ្ទាល់ ដោយលោកគិតថា នឹងអាចមានអំពើក្បត់ណាមួយអាចកើតឡើងផង និងដោយពេលវេលាកាន់តែខើចទៅហើយផង លោកបានសំរេចបង្កើនការគាបសង្កត់លើពួកគេទាំងអស់គ្នា ។ លោកបានបញ្ជាអោយ *ម៉ារីកូ* ទៅនៅឯផ្ទះ *អូមី* ដោយបញ្ជាអោយនាងសំរាកនៅតែក្នុងផ្ទះ ហើយមិនមានទាក់ទងអីទៀតជាមួយនឹង *អាន់ជីន - សាន* ។ បន្ទាប់មកលោកបានអោយគេទៅហៅ *អាន់ជីន - សាន* មកជួបហើយលោកធ្វើជាមូម៉ៅថា មិនអាចនិយាយជាមួយ *អាន់ជីន -សាន* បាន ហើយក៏បណ្តេញគេចេញមកវិញ ។ ការរឹតហាត់ទាំងឡាយត្រូវបានជំរុញកាន់តែខ្លាំងឡើងថែមទៀត ។ ពួកមេបញ្ជាការត្រូវបានបញ្ជូនចេញដើរបង្ហំ ដោយឥតសំរាកជាធម្មតាដូចសព្វមួយដងឡើយ ។ *ណាកា* ត្រូវបានទទួលបញ្ជាអោយនាំ *អាន់ជីន - សាន* ទៅជាមួយ ហើយនាំអោយដើរទាល់តែវារ ។ តែ *ណាកា* ឥតបានធ្វើអោយ *អាន់ជីន - សាន* វារឡើយ ។

ដោយហេតុនេះ លោកបានសំរេចសាកល្បងដោយផ្ទាល់ខ្លួនលោក ។ លោកបាននាំពួកកងទ័ពដើរកាត់កូនភ្នំទាំងឡាយក្នុងរយៈពេលដប់មួយម៉ោង ។ *អាន់ជីន - សាន* ទៅតែទ្រោលរួច ពិតមែនតែមិនបាននៅក្នុងជួរមុខក្តី តែគេបានទ្រោលរួច ។ នៅពេលទៅដល់ *អាន់ជ្ញ៉ូ* វិញ *អាន់ជីន - សាន* បាននិយាយស្ទើរស្តាប់មិនបានថា :

- *តូរ៉ាណាកា - សាម៉ា* ។ ខ្ញុំដើរអាច ។ ខ្ញុំកាំភ្លើងហាត់អាច ។ តែសូមទោសមិនអាចពីរក្នុងពេលតែមួយទេ *នេ ?*

អីលូវនេះ *តូរ៉ាណាកា* ញញឹមម្តង ។ ចិត្តរបស់លោកមានការពុះពារនឹងល្បែងផ្សាំង *ប្លាក់ថន* នេះជាពន់ពេក ។ពិតហើយ វាគឺជាស្ទាំងស្លាបខ្ចី ។ *ម៉ារីកូ* ក៏ខ្លាំងណាស់ដែរ មានប្រាជ្ញាដែរ តែនាងវាងវៃជាង ហើយមានភាពដាច់មេត្តាមួយដែល *អាន់ជីន - សាន* មិនមាន ។ នាងប្រៀបដូចជាស្ទាំងញី *គេឈ្មូកូ* អ៊ីចឹងដែរ ។ នាងគឺលើសគេ ។ តើហេតុអីបានជាស្ទាំងញីតែងតែមានមាឌធំជាង រហ័សជាង ខ្លាំងជាង និងគ្រាន់បើជាងស្ទាំងឈ្មោលជានិច្ច អីចឹង ?



www.budinst.gov.kh www.elibraryofcambodia.org

ពួកវាទាំងអស់គ្នាសុទ្ធតែជាស្ពាំង : *ម៉ារីកូ ប៊ុនតារ៉ូ យ៉ាប៊ូ អូមី កូជីកូ អូជីបា ណាកា* និងរាល់កូនប្រុស កូនស្រី និងប្រពន្ធទាំងប៉ុន្មានរបស់អញ ពួកអណ្តាប់និងសត្រូវទាំងឡាយរបស់អញ ។ ទាំងអស់នេះជាស្ពាំង រឺជាចំនីស្ពាំង ។

អញត្រូវតែអោយ *ណាកា* ហើរឡើងទីខ្ពស់ រួចទើបសំយុងឆាបយកតែម្តង ។ តើយកអ្នកណា ? *អូមី* រឺ *យ៉ាប៊ូ ?*

អ្វីដែល *ណាកា* បាននិយាយរ៉ាយរ៉ាប់ពី *យ៉ាប៊ូ* គឺត្រឹមត្រូវមែន ។

នៅថ្ងៃទីពីរលោកបានសួរទៅ *យ៉ាប៊ូ* ថា :

- បើអ៊ីចឹង *យ៉ាប៊ូ - សាន* តើលោកសំរេចយ៉ាងដូចម្តេច ?

- ខ្ញុំមិនទៅ *អូសាកា* ទេ នៅពេលណាដែលលោកមិនទៅ ។ ខ្ញុំបានចេញបញ្ជាអោយធ្វើការកេណ្ឌទ័ពមួយតំបន់ *អ៊ីស៊ូ* នេះហើយ ។

- *អ៊ីស៊ីដូ* នឹងផ្តន្ទាទោសលោកណា៎ ។

- គាត់នឹងផ្តន្ទាទោសលោកមុន ហើយបើ *ក្វាន់តូ* រស់ *អ៊ីស៊ូ* ក៏នឹងរស់ ។ ខ្ញុំបានធ្វើកិច្ចព្រមព្រៀងដ៏មហោឡារិកជាមួយលោកថា ខ្ញុំនៅខាងណា ។ ត្រកូល *កាស៊ិគី* រក្សាពាក្យសំដីរបស់ខ្លួនណាស់ ។

- ខ្ញុំក៏មានកិត្តិយសណាស់ដែរ ដែលបានលោកមកជាសព័ន្ធមិត្តនោះ ។

នោះគឺជាសំដីកុហករបស់លោក ។ លោកមានការពេញចិត្តយ៉ាងខ្លាំងដែលបានឃើញជាថ្មីម្តងទៀតថា *យ៉ាប៊ូ* បានធ្វើនូវអ្វីៗតាមគំរោងរបស់លោក ។ ថ្ងៃបន្ទាប់មក *យ៉ាប៊ូ* បានអញ្ជើញ *តូរ៉ាណាកា* ត្រួតពលរបស់ខ្លួន ហើយនៅពីមុខអ្នកទាំងនេះបានលុតជង្គង់ជាផ្លូវការសុំខ្លួនជាអណ្តាប់របស់លោកតែម្តង ។ ពេលនោះ *តូរ៉ាណាកា* បានសួរឡើង :

- លោកទទួលស្គាល់ខ្ញុំជាអម្ចាស់របស់លោករឺ ?

- បាទទាន ហើយជាមួយនឹងមនុស្សនៅតំបន់ *អ៊ីស៊ូ* នេះទាំងមូល ។ ហើយសូមលោកម្ចាស់ទទួលរបស់នេះជាចំនងដៃនៃភក្តីភាពទាន - ទាំងនៅក្នុងស្ថានភាពលុតជង្គង់ *យ៉ាប៊ូ* ប្រគល់ដាវ *មូរ៉ាសាម៉ា* របស់ខ្លួន - នេះគឺជាដាវដែលបានធ្វើឃាតជីតារបស់លោក



www.budinst.gov.kh www.elibraryofcambodia.org

ម្ចាស់ ។

- អានេះមិនកើតទេ ។

*យ៉ាប៊ូ* បាននិទានប្រាប់លោកពីប្រវត្តិដាវនេះ ពីហេតុបែបម៉េចដែលដាវនេះបានធ្លាក់មកលើដៃគេ ហើយដែលគេទើបដឹងពីប្រវត្តិពិតប្រាកដរបស់ដាវនេះ ។ លោកទទួលយកដាវ ហើយដាវនេះហាក់ដូចជាញាក់ទទ្រើតពោរពេញដោយភាពប្រទុស្តនៅក្នុងដៃរបស់លោក ។ លោកតែងតែចំអកចំពោះរឿងនិទានស្តីពីដាវខ្លះដែលស្រេកឈាម ហើយដែលថាមានដាវខ្លះលោតចេញពីស្រោមដើម្បីហុតឈាមទៀតផងនោះ តែនៅពេលនេះលោកជឿហើយ ។

លោកឡើងព្រឺខ្លួននៅពេលដែលលោករំលឹកឃើញថ្ងៃនោះ ។ ហេតុអីបានជាកាំបិត *មូរ៉ាំសាម៉ា* ស្អប់ពួកយើងម្ល៉េះ ? កាំបិតមួយបានសំលាប់ជីតាអញ ។ អាមួយទៀតរិះកាត់អញកំបុតដៃកាលពីអញនៅអាយុប្រាំមួយឆ្នាំ ។ កាលនោះ ចំជាគ្រោះថ្នាក់មួយរកពន្យល់មិនបាន ព្រោះគ្មានអ្នកណាម្នាក់នៅជិតអញសោះ តែដៃអញត្រូវរយះហូរឈាមស្ទើរខ្សោះខ្លួនស្លាប់ ។ ហើយកាំបិតទីបីបានកាត់កកូនប្រុសច្បងរបស់អញ ។

*យ៉ាប៊ូ* បាននិយាយថា :

- លោកម្ចាស់ កាំបិតចង្រៃយ៉ាងនេះមិនគួរទុកអោយមានជីវិតទេ *នេ ?* សូមលោកម្ចាស់អនុញ្ញាតអោយខ្ញុំយកវាទៅបោះចោលនៅឯសមុទ្រតែម្តងទៅ ដើម្បីកុំយ៉ាងហោចណាស់បានកាំបិតនេះមួយដែរ ដែលនឹងលែងជាគ្រោះតំរាមកំហែងដល់លោកម្ចាស់ រឺកូនចៅស្រករក្រោយរបស់លោកម្ចាស់ ។

- ណឹងហើយ....ណឹងហើយ -លោកនិយាយស្ទើរមិនចេញទាំងក្នុងចិត្តសែនដឹងគុណចំពោះ *យ៉ាប៊ូ* ដែលបានលើកគំនិតនេះឡើង - ចាត់ចែងធ្វើអីលូវណឹងភ្លាមទៅ !

ហើយនៅក្រោយពេលដែលដាវត្រូវបានលិចចុះបាត់ទៅក្នុងតំបន់ទឹកជ្រៅនៃសមុទ្រក្រោមក្រសែភ្នែកកូនចៅរបស់លោកហើយ ទើបបេះដូងរបស់លោកលោតជាប្រក្រតីឡើងវិញ ។ លោកបានអរគុណ *យ៉ាប៊ូ* សំរេចអោយពន្ធដារនៅថេរត្រឹមហុកសិបភាគរយសំរាប់



www.budinst.gov.kh www.elibraryofcambodia.org

កសិករ និងសែសិបភាគទៀតសំរាប់លោកម្ចាស់របស់ពួកគេ ហើយនឹងប្រគល់តំបន់ *អ៊ុស៊ូ* ជាដែនគ្រប់គ្រងរបស់ *យ៉ាហ្គិ* ។ ដល់អីចឹងទៅ អ្វីៗក៏បានស្ថិតនៅដូចដើម ខុសគ្នាតែថា រាល់អំនាចទាំងឡាយនៅ *អ៊ុស៊ូ* ស្ថិតនៅក្រោមកណ្ដាប់ដៃរបស់ *តូរ៉ាណាកា* វិញ បើសិនជាលោកចង់យកមកវិញនោះ ។

អីលូវនេះ ដាវនេះរលាយបាត់រូបជារៀងរហូតហើយ ។ លួមែនទែនតែម្ដង តែត្រូវចងចាំសំដីដែលគ្រូទាយចិនម្នាក់បាននិយាយប្រាប់ផង - លោកគិតនៅក្នុងចិត្ត ។ នោះគឺគ្រូទាយបាននិយាយថា : លោកត្រូវស្លាប់ដោយផ្លែដាវ ។ តែតើដោយដាវរបស់អ្នកណា ហើយតើអញស្លាប់ដោយដៃអញផ្ទាល់ រឺដៃអ្នកណាម្នាក់ទៀត ?

អញគង់តែដឹងនៅពេលដែលអញដឹង -លោកនិយាយគ្មានការភ័យខ្លាចនៅក្នុងចិត្ត ។

អីលូវនេះដេក ។ *កាម៉ា* ជា *កាម៉ា* ។

សំលេងស្រែកល្ហើយៗបានទាញលោកអោយចេញផុតពីការស្ញឹងស្មាធនេះ ។ លោកស្ទុះក្រោកឈរភ្លាម ។ *ណាកា* កំពុងចង្អុលយ៉ាងរន្ថាន់ទៅទិសខាងលិច ។ ទាំងអស់គ្នាសំឡឹងមើលតាមការចង្អុលរបស់ *ណាកា* ។

ព្រាបនាំសារមួយកំពុងហើរមកពីទិសខាងលិចតំរង់ទៅ *អាន់ជិរ៉ូ* ។ វាឈប់ទំសំរាកនៅលើដើមឈើមួយឆ្ងាយពីនេះ មួយស្របក់ទើបចាប់ផ្ដើមហើរបន្តទៅទៀត នៅពេលដែលភ្លៀងចាប់ផ្ដើមធ្លាក់ខ្សោកៗ ។

នៅឯឆ្ងាយនាទិសខាងលិចនោះ គឺ *អូសាកា* ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៣៧

អ្នកបំរើទទួលទ្រុងព្រាប កាន់ព្រាបយ៉ាងថ្នមនិងយ៉ាងណែនក្នុងពេលដែល *តូរ៉ាណាកា* ដោះសំលៀកបំពាក់ទទឹករបស់លោកចេញ ។ លោកបានបំបោលសេះត្រលប់មកវិញទាំងកាត់ភ្លៀងធ្លាក់ដូចគេចាក់ទឹក ។ *ណាកា* និងពួក *សាមូរ៉ៃ* ឯទៀតនៅចាំកកកុញឯមាត់ទ្វារដ៏តូចចង្អៀត ដោយឥតវិវរល់នឹងតំនក់ទឹកភ្លៀងដែលធ្លាក់ខ្វោក១លាន់រណ្ដំងំបូលគ្រឿងនោះឡើយ ។

យ៉ាងប្រុងប្រយ័ត្ន លោកសំងួតដៃរបស់លោកចេញ រួចទើបអ្នកថែព្រាបហុចព្រាបមកជូនលោក ។ បំពង់ប្រាក់តូច១ពីរត្រូវបានចងនឹងជើងព្រាបទាំងគូ ។ បើតាមធម្មតាគេប្រើតែបំពង់មួយទេ ។ *តូរ៉ាណាកា* ត្រូវប្រឹងប្រែងមែនទែនដើម្បីទប់ម្រាមដៃលោកកុំអោយញ័របាន ។ លោកស្រាយយកបំពង់ទាំងពីរ ហើយយកវាមកដាក់ក្រោមពន្លឺបង្គួច ដើម្បីពិនិត្យមើលស្លាមត្រាអាច់ល័ក្ត ។ លោកបានស្គាល់សញ្ញាសំងាត់របស់ *គីរី* ។ *ណាកា* ព្រមទាំងអ្នកឯទៀតនៅតែចាំតាមសង្កេតមើលយ៉ាងតឹងតែងជាទីបំផុត ប៉ុន្តែទឹកមុខរបស់លោកឥតមានបង្ហាញអ្វីបន្តិចណាសោះ ។

ទោះលោកអន្ទះអន្ទែងនៅក្នុងចិត្តយ៉ាងណាក៏ដោយ ក៏ *តូរ៉ាណាកា* ឥតបំបែកត្រាភ្ជិតសារនោះឡើយ ។ លោករង់ចាំយ៉ាងអត់ធ្មត់រហូតដល់គេយក *គីម៉ូណូ* ស្ងួតមួយសំរាប់មកជូនលោក ។ បន្ទាប់មកទើបលោកដើរទៅកាន់កន្លែងដែលលោកស្នាក់នៅក្នុងបន្ទាយដោយមានអ្នកបំរើម្នាក់បាំងឆត្រដ៏ធំទូលាយមួយជូនលោកផង ។ សំលហើយនឹងតែទៅរង់ចាំលោកជាស្រេចនៅទីនោះ ។ ក្រោយពីក្រេបសំលហើយនឹងតែរួចហើយ លោកនៅផ្ទៀងត្រចៀកស្ដាប់ស្នូរតំនក់ទឹកភ្លៀង លុះត្រាតែលោកមានអារម្មណ៍នឹងនៅក្នុងចិត្តហើយនោះទើបលោកចាត់ចែងដាក់អ្នកយាមអោយនៅប្រចាំការ ហើយលោកក៏ចូលទៅបន្ទប់ខាងក្នុងរបស់លោក ។ ពេលនៅក្នុងភាពស្ងប់ស្ងាត់តែម្នាក់ឯងហើយទើបលោកបំបែកត្រាភ្ជិតនោះចេញ ។ សារទាំងបួនរមូរធ្វើពីក្រដាសដ៏ស្តើងបំផុត អក្សរមានលក្ខណៈតូចឆ្មារ *សារវែង* ហើយសរសេរជាកូតសំងាត់ថែមទៀត ។ ដោះកូតសំងាត់នេះ គឺទាមទារការព្យាយាមមួយ ។



www.budinst.gov.kh www.elibraryofcambodia.org

នៅពេលដែលលោកដោះកូតចេញហើយលោកក៏អានសារ ហើយបន្ទាប់មកលោកអានវាឡើងវិញពីរដងទៀត ទើបលោកបណ្តោយអោយអារម្មណ៍របស់លោកអណ្តែតត្រសែតទៅ ។

រាត្រីកាលបានមកដល់ ។ ភ្លៀងក៏បានរាំងទៅហើយដែរ ។

- *ណាកា - សាន ! ណាកា - សាន !*

*ណាកា* រត់មកដល់ភ្លាម ៖

- បាទពុក ?

- ពេលភ្លឺល្អះ១ នាំ *យ៉ាប៊ូ - សាន* និង ទីប្រឹក្សាសំខាន់ៗរបស់គាត់ ទៅលើខ្ពង់រាប ។ នាំទាំង *ប៊ុនតារ៉ូ* និងមេទ័ពធំជាងគេបីនាក់របស់យើងទៅផង ។ ហើយ *ម៉ារីកូ - សាន* ក៏ដែរ ។ នាំពួកណឹងទាំងអស់ទៅលើខ្ពង់រាបនៅពេលភ្លឺ ។ អោយ *ម៉ារីកូ - សាន* ជាអ្នកជួយបំរើតែបានហើយ ។ អោយ *អាន់ជីន - សាន* ត្រៀមនៅឯជំរំ ។ អោយពួកការពារនៅយាមព័ទ្ធយើងក្នុងចំងាយពីររយជំហាន ។

- បាទពុក ។

*ណាកា* បែរខ្លួនដើម្បីអនុវត្តតាមបញ្ជា តែដោយទប់ចិត្តរបស់ខ្លួនមិនបានសោះនោះគេក៏ផ្ទុះសំនួរឡើង ។

- នេះជាសង្គ្រាមហើយ ? ជាសង្គ្រាមហើយ មែនទេ ?

អាស្រ័យដោយលោកត្រូវការអ្នកនាំសារប្រកបដោយសុទិដ្ឋិនិយមមួយសំរាប់បន្ទាយនេះ ទើបលោកមិនបានស្តីបន្ទោសកូនប្រុសលោកចំពោះភាពព្រហើននេះឡើយ លោកពោលតប ៖

- ពិត ។ ប្រាកដជាពិតមែនហើយ... តែជាសង្គ្រាមតាមលក្ខខណ្ឌរបស់ពុក ។

*ណាកា* ទាញទ្វារបិទ ហើយប្រញាប់ប្រញាល់ចេញទៅ ។ ថ្វីត្បិតតែ *ណាកា* ខិតខំរក្សាទឹកមុខ និងអាកប្បកិរិយារបស់ខ្លួនយ៉ាងណាក៏ដោយ តែដំណើរយ៉ាងរចល់របស់គេព្រមទាំងពន្លឺដែលជះឡើងដូចភ្លើងនៅក្នុងភ្នែករបស់គេមិនអាចលាក់ជិតពីភ្នែករបស់ *តូរ៉ាណាកា* បានឡើយ ។ អីលូវនេះ បើសិនជាគេចេះថៃភ្លើងអោយបានល្អ ពាក្យចចាមអារ៉ាម ពាក្យប្រឆាំងចចាមអារ៉ាមនឹងរត់កាន់តែរហ័សគាត់ *អាន់ជីរ៉ូ* ហើយនឹងរាលដាលពេញតំបន់ *អ៊ីស៊ូ*



www.budinst.gov.kh www.elibraryofcambodia.org

ហើយនឹងហួសពីនេះតទៅទៀតផង ។

- អញចូលសាច់រឿងមែនទែនហើយ ។

លោកនិយាយទៅកាន់ផ្កាដែលនៅទីងនលើ *តាកូណាម៉ា* ហើយដែលជះស្រមោលគួរអោយត្រអាលតាមពន្លឺភ្លើងទៀន ។ *គិរី* បានសរសេរថា :

" លោកម្ចាស់ ខ្ញុំបទព្រះសូមលោកបានសេចក្តីសុខនិងសេចក្តីសប្បាយ ។ នេះជាព្រាបនាំសារចុងក្រោយរបស់យើង ដោយហេតុនេះខ្ញុំបទព្រះសូមអោយព្រះអង្គជួយអោយវាបានមកដល់ដៃលោកម្ចាស់ផង ។ ពួកក្បត់បានដុតទ្រុងសំលាប់ព្រាបទាំងអស់កាលពីយប់មិញនេះ តែមួយនេះមានជីវិតរស់រានបានដោយវាឈឺ ហើយខ្ញុំត្រូវយកវាទៅថែទាំដោយផ្ទាល់ដៃតែប៉ុននោះ ។

កាលពីព្រឹកម្សិលមិញ លោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ស្រាប់តែបានសូមលាលែងដូចតំរោងមែន ។ ប៉ុន្តែមុនពេលដែលលោកគេចខ្លួនរួច គាត់ត្រូវជាប់អន្ទាក់ពួក *រ៉ូនីន* របស់ *អ៊ីស៊ីដូ* នៅឯជាយក្រុង *អូសាកា* ។ ជាការគួរអោយអាក្រក់ណាស់ គឺសមាជិកគ្រួសារលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ខ្លះក៏ត្រូវចាប់ខ្លួនជាមួយលោកដែរ ។ ខ្ញុំឮថា គាត់ត្រូវមនុស្សរបស់គាត់ក្បត់ ។ ពាក្យចចាមអារ៉ាមបានអោយដឹងថា *អ៊ីស៊ីដូ* បានអោយជំរើសគាត់ដូចតទៅនេះ : បើសិនជាលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ព្រមពន្យារការសុំលាលែងរបស់លោករហូតដល់ក្រោយពេលដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិប្រជុំ ( នៅថ្ងៃស្អែក ) ដើម្បីគេអាចផ្តន្ទាទោស លោកម្ចាស់ស្របច្បាប់បាននោះ *អ៊ីស៊ីដូ* ធានាថា ក្រុមប្រឹក្សានឹងផ្តល់អោយលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ជាផ្លូវការនូវតំបន់ *ក្វាន់តូ* ទាំងមូល ហើយដើម្បីបង្ហាញពីសន្តានចិត្តស្មោះត្រង់របស់ខ្លួន *អ៊ីស៊ីដូ* នឹងដោះលែងលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* និងគ្រួសាររបស់លោកភ្លាម ។ *ស៊ូគីយ៉ាម៉ា* បានប្រកែកមិនព្រមក្បត់លោកម្ចាស់ ហើយភ្លាមៗនោះ *អ៊ីស៊ីដូ* បានបញ្ជាអោយពួក *អេតា* ចាប់បង្ខំលោកភ្លាម ។ ពួកវាបានធ្វើទារុណកម្មកូនចៅរបស់លោក រួចប្រពន្ធចុងលោកទៀតនៅចំពោះមុខលោកតែម្តង តែគាត់នៅតែមិនព្រមបោះបង់លោកម្ចាស់ដដែល ។ ពួកលោកត្រូវបានគេសំលាប់យ៉ាងវេទនា ។ លោក *ស៊ូគីយ៉ាម៉ា* ដែលត្រូវស្លាប់ចុងក្រោយគេរឹតតែវេទនាជាងគេទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

ជាការពិតហើយដែលថា គ្មានអ្នកណាបានឃើញហេតុការណ៍ដ៏ចោកទាបទាំងនេះដោយផ្ទាល់ភ្នែកទេ ហើយអ្វីសុទ្ធតែលឺតាមការនិយាយប្រាប់គ្នាទាំងអស់ តែខ្ញុំជឿថា នេះជាការពិត ។ ជាការធម្មតាទេ *អ៊ីស៊ីដូ* បានប្រកាសមិនទទួលដឹងលឺពីរឿងឃាតកម្ម រឺការចូលរួមចំនែកក្នុងរឿងនេះ ហើយថែមទាំងប្ដេជ្ញាតាមរុករកពួក " ឃាតក " ទៀតផង ។ ដំបូង *អ៊ីស៊ីដូ* បានអះអាងថា លោកម្ចាស់ *ស៊ូតឺយ៉ាម៉ា* ឥតបានសុំលាលែងតំនែងទេ ដោយហេតុនេះខ្ញុំយល់ឃើញថា ក្រុមប្រឹក្សានៅតែអាចធ្វើការប្រជុំបានដដែល ។ ខ្ញុំបានបញ្ជូនច្បាប់ចំលងនៃសំនុំលិខិតលាលែងរបស់លោកម្ចាស់ *ស៊ូតឺយ៉ាម៉ា* ទៅសមាជិកឯទៀតនៃក្រុមប្រឹក្សា គឺមានលោកម្ចាស់ *គឺយ៉ាម៉ា អ៊ីតូ* និង *អូណូស៊ី* ហើយនឹងបញ្ជូនមួយច្បាប់ទៀតជាចំហទៅ *អ៊ីស៊ីដូ* ហើយបញ្ជូនច្បាប់ចំលងបួនទៀតទៅក្នុងចំនោមពួក *ដៃមីញ៉ូ* ទាំងឡាយ ( លោកចំជាវាងវៃមែនដែលដឹងច្បាស់ថា ច្បាប់ចំលងច្រើនទៀតជាការចាំបាច់នេះ ) ដោយហេតុនេះហើយ ដូចជាការគ្រោងទុករបស់លោកជាមួយ *ស៊ូតឺយ៉ាម៉ា* អីចឹង ជាផ្លូវច្បាប់គ្មានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិទៀតទេ ។ ពោលគឺក្នុងរឿងនេះ លោកបានទទួលជោគជ័យទាំងស្រុង ។

ដំណឹងល្អ : លោកម្ចាស់ *ម៉ូកាមី* បានចាកចេញពីទីក្រុងប្រកបដោយសុវត្ថិភាពជាមួយនឹងគ្រួសារ និង*សាមូរ៉ៃ* របស់លោកទាំងអស់ហើយ ។ អីលូវនេះ លោកជាសម្ព័ន្ធមិត្តយ៉ាងធំរបស់លោកហើយ ពោលគឺឆ្អឹងជំនីខាងជើងបំផុតរបស់លោកធានាបានទាំងស្រុង ។ លោកម្ចាស់ *ម៉ាអេដា*. *តូតូស៊ីម៉ា*. *អាសាណូ* . *អ៊ីកេដា* និង *អូតូនីអារ៉ា* បានលបចេញយ៉ាងស្ងៀមស្ងាត់ពីទីក្រុង *អូសាកា* កាលពីយប់មិញនេះដើម្បីគេចរកសុខ ។ រួមទាំងលោកម្ចាស់គ្រិស្តសាសនិក *អូដា* ផង ។

ដំណឹងដែលអាក្រក់ គឺក្រុមគ្រួសាររបស់លោកម្ចាស់ *ម៉ាអេដា*. *អ៊ីកាដេ* និង *អូដា* ព្រមទាំង *ដៃមីញ៉ូ* សំខាន់ៗទាំងប៉ុន្មានដណ្ដប់នាក់ទៀតមិនបានគេចខ្លួនរួចទេ ហើយបានស្ថិតនៅជាចំនាប់ខ្មាំងនៅទីនេះ រួមជាមួយលោកម្ចាស់ឯទៀតដែលមិនចូលខាងណា តែក៏មិនសំខាន់ណាស់ណាដែរទេនោះ ចំនួនប្រហែលហាទៅហុកសិបនាក់ទៀតផង ។

ដំណឹងដែលអាក្រក់ គឺពីម្សិលមិញ ប្អូនប្រុសឪពុកទីទែររបស់លោកឈ្មោះ*សាកាគី* ដែលជា



www.budinst.gov.kh www.elibraryofcambodia.org

ហើយនឹងហួសពីនេះតទៅទៀតផង ។

- អញចូលសាច់រឿងមែនទែនហើយ ។

លោកនិយាយទៅកាន់ផ្កាដែលនៅទីងនលើ *តាកូណាម៉ា* ហើយដែលជះស្រមោលគួរអោយត្រអាលតាមពន្លឺភ្លើងទៀន ។ *គីរី* បានសរសេរថា :

" លោកម្ចាស់ ខ្ញុំបន់ព្រះសូមលោកបានសេចក្តីសុខនិងសេចក្តីសប្បាយ ។ នេះជាព្រាបនាំសារចុងក្រោយរបស់យើង ដោយហេតុនេះខ្ញុំបន់ព្រះសូមអោយព្រះអង្គជួយអោយវាបានមកដល់ដៃលោកម្ចាស់ផង ។ ពួកក្បត់បានដុតទ្រុងសំលាប់ព្រាបទាំងអស់កាលពីយប់មិញនេះ តែមួយនេះមានជីវិតរស់រានបានដោយវាឈឺ ហើយខ្ញុំត្រូវយកវាទៅថែទាំដោយផ្ទាល់ដៃតែប៉ុននោះ ។

កាលពីព្រឹកម្សិលមិញ លោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ស្រាប់តែបានសូមលាលែងដូចគំរោងមែន ។ ប៉ុន្តែមុនពេលដែលលោកគេចខ្លួនរួច គាត់ត្រូវជាប់អន្ទាក់ពួក *រ៉ូនីន* របស់ *អ៊ីស៊ីដូ* នៅឯជាយក្រុង *អូសាកា* ។ ជាការគួរអោយអភ័ព្វនោះ គឺសមាជិកគ្រួសារលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ខ្លះក៏ត្រូវចាប់ខ្លួនជាមួយលោកដែរ ។ ខ្ញុំលឺថា គាត់ត្រូវមនុស្សរបស់គាត់ក្បត់ ។ ពាក្យចចាមអារ៉ាមបានអោយដឹងថា *អ៊ីស៊ីដូ* បានអោយជំរើសគាត់ដូចតទៅនេះ : បើសិនជាលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ព្រមពន្យារការសុំលាលែងរបស់លោករហូតដល់ក្រោយពេលដែលក្រុមប្រឹក្សាអាជ្ញានុសិទ្ធិប្រជុំ ( នៅថ្ងៃស្អែក ) ដើម្បីគេអាចផ្តន្ទាទោស លោកម្ចាស់ស្របច្បាប់បាននោះ *អ៊ីស៊ីដូ* ធានាថា ក្រុមប្រឹក្សានឹងផ្តល់អោយលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ជាផ្លូវការនូវតំបន់ *ក្វាន់តូ* ទាំងមូល ហើយដើម្បីបង្ហាញពីសន្តានចិត្តស្មោះត្រង់របស់ខ្លួន *អ៊ីស៊ីដូ* នឹងដោះលែងលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* និងគ្រួសាររបស់លោកភ្លាម ។ *ស៊ូគីយ៉ាម៉ា* បានប្រកែកមិនព្រមក្បត់លោកម្ចាស់ ហើយភ្លាម១នោះ *អ៊ីស៊ីដូ* បានបញ្ជាអោយពួក *អេតា* ចាប់បង្ខំលោកភ្លាម ។ ពួកវាបានធ្វើទារុណកម្មកូនចៅរបស់លោក រួចប្រពន្ធចុងលោកទៀតនៅចំពោះមុខលោកតែម្តង តែគាត់នៅតែមិនព្រមបោះបង់លោកម្ចាស់ដដែល ។ ពួកលោកត្រូវបានគេសំលាប់យ៉ាងវេទនា ។ លោក *ស៊ូគីយ៉ាម៉ា* ដែលត្រូវស្លាប់ចុងក្រោយគេរឹតតែវេទនាជាងគេទៅទៀត ។



www.budinst.gov.kh www.elibraryofcambodia.org

ជាការពិតហើយដែលថា គ្មានអ្នកណាបានឃើញហេតុការណ៍ដ៏ចោកទាបទាំងនេះ ដោយផ្ទាល់ភ្នែកទេ ហើយអ្វីសុទ្ធតែលឺតាមការនិយាយប្រាប់គ្នាទាំងអស់ តែខ្ញុំជឿថា នេះជាការពិត ។ ជាការធម្មតាទេ *អ៊ីស៊ីដូ* បានប្រកាសមិនទទួលដឹងលឺពីរឿងឃាតកម្ម រឺការចូលរួមចំនែកក្នុងរឿងនេះ ហើយថែមទាំងប្តេជ្ញាតាមរុករកពួក " ឃាតក " ទៀតផង ។ ដំបូង *អ៊ីស៊ីដូ* បានអះអាងថា លោកម្ចាស់ *ស៊ូតឺយ៉ាម៉ា* ឥតបានសុំលាលែងតំនែងទេ ដោយហេតុនេះខ្លួនយល់ឃើញថា ក្រុមប្រឹក្សានៅតែអាចធ្វើការប្រជុំបានដដែល ។ ខ្ញុំបានបញ្ជូនច្បាប់ចំលងនៃសំនុំលិខិតលាលែងរបស់លោកម្ចាស់ *ស៊ូតឺយ៉ាម៉ា* ទៅសមាជិកឯទៀតនៃក្រុមប្រឹក្សា គឺមានលោកម្ចាស់ *តឺយ៉ាម៉ា* *អ៊ីតូ* និង *អូណូស៊ី* ហើយនឹងបញ្ជូនមួយច្បាប់ទៀតជាចំហទៅ *អ៊ីស៊ីដូ* ហើយបញ្ជូនច្បាប់ចំលងបួនទៀតទៅក្នុងចំនោមពួក *ដៃមីញ៉ូ* ទាំងឡាយ ( លោកចំជាវាងវៃមែនដែលដឹងច្បាស់ថា ច្បាប់ចំលងច្រើនទៀតជាការចាំបាច់នេះ ) ដោយហេតុនេះហើយ ដូចជាការគ្រោងទុករបស់លោកជាមួយ *ស៊ូតឺយ៉ាម៉ា* អ៊ីចឹង ជាផ្លូវច្បាប់គ្មានក្រុមប្រឹក្សាអាជ្ញាធសិទ្ធិទៀតទេ ។ ពោលគឺក្នុងរឿងនេះ លោកបានទទួលជោគជ័យទាំងស្រុង ។

ដំណឹងល្អ : លោកម្ចាស់ *ម៉ូកាមី* បានចាកចេញពីទីក្រុងប្រកបដោយសុវត្ថិភាពជាមួយនឹងគ្រួសារ និង*សាមូរ៉ៃ* របស់លោកទាំងអស់ហើយ ។ អីលូវនេះ លោកជាសម្ព័ន្ធមិត្តយ៉ាងចំហរបស់លោកហើយ ពោលគឺឆ្អឹងដំនីខាងជើងបំផុតរបស់លោកធានាបានទាំងស្រុង ។ លោកម្ចាស់ *ម៉ាអេដា*. *តូតូស៊ីម៉ា*. *អាសាណូ* . *អ៊ីកេដា* និង *អូតូទីអារ៉ា* បានលបចេញយ៉ាងស្ងៀមស្ងាត់ពីទីក្រុង *អូសាកា* កាលពីយប់មិញនេះដើម្បីគេចរកសុខ ។ រួមទាំងលោកម្ចាស់គ្រិស្តសាសនិក *អូដា* ផង ។

ដំណឹងដែលអាក្រក់ គឺក្រុមគ្រួសាររបស់លោកម្ចាស់ *ម៉ាអេដា*. *អ៊ីកាដេ* និង *អូដា* ព្រមទាំង *ដៃមីញ៉ូ* សំខាន់ៗទាំងប៉ុន្មានដណ្តប់នាក់ទៀតមិនបានគេចខ្លួនរួចទេ ហើយបានស្ថិតនៅជាចំនាប់ខ្មាំងនៅទីនេះ រួមជាមួយលោកម្ចាស់ឯទៀតដែលមិនចូលខាងណា តែក៏មិនសំខាន់ណាស់ណាដែរទេនោះ ចំនួនប្រហែលហាទៅហុកសិបនាក់ទៀតផង ។

ដំណឹងដែលអាក្រក់ គឺពីម្សិលមិញ ប្អូនប្រុសឪពុកទីទៃរបស់លោកឈ្មោះ*សាតាគី* ដែលជា



www.budinst.gov.kh www.elibraryofcambodia.org

ម្ចាស់តំបន់ *ស៊ីណាណូ* នោះបានប្រកាសជាសាធារណៈគាំទ្រទាយាទ *វ៉ៃយទម៉ុន* ប្រឆាំងនឹងលោក ដោយបានចោទលោកថា បានរួមគំនិតជាមួយ *ស៊ូគីយ៉ាម៉ា* ដើម្បីផ្ដួលរំលំក្រុមប្រឹក្សាអាជ្ញាធរសិទ្ធិតាមរយៈបង្កអោយមានភាពចលាចល ។ ហេតុនេះ ព្រំដែនភាគអីសានរបស់លោកត្រូវរងការគំរាមកំហែងហើយ។លោកត្រូវប្រឈមមុខនឹង *សាតាគី* ហើយនឹងពួកគាំទ្រយ៉ាងងងឹតងងល់របស់គេទាំងប្រាំម៉ឺននាក់ទៀត ។

ដំណឹងដែលអាក្រក់ គឺ *ដៃមីញ៉ូ* ស្ទើរគ្រប់គ្នាបានទទួលយល់ព្រម " ការអញ្ជើញ " របស់ព្រះចៅអធិរាជ ។

ដំណឹងដែលអាក្រក់ គឺមានមិត្ត និង សម្ព័ន្ធមិត្តរបស់លោកមិនតិចទេ ដែលម្ទៅនឹងការដែលលោកមិនបានប្រាប់ពួកគេជាមុនពីយុទ្ធសាស្ត្ររបស់លោក ដើម្បីពួកគេអាចរៀបចំទីដកថយបាន ។ ក្នុងនោះមានមិត្តចាស់លោក គឺលោកម្ចាស់ *ស៊ីម៉ាស៊ូ* ដ៏មហិមាម្នាក់ដែរ ។ កាលពីរសៀលនេះ ខ្ញុំបានលឺគាត់ស្នើសុំជាចំហអោយព្រះចៅបញ្ជាអោយពួកអម្ចាស់ទាំងអស់ត្រូវតែលុតជង្គង់ចំពោះមុខកុមារ *វ៉ៃយទម៉ុន* នៅពេលនេះតែម្តង ។

ដំណឹងដែលអាក្រក់ គឺជំទាវ *អូជីបា* បានរាយក្រលារបស់គាត់យ៉ាងស្អាត ដោយសន្យាដែនដី និង ឋានៈដល់អ្នកដែលនៅអព្យាក្រឹតទាំងប៉ុន្មាន ។ *តូរ៉ា - ចាន* គឺជាការគួរអោយស្តាយណាស់ដែលនាងមិននៅខាងលោក ។ នាងជាសត្រូវដ៏មានគ្រោះថ្នាក់ណាស់ ។ តែមានលោកជំទាវ *យ៉ូដូកូ* តែម្នាក់គត់ដែលអង្វរអោយគេឯងសូត្រធម៌ និង រក្សាភាពនឹងនតែគ្មានអ្នកណាស្ដាប់ឡើយ ។ ជំទាវ *អូជីបា* ចង់ជំរុញអោយមានសង្គ្រាមអោយបានរហ័សព្រោះគាត់មានអារម្មណ៍ថា លោកកំពុងចុះខ្សោយ ហើយនៅឯកោទៀតផង ។ សូមទោសទៅចុះលោកម្ចាស់ ប៉ុន្តែពេលនេះលោកស្ថិតនៅឯកោហើយបើតាមខ្ញុំគិត លោកត្រូវគេក្បត់ថែមទៀតផង ។

អាក្រក់ជាងគេបង្អស់ គឺនៅពេលនេះ សមាជិកក្រុមប្រឹក្សាដែលជាគ្រិស្តសាសនិកទាំងពីរ ពោលគឺ *គីយ៉ាម៉ា* និង *អូណូស៊ី* បានរួបរួមគ្នាជាចំហ ហើយបានចេញមុខប្រឆាំងយ៉ាងខ្លាំងក្លានឹងរូបលោក ។ ពួកគេបានចេញសេចក្ដីថ្លែងការណ៍រួមនៅពេលព្រឹកមិញនេះ



www.budinst.gov.kh www.elibraryofcambodia.org

ដោយសំដែងនូវការសោកស្តាយចំពោះ " ការរត់ចោលជួរ " របស់ *ស៊ូគីយ៉ាម៉ា* ដែលពួកគេថា នេះជាការដាក់ទគរអោយស្ថិតក្នុងភាពច្របូកច្របល់ថា " យើងត្រូវតែខ្លាំងក្លាទាំងអស់គ្នាឡើងដើម្បីជាគុណប្រយោជន៍ចក្រភព ។ ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិមានការទទួលខុសត្រូវខ្ពស់បំផុត ។ យើងត្រូវត្រៀមខ្លួនជានិច្ចដើម្បីរួមគ្នាកំទេចអម្ចាស់ណា រឺពួកអម្ចាស់ណាដែលចង់បំផ្លាញឆន្ទៈលោកម្ចាស់ *តៃកូ* រឺការស្នងដ៏ស្របច្បាប់ " ( តើនេះមានន័យថា ពួកគេចង់ធ្វើការប្រជុំក្រុមប្រឹក្សាអាជ្ញានុសិទ្ធិដែលមានគ្នាតែបួននាក់ រឺយ៉ាងម៉េច ? ) ។ ពួកអ្នកយកការណ៍ជាគ្រិស្តសាសនិករបស់យើងម្នាក់ដែលនៅក្នុងសេនាធិការពួកស្បង់ខ្មៅនោះ បានលួចប្រាប់យើងអោយដឹងថា បព្វជិត *ឈូគូ - សាន* បានចាកចេញជាសំងាត់ពី *អូសាកា* កាលពីប្រាំថ្ងៃមុននេះ តែពួកយើងមិនដឹងថា តើគាត់ទៅ *យេដូ* រឺ *ណាកាសាគី* ដែលជាកន្លែងគេរង់ចាំ *សំពៅខ្មៅ* នោះទេ ។ តើលោកដឹងថា សំពៅនេះមកដល់លឿនជាងរាល់ដងទេនៅរដូវនេះ ? អាចលឿនជាងរាល់ឆ្នាំពីម្ភៃទៅសាមសិបថ្ងៃឯណោះ ?

លោកម្ចាស់ : ជានិច្ចកាល ខ្ញុំតែងរួញរាក្នុងការឆាប់ផ្តល់មតិដោយផ្អែកលើការនិយាយពីមាត់មួយទៅមាត់មួយ លើពាក្យចចាមអារ៉ាម លើអ្នកយកការណ៍ រឺលើការពិភាល់របស់មនុស្សស្រី ( លោកឃើញទេ *តូរ៉ា - ចាន* រឿងនេះខ្ញុំរៀនបានពីលោកណា ! ) តែពេលវេលានៅខ្លីណាស់ ហើយប្រហែលជាខ្ញុំគ្មានពេលជជែកជាមួយលោកទៀតទេ : ទីមួយមានក្រុមគ្រួសារច្រើនណាស់ដែលនៅជាប់ជុំចទីនេះ ។ *អ៊ីស៊ីដូ* ពិតជានឹងមិនដោះលែងពួកនេះទេ ( ក៏ដូចជាមិនលែងពួកយើងដែរ ) ។ ពួកចំនាប់ខ្មាំងទាំងនេះ គឺជាគ្រោះថ្នាក់ដ៏ធំធេងណាស់សំរាប់លោក ។ មានអម្ចាស់តិចណាស់ដែលនឹងមានមនសិការភារកិច្ច រឺសេចក្តីក្លាហានក្នុងគុណធម៌ដូចជាលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ។ តាមខ្ញុំស្មាន មនុស្សច្រើនណាស់ដែលអីលូវនេះនឹងចូលដៃជាមួយ *អ៊ីស៊ីដូ* ទោះជាក្នុងភាពទើសទាល់យ៉ាងណាក្តី ព្រោះតែរឿងចំនាប់ខ្មាំងទាំងនេះ ។ មួយវិញទៀត ខ្ញុំគិតថា *ម៉ាអេតា* នឹងក្បត់លោក ។ *អាសាណូ* ក៏ប្រហែលជាយ៉ាងនោះដែរ ។ ខ្ញុំពិនិត្យមើលទៅ ក្នុងចំនោម *ដៃមីញ៉ូ* ទាំងពីររយហុកសិបបួននាក់នៅក្នុងនគរយើងនេះ មានតែម្ភៃបួននាក់ទេដែលច្បាស់ថាតាមលោក ហើយហាសិប



www.budinst.gov.kh www.elibraryofcambodia.org

នាក់ទៀតអាចតាម ។ ចំនួននេះមិនគ្រប់គ្រាន់ទេ ។ *គីយ៉ាម៉ា* និង *អួណូស៊ី* នឹងកៀងគរយកពួក *វ៉េមីញ៉ូ* គ្រិស្តសាសនិកទាំងអស់ រឺស្ទើរតែទាំងអស់ ហើយខ្ញុំជឿថា ពួកគេនឹងមិនរួមជាមួយលោកឡើយនៅពេលនេះ ។ លោកម្ចាស់ *មូរី* ដែលជាអម្ចាស់ ដែលមានជាងគេបំផុត និងមហិមាជាងគេបំផុតនោះពិតជាប្រឆាំងនឹងលោកដូចសព្វដងអីចឹង ហើយគាត់ពិតជាអូសទាញ *អាសាណូ , តូចាយ៉ាកាវ៉ា* និងប្រហែល *អូដា* ផង អោយទៅជាមួយទៀតផង ។ ដោយថែមទាំង *សាតាគី* ដែលប្រឆាំងនឹងលោកទៀតនោះ ស្ថានភាពរបស់លោកពិតជាផុយស្រួយមែនទែន ។ ខ្ញុំសូមជូនយោបល់លោក សូមលោកប្រកាសថ្ងៃមេឃក្រហមភ្លាម ហើយប្រញាប់ទៅ *ក្យូតូ* ជាបន្ទាន់ ។ នេះជាសង្ឃឹមតែមួយគត់របស់លោក ។

ចំនែកឯជំទាវ *សាស៊ូកូ* និងខ្ញុំវិញ ពួកយើងបានសុខសប្បាយជាទេ ។ ទារកកាន់តែមានការរីកចំរើនធំធាត់ល្អណាស់ ហើយបើសិនជា *កាម៉ា* តំរូវអោយទារកនេះប្រសូតចេញមកនោះក៏ទៅតាមនោះទៅ ។ ក្នុងជ្រុងម្ខាងនៃវិមាននេះ ពួកយើងបានសេចក្តីសុខជាទេ ។ ទ្វារត្រូវបានចាក់សោយ៉ាងម៉ាំទាំ ហើយចរឹងដែកក៏ត្រូវបានដាក់ចុះដែរ ។ ពួក *សាមូរ៉ៃ* យើងសុទ្ធសឹងពោរពេញដោយភក្តីភាពចំពោះលោក និង ចំពោះបុព្វហេតុរបស់លោក ហើយបើសិនជា *កាម៉ា* តំរូវអោយយើងលាចាកលោកនេះ ពួកយើងនឹងលាចាកដោយអារម្មណ៍ស្ងប់ស្ងាត់បំផុត ។ លោកជំទាវភរិយាលោកនឹកលោកណាស់ នឹកខ្លាំងមែនទែនតែម្តង ។ ចំពោះខ្ញុំវិញ *តូរ៉ា - ចាន* ខ្ញុំមានបំនងយ៉ាងខ្លាំងក្លាចង់ឃើញលោក ចង់សើចជាមួយលោក និងចង់ឃើញភាពញញឹមរបស់លោកជាពន់ពេក ។ ការសោកស្តាយតែមួយនៅក្នុងមរណភាពរបស់ខ្ញុំគឺការដែលមិនអាចធ្វើបានតាមបំនងទាំងអស់នេះបានទៀត ក៏ដូចជាការដែលខ្ញុំមិនអាចទៅថែរក្សាលោកបានទៀតតែប៉ុណ្ណោះ ។ បើសិនទៅឯបរលោក មានព្រះអាទិទេព មានព្រះពុទ្ធរឺក៏មាន *កាមី* ខ្ញុំសូមសន្យាថា ខ្ញុំនឹងប្រឹងប្រែងសព្វបែបយ៉ាងដើម្បីបន្ទន់ចិត្តអស់លោកទាំងនោះអោយនៅខាងលោក... ថ្វីត្បិតដំបូងបង្អស់ ខ្ញុំត្រូវអង្វរករអស់លោកទាំងអស់នោះអោយជួយធ្វើអោយខ្ញុំមានរាងច្រលឹង រូបក្មេង គួរជាទីពេញចិត្តចំពោះលោក ទន្ទឹមនឹងនៅតែ



www.budinst.gov.kh www.elibraryofcambodia.org

ទទួលទានបានតាមចំនង់ក្ដី ។ ឱ ! នោះពិតជាឋានសួគ៌មែនទែន បើសិនជាអាចហូប ហូប ហូប ហើយនៅតែក្មេង និង រាងច្រលឹងជារៀងរហូតបាននោះ ។

ខ្ញុំសូមផ្ញើជូនលោកនូវសំនើចរបស់ខ្ញុំ ។ សូមព្រះជួយប្រទានពុទ្ធពរជូនលោក ″ ។

☆ ☆ ☆

*តូរ៉ាណាកា* អានសារអោយអ្នកទាំងអស់គ្នាស្ដាប់ លើកលែងតែផ្នែកឯកជនទាក់ទិននឹងជំទាវ *សាស៊ូកូ* និង *គីរី* តែប៉ុណ្ណោះ ។ នៅពេលដែលលោកអានចប់ហើយ ទាំងអស់ គ្នាស់លឹងមើលលោក ហើយមើលគ្នាទៅវិញទៅមកសឹងមិនជឿក្នុងចិត្ត មិនមែនគ្រាន់តែដោយសារអ្វីដែលសារនេះបានរ៉ាយរ៉ាប់នោះទេ តែគឺដោយសារតែលោកបានយករឿងសំងាត់របស់លោកមកអោយពួកគេដឹងយ៉ាងចំហបែបនេះថែមទៀតផង ។

ពួកគេអង្គុយលើកន្ទេលដែលរៀបជាកន្លះរង្វង់ពីមុខ *តូរ៉ាណាកា* នៅចំកណ្ដាលខ្ទង់រាប ។ គ្មានអ្នកការពារណាម្នាក់នៅទីនេះទេ ហើយពួកគេក៏មិនបារម្ភពីមានអ្នកលួចស្ដាប់ដែរ ។ *ប៊ុនតារ៉ូ . យ៉ាប៊ូ . អ៊ីកូរ៉ាជី . អូមី . ណាកា* . ពួកមេទ័ព និង *ម៉ារីកូ* ។ ពួកអ្នកការពារទាំងប៉ុន្មាននៅឆ្ងាយពីទីនេះពីររយជំហាន ។

*តូរ៉ាណាកា* ពោលឡើង :

- ខ្ញុំចង់បានមតិខ្លះ ។ ពួកទីប្រឹក្សារបស់ខ្ញុំនៅឯ *យេដូ* ឯណោះ ។ កិច្ចការនេះបន្ទាន់ណាស់ ហើយខ្ញុំចង់អោយអស់លោកធ្វើរឿងនេះជំនួសពួកគេ ។ តើនឹងមានរឿងអ្វីខ្លះដែលកើតឡើង ហើយតើខ្ញុំគិតគួរធ្វើយ៉ាងណា ? *យ៉ាប៊ូ - សាន* ?

*យ៉ាប៊ូ* សែនកន្ទះរានៅក្នុងចិត្តជាពន់ពេក ។ ច្រកណាក៏ហាក់នាំទៅរកមហន្តរាយដែរ :

- លោកម្ចាស់ ដំបូងបង្អស់ស្អីទៅជា ″ *វិថីមេឃក្រហម* ″ នោះ ?

- នោះគឺជាពាក្យសំងាត់សំរាប់ផែនការប្រយុទ្ធចុងក្រោយរបស់ខ្ញុំ ។ ជាការវាយសំរុកតំហុកចូល *ក្យូតូ* តែមួយប្រាវ ដោយប្រើកំលាំងទ័ពទាំងអស់របស់ខ្ញុំដើម្បីដណ្ដើមកាន់កាប់រាជធានីអោយចេញផុតពីពួកកំលាំងអប្រិយទាំងប៉ុន្មាន ដែលសព្វថ្ងៃនៅហ៊ុមព័ទ្ធទីនោះ ដើម្បីរំដោះព្រះចៅចេញពីក្រញ៉ាំដ៏កខ្វក់របស់ពួកដែលបានបោកប្រាសព្រះអង្គ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

នាក់ទៀតអាចតាម ។ ចំនួននេះមិនគ្រប់គ្រាន់ទេ ។ *គីយ៉ាម៉ា* និង *អូលូស៊ី* នឹងកៀងគរយកពួក *ដៃមីញ៉ូ* គ្រិស្តសាសនិកទាំងអស់ វិសេីវតែទាំងអស់ ហើយខ្ញុំជឿថា ពួកគេនឹងមិនរួមជាមួយលោកឡើយនៅពេលនេះ ។ លោកម្ចាស់ *អូរី* ដែលជាអម្ចាស់ ដែលមានជាងគេបំផុត និងមហិមាជាងគេបំផុតនោះពិតជាប្រឆាំងនឹងលោកដូចសព្វដងអ៊ីចឹង ហើយគាត់ពិតជាអូសទាញ *អាសាណូ . តូបាយ៉ាកាវ៉ា* និងប្រហែល *អូដា* ផង អោយទៅជាមួយទៀតផង ។ ដោយថែមទាំង *សាគាគី* ដែលប្រឆាំងនឹងលោកទៀតនោះ ស្ថានភាពរបស់លោកពិតជាផុយស្រួយមែនទែន ។ ខ្ញុំសូមជូនយោបល់លោក សូមលោកប្រកាសថ្ងៃមេឃក្រហមភ្លាម ហើយប្រញាប់ទៅ *ក្យូតូ* ជាបន្ទាន់ ។ នេះជាសង្ឃឹមតែមួយគត់របស់លោក ។

ចំនែកឯជំទាវ *សាស៊ូកូ* និងខ្ញុំវិញ ពួកយើងបានសុខសប្បាយជាទេ ។ ទារកកាន់តែមានការរីកចំរើនធំធាត់ល្អណាស់ ហើយបើសិនជា *កាម៉ា* តំរូវអោយទារកនេះប្រសូតចេញមកនោះក៏ទៅតាមនោះទៅ ។ ក្នុងជ្រុងម្ខាងនៃវិមាននេះ ពួកយើងបានសេចក្តីសុខជាទេ ។ ទ្វារត្រូវបានចាក់សោយ៉ាងមាំទាំ ហើយចរឹងដែកក៏ត្រូវបានដាក់ចុះដែរ ។ ពួក *សាមូរ៉ៃ* យើងសុទ្ធសឹងពោរពេញដោយភក្តីភាពចំពោះលោក និង ចំពោះបុព្វហេតុរបស់លោក ហើយបើសិនជា *កាម៉ា* តំរូវអោយយើងលាចាកលោកនេះ ពួកយើងនឹងលាចាកដោយអារម្មណ៍ស្ងប់ស្ងាត់បំផុត ។ លោកជំទាវភរិយាលោកនឹកលោកណាស់ នឹកខ្លាំងមែនទែនតែម្តង ។ ចំពោះខ្ញុំវិញ *តូរ៉ា - ចាន* ខ្ញុំមានបំនងយ៉ាងខ្លាំងក្លាចង់ឃើញលោក ចង់សើចជាមួយលោក និងចង់ឃើញភាពញញឹមរបស់លោកជាពន់ពេក ។ ការសោកស្តាយតែមួយនៅក្នុងមរណភាពរបស់ខ្ញុំគឺការដែលមិនអាចធ្វើបានតាមបំនងទាំងអស់នេះបានទៀត ក៏ដូចជាការដែលខ្ញុំមិនអាចនៅថែរក្សាលោកបានទៀតតែប៉ុណ្ណោះ ។ បើសិននៅឯបរលោក មានព្រះអាទិទេព មានព្រះពុទ្ធ រឺក៏មាន *កាមី* ខ្ញុំសូមសន្យាថា ខ្ញុំនឹងប្រឹងប្រែងសព្វបែបយ៉ាងដើម្បីបន្ទន់ចិត្តអស់លោកទាំងនោះអោយនៅខាងលោក... ថ្វីត្បិតដំបូងបង្អស់ ខ្ញុំត្រូវអង្វរករអស់លោកទាំងអស់នោះអោយជួយធ្វើអោយខ្ញុំមានរាងច្រលឹង រូបក្មេង គួរជាទីពេញចិត្តចំពោះលោក ទន្ទឹមនឹងនៅតែ



www.budinst.gov.kh www.elibraryofcambodia.org

ទទួលទានបានតាមចំនង់ក្ដី ។ ឱ ! នោះពិតជាឋានសួគ៌មែនទែន បើសិនជាអាចហូប ហូប ហូប ហើយនៅតែក្មេង និង រាងច្រលឹងជារៀងរហូតបាននោះ ។

ខ្ញុំសូមផ្ញើជូនលោកនូវសំនើចរបស់ខ្ញុំ ។ សូមព្រះជួយប្រទានពុទ្ធពរជូនលោក ៉ ។

☆ ☆ ☆

*តូរ៉ាណាកា* អានសារអោយអ្នកទាំងអស់គ្នាស្ដាប់ លើកលែងតែផ្នែកឯកជនទាក់ទិននឹងជំទាវ *សាស៊ូកូ* និង *គីរី* តែប៉ុណ្ណោះ ។ នៅពេលដែលលោកអានចប់ហើយ ទាំងអស់គ្នាស់លឹងមើលលោក ហើយមើលគ្នាទៅវិញទៅមកស៊ឹងមិនជឿក្នុងចិត្ត មិនមែនគ្រាន់តែដោយសារអ្វីដែលសារនេះបានរ៉ាយរ៉ាប់នោះទេ តែគឺដោយសារតែលោកបានយករឿងសំងាត់របស់លោកមកអោយពួកគេដឹងយ៉ាងចំហបែបនេះថែមទៀតផង ។

ពួកគេអង្គុយលើកន្ទេលដែលរៀបជាកន្ទះរង្វង់ពីមុខ *តូរ៉ាណាកា* នៅចំកណ្ដាលខ្ពង់រាប ។ គ្មានអ្នកការពារណាម្នាក់នៅទីនេះទេ ហើយពួកគេក៏មិនបារម្ភពីមានអ្នកលួចស្ដាប់ដែរ ។ *ប៊ុនតារ៉ូ* , *យ៉ាប៊ូ* , *អ៊ីកូរ៉ាជី* , *អូមី* , *ណាកា*, ពួកមេទ័ព និង *ម៉ារីកូ* ។ ពួកអ្នកការពារទាំងប៉ុន្មាននៅឆ្ងាយពីទីនេះពីររយជំហាន ។

*តូរ៉ាណាកា* ពោលឡើង :

- ខ្ញុំចង់បានមតិខ្លះ ។ ពួកទីប្រឹក្សារបស់ខ្ញុំនៅឯ *យេដូ* ឯណោះ ។ កិច្ចការនេះបន្ទាន់ណាស់ ហើយខ្ញុំចង់អោយអស់លោកធ្វើរឿងនេះជំនួសពួកគេ ។ តើនឹងមានរឿងអ្វីខ្លះដែលកើតឡើង ហើយតើខ្ញុំគិតគួរធ្វើយ៉ាងណា ? *យ៉ាប៊ូ - សាន* ?

*យ៉ាប៊ូ* សែនកន្ទះរានៅក្នុងចិត្តជាពន់ពេក ។ ច្រកណាក៏ហាក់នាំទៅរកមហន្ដរាយដែរ :

- លោកម្ចាស់ ដំបូងបង្អស់ស្ដីទៅជា ៉ *ផ្ទៃមេឃក្រហម* ៉ នោះ ?

- នោះគឺជាពាក្យសំងាត់សំរាប់ផែនការប្រយុទ្ធចុងក្រោយរបស់ខ្ញុំ ។ ជាការវាយសំរុកគំហុកចូល *ក្យូតូ* តែមួយប្រាវ ដោយប្រើកំលាំងទ័ពទាំងអស់របស់ខ្ញុំដើម្បីដណ្ដើមកាន់កាប់រាជធានីអោយចេញផុតពីពួកកំលាំងអប្រិយទាំងប៉ុន្មាន ដែលសព្វថ្ងៃនៅហ៊ុមព័ទ្ធទីនោះ ដើម្បីរំដោះព្រះចៅចេញពីក្រញ៉ាំដ៏កខ្វក់របស់ពួកដែលបានបោកប្រាសព្រះអង្គ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

ដែលមាន *អ៊ីស៊ីដូ* ជាមេក្លោង ។ នៅពេលណាដែលព្រះចៅអធិរាជត្រូវបានរំដោះប្រកប ដោយសុវត្ថិភាពចេញផុតពីក្រញាំរបស់ពួកវាហើយ យើងនឹងទូលសូមព្រះអង្គលុបព្រះអាជ្ញា ដែលបានប្រទានទៅអោយក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ដែលយើងឃើញច្បាស់ហើយថា ជាពួកក្បត់ វិនៅក្រោមការត្រួតត្រារបស់ពួកក្បត់នោះចោលចេញ ហើយសូមព្រះអង្គប្រទានព្រះអាជ្ញាអោយមកខ្ញុំ ដើម្បីរៀបចំក្រុមប្រឹក្សាជាថ្មីដែលយកផលប្រយោជន៍របស់នគរ និងទាយាទ ដាក់មុនមហិច្ឆតាផ្ទាល់ខ្លួនវិញ ។ នៅក្នុងការវាយលុកនេះ ខ្ញុំនឹងដឹកនាំទ័ពពីប៉ែតសិបទៅមួយរយពាន់នាក់ ដោយឥតមានទុកកំលាំងនៅការពារផែនដីរបស់ខ្ញុំ ទុកឆ្អឹងជំនីរទ័ពនៅទទេ ហើយក៏គ្មានកំលាំងបិទគ្មួចអ្វីទាំងអស់ ។

*តូរ៉ាណាកា* ឃើញអ្នកទាំងអស់គ្នាសំលឹងមើលមកលោកទាំងស្រឡាំងកាំង ។ លោកឥតបាននិយាយផងទេពីក្រុម *សាមូរ៉ៃ* ជើងឆើតដ៏ច្រើន ដែលលោកបានបង្កប់នៅតាមវិមាន និងខេត្តសំខាន់ៗ ជាច្រើនឆ្នាំមកហើយ ។ ដែលនឹងផ្ទុះចលនាបះបោរព្រមៗគ្នា ដើម្បីបង្កជាចលាចលដែលជាកត្តាកំនត់មួយនៃផែនការរបស់លោក ។

*យ៉ាប៊ូ* លាន់មាត់ឡើង :

- តែបើធ្វើយ៉ាងនេះ លោកត្រូវធ្វើការប្រយុទ្ធនៅគ្រប់ជំហានតែម្តងហើយ ។ *អ៊ីកាវ៉ា ជីគីយូ* ត្រួតត្រា *តូកៃដូ* ជាងមួយរយលី ហើយសល់ប៉ុន្មានទៀតកំលាំង *អ៊ីស៊ីដូ* ត្រួតទាំងអស់ហ្នឹង !

- ត្រូវហើយ ។ តែខ្ញុំមានផែនការវាយសំរុកតាមនិរតីទិស តាមបណ្តោយ *តូស៊ី-កៃដូ* ទើបបុកទៅ *ក្យូតូ* តែម្តងដោយចៀសឆ្ងាយពីតំបន់ឆ្នេរសមុទ្រ ។

ទាំងអស់គ្នាក៏ងក់ក្បាល ហើយចាប់ផ្តើមដណ្តើមគ្នានិយាយ តែ *យ៉ាប៊ូ* និយាយគ្រប លើអ្នកឯទៀត :

- តែលោកម្ចាស់ សារបាននិយាយថា សាច់ញាតិរបស់លោកម្ចាស់ គឺ *សាកាគី - សាន* បានចូលដៃជើងជាមួយសត្រូវទៅហើយ ! ពេលនេះផ្លូវភាគខាងជើងរបស់លោកម្ចាស់ ត្រូវបិទទៅហើយដែរ ។ ខេត្តរបស់គាត់នៅទន្ទឹមគ្នានឹង *តូស៊ី - កៃដូ* ហេតុនេះលោកត្រូវ



www.budinst.gov.kh www.elibraryofcambodia.org

តែវាយបើកផ្លូវរហូតពេញមួយតំបន់ *ស៊ីណាណូ* ដែលជាតំបន់ភ្នំលំបាកលំបិន ។ ពួកទ័ពនៅទីនោះក៏សុខស៊ឹងជាទ័ពស្មោះត្រង់ទៅទៀត ។ លោកនឹងត្រូវគេកំទេចម៉ត់នៅក្នុងតំបន់ភ្នំទាំងនោះជាមិនខាន ។

- នេះជាផ្លូវតែមួយ ជាផ្លូវតែមួយគត់ដែលខ្ញុំអាចមានសំនាងខ្លះ ។ ខ្ញុំឯកភាពថានៅតំបន់ឆ្នេរសមុទ្រមានភាពប្រទូស្តច្រើនមែនទែន ។

*យ៉ាប៊ូ* ចោលភ្នែកសំលឹងមើលទៅ *អូមី* ទាំងក្នុងចិត្តមមៃចង់ពិគ្រោះជាមួយបុរសនេះផង ទាំងប្រទេចនៅក្នុងពោះបណ្តើរចំពោះសារនេះ ហើយនិងភាពរញ៉ីករញ៉ូនៅ *អូសាកា* ផង ។ គេស្អប់បំផុតដែលត្រូវឡើងនិយាយមុនគេបែបនេះ ហើយគេរឹតតែស្អប់ឋានៈជាអណ្តាប់ដែលគេព្រមទទួលយកតាមការអោយគំនិតរបស់ *អូមី* នេះថែមទៀត ។

កាលនោះ *អូមី* ពន្យល់ថា :

- នេះជាច្រកចេញតែមួយគត់ *យ៉ាប៊ូ - សាម៉ា* ។ ជាវិធីតែមួយគត់ដើម្បីគេចផុតពីអន្ទាក់របស់ *តូរ៉ាណាកា* ហើយដើម្បីលោកម្ចាស់មានទីដើម្បីបត់បែនផង ...

*អ៊ីកូរ៉ាជី* និយាយកាត់ទាំងកំហឹង :

- ល្អបំផុតត្រូវកំចាត់ *តូរ៉ាណាកា* ក្នុងពេលនេះ ទាន់គាត់មានទ័ពតែបន្តិចបន្តួចនៅជាមួយ ! ល្អបំផុតសំលាប់គាត់ ហើយកាត់ក្បាលយកទៅជូន *អ៊ីសូដូ* ទៅ ទាន់នៅមានពេល ។

- យកល្អត្រូវរង់ចាំ ។ យកល្អត្រូវអត់ធ្មត់...

- ចុះតើវានឹងទៅជាយ៉ាងណាទៅ បើសិនជា *តូរ៉ាណាកា* បញ្ជាអោយលោកម្ចាស់យើងបោះបង់ចោលតំបន់ *អ៊ីស៊ូ* ទៅនោះ ? - *អ៊ីកូរ៉ាជី* ស្រែកគំហកឡើង - ក្នុងឋានៈជាអម្ចាស់នឹងអណ្តាប់ *តូរ៉ាណាកា* មានសិទ្ធិនឹងបញ្ជាបែបនេះបានណា ។

- គាត់នឹងមិនធ្វើបែបនោះជាដាច់ខាត ។ ពេលនេះជាពេលដែលគាត់ត្រូវការលោកម្ចាស់យើងជាងពេលណាៗទាំងអស់ ។ តំបន់ *អ៊ីស៊ូ* ជារនាំងការពារច្រកទ្វារខាងត្បូងរបស់គាត់ ។ គាត់មិនអាចប្រទូស្តជាមួយ *អ៊ីស៊ូ* បានទេ ! គាត់ត្រូវការចង់បានលោកម្ចាស់យើង ...



www.budinst.gov.kh www.elibraryofcambodia.org

- ចុះបើគាត់សំរេចបណ្តេញលោកម្ចាស់យើងចេញ ?

- យើងនឹងបះបោរភ្លាម ! យើងសំលាប់ *តូរ៉ាណាកា* បើគាត់នៅទីនោះ រឺក៏វាយតទល់នឹងកងទ័ពណាក៏ដោយដែលគាត់បញ្ជូនមកប្រឆាំងនឹងយើង ។ តែគាត់នឹងមិនធ្វើបែបនេះឡើយ លោកមិនឃើញទេអ្វី ? ក្នុងឋានៈជាអណ្តាប់របស់ខ្លួន *តូរ៉ាណាកា* ត្រូវតែការពារ...

*យ៉ាប៊ូ* ទុកអោយអ្នកទាំងពីរជជែកតទល់គ្នា ហើយទីបំផុតលោកបានមើលឃើញនូវគតិបណ្ឌិតរបស់ *អូមី* : " ល្អណាស់ ! ខ្ញុំឯកភាព ! ហើយខ្ញុំនឹងប្រគល់ដាវ *មូរ៉ាសាម៉ា* របស់ខ្ញុំដើម្បីជារបស់តាងនៃកិច្ចព្រមព្រៀងនេះ ។ ពិតហើយ ពេលនេះខ្ញុំមានតំលៃចំពោះ *តូរ៉ាណាកា* ច្រើនជាងពេលមុនៗឆ្ងាយណាស់ ។ *អូមី* យល់ត្រឹមត្រូវមែន *អ៊ីកូរ៉ាជី* ។ ខ្ញុំគ្មានជំរើសទេ ។ ខ្ញុំនឹងដាក់ខ្លួនជាអណ្តាប់របស់ *តូរ៉ាណាកា* ចាប់ពីពេលនេះទៅចុះ " ។

*អូមី* ពោលបន្ថែម :

- រហូតដល់ពេលណាដែលសង្គ្រាមមកដល់ ។

- ពិតហើយ ។ គឺពិតជាត្រឹមត្រូវរហូតដល់ពេលណាសង្គ្រាមមកដល់តែប៉ុណ្ណោះ ! ដល់ពេលនោះខ្ញុំអាចដូរក៏បាន.... រឺអាចធ្វើកិច្ចការបួនដប់រឿងហើយស្រេចក៏បាន ។ ឯងយល់ត្រូវណាស់ *អូមី - សាន* ។ ត្រូវម្តងទៀតហើយ ។

*អូមី* ជាទីប្រឹក្សាដ៏ល្អបំផុតដែលអញមាន - *យ៉ាប៊ូ* គិតនៅក្នុងចិត្ត ។ តែក៏ជាមនុស្សដ៏មានគ្រោះថ្នាក់បំផុតផងដែរ ។ វាមានប្រាជ្ញាគ្រប់គ្រាន់នឹងកាន់កាប់ *អ៊ីស៊ូ* បើសិនជាអញស្លាប់ទៅនោះ ។ តែអត់ការទេរឿងហ្នឹង ។ យើងទាំងអស់គ្នាគង់តែស្លាប់ទេតើ ។

*យ៉ាប៊ូ* និយាយទៅ *តូរ៉ាណាកា* បន្តទៀត :

- លោកត្រូវតែខ្ជប់អស់ហើយ ។ លោកត្រូវឯកោហើយ ។

- តើមានផ្លូវដោះផ្សេងទៀតទេ ? - *តូរ៉ាណាកា* សួរ ។

- អោយខ្ញុំសូមអភ័យទោសទៅចុះលោកម្ចាស់ - *អូមី* ពោលឡើង - តើយើងត្រូវការរយៈពេលប៉ុន្មានដើម្បីត្រៀមការវាយលុកនេះ ?

- អីលូវនេះត្រៀមរួចរាល់អស់ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- *អ៊ីស៊ូ* ក៏រៀបចំហើយអស់ដែរទាន - *យ៉ាប៊ូ* និយាយ - ទ័ពទាំងសែនរបស់លោកម្ចាស់ និងទ័ពខ្ញុំដប់ប្រាំមួយពាន់ បូកនឹងកង *មូរស្ត* ទៀត តើប៉ុនណឹងគ្រប់គ្រាន់ទេ ?

- ទេ ។ *វ៉ៃរមេឃក្រហម* ជាផែនការប្រថុយចុងក្រោយ ។ អ្វី១ត្រូវបានប្រថុយក្នុងការវាយលុកតែមួយប្រាវតែប៉ុននោះ ។

- លោកត្រូវតែប្រថុយរឿងនេះ នៅពេលណាដែលអស់ត្បៀង ហើយនៅពេលដែលយើងអាចធ្វើសឹកបាន - *យ៉ាប៊ូ* ជំរុញបន្ថែម - តើលោកមានជំរើសអីទៅ ? *អ៊ីស៊ីដូ* នឹងបង្កើតក្រុមប្រឹក្សាថ្មីមួយជាបន្ទាន់ ។ ពួកគេនៅតែមានព្រះអាជ្ញាព្រះចៅនៅឡើយ ។ ដោយហេតុនេះ លោកនឹងត្រូវគេផ្តន្ទាទោសថ្ងៃនេះ រឺថ្ងៃស្អែក រឺថ្ងៃបន្ទាប់ទៀត ។ ហេតុអីនៅរង់ចាំអោយគេត្របាក់ធ្វើអី ? សូមស្តាប់ខ្ញុំ ។ អាចកងកាំភ្លើងវាយបើកផ្លូវចេញរួចតាមភ្នំទាំងឡាយនោះ ! ប្រកាស *វ៉ៃរមេឃក្រហម* ទៅ ! ទ័ពទាំងអស់ផ្តុំវាយចំតែមួយលើកតែម្តង ។ នេះជាមាគ៌ានៃអ្នកប្រយុទ្ធ ។ នេះបានសក្តិសមជា *សាមូរ៉ៃ តូរ៉ាណាកា - សាម៉ា* ។ កាំភ្លើងយើងពិតជាអាច នឹងបំបើង *សាតាគី* ចេញពីផ្លូវរបស់យើងបាន ហើយបើសិនជាលោកចាញ់ រឺបរាជ័យ តើវាមានទៅចី ? ការវាយលុកនេះនឹងរស់នៅជាអលង្ការ !

*ណាកា* ពោល :

- ពិតហើយ ។ តែយើងនឹងឈ្នះ ។ ប្រាកដជាឈ្នះ ។

មេទ័ពមួយចំនួនតូចងក់ក្បាលឯកភាព ។ ពួកគេចូរខ្សែងដោយថា សង្គ្រាមបានមកដល់ហើយ ។ *អូមី* ឥតនិយាយអ្វីទាំងអស់ ។

*តូរ៉ាណាកា* ងាកសំលឹងទៅ *ប៊ុនតារ៉ូ* :

- យ៉ាងម៉េចដែរ ?

- លោកម្ចាស់ ខ្ញុំសូមលោកម្ចាស់អធ្យាស្រ័យកុំសួរយោបល់ខ្ញុំធ្វើអ្វី ។ ខ្ញុំនិងកូនចៅខ្ញុំធ្វើតាមអ្វីដែលលោកម្ចាស់សំរេច ។ នេះជាភារកិច្ចតែមួយគត់របស់ខ្ញុំ ។ មតិខ្ញុំមិនមានតំលៃអ្វីទេចំពោះលោកម្ចាស់ ដោយថាខ្ញុំនឹងធ្វើតាមអ្វីដែលលោកម្ចាស់បានសំរេចតែប៉ុននោះ ។

- ជាធម្មតា ខ្ញុំយល់ព្រម តែថ្ងៃនេះអត់ទេ !



www.budinst.gov.kh www.elibraryofcambodia.org

*- ចុះបើគាត់សំរេចបណ្តេញលោកម្ចាស់យើងចេញ ?*

- យើងនឹងបះបោរភ្លាម ! យើងសំលាប់ *តូរ៉ាណាកា* បើគាត់នៅទីនោះ រឺក៏វាយតទល់នឹងកងទ័ពណាក៏ដោយដែលគាត់បញ្ជូនមកប្រឆាំងនឹងយើង ។ តែគាត់នឹងមិនធ្វើបែបនេះឡើយ លោកមិនឃើញទេអ្វី ? ក្នុងឋានៈជាអណ្តាប់របស់ខ្លួន *តូរ៉ាណាកា* ត្រូវតែការពារ...

*យ៉ាប៊ូ* ទុកអោយអ្នកទាំងពីរជជែកតទល់គ្នា ហើយទីបំផុតលោកបានមើលឃើញនូវគតិបណ្ឌិតរបស់ *អូមី* : " ល្អណាស់ ! ខ្ញុំឯកភាព ! ហើយខ្ញុំនឹងប្រគល់ដាវ *មូរ៉ាសាម៉ា* របស់ខ្ញុំដើម្បីជារបស់តាងនៃកិច្ចព្រមព្រៀងនេះ ។ ពិតហើយ ពេលនេះខ្ញុំមានតំលៃចំពោះ *តូរ៉ាណាកា* ច្រើនជាងពេលមុន១ឆ្ងាយណាស់ ។ *អូមី* យល់ត្រឹមត្រូវមែន *អ៊ិកូរ៉ាជី* ។ ខ្ញុំគ្មានជំរើសទេ ។ ខ្ញុំនឹងដាក់ខ្លួនជាអណ្តាប់របស់ *តូរ៉ាណាកា* ចាប់ពីពេលនេះទៅចុះ " ។

*អូមី* ពោលបន្ថែម :

- រហូតដល់ពេលណាដែលសង្គ្រាមមកដល់ ។

- ពិតហើយ ។ គឺពិតជាត្រឹមត្រូវរហូតដល់ពេលណាសង្គ្រាមមកដល់តែប៉ុណ្ណោះ ! ដល់ពេលនោះខ្ញុំអាចដូរក៏បាន.... រឺអាចធ្វើកិច្ចការបួនដប់រឿងហើយស្រេចក៏បាន ។ ឯងយល់ត្រូវណាស់ *អូមី - សាន* ។ ត្រូវម្តងទៀតហើយ ។

*អូមី* ជាទីប្រឹក្សាដ៏ល្អបំផុតដែលអញមាន - *យ៉ាប៊ូ* គិតនៅក្នុងចិត្ត ។ តែក៏ជាមនុស្សដ៏មានគ្រោះថ្នាក់បំផុតផងដែរ ។ វាមានប្រាជ្ញាគ្រប់គ្រាន់នឹងកាន់កាប់ *អ៊ីស៊ូ* បើសិនជាអញស្លាប់ទៅនោះ ។ តែអត់ការទេរឿងហ្នឹង ។ យើងទាំងអស់គ្នាគង់តែស្លាប់ទេតើ ។

*យ៉ាប៊ូ* និយាយទៅ *តូរ៉ាណាកា* បន្តទៀត :

- លោកត្រូវតែខ្ជប់អស់ហើយ ។ លោកត្រូវឯកោហើយ ។

- តើមានផ្លូវដោះផ្សេងទៀតទេ ? - *តូរ៉ាណាកា* សួរ ។

- អោយខ្ញុំសូមអភ័យទោសទៅចុះលោកម្ចាស់ - *អូមី* ពោលឡើង - តើយើងត្រូវការរយៈពេលប៉ុន្មានដើម្បីត្រៀមការវាយលុកនេះ ?

- អីលូវនេះត្រៀមរួចរាល់អស់ហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- *អ៊ីស៊ូ* ក៏រៀបចំហើយអស់ដែរទាន - *យ៉ាប៊ូ* និយាយ - ទ័ពទាំងសែនរបស់លោកម្ចាស់ និងទ័ពខ្ញុំដប់ប្រាំមួយពាន់ បូកនឹងកង *មូរស្កេ* ទៀត តើប៉ុនណឹងគ្រប់គ្រាន់ទេ ?

- ទេ ។ *រំផ្ទៃមេឃក្រហម* ជាផែនការប្រថុយចុងក្រោយ ។ អ្វី១ត្រូវបានប្រថុយក្នុងការវាយលុកតែមួយប្រាវតែប៉ុននោះ ។

- លោកត្រូវតែប្រថុយរឿងនេះ នៅពេលណាដែលអស់ក្បៀង ហើយនៅពេលដែលយើងអាចធ្វើសឹកបាន - *យ៉ាប៊ូ* ជំរុញបន្ថែម - តើលោកមានជំរើសអីទៅ ? *អ៊ីស៊ីដូ* នឹងបង្កើតក្រុមប្រឹក្សាថ្មីមួយជាបន្ទាន់ ។ ពួកគេនៅតែមានព្រះអាជ្ញាព្រះចៅនៅឡើយ ។ ដោយហេតុនេះ លោកនឹងត្រូវគេផ្ដន្ទាទោសថ្ងៃនេះ រឺថ្ងៃស្អែក រឺថ្ងៃបន្ទាប់ទៀត ។ ហេតុអីនៅរង់ចាំអោយគេត្របាក់ធ្វើអី ? សូមស្ដាប់ខ្ញុំ ។ អាចកងកាំភ្លើងវាយបើកផ្លូវចេញរូចតាមភ្នំទាំងឡាយនោះ ! ប្រកាស *រំផ្ទៃមេឃក្រហម* ទៅ ! ទ័ពទាំងអស់ផ្ដុំវាយធំតែមួយលើកតែម្ដង ។ នេះជាមាតានៃអ្នកប្រយុទ្ធ ។ នេះបានសក្ដិសមជា *សាមូរ៉ៃ តូរ៉ាណាកា - សាម៉ា* ។ កាំភ្លើងយើងពិតជាអាច នឹងបំបុ៊ង *សាតាគី* ចេញពីផ្លូវរបស់យើងបាន ហើយបើសិនជាលោកចាញ់ រឺបរាជ័យ តើវាមានទៅថី ? ការវាយលុកនេះនឹងរស់នៅជាអលង្ការ !

*ណាកា* ពោល :

- ពិតហើយ ។ តែយើងនឹងឈ្នះ ។ ប្រាកដជាឈ្នះ ។

មេទ័ពមួយចំនួនតូចងក់ក្បាលឯកភាព ។ ពួកគេចូរទ្រូងដោយថា សង្គ្រាមបានមកដល់ហើយ ។ *អូមី* ឥតនិយាយអ្វីទាំងអស់ ។

*តូរ៉ាណាកា* ងាកសំលឹងទៅ *ប៊ុនតារ៉ូ* :

- យ៉ាងម៉េចដែរ ?

- លោកម្ចាស់ ខ្ញុំសូមលោកម្ចាស់អធ្យាស្រ័យកុំសួរយោបល់ខ្ញុំធ្វើអ្វី ។ ខ្ញុំនិងកូនចៅខ្ញុំធ្វើតាមអ្វីដែលលោកម្ចាស់សំរេច ។ នេះជាភារកិច្ចតែមួយគត់របស់ខ្ញុំ ។ មតិខ្ញុំមិនមានតំលៃអ្វីទេចំពោះលោកម្ចាស់ ដោយថាខ្ញុំនឹងធ្វើតាមអ្វីដែលលោកម្ចាស់បានសំរេចតែប៉ុននោះ ។

- ជាធម្មតា ខ្ញុំយល់ព្រម តែថ្ងៃនេះអត់ទេ !



www.budinst.gov.kh www.elibraryofcambodia.org

- បើអីចឹងគឺធ្វើសង្គ្រាមទៅ ។ អ្វីដែល *យ៉ាប៊ូ - សាន* និយាយ គឺត្រឹមត្រូវ ។ ទៅ *ក្យូតូ* តែម្តងទៅ ។ នៅថ្ងៃនេះ ថ្ងៃស្អែក រឺនៅពេលដែលអស់ភ្លៀង ។ *វ៉ែរមេឃក្រហម !* ខ្ញុំធុញនឹងរង់ចាំណាស់ ។

- *អូមី - សាន ?* - *តូរ៉ាណាកា* សួរ ។

- *យ៉ាប៊ូ - សាម៉ា* មានមតិត្រឹមត្រូវទាន ។ *អ៊ីស៊ីដូ* នឹងប្រែក្រលាស់បណ្តាំរបស់លោកម្ចាស់ *រ៉ៃគួ* ដើម្បីតែងតាំងក្រុមប្រឹក្សានៅពេលឆាប់ៗនេះជាមិនខាន ។ ក្រុមប្រឹក្សាថ្មីនឹងទទួលបានព្រះអាជ្ញាពីព្រះចៅ ។ សត្រូវលោកម្ចាស់ទាំងប៉ុន្មាននឹងទះដៃលោតកញ្ឆេងឯមិត្តរបស់លោកម្ចាស់ភាគច្រើន នឹងមានការរួញរា ហើយនឹងក្បត់លោកម្ចាស់ ។ ក្រុមប្រឹក្សាថ្មីនឹងផ្តន្ទាទោសលោកម្ចាស់ភ្លាម ។ ហើយពេលនោះ...

*យ៉ាប៊ូ* និយាយកាត់ :

- ហើយពេលនោះ គឺ *វ៉ៃមេឃក្រហម ?*

- បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* ចេញបញ្ជា នោះគឺពិតជាមាន ។ តែខ្ញុំគិតថាអាជ្ញាផ្តន្ទាទោសនោះនឹងគ្មានតំលៃអីទាំងអស់ លោកម្ចាស់អាចមិនរវីរវល់នឹងវា ក៏មិនមានបញ្ហាអ្វីដែរ ។

- ហេតុអី ?

*តូរ៉ាណាកា* សួរឡើង ។ អារម្មណ៍ទាំងអស់បានផ្តោតលើ *អូមី* តែម្នាក់ ។

- ខ្ញុំឯកភាពជាមួយលោកម្ចាស់ ។ *អ៊ីស៊ីដូ* ជាទុរជន *ទេ ?* ហើយពួក *ដៃមីញ៉ូ* ណាដែលយល់ព្រមស្ម័គ្របំរើគាត់ក៏ជាទុរជនដែរ ។ មនុស្សពិតប្រាកដដឹងថា *អ៊ីស៊ីដូ* ជាមនុស្សយ៉ាងម៉េចហើយៗគេក៏ដឹងដែរថា ព្រះចៅអធិរាជត្រូវបានគេបោកប្រាស ។

*អូមី* ដឹងថា គេត្រូវតែប្រុងប្រយ័ត្នលើផ្លូវដ៏គ្រោះថ្នាក់នេះ ។ គេបន្ត :

- ខ្ញុំគិតថា *អ៊ីស៊ីដូ* បានធ្វើការភាន់ច្រលំដ៏ធំបំផុតក្នុងការដែលអោយគេធ្វើឃាតលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* នេះ ។ ពីព្រោះតែរឿងឃាតកម្មដ៏ស្អប់ខ្ពើមនេះ ខ្ញុំគិតថា នៅពេលនេះ ពួក *ដៃមីញ៉ូ* ទាំងអស់មានការសង្ស័យពីល្បិចថោកទាបរបស់ *អ៊ីស៊ីដូ* ហើយក្រៅតែពី



www.budinst.gov.kh www.elibraryofcambodia.org

ពួកប៉ុន្មាននាក់ដែលនៅជិតដៃជើងរបស់ *អ៊ីស៊ីដូ* ចេញ មាន *ដៃមីញ៉ូ* តិចនាក់ណាស់ ដែលព្រមគោរពតាមបញ្ជារបស់ " ក្រុមប្រឹក្សា " *អ៊ីស៊ីដូ* នោះ ។ ហេតុនេះលោកមិនមានការភ័យព្រួយបារម្ភអ្វីឡើយ ។ យ៉ាងហោចណាស់មួយរយៈដែរ ។

- មួយរយៈណឹងប៉ុន្មានពេលទៅ ?

- យើងមានភ្លៀងប្រហែលពីរខែ ។ នៅពេលអស់ភ្លៀង *អ៊ីស៊ីដូ* នឹងមានផែនការបញ្ជូន *អ៊ីកាវ៉ា ជីគីយូ* និងលោកម្ចាស់ *សាភាគី* វាយលោកម្ចាស់ព្រម១គ្នាជាមាត់ដង្កាប់ឯកងទ័ពធំរបស់ *អ៊ីស៊ីដូ* នឹងវាយតាំទ្រពួកនេះតាមផ្លូវ *តូរ៉ៃកដូ* ។ តែក្នុងពេលអីលូវនេះរហូតដល់ពេលអស់ភ្លៀង *ដៃម័ញ៉ូ* ម្នាក់១ដែលមានគំនិតគុំគួននឹង *ដៃមីញ៉ូ* ម្នាក់ទៀតនោះនឹងគ្រាន់តែអីអើនឹងមាត់ជាមួយ *អ៊ីស៊ីដូ* តែប៉ុននោះ រហូតដល់គាត់ចាប់ចេញសកម្មភាពដល់ពេលនោះខ្ញុំគិតថា ពួកគេនឹងបំភ្លេចគាត់ចោល ហើយម្នាក់១នឹងចាត់ការសងសឹកគ្នារិងញើមដែនដីគ្នាតាមតែក្បាលចិត្តរៀង១ខ្លួនហើយ ។ ចក្រភពនឹងត្រូវហែកហួរដូចកាលជំនាន់មុនលោកម្ចាស់ *តៃកូ* ដដែល ។ ប៉ុន្តែលោកម្ចាស់វិញ លោកជាមួយ *យ៉ាប៊ូ - សាម៉ា* ដោយជោគវាសនាល្អ លោកទាំងពីរមានកំលាំងគ្រប់គ្រាន់នឹងរក្សាច្រកទៅ *ក្វាន់តូ* និង *អ៊ីស៊ូ* តទល់នឹងការវាយលុកលើកទីមួយ ហើយលោកពិតជាកំទេចពួកនេះបាន ។ ខ្ញុំគិតថា *អ៊ីស៊ីដូ* មិនអាចរៀបចំទ័ពវាយបុកបានម្តងទៀតទេ... គឺមិនអាចរៀបទ័ពធំបានជាដាច់ខាត ។ នៅពេលដែល *អ៊ីស៊ីដូ* និងពួកឯទៀតចំនាយកំលាំងពួកគេអស់ហើយនោះ លោកម្ចាស់ ព្រមទាំងលោកម្ចាស់ *យ៉ាប៊ូ* អាចឈានចេញពីភ្នំយើងដោយប្រយ័ត្នប្រយែង ហើយជាជំហាន១ដណ្តើមយកចក្រភពនេះមកនៅក្នុងកណ្តាប់ដៃលោកម្ចាស់បាន ។

- តើអាណឹងសំរេចនៅពេលណា ?

- ក្នុងសម័យកូនរបស់លោកម្ចាស់ ទាន ។

*យ៉ាប៊ូ* សួរសំនួរក្នុងភាពមាត់ងាយ :

- ឯងចង់អោយមានការប្រយុទ្ធគ្រាន់តែទប់ការពារខ្លួនណឹង ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំគិតថា លោកម្ចាស់ទាំងពីរអាចរួមគ្នារក្សាបានសុវត្ថិភាពខ្លួននៅពីក្រោយភ្នំទាំងឡាយនេះ ។ លោករង់ចាំ *តូរ៉ាណាកា - សាម៉ា* ។ លោករង់ចាំរហូតដល់លោកមានសម្ព័ន្ធមិត្តច្រើនថែមទៀត ។ លោកកាន់កាប់ច្រកចូលភ្នំទាំងនេះ ។ អានេះលោកអាចធ្វើបាន ! *អ៊ីស៊ីដូ* ជាទុរជន តែមិនមែនល្ងង់រហូតដាក់កំលាំងទាំងអស់ដើម្បីធ្វើការប្រយុទ្ធតែម្តងនោះទេ ។ គាត់នឹងសំងំក្រាបពងនៅក្នុង *អូសាកា* ឯនោះ ។ ដោយហេតុនេះក្នុងដំណាក់កាលនោះ យើងមិនត្រូវប្រើកងពលកាំភ្លើងរបស់យើងទេ ។ យើងត្រូវបន្តឹងសន្តិសុខ ហើយទុកពួកនេះជាអាវុធសំងាត់របស់យើង ដោយទុកពួកនេះក្នុងស្ថានភាពត្រៀមរហូតដល់លោកចេញពីក្រោយភ្នំទាំងនេះ... តែក្នុងពេលនេះខ្ញុំគិតថា គេមិនគួរប្រើពួកនេះទេ ។

*អូមី* ដឹងថា ក្រសែភ្នែកគ្រប់ៗគ្នាបានផ្ដោតមកលើរូបគេ១លំអោនខ្លួនគោរព *តូរ៉ាណាកា* :

- សូមលោកម្ចាស់អភ័យទោសដល់រូបខ្ញុំដែលនិយាយវែងយ៉ាងនេះ ទាន ។

*តូរ៉ាណាកា* សំលឹងពិចារណាលើរូប *អូមី* រួចចោលភ្នែកសំលឹងមើលកូនប្រុសរបស់លោក ។ លោកឃើញការប្រឹងបង្ក្រាបភាពរចល់របស់យុវជននេះ ហើយលោកដឹងថា ដល់ពេលដែលលោកត្រូវព្រលែងអោយវានាបចំនីវាហើយ :

- *ណាកា - សាន* ?

- អ្វីដែល *អូមី - សាន* បាននិយាយ គឺជាការពិត - *ណាកា* និយាយយ៉ាងរហ័ស - ពិតដោយភាគច្រើន ។ តែខ្ញុំយល់ថា ត្រូវប្រើរយៈពេលពីរខែនេះដើម្បីប្រមូលសម្ព័ន្ធមិត្តថែមទៀត ដើម្បីកាន់តែឯកោ *អ៊ីស៊ីដូ* ហើយនៅពេលដែលអស់ភ្លៀងហើយ ត្រូវបើកការវាយលុកដោយមិនអោយដឹងមុន... *ផែនមេឃក្រហម* ។

*តូរ៉ាណាកា* សួរ :

- ឯងមិនឯកភាពជាមួយ *អូមី - សាន* ពីរឿងសង្គ្រាមអូសបន្លាយមែនទេ ?

- ទេ ។ តែមិនមែន...

រួច *ណាកា* ឈប់នៅត្រង់នេះ ។



www.budinst.gov.kh www.elibraryofcambodia.org

- និយាយទៅ *ណាកា - សាន* ។ និយាយអោយគេដឹងទាំងអស់គ្នាផង !

*ណាកា* ខាំមាត់ជាប់ មុខគេឡើងសស្លេត ។

- ខ្ញុំបញ្ជាអោយឯងបន្តទៀត !

- បាទលោកពុក ខ្ញុំទើបនឹងមានគំនិតថា... - គេឈប់ម្តងទៀត រួចក៏និយាយតែមួយប្រាវតែម្តង - តើនេះមិនជាឱកាសល្អដើម្បីពុកអាចក្លាយជាអគ្គមហាសេនាទេអ្វី ? បើពុកមានជោគជ័យក្នុងការកាន់កាប់ *ក្យូតូ* ហើយទទួលព្រះអាជ្ញាហើយ ហេតុអ្វីចាំបាច់បង្កើតក្រុមប្រឹក្សាធ្វើអី ? ហេតុអីមិនសូមព្រះចៅតែងតាំងពុកជាអគ្គមហាសេនាតែម្តងទៅ ? នេះគឺល្អបំផុត ទាំងចំពោះពុក ទាំងចំពោះនគរ ។

*ណាកា* ប្រឹងទប់កុំអោយមានការភ័យខ្លាចទាំងប៉ុន្មានលេចចេញមកតាមរយៈសំលេងរបស់ខ្លួន ដោយអ្វីដែលគេកំពុងនិយាយនេះ គឺជាការក្បត់នឹង *យែទម៉ុន* ហើយពួក *សាមូរ៉ៃ* ស្ទើរតែទាំងអស់ដែលនៅទីនេះ - *យ៉ាប៉ូ , អូមី , អ៊ីកូរ៉ាជី* និងពិសេស *ប៊ុនតារ៉ូ* - សុទ្ធសឹងតែជាពួកស្មោះត្រង់នឹងលោកម្ចាស់ *តែកូ* ។ គេបន្ត :

- ខ្ញុំគិតថា ពុកគួរតែធ្វើជាអគ្គមហាសេនា - គេងាកទៅនិយាយការពារមតិរបស់គេជាមួយអ្នកឯទៀតវិញម្តង - បើសិនជាបណ្តោយអោយឱកាសនេះកន្លងផុតទៅ... *អូមី - សាន* លោកយល់ត្រូវហើយពីរឿងសង្គ្រាមយូរអង្វែង តែខ្ញុំយល់ថា លោកម្ចាស់ *តូរ៉ាណាកា* ត្រូវតែកាន់អំនាចដើម្បីអាចផ្តល់អំនាចបាន ! សង្គ្រាមយូរអង្វែងនឹងបង្ហិនបង្ហោចនគរ បំបែកនគរជាភាប់ពាន់ចំរៀកទៀតជាមិនខាន ! តើអ្នកណាចង់បានរបៀបនោះ ? លោកម្ចាស់ *តូរ៉ាណាកា* ត្រូវតែជាអគ្គមហាសេនា ។ ដើម្បីផ្តល់ចក្រភពនេះនេះជារង្វាន់ទៅ *យែទម៉ុន* ទៅលោកម្ចាស់ *យែទម៉ុន* នគរត្រូវតែរឹងមាំសិន ! គឺគ្មានឱកាសណាមួយទៀតទេ...

សំដីរបស់គេក៏រលត់បាត់ទៅ ។ គេតំរង់ខ្នងឡើងវិញ ។ នៅក្នុងចិត្តគេភ័យខ្លាចចំពោះអ្វីដែលគេបាននិយាយផង រីករាយនឹងបាននិយាយជាចំហនូវអ្វីដែលគេតែងគិតនៅក្នុងចិត្តជានិច្ចនោះផង ។

*តូរ៉ាណាកា* ដកដង្ហើមធំ :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំមិនដែលស្ទះស្ទែងចង់ធ្វើជាអគ្គមហាសេនាម្តងណាឡើយ ។ តើខ្ញុំត្រូវនិយាយបញ្ជាក់រឿងនេះប៉ុន្មានដងទៀតទៅ ? ខ្ញុំគាំទ្រកូនខ្ញុំ គឺ *វ៉ាយទម៉ុន* ហើយនឹងបណ្តាំ *តែក្ង* ។

លោកសំលឹងមើលមនុស្សម្តងមួយៗ ហើយមកឈប់ត្រឹម *ណាកា* ជាចុងក្រោយ ។ យុវបុរសញ្ញោចខ្លួន តែ *តូរ៉ាណាកា* និយាយយ៉ាងទន់ភ្លន់ :

- ឆន្ទៈក្លៀវក្លាហួសរបស់ឯង និងយុវវ័យរបស់ឯងបានអនុគ្រោះដល់ឯង ។ តែមានមនុស្សជាច្រើនដែលគេមានអាយុច្រើនជាង និងមានភាពវាងវៃជាងនោះនឹងគិតថា នេះជាមហិច្ឆតារបស់ខ្ញុំហើយ ។ តាមពិតនេះមិនមែនអីចឹងទេ ។ វិធីតែមួយគត់ដើម្បីជំរះការយល់ច្រលំច្រកាច់ច្រកូវនោះគឺត្រូវលើកលោកម្ចាស់ *វ៉ាយទម៉ុន* អោយកាន់អំនាច ។ ហើយនេះជាអ្វីដែលពុកកំពុងធ្វើនេះ ។

- បាទពុក ។ សូមអរគុណ ។ សូមអរគុណ ។

*ណាកា* តបទាំងអស់សង្ឃឹម ។ *តូរ៉ាណាកា* ងាកមើលទៅ *អ៊ីតូរ៉ាជី* វិញម្តង :

- តើលោកមានយោបល់យ៉ាងម៉េចដែរ ?

*សាមូរ៉ៃ* ភ្នែកមួយនោះអេះក្បាល :

- ខ្ញុំគ្រាន់តែជាទាហានម្នាក់ មិនមែនជាទីប្រឹក្សាទេ ។ តែដូច *អូមី- សាន* និយាយអំបាញ់មិញអីចឹង បើយើងអាចធ្វើសឹកតាមលក្ខខណ្ឌរបស់យើងបាន ខ្ញុំយល់ថាមិនគួរអនុវត្តផែនការ *ផ្កាមេឃក្រហម* ទេ ។ កាលពីប៉ុន្មានឆ្នាំមុន ខ្ញុំបានធ្វើសឹកនៅ *ស៊ីណាណូ* ។ នោះចំជាស្រុកយ៉ាប់យ៉ឺនមែនទែន ហើយកាលនោះលោកម្ចាស់ *សាគាគី* នៅជាមួយពួកយើងផង ។ ខ្ញុំមិនចង់ធ្វើសឹកនៅ *ស៊ីណាណូ* ទៀតទេ ហើយដាច់ខាតមិនធ្វើសឹកនៅទីនោះដោយមាន *សាគាគិ* ប្រទូស្តនឹងពួកយើងឡើយ ។ ហើយបើសិនជាលោកម្ចាស់ *ម៉ារអេដា* ត្រូវជាប់សង្ស័យទៀត តើលោករៀបផែនការប្រយុទ្ធយ៉ាងម៉េចទៅ បើសម្ព័ន្ធមិត្តដ៏ធំបំផុតរបស់លោកអាចក្បត់លោកនោះ ? លោកម្ចាស់ *អ៊ីស៊ីដូ* អាចចាត់កំលាំងពីក្រៅបីរយពាន់នាក់ដើម្បីវាយលោក ទន្ទឹមនឹងរក្សាទ័ពច្រើនរយនាក់ទៀតអោយនៅការពារ *អូសាកា* ។ ទោះជាយើងប្រើកាំភ្លើងក្តី ក៏យើងមិនមានមនុស្សគ្រប់គ្រាន់វាយលុក *អូសាកា* បានដែរ ។ តែបើប្រើកាំភ្លើង



www.budinst.gov.kh www.elibraryofcambodia.org

ហើយនៅតែពីក្រោយភ្នំទាំងនេះ យើងអាចត្រួតត្រាកន្លែងនេះជារហូត បើសិនជាអ្វីៗកើតមានដូច *អូមី - សាន* បាននិយាយមែននោះ ។ យើងអាចត្រួតត្រាច្រកភ្នំទាំងឡាយបាន ។ យើងមានស្បៀងគ្រប់គ្រាន់ ។ មិនគឺ *ក្រាន់តូ* ទើរីដែលអាចផ្គត់ផ្គង់អង្ករសំរាប់មាំចំហៀងនគរនោះ ? រឺយ៉ាងហោចណាស់មួយភាគបីនៃនគរនេះដែរ ។ ហើយត្រីត្រូវការប៉ុន្មានក៏មិនខ្វះដែរ ។ លោកនឹងមានសុវត្ថិភាពគ្រប់គ្រាន់ ។ ទុកអោយលោកម្ចាស់ *អ៊ីស៊ីដូ* និងអាចប្រែជីតយូ មករកពួកយើងមក បើដូចជា *អូមី - សាន* និយាយមែននោះ ហើយពួកវានឹងត្របាក់ស៊ីគ្នាវាជាមិនខាន ។ បើមិនដូចនេះទេនោះត្រៀម *ផ្លែមេយក្រហម* ទៅ ។ មនុស្សម្នាក់អាចស្លាប់ដើម្បីអម្ចាស់ខ្លួនតែម្តងទេក្នុងមួយជីវិតរបស់ខ្លួន ។

- មានអ្នកណាមានចង់បន្ថែមអីទៀតទេ ?

*តូរ៉ាណាកា* សួរ ។ គ្មានអ្នកណាឆ្លើយតបវិញទេ :

- *ម៉ារីកូ - សាន ?*

- នេះមិនមែនជាទីកន្លែងសំរាប់ខ្ញុំនិយាយនោះទេ លោកម្ចាស់ - នាងតប - នាងខ្ញុំជឿជាក់ថា អ្វីដែលត្រូវនិយាយសុទ្ធតែបាននិយាយរួចអស់ហើយ ។ តែតើលោកម្ចាស់អនុញ្ញាតអោយនាងខ្ញុំសួរក្នុងនាមទីប្រឹក្សាទាំងអស់ដែលមានមុខនៅទីនេះនូវសំនួរមួយនោះ គឺថាតាមគំនិតលោកម្ចាស់រឿងនេះនឹងកើតមាននៅពេលណា ?

*តូរ៉ាណាកា* រើសពាក្យនិយាយយ៉ាងម៉ត់ចត់ :

- ខ្ញុំជឿថា អ្វីដែល *អូមី - សាន* បានប្រមើលទុកនោះពិតជានឹងកើតមានឡើង ។ លើកលែងតែរឿងមួយ នោះគឺក្រុមប្រឹក្សាមិនតាំងនោះទេ ។ ក្រុមប្រឹក្សានឹងមានឥទ្ធិពលគ្រប់គ្រាន់ដើម្បីអាចប្រមូលកំលាំងសំព័ន្ធមិត្តអបរាជ័យមួយបាន ។ នៅពេលអស់ភ្លៀងហើយកំលាំងនេះនឹងត្រូវប្រមូលផ្តុំវាយបុក *ក្រាន់តូ* ដោយវាំង *អ៊ីស៊ូ* ។ *ក្រាន់តូ* នឹងត្រូវគេលេបបាន ហើយ *អ៊ីស៊ូ* ក៏ដូចគ្នានៅពេលបន្ទាប់មក ។ គឺក្រោយពីខ្ញុំស្លាប់ទេ ដែលពួក *ដៃមីញ៉ូ* ទាំងអស់នឹងប្រកាប់ប្រចាក់គ្នានោះ ។

- តែមកពីហេតុអ្វីទៅលោកម្ចាស់ ? - *អូមី* ប្រជុំយសួរ ។



www.budinst.gov.kh www.elibraryofcambodia.org

- ព្រោះខ្ញុំមានសត្រូវច្រើនពេក ព្រោះខ្ញុំគ្រប់គ្រង *ក្វាន់តូ* ព្រោះខ្ញុំធ្វើសឹកជាងសែសិបឆ្នាំមកហើយៗមិនដែលបរាជ័យក្នុងការប្រយុទ្ធម្ដងណាឡើយ ។ ពួកគេទាំងអស់សុទ្ធតែខ្លាចរអែងខ្ញុំគ្រប់គ្នា ។ ខ្ញុំដឹងថា ពួកគ្នាគអស់នេះនឹងរួមគ្នាដើម្បីកំទេចខ្ញុំ ។ បន្ទាប់មកទៀតទើបពួកវាកំទេចគ្នាវា តែដំបូងបង្អស់ពួកវាត្រូវតែរួមគ្នាកំទេចខ្ញុំសិន បើសិនណាជាអាចទៅកើតនោះ ។ អ្នកទាំងអស់គ្នាសុទ្ធតែដឹងថា ខ្ញុំគឺពិតជាឧបសគ្គតែមួយគត់របស់ *យែនហ្ស៊ុន* ថ្វីត្បិតតែខ្ញុំមិនមែនជាឧបសគ្គអ្វីទាំងអស់ក្ដី ។ នេះហើយជាចំអកនៃជីវិត ។ ទាំងអស់គ្នាសុទ្ធតែជឿនៅក្នុងចិត្តថា ខ្ញុំចង់ធ្វើជាអគ្គមហាសេនា ។ ខ្ញុំឥតមានចង់ទេ ។ នេះគឺជាសង្គ្រាមមួយទៀតដែលមិនចាំបាច់ទាល់តែសោះ ។

*ណាកា* និយាយបំបែកភាពស្ងៀមស្ងាត់ :

- បើដូចនេះ តើពុកគិតធ្វើយ៉ាងម៉េចទៀត ?

- ហ៊ឹ ?

- តើពុកគិតធ្វើយ៉ាងម៉េចទៀត ?

- ច្បាស់ហើយដែលត្រូវប្រើ *ផ្ទៃមេឃក្រហម - តូរ៉ាណាកា* តប ។

- តែពុកនិយាយថា ពួកវានឹងលេបត្របាក់យើង ។

- ពួកវានឹងលេបត្របាក់យើង បើសិនជាពុកអោយពួកវាមានឱកាស ។ តែពុកមិនទុកអោយពួកវាមានឱកាសសោះឡើយ ។ យើងនឹងចេញធ្វើសង្គ្រាមភ្លាមតែម្ដង ។

- រួចចុះភ្លៀង... គិតយ៉ាងម៉េចពីរឿងភ្លៀងនេះ ?

- យើងនឹងទៅដល់ *ក្យូតូ* ទាំងទទឹក ។ ក្ដៅ ស្ងួយ និងទទឹកជោក ។ ការមិនអោយដឹងជាមុន ភាពចល័ត ការអង់អាច និងការរើសពេលបានត្រឹមត្រូវនាំអោយឈ្នះសង្គ្រាម *ទេ? យ៉ាប៊ូ - សាន* និយាយត្រូវណាស់ ។ កាំភ្លើងនឹងបើកផ្លូវយើងតាមភ្នំទាំង ឡាយនេះ ។

☆ ☆ ☆

អស់ជាងមួយម៉ោងដែលពួកគេជជែកគ្នាពីផែនការ និងលទ្ធភាពនៃសង្គ្រាមក្នុងទ្រង់ទ្រាយធំមួយក្នុងរដូវភ្លៀង ។ ជាយុទ្ធសាស្ត្រដែលមិនធ្លាប់លឺសោះតែម្ដង ។ រួច *តូរ៉ាណាកា*



www.budinst.gov.kh www.elibraryofcambodia.org

អោយពួកគេត្រលប់ទៅវិញទាំងអស់គ្នា លើកលែងតែ *ម៉ារីកូ* ម្នាក់ ។ លោកបានប្រាប់ទៅ *ណាកា* អោយហៅ *អាន់ជីន - សាន* អោយមកជួបលោកនៅកន្លែងដដែលនេះ ។ លោកសំលឹងមើលពួកគេដែលដើរចេញទៅដោយមានអាការៈពុះពោរ អាស្រ័យដោយការសំរេចចិត្តដែលបានប្រកាសអំបាញ់មិញនេះ ។ ពិសេស *ណាកា* និង *ប៊ុនតារ៉ូ* ។ មានតែ *អូមី* ទេ ដែលមានអាការៈស្ងៀមស្ងាត់ គិតគូរ ហើយហាក់មិនសូវជឿប៉ុន្មាន ។ *តូរ៉ាណាកា* មិនយកចិត្តទុកដាក់ប៉ុន្មានលើ *អ៊ីកូរ៉ាជី* ទេ ដោយលោកដឹងយ៉ាងច្បាស់ថា មេទ័ពនេះនឹងធ្វើតាមអ្វីដែល *យ៉ាប៊ូ* បញ្ជាអោយធ្វើតែប៉ុននោះ ។ ហើយ *យ៉ាប៊ូ* ក៏គ្រាន់តែជាកូនអុកមួយតែប៉ុននោះ ។ ជាមនុស្សពោរពេញដោយភាពក្បត់ តែក៏នៅតែជាកូនអុកមួយដដែល ។ *អូមី* ជាមនុស្សតែម្នាក់គត់ដែលគួរយកចិត្តទុកដាក់ - លោកគិតនៅក្នុងចិត្ត ។ មិនដឹងថា តើវាអាចយល់បានពីអ្វីដែលអញបំរុងនឹងធ្វើនោះវឺអត់ ?

- *ម៉ារីកូ - សាន* សូមស៊ើបសួរស្ងាត់ៗមើលថាតើអ្នកកំដរភ្ញៀវថ្លៃប៉ុន្មាន ?

*ម៉ារីកូ* បើកភ្នែកព្រិចៗ :

- *គីគូ - សាន* រឺលោកម្ចាស់ ?

- ណឹងហើយ ។

- អីលូវណឹងរឺលោកម្ចាស់ ? ភ្លាមៗណឹង ?

- យប់នេះពិតជាល្អ - លោកសំលឹងមើលនាងយ៉ាងស្រទន់ - តំលៃនាងមិនមែនចាំបាច់សំរាប់រូបខ្ញុំនោះទេ ។ អាចសំរាប់មេទ័ពណាម្នាក់របស់ខ្ញុំក៏តែបាន ។

- ខ្ញុំគិតថា តំលៃអាស្រ័យថាតើភ្ញៀវនោះជាអ្នកណា ។

- ខ្ញុំគិតថាអីចឹងដែរ ។ តែសាកនិយាយថ្លៃជាមួយគេទៅ ។ ពិតហើយដែលនារីតែមានសិទ្ធិប្រកែកបានដែរ នៅពេលណាដែលគេប្រាប់ឈ្មោះ *សាមូរ៉ៃ* នោះ ។ តែសូមប្រាប់ទៅ *ម៉ាម៉ា - សាន* របស់ *គីគូ* ថា ខ្ញុំសង្ឃឹមថានារីនោះមិនមានអាកប្បកិរិយាខ្វះសុជីវធម៌ធ្វើអោយខ្ញុំខកចិត្តទេ ។ ហើយប្រាប់គាត់ទៀតថា *គីគូ* គឺជាខ្លាតនារីលេខមួយនៅ *មីស៊ីម៉ា* មិនមែននៅ *យេដូ* រឺ *អូសាកា* រឺ *ក្យូតូ* នោះទេ ដោយហេតុនេះ ខ្ញុំត្រូវអោយតំលៃតាម -



www.budinst.gov.kh www.elibraryofcambodia.org

*មីស៊ីម៉ា* មិនមែនតំលៃ *យេដូរី អូសាកាវី ក្យូតូ* នោះទេ ។

- ចាសពិតជាអ៊ីចឹងហើយលោកម្ចាស់ ។

*តូរ៉ាណាកា* ញោចស្មារបស់លោកដើម្បីបង្ហូរការឈឺចាប់ ។

- តើលោកម្ចាស់អនុញ្ញាតអោយខ្ញុំច្រៀងសរសៃជូនទេ ? រឺមួយក៏ទៅហៅ *ស៊ូរី* វិញ ?

- ទេ អរគុណនាងហើយ ។ ចាំប្រើ *ស៊ូរី* ពេលបន្តិចទៀត ។

ព្រះអាទិត្យទាបណាស់ទៅហើយ ។ ពពកភ្លឺទឹកកាន់តែក្រាស់ឡើង១ ។ លោកពោលទាំងរីករាយ :

- មានជីវិតរស់នៅ គឺពិតជាធំធេងមែន ។ ខ្ញុំស្ទើរតែស្តាប់លឺទឹកភ្លៀងដែលកំពុងត្រៀមប្រសូតចេញមក ។

- ចាសពិតមែនលោកម្ចាស់ ។

*តូរ៉ាណាកា* គិតមួយសន្ទុះ ទើបសូត្រជាកំនាព្យមួយឡើង :

**នភាល័យអាកាសា**

**ព្រះសុរិយារះរោសខ្វាខ្វាំ**

**ខ្សឹកខ្សួលជាប្រចាំ**

**ទឹកនេត្រាស្រក់ជាំជោក ។**

ខួរក្បាល *ម៉ារីកូ* វត់ជាស្វ័យប្រវត្តិស្វែងរកកំនាព្យចុងជូនជាមួយ *តូរ៉ាណាកា* ភ្លាម ។ នេះជាល្បែងដ៏ប្រជាប្រិយមួយក្នុងចំនោមពួក *សាមូរ៉ៃ* ។ មួយសន្ទុះក្រោយមក នាងសូត្រកំនាព្យតបវិញ :

**ប៉ុន្តែព្រៃព្រឹក្សា**

**របួសកាយារដោយទារយោ**

**ខ្សឹកខ្សួលក្រោមជំនោរ**

**ស្លឹកឈើស្លាប់ធ្លាក់ចាកមែក ។**

- ល្អណាស់ ! តែងបានល្អមែន !

*តូរ៉ាណាកា* សំលឹងមើលនាងទាំងពេញចិត្ត ។ *ម៉ារីកូ* ស្មៀក *គីម៉ូណូ* ពណ៌ពង



www.budinst.gov.kh www.elibraryofcambodia.org

ក្រសាមានរូបដើមឫស្សី ក្រណាត់រុំចង្កេះនាងពណ៌បៃតងចាស់ ។ លោកដណ្ដឹងសួរនៅក្នុងចិត្តថា បើសិនជា *ប៊ុនតាវ៉ូ* ស្លាប់ តើនាងព្រមទទួលធ្វើប្រពន្ធចុងអញឬអត់ ? លោករមែងចូលចិត្តស្រីមានបទពិសោធន៍ ស្រីមេម៉ាយប្ដីស្លាប់ រឺស្រីដែលលែងលះគ្នា តែលោកមិនចូលចិត្តស្រីរូបស្អាតពេក រឺប្រាជ្ញាពេក រឺកូនអ្នកមានពេក ព្រោះប្រភេទអស់នេះសុទ្ធតែនាំរឿងជានិច្ច ។

លោកអស់សំណើចខឹក ។ អញមិនដែលសួរនាងពីរឿងនេះ ព្រោះនាងមានអ្វី១ទាំងអស់ដែលអញមិនចង់ឃើញមាននៅក្នុងប្រពន្ធចុងរបស់អញ... លើកលែងតែអាយុនាង គឺត្រូវចិត្តអញម៉ាច់តែម្ដង ។ *ម៉ារីកូ* ឃើញអាកប្បកិរិយាប្លែករបស់លោកម្ចាស់ខ្លួន ក៏សួរឡើង :

- លោកម្ចាស់ ?

- ខ្ញុំកំពុងគិតពីកំនាព្យរបស់នាង *ម៉ារីកូ - សាន* ។

លោកតប ហើយក៏សូត្របន្ត :

**ចស្សាន្តរដូច**
**ម្ដេចប្រែត្រជាក់**
**ជំនោរបក់ធ្លាក់**
**សរណជាញជ័យ ៕**

នាងតបវិញភ្លាម :

**បើខ្ញុំមេះប្រើពាក្យសំដី**
**ប្រៀបបីស្លឹកឈើជ្រុះចាកមែក**
**អារម្មណ៍រីករាយពេញរនេក**
**ព្រោះតែកំនាព្យរបស់ខ្ញុំ ៕**

*តូរ៉ាណាកា* សើច ហើយធ្វើអោនគោរពនាង :

- ខ្ញុំសូមចាញ់ហើយ *ម៉ារីកូ - សាន* ។ មើលតើចង់បានរង្វាន់អ្វី ? ជាផ្លិត ? រឺក៏កន្សែងសំរាប់សក់នាង ?

- សូមអរគុណណាស់លោកម្ចាស់ ។ ចាស រឿងនេះស្រេចតែចិត្តសប្បាយរបស់លោកម្ចាស់ចុះ ។



www.budinst.gov.kh www.elibraryofcambodia.org

- មួយម៉ឺន *ក្លូ* មួយឆ្នាំសំរាប់កូនប្រុសនាង !

- លោកម្ចាស់ ពួកយើងមិនសមទទួលបាននូវសគុណបែបនេះទេ ។

- នាងបានឈ្នះ ។ ជ័យជំនះនិងភារកិច្ចត្រូវតែទទួលបានរង្វាន់ ។ *សារូជី* អាយុប៉ុន្មានហើយ ?

- ដប់ប្រាំ... ជិតដប់ប្រាំឆ្នាំហើយលោកម្ចាស់ ។

- អូហ៍ មែន... ថ្មីៗនេះវាភ្ជាប់ពាក្យជាមួយចៅស្រីម្នាក់របស់លោកម្ចាស់ *គីយ៉ាម៉ា* មែនទេ ?

- ចាស ពិតមែនលោកម្ចាស់ ។ ភ្ជាប់កាលពីខែដប់មួយឆ្នាំទៅ ។ សព្វថ្ងៃនេះវានៅឯ *អូសាកា* ជាមួយលោកម្ចាស់ *គីយ៉ាម៉ា* ។

- ល្អ យើងចាប់ផ្តើមពីមួយម៉ឺន *ក្លូ* ទៅសិន ។ ខ្ញុំនឹងធ្វើសារប្រគល់សិទ្ធិស្នេក នេះ ។ អីលូវនេះ កំនាព្យប៉ុននេះបានហើយ ។ សូមនាងជួយអោយមតិខ្ញុំវិញម្តង ។

- លោកម្ចាស់ មតិរបស់ខ្ញុំគឺ ពួកយើងទាំងអស់គ្នាមានសុវត្ថិភាព នៅក្នុងដៃរបស់លោក ដូចជាទឹកដីនេះអីចឹងដែរ ។

- ខ្ញុំចង់អោយនាងម៉ិតប្រាយបន្តិចទៅមើល ។

- ចាស គឺនាងខ្ញុំនិយាយម៉ិតប្រាយមែនណាលោកម្ចាស់ ។ ខ្ញុំសូមអរគុណចំពោះសប្បុរសធម៌ដែលលោកម្ចាស់បានផ្តល់ចំពោះកូនប្រុសខ្ញុំនេះ ។ កាយវិការនេះធ្វើអោយអ្វីៗត្រចះត្រចង់មែនទែនតែម្តង ។ ខ្ញុំជឿថា លោកធ្វើអ្វីក៏ដោយ គឺពិតជាត្រឹមត្រូវ ។ ខ្ញុំសូមស្បថថាខ្ញុំជឿអីចឹងមែន ។

- ល្អហើយ ។ តែខ្ញុំនៅតែចង់បានមតិនាងដដែលណឹង ។

ភ្លាមនោះនាងពោលតបដោយឥតមានការប្រុងប្រយ័ត្នអ្វីទាំងអស់ ហាក់ដូចជានាងកំពុងនិយាយទៅកាន់មនុស្សដែលមានឋានៈស្មើគ្នាម្នាក់អីចឹង :

- ដំបូងបង្អស់ លោកម្ចាស់ត្រូវទាក់ទាញជាសំងាត់លោកម្ចាស់ *សាតាគី* អោយមក



www.budinst.gov.kh www.elibraryofcambodia.org

នៅខាងលោកម្ចាស់វិញ ។ ខ្ញុំពិតជានឹងភ្ញាក់ផ្អើលជាពន់ពេកណាស់បើសិនជាលោកម្ចាស់មិនបានធ្វើការនេះរួចទៅហើយទេនោះ រឺអាចថាលោកម្ចាស់មានកិច្ចព្រមព្រៀងជាសំងាត់ជាមួយប្អូនប្រុសឪពុកទីទៃរបស់លោក ហើយលោកជំរុញអោយគាត់ " ចោលជួរ " នេះជាបងមដើម្បីជំរុញ *អ៊ីស៊ីដូ* អោយប្រកាន់ជំហរមួយខុសឆ្គង ។ បន្តមកទៀត : លោកនឹងមិនបើកការវាយប្រហារមុនឡើយ ។ លោកមិនដែលបើកការវាយប្រហារមុនឡើយ ហើយលោកតែងទូន្មានពីភាពអំនត់ជានិច្ច ។ លោកវាយលុកតែនៅពេលណាដែលលោកជឿជាក់ថាឈ្នះតែប៉ុនោះ ។ ដោយហេតុនេះ ការចេញបញ្ជាជាចំហនូវ *ផ្លែរមេឃក្រហម* គឺជាល្បិចបញ្ឆោតមួយទៀតតែប៉ុននោះ ។ បន្តមកទៀត ការជ្រើសរើសពេលវេលា ។ តាមមតិខ្ញុំ គឺលោកម្ចាស់ត្រូវធ្វើនូវអ្វីដែលលោកម្ចាស់នឹងធ្វើ ធ្វើជាចេញបញ្ជា *ផ្លែរមេឃក្រហម* តែមិនអនុវត្តទេ ។ នេះនឹងធ្វើអោយ *អ៊ីស៊ីដូ* ច្របូកច្របល់ ព្រោះជាការច្បាស់ណាស់ដែលពួកយកការណ៍នៅទីនេះ និងនៅ *យេដូ* ពិតជានឹងរាយការណ៍ពីផែនការរបស់លោក ហើយគាត់នឹងពង្រាយកំលាំងរបស់គាត់ដូចវង្វេងទិសនៅក្នុងអាកាសធាតុដ៏កខ្វក់យ៉ាងនោះដែរ ដើម្បីត្រៀមតទប់នឹងគ្រោះគំរាមកំហែងមួយដែលនឹងមិនកើតមានឡើងសោះឡើយនោះ ។ ក្នុងពេលនោះ លោកម្ចាស់នឹងប្រើរយៈពេលតែពីរខែខាងមុខនេះ ដើម្បីប្រមែប្រមូលសំព័ន្ធមិត្តរបស់លោក បន្ថយសំព័ន្ធមិត្តរបស់ *អ៊ីស៊ីដូ* និងបំបែកសំព័ន្ធភាពរបស់គាត់តាមគ្រប់មធ្យោបាយ ។ ហើយជាការពិតហើយ លោកត្រូវតែល្បួង *អ៊ីស៊ីដូ* អោយចេញក្រៅវិមាន *អូសាកា* ។ បើលោកមិនធ្វើយ៉ាងនេះទេ *អ៊ីស៊ីដូ* នឹងឈ្នះ រឺយ៉ាងហោចណាស់លោកត្រូវបាត់កៅអីអគ្គមហាសេនាដែរ ។ លោក .....

- ចំពោះរឿងណឹងមួយ ខ្ញុំបានបញ្ជាក់ជំហរខ្ញុំច្បាស់លាស់ណាស់ - *តូរ៉ាណាកា* ព្រមានទាំងទឹកមុខមាំ - នាងភ្លេចខ្លួនឯងហើយ ។

*ម៉ារីកូ* តបដោយឥតភ័យខ្លាច និងយ៉ាងរីករាយ :

- ខ្ញុំត្រូវនិយាយពីរឿងសំងាត់ទាំងឡាយនៅថ្ងៃនេះ ព្រោះតែរឿងចំនាប់ខ្មាំងនេះឯងលោកម្ចាស់ ។ ពួកគេទាំងនោះជាកាំបិតនៅក្នុងបេះដូងរបស់លោក ។



www.budinst.gov.kh www.elibraryofcambodia.org

- មួយម៉ឺន *ភូតូ* មួយឆ្នាំសំរាប់កូនប្រុសនាង !

- លោកម្ចាស់ ពួកយើងមិនសមទទួលបានទូវសគុណបែបនេះទេ ។

- នាងបានឈ្នះ ។ ជ័យជំនះនិងភារកិច្ចត្រូវតែទទួលបានរង្វាន់ ។ *សាបូជី* អាយុប៉ុន្មានហើយ ?

- ដប់ប្រាំ... ជិតដប់ប្រាំឆ្នាំហើយលោកម្ចាស់ ។

- អូហ៍ មែន... ថ្មីៗនេះវាភ្ជាប់ពាក្យជាមួយចៅស្រីម្នាក់របស់លោកម្ចាស់ *គីយ៉ាម៉ា* មែនទេ ?

- ចាស ពិតមែនលោកម្ចាស់ ។ ភ្ជាប់កាលពីខែដប់មួយឆ្នាំទៅ ។ សព្វថ្ងៃនេះវានៅឯ *អូសាកា* ជាមួយលោកម្ចាស់ *គីយ៉ាម៉ា* ។

- ល្អ យើងចាប់ផ្ដើមពីមួយម៉ឺន *ភូតូ* ទៅសិន ។ ខ្ញុំនឹងធ្វើសារប្រគល់សិទ្ធិស្ដែកនេះ ។ អីលូវនេះ កំនាព្យប៉ុននេះបានហើយ ។ សូមនាងជួយអោយមតិខ្ញុំវិញម្ដង ។

- លោកម្ចាស់ មតិរបស់ខ្ញុំគឺ ពួកយើងទាំងអស់គ្នាមានសុវត្ថិភាព នៅក្នុងដៃរបស់លោក ដូចជាទឹកដីនេះអ៊ីចឹងដែរ ។

- ខ្ញុំចង់អោយនាងម៉ិតប្រាយបន្តិចទៅមើល ។

- ចាស គឺនាងខ្ញុំនិយាយម៉ិតប្រាយមែនណាលោកម្ចាស់ ។ ខ្ញុំសូមអរគុណចំពោះសប្បុរសធម៌ដែលលោកម្ចាស់បានផ្ដល់ចំពោះកូនប្រុសខ្ញុំនេះ ។ កាយវិការនេះធ្វើអោយអ្វីៗត្រចះត្រចង់មែនទែនតែម្ដង ។ ខ្ញុំជឿថា លោកធ្វើអ្វីក៏ដោយ គឺពិតជាត្រឹមត្រូវ ។ ខ្ញុំសូមស្បថថាខ្ញុំជឿអ៊ីចឹងមែន ។

- ល្អហើយ ។ តែខ្ញុំនៅតែចង់បានមតិនាងដដែលណឹង ។

ភ្លាមនោះនាងពោលតបដោយឥតមានការប្រុងប្រយ័ត្នអ្វីទាំងអស់ ហាក់ដូចជានាងកំពុងនិយាយទៅកាន់មនុស្សដែលមានឋានៈស្មើគ្នាម្នាក់អ៊ីចឹង :

- ដំបូងបង្អស់ លោកម្ចាស់ត្រូវទាក់ទាញជាសំងាត់លោកម្ចាស់ *សាគាគី* អោយមក



www.budinst.gov.kh www.elibraryofcambodia.org

ទៅខាងលោកម្ចាស់វិញ ។ ខ្ញុំពិតជានឹងភ្ញាក់ផ្អើលជាពន់ពេកណាស់បើសិនជាលោកម្ចាស់មិនបានធ្វើការនេះរួចទៅហើយទេនោះ រឺអាចថាលោកម្ចាស់មានកិច្ចព្រមព្រៀងជាសំងាត់ជាមួយប្អូនប្រុសឪពុកទីទៃរបស់លោក ហើយលោកជំរុញអោយគាត់ " ចោលជួរ " នេះជាបងមដើម្បីជំរុញ *អ៊ីស៊ីដូ* អោយប្រកាន់ជំហរមួយខុសឆ្គង ។ បន្តមកទៀត : លោកនឹងមិនបើកការវាយប្រហារមុនឡើយ ។ លោកមិនដែលបើកការវាយប្រហារមុនឡើយ ហើយលោកតែងទទួនបានពីភាពអំនត់ជានិច្ច ។ លោកវាយលុកតែនៅពេលណាដែលលោកជឿជាក់ថាឈ្នះតែប៉ុននោះ ។ ដោយហេតុនេះ ការចេញបញ្ជាជាចំហនូវ *ផ្ទៃមេឃក្រហម* គឺជាល្បិចបញ្ឆោតមួយទៀតតែប៉ុននោះ ។ បន្តមកទៀត ការជ្រើសរើសពេលវេលា ។ តាមមតិខ្ញុំ គឺលោកម្ចាស់ត្រូវធ្វើនូវអ្វីដែលលោកម្ចាស់នឹងធ្វើ ធ្វើជាចេញបញ្ជា *ផ្ទៃមេឃក្រហម* តែមិនអនុវត្តទេ ។ នេះនឹងធ្វើអោយ *អ៊ីស៊ីដូ* ច្របូកច្របល់ ព្រោះជាការច្បាស់ណាស់ដែលពួកយកការណ៍នៅទីនេះ និងនៅ *យេដូ* ពិតជានឹងរាយការណ៍ពីផែនការរបស់លោក ហើយគាត់នឹងពង្រាយកំលាំងរបស់គាត់ដូចរំងទទានៅក្នុងអាកាសធាតុដ៏កខ្វក់យ៉ាងនោះដែរ ដើម្បីត្រៀមតទប់នឹងគ្រោះគំរាមកំហែងមួយដែលនឹងមិនកើតមានឡើងសោះឡើយនោះ ។ ក្នុងពេលនោះ លោកម្ចាស់នឹងប្រើរយៈពេលតែពីរខែខាងមុខនេះ ដើម្បីប្រមែប្រមូលសំព័ន្ធមិត្តរបស់លោក បន្ថយសំព័ន្ធមិត្តរបស់ *អ៊ីស៊ីដូ* និងបំបែកសំព័ន្ធភាពរបស់គាត់តាមគ្រប់មធ្យោបាយ ។ ហើយជាការពិតហើយ លោកត្រូវតែល្បួង *អ៊ីស៊ីដូ* អោយចេញក្រៅវិមាន *អូសាកា* ។ បើលោកមិនធ្វើយ៉ាងនេះទេ *អ៊ីស៊ីដូ* នឹងឈ្នះ រឺយ៉ាងហោចណាស់លោកត្រូវបាត់កៅអីអគ្គមហាសេនាដែរ ។ លោក .....

- ចំពោះរឿងណឹងមួយ ខ្ញុំបានបញ្ជាក់ជំហរខ្ញុំច្បាស់លាស់ណាស់ - *តូរ៉ាណាកា* ព្រមានទាំងទឹកមុខមាំ - នាងភ្លេចខ្លួនឯងហើយ ។

*ម៉ារីកូ* តបដោយឥតភ័យខ្លាច និងយ៉ាងរីករាយ :

- ខ្ញុំត្រូវនិយាយពីរឿងសំងាត់ទាំងឡាយនៅថ្ងៃនេះ ព្រោះតែរឿងចំនាប់ខ្ទាំងនេះឯងលោកម្ចាស់ ។ ពួកគេទាំងនោះជាកាំបិតនៅក្នុងបេះដូងរបស់លោក ។



www.budinst.gov.kh www.elibraryofcambodia.org

- ពួកទាំងនោះមានរឿងអ្វី ?

- សូមលោកម្ចាស់អធ្យាស្រ័យអត់ធ្មត់បន្តិច ។ ខ្ញុំប្រហែលជាមិនអាចនិយាយជាមួយលោកម្ចាស់តាមបែបដែល *អាន់ជីន - សាន* ហៅថា " ការជជែកគ្នាជាធំហ និងជាឯកជនបែបអង់គ្លេស " នេះបានទៀតទេ ។ លោកនឹងមិនទៅស្ងាត់ម្នាក់ឯងដូចដែលយើងទៅស្ងាត់តែពីរនាក់បែបនេះទៀតឡើយ ។ ខ្ញុំសូមលោកអភ័យទោសនូវកង្វះសុជីវធម៌របស់ខ្ញុំផង - *ម៉ារីកូ* ប្រឹងផ្ចុំគំនិត ហើយបន្តនិយាយក្នុងរបៀបស្មើភាពដដែល - មតិដាច់ណាត់របស់ខ្ញុំ គឺ *ណាកា - សាន* យល់ត្រឹមត្រូវណាស់ ។ លោកត្រូវតែធ្វើជាអគ្គមហាសេនា បើមិនដូចនោះទេ *លោកមិនបានបំពេញភារកិច្ចរបស់លោកចំពោះចក្រភព និងចំពោះត្រកូលមីណូវ៉ាក់ឡើយ* ។

- ម៉េចក៏នាងហ៊ាននិយាយបែបណឹង ?

*ម៉ារីកូ* នៅតែរក្សាភាពនឹងនដដែល ។ ភាពច្រលោតរបស់ *តូរ៉ាណាកា* ឥតបានធ្វើអោយនាងញ្ញោចសោះឡើយ :

- ខ្ញុំសូមជូនយោបល់ថា លោកម្ចាស់គួរតែរៀបការជាមួយជំទាវ *អូជីបា* ទៅ ។ នៅសល់ប្រាំបីឆ្នាំទៀត ទើប *យ៉ែនមុ៊ន* គ្រប់អាយុទទួលគ្រប់គ្រងអំនាច ។ ពេលគឺជារយៈពេលអនន្តភាព ( Eternity ) ។ អ្នកណាទៅដឹងថា តើកើតមានរឿងអីខ្លះក្នុងប្រាំបីខែនោះ កុំថាឡើយដល់ទៅប្រាំបីឆ្នាំ ។

- គ្រួសារនាងទាំងមូលអាចរលត់រលាយបានក្នុងរយៈពេលប្រាំបីថ្ងៃ !

- ចាសពិតហើយលោកម្ចាស់ ។ តែនេះមិនទាក់ទិននឹងលោកម្ចាស់ ហើយនឹងភារកិច្ចរបស់លោកម្ចាស់ ហើយនឹងរឿងនគរទេ ។ *ណាកា - សាន* យល់ត្រឹមត្រូវណាស់ ។ លោកត្រូវតែយកអំនាចដើម្បីផ្តល់អំនាច - រួចនាងបន្តដោយធ្វើជាបែបម៉ឺងម៉ាត់វិញម្តង - ហើយតើទីប្រឹក្សាជាទីទំនុកចិត្តរបស់លោកម្ចាស់អាចធ្វើ *សិបពូគូ* នៅពេលនេះ ឬចាំពេលក្រោយ ?

រួចនាងធ្វើហាក់ដូចជាចង់សន្ទប់ ។ *តូរ៉ាណាកា* ផ្ទុះសំណើចឡើងនៅពេលឃើញភាពរប៉ិលរប៉ូចស្ទើរមិនអាចជឿបានរបស់នាង ។ នៅពេលដែលលោកអាចនិយាយបានហើយ



www.budinst.gov.kh www.elibraryofcambodia.org

នោះ លោកក៏ពោលទាំងសំលេងដង្ហក់ :

- ខ្ញុំនឹងមិនយល់ពីនាងតែរហូតណឹង *ម៉ារីក្លូ - សាន* ។

- ចាស គឺលោកបានយល់ពីនាងខ្ញុំច្បាស់ណាស់ - នាងនិយាយដោយយកដៃជូតញើសដែលដក់នៅលើថ្ងាសនាងបណ្ដើរផង - លោកពិតជាមានចិត្តសន្ដោសណាស់ដែលបានអនុញ្ញាតអោយអណ្ដាប់ដំស្មោះត្រង់ម្នាក់ធ្វើអោយលោកសើច លោកបាននៅទ្រាំស្ដាប់សំនូមពររបស់នាង និងអោយនិយាយអ្វីដែលត្រូវនិយាយ ។ សូមលោកម្ចាស់សន្ដោសការព្រហើនរបស់នាងខ្ញុំនេះផង ។

- ហេតុអីបានជាខ្ញុំត្រូវសន្ដោស ? - *គូរ៉ាណាកា* ញញឹម ។

- ពីព្រោះដោយរឿងចំនាប់ខ្លាំង - នាងឆ្លើយយ៉ាងខ្លី ។

- អ្ហា រឿងពូកណុង ! - លោកបានប្រែកពារមុឹងមាត់ភ្លាមវិញដែរ ។

- ចាស ពិតហើយ នាងខ្ញុំត្រូវទៅ *អូសាកា* ។

- ណឹងហើយ ។ ខ្ញុំដឹងហើយ ។

☆ ☆

☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូកទី៣៨

ដោយមាន *ណាកា* អមជាមួយផងនោះ *ប្លាក់ថន* ដើរចុះកូនភ្នំទាំងលំបាក និង ទាំងចំបែងនៅក្នុងចិត្តសំដៅទៅមនុស្សទាំងពីរនាក់ដែលអង្គុយលើម៉ក់ ចំកណ្ដាលរង្វង់ក្រុមការពារ។ នៅឯនាយពួកការពារគឺជាជើងភ្នំទាំងឡាយ ដែលដោលខ្ពស់ទៅលើមេឃដេរដាសដោយពពក។ ថ្ងៃនេះហាក់ដូចជាធ្ងន់ពាប់តែម្ដង ។ ក្បាលគេឈឺខ្ទោកៗដោយម្យ៉ាងបណ្ដាលមកពីការព្រួយបារម្ភ របស់គេក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះផង ម្យ៉ាងមកពីការកង្វល់របស់គេចំពោះ *ម៉ារីកូ* ផង និងម្យ៉ាងទៀតគឺដោយក្នុងរយៈពេលយូរកំក្រែលដែរ ដែលគេមិនអាចនិយាយអីបាន ទាំងអស់ក្រៅតែពីនិយាយភាសាជប៉ុនប៉ុននោះ។ អីលូវនេះនៅពេលដែល គេមើលឃើញស្គាល់នាងភ្លាមការចំបែងមួយចំនួនរបស់គេក៏រលាយបាត់ទៅដែរ ។

ជាច្រើនលើកណាស់ដែលគេបានទៅផ្ទះ *អូមី* ដើម្បីមើល *មារីកូ* ក៏ដើម្បីស៊ើបសួរពីនាង។ បុរសសាមូរ៉ៃនេះរមែងអោយគេត្រលប់ទៅវិញយ៉ាងគួរសមតែយ៉ាងម៉ឺងម៉ាត់។ *អូមី* បានពោលប្រាប់គេក្នុងឋានៈជា *ភូម៉ូដាស៊ី* ពោលជាមិត្ត ថានាងបានសុខស្រួលបួលជាទេ ។

- កុំបារម្ភអី *អាន់ជីន-សាន់* ។ លោកយល់ទេ ?
- បាទយល់ ។

គេឆ្លើយតប ដោយគ្រាន់តែយល់ថាគេមិនអាចជួបនាងបានតែប៉ុននោះ ។

រួចបន្ទាប់មកគេត្រូវ *តូរ៉ាណាកា* ហៅអោយទៅជួប។ គេមានបំនងចង់និយាយច្រើនជាមួយលោកដែរ តែកង្វះពាក្យរបស់គេគ្មាននាំអ្វីក្រៅពីធ្វើអោយ *តូរ៉ាណាកា* កាន់តែមួម៉ៅឡើងវិញតែប៉ុននោះ។ *ភូជីកូ* បានទៅសួរសុខទុក្ខ *ម៉ារីកូ* ច្រើនដងដែរ ហើយនៅពេលដែលនាងត្រលប់មកវិញនាងតែងតែនិយាយប្រាប់គេថា *ម៉ារីកូ* សុខសប្បាយជាទេហើយនាងតែងតែនិយាយបន្ថែមជានិច្ចថា : « *ស៊ីនប៉ាយ ស៊ូរណា អាន់ជីន-សាន* ។ *វ៉ាការីម៉ាស៊ូ ? - កុំខ្វល់អី អាន់ជីន-សាន* ។ តើលោកយល់ទេ ?» ។

ជាមួយ *ប៊ុនតារ៉ូ* វិញហាក់ដូចជាគ្មានរឿងអីកើតឡើងទាំងអស់ ។គេពោលពាក្យគួរសមដាក់គ្នានៅពេលដែលគេជួបគ្នាពេលថ្ងៃ ។ លើកលែងតែពេលជួបគ្នាម្ដងម្កាល នៅឯផ្ទះមុជទឹក



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ិនតារ៉ូ* មានចរិតដូច សាមូរ៉ៃឯទៀត ពោលគឺមិនជាមិត្ត មិនជាសត្រូវ ។

តាំងពីព្រលឹមដល់ព្រលប់ *ភ្លាក់ផន* ត្រូវល្បឿនបន្ថែមនៃការរ៉ឹកហាត់ដេញគួចតែម្តង ។ គេត្រូវខិតខំលុបបំបាត់ភាពខកចិត្តរបស់គេ ដើម្បីប្រឹងបង្ហាត់ និង ដើម្បីប្រឹងហាត់រៀនភាសា ។ ដល់ពេលយប់ គេតែងតែសោះខ្យល់ជានិច្ច ។ ខ្លួនប្រាណគេក្តៅគគុក ព្រមទាំងជោកដោយញើសផង និង ទឹកភ្លៀងផងថែមទៀត ។ មិនដែលមានពេលណា ដែលគេមានអារម្មណ៍ ឯកោ និង មើលឃើញថា ខ្លួនឯងមិនមែនស្ថិតនៅក្នុងពិភពចំលែកពីខ្លួនដូចនៅពេលនេះទេ ។

រួចកាលពីបីថ្ងៃមុននេះ ភាពដ៏តក់ស្លុតមួយបានលេចលេញជារូបរាងឡើង ។ ថ្ងៃនោះ គឺជាមួយថ្ងៃមួយដ៏យូរនិងពោរពេញដោយសំនើម ។ នៅពេលព្រលប់គេបានបំផាយសេះវិលមក ដល់ផ្ទះវិញទាំងទន់ខ្លួនល្ហើយ ។ ហើយមួយរំពេចនោះភ្លាម គេមានអារម្មណ៍ពីភាពចលាចលមួយ ដែលនៅជិតជាប់នឹងផ្ទះរបស់គេភ្លាម ។ *ភូជីកូ* បានចេញមកទទួលគេទាំងរសាប់រសល់ ។

- *ណាន ដេ ស៊ូ កា ?*

*ភូជីកូ* និយាយតបនឹងសំនួររបស់គេយ៉ាងវែង និង ដោយរក្សាភ្នែកសំលឹងដីរហូត ។

- *វ៉ាការីម៉ាសេន* ។ ខ្ញុំមិនយល់ទេ ។ *ណាន ដេស៊ូ កា ?*

គេសួរជាថ្មីម្តងទៀត និង ទាំងធុញទ្រាន់ ដោយហេតុថាការនឿយហត់បានធ្វើអោយ គេសែនមួម៉ៅនៅក្នុងចិត្តជាពន់ពេកណាស់ទៅហើយ ។

*ម៉ារីកូ* ក៏នាំគេចូលទៅក្នុងសួនហើយលើកដៃចង្អុលទៅថ្នមផ្ទះ ប៉ុន្តែ *ភ្លាក់ផន* មើល ឃើញថាដំបូលហាក់នៅមាំទាំជាធម្មតាទេ ។ ក្រោយពីនិយាយវែង និងកាយវិការមួយចំភ្លុះទៀត ទើប *ភ្លាក់ផន* យល់បានថា *ភូជីកូ* ចង់ចង្អុលបង្ហាញទីកន្លែងដែលគេព្យួរមាន់ទោនោះឯង ។

- អូហ៍ ខ្ញុំភ្លេចអោយឈឹងអារឿងណឹង ។ *វ៉ាតាស៊ី...* - *ភ្លាក់ផន* នឹករកពាក្យនិយាយ តែគេនឹកមិនឃើញសោះ ដោយហេតុនេះហើយ គេក៏ញាក់ស្មាយ៉ាងល្ងិតល្ងៃ - *វ៉ាការីម៉ាស៊ី* ។ *ណាន ដេស៊ូតីជី កា* ។ ខ្ញុំយល់ហើយ ។ រួចមាន់ទោណឹងវាយ៉ាងម៉េច ?

ពួកអ្នកបំរើលួចសំលឹងមើលមក *ភ្លាក់ផន* តាមចន្លោះទ្វារ និង បង្អួច ក្នុងអាការៈតក់ ស្លុតយ៉ាងច្បាស់ក្រលែត ។



www.budinst.gov.kh www.elibraryofcambodia.org

- *វ៉ាការីម៉ាសេន ភូជីកូ-សាន ?* - ខ្ញុំមិនយល់ទេ *ភូជីកូ-សាន* ។

*ភូជីកូ* ដកដង្ហើមយ៉ាងវែង ហើយដោយកាយវិការញ៉ាំងរួចប្រាប់នាងធ្វើត្រាប់តាមអ្នកណាម្នាក់ដោះយកមាន់ទោ ហើយយកទៅកប់នៅទីឆ្ងាយ ។

- អា អ្ហាអ្ហា ! *វ៉ាការីម៉ាស៊ី ភូជីកូ-សាន* ។ *វ៉ាការីម៉ាស៊ូ* ។ តើវាខ្ពស់ទេ ? - *ប្លាក់ថន* សួរដោយគេមិនចេះពាក្យជប៉ុន គេធ្វើកាយវិការខ្ពប់ច្រមុះ បង្ហាញពីក្លិនស្អុយ ។

- *ហៃ! ហៃ! អាន់ជីន-សាន* ។ *ដូស្វូ កូមេនណាសៃ* ។

*ភូជីកូ* ធ្វើសំលេងរុយហើយដៃនាងគូសវាសរូបភាពពពកដេរដាស ។

- *អាហ៍ សូតេស៊ូ! វ៉ាការីម៉ាស៊ូ*

នាពេលនោះ គេមានបំនងចង់សុំទោស ហើយបើសិនណាជាគេចេះភាសាជប៉ុននោះ គេនឹងនិយាយថាគេសូមទោសចំពោះការរំខាននេះ ។ ប៉ុន្តែគេគ្រាន់តែញាក់ស្មា បន្ទូរភាពចុកចាប់ខ្លួនដោយនិយាយរង៉ូវ១ថា "*ស៊ីកាតាកាណៃ*" ដោយគេមានបំនងតែមួយគត់ គឺទៅស្រឹមខ្លួននៅក្នុងអាងទឹក និង ការចាប់សរសៃ ដែលជាភាពរីករាយមួយផ្តល់អោយជីវិតមានន័យសមរម្យរបស់វា ។ គេបែរខ្លួនចេញ ដោយនិយាយជាភាសាអង់គ្លេស :

- ប្រកាច់យក៏នេះ! បើសិនជាអញនៅផ្ទះពេលថ្ងៃពិតជាកត់សំគាល់បានទៅហើយ ។ ប្រកាច់យក៏ !

- *ដូស្វូ អានីជីន-សាន* ?

- *ស៊ីកាតា កាណៃ-ប្លាក់ថន* តបដោយសំលេងលឺជាងមុន ។

- *អាហ៍ សូតេស៊ូ អារីកាតូ កូស៊ាមាស៊ីតា* ។

- *តារេត្សូ តេស៊ូ កា?* អ្នកណាយក ?

- *អ៊ូយេតី-យ៉ា*

- អូហ៍ តាប៉ិឡប់ណឹងទេ ! - *អ៊ូយេតី-យ៉ា* ជាតាថៃសួនអត់ធ្មេញហើយដែលតែងថែទាំរុក្ខជាតិនានាដោយដៃយ៉ាងប៉ិនប្រសប់និងយ៉ាងថ្នាក់ថ្នម ហើយដែលបានធ្វើអោយសួនច្បាររបស់ *ប្លាក់ថន* នេះ គួរជាទីពិចពិលរមិលមើល - *យ៉ូយ មុំត្តេ គួរ អ៊ូយេតីយ៉ា* - ល្អហើយទៅហៅ



www.budinst.gov.kh www.elibraryofcambodia.org

*អ៊ុយេគី-យ៉ា* មកនេះ ។

*ភូជីកូ* គ្រវីក្បាល មុខនាងសដូចកំបោរ ។

- *អ៊ូយេគី-យ៉ា ស៊ីនតា កេស៊ូ ! ស៊ីនតា កេស៊ូ !* - *ភូជីកូ* និយាយខ្សាវៗ ។

- *អ៊ូអេគី-យ៉ា ស៊ីតាកូ ? ដូនយ៉ូទី ? ដូស៊ីតេ ? ដូស៊ីតេស៊ីនតាណូដា ?* យ៉ាងម៉េច ? ហេតុអី ? ចឺបានជាគាត់ស្លាប់ ?

*ភូជីកូ* ចង្អុលទៅកន្លែងដែលព្យុះមានទោ ហើយនិយាយថ្ងូរៗយ៉ាងវែងហើយដែល *ប្លាក់ថន* ស្តាប់មិនយល់អ្វីទាំងអស់ ។ រួចទើប *ភូជីកូ* ធ្វើកាយវិការកាប់មួយដាវ ។

- **ព្រះយេស៊ូជាម្ចាស់អើយ !** នាងសំលាប់មនុស្សចាស់ជរាម្នាក់គ្រាន់តែរឿងមាន់ទោដ៏សំអុយរបស់យក៏ណឹង រឺ ?

ពួកអ្នកបំរើក៏ស្ទុះចេញយ៉ាងស្រុះគ្នាមកដល់ក្នុងសួន ហើយលុតជង្គង់គ្រិបៗ ។ ពួកគេដាក់ក្បាលក្រាបទៅលើដីហើយស្ថិតនៅក្នុងស្ថានភាពបែបនេះ ។ សូម្បីតែកូនៗរបស់ចុងភៅក៏ស្ថិតក្នុងស្ថានភាពដូចគ្នានេះដែរ ។

- រួចចុះវាប្រកាច់ប្រកិនរឿងអីណឹង? - *ប្លាក់ថន* សឹងតែឆេះដុំដាច់ក្បាលដាច់កន្ទុយ ។

*ភូជីកូ* នៅរង់ចាំយ៉ាងស្ងៀមស្ងាត់រហូតដល់ទាំងអស់គ្នាមកជុំហើយ ទើបនាងលុតជង្គង់លំអោនខ្លួនគោរពដូចជាសាមូរ៉ៃដែលមានលក្ខណៈខុសគ្នាពីរបៀបគោរពរបស់កសិករ :

- *កូរេមេនណាសៃ ដូសូ កូរេមេនណា...*

- *កូរេមេនណាសៃ* ចុះកួតអី ! តើនាងមានសិទ្ធិអីមកធ្វើអញ្ចឹង ? អ្ហា ? - *ប្លាក់ថន* ជះស្រោចកំហឹងទាំងប៉ុន្មានដាក់ *ភូជីកូ* ដោយគ្មានសំចៃមាត់បន្តិចណាឡើយ - ព្រះអើយព្រះ ហេតុអីបានជាមិនសួរខ្ញុំមុនសិន ? អ្ហា ?

*ប្លាក់ថន* ខំប្រឹងអស់កំលាំងចិត្តដើម្បីទប់ចិត្តរបស់ខ្លួន ដោយគេដឹងថាអ្នកបំរើទាំងអស់ដែលនៅទីនេះសុទ្ធតែដឹងច្បាស់ណាស់ថា គេមានសិទ្ធិគ្រប់គ្រាន់ដើម្បីកាប់ចិញ្ច្រាំ *ភូជីកូ* និងពួកអ្នកបំរើទាំងអស់នៅក្នុងសួនច្បារនេះបានព្រោះតែពួកអស់នេះបានធ្វើអោយរូបគេមួម៉ៅ រឺ ក៏មិនចាំបាច់មានមូលហេតុអីសោះក៏តែបាន ហើយសូម្បីតែ *តូរ៉ាណាកា* ខ្លួនលោកផ្ទាល់ក្តីក៏មិនអាច



www.budinst.gov.kh www.elibraryofcambodia.org

មកជ្រៀតជ្រែកនៅក្នុងរឿងចាត់ចែងកិច្ចការក្នុងផ្ទះរបស់គេបានដែរ ។

គេឃើញកុមារម្នាក់ក្នុងកុមារទាំងឡាយនោះ ញ័រខ្លួនចំប្រប់ដោយការតក់ស្លុត និងស្លន់ស្លោ ។

- ឱ ព្រះអង្គជាម្ចាស់អើយ សូមអោយខ្ញុំមានថាមពលគ្រប់គ្រាន់ផង - *ប្លាក់ថន* ខំតោងឃិតខ្លួននឹងសសរមួយដើម្បីទប់ខ្លួន- ទេមិនមែនជាកំហុសរបស់អែងនោះទេ - គេនិយាយទាំងដង្ហក់ ដោយទាំងភ្លេចខ្លួនថាគេមិនមែននិយាយភាសាជប៉ុនឡើយ - នេះជាកំហុសរបស់នាងនេះទេ ។ គឺនាងអែង ។ នាងព្រាយឃាតកនេះ !

*ភូជីកូ* ងើបមុខឡើង ។ នាងប្រទះឃើញចង្អុលដៃដែលចង្អុលមកនាងក្នុងភាពវិនិច្ឆ័យទោសព្រមទាំងភាពស្អប់ខ្ពើមនៅលើផ្ទៃមុខរបស់ *ប្លាក់ថន* ។ នាងនិយាយតិចៗទៅកាន់ *នីកាតស៊ី* នារីអ្នកបំរើរបស់នាង ។

*នីកាតស៊ី* គ្រវីក្បាលហើយនៅតែបន្តក្រាបលន់តួអង្វរទៅទៀត ។

- *អ៊ីម៉ា !*

នារីអ្នកបំរើរត់ចូលទៅក្នុងហើយត្រលប់មកវិញ ដោយកាន់ទាំងដាវពិឃាតមកជាមួយផង ។ ទឹកភ្នែកស្រក់របាមលើផ្ទៃមុខរបស់នាង ។ *ភូជីកូ* ទទួលយកដាវហើយហុចទៅអោយ *ប្លាក់ថន* ដោយដៃទាំងទ្វេ ហើយថែមទាំងនិយាយដែល *ប្លាក់ថន* ពិតមែនតែមិនអាចយល់បានអស់ក្តីក៏គេអាចយល់បានពីន័យថា : " ខ្ញុំជាអ្នកទទួលខុសត្រូវ សូមលោកប្រហារខ្ញុំមកចុះ ព្រោះខ្ញុំបានធ្វើអោយលោកមានការមិនសប្បាយចិត្ត " ។

- **អ៊ុំយេ !** - *ប្លាក់ថន* ចាប់យកដាវហើយគ្រវាត់ចេញទៅឆ្ងាយ - នាងស្មានថាធ្វើអញ្ចឹងអាចអោយលោកតា *អ៊ូយេគី-យ៉ា* រស់ឡើងវិញបានរឺ ?

រួចទើបរំពេចនោះ គេភ្ញាក់ដឹងខ្លួនថាគេបានធ្វើអ្វី ហើយនឹងគេកំពុងធ្វើអ្វីនៅពេលនេះ ។

- ឱ ព្រះយេស៊ូជាម្ចាស់អើយ...

*ប្លាក់ថន* ក៏ដើរចេញពីពួកទាំងនោះ ។ ទាំងអស់សង្ឃឹម គេដើរឡើងទៅខ្ទលថ្មមួយ



www.budinst.gov.kh www.elibraryofcambodia.org

ដែលនៅពីលើភូមិ ហើយដែលមានវិហារមួយនៅក្បែរនោះដែរ ។ ហើយគេនៅអង្គុយស្រក់ទឹកភ្នែកនៅទីនោះ ។

គេស្រក់ទឹកភ្នែកពីព្រោះមនុស្សល្អម្នាក់បានស្លាប់ដោយឥតប្រយោជន៍ ហើយនេះពីព្រោះគេដឹងថាខ្លួនគេនេះតែម្តងដែលជាអ្នកធ្វើឃាតគាត់នោះ ។

- ឱ ព្រះជាម្ចាស់អើយ សូមសន្តោសប្រោសប្រណីដល់ខ្ញុំផង ។ ខ្ញុំជាអ្នកទទួលខុសត្រូវមិនមែន*ភូជីកូ* ទេ ។ ខ្ញុំជាអ្នកសំលាប់គាត់ ។ ខ្ញុំបានចេញបញ្ជាមិនអោយនរណាក៏ដោយក្រៅតែពីរូបខ្ញុំចេញ មកប៉ះមាន់ទោនេះទេ ។ ខ្ញុំបានសួរទៅ*ភូជីកូ* បញ្ជាក់ទៀតថាតើទាំងអស់គ្នាយល់ទេ ហើយនាងក៏បានប្រាប់ថាពួកគេទាំងអស់គ្នាបានយល់ហើយ ។ កាលនោះខ្ញុំបានចេញបញ្ជាដោយធ្វើជាម៉ាំទាំណាស់គ្រាន់តែកំប្លែងលេងសោះ ។ តែរឿងនេះមិនមែនសំខាន់ទៀតទេ នៅពេលនេះ ។ ខ្ញុំបានចេញបញ្ជាដោយស្គាល់ទាំងច្បាប់របស់ពួកគេ ស្គាល់ទាំងទំលាប់របស់ពួកគេរួចហើយ ។ តាចាស់បានបំពានទៅលើបញ្ជាដ៏ចំកួតរបស់អញ តើអោយ*ភូជីកូ* នាងធ្វើយ៉ាងម៉េចច្បែង ? ខ្ញុំទេដែលជាអ្នកត្រូវទទួលទោសនោះ ។

គេនៅអង្គុយស្រក់ទឹកភ្នែករហូតដល់យប់ជ្រៅទើបវិលត្រលប់ទៅផ្ទះរបស់ខ្លួនវិញ ។

ដូចសព្វដងដែរ*ភូជីកូ* នៅរង់ចាំគេដដែល ។ តែលើកនេះ នាងនៅតែម្នាក់ឯងទេ ។ ជាវត្រូវបានដាក់នៅលើភ្លៅរបស់នាង ។ នាងហុចជាវទៅអោយ*ភ្ញាក់ថុន* ដោយបន្ថឹពាក្យថា :

- *ដូសូ ដូសូ អាន់ជីន-សាន*

- *អ៊ីយេ* - គេនិយាយផងលូកដៃទៅទទួលជាវតាមរបៀបដែលត្រូវទទួលផង - *អ៊ីយេ ភូជីកូ-សាន។ ស៊ីកាតាកាណៃ នេ? កាម៉ា នេ?* - គេយកដៃទៅប៉ះនាងជាសញ្ញាសូមទោសដោយគេដឹងថាតើនាងត្រូវទទួលទ្រាំទ្រយ៉ាងណាចំពោះភាពពត្បិតភ្លើរបស់គេនេះ ។

*ភូជីកូ* ហូរទឹកភ្នែករហាម :

- *អារីកាតូ អារីកាតូ កូ...កូស៊ាម៉ាស៊ីតា អាន់ជីន-សាន* - សំដីនាងដាច់ៗ - *កូមេនណាសៃ...*

បេះដូងរបស់គេផ្តោតជាប់ទៅលើនាង ។



www.budinst.gov.kh www.elibraryofcambodia.org

- *អាន់ជីន-សាន ?*

- បាទ ? មានការអី *ណាកា សាន* ?

*ប្លាក់ថន* ទាញអារម្មណ៍ខ្លួនពីការរវើរវាយហើយសំលឹងមើលទៅយុវជនដែលកំពុងដើរក្បែរគេនេះ :

- សូមទោសតើលោកនិយាយថាម៉េច ?

- ខ្ញុំនិយាយថា ខ្ញុំសង្ឃឹមនឹងបានក្លាយជាមិត្តរបស់លោក !

- អាហ៍ សូមអរគុណ ។

- បាទ ហើយប្រហែលជាលោក....

*ណាកា* និយាយមួយប្រាវតែ *ប្លាក់ថន* ស្តាប់មិនបានទាល់តែសោះ

- សូមទោស ថាម៉េច ?

- បង្រៀន *នេ* ? យល់ទេបង្រៀន ? បង្រៀនពីពិភពលោក ?

- អូហ៍បាទ សូមទោស ។ តែថាបង្រៀនអី ?

- ពីរឿងទឹកដីបរទេស ។ ពីស្រុកក្រៅ ។ ពិភពលោក *នេ* ?

- អូ យល់ហើយ ។ បាទ ។ សាកល្បង ។

ពួកគេកាន់តែខិតមកជិតដល់ពួកការពារហើយ ។

- ចាប់ពីស្អែកទៅណា *អាន់ជីន-សាន* ។ មិត្ត *នេ* ?

- បាទ *ណាកា សាន* ។ សាកល្បង ។

- ល្អ ។

*ណាកា* ងក់ក្បាលទាំងពេញចិត្ត ។ នៅពេលដែលពួកគេមកដល់រង្វង់ពួកការពារហើយនោះ *កាណា* បញ្ជាអោយគេអែបបើកផ្លូវ ហើយធ្វើសញ្ញាអោយ *ប្លាក់ថន* ដើរចូលទៅតែម្នាក់ឯង ។ គេធ្វើតាមទាំងអារម្មណ៍សែនឯកោនៅក្នុងរង្វង់ មនុស្សទាំងនេះ ។ គេចូលទៅរកអ្នកទាំងពីរដោយ បន្ទីវាចាថា :

- *អូហាយ៉ូ តូរ៉ាណាកា-សាម៉ា ។ អូហាយ៉ូ ម៉ារីកូ-សាន ។*



www.budinst.gov.kh www.elibraryofcambodia.org

- *អូហាយ៉ូ អាន់ជីន-សាន* ។ *ដូស្ទ សុ៊ក៉ូ*-ទិវាសួស្ដី *អាន់ជីន-សាន* ។ សូមអញ្ជើញ អង្គុយ ។

*ម៉ារីកូ* ញញឹមពព្រាយទៅរកគេ :

- *អូហាយ៉ូ អាន់ជីន-សានី* ។ *អ៊ីកាកា តេស៊ូកា ?*

- *យ៉ូយ ដូម៉ូ* ។

*ប្លាក់ថន* សំលឹងមើលទៅនាងទាំងចិត្តរីករាយដែលបានជួបនាងនៅទីនេះ ។ គេនិយាយជាភាសាឡាតាំង :

- វត្តមានរបស់អ្នកស្រីធ្វើអោយខ្ញុំមានការសប្បាយចិត្ត ។សប្បាយចិត្តខ្លាំងក្លាតែម្ដង ។ ជាការល្អណាស់ដែលបានជួបអ្នកស្រីនៅទីនេះ តែនៅលើទឹកមុខនាងហាក់ដូចជាមានស្រមោលអ្វីមួយ ។ តើនេះមកពីហេតុអ្វីទៅ ?

- *ណាន ដា ?*

*តូរ៉ាណាកា សួរ* ។ នាងក៏និយាយប្រាប់ពីអ្វីដែលបាននិយាយ ។ *តូរ៉ាណាកា* គ្រហឹមរួចក៏និយាយឡើង :

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា លោកមានទឹកមុខហាក់ដូចជាមានកង្វល់ញ៉ាំញីខ្ញុំក៏ឯកភាពដែរ ។ លោកម្ចាស់សួរថា តើលោកមានកង្វល់ពីរឿងអ្វី ?

- អត់មានអ្វីទេ ។ *ដូម៉ូ តូរ៉ាណាកា-សាម៉ា* ។ *ណាន់ទេ ម៉ូ*- អត់មានអីទេ ។

- *ណាន ដា ?* - *តូរ៉ាណាកា* សួរដោយផ្ទាល់ខ្លួនលោកវិញម្ដង - *ណាន ដា ?*

- *ហៃ អ៊ីយេគី យ៉ា* ។

- *អ្កាសូតេស៊ូ !*

រួច *តូរ៉ាណាកា* និយាយយ៉ាងវែងទៅកាន់ *ម៉ារីកូ* ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថាមិនចាំបាច់កើតទុក្ខព្រួយ រឿងតាថៃសូននោះទេ ។ លោកបានអោយខ្ញុំជំរាបលោកថា នេះជាប្រកាន់យកជាផ្លូវការទៅលើទំរើមួយដែលតាថៃសូនដឹងយ៉ាងច្បាស់ថាគាត់បានធ្វើអ្វីនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំយល់ហើយ ។

- ចាស គឺពិតជាពិបាកណាស់សំរាប់រូបលោក ។ ប៉ុន្តែសូមលោកគិតទៅមើល *អាន់ជីន-សាន* មាន់ទោហើមស្អុយក្រោមកំដៅថ្ងៃ ។រុយរោមឡើងអែ ។ សុខភាពរបស់លោក របស់កំនាន់លោក និងរបស់មនុស្សទាំងអស់ក្នុងផ្ទះលោក ត្រូវតំរាមកំហែង ។ ហើយសូមលោកអភ័យទោសផងចុះ នៅមានការរអ៊ូរទាំតវ៉ាពីសំនាក់មេការនៅក្នុងផ្ទះ *អូមី-សាន* ថែមទៀត និង ពីអ្នកឯទៀតៗផងដែរ ។ បញ្ញាត្តិដ៏សំខាន់បំផុតក្នុងបញ្ញាត្តិនានារបស់ពួកយើង គឺបុគ្គលមិនអាចរំខាន *វ៉ា* ពោលគឺភាពសុខដុមរមនារបស់ក្រុមបានទេ ។ លោកចាំទេ ? ហេតុនេះ អ្វីមួយត្រូវតែធ្វើឡើង ។ លោកយល់ទេ គំរង់ ក្លិនគំរង់ គឺពួកយើងទទួលមិនបានទេ ។ នេះជាក្លិនដ៏អាក្រក់ជាងគេបំផុតសំរាប់ពួកយើង អោយខ្ញុំសូមទោសផងណាលោកនេះគឺខ្ញុំសាកល្បងប្រឹងសំរាប់លោក ហើយមេការក្នុងផ្ទះលោក...

- ចុះហេតុអីក៏មិនមករកខ្ញុំតែម្តងទៅ ? ហេតុអ្វីក៏គ្មានអ្នកណាម្នាក់និយាយប្រាប់ខ្ញុំសោះអញ្ចឹង ? - *ធ្លាក់ថន* សួរឡើង - មាន់ទោនេះគ្មានសារសំខាន់អីសោះសំរាប់ខ្ញុំ ។

- តើមានអ្វីដែលត្រូវនិយាយប្រាប់ទៅ ? លោកបានចេញបញ្ជា ។ លោកគឺជាអម្ចាស់នៅក្នុងផ្ទះលោក ។ ពួកគេមិនដឹងពីទំលាប់របស់លោក ហើយក៏មិនដឹងត្រូវធ្វើយ៉ាងម៉េចទៅទៀត ក្រៅតែពីដោះស្រាយទៅតាមទំលាប់របស់ពួកយើងតែប៉ុននោះ ។

នាងងាកទៅនិយាយជាមួយ *តូរ៉ាណាកា* មួយភ្លែត ហើយងាកមករក *ធ្លាក់ថន* វិញ :

- តើនេះជាការយ៉ាប់យ៉ឺនចំពោះលោកទេ ? តើលោកចង់អោយខ្ញុំនិយាយបន្តទៀតទេ ?

- សូមអញ្ជើញបន្តទៀតចុះ *ម៉ារីកូ-សាន* ។

- លោកច្បាស់ក្នុងចិត្តហើយណឹង ?

- ច្បាស់ហើយ ។

- បើអញ្ចឹងខ្ញុំបន្តទៀត ។ កាលនោះ មេការក្នុងផ្ទះរបស់លោក គឺចុងភៅធ្វេញតូចបានហៅអ្នកបំរើទាំងអស់មកប្រជុំ ។ លោក *មូរ៉ា* ដែលជាមេភូមិត្រូវបានគេអញ្ជើញអោយទៅ



www.budinst.gov.kh www.elibraryofcambodia.org

ចូលរួមជាផ្លូវការដែរ។ ពេលនោះគេបានសំរេចថា ពួក*អេតា* មិនអាចយកមាន់ទោលោកទៅចោលបានទេ ព្រោះនេះជារឿងក្នុងផ្ទះតែប៉ុណ្ណោះ។ ត្រូវតែជាអ្នកបំរើណាម្នាក់នៅក្នុងផ្ទះជាអ្នកយកមាន់នេះទៅកប់ ទោះបីត្បិតតែលោកបានចេញបញ្ជាយ៉ាងដាច់ណាត់មិនអោយអ្នកណាយកវាចេញទៅណាក៏ដោយ។ ជាការពិតហើយ កំនាន់របស់លោកត្រូវមានកាតព្វកិច្ចធានាអោយបញ្ជារបស់លោកត្រូវតែគោរពតាម។ តាថៃសួនបានសុំអោយគាត់ជាអ្នកយកមាន់ទោនោះទៅកប់។ រយៈពេលចុងក្រោយនេះ ទាំងពេលធ្វើការទាំងពេលទទួលទានដំណេក គាត់មានការចុកចាប់នៅក្នុងពោះគាត់យ៉ាងខ្លាំង ហើយរាល់ពេលដែលគាត់លុតជង្គង់ធ្វើស្មៅ រឺ ដាំដើមផ្កា គាត់ដង្ហក់ស្ទើរផុតដង្ហើម ដោយហេតុនេះហើយទើបគាត់បំពេញការងារមិនសមចិត្តដែលគាត់ចង់បានសោះ។ ចុងភៅជំនួយទីបីក៏បានស្នើសុំខ្លួនដែរ ដោយវាថាវានៅក្មេងណាស់ហើយទ្រើកណាស់ទៀតផង ហើយម្យ៉ាងទៀតចំពោះរឿងធំបែបនេះជីវិតវាមួយមិនសំខាន់ឡើយ។ នៅទីបំផុតគេបានសំរេចផ្តល់កិត្តិយសនេះទៅតាថៃសួន។ និយាយតាមពិតទៅ នេះគឺជាកិត្តិយសយ៉ាងធំមួយ*អាន់ជីន-សាន* ។ ទាំងអស់គ្នាបានលំអោនខ្លួនគោរពគាត់ហើយគាត់ក៏លំអោនខ្លួនគោរពតបគេវិញ ហើយបន្ទាប់មកគាត់ក៏យកមាន់ទោនោះទៅកប់ទាំងចិត្តសប្បាយរីករាយ។ ហើយទាំងអស់គ្នាក៏បានធូរទ្រូងសន្សឹកទៅដែរ។ នៅពេលត្រលប់មកវិញ គាត់បានទៅជួបផ្ទាល់នឹង*ភូជីកូ* ហើយបានប្រាប់នាងពីអ្វីដែលគាត់បានធ្វើ ពីប្រការដែលគាត់បានបំពានច្បាប់របស់លោក។ *ភូជីកូ* បានថ្លែងអំនរគុណតាថៃសួនដែលបានយកគ្រឿងមិនល្អនេះចេញហើយបានសុំអោយគាត់នៅរង់ចាំ។ នាងបានមកជួបសួរយោបល់ខ្ញុំថាតើនាងត្រូវធ្វើយ៉ាងណា ព្រោះរឿងនេះត្រូវបានសំរេចជាផ្លូវការ ហេតុនេះត្រូវតែមានដំណោះស្រាយជាផ្លូវការផងដែរ។ ខ្ញុំបានប្រាប់ទៅ*ភូជីកូ* ថាខ្ញុំមិនដឹងទេ*អាន់ជីន-សាន* ។ ខ្ញុំបានសួរទៅ*ប៊ុនតារ៉ូ-សាន* តែគាត់ថាគាត់ក៏មិនដឹងដែរ។ រឿងនេះស្មុគស្មាញព្រោះវាទាក់ទិននឹងរូបលោកនោះឯង ។ ដោយហេតុនេះហើយ ទើប*ប៊ុនតារ៉ូ-សាន* បានមកសួរលោកម្ចាស់*តូរ៉ាណាកា* ហើយលោកម្ចាស់ក៏បានជួបនឹងកំនាន់លោកដោយផ្ទាល់តែម្តង។

*ម៉ារីកូ* ងាកទៅរក*តូរ៉ាណាកា* វិញហើយនិយាយប្រាប់លោកថាតើនាងបាននិយាយដល់ចំនុចណាហើយ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* និយាយបន្តទៀតយ៉ាងញាប់ ។ *ភ្ញាក់ផន* តាមសំលឹងមើលអ្នកទាំងពីរជាប់ ។ នារីមានរូបរាងតូចច្រលឹង និង គួរអោយស្រលាញ់ក្នុងអាកាសៈយកចិត្តទុកដាក់ត្រង់គ្រាប់បុរសមានមាឌកន្លាស់ មាំដូចសិលា ក្រណាត់ក្រវាត់ចង្កេះត្រូវបានចងរឹតយ៉ាងតឹងលើក្បាលពោះដ៏ធំរបស់ខ្លួន ។ ក្នុងពេលនិយាយ លោក*តូរ៉ាណាកា* មិនប្រើកាយវិការដៃទៅជាមួយផងដូចមនុស្សជាច្រើនផងគ្នានោះទេ ។ លោករក្សាដៃលោកនៅស្ងៀម ។ ដៃឆ្វេងលោកច្រត់លើភ្លៅឯដៃស្តាំលោកជានិច្ចកាលដាក់លើដងដាវរបស់លោក ។

- *ហៃ តូរ៉ាណាកា-សាម៉ា* ។ ហៃ

*ម៉ារីកូ* ចោលភ្នែកមករក*ភ្ញាក់ផន* ហើយបន្តទៅទៀត :

- លោកម្ចាស់របស់យើងខ្ញុំបានអោយខ្ញុំពន្យល់រឿងនេះជូនលោក ។ សូមអភ័យទោសផងចុះ បើលោកជាជនជាតិជប៉ុនវិញនោះនឹងមិនជាការលំបាកអ្វីទេ *អាន់ជីន-សាន* ។ តែសូមលោកអធ្យាស្រ័យផងចុះ លោកជាជនជាតិបរទេស ទោះជាលោកម្ចាស់*តូរ៉ាណាកា* តែងតាំងលោកជា*ហាតាម៉ូតូ* ហើយក្តី ហើយនេះក៏ជាប្រការដែលត្រូវកំនត់តាមផ្លូវច្បាប់ថាតើលោកជា*សាមូរ៉ៃ* រឺក៏មិនមែនផងដែរ ។ ខ្ញុំមានកិត្តិយសជំរាបលោកថា លោកម្ចាស់បានកំនត់ថាលោកជា*សាមូរ៉ៃ* ហើយលោកទទួលបានសិទ្ធិរបស់*សាមូរ៉ៃ* ។ ដល់អញ្ចឹងទៅអ្វី១ត្រូវបានដោះស្រាយផុតជ្រះស្រលះអស់តែម្តងហើយងាយស្រួលទៅទៀត ។ អំពើឧក្រិដ្ឋកម្មមួយបានកើតឡើង ។ បញ្ហារបស់លោកត្រូវបានគេបំពានទាំងចេតនា ។ ច្បាប់គឺច្បាស់លាស់ណាស់ ។ មិនមានជំរើសអ្វីទាំងអស់- *ម៉ារីកូ* មានទឹកមុខមុតមាំ - ប៉ុន្តែលោកម្ចាស់*តូរ៉ាណាកា* យល់បានច្បាស់ណាស់នូវវិញ្ញោចរបស់លោកក្នុងរឿងប្រហារជីវិតនេះ ដោយហេតុនេះដើម្បីចៀសវាងកុំអោយលោកមានការវេទនានៅក្នុងចិត្ត លោកម្ចាស់បានបញ្ជាដោយផ្ទាល់អោយ*សាមូរ៉ៃ* របស់លោកម្នាក់ទៅបញ្ជូនតាថៃសួនទៅបរលោកទៅ ។

- ប៉ុន្តែហេតុអីក៏គ្មានអ្នកណាម្នាក់សួរខ្ញុំសិន ? មាន់ទោនោះគ្មានសារសំខាន់អ្វីទាំងអស់ចំពោះខ្ញុំ ។

- មាន់ទោគ្មានទាក់ទងអ្វីនឹងរឿងនោះទេ *អាក់ជីន-សាន* - *ម៉ារីកូ* ពន្យល់ - លោកគឺ



www.budinst.gov.kh www.elibraryofcambodia.org

ជាអម្ចាស់នៅក្នុងផ្ទះនោះ ។ ច្បាប់បានចែងថា គ្មានសមាជិកណាម្នាក់នៅក្នុងផ្ទះរបស់លោកអាចប្រកែកនឹងបញ្ជារបស់លោកបានគេ ។ តាថៃសួនបានបំពានច្បាប់ទាំងចេតនា ។ ពិភពទាំងមូលនឹងត្រូវវិលាយបើសិនជាគ្រប់គ្នាត្រូវបានអនុញ្ញាតអោយធ្វើល្ងង់មិនចេះច្បាប់នោះ ។ អ្នក...

*តូរ៉ាណាកា* កាត់សំដីដើម្បីនិយាយទៅកាន់នាង ។ *ម៉ារីកូ* ស្តាប់សំដីរបស់ *តូរ៉ាណាកា* ឆ្លើយនឹងសំនួរមួយពីររបស់លោក រួចទើបលោកធ្វើសញ្ញាអោយនាងបន្តទៀត ។

- *វែហ* ។ លោកម្ចាស់ *តូរ៉ាណាកា* ចង់អោយខ្ញុំបញ្ជាក់ជូនលោកថា ខ្លួនលោកផ្ទាល់បានចាត់ចែងដើម្បីអោយតាថៃសួនទទួលមរណភាពបានរហ័ស គ្មានការឈឺចាប់ និង ដោយថ្លៃថ្នូរសក្តិសមនឹងទំរើដែលគាត់បានធ្វើ ។ លោកបានអោយ *សាមូរ៉ៃ* ខ្ចីដាវរបស់លោកប្រើ ហើយដាវរបស់លោកម្ចាស់មុតណាស់ ។ហើយខ្ញុំក៏ត្រូវតែជំរាបលោកផងដែរ ថាតាថៃសួនមានមោទនភាពជាពន់ពេកដែលនៅក្នុងពេលចំនាស់ជរាបរបស់គាត់ហើយនេះ គាត់នៅមានលទ្ធភាពជួយដល់ផ្ទះរបស់លោកបានទៀតយ៉ាងនេះ ។ ជាពិសេសបំផុតគាត់មានមោទនភាព ដោយបានជួយលោករក្សាមុខមាត់ជា *សាមូរ៉ៃ* ដដែលនេះ ។ ហើយអ្វីដែលឧត្តុងឧត្តមជាងគេបំផុតនោះ គឺកិត្តិសយដែលទាំងអស់គ្នាបានផ្តល់ជូនគាត់ ។ យើងឥតបានប្រើពួកពេជ្ឈឃាត មកធ្វើរឿងនេះឡើយ *អាន់ជីន-សាន* ។ លោកម្ចាស់ *តូរ៉ាណាកា* ចង់អោយខ្ញុំបញ្ជាក់ចំនុចនេះអោយបានច្បាស់ជូនលោក ។

- សូមអរគុណ *ម៉ារីកូ-សាន* ។ សូមអរគុណដែលអ្នកស្រីបានបំភ្លឺខ្ញុំច្បាស់ពីរឿងនេះ - *ប្លាក់ថន* ងាកទៅរក *តូរ៉ាណាកា* ហើយលំអោនខ្លួនគោរពយ៉ាងត្រឹមត្រូវបំផុត - *ដូម៉ូ តូរ៉ាណាកា-សាម៉ា* ។ *ដូម៉ូ អារីកាតូ* ។ *វ៉ាកាវីម៉ាស៊ី* ។ *ដូម៉ូ* ។

*តូរ៉ាណាកា* លំអោនខ្លួនគោរពតបវិញយ៉ាងស្ម័គ្រស្មោះ :

- *យ៉ស អាន់ជីន-សាន* ។ *ស៊ីនប៉ាយស៊ូរូម៉ូណូចាណៃ នេ? ស៊ីកាតាណៃ នេ?* ល្អ ។ អីលូវនេះឈប់រវល់ ណា? តើលោកអាចធ្វើអ្វីបាន មែនទេ?

- *ណាទេម៉ូ* ។ គ្មានទេ ។



www.budinst.gov.kh www.elibraryofcambodia.org

*ថ្លាក់ថន* តបហើយគេឆ្លើយនឹងសំនួររបស់ *តូរ៉ាណាកា* ពីរឿងការរឹកបាត់កាំភ្លើងមូស្កេ ប៉ុន្តែអ្វីដែលគេជជែកនោះឥតបានចូលទៅដល់វិញ្ញាណរបស់គេឡើយ ។ អារម្មណ៍របស់គេកំពុងតែច្របូកច្របល់ ឃ្លេងឃ្លោង ក្រោមមុខទង្គិចនៃអ្វីដែលអ្នកទាំងនេះបានប្រាប់គេនោះ ។ គេបានបំពានទៅលើ*ភូជីកូ* នៅមុខពួកអ្នកបំរើទាំងអស់ ក៏ដូចជាបានបំពានទៅលើទំនុកចិត្តរបស់មនុស្សទាំងអស់ដែលនៅក្នុងផ្ទះខ្លួនឯងផងដែរ ក្នុងពេលដែល*ភូជីកូ* និងអ្នកឯទៀត គ្រាន់តែបានធ្វើនូវអ្វីដែលជាការត្រឹមត្រូវតែប៉ុននោះ ។

*ភូជីកូ* គ្មានកំហុសអ្វីទាំងអស់ ។ អ្នកឯទៀតក៏យ៉ាងដូចនោះដែរ ។

អញមិនអាចស្តារកែវិញនូវអ្វីដែលកើតមានកន្លងមកហើយនេះទេ ។ ក៏ដូចជាអ្វីដែលបានកើតមានចំពោះ*ភូជីកូ* និង តា*អ៊ូរយេគី-យ៉ា* ដែរ ។ រីក៏ដែលកើតមានឡើងចំពោះពួកគេ ។

តើអញអាចរស់នៅក្នុងភាពអាម៉ាស់នេះបានទេ ?

*ថ្លាក់ថន* នៅអង្គុយពែនភ្នែនទល់មុខ នឹង *តូរ៉ាណាកា* ។ ជំនោរខ្យល់សមុទ្ទបំប៉ោងស្រាល១ជាយ *គីម៉ូណូ* របស់គេ ។ ដាវរបស់គេទាំងពីរសៀតជាប់នឹងចង្កេះ ។ គេស្តាប់ និង ឆ្លើយតប នឹង សំនួរទាំងអារម្មណ៍ហិចហើរ ហើយក៏គ្មានអ្វីសំខាន់សំរាប់រូបគេដែរ ។ នាងបានប្រាប់គេថាសង្គ្រាម នឹង មកដល់ហើយ ។ នៅពេលណាគេបានសួរឡើង ។ ឆាប់១ នេះហើយ នាងតបដោយហេតុនេះលោកត្រូវតែចាកចេញដំណើរភ្លាមហើយរួមដំណើរជាមួយខ្ញុំមួយរយៈដោយថាខ្ញុំត្រូវធ្វើដំណើរទៅ*អូសាកា* ចំណែកឯរូបលោក១ត្រូវទៅ*យេដូ* ដើម្បីរៀបចំសំពៅ ចម្បាំងរបស់លោក ....

រួចរំពេចនោះ ភាពស្ងប់ស្ងាត់ដ៏ស្មើមមួយបានគ្របដណ្តប់ពាប់តែម្តង ។

រួចព្រះធរណីក៏ចាប់ផ្តើមរញ្ជួយ ។

*ថ្លាក់ថន* មានអារម្មណ៍ថាស្ងួតគេស្ទើរផ្ទុះបែកធ្លាយចេញមកក្រៅ ហើយគ្រប់សរសៃសសួងរបស់គេស្រែករទ្ធត់ញាប់ញ័រគ្រប់កន្លែង ។ គេសាកល្បងមើបឈរតែគេមើបមិនរួចសោះឡើយ ហើយគេក៏ឃើញពួកការពារស្ថិតក្នុងស្ថានភាព តែមួយនេះដែរ ។ *តូរ៉ាណាកា* និង *ម៉ារីកូ* ប្រឹងទប់ខ្លួននៅលើដីទាំងអស់សង្ឃឹមដោយប្រើជើងផងដៃផង ។ ស្លូវខ្ទ័រ និង ដំមហន្តរាយលើពី



www.budinst.gov.kh www.elibraryofcambodia.org

លើមេឃផងពីក្រោមដីផង។ សំលេងនេះហ៊ុមព័ទ្ធពួកគេខ្លាំងឡើង១ រហូតដល់ក្រដាសត្រចៀករបស់ពួកគេស្ទើរបែកធ្លាយ ។ ភាពរញ្ជួយញាប់ញ័រ និងពួកគេគឺរលាយចូលគ្នាតែមួយ។ រួចការរញ្ជួយនេះក៏ឈប់បាត់ តែរលកវានៅតែនៅមាននៅឡើយ។ គេមានអារម្មណ៍ចង់ក្អួត ខួរក្បាលរបស់គេប្រឹងស្រែកទាំងមិនជឿខ្លួនឯងថានេះជាដីគោកដែល នៅនឹងថ្កល់ និង មានសុវត្ថិភាព មិនមែនជាសមុទ្រដែលរញ្ជួយគ្រប់ពេលគ្រប់វេលានោះទេ ។ គេស្ដោះចេញនូវជាតិល្វីងជូរចត់ដែលមាននៅក្នុងមាត់របស់គេ ទន្ទឹម នឹង ភាពចង្អោរដែលចេះតែច្រាលចេញមកឥតអាក់ ។

នៅឯខាងជើងដុំថ្មទាំងដុំ១រមៀលធ្លាក់ពីលើភ្នំចុះទៅក្រោម ធ្វើអោយភាពខ្វះខ្វាយកាន់តែសំបើមណាស់ទៅទៀត។ ជំរុំពួកសាមូរ៉ៃមួយផ្នែកបានរលាយបាត់ស្រមោលទៅហើយ។*ប្លាក់ថន* វារពើមនៅលើដី។ *តូរ៉ាណាកា* និង *ម៉ារីកូ* ក៏យ៉ាងដូចនោះដែរ។ ក្នុងខួរក្បាល*ប្លាក់ថន* លឺខ្លួនឯងស្រែកអស់ទំហឹង តែគ្មានសំលេងអ្វីចេញផុតពីក្រអូបមាត់របស់គេបន្តិចបន្តួចណា ឡើយ ។

រួចរលករញ្ជួយក៏រលត់បាត់ទៅទៀតដែរ ។

ព្រះធរណីក៏នៅរឹងមាំដូចដើមរឹងមាំដូចសព្វដង រឹងមាំដូចដែលដីដែលត្រូវរឹងជាធម្មតាយ៉ាងនោះឯង ។ ដៃ ជង្គង់ និង សារពាង្គកាយគេទាំងមូល នៅតែញ័រទទ្រើតទោះប្រឹងទប់ក៏មិនបាន ។ គេប្រឹងទប់ខ្លួនប្រាណអោយនៅ នឹង ធម្មតាហើយនឹងខំទប់ដង្ហើមខ្លួនឯងអោយនៅជាប្រក្រតីឡើងវិញ ។

រួចសំរែកនៃប្រឹថពីក៏លាន់លឺជាថ្មីម្ដងទៀត។ ការរញ្ជួយដីជាលើកទីពីរបានចាប់ផ្ដើមឡើង។ ហើយខ្លាំងជាងលើកទីមួយទៅទៀត។ រួចធរណីក៏ត្រូវបែកជាពីរនៅឯចុងខ្ពង់រាបម្ខាងហើយរណ្ដៅប្រេះនេះ បានរត់យ៉ាងលឿនសំដៅមករកពួកគេ ហើយទៅជិតពីពួកគេតែប្រាំជំហានរួចបន្តដំណើររបស់ខ្លួនហួសទៅ ។ *ប្លាក់ថន* ប្រទះឃើញដោយសឹងមិនជឿភ្នែករបស់ខ្លួននូវភាពទ្រេតទ្រោតរបស់ *តូរ៉ាណាកា* និង *ម៉ារីកូ* នៅលើមាត់ជ្រោះដែលមុននេះបន្តិចជាដីរាបស្មើចេងសោះ ។ ហើយបន្ទាប់មកគេឃើញដូចនៅក្នុងសុបិនអាក្រក់មួយ នូវរូបកាយរបស់*តូណាក៉ាកា* ដែលនៅជិតមាត់ជ្រោះជាងនោះចាប់ផ្ដើមប្រុងធ្លាក់ចុះទៅក្រោម ។ គេជំនះភាពភាន់ភាំងរបស់គេ ហើយក៏ហក់ទៅឡាមចាប់ខ្សែក្រវាត់រុំចង្កេះលោកជាប់ ។ ព្រះធរណីនៅតែ



www.budinst.gov.kh www.elibraryofcambodia.org

ញ័រញ្ញើយដូចស្លឹកឈើត្រូវខ្យល់បក់នៅឡើយ ។

ចង្អៀកដីប្រេះនេះ មានជំរៅប្រហែលជិតដប់ម៉ែត និង មានទទឹងប្រហែលជាងបីម៉ែត។ ចំហាយមច្ឆុរាជផុះភាយពីខាងក្រោមមក ។ ភក់ហើយ នឹងដុំថ្មធ្លាក់ចុះទៅក្នុងចង្អៀកនេះអោយរពុយអួសទាញទាំង *តូរ៉ាណាកា* និង *ប្លាក់ថន* ទៅជាមួយផងដែរ។ *ប្លាក់ថន* តគេះតគះដៃជើងស្វែងរកអ្វីទប់ខ្លួនឯងផង ស្រែកអោយ *តូរ៉ាណាកា* ដែលស្ទើរធ្លាក់ចុះទៅហើយនោះអោយជួយជាកម្លាំងផង។ ថ្វីត្បិតតែលោកនៅល្ងាក់ល្ងើនៅឡើយក្តីក៏ *តូរ៉ាណាកា* បានប្រឹងខ្ទាំម្រាមជើងទៅលើជញ្ជាំងចង្អៀកដីនេះជាប់ ហើយដោយការជួយប្រឹងទាញរបស់ *ប្លាក់ថន* ផងដោយលោកខំប្រឹងធាក់ដោលឡើងដោយខ្លួនលោកផង ទីបំផុតលោកក៏បានចេញផុតពីរណ្តៅមរណៈនេះ ។ ហើយគេទាំងពីរក៏ប្រះខ្លួនដេកដង្ហក់នៅលើទីកន្លែងដ៏សុខសាន្តនោះទៅ ។

ក្នុងខណៈនោះ រលករញ្ជួយមួយទៀតបានបុកមកដល់ភ្លាម ។

ព្រះធរណីក៏របើហកចេញម្តងទៀត ។ *ម៉ារីកូ* ស្រែកឡើងយ៉ាងភ្ញាត់សំលេង ។ នាងខំប្រវេប្រវាចៀសចេញពីមុខចង្អៀកដីដែរ តែមាត់ក្រហែងថ្មីបានគ្របក់នាងឃើបតែម្តង។ *ប្លាក់ថន* ខំវារខ្មីតទៅដល់រង្វះមាត់ក្រហែង តែភាពរញ្ជួយដែលសងមកវិញនោះបានធ្វើអោយគេបាត់ល់នឹងបណ្តោយ ។ គេអោនសម្លឹងមើលទៅក្រោមឃើញ *ម៉ារីកូ* កំពុងនៅញ័រទទ្រើតលើដីមួយដុំដែលលយចេញពីជញ្ជាំងក្រហែងនេះ ។ ក្រហែងនេះមានជំរៅជិតម្ភៃម៉ែត និង មានទទឹងប្រហែលពីរម៉ែត ។ រង្វះមាត់ក្រហែងដែលនៅពីក្រោមខ្លួនរបស់គេ ចេះតែបាក់ចុះទៅយ៉ាងគួរបារម្ភ ។ គេសំរូតខ្លួនចុះទៅក្រោម ។ ភក់ហើយនិងកំទេចថ្មចូលញ៉ុកភ្នែករកមើលអ្វីមិនឃើញឡើយ។ ទីបំផុតគេស្រវាចាប់ដៃនាងបានហើយក៏ទាញនាងទៅកន្លែង លយចេញមួយទៀតដែលមានសុវត្ថិភាពជាង។ គេទាំងពីរនាក់កំពុងតែតគេះតគះរកលំនឹងទប់ខ្លួន ក៏ស្រាប់តែរលករញ្ជួយបុកមកម្តងទៀតភ្លាម។ ដីលយដែលពួកគេកំពុងឈរនោះក៏បាក់ចុះទាញពួកគេទៅជាមួយដែរ។ វិពេចនោះដៃរឹងដូចដែករបស់ *តូរ៉ាណាកា* ក៏ច្បាមជាប់ខ្សែចង្កេះរបស់គេទាន់ ធ្វើអោយគេចៀសផុតពីការធ្លាក់ចុះទៅរកសេចក្តីស្លាប់នេះបាន ។

- ព្រះអើយជួយផង !



www.budinst.gov.kh www.elibraryofcambodia.org

*ភ្លាក់ថន* ឧទានឡើង។ ដៃគេស្ទើររបូតចេញពីស្មាដោយប្រឹងទប់ប្រាណ *ម៉ារីកូ* ផងឯជើងនិងដៃម្ខាងទៀតប្រវេប្រវារកន្លែងទប់ខ្លួនឯងផង ។ *តូរ៉ាណាកា* នៅតែច្បាមជាប់ខ្សែចង្កេះរបស់គេរហូតដល់គេជាន់បានដីលយមួយកន្លែងយ៉ាងតូចមកទើបខ្សែចង្កេះនោះដាច់ភឹងតែម្តង។ ឆ្លៀត ពេលដែលរលករញ្ជួយស្ងប់បាត់មួយភ្លែតនេះ *ភ្លាក់ថន* ក៏រុញ *ម៉ារីកូ* អោយទៅឈរនៅបានកន្លែងមួយដែលខ្ពស់ជាង។ កំទេចកំទីផ្សេងៗធ្លាក់រពុយមកលើពួកគេទាំងពីរនាក់ ។ *តូរ៉ាណាកា* ហក់ទៅកន្លែងដែលមានសុវត្ថិភាពជាងទន្ទឹម នឹងស្រែកប្រាប់ពួកគេអោយរួតរះឡើង ដោយរង្វះក្រហែងដីនេះកំពុងហៀបបិទវិញហើយៗពួកគេនៅជ្រៅនោះនៅឡើយ ។ អីលូវនេះ *តូរ៉ាណាកា* មិនមានលទ្ធភាពអ្វី នឹងជួយពួកគេបានទៀតឡើយ ។ ការតក់ស្លុតបានផ្តល់នូវកម្លាំងយក្សមួយដល់ *ភ្លាក់ថន* តែម្តង។ ទីបំផុតគេសំរេចរុញ *ម៉ារីកូ* ឡើងទៅលើហើយ *តូរ៉ាណាកា* ក៏ចាប់កដៃនាងអូសឡើងផុតពីមាត់រង្វះក្រហែង ។ *ភ្លាក់ថន* ប្រវេប្រវាឡើងតាមនាង តែគេត្រូវធ្លាក់ចុះទៅក្រោមវិញ ដោយផ្ទៃកលយដែលគេឈរនៅពីលើនោះបានបាក់ស្រុតចុះ។ ជញ្ជាំងក្រហែងដែលនៅម្ខាងទៀត កំពុងតែខិតចូលមកយ៉ាងគួរអោយស្លុត។ មួយភ្លែតនោះគេគិតថាគេច្បាស់ជាជាប់ក្នុងគំនាបក្រហែងនេះជាមិនខាន ប៉ុន្តែគេបានប្រឹងរើខ្លួនទាល់តែរួច ហើយហក់ស្ទុះឡើងមកដល់មាត់រង្វះបានត្រឹមពាក់កណ្តាលខ្លួន ។ គេនៅក្រាបលើមាត់រង្វះដែលនៅតែបន្តប្រេះរញ្ជួយ សួតគេដង្ហក់រកខ្យល់ហើយគេគ្មានកម្លាំងកំហែងអី នឹងប្រឹងវារចេញពីមាត់រង្វះអោយបានផុតផងទេ ។ មាត់រង្វះកាន់តែខិតចូលជិតឡើងៗ រួចឈប់ស្ងៀមឈឹងតែម្តង ។ ពេលនេះរង្វះមានប្រវែងប្រហែលជាងមួយម៉ែត ហើយជំរៅជិតពីរម៉ែតតែប៉ុណ្ណោះ ។

ភាពរញ្ជួយទាំងប៉ុន្មានបានបាត់អស់រលីង ។ ប្រឹថពីនៅនឹងថ្កល់ ។ ភាពស្ងាត់ជ្រងំបានមកគ្របដណ្តប់ទីនេះវិញម្តង ។

ម្នាក់ៗនៅក្រាបរង់ចាំគ្រោះមហាភ័យនេះចាប់ផ្តើមម្តងទៀត ។ *ភ្លាក់ថន* ក៏ចាប់ផ្តើមងើបឡើងទាំងញើសពេញខ្លួន ។

- *អ៊ីយេ* !

*តូរ៉ាណាកា* ធ្វើសញ្ញាអោយគេអង្គុយចុះវិញ ។ មុខរបស់លោកប្រលាក់ដីស្រមូស ។



www.budinst.gov.kh www.elibraryofcambodia.org

នៅសៀតផ្ការរបស់លោក មានស្នាមរបួសមួយយ៉ាងជ្រៅ ដែលបណ្តាលមកពីក្បាលលោកទង្គិចនឹងថ្ម ។

ពួកគេនៅតែបន្តរង់ចាំទាំងដង្កក់ដើមទ្រូងចូនំពាប់មាត់ល្ងឹងចង់ក្អួត ។ ពួកកងការពារនាំគ្នាក្រោកឡើងហើយមានខ្លះក៏ស្ទុះស្ទារត់សំដៅមករក*តូរ៉ាណាកា*តែត្រូវលោកស្រែកឃាត់ :

- *អ៊ីយេ ! ម៉ាតេ !* ចាំសិន !

ពួកគេទទួលស្តាប់តាមបញ្ជាហើយក៏លុតជង្គង់ក្រាបបន្តទៀតទៅ ។ ការរង់ចាំដូចជាគ្មានពេលបញ្ចប់សោះតែម្តង ។ រួចក៏ស្រាប់តែសត្វស្លាបមួយទទះស្លាបបោះពួយចេញពីដើមឈើមួយហើរត្រង់ទៅលើមេឃប្រកបដោយសំលេងចេចចាច ។ រួចសត្វស្លាបមួយ ទៀតក៏បោះពួយទៅតាមប្រុយ ។ *ក្ខាក់ថន* គ្រវីក្បាលជជុះញើសដែលចូលពេញភ្នែករបស់ខ្លួន ម្រាមដៃដែលបាក់ក្រចកចេញឈាមរហាមរបស់គេ នៅតែច្បាមស្មៅជាប់នៅឡើយ។ រួចគេ ឃើញស្រមោចមួយវារគតើមនៅក្នុងស្មៅ ។ រួចមួយទៀត ហើយមួយទៀត ។ ពួកវាចាប់ផ្តើមចេញរកអាហារវិញហើយ ។

គេងើបអង្គុយទាំងនៅញ័រខ្លួនចំប្រប់នៅឡើយ :

- តើមានសុវត្ថិភាពហើយរឺនៅ ?

*ម៉ារីកូ* ឥតឆ្លើយតបនឹងគេឡើយ ។ នាងនៅតែភាន់ភាំង នឹង ក្រហែងដីដែលនៅចំហធ្លុងនៅលើដីនៅឡើយ ។ គេក៏វារទៅជិតនាង :

- អ្នកស្រីអត់អីទេ អ្ហី ?

- ចាស... ចាស ... ។

នាងតបទាំងដង្ហក់ ។ មុខនាងប្រលាក់ដីស្រមក ។ គីម៉ូណូ របស់នាងទក់ខ្ទុកខ្ទូរនិងឡើងគគ្រិច ។ ស្បែកជើងនាងមិនដឹងជាបាត់តាំងពីពេលណាមកទេ ។ ផ្ចិតនាងក៏យ៉ាងដូចនោះដែរ ។ គេជួយលើកនាងចេញឆ្ងាយពីរង្វះក្រហែង ។ នាងនៅមិនទាន់ប្រមូលស្មារតីបានពេញលេញវិញនៅឡើយ ។ រួចគេងាកទៅ*តូរ៉ាណាកា*វិញម្តង :

- *អ៊ីកាគា ដេស៊ូកា ?*



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* មិនទាន់អាចនិយាយចេញទៅឡើយ ។ ទ្រូងរបស់លោកដូចត្រូវគេជិះសំពង ដៃ និង ជើងដាច់ឆ្អូតជាច្រើនកន្លែង ។ លោកលើកដៃចង្អុលបង្ហាញក្រហែងដែលហៀបតែក្របាក់លេបលោកអំបាញ់មិញនេះ ហើយដែលពេលនេះបានក្លាយជាកូនចង្អូរយ៉ាងតូចមួយតែប៉ុណ្ណោះ ។ ទៅដល់ខាងចុងខាងជើងចង្អូរនេះរីកធំបន្តិច ប៉ុន្តែមិនជ្រៅ និង មិនធំដូចកាលពីពេលមុននេះបន្តិចឡើយ ។

*ប្លាក់ថន* ញាក់ស្មា :

- *កាម៉ា* ។

*តូរ៉ាណាកា* ជេរបញ្ចោរមួយប្រាវ ស្តោះទឹកមាត់មួយខ្ទាច់ហើយបញ្ចោរបន្ថែមទៀត ។ នេះដើម្បីលោកអាចនិយាយចេញសំលេងរួច ។ ថ្វីត្បិតតែ *ប្លាក់ថន* មិនយល់អស់ភាសាដែល *តូរ៉ាណាកា* បានប្រើក្នុងការជេរបញ្ចោរនេះក្តីក៏គេយល់បានល្មម នឹងផ្ទុះសំណើចឡើងបូកបញ្ចូលទាំងដោយការធូរទ្រូងដែលបានគង់វង្សជីវិតផង ។ មួយសន្ទុះក្រោយមក *តូរ៉ាណាកា* ក៏ផ្ទុះសំណើចតាម ហើយភាពក្អាកក្អាយរបស់អ្នកទាំងពីរក៏បានរាលដាលឆ្លងទៅដល់ *ម៉ារីកូ* ផងដែរ ។

*តូរ៉ាណាកា* ក៏ងើបឈរឡើង ។ ងើបទាំងប្រយ័ត្នប្រយែង ។ អាស្រ័យដោយចំហាយរីករាយនៃជីវិត លោកក៏លោតចាក់ត្នុតពីលើក្រហែងដី ហើយឈប់មួយភ្លែតដើម្បីធ្វើសញ្ញាអោយ *ប្លាក់ថន* ទៅចូលរួមជាមួយលោក ។ នៅពេលដែលគេទាំងពីរមានកម្លាំងកំហែងខ្លះៗឡើងវិញហើយ *ប្លាក់ថន* ក៏ងាកទៅសួរ *ម៉ារីកូ* :

- តើអារញ្ជួយដីណឹងចប់មែនទែនហើយ *ម៉ារីកូ-សាន* ?

- ចប់ហើយ រហូតដល់ពេលក្រោយទៀត ។

នាងនិយាយបណ្តើរ បន្តបំបោសដីចេញពីដៃ និង គីម៉ូណូ នាងបណ្តើរ ។

- តើរាល់ដងអីចឹងអ្វី ?

- ទេ ។ ជួនកាលខ្សោយមែនទែន ។ ជួនកាលមានរញ្ជួយម្តងទៀតក្រោយណឹងមួយថ្ងៃរឺកន្លះថ្ងៃ ។ជួនកាលមានរញ្ជួយតែម្តងក៏តែមានដែរ ។ គ្មានអ្នកណាដឹងបានទេ *អាន់ជីន-សាន*។ វាចប់រហូតដល់ពេលដែលវាចាប់ផ្តើមសាជាថ្មីទៀត ។ *កាម៉ា នេ* ?



www.budinst.gov.kh www.elibraryofcambodia.org

ពួកការពារសំលឹងមើលមកពួកគេដោយឥតកំរើកខ្លួន ដោយគេរង់ចាំបញ្ជារបស់ *តូរ៉ាណាកា* ។ នៅខាងជើងភ្លើងកំពុងឆាបឆេះយ៉ាងសន្ធោសន្ធៅក្នុងជំរំស្នាក់នៅរបស់កងទ័ព ។ ពួកសាមូរ៉ៃកំពុងព្យាយាមពន្លត់ភ្លើងផង ជីកកាយគំនរថ្មដើម្បីរុករកអ្នកដែលត្រូវកប់ក្រោមនោះផង ។ នៅខាងឯកើត *យ៉ាប៊ូ តូមី* និង *ប៊ុនតារ៉ូ* ឈរជាមួយពួកការពារឯទៀតនៅឯចុងក្រហែង។ ពួកគេមិនមានគ្រោះថ្នាក់អ្វីទេ ក្រៅពីរលាត់ជាំសាច់បន្តិចបន្តួច ។ ពួកគេក៏កំពុងរង់ចាំបញ្ជារបស់ *តូរ៉ាណាកា* ដែរ ។ *អ៊ីតូរ៉ាជី* បានបាត់ខ្លួនទៅហើយ ដោយត្រូវព្រះធរណីស្រូប ។

*ប្លាក់ថន* លែងរវីរវល់នឹងអ្វីទាំងអស់ ។ការប្រមាថខ្លួនឯងដែលគេធ្លាប់មានបានរលាយបាត់អស់ ហើយគេមានអារម្មណ៍យ៉ាងសែនស្ងប់ស្ងាត់ ។ ពេលនេះអារម្មណ៍របស់គេមិនទប់បាននូវមោទនភាពដែលគេបានក្លាយខ្លួនជាសាមូរ៉ៃ បានទៅ *យេដូ* បានសំពៅ បានធ្វើសឹកសង្គ្រាមបាន *សំពៅខ្មៅ* និងបានវិលត្រលប់មកជាមួយសាមូរ៉ៃវិញដូចដើម ។ គេចោលភ្នែក សំលឹងមើលទៅ *តូរ៉ាណាកា* ក្នុងបំនងចង់សួរសំនួរបួនដប់ តែគេឃើញ *រ៉ៃមីញ៉ូ* នេះក៏កំពុងលង់ទៅក្នុងអារម្មណ៍របស់ខ្លួនឯងដែរ ហេតុនេះគេដឹងថាគឺជាការខ្វះសុជីវធម៌ណាស់ ដែលរំខានលោកនៅពេលនេះ ។ នៅមានពេលម៉ាគំនរទៀតដែរ-គេគិតទាំងរីករាយនៅក្នុងចិត្តហើយក៏បែរទៅរកមើល *ម៉ារីកូ* វិញ ។ នាងកំពុងរៀបរយសក់ និង មុខមាត់របស់នាង ហេតុនេះគេក៏មិនសំលឹងមើលនាងទៀតដែរ ។ គេក៏ប្រាសខ្លួនដេកសំលឹងមើលទៅមេឃ ដើម្បីរង់ចាំយ៉ាងអត់ធ្មត់ ។ ដីដែលនៅពីក្រោមខ្នងគេជះកម្ដៅឧណ្ហៗ ។

មកដល់ពេលនេះទើប *តូរ៉ាណាកា* និយាយឡើងដោយម៉ឺងម៉ាត់ :

- *ដូម៉ូ អាន់ជីន-សានទេ? ដូម៉ូ* ។
- *ដូស្ហូ តូរ៉ាណាកា-សាម៉ា ។ ណានេ ម៉ូ ។ ហួមប៊ុន នេ ?* - គ្មានអ្វីទេ *តូរ៉ាណាកា-សាម៉ា* ។ ការកិច្ច ។

រួចដោយគេមិនចេះពាក្យបានច្រើនហើយ និង ដោយចង់អោយបានច្បាស់ចំគំនិតរបស់ខ្លួនផងនោះ គេក៏ពោលទៅកាន់ *ម៉ារីកូ* :

- *ម៉ារីកូ-សាន* សូមអ្នកស្រីជួយពន្យល់ជួសខ្ញុំបន្តិច អីលូវនេះខ្ញុំហាក់ដូចជាបានយល់



www.budinst.gov.kh www.elibraryofcambodia.org

ហើយពីអ្វីដែលអ្នកស្រី និងលោកម្ចាស់ *តូវ៉ាណាកា* និយាយរឿង *កាម៉ា* ហើយ នឹង ពីភាពល្ងង់ខ្លៅដែលខំបារម្ភពីបច្ចុប្បន្ននេះ ។ រឿងជាច្រើនដែលអីលូវនេះបានក្លាយជាច្បាស់ជាងមុន ។ ខ្ញុំមិនដឹងថាមកពីហេតុអីទេ នេះប្រហែលពីដើមមកខ្ញុំមិនដែលតក់ស្លុតដូចពេលនេះក៏មិនដឹង ហើយរឿងនេះជួយដុះខាត់ខួរក្បាលខ្ញុំទៅ តែទោះជាយ៉ាងម៉េចទេខ្ញុំហាក់ដូចជាពិតបានច្បាស់ជាមុន ។ ដោយហេតុនេះរាល់កង្វល់ឈឺក្បាលទាំងនេះគឺជាការឥតប្រយោជន៍ពិតមែន មិនអីចឹង? *កាម៉ា*។ ពិតហើយ ខ្ញុំយល់ពី *កាម៉ា* ហើយ តើនាងយល់បានទេ ?

- ចាស យល់-រួចនាងក៏បកប្រាប់ទៅ *តូវ៉ាណាកា* ។

- គាត់មានប្រសាសន៍ថា:ល្អ *អាន់ជីន-សាន* ។ *កាម៉ា* ជាការចាប់ផ្ដើមនៃពុទ្ធិ ។ បន្តមកទៀតគឺខន្តី ។ ខន្តីមានសារសំខាន់ណាស់ ។ អ្នកខ្លាំងគឺអ្នកដែលមានខន្តី *អាន់ជីន-សាន* ។ ខន្តីគឺការទប់បាននូវអារម្មណ៍ទាំងប្រាំពីរៈគំនុំ.ស្រលាញ់.សប្បាយ.បារម្ភ.កំហឹង.ទុក្ខព្រួយ.ខ្លាច ។ បើលោកមិនចុះញ៉ម នឹង អារម្មណ៍ទាំងប្រាំពីរទេ លោកនឹងមានខន្តីហើយពេលនោះលោក នឹងយល់បានពីរាល់ទំរង់ នៃវត្ថុគ្រប់យ៉ាង ហើយលោកនឹងស្ថិតនៅដោយសុខដុមរមនាជាមួយ នឹងអនន្តភាព(Eternity) ជាមិនខាន ។

- តើអ្នកស្រីជឿលើរឿងហ្នឹងដែរ *ម៉ារីកូ-សាន ?*

- ជឿ ។ ជឿណាស់ ។ ខ្ញុំសាកល្បងកាន់ខន្តីដែរ តែលំបាកណាស់ ។

- ខ្ញុំឯកភាព ។ ហើយនៅមាន *វ៉ា* ទៀត គឺសុខដុមរមនា ភាពស្ងប់ស្ងាត់ និងនថែមទៀត *ទេ?*

- ចាស ។

- សូមជំរាបលោកម្ចាស់ *តូវ៉ាណាកា* ផង ថាខ្ញុំសូមថ្លែងអំនរគុណយ៉ាងស្មោះចំពោះអ្វីដែលគាត់បានធ្វើចំពោះតាថៃសូន។ មុននេះខ្ញុំមិនបានអរគុណគាត់ដោយប្រាជ្ញក ដោយចេញពីបេះដូងពិត១របស់ខ្ញុំទេ។ សូមជំរាបគាត់ថាអញ្ជើង។

- មិនចាំបាច់ទេ *អាន់ជីន-សាន* ។ លោកបានដឹងរួចទៅហើយ ថាមុននេះលោកគ្រាន់តែសំដែងជាការគួរសមតែប៉ុននោះ។



www.budinst.gov.kh www.elibraryofcambodia.org

- ម៉េចបានជាគាត់ដឹងបាន ?

- ខ្ញុំបានជំរាបលោកហើយថាគាត់ជាមនុស្សវាងវៃបំផុតក្នុងលោកនេះ ។

*ប្លាក់ថន* ញញឹម ។

- ណ៎ា ខ្ញុំបាននិយាយហើយថាលោកជ្រុះអាយុចេញច្រើនហើយ - រួចនាងនិយាយជាភាសាឡាតាំងវិញម្តង -អីលូវនេះ លោកបានក្លាយជាខ្លួនលោកពិតប្រាកដវិញហើយ ដល់អញ្ចឹងទៅលោកគួរអោយបេញចិត្តជាងពេលមុន ។

ភ្នែករបស់ *ម៉ារីកូ* ពោរពេញដោយភាពគក់ក្តៅ ហើយនាងគេចមិនអោយ *តូរ៉ាណាកា* ឃើញវាឡើយ ។ *ប្លាក់ថន* ប្រទះឃើញភាពប្រុងប្រយ័ត្នរបស់នាង ធ្វើអោយគេកត់សំគាល់ភ្លាម ។ គេក្រោកឈរឡើងហើយសំលឹងមើលទៅតាមក្រហែងដី រួចដោយយ៉ាងប្រយ័ត្នប្រយែង គេក៏លោតចុះទៅក្នុងនោះបាត់ទៅ ។

*ម៉ារីកូ* ប្រវេប្រវាស្ទុះក្រោកឡើងដោយការភ័យខ្លាច តែ *ប្លាក់ថន* ក៏ងើបចេញពីប្រហែងនោះមកវិញយ៉ាងរហ័ស ដោយដៃរបស់គេមានកាន់ដាវរបស់ *ភូជីកូ* ផង ។ ដាវនេះនៅតែស្ថិតនៅក្នុងស្រោមរបស់វាដដែល ថ្វីត្បិតតែស្រោមនេះសុទ្ធតែភក់ និង រលាត់ដោយអន្ទើក្តី ។ ដាវខ្លី របស់គេបានបាត់ទៅហើយ ។

គេលុតជង្គង់ពីមុខ *តូរ៉ាណាកា* ហើយហុចដាវរបស់គេតាមរបៀបដែលត្រូវហុចដោយនិយាយយ៉ាងសាមញ្ញ :

- *ដូស្ហូ តូរ៉ាណាកា-សាម៉ា ។ ការ៉ាសាមូរ៉ៃ នីសាមូរ៉ៃ* នេ ?- សូមអធ្យាស្រ័យលោកម្ចាស់ *តូរ៉ាណាកា* រវាងសាម៉ូរ៉ៃ នឹង សាម៉ូរ៉ៃមែនទេ ?

- *ដូម៉ូ* អាន់ជីន-សាន ។

ស្តេចត្រាញ់ នៃតំបន់ *ក្វាន់តូ* ទទួលយកដាវហើយសៀតវាទៅនឹងចង្កេះ ។ *រួចលោក* ញញឹមឈោងទៅទះស្មា *ប្លាក់ថន* ខ្លាំង១ ដោយពោលថា :

- *តូម៉ូ នេ* ? មិត្ត មែនទេ ?

- *ដូម៉ូ* ។



www.budinst.gov.kh www.elibraryofcambodia.org

រួច*ភ្លាក់ថន* ចោលភ្នែកសំលឹងមើលទៅទីឆ្ងាយ ។ ស្នាមញញឹមរបស់គេរលាយបាត់អស់ ។ ផ្សែងខ្មៅងងឹតបានអណ្តែតត្រសែតថ្កោលឡើងចំពីលើភូមិ ។ គេក៏សួរទៅ*តូវ៉ាណាកា* ថាតើគេអាចចាកចេញពីទីនេះបានហើយរឺនៅ ព្រោះថាគេចង់ទៅមើលថាតើ*ភូជីកូ* បានសុខទុក្ខយ៉ាងណាដែរ ។

- គាត់ថាបាន*អាន់ជីន-សាន* ។ ហើយពួកយើងត្រូវជួបគាត់នៅឯបន្ទាយនៅពេលបាយពេលយប់នេះ ។ មានរឿងមួយចំនួនដែលលោកម្ចាស់ចង់ជជែកជាមួយលោក ។

*ភ្លាក់ថន* វិលត្រលប់ទៅឯភូមិវិញ ។ អ្វីៗត្រូវហិនហោចអស់រលីង ។ ផ្លូវត្រូវវៀចវិល្លមើលលែងស្គាល់ ។ តែទូកទាំងឡាយនៅតង់វង្សល្អទេ ។អគ្គីភ័យនៅមានច្រើនកន្លែងនៅឡើយ ។ អ្នកភូមិនាំគ្នាជញ្ជូនធុងខ្សាច់ និង ធុងទឹកដើម្បីពន្លត់ភ្លើង ។ គេបត់តាមផ្លូវមួយ ។ ផ្ទះរបស់*អូមី* ទ្រេតទៅម្ខាង ឯផ្ទះរបស់គេវិញមានតែផេះតែប៉ុននោះ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូកទី ៣៩

*ភូជីកូ* ត្រូវរបួស ឯ *នីកាគស៊ី* នារីបំរើរបស់នាងវិញបានបាត់បង់ជីវិតទៅហើយ ។ ការរញ្ជួយលើកទីមួយនេះបានធ្វើអោយបាក់សសរកន្លោងផ្ទះ ហើយជះធ្យូងចង្ក្រានពាសពេញ ។ *ភូជីកូ* និង *នីកាគស៊ី* ត្រូវធ្នឹមធ្លាក់សង្កត់ជាប់ ហើយភ្លើងក៏បានឆាបឆេះរូបរាងកាយ *នីកាគស៊ី* ឡើងសន្ធោសន្ធៅដូចចន្លុះ ។ *ភូជីកូ* ត្រូវបានគេជួយអោយចេញទាន់ ។ កូនរបស់ចុងភៅម្នាក់ក៏ត្រូវស្លាប់ដែរ ។ ក្រៅពីនេះទាំងអស់គ្នាគ្រាន់តែមានរបួស និងថ្លោះដៃជើងបន្តិចបន្តួចតែប៉ុណ្ណោះ។ ពួកគេទាំងអស់សុទ្ធតែសំដែងការរីករាយយ៉ាងខ្លាំង នៅពេលដែលឃើញថា *ថ្លាក់ថន* នៅរស់រានមានជីវិត ហើយគ្មានរបួសអ្វីទាំងអស់នោះ ។

*ភូជីកូ* កំពុងសំរាកស្ទើរសន្លប់ស្ទើរដឹងខ្លួននៅលើកំរាលមួយ ដែលដណ្តើមបានពីចំនីភ្លើងក្បែររបងសួនច្បារដែលនៅឥតមានខូចខាតអ្វីបន្តិចណាទេ។ នាងស្ទើរពេបយំនៅពេលដែលឃើញថា *ថ្លាក់ថន* មិនមានរបួសអ្វីនោះ។ នាងពោលខ្សាវៗ :

- សូមអរគុណព្រះអង្គដែលបានការពារលោកមិនអោយមានរបួស *អាន់ជីន-សាន* ។

នាងប្រឹងងើប ថ្វីត្បិតតែនាងនៅល្ងាក់ល្ងើយ៉ាងណាក្តី តែ *ថ្លាក់ថន* សូមអោយនាងកុំកំរើកធ្វើចលនាអ្វីទាំងអស់។ ជើងទាំងពីរ និង ត្រគាករបស់នាងត្រូវរលាកយ៉ាងធ្ងន់ធ្ងរ ។ គ្រូពេទ្យកំពុងព្យាបាលនាងដោយរុំស្បៃពាសដោយកាកតែ និងថ្នាំផ្សេងៗទៀតនៅ លើអវយវៈរបស់នាង ដើម្បីបន្ថយភាពរោលរាលនៃភ្លើង ។ *ថ្លាក់ថន* ខិតខំលាក់ភាពកង្វល់របស់ខ្លួន ហើយអង្គុយចាំរហូត ដល់គ្រូពេទ្យបញ្ចប់ការងារខ្លួន ទើបសាកសួរស្ងាត់ៗទៅគ្រូពេទ្យ :

- *ភូជីកូ-សាន យ័យកា?* *ភូជីកូ* ស្រួលបួលទេ ?

- *វ៉ៃ* ។

គ្រូពេទ្យញញក់ស្មា រួចបន្ត :

- *កាម៉ា នេ?*

- *វ៉ៃ* ។

គេធ្លាប់ឃើញអ្នកដើរសំពៅច្រើនគ្នាហើយដែលត្រូវរលាកភ្លើងស្លាប់ ហើយនេះល្មម



www.budinst.gov.kh www.elibraryofcambodia.org

និងអោយគេដឹងថា ការរលាកភ្លើងធ្ងន់ធ្ងរ គឺគ្រោះថ្នាក់ណាស់ របួសចំហបែបនេះរមែងចាប់ផ្ដើមរលួយក្នុងរវាង ពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះ ហើយគ្មានអ្វីអាចទប់ស្កាត់ដំបៅ នេះមិនអោយរាលដាលបានទេ ។

គេពោលបន្ត :

- ខ្ញុំមិនចង់ឃើញនាងស្លាប់ទេ ។

- *ជូស្វ ?*

គេនិយាយជាភាសាជប៉ុន ទើបលោកគ្រូពេទ្យគ្រវីក្បាល ហើយនិយាយប្រាប់គេថា នាងប្រាកដជាស្រួលបួលឡើងវិញជាមិនខាន ។ នាងនៅក្មេងហើយខ្លាំងក្លាណាស់ :

- *ស៊ីកាតា កាណៃ* ។

លោកគ្រូពេទ្យនិយាយ រួចលោកបានណែនាំអោយពួកនារីអ្នកបំរើរក្សាស្បៃរុំអោយនៅសើមជានិច្ចហើយលោកក៏បានអោយថ្នាំមួយចំនួនទៀតទៅ *ញូក់ថន* ដើម្បីព្យាបាលរបួសរបស់ខ្លួនគេផ្ទាល់ផងដែរ ដោយលោកបញ្ជាក់ថាគេនឹងបានស្រួលបួលឡើងវិញ ក្នុងពេលឆាប់ៗនេះ ។ រួចលោកគ្រូពេទ្យក៏រូតរះសំដៅទៅផ្ទះបែកបាក់របស់ *អូមី* ដែលនៅឯខាងលើជំរាលកូនភ្នំនោះទៅ ។

*ញូក់ថន* ឈរនៅមាត់ទ្វាររបងដែលឥតមានទទួលការខូចខាតអ្វីដែរទេ ។ ព្រួញរបស់ *ប៊ុនតារ៉ូ* នៅតែដោតឆ្កឹងលើមេបង្គោលរបងដដែល ។ គេយកដៃទៅស្ទាបព្រួញ ដោយគ្មានអារម្មណ៍អ្វីទាំងអស់ ។ គឺជា *កាម៉ា* ដែលធ្វើអោយនាងត្រូវរលាកភ្លើងយ៉ាងនេះ - គេគិតយ៉ាងស្រងេះស្រងោចនៅក្នុងចិត្ត ។

រួចគេក៏វិលមកមើល *ភូជីកូ* វិញ ។ គេបញ្ជាអោយនារីបំរើយកទឹកតែមកអោយហើយគេក៏ជួយនាងទទួលទានតែនេះ និងនៅកាន់ដៃនាងរហូតនាងលង់លក់ទៅ ។ ពួកអ្នកបំរើដើររុករើកកាយយកអីវ៉ាន់ដែលនៅសល់ពីភ្លើងឆេះ ហើយដែលអាចប្រើបាន ។ ពួកគេធ្វើការយ៉ាងរហ័សរហួន និងដោយមានជំនួយពីអ្នកភូមិខ្លះផង ។ ពួកគេដឹងថា ភ្លៀងនឹងធ្លាក់មកក្នុងពេលឆាប់ៗនេះហើយ ។ បុរសបួននាក់កំពុងខិតខំតំលើងជំរកបណ្ដោះអាសន្នមួយ ។



www.budinst.gov.kh www.elibraryofcambodia.org

- *ដូស្ហូ អាន់ជីន-សាន* ។

បុរស ចុងភៅបានហុចតែក្តៅហុយៗ ទៅអោយគេដោយប្រឹងលុបបំបាត់ភាពខ្លោចផ្សា ចេញពីមុខរបស់ខ្លួន ។កូនស្រីដែលស្លាប់នោះគឺជាកូនសំនព្វរបស់បុរសនេះ ។*ប្លាក់ថុន* តប :

- *ដូម៉ូ* ។ *ស៊ូមីម៉ាសិន* - ខ្ញុំសោកស្តាយណាស់ ។

- *អារីកាតូ អាន់ជីន-សាន* ។ *កាម៉ា នេ* ?

*ប្លាក់ថុន* ងក់ក្បាលទទួលតែពីបុរសនេះ ដោយធ្វើជាមិនបានកត់សំគាល់នូវភាពខ្លោចផ្សា ដែលផិតនៅលើវង្វង់មុខរបស់បុរសនេះឡើយ ។ បន្តិចក្រោយមក *សាមូរ៉ៃ* ម្នាក់បានពាំនាំសំដី របស់ *តូរ៉ាណាកា* ដែលប្រាប់អោយ *ប្លាក់ថុន* និង *ភូជីកូ* ទៅដេកនៅឯក្នុងបន្ទាយសិន រហូតដល់ ផ្ទះត្រូវបានសាងសង់ហើយឡើងវិញ ។គ្រែស្នែងពីរក៏បានមកដល់ ។ *ប្លាក់ថុន* លើកនាងយ៉ាងថ្នមៗ ទៅដាក់នៅក្នុងគ្រែស្នែងមួយ ហើយក៏អោយគេជូននាង ហើយនឹងពួកនារីអ្នកបំរើទៅមុន ។គេក៏ អោយគ្រែ ស្នែងរបស់គេត្រលប់ទៅវិញដែរ ដោយប្រាប់ថាគេនឹងទៅតាមក្រោយនៅពេលបន្តិច ទៀត ។

ភ្លៀងបានចាប់ផ្តើមធ្លាក់ហើយ ប៉ុន្តែគេឥតរវីរវល់យកចិត្តទុកដាក់ឡើយ ។ គេអង្គុយលើ ថ្មមួយដុំនៅក្នុងសួនច្បារ ហើយដែលជាកន្លែងមួយធ្វើអោយគេមានការរីករាយនៅក្នុងចិត្តជាង អ្វីៗទាំងអស់ ។ អីលូវនេះអ្វីៗ ក៏ខ្ទេចខ្ទីក្រលាប់ចាក់អស់ហើយ ។កូនស្ពានតូចច្រលឹងត្រូវបាក់បែក អណ្តូងបែកខ្ចាត់ខ្ចាយ កូនប្រលាយទឹកក៏រលាយបាត់រូបរាង ។ គេនិយាយតែម្នាក់ឯង :

- កុំទៅគិតនោះ ។ ថ្មមិនដែលងាប់ទេ ។

*អ៊ូយេគី-យ៉ា* តាធ្វើសួនបាននិយាយប្រាប់គេថា សួនត្រូវរៀបចំជុំវិញដុំថ្មហើយបើគ្មានដុំ ថ្មទេសួនគឺជាកន្លែងទទេស្អាត រឺ ជាកន្លែងសំរាប់ដាំដុះតែប៉ុណ្ណោះ ។

មានថ្មមួយដុំនោះប្រេះសព្វកន្លែងហើយចម្លាតាសោះ តែតា *អ៊ូយេគី-យ៉ា* បានដាក់វានៅ ចំកន្លែងមួយដែលបើគេប្រឹងសំលឹងមើលវាយូរនៅវេលាព្រះសុរិយាចូលអស្តង្គតនោះ ពន្លឺក្រហម ព្រាលៗដែលជះចេញពីសរសៃ និង ពីធាតុគ្រីស្តាល់ដែលកប់នៅក្នុងសាច់ថ្មនោះ ធ្វើអោយគេ មើលឃើញនូវជួរភ្នំ បន្តដោយជ្រលង និង បឹងបួរដ៏សែនជ្រៅ ហើយនៅឯនាយ គឺជាជើងមេឃ



www.budinst.gov.kh www.elibraryofcambodia.org

ដីខ្មៅស្រងាត់មួយ ។

- ខ្ញុំដាក់ឈ្មោះឯងថា *អ៊ូយេតី-យ៉ា-សាម៉ា* ។

*ប្លាក់ថន* និយាយបណ្ដើរ យកដៃទៅស្ទាបថ្ងួបណ្ដើរ ។ ហើយកាយវិការនេះធ្វើអោយគេមានការពេញចិត្តនៅក្នុងអារម្មណ៍ផងដែរ ហើយគេដឹងថាបើសិនជាតា *អ៊ូយេតី-យ៉ា* នៅរស់រានមានជីវិតនោះ គាត់ក៏ប្រាកដជាពេញចិត្តផងដែរហើយ ។ តែទោះជាគាត់ទទួលមរណភាពហើយក្ដី ក៏គាត់ប្រហែលជាដឹងពីការដាក់ឈ្មោះនេះដែរហើយមើលទៅ ។ អាចប្រហែលជា *កាមី* គាត់កំពុងស្ថិតនៅទីនេះផងដែរមើលទៅ - *ប្លាក់ថន* គិតនៅក្នុងចិត្ត ។ ពួកកាន់និកាយ *ស៊ីនតូ* ជឿថាពេលណាមនុស្សស្លាប់ទៅគេក្លាយជា *កាមី* ហើយ ...

- តើ *កាមី* ជាស្អីទៅ ម៉ារីកូ-សាន ?

- *កាមី* ពន្យល់មិនកើតទេ *អាន់ជីន-សាន* ។ នេះដូចជាខ្មោចព្រាយ តែមិនមែនជាខ្មោចព្រាយទេ ដូចជាព្រលឹងតែមិនមែនជាព្រលឹងទេ ។ អាចថាជាធាតុគ្មានរូបគ្មានរាង របស់វត្ថុរីមនុស្សក៏បាន.... លោក ប្រហែលជាដឹងហើយថាមនុស្សនៅពេលស្លាប់ទៅក្លាយជា *កាមី* តែដើមឈើ រី ដុំថ្ម រី រុក្ខជាតិ នានា រី ផ្ទាំងគំនូរ នេះក៏ជា *កាមី* ផងដែរ ។ គេគោរព *កាមី* តែគេមិនធ្វើសក្ការៈបូជាចំពោះ *កាមី* ទេ ។ *កាមី* ស្ថិតនៅចន្លោះឋានសួគ៌ និង ឋានមនុស្សលោក ហើយចុះមកលេងនគរនេះ រី ចាកចេញទៅវិញក្នុង ពេលជាមួយគ្នា ។

- ចុះ *ស៊ីនតូ* វិញ ? តើ *ស៊ីនតូ* ជាអ្វីទៅ ?

- សូមទោសទៅចុះ នេះក៏ពន្យល់មិនកើតដែរ ។ នេះដូចជាសាសនា តែមិនមែនសាសនាទេ ។ ដំបូងនេះគឺគ្មានទាំងឈ្មោះផង យើងគ្រាន់តែហៅថា *ស៊ីនតូ* គឺមាគ៌ា *កាមី* កាលពីមួយពាន់ឆ្នាំមុននេះ ដើម្បីកុំអោយច្រលំ និង *ប៊ូឈ្សូ* គឺមាគ៌ាព្រះពុទ្ធ ។ ថ្វីត្បិតតែវាមិនអាចអោយនិយមន័យបានមែនតែ *ស៊ីនតូ* ជាសារជាតិរបស់ប្រទេសជប៉ុន និង ជនជាតិជប៉ុន ហើយថ្វីត្បិតតែ *ស៊ីនតូ* មិនមានក្បួនគម្ពីរ គ្មានព្រះ គ្មានទេវតា គ្មានជំនឿ គ្មានប្រព័ន្ធសីលធម៌ តែនេះជាការអោយនិយមន័យទៅលើអត្ថិភាព ( existence ) ។ *ស៊ីនតូ* ជាការគោរពជាធម្មជាតិទៅលើទេវកថា និងរឿងព្រេង ( Myths and legends) នានាដែលគ្មានអ្នកណាជឿទាំងស្រុងនោះ



www.budinst.gov.kh www.elibraryofcambodia.org

ទេ តែគ្រប់គ្នាគោរពតាមទាំងស្រុង ។ បុគ្គលម្នាក់ជា *ស៊ីនតូ* ដូចគ្នាដែលគេកើតឡើងជាជនជាតិជប៉ុនយ៉ាងនោះដែរ ។

- តើនាងជា*ស៊ីនតូ*ដែរ ? ជា*ស៊ីនតូ* ផង ជាគ្រិស្តសាសនិកផង ?

- ចាស ពិតហើយ គឺអញ្ចឹងមែន...

*ប្លាក់ថន* ស្ដាប់ផ្ទុជាថ្មីម្ដងទៀត - សូម *កាមី* ពា*អ៊ីយេតី-យ៉ា* ស្ថិតនៅក្នុងសួនខ្ញុំផងចុះ ។

* * * *

ត្រចៀករបស់គេប្រាប់អោយគេដឹងខ្លួនឡើង ។គេសំលឹងមើលទៅមុខ ។*អូមី* កំពុងសំលឹងមើលមកគេទាំងនៅអង្គុយចោងហោងយ៉ាងអត់ធ្មត់ ។ ភ្លៀងនៅបន្តធ្លាក់នៅឡើយ ។ *អូមី* ពាក់គីម៉ូណូទើបអុតថ្មីមួយសំរាប់នៅពីក្រោមអាវភ្លៀងធ្វើពីចំបើង និង ពាក់មួកត្បាញ វីស្សីហាមធំមួយ ។សក់របស់គេត្រូវបានកក់យ៉ាងស្អាត ។ គេនិយាយដោយងក់ក្បាលចង្អុលទៅគំនរផេះផង់គេហដ្ឋានដែលនៅហុយៗនៅឡើយ :

- *កាម៉ា អាន់ជីន-សាន* ។

- *ហៃ អ៊ីកាកា គេស៊ូ កា ? - ប្លាក់ថន* សួរបណ្ដើរយកដៃជូតទឹកភ្លៀងចេញពីមុខបណ្ដើរ ។

- *យ៉េយ - អូមី* ចង្អុល ទៅផ្ទះរបស់ខ្លួន - ផ្ទះមុជទឹករបស់ខ្ញុំឥតមានខូចខាតអីទេ តើលោក ចង់ប្រើប្រាស់វាទេ ?

- អ្ហា *សូគេស៊ូ ! ដូម៉ូ អូមី-សាន ។ ហៃ ដូម៉ូ* ។

យ៉ាងដឹងគុណ *ប្លាក់ថន* កំដើរតាម*អូមី* តាមផ្លូវក្រឡិកក្រឡង់ហុយៗទៅដល់ច្នាផ្ទះរបស់ *អូមី* ។ ពួកអ្នកបំរើ និង ពួកជាងភូមិ ក្រោមចំនាត់ចំនែងរបស់*មូរ៉ា* កំពុងតែជំរែកគោល អារក្ការ និងជូសជុលផ្ទះ ។ សសរកន្លោងត្រូវបានបញ្ឈរត្រង់ឡើងវិញហើយៗដំបូលក៏ស្ទើរតែប្រក់ជិតវិញ ហើយដែរ ។

ដោយដៃដោយជើង ដោយភាសាខ្ចីៗសាមញ្ញ និង យ៉ាងខន្តី *អូមី* ពន្យល់ប្រាប់គេថាពួក



www.budinst.gov.kh www.elibraryofcambodia.org

អ្នកបំរើរបស់ខ្លួនបានពន្លត់ភ្លើងទាន់ពេលវេលា។ គេនិយាយប្រាប់ *ត្លាក់ថុន* ថាតែក្នុងពេលមួយថ្ងៃពីរប៉ុននោះ ផ្ទះនេះនឹងរៀបចំស្អាតបាតជាប្រក្រតីឡើងវិញ ហើយ ហេតុនេះគ្មានរឿងអ្វីដែលត្រូវកង្វល់ឡើយ ។ ផ្ទះរបស់លោកត្រូវស៊ីពេលយូរបន្តិច *អាន់ជីន-សាន* ។ ប្រហែលជាមួយអាទិត្យ ។សូមកុំបារម្ភអី *ភូជីកូ-សាន* ជានារីមេផ្ទះមួយចំនាប់ចំនួនណាស់។ នាងនឹងដោះស្រាយរឿងចំនាយនេះជាមួយ *មូរ៉ា* យ៉ាងរហ័ស ហើយផ្ទះរបស់លោកនឹងល្អប្រសើរជាងមុនទៅទៀត។ ខ្ញុំលឺថានាងត្រូវភ្លើងឆេះមែនទេ ? មិនអីទេ អារឿងអញ្ជឹងតែងកើតមានម្តងម្កាល តែគ្រូពេទ្យពួកយើងជំនាញណាស់អារឿងរលាកភ្លើងនេះ ។ ពួកគេត្រូវតែជំនាញ *ទេ* ? ពិតហើយ *អាន់ជីន-សាន* នេះជាការរញ្ជួយដីមួយដ៏អាក្រក់តែមិនមែនអាក្រក់អាក្រីណាស់ណាទេ។ ស្រែភ្លឺខូចខាតតែបន្តិចបន្តួច ហើយប្រព័ន្ធធារាសាស្ត្រដែលចាំបាច់បំផុតនោះឥតមានខូចខាតអីទេ។ ទូកទាំងអស់ក៏ឥតមានការខូចខាតដែរទេ ហើយនេះក៏សំខាន់ណាស់ដែរ ។ ពួកសាមូរ៉ៃមានស្លាប់ ដោយបាក់រលំផ្ទះភ្នំតែមួយរយហាសិបនាក់ទេ នេះក៏មិនច្រើនដែរ *ទេ* ? ឯរឿងភូមិវិញ តែមួយអាទិត្យក្រោយ លោកស្ទើរមិនដឹងថានៅទីនេះមានរញ្ជួយផែនដីផង។ កសិករប្រាំនាក់ត្រូវស្លាប់ ហើយមានទាំងកូនក្មេងខ្លះផងដែរ តែនេះអត់ការអីទាំងអស់ ! *អាន់ជី* មានសំនាងណាស់ *ទេ* ? ខ្ញុំលឺថា លោកបានជួយទាញលោកម្ចាស់ *តូរ៉ាណាកា* ចេញផុតពីរណ្តៅមច្ចុរាជ។ ពួកយើងសែនដឹងគុណលោកណាស់ *អាន់ជីន-សាន* ។ មហាសែនដឹងគុណ ។ បើសិនជាពួកយើងបាត់ បង់គាត់វិញ.... លោកម្ចាស់ *តូរ៉ាណាកា* បានមានប្រសាសន៍ថា លោកបានទទួលយកដាវរបស់លោកហើយ ។ លោកចំជាមានសំនាងណាស់ ហើយនេះគឺជាកិត្តិយសណាស់ ។ ពិតមែនណា៎ ។ *កាម៉ា* របស់លោកគឺខ្លាំងមែនទែន ល្អមែនទែន ហួរហៀរមែនទែន ។ ពិតហើយ ពួកយើងសូមអរគុណលោក យ៉ាងអនេកប្បការ ។ អីលូវនេះសូមលោកស្តាប់ខ្ញុំ ។ យើងនឹងជជែកគ្នាច្រើនទៀតនៅពេលណា ដែលលោកមុជទឹករួច ។ ខ្ញុំរីករាយណាស់ដែលបានលោកជាមិត្តយ៉ាងនេះ ។

រួច *អូមី* ស្រែកប្រាប់ទៅអ្នករៀបចំអាងទឹក :

- *អ៊ីសូគី* ! ប្រញាប់ឡើង !

ពួកអ្នកបំរើជូន *ត្លាក់ថុន* ទៅដល់ផ្ទះមុជទឹកដែលនៅក្នុងបុសដើមឈើមួយកន្លែង ។



www.budinst.gov.kh www.elibraryofcambodia.org

បន្ទប់មុជទឹកនេះមានភាពប្រណីតជាងបន្ទប់មុជទឹករបស់គេ ។ ជញ្ជាំងម្ខាងប្រេះយ៉ាងជំពាំ ប៉ុន្តែអ្នកស្រុកបានប្លុកបិទវារួចរាល់អស់ហើយ ។ ដំបូលនៅល្អសមគួរទេ ថ្វីត្បិតតែបាត់ក្បឿងខ្លះហើយមានទឹកភ្លៀងលិចឯនេះឯនោះបន្តិចបន្តួចក្តី ។

*ប្លាក់ថន* ដោះខោអាវចេញ ហើយអង្គុយលើជើងម៉ាតូចមួយនៅក្រោមភ្លៀង ។ ពួកអ្នកបំរើក៏ដុសសាប៊ូ និងកក់សក់អោយគេ ហើយនៅពេលដែលខ្លួនប្រាណរបស់គេបានស្អាតហើយនោះ គេក៏ចូលទៅក្នុងបន្ទប់ទឹក ហើយត្រាំខ្លួននៅក្នុងទឹកក្តៅហុយៗនោះ ។ រាល់កង្វល់របស់គេទាំងប៉ុន្មានក៏រលាយចេញទៅអស់ដែរ ។

*កូជីកូ* នឹងបានស្រួលបួលឡើងវិញ ។ អញជាមនុស្សមានសំនាងមែន ។ សំនាងដោយអញបាននៅទីនោះដើម្បីជួយទាញ *តូរ៉ាណាកា* ចេញ សំនាងដោយបានជួយសង្គ្រោះ *ម៉ារីកូ* ហើយសំនាងដែល *តូរ៉ាណាកា* នៅទីនោះដើម្បីជួយទាញពួកយើងចេញ ។

ដូចសព្វដងដែរ បច្ចេកទេសធ្វើសរសៃរបស់ *ស៊ូរ៉ូ* បានធ្វើអោយគេកើតម្តងទៀត ។ ក្រោយពី *ស៊ូរ៉ូ* រៀបចំមុខរបួសរួចហើយ គេក៏ស្លៀកពាក់គីម៉ូណូ ប៊ីង និង ចងខ្សែចង្កេះថ្មីដែលគេបានរៀបចំទុកអោយជាស្រេចនោះ ហើយក៏ដើរចេញទៅក្រៅ ។ ភ្លៀងបានឈប់ធ្លាក់ហើយ ។

ជំរកបណ្តោះអាសន្នមួយ ត្រូវបានគេតំលើងនៅឯជ្រុងម្ខាងនៃសួនច្បារ ។ ក្តារក្រាលត្រូវបានធ្វើផុតពីដី ហើយក្រាលដោយកំរាលស្អាតភ្លឹង ហើយមានទាំងលំអដោយថូមួយដែលមានផ្ការៀបចំយ៉ាងស្អាត ។ *អូមី* នៅរង់ចាំនៅទីនេះ ដោយនៅក្បែរខ្លួនគេមានយាយចាស់ម្នាក់គ្រហុបធ្មេញ និង មានទឹកមុខមាំនៅជិតខ្លួនផង ។ គេពោលឡើង :

- សូមអញ្ជើញអង្គុយ *អាន់ជីន-សាន* ។

- សូមអរគុណ និងសូមអរគុណចំពោះខោអាវផង -គេនិយាយភាសាជប៉ុនរដាក់រដុប ។

- សូមកុំចាំបាច់រំលឹកអី ។ លោកពិសាតែ រឺ សាកេ ?

- តែ-*ប្លាក់ថន* សំរេចថា គេត្រូវទុកខួរក្បាលអោយស្រលះសំរាប់ជំនួបរបស់គេជាមួយ *តូរ៉ាណាកា* - អរគុណ ។

- នេះគឺជាម្តាយរបស់ខ្ញុំ ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* និយាយណែនាំ ។ អាកប្បកិរិយារបស់គេបង្ហាញនូវការគោរពចំពោះម្តាយគេយ៉ាងខ្លាំង ។ *ប្លាក់ថន* លំអោនខ្លួនគោព ។ លោកយាយពោលឡើង :

- នេះជាកិត្តិយសរបស់ខ្ញុំណាស់ *អាន់ជីន-សាន* ។

- សូមអរគុណ តែនេះក៏ជាកិត្តិយសចំពោះខ្ញុំដែរ - *ប្លាក់ថន* និយាយដោយប្រើនូវរូបមន្តគួរសមដែល *ម៉ារីកូ* បានបង្ហាត់ដល់គេ ។

- *អាន់ជីន-សាន* ពួកយើងសោកស្តាយណាស់ដែលផ្ទះលោកត្រូវភ្លើងឆេះយ៉ាងនេះ ។

- ចុះអ្នកណាទៅធ្វើអីកើតទៅ ? នេះគឺ *កាម៉ា នេ*?

- ចាស គឺ *កាម៉ា*- លោកយាយសំលឹងមើលទៅឯនាយរួចជ្រួញចិញ្ចើម-ប្រញាប់ឡើង! *អាន់ជីន-សាន* ត្រូវការពិសាតែក្តៅណាំ !

នារីដែលមកជាមួយនារីអ្នកបំរើលើកទឹកតែមកនោះ ធ្វើអោយ *ប្លាក់ថន* សឹងភ្លេចភ្លឹកជង្ហើម ។ រួចបន្ទាប់មកគេក៏នឹកឃើញពីនាង ។ មិនគឺនារីនោះទេរឺ ដែលគេបានឃើញនៅជាមួយ *អូមី* ជាលើកដំបូងនៅពេលដែលគេដើរកាត់ថ្នាភូមិសំដៅទៅទូកចំរឹញនោះ ?

*អូមី* និយាយយ៉ាងច្បាស់ៗ :

- នេះគឺជាប្រពន្ធខ្ញុំ ។

- ខ្ញុំមានកិត្តិយសណាស់ ។

*ប្លាក់ថន* និយាយក្នុងពេលដែលនាងលុតជង្គង់ក្បែរប្តីនាង ហើយលំអោនខ្លួនគោរព ។

ម្តាយ *អូមី* ពោលឡើង :

- សូមលោកអភ័យទោស ចំពោះការយឺតយ៉ាវរបស់នាងផង ។ តើទឹកតែក្តៅគួរសមសំរាប់លោកហើយរឺនៅ ?

- បាទអរគុណ ។ ឆ្ងាញ់ណាស់ ។

គេកត់សំគាល់ឃើញថា ម្តាយ *អូមី* មិនហៅឈ្មោះកូនប្រសាស្រីខ្លួនឡើយតែគេមិនជាភ្ញាក់ផ្អើលប៉ុន្មានទេ ដោយ *ម៉ារីកូ* បានប្រាប់គេរួចហើយពីឋានៈត្រូតត្រារបស់ម្តាយក្មេក លើកូនប្រសាស្រីនៅក្នុងសង្គមជប៉ុន ។ ពេលនោះគេបាននិយាយប្រាប់នាងវិញថា :



[stamp: បណ្ណាល័យ LIBRARY BUDDHIST INSTITUTE]
www.budinst.gov.kh www.elibraryofcambodia.org

បន្ទប់មុជទឹកនេះមានភាពប្រណីតជាងបន្ទប់មុជទឹករបស់គេ ។ ជញ្ជាំងម្ខាងប្រេះយ៉ាងជំលាំ ប៉ុន្តែអ្នកស្រុកបានបូកបិទវារួចរាល់អស់ហើយ ។ ដំបូលនៅល្អសមគួរទេ ថ្វីត្បិតតែបាត់ក្បឿងខ្លះហើយមានទឹកភ្លៀងលិចឯនេះឯនោះបន្តិចបន្តួចក្តី ។

*ប្លាក់ថន* ដោះខោអាវចេញ ហើយអង្គុយលើជើងម៉ាតូចមួយនៅក្រោមភ្លៀង ។ ពួកអ្នកបំរើក៏ជុសសាប៊ូ និងកក់សក់អោយគេ ហើយនៅពេលដែលខ្លួនប្រាណរបស់គេបានស្អាតហើយនោះ គេក៏ចូលទៅក្នុងបន្ទប់ទឹក ហើយត្រាំខ្លួននៅក្នុងទឹកក្តៅហុយៗនោះ ។ រាល់កង្វល់របស់គេទាំងប៉ុន្មានក៏រលាយចេញទៅអស់ដែរ ។

*ភូជីកូ* នឹងបានស្រួលបួលឡើងវិញ ។ អញជាមនុស្សមានសំនាងមែន ។ សំនាងដោយអញបាននៅទីនោះដើម្បីជួយទាញ *តូរ៉ាណាកា* ចេញ សំនាងដោយបានជួយសង្គ្រោះ *ម៉ារីកូ* ហើយសំនាងដែល *តូរ៉ាណាកា* នៅទីនោះដើម្បីជួយទាញពួកយើងចេញ ។

ដូចសព្វដងដែរ បច្ចេកទេសធ្វើសរសៃរបស់ *ស៊ូហ្ស៊ី* បានធ្វើអោយគេកើតម្តងទៀត ។ ក្រោយពី *ស៊ូហ្ស៊ី* រៀបចំមុខរបួសរួចហើយ គេក៏ស្លៀកពាក់គីម៉ូណូ ប៊ីង និង ចងខ្សែចង្កេះថ្មីដែលគេបានរៀបចំទុកអោយជាស្រេចនោះ ហើយក៏ដើរចេញទៅក្រៅ ។ ភ្លៀងបានឈប់ធ្លាក់ហើយ ។

ជំរកបណ្តោះអាសន្នមួយ ត្រូវបានគេតំលើងនៅឯជ្រុងម្ខាងនៃសួនច្បារ ។ ក្តារក្រាលត្រូវបានធ្វើផុតពីដី ហើយក្រាលដោយកំរាលស្អាតភ្លឹង ហើយមានទាំងលំអដោយថូមួយដែលមានផ្ការៀបចំយ៉ាងស្អាត ។ *អូមី* នៅរង់ចាំនៅទីនេះ ដោយនៅក្បែរខ្លួនគេមានយាយចាស់ម្នាក់គ្រហុបធ្មេញ និង មានទឹកមុខមាំនៅជិតខ្លួនផង ។ គេពោលឡើង :

- សូមអញ្ជើញអង្គុយ *អាន់ជីន-សាន* ។

- សូមអរគុណ និងសូមអរគុណចំពោះខោអាវផង -គេនិយាយភាសាជប៉ុនរដាក់រដុប ។

- សូមកុំចាំបាច់រំលឹកអី ។ លោកពិសាតែ រឺ សាកេ ?

- តែ-*ប្លាក់ថន* សំរេចថា គេត្រូវទុកខួរក្បាលអោយស្រលះសំរាប់ជំនួបរបស់គេជាមួយ *តូរ៉ាណាកា* - អរគុណ ។

- នេះគឺជាម្តាយរបស់ខ្ញុំ ។



www.budinst.gov.kh www.elibraryofcambodia.org

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE

*អូមី* និយាយណែនាំ ។ អាកប្បកិរិយារបស់គេបង្ហាញនូវការគោរពចំពោះម្ដាយគេយ៉ាងខ្លាំង ។ *ញូក់ថុន* លំអោនខ្លួនគោព ។ លោកយាយពោលឡើង :

- នេះជាកិត្តិយសរបស់ខ្ញុំណាស់ *អាន់ជីន-សាន* ។

- សូមអរគុណ តែនេះក៏ជាកិត្តិយសចំពោះខ្ញុំដែរ -*ញូក់ថុន* និយាយដោយប្រើប្រាស់នូវរូបមន្តគួរសមដែល *ម៉ារីកូ* បានបង្ហាត់ដល់គេ ។

- *អាន់ជីន-សាន* ពួកយើងសោកស្ដាយណាស់ដែលផ្ទះលោកត្រូវភ្លើងឆេះយ៉ាងនេះ ។

- ចុះអ្នកណាទៅធ្វើអីកើតទៅ ? នេះគឺ *កាម៉ា នេ* ?

- ចាស គឺ *កាម៉ា*- លោកយាយសំលឹងមើលទៅឯនាយរួចជ្រួញចិញ្ចើម-ប្រញាប់ឡើង! *អាន់ជីន-សាន* ត្រូវការពិសាតែក្ដៅណាំ !

នារីដែលមកជាមួយនារីអ្នកបំរើលើកទឹកតែមកនោះ ធ្វើអោយ *ញូក់ថុន* សឹងភ្លេចភ្លឹកផង្អើម ។ រួចបន្ទាប់មកគេក៏នឹកឃើញពីនាង ។ មិនគឺនារីនោះទេរឺ ដែលគេបានឃើញនៅជាមួយ *អូមី* ជាលើកដំបូងនៅពេលដែលគេដើរកាត់ធ្លាភូមិសំដៅទៅទូកផឹវិញនោះ ?

*អូមី* និយាយយ៉ាងច្បាស់ៗ :

- នេះគឺជាប្រពន្ធខ្ញុំ ។

- ខ្ញុំមានកិត្តិយសណាស់ ។

*ញូក់ថុន* និយាយក្នុងពេលដែលនាងលុតជង្គង់ក្បែរប្ដីនាង ហើយលំអោនខ្លួនគោរព ។

ម្ដាយ *អូមី* ពោលឡើង :

- សូមលោកអភ័យទោស ចំពោះការយឺតយ៉ាវរបស់នាងផង ។ តើទឹកតែក្ដៅគួរសមសំរាប់លោកហើយរឺនៅ ?

- បាទអរគុណ ។ ឆ្ងាញ់ណាស់ ។

គេកត់សំគាល់ឃើញថា ម្ដាយ *អូមី* មិនហៅឈ្មោះកូនប្រសាស្រីខ្លួនឡើយតែគេមិនជាភ្ញាក់ផ្អើលប៉ុន្មានទេ ដោយ *ម៉ារីកូ* បានប្រាប់គេរួចហើយពីឋានៈត្រួតត្រារបស់ម្ដាយក្មេក លើកូនប្រសាស្រីនៅក្នុងសង្គមជប៉ុន ។ ពេលនោះគេបាននិយាយប្រាប់នាងវិញថា :



www.budinst.gov.kh www.elibraryofcambodia.org

- អរគុណព្រះអង្គហើយដែលមិនមានរឿងដូចនេះនៅអឺរ៉ុប ។

- ម្ដាយក្មេករបស់កូនប្រសាស្រី មិនអាចធ្វើអ្វីខុសទេ ។ ទោះយ៉ាងម៉េច ក៏ដោយ *អាន់ជីន-សាន* ឪពុកម្ដាយជាអ្នករើសប្រពន្ធអោយកូន ហើយតើឪពុកទៅរើសអ្នកណាបើមិនដំបូងបង្អស់សួរប្រពន្ធខ្លួនឯងនោះ ? ហេតុនេះហើយ កូនប្រសាស្រីត្រូវស្ដាប់បង្គាប់គាត់ហើយ កូនប្រុសជានិច្ចកាលត្រូវធ្វើតាមបំណងឪពុកម្ដាយខ្លួន ។

- ជានិច្ចកាល ?

- ជានិច្ចកាល ។

- ចុះបើសិនជាកូនប្រុសនោះប្រកែក ?

- មិនអាចទៅរួចទេ ។ អ្នកណាក៏ដោយ ត្រូវតែស្ដាប់មេកន្ទោងផ្ទះ ។ ភារកិច្ចទីមួយរបស់កូនប្រុស គឺឪពុកម្ដាយ ។ ម្ដាយបានផ្ដល់អ្វីៗ សព្វបែបយ៉ាងទៅកូនប្រុស : ជីវិតម្ហូបអាហារ ភាពផ្ទាក់ផ្ទម កិច្ចគាំពារ ។ ម្ដាយការពារកូនពេញមួយជីវិត ។ ហេតុនេះគឺជាការត្រឹមត្រូវណាស់ ដែលកូនប្រុសត្រូវបំពេញចិត្តម្ដាយរបស់ខ្លួន ។ ឯកូនប្រសាស្រីត្រូវគោរពម្ដាយក្មេកខ្លួន។ នេះគឺជាភារកិច្ចរបស់នាង ។

- ពួកខ្ញុំមិនដូចគ្នាទេ ។

- ជាការលំបាកណាស់ ដែលធ្វើជាកូនប្រសាស្រីដ៏ល្អបាន។ លំបាកមែនទែន ។ គេមានសង្ឃឹមតែមួយទេ គឺរស់បានយូរល្មម និង មានកូនប្រុសមួយ ដើម្បីមានកូនប្រសាស្រីមួយនឹងគេតែប៉ុននោះ ។

- ចុះម្ដាយក្មេកនាង ?

- អូហ៍ គាត់ខូចហើយ *អាន់ជីន-សាន* ។ គាត់ខូចយូរឆ្នាំហើយ ។ ខ្ញុំមិនដែលស្គាល់គាត់ទេ ។ លោកម្ចាស់ *ហ៊ីរ៉ូ ម៉ាត់ស៊ី* មិនបានយកប្រពន្ធទៀតទេ ដើម្បីរក្សាចិត្តស្រលាញ់របស់គាត់ចំពោះម្ដាយក្មេកខ្ញុំនេះ ។

- *ប៊ុនតារ៉ូ-សាន* ជាកូនប្រុសតែមួយគត់របស់គាត់គឺ ?

- ចាស ប្ដីខ្ញុំមានបងប្អូនស្រីដែលនៅរស់ប្រាំនាក់ តែគាត់គ្មានបងប្អូនប្រុសទេ -រួចនាង



www.budinst.gov.kh www.elibraryofcambodia.org

- អរគុណព្រះអង្គហើយដែលមិនមានរឿងដូចនេះនៅអឺរ៉ុប ។

- ម្ដាយក្មេករបស់កូនប្រសាស្រី មិនអាចធ្វើអ្វីខុសទេ ។ ទោះយ៉ាងម៉េច ក៏ដោយ *អាន់ជីន-សាន* ឪពុកម្ដាយជាអ្នករើសប្រពន្ធអោយកូន ហើយតើឪពុកទៅរើសអ្នកណាបើមិនដឹងបួងសួងសួរប្រពន្ធខ្លួនឯងនោះ ? ហេតុនេះហើយ កូនប្រសាស្រីត្រូវស្ដាប់បង្គាប់គាត់ហើយកូនប្រុសជានិច្ចកាលត្រូវធ្វើតាមបំណងឪពុកម្ដាយខ្លួន ។

- ជានិច្ចកាល ?

- ជានិច្ចកាល ។

- ចុះបើសិនជាកូនប្រុសនោះប្រកែក ?

- មិនអាចទៅរួចទេ ។ អ្នកណាក៏ដោយ ត្រូវតែស្ដាប់មេកន្លោងផ្ទះ ។ ភារកិច្ចទីមួយរបស់កូនប្រុស គឺឪពុកម្ដាយ ។ ម្ដាយបានផ្ដល់អ្វីៗ សព្វបែបយ៉ាងទៅកូនប្រុស : ជីវិតម្ហូបអាហារ ភាពផ្ទាក់ផ្ទួម កិច្ចគាំពារ ។ ម្ដាយការពារកូនពេញមួយជីវិត ។ ហេតុនេះគឺជាការត្រឹមត្រូវណាស់ ដែលកូនប្រុសត្រូវបំពេញចិត្តម្ដាយរបស់ខ្លួន ។ ឯកូនប្រសាស្រីត្រូវគោរពម្ដាយក្មេកខ្លួន។ នេះគឺជាភារកិច្ចរបស់នាង ។

- ពួកខ្ញុំមិនដូចគ្នាទេ ។

- ជាការលំបាកណាស់ ដែលធ្វើជាកូនប្រសាស្រីដ៏ល្អបាន។ លំបាកមែនទែន ។ គេមានសង្ឃឹមតែមួយទេ គឺរស់បានយូរល្មម និង មានកូនប្រុសមួយ ដើម្បីមានកូនប្រសាស្រីមួយនឹងគេតែប៉ុននោះ ។

- ចុះម្ដាយក្មេកនាង ?

- អូហ៎ គាត់ខូចហើយ *អាន់ជីន-សាន* ។ គាត់ខូចយូរឆ្នាំហើយ ។ ខ្ញុំមិនដែលស្គាល់គាត់ទេ ។ លោកម្ចាស់ *ហ្ស៊ីហ្ស៊ូ ម៉ាត់ស៊ី* មិនបានយកប្រពន្ធទៀតទេ ដើម្បីរក្សាចិត្តស្រលាញ់របស់គាត់ចំពោះម្ដាយក្មេកខ្ញុំនេះ ។

- *ប៊ុនតារ៉ូ-សាន* ជាកូនប្រុសតែមួយគត់របស់គាត់ឬ ?

- ចាស ប្ដីខ្ញុំមានបងប្អូនស្រីដែលនៅរស់ប្រាំនាក់ តែគាត់គ្មានបងប្អូនប្រុសទេ -រួចនាង



www.budinst.gov.kh www.elibraryofcambodia.org

ពោលកំប្លែងឡើង - តាមពិតទៅយើងជាប់សាច់ញាតិ នឹងគ្នាណា៎ ព្រោះ *ភូជីកូ* ត្រូវជាក្មួយរបស់ប្ដីខ្ញុំ ។ ចុះមានរឿងអីហ្នឹង ?

- អត់អីទេ ខ្ញុំគ្រាន់តែឆ្ងល់ថា នាងមិនដែលនិយាយប្រាប់ខ្ញុំសោះពីរឿងហ្នឹង ។

- ព្រោះវាជំពាក់វាកវិនដូចសំលក់ពិសអីចឹង ។

រួចទើប *ម៉ារីកូ* ពន្យល់គេថា *ភូជីកូ* ជាកូនចិញ្ចឹមរបស់ *ទូម៉ាតា អាគីហ្សូរី* ដែលបានរៀបការជាមួយប្អូនស្រីពៅរបស់ *ប៊ុនតារ៉ូ* ហើយឪពុកបង្កើតរបស់ *ភូជីកូ* គឺជាចៅរបស់ប្រពន្ធចុងទីប្រាំបីនៃស្ដេចព្រាញ់ *ក្យូដោ*។ *ភូជីកូ* ត្រូវបានលោកម្ចាស់ *តែកូ* បញ្ជាអោយ *ទូម៉ាតា* យកទៅចិញ្ចឹមតាំងពីនៅជាទារិកាម្ល៉េះ ក្នុងបំនងរឹតបន្តឹងចំនងទាក់ទងរវាងត្រកូល *ហ៊ីរ៉ូ ម៉ាត់ស៊ី* និង *ក្យូដោ* ។

- ថាម៉េច ?

*ម៉ារីកូ* សើចរួចទើបពន្យល់ថាទំនាក់ទំនងគ្រួសារជប៉ុន គឺជំពាក់ជំពិនដូចសំលក់ពិសដែលនាងនិយាយអំបាញ់មិញនេះឯង ព្រោះការសុំកូនចិញ្ចឹមជារឿងធម្មតា ហើយជាញឹកញយគេតែងដូរកូនប្រុស កូនស្រីជាមួយគ្នា ក៏ដូចជាការលែងលះគ្នា ការរៀបការ និង ការរៀបការក្នុងរង្វង់សាច់ញាតិផងដែរ។ ដោយថា គេអាចមានប្រពន្ធចុងស្របច្បាប់ច្រើនបាន ហើយការលែងលះស្របច្បាប់ក៏ងាយ យូរៗទៅក្រុមគ្រួសារទាំងអស់ជាប់សាច់ញាតិប្រទាក់គ្នា តែទាំងអស់ហ្នឹង ។ នាងពោលពន្យល់ :

- បើចង់ស្រាវជ្រាវចំនងទាក់ទងត្រកូលលោកម្ចាស់ *តូរ៉ាណាកា* អោយបានច្បាស់គឺត្រូវស៊ីពេលរាប់ថ្ងៃ *អាន់ជីន-សាន* ។ អីលូវគ្រាន់តែគិតពីការស្មុគស្មាញមួយទៅចុះ : បច្ចុប្បន្នគាត់មានប្រពន្ធចុងជា *ផ្លូវការ* និងដែលនៅរស់ចំនួនប្រាំពីរនាក់ ហើយដែលទាំងអស់បានផ្ដល់អោយគាត់នូវកូនប្រុសប្រាំ និងកូនស្រីបី។ ប្រពន្ធចុងរបស់គាត់ខ្លះជាមេម៉ាយប្ដីស្លាប់ រឺមេម៉ាយប្ដីលែង ហើយដែលមានកូនប្រុសកូនស្រីរួចទៅហើយ ។ កូនទាំងនេះ មានខ្លះ *តូរ៉ាណាកា* ចិញ្ចឹមជាកូន ឯខ្លះទៀតអត់ទេ ។ នៅជប៉ុនលោកមិនត្រូវសួរថាកូនចិញ្ចឹម រឺកូនបង្កើតទេ ។ ហើយតាមពិតទៅរឿងនេះគ្មានអ្វីសំខាន់ឯណា? ការស្នងកេរមរតក គឺអាស្រ័យតាមឆន្ទៈរបស់មេកន្លោងផ្ទះទេតើ ដោយហេតុនេះ ចិញ្ចឹមរឺបង្កើតវាដូចតែគ្នាហ្នឹង *នេ* ? សូម្បីតែម្ដាយរបស់លោកម្ចាស់



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* ក៏លែងប្ដីដែរ ។ បន្ទាប់មកគាត់រៀបការប្ដីថ្មី ហើយបានកូនប្រុសបី និងកូនស្រីពីរ ថែមទៀត ។ អីលូវ ពួកទាំងនោះរៀបការមានគ្រួសារអស់ហើយ ។ កូនប្រុសច្បងជាមួយប្ដីទីពីរនេះ គឺលោកម្ចាស់ *សាកាគី* ដែលជាអម្ចាស់តំបន់*ស៊ុំណាញូ* ។

- ពួកយើងវិញ យើងមិនអាចលែងលះគ្នាបានទេ ។

- ចាស ខ្ញុំលឺសម្ដេចព្រះសង្ឃនិយាយដែរ ។ តែសូមទោសទៅចុះ *អាន់ជីន-សាន* ធ្វើយ៉ាងនេះតឹរឹងត្អឹងពេកហើយ ។ ការភ័ន្តច្រលំតែងតែមាន មនុស្សតែងប្ដូរចិត្តនេះតើជា *កាម៉ា នេ?* ហេតុអ្វីបានជាប្ដី ត្រូវតែទ្រាំទ្រជាមួយប្រពន្ធអប្រិយជួជាតិ រឺប្រពន្ធត្រូវតែទ្រាំទ្រប្ដីអប្រិយជួជាតិទៅវិញ ? ចំជាលេលាមែន ដែលអោយនៅតោងក្រាញរហូតអស់មួយជីវិតយ៉ាងនេះ ស្រីក៏ដោយប្រុសក៏ដោយ *នេ?*

- ពិតមែន ។

- ត្រង់ចំនុចនេះយើងវាងវៃជាង ហើយគឺគណៈសង្ឃមិនវាងវៃទេ ។នេះគឺជាមូលហេតុមួយក្នុងចំនោមមូលហេតុទាំងពីរដែលធ្វើអោយលោកម្ចាស់ *តែតូ* មិនចូលសាសនាគ្រិស្តនោះ ។គឺភាពលេលានៃការហាមមិនអោយលែងលះគ្នានេះមួយ និងការហាមមិនអោយសំលាប់នេះពីរ ។ កាលនោះ ព្រះតេជគុណគណៈអធិការសង្ឃបានខំធ្វើដំណើររហូតដល់ទីក្រុងរ៉ូម ដើម្បីអង្វរសុំអោយជនជាតិជប៉ុនចេញផុតពីបំរាមលះលែងគ្នានេះ ។ តែសម្ដេចប៉ាប នៅតែរឹងកំព្រឹសលើគតិបណ្ឌិតដ៏មហាអនន្តរបស់លោក ហើយបានប្រកែកនឹងសំនូមពរលើកលែងនេះ ។ បើសិនជាកាលនោះ សម្ដេចប៉ាបឆ្លើយទទួលយល់ព្រមវិញនោះ ខ្ញុំជឿថាលោកម្ចាស់ *តែតូ* ពិតជានឹងជួរសាសនា ហើយពួក *ដៃមីញ៉ូ* ទាំងអស់នឹងធ្វើតាម ហើយនគរនេះនឹងក្លាយជានគរគ្រីស្តសាសនិកបាត់ទៅហើយ ។ រឿង " សំលាប់ " នឹងមិនជារឿងសំខាន់ទេ ព្រោះតាមពិតទៅគ្មានអ្នកណាយកចិត្តទុកដាក់លើរឿងនេះផង ហើយពួកគ្រីស្តសាសនិករិតតែជាងគេទៅទៀត ។ ស្ដាយណាស់ យកត្រីតូច ស្ទូចត្រីធំសោះ *នេ?*

- តើប្រពន្ធ*តូរ៉ាណាកា* យ៉ាងម៉េចដែរ ?

*ប្លាក់ថន* សួរដើម្បីជំរុញនាងអោយបន្តនិយាយ ។ ភាគច្រើននាងតែងចៀសមិននិយាយពី



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* ហើយនឹងគ្រួសាររបស់លោកឡើយ តែចំពោះ*ប្លាក់ថន* គឺជាការចាំបាច់ដែលគេត្រូវដឹងសព្វដឹងគ្រប់ ។ ចំពោះសំនួរនេះ ភាពក្រៀមក្រំបានលេចឡើងនៅលើមុខរបស់ *ម៉ារីកូ* ។

- គាត់ទទួលមរណភាពហើយ ។ គាត់គឺជាប្រពន្ធទីពីររបស់លោកម្ចាស់ ហើយគាត់ទទួលមរណភាពកាលពីដប់ ពីរមួយដណ្តប់ឆ្នាំមុនម្ល៉េះ ។ គាត់គឺជាប្អូនថ្លៃស្រីរបស់លោកម្ចាស់ *តៃកូ* ។ លោកម្ចាស់*តូរ៉ាណាកា* មិនសូវកបរឿងប្រពន្ធទេ *អាន់ជីន-សាន* ។

- ហេតុអីទៅ ?

- អូហ៍ ព្រោះប្រពន្ធទីពីរនេះចាស់ គ្មានកំលាំងហើយលោភលន់ ស្រលាញ់តែមាសដូចបងរបស់គាត់ គឺលោកម្ចាស់ *តៃកូ* ដែរ គ្រាន់តែខាងក្រៅធ្វើហាក់ដូចជាអត់រវីរវល់អីទាំងអស់ ។ គាត់ជាស្រីអារ ហើយមានចរិតឆេវឆាវ ។ ពិតហើយ នោះគឺជាអាពាហ៍ពិពាហ៍នយោបាយតែប៉ុណ្ណោះ ។ខ្ញុំធ្លាប់នៅជានារីកំដរគាត់មួយរយៈដែរ ។ គ្មានអ្វីដែលធ្វើអោយគាត់ពេញចិត្តទេហើយ គ្មានប្រុសក្មេង រឺចាស់ណាម្នាក់បំពេញពណ្ឌគាត់ស្កប់ស្កល់ទេ ។

- ទោះ*តូរ៉ាណាកា* ក៏ដោយ ?

- លោកម្ចាស់មិនដែលរួមរក្សជាមួយទេ *អាន់ជីន-សាន* ។ ការរួចហើយគាត់មិនដែលរវីរវល់នឹងប្រពន្ធនេះទេក្រៅពីអោយវិមានស្នាក់នៅ អោយអ្នកបំរើហើយនឹងអោយសោឃ្លាំងមាសប្រាក់របស់គាត់ប៉ុណ្ណោះ ។ អោយគាត់រួមរក្សយ៉ាងម៉េចទៅ បើយាយនោះចាស់ ហើយរៀបការ ពីរដងរួច ទៅហើយ ។ លោកម្ចាស់ *តៃកូ* លុបការចងសំបាច់នោះទាំងពីរដង ។ នោះបានចំជាស្រីជូជាតិ មែនទែន ហេតុនេះហើយពេលគាត់ស្លាប់ទៅអ្នកណាក៏ធូរទ្រូងដែរ សូម្បីតែលោកម្ចាស់ *តៃកូ* ក៏ ដោយ ។ ឯពួកប្រពន្ធ១ចុងវិញ គេលួចអុជធូបអរថែមទៀត ។

- ចុះប្រពន្ធទីមួយរបស់*តូរ៉ាណាកា*វិញ ?

- អូ្ហ៎ នោះគឺជំទាវ *គាជីបាណា* ។ នោះក៏ជាអាពាហ៍ពិពាហ៍នយោបាយមួយទៀតដែរ ។ កាលនោះលោកម្ចាស់*តូរ៉ាណាកា* មានអាយុដប់ប្រាំបីឆ្នាំ ជំទាវ *គាជីបាណា* អាយុដប់ប្រាំឆ្នាំ ។គាត់បានចាត់ចំក្លាយជានារីមួយគួរអោយខ្លាច ។ កាលពីម្ភៃឆ្នាំមុនលោកម្ចាស់*តូរ៉ាណាកា* បានប្រហារជីវិតគាត់ចោល ដោយគាត់បានរកឃើញថាលោកជំទាវនេះ រៀបផែនការសំលាប់អម្ចាស់របស់



www.budinst.gov.kh www.elibraryofcambodia.org

គាត់គឺស្តេចព្រាញ់ *ក្លូដោ* ។ លោកជំទាវស្អប់ស្តេចព្រាញ់នេះណាស់ ។ ឪពុកខ្ញុំតែងនិយាយថា ពួកទាំងនេះសំនាងណាស់ដែលរក្សាក្បាលខ្លួនឯងអោយនៅជាប់ស្មាបាន ។ ពួកទាំងនេះគឺ *តូរ៉ាណាកា ណាកាមូរ៉ា* និងពួកមេទ័ពទាំងប៉ុន្មានឯទៀត ។ ពីព្រោះ *ក្លូដោ* ជាមនុស្សគ្មានមេត្តាធម៌ គ្មានសន្តោស ហើយសង្ស័យអ្នកដែលនៅជំនិតខ្លួនជានិច្ច ។ ជំទាវណឹងហើយធ្វើអោយពួកគេទាំងអស់រលត់រលាយបាន ទោះជាពួកគេគ្មានកំហុសអ្វីក៏ដោយ ។ ដោយមកពីផែនការសំលាប់ស្តេចព្រាញ់នេះហើយ ទើបសូម្បីតែកូនប្រុសមួយរបស់នាងឈ្មោះ *ណូប៊ូណាកា* ក៏ត្រូវប្រហារជីវិតផងដែរ ។ គឺនាងបានសំលាប់កូននាង *អាន់ជីន-សាន* ។ លោកគិតទៅមើលថាតើកំសត់ និងសាហាវយ៉ាងណាទៅ ។ អាណិត *ណូប៊ូណាកា* ណាស់ ។ គេជាកូនប្រុសសំនព្វ និង ជាអ្នកស្នងត្រកូលជាផ្លូវការរបស់លោកម្ចាស់ *តូរ៉ាណាកា* ជាមនុស្សក្លាហាន ជាមេទ័ពដ៏សក្តិសម ហើយមានភក្តីបំផុត ។ គេឥតមានដឹងអីទេ តែម្តាយនាំអោយធ្លាក់ជាំពាក់ជាំពិនក្នុងផែនការក្បត់ ហេតុនេះលោកម្ចាស់ *តូរ៉ាណាកា* បញ្ជាអោយធ្វើសិបពូគួ ទៅ ។ កាលនោះគេមានអាយុដប់ប្រាំបួនឆ្នាំ ។

- *តូរ៉ាណាកា* សំលាប់កូនខ្លួនឯង ? ហើយសំលាប់ប្រពន្ធឯងទៀត ?

- ចាស គឺគាត់បានចេញបញ្ជា តែគាត់ក៏គ្មានជំរើសផ្សេងទៀតដែរ *អាន់ជីន-សាន* ។ បើគាត់មិនចេញបញ្ជានេះ លោកម្ចាស់ *ក្លូដោ* ពិតជា នឹងម៉ែថា គាត់ក៏រួមក្នុងផែនការនេះដែរ ហើយពេលនោះពិតជា ចេញបញ្ជាអោយគាត់វះពោះខ្លួនឯងជាមិនខាន ...

អីឡូវនេះពេលសំលឹងមើលទៅម្តាយ *អូមី ប្លាក់ថន* ដឹងថា យាយចាស់នេះអាចអោយ *មីដូរី* ស្លាប់ រឺ រស់ រឺនៅមេម៉ាយ រឺចុះឋានៈបានតាមចិត្ត ក្នុងលក្ខខណ្ឌដែលថាប្តីនាងឯកភាពតាមនោះ ។ហើយទោះជាគេទាំងពីរនាក់នេះសំរេចយ៉ាងណាក៏ដោយ ក៏ *មីដូរី* ត្រូវតែគោរពតាមដែរ ។ នេះបានចំជាវេទនាមែន គេគិតតែនៅក្នុងចិត្ត ។

យាយចាស់កាន់តែអាក្រក់ កាន់តែជរាប៉ុនណា *មីដូរី* កាន់តែស្អាត និង កាន់តែក្មេងប៉ុននោះដែរ ។ មុខនាងមានទំរង់ពងក្រពើ សក់នាងក្រាស់ឃ្មឹក ។ នាងមានសំរស់ស្អាតជាង *ម៉ារីកូ* តែមិនមានថាមពលគ្បៀវក្លាដូច *ម៉ារីកូ* ទេ ។ នាងមានលក្ខណៈទន់ភ្លន់ដូចជាមែកបុប្ផា ហើយផុយស្រួយដូចសំនាញ់ពីងពាង ។ យាយចាស់ពោលបន្ថែម :



www.budinst.gov.kh www.elibraryofcambodia.org

- ឯណាម្ហូបកំដរមាត់ ? *អាន់ជីន-សាន* ប្រហែលជាឃ្លានហើយ *នេ* ?

- អូហ៍ សូមទោស - *មីដូរី* ប្រាប់ជាបន្ទាន់ទៅនារីបំរើ - យកម្ហូបខ្លះចេញមកអីល្ងូវនេះមក ។ ប្រញាប់ឡើង ! សូមទោសផងទៅចុះ *អាន់ជីន-សាន* ។

ម្ដាយ *អូមី* បន្ទរតាមក្រោយ :

- សូមទោស *អាន់ជីន-សាន* ។

- សូមមេត្តាកុំសូមទោសអី ។

*ប្លាក់ថន* ពោលទៅកាន់ *មីដូរី* ហើយរំពេចនោះគេដឹងថា គេបានធ្វើការភ័ន្តច្រលំមួយ ។ តាមសុជីវធម៌ គេត្រូវទាក់ទងតែជាមួយម្ដាយក្មេកតែប៉ុណ្ណោះ ពិសេសម្ដាយក្មេកឆន្ទា ។ គេនិយាយទៅកាន់យាយចាស់ :

- សូមទោស ខ្ញុំមិនទាន់ឃ្លានទេ ។ យប់នេះខ្ញុំត្រូវទទួលទានបាយជាមួយលោកម្ចាស់ *តូរ៉ាណាកា* ផង ។

យាយចាស់តប :

- អ្ហា៎ *សូរកេស៊ូ* ! ពួកយើងលឺថាលោកបានសង្គ្រោះជីវិតគាត់ផង ។ លោកគួរដឹងថាពួកយើងដឹងគុណលោកជាពន់ពេកណាស់ ពោលគឺអណ្ដាប់របស់គាត់ទាំងអស់គ្នាណឹងតែម្ដងដែលដឹងគុណលោក ។

- នេះគឺជាភារកិច្ច ។ ខ្ញុំគ្មានធ្វើអ្វីផង ។

- លោកបានធ្វើគ្រប់សព្វ *អាន់ជីន-សាន*។ *អូមី-សាន* និងលោកម្ចាស់ *យ៉ាប៊ូ* វាយតំលៃទំរើរបស់លោកខ្ពស់ដូចពួកយើងទាំងអស់គ្នាដែរ ។

*អូមី* និយាយ :

- ម៉ែ ខ្ញុំសំនាងណាស់ដែលបាន *អាន់ជីន-សាន* ជាមិត្ត ។

- ពួកយើងទាំងអស់គ្នាតែម្ដងដែលមានសំនាងនេះ - យាយតប ។

- ទេ គឺខ្ញុំទេដែលមានសំនាងនោះ - *ប្លាក់ថន* តប - ខ្ញុំមានសំនាងដោយបាន *កាស៊ីគី អូមី-សាន* ជាមិត្តដូចគ្រួសារ ។



www.budinst.gov.kh www.elibraryofcambodia.org

គាត់គឺស្តេចព្រាញ់*ក្លូវ៉េ* ។ លោកជំទាវស្អប់ស្តេចព្រាញ់នេះណាស់ ។ ឪពុកខ្ញុំតែងនិយាយថា ពួកទាំងនេះសំខាន់ណាស់ដែលរក្សាក្បាលខ្លួនឯងអោយនៅជាប់ស្មាបាន ។ ពួកទាំងនេះគឺ *តូរ៉ាណាកា ណាកាម្ហូរ៉ា* និងពួកមេទ័ពទាំងប៉ុន្មានឯទៀត ។ ពីព្រោះ*ក្លូវ៉េ* ជាមនុស្សគ្មានមេត្តាធម៌ គ្មានសន្តោស ហើយសង្ស័យអ្នកដែលនៅជិតខ្លួនជានិច្ច ។ ជំទាវណឹងហើយធ្វើអោយពួកគេទាំងអស់រលត់រលាយបាន ទោះជាពួកគេគ្មានកំហុសអ្វីក៏ដោយ ។ ដោយមកពីផែនការសំលាប់ស្តេចព្រាញ់នេះហើយ ទើបសូម្បីតែកូនប្រុសមួយរបស់នាងឈ្មោះ*ណូប៊ូណាកា* ក៏ត្រូវប្រហារជីវិតផងដែរ ។ គឺនាងបានសំលាប់កូននាង *អាន់ជីន-សាន* ។ លោកគិតទៅមើលថាតើកំសត់ និងសាហាវយ៉ាងណាទៅ ។ អាណិត *ណូប៊ូណាកា* ណាស់ ។ គេជាកូនប្រុសសំនព្វ និង ជាអ្នកស្នងត្រកូលជាផ្លូវការរបស់លោកម្ចាស់ *តូរ៉ាណាកា* ជាមនុស្សក្លាហាន ជាមេទ័ពដ៏សក្តិសម ហើយមានភក្តីបំផុត ។ គេឥតមានដឹងអីទេ តែម្តាយនាំអោយគ្នាជំពាក់ជំពិនក្នុងផែនការក្បត់ ហេតុនេះលោកម្ចាស់ *តូរ៉ាណាកា* បញ្ជាអោយធ្វើសិបពុគូ ទៅ ។ កាលនោះគេមានអាយុដប់ប្រាំបួនឆ្នាំ ។

- *តូរ៉ាណាកា* សំលាប់កូនខ្លួនឯង ? ហើយសំលាប់ប្រពន្ធឯងទៀត ?

- ចាស គឺគាត់បានចេញបញ្ជា តែគាត់ក៏គ្មានជំរើសផ្សេងទៀតដែរ *អាន់ជីន-សាន* ។ បើគាត់មិនចេញបញ្ជានេះ លោកម្ចាស់*ក្លូវ៉េ* ពិតជា នឹងថែថា គាត់ក៏រួមក្នុងផែនការនេះដែរ ហើយពេលនោះពិតជា ចេញបញ្ជាអោយគាត់វះពោះខ្លួនឯងជាមិនខាន ...

អីឡូវនេះពេលសំលឹងមើលទៅម្តាយ *អូមី ច្ញាក់ផន* ដឹងថា យាយចាស់នេះអាចអោយ *មីដូរី* ស្លាប់ រឺ រស់ រឺនៅមេម៉ាយ រឺចុះហ៊ានៈបានតាមចិត្ត ក្នុងលក្ខខណ្ឌដែលថាប្តីនាងឯកភាពតាមនោះ ។ហើយទោះជាគេទាំងពីរនាក់នេះសំរេចយ៉ាងណាក៏ដោយ ក៏ *មីដូរី* ត្រូវតែគោរពតាមដែរ ។ នេះបានចំជាវេទនាមែន គេគិតតែនៅក្នុងចិត្ត ។

យាយចាស់កាន់តែអាក្រក់ កាន់តែជរាប៉ុនណា *មីដូរី* កាន់តែស្អាត និង កាន់តែក្មេងប៉ុននោះដែរ ។ មុខនាងមានទំរង់ពងក្រពើ សក់នាងក្រាស់ឃ្មឹក ។ នាងមានសំរស់ស្អាតជាង *ម៉ារីកូ* តែមិនមានថាមពលក្បៀវក្លាដូច *ម៉ារីកូ* ទេ ។ នាងមានលក្ខណៈទន់ភ្លន់ដូចជាមែកបុប្ផា ហើយផុយស្រួយដូចសំនាញ់ពីងពាង ។ យាយចាស់ពោលបន្ថែម :



www.budinst.gov.kh www.elibraryofcambodia.org

- ឯណាម្ហូបកំដរមាត់ ? *អាន់ជីន-សាន* ប្រហែលជាឃ្លានហើយ *នេ* ?

- អូហ៊ី សូមទោស - *មីដូរី* ប្រាប់ជាបន្ទាន់ទៅនារីបំរើ - យកម្ហូបខ្លះចេញមកអីលូវនេះមក ។ ប្រញាប់ឡើង ! សូមទោសផងទៅចុះ *អាន់ជីន-សាន* ។

ម្ដាយ *អូមី* បន្ទរតាមក្រោយ :

- សូមទោស *អាន់ជីន-សាន* ។

- សូមមេត្តាកុំសូមទោសអី ។

*ប្លាក់ថន* ពោលទៅកាន់ *មីដូរី* ហើយរំពេចនោះគេដឹងថា គេបានធ្វើការភ័ន្តច្រលំមួយ ។ តាមសុជីវធម៌ គេត្រូវទាក់ទងតែជាមួយម្ដាយក្មេកតែប៉ុណ្ណោះ ពិសេសម្ដាយក្មេកឆ្នា ។ គេនិយាយទៅកាន់យាយចាស់ :

- សូមទោស ខ្ញុំមិនទាន់ឃ្លានទេ ។ យប់នេះខ្ញុំត្រូវទទួលទានបាយជាមួយលោកម្ចាស់ *តូរ៉ាណាកា* ផង ។

យាយចាស់តប :

- អ្ហា៎ *សូរេស៊ូ* ! ពួកយើងលឺថាលោកបានសង្គ្រោះជីវិតគាត់ផង ។ លោកគួរដឹងថាពួកយើងដឹងគុណលោកជាពន់ពេកណាស់ ពោលគឺអណ្ដាប់របស់គាត់ទាំងអស់គ្នាណឹងតែម្ដងដែលដឹងគុណលោក ។

- នេះគឺជាភារកិច្ច ។ ខ្ញុំគ្មានធ្វើអ្វីផង ។

- លោកបានធ្វើគ្រប់សព្វ *អាន់ជីន-សាន*។ *អូមី-សាន* និងលោកម្ចាស់ *យ៉ាប៊ូ* វាយតំលៃទំរើរបស់លោកខ្ពស់ដូចពួកយើងទាំងអស់គ្នាដែរ ។

*អូមី* និយាយ :

- ម៉ែ ខ្ញុំសំនាងណាស់ដែលបាន *អាន់ជីន-សាន* ជាមិត្ត ។

- ពួកយើងទាំងអស់គ្នាតែម្ដងដែលមានសំនាងនេះ - យាយតប ។

- ទេ គឺខ្ញុំទេដែលមានសំនាងនោះ - *ប្លាក់ថន* តប - ខ្ញុំមានសំនាងដោយបាន *កាស៊ីគី* *អូមី-សាន* ជាមិត្តដូចគ្រួសារ ។



www.budinst.gov.kh www.elibraryofcambodia.org

ពួកយើងទាំងអស់គ្នាកំពុងតែនិយាយកុហក - *ភ្លាក់ផន* គិតនៅក្នុងចិត្ត ។ តែអញមិនដឹងថា ហេតុអីពួកឯងកុហកដែរទេ ។ អញកុហក ព្រោះដើម្បីការពារខ្លួនអញហើយនេះជាទំនៀមផង ។ តែអញមិនភ្លេចជាដាច់ខាត... ចាំបន្តិចសិន ។ និយាយតាមត្រង់ទៅ នេះមិនគឺ *កាម៉ា* ទេរឺ ? ក្រែងជាតិមុនអញធ្វើបែបនេះដាក់ *អូមី* ទេដឹង ?

អ្នកជិះសេះមួយក្រុមបានបំផាយសេះឡើងមក ដោយមាន*ណាកា* នាំមុខ ។ គេចុះពីលើខ្នងសេះ ហើយដើរកាត់សួនច្បារ ។ អ្នកភូមិទាំងប៉ុន្មានដែលនៅទីនោះនាំគ្នាឈប់ធ្វើការងារ ហើយលុតជង្គង់គោរពភ្លាម ។ គេធ្វើសញ្ញាអោយបន្តការងារទៅទៀត ។

- សូមអភ័យទោសផងចុះចំពោះការរំខាននេះ *អូមី-សាន* តែលោកម្ចាស់*តូរ៉ាណាកា* ប្រើខ្ញុំមក ។

- បាទមិនអីទេ លោកមិនបានរំខានខ្ញុំទេ ។ មកចូលរួមទាំងអស់គ្នាមក - *អូមី* តប ។ ភ្លាមនោះ *មីដូរី* ក៏លំអោនខ្លួនយ៉ាងទាប ហើយប្រគល់ម៉ក់ខ្លួនទៅអោយ*ណាកា* - តើលោកពិសាតែ រឺសាកេ *ណាកា-សាម៉ា* ?

*ណាកា* អង្គុយចុះ :

- អត់ទាំងអស់ សូមអរគុណ ។ ខ្ញុំអត់ស្រេកទេ ។

- លោកម្ចាស់ *តូរ៉ាណាកា* យ៉ាងម៉េចហើយ ?

- ល្អស្រួលបួលទេ ។ *អាន់ជីន-សាន* លោកបានធ្វើគុណមួយយ៉ាងធំណាស់មកលើពួកយើង ។ បាទមែនណា៎ ខ្លួនខ្ញុំផ្ទាល់ខ្ញុំសូមអរគុណលោក ។

- នេះជាភារកិច្ចទេ*ណាកា-សាន* ។ តែខ្ញុំធ្វើបន្តិចបន្តួចទេ ។ លោកម្ចាស់ *តូរ៉ាណាកា* បានទាញខ្ញុំចេញ... ចេញពីដីដែរ ។

- មែនហើយ តែនោះគឺក្រោយមកទៀតទេ ។ ខ្ញុំសូមអរគុណលោកជាអនេកប្បការ ។

*អូមី* សួរឡើង :

- *ណាកា-សាន* តើមានអ្វីដែលខ្ញុំអាចធ្វើជូនលោកម្ចាស់ *តូរ៉ាណាកា* បានទេ ?

- គាត់ចង់ជួបលោកនៅក្រោយពេលបាយល្ងាចហើយនោះ នឹងមានការប្រជុំធំមួយ



www.budinst.gov.kh www.elibraryofcambodia.org

ជាមួយមេទព័ទាំងអស់ ។

- ខ្ញុំមានកិត្តិយសណាស់ ។

- *អាន់ជីន-សាន* បើលោកមិនជំទាស់ទេ សូមលោកអញ្ជើញទៅជាមួយខ្ញុំអីឡូវនេះ ។

- បាន ខ្ញុំទៅ ។ នេះជាកិត្តិយសខ្ញុំហើយ ។

ក្រោយពីការលំអោនគោរពជាច្រើនដងមក *ប្លាក់ថន* ក៏ឡើងសេះហើយលុនវាចុះតាមជំរាលកូនភ្នំ ។ នៅពេលដែលកងសាមូរ៉ៃ មកដល់ទីធ្លាភូមិហើយនោះ *ណាកា* ក៏បន្ថយល្បឿនសេះ :

- *អាន់ជីន-សាន* ?

- *ហៃ* ?

- ខ្ញុំ សូមថ្លែងអំនរគុណយ៉ាងអស់ពីចិត្តពីថ្លើម ក្នុងការដែលលោកបានជួយសង្គ្រោះលោកម្ចាស់ *ភូមិណាកា* នេះ ។ សូមអនុញ្ញាតអោយខ្ញុំបានចងមិត្តជាមួយលោកផង... - ហើយគេនិយាយប៉ុន្មានម៉ាត់ទៀត តែ *ប្លាក់ថន* ស្តាប់មិនយល់សោះ :

- សូមទោស ខ្ញុំស្តាប់មិនបានទេ ពាក្យ *ការីតេ អ៊ីរូ* ?

- អ្ហា សូមទោស ។ *ការីតេ អ៊ីរូ* ឧទាហរណ៍មនុស្សម្នាក់ *ការីតេ អ៊ីរូ* មនុស្សម្នាក់ទៀតនូវរបស់មួយ ។ ដូចបំនុលអញ្ចឹង ។ លោកយល់ពាក្យ « បំនុល » ទេ ?

*ប្លាក់ថន* យល់ភ្លាមថា *ណាកា* ចង់និយាយពីពាក្យ « ជំពាក់ » :

- អ្ហា *សូកេស៊ូ* ! *វ៉ាការីម៉ាស៊ូ*។

- ល្អ ។ ខ្ញុំនិយាយថា ខ្ញុំជំពាក់បំនុលលោក ។

- នេះជាភារកិច្ចខ្ញុំ *ទេ* ?

- ពិតហើយ ។ ទោះជាយ៉ាងនេះក្តី ក៏ខ្ញុំជំពាក់ជីវិតលោកមួយដែរ ។

****



www.budinst.gov.kh www.elibraryofcambodia.org

-*តូរ៉ាណាកា-សាម៉ា* មានប្រសាសន៍ថា រំសេវ កាណុង និងគ្រាប់ត្រូវបានរៀបចំដាក់ទៅក្នុងសំពៅរបស់លោកវិញអស់ហើយស្រេចមុនចេញពី *អាន់ជីវ៉ូ* ទៅ *យេដូ* នេះ *អាន់ជីន-សាន* ។ លោកម្ចាស់សួរថា តើលោកត្រូវការពេលវេលាប៉ុន្មានដើម្បីចេញដំណើរ ?

- នេះអាស្រ័យតាមស្ថានភាពសំពៅ ។ ត្រូវមានមនុស្សជួសជុលនិងថែទាំវា ដូរបង្គោលក្ដោងវាជាដើម ។ តើលោកម្ចាស់ *តូរ៉ាណាកា* បានដឹងពីស្ថានភាពវាទេ ?

- លោកម្ចាស់មានប្រសាសន៍ថា មើលទៅសំពៅដូចជាល្អទេ តែដោយលោកមិនមែនជាអ្នកដើរសំពៅ ហេតុនេះលោកមិនប៉ានច្បាស់ដែរទេ ។ លោកក៏មិនដែលបានឡើងទៅមើលទៀតដែរតាំងពីលោកបានបញ្ជាអោយគេអូសទៅ *យេដូ* ដើម្បីជួសជុលវានោះ ។ អីលូវបើយើងគិតថាសំពៅនេះចុះទឹកបានចុះ លោកម្ចាស់សួរថាតើលោកត្រូវការពេលវេលាប៉ុន្មាន ដើម្បីចេញធ្វើសង្គ្រាម ?

*ប្លាក់ថន* ញ្ញោចខ្លួន :

- តើខ្ញុំត្រូវធ្វើសង្គ្រាមជាមួយអ្នកណា *ម៉ារីកូ-សាន* ?

- លោកម្ចាស់សួរថា លោកចង់ធ្វើសង្គ្រាមជាមួយអ្នកណា ?

- *សំពៅខ្មៅ* ឆ្នាំនេះ ។

*ប្លាក់ថន* ឆ្លើយយ៉ាងរហ័ស ។ គេបានធ្វើការសំរេចចិត្តយ៉ាងបន្ទាន់ ដោយគេប្រឹងត្រដររ សង្ឃឹមថា នេះគឺជាពេលដ៏ត្រឹមត្រូវដើម្បីលើកឡើងចំពោះមុខ *តូរ៉ាណាកា* នូវផែនការដែលគេបានគិតគូរជាសំងាត់អស់ច្រើនថ្ងៃមកហើយ ។ គេប្រថុយពេលនេះដោយថា ប្រការដែលគេបានជួយសង្គ្រោះជីវិត *តូរ៉ាណាកា* កាលពីព្រឹកមិញនេះនឹងផ្ដល់អភ័យឯកសិទ្ធិពិសេសមួយដែលជួយគេអោយគេចព្ទុះបាន ។

*ម៉ារីកូ* ភ្ញាក់ក្រញ្ញាង :

- លោកថាម៉េច ?

- *សំពៅខ្មៅ*។ ជំរាបទៅលោកម្ចាស់ *តូរ៉ាណាកា* ថាគាត់គ្រាន់តែផ្ដល់សិទ្ធិអោយខ្ញុំមក។ រឿងឯទៀតគឺខ្ញុំរ៉ាប់រង ។ ជាមួយសំពៅរបស់ខ្ញុំ និងដោយមានជំនួយបន្តិចបន្តួច... យើងចែកស្ពត



www.budinst.gov.kh www.elibraryofcambodia.org

-*តូរ៉ាណាកា-សាម៉ា* មានប្រសាសន៍ថា រំសេវ កាណុង និងគ្រាប់ត្រូវបានរៀបចំដាក់ទៅក្នុងសំពៅរបស់លោកវិញអស់ហើយស្រេចមុនចេញពី *អាន់ជីរ៉ូ* ទៅ *យេដូ* នេះ *អាន់ជីន-សាន* ។ លោកម្ចាស់សួរថា តើលោកត្រូវការពេលវេលាប៉ុន្មានដើម្បីចេញដំណើរ ?

- នេះអាស្រ័យតាមស្ថានភាពសំពៅ ។ ត្រូវមានមនុស្សជួសជុលនិងថែទាំវា ដូរបង្គោលក្តោងវាជាដើម ។ តើលោកម្ចាស់ *តូរ៉ាណាកា* បានដឹងពីស្ថានភាពវាទេ ?

- លោកម្ចាស់មានប្រសាសន៍ថា មើលទៅសំពៅដូចជាល្អទេ តែដោយលោកមិនមែនជាអ្នកដើរសំពៅ ហេតុនេះលោកមិនហ៊ានច្បាស់ដែរទេ ។ លោកក៏មិនដែលបានឡើងទៅមើលទៀតដែរតាំងពីលោកបានបញ្ជាអោយគេអូសទៅ *យេដូ* ដើម្បីជួសជុលវានោះ ។ អីលូវបើយើងគិតថាសំពៅនេះចុះទឹកបានចុះ លោកម្ចាស់សួរថាតើលោកត្រូវការពេលវេលាប៉ុន្មាន ដើម្បីចេញធ្វើសង្គ្រាម ?

*ប្លាក់ថន* ញញោចខ្លួន :

- តើខ្ញុំត្រូវធ្វើសង្គ្រាមជាមួយអ្នកណា *ម៉ារីកូ-សាន*?

- លោកម្ចាស់សួរថា លោកចង់ធ្វើសង្គ្រាមជាមួយអ្នកណា ?

- *សំពៅខ្មៅ* ឆ្នាំនេះ ។

*ប្លាក់ថន* ឆ្លើយយ៉ាងរហ័ស ។ គេបានធ្វើការសំរេចចិត្តយ៉ាងបន្ទាន់ ដោយគេប្រឹងគ្រវីរសង្ឃឹមថា នេះគឺជាពេលដ៏ត្រឹមត្រូវដើម្បីលើកឡើងចំពោះមុខ *តូរ៉ាណាកា* នូវផែនការដែលគេបានគិតគូរជាសំងាត់អស់ច្រើនថ្ងៃមកហើយ ។ គេប្រថុយពេលនេះដោយថា ប្រការដែលគេបានជួយសង្គ្រោះជីវិត *តូរ៉ាណាកា* កាលពីព្រឹកមិញនេះនឹងផ្តល់អភ័យឯកសិទ្ធិពិសេសមួយដែលជួយគេអោយគេចព្យុះបាន ។

*ម៉ារីកូ* ភ្ញាក់ក្រញាង :

- លោកថាម៉េច ?

- *សំពៅខ្មៅ*។ ជំរាបទៅលោកម្ចាស់ *តូរ៉ាណាកា* ថាគាត់គ្រាន់តែផ្តល់សិទ្ធិអោយខ្ញុំមក ។ រឿងឯទៀតគឺខ្ញុំរ៉ាប់រង ។ ជាមួយសំពៅរបស់ខ្ញុំ និងដោយមានជំនួយបន្តិចបន្តួច... យើងចែកស្មើ



www.budinst.gov.kh www.elibraryofcambodia.org

និងជ័យភណ្ឌជាមួយគ្នា ។

*ម៉ារីកូ* សើច តែ *ភូរ៉ាណាកា* ឥតសើចជាមួយទេ ។

- លោកម្ចាស់ខ្ញុំនិយាយថា នេះជាទំរើប្រឆាំងនឹងប្រទេសជាមិត្តមួយដែលមិនអាចអត់អោនអោយបាន ។ ពួក *ប៉ុកទុយកាល់* មានសារសំខាន់ណាស់សំរាប់ប្រទេសជប៉ុន ។

- ពិតមែនហើយ ពួកវាមានសារសំខាន់មែនក្នុងពេលបច្ចុប្បនេះ ។ តែខ្ញុំជឿថាពួកវាជាសត្រូវរបស់គាត់ដូចជារបស់ខ្ញុំដែរ ទោះជាពួកវាបានផ្តល់សេវាអ្វីក៏ដោយ ។ ពួកយើងធ្វើបានល្អជាងណឹង ហើយថោកជាងផង ។

- លោកម្ចាស់មានប្រសាសន៍ថា ប្រហែលដែរ ។ ប៉ុន្តែមិនជាជឿថា ប្រទេសចិន នឹងរកស៊ីជាមួយលោកឡើយ ។ ទាំងអង់គ្លេស ទាំងហូឡង់ មិនទាន់មានកំលាំងនៅអាស៊ីនេះទេ ហើយយើងត្រូវការសូត្រនៅពេលនេះ និងក្នុងចំនួនមួយមិនអោយដាច់ ។

- លោកយល់ត្រូវហើយ ។តែក្នុងមួយឆ្នាំពីរឆ្នាំទៀត សភាពការណ៍ នឹង ប្រែប្រួលហើយ១ ពេលនោះគាត់ នឹងឃើញជាក់ស្តែងជាមិនខាន ។ អ៊ីចឹងហើយទើបខ្ញុំមានសំណើមួយទៀតជូន ។ ខ្ញុំកំពុងច្បាំងជាមួយពួក *ប៉ុកទុយកាល់* រួចទៅហើយ ក្រៅពីរង្វង់បីម៉ៃ គឺជាតំបន់ទឹកអន្តរជាតិ ។ ដោយមានលិខិតប្រគល់សិទ្ធិរបស់លោក ខ្ញុំអាចចាប់យក *សំពៅខ្មៅ* ហើយខ្ញុំអាចយកសំពៅ និងមុខទំនិញក្នុងសំពៅនោះទៅលក់នៅតាមកំពង់ផែណាក៏បាន ។ ដោយប្រើសំពៅខ្ញុំហើយ នឹងពួកនាវិកឯទៀត រឿងនេះងាយទេ ។ តែក្នុងប៉ុន្មានអាទិត្យ រឺប៉ុន្មានខែប៉ុននោះខ្ញុំអាចយក *សំពៅខ្មៅ* ហើយនឹងមុខទំនិញទាំងអស់ក្នុងសំពៅនោះទៅដល់ *យេដូ* បាន ។ ខ្ញុំអាចលក់សំពៅនៅ *យេដូ* តែម្តង ។ តំលៃពាក់កណ្តាលរបស់វាត្រូវទុកជាពន្ធផែ ។

- លោកម្ចាស់មានប្រសាសន៍ថា អ្វីដែលកើតមានឡើងនៅឯលំហសមុទ្ររវាងលោក និងសត្រូវរបស់លោក មិនមានទាក់ទងអ្វីដល់លោកម្ចាស់ទេ ។ សមុទ្រជារបស់គ្រប់១គ្នាទេ ។ តែដីនេះជារបស់យើង ហើយនៅទីនេះគឺច្បាប់យើងគ្រប់គ្រង ហើយច្បាប់នេះមិនអាចបំពានបានឡើយ ។

*ប្លាក់ថន* ដឹងថា ដំណើរគេនេះប្រកបដោយគ្រោះថ្នាក់ តែការពិភាល់របស់គេបានប្រាប់



www.budinst.gov.kh www.elibraryofcambodia.org

គេថា ពេលវេលានេះ គឺចំល្ងលណាស់ ហើយ *តូរ៉ាណាកា* ពិតជាព្រួយបារម្ភ ។ ព្រមទាំង *ម៉ារីកូ* ផង៖

- បាទ ពិតហើយ ។ នេះគ្រាន់ជាការជូនគំនិតតែប៉ុណ្ណោះ ។ លោកម្ចាស់ បានសួរខ្ញុំថា តើខ្ញុំចង់ធ្វើសង្គ្រាមជាមួយអ្នកណា ។ សូមអភ័យទោសដល់ខ្ញុំផង តែមានពេលខ្លះ គឺជាការល្អ ដែលយើងត្រូវលើកផែនការទប់ទល់ និង គ្រប់យថាហេតុ ។ ក្នុងនេះខ្ញុំជឿថា ផលប្រយោជន៍ របស់លោកម្ចាស់ *តូរ៉ាណាកា* គឺជាផលប្រយោជន៍របស់ខ្ញុំដែរ ។

*ម៉ារីកូ* បកប្រែ *តូរ៉ាណាកា* គ្រហឹមហើយនិយាយយ៉ាងខ្លី ។

- លោកម្ចាស់ *តូរ៉ាណាកា* វាយតម្លៃយ៉ាងខ្ពស់នូវការជូនគំនិតវាងវៃទាំងឡាយ *អាន់ជីន-សាន* ។ តែគំនិតមួយនេះគួរអោយអស់សំណើចណាស់ ។ ទោះជាផលប្រយោជន៍របស់លោកដូច គ្នា និង ផលប្រយោជន៍របស់លោកម្ចាស់ក្តី ហើយតាមពិតវាអត់ដូចគ្នាផងទេ តើលោក និង មនុស្សប្រាំបួននាក់របស់លោកអាចវាយប្រហារសំពៅដ៏ធំដែលមានមនុស្សជិតមួយពាន់នាក់ នៅលើនោះយ៉ាងម៉េចកើតទៅ ?

- ខ្ញុំមិនអាចទេ ។ ខ្ញុំត្រូវតែមានកងនាវិកថ្មី *ម៉ារីកូ-សាន* ។ ត្រូវការមនុស្សប៉ែតសិប រឺ កៅសិបនាក់ ។ ជាអ្នកដើរសមុទ្រ និង បាញ់កាណុងស្ទាត់ជំនាញ ។ ខ្ញុំអាចរកពួកនេះបាននៅឯ *ណាកាសាគី* ពីក្នុងសំពៅពួក *ប៉័កទុយកាល់* នេះឯង ។

*ប្លាក់ថន* ធ្វើជាមិនឃើញភាពជង្ហក់របស់ *ម៉ារីកូ* ក៏ដូចជាមិនឃើញថា ផ្ចិតរបស់នាងលែង បក់ទៀតហើយដែរ ។ គេបន្ត :

- ត្រូវតែមានពួកបារាំងខ្លះ ពួកអង់គ្លេសម្នាក់រឺពីរនាក់បើសិនជាខ្ញុំហេង ពួកអាឡឺម៉ង់ រឺ ហូឡង់ខ្លះ ។ ភាគច្រើនជាពួករត់ចោលជួរ រឺត្រូវគេបង្ខំអោយដើរសំពៅ ។ ខ្ញុំត្រូវការសំបុត្រ បើកផ្លូវទៅ*ណាកាសាគី* ត្រូវការកិច្ចការពារខ្លះ ហើយ និងប្រាក់រឺមាសបន្តិចបន្តួច ។ នៅក្នុងកង នាវាខ្ទាំងរមែងមានពួកនាវិកដែលតែងតែព្រមចូលដៃចូលជើងជាមួយយើងដើម្បីប្រាក់ និងជ័យ ភណ្ឌជានិច្ច ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា មេបញ្ជាការណាដែលទុកចិត្តសំពៅបែបនេះនៅក្នុង ការប្រយុទ្ធនោះ គឺចំជាឆ្កួតតែម្តង ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំឯកភាព ។ តែខ្ញុំត្រូវតែមានពួកនាវិក ដើម្បីដើរសមុទ្របាន ។

- លោកម្ចាស់សួរថា តើអាចបង្ហាត់ពួកសាមូរ៉ៃ និង ពួកដើរទូកយើងអោយធ្វើជាអ្នកបាញ់កាំភ្លើង និង អ្នកដើរសំពៅបានទេ ?

- បានយ៉ាងងាយ ។ ប៉ុន្តែត្រូវស៊ីពេលរាប់ខែ ។ ពួកនេះនឹងអាចប្រើការបាននៅឆ្នាំក្រោយ ហើយពេលនោះគ្មានផ្លូវអ្វីដែលអាចវាយលុកយក*សំពៅខ្មៅ*នៅឆ្នាំនេះបានទេ ។

- លោកម្ចាស់*តូរ៉ាណាកា* មានប្រសាសន៍ថា : « ខ្ញុំមិនមានផែនការវាយប្រហារ*សំពៅខ្មៅ* របស់ពួកប៉ិកទុយកាល់នៅឆ្នាំនេះ រឺនៅឆ្នាំក្រោយទេ ។ ពួកគេមិនមែនជាសត្រូវរបស់ខ្ញុំ ហើយខ្ញុំមិនមានសង្គ្រាមជាមួយពួកគេក៏ទេដែរ » ។

- ខ្ញុំដឹងហើយ ។ តែខ្ញុំគឺមានសង្គ្រាមជាមួយពួកនេះ ។ សូមអភ័យទោសដល់ខ្ញុំផង ។ ជាការពិតហើយ នេះគ្រាន់តែជាការពិភាក្សាគ្នាតែប៉ុណ្ណោះ ប៉ុន្តែខ្ញុំត្រូវការមនុស្សខ្លះដើម្បីដើរសមុទ្រ ដើម្បីអាចជួយលោកម្ចាស់*តូរ៉ាណាកា* បានខ្លះនៅពេលណាដែលលោកត្រូវការនោះ ។

ពួកគេអង្គុយនៅក្នុងបន្ទប់ផ្ទាល់ខ្លួនរបស់*តូរ៉ាណាកា* ដែលបើកចំហទៅរកសួនច្បារ ។ បន្ទាយមិនមានខូចខាតអ្វីធំដុំបណ្តាលមកពីការរញ្ជួយដីនោះឡើយ ។ រាត្រីនេះពោរពេញដោយសំណើម ហើយគ្មានខ្យល់បក់បន្តិចណាសោះឡើយ ។ ផ្សែងធូបសំរាប់បណ្តេញមូសនោះហុយយឺតៗឡើងទៅលើ ។ *ម៉ារីកូ* និយាយ :

- លោកម្ចាស់ខ្ញុំដឹងថា បើសិនជាលោកបានសំពៅនៅពេលនេះហើយ និង ពួកនាវិកប៉ុន្មាននាក់ដែលមកដល់ទីនេះជាមួយលោកនោះ តើលោកនឹងបើកវាទៅ*ណាកាសាគី* ដើម្បីរើសមនុស្សបន្ថែមដូចសំនើរបស់លោករឺទេ ?

- ទេ ធ្វើបែបនេះគឺគ្រោះថ្នាក់ណាស់ ។ ខ្ញុំខ្វះមនុស្សយ៉ាងហ្នឹង ពិតជាធ្វើអោយពួកប៉ិកទុយកាល់ចាប់ខ្លួនខ្ញុំបាន ។ ល្អបំផុតត្រូវមានមនុស្សមុន ហើយនាំពួកនោះទៅ*យេដូ* ។ នៅពេលណាដែលខ្ញុំមាននាវិកគ្រប់ចំនួនហើយៗមានអាវុធហើយនោះ ពួកសត្រូវមិនអាចប៉ះពាល់ខ្ញុំបានទេ ។

- លោកម្ចាស់ខ្ញុំគិតថា លោកនិងមនុស្សទាំងកៅសិបនាក់នោះមិនអាចកាន់កាប់*សំពៅ*



www.budinst.gov.kh www.elibraryofcambodia.org

*ខ្មៅ* បានទេ ។

- ជាមួយសំពៅ*អេវ៉ាស* ខ្ញុំអាចយកល្បឿនឈ្នះវាហើយពន្លិចវាបាន ។ ជាការពិតហើយ *ម៉ារីកូ-សាន* ទាំងនេះគ្រាន់តែជាត៌និត តែបើខ្ញុំទទួលបានការអនុញ្ញាតអោយវាយប្រហារ សត្រូវរបស់ខ្ញុំមែននោះ នៅពេលណាដែលខ្ញុំមាននាវិកហើយនោះ ខ្ញុំនឹងបើកសំពៅខ្ញុំទៅ*ណាកាសាគី*។ បើសិនជា*សំពៅខ្មៅ* ចូលផែហើយនោះ ខ្ញុំនឹងលើកទង់ប្រយុទ្ធរបស់ខ្ញុំ ហើយនៅបិទច្រកសមុទ្រនោះមិនអោយវាចេញរួច ។ ខ្ញុំនឹងទុកអោយសំពៅនេះជួញដូររួចរាល់ហើយ១ នៅពេលណាដែលមានខ្យល់សំរាប់វាវិលទៅស្រុកវិញនោះ ខ្ញុំធ្វើជាត្រូវការស្បៀងផ្គត់ផ្គង់ ហើយបណ្តោយអោយសំពៅនេះលួចចេញពីផែ ។ អាស្រ័យដោយសំពៅខ្ញុំលឿនជាង ខ្ញុំនឹងទៅតាមវាទាន់ ក្នុងប៉ុន្មានគាវុត ហើយកាណុងខ្ញុំនឹងរ៉ាប់រងបង្ហើយ ។ នៅពេលណាដែលសំពៅនេះទំលាក់ទង់ចុះចាញ់ហើយនោះ ខ្ញុំនឹងដាក់ពួកខ្ញុំឡើងលើសំពៅនោះ ហើយនាំវាមក*យេដូ* វិញ ។ យ៉ាងតិចណាស់ក៏មានមាសបី ទៅជិតបួនតោនដែរនៅលើសំពៅនោះ ។

- ហេតុអីបានជាមេបញ្ជាការសំពៅនោះមិន ពន្លិចសំពៅវាទៅបើវាចាញ់ទៅហើយនោះ ? នោះបើសិនជាលោកឈ្នះមែន ។ វាពន្លិចមុនលោកឯងឡើងលើសំពៅវា ។

- ពីព្រោះ...

*ត្វាក់ថន* ហៀបនិយាយថា: « ព្រោះពួកនាវិកអាចបះបោរបាន បើមេបញ្ជាការដាច់ខាតពេកនោះ ។ តែខ្ញុំមិនដែលឃើញអ្នកណាដែលឆ្កួតដល់ថ្នាក់ហ្នឹងទេ ។ ភាគច្រើនអ្នកឯងចរចាជាមួយមេបញ្ជាការ ដូចជាលើកលែងជីវិតពួកគេ ចែកចំនែកមួយភាគតូចអោយ ហើយអោយពួកគេចុះដោយសុវត្ថិភាពនៅផែណាមួយដែលនៅជិតជាងគេជាដើម ។ តែលើកនេះខ្ញុំត្រូវចរចាជាមួយ *រ៉ូឌ្រិច* ហើយខ្ញុំស្គាល់វា ហើយដឹងថាតើវានឹងធ្វើអ្វី » តែគេគិតថា ជាការល្អដែលមិនត្រូវបើកបង្ហាញផែនការរបស់គេទេ ។ យកល្បេងរបៀបពួកអ្នកចុងស្រុកទុកអោយអ្នកចុងស្រុកទៅ - គេគិត នៅក្នុងចិត្ត ។ ហេតុនេះគេបែរនិយាយផ្សេងទៅវិញ :

- ចម្ងាស់សំពៅដែលចាញ់រមែងសុំសារភាពហើយ *ម៉ារីកូ-សាន* ។ នេះជាទំលាប់... ជាទំលាប់មួយនៃសង្គ្រាមសមុទ្ររបស់ពួកយើង ។ នោះគឺចៀសវាងការបាត់បង់ជីវិត ដោយមិនចាំ



www.budinst.gov.kh www.elibraryofcambodia.org

បាច់ ។

- លោកម្ចាស់ តូរ៉ាណាកា មានប្រសាសន៍ថាអោយគាត់សូមទោស តែនេះជាទំលាប់គួរស្ងប់ខ្ពើមមួយ ។ បើសិនជាលោកមានកងនាវារបស់លោកវិញគឺគ្មានរឿងសារភាពឡើយ - នាងក្រេបទឹកតែ បន្តិចរួចបន្ត - រួចចុះបើសំពៅមិនទាន់ចូលផែ ?

- នៅពេលនោះ ខ្ញុំជ្រើសមុទ្រដើម្បីស្ទាក់សំពៅនេះនៅក្នុងដែនទឹកអន្តរជាតិ ។ ពេលនោះគឺងាយនឹងកាន់កាប់ទេ ដោយសំពៅផ្ទុកអីវ៉ាន់ធ្ងន់ តែក៏ពិបាកនាំទៅដល់ យេដូ ដែរ ។ តើពេលណាដែលសំពៅនេះចូលផែ ?

- លោកម្ចាស់ខ្ញុំមិនដឹងដែរ ។ លោកថាប្រហែលក្នុងសាមសិបថ្ងៃ ។ សំពៅឆ្នាំនេះមកលឿនជាងសព្វដង ។

ប្លាក់ថន ដឹងថា គេជិតចូលដល់រង្វាន់ធំហើយ ។ ជិតក្បែរបង្កើយ :

- បើអីចឹងយើងអាចខ្ចប់ច្រកចេញ ហើយចាប់យកសំពៅនេះបាននៅចុងរដូវ ។

ម៉ារីកូ បកហើយ ប្លាក់ថន មើលឃើញនូវកំហកចិត្តលេចឡើងមួយភ្លែតនៅលើមុខរបស់ តូរ៉ាណាកា ។ គេនៅស្ងៀមបន្តិច ធ្វើហាក់ដូចជារកមើលចំលាស់ថ្មី រួចពោលឡើង :

- បើសិននេះជាអឺរ៉ុបវិញ នៅមានរបៀបមួយទៀត ។ យើងអាចចេញសំពៅនៅពេលយប់ហើយប្រើកំលាំងវាយកាន់កាប់យកតែម្តង ។ នេះជាការវាយប្រហារដោយមិនអោយដឹងខ្លួនជាមុន ។

ដៃរបស់ តូរ៉ាណាកា ក្តាប់ផងដាវយ៉ាងណែន :

- លោកម្ចាស់មានប្រសាសន៍ថា លោកហ៊ានធ្វើសង្គ្រាមលើទឹកដីរបស់យើងប្រឆាំងនឹងសត្រូវរបស់លោកផង ?

បប្ញូរមាត់ ប្លាក់ថន ឡើងស្ងួតថែសតែម្តង :

- ទេ ។ ពិតហើយថា នេះគ្រាន់តែជាការលើកគំនិតឡើងតែប៉ុណ្ណោះ តែបើសិនជាសង្គ្រាមកើតមានឡើងរវាងលោក នឹងពួកប៉ក់ទុយកាល់ ហើយបើលោកម្ចាស់ តូរ៉ាណាកា ចង់បំផ្លាញពួកវានោះ នេះគឺជារបៀបដែលត្រូវធ្វើ ។ បើសិនជាខ្ញុំមានអ្នកប្រយុទ្ធស្ទាត់ជំនាញ និងដឹ



www.budinst.gov.kh www.elibraryofcambodia.org

*ខ្មៅ* បានទេ ។

- ជាមួយសំពៅ*អេវ៉ាស* ខ្ញុំអាចយកល្បឿនឈ្នះវាហើយពន្លិចវាបាន។ ជាការពិតហើយ *ម៉ារីកូ-សាន* ទាំងនេះគ្រាន់តែជាគំនិត តែបើខ្ញុំទទួលបានការអនុញ្ញាតអោយវាយប្រហារ សត្រូវរបស់ខ្ញុំមែននោះ នៅពេលណាដែលខ្ញុំមាននាវិកហើយនោះ ខ្ញុំនឹងបើកសំពៅខ្ញុំទៅ*ណាកាសាគី*។ បើសិនជា*សំពៅខ្មៅ* ចូលផែហើយនោះ ខ្ញុំនឹងលើកទង់ប្រយុទ្ធរបស់ខ្ញុំ ហើយនៅបិទច្រកសមុទ្រនោះមិនអោយវាចេញរួច ។ ខ្ញុំនឹងទុកអោយសំពៅនេះជួញដូររួចរាល់ហើយ១ នៅពេលណាដែលមានខ្យល់សំរាប់វាវិលទៅស្រុកវិញនោះ ខ្ញុំធ្វើជាត្រូវការស្បៀងផ្គត់ផ្គង់ ហើយបណ្តោយអោយសំពៅនេះលួចចេញពីផែ ។ អាស្រ័យដោយសំពៅខ្ញុំលឿនជាង ខ្ញុំនឹងទៅតាមវាទាន់ ក្នុងប៉ុន្មានគាវុត ហើយកាណុងខ្ញុំនឹងរ៉ាប់រងបង្ហើយ ។ នៅពេលណាដែលសំពៅនេះទំលាក់ទង់ចុះចាញ់ហើយនោះ ខ្ញុំនឹងដាក់ពួកខ្ញុំឡើងលើសំពៅនោះ ហើយនាំវាមក*យេដូ* វិញ ។ យ៉ាងតិចណាស់ក៏មានមាសបី ទៅជិតបួនតោនដែរនៅលើសំពៅនោះ ។

- ហេតុអីបានជាមេបញ្ជាការសំពៅនោះមិន ពន្លិចសំពៅវាទៅបើវាចាញ់ទៅហើយនោះ ? នោះបើសិនជាលោកឈ្នះមែន ។ វាពន្លិចមុនលោកឯងឡើងលើសំពៅវា ។

- ពីព្រោះ...

*ធ្វាក់ផន* ហៀបនិយាយថា: « ព្រោះពួកនាវិកអាចបះបោរបាន បើមេបញ្ជាការដាច់ខាតពេកនោះ ។ តែខ្ញុំមិនដែលឃើញអ្នកណាដែលឆ្កួតដល់ថ្នាក់ហ្នឹងទេ។ ភាគច្រើនអ្នកឯងចរចាជាមួយមេបញ្ជាការ ដូចជាលើកលែងជីវិតពួកគេ ចែកចំនែកមួយភាគតូចអោយ ហើយអោយពួកគេចុះដោយសុវត្ថិភាពនៅផែណាមួយដែលនៅជិតជាងគេជាដើម ។ តែលើកនេះខ្ញុំត្រូវចរចាជាមួយ *រ៉ូឌ្រិច* ហើយខ្ញុំស្គាល់វា ហើយដឹងថាតើវានឹងធ្វើអ្វី » តែគេគិតថា ជាការល្អដែលមិនត្រូវបើកបង្ហាញផែនការរបស់គេទេ។ យកល្អរបៀបពួកអ្នកចុងស្រុកទុកអោយអ្នកចុងស្រុកទៅ - គេគិត នៅក្នុងចិត្ត ។ ហេតុនេះគេបែរនិយាយផ្សេងទៅវិញ :

- ធម្មតាសំពៅដែលចាញ់រមែងសុំសារភាពហើយ *ម៉ារីកូ-សាន* ។ នេះជាទំលាប់... ជាទំលាប់មួយនៃសង្គ្រាមសមុទ្ររបស់ពួកយើង ។ នោះគឺចៀសវាងការបាត់បង់ជីវិត ដោយមិនចាំ



www.budinst.gov.kh www.elibraryofcambodia.org

បាច់ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថាអោយគាត់សូមទោស តែនេះជាទំលាប់គួរស្អប់ខ្ពើមមួយ ។ បើសិនជាលោកមានកងនាវារបស់លោកវិញគឺគ្មានរឿងសារភាពឡើយ - នាងក្រេបទឹកតែ បន្តិចរួចបន្ត - រួចចុះបើសំពៅមិនទាន់ចូលផែ ?

- នៅពេលនោះ ខ្ញុំជ្រើសមុទ្ទដើម្បីស្ទាក់សំពៅនេះនៅក្នុងដែនទឹកអន្តរជាតិ ។ ពេលនោះគឺងាយនឹងកាន់កាប់ទេ ដោយសំពៅផ្ទុកអីវ៉ាន់ធ្ងន់ តែក៏ពិបាកនាំទៅដល់ *យេដូ* ដែរ ។ តើពេលណាដែលសំពៅនេះចូលផែ ?

- លោកម្ចាស់ខ្ញុំមិនដឹងដែរ ។ លោកថាប្រហែលក្នុងសាមសិបថ្ងៃ ។ សំពៅឆ្នាំនេះមកលឿនជាងសព្វដង ។

*ប្លាក់ថន* ដឹងថា គេជិតចូលដល់រង្វាន់ធំហើយ ។ ជិតក្បែរកបង្កើយ :

- បើអីចឹងយើងអាចខ្ទប់ច្រកចេញ ហើយចាប់យកសំពៅនេះបាននៅចុងរដូវ ។

*ម៉ារីកូ* បកហើយ *ប្លាក់ថន* មើលឃើញនូវកំហកចិត្តលេចឡើងមួយភ្លែតនៅលើមុខរបស់ *តូរ៉ាណាកា* ។ គេនៅស្ងៀមបន្តិច ធ្វើហាក់ដូចជារកមើលចំលាស់ថ្មី រួចពោលឡើង :

- បើសិននេះជាអ៊ីរ៉ុបវិញ នៅមានរបៀបមួយទៀត ។ យើងអាចចេញសំពៅនៅពេលយប់ហើយប្រើកំលាំងវាយកាន់កាប់យកតែម្តង ។ នេះជាការវាយប្រហារដោយមិនអោយដឹងខ្លួនជាមុន ។

ដៃរបស់ *តូរ៉ាណាកា* ក្តាប់ដងដាវយ៉ាងណែន :

- លោកម្ចាស់មានប្រសាសន៍ថា លោកហ៊ានធ្វើសង្គ្រាមលើទឹកដីរបស់យើងប្រឆាំងនឹងសត្រូវរបស់លោកផង ?

បបូរមាត់ *ប្លាក់ថន* ឡើងស្ងួតថែសតែម្តង :

- ទេ ។ ពិតហើយថា នេះគ្រាន់តែជាការលើកគំនិតឡើងតែប៉ុណ្ណោះ តែបើសិនជាសង្គ្រាមកើតមានឡើងរវាងលោក និងពួកប៉ក់ទុយកាល់ ហើយបើលោកម្ចាស់ *តូរ៉ាណាកា* ចង់បំផ្លាញពួកវានោះ នេះគឺជារបៀបដែលត្រូវធ្វើ ។ បើសិនជាខ្ញុំមានអ្នកប្រយុទ្ធស្ទាត់ជំនាញ និងដំ



www.budinst.gov.kh www.elibraryofcambodia.org

មានវិន័យពីរឺបីរយនាក់ មានពួកនាវិកហើយនឹងសំពៅ *អេរ៉ាស* គឺជាការងាយបំផុតដែលទៅអែប *សំពៅខ្មៅ* ដើម្បីវាយលុកកាន់កាប់សំពៅនេះ ហើយយកទៅឯលំហសមុទ្រនោះ ។ លោកម្ចាស់អាចរើសពេលវេលាសំរាប់ការវាយលុកមិនអោយដឹងខ្លួនទេ... នេះបើសិនជានៅអឺរ៉ុប ។

ភាពស្ងៀមស្ងាត់បានកើតមានឡើងអស់រយៈពេលយ៉ាងយូរ :

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា ទីនេះមិនមែនជាអឺរ៉ុបហើយគ្មានស្ថានភាពសង្គ្រាម និងនឹងមិនមានស្ថានភាពសង្គ្រាមជាដាច់ខាតរវាងលោក នឹងពួក *ប៉័កទុយកាល់* ផង ។

- ពិតហើយ ។ នៅចំនុចមួយទៀត *ម៉ារីកូ-សាន* : *ណាកាសាគី* មិនស្ថិតនៅក្រោមការត្រួតត្រារបស់លោកម្ចាស់ *តូរ៉ាណាកា* ទេ មែនទេ ?

- ពិតមែនហើយ ។ លោកម្ចាស់ *ហារីម៉ា* ត្រួតត្រាកំពង់ផែ ហើយនឹងតំបន់ជុំវិញនោះ ។

- តែមិនគឺពួក *យេស៊ូអ៊ីត* ទេវីដែលក្នុងជាក់ស្តែងជាអ្នកត្រួតត្រាកំពង់ផែ ហើយនឹងជំនួញជួញដូរទាំងអស់នោះ ?

*ប្លាក់ថន* កត់សំគាល់នូវភាពតុញ្ញុះរបស់នាងក្នុងការបកប្រែរឿងនេះ ប៉ុន្តែគេនៅតែសង្កត់ជាប់ :

- នេះមិនគឺ *ហុនតូ* ទេរី *ម៉ារីកូ-សាន* ? ហើយក្រែងលោកម្ចាស់ *ហារីម៉ា* ជាកាតូលិចអ្វី ? មិនគឺភាគច្រើននៃតំបន់ *ក្យូស្យូ* ជាកាតូលិច ? ហេតុនេះមិនគឺពួកយេស៊ុអ៊ីតទេរីដែលត្រួតត្រាកោះនេះទាំងមូលនោះ ?

- គ្រិស្តសាសនា ជាសាសនា ។ ពួក *ដៃមីញ៉ូ* ត្រួតត្រាដែនដីរបស់ខ្លួន *អាន់ជីន-សាន* ។

- តែគេប្រាប់ខ្ញុំថា *ណាកាសាគី* គឺពិតជាទឹកដី *ប៉័កទុយកាល់* ។ គេប្រាប់ថាពួកវានៅទីនោះធ្វើមើលតែពួកវានៅស្រុកវាអ៊ីចឹង ។ មិនគឺឪពុកលោកម្ចាស់ *ហារីម៉ា* ទេអ្វីដែលបានលក់ដីទៅអោយពួក *យេស៊ូអ៊ីត* នោះ ?

សំលេងរបស់ *ម៉ារីកូ* ឡើងមុតស្រួច :

- ចាសពិតមែន តែលោកម្ចាស់ *តៃកូ* បានយកដីនោះមកវិញ ។ បច្ចុប្បន្ននេះជនបរទេសមិនអាចកាន់កាប់ដីនៅទីនេះបានទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- តែមិនគឺលោកម្ចាស់ *វ៉កកូ* បានបណ្តោយអោយអាជ្ញារបស់លោកអស់ឥទ្ធិពលដែលជាហេតុអោយបច្ចុប្បន្ននេះ គ្មានអ្វីដែលកើតឡើងនៅទីនោះ ដោយគ្មានការយល់ព្រមរបស់ពួក *យេស៊ិត*ទ មែនទេ? មិនគឺពួក*យេស៊ិត* ទើបដែលត្រួតត្រារាល់នាវាចរណ៍ និងពាណិជ្ជកម្មទាំងអស់នៅទីនោះ? មិនគឺពួក*យេស៊ិត* ទើបដែលធ្វើការចរចាពាណិជ្ជកម្មទាំងអស់ជំនួសពួកនាង ហើយធ្វើជាឈ្មួញកណ្តាលអោយពួកនាងនោះ ។

*ម៉ារីកូ* តបដោយយ៉ាងគំបុត :

- *អាន់ជីន-សាន* លោកមានពតិមានច្បាស់លួណាស់ពី*ណាកាសាគី* ។

- ប្រហែលជាលោកម្ចាស់ *តូរ៉ាណាកា* គួរតែដណ្តើមការត្រួតត្រាកំពង់ផែនេះពីពួកសត្រូវមកវិញ ។ អាច...

- ពួកនោះជាសត្រូវរបស់លោក*អាន់ជីន-សាន* មិនមែនជាសត្រូវរបស់ពួកយើងទេ-*ម៉ារីកូ* នៅទីបំផុតបានត្របាក់នុយមែន - ពួក*យេស៊ិត*ជា....

- *ណាន ចា?*

នាងបែរខ្លួនសូមទោស ហើយពន្យល់ប្រាប់*តូរ៉ាណាកា* ពីអ្វីដែលគេទាំងពីរនាក់បានជជែកគ្នា ។ ពេលនាងនិយាយចប់ហើយលោកក៏និយាយម៉ាត់១ ដែលជាការបន្ទោសយ៉ាងច្បាស់ ។ *ម៉ារីកូ* តបវិញថា *វ៉ៃ* ១ ជាច្រើនដងហើយក្រាបលំអោនខ្លួនយ៉ាងទាបទទួលកំហុស ។ នាងពោលឡើង :

- លោកម្ចាស់*តូរ៉ាណាកា* រំលឹកខ្ញុំថា មតិរបស់ខ្ញុំគ្មានតំលៃទេ ហើយអ្នកបកប្រែត្រូវតែបកប្រែតែប៉ុននោះ *នេ?* សូមលោកអភ័យទោសអោយខ្ញុំផង ។

ដំបូង*ប្លាក់ថន* ក៏មានបំនងសូមទោសនាងចំពោះអន្ទាក់ដែលគេដាក់នេះដែរ ។ តែគេលែងមានគំនិតនេះទៀតហើយ១ ដោយពេលនេះគេបានបោះមួយជំហានទៅមុខហើយនោះ គេសើច ហើយនិយាយឡើង :

- *វ៉ៃ កាវ៉ាយ ឈូតូកូ-សាម៉ា!* បាទអ្នកស្រីបកប្រែដ៏ល្អស្រស់ !

*ម៉ារីកូ* ញញឹមទាំងបង្ខំ នៅក្នុងចិត្តសែនក្តៅក្រហាយដោយភ្លាត់ចូលអន្ទាក់របស់គេ



www.budinst.gov.kh www.elibraryofcambodia.org

អារម្មណ៍នាងពោរពេញដោយទំនាស់ រវាងភក្ដីភាពទាំងពួងដែលនាងមិនអាចបែងចែកដាក់បាន ។ *តូរ៉ាណាកា* បន្ទរឡើងក្នុង អាការៈរីករាយឡើងវិញ :

- *យ៉ាយ អាន់ជីន-សាន* ។

- *ម៉ារីកូ-សាន ការ៉ាយ គេស៊ូយូរី ឈូតូ-សាន អាណោមស៊ីកាណូរីម៉ាសេន ទេ?* ហើយមិនគឺ *ម៉ារីកូ* ស្អាតជាងកញ្ញាស់ *ឈូកូ-សាន* ដែរមែនទេ លោកម្ចាស់ ?

*តូរ៉ាណាកា* សើច :

- *ហៃ* !

*ម៉ារីកូ* មុខឡើងក្រហម ។ នាងចាក់តែដោយមានចិត្តត្រជាក់ជាងមុនបន្តិចហើយ ។ រួច *តូរ៉ាណាកា* ក៏និយាយឡើងក្នុងសំដីយ៉ាងម៉ត់ចត់ :

- លោកម្ចាស់យើងសួរថា ហេតុអ្វីក៏លោកសួរសំនួរ រឹក៏វាយវ៉ាប់ច្រើនម្ល៉េះពីលោកម្ចាស់ *ហារីម៉ា* និងទីក្រុង *ណាកាសាគី* ?

- នេះគឺគ្រាន់តែបង្ហាញថា ការពិត *ណាកាសាគី* ត្រូវព្រួតត្រា ដោយ**ពួកបរទេស**តែប៉ុននោះ ។ព្រួតត្រាដោយពួក**ប៉ិគន្ទុយគាល់** ។ ហើយបើតាមច្បាប់របស់ខ្ញុំៗមានសិទ្ធិស្របច្បាប់នឹង វាយប្រហារសត្រូវខ្ញុំនៅកន្លែងណាក៏បាន ។

- តែលោកម្ចាស់មានប្រសាសន៍ថា ទីនេះមិនមែនជា« កន្លែងណា »នោះទេ ។ នេះជាទេវនគរ ហើយការវាយប្រហារបែបនេះមិនអាចកើតមានបានឡើយ ។

- ខ្ញុំឯកភាពអស់ពីពោះពីពុង ។ តែនេះបើសិនជាលោកម្ចាស់ *ហារីម៉ា* ក្លាយជាសត្រូវ រឺនៅពេលណាដែលពួក *យេស៊ូត* ដែលដឹកនាំពួក *ប៉ិកទុយកាល់* ក្លាយជាសត្រូវ នេះ គឺជាវិធីដើម្បីដេញពួកវាអោយទាល់ជញ្ជាំង ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថាលោកក្ដី *ដៃមីញ៉ូ* ឯទៀតក្ដីនឹងមិនអនុញ្ញាតអោយប្រជាជាតិបរទេសមួយវាយលុកទៅ លើប្រជាជាតិមួយទៀតនៅលើដីជប៉ុន ក៏ដូចជាមិនអនុញ្ញាតពួកនេះសំលាប់ប្រជារាស្ត្រជប៉ុនណាម្នាក់ឡើយ ។បើប្រឆាំង នឹងសត្រូវព្រះចៅនោះជារឿងផ្សេង។ ក្នុងការរកពួកប្រយុទ្ធ និងពួកនាវិកនោះវិញអោយតែអ្នកដើររកនោះចេះនិយាយ



www.budinst.gov.kh www.elibraryofcambodia.org

ជប៉ុន គឺមិនពិបាកទេ ចង់បានប៉ុន្មាន ក៏បានដែរ ។ មានពួក *វ៉ាកូ* ច្រើនណាស់នៅ *ត្សូស៊ុ* ។

- ចុះនៅ *វ៉ាកូ ម៉ារីកូ-សាន* ?

- *វ៉ាកូ* គឺជាប្រភេទពួក *កកស៊ែ* (Corsair) ណា *អាន់ជីន-សាន* ។ ពួកនេះមានជីវរបស់ខ្លួននៅជុំវិញ *ត្សូស៊ុ* តែពួកនេះភាគច្រើនត្រូវកំចាត់ដោយលោកម្ចាស់ *តែកូ* ។ តែក៏នៅមានពួកសេសសល់នៅឡើយដែរ ។ ពួក *វ៉ាកូ* ធ្វើព្យុះធ្វើផ្គររាប់សតវត្សរ៍មកហើយនៅតាមឆ្នេរសមុទ្រស្រុកចិន ។ គឺដោយពួកនេះហើយដែលប្រទេសចិនបិទទ្វារមិនអោយពួកយើងចូលនោះ ។

រួចនាង ក៏ងាកទៅពន្យល់ *តូរ៉ាណាកា* ពីអ្វីដែលនាងបាននិយាយ ។ *តូរ៉ាណាកា* ក៏និយាយបន្តទៅទៀត ៖

- លោកម្ចាស់មានប្រសាសន៍ថា លោក នឹង មិនបណ្តោយ រឺ មានគំរោង រឺអនុញ្ញាតជាដាច់ខាតអោយលោក បើកការវាយប្រហារលើគោកឡើយ ថ្វីត្បិតតែជាការត្រឹមត្រូវដែលលោកយារយីសត្រូវ មហាក្សត្រិយ៍របស់លោកនៅក្នុង លំហសមុទ្រក៏ដោយ ។ លោកមានប្រសាសន៍ម្តងទៀតថា ទីនេះមិនមែនជា « កន្លែងណា » នោះទេ ។ នេះជាទេវនគរ ។ លោកត្រូវចេះខន្តីដូចដែលលោកម្ចាស់បានប្រាប់លោកពីពេលមុននោះអីចឹង ។

- បាទ ខ្ញុំបានប្រឹងប្រែងខន្តីតាមដំណើររបស់គាត់ហើយ ។ខ្ញុំចង់បំផ្លាញពួកសត្រូវពីព្រោះពួកវាជាសត្រូវ ។ ហើយខ្ញុំជឿយ៉ាងជាក់ថា ពួកនេះ ក៏ជាសត្រូវរបស់លោកដែរ ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថាពួក *ប៉ាកទុយកាល់* ក៏បានប្រាប់លោកថា **លោកឯង** ក៏ជាសត្រូវរបស់លោកម្ចាស់ដែរ ហើយទាំង *ឈូតូ-សាន* និង ព្រះតេជគុណគណៈអធិការសង្ឃ ក៏ច្បាស់ពិតប្រាកដក្នុងអំនះអំនាងនេះដែរ ។

- ចុះបើសិនជាខ្ញុំអាចចាប់បាន *សំពៅខ្មៅ* នៅឯលំហសមុទ្រ ហើយអូសវាជាជ័យភណ្ឌមកកំពង់ផែ *យេដូ* ក្រោមទង់ប្រទេសអង់គ្លេស តើខ្ញុំនឹងទទួលការអនុញ្ញាតអោយលក់សំពៅនោះហើយ នឹងមុខទំនិញរបស់វានៅឯ *យេដូ* ស្របទៅតាមទំលាប់របស់ពួកយើងបានទេ?

- លោកម្ចាស់មានប្រសាសន៍ថា នេះចំនុះលក្ខខណ្ឌមួយចំនួនដែរ ។

- បើសិនជាសង្គ្រាមមកដល់ តើខ្ញុំនឹងទទួលអោយធ្វើការវាយប្រហារលើពួកសត្រូវ



www.budinst.gov.kh www.elibraryofcambodia.org

ពោលគឺសត្រូវរបស់លោកម្ចាស់ *តូកីណាកា* តាមផ្លូវណាដែលខ្ញុំយល់ថាល្អប្រសើរបំផុតទេ ?

- លោកម្ចាស់មាន ប្រសាសន៍ថា នេះជាភារកិច្ចរបស់ *ហាតាម៉ូតូ* ។ ជាការពិតហើយ *ហាតាម៉ូតូ* ត្រូវស្ថិតនៅក្រោមបញ្ជារបស់ លោកគ្រប់ពេលវេលា ។ លោកម្ចាស់ខ្ញុំចង់អោយខ្ញុំបញ្ជាក់អោយច្បាស់ថា រឿងរ៉ាវនៅប្រទេសជប៉ុនមិនអាច ដោះស្រាយបានតាមវិធីណាផ្សេងក្រៅតែតាមវិធីរបស់ជប៉ុនតែប៉ុណ្ណោះ ។

- បាទ ខ្ញុំយល់បានទាំងស្រុង ។ ដោយយ៉ាងរាបសាបំផុត ខ្ញុំចង់បញ្ជាក់ថានៅពេលណាដែល ខ្ញុំដឹងពីបញ្ហារបស់លោកម្ចាស់ កាន់តែច្រើនពេលណា ខ្ញុំកាន់តែអាចជួយលោកច្រើនពេលនោះ ។

- លោកម្ចាស់មានប្រសាសន៍ថា ភារកិច្ចរបស់ *ហាតាម៉ូតូ* គឺជួយអម្ចាស់របស់ខ្លួនហើយ *អាន់ជីន-សាន* ។ លោកមានប្រសាសន៍ថា អោយខ្ញុំឆ្លើយចំពោះសំនួរសមហេតុផលដែលលោកមានបំនងចង់សួរ ។

- សូមអរគុណ ។ តើខ្ញុំអាចសួរលោកម្ចាស់ថា តើគាត់ចង់បានកងនាវាចរផ្ទាល់ខ្លួនរបស់លោកទេ ?គឺដូចកាលខ្ញុំបានជូនគំនិតកាលពីនៅលើទូកធំនោះណា ។

- លោកបានមានប្រសាសន៍ហើយថា លោកចង់បានកងនាវាចរ។ កងនាវាចរទំនើបដែលបញ្ជាដោយមនុស្សរបស់លោក ។ តើដៃមីញ៉ូណាដែលមិនចង់បាននោះ *អាន់ជីន-សាន ?*

- បើអ៊ីចឹងសូមជំរាបទៅលោកថាអ៊ីចេះ : បើខ្ញុំមានសំនាងអាចចាប់បាន*សំពៅខ្មៅ* ខ្ញុំនឹងយកសំពៅនោះទៅ *យេដូ* ដើម្បីកែកុនវា។ រួចខ្ញុំផ្ទេរជ័យកណ្តាពាក់កណ្តាលដាក់ទៅលើសំពៅ *អេរ៉ាស* របស់ខ្ញុំហើយលក់*សំពៅខ្មៅ* ទៅអោយពួក*ប៉ុកទុយកាល់* វិញរីក៏ជូនទៅលោកម្ចាស់ *តូកីណាកា* ជាជំនូន រីក៏ដុតវាចោលក៏បានស្រេចតែលោកចង់ ។ រួចខ្ញុំវិលទៅប្រទេសវិញ ។ ក្នុង រង្វង់មួយឆ្នាំខ្ញុំ នឹងត្រលប់មកវិញ ដោយនាំមកនូវសំពៅបួនមកជាមួយផង ដែលជាចំនងដៃរបស់ព្រះមហាក្សត្រីយ៍ប្រទេសអង់គ្លេសចំពោះលោកម្ចាស់ *តូកីណាកា* ។

- លោកម្ចាស់សួរថា នៅក្នុងរឿងនេះ តើលោកបានចំនេញអីទៅ ?

- ការពិតគឺថា នៅពេលណាដែលព្រះមហាក្សត្រីយ៍សងថ្លៃសំពៅទាំងនោះហើយ ខ្ញុំនឹង



www.budinst.gov.kh www.elibraryofcambodia.org

មានប្រាក់ចំនេញយ៉ាងច្រើន ។ បន្ទាប់មកទៀត ខ្ញុំចង់នាំទីប្រឹក្សាណាដែលលោកទុកចិត្តបំផុត អោយទៅជាមួយខ្ញុំក្នុងឋានៈជាឯកអគ្គរាជទូត ។ សន្ធិសញ្ញាមិត្តភាពរវាងប្រទេសយើងទាំងពីរ ពិតជានាំមកនូវផលប្រយោជន៍សំរាប់លោកម្ចាស់ជាមិនខាន ។

- លោកម្ចាស់ខ្ញុំមានប្រសាសន៍ថា មហាក្សត្រីយ៍របស់លោកដូចជាចិត្តល្អពេកហើយ ។ លោកបន្ថែមថា តែបើសិនជារឿងនេះកើតមានឡើងមែនដូចរឿងអព្ភូតហេតុទៅចុះ ហើយលោកត្រលប់មកវិញជាមួយសំពៅថ្មីទាំងនោះមែន តើអ្នកណានឹងបង្ហិកហាត់ពួកនាវិក ពួកសាមូរ៉ៃ និងបញ្ជាការដើម្បីបញ្ជាកងសំពៅរបស់លោក ?

- បើសិនជាលោកម្ចាស់ពេញចិត្ត នៅដើមដំបូងខ្ញុំ នឹងទទួលបង្ហាត់ពួកនោះ ។

- លោកម្ចាស់ខ្ញុំសួរថា «ដើមដំបូង» នេះមានន័យយ៉ាងម៉េច ?

- គឺក្នុងពីរឆ្នាំ ។

*តូរ៉ាណាកា* ញញឹមមួយខ្ទាច់ ។

- លោកម្ចាស់មានប្រសាសន៍ថា « ដើមដំបូង » ពីរឆ្នាំនេះមិនគ្រប់គ្រាន់ទេ ។ លោកបានបន្ថែមថា តែទោះយ៉ាងណាក្តី ក៏នេះគ្រាន់តែជាការស្រមើស្រមៃតែប៉ុណ្ណោះ ។ លោកមិនមានធ្វើសង្គ្រាមជាមួយពួក*ប៉ិកទុយកាល់* រឺលោកម្ចាស់*ហារីម៉ា* នៃតំបន់*ណាកាសាគី* ឡើយ ។ លោកសូមនិយាយម្តងទៀតថា អ្វីដែលលោកធ្វើនៅក្រៅដែនសមុទ្រជប៉ុននៅលើសំពៅផ្ទាល់ខ្លួនរបស់លោក ជាមួយពួកនាវិក ផ្ទាល់ខ្លួនរបស់លោក នេះ គឺជា*កាម៉ា* ផ្ទាល់ខ្លួន របស់លោកតែប៉ុនោះ - *ម៉ារីកូ* ហាក់បង្ហាញភាពជ្រួលច្របល់-លោកម្ចាស់ថាក្រៅដែនទឹករបស់យើង លោកគឺជាជនបរទេស ។ តែនៅទីនេះ លោកគឺជា *សាមូរ៉ៃ* ។

- បាទ ហើយខ្ញុំដឹងណាស់ពីទំហំនៃកិត្តិយសដែលលោក បានផ្តល់មកអោយខ្ញុំ។ *ម៉ារីកូ-សាន* តើខ្ញុំអាចសួរបានទេថា តើពួកសាមូរ៉ៃខ្ចីលុយរបៀបណាទៅ ?

- ពីពួកអ្នកចងការ *អាន់ជីន-សាន* ។ ក្រៅពីណឹងទៅរកឯណា ? មានតែខ្ចីលុយពីពួកឈ្មួញ ដ៏តត្រិចទាំងនោះឯង - នាងបកប្រែទៅអោយ *តូរ៉ាណាកា* - ហេតុអីបានជាលោកត្រូវការលុយ ?



www.budinst.gov.kh www.elibraryofcambodia.org

- មានអ្នកចង់ការប្រាក់នៅ *យេដូ*រទេ ?

- ចាស មាន ។ អ្នកចង់ការមាននៅសព្វទីកន្លែងហ្នឹង *នេ* ? ក្រែងដូចគ្នានឹងស្រុករបស់លោកដែរអ្ហី ? សូមសួរទៅកំនាន់របស់លោកទៅ *អាន់ជីន-សាន* ។ ប្រហែលជានាងអាចជួយបាន ព្រោះនេះជាផ្នែកមួយនៃការកិច្ចរបស់នាងដែរ ។

- នាងនិយាយថា យើងចេញដំណើរទៅ *យេដូ* ស្អែកនេះអ្ហី ?

- ចាស ស្អែកនេះ ។

- បើអ៊ីចឹង គឺជាការគួរអោយស្តាយ ដោយ *ភូជីកូ-សាន* មិនអាចធ្វើដំណើរបានទេ ។ *ម៉ារីកូ* និយាយទៅកាន់ *តូរ៉ាណាកា* ។

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា លោកនឹងបញ្ជូននាងទៅតាមទូកធំនៅពេលណាដែលទូកនេះត្រូវចេញដំណើរ ។ លោកសួរថា តើលោកត្រូវការខ្ចីប្រាក់សំរាប់ធ្វើអ្ហី ?

- ខ្ញុំត្រូវការរើសពួកនាវិកថ្មី *ម៉ារីកូ*-សាន ។ ដើម្បីចេញសំពៅទៅសព្វទីកន្លែងដើម្បីបំរើសព្វបំនងរបស់លោកម្ចាស់ *តូរ៉ាណាកា* តើនេះត្រូវបានអនុញ្ញាតទេ ?

- យកពួកនាវិកពី *ណាកាសាគី* រឺ ?

- បាទ ។

- លោកម្ចាស់នឹងផ្តល់ចំលើយដល់លោកនៅពេលណាដែលលោកទៅដល់ *យេដូ* ។

- *ដូម៉ូ តូរ៉ាណាកា-សាម៉ា* ? *ម៉ារីកូ-សាន* នៅពេលដែលខ្ញុំទៅដល់ *យេដូ* ហើយតើខ្ញុំត្រូវទៅកន្លែងណា? តើនៅទីនោះមានអ្នកណាគ្រាន់ជួយនាំផ្លូវខ្ញុំទេ ?

- អូហ៍ លោកមិនគួរខ្វល់ពីរឿងអ៊ីចឹងៗទេ *អាន់ជីន-សាន* ។ លោកគឺជា *ហាតាម៉ូតូ* ម្នាក់របស់លោកម្ចាស់ *តូរ៉ាណាកា* ណា៎ ។

ស្នូរគោះទ្វារបានលាន់ឡើងនៅឯមាត់ទ្វារខាងក្នុង ។

- ចូលមក ។

*ណាកា* ទាញទ្វាររអែបទៅម្ខាង ហើយលំអោនខ្លួន :

- សូមទោស ពុកបានអោយជំរាបពុកនៅពេលណាដែលមេទ័ពពុកទាំងអស់មកជួប



www.budinst.gov.kh www.elibraryofcambodia.org

ជុំគ្នាហើយ ។

- អរគុណហើយ ។ បន្តិចទៀតពុកទៅដល់ហើយ ។

*តូរ៉ាណាកា* គិតមួយសន្ទុះ រួចធ្វើសញ្ញាទៅអោយ *ឡាក់ថុន* ។ កាយវិការរបស់លោក មានភាពស្និទ្ធស្នាល :

- *អាន់ជីន-សាន* ទៅជាមួយ*ណាកា-សាន* ។ វានឹងបង្ហាញទីកន្លែងដល់លោក ។ អរគុណលើទស្សនៈលោក ។

- បាទ ទាន ។ សូមអរគុណដែលបានស្តាប់ ។ សូមអរគុណចំពោះសំដីរបស់លោកម្ចាស់ ។ បាទ ខ្ញុំនឹងខិតខំខន្តី និងសុក្រឹត ។

- សូមអរគុណ*អាន់ជីន-សាន* ។

*តូរ៉ាណាកា* សំលឹងមើល*ឡាក់ថុន* ដែលលំអោនខ្លួន និងចេញទៅ ។ រួចលោកងាកទៅសួរ *ម៉ារីកូ* :

- មើល តើនាងយល់យ៉ាងណាដែរ ?

- មានពីរលោកម្ចាស់ ។ ទីមួយ គំនុំគាត់ជាមួយពួក*យេស៊ូអ៊ីត* គឺមហាសែនជ្រៅគឺលើសពីប្រការដែលគាត់ស្អប់ពួក*ប៉ិកទុយកាល់* ទៅទៀត ។ ដោយហេតុនេះ គាត់គឺជារំពាត់ខ្សែតីមួយដែលលោកម្ចាស់អាចវាយវាត់ពួកទាំងពីរក្រុមនេះ រឺមួយណាក៏បានដែរ នេះបើលោកម្ចាស់ចង់ប្រើខ្សែតី ។ យើងសុទ្ធតែដឹងហើយថា គាត់ជាមនុស្សក្លាហាន ហើយគាត់ពិតជាវិញ្ញូប្រានបានវាល់ការវាយលុកទាំងអស់ដែលមកពីសមុទ្ទ ។ ទីពីរលុយកាក់ គឺទៅតែស្ថិតជាគោលដៅរបស់គាត់ ។ អ្វីដែលខ្ញុំយល់ដឹងបាន គឺលុយកាក់ជាមធ្យោបាយពិតប្រាកដតែមួយគត់សំរាប់អំនាចដ៏ស្ថិតស្ថេរមួយ ។ ពួកគេនេះទិញដី ទិញឋានៈ សូម្បីតែព្រះមហាក្សត្រីយ៍របស់ពួកនេះក៏ជាឈ្មួញដែរ ហើយស្តេចស្រីគេនេះ «លក់» ដីអោយពួកអម្ចាស់របស់ខ្លួនឯង ហើយទទួលទិញ សំពៅទិញដីផងដែរ ។ ពួកនេះមិនសូវខុសពីយើងទេលោកម្ចាស់ ក្រៅតែពីលើចំនុចនេះ ។ និងខុសពីយើងត្រង់ពួកគេមិនយល់ថាអ្វីទៅដែលជាអំនាច ហើយនឹងថា សង្គ្រាមគឺជីវិត ហើយជីវិត គឺស្លាប់នោះឯង ។



www.budinst.gov.kh www.elibraryofcambodia.org

- តើពួក*យេស៊ុីត*ជាសត្រូវរបស់ខ្ញុំ រឺ ?

- ខ្ញុំមិនជឿទេលោកម្ចាស់ ។

- ចុះពួក*ប៉ិកទុយកាល់* ?

- ខ្ញុំជឿថា ពួកនេះខ្វល់តែពីរឿងចំនេញ រឿងដី និងផ្សព្វផ្សាយបន្ទូលព្រះជាម្ចាស់តែប៉ុននោះ ។

- តើពួកគ្រិស្តសាសនិកជាសត្រូវរបស់ខ្ញុំ រឺ ?

- មិនមែនទេលោកម្ចាស់ ។ ថ្វីត្បិតតែសត្រូវរបស់លោកខ្លះអាចជាគ្រិស្តសាសនិកក្តី ពោល គឺពួកកាតូលិច រឺប្រូតេស្តង់ ។

- តើនាងគិតថា *អាន់ជីន-សាន* ជាសត្រូវរបស់ខ្ញុំ រឺ ?

- ទេ លោកម្ចាស់ ។ ទេ ។ ខ្ញុំជឿថាគាត់គោរពលោកម្ចាស់ ហើយពេលណាមួយគាត់ នឹងក្លាយជាអណ្តាប់ ដ៏ពិតប្រាកដរបស់លោកម្ចាស់ជាមិនខាន ។

- ចុះពួកគ្រិស្តសាសនិកវិញ ? តើអ្នកណាជាសត្រូវ ?

- ពួកលោកម្ចាស់*ហារីម៉ា* , *គីយ៉ាម៉ា*, *អូណូស៊ី* និងពួកសាមូរ៉ៃឯទៀតដែលងាកមកប្រឆាំងនឹងលោក ។

*តូរ៉ាណាកា* ផ្ទុះសំនើច :

- ណឹងហើយ តែតើពួកបព្វជិតបញ្ជាលើពួកនេះ ដូចដែល*អាន់ជីន-សាន* លើកជាគំនិតនោះទេ ?

- ខ្ញុំគិតថា ដូចជាមិនមែនទេ ។

- តើពួកអាបីនាក់ណឹង នឹងប្រឆាំងខ្ញុំទេ ?

- ខ្ញុំមិនដឹងទេលោកម្ចាស់ ។ កាលពីអតីតកាល ពួកនេះធ្លាប់ជាសត្រូវផងធ្លាប់ជាមិត្តផងជាមួយលោកម្ចាស់ ។ តែបើពួកគេចូលដៃជាមួយ *អ៊ីស៊ីដូ* នោះគឺពិតជាអាក្រក់មែនទែន ។

- ខ្ញុំឯកភាព ។ ពិតមែនហើយ នាងគឺជាទីប្រឹក្សាមួយដ៏មានតំលៃ ។ គឺពិតជាពិបាកណាស់ចំពោះនាងដែលជាកាតូលិច ហើយត្រូវធ្វើមិត្តជាមួយសត្រូវ ស្តាប់គំនិតរបស់សត្រូវយ៉ាង



www.budinst.gov.kh www.elibraryofcambodia.org

នេះ ។

- ចាស ពិតមែនហើយលោកម្ចាស់ ។

- នាងភ្ញាត់ចូលអន្ទាក់ *ប្លាក់ថន* ទេ ?

- ចាស ។ តែនិយាយតាមពិតទៅគាត់ធ្វើត្រូវ ។ ខ្ញុំមិនបានធ្វើតាមការបញ្ជារបស់លោកម្ចាស់ ។ ខ្ញុំបានដាក់ខ្លួនខ្ញុំនៅចន្លោះគំនិតរបស់គាត់ និងលោកម្ចាស់។ សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ។

- រឿងរ៉ាវនៅតែលំបាក ហើយប្រហែលជាកាន់តែលំបាកថែមទៀតផងមើលទៅ ។

- ចាស ពិតហើយលោកម្ចាស់ ។ តែជាការល្អ ដែលយើងដឹងរឿងរ៉ាវគ្រប់ជ្រុងជ្រោយ ។ អ្វីៗដែលគាត់បាននិយាយភាគច្រើនអាចជាការពិត ដូចជារឿងដែលពួកអេស្ប៉ាញនិងប៉ិកទុយកាល់ ការបែងចែកពិភពលោក រឿងពួកបព្វជិតលួចដឹកកាំភ្លើងជាដើម ថ្វីត្បិតតែរឿងទាំងនេះសឹងមិនអាចជឿបានក្តី។ លោកម្ចាស់មិនចាំបាច់ខ្វាយខ្វល់ពីភក្តីភាពរបស់ខ្ញុំទេ។ ទោះជារឿងរ៉ាវធ្លាក់ដល់អាក្រក់យ៉ាងណាក៏ដោយ ក៏ខ្ញុំនៅតែបំពេញភារកិច្ចចំពោះលោកម្ចាស់ដែរ ។

- អរគុណ។ តិតទៅអ្វីដែល *អាន់ជីន-សាន* បាននិយាយ ក៏មានសារសំខាន់ដែរ *ទេ* ? សារសំខាន់តែលេលា ។ ពិតមែនហើយ *ម៉ារីកូ-សាន* តើខ្ញុំត្រូវបញ្ជាអោយនាងលែង*ប៊ុនតារ៉ូ* រឺទេ ?

- លោកម្ចាស់ ?

- ហើងហើយ យ៉ាងម៉េចដែរ ?

អារម្មណ៍របស់នាងពុះកញ្ជ្រោលមួយរំពេច ។ ឱព្រះអើយ មានសេរីភាព !

ត្រូវចាំថា ខ្លួនឯងជាអ្នកណា *ម៉ារីកូ* ត្រូវចាំថាខ្លួនឯងជាអ្វី ។ ហើយត្រូវចាំពាក្យថា « ស្នេហា » ជាពាក្យរបស់ពួកអ្នកចុងស្រុកទេណា។

*តូរ៉ាណាកា* សំលឹងមើលនាងដោយស្ងៀមស្ងាត់។ នៅឯខាងក្រៅ មូសហើរវង្វេងវង្វាន់ក្នុងរង្វង់ផ្សែងធូប ហើយប្រឹងហើរចេញទៅរកទីសុខវិញ ។ពិតមែនហើយនាងគឺជាស្ទាំង -លោកគិតនៅក្នុងចិត្ត។ តែតើប្រភេទសត្វណា ដែលអញត្រូវព្រលែងស្ទាំងចេញទៅម្តងទៀតនេះ។ នៅ



www.budinst.gov.kh www.elibraryofcambodia.org

ទីបំផុតនាងក៏ឆ្លើយមកវិញ :

- ចាស ទេ លោកម្ចាស់ ។ សូមអរគុណហើយលោកម្ចាស់ ។

- *អាន់ជីន-សាន* ជាមនុស្សចំលែកណាស់មែនទេ ? ខួរក្បាលគេពោរពេញដោយសុបិន ។ ចំជាគួរអោយអស់សំនើចមែនដែលលើកគំរោងវាយប្រហារមិត្ត*ប៊ុកទុយកាល់* របស់យើង រឺវាយប្រហារ*សំពៅខ្មៅ* ។ ចំជាលេលាមែនដែលទៅជឿស៊ីវាថា អារឿងសំពៅបួន រឺម្ភៃក៏ដោយ ។

*ម៉ារីកូ* អេះអុញ :

- បើគាត់និយាយថា រឿងនាវាចរអាចធ្វើបាន ខ្ញុំជឿថាច្បាស់ជាបានហើយលោកម្ចាស់ ។

- ខ្ញុំមិនឯកភាពទេ ។តែនាងនិយាយត្រូវ អារឿងវាជាជញ្ជីងទប់នឹងអ្នកឯទៀតនោះ ។ ដូច*អូមី* និយាយអ៊ីចឹង : អីលូវនេះយើងត្រូវការពួកអ្នកចុងស្រុកដើម្បីរៀនសូត្រពីពួកនេះ ។ ហើយនៅរឿងច្រើនណាស់ដែលត្រូវរៀនសូត្រ ពិសេសពីមនុស្សនេះ *ទេ?*

- ចាស ។

- អីលូវនេះ គឺដល់ពេលដែលត្រូវបើកចំហចក្រភពហើយ *ម៉ារីកូ-សាន* ។ *អ៊ីស៊ីដូ* នឹងបិទចក្រភពនេះដូចមាត់ត្រំអ៊ីចឹង ។ បើខ្ញុំជាប្រធានក្រុមប្រឹក្សាអាជ្ញានុសិទ្ធិជាថ្មីម្តងទៀត ខ្ញុំនឹងចុះសន្ធិសញ្ញាជាមួយគ្រប់ប្រទេសទាំងអស់អោយតែគេជាមិត្ត ។ ខ្ញុំ នឹងបញ្ជូនមនុស្សរបស់ខ្ញុំអោយទៅរៀនសូត្រនៅឯប្រទេសនានា ហើយខ្ញុំ នឹងបញ្ជូនពួកឯកអគ្គរាជទូត ។ មហាក្សត្រីយ៍របស់បុរសនេះ គឺជាការចាប់ផ្តើមដ៏ល្អមួយ ។ ជាមួយស្តេចស្រីអ៊ីចឹងប្រហែលជាខ្ញុំបញ្ជូនឯកអគ្គរាជ ទូតស្រីផងមើលទៅ អោយតែស្រីនោះវាងវៃគ្រាន់បើបន្តិច ។

- នាងនោះត្រូវតែខ្លាំង និងវាងវៃណាស់ទើបបានលោកម្ចាស់ ។

- ពិតហើយ នោះ គឺជាការធ្វើដំណើរមួយដ៏គ្រោះថ្នាក់ ។

- រាល់ដំណើរទាំងអស់ សុទ្ធតែមានគ្រោះថ្នាក់ណាំលោកម្ចាស់- *ម៉ារីកូ* និយាយតប ។

- ពិតមែនហើយ - រូច*តូរ៉ាណាកា* ក៏ជូរសាច់រឿងភ្លាមៗ - បើសិនជា*អាន់ជីន-សាន*



www.budinst.gov.kh www.elibraryofcambodia.org

ចេញសំពៅទៅដោយមានទាំងមាសជាច្រើនតាមខ្លួន តើគេនឹងត្រលប់មកវិញទេ ?

អស់រយៈពេលយ៉ាងយូរទើប *ម៉ារីកូ* ឆ្លើយតប :

- ខ្ញុំមិនដឹងដែរ ។

នៅពេលនេះ *តូរ៉ាណាកា* សំរេចថាមិនជំរុញនាងអោយហួសហេតុទេ ។លោកនិយាយបញ្ចប់ជំនួបដោយសំលេងរាប់អាន :

- អរគុណនាងណាស់ *ម៉ារីកូ-សាន* ។ ខ្ញុំចង់អោយនាងមានវត្តមាននៅក្នុងកិច្ចប្រជុំ ដើម្បីនាងអាចបកនូវអ្វីដែលខ្ញុំនិយាយប្រាប់ *អាន់ជីន-សាន* បាន ។

- បកប្រាប់ទាំងអស់ វីលោកម្ចាស់ ?

- ណឹងហើយ ។ ហើយយប់នេះពេលដែលនាងទៅផ្ទះតែដើម្បីទិញកិច្ចសន្យារបស់ *គីតូ* យក *អាន់ជីន-សាន* ទៅជាមួយនាងផង ។ ប្រាប់ទៅកំនាន់គាត់អោយចាត់ចែងតាមណឹងទៅ ។ គាត់គួរទទួលបានរង្វាន់ *ទេ* ?

- *វ៉ៃ* ។

នៅពេលដែលនាង ទៅដល់មាត់ទ្វារហើយ *តូរ៉ាណាកា* ពោលបន្ថែម :

- នៅពេលដែលរឿង *អ៊ីស៊ីដូ* និងខ្ញុំត្រូវដោះស្រាយរួចរាល់អស់ហើយនោះខ្ញុំនឹងបញ្ជាអោយនាងលែងប្តីហើយ ។

ដៃរបស់ *ម៉ារីកូ* ក្តាប់មេទ្វារយ៉ាងណែន ។នាងងក់ក្បាលទទួលលីវាចារបស់ *តូរ៉ាណាកា* តែនាងមិនងាកក្រោយទេ ។ ទ្វារត្រូវបានបិទជិតពីក្រោយខ្នងនាងទៅវិញ ។

* * * * *

ពួកមេទ័ពទាំងមួយរយហាសិបនាក់ឈរ តំរង់ជាជួរត្រង់ភ្លឹង ។*យ៉ាប៊ូ* , *អូមី* និង *ប៊ុនតារ៉ូ* នៅពីមុខគេ ។ *ម៉ារីកូ* លុតជង្គង់ក្បែរ *ប្លាក់ថន* នៅចំហៀង ។ *តូរ៉ាណាកា* ដើរចូលមកក្នុងបន្ទប់ប្រជុំហែអមដោយអង្គរក្សរបស់លោក ហើយក៏ដាក់បង្គុយនៅលើទីកដែលមានតែមួយគត់នៅទល់មុខមេទ័ពរបស់លោកទាំងប៉ុន្មាននេះ ។ លោកទទួលការលំអោនគោរពពីអ្នកផង រួចប្រាប់



www.budinst.gov.kh www.elibraryofcambodia.org

ដោយសង្ខេបនូវវត្ថុបំណងនៃការប្រជុំនេះ ។ បន្ទាប់មក និងជាលើកទីមួយ លោកបានលើកឡើងជាចំហនូវផែនការប្រយុទ្ធកំពូលរបស់លោក ។ ក៏ដូចជាលើកមុនដែរ លោកនិយាយចេញនូវចំនុចដែលទាក់ទិនទៅនឹងការរៀបចំជាសំងាត់ និងយ៉ាងម៉ត់ចត់នៃការបះបោរ ក៏ដូចជាផែនការដែលធ្វើការវាយលុកតាមខាងជើងមិនមែនតាមផ្លូវបណ្តោយឆ្នេរសមុទ្រខាងត្បូងនោះឡើយ ។ ហើយលោកបានប្រាប់ពួកមេទ័ពទាំងអស់របស់លោកថា នៅពេលណាដែលអស់ភ្លៀងហើយ លោកនឹងបញ្ជាពាក្យកូដ *ផ្ទៃមេឃក្រហម* ដែលនឹងអនុញ្ញាតអោយពួកគេបើកការវាយប្រហារបានភ្លាម ។ ដំណឹងនេះធ្វើអោយពួកគេអបអរជាទូទៅ ព្រោះពួកគេបានបញ្ចប់នូវស្ថានភាពមួយ ដែលមិនច្បាស់លាស់នោះហើយ ។ លោកបញ្ជាក់ថា :

- ក្នុងពេលរង់ចាំនេះ ខ្ញុំគិតថា *អ៊ីស៊ីដូ* នឹងកោះប្រជុំដោយខុសច្បាប់នូវក្រុមប្រឹក្សាអាជ្ញានុសិទ្ធិថ្មីមួយ ហើយខ្ញុំគិតថា ខ្ញុំនឹងត្រូវពួកគេផ្តន្ទាទោសទាំងបន្លំ ។ ខ្ញុំគិតថាគេ នឹងប្រកាសសង្គ្រាមជាមួយខ្ញុំទាំងបំពានច្បាប់ ។

លោកអោនខ្លួនទៅមុខ កណ្តាប់ដៃឆ្វេងរបស់លោកច្រត់លើភ្លៅ ឯកណ្តាប់ដៃស្តាំរបស់លោកវិញក្តាប់ដងដាវយ៉ាងណែន :

- សូមស្តាប់ខ្ញុំ ។ ខ្ញុំគាំទ្រមរតកសាសន៍របស់លោកម្ចាស់ *រ៉ាកូ* និងទទួលស្គាល់ក្មួយខ្ញុំគឺ *វ៉ៃយនម៉ុន* ជា*ក្វាមប៉ាគូ* និងជាអ្នកស្នងអំនាចរបស់លោកម្ចាស់ *រ៉ាកូ* ។ ខ្ញុំឥតមានបំណងចង់បានដែនដីណាទៀតទេ ។ ខ្ញុំឥតមានបំណងចង់បានកិត្តិយសណាទៀតទេ ។ តែបើសិនជាពួកក្បត់វាយប្រហារខ្ញុំៗត្រូវតែការពារខ្លួន ។ បើសិនជាពួកក្បត់បោកបញ្ឆោតព្រះចៅ ហើយមានបំណងចង់កាន់កាប់អំនាចនៅក្នុងនគរនេះ គឺជាភារកិច្ចរបស់ខ្ញុំដែលត្រូវការពារព្រះចៅ និងកំចាត់ពួកបិសាចទាំងនេះ *ទេ*?

សម្លេង គ្រហឹមគាំទ្របានលាន់លឺឡើង ។ សំរែកប្រយុទ្ធ : « *កាស៊ីគី* » និង « *តូរ៉ាណាកា* » បានលាន់លឺពេញបន្ទប់ ហើយខ្ចរចេញទៅពេញបន្ទាយ :

- កងពលវាយលុកត្រូវត្រៀមចុះទូកធំដើម្បីធ្វើដំណើរទៅ *យេដូ* ក្នុងប្រាំថ្ងៃទៀត ។ *តូដាប៊ុនតារ៉ូ-សាន* ជាមេបញ្ជាការលើកងពលនេះ ឯ*កាស៊ីគី អូមី-សាន* ជាមេបញ្ជាការរង ។



www.budinst.gov.kh www.elibraryofcambodia.org

*កាស៊ីគី យ៉ាប៊ូ-សាន* លោកត្រូវចាត់កេណ្ឌទ័ពក្នុងតំបន់*អ៊ីស៊ូ* នេះ ហើយបញ្ជូនមនុស្សប្រាំមួយពាន់នាក់ទៅការពារច្រកភ្នំឯទល់ដែនទាំងប៉ុន្មានក្នុងករណីដែលអាក្បត់ *អ៊ីកាវ៉ា ជីគីយូ* បញ្ចុះទ័ពវាទៅខាងត្បូងដើម្បីកាត់ផ្តាច់ផ្លូវទាក់ទងរបស់យើង ។ នៅពេលអស់ភ្លៀងហើយ *អ៊ីស៊ីអូ* នឹងវាយលុក*ក្កាន់តូ*...

*អូមី , យ៉ាប៊ូ និងប៊ុនតារ៉ូ* សុទ្ធតែបានឯកភាពយ៉ាងស្ងៀមស្ងាត់ជាមួយគំនិតរបស់ *តូរ៉ាណាកា* ដែលថា គួរលាក់សេចក្តីសំរេចកាលពីរសៀលមិញនេះដែលថា ត្រូវតែបើកការវាយលុកនៅក្នុងរដូវភ្លៀងនេះតែម្តងនោះសិន ។

នេះពិតជាអស្ចារ្យណាស់តែម្តង-*អូមី* គិតនៅក្នុងចិត្ត ។ ពោះវៀនពោះតាំងគេរមួរខ្នួលខ្វាញ់នៅពេលដែលគេគិតទៅដល់ការធ្វើសង្គ្រាមតាមដងភ្នំនានានៃតំបន់*ស៊ុរ៉ាណាហ្គ* នោះ ។ កាលពីរសៀលនេះ *យ៉ាប៊ូ* ក៏បាននិយាយទាំងរំភើបផងដែរថា :

- កាំភ្លើងរបស់យើង នឹងចោះផ្លូវទៅតែម្តង ។
- ពិតមែនហើយ ។

កាលនោះ*អូមី* បន្ទរតាម ។ គេមិនទុកចិត្តទៅលើផែនការនេះទេ តែគេក៏មិនមានចំលាស់អ្វីផងដែរ ។ នេះចំជាលេលាមែន - គេគិតនៅក្នុងចិត្ត ថ្វីត្បិតតែតើរកវាយដោយត្រូវបានតែងតាំងជាមេបញ្ជាការរងថ្មីៗនេះក្តី ។ អញមិនយល់សោះតែម្តងថាហេតុអ្វី *តូរ៉ាណាកា* យល់ឃើញថា ពួកយើងមានលទ្ធភាពឈ្នះបាន បើយើងវាយតាមផ្លូវខាងជើងនោះទេវិញ ?

គឺគ្មានសោះតែម្តង- គេគិតនៅក្នុងចិត្តបន្តទៅទៀត ។ គេប្រឹងធ្វើជាមិនលឺនូវសំលេងបំផុស ដ៏គ្រលួចរបស់ *តូរ៉ាណាកា* ដើម្បីប្រមូលអារម្មណ៍របស់គេមកគិតពីរឿងសងសឹករបស់គេម្តងទៀត ។ ជាការពិតហើយ ការវាយលុកទៅ*ស៊ុរ៉ាណាហ្គ* នឹងផ្តល់អោយអញនូវឱកាសយ៉ាងច្រើនក្នុងការលេងល្បិចអោយ *យ៉ាប៊ូ* ឡើងទៅជួរមុខដោយមិនបាច់ប្រជុំប្រថានខ្លួនអញ ។ ទោះជាសង្គ្រាមណាក៏ដោយ នឹងផ្តល់ភាពមានប្រៀបដល់ឯង កុំអោយតែសង្គ្រាមនោះចាញ់គេ...

រួចគេលឺ *តូរ៉ាណាកា* បន្លឺឡើង :

- ថ្ងៃនេះខ្ញុំរីះតែ នឹងត្រូវស្លាប់ទៅហើយ ។ ថ្ងៃនេះ*អាន់ជីន-សាន* បានទាញខ្ញុំចេញពី



www.budinst.gov.kh www.elibraryofcambodia.org

ជី ។ នេះជាលើកទីពីរ រឺប្រហែលជាលើកទីបីផងដែលគាត់បានជួយសង្គ្រោះជីវិតខ្ញុំ ។ ជីវិតខ្ញុំមិនមានសារសំខាន់អ្វីទេបើប្រៀបធៀបទៅនឹងអនាគតនៃសំព័ន្ធត្រកូលរបស់ខ្ញុំ ។ ថ្វីត្បិតតែស្មារតីប៊ូស៊ីដូ កំនត់ថា អណ្តាប់មិនត្រូវរំពឹងពីរឿងរង្វាន់ខាន់ខៅចំពោះកិច្ចការដែលខ្លួនបានធ្វើនោះក្តី ក៏អម្ចាស់គេមានភារកិច្ចផ្តល់នូវការលើកទឹកចិត្តខ្លះម្តងម្កាលដែរ ។

នៅក្នុងជយឃោសជាទូទៅនោះ *តូរ៉ាណាកា* និយាយឡើង :

- *អាន់ជីន-សាន* អង្គុយត្រង់នេះមក ! *ម៉ារីកូ-សាន* ក៏អីចឹងដែរ ។

*អូមី* សំលឹងមើលទាំងច្រណែន បុរសមាឌធំដូចយក្សងើបឡើងទៅលុតជង្គង់នៅចំកន្លែងដែល *តូរ៉ាណាកា* ចង្អុលប្រាប់ ពោលគឺនៅក្បែរកន្លែងរបស់លោកតែម្តង ។ នៅក្នុងសាលធំនេះ គ្មានអ្នកណាដែលមិនមានបំនងចង់បានសំនាង ដើម្បីនឹងធ្វើអ្វីដែលមនុស្សចុងស្រុកនេះបានធ្វើឡើយ ។

- *អាន់ជីន-សាន* នឹងទទួលបានដីដែលមានតំលៃពីរពាន់*កូគូ* ក្នុងមួយឆ្នាំ ហើយដែលនៅក្បែរភូមិអ្នកនេសាទនៅ *យ៉ូកូហាម៉ា* ខាងត្បូង*យេដូ* និងសិទ្ធិរើសសាមូរ៉ៃសំរាប់បំរើខ្លួនចំនួនពីររយនាក់ក្នុងឋានៈជាសាមូរ៉ៃ និង *ហាតាម៉ូតូ* ពេញសិទ្ធិនៃត្រកូល *យ៉ូស៊ី តូរ៉ាណាកា ណូ ជីគីតាដា មីណូវ៉ារ៉ា* ។ ក្រៅពីនេះគេនឹងទទួលបានសេះដប់ គីម៉ូណូម្ភៃ គ្រឿងយុទ្ធោបករណ៍គ្រប់គ្រាន់សំរាប់អណ្តាប់ទាំងឡាយរបស់ខ្លួន ហើយ នឹង ឋានៈជាឧត្តមនាវី និងជាមេសំពៅនៃតំបន់*ក្វាន់តូ* ។

*តូរ៉ាណាកា* រង់ចាំ *ម៉ារីកូ* បកចប់ទើបចេញបញ្ជា :

- *ណាកា-សាន* !

*ណាកា* កាន់ប្រអប់មួយរុំដោយក្រណាត់សូត្រដើរចេញមកយ៉ាងគោរព ។ *តូរ៉ាណាកា* បកសូត្រចេញ ។ ក្នុងប្រអប់មានដាវពីរ មួយខ្លី មួយវែង :

- ដោយបានឃើញថា ព្រះប្រឹថពី បានលេបត្របាក់ដាវទាំងពីររបស់ខ្ញុំ ធ្វើអោយខ្ញុំគ្មានអាវុធនៅនឹងដៃ *អាន់ជីន-សាន* បានចុះទៅក្នុងក្រហែងដីម្តងទៀតដើម្បីយកដាវរបស់ខ្លួនឯងមកប្រគល់អោយខ្ញុំ ។ *អាន់ជីន-សាន* ខ្ញុំប្រគល់ដាវទាំងពីរនេះសងលោកវិញ ។ ដាវនេះធ្វើ



www.budinst.gov.kh www.elibraryofcambodia.org

ដោយកំពូលជាងដាវ ឈ្មោះ *យូរី-យ៉ា* ។ សូមចាំអោយច្បាស់ ដាវគឺជាព្រលឹងរបស់សាមូរ៉ៃ ។ បើសិនជាគេភ្លេច រឺបាត់វា សាមូរ៉ៃនោះគ្មានលេសអ្វីដោះស្រាយទាំងអស់ ។

ក្រោមជយឃោសកាន់តែខ្លាំងក្លា *ភ្វាក់ថន* ទទួលយកដាវ លំអោនខ្លួនយ៉ាងត្រឹមត្រូវ រួចសៀតដាវទាំងគូទៅនឹងចង្កេះ រួចអោនគោរពម្តងទៀត :

- សូមអរគុណ *តូកិណាកា-សាម៉ា* ។ លោកបានផ្តល់ កិត្តិយសដល់ខ្ញុំ សំបើមពេកហើយ ។ សូមអរគុណ ។

គេហៀបថយខ្លួនចេញទៅហើយ តែ *តូកិណាកា* សូមអោយគេនៅអង្គុយដដែល :

- ទេ នៅអង្គុយជិតខ្ញុំនេះហើយ *អាន់ជីន-សាន* ។

រួចលោកងាកបែរទៅមើលមុខ ដ៏ដាច់ខាតរបស់ពួកមេទ័ពរបស់លោកម្តង ។

« ពួកអាភ្លើ-លោកចង់ស្រែកនៅក្នុងចិត្ត ។ តើពួកឯងមិនយល់ថា សង្គ្រាមនេះ ទោះជាក្នុងខែភ្លៀង រឺខែក្រោយភ្លៀងក្តី មានតែរឿងរលត់រលាយទេអ្វី ? សង្គ្រាមណាមួយជាមួយ *អ៊ីស៊ីដូ* , *អ៊ីជីណ* , *យែនមុន* ហើយ និង ពួកសំព័ន្ធមិត្ត របស់គេនេះ បាន បញ្ចប់ត្រឹមតែការកាប់ចិញ្ច្រាំកងទ័ពទាំងអស់របស់អញ រាប់ទាំងពួកឯងនេះផង ហើយនឹងការកំទេចរលាយបាត់នូវរូបអញ និងវង្សត្រកូលរបស់អញតែប៉ុននោះ ។ តើពួកឯងមិនយល់ទេអ្វី ថាអញគ្មានសំនាងឈ្នះអ្នកណាមួយសោះ លើកលែងតែរង់ចាំ និង សង្ឃឹមថា អា *អ៊ីស៊ីដូ* ច្រឡំកខ្លួនឯងងាប់តែប៉ុណ្ណឹង » ។

ទោះជាយ៉ាងនេះក្តី លោករឹតតែបំផុសពួកទាំងនេះកាន់តែខ្លាំងក្លាថែមទៀត ព្រោះជាការសំខាន់ណាស់ដែលត្រូវធ្វើអោយសត្រូវច្រលំបល់នោះ :

- សូមស្តាប់ខ្ញុំ សាមូរ៉ៃទាំងឡាយ : បន្តិចទៀតនេះ អ្នកទាំងអស់គ្នាអាចបញ្ចេញនូវស្នាដៃរបស់ខ្លួនបានហើយ ។ បង្ហាញស្នាដៃជាកូនប្រុស ដូចដែលបុព្វបុរសយើងបានបង្ហាញស្នាដៃរបស់លោកកន្លងមកហើយដែរ ។ ខ្ញុំនឹងកំទេច *អ៊ីស៊ីដូ* ហើយនឹងក្រុមពួកក្បត់របស់វាទាំងប៉ុន្មានហើយដំបូងបង្អស់ គឺ *អ៊ីកាកី ជីគីយូ* ។ ហើយបន្ទាប់ពីនេះ ខ្ញុំនឹងយកដីរបស់វាទាំងអស់ ទាំងខេត្ត *ស៊ូរុកា* ទាំងខេត្ត *តូតូមី* ដែលមានតំលៃទាំងអស់បីរយពាន់ *កូកូ* ប្រគល់ទៅឱ្យអណ្តាប់ដំមានភក្តី



www.budinst.gov.kh www.elibraryofcambodia.org

ភាពរបស់ខ្ញុំ គឺលោកម្ចាស់ *កាស៊ីគី យ៉ាប៊ូ* ហើយជាមួយនឹងតំបន់*អ៊ីស៊ូ* ទៀតនោះ ប្រកាស*យ៉ាប៊ូ-សាន* និងត្រកូលនេះជាអម្ចាស់លើតំបន់ទាំងនេះ ។

ស្នូរជយឃោសលាន់លឺដូចផ្គរលាន់លើមេឃ ។ *យ៉ាប៊ូ* មុខឡើងក្រហមដោយការសប្បាយចិត្ត ។

*អូមី* ធាក់ជីផង ស្រែកអបអរសាទរស្ទើរឆ្កួតវង្វេងស្មារតីផង ។ អីល្ងូវនេះជ័យកណ្ដូរបស់គេគ្មានកិរិតទេ ព្រោះតាមប្រពៃណីអ្នកស្នងកេរ្តិ៍របស់*យ៉ាប៊ូ* ទទួលយកទាំងទឹកដីរបស់*យ៉ាប៊ូ* ផងដែរ ។

តើធ្វើម៉េចអាចសំលាប់*យ៉ាប៊ូ* បានដោយមិនចាំបាច់រង់ចាំសង្គ្រាម ?

រួចភ្នែកគេក៏ផ្ដោតទៅលើ *អាន់ជីន-សាន* ដែលកំពុងតែស្រែកអបអរយ៉ាងស្វាហាប់ ។ ហេតុអីមិនអោយ *អាន់ជីន-សាន* ចាត់ការជំនួសឯង - គេគិតនៅក្នុងចិត្ត ។ រួចគេអស់សំណើចនឹងគំនិតភ្លឺភ្លើនេះ ។ *ប៊ុនតារ៉ូ* ឈោងមកខាងមុខ ទះស្មាគេក្នុងលក្ខណៈរាប់អាន ដោយលោកនឹកស្មានច្រលំថា អូមីកំពុងសើចសប្បាយចំពោះ*យ៉ាប៊ូ* ។ លោកស្រែកលុបភាពទ្រហឹងអឺងកង :

- បន្តិចទៀតលោកនឹងបានដែនដីសក្តិសម នឹងរូបលោកជាមិនខាន *ទេ*? លោកក៏ត្រូវតែបាន ទទួលស្គាល់ស្នាដៃដែរ ។ គំនិតនិងយោបល់របស់លោកមានតំលៃជាពន់ពេកណាស់ ។

- សូមអរគុណ *ប៊ុនតារ៉ូ-សាន* ។

- កុំខ្វល់ ភ្នំណាក៏ដោយក៏យើងឆ្លងកាត់បានទាំងអស់ហ្នឹង ។

- បាទ ពិតហើយ ។

*ប៊ុនតារ៉ូ* គឺជាមេទ័ពប្រយុទ្ធមួយដ៏ស្ទិតស្ទាញ ហើយ *អូមី* ដឹងថាគេទាំងពីរនាក់សក្តិសមជាដៃគូនឹងគ្នាណាស់ : *អូមី* យុទ្ធវិទូដ៏ក្លាហាន *ប៊ុនតារ៉ូ* មេទ័ពវាយលុកដែលមិនចេះព្រឺរោម ។

គ្មានអ្នកណាម្នាក់អាចបើកផ្លូវកាត់តាមផងភ្នំទាំងនេះបានឡើយ ។ មានតែរូបគេមួយគត់ ។

សំលេងហោកញ្ជ្រៀវលាន់លឺម្តងទៀត នៅពេលដែល *តូរ៉ាណាកា* បញ្ជាអោយគេយកស្រាសាកេមកដើម្បីបញ្ចប់ពិធីប្រជុំជាផ្លូវការនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ក្រេបសាកេរបស់ខ្លួនរួច ហើយតាមសំលឹងមើល *ប្លាន់ថន* ដែលលើកបង្អើយមួយពែងទៀតទៅហើយ ។ *តីម៉ូណូ* របស់ *ប្លាន់ថន* ស្មាតភ្លឹង ដាវទាំងពីរសៀតយ៉ាងត្រឹមត្រូវ *ម៉ារីកូ* និយាយជាប់ ។ ឯងផ្លាស់ប្តូរច្រើនណាស់ *អាន់ជីន-សាន* ចាប់ពីថ្ងៃដំបូងដែលយើងជួបគ្នា មក - គេគិតទាំងពេញចិត្ត ។ គំនិតបរទេសរបស់ឯងជាច្រើននៅតែចាក់រឹសជ្រៅនៅឡើយ តែឯងចាប់ផ្តើមមានអារម្មណ៍មិនឹងគេខ្លះៗហើយ....

- មានរឿងអីហើងអូមី-សាន?

- អត់ទេ... អត់មានអីទេ *ប៊ុនកាវ៉ូ-សាន* ។

- មុខលោកដូចឃើញអា *រអេតា* ណាមកស្រោតខោចំពិតដាក់អ៊ីចឹង ។

- ទេអត់មានរឿងបែបហ្នឹងទេ ។ អត់សោះ ! ផ្ទុយទៅវិញទេ ។ ខ្ញុំទើបមានគំនិតមួយ ។ ម៉ស់ផឹកទៅ ! ហេ ! យកសាកេមកថែមទៀត មិនឃើញពែងលោកម្ចាស់ *ប៊ុនកាវ៉ូ* អស់ហើយទេអ្ហី ?

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

ភាពរបស់ខ្ញុំ គឺលោកម្ចាស់ *កាស៊ិតិ យ៉ាប៊ូ* ហើយជាមួយនឹងតំបន់ *អ៊ីស៊ូ* ទៀតនោះ ប្រកាស *យ៉ាប៊ូ-សាន* និងត្រកូលនេះជាអម្ចាស់លើតំបន់ទាំងនេះ ។

ស្នូរជយឃោសលាន់លឺដូចផ្គរលាន់មេឃ ។ *យ៉ាប៊ូ* មុខឡើងក្រហមដោយការសប្បាយចិត្ត ។

*អូមី* ទាក់ជីផង ស្រែកអបអរស្ទើរឆ្លុតវង្វេងស្មារតីផង ។ អីលូវនេះជ័យកណ្ដូរបស់គេគ្មានកំរិតទេ ព្រោះតាមប្រពៃណីអ្នកស្នងកេររបស់ *យ៉ាប៊ូ* ទទួលយកទាំងទឹកដីរបស់ *យ៉ាប៊ូ* ផងដែរ ។

តើធ្វើម៉េចអាចសំលាប់ *យ៉ាប៊ូ* បានដោយមិនចាំបាច់រង់ចាំសង្គ្រាម ?

រួចភ្នែកគេក៏ផ្តោតទៅលើ *អាន់ជីន-សាន* ដែលកំពុងតែស្រែកអបអរយ៉ាងស្វាហាប់ ។ ហេតុអីមិនអោយ *អាន់ជីន-សាន* ចាត់ការជំនួសឯង - គេគិតនៅក្នុងចិត្ត ។ រួចគេអស់សំណើចនឹងគំនិតភ្លឺភ្លើនេះ ។ *ប៊ុនតារ៉ូ* ឈ្ងោកមកខាងមុខ ទះស្មាគេក្នុងលក្ខណៈរាប់អាន ដោយលោកនឹកស្មានច្រលំថា អូមីកំពុងសើចសប្បាយចំពោះ *យ៉ាប៊ូ* ។ លោកស្រែកលុបភាពទ្រហឹងអឹងកង :

- បន្តិចទៀតលោកនឹងបានដែនដីសក្តិសម នឹងរូបលោកជាមិនខាន *ទេ* ? លោកក៏ត្រូវតែបាន ទទួលស្គាល់ស្នាដៃដែរ ។ គំនិតនិងយោបល់របស់លោកមានតំលៃជាពន់ពេកណាស់ ។

- សូមអរគុណ *ប៊ុនតារ៉ូ-សាន* ។

- កុំខ្វល់ ភ្នំណាក៏ដោយក៏យើងឆ្លងកាត់បានទាំងអស់ណឹង ។

- បាទ ពិតហើយ ។

*ប៊ុនតារ៉ូ* គឺជាមេទ័ពប្រយុទ្ធមួយដ៏ស្ទិតស្ទាញ ហើយ *អូមី* ដឹងថាគេទាំងពីរនាក់សក្តិសមជាដៃគូនឹងគ្នាណាស់ : *អូមី* យុទ្ធវិទូដ៏ក្លាហាន *ប៊ុនតារ៉ូ* មេទ័ពវាយលុកដែលមិនចេះព្រឺរោម ។

គ្មានអ្នកណាម្នាក់អាចបើកផ្លូវកាត់តាមជងភ្នំទាំងនេះបានឡើយ ។ មានតែរូបគេមួយគត់ ។

សំលេងហោកញ្ជ្រៀវលាន់លឺម្តងទៀត នៅពេលដែល *តូរ៉ាណាកា* បញ្ជាអោយគេយកស្រាសាកេមកដើម្បីបញ្ចប់ពិធីប្រជុំជាផ្លូវការនេះ ។



www.budinst.gov.kh www.elibraryofcambodia.org

*អូមី* ក្រេបសាកេរបស់ខ្លួនរួច ហើយតាមសំលឹងមើល*ហ្គាន់ថន* ដែលលើកបង្ហើយមួយពែងទៀតទៅហើយ ។ *គីម៉ូណូ* របស់ *ហ្គាន់ថន* ស្អាតភ្លឹង ដាវទាំងពីរសៀតយ៉ាងត្រឹមត្រូវ *ម៉ារីកូ* និយាយជាប់ ។ ឯងផ្លាស់ប្តូរច្រើនណាស់ *អាន់ជីន-សាន* ចាប់ពីថ្ងៃដំបូងដែលយើងជួបគ្នា មក - គេគិតទាំងពេញចិត្ត ។ គំនិតបរទេសរបស់ឯងជាច្រើនទៅតែចាក់រឹសជ្រៅនៅឡើយ តែឯងចាប់ផ្តើមមានអារក្សចមិនឹងគេខ្លះៗហើយ....

- មានរឿងអីណឹង*អូមី-សាន*?

- អត់ទេ... អត់មានអីទេ *ប៊ុនគារ៉ូ-សាន* ។

- មុខលោកដូចឃើញអា*រអេកា* ណាមកស្រោតខោចំពិតដាក់អីចឹង ។

- ទេអត់មានរឿងបែបណឹងទេ ។ អត់សោះ ! ផ្ទុយទៅវិញទេ ។ ខ្ញុំទើបមានគំនិតមួយ ។ ម៉ស់ផឹកទៅ ! ហេ ! យកសាកេមកថែមទៀត មិនឃើញពែងលោកម្ចាស់*ប៊ុនគារ៉ូ* អស់ហើយទេអ្ហី ?

☆☆☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៤០

*ម៉ារីកូ* និយាយ :

- ខ្ញុំទទួលបញ្ជាអោយមកសួរថា តើ *គីកូ-សាន* ទំនេរឬទេនៅយប់នេះ ?

- ចាស អូហ៎ សូមទោសអ្នកស្រី *តូដា* ។ ខ្ញុំមិនច្បាស់ដែរទេ- *គីយ៉ូកូ* ដែលជា *ម៉ាម៉ា-សាន* ឆ្លើយតបទាំងញញឹមពព្រាយ - អនុញ្ញាតអោយខ្ញុំដឹងផងថា តើភ្ញៀវដ៏ថ្លៃថ្លានោះ ចង់បាន *គីកូ* មួយយប់ឬក៏តែមួយយាម ឬរហូតដល់ថ្ងៃស្អែក? នេះបើសិនជា *គីកូ* មិនមានជាប់ជាមួយអ្នកណាទេនោះ ។

*ម៉ាម៉ា-សាន* ជានារីម្នាក់ខ្ពស់សង្ហា និង មានអាយុប្រហែលហាសិបឆ្នាំយព្រមទាំងមានភាពញញឹមគួរអោយស្រលាញ់ ។ តែគាត់ទទួលទានស្រាសាកេច្រើនហួសប្រមាណដែលធ្វើអោយបេះដូងគាត់មិនប្រក្រតី ហើយច្រមុះគាត់អាចហិតធុំក្លិនកាក់ប្រាក់ក្នុងចំងាយហាសិបលីបាន ។

នារីទាំងពីរស្ថិតនៅក្នុងបន្ទប់មួយដែលជាប់ នឹងបន្ទប់ផ្ទាល់ខ្លួនរបស់ *តូរ៉ាណាកា* ។ បន្ទប់នេះត្រូវបានរៀបចំឡើងសំរាប់ *ម៉ារីកូ* ហើយបើកចំហទៅលើកូនសួនច្បារតូចមួយ ហើយដែលហ៊ុមព័ទ្ធដោយកំផែងការពារខាងក្នុងទីមួយ ។ ពេលនេះភ្លៀងបានចាប់ផ្តើមធ្លាក់ឡើងវិញ ហើយតំនក់ទឹកភ្លៀងដេញពន្លឺភ្លើងភ្លឹបភ្លែត១ ។

*ម៉ារីកូ* និយាយយ៉ាងស្រទន់ :

- រឿងនេះអាស្រ័យលើភ្ញៀវជាអ្នកសំរេច ។ អាចយើងជជែកពីរឿងនេះតាមគ្រប់លទ្ធភាពអោយហើយពីពេលនេះតែម្តងទៅក៏ស្រួលម្យ៉ាងដែរ ។

- សូមទោស ដែលខ្ញុំមិនដឹងបានភ្លាម១ ថានាងទំនេរឬអត់នោះ ។ គេរកនាងច្រើនណាស់អ្នកស្រី *តូដា* ។ ខ្ញុំជឿថា អ្នកស្រីពិតជាយល់បានហើយ ។

- ចាស ពិតហើយ ។ ពួកយើងសំនាងណាស់ដែលបាននារីមានគុណសម្បត្តិដូចនាងអីចឹងនៅ *អានជិរ៉ូ* នេះ ។

*ម៉ារីកូ* សង្កត់ពាក្យ *អានជិរ៉ូ* ។ នាងបានប្រើគេអោយទៅហៅ *គីយ៉ូកូ* មកជួបនាងវិញ



www.budinst.gov.kh www.elibraryofcambodia.org

ដោយនាងមិនទៅជួបផ្ទាល់ខ្លួនឯងនៅឯកន្លែងរបស់នារីចំនាស់នេះឡើយ ។ នាងសួរ :

- តើផ្ទះតែមានខូចខាតច្រើនទេ ?

- ទេ សំនាងល្អដែរ ។ ខូចខាតតែជូមានតម្លៃ និង ខោអាវខ្លះប៉ុណ្ណោះ ។ តែទោះជាយ៉ាងណាក៏ត្រូវអស់លុយមិនស្ទើរដែរទេ ដើម្បីជួសជុលដំបូល និង កែកុនសួនច្បារឡើងវិញនោះ ។ ចង់ធ្វើអ្វីអោយបានរហ័ស គឺតែងតែថ្លៃជានិច្ច មែនទេអ្នកស្រី?

- ចាស យ៉ាប់មែនទែន ។ទាំងនៅ *យេដូ* នៅ *មីស៊ីម៉ា* រឺនៅក្នុងកូនភូមិតូចមួយនេះក្តី ។

- ជាការសំខាន់ណាស់ដែលត្រូវមានបរិយាកាសស្ងប់ស្ងាត់ព័ទ្ធជុំវិញ *ទេ* ? តើភ្ញៀវនឹងផ្តល់កិត្តិយសដល់យើងខ្ញុំនៅឯផ្ទះតែ រឺមួយក៏ភ្ញៀវអោយ*គីគូ* មកជួបនៅទីនេះ ? នេះបើនាងទំនេរ ។

*ម៉ារីកូ* ក្របួចបបូរមាត់ក្នុងការរិះគិត :

- ផ្ទះតែ ។

- អា *សូកេស៊ូ* !

ឈ្មោះពិតប្រាកដរបស់ *ម៉ាម៉ា-សាន* គឺ *ហែកូអ៊ីជី* កូនស្រីទីមួយ នៃអ្នកធ្វើជញ្ជាំង ។ ឪពុកហើយ និងជីតាគាត់ជាអ្នកឯកទេសខាងធ្វើជញ្ជាំងសួនច្បារ ។គាត់ធ្លាប់ធ្វើជាអ្នកទទួលភ្ញៀវថ្នាក់ទីពីរជាច្រើនឆ្នាំនៅឯ *មីស៊ីម៉ា* ដែលជាទីក្រុងនៃតំបន់ *អ៊ីស៊ូ* ហើយអាស្រ័យដោយអំនោយរបស់ថៅកែ និងដោយមាននិស្ស័យរកស៊ីផងនោះ គាត់បានសន្សំលុយកាក់ និងលោះខ្លួន ហើយមកបើកផ្ទះតែធ្វើថៅកែដោយខ្លួនឯងនេះ ។ អីលូវនេះគាត់ដាក់ឈ្មោះខ្លួនឯងថា *គីយ៉ូកូ* - នារីហេង ។ ពេលគាត់នៅហាត់រៀនទទួលភ្ញៀវក្នុងអាយុដប់បួនឆ្នាំ ថៅកែបានអោយឈ្មោះគាត់ថា *ឈូរ៉ែកូ* - អ្នកផ្សាំងពស់ ។ ថៅកែបានពន្យល់គាត់ថា ផ្នែកពិសេសរបស់មនុស្សប្រុស គឺអាចប្រៀបបានទៅនឹងពស់ ហើយពស់ជានិមិត្តរូបហេង ហើយបើសិនជាគាត់អាចក្លាយខ្លួនជា អ្នកផ្សាំងពស់បាននោះ គាត់ច្បាស់ជាមានជោគជ័យធំជាមិនខាន ។ ម្យ៉ាងទៀត ឈ្មោះនេះ នឹងធ្វើអោយភ្ញៀវសើចចុកពោះជាមិនខាន ហើយសំនើចគឺមានសារៈសំខាន់ជាសារវន្តសំរាប់របររកស៊ីនេះ ។ *គីយ៉ូកូ* មិនដែលភ្លេចពី រឿងសំនើចនេះឡើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិសាសាកេ *គីយ៉ូកូ-សាន* ?

- អរគុណ ចាស ។ សូមអរគុណអ្នកស្រី *តូដា* ។

នារីបំរើចាក់សាកេរួច *ម៉ារីកូ* ក៏អោយនាងចេញទៅវិញទៅ ។

គេទាំងពីរនាក់ទទួលទានយ៉ាងស្ងាត់ស្ងៀមមួយរយៈ ។ *ម៉ារីកូ* ក៏ចាក់ស្រាបំពេញពែងឡើងវិញ ។ *គីយ៉ូកូ* ឧទានឡើង :

- ពែងស្អាត១ដល់ហើយ ។ រាងសង្ហាមែន ។

- ពែងនេះអន់ណាស់ ។ ខ្ញុំសូមទោសដែលយើងត្រូវប្រើពែងរបៀបនេះ ។

- បើសិនខ្ញុំអាចនិយាយអោយនាងទំនេរបាន តើប្រាំ *កូបាន* បានទេ ?

*កូបាន* គឺជាកាក់មាសដែលមានទម្ងន់ប្រាំបីក្រាម ។ មួយ *កូបាន* ស្មើនឹងស្រូវបី *កូគូ* ។

- សូមទោស ដែលខ្ញុំមិនបានបញ្ជាក់អោយច្បាស់ ។ ខ្ញុំមិនមែនចង់ទិញផ្ទះតែទាំងអស់នៅ *មីស៊ីម៉ា* នោះទេ តែគឺទិញការបំរើរបស់នារីតែមួយយប់ទេ ។

*គីយ៉ូកូ* សើចកក្អិក:

- អ្នកស្រី *តូដា* អ្នកស្រីសក្តិសម នឹងកេរ្តិ៍ឈ្មោះមែន ។ តែខ្ញុំសូមជំរាបអ្នកស្រីថា *គីតូ-សាន* ជាប្រភេទថ្នាក់ទីមួយណាំ ។ សាវជីកម្មបានផ្តល់កិត្តិយសនេះដល់នាងកាលពីឆ្នាំទៅណាំ ។

- ពិតហើយ ១ ខ្ញុំជឿថានាងសក្តិសម នឹង ឋានៈនេះ។ តែនោះគឺនៅ *មីស៊ីម៉ា* ។ ទោះជា នៅ *ក្យូតូ* ក៏ ... តែតាមពិតលោកស្រីគ្រាន់តែកំប្លែងលេងទេ ។ អោយខ្ញុំសូមទោសផងចុះ ។

*គីយ៉ូកូ* ប្រឹងទប់កុំអោយជ្រុលមាត់បញ្ចោរ ហើយប្រឹងញញឹមគ្រហាញ :

- ជាការស័យស្ញើរណាស់ដែលខ្ញុំត្រូវសងភ្ញៀវដែលគេបានកក់នាងទុកហើយដែលខ្ញុំទើបនឹកឃើញអំបាញ់មិញនេះឯង ។ អាណិតនាងណាស់ ។ *គីម៉ូណូ* នាងប្អូន ត្រូវខូចខាត ដោយសារទឹកដែលជះពន្លត់ភ្លើងនោះ។ អីលូវនេះរកស៊ីតឹងតែងណាស់ លោកស្រីជ្រាបស្រាប់ហើយ ។ ប្រាក់នេះមិនជាច្រើនហួសហេតុទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិតហើយវាមិនហួសហេតុទេ ។ ប្រាំនេះល្មមនៅ*ក្យូតូ* សំរាប់ស៊ីធីកមួយអាទិត្យ ជាមួយស្រីកំដរថ្នាក់លេខមួយពីរនាក់ ។ តែយើងមិនមែននៅក្នុងពេលធម្មតាឯណា ហេតុនេះ ម្នាក់ៗ ត្រូវចុះថ្លៃខ្លះទៅ កន្លះ*កូបាន*ណា ។ ពិសាសាកេទៀតទេ *គីយ៉ូកូ-សាន* ?

- អរគុណ ។ អរគុណ ។ សាកេឆ្ងាញ់មែនទែន ។ គុណភាពល្អណាស់ ។ ល្អមែនទែន តែម្តងហើយ ។ តែមួយពែងទៀតទេ ហើយខ្ញុំត្រូវទៅវិញហើយ ។ បើសិនជា*គីកូ-សាន* មិនទំនេរ នៅយប់នេះទេ ខ្ញុំអាចរៀបចំស្រីផ្សេងទៀតជូនបាន ដូចជា *អារកកូ* ជាដើម ។ រឺរង់ចាំថ្ងៃផ្សេង ទៀតទៅ តើបានរឺទេ ? ចាំខានស្អែកទៅយ៉ាងម៉េចដែរ ?

*ម៉ារីកូ* នៅស្ងៀមស្ងាត់មួយរយៈ ។ ប្រាំ*កូបាន* ចំជាហួសហេតុពេកតែម្តង ។ គឺថ្លៃស្មើ និង ស្រីកំដរថ្នាក់លេខមួយល្បីឈ្មោះនៅ*យេដូ* ទៅហើយ ។ ចំពោះ *គីកូ* កន្លះ*កូបាន* គឺសមសួន ណាស់ទៅហើយ ។ *ម៉ារីកូ*ដឹងថ្លៃស្រីបំរើភ្ញៀវទាំងនេះដោយថាមួយផងមួយយាម *ប៊ុនតារ៉ូ* តែង ត្រូវការពូកនេះ ហើយមានទាំងលោះយកម្នាក់ថែមទៀត ហើយនាងជាអ្នកចេញថ្លៃទាំងអស់ នេះផង ។ ភ្នែករបស់នាងសំលឹងមើលចិត្ត *គីយ៉ូកូ* ។ ស្រីចំនាស់នេះចាក់ស្រាសាកេយឺតៗ និង យ៉ាងនឹងន ដៃរបស់គាត់ឥតមានញ័របន្តិចណាឡើយ ។

*ម៉ារីកូ* និយាយ :

- អាចដែរមើលទៅ ។ តែខ្ញុំគិតថា មិនចាំបាច់ស្រីផ្សេង រឺយប់ផ្សេងនោះឡើយ... បើ សិនជាយើងមិនអាចរៀបចំបានយប់នេះទេ ខ្ញុំបារម្ភ តែខានស្អែកវាយឺតពេលណាស់ទៅហើយ ។ អោយខ្ញុំសូមអភ័យទោសផងចុះ ។ ចំនែកថាយកស្រីផ្សេងទៀតនោះ ...

*ម៉ារីកូ* ញញឹម ហើយញាក់ស្មា ។ *គីយ៉ូកូ* ក៏ដាក់ពែងចុះទាំងអាការៈគ្រៀមក្រំ :

- ខ្ញុំបានលឺថា សាមូរ៉ៃ ដ៏ជាញជ័យរបស់យើងនឹងចាកចេញពីយើងហើយ ។ គួរអោយ ស្រណោះណាស់ ! នៅទីនេះ រាត្រីពោរពេញដោយសេចក្តីសុខម្លេះទេ ។ នៅឯ *មីស៊ីម៉ា* យើងមិន បានទទួលជំនោរសមុទ្រដូចនៅទីនេះទេ ។ ខ្ញុំសូមទោស ដែលត្រូវសូមលាចេញទៅដែរ ចាស ។

- រឺមួយ*កូបាន* ទៅអ្វី? បើសិនជាពេញចិត្ត នោះខ្ញុំនឹងនិយាយពីតំលៃកិច្ចសន្យារបស់ នាងទៀតផង ។



www.budinst.gov.kh www.elibraryofcambodia.org

- កិច្ចសន្យារបស់នាង ?

- ចាស ។ សាកេទៀតទេ ?

- ចាស អរគុណអ្នកស្រីហើយ ។ កិច្ចសន្យា... កិច្ចសន្យារបស់នាង ? អានេះជារឿងមួយផ្សេង ។ ប្រាំពាន់*ក្លូ* ។

- មិនអាចដល់ប៉ុនណឹងទេ ។

- ចាស ពិតហើយ-*គីយ៉ូកូ* ឯកភាព-តែ *គីតូ-សាន* ដូចជាកូនស្រីបង្កើតរបស់ខ្ញុំទៅហើយ ។ នាងជាកូនស្រីរបស់ខ្ញុំ គ្រាន់បើជាងកូនស្រីខ្ញុំទៅទៀត ។ ខ្ញុំបង្ហាត់បង្រៀននាងតាំងពីនាងអាយុបានប្រាំមួយឆ្នាំ ។ នាងជានារីស្ទាត់ជំនាញជាងគេបំផុតនៅក្នុងតំបន់*អ៊ីស្ទី* នេះ ។ ចាស ខ្ញុំដឹងហើយថា នៅ*យេដូ* មាននារីពូកែជាងនេះ វាងវៃជាងនេះ មានចំនេះដឹងជាងនេះ តែនេះក៏ព្រោះតែ*គីតូ-សាន* មិនមានវាសនាដើម្បីទាក់ទងជាមួយមនុស្សដែលមានគុណសម្បត្តិដូចនោះបានតែប៉ុននោះ ។ តែមកដល់ពេលនេះ គ្មានណាម្នាក់ស៊ីដាច់នាងលើរឿងចំរៀង និងលេង*សាមីសេន*(១) បានទេ ។ ខ្ញុំសូមស្បថទៅចុះ ។ អោយនាងទៅនៅឯ*យេដូ* មួយឆ្នាំលមើលហើយរើសថៅកែអោយល្អ និង ប្រភពចំនេះដឹងអោយបានត្រឹមត្រូវ នាងពិតជាអាចប្រកួតប្រជែងធូរល្មុយជាមួយអ្នកបំរើភ្ញៀវមួយណាក៏បានដែរក្នុងមួយនគរនេះ ។ ប្រាំពាន់*ក្លូ* គឺតិចតួចទេសំរាប់បុប្ផាដ៏ចំនាប់បែបនេះ - តំនក់ញើសនៅជិតលើថ្ងាសរបស់ *គីយ៉ូកូ* - សូមអ្នកស្រីអធ្យាស្រ័យផងចុះ ប៉ុន្តែតាំងពីដើមមក ខ្ញុំមិនដែលនឹកឃើញចង់លក់កិច្ចសន្យារបស់នាងទេ ។ នាងទើបមានអាយុដប់ប្រាំបីឆ្នាំបន្តិចបន្តួច ហើយគ្មានចំនុចណាទាស់បន្តិចឡើយ ។ នាងជានារីប្រភេទថ្នាក់លេខមួយដែលខ្ញុំមានសំនាងបានគ្រប់គ្រងនេះ ។ មែនទែនទៅខ្ញុំមិនដឹងថាអាចលក់កិច្ចសន្យារបស់នាង រឺអត់ផង ទោះក្នុងតំលៃដែលបាននិយាយអំបាញ់មិញនេះក៏ដោយ ។ ទេ ខ្ញុំគិត១ទៅ ខ្ញុំត្រូវគិតឡើងវិញសិន ។ សូមទោសណាអ្នកស្រី មើលទៅចាំយើងជជែករឿងនេះម្តងទៀតនៅថ្ងៃស្អែកទៅ រឺអី ? ចោល *គីតូ-សាន* ? មីល្អិត *គីតូ-សាន* របស់ខ្ញុំ ណឹង ?

នៅក្បៀនកន្ទុយភ្នែក ទឹកភ្នែករបស់ស្រីចំនាស់នៅរលីងរលោងក្បែរនោះ ។ បើសិនជា

---

*១- ចាប៉ី ម្យ៉ាងរបស់ជប៉ុន*



www.budinst.gov.kh www.elibraryofcambodia.org

ទឹកភ្នែកយាយឯងជាទឹកភ្នែកចេញពីចិត្តពិត១នោះ - *ម៉ារីកូ* គិតនៅក្នុងចិត្ត - ទាល់តែយាយឯងមិនដែលលើកជើងអោយគេ ។

- សូមទោសផងចុះ ។ *ស៊ីកាតា កា រ៉ៃហៃ នេ* ?

*ម៉ារីកូ* និយាយយ៉ាងគួរសម ហើយនាងទុកអោយស្រីចំនាស់នេះនៅយំសសឹកដោយខ្សឿតចាក់ស្រាបំពេញពែងជាប់ ។ តើកិច្ចសន្យានោះមានតំលៃពិតប្រាកដប៉ុន្មានទៅ-នាងដណ្តឹងសួរនៅក្នុងចិត្ត ។

ប្រាំរយ *កូគូ* ពិតជាសមរម្យសំបើមណាស់ហើយ ។ នេះ ក៏វាអាស្រ័យដោយភាពតក់ក្រហល់របស់មនុស្សប្រុសផងដែរ ។ តែអ្នកណាមួយមិនតក់ក្រហល់ក្នុងករណីនេះ ? បើលោក *តូរ៉ាណាកា* មួយតឺគាត់ច្បាស់ជាមិនតក់ក្រហល់ទេ ។ តើគាត់ចង់លោះ *គីតូ* អោយអ្នកណាអ៊ីចេះ ។ *អូមី* ? អាចដែរ ។ តើបើអ៊ីចឹង ហេតុអីក៏លោកម្ចាស់ *តូរ៉ាណាកា* បញ្ជាអោយ *អាន់ជីន-សាន* មានវត្តមាននៅទីនេះធ្វើអីដែរ ?

- លោកយល់ព្រមទេ *អាន់ជីន សាន* ?

នាងបានសួរទៅគេកាលពីមុននេះ ដោយសាយទាំងសំនើចរសាប់រសល់ក្នុងចំនោមប៉ោរកញ្ច្រៀវនៃពូកមេទ័ពដែលកំពុងស្រវឹងនោះ ។

- អ្នកស្រីនិយាយថា លោកម្ចាស់ *តូរ៉ាណាកា* បានរៀបចំស្រីម្នាក់អោយខ្ញុំ? ថានេះជារង្វាន់មួយសំរាប់ខ្ញុំ ?

- ចាស *គីតូ-សាន* ។ លោកពិបាកប្រកែកហើយ ។ ខ្ញុំ... ខ្ញុំទទួលបញ្ជាអោយមកបកប្រែជូនលោក ។

- ទទួលបញ្ជា ?

- អូហ៍ ខ្ញុំសប្បាយរីករាយ នឹង បកប្រែជូនលោកណាស់ ។ តែ *អាន់ជីន-សាន* លោកមិនអាចប្រកែកបានទេ ។ បន្ទាប់ពីកិត្តិយស ដ៏ច្រើនសំបើមយ៉ាងនេះ បើលោកប្រកែក គឺពិតជាខ្ទះសុជីវធម៌មែនទែន *នេ* ?

នាងញញឹមយ៉ាងព្រហើន ពោរពេញដោយមោទនភាពនិងភាពរីករាយចំពោះសប្បុរស



www.budinst.gov.kh www.elibraryofcambodia.org

ធមិមិនអាចជឿបានរបស់ *តូរ៉ាណាកា* ។ នាងបន្ត :

- ខ្ញុំមិនដែលឃើញខាងក្នុងផ្ទះតែទេ ។ ខ្ញុំចង់ឃើញដោយផ្ទាល់ភ្នែកខ្លួន ហើយនឹងមានឱកាសជជែកជាមួយនារី១ នៃពិភពដើមស្លូល[២] ផង ។

- ថាម៉េច ?

- គេហៅពួកនាងយ៉ាងនេះ ព្រោះនារីទាំងនេះត្រូវចេះទន់ភ្លន់ ដូចដើមស្លូលអ៊ីចឹងដែរ ។ ជូនកាលគេហៅពិភពអណ្តែត ព្រោះគេប្រដូចពួកនាងទៅនឹងផ្កាម្លិះដែលអណ្តែតនៅលើទឹកបឹង ។ ទៅ *អាន់ជីន-សាន* យល់ព្រមទៅ ។

- ចុះ *ប៊ុនតារ៉ូ-សាម៉ា* ?

- អូហ៍ គាត់ដឹងថា ខ្ញុំត្រូវរៀបចំរឿងនេះសំរាប់លោកហើយ ។ លោកម្ចាស់ *តូរ៉ាណាកា* បានជំរាបគាត់ហើយ ។ នេះជារឿងផ្លូវការ ។ ខ្ញុំទទួលបញ្ជា ។ លោកក៏ទទួលបញ្ជាដែរ ។ សូមអញ្ជើញ ចាស ។

រួចនាងក៏និយាយបន្ថែមជាភាសាឡាតាំង ទាំងក្នុងចិត្តរីករាយដែលនៅមួយ *អាន់ជីន* នេះគ្មានអ្នកណាម្នាក់ទៀតចេះនិយាយភាសានេះឡើយ :

- នៅមានមូលហេតុមួយទៀតដែលខ្ញុំនឹងជំរាបលោកនៅពេលក្រោយ ។

- អ្ហា ! ប្រាប់ខ្ញុំអីលូវនេះមក ។

- ចាំក្រោយ តែព្រមរឿងសប្បាយសិន ។ ព្រោះខ្ញុំសំនូមពរលោក ។

- នាង... អ្នកណាប្រកែកជាមួយនាងកើត ?

- តែដោយរីករាយណា ។ នេះគឺទាំងក្នុងការរីករាយ ។ លោកសន្យាមក !

- ទាំងសើចក្អាកក្អាយថែមទៀត ។ ខ្ញុំសូមសន្យា ។ ខ្ញុំនឹងប្រឹងសាកល្បង ។

រួចទើបនាងចាកចេញពីគេ ដើម្បីមកធ្វើការរបៀបនេះ ។

*គីយ៉ូកូ* គំអួញ :

- ខ្ញុំរបោចចិត្តអស់ហើយ គ្រាន់តែគិតដល់រឿងលក់កិច្ចសន្យាបវរកញ្ញារបស់ខ្ញុំយ៉ាង

២- *ប្រភេទឈើម្យ៉ាងដែលមានស្លឹកធ្លាក់ដូចស្រល់(willow)* ។



www.budinst.gov.kh www.elibraryofcambodia.org

នេះ ។ ចាស សូមអរគុណហើយ សុំស្រាសាកេបន្ថិចទៀតមកអាលខ្ញុំទៅផ្ទះវិញ ។

គាត់លើកភ្នែកអស់ភ្នាម ហើយនៅកាន់ពែងជាប់រង់ចាំ *មារីកូ* ចាក់បំពេញវិញៈ

- អីលូវនេះពីរ *តូបាន* សំរាប់យប់នេះទៅអ្អី ?

- មួយ ។ ហើយបើព្រមហើយ យើងអាចជជែកថែមទៀតពីរឿងកិច្ចសន្យានៅយប់នេះឯផ្ទះតែ ។ សូមអធ្យាស្រ័យដែលរហាក់រហន់យ៉ាងនេះ តែគឺពេលវេលា... អ្នកស្រីយល់ហើយ... - *មារីកូ* លើកដៃគ្រវាសចោលតំរង់ទៅបន្ទប់ប្រជុំ - ការងាររដ្ឋ លោកម្ចាស់ *តូរ៉ាណាកា*... អនាគតម្ចាស់លើនគរនេះ... អ្នកស្រីយល់ហើយ *គីយ៉ូកូ-សាន* ។

- ចាស ចាស យល់ហើយអ្នកស្រី *តូដា* - *គីយ៉ូកូ* ចាប់ងើបឈរ - តើយើងព្រមព្រៀងគ្នាត្រឹមមួយ *តូបាន* កន្លះសំរាប់យប់នេះទៅអ្អី ? បើសំរេចអីចឹង......

- មួយ *តូបាន* ។

- ឱលោកស្រីអើយ អាកន្លះនេះទុកដូចជាជំនូនទេតើ ចាំបាច់ជជែកគ្នាធ្វើអី? -*គីយ៉ូកូ* តំអូញ ។មួយ *តូបាន* កន្លះ គឺលើសមួយជាបីនៃថ្លៃឈ្នួលហើយ ។ តែអ្វីលើស ពីលុយនោះគឺអ្វីដែលគាត់ទន្ទឹងរង់ចាំជាយូរមកហើយ ពោលគឺការអញ្ជើញជាលើកទីមួយពីវណ្ណៈអភិជនពិតប្រាកដនៃប្រទេសជប៉ុន ហើយដែលគាត់ពិតជារីករាយប្រាប់ *គីកូ* អោយធ្វើគ្រប់បែបយ៉ាងដោយមិនយកលុយទៀតផង-លោកស្រី *តូដា* អើយខ្ញុំដាក់ខ្លួនខ្ញុំអស់ប៉ុនណឹងហើយ ។មួយ *តូបាន* កន្លះទៅ ។សូមលោកស្រីយល់ដល់កូន១ខ្ញុំដែលត្រូវស្លៀកពាក់ ត្រូវហាត់រៀនត្រូវចិញ្ចឹមស៊ីចុករាប់ឆ្នាំ ហើយដែលមិនអាចមានតំលៃដូចជា *គីកូ-សាន* ផង ។

- មួយ *តូបាន* មាស ។ ស្អែក *នេ* ?

*គីយ៉ូកូ* លើកថូប៉កសីឡៃនចាក់ស្រាពីរពែង ។ គាត់ហុចមួយទៅ *មារីកូ* ភ្លើយផឹកពែងរបស់គាត់ ហើយចាក់បំពេញពែងខ្លួនភ្លាម ។ គាត់និយាយឡើង :

- មួយ *តូបាន* ។

- អរគុណណាស់ លោកស្រីចំជាមានសន្ដានចិត្តល្អ ហើយចេះគិតគូរល្អមែន ។ ជាការពិតហើយ ពេលនេះតឹងណាស់ - *មារីកូ* គ្រេបស្រាចិប១ - *អាន់ជីន-សាន* និងរូបខ្ញុំនឹងទៅដល់



www.budinst.gov.kh www.elibraryofcambodia.org

ធម៌មិនអាចជឿបានរបស់ *តូវ៉ាណាកា* ។ នាងបន្ត :

- ខ្ញុំមិនដែលឃើញខាងក្នុងផ្ទះតែទេ ។ ខ្ញុំចង់ឃើញដោយផ្ទាល់ភ្នែកខ្លួន ហើយនឹងមានឱកាសជជែកជាមួយនារី១ នៃពិភពដើមស្លូល[២] ផង ។

- ថាម៉េច ?

- គេហៅពួកនាងយ៉ាងនេះ ព្រោះនារីទាំងនេះត្រូវចេះទន់ភ្លន់ ដូចដើមស្លូលអ៊ីចឹងដែរ ។ ជូនកាលគេហៅពិភពអណ្ដែត ព្រោះគេប្រដូចពួកនាងទៅនឹងផ្កាម្លិះដែលអណ្ដែតនៅលើទឹកបឹង ។ ទៅ *អាន់ជីន-សាន* យល់ព្រមទៅ ។

- ចុះ *ប៊ុនតារ៉ូ-សាម៉ា* ?

- អូហ៍ គាត់ដឹងថា ខ្ញុំត្រូវរៀបចំរឿងនេះសំរាប់លោកហើយ ។ លោកម្ចាស់ *តូវ៉ាណាកា* បានជំរាបគាត់ហើយ ។ នេះជារឿងផ្លូវការ ។ ខ្ញុំទទួលបញ្ជា ។ លោកក៏ទទួលបញ្ជាដែរ ។ សូមអញ្ជើញ ចាស ។

រួចនាងក៏និយាយបន្ថែមជាភាសាឡាតាំង ទាំងក្នុងចិត្តរីករាយដែលនៅមួយ *អាន់ជីរ៉ុ* នេះគ្មានអ្នកណាម្នាក់ទៀតចេះនិយាយភាសានេះឡើយ :

- នៅមានមូលហេតុមួយទៀតដែលខ្ញុំនឹងជំរាបលោកនៅពេលក្រោយ ។

- អ្ហា ! ប្រាប់ខ្ញុំអីលូវនេះមក ។

- ចាំក្រោយ តែព្រមរឿងសប្បាយសិន ។ ព្រោះខ្ញុំសំនូមពរលោក ។

- នាង... អ្នកណាប្រកែកជាមួយនាងកើត ?

- តែដោយរីករាយណា ។ នេះគឺទាំងក្នុងការរីករាយ ។ លោកសន្យាមក !

- ទាំងសើចក្អាកក្អាយថែមទៀត ។ ខ្ញុំសូមសន្យា ។ ខ្ញុំនឹងប្រឹងសាកល្បង ។

រួចទើបនាងចាកចេញពីគេ ដើម្បីមកធ្វើការរបៀបនេះ ។

*គីយ៉ូកូ* តំអូញ :

- ខ្ញុំរបោចចិត្តអស់ហើយ គ្រាន់តែគិតដល់រឿងលក់កិច្ចសន្យាបវរកញ្ញារបស់ខ្ញុំយ៉ាង

---

២- *ប្រភេទឈើម្យ៉ាងដែលមានស្លឹកធ្លាក់ដូចស្រល់*(willow) ។



www.budinst.gov.kh www.elibraryofcambodia.org

នេះ ។ ចាស សូមអរគុណហើយ សុំស្រាសាកេបន្តិចទៀតមកអាលខ្ញុំទៅផ្ទះវិញ ។

គាត់លើកភ្លៀយអស់ភ្លាម ហើយនៅកាន់ពែងជាប់រង់ចាំ *មារីកូ* ចាក់បំពេញវិញ:

- អីលូវនេះពីរ *កូបាន* សំរាប់យប់នេះទៅអ្ហ៎ ?

- មួយ ។ ហើយបើព្រមហើយ យើងអាចជជែកថែមទៀតពីរឿងកិច្ចសន្យានៅយប់នេះឯផ្ទះតែ ។ សូមអធ្យាស្រ័យដែលរហាក់រហន់យ៉ាងនេះ តែគឺពេលវេលា... អ្នកស្រីយល់ហើយ... - *មារីកូ* លើកដៃគ្រវាសចោលតំរង់ទៅបន្ទប់ប្រជុំ - ការងាររដ្ឋ លោកម្ចាស់ *តូរ៉ាណាកា...* អនាគតម្ចាស់លើនគរនេះ... អ្នកស្រីយល់ហើយ *គីយ៉ូកូ-សាន* ។

- ចាស ចាស យល់ហើយអ្នកស្រី *តូដា* - *គីយ៉ូកូ* ចាប់ងើបឈរ - តើយើងព្រមព្រៀងគ្នាត្រឹមមួយ *កូបាន* កន្លះសំរាប់យប់នេះទៅអ្ហ៎ ? បើសំរេចអីចឹង......

- មួយ *កូបាន* ។

- ឱលោកស្រីអើយ អាកន្លះនេះទុកដូចជាជំនូនទេតើ ចាំបាច់ជជែកគ្នាធ្វើអី? - *គីយ៉ូកូ* តំអូញ ។មួយ *កូបាន* កន្លះ គឺលើសមួយជាបីនៃថ្លៃឈ្នួលហើយ ។ តែអ្វីលើស ពីលុយនោះគឺអ្វីដែលគាត់ទទឹងរង់ចាំជាយូរមកហើយ ពោលគឺការអញ្ជើញជាលើកទីមួយពីវណ្ណៈអភិជនពិតប្រាកដនៃប្រទេសជប៉ុន ហើយដែលគាត់ពិតជារីករាយប្រាប់ *គីកូ* អោយធ្វើគ្រប់បែបយ៉ាងដោយមិនយកលុយទៀតផង-លោកស្រី *តូដា* អើយខ្ញុំដាក់ខ្លួនខ្ញុំអស់ប៉ុនណឹងហើយ ។មួយ *កូបាន* កន្លះទៅ ។សូមលោកស្រីយល់ដល់កូន១ខ្ញុំដែលត្រូវស្លៀកពាក់ ត្រូវហាត់រៀនត្រូវចិញ្ចឹមស៊ីចុករាប់ឆ្នាំ ហើយដែលមិនអាចមានតំលៃដូចជា *គីកូ-សាន* ផង ។

- មួយ *កូបាន* មាស ។ ស្អែក *ទេ?*

*គីយ៉ូកូ* លើកផ្ទប៊ិកសីឡែនចាក់ស្រាពីរពែង ។ គាត់ហុចមួយទៅ *មារីកូ* ភ្លៀយផឹកពែងរបស់គាត់ ហើយចាក់បំពេញពែងខ្លួនភ្លាម ។ គាត់និយាយឡើង :

- មួយ *កូបាន* ។

- អរគុណណាស់ លោកស្រីចំជាមានសន្តានចិត្តល្អ ហើយចេះគិតគូរល្អមែន ។ ជាការពិតហើយ ពេលនេះតឹងណាស់ - *មារីកូ* ក្រេបស្រាចិប១ - *អាន់ជីន-សាន* និងរូបខ្ញុំនឹងទៅដល់



www.budinst.gov.kh www.elibraryofcambodia.org

ផ្ទះតែបន្តិចទៀតណឹង ។

- អ្ហែ ? លោកស្រីមានប្រសាសន៍ថាម៉េចណឹង ?

- ខ្ញុំថា *អាន់ជីន-សាន* និងខ្ញុំនឹងទៅផ្ទះតែក្នុងពេលបន្តិចទៀតនេះហើយ ។ ខ្ញុំជាអ្នកបកប្រែជូនគាត់ ។

* * * *

*គីតូ* ស្ទើរស្នាក់ខ្យល់ស្លាប់ :

- មនុស្សចុងស្រុក ?

- មនុស្សចុងស្រុក ។ ហើយវានឹងមកដល់ទីនេះតែអីលូវៗនេះឯង បើយើងមិនឃាត់វាទេ ។ ហើយវាមកជាមួយមីឆ្នា មីកំនាចបំផុតមួយដែលអញមិនដែលជួបទេ ។ មីណុងជាតិក្រោយអោយវាធ្លាក់ខ្លួនទៅធ្វើសំផឹងថ្នាក់ទីដប់ប្រាំនៅតាមផ្លូវច្រកកន្លុកកន្លៀត តែម្តង ។

ថ្វីត្បិតតែនាងមានការភ័យខ្លាច តែ *គីតូ* ទប់សំនើចខ្លួនមិនបានដែរ :

- អូហ៎ *ម៉ាម៉ា-សាន* កុំជេរប្រទេចផ្តាសាគេយ៉ាងណឹង ! គាត់ហាក់ដូចជាលោកស្រីមួយដ៏គួរអោយស្រលាញ់ ហើយមួយ *កូបាន* ពេញទៅទៀត ។ ម៉ែរៀបចំល្អមែនទែន! មក!មក! យើងនៅសល់ពេលម៉ាត់នរគោកទេតើ ។ ដំបូងបង្អស់ដាក់ស្រាសាកេទៅ ដើម្បីកុំអោយឆ្អិតថ្ងៃអីទៀត ។ *អាកូ* អោយលឿន ដួលកុំងើប !

*អាកូ* បាត់ស្រមោលភ្លាម ។ ពេលនិយាយចេញ *គីយ៉ូកូ* ស្ទើរស្ទះម្តងទៀត :

- ពិតហើយក្មេវគឺ *អាន់ជីន-សាន* ។

*គីតូ* បក់ធ្មិតអោយគាត់ហើយ *ហាណា* ដែលទើបមកហាត់រៀននោះក៏ជួយបក់ផងកាន់រមូរគ្រឿងក្រអូបដាក់ជិតច្រមុះគាត់បណ្តើរផង ។

- ម៉ែស្មានថា អ្នកស្រីនោះមកនិយាយសំរាប់អោយលោកម្ចាស់ *ប៊ុនតារ៉ូ* រឺលោកម្ចាស់ *តូរ៉ាណាកា* ខ្លួនឯង ។ នៅពេលដែលគាត់ប្រាប់ថា គឺសំរាប់ *អាន់ជីន-សាន* ម៉ែក៏សូរភ្លាម



www.budinst.gov.kh www.elibraryofcambodia.org

ថាម៉ែចក៏កំនាន់គាត់ គឺលោកស្រី *ភូជីកូ* មិនមកនិយាយរឿងនេះទៅតាមសុជីវធម៌ត្រឹមត្រូវទៅ តែគាត់ថាកំនាន់គាត់នេះមានរបួសរលាកភ្លើង ហើយលោកម្ចាស់*តូរ៉ាណាកា* បានបញ្ជាផ្ទាល់អោយរូបគាត់មកជួបនិយាយជាមួយម៉ែនេះ ។

- អូហ៍ អូហ៍ បើអីចឹងខ្ញុំមានសំនាងណាស់ដែលបានបំរើអម្ចាស់ធំយ៉ាងនេះ !

- ឯងនឹងមាន ! ឯងនឹងមានបើយើងចេះមានផែនការ ។ តែនេះអាមនុស្សចុងស្រុកហ៊ឹង ! តើក្មេងឯងទាំងអស់គេនឹងគិតយល់យ៉ាងម៉េចទៅ ? តើគេនឹងថាយ៉ាងម៉េចទៅ ? ពិតហើយម៉ែទុករឿងនេះមិនទាន់អោយដាច់ស្រេចទេ ដោយម៉ែប្រាប់អ្នកស្រី*តូដា* ថាម៉ែមិនទាន់ច្បាស់ថាឯងទំនេរ រឺអត់ទេ ហេតុនេះឯងនៅតែអាចប្រកែកបានទេ បើសិនណាជាឯងមិនចង់ទទួល ។ ហើយគេក៏មិនខឹងសំបាអីដែរ ។

- តើក្មេងឯងទៀតអាចនិយាយអីបានទៅ ? លោកម្ចាស់ *តូរ៉ាណាកា* បានចេញបញ្ជារឿងនេះ ។ គ្មានអ្វីត្រូវគិតនោះទេ *នេ* ?

- ឯងអាចប្រកែកបានយ៉ាងងាយ ។ តែឯងត្រូវតែអោយលឿនណា *គីគូ-សាន* ។ ស្តាយណាស់ម៉ែគួរតែវាងវៃជាងនេះឆ្ងាយណាស់ ។

- កុំបារម្ភពេក *គីយ៉ូកូ-សាម៉ា* ។ អ្វីៗនឹងស្រួលបួលជាមិនខាន ។ តែយើងត្រូវគិតអោយបានច្បាស់ ។ ព្រោះនេះជាការប្រថុយប្រថានខ្លាំងណាស់ *នេ* ?

- ខ្លាំងណាស់ ។ ខ្លាំងមែនទែនតែម្តង ។

- យើងមិនអាចប្រែក្រលាស់បានទេ នៅពេលណាដែលយើងទទួលការយល់ព្រមហើយ ។

- អី ម៉ែដឹងហើយ ។

- ជួយអោយយោបល់ខ្ញុំផង ។

- ម៉ែមិនដឹងជាអោយយោបល់អីទេ *គីគូ-សាន* អើយ ។ ម៉ែដូចជាជាប់អង្គប់ *កាមីអីចឹង* ។ រឿងនេះត្រូវជាការសំរេចចិត្តរបស់ឯងហើយ ។

*គីគូ* ថ្លឹងថ្លែងរឿងដ៏វន្ទត់ទាំងប៉ុន្មាន ។ រួចនាងពិចារណារឿងដែលល្អទាំងប៉ុន្មានវិញ :



www.budinst.gov.kh www.elibraryofcambodia.org

- អីល្អវង្វេចយើងចាក់ល្បែងទៅចុះ ។ទទូលគាត់នោះទៅ ។តិច១ទៅគាត់ក៏ជាសាមូរ៉ៃជា *ហាគាម៉ូតូ* ហើយជាអណ្ដាប់សំនព្វរបស់លោកម្ចាស់ *តូរ៉ាណាកា* ទៅទៀត ។ កុំភ្លេចរឿងគ្រូទាយដែលបានទាយថា ខ្ញុំនឹងជួយម៉ែអោយក្លាយជាអ្នកមានល្បីឈ្មោះជារៀងរហូតអោយសោះ ។ ខ្ញុំតែងបួងសួងសូមអោយខ្ញុំបានទទួលធ្វើអ្វីដែលអាចសងទឹកចិត្តសប្បុរសធម៌ របស់ម៉ែមកលើខ្ញុំនេះវិញផង ។

*គីយ៉ូកូ* ទះសក់ដ៏ល្អស្អាតរបស់ *គីគូ* បន្ថើរ ១ :

- ឯងចំជាល្អមែន ។ អរគុណ ! អរគុណ ! ពិតហើយ ម៉ែគិតថា : ឯងវាងវៃណាស់ ។ ម៉ែឯកភាពតាមហើយ ។អោយគេមកលេងផ្ទះយើងម្ដងចុះ ។ ឯងជាមនុស្សសំនព្វបំផុតរបស់ម៉ែ! តែបើម៉ែដឹងថា នេះជាបុរសចុងស្រុកនោះ ម៉ែនឹងទារមួយជាពីរជាមិនខាន ។

- តែយើងបានមួយជាពីរហើយតើ *ម៉ាម៉ា-សាន* ។

- បើអីចឹងយើងគួរទារមួយជាបីវិញ ។

*គីគូ* ទះដៃ *គីយ៉ូកូ* ថ្នមៗ :

- កុំបារម្ភអី ។ នេះគឺជាការចាប់ផ្ដើមហេងរបស់ម៉ែហើយ ។

- មែនហើយ១ជាការពិតដែល *អាន់ជីន-សាន* មិនមែនជាមនុស្សចុងស្រុកធម្មតាតែជាសាមូរ៉ៃ និងជាមនុស្សចុងស្រុក*ហាគាម៉ូតូ* ។ អ្នកស្រី *តូដា* បានប្រាប់ម៉ែថាគាត់ទើបបានទទួលដីមានតំលៃពីរពាន់*កូគូ* ហើយនឹងត្រូវតែងតាំងជាឧត្ដមនាវី លើកងនាវាទាំងអស់របស់លោកម្ចាស់ *តូរ៉ាណាកា* ហើយថាគាត់មុជទឹកដូចមនុស្សមានអារ្យធម៌ដែរ និងលែងធុំក្លិនស្អុយទៀតហើយ...

*អាកូ* ត្រលប់មកវិញទាំងដង្ហក់ហើយចាក់ស្រាដោយឥតអោយកំពប់មួយតក់ឡើយ ។ ស្រាបូនពែងត្រូវបានអកអស់ជាបន្តបន្ទាប់ ។ *គីយ៉ូកូ* ចាប់ផ្ដើមស្រួលចិត្តជាងមុន :

- យប់នេះត្រូវតែឥតខ្ចោះ ។ ពិតហើយ ។ បើលោកម្ចាស់ *តូរ៉ាណាកា* បញ្ជារឿងនេះអ្វី១ត្រូវតែតាមនោះ ។ លោកនឹងមិនបញ្ជាដោយផ្ទាល់ទេបើរឿងនេះមិនមានសារសំខាន់សំរាប់លោកផ្ទាល់នោះ *ទេ*? ហើយ *អាន់ជីន-សាន* ប្រៀបដូចជា *ដៃមីញ៉ូ* ពិត១ ។ ពីរពាន់*កូគូ* មួយឆ្នាំ



www.budinst.gov.kh www.elibraryofcambodia.org

*កាមី* អើយពួកយើងចំជាហេងមែនទែន ! *គីតូ-សាន* ស្តាប់ណាំ !

ស្រីចំនាស់អោនខ្លួនទៅមុខ *អាកូ* ក៏ប្រឹងអោនទៅតាមស្តាប់ដែរ :

- ម៉ែបានសួរអ្នកស្រី *ភូដា* ដោយម៉ែឃើញថា អ្នកស្រីហ្នឹងចេះនិយាយភាសាចំលែករបស់ពួកនេះ ថាតើគាត់មានដឹងថា មានវិធី រឺទំលាប់ប្លែក រឿងនិទាន រឺរបាំ រឺរបៀប រឺចំរៀង រឺឧបករណ៍ រឺថ្នាំប៉ូវអីដែល *អាន់ជីន-សាន* ចូលចិត្តរឺទេ ។

*គីតូ* តបទាំងទឹកខ្លាចនៅក្នុងចិត្ត នៅពេលដែលនាងបានសំរេចចិត្តរួចហើយនេះ :

- អ្នាំ ហ្នឹងពិតជាជួយច្រើនណាស់ ។ ច្រើនមែនទែន ។

- អ្នកស្រីនោះអត់មានប្រាប់បានអីទាំងអស់ ! គាត់ថាគាត់និយាយភាសាពួកនោះមែន តែអត់ដឹងអីមួយគ្រាប់ពីរឿងទំលាប់រូមវ័ក្សរបស់ពួកគេទេ។ ម៉ែបានសួរថាតើគាត់មានដែលសួរគាត់នោះពីរឿងហ្នឹងទេ គាត់ថាដែល តែលទ្ធផលគឺរិះតែរលត់រលាយ -*គីយ៉ូកូ* និយាយរ៉ាយរ៉ាប់ពីរឿងរ៉ាវដែលកើតឡើងនៅឯក្នុងវិមាន*អូសាកា* - កូនឯងយល់បានហើយថា តើវាលំបាក ចិត្តតឹងទ្រូងយ៉ាងណាទៅ !

- យ៉ាងហោចណាស់ក៏យើងអាចដឹងបានថា មិនត្រូវស្នើយកក្មេងប្រុសអោយគាត់ដែរ ។ អានេះ ក៏រឿងមួយទៅដែរ ។

- ក្រៅពីនេះ មានតែនារីបំរើនៅក្នុងផ្ទះនោះទេ ដែលទៅជាមួយគាត់ !

- តើយើងមានពេលឯណាទៅរកនារីអ្នកបំរើនោះ ?

- ម៉ែទៅដល់កន្លែងនោះភ្លាមពេលចេញពីបន្ទាយមក។ តែអោយលុយស្មើ នឹងប្រាក់ខែមួយខែហើយ ក៏ស្រីបំរើនោះមិនហើបមាត់មួយម៉ាត់ ។ ចំជាមីក្មេងភ្លើមែន !

- នាងនោះសមគួរទេ ?

- ល្មម ចំពោះស្រីបំរើដែលមិនបានបង្ហាត់នោះ ។ អ្វីដែលស្រីនោះបញ្ជាក់ គឺថាម្ចាស់ប្រុសរបស់វានេះមាំមួនខ្លាំងក្លា មិនធូរទេ ហើយរូមវក្សញឹកញាប់បំផុត តាមក្បាច់ដូនតាតែប៉ុនហ្នឹង ។ ហើយថាប្រដាប់ក៏ធំដែរ ។

- ប៉ុនហ្នឹងដូចជាមិនជួយយើងប៉ុន្មានទេ *ម៉ាម៉ា-សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

- ម៉ែដឹងហើយ ។ តាមមើល ល្អបំផុត គឺ ត្រូវរៀបចំត្រៀមគ្រប់តែទាំងអស់ម្តងទៅ ក្រែងលោត្រូវការ *វេ*? ត្រៀមទាំងអស់តែម្តង ។

- ចាស ខ្ញុំត្រូវតែប្រយ័ត្នមែនទែន ។ ជាការសំខាន់ណាស់ ដែលអ្វីៗត្រូវតែសុក្រឹត ។ មើលទៅប្រហែលជាលំបាកមែនទែន ក្នុងការកំដរគាត់អោយបានត្រឹមត្រូវនោះ ។ អាចធ្វើទៅមិនបានផង ក៏មិនដឹង ។ បើខ្ញុំមិនអាចនិយាយជាមួយគាត់បានផង ។

- អ្នកស្រី *តូដា* ថាគាត់ នឹង បកប្រែអោយឯង និង *អាន់ជីន-សាន* ។

- អូហ៎ គាត់ចំជាចិត្តបានមែន ។ នេះ គឺជួយបានច្រើនដែរ ទោះវាមិនដូចគ្នា នឹង និយាយផ្ទាល់ក្តី ។

- ពិតហើយ ។ ពិតហើយ ។ ចាក់សាកេថែមទៀត *អាកូ* ។ តែ *គីតូ-សាន* កូនឯងជាអ្នកកំដរភ្ញៀវថ្នាក់លេខមួយ ។ ចេះច្នៃខ្លះទៅ ។ មនុស្សចុងស្រុកឧត្តមនារីនេះបានជួយជីវិតលោកម្ចាស់ *តូរ៉ាណាកា* នៅថ្ងៃនេះ ហើយស្ថិតនៅក្រោមម្លប់របស់លោកម្ចាស់តែម្តង ។ អនាគតពួកយើងពឹងផ្អែកលើឯងហើយ ! ម៉ែដឹងថា ឯងច្បាស់ជាទទួលបានជោគជ័យយ៉ាងសម្ភាជាមិនខាន ។ *អាកូ* !

- ចាស លោកស្រីម្ចាស់ !

- មើលម៉ក់មើលអីអោយ ល្អខ្លោះ ។ មើលផ្កា... ទេ ផ្កាអញ្ចៀរៀបចំខ្លួនអញវិញ ! ហើយ *យូក* ? *យូក* នៅឯណា ? - ស្រីចំនាស់ទះជង្គង់ *គីតូ* - ពាក់គីម៉ូណូពណ៌ទឹកមាសពីលើគីម៉ូណូពណ៌បៃតងទៅ ។ យប់នេះយើងត្រូវធ្វើយ៉ាងណាបន្ទន់ចិត្តអ្នកស្រី *តូដា* អោយបាន ។

រួចគាត់ក៏រលះរលាំងចេញទៅចាប់ផ្តើមរៀបរយផ្ទះសំបែង ដោយមានការជួយប្រញាប់ប្រញាល់របស់ពួកនារីកំដរ ពួកមកហាត់រៀន និង ពួកនារីបំរើទាំងអស់ នោះផង ។

នៅពេលដែលអ្វីៗ ត្រូវបានរៀបចំស្រេចបាច់ហើយៗ កម្មវិធីនារីឯទៀតៗ ក៏ត្រូវបានរៀបចំឡើងវិញដែរហើយនោះ *គីយ៉ូកូ* ក៏ចូលទៅបន្ទប់ខ្លួន ហើយប្រះខ្លួនសំរាកមួយខណៈដើម្បីប្រមូលកំលាំងឡើងវិញ ។ គាត់មិនទាន់ពោលប្រាប់ *គីតូ* នៅឡើយពីរឿងទិញកិច្ចសន្យាលោះរូបនាង ។



www.budinst.gov.kh www.elibraryofcambodia.org

អញនៅរង់ចាំមើលបន្តិចសិន- គាត់គិតនៅក្នុងចិត្ត ។ បើសិន ជាអញអាចរៀបចំតាមដែលអញស្មើបាននោះ អញប្រហែលជាអាច នឹងយល់ព្រមអោយ *គីកូ* ជាទីស្រលាញ់របស់អញចេញ ។តែទាល់តែអញដឹងថា នាងទៅជាមួយអ្នកណាដែរ ។អញរីករាយចិត្តដែរដែលបានបញ្ជាក់រឿងនេះច្បាស់លាស់ជាមួយអ្នកស្រី *ភូជា* មុនអញបែកចេញពីគាត់មកនេះ ។

- *ហាណា-ចាន* !

- ចាស *ម៉ាម៉ា-សាន* ?

កុមារីរត់មកដល់យ៉ាងរហ័ស ។នាងទើបមានអាយុប្រាំមួយឆ្នាំ មានភ្នែកធំ១ពណ៌ខ្មៅតមានសក់គួរជាទីស្រលាញ់ ហើយស្លៀកគីម៉ូណូសូតចាំងភ្លឺផ្លេក ។ *គីយ៉ូកូ* ទើបទិញនាង កាលពីពីរថ្ងៃមុននេះតាមរយៈ *មូរ៉ា* និងផ្ទះលក់ក្មេងមួយនៅក្នុងភូមិនេះ ។

- កូនឯងស្រលាញ់ឈ្មោះថ្មីរបស់ឯងទេ ?

- ស្រលាញ់ ។ ស្រលាញ់ណាស់ ។ អរគុណ *ម៉ាម៉ា-សាន* ។

ឈ្មោះនាងមានន័យថា « ត្រួយបុប្ផា » ។ *គីកូ* មានន័យថា « ស្បៃរឿង » ។ *គីយ៉ូកូ* បានដាក់ឈ្មោះអោយកុមារីនេះតាំងពីថ្ងៃដំបូង បន្ទាប់ពីការតថ្លៃយ៉ាងតឹងតែងអស់រយៈបួនថ្ងៃមក ។ គាត់បានបង់ប្រាក់មួយ *កូបាន* សំរាប់ការងាររបស់កុមារីនេះរហូតដល់អាយុម្ភៃឆ្នាំ ពេលគឺគ្រប់គ្រាន់អាច នឹងចិញ្ចឹមគ្រួសាររបស់កុមារីនេះគឺ *ភាម៉ាសាគី* បានពីរឆ្នាំដែរ ។

- ឯងទៅយកទឹកតែ យកក្រាស ហើយយកស្លឹកតែខ្លះមកផង ដើម្បីបំបាត់ក្លិនសាកេ ។

- ចាស *ម៉ាម៉ា-សាន* ។

កុមារីរត់ទាំងសស្លើតដើម្បីបំពេញចិត្ត *ម៉ាម៉ា-សាន* ហើយក៏មកបុកផាំងជាមួយ *គីកូ* នៅឯច្រកមាត់ទ្វារ ។

- អូហ៍ សូមទោស ...

- ឯងត្រូវរៀនប្រយ័ត្នប្រយែងណា៎ *ហាណា-ចាន* ។

- សូមទោស ។ សូមទោស ។ សូមទោសអ្នកបងធំ ។



www.budinst.gov.kh www.elibraryofcambodia.org

*ហាណា* ស្ទើរពេបទៅហើយ ។

- ម៉េចបានជាឯងធ្វើមុខកំសត់អ៊ីចឹង *ហាណា-ចាន* ? មើលនេះ ។មើល៍- *គីគូ* និយាយផងជូតតំនក់ទឹកភ្នែកកុមារីចេញផង - នៅក្នុងផ្ទះនេះយើងត្រូវបោះបង់ចោលអោយអស់នូវភាពទុក្ខព្រួយ ។ ឯងត្រូវចាំថា ពួកយើងនៅក្នុងពិភពដើមសូលយើងឥតត្រូវការភាពទុក្ខព្រួយព្រោះវាគ្មានបាននាំអ្វីល្អមកដល់ពួកយើងឡើយ ។ ភាពទុក្ខព្រួយមិនដែលនាំមកនូវការរីករាយទេ ។ ភារកិច្ចរបស់យើង គឺធ្វើអោយគេរីករាយចិត្ត និង ត្រូវតែសប្បាយចិត្ត ។ អីលូវរត់ទៅ ទៀតចុះតែប្រយ័ត្នប្រយែង ។

រួចនាងបង្ហាញខ្លួនចំពោះមុខ *គីយ៉ូកូ* ទាំងញញឹមពព្រាយ :

- ប៉ុនណឹងពេញចិត្តទេ *ម៉ាម៉ា-សាន* ?

* * * *

*ប្លាក់ថន* សំលឹងមើលនាង ហើយលាន់មាត់តិចៗ :

- *ហាលេលូយ៉ា* !

- នេះ គឺ *គីគូ-សាន* ។

*ម៉ារីកូ* ធ្វើការណែនាំជាផ្លូវការ ទាំងក្នុងចិត្តរីករាយចំពោះប្រតិកម្មរបស់ *ប្លាក់ថន* ។នារីដើរចូលមកក្នុងបន្ទប់ក្នុងសំលេងស្រោកស្រាកនៃក្រណាត់សូត ។ នាងលុតជង្គង់ចុះ រួចលំអោនខ្លួនគោរពដោយនិយាយពាក្យប៉ុន្មានម៉ាត់ដែល *ប្លាក់ថន* ចាប់មិនទាន់ ។

- នាងនិយាយថា សូមស្វាគមន៍លោក ហើយលោកបានផ្តល់កិត្តិយសដល់ផ្ទះរបស់នាង ។

- *ដូម៉ូ* - គេតប ។

- *ដូ អ៊ីតាសេម៉ាស៊ីតេ* ។ សាកេ *អាន់ជីន-សាន* ? - *គីគូ* សួរ ។

- *ហៃ ដូម៉ូ* ។



www.budinst.gov.kh www.elibraryofcambodia.org

គេសំលឹងមើលដៃដ៏ស្អាតស្រលូនរបស់នាងចាប់យកថូយ៉ាងឥតខ្មាះ ហើយក្រោយពីពិនិត្យថាកំដៅសមរម្យហើយនោះ នាងក៏ចាក់ទៅក្នុងពែងដែល *ភ្លាក់ថន* ហុចអោយដោយខំប្រឹងយ៉ាងសមបំផុតតាមដែល *ម៉ារីកូ* បង្ហាត់គេ ។

នៅពេលពួកគេចេញពីបន្ទាយដោយមាន *ម៉ារីកូ* អង្គុយក្នុងស្នែង និងដោយមាន *ភ្លាក់ថន* ដើរ អែបក្បែរនោះ នាងបានសួរទៅ *ភ្លាក់ថន* :

- លោកសន្យាថានឹងធ្វើដូចជនជាតិជប៉ុនណាំ ។ តើពិតទេ ?

អ្នកកាន់ចន្លុះដើរពីខាងមុខដើម្បីបំភ្លឺផ្លូវ ។ សាមូរ៉ៃដប់នាក់ រួមដំនើរជាមួយពួកគេក្នុងឋានៈជាកងការពារកិត្តិយស ។ ពួកគេដើរតំរង់ទៅភូមិ រួចទៅដល់ផ្ទាភូមិដែលនៅទល់មុខសមុទ្ទ ។ *ភ្លាក់ថន* តប :

- ខ្ញុំនឹងប្រឹងប្រែង បាទ ។ តើខ្ញុំត្រូវធ្វើយ៉ាងម៉េចខ្លះទៅ ?

- អ្វីដែលលោកត្រូវធ្វើដំបូងបំផុត គឺបំភ្លេចអោយអស់នូវអ្វីដែលលោកត្រូវធ្វើហើយត្រូវចាំជាសំខាន់ គឺថាយប់នេះសំរាប់តែការសប្បាយរីករាយរបស់លោកតែប៉ុននោះ ។

ថ្ងៃនេះគឺជាថ្ងៃដ៏ល្អបំផុតក្នុងជីវិតរបស់អញ - គេគិតនៅក្នុងចិត្ត ។ ហើយយប់នេះ... តើយប់នេះយ៉ាងម៉េចហ្ន៎ ? គេហាក់មានការរំភើបនឹងវិញ្ញាសាថ្មីនេះ ហើយគេបានប្តេជ្ញាចិត្តធ្វើអោយដូចជនជាតិជប៉ុន ហើយប្រឹងសប្បាយទាំងសព្វទាំងគ្រប់លែងអឹមអៀន ។ គេសួរទៅ *ម៉ារីកូ* :

- តើ... តើ... កំសាន្តយប់នេះ... អស់ប៉ុន្មានទៅ ?

- សួរអីចឹងមិនមែនជារបៀបជប៉ុនទេ *អាន់ជីន-សាន* - *ម៉ារីកូ* បន្ទោស-តើរឿងនេះមានទាក់ទងនឹងរឿងអី ? *ភូជីកូ-សាន* ឯកភាពថា ការរៀបចំនេះគួរជាទីពេញចិត្តហើយតើ ។

មុនចេញមកនេះ គេបានទៅអើតមើល *ភូជីកូ* ដែរ ។ គ្រូពេទ្យបានមកពិនិត្យនាង និងបានផ្លាស់ប្តូរស្បៀវ ហើយនឹងទុកថ្នាំសំរាប់នាង ។ នាងសែនមានមោទនភាពចំពោះកិត្តិយស ហើយនឹងដីថ្មីដែលទើបទទួលបាន ហើយនាងនិយាយពីនេះពីនោះឥតដាច់ឥតមានបង្ហាញការឈឺចាប់របស់នាងឡើយ ។ នាងសប្បាយចិត្តនៅពេលដែលនាងដឹងតាមរយៈ *ម៉ារីកូ* ថាគេនឹងទៅ



www.budinst.gov.kh www.elibraryofcambodia.org

ផ្ទះតែនោះ ។ នាងសូមទោស ដោយថាបុរសនាងមិនអាចអោយនាងរៀបចំអោយគេដោយខ្លួននាងបាន។ មុនពេលចេញពីនាង គេកាន់ដៃនាងដោយចិត្តអាណិតស្រឡាញ់ ។

*តឺយ៉ូកូ* ហើយនឹងពួកនារីបំរើនៅរង់ចាំស្វាគមន៍គេយ៉ាងហ៊ឹកហ៊ាក់នៅឯ ខ្លោងទ្វារផ្ទះតែ ។

- នេះគឺជា*តឺយ៉ូកូ-សាន* ។ នាងជា *ម៉ាម៉ា-សាន* នៅទីនេះ ។

- មានកិត្តិយសណាស់ *អាន់ជីន-សាន* ។ កិត្តិយសណាស់ !

- *ម៉ាម៉ា-សាន* ? នាងចង់ថាម៉ែណឹងអ្វី? ម៉ែ ? នេះដូចអង់គ្លេសដែរ *ម៉ារីកូ-សាន* ។ *ម៉ាម៉ា-សាន* ។ *ម៉ាម៉ា* ? Mommy-Mother ។

- ចាស ប្រហាក់ប្រហែលគ្នាដែរ តែសូមទោស *ម៉ាម៉ា-សាន* មានន័យត្រឹម «ម៉ែធម៌» រឺ «ម៉ែចិញ្ចឹម» តែប៉ុណ្ណោះ *អាន់ជីន-សាន* ។ ម្តាយបង្កើតគឺ *ហាហា-សាន* រឺ *អូកា-សាន* វិញទេ។

បន្តិចក្រោយមក *តឺយ៉ូកូ* សុំអនុញ្ញាតចេញទៅវិញ។ *ប្លាក់ថន* ញញឹមមើល *ម៉ារីកូ*។ នាងសំលឹងភ្នែកភ្លាំង មើលសព្វមើលគ្រប់ ប្រៀបដូចជាកូនក្មេង :

- អូហ៍ *អាន់ជីន-សាន* ខ្ញុំតែងតែមានបំណងចង់ឃើញ ទិដ្ឋភាពក្នុងផ្ទះអស់នេះជាពន់ពេក ។ មនុស្សប្រុសចំជាមានសំណាងមែន ! អ្វី១ទាំងនេះល្អណាស់មែនទេ ? មិនអស្ចារ្យទេរឺនៅក្នុងកូនភូមិដ៏តូចមួយសោះ ? *តឺយ៉ូកូ-សាន* ច្បាស់ជាប្រើមេដាងដ៏ចំនានណាស់ដើម្បីកែកុនជាថ្មីទាំងស្រុងកន្លែងនេះ ។ មើលសាច់ឈើទាំងនេះ... ឱ! លោកចំជាល្អមែនទែន ដែលយល់ព្រមអោយខ្ញុំមកជាមួយលោក ។បើមិនយ៉ាងនេះទេ ខ្ញុំនឹងមិនមានឱកាសរហូត... លោកមើលផ្កានេះនែ៎... នេះបានចំជាចេះរៀបមែន... ហើយនុះលោកមើលសួនច្បារ...

*ប្លាក់ថន* សប្បាយរីករាយផង ពិបាកនៅក្នុងចិត្តផង ដោយវត្តមានរបស់នារីបំរើនៅក្នុងបន្ទប់មួយ និងដោយទ្វារនៅចំហធ្លុង ។ គេនិយាយជាភាសាឡាតាំង :

- នាងស្អាតណាស់ ។

- លោកក៏អ៊ីចឹងដែរ ។ ខ្ញុំមានមោទនភាពចំពោះរូបលោកណាស់ ។ *ភូជីកូ* ក៏អ៊ីចឹង ។ នាងសែនមានមោទនភាពរហូតតែងមួយកន្លែងស្ទើរមិនជាប់ ។



www.budinst.gov.kh www.elibraryofcambodia.org

- របួសរលាករបស់នាងដូចជាធ្ងន់ធ្ងរណាស់ ។

- កុំខ្លាចអី ។ ពួកគ្រូពេទ្យគេថ្នឹកណាស់ ហើយនាងក៏នៅក្មេងមានកំលាំងពោរពេញ ហើយមានទំនុកចិត្តលើខ្លួនថែមទៀតផង ។ យប់នេះ យកអ្វី១ចេញអោយអស់ពីក្នុងអារម្មណ៍របស់លោក ។ គ្មានរឿងបញ្ហា *អ៊ីស៊ីដូរ៍ អ៊ីកាវ៉ា ជីគីយូ* រឺការប្រយុទ្ធ រឺពាក្យកូត រឺជីធ្វី រឺសំពៅអីទាំងអស់ ។ យប់នេះអត់ខ្វល់ ។ យប់នេះសូមមានតែទិព្វសំភារៈតែប៉ុននោះសំរាប់រូបលោក ។

- ចំពោះខ្ញុំ នាងជាទិព្វសំភារៈហើយ ។

*ម៉ារីកូ* រលាស់ផ្លិតបក់ ហើយចាក់ស្រាដោយឥតនិយាយស្តីមួយម៉ាត់ឡើយ ។គេសំលឹងមើលនាង រួចគេញញឹមទាំងពីរនាក់ ។ នាងនិយាយ :

- ដោយថានៅទីនេះក៏មានអ្នកឯទៀតដែរ យើងត្រូវតែប្រយ័ត្នប្រយែង ។ តែខ្ញុំសប្បាយណាស់ដែលបានមកទីនេះ ។

- តើមូលហេតុមួយទៀតនោះគឺស្អីទៅ ? នាងបាននិយាយថា មានមូលហេតុមួយទៀតដែលនាងចង់អោយខ្ញុំមកកាន់ទីនេះនៅយប់នេះ ។

- ចាស នៅមានមូលហេតុមួយទៀត - ក្លិនក្រអូបដដែលនេះនៅហ៊ុមព័ទ្ធខ្លួនរបស់ *ឆ្កាន់ថន* ជុំជិត - នេះគឺជាប្រពៃណីដែលយើងមានតាំងពីបុរមបុរាណមក *អាន់ជីន-សាន* ។ នៅពេលណានារីម្នាក់ ដែលជាកម្មសិទ្ធិរបស់អ្នកណាម្នាក់ចង់យកចិត្តទុកដាក់លើអ្នកផ្សេងមួយទៀត ហើយចង់អោយនូវអ្វីដែលត្រូវហាមឃាត់ទៅបុរសនោះ នាងនឹងរៀបចំយ៉ាងណាអោយនារីម្នាក់ទៀតជំនួសនាង នោះគឺជាការជូននារីកំដរឥតខ្ចោះម្នាក់តាមលទ្ធភាពដែលខ្លួនអាចធ្វើទៅបានវិញ ។

- ពេលដែលនាងថា: « នៅពេលដែលនារីយកចិត្តទុកដាក់លើអ្នកផ្សេងមួយទៀត » គឺនាងចង់និយាយពី « ស្រលាញ់ » រឺ ?

- ចាស តែពាក្យនេះសំរាប់តែយប់នេះទេ ។

- ហេតុអីយប់នេះ *ម៉ារីកូ-សាន* ? ហេតុអ្វីមិនពីមុនផង ?

- យប់នេះជាយប់ប្រកបដោយវេទមន្ត ហើយ *កាមី* បានធ្វើដំណើរមកជាមួយយើង



www.budinst.gov.kh www.elibraryofcambodia.org

ផងដែរ ។ ខ្ញុំចង់បានលោក ។

រួច*គីតូ* បានបង្ហាញខ្លួនទៅមាត់ទ្វារ ធ្វើអោយគេលាន់មាត់ « ហាលេលូយ៉ា » ឡើងម្តងទៀត ។

- តើខ្ញុំ និយាយថា នាងស្អាតជាពិសេសនោះថាម៉េច ?

*ម៉ារីកូ* និយាយប្រាប់ហើយគេក៏និយាយតាម ។ *គីតូ* សើចយ៉ាងរីករាយទទួលយកនូវការសរសើរនេះ ។

- *គីតូ-សាន* សួរថាតើលោកចង់អោយនាងច្រៀងរាំជូនលោកទេ ?

- តើនាងវិញ នាងចូលចិត្តអីជាងគេ ?

- នារីនេះមកសំរាប់ការរីករាយរបស់លោក ដែលជាសាមូរ៉ៃ មិនមែនមកសំរាប់ខ្ញុំទេ ។

- ចុះនាង ? មិននាងមកទីនេះដើម្បីការសប្បាយរីករាយរបស់ខ្ញុំដែរទេរឺ ?

- ចាស តែមួយបែបផ្សេង ។ មួយបែបយ៉ាងសំងាត់ផ្ទាល់ខ្លួន ។

- បើអីចឹងសូមអោយនាងច្រៀងចុះ ។

*គីតូ* ទះដៃយ៉ាងថ្នមៗ ហើយ *អាកូ* ក៏យក*សាមីសេន* ចូលមក ។ នេះជាចាប៉ីវែងដែលមានខ្សែបី ។ ក្រោយពីដាក់នៅលើក្តារហើយ *អាកូ* ក៏ហុចក្រចកទៅអោយ*គីតូ* ។ នាងនិយាយឡើង :

- អ្នកស្រី*តូដា* សូមអ្នកស្រីអធ្យាស្រ័យជំរាបទៅភ្ញៀវដ៏ខ្ពង់ខ្ពស់របស់យើងខ្ញុំថា ដំបូងបង្អស់ខ្ញុំនឹងច្រៀង « ចំរៀងរបស់សត្វកន្ទុំរុយ » ចាស ។

- *គីតូ-សាន* ខ្ញុំនឹងមានកិត្តិយសបំផុត បើសិនជានៅយប់នេះនាងហៅខ្ញុំថា *ម៉ារីកូ-សាន* នោះ ។

- អ្នកស្រីចំជាមានសន្តានចិត្តល្អចំពោះខ្ញុំមែន ។តែសូមអ្នកស្រីមេត្តាអភ័យទោសដល់ខ្ញុំផង ខ្ញុំមិនអាចខ្វះការគួរសមបែបនេះបានទេ ។

- ខ្ញុំសូមចិត្តនាង ។



www.budinst.gov.kh www.elibraryofcambodia.org

- បើអ្នកស្រីចូលចិត្ត ខ្ញុំនឹងបំពេញបំនងអ្នកស្រីចុះ ថ្វីត្បិតតែ... - ស្នាមញញឹមរបស់នាងគួរអោយស្រលាញ់ - សូមអរគុណ *ម៉ារីកូ-សាន* ។

នាងយកដៃត្រេះខ្សែចាប៉ីឡើង ។ តាំងពីពេលដែលភ្ញៀវខ្លួនគាត់មាត់ទ្វាររបងរហូតមកដល់ពិភពរបស់នាងនេះ វិញ្ញាណទាំងប៉ុន្មានរបស់នាងកក្រើករំពើកជាប់ជានិច្ច ។ នាងបានតាមឃ្លាំមើលភ្ញៀវរបស់នាងជាប់ និងជាសំងាត់តាំងពីពេលដែលគេនៅជាមួយ *គីយ៉ូកូ* រហូតដល់ពេលដែលគេនៅតែពីរនាក់ ដើម្បីស្វែងរកគំរុយណាមួយដើម្បីបំពេញចិត្តរបស់គេ រឺទាក់ទាញអារម្មណ៍របស់អ្នកស្រី *ភូដា* បាន ។

តែនាងមិនបានត្រៀមចំពោះអ្វីដែលលេចមកយ៉ាងច្បាស់បែបនេះទេ ។ ច្បាស់ណាស់ដែល *អាន់ជីន-សាន* ចង់បានអ្នកស្រី *ភូដា* ថ្វីត្បិតតែបុរសនេះបានលាក់គំនួចចិត្តខ្លួនដូចមនុស្សមានអារ្យធម៌ឯទៀត១យ៉ាងណាក្តី ។ តាមពិតរឿងនេះគ្មានអ្វីចំលែកទេដោយថា អ្នកស្រី *ភូដា* ជានារីដ៏ស្អាតជាងគេ និងមានចរិយាសម្បត្តិល្អជាងគេ ហើយអ្វីដែលសំខាន់បំផុតនោះ នាងគឺជានារីតែម្នាក់គត់ដែលអាចនិយាយជាមួយបុរសនោះបាន ។ តែអ្វីដែលធ្វើអោយនាងភ្ញាក់ផ្អើលនោះគឺនាងជឿជាក់នៅក្នុងចិត្តថាអ្នកស្រី *ភូដា* ក៏ចង់បានបុរសនេះដូចគ្នាដែរ រឺលើសពីបុរសនេះផង ។

បុរសចុងស្រុកសាមូរ៉ៃ និងអ្នកស្រីសាមូរ៉ៃ ជាត្រកូលអភិជន និងជាកូនស្រីរបស់ឃាតក *អាកេជី ជិនសៃ* ជាប្រពន្ធរបស់លោកម្ចាស់ *ប៊ុនតារ៉ូ* ថែមទៀត ! អីយ៉ា ! បុរសកំសត់នារីកំសត់ ។ គួរអោយកំសត់មែន ។ ជាការពិតណាស់ ពួកគេនឹងត្រូវបញ្ចប់នៅក្នុងសោកនាដកម្មជាពុំខានឡើយ ។

*គីគូ* ស្ទើរស្រក់ទឹកភ្នែក នៅពេលដែលនាងនឹកគិតដល់ភាពកំសត់ និងទៅលើភាពអយុត្តិធម៌នៃជីវិតរស់នៅ ។ ឱ អញចង់កើតមកជាសាមូរ៉ៃម្ល៉េះទេ ព្រោះយ៉ាងហោចណាស់ក៏អញអាចក្លាយខ្លួនជាប្រពន្ធចុង *អូមី-សាម៉ា* ដែរ មិនមែនគ្រាន់តែត្រឹមជាល្បែងលេងកំសាន្តរបស់គេដូចនេះទេ ។

ប៉ុន្តែបោះចោលទៅភាពកំសត់សោយសោកនេះ ។ ភារកិច្ចរបស់ឯង គឺផ្តល់នូវភាពរីករាយ ។



www.budinst.gov.kh www.elibraryofcambodia.org

ម្រាមដៃនាងកេះបទទីពីរ ជាបទដែលពោរពេញដោយភាពស្រនោះស្រនោក ។ រួចទើបនាងបានសង្កេតឃើញថា ថ្វីត្បិតតែ *ម៉ារីកូ* ឃាក់ជក់ចិត្តជក់អារម្មណ៍នឹងភ្លេងរបស់នាងក្តីតែ *អាន់ជីន-សាន* មិនបានជាប់អារម្មណ៍ជាមួយឡើយ ។

បទទីបីដែលពីរោះជាងមុន ត្រូវបាននាងសាកល្បងដេញឡើង ។ គ្មានអ្វីសង្ស័យឡើយ - នាងគិតនៅក្នុងចិត្តយ៉ាងរហ័ស - ទាំងនេះមិនបានធ្វើអោយគាត់រីករាយនៅក្នុងចិត្តឡើយ ។ នាងបណ្តោយអោយសំលេងភ្លេងរលត់ទៅតាមសំរួល ហើយក៏ច្រៀងចំរៀងមួយបទដោយមិនបាច់ដេញភ្លេងកំដរតាម ។ សំលេងរបស់នាងរត់ឡើងគ្រលួចទៅតាមបំលាស់ប្តូរទំនុកដែលជាសំលេងមួយទាមទារការរឹកហាត់រាប់ឆ្នាំទើបបានថ្វីក ។ ជាថ្មីម្តងទៀត *ម៉ារីកូ* ត្រូវមន្តស្នេហ៍ចំរៀងខាបព្រលឹងទៅតាមយ៉ាងលន្លង់លន្លោច តែ *អាន់ជីន-សាន* នៅតែមិនមានអារម្មណ៍អ្វីទាំងអស់ ។ *គីគូ* ក៏បញ្ឈប់ហើយនិយាយឡើង :

- យប់នេះមិនសំរាប់លេងភ្លេង រឺច្រៀងទេ ។ យប់នេះ គឺសំរាប់សុភមង្គល ។ *ម៉ារីកូ-សាន* តើពាក្យថា « សូមអភ័យទោសដល់នាងខ្ញុំផង » ជាភាសាគាត់និយាយថាម៉េច ?

- Per favor ។

- Per favor. *អាន់ជី-សាន* យប់នេះយើងត្រូវសើចសប្បាយ *នេ* ?

- *ដូម៉ូ គីគូ-សាន រ៉ៃ* ។

- ជាការលំបាកណាស់ដែលចង់ធ្វើអោយសប្បាយដោយមិននិយាយស្តី តែមិនមែនធ្វើមិនបាននោះទេ *នេ* ? អូហ៎មែន ខ្ញុំដឹងហើយ ។

នាងក៏ស្ទុះក្រោកឈរ ហើយក៏ចាប់ផ្តើមធ្វើកាយវិការត្រាប់កំប្លែងតាម ពួក *រ៉ៃមីញ៉ូ* ពួក *កាកា* អ្នកស្ទូចត្រី អ្នកប្រមាញ់ស្វាំង សាមូរ៉ៃរីកធំ រហូតដល់ត្រាប់តាមកសិករថែមទៀត ។ កាយវិការត្រាប់របស់នាងសំដែងបានដូច ហើយមានលក្ខណៈក្រមាច់ក្រមើមទាល់តែក្នុងរយៈពេលមួយភ្លែតសោះ ទាំង *ក្លាក់ថុន* ទាំង *ម៉ារីកូ* សើចកក្អិកបណ្តើរ ទះដៃបន្ទរបណ្តើរ ។

*គីគូ* លំអោនខ្លួនចំពោះការទះដៃសរសើរ ហើយក្រេបតែបន្តិច ព្រមទាំងផ្តិតញើសដែលនៅនឹងថ្ងាសនាងផង ។ នាងសង្កេតឃើញ *ក្លាក់ថុន* ពត់ស្មារបស់ខ្លួនចុះឡើង នាងក៏ពោល



www.budinst.gov.kh www.elibraryofcambodia.org

ឡើង :

- អូហ៍ per favor លោក !

រួចនាងក៏លុតជង្គង់ពីក្រោយខ្នង *ភ្លាក់ផន* ហើយធ្វើសរសៃករបស់គេ ។ ដៃដ៏ថ្មីករបស់នាងរកឃើញសរសៃសំរួលភ្លាម ។

- អូហ៍ ព្រះអើយស្រួលមែន... *វ៉ោ* កន្លែងណឹងហើយ !

នាងធ្វើតាមការប្រាប់របស់ *ភ្លាក់ផន* :

- បន្តិចទៀតកលោកនឹងស្រួលបួលវិញហើយ ។ អង្គុយច្រើនពេក *អាន់ជីន-សាន* !

- ស្រួលមែនទែន *គីគូ-សាន*។ នាងធ្វើអោយខ្ញុំមានអារម្មណ៍ថាតា *ស៊ូរ៉ូ* អន់តែម្តង ។

- ចាស សូមអរគុណ *អាន់ជីន-សាន* ។ *ម៉ារីកូ-សាន* ស្មារបស់ *អាន់ជីន-សាន* ធំទូលាយមែនទែន តើលោកស្រីអាចជួយខ្ញុំបានទេ ? លោកស្រីធ្វើសរសៃស្មាឆ្វេងទៅ ឯខ្ញុំធ្វើស្មាស្តាំគាត់ ។ សូមអភ័យទោសផងទៅចុះ ដៃខ្ញុំមិនសូវខ្លាំងទេ ។

*ម៉ារីកូ* ទទួលពាក្យរបស់ *គីគូ* ហើយធ្វើតាមនាងប្រាប់ ។ *គីគូ* លួចញញឹមនៅពេលដែលនាងសប្បាយចិត្តនឹងខ្លួនឯងដែលចេះច្នៃប្រឌិតភ្លាម១នេះ ។

- គ្រាន់បើទេ *អាន់ជីន-សាន* ?

- គ្រាន់បើ ។ គ្រាន់បើមែនទែន ។ សូមអរគុណនាង ។

- ចាស មិនចាំបាច់អរគុណទេ នេះជាការរីករាយរបស់នាងខ្ញុំទៅវិញទេ ។ ប៉ុន្តែគឺអ្នកស្រី *តូដា* ទេ ដែលប៉ិនប្រសប់ជាងខ្ញុំទៅទៀត - *គីគូ* អាចស្ទង់បាននូវចរន្តទាក់ទាញរវាងអ្នកទាំងពីរនាក់ ថ្វីត្បិតតែពួកគេខំលាក់យ៉ាងណាក្តី - អីលូវនេះពិសាអីបន្តិចសិនទៅរឺអី ?

ម្ហូបត្រូវបានលើកចេញមកភ្លាម ។

- ម្ហូបនេះសំរាប់លោកណា *អាន់ជីន-សាន* ។

*គីគូ* និយាយប្រាប់ទាំងមោទនភាព ។ នោះគឺជាមាន់ទោអាំងតូចមួយដែលគេកាត់ជាដុំ១ ព្រមទាំងទឹកស៊ីអ៊ីវផង ។ នាងចាប់ម្ហូបដាក់ចាន *ភ្លាក់ផន* ។

- ឆ្ងាញ់ណាស់ ។ មានរសជាតិមែន ។



www.budinst.gov.kh www.elibraryofcambodia.org

ហើយនេះជាការពិត ។

- *ម៉ារីកូ-សាន* ?

- ចាស អរគុណ ។

នាងទទួលយកសាច់មួយដុំដែលហុចអោយ តែនាងមិនទទួលទានវាទេ ។ *គីតូ* លូកចង្កឹះចាប់សាច់មួយដុំមកទំពាយ៉ាងឆ្ងាញ់ :

- ឆ្ងាញ់ *ទេ*?

- មិនមែនទេ *គីតូ-សាន* ។ គឺឆ្ងាញ់ណាស់! មហាសែនឆ្ងាញ់ !

- *អាន់ជីន-សាន* សូមអញ្ជើញពិសាទៀតទៅ - នាងលូកយកដុំទីពីរផងដែរ - មានច្រើនណាស់ ។

- អរគុណ ។ រូច... រូចអានេះយ៉ាងម៉េច ? - គេចង្អុលទៅទឹកស៊ីអ៊ីវ ។

*ម៉ារីកូ* បកប្រែអោយ :

- *គីតូ* ថា នេះធ្វើពីស្ករ សណ្តែកសៀង និងខ្ទឹមបន្តិច ។ នាងសួរថា នៅស្រុកលោកមានស្ករ និងសណ្តែកសៀងឬទេ ?

- ស្ករតែថាមាន ឯសណ្តែកសៀងគ្មានទេ *គីតូ-សាន* ។

- អ្ហា ! អត់សណ្តែកសៀង តើរស់យ៉ាងម៉េចបានទៅ? - *គីតូ* ប្រែជាម៉ឹងមាត់ - សូមអធ្យាស្រ័យជំរាប *អាន់ជី-សាន* ថាយើងមានស្ករនៅទីនេះតាំងពីមួយពាន់ឆ្នាំមុនម្លេះ ។ ព្រះសង្ឃព្រះនាម *កាងជិញ* បានយកស្ករពីស្រុកចិនមកស្រុកជប៉ុនយើងនេះ ។ អ្វីៗដែលល្អនៅស្រុកយើងគឺសុទ្ធតែមកពីចិនទាំងអស់ *អាន់ជីន-សាន* ។ ដើមតែមកដល់ស្រុកយើងកាលពីប្រហែលប្រាំរយឆ្នាំមុននេះ ។ គឺព្រះសង្ឃព្រះនាម *អីសាយ* បាននាំពូជប៉ុន្មានគុម្ពយកមកដាំនៅខេត្ត *ជីគូសេន* ដែលជាខេត្តដែលនាងខ្ញុំកើត ។ ព្រះអង្គក៏ជាអ្នកនាំព្រះពុទ្ធសាសនានិកាយ *សេន* ចូលជប៉ុនផងដែរ ។

*មារីកូ* បកប្រែក្នុងលក្ខណៈម៉ឹងម៉ាត់ដូចគ្នាដែរ ។ ឃើញយ៉ាងនេះ *គីតូ* ក៏ផ្ទុះសំណើចកក្អឹកស្រួយស្រែស :

- អូហ៍ សូមទោស *ម៉ារីកូ-សាន* ។ ប៉ុន្តែលោកប្រុសនិងអ្នកស្រីពីរនាក់នេះដូចជា



www.budinst.gov.kh www.elibraryofcambodia.org

ម៉ាំទាំដល់ហើយ ។ ខ្ញុំធ្វើហាក់ដូចជាម៉ឺងម៉ាត់នៅពេលនិយាយពីរឿងតែ ដើម្បីកំប្លែងលេងជាមួយលោកទាំងពីរទេតើ ។

ពួកគេទាំងពីរនាក់សំលឹងមើល *ភ្លាក់ថន* ដែលកំពុងបង្ហើយមាន់ទោ ។

- ឆ្ងាញ់ ! - គេនិយាយ - ឆ្ងាញ់ណាស់ ! សូមអរគុណ *គីយូកូ ផង* ។

- គាត់ច្បាស់ជារីកថ្លើមតែម្តងហើយ ។

និយាយតបបណ្តើរ *គីតូ* ចាក់ស្រាសាកេបន្ថែមសំរាប់ភ្ញៀវនាងទាំងពីរ ។ រួចនាងធ្វើជាសួរដោយជាមិនដឹងអីទាំងអស់ :

- អនុញ្ញាតអោយនាងខ្ញុំសួរបានទេ ថាតើថ្ងៃនេះមានកើតរឿងអីខ្លះនៅពេលរញ្ជួយដីនោះ ? នាងខ្ញុំលឺថា *អាន់ជីន-សាន* បានជួយសង្គ្រោះជីវិតលោកម្ចាស់ *តូរ៉ាណាកា* តើមែនរឺទេ ? នាងខ្ញុំគិតថា នេះពិតជាកិត្តិយសណាស់ដែលបានស្តាប់រឿងទាំងនេះដោយផ្ទាល់យ៉ាងដូចនេះ ។

រួច *គីតូ* រៀបបង្គុយខ្លួនយ៉ាងខន្តី ហើយទុកអោយ *ភ្លាក់ថន* និង *ម៉ារីកូ* សប្បាយនឹងរៀបរាប់ពីរឿងរ៉ាវទាំងឡាយដែលបានកើតឡើង ដោយគ្រាន់តែបន្ថែម « អូហ៍ » រឺ « រួចយ៉ាងម៉េចទៅ » រឺក៏ចាក់ស្រាសាកេតែប៉ុននោះ ដោយឥតមានបន្ទុចបង្អាក់ភ្ញៀវរបស់នាងទាំងពីរឡើយ ពោលគឺនាងដើរតួបានយ៉ាងសក្តិសមជាអ្នកស្តាប់មួយដ៏សុក្រិត ។

នៅពេលដែលគេទាំងពីរនាក់និយាយចប់ *គីតូ* ក៏ថ្លែងសរសើរពីវីរភាពរបស់ពួកគេ និងពីសំនាងរបស់លោកម្ចាស់ *តូរ៉ាណាកា*។ពួកគេនៅនិយាយជាមួយគ្នាមួយរយៈទៀត ទើប *ភ្លាក់ថន* ងើបឡើង ហើយនារីបំរើម្នាក់ត្រូវបានគេហៅអោយមកជូនដំនើរគេទៅ ។

*ម៉ារីកូ* និយាយបំបែកភាពស្ងាត់ស្ងៀម :

- ពីមុនមកនាងមិនដែលញ៉ាំសាច់សត្វទេ *គីតូ-សាន* មែនទេ ?

- នេះជាភារកិច្ចរបស់ខ្ញុំដែលត្រូវធ្វើសព្វបែបយ៉ាងដើម្បីបំពេញចិត្តគាត់ យ៉ាងហោចណាស់ក៏មួយរយៈពេលខ្លីដែរ *ទេ* ?

- ខ្ញុំមិនដឹងថា នារីកំដរត្រូវតែឥតខ្មោះបែបនេះសោះ ។ អីលូវនេះខ្ញុំយល់ហើយថាហេតុអីចាំបាច់មានពិភពអណ្តែត មានពិភពដើមសូល ហើយមនុស្សប្រុសមានសំនាងបែបណា



www.budinst.gov.kh www.elibraryofcambodia.org

ហើយតើខ្ញុំនៅខ្វះខាតយ៉ាងណានោះ ។

- អូហ៎ ចាសទេ នេះមិនមែនជាគោលបំណងរបស់ខ្ញុំទេ ។ មិនមែនសោះតែម្តង *ម៉ារីតូ-សាម៉ា* ។ ហើយក៏មិនមែនជាបំណងរបស់ពួកយើងរាល់គ្នានេះក៏ទេដែរ ។ ពួកយើងនៅទីនេះ គឺដើម្បីការសប្បាយរីករាយតែប៉ុណ្ណោះ ដើម្បីពេលវេលាមួយបំភ្លេចភ្លេកតែប៉ុណ្ណោះ ។

- ពិតហើយ ។ ខ្ញុំចង់និយាយថា ខ្ញុំសរសើរនាងជាពន់ពេកណាស់ ។ ខ្ញុំចង់បាននាងជាប្អូនស្រីរបស់ខ្ញុំណាំ ។

*គីតូ* លំអោនខ្លួន :

- ខ្ញុំមិនសក្តិសមនឹងកិត្តិយសនេះទេ អ្នកស្រី ។

អ្នកទាំងពីរហាក់មានអារម្មណ៍កក់ក្តៅមួយជាមួយនឹងគ្នា ។ រួច *គីតូ* និយាយ :

- នេះគឺជាកន្លែងសំងាត់បំផុត ហើយមនុស្សដែលនៅទីនេះសុទ្ធតែជាមនុស្សទុកចិត្តបាន ។ គ្មានអ្នកលួចចាំឃ្លាំមើលទេ ។ បន្ទប់កំសាន្តនៅឯក្នុងសួនច្បារអាចងងឹតឈ្លប់បើសិនជាគេចង់ងងឹត ។ ហើយភាពងងឹតតែងរក្សាបាននូវរឿងសំងាត់ទាំងអស់បាន ។

- វិធីតែមួយដែលអាចរក្សាការណ៍សំងាត់បាន គឺនៅម្នាក់ឯង ហើយនិយាយរឿងសំងាត់នេះឱ្យបប្រាប់អណ្តូងទទេមួយនៅវេលាថ្ងៃត្រង់ជាក់ *នេ?*

*ម៉ារីតូ* ឆ្លើយតបយ៉ាងបែបវាហ៊ី ដោយនាងត្រូវការពេលវេលាដើម្បីរិះគិត ។

- រវាងបងប្អូនស្រី គ្មានអ្វីដែលចាំបាច់ត្រូវការអណ្តូងនោះទេ ។ ខ្ញុំបានបណ្តេញនារីបំរើរបស់ខ្ញុំរហូតដល់ភ្លឺហើយ ។ បន្ទប់កំសាន្តរបស់យើងជាកន្លែងសំងាត់ផ្ទាល់ខ្លួនបំផុត ។

- អ៊ីចឹងនាងអាចនៅតែម្នាក់ឯងជាមួយនឹងគាត់បានហើយ ។

- ខ្ញុំអាចនៅតែម្នាក់ឯងគ្រប់ពេល ។ គ្រប់ពេលវេលា ។

- នាងមានចិត្តល្អចំពោះខ្ញុំណាស់ *គីតូ-សាន* ។ នាងចេះគិតគូរណាស់ ។

- នេះជារាត្រីវេទមន្ត *នេ?* ហើយជារាត្រីយ៉ាងពិសេសបំផុត ។

- រាត្រីវេទមន្តឆាប់ចប់រហ័សណាស់ប្អូនស្រី ។ រាត្រីវេទមន្តសំរាប់ក្មេងៗ *នេ?* ខ្ញុំមិនមែនក្មេងទៀតទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- តើអ្នកណាអាចដឹងបានថា នឹងមានអ្វីកើតឡើងខ្លះក្នុងរាត្រីវេទមន្តនោះ? ភាពងងឹតតែងមានសព្វមានគ្រប់នៅក្នុងនោះ ។

*ម៉ារីកូ* គ្រវីក្បាលទាំងទុក្ខព្រួយ ហើយកាន់ដៃ *គីគូ* យ៉ាងថ្នាក់ថ្នម :

- ពិតមែនហើយ ។ តែចំពោះគាត់បើភាពងងឹតនោះមានរូបនាង នោះគឺមានសព្វមានគ្រប់មែន ។

*គីគូ* មិនចង់លើកពីរឿងនេះទៀតទេ ។ នាងក៏ពោលឡើង :

- រូបខ្ញុំគឺជាជំនួនសំរាប់ *អាន់ជីន-សាន* រឺ ? មិនមែនគាត់ចង់បានខ្ញុំដោយចិត្តគាត់ផ្ទាល់ទេរឺ ?

- បើសិនជាគាត់បានឃើញនាង តើគាត់អាចមិនសួររកនាងបានរឺ? តាមពិតទៅ នេះជាកិត្តិយសសំរាប់គាត់ណាស់ ដែលនាងបានស្វាគមន៍គាត់ ។អីលូវនេះខ្ញុំយល់ពីប្រការនេះហើយ ។

- តែគាត់បានឃើញខ្ញុំម្តងហើយតើ *ម៉ារីកូ-សាន* ។ កាលនោះខ្ញុំឈរនៅជាមួយ *អូមី-សាន* នៅពេលដែលគាត់ធ្វើដំណើរឡើងទូកទៅ *អូសាកា* ជាលើកដំបូងនោះ ។

- អឺចឹង ? តែ *អាន់ជីន-សាន* និយាយថាបានឃើញ *មីដូរី-សាន* ជាមួយ *អូមី-សាន* ទេវិញ ។ បើអីចឹងនោះគឺជារូបនាងទេ ? នៅក្បែរស្ពែងនោះណា ?

- ចាស នៅឯទីធ្លាភូមិនោះឯង ។ ចាស គឺពិតជាខ្ញុំមែន *ម៉ារីកូ-សាន* មិនមែនលោកស្រី *មីដូរី* ទេ ។គាត់ថែមទាំងនិយាយថា *កូនីជីក៉* ដាក់ខ្ញុំថែមទៀតផង ។ តែពិតហើយគាត់ច្បាស់ជាមិនចាំទេ ។ តើអោយគាត់ចាំម៉េចនឹងកើត ? នោះគឺនៅក្នុងជីវិតមុនរបស់គាត់ឯនោះ *នេ* ?

- អូហ៎ គាត់ចាំរូបនារីនោះណាស់... នារីដ៏ល្អប្រិមប្រិយម្នាក់ជាមួយ នឹងឆត្រពណ៌បៃតងមួយ ។គាត់និយាយថា នោះជានារីដ៏ស្អាតបំផុតដែលគាត់បានជួប ។ គាត់តែងនិយាយប្រាប់ខ្ញុំពីនារីនោះជាច្រើនលើក - *ម៉ារីកូ* សំលឹងពិនិត្យ *គីគូ* ជិតជាងមុនបន្តិចទៀត - ពិតហើយ *គីគូ-សាន* នាងងាយគេច្រលំជាមួយ *មីដូរី* ណាស់នៅក្រោមថ្ងៃបែបនោះ និង ពីក្រោមឆត្រ ។

*គីគូ* ចាក់ស្រោសាកេ ឯ *ម៉ារីកូ* វិញព្រលឹងនាងហាក់ត្រូវស្រូបដោយសំរស់ របស់នារីនេះទៅហើយ ។ *គីគូ* ពោលទាំងរីករាយដោយឃើញថា *ធ្លាក់ចន* នៅនឹកឃើញនាងដែរនោះ :



www.budinst.gov.kh www.elibraryofcambodia.org

- កាលនោះឆត្រខ្ញុំពណ៌ខៀវទឹកសមុទ្ទ ។

- តើកាលនោះ *អាន់ជីន-សាន* រាងយ៉ាងម៉េចទៅ ? ខុសគ្នាឆ្ងាយណាស់ទៅរឺ ? រាត្រីសំរែកពិតជាគួរអោយរន្ធត់ណាស់មើលទៅ ។

- ចាស ចាស ពិតមែនហើយ ។ ហើយកាលនោះគាត់ចាស់ជាងពេលនេះ ។ ស្បែកមុខគាត់ឡើងយាកតែម្តង... តែពួកយើងដូចជាម៉ឺងម៉ាត់សាច់ការហួសហេតុពេកហើយបងស្រី ។អ្នកបងមិនដឹងថា តើខ្ញុំមានកិត្តិយសប៉ុនណាទេ ដែលបានអនុញ្ញាតអោយខ្ញុំហៅបែបនេះ ។ យប់នេះជាយប់សំរាប់សប្បាយរីករាយតែមួយមុខគត់ ។ លែងនិយាយរឿងសាច់ការទៀត *រេ* ?

- ចាស ខ្ញុំយល់ព្រម ។ សូមអភ័យទោសដល់ខ្ញុំផងចុះ ។

- អ៊ីលូវនេះនិយាយពីរឿងជាក់ស្តែងម្តង ខ្ញុំចង់អោយអ្នកបងជួយផ្តល់ដំបូន្មានខ្លះៗដល់ខ្ញុំផងបានទេ ?

- ស្អីក៏បានដែរ - *ម៉ារីកូ* ឆ្លើយយ៉ាងស្និទ្ធស្នាល ។

- ក្នុងរឿងខ្នល់ខ្មៅយ តើអ្នកបងមានដឹងថា ជាតិសាសន៍គាត់មានចូលចិត្តឧបករណ៍អ៊ីរឹក្សាច់អីទេ ? សូមទោសដែលសួរសំនួរនេះ តែប្រហែលជាអ្នកបងអាចជួយណែនាំខ្ញុំបានខ្លះ ។

*ម៉ារីកូ* ត្រូវប្រើអស់ការហាត់រៀនរបស់នាង ដើម្បីមិនបង្ហាញភាពភ្ញាក់ផ្អើលរបស់នាងៈ

- ទេ បើតាមខ្ញុំដឹង ។ *អាន់ជីន-សាន* ឆាប់ញ្ញោចណាស់ នឹងរាល់រឿងទាំងឡាយដែលទាក់ទិន នឹងរឿងខ្នល់ខ្មៅយនេះ ។

- តើយើងអាចសួរគាត់របៀបបញ្ឆិតបញ្ឆៀងបានទេ ?

- ខ្ញុំគិតថា នាងមិនអាចសួរមនុស្សអ្នកក្រៅបែបនេះបានទេ ។ ពិសេស *អាន់ជីន-សាន* ។ ហើយ... អោយខ្ញុំសូមទោសទៅចុះ ខ្ញុំមិនដឹងថា... ថាឧបករណ៍នោះស្អីផង...លើកលែងតែ *ហារីកាតា* ប៉ុននោះ ។

- អ៊ីចឹង ? - ជាថ្មីម្តងទៀត វិញ្ញាណរបស់នាងជាអ្នកនាំផ្លូវ ។ នាងសួរឡើងយ៉ាងប៉ិនប្រសប់ - តើអ្នកបងចង់ឃើញឧបករណ៍ទាំងនោះទេ ? ខ្ញុំអាចបង្ហាញរបស់ទាំងអស់នោះជូនអ្នកបងមើល ហើយអាចដោយមានគាត់ជាមួយផង ។ ដល់អ៊ីចឹង យើងមិនបាច់សួរគាត់ផង ។



www.budinst.gov.kh www.elibraryofcambodia.org

គ្រាន់តែឃើញប្រតិកម្មគាត់ យើងអាចដឹងបានហើយ ។

*ម៉ារីកូ* អេះអុញ តែចិត្តចង់ដឹងបានគ្របដណ្តប់លើចិត្តវិនិច្ឆ័យរបស់នាង ។

- បើដើម្បីសប្បាយកំប្លែងលេង ថា...

ពួកគេលឺ *ឡាក់ថុន* ដែលវិលត្រលប់មកវិញ ។ *គីគូ* ស្វាគមន៍ការវិលត្រលប់វិញរបស់គេ ហើយចាក់ស្រាជូន ។ *ម៉ារីកូ* លើកពែងរបស់នាងក្បើយអស់តែមួយក្អឹក ក្នុងចិត្តនាងសែនរីករាយ ដោយនាងមិននៅតទល់តែម្នាក់ឯងជាមួយ *គីគូ* ទៀត ដោយនាងមានអារម្មណ៍យ៉ាងរសាប់រសល់ថា នារីនេះពិតជាអាចមើលគំនិតនាងធ្លុះបាន ។

ពួកគេបន្តជជែកគ្នាពីនេះពីនោះ និងលេងល្បែងនេះនោះមួយសន្ទុះ ទើបនៅពេលដែលនាងយល់ឃើញថា ពេលវេលាសមគួរហើយនោះ *គីគូ* ស្នើដល់ភ្ញៀវនាងក្រែងពួកគេចង់មើលសួនច្បារ និងបន្ទប់កំសាន្ត ។

ពួកគេដើរចេញទៅក្នុងស្បៃរាត្រី ។ សួនច្បារដែលនៅមានជាប់តំនក់ទឹកភ្លៀងនៅឡើយ បានជះពន្លឺផ្លេក១ដោយចាំងនឹងពន្លឺចន្ទ្រ ។ ផ្លូវដើរបត់បែនតាមថ្លុកទឹកតូចមួយ និងកន្លែងទឹកធ្លាក់មួយដែលបញ្ចេញសូរស្រាល១ ។ នៅចុងផ្លូវ គឺជាកូនផ្ទះមួយដែលនៅដាច់តែឯងក្នុងបុសរឹស្សី ។ ផ្ទះនេះសង់លើដីទូលមួយដែលជិះយ៉ាងស្អាតមានជណ្តើរបួនកាំ ហើយមានរានហាលនៅពទ្ធ័ជុំវិញ ។ អ្វី១ដែលមាននៅក្នុងបន្ទប់ទាំងពីរនៃកូនផ្ទះនេះ គឺសុទ្ធតែមានតំលៃ និងប្រណិតទាំងអស់ ។ ឈើសាច់ល្អបំផុត ព្រំល្អបំផុត កំរាលល្អបំផុត ម៉ក់សូតល្អបំផុត ហ៊ុំងបូជាក៏មានព្យួររបស់ល្អបំផុតដែរ ។

*ម៉ារីកូ* លាន់មាត់ :

- ទាំងនេះគួរអោយស្រលាញ់មែន *គីគូ-សាន* ។

- ផ្ទះតែនៅ *មីស៊ីម៉ា* ល្អជាងនេះ *ម៉ារីកូ-សាន* ។ សូមអង្គុយអោយបានស្រួលចុះ *អាន់ជីន-សាន* ! Per favor តើលោកពេញចិត្តកន្លែងនេះទេ *អាន់ជីន-សាន* ?

- ពេញចិត្ត ។ ពេញចិត្តណាស់ ។

*គីគូ* ឃើញថាគេនៅតែរីករាយចំលែកចិត្តនឹងរាត្រីនេះ ហើយនឹងសាកេ តែអារម្មណ៍



www.budinst.gov.kh www.elibraryofcambodia.org

របស់គេនៅផ្ដោតទាំងស្រុងលើ *ម៉ារីកូ* ដដែល ។ នាងចង់តែងើបចេញ ហើយដើរទៅបាត់តែម្ដង។ តែបើនាងធ្វើបែបនេះ នាងដឹងថានាងរំលោភច្បាប់ហើយ ។ លើសពីនេះទៀត នាងមានអារម្មណ៍ថាបើនាងធ្វើយ៉ាងដូចនេះ គឺជាការមិនទទួលខុសត្រូវពេញបន្ទុក ព្រោះនៅក្នុងជំរៅនៃដួងចិត្តនាង១ដឹងថា *ម៉ារីកូ* កំពុងត្រៀមខ្លួនស្រេចទៅហើយ១លែងរវល់ពីអ្វីទាំងអស់ថែមទៀត ។

ទេ - នាងគិតនៅក្នុងចិត្ត - អញមិនធ្វើអោយនាងស្ថិតនៅក្នុងការបើកមុខដ៏គួរអោយខ្មាសនេះទេ ម្យ៉ាងទៀតនេះអាចមានតំលៃសំរាប់អនាគតរបស់អញផង ។ អញធ្វើជាអញ្ជើញនាង ពេលនោះ *ម៉ារីកូ* ត្រូវប្រកែកយកគួរ ។ ធ្វើបែបនេះគឺវាងវៃជាង ។ តើពួកគេជាគូសង្សារគ្នាឬ ? អញមិនដឹងទេ ។ នេះជា *កាម៉ា* របស់ពួកគេចុះ ។

នាងលោខ្លួនទៅមុខ ហើយសើចរបៀបដឹងរឿងជាមួយគ្នា :

- អ្នកបង សូមសួរទៅ *អាន់ជីន-សាន* ថា នៅទីនេះមានឧបករណ៍សំរាប់ខ្វល់ខ្វាយមួយចំនួន ។ តើគាត់មានឧបករណ៍ទាំងនេះនៅស្រុកគាត់ ឬទេ ?

- គាត់ថាទេ *តីតូ-សាន* ។ គាត់ថាសូមទោស គាត់មិនដែលលឺរឿងនេះទេ ។

- អីចឹង ? តើគាត់ចង់មើលអោយសប្បាយភ្នែកទេ ? ឧបករណ៍ទាំងនោះនៅឯបន្ទប់ម្ខាងទៀត ខ្ញុំអាចយកវាមកបង្ហាញបាន ។ គួរអោយស្រើបស្រាលនឹងមើលវាដែរ ។

- តើលោកចង់មើលរបស់ទាំងនោះទេ *អាន់ជីន-សាន* ? នាងថាសប្បាយភ្នែកនឹងមើលវាដែរ ។

- មើលក៏មើល ។

*ប្លាក់ថន* ឆ្លើយតប ។ បំពង់ករបស់គេឡើងល្ហួត ខ្លួនប្រាណរបស់គេទាំងមូលញាប់ញ័របណ្ដាលមកពីក្លិនក្រអូប ហើយនឹងធាតុផ្ទុយដែលនៅជិតគេនេះ ។ គេសួរបន្ត :

- នាង... នាង... ប្រើឧបករណ៍សំរាប់រឿងខ្វល់ខ្វាយជាមួយគ្នា ?

- *តីតូ-សាន* និយាយថាម្ដងម្កាល *អាន់ជីន-សាន* ។ នាងនិយាយថា ហើយនេះជាការពិត ប្រពៃណីរបស់យើងគឺអូសបន្លាយរយៈពេល « ពពកនិងភ្លៀង » ព្រោះយើងយល់ថាក្នុងរយៈមួយភ្លែតនោះឯង ដែលយើងជាមនុស្សអាចរលាយខ្លួនមួយជាមួយនឹងទេវតាបាន - *ម៉ារី*



www.budinst.gov.kh www.elibraryofcambodia.org

*ក្វ* និយាយបណ្ដើរសង្កេតមើលទឹកមុខ *ភ្វាក់ថុន* បណ្ដើរ - ដោយហេតុនេះហើយ គឺជាការសំខាន់ណាស់ដែលត្រូវធ្វើអោយខណៈនេះកាន់តែអូសបន្លាយយូរកាលណាល្អកាលនោះ *វេ* ? នេះគឺស្ទើរតែជាភារកិច្ចមួយ *វេ*?

- ពិតហើយ ។

- ចាស នាងនិយាយថា វលោយសាច់មួយជាមួយទេវតា គឺជាសារវន្ត ។ នេះជាជំនឿមួយដ៏ល្អ ហើយអាចធ្វើទៅបាន ។ តើលោកជឿទេ ? អារម្មណ៍ភ្លៀងដូចគេហែកមេឃ គឺដូចជារបស់ឋានសួគ៌ និងជាអារម្មណ៍របស់ទេវតា ។ តើមែន រឺទេ ។

- ពិតហើយ ។ បាទ ពិតហើយ ។

- លោកត្រូវការសាកេទៀតទេ *អាន់ជីន-សាន* ?

- បាទ អរគុណ ។

*ម៉ារីកូ* បក់ផ្ចិតបណ្ដើរ និយាយបណ្ដើរ :

- រឿង « ភ្លៀងដូចគេហែកមេឃ »« ពពកនិងភ្លៀង » រឺក៏ « ភ្លើងនិងទឹកជ្រោះ » ដែលជូនកាលយើងហៅវានេះ គឺជាលក្ខណៈជប៉ុនសុទ្ធសាធ *អាន់ជីន-សាន*។ ជាការសំខាន់ណាស់ដែលត្រូវជាជប៉ុននៅក្នុងរឿងខ្ពស់ខ្ពើយនេះ មែនទេ *អាន់ជីន-សាន ?*

នាងចូរទ្រូងសន្ទឹកនៅពេលដែលឃើញ *ភ្វាក់ថុន* ញាក់មុខ ហើយលំអោនខ្លួនដាក់នាង:

- បាទមែន ។ សំខាន់មែនទែន ។ ខ្ញុំជាជប៉ុនណា *ម៉ារីកូ-សាន* ! *ហុនតូ* !

*គីកូ* ត្រលប់មកវិញដោយយូរទាំងប្រអប់ពាសសូតមួយមកជាមួយផង ។ នាងបើកប្រអប់នេះឡើង ហើយយកអង្គជាតិមួយធ្វើពីភ្លុក ប៉ុនរបស់មែន១ និងមួយទៀតធ្វើពីរបស់ម្យ៉ាងទន់យឺត ដែលមួយជីវិតនេះ *ភ្វាក់ថុន* មិនដែលបានឃើញឡើយ ។ *គីកូ* បោះរបស់នេះទៅម្ខាង ។

*ម៉ារីកូ* និយាយពន្យល់ ដោយឥតរវល់នឹងរបស់ទាំងពីរនេះទេ ព្រោះភ្នែកនាងកំពុងតាមមើលរបស់ផ្សេងទៀត :

- នេះគ្រាន់តែជា *ហារីកាតា* ធម្មតាតែប៉ុននោះទេ *អាន់ជីន-សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

- ម៉ែ អើ្ហយ ធម្មតាហើយណឹង ?

- ចាស អានេះជា *ហារីកាតា* ធម្មតាទេតើ ។ អានេះច្បាស់ជានារី១ នៅស្រុកលោក មានដែរហើយ !

- ទេ ច្បាស់ជាអត់តែម្តង ! ពួកស្រី១ស្រុកខ្ញុំអត់មានអារបស់ណឹងទេ ។

គេនិយាយដោយទៅចាំថា អ្វី១ស្ថិតនៅក្នុងការសើចលេងសប្បាយ ។

*ម៉ារីក្ខ* សឹងមិនជឿអ្វីដែលនាងលឺឡើយ ។ នាងពន្យល់រឿងនេះទៅ*គីតូ* ដែលភ្ញាក់ផ្អើលដូចរូបនាងដែរ ។ *គីតូ* និយាយយ៉ាងវែង *ម៉ារីក្ខ* ងក់ក្បាលឯកភាព :

- *គីតូ-សាន* និយាយថា នេះចំជាចំលែកពេកណាស់ ។ ហើយខ្ញុំក៏ឯកភាពជាមួយនាងដែរ *អាន់ជីន-សាន* ។ នៅទីនេះនារីស្ទើរគ្រប់រូបប្រើវាដើម្បីបន្ធូរខ្លួនធម្មតាដោយមិនមានគំនិតអីផ្តេសផ្តាសនោះទេ ។ តើធ្វើយ៉ាងម៉េចអោយនារីមានសុខភាពល្អ បើនាងត្រូវខាឃាំងគំហិតឯមនុស្សប្រុសហួតកន្លះលែងនោះ ? លោកច្បាស់ហើយណឹង *អាន់ជី-សាន* ? មិនមែនលោកលលេងពួកយើងទេរី ?

- ទេ... ខ្ញុំ... អឺ... ខ្ញុំច្បាស់ណាស់ថា ស្រីស្រុកខ្ញុំអត់មានអាណឹងទេ ។ មានអីចឹងមុខជា... មុខជា... អឺ... គឺថាស្រី១ស្រុកខ្ញុំគ្មានតែម្តង ។

- អត់របស់ទាំងនេះ ជីវិតច្បាស់ជាយ៉ាប់មែនទែនហើយ ។ យើងមានពាក្យពំនោលថា *ហារីកាតា* ប្រៀបដូចជាបុរសតែល្អជាងបុរស ព្រោះវាដូចផ្នែកដែលល្អបំផុតរបស់មនុស្សប្រុសដោយមិនមានផ្នែកអាក្រក់ជាប់មកជាមួយផង ។ *នេ* ? ហើយវាល្អជាង ព្រោះមិនមែនមនុស្សប្រុសទាំងអស់សុទ្ធតែ... មិនមែនសុទ្ធតែល្អមដូច *ហារីកាតា* នោះទេ ។ ម្យ៉ាងទៀតវាស្មោះត្រង់រហូត *អាន់ជីន-សាន* វាមិនដែលនឿយណាយធុញទ្រាន់នឹងយើងដូចប្រុស១នោះទេ ។ ហើយមួយទៀតដែរ គឺវាអាចរឹង រឺទន់... *អាន់ជីន-សាន* លោកបានសន្យាហើយណោ លោកចាំទេ ? នេះដើម្បីសប្បាយកំប្លែងលេង !

- ត្រឹមត្រូវហើយ - *ភ្ញាក់ផ្អើល* ញាក់មុខ - នាងពិតជានិយាយត្រូវ ។ អោយខ្ញុំសូមទោស ។



www.budinst.gov.kh www.elibraryofcambodia.org

គេចាប់យក *ហារីកាតា* ហើយពិនិត្យពិច័យវាយ៉ាងម៉ត់ចត់បណ្តើរ ហូចតែពីសតែពាស បណ្តើរ ។ រួចគេលើកវាឡើងលើ :

- នាងនិយាយថាម៉េចអំបាញ់មិញ អ្នកគ្រូ - *សាន* ! វាអាចរឹងអីចឹង ?

- ចាស - នាងតបយ៉ាងរីករាយ - វាអាចរឹង រឺទន់ល្មើយតាមយើងចង់ ហើយជាពិសេស *ហារីកាតា* ធន់បានយូរជាងមនុស្សប្រុសគ្រប់រូប ហើយវាមិនចេះសឹកផង !

- អូហ៍ អានេះហើយជាចំនុចសំខាន់ !

- ចាស សូមកុំភ្លេចថា មិនមែននារីគ្រប់រូបសុទ្ធតែមានសំនាងបានប្តីខ្លាំងក្លានោះទេ។ បើសិនជាគ្មានរបស់អស់នេះដើម្បីជួយបន្ធូរតណ្ហាសាមញ្ញ និងតំរូវការជាធម្មតាទេនោះ នារី១ ធម្មតានឹងមានជាតិពុលនៅក្នុងខ្លួន ហើយមិនយូរមិនឆាប់វានឹងបំផ្លាញភាពសុខដុមរមនារបស់នារី ហើយនេះនឹងធ្វើអោយប៉ះពាល់ដល់នារីនោះផង ដល់អ្នកដែលនៅជុំវិញនាងផង។ នារីមិនមានសេរីភាពដូចបុរសនោះទេ *នេ* ? ពិភពលោកជារបស់បុរស ហើយជាការត្រឹមត្រូវ *នេ* ?

*ប្លាក់ថន* ញញឹម :

- ត្រូវផង ខុសផង ។

- សូមទោស តែខ្ញុំអាណិតនារី១ស្រុកលោកណាស់ ។ ពួកគេត្រូវតែដូចពួកយើងដែរ ។ ពេលលោកត្រលប់ទៅស្រុកវិញ លោកត្រូវតែបង្រៀនពួកនារីស្រុកលោកណា៎ *អាន់ជីន-សាន* ។ អូហ៍មែនហើយ លោកត្រូវទូលមហាក្សត្រីយ៍លោកទៅ ព្រះអង្គនឹងយល់យល់ជាមិនខាន ។ ពួកយើងញ្ញោចណាស់រឿងខ្វល់ខ្វាយនេះ ។

- ខ្ញុំនឹងទូលព្រះមហាក្សត្រីយ៍ខ្ញុំ-គេដាក់ *ហារីកាតា* ទៅម្ខាង-រួចមានអីទៀត ?

*គីគូ* យកដុំថ្មយក់(Jade) មូល១បួនដុំ ពណ៌ស ហើយដែលចងភ្ជាប់គ្នាដោយខ្សែសូតមួយខ្សែចេញមក ។ *ម៉ារីកូ* ស្តាប់យ៉ាងយកចិត្តទុកដាក់នូវការពន្យល់របស់ *គីគូ* ភ្លែកនាងបើកត្រលួងសំលឹងមើលខ្សែថ្មយក់ថ្លាំង ដៃនាងបក់ផ្ចិតរន្ទាន់ :

- របស់នេះហៅថា *កូណូមី-ស៊ីនជូ* គឺតជីរករាយ ហើយមនុស្សប្រុសស្រីអាចប្រើវាបានដូចគ្នា ។ សាកេទៀត *អាន់ជីន-សាន* ?



www.budinst.gov.kh www.elibraryofcambodia.org

- អរគុណ ។

- ចាស ទាំងបុរស ទាំងនារីអាចប្រើវាបានដូចគ្នា ហើយគ្រាប់នេះគេដាក់នៅទ្វារក្រោយ ។ ក្នុងពេលពពកនិងភ្លៀង គេទាញគ្រាប់នេះម្តងមួយៗ យឺតៗចេញមក ។

- ចាំម៉េច ?

*ម៉ារីកូ* ដាក់ខ្សែថ្នាំយក់នៅលើម៉ិក :

- ចាស *គីកូ-សាន* និយាយថាពេលវេលាសំខាន់ណាស់ ។ ហើយនេះត្រូវតែ... ខ្ញុំមិនដឹងជាលោកហៅរបស់នោះថាម៉េចទេ អូហ៍មែន ត្រូវប្រើប្រេងរំអិលដើម្បីស្រួល *អាន់ជីន-សាន* - នាងសំលឹងមើលគេរួចពោលបន្ថែម-នាងនិយាយថែមទៀតថា គជីរីកភាយនេះ មានធំមានតូច ហើយប្រើវាត្រឹមត្រូវវានឹងនាំអោយមានលទ្ធផល យ៉ាងរហ័សជាមិនខាន ។

*ប្លាក់ថន* សើចលាន់ខ្ទរ ហើយនិយាយតតាក់តតុបជាអង់គ្លេស :

- អញភ្នាល់ស្រាបៀរមួយធុងជាមួយអាចម៍ជ្រូកមួយដុំ បើមានអ្នកណាជឿ ។

- សូមទោស *អាន់ជីន-សាន* ខ្ញុំស្តាប់អត់យល់ទេ ។

នៅពេលដែលគេនិយាយចេញបានវិញហើយ ទើបគេនិយាយពន្យល់ជាភាសាបិកទុយកាល់ :

- ខ្ញុំភ្នាល់មាសប៉ុនភ្នំជាមួយនឹងស្មៅមួយកងថា លទ្ធផលពិតជាអស្ចារ្យ *ម៉ារីកូ-សាន*។

គេចាប់យកថ្នាំយក់មកពិនិត្យ :

- អាណឹងរឹតជីរីកភាយនោះ ? -បន្តិចក្រោយមកគេដាក់វាចុះវិញ-រួចមានអីទៀតទេក្នុងនោះ ?

*គីកូ* សប្បាយចិត្តជាពន់ពេក ដែលពិសោធន៍របស់នាងបានទទួលជោគជ័យនេះ។ បន្ទាប់មកទៀត នាងយកមកបង្ហាញគ្រឿងនូវ *ហ៊ីមីគស៊ូ-កាវ៉ា*រីស្បែកសំងាត់ :

- នេះគឺជាកងរីកភាយ *អាន់ជីន-សាន* ។ មនុស្សប្រុសពាក់វាដើម្បីអោយនៅតែរឹងពេលណាដែលគេអស់កំលាំងហើយនោះ។ *គីកូ-សាន* និយាយថាប្រើរបស់នេះ បុរសនៅអាចអោយវង្វាន់ទៅនារីបាន ទោះខ្លួនបានដល់ទីសុខក្តី រឺមួយក៏ពេលខ្លួនអស់ចំនង់ហើយក្តី - *ម៉ារីកូ*



www.budinst.gov.kh www.elibraryofcambodia.org

សំលឹងមើល *ភ្លាក់ថន - នេ?*

- ពិតហើយ ។ ព្រះអើយ សូមកុំអោយខ្ញុំយ៉ាប់យ៉ឺនដល់ថ្នាក់នេះ តែសូមប្រាប់ទៅ *គីតូ* អោយទិញអោយខ្ញុំបីផង ក្រែងលោយ៉ាងម៉េច១ !

បន្ទាប់មកទៀត *គីតូ* បង្ហាញ *ហ៊្គី-តុមប៊ី* រីអារុចអ្នកខ្សោយ ដែលជាសំបករុក្ខជាតិហាលស្ងួត ដែលនៅពេលណាដែលគេត្រាំទឹក ហើយយកវាមករុំនឹងផ្នែកពិសេសរបស់ ខ្លួននោះ វាធ្វើអោយរីកប៉ោងឡើង ហើយហាក់ខ្លាំងឡើង។ រួចមានថ្នាំគ្រប់ប្រភេទសំរាប់បំរើការរីករាយ មានតាំងពីថ្នាំបង្កើន រហូតដល់បន្ថយតណ្ហា ហើយមានគ្រប់ប្រេង : ប្រេងសំរាប់ រំអិល ប្រេងសំរាប់អោយប៉ោង សំរាប់អោយរឹង ។

*ភ្លាក់ថន* កាន់តែភ្ញាក់ភ្លាយថែមទៀត :

- អត់មានអាអោយខ្សោយទេ ?

- ចាសទេ *អាន់ជីន-សាន* នេះផ្ទុយនឹងធម្មជាតិហើយ ។

រួច *គីតូ* នៅបង្ហាញឧបករណ៍សំរាប់ការរីករាយជាច្រើនមុខទៀតសំរាប់បុរស :

- *គីតូ-សាន* និយាយថា ជាមួយឧបករណ៍មួយណាក៏ដោយក្នុងចំនោមនេះក៏អាចធ្វើអោយនារីដែលអៀនបំផុតក្លាយទៅជាសេះដាច់បង្ហៀរបានដែរ ។

ឱ ព្រះអើយ ខ្ញុំចង់ឃើញនាងដាច់បង្ហៀរដល់ហើយ គេសួរបន្ត :

- តែនេះសំរាប់តែបុរស១ទេ មែនទេ? ។

*ម៉ារីកូ* តប :

- នារីកាន់តែមានសំរើប ការរីករាយរបស់បុរសក៏រឹតតែខ្លាំងក្លាកាលនោះដែរ *នេ* ? ជាការពិតហើយ ផ្តល់នូវការរីករាយដល់នារីក៏ជាភារកិច្ចរបស់បុរសផងដែរមិនអីចឹង ? តែបើសិនជាបុរសស៊ិយស្សៀវប្រដាប់តូច រឺខ្សោយ រឺចាស់ រឺហត់គ្មានកំលាំង គេនៅតែអាចធ្វើអោយនារីមានការរីករាយបានក្នុងកិត្តិយសអាស្រ័យដោយឧបករណ៍ណាមួយក្នុងនេះ ។

- នាងដែលប្រើរបស់នេះទេ *ម៉ារីកូ-សាន ?*

- ទេ *អាន់ជីន-សាន* តាំងពីដើមមកខ្ញុំមិនដែលឃើញរបស់អស់ទាំងនេះទេ ។ របស់



www.budinst.gov.kh www.elibraryofcambodia.org

នេះសំរាប់... គឺថា ប្រពន្ធមិនមែនសំរាប់ការរីករាយនោះទេ តែគឺសំរាប់ពពោះ មើលកូនចៅ និង ថែផ្ទះសំបែងតែប៉ុននោះ ។

- បើអីចឹងប្រពន្ធមិនត្រូវសង្ឃឹមរង់ចាំទទួលភាពរីករាយទេអី ?

- ចាស ។ ព្រោះបើមិនអីចឹងមិនប្រក្រតីឡើយ ។ រឿងអីចឹង១គឺសំរាប់តែនារី១នៃពិភពដើមសួលតែប៉ុននោះ ។

*ម៉ារីកូ* បក់ផ្លិត ហើយនិយាយពន្យល់ទៅ*គីកូ* នូវអ្វីដែលគេបាននិយាយ :

- នាងនិយាយថា នេះក៏ច្បាស់ជាដូចនៅប្រទេសលោកដែរ មែនទេ ? គឺភារកិច្ចរបស់បុរសត្រូវបំពេញការសប្បាយរបស់នារី ដូចជាភារកិច្ចរបស់នារីដែលត្រូវផ្តល់ការសប្បាយទៅអោយបុរសដែរ ។

- សូមទោសទៅចុះ សូមប្រាប់នាងថា នៅស្រុកខ្ញុំមិនដូចគ្នានឹងទីនេះទេ ។ គឺផ្ទុយទៅវិញទេ ។

- នាងនិយាយថា មិនល្អទេ ។ សាកេទៀតទេ ?

- សូមជំរាបនាងថា គេបានបង្ហាត់យើងអោយរៀនខ្មាសនឹងរាងកាយយើង អោយរៀនខ្មាសនឹងរឿងខ្ពល់ខ្ពើយ ហើយនឹងភាពអាក្រាត និង... ហើយនឹងរឿងឆ្អួត១ទាំងសព្វទាំងគ្រប់ ។ ទើបតែមកដល់ទីនេះទេ ដែលធ្វើអោយខ្ញុំមើលឃើញពីរឿងទាំងនេះ ។ អីលូវនេះពេលដែលខ្ញុំមាន អារ្យធម៌បន្តិចហើយនោះ ទើបខ្ញុំមានការយល់ដឹងប្រសើរជាងមុន ។

*ម៉ារីកូ* បកទៅអោយ*គីកូ* ។ *ធ្លាក់ថន* ភ្លើយពែងស្រារបស់គេបង្ហើយ ។ *គីកូ* ឈោងចាក់ស្រាបំពេញវិញភ្លាម ដោយយកដៃឆ្វេងនាងទប់ដៃស្តាំរបស់នាងកុំអោយប៉ះគុខ្នុកម្រ័ក្សក្នុងពេលដែលដៃស្តាំនាងកាន់ចូចាក់ស្រានោះ ។

- *ដូម៉ូ* ។

- *ដូ អ៊ីតាស៊ីម៉ាស៊ីតេ អាន់ជីន-សាន* ។

- *គីកូ-សាន* និយាយថា ពួកយើងទាំងអស់គ្នាមានកិត្តិយសណាស់ដែល *អាន់ជីន-សាន* មានប្រសាសន៍បែបនេះ ។ខ្ញុំឯកភាពតាមសំដីរបស់នាង ។ លោកបានធ្វើអោយខ្ញុំមានមោទនភាព



www.budinst.gov.kh www.elibraryofcambodia.org

ជាពន់ពេក។ ថ្ងៃនេះ ខ្ញុំសែនមានមោទនភាពចំពោះរូបលោក ។ តែគិត១ទៅ អ្វី១មិនជាអាក្រក់ដូចដែលលោកបានពោលនោះពេកទេ ។

- អាក្រក់ជាងទៅទៀត ។ អានេះពិបាកយល់ណាស់ បើសិនជាពួកនាងមិនដែលនៅទីនោះ រឺកើតឡើងនៅទីនោះ ។ នាងដឹងទេ និយាយតាមពិតទៅ...

គេឃើញនារីទាំងពីរសំលឹងមើលមុខគេផ្ទាំង រង់ចាំយ៉ាងខន្តី យ៉ាងចំរុះពណ៌ យ៉ាងស្អាតឆ្នងគួរអោយស្រលាញ់ នៅក្នុងបន្ទប់មួយដែលមានការរៀបចំយ៉ាងគ្រប់គ្រាន់និងយ៉ាងមានរបៀប ។ ភ្លាម១នោះអារម្មណ៍របស់គេចាប់ផ្ដើមធ្វើការប្រៀបធៀបទៅនឹងផ្ទះអង់គ្លេស របស់គេដែលមានភាពស្និទ្ធស្នាល កក់ក្ដៅ លើដីក្រាលចំបើង មានផ្សែងហុយទ្រលោមតាមប្រហោងជំបូល។ នៅក្នុងភូមិរបស់គេទាំងមូលមានតែផ្ទះបីដែលជារបស់អ្នកមានទ្រព្យទេ ដែលមានបំពង់ផ្សែង ។ ក្នុងផ្ទះគេមានបន្ទប់ដេកតូច១ពីរហើយនឹងបន្ទប់ធំមួយដ៏អត់សណ្ដាប់ធ្នាប់ សំរាប់ហូបចុក ស្លស្លុក ជួបជុំនិងជជែកគ្នា ។ គេដើរចូលទៅក្នុងផ្ទះទាំងពាក់ស្បែកជើង ខែក្ដៅក៏ដូចខែរងា មិនខ្វីរវល់រឿងជាន់ភក់ មិនខ្វីរវល់រឿងជាន់អាចម៌ លើតុរញ៉េរញ៉ៃដូចក្នុងបន្ទប់ដេកឆ្កែបីបួន ក្មេងពីរ មួយជាកូនប្រុសរបស់គេ មួយទៀតជាកូនស្រីរបស់ខ្មោចបងប្រុសគេឈ្មោះ *អាកចូ* ដែលរត់ប្រលែងគ្នាដូលច្រងាប់ច្រងិល ។ *កេលីស៊ីទី* កំពុងដាំស្ល ក្នុងសំពត់វែងអូសដល់ដីស្រីបំរើមួយដែលជង្គក់ ហើយនៅទទើសទទែង និង *ម៉ារី* ប្រពន្ធរបស់ *អាកចូ* ដែលនៅក្អកគឃូសក្នុងបន្ទប់ក្បែរនោះដែលគេបានសង់ឡើងសំរាប់នាង ។

*កេលីស៊ីទី* ! *កេលីស៊ីទី* ប្រពន្ធសំលាញ់បងអើយ ។ ប្រហែលមួយខែម្ដងទើបមុជទឹកហើយតែក្នុងរដូវក្ដៅទៀត ។ មុជនៅក្នុងធុងស្អាន់យ៉ាងសំងាត់។ តែនាងលាងមុខ និងដៃជើងរាល់ថ្ងៃ ហើយពេញមួយឆ្នាំគ្រលុំខ្លួនជិតតែក្នុងខ្សៀន ដែលរាប់ខែ រឺមួយឆ្នាំបានបោកទឹកម្ដង ធុំក្លិនផ្ទុះដូចអ្នកផង ចៃពេញខ្លួនដូចអ្នកផង អេះអោយរញ៉ៃដូចអ្នកផងដែរ ។

ក្រៅពីនេះ នៅមានជំនឿ និងអបិយជំនឿដ៏លេលារាប់មិនអស់ថែមទៀត ។ ស្អាតពេកឆាប់ងាប់ បើកបង្អួចអាចងាប់ ទឹកអាចធ្វើអោយឆាប់ងាប់ ហើយនាំកើតជំងឺប៉េស រឺអាសន្នរោគផ្សេង១ ហើយថាចៃ សង្កើច រុយ រោគនានា គឺជាការផ្ដន្ទារបស់ព្រះជាម្ចាស់ទៅលើបាបកម្ម



www.budinst.gov.kh www.elibraryofcambodia.org

នានានៅលើផែនដីនេះទៅវិញ ។

សម្ដេច រុយ ចំបើង រាល់រដូវក្ដៅ ប៉ុន្តែរាល់ថ្ងៃត្រូវទៅវិហារ ហើយថ្ងៃអាទិត្យត្រូវទៅពីរដងថែមទៀត ដើម្បីទៅស្ដាប់បន្ទូលព្រះជាម្ចាស់សំពងលើក្បាល : គ្មានអ្វីសំខាន់ទេ មានតែព្រះជាម្ចាស់ និងការជួយសង្គ្រោះរបស់ព្រះអង្គ ។

កើតឡើងក្នុងបាបធម៌ រស់នៅក្នុងក្ដីអាម៉ាស់ ជាសាច់ជាឈាមរបស់បិសាចត្រូវទទួលវាសនាចុះនរក សូត្រធម៌ដើម្បីព្រះជាម្ចាស់ជួយសង្គ្រោះ និងប្រណីទោសអោយ ។ *កេលីស៊ីទី* ជានារីគោរពធម៌អាថ៌យ៉ាងខ្ជាប់ខ្ជួន ហើយក្នុងចិត្តគំនិតរមែងពោរពេញដោយការភ័យខ្លាចព្រះជាម្ចាស់ និងការធ្វើទុក្ខបុកម្នេញរបស់បិសាច អារម្មណ៍ភ័យព្រួយខ្លាចមិនបានឡើងឋានសួគ៌ ។ នាងចាស់ទាំងអាយុនៅក្មេង រូបអាក្រក់ទាំងនៅក្មេងហើយជិតស្លាប់ទាំងនៅក្មេង ។ *កេលីស៊ីទី* អីលូវនេះអូនមានអាយុម្ភៃប្រាំបួនឆ្នាំ តែសក់ល្បាយអាច់ខ្លា បាក់ធ្មេញស្ទើរអស់ ចាស់ជ្រីវជ្រួញ ហើយស្វិតដូចប្រចៀវចងគ្រឿង ។

*ប្លាក់ថន* លាន់មាត់ទាំងមិនដឹងខ្លួន :

- ចំជាការខាតបង់មែន ។ ស្លាប់មុនអាយុ !

- *ណាន កេស៊ូកា អាន់ជីន-សាន ?*

នារីទាំងពីរសួរយ៉ាងរហ័សដូចគ្នា ។ទឹកមុខសប្បាយរីករាយអំបាញ់មិញបានរលត់បាត់អស់ ។

- សូមទោស... នេះគ្រាន់តែ... គ្រាន់តែ... ពួកនាងសែនសំអាតខ្លួន ឯពួកយើងគគ្រិច ហើយនេះចំជាការខ្វះខាយ ។ ខ្ញុំក៏អីចឹងដែរ... ហើយនេះក៏ពីព្រោះតែយើងមិនបានដឹងពីអ្វីដែលល្អជាង ! ព្រះគ្រិស្តអើយ នេះបានចំជាការខ្វះខាយមួយ ! នេះមកពីពួកបព្វជិតនោះតែម្ដង ពួកវាជាសិស្សផង ជាគ្រូផង ។ ពួកបព្វជិតគ្រប់គ្រងសាលាទទួលបង្រៀន សព្វមុខ ហើយក្នុងនាមព្រះជាម្ចាស់ទាំងអស់ ហើយធ្វើអំពើស្មោគគ្រោកក៏ក្នុងនាមព្រះជាម្ចាស់ដែរ... នេះជាការពិត !

- ចាសពិតហើយ- *ម៉ារីកូ* និយាយថ្នមៗ អារម្មណ៍នាងវង្វេងនឹងការចុកចាប់របស់គេ - តែសូមលោកកុំយកកង្វល់នេះដាក់ក្នុងខ្លួនធ្វើអី *អាន់ជីន-សាន* ។ រឿងនេះចាំស្អែកទៅ...



www.budinst.gov.kh www.elibraryofcambodia.org

*គីតូ* នៅតែពញាក់មជាប់ តែនាងសែនមួម៉ៅនឹងខ្លួនឯង ។ ឯងគួរតែប្រយ័ត្នប្រយែងជាងនេះ-នាងនិយាយនៅក្នុងចិត្ត ។ ចំជាភ្លើ ! ចំជាភ្លើ ! ឯងធ្វើអោយរាត្រីនេះត្រូវខូចខាតអស់ហើយវេទមន្តក៏រលាយបាត់ទៅដែរ ។

ដោយពិតទៅ ភាពស្រើបស្រាលដោយតណ្ហាដែលបានមកគ្របដណ្តប់ពួកគេទាំងអស់គ្នានោះ បានរលាយបាត់ទៅហើយ ។ តែអ៊ីចឹងក៏ស្រួលដែរ-*គីតូ* គិតនៅក្នុងចិត្ត ។ យ៉ាងហោចណាស់ ទាំង *ម៉ារីកូ* ទាំង *អាន់ជីន-សាន* ត្រូវទប់ការពារបានមួយយប់ទៀតដែរ ។

បុរសកំសត់ នារីកំសត់ ។ គួរអោយកំសត់មែន ។ នាងសំលឹងមើលគេទាំងពីរនាក់ដែលនិយាយសាសងគ្នា ហើយនាងសំគាល់ឃើញថាសំលេងរបស់គេទាំងពីរបានប្រែប្រួល ។

*ម៉ារីកូ* និយាយជាភាសាឡាតាំង :

- អ៊ីលូវនេះខ្ញុំសូមលាលោកហើយ ។

- ទេ យើងទៅទាំងអស់គ្នា ។

- ខ្ញុំសូមអង្វរ សូមលោកនៅទីនេះហើយ ។ ដើម្បីកិត្តិយសលោក និងដើម្បីកិត្តិយសនាង ។ ហើយនឹងកិត្តិយសខ្ញុំផង *អាន់ជីន-សាន* ។

- ខ្ញុំមិនចង់បានជំនួននេះទេ ខ្ញុំចង់បាននាង ។

- ខ្ញុំជារបស់លោកហើយ ជឿខ្ញុំចុះ *អាន់ជីន-សាន* ។ ខ្ញុំសូមអង្វរ សូមលោកស្នាក់នៅទីនេះចុះ ហើយសូមលោកដឹងថា យប់នេះខ្ញុំជារបស់លោកហើយ ។

គេក៏លែងទាមទារអោយនាងស្នាក់នៅទៀតដែរ ។

* * * *

ក្រោយពី *ម៉ារីកូ* ចាកចេញទៅ គេប្រះខ្លួនគេងកើយដៃសំលឹងមើលរាត្រីកាលតាមបង្អួច ។ ភ្លៀងលាន់រណ្តំនៅលើក្បឿង ខ្យល់បក់វូៗពីសមុទ្ទ ។

*គីតូ* នៅលុតជង្គង់យ៉ាងស្ងៀមស្ងាត់ឥតកំរើកពីមុខគេ ។ ដើងទាំងគូរបស់នាងឡើង



www.budinst.gov.kh www.elibraryofcambodia.org

រឹង។ នាងចង់ប្រះខ្លួនសំរាកដែរ តែនាងមិនហ៊ានធ្វើកាយវិការអ្វីទាំងអស់ដែលអាចរំខានដល់អារម្មណ៍របស់គេ។ ឯងមិនហត់ទេ។ ជើងឯងមិនចុកស្រពន់ទេ -នាងខំនិយាយកំលាចិត្ត។ ស្តាប់ទឹកភ្លៀង គិតដល់អ្វីជាទីស្រលាញ់។ គិតដល់ *អូមី-សាន* គិតដល់ផ្ទះតែនៅ *មីស៊ីម៉ា* ។ គិតថាឯងនៅមានជីវិតរស់នៅនៅឡើយហើយការរញ្ជួយដីពីម្សិលមិញគ្រាន់តែជាការរញ្ជួយដីមួយ ទៀតតែប៉ុណ្ណោះ។ ចូរគិតពីលោកម្ចាស់ *តូរ៉ាណាកា-សាម៉ា* ហើយនឹងតំលៃដ៏សំបើមដែល *គីយ៉ូកូ-សាន* បានហាមាត់ទារពីដំបូងដៃ ។ គ្រូទាយតុតមែន ដែលថាសំនាងឯងនឹងធ្វើអោយ *គីយ៉ូកូ-សាន* មានហួសពីការយល់សប្តិទៅទៀតនោះ ។ ហើយបើគ្រូទាយត្រូវកន្លែងនេះ ហេតុអីក៏កន្លែងឯទៀតមិនត្រូវនោះ ? គ្រូទាយថាឯងនឹងរៀបការជាមួយសាមូរ៉ៃដែលឯងគោរព ហើយនឹងបានកូនប្រុសមួយជាមួយគាត់ ហើយថាឯងនឹងរស់នៅរហូតដល់ចាស់ស្លាប់ក្នុងឋានៈជាមនុស្សក្នុងផ្ទះរបស់គាត់ ឯងនឹងមានទ្រព្យសម្បត្តិ មានកិត្តិយស ហើយកូនប្រុសឯងនឹងធំឡើងជាសាមូរ៉ៃដូចកូនប្រុសឯទៀត១របស់គាត់ដែរ ។

*គីគូ* ចាប់ផ្តើមមើលឃើញអនាគតដ៏អស្ចារ្យ និងដ៏ភ្លឺថ្លារបស់នាងហើយ ។

មួយសន្ទុះក្រោយមក *ប្លាក់ថន* ក៏ពត់ខ្លួនយ៉ាងសុខស្រួល ។ គេប្រទះឃើញនាងហើយក៏ញញឹមដាក់នាង ។

- *ណាននេស៊ីកា អាន់ជីន-សាន ?*

គេគ្រវីក្បាលក្រោកឡើង ហើយទាញទ្វារបើកដើរចូលទៅបន្ទប់គេង ហើយដោះគីម៉ូណូរបស់គេចេញ ទទួលយកគីម៉ូណូស្រោលសំរាប់ទទួលទានដំណេកមួយធ្វើពីសូតដែល *គីគូ* ហុចអោយគេនោះមកពាក់ជំនួសវិញ។ រួច *គីគូ* ក៏បើកមុងអោយគេចូលទៅប្រះខ្លួននៅក្នុងនោះទៅ។

បន្ទាប់ពីផ្លាស់សំលៀកបំពាក់របស់នាងរួចហើយ *គីគូ* លុតជង្គង់នៅពីក្រៅមុង :

- *ដូស្ទូ អាន់ជីន-សាន ?*

- *ដូម៉ូ* ។

- *ដូម៉ូ អារីកាតូ គូស៊ីអេម៉ាស៊ីតា* ។

នាងនិយាយខ្សឹប១ រួចក៏បើកមុងចូលមកប្រះខ្លួនក្បែរ *ប្លាក់ថន* ។ ទ្រេន និងចម្រៀង



www.budinst.gov.kh www.elibraryofcambodia.org

ប្រេងឆេះជះពន្លឺព្រោងព្រាត ។ គេសប្បាយចិត្តនឹងពន្លឺនេះ ព្រោះ *គីតូ* មានសំរស់ស្អាតមែនទែន ។

ចំនង់របស់គេបានរលត់បាត់ទៅហើយ ។ ខ្ញុំមិនចង់បាននាងទេ *គីតូ-ចាន* គេគិតនៅក្នុងចិត្ត ។ ទោះនាងជា *ម៉ារីកូ* ក្តីក៏ដដែលហ្នឹង ។ ប្រហែលពេលក្រោយទៀតក៏មិនដឹង តែមិនមែនពេលនេះទេ ។ អភ័យទោសអោយខ្ញុំផងចុះ ។

ដៃរបស់ *គីតូ* លូកមកប៉ះគេ :

- *ដូសូ* ?

- *អ៊ីយេ* !

គេនិយាយថ្នម១ដោយគ្រវីក្បាលផង ។គេកាន់ដៃនាងជាប់ ហើយបន្ទាប់មកគេដាក់ដៃអោយនាងកើយក្បាល ។ ក្លិនពិដោររបស់នាងលាយឡំនឹងកំរាលហើយនឹងព្រំ ។ ចំជាស្អាតមែនអ្វី១ស្អាតទាំងអស់ ។

តើកាលនោះ *អាប៊ូទ្រិច* វាថាម៉េច ?« ជប៉ុនជាឋានសួគ៌លើភពផែនដីនេះអោយតែឯងដឹងកន្លែងរក » ។ អញមិនចាំទេ ។ អញដឹងតែម្យ៉ាង គឺឋានសួគ៌មិនមែននៅឯនាយ មិនមែននៅឆ្លងសមុទ្ទ មិនមែននៅកន្លែងដែលអញគិតថានៅទីនោះឡើយ ។

ឋានសួគ៌លើភពផែនដី គឺនៅទីនេះ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

រឹង ។ នាងចង់ប្រះខ្លួនសំរាកដែរ តែនាងមិនបានធ្វើកាយវិការអ្វីទាំងអស់ដែលអាចរំខានដល់អារម្មណ៍របស់គេ ។ ឯងមិនហត់ទេ ។ ជើងឯងមិនចុកស្រពន់ទេ -នាងខំនិយាយកំលាចិត្ត ។ ស្តាប់ទឹកភ្លៀង គិតដល់អ្វីជាទីស្រលាញ់ ។ គិតដល់ *អូមី-សាន* គិតដល់ផ្ទះតែនៅ *មីស៊ីម៉ា* ។ គិតថាឯងនៅមានជីវិតរស់នៅនៅឡើយហើយការរញ្ជួយដីពីម្សិលមិញគ្រាន់តែជាការរញ្ជួយដីមួយ ទៀតតែប៉ុននោះ ។ ចូរគិតពីលោកម្ចាស់ *តូរ៉ាណាកា-សាម៉ា* ហើយនឹងតំលៃដ៏សំបើមដែល *គីយ៉ូកូ-សាន* បានហាមាត់ទារពីដំបូងដៃ ។ គ្រូទាយអុតមែន ដែលថាសំនាងឯងនឹងធ្វើអោយ *គីយ៉ូកូ-សាន* មានហួសពីការយល់សប្តិទៅទៀតនោះ ។ ហើយបើគ្រូទាយត្រូវកន្លែងនេះ ហេតុអីក៏កន្លែងឯទៀតមិនត្រូវនោះ ? គ្រូទាយថាឯងនឹងរៀបការជាមួយសាមូរ៉ៃដែលឯងគោរព ហើយនឹងបានកូនប្រុសមួយជាមួយគាត់ ហើយថាឯងនឹងរស់នៅរហូតដល់ចាស់ស្លាប់ក្នុងឋានៈជាមនុស្សក្នុងផ្ទះរបស់គាត់ ឯងនឹងមានទ្រព្យសម្បត្តិ មានកិត្តិយស ហើយកូនប្រុសឯងនឹងធំឡើងជាសាមូរ៉ៃដូចកូនប្រុសឯទៀតៗរបស់គាត់ដែរ ។

*គីគូ* ចាប់ផ្តើមមើលឃើញអនាគតដ៏អស្ចារ្យ និងដ៏ភ្លឺថ្លារបស់នាងហើយ ។

មួយសន្ទុះក្រោយមក *ក្លាក់ថុន* ក៏ពត់ខ្លួនយ៉ាងសុខស្រួល ។ គេប្រទះឃើញនាងហើយក៏ញញឹមដាក់នាង ។

- *ណាននេតេស៊ូកា អាន់ជីន-សាន ?*

គេគ្រវីក្បាលក្រោកឡើង ហើយទាញទ្វារបើកដើរចូលទៅបន្ទប់គេង ហើយដោះគីម៉ូណូរបស់គេចេញ ទទួលយកគីម៉ូណូស្រាលសំរាប់ទទួលទានដំណេកមួយធ្វើពីសូត្រដែល *គីគូ* ហុចអោយគេនោះមកពាក់ជំនួសវិញ ។ រួច *គីគូ* ក៏បើកមុងអោយគេចូលទៅប្រះខ្លួននៅក្នុងនោះទៅ ។

បន្ទាប់ពីផ្លាស់សំលៀកបំពាក់របស់នាងរួចហើយ *គីគូ* លុតជង្គង់នៅពីក្រៅមុង :

- *ដូស៊ូ អាន់ជីន-សាន ?*

- *ដូម៉ូ* ។

- *ដូម៉ូ អារីកាតូ កូស៊ីអេម៉ាស៊ីតា* ។

នាងនិយាយខ្សឹបៗ រួចក៏បើកមុងចូលមកប្រះខ្លួនក្បែរ *ក្លាក់ថុន* ។ ទៀន និងចង្កៀង



www.budinst.gov.kh www.elibraryofcambodia.org

ប្រែងឆេះជះពន្លឺព្រោងព្រាត ។ គេសប្បាយចិត្តនឹងពន្លឺនេះ ព្រោះ *គីតូ* មានសំរស់ស្អាតមែនទែន ។

ចំនង់របស់គេបានរលត់បាត់ទៅហើយ ។ ខ្ញុំមិនចង់បាននាងទេ *គីតូ-ចាន* គេគិតទៅក្នុងចិត្ត ។ ទោះនាងជា *ម៉ារីកូ* ក្តីក៏ដដែលណឹង ។ ប្រហែលពេលក្រោយទៀតក៏មិនដឹង តែមិនមែនពេលនេះទេ ។ អភ័យទោសអោយខ្ញុំផងចុះ ។

ដៃរបស់ *គីតូ* លូកមកប៉ះគេ :

- *ជូសូ ?*

- *អ៊ីយេ !*

គេនិយាយថ្នមៗដោយគ្រវីក្បាលផង ។គេកាន់ដៃនាងជាប់ ហើយបន្ទាប់មកគេដាក់ដៃអោយនាងកើយក្បាល ។ ក្លិនពិដោររបស់នាងលាយឡំនឹងកំរាលហើយនឹងព្រំ ។ ចំជាស្អាតមែនអ្វីៗស្អាតទាំងអស់ ។

តើកាលនោះ *អារ៉ូគ្រិច* វាថាម៉េច ?« ជប៉ុនជាឋានសួគ៌លើភពផែនដីនេះអោយតែឯងដឹងកន្លែងរក » ។ អញមិនចាំទេ ។ អញដឹងតែម្យ៉ាង គឺឋានសួគ៌មិនមែននៅឯនាយ មិនមែននៅឆ្លងសមុទ្ទ មិនមែននៅកន្លែងដែលអញគិតថានៅទីនោះឡើយ ។

ឋានសួគ៌លើភពផែនដី គឺនៅទីនេះ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៤១

នារសាបំផាយសេះកាត់ស្បែរាត្រីចុះត់រង់ទៅភូមិ ដែលកំពុងនិទ្រាយ៉ាងស្ងប់ស្ងាត់ ។ មេឃចាប់ផ្ដើមភ្លឺល្អះៗ ទូកនេសាទពេលយប់ទាំងឡាយដែលបានចេញទៅវាយសំនាញ់ស្បែរៗ ផ្ទុកខ្សាច់នោះ ក៏ចាប់ផ្ដើមចូលច្រាំងវិញបណ្ដើរៗហើយដែរ ។ នារសានេះបំផាយសេះ ឥតមានឈប់សំរាកមួយស្រលេតណាសោះឡើយ តាំងពី *មីស៊ីម៉ា* មកដោយកាត់ច្រកភ្នំនិងផ្លូវដំសែនយ៉ាប់យ៉ឺនទាំងឡាយ គ្រាន់តែប្ដូរសេះថ្មីៗនៅតាមគ្រប់កន្លែងដែលគេអាចប្ដូរបានតែប៉ុននោះ ។

ជើងសេះរបស់គេលាន់ខ្ទរទៅតាមផ្លូវក្នុងភូមិ ។ អីលូវនេះមានភ្នែកជាច្រើនកំពុងលួចសំលឹងតាមមើលរូបគេដែលបំផាយសេះកាត់ទីធ្លាភូមិ ហើយឡើងជំរាលកូនភ្នំសំដៅទៅវិកបន្ទាយ ។ ទង់របស់គេមានរូបសញ្ញារបស់ *តូរ៉ាណាកា* ហើយគេស្គាល់ពាក្យសំងាត់ដែលប្រើនៅក្នុងពេលនោះ ។ ទោះជាយ៉ាងនេះក្ដី ក៏គេត្រូវឆ្លងកាត់ការពិនិត្យនិងសាកសួរបញ្ជាក់ពីអត្តសញ្ញាណរបស់គេបួនកន្លែងដែរ ទើបបានគេនាំទៅជួបនឹងមេវេនយាមកាម ។

- សារបន្ទាន់ពី *មីស៊ីម៉ា* មក *ណាកា- សាន* ។ លោកម្ចាស់ *ហ៊្សី-ម៉ាត់ស៊ី* ផ្ញើមក ។

*ណាកា* ទទួលយករមូរសារ ហើយរលះរលាំងដើរចូលទៅក្នុង ។ ទៅដល់មាត់ទ្វារដែលមានការយាមកាមយ៉ាងមាំមួននោះ គេក៏ឈប់នៅទីនោះ :

- ពុក ?

- មានការអី ?

*ណាកា* ទាញទ្វារទៅម្ខាង ហើយនៅស្ងៀមរង់ចាំ ។ ដាវរបស់ *តូរ៉ាណាកា* ក៏វិលទៅក្នុងស្រោមវិញដែរ ។ ឆ្មាំម្នាក់យកចង្កៀងប្រេងចូលមក ។

*តូរ៉ាណាកា* អង្គុយនៅក្នុងមុង ហើយបំបែកត្រាអាច់ល័ក្ខចេញ ។ កាលពីពីរអាទិត្យមុននេះ លោកបានបញ្ជាអោយ *ហ៊្សី - ម៉ាត់ស៊ី* យកកងពលជើងឆើតមួយកងធ្វើដំណើរជាសំងាត់ទៅ *មីស៊ីម៉ា* ដែលជាទីក្រុងព័ទ្ធដោយកំផែងប៉មយ៉ាងរឹងមាំមួយ នៅតាមផ្លូវ *តូកៃដូ* ហើយដែលការពារច្រកភ្នំដែលនាំទៅកាន់ទីក្រុង *អាតាមី* និង *អូដាវ៉ារ៉ា* នៅឯខាង



www.budinst.gov.kh www.elibraryofcambodia.org

ជើង ។ *អូដាវ៉ាភ៌* ជាកូនសោសំរាប់កិច្ចការពារតំបន់ *ក្វាន់តូ* ទាំងមូលតែម្តង ។ *ប៉ុរ៉ូ - ម៉ាត់ស៊ី* សរសេរថា : " លោកម្ចាស់ ប្អូនប្រុសរបស់លោក គឺលោកម្ចាស់ *សាគាគី* នៃខេត្ត *ស៊ីណាណូ* បានមកពី *អូសាកា* ហើយបានសុំលិខិតបើកផ្លូវដើម្បីមកជួបនឹងលោកម្ចាស់នៅឯ *អាន់ជីរ៉ូ* នេះ ។ គាត់ធ្វើដំណើរជាផ្លូវការដោយមានសាមូរ៉ៃមួយរយនាក់ និងអ្នកស្នែងជាច្រើននាក់ផង ដោយប្រើទង់សញ្ញារបស់ក្រុមប្រឹក្សាអាជ្ញាទុសិទ្ធ " ថ្មី " ។ ខ្ញុំមានការសោកស្តាយ ដោយត្រូវជំរាបលោកម្ចាស់ថា ដំណឹងដែលលោកជំទាវ *គីរីស៊ូបូ* បានជំរាបនោះ គឺជាការត្រឹមត្រូវ ។ *សាគាគី* បានក្លាយខ្លួនជាជនក្បត់ ហើយថែមទាំងបានបង្ហាញជាសាធារណៈនូវការដាក់ខ្លួនគេបំរើ *អ៊ីស៊ីដូ* ហើយ ។ អ្វីដែលលោកជំទាវ *គីរីស៊ូបូ* មិនបានដឹង គឺថា*សាគាគី* នៅពេលនេះបានក្លាយខ្លួនជាសមាជិកក្រុមប្រឹក្សាជំនួសលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ហើយ ។ គាត់បានបង្ហាញខ្ញុំនូវលិខិតតែងតាំងខ្លួនគាត់ជាផ្លូវការ ដោយមានទាំងហត្ថលេខាត្រឹមត្រូវរបស់ *អ៊ីស៊ីដូ, គីយ៉ាម៉ា, អូណូស៊ី* និង *អ៊ីតូ* ថែមទៀតផង ។ ខ្ញុំប្រឹងសំបើមណាស់ ដើម្បីខាឃាំងកូនចៅខ្ញុំកុំអោយវាមានប្រតិកម្មចំពោះរឹកពារដ៏កោងរបស់ *សាគាគី* ហើយនឹងគោរពតាមបទបញ្ជារបស់លោកម្ចាស់ដែលថា ត្រូវបើកផ្លូវអោយគ្រប់នារសាទាំងអស់របស់ *អ៊ីស៊ីដូ* ចេញចូលនោះ ។ ខ្ញុំចង់សំលាប់អាមនុស្សថោកទាបនេះដោយផ្ទាល់ដៃរបស់ខ្ញុំណាស់ ។ ធ្វើដំណើរជាមួយ *សាគាគី* មានបព្វជិតចុងស្រុក *ឈូតូ - សាន* ដែលបានចេញដំណើរពី *ណាកាសាគី* មកដល់កំពង់ផែ *នូម៉ាស៊ូ* នេះ ។ គាត់បានសុំច្បាប់អនុញ្ញាតមកសួរសុខទុក្ខលោកម្ចាស់ ហើយខ្ញុំក៏បញ្ជូនលោកមកជាមួយរវ៉ូងគេនេះជាមួយគ្នាតែម្តងទៅ ។ ខ្ញុំបានអោយកូនចៅខ្ញុំពីររយនាក់ជូនពួកគេមក ។ ពួកគេនឹងមកដល់ *អាន់ជីរ៉ូ* ក្នុងរយៈពេលពីរថ្ងៃទៀត ។ តើអង្កាល់ទៅទើបលោកម្ចាសវិលត្រលប់ទៅ*យេដូ*វិញ ? ពួកយកការណ៍បានប្រាប់ថា *ជីគីយូ* កំពុងកេណ្ឌទ័ពជាសំងាត់ ហើយដំណឹងនានាដែលមកពី *យេដូ* បានអោយដឹងថា ពួកបក្សសំព័ន្ធភាគខាងជើងរៀបចំនឹងចូលជាមួយ *អ៊ីស៊ីដូ* ដោយថាខេត្ត *ស៊ីណាណូ* របស់ *សាគាគី* នោះបានប្រឆាំងនឹងលោកម្ចាស់ហើយ ។ ខ្ញុំសូមចិត្តលោកម្ចាស់ សូមលោកម្ចាស់ចាកចេញពី *អាន់ជីរ៉ូ* ភ្លាមទៅ ។ ដកថយតាមសមុទ្រ ។ ទុកអោយ *សាគាគី* តាមលោកម្ចាស់



www.budinst.gov.kh www.elibraryofcambodia.org

ទៅឯ *យេដូ* ដែលជាកន្លែងយើងអាចដោះស្រាយជាមួយមនុស្សនេះបានសមស្របជាង ។

*តូរ៉ាណាកា* ទះក្តារសូរម៉ាំង ។

- *ណាកា - សាន* ។ ទៅហៅ *ប៊ុនតារ៉ូ - សាន យ៉ាប៊ូ - សាន* និង *អូមី - សាន* អោយមកនេះភ្លាម ។

ពួកគេមកដល់យ៉ាងឆាប់រហ័ស ។ *តូរ៉ាណាកា* អានសារអោយគេទាំងអស់គ្នាស្តាប់ ។

- យកល្អ ពួកយើងត្រូវផ្អាកការរ៉ឹកហាត់សិនទៅ ហើយបញ្ជូនកងមូស្កេហើយនឹងទ័ពទាំងអស់ទៅតាមភ្នំ ។ ពួកយើងមិនចង់អោយមានការផ្លោះធ្លោយផ្នែកសុវត្ថិភាពឡើយ ។

*អូមី* ពោលឡើង :

- សូមអភ័យទោសដល់ខ្ញុំផងទៅចុះលោកម្ចាស់ ។ តែលោកម្ចាស់អាចពិចារណាពីការទទួលពួកនេះនៅតាមផ្លូវក្នុងដងភ្នំទាំងនេះក៏បាន ។ កាត់ជួបនៅ *យ៉ូកូសេ* ក៏បាន ។ លោកម្ចាស់អញ្ជើញលោកម្ចាស់ *សាតាគី - អូមី* ហៅម៉ានៈយ៉ាងប្រយ័ត្នប្រយែង - អោយកំសាន្តទឹកនៅកន្លែងទឹកពុះណាមួយជិតនោះក៏បាន តែកន្លែងជួបគ្នាគឺនៅ *យ៉ូកូសេ* ។ ហើយនៅពេលដែលគាត់ប្រគល់សារហើយ គាត់និងកូនចៅគាត់អាចបញ្ជូនត្រលប់ទៅដល់ព្រំដែនវិញក៏បាន កំទេចចោលក៏បានតាមចិត្តប្រាថ្នារបស់លោកម្ចាស់ ។

- ខ្ញុំមិនស្គាល់ *យ៉ូកូសេ* ផង ។

- នេះជាកន្លែងដ៏ល្អស្រស់ប្រិមប្រិយ - *យ៉ាប៊ូ* និយាយយ៉ាងអឿ - ស្ទើរតែនៅចំកណ្តាល *អ៊ីស៊ូ* តែម្តង ។ នៅឯនាយភ្នំក្នុងជ្រលងមួយក្បែរស្ទឹង *កាណូ* ។ ស្ទឹង *កាណូ* ហូរទៅចាក់ចូលក្នុងសមុទ្រនៅភាគខាងត្បូង *ទេ ? យ៉ូកូសេ* ស្ថិតនៅចំកន្លែងប្រសព្វមុខគ្នាពោលគឺផ្លូវទៅខាងជើង - ត្បូង និង ផ្លូវកើត - លិច ។ ពិតមែនហើយ *យ៉ូកូសេ* ពិតជាកន្លែងល្អសំរាប់ជួបគ្នាមែនលោកម្ចាស់ ។ កន្លែងមុជទឹកផុស គឺ *ស្ប៉ា ស៊ូចិនជី* នៅជិតនោះទៀត ។ ទឹកក្តៅល្អណាស់ ល្អមែនទែន ។ អាចថាល្អបំផុតក្នុងចំនោមទឹកផុសល្អៗ បំផុតរបស់យើង ។ លោកម្ចាស់គួរអញ្ជើញទៅលេងកន្លែងនោះតែម្តងទៅ ។ ខ្ញុំគិតថា *អូមី - សាន* អោយយោបល់នេះល្អបំផុត ។



www.budinst.gov.kh www.elibraryofcambodia.org

- តើកន្លែងនោះស្រួលការពារទេ ?

- បាទ ស្រួលទាន - *អូមី* និយាយយ៉ាងប្រញាប់ - នៅទីនោះមានស្ពានមួយ ។ ជញ្ជាំងភ្នំចោតណាស់ ។ អ្នកវាយលុកណាក៏ដោយ ក៏ត្រូវតែវាយតាមផ្លូវដ៏ក្រចិកក្រងុកដូច ពស់ពេនដែរ ។ ច្រកចូលទាំងសងខាងអាចប្រើមនុស្សតែប៉ុន្មាននាក់ក៏អាចការពារបានទៅ ហើយ ។ នៅទីនោះគ្មានអ្នកណាអាចដាក់អន្ទាក់លោកម្ចាស់បានឡើយ ។ យើងមានកងទ័ព គ្រប់គ្រាន់ដើម្បីការពារលោកម្ចាស់ ហើយនឹងសំលេះសត្រូវច្រើនជាងយើងដប់ដងទៀតបាន យ៉ាងងាយ... នេះបើចាំបាច់ ។

- យើងសំលេះពួកវា ទោះជាមានអ្វីកើតឡើងក៏ដោយ *ទេ ? - ប៊ុនតារ៉ូ* និយាយ ទាំងប្រមាថមើលងាយ - តែសំលេះនៅទីនោះគ្រាន់បើជាងទីនេះ ។ ខ្ញុំសូមលោកម្ចាស់ចាត់ ចែងរៀបចំសន្តិសុខជូនទាន ។ យកខ្មាន់ព្រួញប្រាំរយនាក់ មិនបាច់ប្រើពួក *មូស្កេ* ទេ ។ ពួកនេះជាទ័ពសេះទាំងអស់ ហើយបូកបន្ថែមទ័ពដែលឪពុកខ្ញុំបញ្ជូនមកទៀត គឺលើសពីល្មម ទៅទៀត ។

*តូរ៉ាណាកា* ពិនិត្យផ្ទៀងផ្ទាត់ថ្ងៃខែជាមួយសារ :

- ពួកវាមកដល់ផ្លូវបំបែកនៅពេលណា ?

*យ៉ាប៊ូ* ងាកមើលទៅ *អូមី* ដើម្បីបញ្ជាក់ :

- បើលឿនគឺដល់យប់នេះ ។

- *ប៊ុនតារ៉ូ - សាន* ចេញដំណើរទៅភ្លាម - *តូរ៉ាណាកា* បញ្ជា - ឃាត់ពួកនោះអោយ ទៅត្រឹម *យ៉ូកូសេ* តែអោយនៅម្ខាងស្ពឹង ។ ស្អែកព្រឹកព្រលឹមខ្ញុំនឹងចេញដំណើរទៅជាមួយ កូនទ័ពខ្ញុំមួយរយនាក់ទៀត ។ ពួកយើងទៅដល់នោះប្រហែលនៅថ្ងៃត្រង់ ។ *យ៉ាប៊ូ - សាន* ក្នុងរយៈពេលនេះលោកទទួលកងពល *មូស្កេ* ហើយចាំបិទគូថ ។ បង្កប់ទ័ពនៅតាមសងខាង ផ្លូវ *វែហកាវ៉ា* ។ បើសិនជាចាំបាច់ពួកយើងនឹងចាក់ទៅខាងលោកហើយ ។

*ប៊ុនតារ៉ូ* ងើបឡើងបំរុងដើរចេញទៅហើយ តែលោកក៏ឈប់ម៉ិក់ទៅវិញនៅពេល ដែលលឺ *យ៉ាប៊ូ* និយាយទាំងរសាប់រសល់ :



www.budinst.gov.kh www.elibraryofcambodia.org

- តើនេះជាល្បិចបានដែររឺទេលោកម្ចាស់ ? ពួកវាមានតែមួយរយនាក់ណឹង ។

- ខ្ញុំគិតថា នឹងអាចមានអំពើល្បិច ។ *សាកាគី* មិនយកក្បាលវាមកដាក់ក្នុងកណ្តាប់ដៃខ្ញុំដោយគ្មានផែនការនោះទេ ព្រោះវាដឹងថា បើខ្ញុំអាចធ្វើបាន ខ្ញុំពិតជានឹងយកក្បាលវាហើយ - *តូរ៉ាណាកា* និយាយ - បើសិនជាគ្មានវានៅសំរាប់ដឹកនាំពួកបងប៉ុលទាំងនេះទេ យើងមានវាសនាល្អច្រើនជាងក្នុងការឆ្លងកាត់ជួរភ្នំទាំងនោះ ។ តែហេតុអីបានជាវាមកប្រថុយប្រថានយ៉ាងនេះ ? ហេតុអីទៅ ?

*អូមី* ប្រថុយនិយាយ :

- ក្រែងគាត់មានបំនងមកចងសំព័ន្ធមិត្តឡើងវិញទេដឹង ?

ទាំងអស់គ្នាសុទ្ធតែបានដឹងពីការប្រណាំងប្រជែងតាំងពីយូរលង់មកហើយ រវាងបងប្អូនឪពុកទីទៃទាំងពីរនាក់នេះ ។

- ទេ មិនមែនជារបៀបវាទេ ។ ខ្ញុំមិនដែលទុកចិត្តវាតាំងពីដើមមក ។ តើអីល្វើនេះមានអស់លោកណាទុកចិត្តវាទេ ?

ទាំងអស់គ្នាគ្រវីក្បាល ។

*យ៉ាប៊ូ* ពោលឡើង :

- ពិតណាស់ ថាគ្មានអ្វីដែលមករំខានលោកម្ចាស់បានទេ ។ លោកម្ចាស់ *សាកាគី* ជាសមាជិកក្រុមប្រឹក្សាក៏ពិតមែន តែគាត់គ្រាន់តែជាអ្នកនាំសារម្នាក់ប៉ុនោះ *រទ* ?

ស្ងួត ។ *តូរ៉ាណាកា* ចង់ស្រែកចេញមកក្រៅ ។ តើពួកអ្នែងមិនយល់អ្វីទាំងអស់តែម្តងអី ?

- បន្តិចទៀតយើងគង់តែដឹងទេ ។ *ប៊ុនតារ៉ូ - សាន* ចេញដំណើរភ្លាមទៅ ។

- បាទលោកម្ចាស់ ។ ខ្ញុំបាទនឹងរើសកន្លែងជួបជុំគ្នាយ៉ាងប្រយ័ត្នប្រយែងបំផុត ។ តែសូមលោកម្ចាស់កុំអោយវាចូលជិតជាងដប់ជំហានអោយសោះ ។ ខ្ញុំបាទធ្លាប់នៅជាមួយវាកាលនៅកូរ៉េហើយ ។ អានេះរហ័សណាស់រឿងដាវនេះ ។

- ណឹងហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ុនតាវ៉ូ* រលះរលាំង ចេញទៅ ។ *យ៉ាប៊ូ* ពោល ៖

- រឺមួយយើងអាចសាកល្បងអូសទាញ *សាតាតិ* អោយក្បត់ *អ៊ីស៊ីដូ* បានទេ ? រឺង៉ាន់ខាន់ខៅអីទៅ ? តើយើងអាចរកនុយអ្វីផ្តក់គាត់អីចេះ ? ទោះជាគ្មានការដឹកនាំគាត់ក៏ដោយ ក៏ភ្នំ *ស៊ីណាណូ* នៅតែសាហាវដែរ ។

- នុយគឺច្បាស់ណាស់- *តូរ៉ាណាកា* តប-នោះគឺ *ក្វាន់តូ* ។ មិនតឹកខ្ទែងណុងទេរឺ ដែលវាតែងស្រក់ទឹកមាត់ចង់បាននោះ? មិនតឹកខ្ទែងដដែលណឹងទេអ្វីដែល *អ៊ីស៊ីដូ* ខ្លួនឯងក៏ចង់បានដែរនោះ ។

ពួកគេឥតឆ្លើយតបនឹងលោកវិញឡើយ ។ មិនចាំបាច់មានចំលើយទេ ។

*តូរ៉ាណាកា* និយាយយ៉ាងធ្ងន់ពាប់ ៖

- ព្រះអង្គលោកនឹងជួយពួកយើងជាមិនខាន ។ សន្តិភាពរបស់លោកម្ចាស់ *តែតូ* បានបញ្ចប់ហើយ ។ សង្គ្រាមបានចាប់ផ្តើមវិញម្តង ។

☆ ☆ ☆

គ្រចៀកដើរសមុទ្ររបស់ *ប្លាក់ថន* បានលឺស្នូរដំរន្ថើននៃក្រចកជើងសេះ ហើយដែលអោយសញ្ញាអាសន្នដល់រូបគេភ្លាម ។ គេភ្ញាក់ពីដំណេកមួយរំពេច ខ្លួនប្រាណគេទាំងមូលត្រៀមជាបន្ទាន់ដើម្បីធ្វើការវាយលុក រឺដកថយ ។ ស្នូរជើងសេះបានឆ្លងហួសទៅដោយតំរង់ទៅរកបន្ទាយ ហើយរលត់បាត់បន្តិចម្តង១ នៅឯទីឆ្ងាយ ។

គេនៅរង់ចាំបន្ត ។ គ្មានសំលេងក្បួនជូនដំណើរអ្វីទាំងអស់ ។ ប្រហែលជានាំសារតែម្នាក់ឯងហើយ - គេនឹកក្នុងចិត្ត ។ តើគេមកពីណាមក ? តើសង្គ្រាមកើតឡើងហើយឬ ?

មេឃភ្លឺល្អះ១ ហើយ ។ អីលូវនេះ *ប្លាក់ថន* អាចមើលឃើញមេឃមួយចំនិតតូចដែរ ។ មេឃមានពពកងងាស និង ធ្ងន់ពាប់ដោយទឹកភ្លៀង ជំនោរខ្យល់មានភាពក្តៅឧណ្ហ១ លាយឡំដោយជាតិអំបិលបក់អង្រួនមួយដងមួយយាមស្បៃមុងអោយរលាស់រំពើត ។ សំលេងមូសនៅលាន់ហ៊ឹង១ នៅឯក្រៅនៅឡើយ ។ គេសប្បាយចិត្តដែរ ដែលក្នុងពេលនេះគេនៅក្នុងសុវត្ថិភាពនៃស្បៃមុងរបស់គេនៅឡើយ ។ សប្បាយរីករាយនឹងសុវត្ថិភាព ហើយនឹងភាពស្ងប់ស្ងៀមអោយហើយទៅទាន់នៅមានពេល - គេគិតនៅក្នុងចិត្ត ។



www.budinst.gov.kh www.elibraryofcambodia.org

*គីតូ* នៅតែងក្រវៀន១ ដូចកូនឆ្មានៅជិតតែនៅឡើយ ។ តែឃើញទឹកមុខលង់លក់ក្នុងនិទ្រារបស់នាងរឹតតែល្អស្រស់ជាងថៃមទៀត ។ គេប្រាសខ្លួនយ៉ាងថ្នមៗទៅលើកំរាលដោយគ្រលំភួយយ៉ាងសុខស្រួល ។

កន្លែងនេះស្រួលជាងគ្រែដេកទៅទៀត ។ ហើយរឹតតែស្រួលជាងគ្រែព្យូរនៅលើសំពៅណាទាំងអស់ ។ ឱព្រះអើយ ! ស្រួលអីក៏ស្រួលម្ល៉េះ ! តែបន្តិចទៀតត្រូវឡើងសំពៅវិញហើយ *ទេ* ? បន្តិចទៀតត្រូវវាយលុក*សំពៅខ្មៅ* ហើយកាន់កាប់វា *ទេ* ? អញគិតថា *តូរ៉ាណាកា* ឯកភាព ហើយគ្រាន់តែគាត់មិននិយាយចេញតែប៉ុននោះ ។ មិនតឹគាត់យល់ព្រមតាមបែបជប៉ុនទេអ្វី ? " គ្មានអ្វីដែលអាចដោះស្រាយបាននៅជប៉ុន ក្រៅពីតាមរបៀបជប៉ុននោះឡើយ " ។ ពិតហើយ អញជឿថានេះជាការពិត ។

អញចង់បានទទួលពតិមានល្អជាងនេះទៀត ។ មិនតឹលោក *តូរ៉ាណាកា* បានប្រាប់ទៅ *ម៉ារីកូ* អោយបកទាំងសព្វទាំងគ្រប់ពីរឿងបញ្ហានយោបាយរបស់គាត់ទេអ្វី ?

អញចង់បានលុយដើម្បីពួកនាវិកថ្មីរបស់អញ ។ មិនតឹគាត់អោយអញពីរពាន់ *កូកុ* ទេអ្វី ?

អញសុំពួក *កកស៊ែ* ពីពីររយទៅបីរយនាក់ ។ មិនគាត់អោយមកអញនូវ *សាមូរ៉ៃ* ពីររយនាក់ជាមួយនឹងអំនាចនិងឋានៈគ្រប់គ្រាន់ទេអ្វី ? តើពួកវានឹងស្តាប់បង្គាប់អញទេ ? ត្រូវតែស្តាប់ ។ *តូរ៉ាណាកា* បានប្រកាសអញជា *សាមូរ៉ៃ* និងជា *ហាតាម៉ូតូ* ហើយហេតុនេះពួកវាត្រូវតែស្តាប់បង្គាប់អញរហូតដល់ស្លាប់ ហើយអញនឹងនាំពួកវាចុះសំពៅ *អេរ៉ាស់* ដើម្បីដឹកនាំវាប្រយុទ្ធ ។

គិតៗ ទៅ អញចំជាមានសំនាងមហាអស្ចារ្យតែម្តង ! អញបានអ្វីៗទាំងអស់ដែលអញចង់បាន ។ លើកលែងតែ *ម៉ារីកូ* មួយប៉ុននោះ ។ តែអញក៏បាននាងដែរ ។ អញបានគំនិតអារម្មណ៍សំងាត់ ហើយនឹងសេចក្តីស្នេហារបស់នាង ។ ហើយអញក៏បានខ្លួននាងដែរនៅយប់មុននោះ ជាយប់វេទមន្តដែលគ្មានអត្ថិភាព ។ យើងស្រលាញ់គ្នាដោយឥតស្រលាញ់ ។ តើនេះខុសគ្នាណាស់ទៅរឺ ?



www.budinst.gov.kh www.elibraryofcambodia.org

រវាង *គីគូ* នឹងអញ គ្មានសេចក្តីស្នេហាទេ គឺមានតែចំនងដែលទើបដុះពន្លកឡើង។ នេះគឺចំជាមហិមាតែម្តងចំពោះអញ ។ សង្ឃឹមថានេះក៏ពិតជាមហិមាសំរាប់នាងដែរ ។ អញបាន ខិតខំធ្វើខ្លួនជាជនជាតិជប៉ុន ហើយបំពេញភារកិច្ចរបស់អញដើម្បីធ្វើអោយនាងសប្បាយរីករាយផង ដើម្បីអញបានសប្បាយរីករាយផង ។

គេនឹកចាំបានថា តើគេបានប្រើកងរីករាយយ៉ាងម៉េច ។ នៅពេលនោះគេមានអារម្មណ៍អៀនខ្មាសផង ទីទើរផង ហើយគេត្រូវបែរខ្លួងចេញដើម្បីដាក់វាទាំងអារម្មណ៍ភ័យខ្លាចក្រែងខ្លួនឯងធ្លាក់ទន់រងៀកទៅវិញ ។ តែផ្ទុយទៅវិញសោះ គ្រាន់តែដាក់ហើយ គេរួមរក្សជាមួយនាងម្តងទៀតភ្លាម ។ ខ្លួនប្រាណដ៏រមូល ដ៏ញ័រញាក់ ដ៏រញ្ជួយរបស់ *គីគូ* បានធ្វើអោយគេទទួលនូវអារម្មណ៍មួយដែលតាំងពីដើមមកគេមិនដែលទទួលបានឡើយ ។

បន្ទាប់មកទៀត នៅពេលដែលគេដកដង្ហើមបានស្រួលបួលវិញហើយនោះ គេក៏ផ្ទុះសំណើចឡើង ហើយ *គីគូ* ក៏ខ្សឹបសួរថា ហេតុអីដែលបណ្តាលអោយគេសើចនោះ ។ គេឆ្លើយថា ខ្លួនគេក៏មិនដឹងដែរ ក្រៅពីដឹងថានាងធ្វើអោយគេមានការរីករាយតែប៉ុននោះ ។

រាល់ដងក្នុងពេលដូចនេះអញមិនដែលសើចទេ ។ សំណើចនេះធ្វើអោយអ្វីៗ ឥតខ្ទោះតែម្តង ។ អញអត់ស្រលាញ់ *គីគូ - សាន* តែអញថ្លាក់ថ្លមនាង ។ អញស្រលាញ់ *ម៉ារីកូ - សាន* ដោយឥតសំចៃ ហើយអញស្រលាញ់ *ភូជីកូ - សាន* ទាំងស្រុងតែម្តង ។

តើអញនឹងរួមរក្សជាមួយ *ភូជីកូ* ទេ ? ទេ ។ យ៉ាងហោចណាស់អញគិតថា ប្រហែលអញទៅមិនរួចទេ ។

តែតើនេះមិនជាភារកិច្ចរបស់ឯងទើរ ? បើឯងទទួលយកបុព្វសិទ្ធិទាំងឡាយរបស់ *សាមូរ៉ៃ* ហើយទាមទារអោយអ្នកឯទៀតចាត់ទុកឯងដូចជា *សាមូរ៉ៃ* ទាំងស្រុងនោះ ឯងត្រូវទទួលយកនូវការទទួលខុសត្រូវ ហើយនឹងរាល់ភារកិច្ចទាំងអស់ *ទេ* ? នេះបានយុត្តិធម៌ *ទេ* ? ហើយនេះជាកិត្តិយសផង *ទេ* ? មិនគឺភារកិច្ចឯងទើរ ដែលត្រូវផ្តល់កូនប្រុសមួយទៅអោយ *ភូជីកូ* នោះ ។

រួចចុះ *កេលីស៊ី* វិញ ? តើនាងនឹងនិយាយយ៉ាងម៉េចទៅ ?



www.budinst.gov.kh www.elibraryofcambodia.org

រួចនៅពេលដែលឯងចេញសំពៅទៅស្រុកវិញ តើ *ភូជីកូ-សាន* និង *ម៉ារីកូ - សាន* នឹងទៅជាយ៉ាងណា ? តើឯងពិតជានឹងត្រលប់មកទីនេះវិញ ដោយបោះបង់ឋានៈ *សីហាល្បែ* និងមហាកិត្តិយស ដែលឯងនឹងទទួលនៅពេលដែលឯងចូលស្រុកប្រកបដោយសម្បត្តិមហាសាល នោះរឺទេ ? តើឯងនឹងដើរសំពៅកាត់អរិភាពនៃអន្ធការ ជំនះភាពជំរុញនៃច្រក *ម៉ាសេឡង់* ទ្រាំទ្រព្យុះ ឆ្លងកាត់សមុទ្ទ និង *ស្គ័ព៌ត* និងការបះបោរក្នុងរយៈប្រាំមួយរយកៅសិបប្រាំបីថ្ងៃ ដើម្បីមកឡើងគោកជាលើកទីពីរនៅទីនេះម្តងទៀតដែររឺទេ ? ដើម្បីបន្តជីវិតបែបនេះជាថ្មីម្តងទៀតរឺទេ ?

សំរេចចិត្តទៅ !

រួចគេក៏នឹកឃើញសំដីរបស់ *ម៉ារីកូ* ដែលពោលប្រាប់គេពីការខណ្ឌត់និតអារម្មណ៍ ៈ"ធ្វើខ្លួនជាជប៉ុន *អាន់ជីន - សាន* ។ លោកត្រូវតែធ្វើយ៉ាងនេះ ។ បើចង់រស់បាន ។ ធ្វើតាមអ្វីដែលពួកយើងខ្ញុំធ្វើ ។ បណ្តោយខ្លួនដោយឥតរអៀនខ្មាសទៅតាមសង្វាក់របស់ *កាម៉ា* ។ ត្រូវទទួលយកនូវអានុភាពណាដែលយើងមិនអាចត្រួតត្រាបាន ។ ត្រូវដាក់អ្វី ១ ទៅក្នុងខណ្ឌដោយឡែក ១ ពីគ្នា ហើយបណ្តោយខ្លួនទៅតាម *វ៉ា* ពោលគឺភាពសុខដុមរមនានៃជីវិត ។ បណ្តោយខ្លួន *អាន់ជីន - សាន* ។ *កាម៉ា* គឺ *កាម៉ា នេ* ?"

ពិតមែនហើយ ។ អញនឹងសំរេចនៅពេលណាដែលពេលសំរេចបានមកដល់ ។

ដំបូងបង្អស់ អញត្រូវរើសពួកនាវិកសិន ។ បន្ទាប់មកទៀត អញត្រូវចាប់*សំពៅខ្មៅ* ។ រួចអញបើកសំពៅកន្លះជុំផែនដីដើម្បីទៅប្រទេសអង់គ្លេសវិញ ។ រួចអញទិញសំពៅចំបាំងមួយចំនួន និងបំពាក់ឧបករណ៍វា ។ រួចអញនឹងសំរេចចិត្ត ។ *កាម៉ា* គឺ *កាម៉ា* ។

*គីគូ* កំរើកខ្លួន ហើយរុលខ្លួនទៅក្នុងភួយបន្ថែមទៀត ដោយខិតទៅសសុលជាមួយ*ប្លាក់ថន* ធ្វើអោយគេមានអារម្មណ៍ព្រឺព្រួច ។

- *អាន់ជីន-សាន*- នាងនិយាយខ្សឹប១ ទាំងនៅក្នុងភាពមិនទាន់អស់ងងុយនៅឡើយ ។

- *ហៃ?*

គេឥតរំខានដំណេកនាងទេ ។ គេសែនរីករាយនឹងអោបនាងនៅក្នុងរង្វង់ដៃខ្លួន



www.budinst.gov.kh www.elibraryofcambodia.org

ហើយនៅសំភាកស្មៀមបែបនេះ ក្នុងអារម្មណ៍រីករាយចំពោះភាពស្ងប់ចិត្តបណ្តាលមកពីការបណ្តោយខ្លួនបែបនេះ ។ តែនៅមុនពេលដែលគេលង់លក់ គេបានទឹកអរគុណ *ម៉ារីកូ* ដែលបានបង្ហាត់បង្ហាញដល់រូបគេនេះផងដែរ ។

☆ ☆ ☆

*គីយ៉ូកូ* និយាយ :

- ចាស *អូមី - សាន* ។ ចាស ។ ខ្ញុំនឹងទៅហៅ *អាន់ជីន - សាន* ភ្លាម ។ សូមអភ័យទោសដល់ខ្ញុំផង ។ *អាកូ* មកជាមួយខ្ញុំ ។

*គីយ៉ូកូ* ក៏ប្រើ *អាកូ* ទៅយកតែមកបំរើភ្ញៀវ ឯខ្លួនឯងក៏រលះរលាំងទៅឯក្នុងសួនទាំងដណ្តឹងសួរនៅក្នុងចិត្ត មិនដឹងជានារសារដែលបំផាយសេះមកទាំងយប់នោះយកដំណឹងស្លាប់រស់របៀបណាមកអោយ ។ ព្រោះគាត់ក៏បានលឺសួរជើងសេះដូច *ក្លាក់ថន* ដែរ ។ រួចម៉េចបានជា *អូមី* ហាក់ដូចជាចំលែកម្ល៉េះនៅថ្ងៃនេះ - *គីយ៉ូកូ* គិតក្នុងចិត្ត ។ គាត់មានអាកប្បកិរិយាត្រជាក់ស្រេង គំរោះគំរើយ និងប្រកបដោយគ្រោះថ្នាក់ម្ល៉េះ ? ហេតុអីក៏គាត់មកធ្វើការកំប៉ិកកំប៉ុកនេះដោយខ្លួនឯងទៅវិញ ? ម៉េចក៏មិនប្រើ *សាមូរ៉ៃ* ណាម្នាក់មកវិញ ?

អ្ហា តើអ្នកណាដឹង ? *អូមី* ជាមនុស្សប្រុស ។ តើអ្នកណាទៅយល់ចិត្តពួកនេះបានពិសេសពួក *សាមូរ៉ៃ* នេះ ? តែមានអ្វីមួយដែលមិនប្រក្រតី ។ មិនប្រក្រតីមែនទែន ។ តើនារសារនាំយកដំណឹងប្រកាសសង្គ្រាមទេដឹង ? បើតាមអញស្មានប្រហែលអីចឹងហើយ ។ បើសិនជាមានសង្គ្រាមមែន គឺសង្គ្រាមហើយ ហើយសង្គ្រាមមិនដែលរាំងរានរបររកស៊ីពួកយើងទេ ។ ពួក *ដៃមីញ៉ូ* និងពួក *សាមូរ៉ៃ* នៅតែត្រូវការការកំសាន្តដូចសព្វដងតែអីចឹងរឹមានតែត្រូវការច្រើន ជាងផងនៅពេលមានសង្គ្រាម ។ ហើយនៅក្នុងសង្គ្រាមលុយមិនសំខាន់ទេសំរាប់ពួកគេទាំងនេះ ។ ល្អ ល្អ ល្អ ។

*គីយ៉ូកូ* ញញឹមពព្រាយ ។ ឯងនៅចាំពីពេលសង្គ្រាមកាលពីសែសិបឆ្នាំមុន ក្នុងពេលដែលឯងមានអាយុដប់ប្រាំពីរឆ្នាំ និងក្នុងពេលដែលឯងជាគ្រាប់គជ់នៃ *មីស៊ីម៉ា* រឺទេ ? តើឯងនៅចាំពីសំនើច ពីការរួមរក្ស និងពីរាត្រីដ៏អស្ចារ្យនានាដែលបានបន្តរហូតដល់ពេលថ្ងៃរី



www.budinst.gov.kh www.elibraryofcambodia.org

ទេ ? តើឯងនៅចាំពីការបំរើគាត់ពែកឪពុក *យ៉ាប៊ូ* ដែលជាសុភាពបុរសដ៏ល្អម្នាក់ ហើយដែលតែងស្មោរពូកឧក្រិដ្ឋជន ហើយដែលកូនគាត់បន្តធ្វើនេះរឺទេ ? យើងរួមរក្សាបីយប់បីថ្ងៃ រួចគាត់ក៏ក្លាយជាចៅកែអញ្ជូពេញមួយឆ្នាំ ។ កាលនោះចំជាសប្បាយមែន ។

សង្គ្រាម រឺ សន្តិភាព កុំទៅខ្វល់ ! តែនៅតែមានការវិវិនិយោគជានិច្ច ។ ជាមួយពួកចងការប្រាក់ឯនេះបន្តិច ជាមួយពួកឈ្មួញអង្ករឯនោះបន្តិច ។ រួចនៅមានកុងស៊ីស្រា *សាកេ* នៅ *អូដាវ៉ារ៉ា* ផ្ទះតែនៅ *មីស៊ីម៉ា* ហើយថ្ងៃនេះ លោកម្ចាស់ *តូរ៉ាណាកា* នឹងទិញយកកិច្ចសន្យារបស់ *គីគូ* ថែមទៀត ។

មែនហើយ នៅខាងមុខនេះគឺពិតជាពេលវេលាមួយដ៏មានសារសំខាន់ ហើយកាលពីយប់មិញនេះទៀតសោតក៏ចំជាមានសារសំខាន់មហាស្ចារ្យមែនតែម្តង ។ *គីគូ* សែនត្រចះត្រចង់ *អាន់ជីន-សាន* សែនមហាខ្ទរ ។ ហើយ *គីគូ* បានជួយស្តារស្ថានភាពនេះយ៉ាងប៉ិនប្រសប់ដូចជាអ្នកកំដរភ្ញៀវឯទៀតនៅក្នុងនគរនេះដែរ ។ រួចនៅពេលដែលអ្នកស្រី *តូដា* បានចាកចេញពីពួកគេទៅហើយនោះ សិល្បៈឯករបស់ *គីគូ* បានធ្វើអោយរាត្រីនេះពេញជារាត្រីទឹកឃ្មុំតែម្តង ។

ហ៊ឺ បុរស និង នារី ។ ពេញជាស្រួលកាត់ស្មានបានមែន ។ ពិសេសមនុស្សប្រុស ។

*គីយ៉ូកូ* លាន់សំនើចខឹកហើយដណ្តឹងសួរខ្លួនឯងជាលើកទីម៉ឺនដងថា តើបើសិនជាគ្មានមនុស្សប្រុសទេ តើពួកយើងនឹងទៅជាយ៉ាងណាទៅនៅក្នុងលោកនេះ ។

*គីយ៉ូកូ* ស្រូតដំណើរ ដោយខិតខំបន្លឺស្នូរជើងល្មមនឹងអោយគេដឹងពីវត្តមានរបស់ខ្លួនបាន ។ គាត់ឡើងជណ្តើរ ហើយគោះទ្វារ ។

- *អាន់ជីន - សាន* ! *អាន់ជីន - សាន* ! សូមអភ័យទោស ប៉ុន្តែលោកម្ចាស់ *តូរ៉ាណាកា* បានប្រើគេមកហៅលោកអោយទៅបន្ទាយភ្នាមនេះ ។

- ថាម៉េច ? អ្នកស្រីថាម៉េច ?

*គីយ៉ូកូ* និយាយម្តងទៀត ដោយប្រើពាក្យសាមញ្ញវិញម្តង ។

- អូហ៍ ! យល់ ! បាន ។ ខ្ញុំ កន្លែងនោះ រហ័ស - *គីយ៉ូកូ* លឺសំលេងឆ្លើយតប



www.budinst.gov.kh www.elibraryofcambodia.org

របស់ *ឆ្មាក់ថង* ប្រកបដោយសព្ទសំលេងដ៏គួរអោយអស់សំណើចរបស់ខ្លួន ។

- សូមទោស សូមអធ្យាស្រ័យអោយខ្ញុំផង ។ *គីតូ - សាន* ?

- ចាស *ម៉ាម៉ា - សាន* ?

បន្តិចក្រោយមក ទ្វារក៏ត្រូវទាញទៅម្ខាង ហើយលេចរូប *គីតូ* ទាំងញញឹមពព្រាយ។ *គីម៉ូណូ* របស់នាងឡើងសាកគ្រាក ហើយសក់របស់នាងឡើងរលាប្រកបដោយសោភ័ណភាពម៉្យាង :

- អរុណសួស្តី *ម៉ាម៉ា - សាន* ។ បានយល់សប្តិល្អទេ ?

- ល្អ ។ ល្អ ។ សូមអរគុណ ។ សូមទោសដែលរំខាននាងយ៉ាងដូចនេះ *គីតូ - ចាន* ។ តើនាងចង់បានតែទេ ?

- អូហ៍ !

ស្នាមញញឹមរលត់បាត់ភ្លាមពីផ្ទៃមុខរបស់ *គីតូ* ។ នេះគឺជាឃ្លាសំងាត់ដែល *គីយ៉ូកូ* អាចប្រើបានយ៉ាងសេរីនៅចំពោះមុខគ្រប់ភ្ញៀវទាំងអស់ហើយដែលមានន័យថា ភ្ញៀវពិសេសបំផុតរបស់នាង គឺ *អូមី - សាន* ស្ថិតនៅក្នុងផ្ទះតែ ។ នៅពេលនោះ *គីតូ* អាចបញ្ចប់ការនិយាយរឿង រាំចំរៀង រាំរបាំរបស់នាងបានរហ័សជាង ហើយបើសិនជានាងចង់ គឺនាងអាចទៅជួប *អូមី - សាន* បាន ។ *គីតូ* ទទួលរួមរក្សជាមួយភ្ញៀវតិចនាក់ណាស់ ថ្វីត្បិតតែនាងទទួលកំដរភ្ញៀវជាច្រើននាក់ក៏ដោយ ព្រោះភ្ញៀវតិចណាស់ដែលមានលទ្ធភាពបង់ថ្លៃការបំរើគ្រប់យ៉ាងរបស់នាងបាន ។

*គីយ៉ូកូ* សួរ :

- យ៉ាងម៉េចណឹង ?

- អត់យ៉ាងម៉េចទេ *ម៉ាម៉ា - សាន* - រួច *គីតូ* ស្រែកសួរយ៉ាងរីករាយ - *អាន់ជីន - សាន* តើលោកត្រូវការតែទេ ?

- បាទ សូមអរគុណ ។

- ទឹកតែមកដល់អីលូវហើយ - *គីយ៉ូកូ* តប - *អាកូ* ! ឆាប់ឡើងកូន !



www.budinst.gov.kh www.elibraryofcambodia.org

- ចាស អ្នកស្រី ។

*អាកូ* លើកថាសតែមកដោយមានពែងពីរផង ។ ក្រោយពីនាងចាក់តែហើយ *គីយ៉ូកូ* ក៏បានចាកចេញទៅវិញដោយសូមទោសម្តងទៀតពីការរំខានរបស់គាត់នេះ ។

*គីកូ* លើកពែងតែហុចទៅអោយ *ភ្ញាក់ថន* ។ ក្រោយពីគេទទួលទានទឹកតែរួចហើយ នាងក៏ជួយគេស្លៀកពាក់ទៀត ។ *អាកូ* បានទុកគីម៉ូណូថ្មីមួយសំរាប់ខ្លួននាងផងដែរ ។ ថ្វីត្បិតតែនាងបំពេញការងាររបស់នាងដោយយកចិត្តទុកដាក់ក្តី ក៏នៅក្នុងចិត្តនាងសែនខ្វាយខ្វល់អំពីគំនិតដែលនាងត្រូវជូនភ្ញៀវចេញផុតពីរបង ហើយលំអោនខ្លួនជូនដំណើរ *ភ្ញាក់ថន* ទៅវិញនេះ ។ នេះគឺជាសុជីវធម៌ ។ លើសពីនេះទៅទៀត នេះជាបុព្វសិទ្ធិ និងជាភារកិច្ចរបស់នាងតែម្តង ។ មានតែអ្នកកំដរភ្ញៀវថ្នាក់លេខមួយទេដែលត្រូវទទួលបានការអនុញ្ញាតអោយចេញផុតទ្វាររបងបែបនេះ អ្នកផ្សេងទៀតត្រូវនៅក្នុងទីធ្លា ។ គឺពិតជាមិនត្រឹមត្រូវទាល់តែសោះ ដែលនាងមិនបានបញ្ចប់រាត្រីរបស់នាងទៅតាមទំលាប់... នោះជាការប្រមាថដ៏ធ្ងន់ធ្ងរចំពោះភ្ញៀវ ហើយនឹងក៏...

នេះជាលើកទីមួយនៅក្នុងជីវិតរបស់នាងហើយ ដែល *គីកូ* មិនមានបំណងចង់លំអោនខ្លួនជូនដំណើរភ្ញៀវនៅចំពោះមុខភ្ញៀវម្នាក់ទៀតនោះ ។

អញធ្វើទៅមិនកើតទេ ។ អញមិនអាចលំអោនខ្លួនជូនដំណើរ *អាន់ជីន - សាន* នៅចំពោះមុខ *អូមី - សាន* បានទេ ។

ហេតុអីទៅ ? នាងដណ្តឹងសួរខ្លួនឯង ។ តើនេះដោយសារ *អាន់ជីន - សាន* ជាមនុស្សចុងស្រុក ហើយឯងខ្មាសខ្លាចគេទាំងអស់គ្នាដឹងថាមនុស្សចុងស្រុកបានខ្លួនឯងអី ? ទេ ។ មួយ *អាន់ជីន្ញូ* នេះគេដឹងគ្រប់គ្នាទៅហើយៗស្ទើរគ្រប់ពេល មនុស្សប្រុសណាក៏ដូចមនុស្សប្រុសណាដែរ ។ បុរសនេះជា *សាមូរ៉ៃ* ជា *ហាតាម៉ូតូ* និងជាឧត្តមនាវីនៃកងសំពៅរបស់លោកម្ចាស់ *តូរ៉ាណាកា* ទៅទៀត ! ទេ គ្មានរឿងអៀនខ្មាសបែបណឹងទេ ។

បើអីចឹង តើជាស្អីទៅវិញទៅ ?

នេះមកពីយប់មិញអញបានដឹងថា អញមានការអាម៉ាស់ព្រោះតែអ្វីដែល *អូមី -*



www.budinst.gov.kh www.elibraryofcambodia.org

*សាន* បានប្រព្រឹត្តទៅលើរូបគាត់ ។ *អូមី - សាន* មិនគួរធ្វើបែបនេះសោះ ។ *អាន់ជីន - សាន* នៅមានគំនុំនៅឡើយ ហើយអញអាចមានអារម្មណ៍ដឹងបានពីគំនុំនេះដែលកាយឆ្លងកាត់គីម៉ូណូរបស់គាត់មកតាមម្រាមដៃរបស់អញ ។ អញសែនខ្មាសជំនួសគាត់ ។ មនុស្សល្អម្នាក់ដែលគេមិនគួរប្រព្រឹត្តបែបនេះទៅលើសោះ ។

រួចនៅក្នុងជ្រុងមួយនៃអារម្មណ៍របស់នាង១បានលឺសំលេងរបស់ *ម៉ាម៉ា - សាន* ម្តងទៀត ។ កូន ! កូន ! ទុករឿងប្រុស១អោយប្រុស១ទៅ ។ សំនើចជាប្រេងរីតរបស់យើងទប់ទល់នឹងពួកគេ ទប់ទល់នឹងពិភពលោក នឹងទេវតា នឹងជរាភាពផង ។

- *គីឌូ - សាន ?*

- ចាស *អាន់ជីន - សាន ?*

- អីលូវនេះខ្ញុំទៅ ។

- ចាស យើងចេញទាំងអស់គ្នា - នាងតប ។

គេយកដៃដ៏ក្រិនរបស់គេកាន់មុខនាងយ៉ាងថ្នម១ ហើយថើបនាង :

- អរគុណ ។ អត់មានពាក្យគ្រប់គ្រាន់ដើម្បីអរគុណទេ ។

- គឺខ្ញុំទេដែលត្រូវអរគុណលោកនោះ ។ សូមលោកអនុញ្ញាតអោយខ្ញុំបានថ្លែងអំនរគុណចំពោះលោកផង ។ អីលូវនេះយើងចេញទៅទាំងអស់គ្នា ។

នាងអោយ *អាកូ* សំរូលជាចុងក្រោយនូវសក់របស់នាងដែលចងទំលាក់សំយាកសំរូល *គីម៉ូណូ* ថ្មី រួចទើបចេញទៅជាមួយ *ឲ្យាក់ថន* ។

នាងដើរចំហៀង *ឲ្យាក់ថន* ដែលជាបុព្វសិទ្ធិរបស់នាង ពោលគឺនាងមិនដើរពីក្រោយពីរបីជំហានដូចប្រពន្ធ ប្រពន្ធចុង រឺកូនស្រី រឺអ្នកបំរើនោះទេ ។ *ឲ្យាក់ថន* ដាក់ដៃលើស្មានាងមួយភ្លែត ហើយកាយវិការនេះធ្វើអោយនាងមិនពេញចិត្តទាល់តែសោះ ដោយថា ពួកគេទាំងពីរនាក់ឥតនៅក្នុងភាពសំងាត់នៃបន្ទប់ទៀតទេ ។ រួចនាងក៏មានពិភាល់មួយដ៏តក់ស្លុត នោះគឺ *អាន់ជីន - សាន* នឹងថើបនាងនៅមុខគេឯងនៅឯមាត់ទ្វារ ដែលជាទំលាប់បែបពួកអ្នកចុងស្រុក ហើយដែល *ម៉ារីកូ* ទើបបាននិយាយប្រាប់នាង ។



www.budinst.gov.kh www.elibraryofcambodia.org

ឱ ! ព្រះអង្គអើយព្រះអង្គ យ៉ាងម៉េចយ៉ាងម៉ាសូមកុំអោយមានរឿងបែបនេះអោយសោះលោក ។ គ្រាន់តែគិតពីរឿងនេះ *គីតូ* រឹតតែសន្ធប់បាត់ស្មារតីទៅហើយ ។

ដាវរបស់ *ប្លាក់ថន* នៅឯក្នុងបន្ទប់ទទួលភ្ញៀវ ។ ជាទំលាប់ អាវុធទាំងអស់ត្រូវទុកអោយគេមើលថែរក្សាអោយ មិនត្រូវនាំចូលទៅក្នុងបន្ទប់កំសាន្តឡើយ ម្យ៉ាងដើម្បីចៀសវាងការប្រកាប់ប្រចាក់ស្លាប់រស់រវាងភ្ញៀវ និង ម្យ៉ាងទៀតដើម្បីបង្ការក្រែងមាននារីកំដរភ្ញៀវណាមួយមានបំណងចង់ប្រើអាវុធទាំងនោះដើម្បីបញ្ចប់ជីវិតរបស់ខ្លួនផង ។ ព្រោះថា មិនមែនគ្រប់តែនារីនៃពិភពដើមសូលសុទ្ធតែមានសុភមង្គល រឺ មានសំនាងទាំងអស់គ្នានោះទេ ។

*ប្លាក់ថន* ស៊កដាវទៅក្នុងក្រណាត់ក្រវាត់ចង្កេះ ។ *គីតូ* លំអោនខ្លួនគោរពគេរហូតដល់សំយាបផ្ទះ ។ *គីយ៉ូកូ* និងអ្នកឯទៀតនៅជុំគ្នាដើម្បីគោរពជូនដំណើរគេ ក្នុងឋានៈជាភ្ញៀវកិត្តិយស ។ ផុតពីមាត់ទ្វាររបង គឺជាទីផ្លាភូមិ ហើយនឹងសមុទ្ទ ។ *សាមូរ៉ៃ* ជាច្រើននាក់កំពុងដើរត្រែតត្រតនៅទីនោះ ។ *ប៊ុនតារ៉ូ* ក៏មានវត្តមាននៅទីនោះដែរ ។ *គីតូ* រកមើលមិនឃើញ *អូមី* សោះ ថ្វីត្បិតតែនាងដឹងច្បាស់ថា បុរសនេះកំពុងតាមសំលឹងមើលនាងពីក្នុងកន្លែងណាមួយក៏ដោយ ។

*អាន់ជីន - សាន* ហាក់មានមាឌធំសំបើមតែម្តង ដល់អីចឹងទៅនាងដែលនៅជិតរូបគេនេះហាក់ដូចជាតូចច្រមក់ទៅវិញ ។ នៅពេលដែលពួកគេដើរកាត់សួនច្បារទើបពួកគេប្រទះឃើញ *អូមី* ដែលនៅឈរក្បែរមាត់ច្រកទ្វាររបង ។

*ប្លាក់ថន* ក៏ឈប់ភ្លាម :

- អរុណសួស្តី *អូមី - សាន* ។

គេពោលទៅកាន់ *អូមី* ក្នុងឋានៈជាមិត្ត ហើយលំអោនខ្លួនគោរពក្នុងឋានៈជាមិត្តដែរ តែគេមិនដឹងថារវាង *អូមី* នឹង *តូតី* ទាំងពីរនាក់នោះលើសពីមិត្តទៅទៀតឡើយ ។ គ្មានអ្នកណាម្នាក់បានប្រាប់គេទេ ហើយគ្មានហេតុផលអ្វីដែលពួកគេត្រូវប្រាប់ទៅ *ប្លាក់ថន* ផងដែរទេ ។ ហើយប្រាប់ រឺមិនប្រាប់តើវាមានខុសគ្នាត្រង់ណាទៅ ?

- អរុណសួស្តី *អាន់ជីន -សាន* ។



www.budinst.gov.kh www.elibraryofcambodia.org

សំលេង *អូមី* ក៏មានលក្ខណៈជាមិត្តភាពដូចគ្នាដែរ តែ *គីគូ* បានសំគាល់ឃើញថា *អូមី* លំអោនខ្លួនតបវិញត្រឹមតែមួយគួរសមយ៉ាងល្មមតែប៉ុននោះ ។ បន្ទាប់មកភ្នែកដ៏ខ្មៅក្រិប របស់គេងាកមករកនាងវិញម្តង ។ នាងញញឹមយ៉ាងស្រស់ ហើយលំអោនខ្លួនគោរពភ្លាម :

- អរុណសួស្តី *អូមី - សាន* ។ ផ្ទះនេះមានកិត្តិយសណាស់ ។

- អរគុណ *គីគូ - សាន* ។ អរគុណ ។

នាងដឹងថា ភ្នែកបុរសនេះកំពុងសំលឹងពិនិត្យរូបនាង តែនាងធ្វើជាមិនដឹង ដោយនៅតែរក្សាភ្នែកនាងសំលឹងទៅក្រោមដដែល ។ *គីយ៉ូកូ* ពួកស្រីបំរើ និង ពួកនារីកំដរភ្ញៀវដែលទំនេរដៃទាំងប៉ុន្មានឈរសំលឹងមើលពីក្រោមសំយាបផ្ទះ ។

*ប្លាក់ថន* ពោលឡើង :

- ខ្ញុំទៅបន្ទាយ ។ អ្វីៗស្រួលបួលទេ ?

- ស្រួលបួលទេ ។ លោកម្ចាស់ *តូរ៉ាណាកា* អោយមកហៅលោក ។

- ទៅអីលូវហើយ ។ សង្ឃឹមថាបន្តិចទៀតនឹងជួបគ្នា ។

- បាទ ។

*គីគូ* ងើបមុខឡើង ។ *អូមី* នៅតែសំលឹងមើលរូបនាងជាប់ ។ នាងញញឹមផ្ទាក់ល្វែខមួយដាក់គេ ហើយងាកទៅមើល *អាន់ជីន - សាន* វិញម្តង ។ គេកំពុងតែសំលឹងមើល *អូមី* យ៉ាងមុត តែនៅពេលដែលគេមានអារម្មណ៍ថា ក្រសែភ្នែកនាងផ្តោតមកលើរូបគេនោះគេក៏ងាកមករកនាង ហើយញញឹមតប ។ ចំពោះរូបនាងៗមានអារម្មណ៍ថា នោះគឺជាការញញឹមទាំងបង្ខំ ។

- សូមអភ័យទោស *គីគូ - សាន* *អូមី - សាន* ។ ខ្ញុំត្រូវទៅហើយ ។

គេលំអោនគោរព *អូមី* ។ *អូមី* គោរពតបវិញ ។ គេចេញឆ្លងកាត់ទ្វាររបងដោយមាន *គីគូ* ដើរតាមពីក្រោយទាំងស្ទើរមិនបានដកដង្ហើម ។ ចលនាទាំងឡាយនៅឯច្បារ៉ិមិបានឈប់ទ្រឹង ។ នៅក្នុងភាពស្ងប់ស្ងាត់នេះ នាងឃើញ *ប្លាក់ថន* បែរខ្លួនមកវិញ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងខណៈដ៏សែនវន្ទត់នោះនាងគិតថា គេច្បាស់ជាអោបនាងថើបជាមិនខាន ។ តែនាងក៏បានធូរទ្រូងសន្ទឹកដោយនាងបានឃើញថា *ប្លាក់ថន* ឥតបានធ្វើដូចនាងបានគិតនោះទេ គេគ្រាន់តែឈរវង់ចាំនូវអ្វីដែលមនុស្សមានអារ្យធម៌ទាំងឡាយត្រូវវង់ចាំតែប៉ុននោះ ។

នាងលំអោនខ្លួនដោយសុភាពដ៏ទន់ភ្លន់បំផុតរបស់នាង ។ ភ្នែករបស់ *អូមី* ប្រៀបដូចជាផ្លែព្រូញរាប់មិនអស់ចាក់ទំលាយសព្វសាច់របស់នាង ។ នាងពោលទាំងញញឹម :

- សូមអរគុណ *អាន់ជីន - សាន* ។

ភាពធូរទ្រូងបានកើតមានឡើងវិញនៅឯទីធ្លាភូមិ ។ នាងពោលបន្ថែម :

- សូមអញ្ជើញមកលេងទៀត ។ នាងខ្ញុំនឹងអង្គុយរាប់រហូតដល់ថ្ងៃដែលយើងនឹងជួបគ្នាជាថ្មីម្តងទៀត ។

គេលំអោនខ្លួនយ៉ាងល្មមបែបវ៉ាហ៊ី ហើយដើរចេញទៅយ៉ាងកោងក្នុងឋានៈជា *សាមូរ៉ៃ* ថ្នាក់ខ្ពស់ម្នាក់ ។ បន្ទាប់មក ដោយគោរពការរាប់អានដ៏ថ្លៃថ្នូររបស់ *ប្លាក់ថន* ផង និងដើម្បីផ្តន្ទា *អូមី* ចំពោះភាពដ៏ត្រជាក់មិនចាំបាច់នៃការលំអោនខ្លួនរបស់បុរសនេះផងនោះ នាងមិនបានចូលទៅក្នុងផ្ទះវិញភ្លាមទេ តែនាងនៅបន្តឈរនៅកន្លែងដដែល ហើយតាមមើលគេរហូត ដែលជាការផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ដល់ *អាន់ជីន - សាន* ទៅវិញ ។ នាងនៅឈររហូតដល់ពេលដែល *ប្លាក់ថន* ដើរដល់ផ្លូវកែងចុងក្រោយ ។ នាងឃើញគេងាកមកក្រោយហើយលើកដៃគ្រវី ។ នាងលំអោនខ្លួនយ៉ាងទាប នៅក្នុងចិត្តនាងសែនរីករាយចំពោះការយកចិត្តទុកដាក់ដែលកំពុងកើតមាននៅក្នុងទីធ្លាភូមិ ។ ប៉ុន្តែនាងធ្វើជាមិនបានកត់សំគាល់អ្វីទាំងអស់ ។ ហើយទាល់តែបាត់ស្រមោលរបស់ *ប្លាក់ថន* ទើបនាងដើរចូលទៅក្នុងផ្ទះវិញ ។ ដើរចូលយ៉ាងមោទនៈ និងឆើតឆាយគួរពេចពិលរមិលមើល ។ បុរសទាំងអស់តាមសំលឹងមើលរូបនាងទាំងភ្លេចភ្លាំងនឹងសំរស់ដ៏អស្ចារ្យរបស់នាង ។ ម្នាក់ៗ នឹកចង់បានដូចជា *អាន់ជីន - សាន* ដែលប្រហែលសមជាបុរសពេញលក្ខណៈតែម្តង ទើបបានជានាងឈរចាំជូនដំណើរគេយ៉ាងនេះ ។

*អូមី* ពោលទៅរកនាង :



www.budinst.gov.kh www.elibraryofcambodia.org

- នាងចំជាស្អាតមែន ។

-ខ្ញុំសង្ឃឹមថានេះជាការពិតទៅចុះ *អូមី-សាន*-នាងតបទាំងការញញឹមថ្នាក់លេខពីររបស់នាងផង - តើលោកត្រូវការតែទេ *អូមី - សាន* ? រឺមួយត្រូវការម្ហូបអាហារទទួលទានវិញ ?

- បើជាមួយនាង ខ្ញុំយល់ព្រម ។

*គីយ៉ូកូ* ក៏មកដល់ដែរ ដោយប្រើសំដីយ៉ាងផ្អែមដូចទឹកឃ្មុំ :

- សូមអភ័យទោសចំពោះកង្វះសុជីវធម៌របស់ខ្ញុំផង *អូមី - សាន* ។ សូមនៅពិសាអាហារជាមួយពួកយើងទៅ ។ តើលោកបានស្រស់ស្រូបអាហារដំបូងហើយរឺនៅ ?

- នៅទេ ។ មិនទាន់ទេ ។ ប៉ុន្តែខ្ញុំអត់ឃ្លានទេ - គេចោលភ្នែករំលងមើលទៅ *គីកូ* - នាងទទួលទានហើយរឺនៅ ?

*គីយ៉ូកូ* កាត់ភ្លាម :

- សូមអនុញ្ញាតអោយពួកយើងជូនម្ហូបសមសួនខ្លះជូនលោកពិសាផង ។ *គីកូ - សាន* ពេលនាងផ្លាស់សំលៀកបំពាក់ហើយ នាងមកចូលរួមជាមួយយើង *នេ* ?

- ពិតជាអីចឹង ។ សូមអភ័យទោសដល់ខ្ញុំផង *អូមី - សាន* ដែលខ្ញុំស្លៀកពាក់បែបនេះចេញមក ។ សូមទោស ។

ហើយនាងក៏រត់ចេញទៅធ្វើហាក់ដូចជាសប្បាយចិត្តណាស់ ។ តែក្នុងអារម្មណ៍របស់នាងគឺទទេស្អាត ។ *អាកូ* ក៏ទៅតាមនាងតត្រុកទៅ ។

*អូមី* និយាយយ៉ាងខ្លី :

- ខ្ញុំចង់នៅជាមួយនាងយប់នេះ ។ ដើម្បីហូបចុក និង កំសាន្ត ។

- ចាស បាន *អូមី - សាន - គីយ៉ូកូ* ឆ្លើយតបដោយលំអោនខ្លួនយ៉ាងយូរ និងដោយដឹងច្បាស់ថា *គីកូ* ពិតជានឹងមិនទំនេរឡើយនៅយប់នេះ - លោកបានផ្តល់កិត្តិយសដល់ផ្ទះនេះ ហើយនឹងផ្តល់កិត្តិយសកាន់តែធំធេងណាស់ទៅទៀតដល់ពួកយើងខ្ញុំ ។ *គីកូ - សាន* មានសំនាងណាស់ដែលបានលោករាប់អាននាងយ៉ាងនេះ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* ស្ទើរងាច់ផ្ការ :

- បីពាន់*កូតូ* ?

- ចាស លោកម្ចាស់ ។

*ម៉ារីកូ* ឆ្លើយតប ។ ពួកគេនៅក្រោមសំយាបមួយនៅក្នុងបន្ទាយ ហើយដែលសំរាប់តែ *តូរ៉ាណាកា* ម្នាក់ប៉ុណ្ណោះ ។ ភ្លៀងបានចាប់ផ្តើមធ្លាក់ ប៉ុន្តែចំហាយក្តៅឥតបានរលត់បាត់ឡើយ ។ នាងមានអារម្មណ៍រសេះរសោះ អស់កំលាំង ហើយទន្ទឹងរង់ចាំតែភាពត្រជាក់នៃរដូវស្លឹកឈើធ្លាក់ ។ នាងពោលបន្ត :

- អោយខ្ញុំសូមអភ័យទោសផងចុះ ប៉ុន្តែខ្ញុំមិនអាចអោយយាយនោះចុះថ្លៃជាងនេះទៀតបានទេ ។ ខ្ញុំនិយាយរហូតដល់ជិតក្លឹងណោះ ។ សូមលោកម្ចាស់អភ័យទោសផងទៅចុះ ប៉ុន្តែលោកម្ចាស់បានបញ្ជាអោយខ្ញុំដោះស្រាយអោយបានក្នុងយប់មិញនេះ ។

- តែបីពាន់ ណា *ម៉ារីកូ - សាន* ! នេះគឺហុតឈាមតែម្តង !

ពេលនេះ *តូរ៉ាណាកា* សប្បាយចិត្ត ដោយមានបញ្ហាថ្មីមកបង្វែរអារម្មណ៍ របស់លោកចេញពីអ្វីដែលកំពុងធ្វើអោយលោកខ្វាយខ្វល់នោះ ។ បព្វជិតគ្រិស្ត *ឈូតូ - សាន* ធ្វើដំណើរជាមួយ *សាតាគី* ដែលជាសមាជិកថ្មីដ៏ក្រអឺតក្រទមនៃក្រុមប្រឹក្សាអាជ្ញានុសិទ្ធិនេះ គ្មានអ្វីក្រៅតែពីនាំរឿងដ៏រញ៉េរញ៉ៃតែប៉ុណ្ណោះ ។ លោកបានពិនិត្យគ្រប់លទ្ធភាពគេចខ្លួន ពិនិត្យគ្រប់ផ្លូវសំរាប់ដកថយ និង វាយលុក ចំលើយគឺមានតែមួយ : បើសិនជា *អ៊ីស៊ីដូ* ចល័តទ័ពរហ័ស អញនឹងបរាជ័យ ។

អញត្រូវតែរកពេលបន្ថែម ។ តែតើរកយ៉ាងម៉េច ?

បើសិនអញជា *អ៊ីស៊ីដូ* វិញ អញនឹងចាប់ផ្តើមអីលូវនេះ ។ ចាប់ផ្តើមមុនពេលរដូវភ្លៀងចប់ ។

អញនឹងដាក់កងទ័ពក្នុងស្ថានភាពដូចដែលលោកម្ចាស់ *រីគូ* និងអញបានរៀបចំដើម្បីបំផ្លាញ *របបតូ* យ៉ាងនោះដែរ ។ ផែនការដែលនឹងនាំមកនូវជ័យជំនះជានិច្ច ។ ងាយដូចបកចេក ! *អ៊ីស៊ីដូ* មិនល្ងង់រហូតដល់ថ្នាក់ទៅមើលមិនឃើញថា ផ្លូវតែមួយគត់ដើម្បីការពារ *ក្វាន់តូ* បាន គឺត្រូវកាន់កាប់ *អូសាកា* និងដែនដីទាំងអស់ដែលនៅចន្លោះ *យេដូ* នឹង



www.budinst.gov.kh www.elibraryofcambodia.org

*អូសាកា* នោះទេ ។ ដារាបណា *អូសាកា* នៅតែប្រទូស្តរ៉ាយ *ក្វាន់តូ* ត្រូវតែស្ថិតក្នុងគ្រោះថ្នាក់ជានិច្ច ។ លោកម្ចាស់ *រ៉ៃកូ* យល់ពីរឿងនេះណាស់ បើមិនអីចឹង ម៉េចគាត់អោយតំបន់នេះមកអញធ្វើអ្វី ? បើគ្មាន *គីយ៉ាម៉ា* និងបព្វជិតចុងស្រុកនេះ...

លោកបានប្រឹងប្រែងយ៉ាងខ្លាំង ដើម្បីជំរុញរឿងថ្លៃស្អែកទៅក្នុងខណ្ឌរបស់វា ហើយវិលមកផ្តោតទាំងស្រុងលើចំនួនប្រាក់ដ៏សំបើមនេះវិញ :

- បីពាន់ *ក្វូតូ* គឺមិនបាច់និយាយទេ !

- ខ្ញុំឯកភាព លោកម្ចាស់ ។ លោកម្ចាស់មានយោបល់ត្រូវណាស់ ។ ទាំងនេះគឺជាកំហុសរបស់ខ្ញុំទាំងស្រុង ។ ខ្ញុំគិតថា សូម្បីតែប្រាំរយក៏វាថ្លៃហួសផង តែ *គីយ៉ូកូ* មិនព្រមចុះថោកជាងនេះសោះតែម្តង ។ តែគាត់ក៏ព្រមលើសម្បទានមួយដែរចាស ។

- សម្បទានស្អីទៅ ?

- *គីយ៉ូកូ* អង្វរសូមកិត្តិយសបញ្ចុះថ្លៃនៅត្រឹមពីរពាន់ប្រាំរយ *ក្វូតូ* បើសិនជាលោកម្ចាស់ព្រមជួបគាត់មួយធ្លប ។

- *ម៉ាម៉ា - សាន* ម្នាក់សុខចិត្តចោលលុយប្រាំរយ *ក្វូតូ* ដោយគ្រាន់តែបាននិយាយជាមួយខ្ញុំ ?

- ចាស ពិតមែនលោកម្ចាស់ ។

- ហេតុអីទៅ - លោកសួរទាំងចិត្តសង្ស័យ ។

- គាត់បានពន្យល់ខ្ញុំពីមូលហេតុរបស់គាត់ ប៉ុន្តែគាត់បានអង្វរករខ្ញុំ សូមទុកអោយគាត់បានទទួលការអនុញ្ញាតពន្យល់ជូនលោកម្ចាស់ដោយផ្ទាល់ខ្លួនគាត់វិញ ។ ខ្ញុំជឿថាសំនើរបស់គាត់ពិតជានឹងធ្វើអោយលោកម្ចាស់យកចិត្តទុកដាក់ ។ម្យ៉ាងទៀតប្រាំរយ *ក្វូតូ...* នេះក៏សន្សំបានច្រើនដែរ ។ ខ្ញុំបារម្ភណាស់ដែលមិនអាចធ្វើការងារនេះអោយបានល្អជាងនេះ ថ្វីត្បិតតែ *គីគូ - សាន* ជាស្រីថ្នាក់លេខមួយ ហើយសក្តិសមនឹងឋានៈនេះក្តី ។ ខ្ញុំដឹងថា ខ្ញុំបានធ្វើអោយលោកម្ចាស់ខកចិត្តស្រលះហើយ ។

- ខ្ញុំឯកភាពហើយ - *តូរ៉ាណាកា* និយាយយ៉ាងកំបុត - ទោះត្រឹមមួយពាន់ *ក្វូតូ* ក៏នៅ



www.budinst.gov.kh www.elibraryofcambodia.org

តែច្រើនហួសដែរ ។ ទីនេះជា *អ៊ីស៊ូ* មិនមែន *ក្យូតូ* ទេ !

- លោកម្ចាស់ពិតជាមានប្រសាសន៍ត្រូវណាស់ ។ ខ្ញុំបានប្រាប់យាយនោះដែរថា តំលៃនេះកំប្លុកកំប្លែងពេកហើយ។ សូម្បីតែខ្លួនខ្ញុំផ្ទាល់ក៏មិនអាចយល់ព្រមបានដែរ ទោះជាលោកម្ចាស់បញ្ជាមកខ្ញុំផ្ទាល់អោយធ្វើការតថ្លៃនេះ អោយបានចប់សព្វគ្រប់ពីយប់មិញនេះក្ដី ។ ខ្ញុំសង្ឃឹមថា លោកម្ចាស់នឹងអត់អោនដល់ការមិនស្ដាប់បញ្ជានេះផង ។ តែខ្ញុំបានគិតថា ដំបូងបង្អស់ខ្ញុំត្រូវពិគ្រោះជាមួយលោកស្រី *កាស៊ុគី* ម្ដាយរបស់ *អូមី - សាន* សិន ដោយថា លោកស្រីជាមនុស្សចាស់ទុំជាងគេនៅទីនេះ មុននឹងសំរេចរឿងនេះជាផ្លូវការ ។

*តូរ៉ាណាកា* រឹកទឹកមុខឡើងវិញ ។ កង្វល់ឯទៀតក៏ត្រូវបានភ្លេចបាត់ទៅហើយដែរ:

- អូហ៍ បើអីចឹងរឿងហ្នឹងសំរេចរួចហើយ គ្រាន់មិនទាន់សំរេចនៅឡើយទើ ?

- ចាស លោកម្ចាស់ រឿងនេះមិនទាន់ដល់ចងចំនងនឹងគ្នានៅឡើយទេ ដរាបណាខ្ញុំមិនបានពិគ្រោះជាមួយលោកស្រីម្ដាយ *អូមី - សាន* នោះ ។ ខ្ញុំបាននិយាយថា ខ្ញុំនឹងផ្ដល់ចំលើយនៅវេលាថ្ងៃត្រង់នេះ ។ សូមលោកម្ចាស់អភ័យទោសដែលខ្ញុំមិនស្ដាប់តាមបញ្ជារបស់លោកម្ចាស់ ។

- នាងគួរតែដោះស្រាយតាមការបញ្ជារបស់ខ្ញុំ !

តែនៅក្នុងចិត្ត *តូរ៉ាណាកា* សែនរីករាយ ដោយ *ម៉ារីកូ* បានវាងវៃទុកឱកាសអោយលោកជាអ្នកសំរេចថាយល់ព្រម រឺមិនយល់ព្រមដោយមិនបាក់មុខ ។ គឺជាការមិនសមរម្យទេ ដែលមនុស្សដូចលោកមករញ៉ីរញ៉ៃពីរឿងលុយកាក់នោះ ។ តែម៉េអ្ហើយបីពាន់*កូគូ*...

- នាងនិយាយថា កិច្ចសន្យារបស់ស្រី នោះល្មមនឹងចិញ្ចឹមបាយគ្រួសារមួយពាន់ជ្រើក្នុងរយៈបីឆ្នាំបានអ្វី ?

- តំលៃវាសមនឹងគ្រាប់អង្ករទាំងនោះ បើសិនជាស្រីនោះសំរាប់មនុស្សដែលគួរនឹងបាននាង ។

ភ្នែករបស់ *តូរ៉ាណាកា* សំលឹងមើលនាងយ៉ាងមុត :



www.budinst.gov.kh www.elibraryofcambodia.org

- អូហ៎ អីចឹងផង ? មើលនិយាយប្រាប់ខ្ញុំពីនាង និងរឿងរ៉ាវដែលកើតមានឡើងផងទៅមើល ?

នាងក៏និយាយប្រាប់លោកទាំងសព្វទាំងគ្រប់ លើកលែងតែមនោសញ្ចេតនារបស់នាងចំពោះ *អាន់ជីន - សាន* ហើយនឹងមនោញ្ចេតនាដ៏ជ្រាលជ្រៅរបស់គេចំពោះនាង ។ ហើយនិងអ្វីដែល *គីគូ* បានស្នើដល់នាង ។

- ល្អ ។ ល្អមែនទែន ។ នេះបានចំជាវាងវៃមែន ។ គាត់ច្បាស់ជាធ្វើអោយនាងពេញចិត្តណាស់ បានជានាងឈរយ៉ាងនេះនៅឯមាត់ទ្វាររបងនៅពេលលើកដំបូងយ៉ាងនេះ ។

មនុស្សភាគច្រើននៅ *អាន់ជ៉ី* បានរង់ចាំពេលវេលានោះ ដើម្បីចង់ដឹងថា តើអ្នកទាំងពីរនាក់នឹងប្រកាន់អាកប្បកិរិយាបែបណា ម្នាក់ជាមនុស្សចុងស្រុក ម្នាក់ជាធីតាដើមសួលផ្កាក់ទីមួយ ។

- ចាស ពិតហើយ ។

- គិតទៅ បី *គូគូ* ដែលវិនិយោគទៅនោះមិនខាតទេ ។ អីលូវនេះកេរ្តិ៍ឈ្មោះរបស់គាត់នឹងរត់នាំមុខគាត់ជាមិនខាន ។

- ចាស ។

*ម៉ារីកូ* ឯកភាពទាំងក្នុងចិត្តមោទនភាពមិនតិចទេចំពោះ *ប្អាក់ថន* ។ នាងបន្ត :

- នាងនោះ គឺពិតជាពិសេសតែម្តងលោកម្ចាស់ ។

*តូរ៉ាណាកា* សែនជឿងឆ្ងល់នឹងទំនុកចិត្តរបស់ *ម៉ារីកូ* ទៅលើការដោះស្រាយរបស់នាងនេះជាពន់ពេក ។ តែប្រាំរយ *គូគូ* សំរាប់កិច្ចសន្យា គឺពិតជាលើសពីសមរម្យណាស់ទៅហើយ ។ ប្រាំរយ *គូគូ* គឺជាចំនួនមួយដែល *ម៉ាម៉ា - សាន* ភាគច្រើនរកមិនបានផងក្នុងមួយជីវិតរបស់ខ្លួន ។ ហេតុនេះ និយាយពី *ម៉ាម៉ា - សាន* ម្នាក់សុខចិត្តចោលប្រាំរយ *គូគូ*...

- នាងនិយាយថា តំលៃវាសមនឹងគ្រាប់អង្ករទាំងនោះ មែនអ្វី ? ខ្ញុំពិបាកជឿណាស់ ។

- សំរាប់បុរសដែលគួរទទួលបានរូបនាងលោកម្ចាស់ ។ តែខ្ញុំមិនអាចវិនិច្ឆ័យបានថា



www.budinst.gov.kh www.elibraryofcambodia.org

បុរសណាទៅដែលគួរនោះឡើយ ។

ស្នូរគោះទ្វារលាន់លឺឡើង ។

- មានការអីហ្នឹង ?

- *អាន់ជីន - សាន* កំពុងនៅឯទ្វារធំ លោកម្ចាស់ ។

- នាំគាត់មកនេះមក ។

- បាទ ទាន ។

*តូរ៉ាណាកា* បក់ផ្ចិតបណ្ដើរ លួចសំលឹងមើល *ម៉ារីកូ* បណ្ដើរ ។ លោកបានប្រទះឃើញរង្វង់ភក្ត្ររបស់នាងជះចេញនូវពន្លឺមួយភ្លែតឡើង ។ មុននេះ លោកបានលាក់ដោយចេតនាពីប្រការដែលលោកបានប្រើអោយគេទៅហៅ *ប្លាក់ថន* មកកាន់ទីនេះ ។

តើដោះស្រាយយ៉ាងម៉េច ? អ្វីៗដែលបានគ្រោងទៅតែបន្តអនុវត្ត ។ តែនៅពេលនេះ អញត្រូវការ *ប៊ុនតារ៉ូ*, *អាន់ជីន - សាន* និង *អូមី - សាន* ជាងពេលណាៗទាំងអស់ ។ ហើយរឹតតែត្រូវការ *ម៉ារីកូ* ណាស់តែមែនទែនតែម្ដង ។

- អរុណសួស្ដី *តូរ៉ាណាកា - សាម៉ា* ។

លោកលំអោនខ្លួនតប ហើយកត់សំគាល់នូវភាពកក់ក្ដៅដែលលេចឡើងភ្លាមៗបន្ទាប់ពីបុរសនេះឃើញ *ម៉ារីកូ* នោះមក ។ ក្រោយពីនិយាយគួរសមសព្វបែបយ៉ាងមកលោកក៏ពោលឡើង :

- *ម៉ារីកូ - សាន* សូមប្រាប់គាត់ថា គាត់ត្រូវចេញដំណើរជាមួយខ្ញុំនៅពេលព្រឹមនេះ ។ រួចនាងក៏អីចឹងដែរ ។ រួចនាងត្រូវបន្តដំណើរទៅ *អូសាកា* ។

ភាពព្រឺព្រួចបានរត់កាត់សព្វសពាង្គកាយរបស់នាង :

- ចាស លោកម្ចាស់ ។

*ប្លាក់ថន* សួរ :

- ខ្ញុំទៅ *អូសាកា* រឺ *តូរ៉ាណាកា - សាម៉ា* ?

- ទេ *អាន់ជីន - សាន* ។ *ម៉ារីកូ - សាន* ប្រាប់គាត់ថា ខ្ញុំទៅ *ស៊្សា ស៊ូចិនជី*



www.budinst.gov.kh www.elibraryofcambodia.org

ប្រហែលមួយថ្ងៃ រឺ ពីរ ។ អ្នកទាំងពីរនាក់រួមដំណើរជាមួយខ្ញុំទៅទីនោះ ។ នាងនឹងបន្តដំណើរទៅ *អូសាកា* ។ គាត់នឹងបន្តដំណើរជាមួយនាងរហូតដល់ព្រំតំបន់ រួចគាត់បន្តដំណើរតែម្នាក់ឯងទៅ *យេដូ* ។

លោកសង្កេតមើលអ្នកទាំងពីរជាប់ ក្នុងខណៈដែល *ប្លាក់ថន* កំពុងនិយាយយ៉ាងរហ័ន និង យ៉ាងរហ័សជាមួយនាង ៖

- សូមអភ័យទោស *តូរ៉ាណាកា - សាម៉ា* ប៉ុន្តែ *អាន់ជីន - សាន* សូមដាក់ខ្លួនសួរលោកម្ចាស់ថា តើគាត់អាចខ្ចីខ្ញុំបានប៉ុន្មានថ្ងៃទៀតរឺទេ ។ សូមលោកម្ចាស់អធ្យាស្រ័យដល់ខ្ញុំផងចុះ គាត់បាននិយាយថា វត្តមានខ្ញុំជាមួយគាត់អាចនឹងជួយជំរុញរឿងការងារសំពៅរបស់គាត់កាន់តែបានរហ័សថែមទៀត ។ រួចបើសិនជាលោកម្ចាស់យល់ព្រម គាត់នឹងយកទូកសមុទ្ធមួយរបស់លោកម្ចាស់ដើម្បីជូនខ្ញុំទៅ *អូសាកា* ហើយបន្ទាប់មកគាត់ក៏នឹងទៅ *ណាកាសាគី* ដោយខ្លួនឯង ។ គាត់ជូនជាគំនិតថា ធ្វើបែបនេះគឺចំនេញពេលវេលាជាង ។

- ខ្ញុំមិនទាន់បានសំរេចអំពីរឿងសំពៅគាត់នៅឡើយទេ ។ រឺពីរឿងនាវិកនោះក៏ទេដែរ ។ គាត់អាចមិនចាំបាច់ទៅ *ណាកាសាគី* ទេ ហើយនាងត្រូវបញ្ជាក់រឿងនេះអោយបានច្បាស់លាស់ ។ អ្វី១ទាំងអស់មិនទាន់ត្រូវបានសំរេចទេ ។ តែខ្ញុំនឹងពិនិត្យលើសំនូមពរទាក់ទិននឹងរូបនាង ។ នាងនឹងទទួលបានការសំរេចរបស់ខ្ញុំនៅវេលាថ្ងៃស្អែកនេះ ។ នាងអាចទៅបានហើយអីលូវនេះ... អូហ៍ មែនហើយ នៅមានរឿងចុងក្រោយមួយទៀត *ម៉ារីកូ-សាន* ។ ប្រាប់គាត់ថា ខ្ញុំចង់បានប្រវត្តិរូបគ្រួសាររបស់គាត់ ។ គាត់អាចសរសេរមក ហើយនាងបកប្រែអោយខ្ញុំវិញ ដើម្បីទុកសំគាល់ថា ការរ៉ាយរ៉ាប់របស់គាត់ជាការពិត ។

- ចាស លោកម្ចាស់ ។ តើលោកម្ចាស់ចង់បានវាភ្លាម១នេះរឺ ?

- ទេ ។ យកនៅពេលទៅដល់ *យេដូ* ចុះ នោះគឺគាត់មានពេលគ្រប់គ្រាន់ហើយ ។

*ម៉ារីកូ* ពន្យល់ប្រាប់ទៅ *ប្លាក់ថន* ។ សួរទៅវិញ ៖

- ហេតុអីបានជាគាត់ចង់បានអាណឹង ?

*ម៉ារីកូ* សំលឹងថ្នាំងទៅរក *ប្លាក់ថន* ៖



www.budinst.gov.kh www.elibraryofcambodia.org

- ត្រូវការអ៊ីចឹងហើយ ។ *សាមូរ៉ៃ* ទាំងអស់ត្រូវតែមានការកត់ត្រាការកើត និង ការស្លាប់របស់ខ្លួន ក៏ដូចជាកត់ត្រាដែនដី និង ដីធ្លីទាំងអស់ដែលខ្លួនទទួលបានណា *អាន់ជីន - សាន* ។ បើមិនអ៊ីចឹងទេ តើអោយអម្ចាស់របស់ខ្លួនរក្សាគុណភាពម្តេចនឹងបានទៅ ? ក្រែង នៅប្រទេសលោកក៏គេធ្វើអ៊ីចឹងដែរអី ? នៅទីនេះតាមច្បាប់ ពលរដ្ឋយើងទាំងអស់សុទ្ធតែ មានចុះក្នុងបញ្ជីផ្លូវការ សូម្បីតែពួក *អេតា* ក៏ដោយ គឺចុះពីការកើត ស្លាប់ អាពាហ៍ពិពាហ៍។ គ្រប់ភូមិ គ្រប់ឃុំ គ្រប់ផ្លូវនៅក្នុងទីក្រុង សុទ្ធតែមានបញ្ជីផ្លូវការ ។ បើមិនអ៊ីចឹងទេ ធ្វើម៉េចយើងអាចដឹងបានថាយើងមកពីណា កូនចៅអ្នកណាបានទៅ ?

- ពួកយើងអត់មានចុះបញ្ជីទេ ។ មិនមែនចុះគ្រប់ពេលទេ ហើយមិនមែនផ្លូវការ ទៀត ។ ទាំងអស់គ្នានៅទីនេះសុទ្ធតែចុះបញ្ជីមែនរឺ ? ទាំងអស់គ្នា ?

- ចាស សូម្បីតែពួក *អេតា* ក៏ដោយ ។ នេះសំខាន់ណាស់ *នេ* ? ដល់អ៊ីចឹងទៅ គ្មានអ្នកណាមកអះអាងបន្លំថាខ្លួនជានេះជានោះបានទេ ហើយអ្នកធ្វើខុសក៏ងាយចាប់ខ្លួន ហើយប្រុសក៏ដោយ ស្រីក៏ដោយ ឪពុកម្តាយក៏ដោយ អត់មកបន្លំបានក្នុងរឿងរៀបការបាន ឡើយ *នេ* ?

*ប្លាក់ថន* សំរេចទុករឿងនេះសំរាប់គិតពិចារណាទៅថ្ងៃក្រោយ ហើយក៏ចាប់លេង សន្ទឹកបៀមួយទៀតនៅក្នុងល្បែងដែលគេបានលេងជាមួយ *តូរ៉ាណាកា* នេះ ហើយដែលគេ សង្ឃឹមថានឹងនាំទៅដល់ការវិនាសបង់នៃ*សំពៅខ្មៅ* ។

*ម៉ារីកូ* ស្តាប់គេយ៉ាងយកចិត្តទុកដាក់ រួចសួរសំនួរមួយរយៈ ទើបបែរទៅរក *តូរ៉ាណាកា* វិញ :

- លោម្ចាស់ *អាន់ជីន - សាន* សូមថ្លែងអំនរគុណលោកម្ចាស់ចំពោះរង្វាន់ខាន់ខៅ និងការអនុគ្រោះជាច្រើនរបស់លោកម្ចាស់នេះ ។ គាត់សួរថា តើលោកម្ចាស់អាចផ្តល់កិត្តិយសដល់គាត់ អាស្រ័យការជួយរើសអណ្តាប់ពីររយនាក់របស់គាត់អោយគាត់បានរឺទេ ? គាត់ និយាយថា ការណែនាំរបស់លោកម្ចាស់នៅក្នុងរឿងនេះពិតជាមានតំលៃកាត់ថ្លៃមិនបាន ទេ ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* សួរផ្ទួង ៖

- តើការណែនាំនេះស្មើមួយពាន់ *កូគូ* ទេ ?

លោកឃើញភាពភ្ញាក់ផ្អើលរបស់ *ម៉ារីកូ* និង *ភ្លាក់ថន* ។ អញរីករាយណាស់ដែលឯងនៅតែអោយគេមើលធ្លុះចិត្តបាន *អាន់ជីន - សាន* ថ្វីត្បិតតែឯងបាត[illegible] អារ្យធម៌របស់ឯងក៏ដោយ ។ បើសិនជាអញអ្នកលេងល្បែងវិញ អញហ៊ានភ្នាល់ថា អានេះមិនមែនចេញមកពីគំនិតរបស់ឯងឡើយ... អារឿងស្មើសុំការណែនាំរបស់ អញនេះ ។

លោកលឺ *ភ្លាក់ថន* ឆ្លើយថា " ហៃ " យ៉ាងដាច់ណាត់ ។ លោកក៏ឆ្លើយតបវិញយ៉ាងម៉ាត់ៗ ៖

- ល្អ ។ បើសិនជា *អាន់ជីន-សាន* ចិត្តល្អយ៉ាងនេះ ខ្ញុំទទួលយកចុះ ។ មួយពាន់ *កូគូ* ។ នេះអាចជួយ *សាមូរ៉ៃ* ឯទៀតៗណាដែលមានការខ្វះខាតផងដែរ ។ ប្រាប់ទៅគាត់ថា មនុស្សរបស់គាត់នៅរង់ចាំគាត់នៅឯ *យេដូ* ។ *អាន់ជីន - សាន* ខ្ញុំនឹងជួបលោកនៅស្អែកព្រឹកព្រលឹមនេះ ។

- បាទ សូមអរគុណ *តូរ៉ាណាកា - សាម៉ា* ។

- *ម៉ារីកូ -សាន* ពិព្រោះជាមួយលោកស្រី *កាស៊ីគី* ភ្លាមទៅ ។ ដោយថានាងបានឯកភាពទៅលើចំនួនទឹកលុយហើយនោះ ខ្ញុំគិតថា គាត់នឹងយល់ព្រមតាមការព្រមព្រៀងនេះ ទោះជាការព្រមព្រៀងនេះវាគួរអោយស្អប់ខ្ពើមយ៉ាងណាក្ដី និងទោះជាខ្ញុំគិតថា គាត់ត្រូវការពេលវេលាយ៉ាងតិចណាស់រហូតដល់ពេលព្រឹកស្អែកដែរ ដើម្បីពិចារណាអោយបានគ្រប់គ្រាន់ពីចំនួនទឹកលុយដ៏ហួសចិត្តនេះក៏ដោយក្ដី ។ អោយអ្នកបំរើម្នាក់ទៅបញ្ជាអោយ *គីយ៉ូកូ* មកកាន់ទីនេះនៅពេលព្រះអាទិត្យលិច ។ គាត់អាចយកស្រីកំដរនោះមកទីនេះក៏បានដែរ ។ ពេលយើងជជែកគ្នា *គីគូ - សាន* អាចច្រៀងកំដរបាន *ទេ* ?

លោកអោយទាំងអស់គ្នាចេញទៅ ។ នៅក្នុងចិត្តលោកសែនរីករាយ ព្រោះលោកអាចសំចៃបានមួយពាន់ប្រាំរយ *កូគូ* បានដែរ ។ មនុស្សអីលូវនេះដៃធំមែន - លោកគិតនៅក្នុងចិត្ត ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

*ញាក់ថន* សួរ :

- មើលទៅតើអាចនៅសល់លុយដើម្បីពួកនារីកបានដែររឺទេ ?

- ចាស បាន *អាន់ជីន - សាន* ។ ប៉ុន្តែលោកម្ចាស់មិនទាន់ឯកភាពអនុញ្ញាតអោយលោកទៅ *ណាកាសាគី* នៅឡើយទេ - *ម៉ារីកូ* តប - ប្រាំរយ *កូគូ* គឺគ្រប់គ្រាន់ណាស់ទៅហើយដើម្បីរស់នៅបានមួយឆ្នាំ ហើយប្រាំរយទៀតអាចផ្តល់អោយប្រហែលមួយរយប៉ែតសិប *កូបាន* មាស ដើម្បីទិញពួកដើរសមុទ្ទ ។ គិតទៅច្រើនណាស់ ។

*កូជីកូ* ងើបខ្លួនទាំងលំបាក ហើយនិយាយទៅកាន់ *ម៉ារីកូ* ។

- កំនាន់របស់លោកនិយាយថា លោកមិនគួរខ្វល់ខ្វាយពីរឿងនេះទេ *អាន់ជីន - សាន* ។ នាងអាចធ្វើលិខិតធានាសំរាប់ពួកចងការប្រាក់មួយចំនួនដែលនឹងអោយលោកខ្ចីប្រាក់ប៉ុន្មានតាមតែចិត្តលោកចង់បាន ។ នាងទទួលដោះស្រាយទាំងអស់ ។

- អីចឹងហើយ តែខ្ញុំត្រូវទទួលបន្ទុកចំនាយបរិពាររបស់ខ្ញុំនោះ ? រួចតើខ្ញុំធ្វើម៉េចដើម្បីចេញលុយរឿងផ្ទះ រឿង *កូជីកូ - សាន* និងពួកអ្នកបំរើឯទៀតនោះ ?

*ម៉ារីកូ* ហាក់ស្រលាំងកាំងនឹង *ញាក់ថន* :

- សូមទោសផងទៅចុះ តែរឿងទាំងនេះមិនមែនជារឿងដែលលោកត្រូវខ្វល់នោះទេ ។ កំនាន់របស់លោកបាននិយាយប្រាប់លោកហើយតើ ថានាងនឹងដោះស្រាយអ្វីៗទាំងអស់ហើយ ។ នាង...

*កូជីកូ* និយាយកាត់ ហើយនារីទាំងពីរជជែកគ្នាមួយសន្ទុះ ។

- អ្ហា *សូតេស៊ូ កូជីកូ - សាន* - រួចនាងងាកមករក *ញាក់ថន* - នាងនិយាយថាលោកមិនគួរចំនាយពេលដើម្បីគិតពីរឿងទាំងនេះទេ ។ នាងសូមអង្វរលោក សូមលោកចំនាយពេលវេលារបស់លោកគិតគូរពីរឿងរ៉ាវរបស់លោកម្ចាស់ *តូរ៉ាណាកា* វិញទៅ ។ នាងមានប្រាក់របស់នាងផ្ទាល់ដែលអាចចាយវាយបាន បើសិនជាចាំបាច់ ។

*ញាក់ថន* ព្រិចភ្នែក :

- នាងអោយខ្ញុំខ្ចីលុយរបស់នាងផ្ទាល់រឺ ?



www.budinst.gov.kh www.elibraryofcambodia.org

- ទេ *អាន់ជីន -សាន* នាងនឹងជូនលុយនាងទៅលោក បើសិនជាលោកត្រូវការ ។ សូមកុំភ្លេចថា បញ្ហាលោកគឺមានសំរាប់តែឆ្នាំនេះទេ - *ម៉ារីកូ* ពន្យល់ - នៅឆ្នាំក្រោយលោកនិងក្លាយជាអ្នកមានស្តុកស្តម្ភហើយ *អាន់ជីន - សាន* ។ ចំនែកបរិពាររបស់លោក ពួកនេះទទួលបានពីរ *កូកូ* ម្នាក់ក្នុងមួយឆ្នាំ ។ ហើយកុំភ្លេចថា *តូរ៉ាណាកា - សាម៉ា* បានជូនលោកនូវអាវុធយុទ្ធភណ្ឌ ហើយនឹងសេះសំរាប់ពួកគេរួចហើយ ហេតុនេះពីរ *កូកូ* នេះគឺល្មមគ្រប់គ្រាន់ដើម្បីចិញ្ចឹមខ្លួនគេ គ្រួសារគេ និងសេះគេបានហើយ ។ ហើយលោកក៏មិនត្រូវភ្លេចផងដែរទេថា លោកបានជូនចំនូលប្រចាំឆ្នាំរបស់លោកពាក់កណ្តាលទៅលោកម្ចាស់ *តូរ៉ាណាកា* ដើម្បីធានាថា ពួកទាំងនេះត្រូវបានជ្រើសរើសដោយខ្លួនលោកផ្ទាល់ ។ នេះជាមហាកិត្តិយសណាស់ *អាន់ជីន - សាន* ។

- នាងយល់ថាអីចឹងមែន ?

- ច្បាស់ណាស់ ។ *កូជីកូ* ឯកភាពទាំងចិត្តទាំងថ្លើម ។ លោកចំជាឆ្លាតមែន ដែលបានគិតដល់រឿងនេះ ។

- អរគុណ ។

គេបង្ហាញអោយឃើញមួយភ្លែតនូវភាពរីករាយរបស់គេ ។ ឯងកំពុងប្រមូលយកភាពឆ្លាតឆ្លៃរបស់ឯងមកវិញហើយ១ ចាប់ផ្តើមគិតដូចពួកវាហើយ - គេនិយាយក្នុងចិត្តទាំងរីករាយ ។ ពិតហើយ គឺជាការវាងវៃដែលត្រូវបញ្ចូល *តូរ៉ាណាកា* ជាមួយនោះ ។ អីលូវនេះឯងនឹងបានមនុស្សឆើត១បំផុតដែលអាចរកបាន ហើយការនេះឯងពិតជាមិនអាចធ្វើបានដោយខ្លួនឯងឡើយ ។ ប្រៀបទៅ*សំពៅខ្មៅ* តើមួយពាន់*កូកូ* វាប៉ុន្មានទៅ ? ហើយរឿងមួយទៀត ដែល *ម៉ារីកូ* បាននិយាយប្រាប់គេ គឺពិតដូចស់ដីនាងមែន ។ នោះគឺ *តូរ៉ាណាកា* ជាមនុស្សកំនាញ់ម៉ៅស្វិត ។ ពិតហើយ នាងមិនបាននិយាយត្រង់១ បែបនេះទេ តែនាងបាននិយាយពីប្រការដែល *តូរ៉ាណាកា* បង្កើនសម្បត្តិមហាសាលរបស់ខ្លួនអោយលើសផុតពីពួក *ដៃមីញ៉ូ* ទាំងអស់ ក៏ដូចជាការសង្កេតផ្សេង១ទៀត ដូចជាប្រការដែល *តូរ៉ាណាកា* ស្លៀកសំលៀកបំពាក់សាមញ្ញ ហូបចុកសាមញ្ញ ហើយការរស់នៅរបស់លោកក៏មានការខុសគ្នាបន្តិច



www.budinst.gov.kh www.elibraryofcambodia.org

បន្ទុចពីពួក *សាមូរ៉ៃ* ធម្មតា ទាំងអស់នេះសុទ្ធតែជាកូនសោដែលបើកដួងចិត្ត *តូរ៉ាណាកា* បានដោយជោគជ័យ ។

អរគុណព្រះជាម្ចាស់ដែលអោយអញបានជួប *ម៉ារីកូ* និងបព្វជិត *ដូមិញ្ញូ* ។

ល័និករបស់ *ប្លាក់ថន* បាននាំគេទៅដល់ទីឃុំឃាំង ហើយគេគិតថា មរណភាពទៅពេលនោះបាននៅកៀកនឹងខ្លួនគេមែនទែនដូចពេលនេះដែរ ថ្វីត្បិតតែពេលនេះគេមានកិត្តិយសពោរពេញយ៉ាងណាក៏ដោយ ។ អ្វីៗដែល *តូរ៉ាណាកា* ប្រគល់អោយ គាត់អាចដកហូតយកទៅវិញបាន ។ ឯងគិតថាគាត់ជាមិត្តរបស់ឯង តែបើគាត់អាចប្រហារជីវិតប្រពន្ធ និងធ្វើឃាតកូនប្រុសសំនព្វរបស់ខ្លួនបាន តើឯងអាចអោយតំលៃមិត្តភាពពីជីវិតរបស់ឯងយ៉ាងម៉េចទៅ ? មិនអាចទេ ។ នេះជា *កាម៉ា* ។ ហើយអញជឿលើ *កាម៉ា* ក្នុងការជួយអញនៅប្រាំមួយខែខាងមុខនេះ ដើម្បីចេញតាមច្រកម៉ាសេឡង់ តំរង់ក្បាលទៅទីក្រុងឡុង គេចផុតពីកណ្តាប់ដៃរបស់មនុស្សនេះ ...

*កូជីកូ* បន្តនិយាយ ។ គេសំលឹងមើលនាង ។ ស្បែរុំនៅតែឥតប្រែពណ៌នៅឡើយ ។ នាងទំរេតខ្លួនទាំងឈឺចាប់ នារីម្នាក់កំពុងបក់ផ្លិតអោយនាង ។

*ម៉ារីកូ* និយាយ :

- នាងនឹងចាត់ចែងកិច្ចការទាំងអស់សំរាប់លោកនៅពេលព្រឹកព្រលឹមនេះ *អាន់ជីន - សាន* ។ កំនាន់លោកស្នើអោយលោកយកសេះពីរ និងសេះដាក់អីវ៉ាន់មួយ អ្នកបំរើប្រុសម្នាក់ ស្រីម្នាក់...

- អ្នកបំរើប្រុសម្នាក់គ្រប់គ្រាន់ហើយ ។

- សូមទោស នារីបំរើត្រូវតែទៅតាមបំរើលោក ។ នៅមានចុងភៅ ហើយនិងជំនួយការចុងភៅថែមទៀត ។

- តើអត់មានម្ហូបអីដែលខ្ញុំញ៉ាំបាន រឺយ៉ាងម៉េច ?

- មាន ។ តែលោកនៅតែត្រូវមានចុងភៅផ្ទាល់ខ្លួនរបស់លោកដែរ *អាន់ជីន - សាន* ។ លោកជា *ហាតាម៉ូតូ* ណា ។



www.budinst.gov.kh www.elibraryofcambodia.org

គេដឹងថា គ្មានអ្វីដែលត្រូវតវ៉ាប្រកែកបានទេ :

- រឿងទាំងអស់ណឹងខ្ញុំទុកអោយពួកនាងជាអ្នកចាត់ចែងទៅចុះ ។

- ចាស នេះបានចំជាវាងវៃមែន *អាន់ជីន - សាន* ។ ពិតជាវាងវៃមែន ។ អីលូវនេះខ្ញុំត្រូវទៅរៀបចំអីវ៉ៃអីវ៉ាន់ហើយដែរ ។ សូមអភ័យទោសផងចុះ ។

រូច *ម៉ារីកូ* ក៏លាអ្នកទាំងពីរទាំងចិត្តរីករាយ ។ គេមិនបាននិយាយគ្នាច្រើនទេ តែគេបាននិយាយគ្នាជាភាសាឡាតាំងល្មមគ្រប់គ្រាន់ដើម្បីនឹងដឹងគ្នាថា ថ្វីបើរាត្រីវេទមន្តមិនបានមកដល់ ហើយថ្វីត្បិតតែដូចកាលរាត្រីមុននោះ ពួកគេមិនត្រូវនិយាយដល់ក្តី ក៏រាត្រីទាំងពីរនេះបានស្ថិតនៅជាអមតៈក្នុងអារម្មណ៍របស់គេទាំងពីរនាក់ដែរ ។

កាលនោះនាងបាននិយាយថា :

- ខ្ញុំមានមោទនភាពណាស់ នៅពេលដែលខ្ញុំលឺថានាងឈរនៅមាត់ទ្វាររបងយ៉ាងយូរដូចនេះ ។ មុខមាត់លោកអស្ចារ្យណាស់នៅពេលនេះ *អាន់ជីន - សាន* ។

- មួយភ្លែតនោះ ខ្ញុំហៀបតែនឹងភ្លេចនូវអ្វីដែលនាងបានប្រាប់ខ្ញុំ ។ ដោយអចេតនានៅតែមួយសរសៃសក់ទៀតខ្ញុំនឹងអោបនាងថើបជាសាធារណៈបាត់ ។

- អូហ៍ *កូ អាន់ជីន - សាន* នោះពិតជាចង្រៃចំតែម្តង !

- អូហ៍ *កូ* នាងនិយាយត្រូវណាស់ ! បើសិនជាគ្មានការណែនាំពីនាងទេ ខ្ញុំមិនដឹងជាយកមុខទៅទុកឯណាទេ ។ ច្បាស់ជាក្លាយទៅជាដង្កូវរវើកក្នុងធូលីបាត់ទៅហើយ ។

- ផ្ទុយទៅវិញលោកមានឈ្មោះកាន់តែល្បីសុសសាយ ។ តើលោកមានទទួលបានការសប្បាយពីឧបករណ៍ចំលែកទាំងនោះទេ ?

- ឱ ទេពធីតាខ្ញុំអើយ ។ នៅស្រុកខ្ញុំ យើងមានពាក្យទំនៀមមួយ គឺ : មនុស្សប្រុសមិនត្រូវនិយាយពីទំលាប់សំងាត់បំផុតរបស់នារីប្រាប់មនុស្សប្រុសម្នាក់ទៀតឡើយ ។

- ពួកយើងក៏មានទំលាប់ដូចគ្នានេះដែរ ។ តែខ្ញុំសួរពីរឿងសប្បាយ មិនមែនពីរឿងប្រើនោះទេ ។ ខ្ញុំសប្បាយចិត្តណាស់ដែលរាត្រីនោះបានជាទីពេញចិត្តរបស់លោក ។ ធ្វើជាជប៉ុននៅប្រទេសជប៉ុន គឺជាការវាងវៃ *នេ* ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំមិនអាចអរគុណនាងអោយបានស្មើនឹងការដែលនាងបានបង្ហាត់បង្រៀនខ្ញុំ ណែនាំខ្ញុំ និងបើកភ្នែកខ្ញុំនោះឡើយ ។ ហើយនឹងការ...

គេរៀបរាប់នឹងនិយាយថា : " នឹងការដែលនាងស្រលាញ់ខ្ញុំ" ទៅហើយ តែគេកែទៅពោលថា :

- និងការដែលនាងអោយខ្ញុំជាមនុស្សម្នានឹងគេ ។

- ខ្ញុំឥតមានធ្វើអ្វីសោះ ។ លោកបានធ្វើការនេះដោយខ្លួនលោកទេតើ ។

- ខ្ញុំសូមអរគុណនាង ។ អរគុណចំពោះរឿងគ្រប់សព្វ ព្រមទាំងអំនោយរបស់នាងផង ។

- ខ្ញុំសប្បាយចិត្តណាស់ដែលលោកបានទទួលការការសប្បាយយ៉ាងធំធេងយ៉ាងនេះ ។

- ខ្ញុំលំបាកចិត្តណាស់ដែលនាងមិនបានទទួលការរីករាយអ្វីទាំងអស់ ។ ខ្ញុំក៏សប្បាយចិត្តដែរដែលនាងបានទទួលបញ្ជាអោយទៅ *ស្យ៉ា* ដែរ ។ តែម៉េចបានទៅ *អូសាកា* ?

- អូហ៏ នោះមិនមែនខ្ញុំទទួលបញ្ជាអោយទៅ *អូសាកា* ទេ តែគឺលោកម្ចាស់ *តូរ៉ាណាកា* អនុញ្ញាតអោយខ្ញុំទៅទីនោះតែប៉ុននោះ ។ ពួកយើងមានកម្មសិទ្ធិ មានកិច្ចការគ្រួសារដែលត្រូវទៅមើល ។ ហើយកូនប្រុសខ្ញុំក៏នៅទីនោះដែរ ។ ទន្ទឹមនោះដែរខ្ញុំអាចនាំសារទៅជូន *គីរីស៊ីមួ - សាន* និងលោកជំទាវ *សាស៊ូកូ* បានផងដែរ ។

- ក្រែងមានគ្រោះថ្នាក់ណាស់ទេដឹង ? នាងចាំសំដីនាងទេ : សង្គ្រាមមកដល់ហើយៗ *អ៊ីស៊ីដូ* ជាសត្រូវ ។ មិនគឺលោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ដូចគ្នានេះដែរទេរឺ ?

- ចាស ប៉ុន្តែអីលូវនេះមិនទាន់មានសង្គ្រាមនៅឡើយទេ *អាន់ជីន - សាន* ។ ហើយពួក *សាមូរ៉ៃ* មិនដែលប្រយុទ្ធនឹងនារីទេ លើកលែងតែនារីនោះវាយប្រយុទ្ធពួកគេ ។

- ចុះនាងវិញ ? នាងនៅចាំរឿងនៅលើស្ពានឯ *អូសាកា* ទេ ? មិនគឺនាងបានទៅតាមខ្ញុំដើម្បីបោក *អ៊ីស៊ីដូ* ទេរឺ ? អាគាត់នោះអាចប្រហារជីវិតខ្ញុំបាន ។ ហើយនាងចាំបានទេ ពីដាវរបស់នាងក្នុងការប្រយុទ្ធលើទូកនោះ ។

- ចាស នោះគឺគ្រាន់តែដើម្បីការពារជីវិតរបស់អម្ចាស់ខ្ញុំ ជីវិតខ្ញុំ ដែលត្រូវតំរាម



www.budinst.gov.kh www.elibraryofcambodia.org

កំហែងតែប៉ុណ្ណោះ ។ នេះគឺជាភារកិច្ចរបស់ខ្ញុំ *អាន់ជីន - សាន* ។ គ្មានអ្វីផ្សេងពីនេះទេ ។ គ្មានគ្រោះថ្នាក់សំរាប់ខ្ញុំទេ ។ ខ្ញុំធ្លាប់ធ្វើជានារីកិត្តិយសសំរាប់លោកជំទាវ *យ៉ូដូកូ* ដែលជាភរិយាមេម៉ាយរបស់លោកម្ចាស់ *តែកូ* ហើយនឹងលោកជំទាវ *អូជីបា* ម្តាយរបស់ទាយាទ *យែនមុ៉ន* ថែមទៀតផង ។ ខ្ញុំមានកិត្តិយសបានធ្វើជាម្រាក់របស់ពួកគេ ។ ខ្ញុំមានសុវត្ថិភាពគ្រប់គ្រាន់ទេ ។ ព្រោះដោយហេតុនេះហើយ ទើប *តូរ៉ាណាកា - សាម៉ា* អនុញ្ញាតអោយខ្ញុំទៅនោះ ។ តែចំពោះលោកវិញ *អូសាកា* មិនមែនជាទីសុវត្ថិភាពទេ ព្រោះតែរឿងគេចខ្លួនរបស់លោកម្ចាស់ *តូរ៉ាណាកា* និងពីអ្វីដែលធ្វើទៅលើលោកម្ចាស់ *អ៊ីស៊ីដូ* នោះ ។ ហេតុនេះលោកមិនត្រូវជាន់ជើងទៅទីនោះឡើយ ។ *ណាកាសាគី* នឹងផ្តល់សុវត្ថិភាពដល់លោកជាង ។

- អ៊ីចឹង គាត់ឯកភាពអោយខ្ញុំទៅហើយរឺ ?

- ទេ ។ មិនទាន់ទេ ។ តែនៅពេលគាត់ផ្តល់ការអនុញ្ញាតហើយ នោះគឺសុវត្ថិភាពហើយ ។ គាត់មានអំនាចនៅ *ណាកាសាគី* នោះ ។

គេចង់សួរថា តើអំនាចនោះធំជាងអំនាចរបស់ពួក *យេស៊ុីត* ទៅទៀតរឺ ? ប៉ុន្តែគេបែរនិយាយថា :

- ខ្ញុំបន់ស្រន់សូមអោយលោកម្ចាស់ *តូរ៉ាណាកា* បញ្ជាអោយនាងទៅ *អូសាកា* តាមទូកទេ ។

គេឃើញនាងញ័រខ្លួនបន្តិច គេក៏សួរ :

- នាងមានរឿងអ្វីរឺ ?

- អត់មានអីទេ គ្រាន់តែ... គ្រាន់តែខ្ញុំមិនចូលចិត្តសមុទ្រតែប៉ុណ្ណោះ ។

- តើគាត់នឹងបញ្ជាអោយនាងធ្វើដំណើរតាមទូករឺទេ ?

- ខ្ញុំមិនដឹងដែរ ។ ប៉ុន្តែ...

រួចនាងក៏ដូរសាច់រឿងនិយាយដោយបែរមកនិយាយចាក់ចុចលេងជាភាសា *ប៉ក្នុយកាល់* វិញម្តង :

- តែដើម្បីសុខភាពរបស់លោក យើងគួរនាំ *គីតូ - សាន* ទៅជាមួយផង *ទេ ?*



www.budinst.gov.kh www.elibraryofcambodia.org

យប់នេះ តើលោកទៅរកនាងនៅឯបន្ទប់ល័ក្ខក្រហមរបស់នាងទៀតរឺទេ ?

គេសើចជាមួយនាង :

- នោះរឹតតែល្អហើយ ថ្មី...

រួចគេឈប់ងក់ ដោយគេនឹកឃើញយ៉ាងច្បាស់ក្រលែតនូវទឹកមុខរបស់ *អូមី* :

- នាងដឹងទេ *ម៉ារីកូ - សាន* នៅពេលដែលខ្ញុំនៅមាត់ទ្វាររបង ខ្ញុំច្បាស់ណាស់ថា ខ្ញុំបានឃើញ *អូមី* សំលឹងមើល *គីតូ - សាន* យ៉ាងបែបពិសេសមួយ គឺមើលរបៀបសង្សារ ។ ខ្ញុំចង់និយាយថា សង្សារប្រច័ណ្ឌ ។ ខ្ញុំឥតដឹងថាពួកគេជាសង្សារនឹងគ្នាទេ ។

- តាមខ្ញុំដឹង *អូមី* ជាក្មេងបំរើរបស់នាង ។ ជាក្មេងបំរើសំនព្វផង ។ ហេតុអ្វីបានជារឿងនេះនាំអោយលោកមានការខ្វាយខ្វល់ ?

- ពីព្រោះជាទឹកមុខមួយយ៉ាងសំងាត់ ។ គឺពិសេសអស្ចារ្យតែម្តង ។

- *អូមី* គ្មានសិទ្ធិហួងហែងពិសេសណាមួយលើរូបនាងទេ *អាន់ជីន - សាន* ។ នាងជានារីកំដរថ្នាក់លេខមួយ ។ នាងមានសេរីភាពពេញទីក្នុងការទទួល រឺមិនទទួលអ្នកណាតាមចិត្តចង់របស់នាងបាន ។

- បើសិនជាយើងនៅអឺរ៉ុប ហើយបើខ្ញុំរួមរក្សស្រីរបស់គេអ៊ីចឹង... នាងយល់ទេ *ម៉ារីកូ - សាន* ?

- ខ្ញុំគិតថាខ្ញុំយល់បាន *អាន់ជីន - សាន* ។ តែចុះលោកទៅខ្វាយខ្វល់ពីរឿងនេះធ្វើអ្វី ? លោកមិនមែននៅអឺរ៉ុបទេ *អាន់ជីន - សាន* ។ *អូមី* គ្មានសិទ្ធិហួងហែងទេ ។ បើសិនជានាងចង់ទទួលលោក និង *អូមី* រឺទោះជានាងមិនចង់ទទួលលោក និង *អូមី* ក្តី តើនេះមានទាក់ទងនឹងអ្វីទៅ ?

- ខ្ញុំថា *អូមី* ជាសង្សាររបស់ *គីតូ - សាន* ។ ហើយមិនទាក់ទងទេរឺ ?

- ចុះនេះមានទៅទាក់ទងអីនឹងរឿងមុខរបរនាង ? រឺរឿងរួមរក្សគ្នានោះ ?

ជាថ្មីម្តងទៀត គេអរគុណនាង ហើយលែងនិយាយពីរឿងនេះទៀត ។ តែខួរក្បាល និង បេះដូងរបស់គេបានប្រាប់គេអោយប្រុងប្រយ័ត្ន ។ មិនមែនងាយសាមញ្ញដូចដែល



www.budinst.gov.kh www.elibraryofcambodia.org

នាងនិយាយនោះទេ *ម៉ារីកូ - សាន* ។ ទោះជានៅទីនេះក៏ដោយ ។ *អូមី* មានជំនឿថា *គីតូ - សាន* គឺលើសពីពិសេសទៅទៀត ទោះជា *គីតូ* មិនមានអារម្មណ៍ដូចគ្នានេះក្តី ។ បន់អោយអញដឹងថា *អូមី* ជាសង្សាររបស់ *គីតូ* ទៅចុះ... ។ អញសុខចិត្តយក *អូមី* ជាមិត្តជាជាងយកជាសត្រូវ ។ តើលើកនេះ *ម៉ារីកូ* យល់ត្រូវទៀតទេ ។ រឿងដែលថារូមរក្សមិនទាក់ទងអ្វីនឹងស្នេហារបស់ពួកគេនោះ ?

ព្រះជាម្ចាស់អើយ ! ជួយខ្ញុំផង ។ ខ្ញុំវង្វេងស៊ុងហើយ ។ អីលូវនេះ មួយចំនែក ខ្ញុំជាប៉ូញ៉ា តែភាគច្រើនជាបស្ចិម ។ ខ្ញុំត្រូវធ្វើដូចពួកគេ គិតដូចពួកគេ ដើម្បីរស់រានមានជីវិតបាន ។ ហើយភាគច្រើននៃអ្វីដែលពួកគេជឿនេះ គឺគ្រាន់ជាងពួកយើង ហេតុនេះហើយបានជាចំនង់មួយចង់ក្លាយទៅជាពួកគេទាំងស្រុង ទោះជា... ទ្វនំនៅឯនោះ នៅឯនាយសមុទ្រ ជាទីកន្លែងដែលជីដូនជីតាអញមានកំនើត ជាទីកន្លែងដែលគ្រួសារអញរស់នៅ មាន *កេលីស៊ី ទូន័រ* និង *អេលីសាបែត* ។

- *អាន់ជីន - សាន* ?

- មានការអី *កូជីកូ - សាន* ?

- សូមលោកកុំខ្វល់ពីរឿងលុយកាក់អោយសោះ ។ ខ្ញុំមិនអាចទ្រាំទ្រមើលលោកខ្វល់ខ្វាយនៅក្នុងចិត្តបានទេ ។ ខ្ញុំស្តាយណាស់ដែលខ្ញុំមិនអាចទៅ *យេដូ* ជាមួយលោកបាន ។

- បន្តិចទៀតជួបនៅ *យេដូ នេ* ?

- ចាស គ្រូពេទ្យនិយាយថា ខ្ញុំសះរប៉ាសណាស់ ហើយម្តាយ *អូមី - សាន* ក៏ឯកភាពដែរ ។

- អង្កាល់គ្រូពេទ្យមកទីនេះ ?

- ថ្ងៃលិច ។ ខ្ញុំស្តាយណាស់ ខ្ញុំមិនអាចទៅជាមួយលោកបាននៅថ្ងៃស្អែកនេះ ។ សូមអធ្យាស្រ័យដល់ខ្ញុំផង ។

គេពិចារណាម្តងទៀតពីភារកិច្ចរបស់គេជាមួយនឹងកំនាន់នេះ ។ រួចគេក៏ដាក់គំនិតនេះទៅក្នុងខណ្ឌរបស់វាដើម្បីគិតពីរឿងថ្មីវិញ ។ គេពិចារណាពីគំនិតថ្មីនេះហើយយល់ថា នេះ



www.budinst.gov.kh www.elibraryofcambodia.org

ជាត់និតល្អ ។ ហើយបន្ទាន់ទៀតផង ។ គេពោលទៅកាន់ *ភូជីក្ក* :

- ខ្ញុំទៅហើយ ។ឆាប់ត្រលប់មកវិញ ។ នាងសំរាក ។ យល់ទេ ?

- ចាស សូមអភ័យទោសដែលខ្ញុំមិនអាចក្រោករួច និង...សូមទោស ។

គេចេញពី *ភូជីក្ក* ហើយទៅបន្ទប់របស់គេ ។ នៅទីនោះ គេយកកាំភ្លើងខ្លីពីកន្លែងដែលគេលាក់វា ពិនិត្យថាត្រូវបានច្រកគ្រាប់ស្រួលបួលហើយ ទើបសៀតវាទៅពីក្នុង *តឹម៉ូណូ* ។ បន្ទាប់មកទៀត គេក៏ដើរតែម្នាក់ឯងសំដៅទៅផ្ទះ *អូមី* ។ *អូមី* ឥតនៅផ្ទះទេ ។ *មីដូរី* បានស្វាគមន៍គេ និងអញ្ជើញគេទទួលទានទឹកតែសិន តែគេបានប្រកែកយ៉ាងគួរសម ។ *មីដូរី* ៣ ទារកអាយុពីរខួបនៅនឹងដៃ ។ នាងបានប្រាប់ថា *អូមី* នឹងត្រលប់មកវិញអីលូវហើយ ។ តើ *អាន់ជីន - សាន* ចង់នៅចាំទេ ? ថ្វីត្បិតតែនាងបានបង្ហាញអាកប្បកិរិយាគួរសម និងយកចិត្តទុកដាក់ក្តី ក៏នាងហាក់មិនសុខមិនសាប់សោះឡើយ ។ ជាថ្មីម្តងទៀត គេបានប្រកែក ហើយអរគុណនាង និងប្រាប់នាងថា គេនឹងត្រលប់មកវិញម្តងទៀត រួចគេក៏ដើរចុះទៅរកផ្ទះរបស់គេទៅ ។

ពួកអ្នកភូមិបានរើសំអាតទីកន្លែងជាស្រេចដើម្បីសង់ផ្ទះជាថ្មី ។ គ្មានអ្វីដែលត្រូវបានជួយផុតពីអគ្គីភ័យឡើយ លើកលែងតែគ្រឿងចង្ក្រានតែប៉ុននោះ ។ *ភូជីក្ក* មិនព្រមប្រាប់គេពីតំលៃនៃការសាងសង់ផ្ទះវិញទេ ។ នាងគ្រាន់តែនិយាយថា ថោកណាស់តែប៉ុននោះ ។

អ្នកភូមិម្នាក់និយាយទៅកាន់ *ប្លាក់ថន* :

- *កាម៉ា អាន់ជីន - សាន* ។

- ពិតហើយ ។

- តើអ្នកណាទៅធ្វើអីកើត ? តែកុំបារម្ភអី ផ្ទះលោកតែបន្តិចទៀតនឹងរួចរាល់ស្រេចបាច់ហើយ១ល្អជាងមុនផង ។

*ប្លាក់ថន* ក៏ប្រទះឃើញ *អូមី* ដែលកំពុងឡើងជំរាលទាំងអាការៈរឹងត្អឹត និងទឹកមុខតឹងតែង ។ គេដើរចុះទៅជួបទល់មុខតែម្តង ។ នៅពេលដែលឃើញរូបគេ *អូមី* ហាក់ដូចជាបន្ធូរភាពតានតឹងរបស់គេបន្តិច ។ គេពោលឡើងយ៉ាងស្និទ្ធស្នាល :



www.budinst.gov.kh www.elibraryofcambodia.org

- អ្ហា *អាន់ជីន - សាន* ។ ខ្ញុំលឺថាលោកនឹងចេញដំណើរជាមួយ *តូរ៉ាណាកា - សាម៉ា* ដែរនៅពេលព្រឹកព្រលឹមនេះ ។ អីចឹងល្អហើយ យើងអាចជិះសេះជាមួយគ្នា ។

ថ្វីត្បិតតែ *អូមី* ហាក់បង្ហាញនូវភាពស្និទ្ធស្នាលក្តី ក៏ *ប្លាក់ថន* នៅតែប្រយ័ត្នខ្លួនជាប់ជានិច្ច ។

- ស្តាប់ខ្ញុំ *អូមី - សាន* អីលូវនេះខ្ញុំទៅនោះ - គេលើកដៃចង្អុលទៅខ្ពង់រាប - សូមលោកអញ្ជើញទៅជាមួយខ្ញុំ ?

- ថ្ងៃនេះអត់មានរឹកហាត់ទេ ។

- យល់ហើយ ។ សូមលោកអញ្ជើញទៅជាមួយខ្ញុំបានទេ ?

*អូមី* ប្រទះឃើញដៃរបស់ *ប្លាក់ថន* ដាក់នៅលើដងដាវប្រហារជីវិតក្នុងលក្ខណៈត្រៀមហើយជាស្រេច ។ រួចភ្នែកដ៏មុតរបស់គេបានកត់សំគាល់នូវទំនួលដែលដោលពីក្នុងខ្សែក្រវាត់ក្រណាត់របស់បុរសនេះមកថែមទៀត ហើយតាមទំរង់នៃទំនួលនេះ គេដឹងថាជាតូកាំភ្លើងដែលត្រូវបានបង្កប់នៅក្នុងនោះ ។

*អូមី* សួរទៅ *ប្លាក់ថន* ក្នុងសំលេងយ៉ាងនឹងន :

- បុរសម្នាក់ដែលទទួលបានការអនុញ្ញាតអោយប្រើដាវពីរ ត្រូវតែមានសមត្ថភាពប្រើប្រាស់វា *ទេ ?*

- សូមទោស ខ្ញុំមិនយល់ទេ ។

*អូមី* និយាយម្តងទៀត ដោយប្រើភាសាសាមញ្ញជាងមុន ។

- អាហ៎ យល់ហើយ ។ ពិតមែន ។ ប្រការល្អគួរតែអញ្ចឹង ។

- បាទ ។ លោកម្ចាស់ *យ៉ាប៊ូ* បានមានប្រសាសន៍ថា នៅពេលដែលខ្លួនគេក្លាយជាសាមូរ៉ៃពេញលេញហើយនោះ គេត្រូវតែរៀនសូត្រនូវអ្វីដែលគេគិតថាជារឿងធម្មតានោះ ។ ឧទាហរណ៍ តើធ្វើយ៉ាងដូចម្តេចក្នុងឋានៈជាជំនួយនៅក្នុង *សិបពូគូ* នោះ ? រហូតដល់ត្រៀមខ្លួនធ្វើ *សិបពូគូ* ខ្លួនថែមទៀត ដោយថានេះជាកាតព្វកិច្ចដែលពួកយើងត្រូវធ្វើទាំងអស់គ្នា ។ ជាការពិតណាស់ *អាន់ជីន - សាន* លោកគួរតែរៀនប្រើដាវទាំងនេះ ។ នេះគឺជាការចាំបាច់



www.budinst.gov.kh www.elibraryofcambodia.org

ដែល *សាមូរ៉ៃ* ត្រូវចេះប្រើដាវ និង គោរពដាវរបស់ខ្លួន *ទេ ?*

*ប្លាក់ថន* ស្តាប់យល់បានតែពាក់កណ្តាលនូវអ្វីដែល *អូមី* និយាយតែប៉ុណ្ណោះ ។ ប៉ុន្តែគេយល់បាននូវអ្វីដែល *អូមី* និយាយ រី យ៉ាងហោចណាស់ស្តាប់បានច្បោល១ដែរ - គេគិតកំលានៅក្នុងចិត្ត ។

- បាទ ពិតមែន - *ប្លាក់ថន* តប - សូមអធ្យាស្រ័យ ថ្ងៃណាមួយលោកបង្ហាត់ ។ សូមទោស លោកប្រហែលបង្ហាត់ ? បានទេ ? ខ្ញុំមានកិត្តិយស ។

- បាន ខ្ញុំសប្បាយចិត្តនឹងបង្ហាត់លោក *អាន់ជីន - សាន* ។

រោមក *ប្លាក់ថន* ឡើងព្រឺខ្នាកនៅពេលលឺសំដីបង្កប់ដោយការគំរាមរបស់ *អូមី* នេះ។ ប្រយ័ត្នប្រយែងអាវ៉ា - គេរំលឹកស្មារតីខ្លួន ។ កុំស្រមៃផ្តេសផ្តាសអោយសោះ ។

- អរគុណ ។ អីលូវនេះ ដើរទៅទីនុះ ? ពេលតិច ។ លោកមកជាមួយ ? បាន ?

- ក៏បាន *អាន់ជីន - សាន* ។ តែយើងជិះសេះវិញ ។ ខ្ញុំទៅតាមលោកអីលូវនេះហើយ ។

រួច *អូមី* ក៏ដើរចូលទៅក្នុងទីធ្លារបស់ផ្ទះខ្លួនទៅ ។

*ប្លាក់ថន* បញ្ជាអោយអ្នកបំរើរៀបចំសេះ រួចគេក៏ឡើងសេះទាំងលំបាក ដោយគេត្រូវឡើងសេះពីខាងស្តាំ ដែលជាទំលាប់ពួកចិន និងជប៉ុន នោះ ។ កុំគិតសង្ឃឹមពេកពីរឿងអោយវាបង្ហាត់គុនដាវអែងនោះ - *ប្លាក់ថន* និយាយនៅក្នុងពោះ ។ ដៃស្តាំរបស់គេទះបន្ធើរដងកាំភ្លើងខ្លីដែលគេលាក់នោះអោយកាន់តែតត់មត់ជាងមុន ។ កំដៅកាំភ្លើងបានផ្តល់នូវភាពធានាមួយដល់រូបគេផងដែរ ។ ប៉ុន្តែទំនុកចិត្តនេះរលាយបាត់មួយរំពេចនៅពេលដែល *អូមី* លេចចេញមកវិញ ដោយមានទាំង *សាមូរ៉ៃ* បួននាក់ជិះសេះអមមកជាមួយផង ។ ពួកគេបំផាយសេះតាមផ្លូវពោរពេញដោយជង្ហុកឡើងទៅលើខ្ពង់រាប ។ ពួកគេជិះសេះកាត់អង្គភាព *សាមូរ៉ៃ* ជាច្រើនដែលកំពុងប្រុងប្រៀបរៀបចំចេញដំណើរ ប្រកបដោយអាវុធយុទ្ធភណ្ឌ និងក្រោមការដឹកនាំរបស់មេកងរបស់ពួកគេ ។ ទង់របស់ពួកគេបក់វិចនៅតាមចុងលំពែង ។ នៅពេលដែលពួកគេជិះសេះតាមជំរាលនោះ ទើបគេមើលឃើញថាកងពល *មូស្កេ* ទាំងអស់កំពុង



www.budinst.gov.kh www.elibraryofcambodia.org

តំរង់ជួរនៅក្រៅជំរំរៀបចំចេញដំណើរ ម្នាក់ៗឈរនៅក្បែរសេះរបស់ខ្លួន ។ *យ៉ាប៊ូ ណាកា* និងពួកមេទ័ពរបស់ពួកគេនៅខាងមុខក្បួន ។ ភ្លៀងចាប់ផ្តើមធ្លាក់ខ្សោកៗដូចគេចាក់ទឹក ។

ដោយអារម្មណ៍ច្របូកច្របល់ *ប្លាក់ថន* បង្អង់សេះ ហើយសួរទៅ *អូមី* :

- ទ័ពទាំងអស់ចេញដំណើរឬ ?

- បាទ ។

- ទៅ *ស្ប៉ា* ( spa ) ជាមួយ *តូរ៉ាណាកា - សាម៉ា* ?

- ខ្ញុំមិនដឹងដែរ ។

វិញ្ញាណរបស់ *ប្លាក់ថន* បានប្រាប់គេកុំអោយសួរសំនួរអ្វីតទៅទៀត ។ តែសំនួរមួយត្រូវការចំលើយជាចាំបាច់ ។ គេសួរដោយធ្វើបែបហ៊ី :

- រួចចុះ *ប៊ុនតារ៉ូ - សាម៉ា* ? គាត់ទៅជាមួយយើងនៅព្រឹកស្អែកនេះដែរទេ ?

- ទេ គាត់ចេញដំណើរទៅបាត់ហើយ ។ ព្រឹកមិញនេះ គាត់នៅឯទីធ្លាភូមិជិតផ្ទះតែនោះឯង ។ លោកអត់ឃើញគាត់នៅក្បែរផ្ទះតែនោះទេអ្វី ?

ទឹកមុខរបស់ *អូមី* ឥតអោយគេមើលដឹងពីជំរៅចិត្តបន្តិចណាឡើយ :

- ទេ ។ អត់ឃើញ សូមទោស ។ គាត់ទៅ *ស្ប៉ា* ដែរ ?

- ខ្ញុំគិតថាប្រហែលដែរ ។ តែខ្ញុំមិនសូវច្បាស់ទេ ។

ភ្លៀងហូរស្រក់តាមដូនដែល *អូមី* ពាក់ ហើយដែលគេចងខ្សែជាប់ក្រោមចង្ការបស់គេ ។ បាមដូនស្ទើរបាំងជិតភ្នែករបស់គេ ។ គេពោលបន្ត :

- អីលូវនេះប្រាប់ខ្ញុំមក ហេតុអីបានជាលោកចង់អោយខ្ញុំមកទីនេះជាមួយលោក ?

- បង្ហាញកន្លែង ។

មុនពេលដែល *អូមី* អាចនិយាយអីបាននោះ *ប្លាក់ថន* ក៏បំផាយសេះចេញទៅមុនគ្នាម ។ ជាមួយនឹងវិញ្ញាណដើរសមុទ្ររបស់គេ *ប្លាក់ថន* មានលំនឹកពីទីតាំងយ៉ាងច្បាស់លាស់ ដោយហេតុនេះគេបានមកដល់មាត់ក្រហែងដីយ៉ាងរហ័ស ។ គេចុះពីលើខ្នងសេះ ហើយធ្វើសញ្ញាទៅរក *អូមី* :



www.budinst.gov.kh www.elibraryofcambodia.org

- សូមអញ្ជើញ ។

- ស្អីគេហ្នឹង ? - សំលេង *អូមី* មុត ១ ។

- សូមអញ្ជើញមកទីនេះ *អូមី - សាន* ។ មកម្នាក់ឯង ។

*អូមី* ធ្វើសញ្ញាអោយអ្នកការពារខ្លួនចេញ ហើយញាក់សេះទៅជិត *ប្លាក់ថន* :

*- ណាន តេស៊ូកា ?*

មាត់សួរ តែដៃរបស់ *អូមី* ហាក់កាន់ដងដាវណែនជាងមុន ។

- កន្លែងនេះ *តូរ៉ាណាកា - សាម៉ា ...* - ដោយគេរកទឹកពាក្យមិនឃើញ *ប្លាក់ថន* ក៏ធ្វើកាយវិការពន្យល់ - យល់ទេ ?

- កន្លែងនេះលោកទាញគាត់ចេញ *ទេ* ? រួចយ៉ាងម៉េច ?

*ប្លាក់ថន* សំលឹងមើល *អូមី* រួចសំលឹងយ៉ាងចេតនាមើលទៅដាវរបស់បុរសនេះ រួចងើយមើលមុខវិញ ដោយគ្មាននិយាយស្តីអ្វីមួយម៉ាត់ ។ *អូមី* សួរបញ្ជាក់ម្តងទៀតទាំងមួម៉ៅ:

*- ណាន តេស៊ូ កា ?*

*ប្លាក់ថន* នៅតែឥតឆ្លើយតបដដែល ។ *អូមី* អោនសំលឹងមើលរង្វះក្របែហងដី រួចងើបមើលមុខ *ប្លាក់ថន* វិញ ។ រួចទើបគេភ្លឺភ្នែកឡើង :

*- អ្អា សូតេស៊ូ ! វ៉ាការីម៉ាស៊ូ !*

តេគិតមួយភ្លែត រួចក៏ហៅអ្នកការពារខ្លួនម្នាក់ :

- ទៅហៅ *មូរ៉ា* មកនេះភ្លាម ។ យកមនុស្សម្តេនាក់ និងចបមកផង !

*សាមូរ៉ៃ* នោះបំផាយសេះចេញទៅភ្លាម ។ *អូមី* ក៏អោយអ្នកនៅសល់ទាំងប៉ុន្មានត្រលប់ទៅភូមិវិញ ។ បន្ទាប់មកគេចុះពីលើខ្នងសេះ ហើយឈរនៅក្បែរ *ប្លាក់ថន* ដោយនិយាយឡើង :

- ពិតហើយ *អាន់ជីន - សាន* ។ នេះចំជាការគិតឃើញមួយដ៏ប្រសើរបំផុត ។ ចំជាគំនិតល្អមែន ។

- គំនិត ? គំនិតអីទៅ ? - *ប្លាក់ថន* សួរដោយធ្វើពើ - គ្រាន់បង្ហាញកន្លែង



www.budinst.gov.kh www.elibraryofcambodia.org

ទេតើ ។ ខ្ញុំគិតថា លោកចង់ស្គាល់កន្លែង *នេ* ? សូមទោស... អត់យល់ ។

- *តូរ៉ាណាកា* បាត់ដាវនៅទីនេះ - *អូមី* និយាយ - ដាវមានតំលៃណាស់ ។ លោកពិតជារីករាយនៅពេលណាដែលបានដាវរបស់លោកវិញ ។ រីករាយមែនទែន *នេ* ?

- អ្ហា *សូ* ! មិនមែនគំនិតខ្ញុំទេ *អូមី - សាន* ។ គំនិត *អូមី - សាន* ទេ ។

- ពិតហើយ ។ អរគុណ *អាន់ជីន - សាន* ។ លោកចំជាមិត្តដ៏ល្អ ប្រាជ្ញាលោកវ៉ៃសវាងវៃ ។ ខ្ញុំគួរតែគិតរឿងនេះដោយខ្លួនឯង ។ ពិតហើយ លោកជាមិត្តដ៏ល្អ ហើយក្នុងប៉ុន្មានខែខាងមុខនេះ យើងទាំងអស់គ្នានឹងត្រូវការមិត្តល្អ ។ សង្គ្រាមបានមកដល់ពួកយើងហើយ ទោះជាពួកយើងចង់ រឺមិនចង់ក្ដី ។

- សូមទោស ? សូមអធ្យាស្រ័យ ។ ខ្ញុំមិនយល់ទេ ។ និយាយញាប់ណាស់ ។ សូមទោស ។

- សប្បាយចិត្ត យើងជាមិត្តនឹងគ្នា ។ លោក និងខ្ញុំ ។ យល់ទេ ?

- *វ៉ៃហ* ។ លោកនិយាយថាសង្គ្រាម ។ សង្គ្រាមពេលនេះ ?

- បន្តិចទៀត ។ តើយើងអាចធ្វើអ្វីបាន ? គ្មានធ្វើអ្វីបានទាំងអស់ ។ កុំខ្វល់អី *តូរ៉ាណាកា* នឹងប្រាមប្រាប *អ៊ីស៊ីដូ* ព្រមទាំងពួកក្បត់របស់វាទាំងប៉ុន្មានជាមិនខាន ។ នេះគឺជាការពិត ។ យល់ទេ ។ ឥតខ្វល់ខ្វាយ *នេ* ?

- យល់ ។ ខ្ញុំទៅអីលូវ ។ ផ្ទះខ្ញុំ ។ អត់អីទេ ?

- បាទ ។ ជួបគ្នាពេលព្រលឹម ។ ជាថ្មីម្ដងទៀត សូមអរគុណ ។

*ប្លាក់ថន* ងក់ក្បាល ប៉ុន្តែគេឥតដើរចេញទេ ។ គេពោល :

- នាងស្អាត *នេ* ?

- ថាម៉េច ?

- *គីគូ - សាន* ។

*ប្លាក់ថន* កន្ទែកជើងបន្តិចត្រៀមលោតថយក្រោយ និង ដកកាំភ្លើងតំរង់បាញ់តែម្ដង ។ គេនៅចាំយ៉ាងច្បាស់នូវល្បឿនហូតដាវដែលមិនអាចជឿបានរបស់ *អូមី* នៅពេល



www.budinst.gov.kh www.elibraryofcambodia.org

ដែលគេដកកាត់ក្បាលអ្នកភូមិទីមួយ កាលពីយូរពេលមកហើយនោះ ។ ហេតុនេះហើយគេត្រូវតែត្រៀមខ្លួនតាមដែលអាចធ្វើទៅបាន ។ គេយល់ឃើញថា សុវត្ថិភាពរបស់គេស្ថិតនៅលើការនិយាយរឿងរបស់ *គីតូ* អោយបានលឿន ។ *អូមី* ពិតជានឹងមិននិយាយពីរឿងនេះឡើយ ព្រោះគេចាត់ទុកថា ធ្វើរបៀបនេះជាកង្វះសុជីវធម៌មួយស្មានមិនដល់ ។ ហើយដោយគេចាត់រឿងប្រច័ណ្ឌនេះមិនមែនជាទំលាប់របស់ជនជាតិជប៉ុន គេពិតជាទុកភាពទន់ខ្សោយរបស់គេនៅក្នុងរឿងនេះជាប្រការអាម៉ាស់មួយ គេពិតជាសំងំលេបវារហូតដល់ពេលណាមួយដែលគេមិនអាចស្មានទុកជាមុន វានឹងផ្ទុះឡើងយ៉ាងងងឹតងងល់ និងយ៉ាងសាហាវជាមិនខាន ។

*អូមី* និយាយតាម :

- *គីតូ - សាន* ?

- *ហៃ* ។

នៅពេលនេះ *ប្លាក់ថន* សង្កេតឃើញថា *អូមី* មានការញាប់ញ័រដែរ ។ ទោះជាយ៉ាងនេះក្តី ក៏គេរីករាយដែលគេបានរើសយកពេលវេលា និងទីកន្លែងនេះ ។ *អូមី* និយាយ :

- ស្អាត ?

- *ហៃ* ?

ភ្លៀងកាន់តែខ្លាំងឡើងថែមទៀត ។ តំនក់ទឹកភ្លៀងធំៗធ្វើអោយខ្វាយភក់ពាសពេញ ។ សេះរបស់ពួកគេគ្រញែងខ្លួន ប៉ុន្តែតំនក់ទឹកភ្លៀងមានភាពក្តៅស្រួលទេ ។

*អូមី* តប :

- ពិតហើយ ។ *គីតូ - សាន* ស្អាតណាស់ ។

រួចគេបន្តនិយាយច្រើនទៀត តែ *ប្លាក់ថន* ស្តាប់មិនបាន គេក៏ពោលតបទៅវិញ :

- ទេ ពាក្យនិយាយមិនគ្រប់គ្រាន់ទេ *អូមី - សាន* ។ អត់ចេះគ្រប់គ្រាន់ និយាយមិនច្បាស់ ។ បន្តិចទៀតបាន អីលូវនេះមិនបានទេ ។ យល់ទេ ?

*អូមី* ហាក់ដូចជាមិនលឺនូវអ្វីដែល *ប្លាក់ថន* និយាយទេ ។ គេតប :



www.budinst.gov.kh www.elibraryofcambodia.org

- នៅមានពេលច្រើនណាស់ *អាន់ជីន -សាន* ។ មានពេលច្រើនណាស់ដើម្បីនិយាយពីនាង ពីលោក ពីខ្ញុំ និង ពី *កាម៉ា* ។ តែខ្ញុំក៏ឯកភាពដែរ ពេលនេះមិនមែនជាពេលដែលត្រូវនិយាយពីរឿងនេះទេ *នេ* ?

- ខ្ញុំគិតថា ខ្ញុំយល់ ។ ពិតហើយ ។ ពីម្សិលមិញ អត់ដឹង *អូមី - សាន* និង *គីតូ -សាន* មិត្តល្អនឹងគ្នា ។

- នាងមិនមែនជាកម្មសិទ្ធិរបស់ខ្ញុំទេ ។

- អីលូវនេះដឹងថា លោក និង នាងជាមិត្តដ៏ល្អនឹងគ្នាណាស់ ។ អីលូវនេះ...

- អីលូវនេះ ចេញទៅ ។ រឿងនេះចប់ត្រឹមណឹង ។ មនុស្សស្រីគ្មានអ្វីសំខាន់ទេ ។ គ្មានទាល់តែសោះ ។

*ឮាក់ថន* នៅតែឈរយ៉ាងចចេសនៅកន្លែងដដែល :

- លើកក្រោយ ខ្ញុំ...

- កិច្ចសន្ទនានេះចប់ហើយ ! លោកមិនលឺទេអ្វី ? ចប់ហើយ !

- *អ៊ីយេ ! អ៊ីយេ !*

ដៃរបស់ *អូមី* វារវកដាវ *ឮាក់ថន* ថយក្រោយពីរជំហានភ្លាមទាំងមិនដឹងខ្លួន ។ តែ *អូមី* ឥតបានដកដាវរបស់ខ្លួនទេ ហើយ *ឮាក់ថន* ក៏មិនបានហូតកាំភ្លើងខ្លីខ្លួនចេញមកដែរ ។ គេប្រុងប្រៀបទាំងពីរនាក់ តែគ្មានអ្នកណាម្នាក់ចង់ចាប់ផ្តើមនោះឡើយ ។

- តើលោកចង់និយាយពីរឿងអ្វី *អាន់ជីន -សាន* ?

- លើកក្រោយ ដំបូងខ្ញុំសួរ... រឿង *គីតូ - សាន* ។ បើ *អូមី* ថា បាទ ... បាទ ។ បើទេ... ទេ ! យល់ទេ ? មិត្ត នឹង មិត្ត *នេ* ?

*អូមី* បន្ធូរដៃពីដងដាវបន្តិច :

- ខ្ញុំនិយាយម្តងទៀត ។ នាងមិនមែនជាកម្មសិទ្ធិខ្ញុំទេ ។ អរគុណលោកដែលបង្ហាញកន្លែងនេះដល់ខ្ញុំ *អាន់ជីន - សាន* ។ សូមលា ។

- មិត្ត ?



www.budinst.gov.kh www.elibraryofcambodia.org

- ពិតហើយ ។

រួច *អូមី* ដើរទៅកាន់បង្អៀសេះរបស់ *ភ្លាក់ថន* ដើម្បីទប់សេះទុកអោយ *ភ្លាក់ថន* ឡើងដោយសំរួល ។

គេអោនសំលឹងមើល *អូមី* ពីលើខ្នងសេះ ។ បើសិនជាគេអាច គេដឹងថាគេច្បាស់ជាបាញ់បំបែកក្បាល *សាមូរ៉ៃ* នេះជាពិតប្រាកដ ។ នេះគឺជាច្រកសុវត្ថិភាពរបស់គេតែម្តង ។

- លាហើយ *អូមី - សាន* ។ ហើយសូមអរគុណ ។

- លាហើយ *អាន់ជីន - សាន* ។

*អូមី* នៅឈរសំលឹងមើល *ភ្លាក់ថន* រហូតដល់គេឆ្លងទៅម្ខាងទួលបាត់ទើបវិលត្រលប់មកកន្លែងចាសវិញ ។ គេយកដុំថ្មមកដាក់សំគាល់កន្លែង ។ រួចរាល់ហើយ គេអង្គុយចោងហោងនៅក្បែរនោះដើម្បីរង់ចាំ ។ អារម្មណ៍ជ្រួលច្របល់របស់គេឥតបានយកចិត្តទុកដាក់នឹងភ្លៀងដូចគេហែកមេឃនោះឡើយ ។

បន្តិចមក *មូរ៉ា* និងពួកកសិករបានឡើងមកដល់ទាំងដើរបប៉ិចប៉ាច់កាត់ភក់ ។

- *មូរ៉ា ! តូរ៉ាណាកា - សាម៉ា* បានធ្លាក់ចុះក្នុងក្រហែងដីនៅកន្លែងនេះ ។ ដាវទាំងពីររបស់លោកត្រូវកប់ក្នុងនេះ ។ មុនព្រះអាទិត្យលិចយកដាវទាំងពីរនេះទៅអោយខ្ញុំ ។

- បាទ *អូមី - សាម៉ា* ។

- បើសិនជាឯងមានខួរក្បាល បើសិនជាឯងយកចិត្តទុកដាក់នឹងខ្ញុំ យកចិត្តទុកដាក់អម្ចាស់ឯង មកដល់ពេលនេះប្រហែលជាឯងធ្វើរឿងនេះបាត់ទៅហើយ ។

- សូមអភ័យទោសដល់ភាពល្ងីល្ងើរបស់ខ្ញុំផង ។

រួច *អូមី* ក៏ចេញដំណើរត្រលប់ទៅវិញ ។ ពួកគេតាមសំលឹងមើលមួយភ្លែតរួចក៏នាំគ្នាឈរជុំវិញដុំថ្មដែល *អូមី* ដាក់សំគាល់នោះ ហើយចាប់ផ្តើមជីកភ្លាមដែរ ។

*មូរ៉ា* ទំលាក់សំលេងរបស់ខ្លួន :

- *អ៊ូយ៉ូ* អែងត្រូវទៅជាមួយក្បួនអីវ៉ាន់ ណា៎

- បាទ *មូរ៉ា - សាន* ។ តែទៅយ៉ាងម៉េច ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំនឹងប្រគល់អែងជូនទៅ *អាន់ជីន - សាន* ។ គាត់នឹងមិនឃើញខុសគ្នានោះទេ ។

*អ៊ូយូ* និយាយខ្សិបៗតបទៅវិញ :

- តែកំណាន់គាត់អាចដឹងបាន *អូហ៍កូ* នាងពិតជាដឹង ។

- នាងមិនទៅជាមួយគាត់ទេ ។ ខ្ញុំលឺថានាងរលាកភ្លើងធ្ងន់ធ្ងរណាស់ ។ នាងត្រូវទៅ *យេដូ* តាមជើងទឹកនៅពេលក្រោយទៀត ។ អែងដឹងថាត្រូវធ្វើអ្វីហើយ *ទេ ?*

- ស្វែងជួបគណៈសង្ឃជាសំងាត់ និង ឆ្លើយគ្រប់សំនួរ ។

- ត្រូវហើយ - *មូរ៉ា* បន្ទូរភាពតានតឹងនៅក្នុងចិត្តហើយនិយាយក្នុងសំលេងធម្មតាវិញ - អែងអាចទៅជាមួយ *អាន់ជីន - សាន* បាន *អ៊ូយូ* ។ គាត់អោយប្រាក់កំរៃច្រើន ។ ធ្វើខ្លួនអែងអោយមានផលប្រយោជន៍ តែកុំមានផលប្រយោជន៍ហួសហេតុ បើមិនយ៉ាងដូចនោះទេ *អាន់ជីន - សាន* នឹងយកអែងតាមរហូតដល់ *យេដូ* ជាមិនខាន ។

*អ៊ូយូ* លាន់សំនើច :

- អេ ខ្ញុំលឺគេថា *យេដូ* មានហូរហៀរហូតដល់ម្នាក់ៗបាញ់នោមដាក់កន្ថោរប្រាក់ទៀតផង ។ សូម្បីតែពួក *អេតា* ក៏អញ្ចឹងដែរ ។ ហើយគេថានារីៗមានសាច់ថ្លាផ្លុះដូចពពុះសមុទ្ទនិងរលីងស្អាតឆិញតែម្តង ។

អ្នកភូមិម្នាក់ទៀតសួរឡើងភ្លាម :

- មែនរឺ *មូរ៉ា - សាន ?* ពិតជារលីងឆិញមែនរឺ ?

- កាលខ្ញុំទៅទីនោះជាលើកដំបូង *យេដូ* គ្រាន់តែជាភូមិនេសាទដ៏សំអុយមួយតែប៉ុននោះ មិនមែនល្អដូច *អាន់ជីរ៉ូ* នេះទេ - *មូរ៉ា* និយាយប្រាប់អ្នកភូមិបណ្តើរ ដៃទៅបន្តជីកដីបណ្តើរ - កាលនោះពួកយើងដេញតាមកំចាត់ពួក *ប៊ិបពូ* ជាមួយលោកម្ចាស់ *តូរ៉ាណាកា - សាម៉ា* ។ កាលនោះ ពួកយើងកាត់ក្បាលបានជាងបីពាន់ ហើយស្រីណាក៏មានរោមដែរ លើកលែងតែស្រីម្នាក់មកពីកូរ៉េ តែវាប្រាប់ថាវាដកទេ ។ ដកម៉ាសរសៃម្តង ។

អ្នកណាម្នាក់បន្ទរឡើង :

- គិតទៅស្រីៗធ្វើអីក៏ធ្វើដែរ អោយតែទាក់ប្រុសបាន មែនទេ ?



www.budinst.gov.kh www.elibraryofcambodia.org

- ពិតហើយ តែខ្ញុំចង់ឃើញផ្ទាល់ភ្នែកខ្ញុំណា៎ - *នីនជីន* និយាយទាំងមាត់ត្រហុប - ចង់ឃើញរូងនាគដោយគ្មានគុម្ពោតព្រៃណា៎ ។

- អញហ៊ានភ្នាល់ដាក់ត្រីមួយទូកទល់នឹងអាចម៍មួយចុង ថាការដករោមនេះពិតជារោទិ៍លាន់ពុទ្ធោហើយអា៎ - *អ៊ុយ៉ូ* និយាយរង្វើរ ៗ ។

*ម៉ូរ៉ា* អោនទ្រោបទៅលើចបដើម្បីសំរាកយកដង្ហើមមួយភ្លែតហើយនិយាយរំលឹករឿងចាស់ :

- តើអ្នកណាអាចគិតដល់បានថាមនុស្សចំលែកចុងស្រុកអាចងើបឡើងពីក្នុងអន្លង់ទៅដល់ស្ថានសួគ៌យ៉ាងដូចនេះ ហ្ន៎ សូម្បីតែរូបខ្ញុំក៏រកជឿមិនបានផង ។ នេះដូចជារឿងព្រេងតែម្តង ។ *កាម៉ា ទេ ?*

- ក្រែងកាលពីជាតិមុន គាត់ជាពួកយើងដែរទេ អ្ហឺ ? ហើយគាត់មកចាប់ជាតិវិញនេះដោយនៅរក្សាចិត្តគំនិតដដែល គ្រាន់តែស្បែកខុសពីមុនតែប៉ុណ្ណោះ ។

*នីនជីន* ងក់ក្បាលឯកភាព :

- អាចដែរ ។ អាចមកពី... បើតាមព្រះតេជគុណសង្ឃគ្រីស្តសាសនា ខ្ញុំគិតថា *អាន់ជីន -សាន* ត្រូវនៅដុតរោលរាលក្នុងភ្លើងអវិចីយូរពេកហើយមើលទៅ ។ មិនតើបព្វជិតលោកបានប្រាប់ថា លោកបានដាក់បណ្តាសាលើ *អាន់ជីន -សាន* នេះជាពិសេសទើរ ? ខ្ញុំលឺលោកអំពាវនាវអោយ *កាមី* យេស៊ូ ផ្ទាល់មកផ្តន្ទាទោសបុរសនេះថែមទៀតផង ហើយខ្ញុំសែនរន្ធត់ញាប់ញ័រមែនទែនតែម្តង - *នីនជីន* ធ្វើសញ្ញាខ្វែងពីមុខខ្លួនតែគ្មានអ្នកណាអើពើសោះឡើយ - តែបើពួកអែងសួរខ្ញុំៗយល់ថាព្រះមាតា *ម៉ាដូណា* ផ្តន្ទាសត្រូវរបស់លោកក្នុងរបៀបចំលែកមែនទែន ។

*អ៊ុយ៉ូ* លូកមាត់ :

- ខ្ញុំមិនមែនគ្រីស្តសាសនិកទេ អ្នកណាក៏ដឹងដែរ តែសូមទោសទៅចុះ ចំពោះខ្ញុំ *អាន់ជីន - សាន* ជាមនុស្សល្អ ហើយគ្រាន់បើជាងបព្វជិតគ្រីស្តដ៏មានក្លិននិងដើរបន្ទាចគេឯងគ្រប់គ្នានោះផង ។ ហើយគាត់ល្អជាមួយពួកយើងថែមទៀតផង *ទេ ?* ហើយគាត់



www.budinst.gov.kh www.elibraryofcambodia.org

យកចិត្តទុកដាក់លើកូនចៅគាត់បានយ៉ាងល្អ ។ អ្នកខ្លះថាគាត់ជាមិត្តភ័ក្រ្តលោកម្ចាស់ *តូរ៉ាណាកា* ផង ហើយនេះអាចដែរបើមើលទៅតាមកិត្តិយសទាំងប៉ុន្មានដែលគាត់មាននេះ *នេ ?* ហើយកុំភ្លេចថា *គីតូ - សាន* បានយកប្រដាប់ម៉ៃចែកអោយមកជូនជាកិត្តិយសដល់គាត់ផងណា ។

- ពិតជាប្រដាប់ម៉ៃចែកមែន ។ ខ្ញុំលឺថា នៅយប់នោះ *អានជីន -សាន* ត្រូវចំនាយអស់ប្រាំ *កូបាន* ឯនោះ ។

- ដប់ប្រាំ *កូតូ* សំរាប់ម៉ាយប់ ? - *នីនជីន* រិះស្នាក់ខ្យល់ - ចុះ *អានជីន - សាន* អីក៏មានសំនាងម្ល៉េះ ? *កាម៉ា* របស់សត្រូវព្រះនេះពិតជាទូលំទូលាយមែនតែម្តង ។

*មូរ៉ា* លូកមាត់ម្តង :

- គាត់អស់តែមួយ *កូបាន* ទេ គឺបី *កូតូ* ។ តែបើពួកអែងគិតថានេះជាចំនួនច្រើននោះ...

រួចគាត់បញ្ឈប់ឃ្លាកណ្តាលទីហើយវេភ្នែកសំលឹងមើលជុំវិញខ្លួនហាក់ខ្លាចមានអ្នកណាម្នាក់មកលួចស្តាប់នូវអ្វីដែលគាត់មានបំនងនិយាយចេញនេះ ថ្វីត្បិតតែគាត់ដឹងថានៅកណ្តាលភ្លៀងនេះគ្មានអ្នកណាម្នាក់មកដល់ទីនេះឡើយក្តី... ហើយបើទោះជាមានអ្នកមកលួចស្តាប់ការជជែកគ្នានេះក្តី ក៏គ្មានការអ្វីដែរ ។

ពួកអ្នកភូមិឈប់ផឹកដីហើយខិតទៅជិត *មូរ៉ា* ។

- ម៉េចទៅ *មូរ៉ា - សាន ?*

- គេទើបខ្សិបប្រាប់ខ្ញុំថា នាងនឹងក្លាយខ្លួនជាកំនាន់របស់លោកម្ចាស់ *តូរ៉ាណាកា* ហើយ ។ លោកម្ចាស់ទើបទិញកិច្ចសន្យារបស់នាងកាលពីព្រឹកមិញនេះ ។ *បីពាន់កូតូ* ។

ចំនួនទឹកប្រាក់នេះធ្វើអោយពួកគេវង្វេងស៊ុងតែម្តង ។ នេះគឺជាចំនួនទឹកប្រាក់មួយដែលមួយភូមិនេះលក់ត្រីនិងស្រូវក្នុងរយៈម្ភៃឆ្នាំសឹងតែមិនបានផង ។ ពួកគេកាន់តែគោរព *គីតូ* ថែមទៀត ។ ក៏ដូចជាការគោរពចំពោះ *អានជីន - សាន* ដែលជាបុរសចុងក្រោយបំផុតនៅលើដែនដីនេះដែលបានទទួលការរីករាយពី *គីតូ* ក្នុងឋានៈជានារីកំដរភ្ញៀវថ្នាក់លេខ



www.budinst.gov.kh www.elibraryofcambodia.org

មួយនេះ ។

- ម៉្រាយអើយ - *អ៊ុយ៉ូ* និយាយស្ទើរលែងចេញ - លុយច្រើនយ៉ាងនេះ អញចង់កួតបន្តិច ចង់លេចនោមបន្តិច ចង់លេចជោមបន្តិច មិនដឹងយ៉ាងម៉េចទេ ។

- មិនបាច់ចង់ធ្វើអីទេ - *មូរ៉ា* តបយ៉ាងកំព្រើស - ជីកដីទៅ " រកដាវអោយឃើញទៅ ។

ពួកគេទទួលធ្វើតាម ដោយម្នាក់១លង់ខ្លួនទៅក្នុងគំនិតរៀង១ខ្លួន ។ រង្វះក្រហែងនេះកាន់តែជ្រៅទៅ១ ។

ប៉ុន្តែ ក្រោយពេលបន្តិចមកទៀត *នីទជីទ* ដែលត្រូវរូបរឹតដោយកង្វល់នោះ ទប់ចិត្តលែងបាន ។ គេបញ្ឈប់ជំនីកហើយសួរជាសំនួរឡើង :

- *មូរ៉ា - សាន* អោយខ្ញុំសូមទោស តើលោកសំរេចយ៉ាងម៉េចហើយអារឿងពន្ធដារថ្មីនេះ ?

ទាំងអស់គ្នាឈប់ជីក ។

*មូរ៉ា* នៅបន្តជីកដីយ៉ាងម៉ត់ចត់ទៅតាមរបៀបរបស់ខ្លួន :

- មានអីត្រូវសំរេចទៀត ? *យ៉ាប៊ូ - សាម៉ា* និយាយថាបង់ ពួកយើងត្រូវតែបង់ហើយ *រទ?*

- តែលោកម្ចាស់ *តូរ៉ាណាកា* កាត់យកបូនភាគក្នុងដប់ភាគទៅហើយ ហេតុនេះគាត់ជាអម្ចាស់យើងហើយនៅពេលនេះ ។

- ពិតហើយ តែលោកម្ចាស់ *យ៉ាប៊ូ* បានទទួលមកវិញនូវតំបន់ *អ៊ីស៊ូ* ហើយ *ស៊ូរ៉ុកា* និង *តូតូមី* ក៏អញ្ចឹងដែរ ធ្វើអោយគាត់នៅជាលោកម្ចាស់ដដែល ។ ហេតុនេះថាទៅមើល អ្នកណាជាអម្ចាស់យើង ?

- *តូរ៉ាណាកា - សាម៉ា* ។ ពិតណាស់ *មូរ៉ា - សាន តូរ៉ា...*

- អញ្ចឹងអែងទៅគវ៉ាជាមួយគាតិរី *នីទជីទ?* អ្ហា ? ភ្លឺភ្នែកឡើង *យ៉ាប៊ូ - សាម៉ា* នៅតែជាអម្ចាស់តំបន់នេះដូចតាំងពីដើមរៀងមកអញ្ចឹង ។ គ្មានអ្វីផ្លាស់ប្តូរទេ ។ ហើយបើ



www.budinst.gov.kh www.elibraryofcambodia.org

លោកម្ចាស់ *យ៉ាប៊ូ* តំលើងពន្ធ ពួកយើងបង់ពន្ធថែមទៅ គឺវាចប់ហើយ ។

- តែបើអញ្ចឹង គឺវាអស់ទាំងស្បៀងរដូវរងារបស់ពួកយើងទៅហើយ ។ អស់និញតែម្តងហើយណា៎ - សំលេងរបស់ *នីនជីន* លាន់ត្រលួចដោយកំហឹង តែទាំងអស់គ្នាសុទ្ធតែបានដឹងថាអ្វីដែលបុរសនេះនិយាយគឺការពិត - ទោះជាមានស្រូវដែលយើងលួច...

*អ៊ីយូ* ខ្សឹបកែតំរូវភ្លាម :

- ស្រូវដែលយើងសន្សំបាន ។

- ទោះជាមានស្រូវដែលសន្សំបានក្តី ក៏មិនគ្រប់គ្រាន់សំរាប់ពេញមួយរដូវរងាដែរ ។ វាទាល់តែយើងលក់ទូក រឺ ...

- ពួកយើងមិនលក់ទូកទេ - *មូរ៉ា* តប ។ គាត់ចាក់ចបទៅក្នុងភក់ ហើយជូតញើសចេញពីរង្វង់ភ្នែកខ្លួន ។ បន្ទាប់មកគាត់រឹតបន្តឹងខ្សែមួកអោយកាន់តែតឹងជាងមុន ហើយចាប់ផ្តើមចូកដីសាជាថ្មី - ធ្វើការទៅ *នីនជីន* ។ នេះអាចអោយអែងភ្លេចពីរឿងថ្ងៃស្អែកបានផង ។

- តើធ្វើម៉េចយើងឆ្លងរដូវរងាបានទៅ *មូរ៉ា - សាន ?*

- ឆ្លងអោយតែរួចរដូវផ្ការីកសិនទៅ ។

- ពិតហើយ - *នីនជីន* ឯកភាពយ៉ាងជូរចត់ - ពួកយើងបង់ពន្ធមុនពីរឆ្នាំទៅហើយ ។ នៅតែមិនគ្រប់គ្រាន់ទៀត ។

- *កាម៉ា ណាកាជីន - អ៊ីយូ* តប ។

- សង្គ្រាមមកដល់ហើយ ។ ប្រហែលជាយើងនឹងបានអម្ចាស់ថ្មីមួយដែលយុត្តិធម៌ជាង *ទេ ?* - បុរសម្នាក់លូកមាត់ចូល ។

- វាគ្មានលើសគ្នាទេ ។ គ្មានអ្នកណាគ្រាន់បើជាងអ្នកណាទេ ។

- កុំទៅភ្លាល់គ្នារឿងណឹង - *មូរ៉ា* និយាយទៅកាន់អ្នកភូមិទាំងអស់ - ពួកអែងនៅមានដង្ហើមដកនៅឡើយទេ ពួកអែងអាចងាប់តែមួយប្រព្រិចភ្នែកហើយពេលណុងលែងមានរូងនាគមើលហើយ ទោះរូងមានគុម្ពោតព្រៃ រឺ អត់ក៏ដោយ ។

ពួកគេរួមគ្នាគាស់ដុំថ្មចេញពីក្នុងភក់ ។ *អ៊ីយូ* និយាយខ្សឹបៗទាំងកង្វល់ទៅ *មូរ៉ា* :



www.budinst.gov.kh www.elibraryofcambodia.org

- *មូរ៉ា - សាន* បើព្រះតេជគុណគណៈសង្ឃសួរខ្ញុំពីរឿងអាវុធ តើត្រូវឆ្លើយថាម៉េចទៅ ?

- ជំរាបលោកទៅ ។ ជំរាបលោកថាយើងត្រៀមរួចហើយ ថា *អាន់ជី* ត្រៀមស្រេចហើយ ។

☆ ☆

☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៤២

ពួកគេបានទៅដល់ *យ៉ូកូសេ* នៅវេលាថ្ងៃត្រង់។ តាមបញ្ជាដែលខ្លួនបានទទួលនោះ *ប៊ុនតារ៉ូ* បានស្ទាក់កាត់ផ្លូវក្បួន *សាតាគី* តាំងពីយប់កន្លងទៅ ហើយបានស្វាគមន៍បុរសនេះ យ៉ាងហ៊ឹកហ៊ាក់ ជាទីបំផុត។ លោកបានរៀបរាប់ប្រាប់ *តូរ៉ាណាហ្គា* ថា :

- ខ្ញុំបានស្នើគាត់អោយបោះជំរំនៅខាងជើងភូមិ រហូតដល់កន្លែងជួបគ្នាត្រូវបានរៀបចំរួច។ ការជួបជាផ្លូវការនឹងត្រូវធ្វើឡើងនៅវេលារសៀលនេះ បើសិនជាលោកម្ចាស់ពេញចិត្ត -រួច *ប៊ុនតារ៉ូ* និយាយបន្ថែមបែបកំប្លែងលេង -ខ្ញុំគិតថា យាមមមែពិតជាល្អ។

- ល្អ។

- គាត់ចង់ជួបលោកម្ចាស់នៅយប់នេះ តែខ្ញុំបានប្រកែកសំនើនេះ ។ ខ្ញុំប្រាប់គាត់ថា លោកនឹង " បានកិត្តិយស " ជួបនៅថ្ងៃនេះ រឺ ថ្ងៃស្អែក អាស្រ័យការសំរេចរបស់លោកម្ចាស់ តែមិនជួបក្រោយពេលព្រលប់នោះទេ។

*តូរ៉ាណាហ្គា* គ្រហឹមជំនួសការឯកភាព តែលោកមិនទាន់ចុះពីលើសេះដែលហត់បែកពពុះមាត់នៅឡើយ។ លោកពាក់ក្រោះការពារទ្រូង មួកការពារក្បាល ហើយនឹងអាវក្រោះរីស្សីស្រាលមួយ ដូចពួកហែហមរបស់លោកដែរ។ លោកសំលឹងមើលសព្វទិសទីដោយប្រយ័ត្នប្រយែង។ ទីលាននេះត្រូវបានជ្រើសរើសយ៉ាងម៉ត់ចត់ដែលមិនអាចអោយមានការហ៊ុមព័ទ្ធមួយណាបានឡើយ ។ គ្មានដើមឈើ គ្មានផ្ទះនៅជិតដែលអាចលាក់បំពួនអ្នកបាញ់ធ្នូ រឺបាញ់មួស្គេបានឡើយ។ នៅខាងកើតជាប់នឹងភូមិគឺជាដីដែលមានភាពរាបស្មើ និងខ្ពស់ជាងបន្តិច។ ខាងជើង ខាងលិច និងខាងត្បូង ត្រូវបានការពារដោយភូមិ និងស្ពានឈើមួយដែលលាតសន្ធឹងពីលើស្ទឹងដែលទឹកកំពុងហូរគ្រចាញ់។ កន្លែងដែលរួមចង្អៀត មានទឹកគួចគ្រចាញ់ ហើយពេញដោយថ្មាំងថ្ម។ នៅឯទិសខាងកើតពោលគឺនៅពីក្រោយលោក និងពួកកងសេះរបស់លោកនោះ ផ្លូវឡើងយ៉ាងចោតរហូតដល់ច្រកទ្វារភ្នំដែលនៅកប់បាត់ក្នុងអ័ព្ទ ចំងាយប្រហែលជាប្រាំលីពីទីនេះ។ នៅជុំវិញមានសុទ្ធតែភ្នំដែលភាគច្រើនជាប្រភេទភ្នំភ្លើង ហើយដែលស្ទើរតែទាំងអស់មានកំពូលលង់លក់នៅក្នុងដុំពពក។ នៅកណ្តាលទីធ្លា រោងមួយដែលមានជប់ពីរសសរ និងដែលមានដំបូលប្រក់



www.budinst.gov.kh www.elibraryofcambodia.org

ជុំជិតនោះ ត្រូវបានគេសង់បន្ទើតពីលើដីបន្តិច។ ក្បាច់ក្បូរនានាគ្មានបានបង្ហាញថាអ្វីៗនៅទីនេះត្រូវបានរៀបចំយ៉ាងប្រញាប់ប្រញាល់នោះឡើយ។ ម៉ក់ចរបាប់ពីរត្រូវបានរៀបចំដាក់ទល់មុខគ្នានៅពីលើ *តាតាមី*។

*ប៊ុនកាវ៉ូ* លើកព្រួញចង្អុលបណ្ដើរ និយាយបណ្ដើរ :

- ខ្ញុំដាក់មនុស្សរបស់ខ្ញុំនៅទីនុះ ! នុះ និង នុះ! ។ លោកម្ចាស់អាចមើលឃើញច្បាស់គ្រប់ទិសក្នុងរង្វង់រាប់លីបាន។ នេះជាទីតាំងការពារដ៏ល្អបំផុត។ យើងគ្រប់គ្រងជាប់ល្អលើភូមិនិងស្ពាន។ ទៅខាងកើត ការដកថយរបស់លោកម្ចាស់ត្រូវបានការពារដោយមនុស្សមួយចំនួនទៀត។ ស្ពាននេះត្រូវបានខ្ញុំដាក់អ្នកយាមគត់មត់ណាស់ ហើយខ្ញុំនៅបានទុក " កងកិត្តិយស " មួយរយនាក់ទៀតនៅឯជំរំរបស់ *សាតាគី* ថែមទៀត។

- អីលូវនេះលោកម្ចាស់ *សាតាគី* នៅក្នុងជំរំនោះ រឺ ?

- អត់ទេ ទាន ។ ខ្ញុំបានជ្រើសរើសតៀមមួយសំរាប់គាត់ និងពួកអ្នកហែហមនៅឯជាយភូមិផ្នែកខាងជើង ហើយដែលសក្តិសមនឹងឋានៈរបស់គាត់។ ខ្ញុំបានអញ្ជើញគាត់ត្រាំទឹកនៅទីនោះតែម្តងទៅ។ តៀមនោះនៅដាច់ពីគេ ហើយមានការធានាសន្តិសុខគ្រប់គ្រាន់។ ខ្ញុំគិតថាលោកម្ចាស់ប្រហែលជាអញ្ជើញទៅ *ស៊ូរ៉ា ស៊ូមិទជី* នាពេលស្អែកដោយមានលោកម្ចាស់ *សាតាគី* ជាភ្ញៀវផង។

*ប៊ុនកាវ៉ូ* លើកដៃចង្អុលទៅផ្ទះតៀមមួយសង់ផ្ទាល់ដីតែមួយជាន់ តែស្អាតច្រលឹងហើយដែលនៅចុងទីធ្លា ក្បែរទឹកជ្រោះក្ដៅដែលហូរបែកពពុះទឹកគ្រុកៗចេញពីដុំថ្ម ហើយដែលក្លាយទៅជាកន្លែងត្រាំទឹកធម្មជាតិមួយ :

- តៀមនោះជាកន្លែងលោកម្ចាស់ហើយ ទាន។

នៅពីមុខតៀម មានបុរសមួយក្រុមនៅលុតជង្គង់ អោនក្បាលយ៉ាងទាប និងយ៉ាងស្ងាត់ស្ងៀមសំដៅមករកពួកគេ។

- ពួកទាំងនោះគឺជាមេភូមិ និងអ្នកចាស់ទុំនៅក្នុងភូមិនេះ។ ខ្ញុំមិនដឹងថាលោកម្ចាស់ចង់ជួបពួកនេះ ពេលនេះ រឺអត់ទេ។



www.budinst.gov.kh www.elibraryofcambodia.org

- ចាំក្រោយទៅ ។

សេះរបស់ *តូរ៉ាណាកា* កញ្ជ្រៀវយ៉ាងឡើយហត់ ហើយគ្រវីក្បាលតតាត់ធ្វើអោយបង្ហៀវលាន់ដូចកណ្តឹង ។ លោកអង្អែលវាថ្នម១ ហើយដោយមានទំនុកចិត្តចំពោះរឿងសុវត្ថិភាពហើយនោះ លោកធ្វើសញ្ញាទៅកូនចៅរបស់លោក រួចចុះពីលើសេះ ។ សាមូរ៉ៃម្នាក់របស់ *ប៊ុនតារ៉ូ* ចាប់បង្ហៀវសេះរបស់លោក ។ សាមូរ៉ៃនេះក៏ដូចជា *ប៊ុនតារ៉ូ* និងយុទ្ធជនឯទៀត១ដែរ ពាក់អាវក្រោះ មានអាវុធគ្រប់គ្រាន់ និងត្រៀមប្រយុទ្ធហើយជាស្រេច ។

*តូរ៉ាណាកា* ពត់ខ្លួនប្រាណដើម្បីបន្ធូរសាច់ដុំខ្នង និងជើងរបស់លោក ។ លោកបានរួតរះធ្វើដំណើរតាំងពី *អាន់ជីរ៉ូ* ដោយគ្មានឈប់សំរាកតាមផ្លូវឡើយ ក្រៅតែពីដើម្បីប្តូរសេះតែប៉ុណ្ណោះ ។អ៊ីរ៉ៃអ៊ីវ៉ាន់ផ្សេងទៀតរួមទាំងត្រៃស្លែង និងអ្នកស្ទែងផងស្ថិតនៅឯក្រោយឆ្ងាយ ក្រោមកិច្ចបញ្ជារបស់ *អូមី* ។ ផ្លូវមកកាន់ *អាន់ជីរ៉ូ* គឺបត់បែនតាមឆ្នេរសមុទ្រ រួចទើបងាកបែកចូលក្នុងតាមផ្លូវខាងលិច ហើយឡើងជំរាលភ្នំរហូតដោយកាត់តាមព្រៃក្រាស់សំបូរដោយសត្វព្រៃ ។ នៅស្តាំដៃគឺជាភ្នំ *អូយ៉ាម៉ា* កំពូលជូរភ្នំភ្លើង *អាម៉ាគី* នៅខាងឆ្វេង ។

លោកពោលទៅកាន់ *ប៊ុនតារ៉ូ* ៖

- ល្អ ។ លោកធ្វើបានល្អណាស់ ។

- បើសិនជាលោកម្ចាស់ចង់ផ្តល់កិត្តិយសដល់ខ្ញុំ សូមអនុញ្ញាតអោយខ្ញុំកំទេច *សាកាគី* និងកូនចៅវាទៅពេលនេះតែម្តងទៅ ។

- វាប្រមាថលោក រឺ.....?

- អត់ទេ ទាន....។ ផ្ទុយទៅវិញ អាកប្បកិរិយារបស់វាថ្លៃថ្នូរទេ.....តែទង់ដែលវាប្រើសំរាប់ធ្វើដំណើរនេះ គឺជាអំពើក្បត់មួយប្រឆាំងនឹងលោកម្ចាស់ហើយ ។

- ត្រូវចេះខន្តី ។ តើខ្ញុំប្រាប់លោកប៉ុន្មានដងហើយ -សំដីរបស់ *តូរ៉ាណាកា* មិនមានភាពប្រទូសអ្វីឡើយ ។

- ខ្ញុំខ្លាចតែលោកម្ចាស់ ត្រូវតែប្រាប់រហូតតែអ៊ីចឹងទេ -*ប៊ុនតារ៉ូ* តប -សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ។



www.budinst.gov.kh www.elibraryofcambodia.org

- លោកធ្លាប់ជាមិត្តនឹងវាដែរតើ ។

- វាក៏ធ្លាប់ជាសំព័ន្ធមិត្តរបស់លោកម្ចាស់ដែរ ។

- វាធ្លាប់ជួយជីវិតលោកនៅឯ *អូដាវ៉ាក៉ា* ផង ។

- នៅឯ *អូដាវ៉ាក៉ា* យើងនៅក្នុងជួរជាមួយគ្នា -*ប៊ុនតារ៉ូ* និយាយយ៉ាងខ្សោយរួចគេផ្ទុះកំហឹងចេញ -ហេតុអីបានជាវាធ្វើយ៉ាងណឹងដាក់លោកម្ចាស់ ? វាជាប្អូនរបស់លោកម្ចាស់ទៅទៀត ! លោកម្ចាស់ធ្លាប់មានសគុណលើវា ធ្លាប់ប្រយុទ្ធនៅក្នុងជួរជាមួយគ្នា ។

- មនុស្សប្រែប្រួលណា ។

*តូរ៉ាណាកា* ផ្តោតអារម្មណ៍ទៅលើរោងម្តង ។ រនាំងធ្វើពីសូតយ៉ាងល្អត្រូវបានគេព្យួរទំលាក់ពីលើធ្នឹមដើម្បីជាគ្រឿងលំអ ។ គ្រឿងវំយោលចរបាប់ដែលស៊ីពណ៌គ្នានឹងម៉ក់នោះ ត្រូវបានដាក់ធ្វើជាស៊ុមគូរអោយរមិលមើល ។ គ្រឿងវំយោលដែលធំជាងគេត្រូវបានដាក់នៅជ្រុងទាំងបួន ។ លោកពោលឡើង :

- សំបូរបែបពេកហើយៗអីចឹងទៅអោយតំលៃទៅលើជំនួបគ្នានេះធំហួសហេតុពេក ។ ធ្វើអោយវាសាមញ្ញជាងនេះទៅ ។ យករនាំង ស៊ុម និងម៉ក់ចេញទៅ ហើយយកទៅសងឈ្មួញវិញ ។បើវាមិនព្រមសងលុយទេ អោយមេការលក់វាចេញទៅ ។ យកម៉ក់បួនមក មិនមែនពីរទេ ។ ហើយយកអាចម្ចតាបានហើយ យកអាច្រកអង្កាម ។

- បាទ ទាន ។

ក្រសែភ្នែករបស់លោកសំលឹងមើលទឹកជ្រោះ ហើយនៅរេរាលើនោះមួយសន្ទុះ ។ ទឹកដែលពុះហុយៗ បញ្ចេញសំលេងដូចពស់វែកនៅពេលដែលវាផុសចេញពីដុំថ្ម ។ ខ្លួនប្រាណលោកទាំងមូលទាមទារត្រាំទឹក ។

លោកសួរ :

- រួចចុះអាគ្រិស្តសាសនិកនោះ ?

- បាទ លោកម្ចាស់ ?

- *ឈូតូ-សាន* បញ្ជិតគ្រិស្តសាសនានោះណា ?



www.budinst.gov.kh www.elibraryofcambodia.org

- អូហ៏ គាត់ហ្នឹងរឺ ? គាត់នៅម្ដុំៗក្នុងភូមិហ្នឹង តែនៅឯចុងស្ពានម្ខាងទៀត។ បើគ្មានបញ្ជារបស់លោកម្ចាស់ទេ គាត់មិនអាចឆ្លងមកខាងនេះបានទេ ទាន។ តើហេតុអីទៅ ? មានអីស៊ាន់ រឺលោកម្ចាស់ ? គាត់និយាយថា បើបានជួបលោកម្ចាស់នៅពេលណាដែលលោកម្ចាស់យល់ថាគួរអោយជួបនោះ គាត់ពិតជានឹងមានកិត្តិយសណាស់។ តើលោកម្ចាស់ចង់អោយគាត់មកនៅពេលនេះទេ ?

- គាត់មកតែម្នាក់ឯងទេអ្ហី ?

*ប៊ុនតារ៉ូ* ខាំបបូរមាត់ :

- អត់ទេ ទាន។ គាត់មានកូនចៅគាត់ម្ភៃនាក់មកជាមួយដែរ។ ពួកនោះសុទ្ធតែកោរសក់ដូចគាត់អីចឹង។ ពួកនោះសុទ្ធតែជាពួកអ្នក *ស៊ូស៊ី* មានពូជអំបូរល្អ ហើយជាសាមូរ៉ៃទាំងអស់។ ពួកគេមានសេះល្អៗ តែគ្មានអាវុធទេ។ ខ្ញុំបានឆែកឆេរពួកនោះអស់ហើយ។ ឆែកយ៉ាងម៉ត់ចត់មែនទែន ទាន។

- រួចគាត់ ?

- បាទ គាត់ក៏អីចឹងដែរ។ ឆែកគាត់ច្រើនជាងអ្នកណាទាំងអស់។ នៅក្នុងអីវ៉ែអីវ៉ាន់គាត់មានព្រាបនាំសារបួនក្បាលដែរ។ ខ្ញុំដកព្រាបទាំងបួននេះទុកសិនហើយ ទាន។

- ល្អ។ កំទេចវាចោលទៅ។ ប្រាប់ថា មានអាភ្នើណាវាច្រលំសំលាប់ចោលអស់ហើយ

*ទេ* ?។

- ខ្ញុំបាទយល់ហើយ ទាន។ លោកម្ចាស់ចង់អោយខ្ញុំទៅហៅគាត់មកអីឡូវនេះរឺ ?

- ចាំបន្តិចទៀតទៅ។ បន្តិចទៀតបានខ្ញុំជួបគាត់។

*ប៊ុនតារ៉ូ* ជ្រួញចិញ្ចើម :

- ខ្ញុំឆែកគាត់ គឺខុសរឺលោកម្ចាស់ ?

*តូរ៉ាណាកា* ត្រវីក្បាល ហើយសំលឹងមើលបែបវាហ៊ីទៅកំពូលភ្នំដែលនៅពីក្រោយខ្នងលោក អារម្មណ៍កំពុងត្រិះរិះពិចារណា។ បន្ទាប់មកទៀត ទើបលោកនិយាយ :

- បញ្ជូនមនុស្សដែលទុកចិត្តពីរបីនាក់ទៅតាមឃ្លាំមើលពួកកងម៉ូស្ដេជងទៅ។



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំបានចាត់ចែងរឿងនេះរួចស្រេចបាច់ហើយលោកម្ចាស់ -ទឹកមុខ *ប៊ុនតារ៉ូ* ឡើងរីក ដោយការពេញចិត្ត -នៅក្នុងកងអង្គរក្សផ្ទាល់របស់លោកម្ចាស់ *យ៉ាហ្គី* ក៏មានភ្នែក និងត្រចៀក របស់ពួកយើងខ្លះដែរ ។ បើសិនជាលោកម្ចាស់ចង់វិញ គាត់គ្រាន់តែផ្ញើមក៏លោកម្ចាស់នឹងដែរ ទាន ។

- ល្អ ។

ក្បាលក្បួនដំណើរអ៊ីវ៉ាន់ដែលនៅឆ្ងាយលីមៗនៅឡើយនោះ ទើបមកដល់ផ្លូវកែងនៅ ឡើយ ។ *តូរ៉ាណាកា* អាចមើលឃើញត្រែស្នែងប៊ី ឃើញ *អូមី* ជិះសេះនាំមុខដូចការណែនាំដោយ មាន *អាន់ជីន-សាន* នៅក្បែរនោះផង ។ អីលូវនេះ *អាន់ជីន-សាន* អាចជិះសេះដោយលែង លំបាកដូចមុនទៀតហើយ ។

លោកងាកត្រលប់មករក *ប៊ុនតារ៉ូ* វិញ :

- ខ្ញុំបានយកប្រពន្ធរបស់លោកមកជាមួយដែរ ។

- បាទ ទាន ។

- នាងបានសុំច្បាប់ទៅ *អូសាកា* ។

*ប៊ុនតារ៉ូ* សំលឹងមើលលោកថ្នាំង ប៉ុន្តែឥតនិយាយអ្វីទាំងអស់ ។ រួចទើបគេចោលកន្ទុយ ភ្នែកទៅក្រោយមួយភ្លែតរកសំលឹងមើលមនុស្សដែលទើបឃើញលីមៗនោះ ។

*តូរ៉ាណាកា* បន្ត :

- ខ្ញុំបានយល់ព្រមនឹងនាងហើយ ក្នុងលក្ខខណ្ឌដែលលោកយល់ព្រមផងដែរ ។

- អ្វីដែលលោកម្ចាស់ឯកភាព ខ្ញុំសូមឯកភាពតាមផងដែរ -*ប៊ុនតារ៉ូ* តប ។

- ខ្ញុំអាចអនុញ្ញាតអោយនាងធ្វើដំណើរតាមផ្លូវគោកពី *មីស៊ីម៉ា* ទៅ រឺមួយនាងអាចទៅ *យេដូ* ជាមួយ *អាន់ជីន-សាន* ហើយធ្វើដំណើរតាមសមុទ្រពីទីនោះទៅដល់ *អូសាកា* តែម្តង ។ *អាន់ជីន-សាន* បានយល់ព្រមទទួលមើលការខុសត្រូវលើរូបនាងហើយ ។ នេះបើសិនជាលោក យល់ព្រម ។

- តាមសមុទ្រមានសុវត្ថិភាពជាង -*ប៊ុនតារ៉ូ* កំពុងតែឆេះឆំនៅក្នុងខ្លួនហើយ ។



www.budinst.gov.kh www.elibraryofcambodia.org

- ទាំងអស់នេះ ក៏អាស្រ័យទៅនឹងសាររបស់ *សាគាតី* ផងដែរ ។ បើ *អ៊ីស៊ីដូ* ប្រកាសជាផ្លូវការធ្វើសង្គ្រាមជាមួយនឹងខ្ញុំ នោះជាធម្មតាទេ ដែលខ្ញុំត្រូវខាយាំងរឿងទាំងនេះ ។ បើគ្មានទេ នោះប្រពន្ធរបស់លោកអាចចេញដំណើរបាននៅថ្ងៃស្អែក រឺខានស្អែក តាមតែលោកយល់ព្រម ។

- លោកម្ចាស់សំរេចបែបណា ខ្ញុំឯកភាពតាមនោះដែរ ទាន ។

- រសៀលនេះប្រគល់ការងាររបស់លោកទៅអោយ *ណាកា-សាន* ទៅ ។ នេះជាឱកាសដ៏ល្អមួយសំរាប់លោកស្រុះស្រួលគ្នាវិញជាមួយប្រពន្ធលោកហើយ ។

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ទាន ។ ខ្ញុំគួរតែស្ថិតនៅជាមួយកូនទ័ពរបស់ខ្ញុំ ។ ខ្ញុំសូមអង្វរលោកម្ចាស់ សូមទុកអោយខ្ញុំនៅជាមួយកូនទ័ពខ្ញុំចុះ ។ នៅរហូតដល់លោកម្ចាស់ចេញផុតដល់កន្លែងមានសុវត្ថិភាពចុះ ទាន ។

- យប់នេះ លោកប្រគល់ភារកិច្ចអោយទៅកូនប្រុសខ្ញុំទៅ ។ លោកហើយនឹងប្រពន្ធរបស់លោកមករួមបាយល្ងាចជាមួយខ្ញុំ ។ លោកត្រូវស្នាក់នៅក្នុងត្បៀមជាមួយខ្ញុំ ។ លោកត្រូវស្រុះស្រួលគ្នាឡើងវិញ ។

*ប៊ុនតារ៉ូ* សំលឹងមើលដី រួចតបទាំងមុខស្មើក :

- បាទ ទាន ។

- ខ្ញុំបញ្ជាអោយលោកឈប់ឈ្លោះគ្នាណា ។

*តូរ៉ាណាកា* និយាយ ។ ហើយលោកហៀបនឹងបន្ថែមថា : " សន្តិភាពក្នុងកិត្តិយសប្រសើរជាងសង្គ្រាម *ទេ* " ? ។ តែនេះមិនមែនជាការពិត ហើយស្រួលមិនស្រួលនាំតែមានការជជែកបែបទស្សនវិជ្ជាលើបញ្ហានេះជាមិនខាន ហើយលោកហត់នឿយណាស់ទៅហើយនឹងការជជែកលើកទឡ្ហីករណ៍នេះ ។ អ្វីដែលលោកត្រូវការនៅពេលនេះគឺមុជទឹក និងសំរាក ។ លោកនិយាយឡើង :

- អីលូវនេះ ទៅហៅមេភូមិមកនេះ !

ទាំងមេភូមិ ទាំងពួកអ្នកចាស់ទុំក្នុងភូមិ មកលុតជង្គង់យ៉ាងប្រញាប់ប្រញាល់ពីមុខ *តូរ៉ាណាកា* និងពោលពាក្យស្វាគមន៍យ៉ាងមហាស្ចារ្យ ។ *តូរ៉ាណាកា* និយាយយ៉ាងកំបុតថា : ប្រាប់



www.budinst.gov.kh www.elibraryofcambodia.org

ចំនាយដែលពួកគេនឹងយកទៅបង្ហាញមេការរបស់លោកនោះ ត្រូវតែអោយសមរម្យ ។

- *ទេ?*

- *ហៃ!*

ពួកគេតបយ៉ាងស្រុះគ្នា ។ នៅក្នុងចិត្ត ពួកគេអរគុណព្រះដែលបានផ្ដល់សំនាងមិនបានគិតជាមុននេះដល់ពួកគេ ព្រមទាំងគិតពីមាសប្រាក់ដ៏ក្រាស់ក្រែលដែលគេនឹងទទួលបានពីទស្សនកិច្ចនេះ ។ បន្ទាប់ពីការលុតក្រាបចុះឡើងៗ និងការពោលសរសើររាប់មិនអស់ពីកិត្តិយស ដែលអ្នកភូមិគាត់បានទទួលក្នុងការស្វាគមន៍ *ដៃមីញ៉ូ* ដ៏មហិមាជាងគេក្នុងនគរមក តាចាស់មេភូមិក៏អញ្ជើញ *តូរ៉ាណាកា* ទៅក្នុងផ្ទះតៀម ។

លោកក៏ដើរពិនិត្យសព្វទីកន្លែង ។ នារីបំរើគ្រប់វ័យដែលត្រូវបានសិរតសំរាំងនៅក្នុងភូមិនេះ ត្រូវបានគេដាក់នៅចាំទទួលលោកសព្វទិសទី និងទាំងញញឹម ។ តៀមនេះមានបន្ទប់ទាំងអស់ដប់ ដែលគេសង់នៅជុំវិញសួនច្បារមួយរកពណ៌នាមិនបាន ហើយដែលមានផ្ទះសំរាប់ទទួលទានទឹកតែតូចមួយនៅចំកណ្ដាល ។ ចង្រ្កាននៅឯខាងក្រោយផ្ទះ ហើយនៅឯទិសខាងលិចមានផ្ទះមុជទឹកដ៏ធំមួយសង់នៅចំកណ្ដាលផ្ទាំងថ្មទាំងឡាយ ហើយដែលប្រើទឹកជ្រោះនោះតែម្ដង ។ ទីផ្ទះតៀមទាំងមូលត្រូវបាំងបិទដោយរបងយ៉ាងស្អាត ហើយងាយការពារទៀតផង ។ ផ្លូវដើរទៅផ្ទះមុជទឹកមានប្រក់ដំបូលពីលើថែមទៀត ។

ពេលដែលលោកចេញមកឈរងយ៉ាបរានហាល *តូរ៉ាណាកា* ក៏ពោលឡើង :

- ខ្ញុំមិនត្រូវការផ្ទះតៀមទាំងមូលនេះទេ *ប៊ុនតារ៉ូ-សាន*។ បន្ទប់តែបីគឺល្មមគ្រប់គ្រាន់ណាស់ទៅហើយ ។ មួយសំរាប់ខ្ញុំ មួយសំរាប់ *អាន់ជីន-សាន* និងមួយទៀតសំរាប់ស្រីៗ ។ លោកយកបន្ទប់មួយទៅ ។ មិនចាំបាច់ចេញថ្លៃគ្រប់បន្ទប់ទាំងអស់នោះទេ ។

- មេការខ្ញុំបានប្រាប់ខ្ញុំថាគាត់តថ្លៃបានល្អណាស់សំរាប់តៀមទាំងមូលនេះតែម្ដង ។គាត់បង់ថ្លៃមួយថ្ងៃម្ដងឃើញថាចំនេញជិតពាក់កណ្ដាលដែរ ។ ម្យ៉ាងទៀតនេះជារដូវមិនសូវមានភ្ញៀវផងដែរទេ ។ ខ្ញុំបានឯកភាពតំលៃនេះដោយយោលលើមូលហេតុសុវត្ថិភាពរបស់លោកម្ចាស់ផង ។

- ល្អណាស់ -*តូរ៉ាណាកា* ពោលទាំងបង្ខំចិត្ត -តែខ្ញុំចង់មើលបញ្ជីទូទាត់លុយមុននឹងពួក



www.budinst.gov.kh www.elibraryofcambodia.org

យើងចេញពីទីនេះទៅវិញ ។ គ្មានចាំបាច់អីដែលត្រូវខ្វះខ្វាយលុយនោះទេ ។ យកល្អ យកពួកអង្គរក្សដាក់តាមបន្ទប់ទៅ ។ ប្អូនទាក់មួយបន្ទប់ទៅ ។

- បាទ ទាន ។

តាមពិត *ប៊ុនតារ៉ូ* បានសំរេចធ្វើបែបនេះទៅហើយ ។ លោកតាមមើល *តូរ៉ាណាកា* ដែលដើរចេញទៅ អមដោយអង្គរក្សផ្ទាល់ខ្លួនពីររូប និងនារីបំរើដ៏ស្អាត១បំផុតប្អូនរបស់ដៅឆ្ពោះទៅកាន់បន្ទប់របស់ខ្លួនដែលនៅស្លាបខាងកើត ។ លោកដណ្តឹងសួរយ៉ាងស្ងៀមស្ងាត់អំពីស្រី១ណា អីចេះដែល *តូរ៉ាណាកា* និយាយនោះ ? តើស្រី១បែបណាដែលត្រូវការបន្ទប់នោះ ? *កូជីកូ* ? យ៉ស កុំទៅខ្វល់ -លោកគិតទាំងឡើយណាយនៅក្នុងចិត្ត -បន្តិចទៀតអញគង់តែដឹងទេ ។

ទាំងអារម្មណ៍ស្មុគស្មាញ លោកដើរចេញមកទីធ្លា ហើយសំលឹងមើលទៅផ្លូវ ។ ហេតុអី *អ៊ូសាកា* ?

☆ ☆ ☆

ទៅវេលាយាមមមៃ អ្នកយាមប្រចាំច្រកស្ពានអែបទៅម្ខាង ។ ក្បួនដំណើរចាប់ផ្តើមឆ្លងស្ពាន ។ នាំមុខគេ គឺពួកអ្នកបើកផ្លូវដែលកាន់ទង់មានសញ្ញាដ៏មានមហិទ្ធិរិទ្ធិរបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ បន្ទាប់មកត្រែស្នែងដ៏ស្កុតស្កម្ភ ហើយចុងក្រោយគឺពួកកងការពារឯទៀត ។

ពួកអ្នកភូមិទាំងអស់លុតជង្គង់លំអោនខ្លួនគោរពទាំងភាន់ភាំងស្រលាំងកាំង នឹងភាពហ៊ឹកហ៊ាក់ និងភាពស្កុតស្កម្ភនៃក្បួនដំណើរនេះ ។ មេភូមិបានប្រយ័ត្នប្រយែងសួរយោបល់ថា តើគាត់គួរប្រមូលអ្នកភូមិមកលើកកិត្តិយសពិធីនេះដែរឬទេ ហើយ *តូរ៉ាណាកា* បានអោយគេប្រាប់ទៅវិញថា : ចំពោះអ្នកណាដែលមិនជាប់ដៃបំពេញការងារអីទេ គឺអាចមកមើលបានដោយត្រូវសុំការអនុញ្ញាតពីម្ចាស់ខ្លួនជាមុន ។ ដោយហេតុយ៉ាងនេះហើយ ទើបមេភូមិរឹតតែប្រយ័ត្នប្រយែងណាស់ទៅទៀត ។ គាត់បានរៀបចំជ្រើសរើសជាគណៈប្រតិភូមួយដោយមានភាគច្រើនជាចាស់ទុំ និងទុកពួកយុវជនដែលងាយស្តាប់គ្នាបានក្នុងចំនួនមួយសមរម្យដើម្បីទទួល តែមិនច្រើនហួសនឹងបញ្ជារបស់ *វ៉េមីក្វ* ដ៏មហិមានេះដែរទេ ។

*សែការ៉ា សាតាគី* អម្ចាស់នៃតំបន់ *ស៊ីណាណូ* មានកំពស់ខ្ពស់ជាង *តូរ៉ាណាកា* ហើយ



www.budinst.gov.kh www.elibraryofcambodia.org

មានអាយុប្អូនលោកប្រាំឆ្នាំ។ គេមានស្មាធំ និងច្រមុះធំដូចបង តែមានពោះតូចជាង ពុកចង្កាលោកខ្មៅក្រាស់ឃ្មឹក ហើយភ្នែកលោកតូច។ ថ្វីបើកាលណាអ្នកទាំងពីរនៅផ្សេងពីគ្នា អ្នកផងតែងមានអារម្មណ៍ថា អ្នកទាំងពីរ រូបរាងដូចគ្នាក្តី តែពេលគេនៅជាមួយគ្នា គេទាំងពីរខុសគ្នាស្រលះតែម្តង។ គីម៉ូណូរបស់ *សាគាគី* គឺប្រណីត ក្រោះការពាររបស់គេចាំងភ្លឺផ្លេក ហើយហ៊ុកប៉ាក់ដាវរបស់គេបង្ហាញថា ត្រូវបានប្រើញឹកញាប់។

- សូមស្វាគមន៍ ប្អូនប្រុស។

*តូរ៉ាណាកា* ដើរចេញពីរោង ហើយលំអោនខ្លួន។ លោកពាក់គីម៉ូណូសាមញ្ញបំផុត ហើយលោកពាក់ស្បែកជើងចំបើងរបស់ពលទាហាន។ ហើយនឹងដាវទាំងពីរ។ លោកបន្ត :

- សូមអភ័យទោស ដែលទទួលលោកប្អូនមិនបានត្រឹមត្រូវជាផ្លូវការ ប៉ុន្តែខ្ញុំខំស្រូតរូតដំណើរមកយ៉ាងអស់ពីសមត្ថភាព។

- សូមអភ័យទោសដល់ខ្ញុំផង ដែលមករំខានបងយ៉ាងនេះ។ បងហាក់ដូចជាមានសុខភាពល្អណាស់។ ល្អមែនតែម្តង។

*សាគាគី* ចេញពីគ្រែស្នែង ហើយលំអោនខ្លួនតបវិញជាកិច្ចចាប់ផ្តើមពិធីការដ៏វែងអន្លាយ និងដ៏មិត់ចត់មួយដែលគ្របដណ្តប់លើគេទាំងពីរនាក់នៅពេលនេះ។

- សូមលោកម្ចាស់ *សាគាគី* អញ្ជើញអង្គុយលើម៉ក់នេះទៅ។

- សូមលោកម្ចាស់ *តូរ៉ាណាកា* អធ្យាស្រ័យផងចុះ តែខ្ញុំពិតជាមានកិត្តិយសណាស់ បើសិនជាលោកអញ្ជើញអង្គុយមុនខ្ញុំនោះ។

- លោកចំជាមានសន្តានចិត្តល្អមែន តែសូមលោកផ្តល់កិត្តិយសដល់ខ្ញុំ ដោយអញ្ជើញអង្គុយមុនចុះ។

គេទាំងពីរបន្តលេងល្បែងដែលគេបានលេងជាមួយគ្នា ជាមួយមិត្ត ជាមួយសត្រូវ ជាច្រើនដងមកហើយតាំងពីមុនមកដើម្បីឡើងកាំជណ្តើរនៃអំនាច ដោយសប្បាយនឹងបញ្ញត្តិនានារបស់វាដែលបញ្ជោរាល់ជំហាន រាល់ឃ្លាឃ្លោង ហើយដែលការពារនូវកិត្តិយសជាបុគ្គលរបស់គេដើម្បីបញ្ចៀសមិនអោយអ្នកណាម្នាក់អាចធ្វើការភាន់ច្រលំមួយ ដែលអាចធ្វើអោយខ្លួនវិបេសក



www.budinst.gov.kh www.elibraryofcambodia.org

កម្មខ្លួនមានគ្រោះថ្នាក់បានឡើយ ។

នៅទីបំផុត គេអង្គុយនៅលើម៉ាក់ទល់មុខគ្នា ក្នុងចំងាយពីរដាវពីគ្នា ។ *ប៊ុនតារ៉ូ* នៅពីខាងក្រោយឆ្វេងដៃរបស់ *តូរ៉ាណាកា* ។ នាយជំនួយការរបស់ *សាកាគី* ដែលជាសាមូរ៉ៃចំនាស់ល្អម និងមានសក់ល្បាយអាច់ខ្លាម្នាក់ នៅពីក្រោយខាងឆ្វេងដៃរបស់មេកោយខ្លួនដែរ ។ ពួកសាមូរ៉ៃរបស់ *តូរ៉ាណាកា* នៅអង្គុយជាជួរជុំវិញរោងក្នុងចំងាយម្ភៃជំហាន ។ ពួកគេពាក់ដោយចេតនានូវសំលៀកបំពាក់ ដែលគេពាក់ក្នុងពេលធ្វើដំណើរមកទីនេះ ប៉ុន្តែអាវុធរបស់ពួកគេវិញគឺឥតខ្ចោះ ។ *អូមី* នៅអង្គុយលើជីងជ្រុងម្ខាងនៃរោង *ណាកា* នៅឯជ្រុងម្ខាងទៀតដែលនៅទល់មុខគ្នា ។ ពួកកូនចៅរបស់ *សាកាគី* វិញ ស្លៀកពាក់ហ៊ឹកហ៉ាក់ និងយ៉ាងផ្លូវការ ។ អាវក្រៅដ៏រលុងនិងដែលមានស្មាបះឡើងលើ ប្រៀបបីដូចជាស្លាបសត្វរបស់ពួកគេត្រូវចងរឹតនៅត្រង់ចង្កេះដោយខ្សែក្រវាត់ក្បាលប្រាក់ ។ ប៉ុន្តែពួកគេក៏មានអាវុធយុទ្ធភ័ណ្ឌគ្រប់ដៃដែរ ។ ពួកគេរៀបចំកន្លែងអង្គុយដោយខ្លួនឯង តែក៏ស្ថិតនៅចំងាយម្ភៃជំហានពីរោងដូចគ្នា ។

*ម៉ារីកូ* រៀបចំបំរើទឹកតែជាផ្លូវការ ហើយបងប្អូនទាំងពីរក៏និយាយរឿងធម្មតា ពីនេះ ពីនោះ ។ នៅពេលដែលនាងយល់ថា ជាពេលសមរម្យហើយនោះ *ម៉ារីកូ* ក៏លំអោនខ្លួនគោរពលាចេញមក ។ ហើយក្នុងខណៈនោះ *សាកាគី* ក៏និយាយជាបន្ទាន់ភ្លាមឡើង :

- ខ្ញុំទទួលនាំបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ។

ភាពស្ងៀមស្ងាត់បានមកគ្របដណ្តប់ទីលាននេះមួយរំពេច ។ គ្រប់ៗគ្នា រាប់ទាំងកូនចៅរបស់ *សាកាគី* ផង មានការភ្ញាក់ផ្អើលនឹងភាពខ្វះសុជីវធម៌របស់បុរសនេះ ភ្ញាក់ផ្អើលនឹងរបៀបដ៏ព្រហើនដែលគេនិយាយពី " បញ្ជា " ពោលគឺមិនប្រើពាក្យ " សារ " ហើយនឹងប្រការដែលគេមិនបានរង់ចាំ *តូរ៉ាណាកា* សួរគេថា " តើត្រូវការអោយខ្ញុំធ្វើអ្វីទេ ? " ទៅតាមគំរូនៃពិធីការនោះឡើយ ។

*ណាកា* ដកភ្នែកចេញពីដាវរបស់ *សាកាគី* ហើយចោលមួយខ្ទាច់សំលឹងមើលឪពុករបស់ខ្លួន ។ គេឃើញករបស់ *តូរ៉ាណាកា* ឡើងក្រហម ដែលជាសញ្ញាមិនចេះច្រលំនៃកំហឹងដែលហៀបផ្ទុះ ។ ប៉ុន្តែទឹកមុខរបស់លោកឥតមានប្រែប្រួលអ្វីទាំងអស់ ហើយ *ណាកា* សែនស្រលាំង



www.budinst.gov.kh www.elibraryofcambodia.org

កាំងទៅពេលដែលគេលឺសំលេងឆ្លើយតបយ៉ាងនឹងន :

- សូមទោស លោកមានបញ្ហាអ្វី ? បញ្ហាសំរាប់អ្នកណា ប្អូនប្រុស ? ពិតជាប្អូនមានសារហើយណឹង ។

*សាគាតី* ចាប់ទាញយកសារពីរមូរពីក្នុងដៃអាវរបស់ខ្លួនចេញមក ។ ដៃរបស់ *ប៊ុនតារ៉ូ* ហៀបតែនឹងចាប់ដាវរបស់ខ្លួនដែលកំពុងតែនៅរង់ចាំនោះទៅហើយ ដោយសារតែភាពដ៏ប្រញាប់ប្រញាល់របស់ *សាគាតី* នេះ ។ ព្រោះតាមទំលាប់ពិធីការ រាល់ចលនាទាំងអស់ត្រូវតែយឺតៗ មិនត្រូវធ្វើដោយសភាវគតិនោះទេ ។ *តូរ៉ាណាកា* នៅស្ងៀមឥតកំរើកឡើយ ។

*សាគាតី* បំបែកអាច់ល័ក្តសារទីមួយ ហើយអានខ្លាំងៗក្នុងសំលេងដ៏គួរអោយស្រៀវខ្លួន :

- " តាមបញ្ជារបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ ក្នុងព្រះនាមព្រះចៅអធិរាជ *កូណូជី* យើងសូមសួរសុខទុក្ខអណ្តាប់ដ៏ល្បីល្បាញរបស់យើងគឺ *យ៉ូស៊ី តូរ៉ាណាកា-ណូមីណូវ៉ារ៉ា* និងសូមអញ្ជើញលោកមកបញ្ជាក់ពីការគោរពរបស់លោកនៅចំពោះមុខយើង នៅឯ *អូសាកា* ភ្លាមហើយនឹងសូមអញ្ជើញលោកអោយជូនពតិមានទៅឯកអគ្គរដ្ឋទូតដ៏ល្បីល្បាញរបស់យើង ជាសមាជិកក្រុមប្រឹក្សា គឺលោកម្ចាស់ *សៃកាវ៉ា សាគាតី* ភ្លាមថា តើលោកទទួលយក រឺមិនទទួលយកការអញ្ជើញរបស់យើងនេះ " ។

*សាគាតី* ងើបក្បាលឡើង ហើយបន្តនៅក្នុងសំលេងខ្លាំងៗដដែល :

- សារនេះត្រូវបានចុះហត្ថលេខាដោយសមាជិកក្រុមប្រឹក្សទាំងអស់ ហើយប្រថាប់ត្រាដោយមហាត្រារបស់នគរ ។

រួចគេក៏ដាក់សារចុះទាំងរើកយ៉ាងកោងនៅពីមុខរបស់គេ ។ *តូរ៉ាណាកា* ធ្វើសញ្ញាទៅ *ប៊ុនតារ៉ូ* ។ក៏ដើរទៅខាងមុខលំអោនខ្លួនយ៉ាងទាបគោរព *សាគាតី* ហើយក៏យករមូរសារទៅប្រគល់ជូន *តូរ៉ាណាកា* ដោយលំអោនខ្លួនម្តងទៀត ។ *តូរ៉ាណាកា* ទទួលយកសារ ហើយធ្វើសញ្ញាអោយ *ប៊ុនតារ៉ូ* ត្រលប់ទៅកន្លែងដើមរបស់ខ្លួនវិញ ។

*តូរ៉ាណាកា* ពិនិត្យមើលសារយ៉ាងយូរ ។ *សាគាតី* សួរឡើង :



www.budinst.gov.kh www.elibraryofcambodia.org

- ហត្ថលេខាទាំងអស់សុទ្ធតែត្រឹមត្រូវឥតក្លែងបន្លំ ។ តើលោកទទួល រឺមិនទទួល ?

ក្នុងសំលេងមួយយ៉ាងទាប ដែលមិនអាចអោយអ្នកណាក្រៅស្តាប់លឺ លើកលែងតែអ្នកនៅក្នុងរោង និង *អូទី* ព្រមទាំង *ណាកា* ប៉ុន្តែ *តូរ៉ាណាកា* និយាយបន្ត :

-ហេតុអ្វីបានជាខ្ញុំមិនកាត់ក្បាលឯង ចំពោះអាកប្បកិរិយាច្រលោងខាមរបស់ឯងនេះ?

- ព្រោះខ្ញុំជាកូនប្រុសរបស់ម៉ែ -*សាគាគី* តប ។

- តែបើឯងនៅតែធ្វើរកបែបនេះទៀត ឯងស្មានថាអាណឹងអាចការពារឯងបានអ្វី ?

- បើអញ្ចឹងមែន គាត់ត្រូវតែស្លាប់មុនអាយុហើយ ។

- ថាម៉េច ?

- លោកម៉ែយើងគាត់នៅឯ *គាកាតូ* ឯនោះ ។

*គាកាតូ* ជាទីរួមខេត្ត *ស៊ូរ៉ូណាកា* ជាបន្ទាយដ៏រឹងមាំ និងមានកន្លែងព័ទ្ធការពារមិនងាយអ្នកណាវាយបែករបស់ *សាគាគី*។ គេបន្តទៀត :

- ខ្ញុំស្តាយណាស់ តែគាត់នឹងត្រូវនៅទីនោះរហូត ។

- អាបោក ! ឯងគោរពគាត់ដូចអញគោរពគាត់ដែរតើ ។

- ពិតហើយ ចំពោះវិញ្ញាណក្ខន្ធរបស់គាត់ ខ្ញុំគោរព។ តែអ្វីដែលបងកំពុងធ្វើចំពោះនគរនេះ ខ្ញុំរឹតតែស្អប់បងជាងទៅទៀត ។

- ខ្ញុំឥតត្រូវការស្វែងរកទឹកដីបន្ថែម រឺក៏........

- បងស្វែងទំលាក់ការស្អងអំនាច ។

- ណឹងក៏ខុសទៀត ហើយបងតែងការពារខ្លួយបងតទល់នឹងពួកក្បត់ជានិច្ច ។

- បងស្វែងរកការរលំចុះរបស់ទាយាទ នេះបើតាមការជឿជាក់របស់ខ្ញុំ ហើយដោយហេតុនេះហើយបានជាខ្ញុំស្វែងរករស់ ហើយខ្ទប់ច្រក *ស៊ូរ៉ូណាកា* និងផ្លូវទិសខាងជើងតទល់នឹងបងទោះជាត្រូវបង់ថ្លៃយ៉ាងណាក៏ដោយ ហើយខ្ញុំនៅតែបន្តធ្វើរបៀបនេះរហូតដល់ *ក្លាន់តូ* ស្ថិតនៅក្នុងកណ្តាប់ដៃមិត្ត.......ទោះជាត្រូវបង់ថ្លៃយ៉ាងណាក៏ដោយ ។

- នៅក្នុងកណ្តាប់របស់ដៃប្អូនរឺ ប្អូនសំលាញ់ ?



www.budinst.gov.kh www.elibraryofcambodia.org

- កណ្តាប់ដៃណាក៏ដោយ អោយតែមានសុវត្ថិភាព......ហើយដែលជាមិនមែនកណ្តាប់ដៃរបស់បង បងសំលាញ់ ។

- ឯងទុកចិត្ត *អ៊ីស៊ីដូ* ដែរ ?

- ខ្ញុំឥតទុកចិត្តអ្នកណាទាំងអស់ ។ បងបានបង្រៀនខ្ញុំរឿងនេះ ។ *អ៊ីស៊ីដូ* ជា *អ៊ីស៊ីដូ* តែគេមិនអាចសង្ស័យលើភក្តីភាពរបស់គាត់បានទេ ។ទោះរូបបងក៏ត្រូវតែទទួលស្គាល់រឿងនេះដែរ ។

- បងទទួលស្គាល់ថា *អ៊ីស៊ីដូ* កំពុងប្រឹងកំទេចបង និងហែកនគរ ថាវាបានច្បាមយកអំនាច ហើយវាកំពុងហែកចោលនូវបំនងប្រាថ្នារបស់លោកម្ចាស់ *តែកូ* ហើយ ។

-តែបងបានឃុបឃិតជាមួយលោកម្ចាស់ *ស៊ូតឺយ៉ាម៉ា* ដើម្បីកំទេចក្រុមប្រឹក្សាមែនទេ?

សរសៃថ្ងាសរបស់ *សាគាគី* ឡើងប៉ោងញាប់រន្ថាន់ ប្រៀបដូចជាដង្កូវរមាស់ ។ គេបន្តទៀត :

- តើបងអាចនិយាយអីបានទៅ ? ទីប្រឹក្សារបស់គាត់ម្នាក់បានសារភាពនូវអំពើក្បត់នេះហើយ : គឺថាបងបានឃុបឃិតជាមួយ *ស៊ូតឺយ៉ាម៉ា* ដើម្បីអោយគាត់ទទួលយកលោកម្ចាស់ *អ៊ីតូ* មកជំនួសកន្លែងបង ហើយសុំឈប់វិញមួយថ្ងៃមុនកិច្ចប្រជុំលើកទីមួយ ហើយគេចខ្លួនទៅពេលយប់ ដើម្បីធ្វើអោយនគរច្របូកច្របល់ ។ ខ្ញុំបានលឺចំលើយសារភាពនេះ បងសំលាញ់ ។

- ឯងគឺជាឃាតកម្នាក់នឹងគេដែរ ?

មុខ *សាគាគី* ឡើងក្រហមឆាំង :

- ពួក *រ៉ូនីន* ដែលស្មោះស្ម័គ្រជ្រុលបានសំលាប់ *ស៊ូតឺយ៉ាម៉ា* មិនមែនខ្ញុំ មិនមែនមនុស្សរបស់ *អ៊ីស៊ីដូ* ណាម្នាក់ទេ !

- ចំណែកដែរ ដែលឯងយកកន្លែងរបស់ *ស៊ូតឺយ៉ាម៉ា* បានយ៉ាងរហ័សបែបនេះ *នេ* ?

- ទេ ។ ពួជពង្សអំបូរខ្ញុំក៏មានចំនាស់មិនចាញ់បងប៉ុន្មានទេ ។ តែខ្ញុំមិនបានបញ្ជាអោយសំលាប់ទេ *អ៊ីស៊ីដូ* ក៏អីចឹងដែរ ។លោក *អ៊ីស៊ីដូ* បានស្បថក្នុងឋានៈជាសាមូរ៉ៃ ។ ខ្ញុំក៏អញ្ចឹងដែរ ។ គឺពួក *រ៉ូនីន* ទេ ដែលបាន សំលាប់ *ស៊ូតឺយ៉ាម៉ា* នោះ ។ ហើយគាត់ក៏សមតែស្លាប់ដែរទេ ។

- ស្លាប់ដោយទារុណកម្ម ទាំងបាត់បង់កិត្តិយសនៅក្នុងគុកដ៏តត្រិច កូន១និងប្រពន្ធចុង



www.budinst.gov.kh www.elibraryofcambodia.org

ទាំងប៉ុន្មានត្រូវកាប់ចិញ្ច្រាំនៅចំពោះមុខបែបណីង៎រ ?

- នេះគ្រាន់តែជាពាក្យចចាមអារ៉ាម ដែលពួកអាមិនសប្បាយចិត្តដ៏សំអុយទាំងប៉ុន្មាន អាចថាជាពួកយកការណ៍របស់បងផង ដែលវានាំគ្នាផ្សព្វផ្សាយដើម្បីបំផ្លាញកិត្តិយសរបស់លោកម្ចាស់ *អ៊ុស៊ីដូ* ហើយតាមរយៈនេះ គឺបំផ្លាញកិត្តិយសរបស់លោកជំទាវ *អូដីបា* ហើយនឹងបាយមាន តែប៉ុននោះ ។ គ្មានភស្តុតាងណាបញ្ជាក់ពីរឿងទាំងនេះឡើយ ។

- មើលខ្លួនប្រាណសាកសពទៅដឹងហើយ ។

- ពួក *រ៉ូនីន* ដុតផ្ទះនេះខ្ទេចទៅហើយ ។ អត់មានសាកសពទេ ។

- ណឹងងាយស្រួលមែនទែន *ទេ* ? ហេតុយ៉ាងម៉េចបានជាឯងទទួលជឿរឿងអ៊ីចឹងៗកើតដែរ ? ឯងមិនមែនជាមនុស្សសំរេលើល្ងើពកថ្វាសឯណា ?

- ខ្ញុំមិនព្រមមកអង្គុយទីនេះដើម្បីស្តាប់រឿងគំរក់បែបនេះទេ ។សូមអោយចំលើយមក ខ្ញុំអីលូវនេះភ្លាមមក ។រួចយកក្បាលខ្ញុំ ហើយម៉ែត្រូវស្លាប់ រឺមួយអោយខ្ញុំចេញទៅវិញ -*សាគាគី* អោនមកខាងមុខ -នៅពេលដែលក្បាលខ្ញុំដាច់ចេញពីស្មាពេលណាព្រាបនាំសារដប់នឹងហើររឹងឆ្ពោះទៅជើង សំដៅ*គាកាតូ*ភ្លាម ។ខ្ញុំមានមនុស្សជាទីទុកចិត្តនៅទិសខាងជើង ខាងលិច ខាងកើត ដើរមួយថ្ងៃទើបដល់ ពោលគឺផុតពីក្រញាំដៃរបស់បង ហើយបើពួកនេះបរាជ័យទៀត នៅមានមនុស្សរបស់ខ្ញុំជាច្រើនទៀត ដែលនៅប្រកបដោយសុវត្ថិភាពផុតពីដែនដីគ្រប់គ្រងរបស់បង ។ បើបងយកក្បាលខ្ញុំ រឺបញ្ជាអោយគេធ្វើឃាតខ្ញុំ រឺបើសិនជាខ្ញុំស្លាប់នៅ *អ៊ុស៊ូ*.....ទោះបណ្តាលមកពីមូលហេតុអ្វីក៏ដោយ នោះម៉ែនឹងស្លាប់ដែរ ។ អីលូវនេះ រឺមួយយកក្បាលខ្ញុំ រឺដោះស្រាយរឿងនេះអោយស្រេចបាច់ហើយ ខ្ញុំនឹងចាកចេញពី *អ៊ុស៊ូ* ភ្លាម ។ ជ្រើសរើសទៅ !

- *អ៊ុស៊ីដូ* បានធ្វើឃាតលោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ។ ក្នុងពេលបន្តិចទៀត ខ្ញុំនឹងអាចផ្តល់ភស្តុតាងអោយឯងបាន ។ រឿងនេះសំខាន់ណាស់ *ទេ* ? ខ្ញុំត្រូវការតែបន្តិច......

- បងមិនមានពេលទៀតឡើយ ! សារបាននិយាយថា ភ្លាម ។ ពិតហើយបងប្រកែកមិនព្រមគោរពតាម ។ ល្អ អ៊ីចឹង ក៏វាអ៊ីចឹងទៅចុះ ។ នេះនែ ។

*សាគាគី* ដាក់សារទីពីរទៅលើកំរាល ហើយបន្ត :



BUDDHIST INSTITUTE LIBRARY

www.budinst.gov.kh www.elibraryofcambodia.org

- នេះគឺជាការផ្តន្ទាទោសបងជាផ្លូវការ ហើយនឹងការបញ្ជាអោយបងធ្វើ *សិបពុគុ* ហើយដោយបងទទួលយកទាំងប្រមាថដូចគ្នា ។ សូមព្រះអង្គជួយប្រោសបងផងចុះ ! អីលូវអ្វីៗក៏រួចរាល់ស្រេចបាច់អស់ហើយ ។ ខ្ញុំចេញដំណើរទៅវិញភ្លាមនេះ ហើយលើកក្រោយនៅពេលដែលយើងជួបគ្នា គឺនៅលើសមរភូមិ ហើយសូមព្រះពុទ្ធអង្គជាម្ចាស់ជាសាក្សីថា : នៅមុនថ្ងៃលិចនៃថ្ងៃដែលយើងជួបគ្នាទៀតនោះ ខ្ញុំសន្យានឹងខ្លួនខ្ញុំថា ខ្ញុំនឹងឃើញក្បាលបងដោតនៅលើចុងលំពែងជាមិនខាន ។

ភ្នែករបស់ *តូរ៉ាណាកា* នៅតែសំលឹងជាប់លើគូប្រជែងរបស់លោក :

- លោកម្ចាស់ *ស៊ូគីយ៉ាម៉ា* ជាមិត្តរបស់ឯង និងជាមិត្តរបស់បង ។ ជាសមមិត្ត ជាសាមូរ៉ៃពោរពេញដោយកិត្តិយសម្នាក់ ។ សច្ចភាពនៃមរណភាពរបស់លោកគួរតែមានសារសំខាន់ខ្លះដែរសំរាប់ឯង ។

- មរណភាពរបស់បងមានសារសំខាន់ជាង បងសំលាញ់ ។

- *អ៊ីស៊ីដូ* អូសទាញឯងបានដូចដោះម្តាយអូសទាញក្មេងអត់ឃ្លានអីចឹង ។

*សាកាគី* បែរទៅនិយាយប្រាប់ទីប្រឹក្សារបស់ខ្លួន :

- និយាយក្នុងកិត្តិយសលោកជាសាមូរ៉ៃមក តើខ្ញុំមានពង្រាយមនុស្សរបស់ខ្ញុំទេ ហើយតើសារមានន័យថាម៉េច ?

បុរសសាមូរ៉ៃចំនាស់ ដែលមានសក់ល្បាយអាច់ខ្លា និងប្រកបដោយចរិតថ្លៃថ្នូរ ដែលជានាយទីប្រឹក្សាជំនិតរបស់ *សាកាគី* ហើយដែល *តូរ៉ាណាកា* ស្គាល់យ៉ាងច្បាស់ថា ជាមនុស្សប្រកបដោយកិត្តិយសមួយនោះ មានអារម្មណ៍រសាប់រសល់ និងសែនអាម៉ាស់ចំពោះការបង្ហាញភាពគំនុំគំកួន ដ៏ក្រលែតបែបនេះ ដូចអ្នកដែលបានលឺកិច្ចសន្ទនាទាំងនេះដែរ ។ លោកនិយាយឡើងខ្សាវៗ និងយ៉ាងរអាក់រអួល ដោយលំអោនខ្លួនគោរព *តូរ៉ាណាកា* ផង :

- សូមអភ័យទោសផងចុះ លោកម្ចាស់ ។ តែអ្វីដែលលោកម្ចាស់ខ្ញុំមានប្រសាសន៍ គឺជាការពិតមែន ទាន ។ តើលោកម្ចាស់ចាំបាច់សង្ស័យលើរឿងនេះធ្វើអ្វី ? ហើយសូមលោកម្ចាស់អធ្យាស្រ័យអោយខ្ញុំផងចុះតែដោយថា នេះជាភារកិច្ចរបស់ខ្ញុំ ខ្ញុំសូមមេត្តាដាក់ខ្លួន ដាក់កិត្តិយស



www.budinst.gov.kh www.elibraryofcambodia.org

ជំរាបថា....ថា កង្វះសុជីវធម៌មិនគួរអោយភ្ញាក់ផ្អើល និងគួរអោយខ្មាសអៀនរវាងលោកម្ចាស់ទាំងពីរមិនសក្តិសមនឹងបុណ្យសក្តិ ក៏ដូចជាមិនសក្តិសមនឹងពិធីជាផ្លូវការនេះទេ។ បើសិនជាអណ្តាប់របស់លោកម្ចាស់ទាំងពីរស្តាប់លឺ ខ្ញុំបារម្ភថា លោកម្ចាស់ទាំងពីរពិតជាពិបាកទប់ពួកគេនោះបានណាស់។ លោកម្ចាស់ទាំងពីរភ្លេចភារកិច្ចខ្លួនជាសាមូរ៉ៃ និងភារកិច្ចរបស់លោកម្ចាស់ទាំងពីរចំពោះកូនចៅរបស់ខ្លួនហើយ។ សូមអភ័យទោសដល់រូបខ្ញុំផង ទាន....... - បុរសនេះលំអោនខ្លួនគោរពអ្នកទាំងពីរ - តែអ្វីដែលត្រូវនិយាយ គឺត្រូវនិយាយ។ សារទាំងអស់មានន័យតែមួយដូចគ្នាលោកម្ចាស់ *តូរ៉ាណាកា* ហើយគ្រប់សារទាំងអស់មានអាច់ល័ក្ខប្រថាប់ត្រារបស់លោកម្ចាស់ *សាគាគី* ដែលមានសរសេរថា : " *សំលាប់លោកជំទាវម្តាយខ្ញុំភ្លាម* "។

*តូរ៉ាណាកា* សួរទៅប្អូនរបស់ខ្លួន :

- តើធ្វើយ៉ាងណាដើម្បីបញ្ជាក់ថាខ្ញុំមិនបានប្រឹងប្រែងទំលាក់ទាយាទទេនោះ ?

- ផ្ទេរឋានៈ និងអំនាចទាំងអស់ទៅអោយកូនប្រុស និងជាទាយាទរបស់បង គឺលោកម្ចាស់ *ស៊ូដារ៉ា* ភ្លាម ហើយធ្វើ *សិបពូគូ* នៅថ្ងៃនេះតែម្តង។ បន្ទាប់ពីនោះ ខ្ញុំនិងកូនចៅពររបស់ខ្ញុំទាំងអស់នឹងគាំទ្រ *ស៊ូដារ៉ា* ក្នុងឋានៈជាអម្ចាស់នៃតំបន់ *ក្វាន់តូ*។

- ខ្ញុំនឹងពិចារណាមើលពីអ្វីដែលឯងនិយាយនេះ។

- ថាម៉េច ?

- ខ្ញុំនឹងពិចារណាពីអ្វីដែលឯងបាននិយាយនេះ -*តូរ៉ាណាកា* និយាយម្តងទៀតក្នុងភាពយ៉ាងនឹងន -ស្អែកនៅម៉ោងនេះយើងនឹងជួបគ្នាទៀត បើសិនជាឯងមិនយល់ទាស់ទេនោះ។

មុខ *សាគាគី* ឡើងក្រញូវ :

- នេះជាល្បិចមួយទៀតរបស់បងអ្វី ? តើមានអ្វីដែលត្រូវជួបគ្នាទៀតនោះ ?

- រឿងអ្វីដែលឯងនិយាយ។ រឿងនេះមួយទៀត -*តូរ៉ាណាកា* លើកសារដែលលោកកាន់នៅក្នុងដៃ - ខ្ញុំនឹងអោយចំលើយនៅវេលាថ្ងៃស្អែក។

- *ប៊ុនតារ៉ូ-សាន* ! - *សាគាគី* ចង្អុលទៅរមូរសារទាំងពីរ -សូមលោកយកសារនេះជូនលោកម្ចាស់លោកផង។



www.budinst.gov.kh www.elibraryofcambodia.org

- ទេ !

សំលេងរបស់ *តូរ៉ាណាកា* លាន់ខ្ទរទីវាល ។ បន្ទាប់មកទៀត លោកនិយាយ ខ្លាំង១ និង យ៉ាងផ្លូវការ :

- ខ្ញុំមានកិត្តិយសណាស់ដែលបានទទួលជាផ្លូវការនូវសាររបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិ យ៉ាងនេះ ហើយខ្ញុំនឹងជូនចំលើយរបស់ខ្ញុំទៅឯកអគ្គរដ្ឋទូតដ៏ល្បីល្បាញ គឺ ប្អូនប្រុសរបស់ខ្ញុំ អម្ចាស់នៃខេត្ត *ស៊ីណាណូ* នៅវេលាថ្ងៃស្អែក ម៉ោងនេះដដែល ។

*សាតាគី* សំលឹងមើលបងប្រុសរបស់ខ្លួនទាំងសង្ស័យនៅក្នុងចិត្ត :

- តើលទ្ធភាពនៃចំ..........

-សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផងទាន -សាមូរ៉ៃចំនាស់និយាយកាត់យ៉ាងស្ងប់ស្ងៀម និងយ៉ាងថ្លៃថ្នូរ ដែលធ្វើអោយកិច្ចសន្ទនានេះ មានលក្ខណៈសំងាត់ឡើងវិញ-សូមអភ័យទោស ទាន ។ តែលោកម្ចាស់ *តូរ៉ាណាកា* ពិតជាត្រឹមត្រូវក្នុងការស្នើ របៀបនេះ ។ នេះជាជំរើសដ៏មហោឡារិកមួយដែលលោកម្ចាស់បានផ្តល់ទៅលោកម្ចាស់ *តូរ៉ាណាកា* ធ្វើការជ្រើសរើស ហើយដែលជាជំរើសមួយមិនមាននៅក្នុងសារផងទេ ។ ហេតុនេះគឺជាយុត្តិធម៌ និងសមរម្យផង ដែលត្រូវផ្តល់ពេលវេលាតាមដែលលោកបានស្នើនោះ ។

*សាតាគី* រើសយកសារទីពីរមកវិញ ហើយដាក់វាចូលទៅក្នុងដៃអាវរបស់ខ្លួន :

- ល្អណាស់ ។ខ្ញុំឯកភាព ។ លោកម្ចាស់ *តូរ៉ាណាកា* អោយខ្ញុំសូមអភ័យទោសចំពោះអាកប្បកិរិយាមិនសមរម្យរបស់ខ្ញុំផង ។ នៅមានរឿងចុងក្រោយមួយទៀតសូមមេត្តាប្រាប់ខ្ញុំផងថា តើលោកម្ចាស់ *កាស៊ីគីយ៉ាប៊ូ* នៅឯណា? ខ្ញុំមានសារមួយជូនគាត់ ។សារតែមួយទេសំរាប់គាត់នោះ ។

- ខ្ញុំនឹងអោយគេទៅហៅមកជួបលោក ។

☆ ☆ ☆

ស្ទាំងត្រដោបស្លាប ហើយទំលាក់ខ្លួនពីលើចាប់ព្រាបជាប់នៅក្នុងក្រញ៉ាំជើងរបស់វាក្នុងស្នូរស្រោកស្រាកនៃរោម ហើយក៏នាំសត្វព្រាបមកដីយ៉ាងលឿន ដូចដុំថ្មដែលធ្លាក់យ៉ាងដូចនោះដែរ ។ នៅសល់តែបន្តិចមកដល់ដី វាទំលាក់សត្វព្រាបដែលស្លាប់បាត់ទៅហើយនោះទៅដីមុនទើប



www.budinst.gov.kh www.elibraryofcambodia.org

បង្អង់ល្បឿន ហើយមកទំចំពីលើជាក្រោយ ។

*តូរ៉ាណាកា* និងដោយមាន *ណាកា* ជាអ្នកជំនួយការផងនោះ បំផាយសេះឡើងទីទួល ។ លោកចុះពីលើសេះ ហើយហៅស្ទាំងយ៉ាងថ្នម១អោយមកទំលើដៃរបស់លោកវិញ ។ ស្ទាំងបានស្ដាប់បញ្ជាលោកជាប្រញាប់ ដោយហើរមកទំនៅលើដៃពាក់ស្រោមរបស់លោកតែម្ដង ។ លោកផ្ដល់សាច់មួយដុំជារង្វាន់ដល់វាភ្លាម រួចទើបលោកគ្របក្រណាត់ក្បាលវាវិញ ដោយប្រើធ្មេញលោកខាំខ្សែរឹត ។ *ណាកា* រើសព្រាបយកទៅដាក់ក្នុងថង់សត្វមួយ ដែលពេញពាក់កណ្ដាលទៅហើយ១ដែលនៅព្យួរនឹងកែបសេះរបស់ឪពុកខ្លួន រួចទើបងាកទៅធ្វើសញ្ញាប្រាប់ទៅអ្នកក្បៀងសត្វ និងពួកអ្នកយាមដែលនៅឯទីឆ្ងាយ ។

*តូរ៉ាណាកា* ត្រលប់មកឡើងសេះវិញ ដោយនៅតែមានស្ទាំងនៅលើដៃពាក់ស្រោមរបស់ខ្លួននៅឡើយ ។ លោកសំលឹងមើលមេឃហើយប៉ាន់ប្រមាណពីពន្លឺដែលនៅសេសសល់ :

- ស្អែកច្បាស់ជាល្អណាស់ ។ បើតាមពុកស្មាន គឺគ្មានពពកទេ ។ ស្អែកពុកគិតមកបរបាញ់តាំងពីព្រលឹមតែម្ដង ។

- បាទពុក ។

*ណាកា* សំលឹងមើលឪពុកខ្លួនទាំងងឿងឆ្ងល់ តែដូចជាសព្វដងដែរ គេតែងតែខ្លាចនឹងសួរសំនួរទៅឪពុករបស់ខ្លួន តែឥឡូវនោះគេសែនចង់ដឹងពីអ្វី១ទាំងសព្វ ។ គេមិនអាចយល់បានថាហេតុអ្វីក៏ឪពុកគេនៅតែធ្វើព្រងើយបន្ទាប់ពីការប្រជុំដ៏គួរអោយស្អប់ខ្ពើមនេះបាន ? ឪពុកគេបានលំអោនគោរព *សាកាគី* នៅមុនពេលដែលបែកគ្នារួចហើយភ្លាម ហៅគេអោយយកស្ទាំងនានារបស់លោកព្រមទាំងពួកក្បៀងសត្វ និងពួកការពារ ហើយនាំពួកទាំងនេះឆ្លងព្រៃឡើងភ្នំ ។ ទាំងនេះហាក់បីដូចជាមិនមែនជាសក្ដិភាពនៃការធ្វើម្ចាស់លើខ្លួនសោះ ។ គ្រាន់តែគិតដល់ *សាកាគី* ភ្លាមសាច់របស់ *ណាកា* ឡើងញាក់មួយរំពេច ហើយគេដឹងថា តាទីប្រឹក្សាមានយោបល់ត្រឹមត្រូវណាស់ : បើសិនតែមួយភាគដប់នៃកិច្ចសន្ទនានោះត្រូវបានស្ដាប់វិញ ពួកសាមូរ៉ៃច្បាស់ជាហក់ទៅការពារកិត្តិយសអម្ចាស់របស់ខ្លួនជាមិនខាន ។ ខ្លួនគេផ្ទាល់បើសិនជាគ្មានគ្រោះគំរាមកំហែងលើជីវិតជីដូនជាទីគោរពរបស់គេទេនោះ គេច្បាស់ជាហក់ដាក់ *សាកាគី* ដោយខ្លួនគេផ្ទាល់ជាមិនខាន ។

អញគិតថា ដោយសារតែហេតុផលអស់នេះហើយ ដែលឪពុកអញបានក្លាយជាអ្វីដូចសព្វថ្ងៃនេះ និងនៅកន្លែងដែលគាត់នៅសព្វថ្ងៃ -គេគិតនៅក្នុងចិត្ត ។

ភ្នែករបស់គេប្រទះឃើញពួកអ្នកជិះសេះមួយក្រុមដែលចេញមកពីព្រៃ ហើយដែលកំពុងផាយសេះឡើងមករកពួកគេដែលនៅឯលើកំពូលកូនភ្នំ ។ នៅពីក្រោយព្រៃដ៏ខៀវងងឹតនេះស្ទឹងប្រៀបបីដូចជាខ្សែបូរពណ៌ខ្មៅមួយ ។ ពន្លឺនៅក្នុងតៀមជះភ្លឺបភ្លែតប្រៀបបីដូចជាពន្លឺអំពិលអំពែក ។

- ពុក !

- អ្ហា ! អូហ៍មែន ពុកមើលឃើញពួកវាហើយ ។ ពួកនោះជាអ្នកណា ?

- *យ៉ាប៊ូ-សាន អូមី-សាន* និង....... ពួកការពារប្រាំបីនាក់ ។

- ភ្នែកឯងគ្រាន់បើជាងពុក ។ អូហ៍មែនហើយ ពុកមើលឃើញគេស្គាល់ហើយ ។

*ណាកា* និយាយដោយមិនបានគិត :

- បើខ្ញុំវិញ ខ្ញុំមិនគួរបណ្តោយអោយ *យ៉ាប៊ូ-សាន* ទៅជួប *សាតាគី* តែម្នាក់ឯងដោយគ្មាន....-រួចគេឈប់ងក់ ហើយនិយាយទាំងតតាក់តតុប -សូមទោស ។

- ហេតុអីបានជាឯងយល់ថា មិនគួរអោយ *យ៉ាប៊ូ-សាន* ទៅម្នាក់ឯង ?

*ណាកា* ប្រទេចផ្តាសាខ្លួនឯងនៅក្នុងចិត្តពីព្រោះមាត់ឥតមានគំរបរបស់ខ្លួន ហើយនៅអែះអុញក្រោមក្រសែភ្នែករបស់ឪពុកខ្លួន :

- សូមអោយខ្ញុំសូមទោសផង តែនេះព្រោះថា បន្ទាប់មកខ្ញុំមិនអាចដឹងថា ពួកគេបានព្រមព្រៀងគ្នាជាសំងាត់លើរឿងអីខ្លះ ។ អាគាត់ណឹងអាចក្បត់លោកពុក ហើយងាយណាស់ ។ បើសិនជាខ្ញុំទុកអោយពួកវាពីរនាក់នេះនៅបែកពីគ្នាវិញ ។ សូមពុកអធ្យាស្រ័យដល់ខ្ញុំផង ។ ខ្ញុំមិនទុកចិត្តគាត់ណឹងទេ ។

- បើសិនជា *យ៉ាប៊ូ-សាន* និង *សាតាគី* រៀបចំគំរោងក្បត់ពីក្រោយខ្នងពុក ពួកវានឹងរៀបចំគំរោងនោះដដែល ទោះបីជាពុកបញ្ជូនមនុស្សទៅជាមួយ វីរអត់ក្តី ។ ជួនកាលគឺជាការវាងវៃវិញទេ ដែលត្រូវទុកច្រកអោយសត្វចេញនោះ ។ ហើយនេះទើបចាប់ត្រីបាន *ទេ* ?



www.budinst.gov.kh www.elibraryofcambodia.org

- បាទ សូមពុកអត់ទោសអោយខ្ញុំផង ។

*តូរ៉ាណាកា* ទើបបានមើលដឹងថា កូនប្រុសរបស់លោកឥតបានយល់ ហើយនឹងមិនយល់រហូត ។ កូនលោកគ្រាន់តែជាស្ទាំងដែលឆាបដេញសត្រូវយ៉ាងរហ័ស យ៉ាងចំ ចំនុច យ៉ាងផ្ដាច់ជីវិតតែប៉ុននោះ ។

លោកពោលដើម្បីលើកទឹកចិត្តកូន ដោយលោកស្គាល់យ៉ាងច្បាស់នូវគុណសម្បត្តិនានារបស់កូន ហើយដែលលោកបានអោយតំលៃយ៉ាងខ្ពស់ :

- ពុកសប្បាយចិត្តណាស់ដែលកូនយល់បាន កូនសំលាញ់ -រួចលោកបន្ថែមដោយសន្ដានចិត្តពិតប្រាកដ -ឯងជាកូនប្រុសដ៏ល្អម្នាក់ ។

- អរគុណពុក-*ណាកា* តបពោរពេញដោយមោទនភាពចំពោះការសរសើរដ៏កំរនេះ-ខ្ញុំគ្រាន់តែសង្ឃឹមថា ពុកនឹងអធ្យាស្រ័យចំពោះភាពល្ងីល្ងើរបស់ខ្ញុំ ហើយនឹងបង្ហាត់បង្ហាញខ្ញុំដើម្បីបានបំរើពុកគ្រាន់បើជាងនេះថែមទៀតប៉ុននោះ ។

- កូនឯងមិនមែនល្ងីល្ងើទេ ។

*យ៉ាប៊ូ* ទេដែលលីល្ងើនោះ -លោកហៀបតែបន្ថែមទៅហើយ ។ តែមានអ្នកដែលដឹងកាន់តែតិចកាលណា កាន់តែល្អកាលនោះ ហើយមិនចាំបាច់ឯងប្រឹងច្របាច់ខួរក្បាលទេ *ណាកា*។ ឯងទៅក្មេងណាស់ ។ ក្មេងជាងគេបំផុត លើសតែប្អូនម្ដាយទីទៃម្នាក់ទៀត គឺ *តាដារ៉ូ* ដែលមានអាយុប្រាំពីរឆ្នាំប៉ុននោះ ។

លោកសំលឹងមើលក្រុមអ្នកជិះសេះដែលកាន់តែចូលមកជិត រួចទើបសួរឡើង :

- តើម្ដាយឯងយ៉ាងម៉េចហើយ *ណាកា* ?

- ដូចតែអ៊ីចឹង ។ គាត់ជាស្ត្រីដែលរីករាយជាងគេបំផុតនៅក្នុងលោកនេះ តែគាត់អោយខ្ញុំជួបគាត់តែម្ដងទេក្នុងមួយឆ្នាំ ។ តើពុកអាចអោយគាត់ដូររឿងហ្នឹងបានទេ ?

- ទេ -*តូរ៉ាណាកា* តប -ម្ដាយឯងមិនប្រែជាដាច់ខាត ។

*តូរ៉ាណាកា* តែងមានអារម្មណ៍ក្ដៅក្រាយៗ នៅពេលដែលលោកនឹកដល់ *ចាណូណូប៊ូទេ* ដែលជាប្រពន្ធចុងផ្លូវការទីប្រាំបីរបស់លោក និង ដែលត្រូវជាម្ដាយរបស់ *ណាកា* ។ នាងគឺជាមេ



www.budinst.gov.kh www.elibraryofcambodia.org

ម៉ាយប្តីស្លាប់របស់កសិករម្នាក់នៅក្បែរតំបន់ *យេដូ* ហើយដែលលោកបានទាក់ភ្នែកកាលពីម្ភៃឆ្នាំមុន ។ នាងបាននៅជាមួយលោកបានបីឆ្នាំ ហើយក៏បានសូមការអនុញ្ញាតពីលោកវិលទៅធ្វើស្រែចំការវិញ ហើយលោកក៏បានយល់ព្រម ។ អីលូវនេះនាងរស់នៅលើការដ្ឋានយ៉ាងល្អមួយជិតភូមិកំណើតរបស់នាង ក្នុងឋានៈជាម្ចាស់ដីមេម៉ាយស្តុកស្តម្ភធាត់ទ្រលុក១ម្នាក់ រីករាយជានិច្ចនិងបានអ្នកផងទាំងពួងគោរពហើយគ្មានជំពាក់លុយអ្នកណាម្នាក់ ។ យូរ១ម្តង លោកទៅសួរសុខទុក្ខនាងហើយនឹងដើម្បីសើចសប្បាយជាមួយនាង ។ សើចទទេ ដោយគ្មានមូលហេតុ ។ សើចក្នុងនាមជាមិត្តនឹងគ្នា ។

លោកពោលឡើង :

- នាងគឺជាស្ត្រីដ៏ល្អម្នាក់ ។

*យ៉ាប៊ូ* និង *អូមី* ឡើងមកដល់ ហើយចុះពីលើសេះ ។ នៅពេលដែលដើរមកដល់ជិតជប់ជំហាន ទាំងពីរនាក់ឈប់ហើយលំអោនខ្លួនគោរព ។

*យ៉ាប៊ូ* ពោលឡើងទាំងក្តៅក្រហាយ ដោយលើកបង្ហាញរមូរសារមួយផង :

-វាអោយសារមកខ្ញុំ : "យើងសូមអញ្ជើញលោកអោយចាកចេញពី *អ៊ីស៊ូ* ទៅ *អូសាកា* ភ្លាម នៅថ្ងៃនេះ ហើយសូមលោកមកបង្ហាញខ្លួននៅវិមាន *អូសាកា* ដើម្បីធ្វើសវនាការ បើមិនយ៉ាងដូចនោះទេ ដីរបស់លោកទាំងអស់នឹងត្រូវរឹបអូស ហើយខ្លួនលោកនឹងត្រូវដាក់អោយនៅក្រៅច្បាប់ "។

លោកឈ្មីសារ ហើយគ្រវាត់ចោលទៅដី ដោយសំដីហួសចិត្តថា :

- " *ថ្ងៃនេះ !* "។ *តូរ៉ាណាកា* ក៏ពោលដោយមួម៉ៅនឹងភាពកោងកាច និងភាពលីល្ងើរបស់ *យ៉ាប៊ូ* :

- បើអ៊ីចឹង យកល្អ លោកគួរចាកចេញដំណើរភ្លាមទៅ ។

- លោកម្ចាស់ ខ្ញុំសូមអង្វរ - *អូមី* លុតជង្គង់ភ្លាម ហើយនិយាយយ៉ាងប្រញាប់-លោកម្ចាស់ *យ៉ាប៊ូ* ជាអណ្តាប់ដែលស៊ូទ្រាំទ្រជាមួយលោកម្ចាស់ ហើយខ្ញុំសូមក្រាបអង្វរករលោកម្ចាស់សូមកុំចំអកដល់គាត់ធ្វើអ្វី ។ សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំដែលមានអាកប្បកិរិយាច្រឡោង



www.budinst.gov.kh www.elibraryofcambodia.org

ខាមនេះផងចុះ ប៉ុន្តែលោកម្ចាស់ *សាគាគី*....... សូមអភ័យទោសដល់អាកប្បកិរិយាច្រលោងខាមរបស់ខ្ញុំផង។

- *យ៉ាប៊ូ-សាន* សូមអភ័យទោសដល់ការកត់សំគាល់អំបាញ់មិញរបស់ខ្ញុំផង។ នេះគឺចង់និយាយផ្លូវល្អទេ-*តូរ៉ាណាកា* ពោលទាំងប្រទេចផ្តាសាដល់ការភ្លេចស្មារតីរបស់លោកអំបាញ់មិញ -យើងគួរតែចេះសើចលេងខ្លះនឹងរបៀបនេះ *ទេ*?

លោកហៅអ្នកថែទាំស្នាំងមកប្រគល់ស្នាំងអោយ ហើយបញ្ជាអោយបុរសនេះ និងពួកក្មេងសត្វត្រលប់ទៅវិញ។ រួចទើបលោកបញ្ជាអោយសាមូរ៉ៃទាំងអស់ លើកលែងតែ *ណាកា* អោយទៅឆ្ងាយផុតពីការស្តាប់លឺលោកនិយាយគ្នា ទើបលោកអង្គុយចោងហោង និងហៅ *យ៉ាប៊ូ* អោយធ្វើដូចលោកដែរ។ លោកពោល :

- យកល្អ លោកគួររ៉ាយរ៉ាប់ប្រាប់ខ្ញុំពីអ្វីដែលបានកើតឡើងផងមើល។

- សឹងតែគ្មានរឿងអីដែលនិយាយរ៉ាយរ៉ាប់ផង -*យ៉ាប៊ូ* តប -ខ្ញុំបានទៅជួបវា។ វាទទួលខ្ញុំក្នុងភាពគួរសមយ៉ាងថោកបំផុត។ ដំបូងមាន " ការគួរសម " ពីសំនាក់ *អ៊ីស៊ីដូ* ហើយនឹងសេចក្តីអញ្ជើញឆោមួយអោយខ្ញុំចងសំព័ន្ធមិត្តជាសំងាត់ជាមួយគាត់ ដើម្បីរៀបផែនការមួយធ្វើឃាតលោកជាបន្ទាន់ ហើយនឹងធ្វើឃាតសាមូរ៉ៃរបស់ *តូរ៉ាណាកា* ទាំងអស់ដែលនៅក្នុង *អ៊ីស៊ូ* នេះ។ ជាធម្មតាទេ ខ្ញុំបានប្រកែក ហើយភ្លាមនោះ ម៉ាភ្លាមៗនោះឯង និងដោយគ្មានការគួរសមអ្វីទាំងអស់ វាហុចអានេះអោយខ្ញុំតែម្តង ! -*យ៉ាប៊ូ* ចង្អុលសារស្ទើរធ្លាយ -បើកុំតែលោកមានបញ្ជាមិនអោយប៉ះពាល់វានោះ កុំអីខ្ញុំកាប់វាជាកំនាត់ភ្លាមនោះតែម្តងហើយ ! ខ្ញុំសូមលោកលុបបញ្ជានោះចោលទៅ។ ខ្ញុំមិនអាចរស់នៅក្នុងភាពអាម៉ាស់នេះបានទេ។ ខ្ញុំត្រូវតែសងសឹក !

- តើរឿងរ៉ាវដែលកើតឡើងមានតែប៉ុននេះទើរ ?

- ប៉ុនណឹងមិនគ្រប់គ្រាន់ទេអ្ហី ?

*តូរ៉ាណាកា* ធ្វើមិនដឹងមិនលឺនូវភាពច្រលោងខាមរបស់ *យ៉ាប៊ូ* នេះ ហើយនិយាយទាំងក្រញូវទៅកាន់ *អូមី* :

- ឯងគួរតែត្រូវបន្ទោស *ទេ* ? ហេតុអីក៏ឯងមិនមានការវាងវៃដើម្បីការពារអម្ចាស់



www.budinst.gov.kh www.elibraryofcambodia.org

ឯងអោយបានប្រសើរជាងនេះ ? ក្រែងឯងជាទីប្រឹក្សាអ្វី ? ឯងគួរធ្វើជាខែលអោយអម្ចាស់ខ្លួន ។ ឯងគួរអូសទាញ *សាតាគី* អោយចេញមកទីចំហ ប្រឹងរកអោយឃើញថាតើ *អ៊ីស៊ីដូ* មានគំនិតយ៉ាងម៉េច តើរបៀបថ្លក់ទឹកចិត្តនោះរបៀបណា តើពួកវាមានផែនការអីខ្លះ ។ ក្រែងឯងជាទីប្រឹក្សាដ៏មានតំលៃអ្វី ? ឯងមានឱកាសមួយដ៏ល្អឥតខ្ចោះ តែឯងបែរជាបំផ្លាញវាចោលឥតអំពើ ដូចមនុស្សត្រមល់ទប់គ្មានដឹងអ្វីសោះទៅវិញ ។

*អូមី* អោនក្បាលចុះ

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផងចុះ ។

- ខ្ញុំអាច ប៉ុន្តែខ្ញុំមើលមិនឃើញថា ហេតុអីលោកម្ចាស់ *យ៉ាប៊ូ* នឹងអភ័យទោសដល់រូបឯងសោះឡើយទេ ។ អីលូវនេះលោកម្ចាស់របស់ឯងទទួលយកសារហើយ ។ អីលូវនេះលោកម្ចាស់ឯងជាប់ពាក្យហើយ ។ អីលូវនេះលោកម្ចាស់របស់ឯងត្រូវតែប្រកាន់សកម្មភាពបើមិនបែបមួយក៏បែបមួយទៀតដែរ ។

- ថាម៉េច ?-*យ៉ាប៊ូ* សួរ ។

- ចុះលោកមិនឃើញថា ហេតុអីបានជាខ្ញុំធ្វើរបៀបដែលខ្ញុំបានធ្វើនេះទេអ្វី ? គឺពន្យារពេល......ធម្មតាទេ ពន្យារពេល -*តូរ៉ាណាកា* តប ។

- តែមួយថ្ងៃណឹង ? តើមួយថ្ងៃបានប្រយោជន៍អីទៅ ?

- អ្នកណាទៅដឹង ? មួយថ្ងៃសំរាប់យើង គឺថយមួយថ្ងៃសំរាប់សត្រូវដែរ ណា៎ ។

ភ្នែករបស់ *តូរ៉ាណាកា* ងាកសំលឹងមើលទៅ *អូមី* វិញ ប្រៀបដូចជាខ្សែតី :

- តើសារពី *អ៊ីស៊ីដូ* ជាសារផ្ទាល់មាត់ រឺ សារសរសេរ ?

*យ៉ាប៊ូ* ជាអ្នកឆ្លើយនឹងសំនួរវិញ :

- ធម្មតាទេ គឺផ្ទាល់មាត់ ។

*តូរ៉ាណាកា* នៅតែសំលឹងមើល *អូមី* យ៉ាងមុតដដែល :

- ឯងមិនបានបំពេញភារកិច្ចឯង ទាំងចំពោះម្ចាស់ឯង ទាំងចំពោះខ្ញុំ ។

- សូមអភ័យទោសដល់.......



www.budinst.gov.kh www.elibraryofcambodia.org

- តើឯងបាននិយាយយ៉ាងម៉េចខ្លះ ?

*អូមី* ឥតបានតបឡើយ ។

- ចុះឯងភ្លេចសុជីវធម៌អីអស់ហើយរឺ ? តើឯងនិយាយថាម៉េចខ្លះ ?

- អត់អីទាំងអស់លោកម្ចាស់ ។ ខ្ញុំអត់មាននិយាយស្អីទាំងអស់.........

- ថាម៉េច ?

*យ៉ាប៊ូ* និយាយខ្លាំងៗឡើង :

- *អូមី* អត់មាននិយាយស្អីទាំងអស់ជាមួយ *សាកាគី* ពីព្រោះគ្នាអត់មានវត្តមានទេ ។ *សាកាគី* សុំជួបនិយាយតែជាមួយខ្ញុំម្នាក់ឯងតែប៉ុណ្ណោះ ។

- អូហ៍ ។

*តូរ៉ាណាកា* លាក់ទុកនូវភាពរីករាយក្នុងចិត្ត នៅពេលដែល *យ៉ាប៊ូ* ត្រូវបង្ខំចិត្តសារភាពនូវអ្វីដែលលោកសង្ស័យតាំងពីយូរណាស់មកហើយនេះ លោកពោលបន្ត :

- សូមអភ័យទោសដល់ខ្ញុំផង *អូមី-សាន*។ នេះមកពីខ្ញុំគិតថា ជាធម្មតាលោកត្រូវមានវត្តមាននៅទីនោះដែរ ។

- នេះជាការភាន់ច្រលំរបស់ខ្ញុំ លោកម្ចាស់ ។ ខ្ញុំគួរតែចចេស ។ លោកម្ចាស់មានប្រសាសន៍ត្រូវណាស់ ខ្ញុំមិនបានបំពេញភារកិច្ចការពារលោកម្ចាស់របស់ខ្ញុំ *-អូមី* តប -ខ្ញុំគួរតែចចេសខ្លាំងជាងនេះ ។ សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ។ *យ៉ាប៊ូ-សាម៉ា* សូមលោកមេត្តាអភ័យទោសដល់ខ្ញុំផង ។

*យ៉ាប៊ូ* មិនទាន់ហើបមាត់ឆ្លើយផង *តូរ៉ាណាកា* និយាយបន្ត :

- ពិតហើយ លោកត្រូវបានអនុគ្រោះទោសហើយ *អូមី-សាន*។ បើសិនជាអម្ចាស់របស់លោកសំរេចផ្ទុយពីគំនិតរបស់លោក នេះជាបុព្វសិទ្ធិរបស់គេ ។ លោកបានសំរេចផ្ទុយពីមតិរបស់ *អូមី-សាន* មែនទេ *យ៉ាប៊ូ-សាម៉ា* ?

- បាទ......បាទ ពិតមែន តែខ្ញុំគិតថា នេះមិនមែនជារឿងធំដុំទេ ។ លោកគិតថាខ្ញុំ......

- បើអីចឹងរឿងដែលអាក្រក់បានកើតមានឡើងរួចទៅហើយ ។ តើលោកមានគំរោង



www.budinst.gov.kh www.elibraryofcambodia.org

ធ្វើយ៉ាងម៉េច ?

- ចម្មតាទេ កុំរវល់នឹងសារនេះតែម្តងទៅ -*យ៉ាប៊ូ* កាន់តែបារម្ភឡើង -លោកគិតថាខ្ញុំអាចគេចមិនទទួលយកសារនេះបានមែនរឺ ?

- ពិតហើយ ។ លោកអាចចរចាជាមួយវាដើម្បីបានមួយថ្ងៃ ។ រឺអាចលើសពីនេះផង ។ រាប់អាទិត្យផង ។

*គូរ៉ាណាកា* បង្វិលកាំបិតកាន់តែជ្រៅទៅក្នុងរបួសរបស់ *យ៉ាប៊ូ* ចិត្តលោករីករាយយ៉ាងលាក់កំបាំងនៅពេលដែលឃើញភាពល្ងីល្ងើរបស់ *យ៉ាប៊ូ* បានរុញគេអោយជាប់ជុំចដោយលោកឥតរវល់អ្វីពីអំពើក្បត់ ដែល *យ៉ាប៊ូ* ត្រូវបានគេអូសទាញចូល អាចដោយការទិញទឹកចិត្ត ការលួងលោម ការបញ្ឆេចបញ្ឆោ រឺការបំភិតបំភ័យនោះឡើយ ។ លោកពោលបន្ថែម :

- គួរអោយស្តាយណាស់ ប៉ុន្តែលោកជាប់ពាក្យហើយ ។ តែមិនអីទេ ដូចលោកបាននិយាយថា : " នៅពេលដែលម្នាក់ៗសំរេចជ្រើសរើសថាខ្លួនទៅខាងណាបានកាន់តែឆាប់ពេលណា ល្អកាលណោះ " អ៊ីចឹង -*គូរ៉ាណាកា* ក្រោកឈរឡើង -មិនចាំបាច់វិលត្រលប់ទៅកងពលវិញទេយប់នេះ ។ ពួកលោកទាំងពីរចូលរួមបាយល្ងាចជាមួយខ្ញុំតែម្តងទៅ ។ ខ្ញុំបានចាត់ចែងរៀបចំការកំសាន្តមួយហើយ ។

- " សំរាប់ទាំងអស់គ្នា " លោកបន្ថែមទាំងសែនពេញចិត្ត ។

☆ ☆ ☆

ក្រោមដៃដ៏ប៉ិនប្រសប់របស់ *គីគូ* កេះជាបទភ្លេងឡើង ។ រួចនាងចាប់ផ្តើមច្រៀង ។ សំលេងពោរពេញទៅដោយទឹកដមរបស់នាងបានបំពេញរាត្រីដ៏ស្ងៀមស្ងាត់នេះ ។ ពួកគេអង្គុយលង់អារម្មណ៍នៅក្នុងបន្ទប់ធំដែលបើកចេញទៅយ៉ាបរានហាល ហើយនិងសួនច្បារដែលនៅជាប់បន្ទប់នេះ ។ ទាំងអស់គ្នាហាក់ត្រូវស្រូបដោយឥទ្ធិពលដ៏អស្ចារ្យរបស់នាង ក្រោមពន្លឺរវាំនៃចន្ទុះ ។សរសៃសូត្រពណ៌មាសនៃគីម៉ូណូរបស់នាងដេញពន្លឺព្រាតៗនៅពេលដែលនាងអោនដេញ *សាមីសេន*។

*គូរ៉ាណាកា* ចោលភ្នែកសំលឹងមើលជុំវិញមួយត្របុស ។ អារម្មណ៍របស់លោកទទួលយ៉ាងប្រត្យក្សនូវឥទ្ធិពលនៃចរន្តរាត្រី ។ នៅខាងម្ខាងរបស់លោក *ម៉ារីកូ* នៅអង្គុយចន្លោះ *ប្លាក់ថន* នឹង



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ុនការ៉ូ* ។ នៅខាងម្ខាងទៀត *អូមី* និង *យ៉ាប៊ូ* នៅអង្គុយទន្ទឹមគ្នា។ កន្លែងកិត្តិយសនៅទំនេរស្អាត។ *សាកាគី* ត្រូវបានអញ្ជើញដែរ តែគេបានប្រកែកដោយថាសុខភាពខ្សោយ ថ្វីបើគេឃើញបុរសនេះបំផាយសេះនៅឯកូនភ្នំខាងជើង ហើយក្នុងថ្មើរនេះកំពុងតែរួមរក្សក្នុងថាមពលមួយដែលក្លាយជារឿងនិទាននៅហើយក្តី។ *ណាកា* និងពួកការពារដែលត្រូវបានជ្រើសរើសយ៉ាងម៉ត់ចត់នោះស្ថិតនៅជុំវិញទីកន្លែងនេះ។ *គីយ៉ូកូ* នៅម្តុំៗនេះឯខាងក្រោយ។ *គីកូ-សាន* លុតជង្គង់នៅយ៉ាបរានហាល បែរមុខមករកពួកគេទាំងអស់គ្នា ហុចខ្នងទៅសួនច្បារ។ នាងមានមាឌតូចច្រលឹង ហើយនៅតែម្នាក់ឯងដែលជាប្រការមួយគំរជាពន់ពេក។

*ម៉ារីកូ* ពិតជានិយាយត្រូវមែន -*តូរ៉ាណាកា* នឹកក្នុងចិត្ត។ នារីកំដរនេះសក្តិសមនឹងទឹកប្រាក់មែន។ អារម្មណ៍របស់លោកញាប់ញ័រនឹងនាងប៉ុនណា ការបារម្ភរបស់លោកចំពោះ *សាកាគី* ក៏ចុះថយប៉ុននោះដែរ។ តើអញហៅនាងទៀតទេនៅយប់នេះ រឺមួយអញត្រូវដេកម្នាក់ឯង ? ចរិតជាបុរសរបស់លោកនៅរំភើបញាប់ញ័រនៅឡើយ នៅពេលដែលលោកនឹកឃើញពីយប់មិញមិញនេះ។

នៅពេលនោះ លោកបានសួរទៅ *ម៉ាម៉ា-សាន* នៅបន្ទប់ផ្ទាល់ខ្លួនរបស់លោកនៅឯក្នុងបន្ទាយ :

- រួចយ៉ាងម៉េច *គីយ៉ូកូ-សាន* នាងចង់ជួបខ្ញុំ រឺ ?

- ចាស លោកម្ចាស់។

លោកចាប់អុជធូបមួយសំរាប់វាស់ពេលវេលា រួចពោល :

- និយាយទៅ។

*គីយ៉ូកូ* លំអោនខ្លួនគោរព ប៉ុន្តែ *តូរ៉ាណាកា* ឥតបានយកចិត្តទុកដាក់ប៉ុន្មានទេ។ នេះជាលើកទីមួយហើយដែលលោកបានឃើញ *គីកូ* ជិតយ៉ាងនេះ។ កាន់តែជិត សំរស់របស់នាងកាន់តែលេចឆើតឡើង ហាក់ដូចជាភាពតឹងតែងនៃមុខបររបស់នាងឥតមានឥទ្ធិពលបន្តិចណាសោះឡើយមកលើរូបនាង។

លោកមានការភ្ញាក់ផ្អើលផងដែរ ដោយលោកមិននឹកស្មានថា *គីយ៉ូកូ* មានបំនងចង់



www.budinst.gov.kh www.elibraryofcambodia.org

និយាយជាមួយលោកនៅចំពោះមុខនាងយ៉ាងដូចនេះឡើយ ។ លោកពោលទៅកាន់ *គីតូ* :

- សូមលេងភ្លេងមួយបទពីរទៅ ក្នុងពេលដែលយើងជជែកគ្នា ។

រួចនាងក៏ចាប់ផ្ដើមលេងភ្លេង ។ តែភ្លេងដែលនាងលេងនៅពេលនោះ មិនដូចជាពេលនេះទេ ។ យប់មិញ ភ្លេងរបស់នាងមានភាពសណ្ដំធ្វើអោយស្ងប់ស្ងាត់ក្នុងអារម្មណ៍ ជាការជូនដំណើរទៅក្នុងការងារដែលហៀបសំរេចផល ។ ភ្លេងនៅយប់នេះ គឺជាការបំផុសសំរើបអារម្មណ៍ ជាការខ្វល់ខ្វាយ និងជាការសន្យា ។

- លោកម្ចាស់ -*គីយ៉ូកូ* ចាប់ផ្ដើមនិយាយ -ដំបូងបង្អស់ សូមអោយខ្ញុំសំដែងនូវអំណរគុណចំពោះកិត្តិយសដែលលោកម្ចាស់បានផ្ដល់ដល់ខ្ញុំ ដល់ផ្ទះដ៏ក្រីក្ររបស់ខ្ញុំ និងដល់ *គីតូ-សាន* ដែលជានារីថ្នាក់លេខមួយនៃពិភពដើមសួល ។ ខ្ញុំដឹងហើយថា តំលៃដែលខ្ញុំទារដើម្បីកិច្ចសន្យានោះ គឺចំជាព្រហើនហួសហេតុ ហើយមិនអាចទទួលយកបាន ហើយនៅតែពេលណាលោកស្រី *កាស៊ីគី* និងលោកស្រី *តូដា*សំរេចចិត្តតែប៉ុននោះនៅព្រឹកស្អែកនេះ ។បើសិននេះជារឿងរបស់លោកម្ចាស់នោះ លោកម្ចាស់ពិតជាសំរេចហើយជាយូរមកហើយ ព្រោះលុយកាក់ប៉ុននេះ មានទៅសំខាន់អីសំរាប់សាមូរ៉ៃនោះ ពិសេសចំពោះ *វ៉ៃមីញ៉ូ* ដ៏មហិមានៅក្នុងលោកនេះទៅទៀតនោះ ?

រួច *គីយ៉ូកូ* ឈប់បង្អង់ដើម្បីស្ទង់ឥទ្ធិពលនៃសំដីរបស់ខ្លួន ។ លោកឥតបានត្របាក់នុយនេះទេ តែលោកបក់ផ្លិតតិចៗ ដែលអាចជាសញ្ញានៃការមួម៉ៅចំពោះសំដីប៉ិប៉ាច់ប៉ិប៉ោច រឺជាការទទួលយកការសរសើរ រឺជាការច្រានចោលទាំងស្រុងនៃតំលៃដែលបានស្នើសុំ ។

*គីយ៉ូកូ* បន្ត :

- តើលុយកាក់ជាស្អីទៅ ? វាគ្រាន់តែជាមធ្យោបាយសំរាប់ទំនាក់ទំនងតែប៉ុននោះ ។ ដូចជាភ្លេងរបស់ *គីតូ-សាន* អីចឹងដែរ ។

តាមពិតទៅ តើពួកយើងស្រីៗនៃពិភពដើមសួលធ្វើអ្វីទៅ ? ពួកយើងគ្មានធ្វើអ្វីក្រៅពីធ្វើទំនាក់ទំនង និងជួយកំដរកំសាន្ត ពួកយើងធ្វើអោយវិញ្ញាណបុរសៗបានភ្លឺត្រចះត្រចែង និងជួយសំរាលទំងន់បុរសៗតែប៉ុននោះ........

*តូរ៉ាណាកា* ទប់មាត់មិនធ្វើការឆ្លើយតបមិនល្អណាមួយ ដោយលោកគិតថា នារីនេះ



www.budinst.gov.kh www.elibraryofcambodia.org

បានទិញពេលជួបមួយធូបក្នុងតំលៃប្រាំរយ *ក្ខុត្ត* ហើយប្រាំរយ *ក្ខុត្ត* ទាមទារសវនាការមួយប្រកប ដោយការយកចិត្តទុកដាក់ ។ ដោយហេតុនេះលោកក៏បន្តបណ្តោយអោយស្ត្រីនេះបន្តនិយាយ ដោយស្តាប់តែត្រចៀកម្ខាង ឯម្ខាងទៀតលោកត្រេកត្រអាលនឹងសុក្រឹតភាពនៃបទភ្លេងដែល ចាក់ជ្រៀតចូលគ្រប់សរសៃវិញ្ញាណរបស់លោក ធ្វើអោយលោកមានអារម្មណ៍អណ្តែតអណ្តូង ។ រួចរំពេចនោះអ្វីដែល *គីយ៉ូក្ខ* បាននិយាយ បានទាញកន្ត្រាក់លោកមករកការពិតយ៉ាងគំហុកតែ ម្តង :

- ថាម៉េច ?

- ខ្ញុំសូមអោយលោកម្ចាស់យកពិភពដើមសូលនេះ ដាក់ក្រោមកិច្ចគាំពាររបស់លោក ម្ចាស់ និងកែប្រែដំណើរប្រវត្តិសាស្ត្រទៅ ។

- ដោយរបៀបណាទៅ ?

- ដោយរបៀបដែលលោកម្ចាស់តែងតែធ្វើតាំងពីដើមរៀងមកយ៉ាងនោះឯង ។ ដោយ ផ្តោតកង្វល់របស់លោកម្ចាស់ទៅនឹងអនាគតរបស់ចក្រភព មុនអនាគតផ្ទាល់របស់លោកម្ចាស់ នោះឯង ។

លោកមិនរវល់នឹងការបញ្ជើចបញ្ជើនេះទេ តែលោកតាំងចិត្តបិទអារម្មណ៍របស់លោក មិនរវល់ស្តាប់ភ្លេងតទៅទៀត ។ លោកបានធ្លាក់ចូលក្នុងអន្ទាក់ទីមួយដោយប្រាប់ *គីយ៉ូក្ខ* អោយ នាំនារីនោះមក ធ្លាក់ក្នុងអន្ទាក់ទីពីរ គឺលោកបានបណ្តោយខ្លួនអោយត្រេកត្រអាលនឹងសំរស់ ហើយនឹងក្លិនរបស់នារី ហើយនឹងធ្លាក់ចូលក្នុងអន្ទាក់ទីបី គឺលោកបានអនុញ្ញាតអោយនាងលេង ភ្លេងបំពេលួងលោមអារម្មណ៍ក្នុងពេលដែលចៅវ៉ាយស្រីខ្លួននិយាយ ។

- ពិភពដើមសូល ? តើវាមានទាក់ទិនអីនឹងពិភពដើមសូល ?

- មានពីរ លោកម្ចាស់ ។ ទីមួយគឺ ពិភពដើមសូលមានទំនាក់ទំនងស្និតល្មួតជាមួយពិ ភពពិតប្រាកដ ដែលធ្វើអោយរំខានដល់ពិភពទាំងពីរ ។ ទីពីរ នារីៗពួកយើងមិនអាចឈានដល់ ក៏រិតឥតខ្ចោះដូចតាមការប៉ុនប៉ងរបស់បុរសៗបានទេ ។

- អ៊ីចឹងរឺ ?



www.budinst.gov.kh www.elibraryofcambodia.org

និយាយជាមួយលោកនៅចំពោះមុខនាងយ៉ាងដូចនេះឡើយ ។ លោកពោលទៅកាន់ *គីគូ* :

- សូមលេងភ្លេងមួយបទពីរទៅ ក្នុងពេលដែលយើងជជែកគ្នា ។

រួចនាងក៏ចាប់ផ្ដើមលេងភ្លេង ។ តែភ្លេងដែលនាងលេងនៅពេលនោះ មិនដូចជាពេលនេះទេ ។ យប់មិញ ភ្លេងរបស់នាងមានភាពសណ្ដំធ្វើអោយស្ងប់ស្ងាត់ក្នុងអារម្មណ៍ ជាការជូនដំណើរទៅក្នុងការងារដែលហៀបសំរេចផល ។ ភ្លេងនៅយប់នេះ គឺជាការបំផុសសំរើបអារម្មណ៍ ជាការខ្នួបខ្នាច និងជាការសន្យា ។

- លោកម្ចាស់ -*គីយ៉ូកូ* ចាប់ផ្ដើមនិយាយ -ដំបូងបង្អស់ សូមអោយខ្ញុំសំដែងនូវអំនរគុណចំពោះកិត្តិយសដែលលោកម្ចាស់បានផ្ដល់ដល់ខ្ញុំ ដល់ផ្ទះដំក្រិត្ររបស់ខ្ញុំ និងដល់ *គីគូ-សាន* ដែលជានារីថ្នាក់លេខមួយនៃពិភពដើមស្លួល ។ ខ្ញុំដឹងហើយថា តំលៃដែលខ្ញុំទារដើម្បីកិច្ចសន្យានោះ គឺចំជាព្រហើនហួសហេតុ ហើយមិនអាចទទួលយកបាន ហើយនៅតែពេលណាលោកស្រី *កាស៊ូគី* និងលោកស្រី *តូដេ*សំរេចចិត្តតែប៉ុននោះនៅព្រឹកស្អែកនេះ ។បើសិននេះជារឿងរបស់លោកម្ចាស់នោះ លោកម្ចាស់ពិតជាសំរេចហើយជាយូរមកហើយ ព្រោះលុយកាក់ប៉ុននេះ មានទៅសំខាន់អីសំរាប់សាមូរ៉ៃនោះ ពិសេសចំពោះ *ដៃមីញ៉ូ* ដ៏មហិមានៅក្នុងលោកនេះទៅទៀតនោះ ?

រួច *គីយ៉ូកូ* ឈប់បង្អង់ដើម្បីស្ទង់ឥទ្ធិពលនៃសំដីរបស់ខ្លួន ។ លោកឥតបានត្របាក់នុយនេះទេ តែលោកបក់ផ្លិតតិចៗ ដែលអាចជាសញ្ញានៃការមួម៉ៅចំពោះសំដីបំប៉ាច់បំប៉ោច រឺជាការទទួលយកការសរសើរ រឺជាការច្រានចោលទាំងស្រុងនៃតំលៃដែលបានស្នើសុំ ។

*គីយ៉ូកូ* បន្ត :

- តើលុយកាក់ជាស្អីទៅ ? វាគ្រាន់តែជាមធ្យោបាយសំរាប់ទំនាក់ទំនងតែប៉ុននោះ ។ ដូចជាភ្លេងរបស់ *គីគូ-សាន* អីចឹងដែរ ។

តាមពិតទៅ តើពួកយើងស្រីៗនៃពិភពដើមស្លួលធ្វើអ្វីទៅ ? ពួកយើងគ្មានធ្វើអ្វីក្រៅពីធ្វើទំនាក់ទំនង និងជួយកំដរកំសាន្ដ ពួកយើងធ្វើអោយវិញ្ញាណបុរសៗបានភ្លឺត្រចះត្រចែង និងជួយសំរាលទំងន់បុរសៗតែប៉ុននោះ........

*តូរ៉ាណាកា* ទប់មាត់មិនធ្វើការឆ្លើយតបមិនល្អណាមួយ ដោយលោកគិតថា នារីនេះ



www.budinst.gov.kh www.elibraryofcambodia.org

បានទិញពេលជួបមួយចប់ក្នុងតំលៃប្រាំរយ *ក្លូ* ហើយប្រាំរយ *ក្លូ* ទាមទារសវនាការមួយប្រកបដោយការយកចិត្តទុកដាក់ ។ ដោយហេតុនេះលោកក៏បន្តបណ្តោយអោយស្ត្រីនេះបន្តនិយាយដោយស្តាប់តែត្រចៀកម្ខាង ឯម្ខាងទៀតលោកត្រេកត្រអាលនឹងសុក្រិតភាពនៃបទភ្លេងដែលចាក់ជ្រៀតចូលគ្រប់សរសៃវិញ្ញាណរបស់លោក ធ្វើអោយលោកមានអារម្មណ៍អណ្តែតអណ្តូង។ រួចរំពេចនោះអ្វីដែល *គីយ៉ូកូ* បាននិយាយ បានទាញកន្ត្រាក់លោកមករកការពិតយ៉ាងគំហុកតែម្តង :

- ថាម៉េច ?

- ខ្ញុំសូមអោយលោកម្ចាស់យកពិភពដើមសូលនេះ ដាក់ក្រោមកិច្ចគាំពាររបស់លោកម្ចាស់ និងកែប្រែដំណើរប្រវត្តិសាស្ត្រទៅ។

- ដោយរបៀបណាទៅ ?

- ដោយរបៀបដែលលោកម្ចាស់តែងតែធ្វើតាំងពីដើមរៀងមកយ៉ាងនោះឯង។ ដោយផ្តោតកង្វល់របស់លោកម្ចាស់ទៅនឹងអនាគតរបស់ចក្រភព មុនអនាគតផ្ទាល់របស់លោកម្ចាស់នោះឯង។

លោកមិនរវល់នឹងការបញ្ចើចបញ្ចើនេះទេ តែលោកតាំងចិត្តបិទអារម្មណ៍របស់លោកមិនរវល់ស្តាប់ភ្លេងតទៅទៀត។ លោកបានធ្លាក់ចូលក្នុងអន្ទាក់ទីមួយដោយប្រាប់ *គីយ៉ូកូ* អោយនាំនារីនោះមក ធ្លាក់ក្នុងអន្ទាក់ទីពីរ គឺលោកបានបណ្តោយខ្លួនអោយត្រេកត្រអាលនឹងសំរស់ហើយនឹងក្លិនរបស់នារី ហើយនឹងធ្លាក់ចូលក្នុងអន្ទាក់ទីបី គឺលោកបានអនុញ្ញាតអោយនាងលេងភ្លេងបំពេលួងលោមអារម្មណ៍ក្នុងពេលដែលចៅវ៉ាយស្រីខ្លួននិយាយ។

- ពិភពដើមសូល ? តើវាមានទាក់ទិនអីនឹងពិភពដើមសូល ?

- មានពីរ លោកម្ចាស់។ ទីមួយគឺ ពិភពដើមសូលមានទំនាក់ទំនងស្និតល្អតជាមួយពិភពពិតប្រាកដ ដែលធ្វើអោយវិនាសដល់ពិភពទាំងពីរ។ ទីពីរ នារី១ពួកយើងមិនអាចឈានដល់កិរិតឥតខ្ចោះដូចតាមការប៉ុនប៉ងរបស់បុរស១បានទេ ។

- អីចឹងរឺ ?



www.budinst.gov.kh www.elibraryofcambodia.org

ក្លិនក្រអូបរបស់ *គីតូ* បានផាត់មកប៉ះច្រមុះរបស់លោក ។ នេះជាក្លិនដែលលោកមិនដែលជួបប្រទះឡើយ ។ ដោយអចេតនា លោកសំលឹងមើលទៅនាង ។នៅលើបបូរមាត់របស់នាងមានស្នាមញញឹមបន្តិចដែលសំរាប់តែរូបលោកម្នាក់ប៉ុណ្ណោះ ។ រួចនាងក៏ទំលាក់ភ្នែកចុះបែបស្រឹមហើយម្រាមដៃរបស់នាងក៏គ្រេះ *សាមីសេន* ឡើង ។ សំលេងទាំងនេះហាក់មករួមរឹតរូបលោកមួយរំពេច ។

លោកប្រឹងប្រមូលផ្តុំសតិអារម្មណ៍មិនអោយបែក :

- សូមទោស *គីយ៉ូកូ-សាន* អ្នកនិយាយថាម៉េច ?

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំដែលនិយាយមិនលះសេចក្តី ។ ទីមួយ : ពិភពដើមស្រួលគួរតែផ្តាច់ចេញពីពិភពពិត ។ ផ្ទះតែរបស់ខ្ញុំនៅ *មីស៊ីម៉ា* នៅតាមផ្លូវមួយនៅផ្នែកខាងត្បូង ផ្ទះតែឯទៀតនៅរាយប៉ាយពេញទីក្រុងតែម្តង ។ នៅ *ក្យូតូ* និង *ណារ៉ា* ក៏ដូចគ្នានេះដែរ ហើយក៏ដូចជានៅគ្រប់ទីកន្លែងនៃចក្រភពនេះដែរ ។ សូម្បីតែនៅ *យេដូ* ក៏ដោយ ។ តែខ្ញុំគិតថា *យេដូ* អាចជាគំរូសំរាប់នគរទាំងមូលបាន ។

- តើដោយរបៀបណាទៅ ?

បេះដូងលោកស្ទើរតាំង នៅពេលដែលសំលេងភ្លេងឈានដល់គំរិតយ៉ាងឯកមួយ ។

- សាជីវកម្មទាំងអស់សុទ្ធតែមានផ្លូវរបស់ខ្លួន តំបន់របស់ខ្លួន ។ ពួកយើងគួរតែមានទីកន្លែងរបស់យើងផ្ទាល់ដែរ លោកម្ចាស់ ។ *យេដូ* ជាទីក្រុងថ្មី ។ លោកម្ចាស់អាចពិចារណារៀបចំជាតំបន់ពិសេសមួយសំរាប់ពិភពដើមស្រួល ។ យកផ្ទះតែទាំងអស់មកនៅក្នុងបរិវេណនេះ ហើយហាមឃាត់មិនអោយផ្ទះតែណាមួយ ទោះតូចប៉ុនណាក៏ដោយ មានទីតាំងក្រៅតំបន់នេះឡើយ ។

អីលូវនេះអារម្មណ៍របស់លោកបានមូលផ្តុំវិញហើយ ព្រោះនេះជាគំនិតដ៏ធំធេងមួយ ។ នេះជាគំនិតដ៏ល្អមែនទែន រហូតដល់លោកបន្ទោសខ្លួនលោកថា ហេតុអីក៏លោកមិនបានគិតដល់យ៉ាងនេះ ។ រាល់ផ្ទះតែទាំងអស់ និងរាល់នារីបំរើទាំងអស់នៅក្នុងបរិវេណតែមួយ ហើយនេះគឺពិតជាងាយស្រួលសំរាប់នគរបាលដើម្បីឃ្លាំមើល ដើម្បីប្រមូលពន្ធដារ ហើយក៏ងាយស្រួលឃ្លាំមើលនិងងាយយកការណ៍ពីភ្ញៀវទាំងអស់ដែលទៅតំបន់នោះថែមទៀតផង ។ លោកក៏ដឹងច្បាស់ដែរ



www.budinst.gov.kh www.elibraryofcambodia.org

នូវឥទ្ធិពលរបស់នារី១ថ្នាក់លេខមួយ ។

ប៉ុន្តែទឹកមុខរបស់លោកឥតបានបង្ហាញនូវទឹកចិត្តរីករាយរបស់លោកឡើយ ។ លោកបែរជាសួរទេវិញ :

- តើធ្វើយ៉ាងនេះបានប្រយោជន៍អីខ្លះទៅ *គីយ៉ូកូ-សាន* ?

- យើងអាចមានសាជីវកម្មរបស់យើងបាន លោកម្ចាស់ ។ មានសាជីវកម្ម គឺមានកិច្ចការពារ ។ មានសាជីវកម្មនៅក្នុងទីកន្លែងតែមួយ ហើយដែលទាំងអស់គួរគោរពតាម.......

- **ត្រូវតែ** គោរពតាម ?

- ចាស លោកម្ចាស់ ។ ត្រូវតែគោរពតាម ដើម្បីគុណប្រយោជន៍រួម ។ សាជីវកម្មនឹងទទួលខុសត្រូវដើម្បីធានាអោយតំលៃមានលក្ខណៈត្រឹមត្រូវ ហើយនិយាមត្រូវបានរក្សា ។ ដោយហេតុនេះ តែក្នុងប៉ុន្មានឆ្នាំ នារីថ្នាក់លេខពីរនៅ *យេដូ* ក៏អាចស្មើគ្នានឹងនារីថ្នាក់ដូចគ្នានៅ *ក្យូតូ* ហើយក៏ចេះតែបន្តគ្នារបៀបនេះទៅ ។ បើសិនជាគំរោងនេះអាចអនុវត្តបាននៅ *យេដូ* ហេតុអីក៏មិនអាចអនុវត្តនៅក្នុងគ្រប់ទីក្រុងនៃតំបន់ដែលលោកម្ចាស់គ្រប់គ្រងនោះ ?

- ប៉ុន្តែពួកម្ចាស់ផ្ទះដែលនៅក្នុងបរិវេណនោះនឹងក្លាយទៅជាពួកផ្តាច់មុខ *ទេ* ? ពួកគេអាចនឹងទារថ្លៃចូលយ៉ាងខ្ពស់កប់ពពក *ទេ* ? ពួកគេអាចបិទទ្វារមិនទទួលយកអ្នកឯទៀត ដែលសុទ្ធតែមានសិទ្ធិមកធ្វើការនៅក្នុងពិភពដើមស្តូលដែរ *ទេ* ?

- ចាស អីចឹងដែរ លោកម្ចាស់ ។ ហើយរឿងនេះអាចកើតមានឡើងនៅកន្លែងខ្លះ នៅក្នុងពេលខ្លះ ។ ប៉ុន្តែច្បាប់យ៉ាងតឹងតែងអាចធានាអោយមានភាពត្រឹមត្រូវ ហើយពេលនោះ លុយច្បាស់ជាស៊ីលើអាក្រក់ជាមិនខាន ដើម្បីជាផលប្រយោជន៍សំរាប់ពួកយើង និងសំរាប់ម៉ូយ និងភ្ញៀវប្រកបដោយកិត្តិយសរបស់យើងទាំងឡាយ ។ ទីពីរ : នារី១........

- ចាំចប់រឿងទីមួយរបស់យើងសិន ។ *គីយ៉ូកូ-សាន -តូរ៉ាណាកា* និយាយកាត់យ៉ាងកំបុត -បើអីចឹង នេះគឺជាចំនុចមួយដែលប្រឆាំងនឹងសំនើរបស់អ្នកហើយ ។

- ចាស ពិតមែនហើយ លោកម្ចាស់ ។ តែ *វ៉េមីញ៉ូ* ណាក៏ដោយក៏អាចបញ្ជាអោយរឿងនេះមានដំណើរបែបផ្សេងទៅបានយ៉ាងងាយដែរ ។ ហើយនៅក្នុងមួយកន្លែង *វ៉េមីញ៉ូ* នោះ



www.budinst.gov.kh www.elibraryofcambodia.org

ទទួលដោះស្រាយតែជាមួយសាជីវកម្មតែមួយប៉ុននោះ។ ចំពោះលោកម្ចាស់វិញ លោកម្ចាស់ពិតជាគ្មានកង្វល់អ្វីទាំងអស់។ តំបន់នីមួយៗត្រូវទទួលខុសត្រូវលើបញ្ហាសន្តិភាពនៅក្នុងតំបន់នោះ។ ហើយទទួលខុសត្រូវលើរឿងពន្ធដារថែមទៀតផង។

-ឱ មែនហើយ រឿងពន្ធដារ ! នៅពេលនោះគឺពិតជាងាយស្រួលជាងក្នុងការប្រមូលពន្ធដារជាមិនខាន។ នេះគឺជាចំនុចល្អបំផុតក្នុងការគាំទ្រគំនិតនេះ។

ភ្នែករបស់ *គីយ៉ូគូ* សំលឹងមើលចួប។ ជាងពាក់កណ្តាលបាននេះបាត់អស់ទៅហើយ :

- នៅក្នុងភាពគតិបណ្ឌិតរបស់លោកម្ចាស់ៗគួរចេញសេចក្តីសំរេចថា ពិភពដើមសួលរបស់យើង គឺជាពិភពតែមួយនៅក្នុងពិភពទាំងមូល ដែលមិនត្រូវជាប់ពន្ធគ្រប់ពេល។ គ្រប់ៗពេលទាំងអស់ -*គីយ៉ូគូ* ងើយមុខសំលឹង *តូក៊ូណាកា* យ៉ាងច្បាស់ សំលេងរបស់គាត់ប្រកបដោយភាពបរិសុទ្ធ -គិតៗទៅគេហៅពិភពយើងថា " *ពិភពអណ្តែត* " ផងដែរទេ រឺ ? តើយើងមានអ្វីសំរាប់ជូន ក្រៅតែពីសំរស់របស់ពួកយើងនោះ ? ហើយសំរស់នេះមួយភាគធំមិនគឺជាចំនែកយុវវ័យទេ រឺ ? យុវវ័យដែលជារបស់ពិសិដ្ឋ និងដែលជាការប្រទានរបស់ព្រះនេះ មិនគឺជាវត្ថុមួយដ៏លឹបលតែមួយភ្លែតប៉ុននោះទេ រឺ ? ក្នុងចំនោមមនុស្សប្រុសទាំងអស់ លោកម្ចាស់ពិតជាមនុស្សដែលយល់ជាងគេថា តើយុវវ័យវាលឹបលតែមួយភ្លែតយ៉ាងណា ពិសេសតើយុវវ័យនារីវាភ្លឹបភ្លែតយ៉ាងណានោះ។

សំលេងភ្លេងបានរលត់បាត់ឈឹងទៅ។ លោកចោលភ្នែកមើលទៅ *គីគូ-សាន* ។ នាងកំពុងសំលឹងថ្នាំងមករកលោក។ ចិញ្ចើមរបស់នាងជ្រួញបន្តិច។ លោកឆ្លើយតបយ៉ាងស្មោះត្រង់ :

- ពិតហើយ ខ្ញុំដឹងថា តើយុវវ័យវាលឹបលតែមួយភ្លែតយ៉ាងណា -លោកក្រេបតែ -ខ្ញុំនឹងពិចារណាពីអ្វីដែលអ្នកបាននិយាយ។ ចុះរឿងទីពីរ ?

- រឿងទីពីរ -*គីយ៉ូគូ* ប្រឹងប្រមូលស្មារតី -គឺលោកម្ចាស់អាចទុកស្នាមលោកម្ចាស់ជារៀងរហូតនៅក្នុងពិភពដើមសួល។ សូមពិនិត្យតែលើនារីខ្លះៗរបស់ពួកយើងចុះ។ ដូចជា *គីគូ-សាន* ជាដើម នាងបានរៀនច្រៀង និងរាំ និងលេង *សាមីសេន* តាំងពីនាងអាយុបានប្រាំមួយឆ្នាំម្ល៉េះ ។ រាល់ពេលដែលនាងបើកភ្នែក គឺនាងបានប្រឹងប្រែងយ៉ាងខ្លាំងក្លា ដើម្បីធ្វើអោយសិល្ប:



www.budinst.gov.kh www.elibraryofcambodia.org

របស់នាងបានសុក្រិត ។គឺជាការត្រឹមត្រូវណាស់ដែលនាងបានក្លាយជានារីថ្នាក់លេខមួយអាស្រ័យដោយសិល្បៈឯករបស់នាង ។ តែនាងនៅតែជានារីកំដរភ្ញៀវម្នាក់ ហើយក៏មានភ្ញៀវខ្លះរំពឹងចង់កំសាន្តជាមួយនាងលើខ្នល់ខ្នើយ ក៏ដូចជាកំសាន្តតាមរយៈសិល្បៈរបស់នាងផងដែរ ។ ខ្ញុំគិតថា គួរបង្កើតចេញជានារីពីរប្រភេទ ។ ប្រភេទទីមួយ គឺប្រភេទនារីកំដរភ្ញៀវដូចរាល់ដង : រួសរាយសប្បាយតាមផ្លូវកាយ ។ ប្រភេទទីពីរ ដែលជាប្រភេទថ្មី គឺអាចហៅ *គីសា* (Geisha ) : ជាសិល្បករ ពោលគឺជាមនុស្សដែលទទួលតែផ្នែកសិល្បៈសុទ្ធសាធ ។ *គីសា* មិនមែនជានារីដែលការរួមរក្ស ជាផ្នែកមួយនៃភារកិច្ចរបស់ខ្លួនទេ ។ ពួកគេគឺជាអ្នកកំដរកំសាន្ត ជាអ្នករបាំ ជាអ្នកចំរៀង ពោលគឺជាអ្នកឯកទេស ហើយដែលទទួលដោយឡែកតែក្នុងវិជ្ជាជីវៈនេះតែម្តង ។ ទុកអោយពួក *គីសា* ជាអ្នកកំដរកំសាន្តសតិអារម្មណ៍ និងស្មារតីរបស់បុរស១ អាស្រ័យរូបសម្ផស្ស ល្អតល្អន់ និងសិល្បភាពរបស់ពួកគេចុះ ។ ហើយទុកអោយនារីកំដរជាអ្នកទទួលកំដររូបរាងកាយតាមរយៈសម្ផស្សល្អតល្អន់ និងសិល្បភាពមួយបែបទៀតរបស់ពួកគេទៅចុះផងដែរ ។

ជាថ្មីម្តងទៀត លោកសែនភ្ញាក់ផ្អើលនឹងសាមញ្ញភាព និងលទ្ធភាពឈានទៅឆ្ងាយនៃគំនិតរបស់ស្ត្រីចំនាស់នេះ :

- តើជ្រើសរើស *គីសា* ដោយរបៀបណាទៅ ?

- តាមរយៈសម្បទា (Aptitude ) របស់នាង ។ នៅពេលនារីគ្រប់ការហើយម្ចាស់របស់នាងនឹងសំរេចពីផ្លូវអនាគតរបស់នាង ។ ហើយសាជីវកម្មអាចឯកភាព រឺច្រានចោលអ្នកចំនូលថ្មីនេះបាន *ទេ* ?

- នេះជាគំនិតដ៏អស្ចារ្យណាស់ *គីយ៉ូកូ-សាន*។

នារីចំនាស់លំអោនខ្លួនគោរពយ៉ាងញ៉ូវខ្លួនចំប្រប់ :

- សូមលោកម្ចាស់ អភ័យទោសដល់ការនិយាយបកក្រោយរបស់ខ្ញុំផង ប៉ុន្តែធ្វើបែបនេះ ទោះជាសំរស់បានបាត់បង់ រូបរាងលែងល្អតល្អន់ក្តី ក៏នារីនៅមានអនាគតមួយដ៏កំរ និងនៅមានតំលៃដ៏ពិតប្រាកដរបស់ខ្លួនដែរ ។ នាងមិនធ្លាក់ខ្លួនលិចកប់បាត់ ដូចដែលនារីកំដរឯទៀត១ទាំងអស់បានជួបប្រទះនៅពេលនេះទេ ។ ខ្ញុំអង្វរករ លោកម្ចាស់ ក្នុងនាមពួកសិល្បករដែលស្ថិត



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងចំនោមពួកអ្នកទាំងនោះ ក្នុងនោះក៏មាន *គីគូ-សាន* របស់ខ្ញុំម្នាក់ដែរ ។ ខ្ញុំអង្វរករ លោកម្ចាស់ សូមផ្ដល់ដល់អ្នកដែលមានសំនាងប៉ុន្មាននាក់នេះនូវអនាគត និងទីតាំងមួយដែលសក្ដិសមនឹងរូបគេនៅក្នុងនគរនេះផង ។ ដើម្បីរៀនច្រៀង រៀនរាំ និងលេងឧបករណ៍តន្ត្រីបាន គឺទាមទារនូវការរឹកហាត់ហើយរឹកហាត់ទៀត រាប់ឆ្នាំ ។ រួមរក្សទាមទារតែយុវវ័យតែប៉ុននោះ ហើយគ្មានអ្វីដែលនាំអោយកំរើកតណ្ហាជាងយុវវ័យដែរ *ទេ?*

-មិនមែនទេ -*តូរ៉ាណាកា* តាមសំលឹងមើលមុខ*គីយ៉ូកូ* ជាប់-*គីសា* អាចមិនទទួលរួមរក្សបាន ?

-នេះមិនមែនជាផ្នែកមួយនៃភារកិច្ចរបស់នាង ទោះជាគេអោយលុយប៉ុន្មានក៏ដោយ ។ *គីសា* នឹងមិនត្រូវបានបង្ខំអោយរួមរក្សឡើយលោកម្ចាស់ ។ បើសិនជា *គីសា* ចង់រួមរក្ស ជាមួយបុរសណាមួយនោះគឺជារឿងផ្ទាល់ខ្លួនរបស់នាងនោះតែប៉ុននោះ ។ វី អាចថានោះ ត្រូវបានរៀបចំដោយមានការអនុញ្ញាតពីម្ចាស់ស្រីរបស់នាង និងក្នុងតំលៃមួយដ៏ខ្ពស់ បំផុតដែល បុរសនោះអាចហ៊ានទទួល ។ ភារកិច្ចរបស់នារីកំដរភ្ញៀវគឺត្រូវរួមរក្សជាមួយបុរស ប្រកបដោយ សិល្បភាពចំនែក ឯ *គីសា* និងហាត់រៀនជា *គីសា* គឺមិនអាចប៉ះពាល់បានទេ ។ សូមលោកម្ចាស់អភ័យទោស ដល់ខ្ញុំដែលនិយាយវែងអន្លាយបែបនេះផង ។

រួចទាំង *គីយ៉ូកូ* ទាំង *គីគូ* ក៏លំអោនខ្លួនគោរព ។ ចួបនៅសល់តែមួយភាគតូចតែប៉ុននោះ ។

*តូរ៉ាណាកា* នៅសាកសួរអ្នកទាំងពីរលើសជាទ្វេនៃម៉ោង ដែលលោកបានអនុញ្ញាតអោយជួបទៅទៀត ដោយលោករីករាយនឹងបានឱកាសស្វែងយល់ពីពិភពរបស់គេ បានសាកសួរពីគំនិត ពីសេចក្ដីសង្ឃឹម និងពីការភ័យខ្លាចរបស់ពួកគេ ។ អ្វីដែលលោកបានរៀនសូត្របានពីនេះរឹតតែធ្វើអោយលោកមានការរំភើបថែមទៀត ។ លោកកត់ត្រាទុកនៅក្នុងខួរក្បាលនូវពត៌មានទាំងនេះ ដើម្បីសំរាប់ប្រើវានៅពេលអនាគត ។ រួចទើបលោកប្រើ *គីគូ* អោយចេញទៅឯសួនច្បារហើយនិយាយទៅកាន់នារីចំនាស់ :

- *គីយ៉ូកូ-សាន* យប់នេះខ្ញុំចង់អោយ *គីគូ* នៅទីនេះរហូតដល់ភ្លឺ បើសិនជានាងយល់



www.budinst.gov.kh www.elibraryofcambodia.org

ព្រម និងបើសិនជានាងទំនេរ ។ តើអ្នកអាចសួរនាងផងបានទេ ? ពិតហើយខ្ញុំដឹងថា នាងហត់ហើយអីលូវនេះ។ ម្យ៉ាងទៀត ខ្ញុំក៏យល់ដែរថា នាងនៅលេងភ្លេងយ៉ាងពិរោះអស់ពីចិត្តក្នុងរយៈពេលយ៉ាងយូរមកហើយ តែនាងអាចពិចារណាពីសំនើខ្ញុំនេះដែរ។ ខ្ញុំសូមអរគុណបើសិនជាអ្នកព្រមសួរនាង។

- ខ្ញុំពិតជាសួរជូនលោកម្ចាស់ តែខ្ញុំដឹងថា នាងពិតជាមានកិត្តិយសធំធេងណាស់តាមរយៈការអញ្ជើញរបស់លោកម្ចាស់នេះ។ ព្រោះថាភារកិច្ចរបស់ពួកយើង គឺបំរើតាមគ្រប់បែបដែលយើងអាចធ្វើទៅបាន *ទេ*?

- ពិតហើយ។ ប៉ុន្តែដូចជាអ្នកបានលើកឡើងយ៉ាងត្រឹមត្រូវមកហើយ នាងនេះគឺពិសេសបំផុត។ បើសិនជានាងហត់នឿយពេកនោះ ក៏ខ្ញុំយល់ដែរ។ សូមអ្នកសួរនាងមួយភ្លែតសិនទៅ។

លោកហុចថង់ស្បែកតូចមួយដែលមានដប់*ក្លូនី* ទៅ *គីយ៉ូកូ* ទាំងសោកស្តាយចំពោះការចាយដៃធំបែបនេះ តែលោកដឹងថា នេះគឺជាតំរូវទាមទារនៃឋានៈរបស់លោកផងដែរ។ លោកនិយាយ :

- ប្រហែលអានេះអាចប៉ះប៉ូវចំពោះរាត្រីដ៏នឿយហត់នេះផង ហើយក៏ជាអំនោយដ៏តិចតួច ជាតំនាងអំនរគុណរបស់ខ្ញុំចំពោះគំនិតទាំងប៉ុន្មានរបស់អ្នកផងចុះ។

- នេះគឺជាភារកិច្ចរបស់ពួកយើងដែលត្រូវបំរើអីចឹងហើយ លោកម្ចាស់។-*គីយ៉ូកូ* តបលោកឃើញថា ទោះជាស្ត្រីចំនាស់នេះប្រឹងទប់យ៉ាងណាក៏ដោយក៏គាត់មិនអាចទប់ម្រាមដៃរបស់គាត់មិនអោយស្ទាបថង់ស្បែករាប់ចំនួនទឹកលុយបានឡើយ ។រួចរាល់ ហើយគាត់ក៏ពោលបន្ត :

- សូមអរគុណ លោកម្ចាស់ ។សូមលោកម្ចាស់អធ្យាស្រ័យផងចុះ ខ្ញុំនឹងទៅសួរនាង - ហើយដោយគ្មានអ្នកណាស្មានបាន និងយ៉ាងគួរអោយចំលែក ស្រាប់តែភ្នែករបស់គាត់ពោរពេញដោយទឹកភ្នែករហាម - សូមលោកម្ចាស់ទទួលនូវអំនរគុណពីមីកញ្ចាស់រហេមរហាមបែបខ្ញុំនេះចំពោះការគួរសមរបស់លោកម្ចាស់ និងចំពោះប្រការដែលលោកម្ចាស់ទទួលស្តាប់ការព្រោកប្រាជ្ញរបស់ខ្ញុំ ។ ជាធម្មតា ពួកយើងជាអ្នកផ្តល់ការសប្បាយរីករាយ ហើយយើងទទួលបានវិញ គឺស្ទើង



www.budinst.gov.kh www.elibraryofcambodia.org

ទឹកភ្នែកតែប៉ុននោះ។ និយាយតាមត្រង់ទៅ លោកម្ចាស់ គឺជាការលំបាកណាស់នឹងពន្យល់ពីអារម្មណ៍របស់មនុស្សស្រីបាន....... សូមលោកម្ចាស់អភ័យទោសផងចុះ.........

- ស្តាប់ខ្ញុំណា *គីយ៉ូកូ-សាន* ។ ខ្ញុំយល់។ សូមអ្នកកុំបារម្ភអ្វីអោយសោះ។ ខ្ញុំនឹងពិចារណាពីគ្រប់អ្វីដែលអ្នកបាននិយាយ ហើយពិតមែនហើយ អ្នកទាំងពីរនឹងចេញដំណើរជាមួយខ្ញុំក្រោយព្រលឹមល្ងះ១បន្តិច។ ទៅលេងភ្នំពីរបីថ្ងៃ នឹងនាំអោយមានការប្រែប្រួលជាទីរីករាយជាមិនខាន។ ខ្ញុំគិតថា តំលៃនៃកិច្ចសន្យា នឹងត្រូវបានឯកភាពគ្នាហើយ *ទេ*?

*គីយ៉ូកូ* លំអោនខ្លួនអរគុណ រួចជូតទឹកភ្នែកចេញ ហើយសួរយ៉ាងម៉ត់ចត់ :

- តើលោកម្ចាស់អនុញ្ញាតអោយខ្ញុំដឹងផងបានទេ ថាតើកិច្ចសន្យានេះត្រូវបានទិញសំរាប់ជូនបុគ្គលឧត្តុង្គឧត្តមណាមួយទៅ ?

- *យ៉ូស៊ី តូរ៉ាណាកា-ណូ-មីណូវ៉ារ៉ា* ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

## ជំពូក ៤៣

*តូរ៉ាណាកា* សំលឹងមើលមាឌដ៏ធំរបស់បព្វជិតដែលដើរកាត់វាលតំរង់មករកលោក។ ពន្លឺចន្ទុះធ្វើអោយមុខរាងស្គមរបស់បព្វជិតនេះមានភាពមាំទាំជាងសព្វដង។ សំពត់ពណ៌លឿង បែបព្រះសង្ឃរបស់បព្វជិតនេះ មានភាពសង្ហា ហើយនៅលើដើមទ្រូងលោកមានអង្កាំ និងឈើឆ្កាងមួយផង។

នៅសល់ដប់ជំហាន បព្វជិត *អាលវីតូ* ឈប់ ហើយលុតជង្គង់លំអោនខ្លួនគោរពជាកិច្ចចាប់ផ្ដើមការគួរសមជាផ្លូវការ។

*តូរ៉ាណាកា* នៅអង្គុយតែម្នាក់ឯងនៅលើរោង។ ពួកអ្នកការពារនៅអមលោកជារាងស្វែងក្របី ឆ្ងាយផុតពីការស្ដាប់លឺកិច្ចសន្ទនាទាំងឡាយ។ មានតែ *ប្លាក់ថន* ម្នាក់ប៉ុននោះដែលនៅជិត ហើយគេនៅផ្អែកបែបហ៊ីនឹងក្ដាររោងតាមដូចដែលគេបានទទួលបញ្ជា។ ភ្នែកគេសំលឹងយ៉ាងធុញថប់បព្វជិត *អាលវីតូ* តែលោកវិញ លោកធ្វើជាមិនបានកត់សំគាល់វត្តមានរបស់គេសោះឡើយ។

នៅពេលដែលលោកយល់ឃើញថា ពេលវេលាល្មមសមរម្យហើយនោះ បព្វជិត *អាលវីតូ* ក៏និយាយឡើង :

- គឺជាប្រការល្អណាស់ដែលបានជួបលោកម្ចាស់។

- ខ្ញុំក៏អ៊ីចឹងដែរ *លូតូ-សាន*។

រួចលោកក៏ធ្វើសញ្ញាអោយបព្វជិត *អាលវីតូ* អង្គុយនៅលើម៉ក់មួយ ដែលដាក់ទុកសំរាប់ភ្ញៀវនៅលើ *តាតាមី* ដែលក្រាលផ្ទាល់ដីហើយដែលនៅទល់មុខរោងដែលលោកកំពុងអង្គុយនោះឯង។ រួចទើបលោកបន្ត :

- ខ្ញុំខានជួបលោកយូរហើយ។

- ពិតមែនហើយលោកម្ចាស់ ហើយក៏មានរឿងច្រើនដែលត្រូវប្រាប់គ្នាទៅវិញទៅមកផងដែរ។

បព្វជិត *អាលវីតូ* ដឹងច្បាស់ណាស់ថា ម៉ក់ដែលលោកកំពុងអង្គុយពីលើនេះ ស្ថិតនៅលើ



www.budinst.gov.kh www.elibraryofcambodia.org

ដី មិនមែននៅលើរោងជាមួយ *តូរ៉ាណាកា* ទេ។ ម្យ៉ាងទៀតលោកបានចាប់អារម្មណ៍យ៉ាងច្បាស់ពីដាវសាមូរ៉ៃនៅនឹងខ្លួន *ភ្លាក់ថន* ក្នុងចំងាយយ៉ាងជិតនឹងរូប *តូរ៉ាណាកា* ក៏ដូចពីអាការៈយ៉ាងព្រងើយរបស់គេនោះផងដែរ ។ លោកបន្ត :

- ខ្ញុំបាននាំសារសំងាត់មួយពីចៅហ្វាយនាយរបស់ខ្ញុំ គឺលោកគណៈអធិការសង្ឃ ហើយដែលសូមគោរពសួរសុខទុក្ខលោកម្ចាស់ ។

- សូមអរគុណ តែដំបូងសូមលោកនិយាយពីរឿងលោកសិនទៅមើល ។

- តើលោកម្ចាស់អនុញ្ញាតអោយខ្ញុំគួរសមជាមួយលោកតៃកុងបានទេ ?

*តូរ៉ាណាកា* យល់ព្រម *អាល់វីតូ* ក៏និយាយជាភាសាប៉ក់ទុយកាល់ទៅកាន់ *ភ្លាក់ថន* :

- ខ្ញុំត្រូវតែសរសើរឯង តៃកុង ។ ដាវនេះសក្តិសមនឹងរូបឯងណាស់ ។

- សូមអរគុណព្រះតេជគុណ *-ភ្លាក់ថន* តប -ខ្ញុំកំពុងតែរៀនប្រើវា។ តែសូមទោសដែលខ្ញុំត្រូវនិយាយថា ខ្ញុំមិនទាន់ចេះប្រើវាស្ទាត់នៅឡើយ ។ បើសិនជាខ្ញុំត្រូវប្រយុទ្ធ ខ្ញុំនៅតែត្រូវប្រើកាំភ្លើង ប្រើកាណុង រឺប្រើដាវអ្នកដើរសមុទ្ទដដែលហ្នឹង ។

-ខ្ញុំសូមបន់ស្រន់សូមកុំអោយលោកត្រូវប្រយុទ្ធអោយសោះ និងសូមអោយភ្នែកលោកបានមើលឃើញពីករុណាធមិដ៏ធំធេងរបស់ព្រះជាម្ចាស់ផង ។

- ភ្នែកខ្ញុំភ្លឺទេ តែគឺភ្នែករបស់តេជគុណទេដែលពាសស្បែកនោះ ។

- បើលោកស្រលាញ់ព្រលឹងលោក សូមលោកតៃកុងឯងនៅតែបើកភ្នែក បើកព្រលឹងតទៅទៀតទៅ។ អាចអ្នកឯងមានការភាន់ច្រលំខ្លះហើយ តែទោះជាយ៉ាងណាក្តី ក៏ខ្ញុំត្រូវតែសរសើរឯងដែលបានជួយសង្គ្រោះជីវិតលោកម្ចាស់ *តូរ៉ាណាកា* ផងដែរ ។

- អ្នកណាប្រាប់លោកពីរឿងនេះ ?

*អាល់វីតូ* ឥតឆ្លើយតប លោកងាកទៅរក *តូរ៉ាណាកា* វិញ។ ដើម្បីបំបាត់ភាពស្ងាត់ស្ងៀមនេះ *តូរ៉ាណាកា* ក៏សួរឡើង :

- តើនិយាយគ្នាពីរឿងអីហ្នឹង ?

*អាល់វីតូ* និយាយប្រាប់ពីអ្វីដែលបានជជែកគ្នា រួចលោកបន្ថែម :



www.budinst.gov.kh www.elibraryofcambodia.org

- ថ្វីត្បិតតែមនុស្សនេះជាសត្រូវនឹងជំនឿរបស់ខ្ញុំ និងជាចោរសមុទ្រក្តី ក៏ខ្ញុំសប្បាយចិត្ត នឹងប្រការដែលមនុស្សនេះបានជួយសង្គ្រោះលោកម្ចាស់ផងដែរ ។ ព្រះជាម្ចាស់លោកដើរផ្លូវមួយ ដ៏អាថ៌កំបាំងមែនទែន។ លោកម្ចាស់បានផ្តល់កិត្តិយសដល់តែកុងនេះសំបើមណាស់ ក្នុងការដែល លោកម្ចាស់តែងតាំងវាជាសាមូរ៉ៃយ៉ាងនេះ ។

- តេក៏ជា *ហាតាម៉ូតូ* ផងដែរ -*តូរ៉ាណាកា* សែនសប្បាយចិត្តនឹងភាពស្រឡាំងកាំង មួយភ្លែតនេះរបស់ *អាលវីតូ* -តើលោកមានយកវចនានុក្រមមកជាមួយផងទេ ?

- យកមកហើយ លោកម្ចាស់ ។ ហើយខ្ញុំមានយកមកផងដែរនូវផែនទីជាច្រើនដែល លោកម្ចាស់ត្រូវការ ហើយដែលមានបង្ហាញពីមូលដ្ឋានបំកទុយកាល់មួយចំនួននៅតាមផ្លូវរហូត ដល់ *ក្យូតូ* ផងដែរ។ សៀវភៅនេះនៅក្នុងចំនោមអីវ៉ាន់អីវ៉ាន់ផ្សេងៗទៀតរបស់ខ្ញុំឯនោះ។ តើខ្ញុំ ត្រូវបញ្ជូនមនុស្សទៅយកសៀវភៅនោះ រឺក៏ចាំអោយសៀវភៅនេះទៅគាត់ដោយផ្ទាល់ដៃខ្ញុំនៅ ពេលក្រោយទៀត ?

- ចាំអោយគាត់នៅពេលក្រោយទៅ។ យប់នេះក៏បាន ស្អែកក៏បាន ។តើលោកមានបាន យករបាយការណ៍មកជាមួយផងទេ ?

- រឿងដែលចោទថាយើងបាននាំកាំភ្លើងពី *ម៉ាកាវ* នោះរឺ ? ព្រះតេជគុណគណៈអធិ ការសង្ឃកំពុងតែរៀបចំហើយ ទាន ។

- រួចចុះរឿងចំនួនពួកជប៉ុនស៊ីឈ្នួលច្បាំង ដែលលោកប្រើនៅតាមមូលដ្ឋាននីមួយៗ របស់លោកនោះ ?

- ព្រះតេជគុណគណៈអធិការសង្ឃកំពុងអោយមូលដ្ឋានទាំងអស់ ផ្ញើរបាយការណ៍ ច្បាស់លាស់មកលោក ហើយនៅពេលដែលលោកបានរបាយការណ៍នេះពេញលេញហើយ លោក នឹងប្រគល់ជូនលោកម្ចាស់ភ្លាម ។

- ល្អ។ អីលូវនេះលោកនិយាយប្រាប់ខ្ញុំទៅមើល ថាហេតុអីបានជាលោកដឹងពីរឿង ជួយសង្គ្រោះខ្ញុំ ?

- តិចណាស់ ដែលថារឿងដែលកើតមានឡើងចំពោះ *តូរ៉ាណាកា -ណូ- មីណូវ៉ារ៉ា* មិន



www.budinst.gov.kh www.elibraryofcambodia.org

ក្លាយទៅជាប្រធានបទនៃពាក្យចចាមអារ៉ាម និងរឿងនិទាននោះ។ ពេលចេញពី *ម៉ីស៊ីម៉ា* មក ពួកយើងបានលឺថាលោកម្ចាស់រិះត្រូវលេបត្របាក់ដោយព្រះធរណីទៅហើយ តែបាន " មនុស្សចុងស្រុកពណ៌មាស " បានទាញលោកម្ចាស់ចេញមកវិញ ។ ហើយពួកយើងក៏បានលឺថា លោកម្ចាស់បានធ្វើកាយវិការបែបនេះវិញដើម្បីមនុស្សចុងស្រុកនេះ ហើយនឹងនារីម្នាក់ បើតាមខ្ញុំគិតប្រហែលជាលោកស្រី *ម៉ារីតូ* ហើយ មែនទេ ?

*តូរ៉ាណាកា* ងក់ក្បាលបន្តិច :

- ពិតមែនហើយ។ នាងនៅ *យ៉ូកូសេ* នេះដែរ -លោកគិតមួយខណៈ រួចពោលបន្ត - ស្អែកនេះនាងចង់សារភាពលាងបាបតាមទំនៀមរបស់ពួកលោក។ តែអានេះបានតែរឿងមិនមែននយោបាយទេ ណ៎។ ខ្ញុំគិតថា រឿងនេះមិនរាប់បញ្ចូលរឿងទាក់ទិននឹង *ហាកាម៉ូតូ* ទាំងប៉ុន្មានរបស់ខ្ញុំទេ *នេ*? ខ្ញុំបានពន្យល់រឿងនេះដល់នាងហើយដែរ។

*អាល់វីតូ* លំអោនគោរពជាសញ្ញាឯកភាព :

- បើសិនជាលោកម្ចាស់ឯកភាព តើខ្ញុំអាចរៀបចំជាពិធីសូត្រធម៌សំរាប់ពួកគ្រិស្តសាសនិកនៅទីនេះបានទេ ? នេះជាពិធីសូត្រធម៌ដែលនឹងប្រព្រឹត្តទៅដោយស្ងាត់ៗមិនហ៊ឹកហ៊ាក់អីទេទាន។ គឺនៅថ្ងៃស្អែកនេះ បានទេ ?

- ខ្ញុំនឹងពិចារណាពីរឿងនេះ។

*តូរ៉ាណាកា* នៅនិយាយពីនេះពីនោះមួយសន្ទុះ ទើបលោកសួរឡើង :

- លោកមានសារមួយសំរាប់ខ្ញុំ រឺ ? ជាសាររបស់មេគណៈសង្ឃរបស់លោក រឺ ?

-ខ្ញុំសូមលំអោនគោរពលោកម្ចាស់ដើម្បីជំរាបលោកម្ចាស់ថានេះជាសារផ្ទាល់ខ្លួនទាន។

*តូរ៉ាណាកា* ធ្វើជាពឹងគិតពីពាក្យសំដីនេះ ថ្វីត្បិតតែលោកបានកំនត់ហើយជាស្រេចថាតើជំនួបនេះនឹងប្រព្រឹត្តទៅយ៉ាងដូចម្តេច ហើយនឹងបានផ្តល់នូវការណែនាំច្បាស់លាស់ហើយជាស្រេចដល់ *ប្លាក់ថន* ថាតើត្រូវមានអាកប្បកិរិយាបែបណា និងត្រូវនិយាយពីអ្វីនោះ។ លោកពោលឡើង :

- ល្អណាស់ -លោកងាកទៅរក *ប្លាក់ថន -អាន់ជីន-សាន* លោកអាចត្រលប់ទៅវិញ



www.budinst.gov.kh www.elibraryofcambodia.org

បានហើយ ។ ចាំបន្តិចទៀតយើងនឹងនិយាយគ្នាថែមទៀត ។

- បាទ លោកម្ចាស់ -*ប្លាក់ថុន* តប -សូមទោស *សំពៅខ្មៅ* ។ មកដល់ *ណាកាសាគី* ហើយ ?

- អូហ៍ មែន ។ បាទ សូមអរគុណ -លោកតបទាំងរីករាយនៅក្នុងចិត្តដោយហេតុសំនួររបស់ *ប្លាក់ថុន* មិនបានបង្ហាញអោយឃើញជាការរៀបឆាកជាមុនឡើយ -នែ *ឈូតូ-សាន* តើសំពៅនោះចូលផែហើយ រឺនៅ ?

*អាល់វីតូ* សែនកាន់ភាំងនឹងការនិយាយភាសាជប៉ុនរបស់ *ប្លាក់ថុន* ហើយលោករឹតតែច្របូកច្របល់ថែមទៀតនឹងសំនួរចុងក្រោយនេះ :

- បាទ លោកម្ចាស់ សំពៅបានចូលផែតាំងពីដប់បួនថ្ងៃមុនម្ល៉េះ ។

- ដប់បួនថ្ងៃហើយ ? -*តូរ៉ាណាកា* ពោល -លោកស្តាប់បានទេ *អាន់ជិន-សាន* ?

- ស្តាប់បាន ។ សូមអរគុណ ។

- ល្អ ។ រឿងផ្សេង១ទៀតលោកអាចសួរ *ឈូតូ-សាន* នៅពេលក្រោយ *នេ* ?

- បាទ ទាន ។ សូមលោកម្ចាស់អធ្យាស្រ័យ ទាន ។

រួច *ប្លាក់ថុន* ក៏ក្រោកឈរលំអោនខ្លួនគោរព ហើយដើរថយថយចេញទៅ ។

*តូរ៉ាណាកា* តាមសំលឹងមើល *ប្លាក់ថុន* រួចលោកនិយាយថា :

- ក្នុងឋានៈជាមេចោរសមុទ្ទ មនុស្សនេះគួរត្រូវបានយកចិត្តទុកដាក់ជាទីបំផុត ។ អីលូវនេះដំបូងបង្អស់ សូមនិយាយប្រាប់ខ្ញុំពីរឿង *សំពៅខ្មៅ* បន្តិចមើល ។

- សំពៅនេះបានមកដល់ដោយសុវត្ថិភាព ហើយដោយមានផ្ទុកទំនិញសូត្រដ៏ច្រើនបំផុតមិនដែលមាន -*អាល់វីតូ* ប្រឹងធ្វើហាក់ដូចជារីករាយណាស់ -កិច្ចសំរុះសំរួលរវាងលោកម្ចាស់ *ហារីម៉ា* លោកម្ចាស់ *គីយ៉ាម៉ា* លោកម្ចាស់ *អ៊ីណូស៊ី* នឹងលោកម្ចាស់នោះ គឺបានចូលជាធរមាន ។ ឆ្នាំក្រោយនេះឃ្លាំងរបស់លោកម្ចាស់នឹងកើនឡើងរាប់ម៉ឺន *កូបាន* ទៀតជាមិនខាន ។ គុណភាពសូត្រលើកនេះ គឺល្អផ្តាច់តែម្តង ទាន ។ ខ្ញុំបានយកបញ្ជីទំនិញមកសំរាប់អោយមេការលោកម្ចាស់ផងដែរ ។ លោកមេបញ្ជាការ *វ័ករីរ៉ា* បានផ្តាំផ្ញើនូវការគោរពរបស់លោកចំពោះលោកម្ចាស់ហើយ



www.budinst.gov.kh www.elibraryofcambodia.org

សង្ឃឹមថានឹងបានជួបលោកម្ចាស់ដោយផ្ទាល់នៅពេលឆាប់ៗនេះជាមិនខាន ។ ហើយក៏មានមូលហេតុដែលខ្ញុំមានការយឺតយ៉ាវក្នុងការមកជួបលោកម្ចាស់ផងដែរ ។ នោះគឺ ព្រះតេជគុណគណៈសង្ឃបានបញ្ជូនខ្ញុំយ៉ាងប្រញាប់ប្រញាល់ពី *អូសាកា* ទៅ *ណាកាសាគី* ដើម្បីចាត់ចែងអោយច្បាស់ថាអ្វីៗប្រព្រឹត្តទៅដោយឥតខ្ចោះ ។ ហើយនៅពេលដែលខ្ញុំចាកចេញពី *ណាកាសាគី* ពួកយើងបានលឺថាលោកម្ចាស់បានចាកចេញពី *យេដូ* ទៅ *អ៊ីស៊ូ* ហើយ ដោយហេតុនេះ ខ្ញុំក៏រូតរះមកទីនេះយ៉ាងប្រញាប់បំផុតទៅតាមលទ្ធភាពដែលយើងមាន ដោយធ្វើដំណើរតាមផ្លូវទឹករហូតដល់កំពង់ផែ *នីម៉ាស៊ូ* រួចបន្តរហូតមកទៀតតាមផ្លូវគោក ។ នៅឯ *មីស៊ីម៉ា* ខ្ញុំក៏វាក់អើនឹងលោកម្ចាស់ *សាគាគី* ហើយក៏សូមអនុញ្ញាតគាត់រួមដំណើរជាមួយតែម្តងទៅ ។

- សំពៅរបស់លោកនៅ *នីម៉ាស៊ូ* នៅឡើយទេ រឺ ?

- បាទ លោកម្ចាស់ ។ វានៅរង់ចាំខ្ញុំនៅទីនោះ ។

- ល្អ ។

លោកវ៉ាពីងគិតមួយសន្ទុះ ថាតើគួរបញ្ជូន *ម៉ារីកូ* តាមសំពៅនេះទៅ *អូសាកា* រឺអត់ រួចលោកសំរេចថានឹងដោះស្រាយរឿងនេះនៅពេលក្រោយចុះ ។ លោកពោលបន្ត :

- យប់នេះ សូមលោកប្រគល់បញ្ជីមុខទំនិញទៅមេការខ្ញុំចុះ ។

- បាទ ទាន ។

- កិច្ចព្រមព្រៀងពីរឿងទំនិញឆ្នាំនេះបានឯកភាពគ្នារួចអស់ហើយមែនទេ ?

- បាទ ចប់សព្វគ្រប់ហើយ ។

- ល្អ ។ អីលូវនិយាយពីរឿងមួយទៀត ។ អារឿងដែលសំខាន់បំផុតជាងគេ ។

ដៃរបស់ *អាលវីតូ* ឡើងស្ងួតតែម្តង :

- ទាំងលោកម្ចាស់ *គីយ៉ាម៉ា* ទាំងលោកម្ចាស់ *អូណូស៊ី* មិនព្រមបោះបង់ចោលលោកមេទ័ព *អូណូស៊ី* ឡើយ ។ ខ្ញុំមានការសោកស្តាយណាស់ ។ ពួកគេមិនព្រមចូលដៃជាមួយលោកឡើយ ថ្វីត្បិតតែមានសំនើយ៉ាងខ្លាំងក្លាបំផុតពីពួកយើងខ្ញុំក្តី ។

សំលេង *តូរ៉ាណាកា* ចុះទាប និងពោរពេញដោយភាពសាហាវ :



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំបានប្រាប់ហើយថា ខ្ញុំត្រូវការច្រើនពីការធ្វើសំនើទៅទៀត !

- ខ្ញុំមានការសោកស្តាយណាស់ ដែលនាំដំណឹងអាក្រក់នៅក្នុងរឿងនេះ តែពួកគេទាំងពីរនាក់នេះ គ្មានអ្នកណាមួយដែលយល់ព្រមជាសាធារណៈ.........

- អូហ៍ លោកនិយាយថាជាសាធារណៈ ! ចុះយ៉ាងម៉េចដែរ បើជាសំងាត់វិញ ?

- ជាសំងាត់វិញ ក៏ពួកគេនៅតែរឹងរូសដូចជាសាធា......

- លោកនិយាយជាមួយពួកគេជាមួយគ្នា រឺនិយាយដោយឡែក១ពីគ្នា ?

- ជាធម្មតាទេ គឺនិយាយរួមគ្នាផង និយាយដោយឡែក១ពីគ្នាផង។ ប៉ុន្តែរាល់សំនើរបស់យើងត្រូវ........

- លោកគ្រាន់តែ " ស្នើ " នូវការប្រកាន់យកសកម្មភាព ? ហេតុអីបានជាលោកមិនបញ្ជាទៅពួកគេ ?

- នេះដូចជាព្រះតេជគុណគណៈអធិការសង្ឃបាននិយាយហើយ ទាន យើងមិនអាចបញ្ជាទៅដៃមីញ៉ូ ណាម្នាក់ រឺក៏ទៅ........

- តែលោកអាចចេញបញ្ជាទៅអ្នកដើងវិហារលោកបាន *រឺ* ?

- ពិតមែនហើយ ទាន។

- តើលោកមានគំរាមបណ្តេញអ្នកទាំងពីរ ចេញពីសហគមន៍សាសនារបស់លោកផងទេ ?

- អត់មានទេ ទាន។

- ហេតុអី ?

- ពីព្រោះពួកគេឥតមានបានប្រព្រឹត្តអំពើបាបធមិដ៏ធ្ងន់ធ្ងរណាមួយឡើយ។

សំដីរបស់បព្វជិត *អាល់វីតូ* នៅពេលនិយាយពាក្យនេះមានភាពម៉ឺងម៉ាត់ដូចដែលរូបលោក និង *ដែឡាក្វា* បានឯកភាពគ្នាយ៉ាងដូចនោះដែរ។ ប៉ុន្តែបេះដូងរបស់លោកលោតស្ទើរធ្លាយចេញតាមមាត់ ហើយលោកស្អប់បំផុតប្រការដែលលោកត្រូវដើរតួជាអ្នកនាំដំណឹងអាក្រក់នេះឯង។ ហើយអ្វីដែលអាក្រក់ទៅទៀតនោះ គឺថាលោកម្ចាស់ *បារីម៉ា* ដែលជាម្ចាស់ស្របច្បាប់



www.budinst.gov.kh www.elibraryofcambodia.org

នៃទីក្រុង *ណាកាសាគី* នោះ បានលួចប្រាប់ពួកលោកថា សម្បត្តិទ្រព្យ និងឥទ្ធិពលដ៏មហាធំធេងរបស់លោកនោះត្រូវបានដាក់អោយ *អ៊ីស៊ីដូ* ប្រើប្រាស់ទាំងអស់ហើយ ។ លោកបន្ត :

- សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ប៉ុន្តែខ្ញុំមិនមែនជាអ្នកចាត់ចែងច្បាប់ព្រះជាម្ចាស់ទេ ក៏ដូចជាលោកម្ចាស់មិនមែនជាអ្នកចាត់ចែងក្រុម *ប៊ូស៊ីដូ* រមាគ៌ានៃអ្នកចំបាំងអ៊ីចឹងដែរ ។ ពួកយើងត្រូវតែអនុលោមខ្លួន......

- លោកបណ្តេញមនុស្សកំប៉ិកកំប៉ុកចេញពីសហគមន៍សាសនារបស់លោក ដោយសារសកម្មភាពចម្លែក ដូចរឿងរូមរក្សជាដើម ប៉ុន្តែនៅពេលដែលមនុស្សរបស់លោកឯងធ្វើសកម្មភាពមិនចម្លែក រឺថាធ្វើសកម្មភាពបែបក្បត់ទៅវិញនោះ នៅពេលដែលខ្ញុំត្រូវការជំនួយរបស់លោក ហើយជាជំនួយបន្ទាន់ទៀតនោះ ហើយក្នុងឋានៈខ្ញុំជាមិត្តរបស់លោកទៅទៀត លោកគ្រាន់តែធ្វើ " សំនើ " ទៅវិញ ។ តើលោកមានបានយល់ពីភាពធ្ងន់ធ្ងរនៃរឿងនេះទេ *នេ?*

- ខ្ញុំមានការសោកស្តាយណាស់ លោកម្ចាស់ ។ សូមអភ័យទោសដល់ខ្ញុំផង ប៉ុន្តែ.......

- ប្រហែលជាខ្ញុំនឹងមិនអភ័យទោសអោយលោកបានទេ *ល្វូត-សាន -តូរ៉ាណាកា* តប -ដូចដែលបាននិយាយពីមុនរួចហើយ ម្នាក់ៗត្រូវតែជ្រើសរើសថា តើត្រូវកាន់ខាងណា ។

- ពិតហើយ ដែលថាពួកយើងនៅខាងលោកម្ចាស់ ។ ប៉ុន្តែពួកយើងមិនអាចបញ្ជាលោកម្ចាស់ *គីយ៉ាម៉ា* រឺលោកម្ចាស់ *អូណូស៊ី* អោយធ្វើនេះ ធ្វើនោះបាន......

- សំនាងដែរ ដែលខ្ញុំអាចបញ្ជាគ្រិស្តសាសនិករបស់ខ្ញុំបាន ។

- លោកម្ចាស់មានប្រសាសន៍ថាម៉េច ?

- ខ្ញុំអាចបញ្ជាអោយដោះលែង *អាន់ជីន-សាន* អោយមានសេរីភាពឡើងវិញ ។ មានសេរីភាពជាមួយនឹងសំពៅរបស់គេ ។ ជាមួយនឹងកាណុងរបស់គេ ។

- សូមលោកម្ចាស់ប្រយ័ត្នប្រយែងចំពោះរឿងវានេះ ទាន ។ អាតៃកុងនេះគឺចំជាមហាឆ្លាតវាងវៃ តែជាទមិឡ ជាចោរសមុទ្រ ហើយជាមនុស្សដែលមិនត្រូវទុកចិត្តឡើយ.....

- នៅទីនេះ *អាន់ជីន-សាន* ជាសាមូរ៉ៃ និងជា *ហាតាម៉ូតូ*។ នៅសមុទ្រគេអាចជាចោរសមុទ្រ ។ បើគេជាចោរសមុទ្រខ្ញុំគិតថា នឹងអូសទាញពួក *កករស៊ែរ* និងពួក *វ៉ាកូ* ជាច្រើនទៀតអោយ



www.budinst.gov.kh www.elibraryofcambodia.org

ទៅជាមួយគេ។ អ្វីដែលជនបរទេសម្នាក់បានធ្វើទៅឯលំហសមុទ្រនោះជារឿងរបស់គេ *ទេ* ? គោលជំហរនេះជាគោលនយោបាយតាំងពីដើមមករបស់យើង *ទេ*?

*អាលវីតូ* រក្សាភាពស្ងៀមស្ងាត់ ហើយប្រឹងសញ្ជឹងគិតរកច្រកចេញ។ គ្មានអ្នកណាម្នាក់គ្រោងគិតថា អា អ៊ិញគីលីស នេះបានក្លាយជាមនុស្សជំនិតបែបនេះនឹង *តូរ៉ាណាកា* ឡើយ។

*តូរ៉ាណាកា* សួរបន្ត ៖

- *វៃមីញ៉ូ* គ្រិស្តសាសនិកទាំងពីរនាក់នោះ មិនព្រមជាប់កិច្ចសន្យាអ្វីទាំងអស់.....ទោះជាសំងាត់ក៏ដោយ រឺ ?

- អត់ទេ លោកម្ចាស់។ ពួកយើងបានសាកល្បងគ្រប់......

- គ្មានសម្បទានអីទាំងអស់ ?

- គ្មានទេ ទាន។

- គ្មានការផ្លាស់ប្តូរគ្នា គ្មានការសំរុះសំរួល គ្មានអ្វីទាំងអស់ ?

- គ្មានអ្វីទាំងអស់ ទាន។ ពួកយើងបានសាកល្បងការទាក់ទាញទឹកចិត្ត និងការបញ្ចុះបញ្ចូលគ្រប់បែបយ៉ាងទាំងអស់ហើយ។ សូមលោកម្ចាស់ជឿខ្ញុំចុះ -*អាលវីតូ* ដឹងថាលោកកំពុងនៅក្នុងអង្គប់ហើយៗភាពជ្រួលច្របល់របស់លោកខ្លះបានបង្ហាញចេញយ៉ាងច្បាស់ក្រលែត -បើសិនជាខ្ញុំវិញ ខ្ញុំពិតជានឹងគំរាមបណ្តេញពួកនេះចេញពីសហគមន៍សាសនិកជាមិនខាន ថ្វីត្បិតតែនេះជាការគំរាមកំហែងបោកបញ្ឆោតក៏ដោយព្រោះថាខ្ញុំមិនអាចអនុវត្តវាបានទេ លើកលែងតែពួកគេនោះបានប្រព្រឹត្តនូវអំពើបាបធម៌ដ៏ធ្ងន់ធ្ងរ ហើយមិនព្រមសារភាពលាងបាបនោះ។ តែសូម្បីតែការគំរាមកំហែងដើម្បីយកចំនេញផ្នែកអាណាចក្របែបនេះក្តី ក៏ជាការធ្ងន់ធ្ងរណាស់ទៅហើយចំពោះរូបខ្ញុំ។ នេះជាបាបធម៌មួយដ៏ធ្ងន់ធ្ងរណាស់។ ខ្ញុំអាចត្រូវចុះនរកជារៀងរហូតផងក៏មិនដឹង។

- លោកនិយាយថា បើសិនជាពួកគេនោះបានធ្វើបាបធម៌ ប្រឆាំងនឹងជំនឿរបស់ពួកលោកៗនឹងបណ្តេញពួកគេភ្លាមមែនរឺ ?

- បាទ ពិតមែន។ តែនេះមិនមែនមានន័យថា ធ្វើបែបនេះនឹងអាចអូសទាញពួកគេមក



www.budinst.gov.kh www.elibraryofcambodia.org

នៅខាងលោកម្ចាស់បានឡើយ ។ សូមលោកម្ចាស់អភ័យទោសដល់ខ្ញុំផង ប៉ុន្តែពួកគេ.......ពួកគេប្រឆាំងជាមួយលោកទាំងស្រុងតែម្តងនៅក្នុងខណៈនេះ ។ អោយខ្ញុំសូមទោស តែនេះជាការពិត ។ ពួកគេទាំងពីរនាក់បានបញ្ជាក់ច្បាស់លាស់ណាស់ ទាំងជារូម ទាំងនៅដោយឡែក ។ចំពោះមុខព្រះជាម្ចាស់ ខ្ញុំសូមបួងសួងសូមអោយពួកគេទាំងពីរប្តូរចិត្តគំនិតឡើងវិញ ។ ពួកយើងបានសន្យាជាមួយលោក នៅចំពោះមុខព្រះជាម្ចាស់ ថាព្រះតេជគុណគណៈអធិការសង្ឃ និងខ្ញុំ នឹងប្រឹងប្រែងសាកល្បង ។ យើងបានបំពេញនូវពាក្យសន្យារបស់យើង ហើយដោយមានព្រះជាម្ចាស់ជាសាក្សីយើងទទួលបរាជ័យ ។

- បើអីចឹង ខ្ញុំគួរតែចាញ់ -*គូរ៉ាណាកា* តប -លោកដឹងដែរមែនទេ ? បើសិនជាពួកគេពួតដៃជាមួយ *អ៊ីស៊ីដូ* ពួក *ដៃមីញ៉ូ* គ្រិស្តសាសនិកទាំងអស់នឹងនៅខាង *អ៊ីស៊ីដូ* ទាំងអស់ដែរ ។ អ៊ីចឹងទៅ ខ្ញុំមានតែផ្លូវចាញ់ប៉ុននោះ ។ សាមូរ៉ៃម្តែទល់នឹងសាមូរ៉ៃរបស់ខ្ញុំមួយ *រទ*?

- អីចឹងមែន ទាន ។

- តើពួកគេមានផែនការយ៉ាងម៉េចដែរ ? អង្កាល់ទើបពួកគេវាយលុកខ្ញុំ ?

- ខ្ញុំមិនដឹងដែរ ទាន ។

- បើសិនជាលោកដឹង តើលោកប្រាប់ខ្ញុំទេ ?

- បាទ ប្រាប់ ទាន ។

ចាំតែប្រាប់ទៅចុះ -*គូរ៉ាណាកា* គិតនៅក្នុងចិត្ត ។ រួចលោកសំលឹងមើលកាត់ស្បែរាត្រី ។ ក្តីកង្វល់សង្កត់លោកពាប់តែម្តង ។ តើត្រូវប្រកាស *ភ្លៀងមេឃក្រហម* រឺក៏យ៉ាងណា ? លោកដណ្តឹង សួរទាំងអស់សង្ស័យនៅក្នុងចិត្ត ។ តើត្រូវបើកការវាយលុកដ៏លេលា និងដែលច្បាស់ជាបរាជ័យនេះទៅលើទីក្រុង ក្យូតូ រឺទេ ?

លោកសែនស្អប់ទ្រុងដ៏អាម៉ាស់ដែលលោកកំពុងស្ថិតនៅក្នុងនេះជាពន់ពេក ។ ដូចជាលោកម្ចាស់ *តៃក្វូ* និង *គូរ៉ាដា* មុនលោកនេះដែរ លោកត្រូវបិទភ្នែកចំពោះវត្តមានរបស់ពួកបព្វជិតកាតូលិចទាំងនេះ ពីព្រោះពួកបព្វជិតមិនអាចកាត់ផ្តាច់បានពីពួកឈ្មួញបំកទុយកាល់បានដូចជារុយនិងសេះយ៉ាងនោះដែរ ហើយពួកបព្វជិតទាំងនេះ តែងមានឥទ្ធិពលលើសលប់ទាំងផ្នែកអា



www.budinst.gov.kh www.elibraryofcambodia.org

ណាចក្រ ទាំងផ្ទៃកចម្មចក្រលើរឿងសាវ័កដ៏សែនលំបាកត្រួតត្រារបស់ខ្លួន។ គ្មានបព្វជិត គ្មានការជួញដូរ។ សុច្ចន្ទៈរបស់ពួកនេះក្នុងការដើរតួជាអ្នកតថ្លៃ និងជាឈ្មួញកណ្ដាល គឺមានតួនាទីស្លាប់រស់នៅក្នុងសកម្មភាពប្រតិបត្តិការរបស់ *សំពៅខ្មៅ* ពីព្រោះពួកនេះចេះភាសា ហើយទាំងសងខាងសុទ្ធតែទុកចិត្តលើ។ បើសិនជាគេហាមឃាត់មិនអោយពួកបព្វជិតទាំងនេះចូលមកក្នុងនគរពួកអ្នកចុងស្រុកទាំងអស់នឹងចាកចេញពីចក្រភពតាមតត្រុក ហើយលែងវិលមកវិញ។ លោកនៅចាំថាមានពេលមួយនោះ លោកម្ចាស់ *រ៉េត្វ* បានសាកល្បងកំចាត់ពួកបព្វជិតចេញ ទន្ទឹមនឹងជំរុញលើកទឹកចិត្តពាណិជ្ជកម្ម។ ក្នុងរយៈពេលពីរឆ្នាំ គឺគ្មាន *សំពៅខ្មៅ* សោះឡើយ។ ពួកយកការណ៍បានរាយការណ៍មកថា មេបព្វជិតធំដែលបោះទីតាំងនៅឯ *ម៉ាកាវ* ប្រៀបបីដូចជាពីងពាងពិសដ៏កំនាចនោះ បានបញ្ជាមិនអោយមានការជួញដូរតទៅទៀត ដើម្បីសងសឹកអាជ្ញាបណ្ដេញរបស់លោកម្ចាស់ *រ៉េត្វ* ដោយមេបព្វជិតនេះដឹងច្បាស់ថានៅទីបំផុតលោកម្ចាស់ *រ៉េត្វ* ត្រូវតែអោនក្បាលដោយខ្លួនឯង។ នៅឆ្នាំទីបី លោកម្ចាស់ *រ៉េត្វ* ត្រូវទទួលស្គាល់នូវអ្វីដែលចៀសមិនផុត ហើយក៏បានអញ្ជើញពួកបព្វជិតអោយត្រលប់ចូលស្រុកវិញទាំងបិទភ្នែកធ្វើមិនដឹងមិនលឺពីអាជ្ញារបស់លោកផ្ទាល់ និង ពីការបំផុសបំផុលទាំងឡាយដែលពួកបព្វជិតបានបង្កឡើងថែមទៀតផង។

គ្មានច្រកណាចេញផុតពីគថភាពនេះទេ -*តូរ៉ាណាកា* គិតនៅក្នុងចិត្ត។ គ្មានសោះតែម្ដង។ អញមិនជឿសំដី *អាន់ជីន-សាន* ទេ។ *អាន់ជីន-សាន* និយាយថា ការជួញដូរគឺជាការងារសារវ័ន្ត ទាំងសំរាប់ពួកចុងស្រុក ទាំងសំរាប់ពួកយើង ហើយភាពលោភលន់ស្រវាស្រទេញរបស់ពួកអ្នកចុងស្រុកនឹងធ្វើអោយពួកវាជួញដូរដដែល ចង់យើងធ្វើអីជាមួយពួកបព្វជិតវាក៏ដោយ។ រឿងនេះប្រថុយប្រថានហួសហេតុមិនគួរសាកល្បងលេងនោះទេ ហើយអញក៏គ្មានពេលវេលា និងអំនាចដើម្បីនឹងធ្វើរឿងនេះផង ។ យើងសាកពិសោធន៍ម្ដងហើយៗយើងត្រូវបរាជ័យ ។ នរណាទៅដឹងបាន ? ប្រហែលពួកបព្វជិតអាចរង់ចាំយើងដល់ដប់ឆ្នាំផងក៏មិនដឹង។ ពួកវាសាហាវឃោរឃៅអាចធ្វើបែបនេះបាន។ បើពួកបព្វជិតបញ្ជាថា មិនអោយមានការជួញដូរ អញជឿថាគឺពិតជាគ្មានការជួញដូរមែន។ពួកយើងមិនអាចរង់ចាំបានដប់ឆ្នាំទេ។ តែប្រាំឆ្នាំក៏មិនបានផង។



www.budinst.gov.kh www.elibraryofcambodia.org

ហើយបើយើងបណ្តេញពួកចុងស្រុកទាំងអស់ចេញពីនគរ យើងត្រូវការយ៉ាងតិចណាស់ក៏ម្ភៃឆ្នាំដែរដើម្បីពួកអ្នកចុងស្រុកអង់គ្លេសមកបំពេញចន្លោះនេះ ហើយនេះបើសិនជា *អាន់ជីន-សាន* និយាយតែការពិតទាំងអស់ផង ហើយនឹងបើសិន-ពាក្យ "បើ" ដ៏មហាសែនធំមួយ -ជាពួកចិនព្រមធ្វើពាណិជ្ជកម្មជាមួយពួកនេះប្រឆាំងពួកចុងស្រុកខាងត្បូងទៀតផង។ អញមិនជឿថា ពួកចិននឹងផ្លាស់ប្តូរវិក្រម (pattern) របស់គេទេ។ ពួកចិនមិនដែលដូរវិក្រមគេជាដាច់ខាត។ ម្ភៃឆ្នាំគឺយូរណាស់។ ដប់ឆ្នាំគឺយូរណាស់។

គ្មានច្រកណាចេញផុតពីគថភាពនេះទេ។ វិតថភាពដ៏អាក្រក់បំផុត ពោលគឺស្រមោលអន្ធការដែលបានធ្វើអោយរន្ធត់ ភាន់ភាំងជាសំងាត់ *តូរ៉ាំង* និង *តែកូ* ហើយដែលកំពុងតែបង្ហាញខ្លួនមកទៀតហើយនៅពេលនេះ : នោះគឺបព្វជិតគ្រិស្តសាសនាដ៏ងប់ងុល និងមិនចេះខ្លាចអ្វីទាំងនេះ នៅពេលណាដែលត្រូវគេបង្ខំខ្លាំងពេក នឹងប្រើឥទ្ធិពលរបស់ខ្លួន ព្រមទាំងអានុភាពពាណិជ្ជកម្ម និងសមុទ្ររបស់ពួកគេទាំងអស់ដើម្បីគាំទ្រ *វ៉េមីញ៉ូ* គ្រិស្តសាសនិកដ៏មហិមាណាម្នាក់។ ជាងនេះទៅទៀតពួកនេះអាចបំផុសអោយមានការវាយលុកលុយរបស់ពួក *កុងគីស្តាឌ័រ* ដ៏ងប់ងុលប្រដាប់ទៅដោយកាំភ្លើងមួស្កេទំនើបបំផុតដើម្បីគាំទ្រ *វ៉េមីញ៉ូ* គ្រិស្តសាសនិកម្នាក់នេះក៏តែបាន។ ដូចដែលពួកគេហៀបតែនឹងធ្វើនៅក្នុងពេលចុងក្រោយនេះ។ បើតែពួកនោះទទេ ទោះជាពួកអ្នកចុងស្រុកនិងពួកបព្វជិតរបស់គេមកលុកលុយក្នុងចំនួនប៉ុន្មានក៏ដោយ ក៏ពួកនោះមិនមែនជាគ្រោះគំរាមកំហែងអ្វីដល់កំលាំងទ័ពរួមគ្នាដ៏ច្រើនលើសលប់របស់ពួកយើងដែរ។យើងបានកំទេចវ៉ូងទ័ពរបស់ *គូប៊ីឡាយខាន់* (*) ហើយយើងអាចចាត់ការជាមួយពួកឈ្លានពានណាក៏បានដែរ។ តែនៅពេលណាដែលពួកនេះ ចងសំព័ន្ធមិត្តជាមួយពួកយើង ដូចជា មហា *វ៉េមីញ៉ូ* គ្រិស្តសាសនិក

---

*(*) Kublai Khan (១២១៤-១២៩៤) ចៅរបស់អធិរាជ ម៉ុងហ្គោល ឈ្មោះ សង់ស៊ីខាន់ (Gengis Khan) វី តិមុយជិន ហើយដែលបានឡើងជាអធិរាជ ម៉ុងហ្គោល កាលពីឆ្នាំ ១២៦០ ដល់ឆ្នាំ ១២៩៤ គ.ស។ ព្រះចៅ គូប៊ីឡាយខាន់ បានបង្ហើយយុទ្ធនាការប្រាមប្រាបប្រទេសចិនភាគខាងត្បូង ហើយនៅគ្រប់គ្រងលើប្រទេសចិនទោះតែម្តង (គ.អ.ប)។*



www.budinst.gov.kh www.elibraryofcambodia.org

ដែលមានទ័ពសាមូរ៉ៃ ជាដើមបែបនេះ នេះគឺពិតជាផ្តល់អោយ *ដៃមីញ៉ូ* នោះមានអំនាចទាំងស្រុងលើពួកយើងទាំងអស់គ្នាជាមិនខាន ។

*គីយ៉ាម៉ា* រឺ *អូល្មូស៊ី* ? ជាការច្បាស់ណាស់នៅពេលនេះ ដែលថានេះគឺជាគំរោងរបស់ពួកបព្វជិតទាំងនេះហើយ ។ ជំរើសពេលវេលាគឺឥតខ្ចោះ ។ តែតើ *ដៃមីញ៉ូ* មួយណា ?

នៅពេលដើមដំបូង មនុស្សទាំងពីរនាក់នេះសុទ្ធតែទទួលការជួយគាំទ្ររបស់ *ហារីម៉ា* អម្ចាស់នៃតំបន់ *ណាកាសាគី*។ តែតើអ្នកណាមួយជាអ្នកលើកជ្រោងទង់ចុងក្រោយ ? *គីយ៉ាម៉ា* ហើយ ព្រោះអាគំលង់ *អូល្មូស៊ី* រស់មិនបានយូរទៀតទេ ។ ពួកគេទាំងពីរនាក់មានសាមូរ៉ៃបួនរយពាន់នាក់ មូលដ្ឋានរបស់ពួកគេនៅឯកោះ *ក្យូស៊ូ* ហើយដែលឆ្ងាយផុតពីកណ្តាប់ដៃរបស់អញទៅទៀត ។ នៅមានពួកគ្រិស្តសាសនិកប្រមាណពីប្រាំទៅប្រាំមួយរយពាន់ថែមទៀតនៅក្នុងទូទាំងនគរ ក្នុងនេះជាងពាក់កណ្តាលជាសាមូរ៉ៃចូលសាសនាគ្រិស្តតាមរយៈពួក *យេស៊ូត* ហើយនៅពង្រាយតាម គ្រប់កងទ័ពនៃពួក *ដៃមីញ៉ូ* ទាំងអស់ ។ ពួកនេះអាចក្លាយជាបណ្តាញចារបុរសឃាតក រឺពួក ក្បត់ ដ៏ទូលំទូលាយបាន នៅពេលណាដែលពួកបព្វជិតទាំងនេះបញ្ជាពួកវា ។ ហើយហេតុអីបាន ជាពួកបព្វជិតទាំងនេះមិនធ្វើបែបនេះ ? ព្រោះពួកគេមានអ្វីៗទាំងអស់ដែលគេចង់បានទៅហើយ នោះគឺអំនាចទាំងស្រុងទៅលើព្រលឹងរបស់យើង និង ទៅលើព្រលឹងទេវនគរនេះ ពោលគឺសិទ្ធិទទួលកេរជាដី និងអ្វីៗដែលមាននៅលើ រឺក្នុងដីនេះ ។ នេះដូចជា *អាន់ជីន-សាន* បានពន្យល់ប្រាប់ពីអ្វីដែលបានកើតឡើងនៅក្នុងពិភពថ្មីរបស់ពួកវាអីចឹង.......ពួកវាអូសទាញស្តេចអោយចូល សាសនាវា រួចប្រើស្តេចនេះប្រឆាំងនឹងសាច់ញាតិឯង រហូតដល់អស់ទឹកដីតែម្តង ។

គិតទៅ ពួកបព្វជិតចុងស្រុកមួយក្តាប់នេះ អាចប្រាមប្រាបយើងបានយ៉ាងងាយបំផុត ។ តើពួកនេះមានប៉ុន្មាននាក់ម៉ាទូទាំងប្រទេសជប៉ុននេះ ? ហាសិប រឺហុកសិបនាក់ ? តែពួកនេះមានអំនាច ។ ហើយពួកនេះមានជំនឿ ។ ពួកនេះត្រៀមខ្លួនស្លាប់ទាំងរីករាយដើម្បីជំនឿរបស់ខ្លួន ។ ស្លាប់ទាំងមោទនភាពប្រកបដោយសេចក្តីក្លាហាន និងដោយទន្ទេញនាមរបស់ព្រះជាម្ចាស់របស់ពួកគេនៅជាប់នឹងបបូរមាត់ ។ ពួកយើងបានឃើញហេតុការណ៍នេះនៅឯ *ណាកាសាគី* ក្នុង



www.budinst.gov.kh www.elibraryofcambodia.org

ពេលដែលបទពិសោធន៍របស់លោកម្ចាស់ *វ៉ែក្ក* ត្រូវបានបង្ហាញអោយឃើញថា ជាការភាន់ច្រលំប្រកបដោយមហន្តរាយមួយនោះ ។ នៅពេលនោះគ្មានបព្វជិតណាមួយប្រកាសដកថយពីជំនឿរបស់ខ្លួនឡើយ ។ មនុស្សរាប់ម៉ឺននាក់បានទៅមើលការដុតទាំងរស់នេះ ហើយមនុស្សរាប់ម៉ឺននាក់បានចូលទស្សនា ។ ការទទួលទារុណកម្មបែបនេះ បានផ្តល់អោយសាសនាគ្រិស្តនូវកិត្យានុភាពយ៉ាងធំធេង ហើយដែលពួកបព្វជិតគ្រិស្តសាសនារមែងទាញយកផលពីរឿងនេះជារៀងរហូត ។

ចំពោះអញ ពួកបព្វជិតទាំងនេះទទួលបរាជ័យហើយ តែនេះមិនបានធ្វើអោយពួកគេងាកចេញពីក្រលាអុករបស់គេឡើយ ។ នេះក៏ជាគថភាពដែរ ។

បើអ៊ីចឹង គឺ *គីយ៉ាម៉ា* ហើយ ។

តើផែនការត្រូវបានដាក់ចេញជាមួយ *អ៊ីស៊ីដូ* និង ជំទាវ *អូជីបា* ព្រមទាំង *យ៉ែនមុំន* ហើយ រឺ ? តើ *ហារីម៉ា* បានភ្ជាប់ខ្លួនជាមួយពួកនេះជាសំងាត់ហើយ រឺ ? តើអញគួរព្រលែង *អាន់ជីន-សាន* ដាក់ *សំពៅខ្មៅ* និង *ណាកាសាគី* ជាបន្ទាន់នេះទេ ?

តើអញគួរធ្វើយ៉ាងម៉េច ?

គ្មានអ្វីដែលត្រូវធ្វើអោយហួសពីការស្មាននោះទេ ។ ត្រូវមានខន្តី ស្វែងរកសុខដុមរមនាទុកទៅម្ខាងនូវរាល់កង្វល់ពីរឿងអញ រឺឯង ពីរឿងរស់ រឺស្លាប់ ពីរឿងការបំភ្លេច រឺបរលោក ពីរឿងបច្ចុប្បន្ន រឺអនាគត ហើយរៀបចំគំរោងការថ្មីមួយវិញ ។ តែផែនការយ៉ាងម៉េច ? លោកស្ទើរស្រែកជំទាលដោយការអស់សង្ឃឹម ។ គ្មានផែនការណាមួយសោះតែម្តង !

-គ្មានអ្វីធ្វើអោយខ្ញុំលំបាកចិត្តជាងដែលឃើញមនុស្សទាំងពីរនាក់នេះនៅជាមួយសត្រូវពិតប្រាកដនោះទេ ។

- ខ្ញុំសូមស្បថថា ពួកយើងបានប្រឹងប្រែងណាស់ ទាន -*អាល់វីតូ* និយាយទាំងសំលឹងមើល *តូរ៉ាណាកា* យ៉ាងអាណិតអាសូរ ។

- បាទ ខ្ញុំជឿហើយ ។ ខ្ញុំជឿថា លោកនិងគណៈអធិការសង្ឃបានគោរពតាមពាក្យសន្យាដ៏ឧឡារិករបស់ខ្លួន ដោយហេតុនេះ ខ្ញុំត្រូវតែគោរពពាក្យសន្យារបស់ខ្ញុំដែរ ។ លោកអាចចាប់ផ្តើមសាងសង់វិហាររបស់លោកនៅឯ *យេដូ* បានហើយ ។ ដីត្រូវបានទុកជូនហើយ ។ ខ្ញុំមិន



www.budinst.gov.kh www.elibraryofcambodia.org

អាចខាយ៉ាងពួកបព្វជិតឯទៀត គឺពួកបព្វជិតទុកសក់នោះមិនអោយចូលមកក្នុងចក្រភពនេះបានទេ តែយ៉ាងហោចណាស់ ខ្ញុំអាចធ្វើអោយពួកនេះមិនត្រូវបានបស្វាគមន៍នៅលើទឹកដីដែលខ្ញុំគ្រប់គ្រងបានដែរ ។ ពួកចុងស្រុកថ្មីៗទៀត ក៏មិនត្រូវបានស្វាគមន៍ផងដែរទេ នេះបើសិនជាមានពួកនេះមក ។ ចំនែក *អាន់ជីន-សាន* វិញ.....-*តូរ៉ាណាកា* ញាក់ស្មា - តើមានពេលប៉ុន្មានទៀតចំពោះរឿងទាំងនេះ........ អ្ហើយ នេះជា *កាម៉ា នេ* ?

នៅក្នុងចិត្ត *អាលវីតូ* អរគុណព្រះជាម្ចាស់ដែលបានបង្ហាញមេត្តាធម៌បែបនេះ ។ លោកឆ្លើយតបទាំងរដិបរដុប :

- សូមអរគុណ លោកម្ចាស់ ។ខ្ញុំដឹងថាលោកម្ចាស់ពិតជាមិនស្ដាយក្រោយឡើយ ។ ខ្ញុំសូមបួងសួងសុំអោយសត្រូវរបស់លោកម្ចាស់ ប៉ើងរលាយខ្ចាត់ខ្ចាយដូចជាអង្កាម ហើយសូមលោកម្ចាស់ទទួលបានទូវរង្វាន់ដែលព្រះជាម្ចាស់ប្រទានដល់លោកម្ចាស់ ។

- ខ្ញុំសូមលោកអភ័យទោសដល់សំដីរម៉ាំងរម៉ោករបស់ខ្ញុំផង ។ នេះជាសំដីដែលនិយាយនៅក្នុងពេលគ្រេវគ្រោចតែប៉ុន្មោះ ។ វាមានច្រើន......-*តូរ៉ាណាកា* ក្រោកឈរឡើងទាំងលំបាក -លោកបានទទួលការអនុញ្ញាតពីខ្ញុំ ដើម្បីធ្វើការប្រជុំសូត្រធម៌នៅពេលស្អែកនេះហើយណាស់លាញ់ចាស់ ។

- សូមអរគុណ លោកម្ចាស់ -*អាលវីតូ* លំអោនខ្លួនយ៉ាងទាបទាំងក្នុងចិត្តអាណិតដល់មនុស្សម្នាក់ដែលធ្លាប់តែពោរពេញទៅដោយភាពរុងរឿង -សូមអរគុណលោកម្ចាស់យ៉ាងអស់ពីចិត្តពីថ្លើម ។ សូមអាទិទេពតាមថែរក្សាលោក ។

*តូរ៉ាណាកា* ដើរចូលទៅក្នុងតៀម ដោយមានពួកការពារតាមពីក្រោយផង ។

- *ណាកា-សាន* !

- បាទ ពុក ! -យុវជនឆ្លើយតបដោយរូសរាន់ចេញមកជួបនឹងឪពុកខ្លួនផង ។

- អ្នកស្រី *ម៉ារីកូ* នៅឯណា ?

- នៅឯនុះ ជាមួយ *ប៊ុនតារ៉ូ-សាន*។

មាត់និយាយ ដៃរបស់ *ណាកា* លើកចង្អុលទៅផ្ទះតែមួយ ដែលមានភ្លើងផ្លុងៗស្ថិតនៅ



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងសួនច្បារ ហើយដែលមានស្រមោលមនុស្សស្ងុង១នៅក្នុងនោះ ។ គេសួរទៅឪពុក :

- តើខ្ញុំត្រូវបញ្ឈប់ *ចា-ណូ-យូ* នេះទេ ?

*ចា-ណូ-យូ* គឺជាពិធីទទួលទានទឹកតែមួយដែលមានលក្ខណៈយ៉ាងផ្លូវការ និង ពោរពេញដោយលក្ខណៈយ៉ាងពិធីការ ។ *តូរ៉ាណាកា* តប :

- ទេ មិនត្រូវជ្រៀតជ្រែកពិធីនេះទេ ។ ចុះ *អូមី-សាន* និង *យ៉ាប៊ូ-សាន* នៅឯណា ?

- នៅក្នុងតៀមរបស់ពួកគេ ពុក ។

*ណាកា* ចង្អុលទៅផ្ទះទាបវែងមួយដែលនៅម្ខាងស្ទឹង ។

- អ្នកណារើសយកផ្ទះណឹង ?

- ខ្ញុំជាអ្នករើស ពុក ។ អោយខ្ញុំសូមទោស ។ ពុកបានអោយខ្ញុំរកផ្ទះសំនាក់អោយពួកនេះនៅឯនាយស្ពាន តើខ្ញុំស្តាប់ច្រលំ រឺ ?

- ចុះ *អាន់ជីន-សាន* ?

- គាត់នៅក្នុងបន្ទប់របស់គាត់ ។ គាត់នៅរង់ចាំក្រែងពុកត្រូវការគាត់ ។

ជាថ្មីម្តងទៀត *តូរ៉ាណាកា* គ្រវីក្បាល :

- ពុកជួបគាត់នៅថ្ងៃស្អែក ។

រួចបន្ទាប់ពីឈប់បង្អង់បន្តិចមក លោកក៏ពោលឡើងក្នុងសំលេងមួយដូចជានៅសែនឆ្ងាយ :

- ពុកទៅមុជទឹកសិនអីលូវនេះ ។ រួចពីនេះរហូតដល់ភ្លឺ ពុកមិនចង់អោយអ្នកណាមករំខានពុកទេ លើកលែងតែ.......

*ណាកា* រង់ចាំយ៉ាងរសាប់រសល់ ភ្នែកឃ្លាំមើលឪពុកដែលសំលឹងទៅទីឆ្ងាយបែបស្លឹ ។ គេសែនភ្ញាក់ផ្អើលនឹងអាកប្បកិរិយារបស់ឪពុកគេជាពន់ពេក :

- ពុក អត់មានអីទេអ្ហ៎ ?

- ថាម៉េច ? អូហ៍ ណឹងហើយ......ពុកអត់មានអីទេ ។ ហេតុអីបានជាសួរអ៊ីចឹង ?

- អត់មានហេតុអីទេ ។ សូមទោស ពុក ។ តើពុកនៅតែចង់ទៅបរបាញ់នៅពេលភ្លឺ



www.budinst.gov.kh www.elibraryofcambodia.org

ទៀតរឺទេ ?

- បរបាញ់ ? អើមែន នេះជាគំនិតល្អមែន។ អរគុណកូនឯងដែលជួយផ្ដល់គំនិតនេះមកពុក។ ពិតមែនហើយ អានេះពិតជាល្អមែន។ រៀបចំចាត់ចែងទៅ។ ល្អរាត្រីសួស្ដី..... អូហ៍ មែនហើយ *ល្ងូត្ង-សាន* បានទទួលការអនុញ្ញាតពីពុកដើម្បីរៀបចំពិធីសូត្រធម៌ជាឯកជនមួយនៅវេលាថ្ងៃស្អែកនេះ។ ពួកគ្រិស្ដសាសនិកទាំងអស់អាចទៅចូលរួមបាន។ កូនឯងក៏ត្រូវទៅចូលរួមដែរ។

- ពុកមានប្រសាសន៍ថាម៉េច ?

- នៅថ្ងៃទីមួយនៃឆ្នាំថ្មី កូនឯងនឹងក្លាយជាគ្រិស្ដសាសនិក។

- ខ្ញុំណឹង ?

- ណឹងហើយ ។ជាគ្រិស្ដសាសនិកដោយស្ម័គ្រចិត្ត ។ប្រាប់ទៅ *ល្ងូត្ង-សាន* ដោយស្ងាត់ៗទៅ។

- ពុក ?

*តូកំណាកា* ដើរទៅជិតកូន :

- ឯងថ្លង់ទេអ្វី ? គ្រាន់តែរឿងយ៉ាងសាមញ្ញបំផុតសោះ ក៏ឯងលែងយល់ដែរហើយអី?

- សូមទោស ពុក។ បាទ កូនយល់ហើយ ពុក។

- ល្អ។

រួចលោកក៏វិលត្រលប់ទៅប្រកាន់យកអាកប្បកិរិយាបែបភ្លឺករបស់លោកវិញដដែល។ បន្ទាប់មកទៀត លោកក៏ដើរតយង៉ិយចេញទៅក្រៅ ដោយមានពួកអ្នកការពារតាមពីក្រោយផង។ សាមូរ៉ៃទាំងអស់នាំគ្នាលំអោនខ្លួនគោរព ប៉ុន្តែលោកហាក់ដូចជាមិនបានឃើញអ្នកទាំងនោះឡើយ។

មេទ័ពម្នាក់ដើរមកជិត *ណាកា* ទាំងក្ដីបារម្ភនៅក្នុងចិត្ត :

- តើលោកម្ចាស់យើងមានរឿងអីណឹង ?



www.budinst.gov.kh www.elibraryofcambodia.org

- ខ្ញុំមិនដឹងទេ *យ៉ុស៊ីណាកា-សាន*។

រួចគេសំលឹងមើលទៅវាណវិញ ។ *អាណរីតូ* ទើបធ្វើដំណើរចាកចេញតំរង់ទៅរកស្ថាន ។ សាមូរ៉ៃតែម្នាក់គត់ជាអ្នកជូនដំណើរលោក ។ គេនិយាយ :

- ច្បាស់ជាមានទាក់ទិននឹងគាត់នោះហើយ ។

- ខ្ញុំមិនដែលឃើញលោកម្ចាស់ *តូរ៉ាណាកា* ដើរយ៉ាងធ្ងន់ពាប់បែបនេះទេ ។ មិនដែលសោះតែម្តង ។ ពួកគេនិយាយថា........ពួកគេនិយាយថា បព្វជិតអ្នកចុងស្រុកនេះជាមេធ្មប់ ជាគ្រូសីលផងណា ។ប្រហែលជាមែនហើយបានជាវាអាចនិយាយភាសាយើងយ៉ាងច្បាស់បែបនេះ*ទេ* ? គ្រែងលោវាដាក់អំពើអីមួយលើលោកម្ចាស់ទេដឹង ?

- ទេ ។ ដាច់ខាតគឺអត់ទេ ។

- ពួកចុងស្រុកធ្វើអោយខ្ញុំស្រៀវឆ្អឹងខ្នងដែរ *ណាកា-សាន*។ តើលោកធ្លាប់ដែលលឺពីរឿង *ឈូតូ-សាន* និងពួកក្រុមគាត់ស្រែកប្រកែកគ្នារញ៉េរដូចពួក *អេតា* ទេ ?

- ណឹងហើយ ។ នេះបានជាគួរអោយស្អប់ខ្ពើមមែន ។ ខ្ញុំជឿថា គាត់នេះបានបំផ្លាញភាពសុខដុមរមនារបស់ឪពុកខ្ញុំតែម្តង ។

- បើលោកប្រើខ្ញុំ នោះព្រួញតែមួយដោតបំពង់កអាបព្វជិតនោះទៅ ច្បាស់ជាលោកម្ចាស់មិនបាច់ខ្វល់ខ្វាយច្រើនទៀតទេ ។

- ពិតមែន ។

- យើងគួរតែជំរាប *ប៊ុនតារ៉ូ-សាន* ពីរឿងលោកម្ចាស់ *តូរ៉ាណាកា* រឺ ទេ ? ព្រោះគាត់ជាមេទ័ពថ្នាក់ខ្ពស់របស់យើង ។

- ខ្ញុំឯកភាព ។ តែចាំបន្តិចទៀត ។ ឪពុកខ្ញុំនិយាយយ៉ាងច្បាស់ថា ខ្ញុំមិនត្រូវបញ្ឈប់ *ចា-ណូ-យូ* ទេ ។ ខ្ញុំនឹងរង់ចាំរហូតដល់គាត់ចប់ពិធីនេះសិន ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

នៅក្នុងសភាពស្ងប់ស្ងាត់នៃផ្ទះដ៏តូច *ប៊ុនតារ៉ូ* បើកយ៉ាងថ្នមៗកូនក្រលផែយ៉ង់ (earthenware) ដែលផលិតក្នុងសម័យរជ្ជកាល *ថាង* (*) ហើយក្នុងកាយវិការដ៏ថ្នមៗដូចគ្នានេះ ដែរ លោកចាប់កាន់កូនស្លាបព្រាឬស្សី ដើម្បីនឹងបញ្ចប់ពិធី។ លោកចាប់យកយ៉ាងប៊ិនប្រសប់នូវ ម្សៅតែពណ៌ខៀវក្នុងចំនួនដ៏ជាក់លាក់យកទៅដាក់ក្នុងពែងអត់ដៃធ្វើពីប៉ាកសីខ្មៅ (porcelain) មួយ។ កំសៀវដែកចាស់មួយនៅពុះតត្រុកនៅលើភ្លើងធ្យូង ។ នៅក្នុងភាពយ៉ាងនឹងន និងគួរអោយគយគន់ *ប៊ុនតារ៉ូ* ចាក់ទឹកពុះទៅក្នុងពែងរួចដាក់កំសៀវលើចង្ក្រានវិញ បន្ទាប់មកទើបលោកយកកូនបន្ទះ ឬស្សីមួយមកកូរតែអោយចេញជាតិស្នើល្អ។

លោកថែមទឹកត្រជាក់មួយស្លាបព្រា លំអោនខ្លួនចំពោះមុខ *ម៉ារីកូ* ដែលនៅលុតជង្គង់ទល់មុខលោក ហើយហុចពែងតែទៅនាង។ នាងលំអោនខ្លួនគោរពតប ទើបទទួលយកពែងតែយ៉ាងល្អតល្អន់ដោយសំលឹងសរសើរនូវទឹកតែពណ៌ខៀវស្រស់ រួចទើបនាងចិបសាកបីដង ឈប់បន្តិចរួចទើបចិបបន្តទៀតបង្ហើយតែម្តង។ នាងក៏ហុចពែងតែត្រលប់ទៅវិញ។ *ប៊ុនតារ៉ូ* រៀបចំទឹកតែក្នុងពិធីដដែល រួចហុចទៅនាងសាជាថ្មី។ ទៅតាមទំលាប់ នាងក៏សូមអោយ *ប៊ុនតារ៉ូ* ទទួលពិសារតែខ្លួនឯងម្តង។លោកក៏ចិបតែម្តងជាពីរដងរួចទើបពិសាបង្ហើយតែម្តង។ បន្ទាប់មកលោករៀបចំតែជាលើកទីបី រួចលើកទីបួន ។ ទាំងនេះសុទ្ធតែត្រូវបានប្រកែកយ៉ាងគួរសមពីសំនាក់ *ម៉ារីកូ*។

រួចលោកក៏លាងពែង ហើយជូតវានឹងក្រណាត់អំបោះដ៏ទន់ ហើយលោករៀបចំទុកដាក់វាយ៉ាងមានរបៀបរៀបរយ ។បន្ទាប់មកលោកក៏លំអោនខ្លួនគោរព *ម៉ារីកូ* ១ក៏គោរពតបទៅវិញ។ ពិធី *ចា-ណូ-យូ* បានចប់សព្វគ្រប់ហើយ។

*ប៊ុនតារ៉ូ* សែនរីករាយនៅក្នុងចិត្ត ព្រោះលោកបានធ្វើអស់ពីលទ្ធភាពរបស់លោកហើយ។ នៅពេលនេះ យ៉ាងហោចណាស់ក៏រវាងលោកនឹង ភរិយារបស់លោកមានភាពស្រុះស្រួល

---

*(* ) Tang Dynasty : រជ្ជកាលព្រះរាជវង្សចិន ដែលគ្រប់គ្រងប្រទេសនេះពីឆ្នាំ ៦១៨ ដល់ ៩០៧ គ.ស. (គ.អ.ប.) ។*



www.budinst.gov.kh www.elibraryofcambodia.org

នឹងគ្នា មួយរយៈដែរ ។ បើកាលពីរសៀលនេះវិញគឺមានតែអវិភាពនឹងគ្នាតែប៉ុននោះ ។

លោកបានទៅចាំត្រៃស្នែងរបស់ *ម៉ារីកូ*។ ដូចតែសព្វដងដែរ លោកតែងមានអារម្មណ៍ចាញ់ចិត្ត និងហាក់ដូចជាខ្លួនលោកជាមនុស្សទទ្រើបទទ្របនៅចំពោះមុខមុខសុក្រឹតភាពដ៏រផុយស្រួយរបស់នាងទៅវិញ។ រាល់ពាក្យសំដីដ៏ល្អៗដែលលោកបានរៀបចំដើម្បីនឹងនិយាយជាមួយនាងនោះ ស្រាប់តែរត់ទៅណាបាត់អស់រលីង ហើយលោកបានតែត្រឹមអញ្ជើញនាងយ៉ាងភ្លាវទៅ *ចា-ណូ-យូ* តែប៉ុននោះ ដោយពោលបន្ថែម :

- ជាច្រើនឆ្នាំមកហើយដែល......ខ្ញុំមិនដែលធ្វើ *ចា-ណូ-យូ* សំរាប់នាងទេ តែយប់នេះពិតជាសមពេលវេលាណាស់ ។

រួចលោកទំលាយចេញមកទាំងអចេតនា ថ្វីបើលោកដឹងថានេះមិនសមសួន និងចំជាឆោតល្ងង់ក្តី :

- លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថាដល់ពេល ដល់វេលាដែលយើងត្រូវនិយាយរកគ្នាហើយ ។

- ប៉ុន្តែលោកម្ចាស់មិនចង់និយាយ រឺ ?

ថ្វីត្បិតតែចិត្តប្តេជ្ញារបស់ខ្លួនក្តីក៏ *ប៊ុនតារ៉ូ* ឡើងមុខក្រហមង៉ាំង ហើយសំលេងរបស់លោកឡើងតឹងភ្លាម :

- ខ្ញុំចង់អោយមានសុខដុមរមនារវាងយើងទាំងពីរនាក់ ។ ម្យ៉ាងទៀតខ្ញុំមិនដែលផ្លាស់ប្តូរទេ *នេ*?

- ចាស ពិតមែនហើយ លោកម្ចាស់ ។ ម្យ៉ាងទៀតហេតុអ្វីបានជាលោកគួរផ្លាស់ប្តូរនោះ ? បើសិនជាមានកំហុសអ្វីនោះ ការផ្លាស់ប្តូរមិនមែនជាតួនាទីរបស់លោកម្ចាស់ទេ តែជាតួនាទីរបស់ខ្ញុំទៅវិញ ។ បើសិនជាមានកំហុសអ្វីកើតឡើងនោះ ក៏ព្រោះតែរូបខ្ញុំប៉ុននោះ សូមអភ័យទោសដល់ខ្ញុំផង ។

- ខ្ញុំអត់ទោសដល់នាងហើយ ។

លោកដឹងច្បាស់ថាអ្នកឯទៀតកំពុងតាមសំលឹងមើលលោក ក្នុងនោះក៏មាន *អាន់ជីន-*



www.budinst.gov.kh www.elibraryofcambodia.org

*សាន* និង *អូមី* ដែរ។ នាងគួរអោយស្រលាញ់ម្ល៉េះទេ នៅក្នុងរាងដ៏តូចច្រឡឹង និងដ៏ឯកយ៉ាងនេះ។ សក់នាងបួងខ្ពស់ឡើងទៅលើ ភ្នែកនាងសែនសុភាព តែចំពោះ *ប៊ុនតារ៉ូ* វិញនៅពេលនេះជាភ្នែកពោរពេញទៅដោយទឹកកកខ្មៅក្រិប ដែលតែងតែជំរុញលោកអោយស្ថិតក្នុងភាពក្តៅក្រហាយងងឹតងងល់ ដែលតែងតែធ្វើអោយលោកមានចិត្តចង់សំលាប់ផ្តាច់ផ្តិលជីវិត ចង់កាត់ ចង់កំទេច ហើយនឹងមានអាការៈមួយដែលសាមូរ៉ៃមិនគួរមានទាល់តែសោះ។

លោកពោលទៅកាន់នាង :

- ខ្ញុំបានសុំម៉ៅផ្ទះតែសំរាប់យប់នេះហើយ។ សំរាប់យប់នេះ ក្រោយពេលបាយល្ងាចរួច។ ពួកយើងបានទទួលបញ្ជាអោយទទួលទានបាយល្ងាចជាមួយលោកម្ចាស់ *តូរ៉ាណាកា*។ ខ្ញុំពិតជាមានកិត្តិយសណាស់ បើសិនជានាងព្រមជាភ្ញៀវរបស់ខ្ញុំបន្ទាប់ពីពេលបាយរួចមក។

- គឺខ្ញុំទេដែលមានកិត្តិយសនោះ។

រួចនាងក៏លំអោនខ្លួនគោរព ហើយនៅរង់ចាំក្នុងភាពបែបនេះ ភ្នែកនាងនៅតែសំលឹងចុះក្រោមជាប់ជានិច្ច។ នៅក្នុងចិត្តរបស់ *ប៊ុនតារ៉ូ* ចង់តែចិញ្ច្រាំនាងនៅលើដីអោយទាល់តែស្លាប់ រួចរត់ចេញអោយឆ្ងាយ ហើយយកកាំបិតវះពោះខ្លួនឯង ដើម្បីអោយការឈឺចាប់ជាអលជ្ជីនេះលាងជំរះអោយអស់នូវកង្វល់ក្នុងដួងព្រលឹងរបស់លោក។

រួចលោកឃើញនាងងើបមុខឡើងសំលឹងមើលលោកដោយក្រសែភ្នែកយ៉ាងមុត។

នាងសួរយ៉ាងស្រទន់ :

- តើមានអីទៀតទេ លោកម្ចាស់ ?

ញើសហូរស្រក់តាមឆ្អឹងខ្នង និងក្លៀករបស់លោក ធ្វើអោយគីម៉ូណូរបស់លោកដាមជោក។ ទ្រូងលោកឈឺខ្ទោក១ដូចក្បាលរបស់លោកដែរ :

- នាង......នាងនឹងស្នាក់នៅក្នុងផ្ទះសំនាក់នៅក្នុងយប់នេះ។

រួចលោកក៏បែកចេញពីនាង ដើម្បីរៀបចំចាត់ចែងយ៉ាងប្រុងប្រយ័ត្ននូវក្បួនដឹកជញ្ជូនអីវ៉ាន់ទាំងមូល។ ហើយក្នុងរយៈពេលយ៉ាងរហ័សដែលអាចធ្វើទៅបាន លោកបានប្រគល់ភារកិច្ចទៅអោយ *ណាកា* ហើយដើរតាមបណ្តោយស្ទឹង ដោយខំរក្សាអាកប្បកិរិយាបែបហ៊ី។ នៅពេល



www.budinst.gov.kh www.elibraryofcambodia.org

ដែលលោកនៅម្នាក់ឯងហើយ លោកក៏ស្រាតខោអាវចេញ ហើយលោតចុះទៅក្នុងទឹកជ្រោះ ដោយឥតខ្វល់ខ្វាយអ្វីនឹងសុវត្ថិភាពរបស់រូបលោកឡើយ ។ លោកនៅហែលក្នុងទឹករហូតដល់លោកស្វាងស្មារតីឡើងវិញ និងការឈឺចាប់ទាំងប៉ុន្មានរលាយបាត់អស់ទៅ ។

លោកនៅដេកសំដិលខ្លួនយកកំលាំងនៅលើឆ្នេរស្ងឹង ។ នៅពេលនេះដែលនាងយល់ព្រមទទួលការអញ្ជើញរបស់លោកហើយ លោកត្រូវតែចាប់ផ្តើមរៀបចំ ។ ហើយពេលវេលាមានតិចណាស់ ។ លោកប្រមែប្រមូលកំលាំងដើរត្រលប់ទៅរកទ្វារសួនហើយឈរនៅទីនោះមួយសន្ទុះដើម្បីពិចារណាឡើងវិញពីគំរោងការរបស់លោក ។ យប់នេះ លោកចង់អោយអ្វី១ប្រព្រឹត្តទៅឥតខ្ចោះ ។ ជាការពិតហើយដែលថាកូនផ្ទះតែនេះសុក្រឹត ដូចជាសួនច្បារនៅទីនេះដែរ ។ តែមិនសំខាន់ទេ -លោកគិតនៅក្នុងចិត្ត ដោយស្ទុងគំនិតនៅក្នុងកិច្ចការរបស់លោក -ធ្វើតាមរបស់ដែលមានទៅ ។ រាត្រីជួយបិទបាំងចំនុចខ្វះខាតទាំងឡាយ ហើយពន្លឺនឹងជួយបង្កើតនូវទំរង់នានាដែលខ្វះខាត ។

ពួកអ្នកបំរើបានយកមកជាស្រេចនូវរបស់នានា ដែលលោកបានបញ្ជាតាំងពីមុនម្ល៉េះ ដូចជា *ភាគាមី* ចង្កៀងប្រេងធ្វើពីដីដុត និងចានក្បានផ្សេង១ ទាំងអស់នេះសុទ្ធតែជារបស់ដ៏ល្អបំផុតនៅ *យ៉ូកូសេ* នេះ ។ អ្វី១សុទ្ធតែទំនើប តែមិនឆើតឆាយ និងមានលក្ខណៈសាមញ្ញ ។

លោកដោះគីម៉ូណូចេញ ដាក់ដាវទុក ហើយចាប់ផ្តើមធ្វើការសំអាត ។ ដំបូងបង្អស់លោកសំអាតបន្ទប់ទទួលភ្ញៀវដ៏តូច ចង្ក្រាន និងរានហាល ។ បន្ទាប់មកទៀតលោកសំអាតផ្លូវបត់បែន ហើយនិងដុំថ្មសំប៉ែត១ដែលមានជាប់ស្លែ ហើយទីបញ្ចប់គឺជាដុំថ្មដា និងសួនច្បារដែលនៅព័ទ្ធជុំវិញនោះ ។ លោកបោស ជូត និងដុសរហូតទាល់តែអ្វី១មានលក្ខណៈសុក្រឹតទាំងអស់ ។ លោកដាក់ខ្លួនធ្វើហត្ថកម្មដែលជាកិច្ចចាប់ផ្តើមនៃរាល់ពិធី *ចា-ណូ-យូ* ទាំងអស់ ដែលតំរូវអោយតែម្ចាស់ទីកន្លែងតែម្នាក់ឯងគត់ទទួលធ្វើអោយអ្វី១គ្មានទាស់ឆ្គង ។ ហើយសុក្រឹតភាពទីមួយ គឺការស្អាតភ្លឹងដាច់ខាត ។

នៅពេលព្រលប់ លោកបានធ្វើអោយចប់សព្វគ្រប់នូវការត្រៀមរៀបចំស្ទើរតែទាំងអស់ ។ បន្ទាប់មក លោកបានមុជទឹកយ៉ាងផ្ចិតផ្ចង់ ចូលរួមពិធីបាយល្ងាច និងស្តាប់ចំរៀង ។ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

យ៉ាងរហ័សតាមដែលអាចទៅបាន លោកបានដូរសំលៀកបំពាក់ងឹតជាងមុនបន្តិច ហើយក៏រូតរះវិលមកសួនច្បារមុន ។លោកដាក់គន្លឹះទ្វាររបង រួចជាដំបូងលោកអុជចង្កៀងប្រេង ។បន្ទាប់មកទៀតលោកប្រោះទឹកយ៉ាងប្រយ័ត្នប្រយែងលើដុំថ្មសំប៉ែត១ និងលើដើមឈើនានាដែលក្រោយពីនោះបានដេញពន្លឺផ្លេក១ ឯនេះបន្តិច ឯនោះបន្តិចទៅតាមពន្លឺភ្លឹបភ្លែតនៃពន្លឺ ធ្វើអោយសួនច្បារប្រែក្លាយជាសួនសួគ៌ាមួយ ដែលមានតំនក់សន្សើមរេរាំនៅក្នុងភាពកក់ក្តៅនៃដំនោរវស្សាន្តរដូវ ។ លោករៀបចំបួរកន្លែងដាក់តោមខ្លះ១ ។ នៅទីបំផុត នៅពេលដែលលោកមានការពេញចិត្តរួចហើយ ទើបលោកទៅដកគន្លឹះទ្វាររបងចេញវិញ ហើយដើរទៅកាន់ល្វែងក្រៅ ។ ដុំធ្យូងដែលត្រូវបានជ្រើសរើសយកយ៉ាងម៉ត់ចត់នោះ ត្រូវបានគរយ៉ាងត្រឹមត្រូវជារាងសាជីនៅលើខ្សាច់ពណ៌សហើយឆេះយ៉ាងស្អាត ។ ផ្កាទាំងឡាយមានភាពសុក្រឹតហើយដាក់នៅលើហ៊ឹង ។ លោកជូតសំអាតឧបភោគភណ្ឌ (ustensil) ដែលស្អាតស្រាប់ហើយនោះជាថ្មីម្តងទៀត ។ កំសៀវចាប់ផ្តើមអោយសំលេងពុះ ហើយសំលេងនេះធ្វើអោយលោកមានការរីករាយនៅក្នុងចិត្ត ពិសេសអាស្រ័យដោយលោកបានបន្ថែមដែកមួយកួនដុំទៅក្នុងកំសៀវ ធ្វើអោយសំលេងពុះកាន់តែពិរោះថែមទៀត ។

អ្វី១ត្រូវបានរៀបចំជាស្រេច ។ សុក្រឹតភាពទីមួយនៃ *ចា-ណូ-យូ* គឺភាពស្អាតភ្លឹង ។ សុក្រឹតភាពទីពីរគឺភាពយ៉ាងសាមញ្ញបំផុត ។ សុក្រឹតភាពចុងក្រោយ និងដែលធំបំផុត គឺភាពសមស្របជាមួយភ្ញៀវ ។

លោកបានលីស្បូរជើងនាងនៅលើដុំថ្មសំប៉ែតនានា ស្បូរដៃនាងដែលលូកលាងក្នុងទឹកជ្រោះ និងការជូតសំអាត ។ ស្បូរជើងយ៉ាងស្រាលបីជំហានមកដល់យ៉ាបរានហាល ។ ពីរជំហានទៀតមកដល់រនាំងទ្វារចូល ។ នាងត្រូវអោនដើម្បីឆ្លងកាត់ទ្វារចូលដែលគេបានធ្វើអោយតូចយ៉ាងចេតនា ដើម្បីអោយគ្រប់ជនានុជនណាដែលឆ្លងកាត់ទ្វារនេះត្រូវតែមានភាពលំអោនលំទោន ។ នៅក្នុងពិធី *ចា-ណូ-យូ* គ្រប់១គ្នាគឺស្មើភាព ទាំងម្ចាស់ផ្ទះក៏ដូចជាទាំងភ្ញៀវ ទាំង *ដៃម៉្យូ* ដ៏ខ្ពង់ខ្ពស់បំផុតក៏ដូចជាទាំងសាមូរ៉ៃដ៏សាមញ្ញ ។ សូម្បីតែកសិករក៏ដោយ បើសិនណាជាត្រូវបានគេអញ្ជើញអោយចូលរួមនោះ ។



www.budinst.gov.kh www.elibraryofcambodia.org

ដំបូងបំផុត នាងពិនិត្យការរៀបចំផ្ការរបស់ប្តីនាង ។ លោកបានរើសយកផ្កាកុលាបព្រៃពណ៌សក្រពុំមួយ ហើយលោកបានដាក់ទឹកមួយតំនក់ទៅលើស្លឹកពណ៌បៃតងរបស់វា ហើយដាក់វានៅលើថ្មក្រហមមួយ ។ សរទរដូវមកដល់ហើយ នេះគឺជាន័យដែលលោកចង់និយាយតាមរយៈផ្កា ។ គេមិនត្រូវយំនៅពេលដែលសរទរដូវមកដល់នៅពេលដែលក្តីស្លាប់បានឈានមកក្នុងពេលដែលព្រះធរណីចាប់ផ្តើមចូលនិទ្រា ។ ចូរសប្បាយរីករាយនឹងពេលចាប់ផ្តើមជាថ្មី ហើយចូរក្រេបយកភាពត្រជាក់ដ៏រុងរឿងនៃរាំយោសរទរដូវក្នុងរាត្រីវស្សាន្តរដូវនេះចុះ....... បន្តិចទៀតទឹកភ្នែកនឹងរលាយបាត់ ក៏ដូចជាកុលាបនេះដែរ ហើយមានតែដុំថ្មទេដែលនៅស្ថិតស្ថេរ......បន្តិចទៀត នាងនិងខ្ញុំនឹងរលាយបាត់ ហើយមានតែដុំថ្មទេដែលនៅស្ថិតស្ថេរ ។

លោកតាមសំលឹងមើលនាងក្នុងភាពអណ្តែតអណ្តូង ។ នាងលំអោនខ្លួនចំពោះមុខផ្កាដើម្បីជាគារវកិច្ច រួចទើបមកអង្គុយលុតជង្គង់ទល់មុខលោក ។ គីម៉ូណូរបស់នាងសំបុរត្នោតហើយជាយពណ៌មាសនៃគីម៉ូណូ រឹតតែធ្វើអោយបំពង់ក និងមុខរបស់នាងកាន់តែលេចសថែមទៀត ។ ក្រណាត់ចងចង្កេះពណ៌បៃតងចាស់ សែនស៊ីគ្នានឹងគីម៉ូណូរបស់នាងថែមទៀត ។ សក់នាងត្រូវបានសិតយ៉ាងមានរបៀប និងដោយគ្មានគ្រឿងលំអអលង្ការអ្វីទាំងអស់ ។

*ប៊ុនតារ៉ូ* លំអោនខ្លួនចំពោះមុខនាង ហើយនិយាយជាកិច្ចចាប់ផ្តើមកម្មវិធី :

- ខ្ញុំសូមស្វាគមន៍នាង ។
- នេះគឺជាកិត្តិយសណាស់សំរាប់ខ្ញុំ -នាងតប ។

លោកក៏ចាប់ផ្តើមលើកម្ហូបបន្តិចដែលដាក់នៅលើថាសលាបខ្មុកម្រ័ក្សមួយយ៉ាងស្អាត ។ ចង្កឹះមួយគូត្រូវបានរៀបចំយ៉ាងមានរបៀប ហើយចំនិតត្រីត្រូវបានដាក់រៀបយ៉ាងស្អាតនៅលើបាយ ។ ដើម្បីអោយកាន់តែមានភាពទាក់ទាញថែមទៀតនោះ ផ្កាព្រៃមួយចំនួនដែលដុះនៅតាមដងស្ទឹងនោះ ត្រូវបានលោកយកមកពង្រាយយ៉ាងរៀបរយនៅលើថាស ។ នៅពេលដែលនាងទទួលទានរួចហើយ១ បន្ទាប់ពីលោកក៏បានទទួលទានតាមក្រោយនោះបានចប់សព្វគ្រប់ហើយនោះលោកក៏លើកថាសបាយចេញទៅចង្ក្រានតាមទ្វារទាបមួយ ។

ពេលនៅតែម្នាក់ឯង *ម៉ារីកូ* សំលឹងទាំងស្ងប់ស្ងាត់ និងក្នុងក្រសែភ្នែកពោរពេញដោយ



www.budinst.gov.kh www.elibraryofcambodia.org

បទពិសោធន៍នូវភ្លើងភ្លើងដែលកំពុងឆេះនៅលើសមុទ្រខ្សាច់សស្កុះក្រោមចង្ក្រាន ត្រចៀកនាងត្រងត្រាប់ស្ដាប់សំលេងថ្ងូចថ្ងូរនៃអគ្គីលាយឡំនឹងដង្ហើមធំនៃកំសៀវដែលកំពុងរពួយតិចៗ ហើយនឹងសំលេងក្រណាត់លើប៊ិកស៊ីឡែន និង សំលេងទឹកដែលលាងរបស់សំអាតស្រាប់ទាំងឡាយពីក្នុងចង្ក្រាន។ បន្ទប់មកភ្នែកនាងវាសទៅមើលថ្នឹមទាំងឡាយ ដែលត្រូវបានប្រទាក់គ្នាជាមួយរ៉ស៊ីនិងកណ្ដុបស្បូវទាំងឡាយ ។ ស្រមោលដែលជះដោយចង្កៀងទាំងឡាយដែល *ប៊ុនកាវ៉ូ* បានដាក់ពង្រាយយ៉ាងមានរបៀបនោះ បានប្រែក្លាយអ្វីដែលតូចអោយទៅជាធំ ហើយធ្វើអោយរបស់កំប៉ិកកំប៉ុកប្រែទៅជាប្រកបដោយសោភ័ណភាព និងធ្វើអោយអ្វីៗពោរពេញដោយភាពសុខដុមរមនាឥតខ្ចោះ។ ក្រោយពីបានមើលឃើញអ្វីៗសព្វគ្រប់ដោយថ្លឹងថ្លែងនឹងដួងព្រលឹងរបស់នាងហើយនាងក៏ចេញទៅសួនច្បារដើរតំរង់ទៅរកអាងទឹកធម្មជាតិមួយ ដែលពេលវេលាបានច្នៃវានៅលើដុំថ្មមួយផ្ទាំង។ ជាថ្មីម្ដងទៀតនាងលាងផ្សុំទ្វដៃ និងមាត់របស់នាងដោយទឹកត្រជាក់ថ្លាឆ្វង់នេះ រួចទើបជូតសំងួតដៃនឹងកន្សែងមួយ។

នៅពេលដែលនាងវិលត្រលប់ចូលមកអង្គុយនៅកន្លែងរបស់នាងហើយនោះ ទើប *ប៊ុនកាវ៉ូ* សួរ :

- តើនាងទទួលទានតែអីលូវនេះ រឺ ?

- នេះគឺពិតជាកិត្តិយសរបស់ខ្ញុំណាស់។ ប៉ុន្តែសូមលោកកុំទៅពិបាកខ្លួនដោយសាររូបខ្ញុំធ្វើអី ?

- នេះគឺជាកិត្តិយសរបស់ខ្ញុំវិញទេ។ នាងជាភ្ញៀវរបស់ខ្ញុំណា៎។

រួចលោកក៏រៀបចំបំរើទឹកតែដល់នាងទៅ។

អីលូវនេះគឺជាពេលបញ្ចប់ហើយ។

នៅក្នុងភាពយ៉ាងស្ងៀមស្ងាត់នេះ *ម៉ារីកូ* ឥតមានធ្វើចលនាអ្វីទាំងអស់ ហើយបន្តនៅក្នុងភាពស្ងប់ស្ងាត់ដដែល ក្នុងបំនងមិនចង់ធ្វើដឹងធ្វើលឺពីការបញ្ចប់ រឺក៏ធ្វើអោយរំខានដល់ភាពសុខសាន្តដែលនៅហ៊ុមព័ទ្ធរូបនាងនោះឡើយ។ ប៉ុន្តែនាងមានអារម្មណ៍ថា ក្រសែភ្នែករបស់ *ប៊ុនកាវ៉ូ* កាន់តែធ្ងន់ឡើងៗហើយ ។ *ចា-ណូ-យូ* បានបញ្ចប់ហើយ ។ អីលូវនេះជីវិតរស់នៅត្រូវតែ



www.budinst.gov.kh www.elibraryofcambodia.org

ចាប់ផ្ដើមឡើងវិញ ។

- លោកធ្វើនេះគឺឥតខ្ចោះទេ ។

នាងនិយាយខ្សឹបៗ ភាពទុក្ខព្រួយបានសង្កត់យ៉ាងធ្ងន់ពាប់លើរូបនាង ។ តំនក់ទឹកភ្នែកបានរមៀលធ្លាក់ពីរង្វង់ភ្នែកនាង ដែលធ្វើអោយបេះដូងរបស់ *ប៊ុនកាប៉ូ* កាន់តែរហែកថែមទៀត ។

- ទេ......ទេ ។ សូមអភ័យទោសដល់ខ្ញុំផង.......នាងទេដែលឥតខ្ចោះនោះ.......ពិធីនេះធម្មតាទេតើ -លោកនិយាយតបទាំងងឿងឆ្ងល់នឹងការសរសើរបែបនេះ ។

- នេះជាពិធី *ចា-ណូ-យូ* ដ៏ល្អប្រសើរបំផុតដែលខ្ញុំមិនដែលបានជួបឡើយ -នាងពោលទាំងរំភើបចិត្ត នឹងភាពស្មោះត្រង់ដ៏មុតមាំដែលលេចចេញតាមសំដីរបស់ស្វាមី ។

- ទេ ទេ ។ សូមអភ័យទោសដល់ខ្ញុំផងបើសិនជាពិធីនេះបានល្អគួរសមនោះ ក៏ដោយសារតែរូបនាងប៉ុននោះ *ម៉ារីកូ-សាន* នេះគឺគ្រាន់តែល្មមគួរសមតែប៉ុននោះ.......នាងបានធ្វើអោយអ្វីៗកាន់តែប្រសើរថែមទៀត ។

- ចំពោះខ្ញុំ នេះគឺឥតខ្ចោះ ។ គ្រប់យ៉ាងទាំងអស់ គឺឥតខ្ចោះ ។ ស្ដាយណាស់ដែលមានអ្នកដែលសក្តិសមជាងខ្ញុំទៅទៀត មិនបានមកឃើញពិធីនេះផង ! -ភ្នែករបស់នាងចែងចាំងក្រោមពន្លឺភ្លឹបភ្លែត ។

- នាងបានឃើញវា ។ នេះគឺគ្រប់គ្រាន់ហើយ ។ ពិធីនេះសំរាប់តែរូបនាងម្នាក់ប៉ុននោះ ។ អ្នកឯទៀត ពិតជាមិនអាចយល់បានទេ ។

នាងមានអារម្មណ៍ថា ទឹកភ្នែកក្ដៅឧណ្ហៗកំពុងហូរកាត់ផែនថ្ពាល់របស់នាង ។ ជាធម្មតានាងរមែងមានភាពអៀនខ្មាសចំពោះស្ថានភាពបែបនេះ តែនៅពេលនេះនាងឥតមានខ្វល់អ្វីទាំងអស់ ។ នាងតប :

- សូមអរគុណ ។ តើខ្ញុំត្រូវអរគុណលោកតាមរបៀបណាទៅ ?

*ប៊ុនកាប៉ូ* ឈោងចាប់ទាំងដៃញ័រទទ្រើតនូវមែកឈើព្រៃមួយមែក ហើយលោកក៏អោនទៅត្រង់យកទឹកភ្នែករបស់នាងយ៉ាងថ្នមៗ ។ លោកសំលឹងយ៉ាងស្ញៀមស្ងាត់តំនក់ទឹកភ្នែក និង



www.budinst.gov.kh www.elibraryofcambodia.org

មែកឈើដែលហាក់ដូចជាសែនតូចនៅក្នុងកណ្ដាប់ដៃដ៏ធំរបស់លោក ។ លោកនិយាយ :

- ការងារខ្ញុំ.....ការងារអីក៏ដោយ.......មិនសក្តិសមនឹងសោភ័ណភាពនៃតំនក់ទឹកភ្លែកនេះទេ ។ សូមអរគុណនាង ។

លោកនៅតែសំលឹងមើលតំនក់ទឹកភ្លែកនេះ ។ ដុំធ្យូងមួយដុំរមៀលធ្លាក់ពីលើភ្នំភ្លើងចុះមកក្រោម ។ ដោយស្វ័យប្រវត្តិលោកយកតំបៀតចាប់ធ្យូងដាក់ទៅលើគំនរភ្លើងវិញ ។ កំទេចភ្លើងរេរាំឡើងទៅលើអាកាស ហើយគំនរធ្យូងក៏បានប្រែក្លាយជាភ្នំភ្លើងឡើងវិញ ។

ទាំងពីរនាក់បានលង់ទៅក្នុងភាពដ៏ស្រងេះស្រងោចមួយយ៉ាងផ្អែមល្ហែម ចិត្តគំនិតរបស់គេទាំងពីរនាក់វេញត្របាញ់ចូលគ្នា អាស្រ័យដោយទឹកភ្លែកមួយតំនក់ គេសប្បាយជាមួយគ្នានៅក្នុងភាពរសាប់រសល់ គេរលាយចូលគ្នាក្នុងភាពអោនលំទោននៅក្នុងចិត្ត គេដឹងច្បាស់ថាអ្វីដែលបានប្រគល់អោយត្រូវបានបង្វិលត្រលប់មកវិញក្នុងភាពបរិសុទ្ធ ។

ក្នុងរយៈពេលយ៉ាងយូរ ទើប *ប៊ុនតារ៉ូ* ពោលឡើង :

- បើសិនជាភារកិច្ចរបស់យើងមិនហាមឃាត់ទេនោះ ខ្ញុំពិតជាសុំអោយនាងរួមស្លាប់ជាមួយខ្ញុំជាមិនខាន ។ ស្លាប់ក្នុងពេលនេះតែម្តង ។

- ខ្ញុំពិតជាព្រមស្លាប់ជាមួយលោក ។ ស្លាប់ទាំងរីករាយ -នាងតបយ៉ាងរហ័ស -យើងស្លាប់ជាមួយគ្នា ។ ស្លាប់ក្នុងពេលនេះតែម្តង ។

- យើងមិនអាចធ្វើយ៉ាងដូចនេះបានទេ ។ ភារកិច្ចរបស់យើង គឺបំរើលោកម្ចាស់ *ភូរ៉ាណាកា* ណាំ ។

នាងយកកាំបិតស្រួចមួយពីក្នុងខ្សែក្រវាត់រុំចង្កេះនាងចេញមក ហើយដាក់វាយ៉ាងគោរពនៅលើ *ភាគាមី* ដោយពោលថា :

- បើអ៊ីចឹង សូមលោកអនុញ្ញាតអោយខ្ញុំត្រួសត្រាយផ្លូវទៅមុនផងចុះ ។

- ទេ ។ ធ្វើបែបនេះគឺយើងមិនបានបំពេញភារកិច្ចរបស់យើងទេ ។

- អ្វីដែលវាយ៉ាងណា វានឹងទៅជាយ៉ាងនោះឯង ។ លោកនិងខ្ញុំមិនអាចផ្លាស់ប្តូរព្រហ្មលិខិតបានទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- ពិតមែនហើយ ។ ប៉ុន្តែយើងមិនអាចទៅមុនលោកម្ចាស់យើងបានទេ ។ ទាំងរូបនាងក៏ដូចទាំងរូបខ្ញុំដែរ ។ លោកម្ចាស់ត្រូវការរាល់អណ្តាប់ជាទីទុកចិត្តយូរជាងនេះបន្តិចទៀត ។ សូមនាងអភ័យទោសដល់ខ្ញុំផងចុះ ប៉ុន្តែខ្ញុំត្រូវតែហាមឃាត់នាងមិនអោយធ្វើយ៉ាងនេះឡើយ ។

- ខ្ញុំពិតជារីករាយណាស់បើបានស្លាប់នៅក្នុងយប់នេះ ។ ខ្ញុំបានត្រៀមរៀបចំខ្លួនជាស្រេចហើយ ។ ជាងនេះទៅទៀត ខ្ញុំសែនចង់ទៅបរលោកជាពន់ពេក ។ ចាស នេះគឺជាការពិត ។ ព្រលឹងរបស់ខ្ញុំពោរពេញដោយអំនរ -ស្នាមញញឹមស្នាក់ស្ទើរមួយបានលេចចេញនៅលើវង្វង់មុខនាង -សូមអភ័យទោសដល់ភាពអត្តទត្តបុគ្គលរបស់ខ្ញុំផង ។ លោកពិតជាយល់ត្រូវបំផុតអំពីភារកិច្ចរបស់យើងនេះ ។

កាំបិតដែលមានមុខស្រួចដូចកាំបិតកោរចាំងពន្លឺព្រាតនឹងភ្លើងទៀន ។ គេទាំងពីរនាក់សំលឹងមើលកាំបិតនេះ អារម្មណ៍ម្នាក់ៗលិចបាត់នៅក្នុងការគិតពិចារណា ។ រួចទើប *ប៊ុនតារ៉ូ* បំបែកភាពភ្លេចភ្លឹកនេះ :

- ហេតុអីបានជាទៅ *អូសាកា ម៉ារីកូ-សាន* ?

- មានភារកិច្ចមួយចំនួនដែលត្រូវធ្វើនៅទីនោះ ហើយដែលមានតែខ្ញុំម្នាក់គត់ដែលអាចធ្វើបាន ។

*ប៊ុនតារ៉ូ* ជ្រួញចិញ្ចើម :

- កិច្ចការអ្វីទៅ ?

- កិច្ចការដែលទាក់ទិនទៅនឹងអនាគតត្រកូលរបស់យើង ហើយដែលខ្ញុំត្រូវតែទទួលបំពេញ ។

- ក្នុងករណីនេះ នាងត្រូវតែទៅ -លោកសំលឹងហាក់ចង់មើលអោយធ្លុះជំរៅចិត្តនាង- តែនាងទៅតែម្នាក់ឯងទេរឺ ?

- ចាស ។ ខ្ញុំចង់អោយបានច្បាស់ថា ការស្រុះស្រួលទាំងប៉ុន្មានរវាងគ្រួសារយើង នឹងគ្រួសារលោកម្ចាស់ *គីយ៉ាម៉ា* ទាក់ទិនទៅនឹងពិធីរៀបមង្គលការរបស់ *សារូជី* នោះគឺគ្មានខើសខាស់កន្លែងណាទៀតទេ ។ ទាំងរឿងលុយកាក់ រឿងបណ្ណាការ រឿងដីធ្លី និងទាំងរឿងផ្សេងៗ



www.budinst.gov.kh www.elibraryofcambodia.org

ទៀត ។នៅទីនោះក៏មានរឿងដែលត្រូវធ្វើក្រដាសស្នាមពីរឿងដីធ្លីរបស់ *សាបូជី* ដែលទើបទទួលបានបន្ថែមទៀតផង ។លោកម្ចាស់ *ហ៊ូរិ-ម៉ាត់ស៊ឺ* និងលោកម្ចាស់ *តូរ៉ាណាកា* បានសំនូមពរអោយចាត់ចែងការងារនេះអោយបានរួចរាល់តែម្តងទៅ ។ ខ្ញុំជាអ្នកទទួលខុសត្រូវលើត្រកូលនេះ ណា៎ ។

- ពិតហើយ -*ប៊ុនតារ៉ូ* ឆ្លើយតបយ៉ាងយឺត១ -នេះជាភារកិច្ចរបស់នាង -ភ្នែករបស់លោកសំលឹងចំភ្នែករបស់នាងឥតមានព្រិច -បើសិនជាលោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៏ថានាងអាចទៅបាន នាងទៅចុះ ប៉ុន្តែមើលទៅមិនសង្ឃឹមថានាងនឹងទទួលបានការអនុញ្ញាតអោយទៅឡើយ ។ ទោះជាយ៉ាងនេះក្តី.........នាងត្រូវត្រលប់មកវិញអោយបានរហ័ស ។ អោយបានរហ័សជាទីបំផុត ។ មិនមែនជាការល្អទេដែលត្រូវនៅ *អូសាកា* លើសពីចាំបាច់នោះទេ ។

- ចាស ។

- ទៅតាមសមុទ្ទគឺរហ័សជាងទៅតាមផ្លូវគោក ។ តែតាំងពីដើមមក នាងស្អប់សមុទ្ទណាស់ ។

- ខ្ញុំនៅតែស្អប់សមុទ្ទដដែល ។

- តើនាងត្រូវទៅដល់ទីនោះយ៉ាងឆាប់បំផុត រឺ ?

- ខ្ញុំគិតថាខុសគ្នាកន្លះខែ រឺមួយខែ មិនជាការអីទេ ។ រឺក៏ខុសគ្នាដែរក៏មិនដឹង ។ តែខ្ញុំមានអារម្មណ៏ថា ខ្ញុំត្រូវតែចេញទៅជាបន្ទាន់ ។

-បើអីចឹង យើងត្រូវទុកជូនលោកម្ចាស់ *តូរ៉ាណាកា* ជាអ្នកកំនត់ពីពេលវេលា និងពីការធ្វើដំណើរនេះទៅចុះ ។ នេះបើសិនជាលោកព្រមអនុញ្ញាតអោយទៅមែននោះ ។ មានលោកម្ចាស់ *អូសាកាគី* នៅទីនេះជាមួយនឹងសារពីររមូរនេះ គឺគ្មានន័យអ្វីក្រៅពីសង្គ្រាមទេ ។ ធ្វើដំណើរទៅ *អូសាកា* គឺមានគ្រោះថ្នាក់ណាស់ ។

- ចាស ។ សូមអរគុណលោក ។

សែនរីករាយ ដោយអ្វី១ត្រូវបានចប់សព្វគ្រប់ហើយនោះ *ប៊ុនតារ៉ូ* ចោលភ្នែកសំលឹងមើលកូនបន្ទប់នេះទាំងពេញចិត្តពេញថ្លើមដោយឥតខ្វាយខ្វល់ថាមាឌដ៏សំបើមរបស់លោកស៊ីស្មើរអស់កន្លែង ភ្លៅរបស់លោកម្ខាង១ធំជាងដើមទ្រូងនាង ហើយដៃរបស់លោកម្ខាង១ធំជាងបំពង់ក



www.budinst.gov.kh www.elibraryofcambodia.org

របស់នាងនោះឡើយ ។

លោកពោល :

- នេះគឺជាបន្ទប់ដ៏ល្អ ។ ល្អជាងការគិតស្មាននៃរបស់ខ្ញុំទៅទៀត ។ ខ្ញុំសែនរីករាយណាស់ដែលបានស្ថិតនៅក្នុងបន្ទប់នេះ ។ ខ្ញុំទើបតែនឹកឃើញថា រូបរាងកាយគ្រាន់តែជាផ្ទះខ្ទមមួយនៅកណ្តាលវាលរហោឋានតែប៉ុណ្ណោះ ។ សូមអរគុណនាងដែលបានមកទីនេះ ។ ខ្ញុំសប្បាយចិត្តណាស់ដែលនាងបានមកដល់ *យ៉ូកូសេ* នេះ *ម៉ារីកូ-សាន*។ បើសិនជាមិនមែនដើម្បីរូបនាងទេនោះ ខ្ញុំនឹងមិនធ្វើ *ចា-ណូ-យូ* នៅទីនេះជាដាច់ខាត ហើយខ្ញុំពិតជាមិនបានរលាយសាច់មួយនឹងអនន្តភាពផងដែរទេ ។

នាងស្ទាក់ស្ទើរបន្តិចរួចក៏ឈោងចាប់យកទាំងអៀនអន់នូវក្រឡដាក់តែសម័យរជ្ជកាល *ថាំង*។ នេះគឺជាក្រឡមានគ្របមួយដ៏សាមញ្ញគ្មានក្បាច់លំអអ្វីទាំងអស់ ។ *ប៊ុនតារ៉ូ* បានទិញក្រឡនេះក្នុងតំលៃពីរម៉ឺន *កូគូ* ពី *សេន-ណាកាដា* ដែលជាគ្រូតែដ៏ធំជាងគេ និងដ៏ល្បីល្បាញជាងគេក្នុងគ្រប់ជំនាន់ទាំងអស់ ។ នាងនិយាយរអ៊ូរទាំក្នុងពេលដែលដៃនាងស្ទាបអង្អែលក្រឡនេះ :

- នេះបានចំជាល្អមែនទែន ។ ចំជាសុក្រឹតតែម្តងសំរាប់ពិធីនេះ ។

- ពិតមែន ។

- លោកចំជាកំពូលតែម្តងនៅយប់នេះ *ប៊ុនតារ៉ូ-សាន*។ លោកបានផ្តល់នូវសុភមង្គលដ៏មហិមាដល់រូបខ្ញុំ -សំលេងនាងទាប តែពោរពេញដោយការសំរេចចិត្ត ។ នាងអោនមុខបន្តិច -អ្វីៗគឺឥតខ្ចោះសំរាប់ខ្ញុំ ។ សូនច្បារនេះ សិល្បភាពដ៏កំពូលដែលលោកបានបង្ហាញតាមរយៈនៃការលាក់ភាពមិនសុក្រិត អាស្រ័យដោយល្បែងស្រមោលចង្កៀងនេះ ហើយនឹងរបស់នេះ -នាងយកដៃស្ទាបក្រឡតែម្តងទៀត -ទាំងអស់នេះគឺឥតខ្ចោះ ។ សូម្បីតែអក្សរដែលសរសេរនៅលើកន្សែងថា " អាយ " ដែលមានន័យថា ថ្នាក់ថ្នម នេះ ។ ពាក្យ " ថ្នាក់ថ្នម " នេះ គឺជាពាក្យឯកសំរាប់ខ្ញុំនៅក្នុងយប់នេះ -ទឹកភ្នែកហូរសស្រាក់កាត់ផែនថ្ពាល់របស់នាង -សូមលោកអភ័យទោសដល់ខ្ញុំផង ។

នាងនិយាយពាក្យចុងក្រោយ ដោយដៃជូតទឹកភ្នែកផង ។



www.budinst.gov.kh www.elibraryofcambodia.org

*ប៊ុនតារ៉ូ* លំអោនខ្លួនគោរពនាងទាំងសែនរសាប់រសល់ចិត្ត ចំពោះពាក្យសរសើរដ៏សន្ធឹកសន្ធាប់យ៉ាងនេះ។ ដើម្បីលាក់បាំងភាពរសាប់រសល់របស់ខ្លួន លោកក៏ចាប់ផ្តើមរៀបចំដាក់ក្រឡទៅក្នុងស្រោមសូត្ររបស់វាវិញ។ រួចលោកទុកវានៅក្នុងប្រអប់មួយ ហើយដាក់វាយ៉ាងប្រយ័ត្នប្រយែងទៅពីមុខ *ម៉ារីកូ* ដោយពោលថា :

-*ម៉ារីកូ-សាន*បើផ្ទះយើងមានបញ្ហារឿងលុយកាក់សូមនាងយករបស់នេះទៅលក់ទៅ។

- មិនបានជាដាច់ខាត ! -ក្រៅពីដាវ និងធ្នូ ក្រឡតែនេះគឺជាកម្មសិទ្ធិតែមួយគត់ដែលប្តីនាងស្រលាញ់ស្មើជីវិតនោះ-នេះជារបស់មួយដែលទោះជាយ៉ាងណាក៏ខ្ញុំមិនលក់វាជាដាច់ខាត។

- សូមនាងអភ័យទោសដល់ខ្ញុំផងចុះ តែបើសិនជានាងមានការលំបាកក្នុងការបើកប្រាក់បំនាច់អោយអណ្តាប់ទាំងប៉ុន្មានរបស់ខ្ញុំ សូមនាងយកវាទៅ។

- ចំពោះពួកទាំងនោះ គឺមានគ្រប់គ្រាន់ អោយតែយើងចាយវាយប្រយ័ត្នប្រយែងបន្តិចទៅបានហើយ។ ហើយនោះ គឺគិតទាំងសេះល្អៗបំផុត អាវុធយុទ្ធភ័ណ្ឌល្អៗបំផុតផង។ ត្រកូលគ្រួសារយើងគឺខ្លាំងនៅក្នុងរឿងនេះ។ទេ *ប៊ុនតារ៉ូ-សាន* ក្រឡរជ្ជកាល *ថាង* នេះគឺជារបស់លោក។

- ពួកយើងមិនមានសល់ពេលច្រើនទេ ។ តើអោយខ្ញុំទុកជាកេរអោយអ្នកណា ? អោយ *សាបូជី* រឺ ?

នាងសំលឹងមើលដុំធ្យូង និងព្រះអគ្គីដែលកំពុងឆេះលេបភ្នំភ្លើង :

- ទេ ។ ដរាបណាគេមិនទាន់បានក្លាយជាម្ចាស់ទឹកតែដ៏សក្តិសម អាចប្រដូចទៅនឹងឪពុកគេបាននោះ។ ខ្ញុំជូនយោបល់ថា គួរទុកក្រឡនេះទៅលោកម្ចាស់ *តូរ៉ាណាកា* ដែលសក្តិសមនឹងរក្សាទុកវា ហើយនឹងសូមអោយគាត់ជ្រើសរើសនៅមុនពេលដែលគាត់ស្លាប់នោះ ថាតើកូនរបស់យើងសក្តិសមនឹងទទួលរបស់នេះបាន រឺ ទេ ?

- ចុះបើលោកម្ចាស់ *តូរ៉ាណាកា* ចាញ់ និងស្លាប់មុនសិសិរដូវទៅវិញ ? ហើយរឿងនេះខ្ញុំច្បាស់នៅក្នុងចិត្តថា គាត់ប្រាកដជាចាញ់។

- ថាម៉េច ?



www.budinst.gov.kh www.elibraryofcambodia.org

- នៅស្ងាត់តែពីរនាក់យ៉ាងនេះ ខ្ញុំអាចនិយាយប្រាប់នាងពីការពិតដោយមិនបាច់បន្ថែមបន្ថយអ្វីទាំងអស់បាន ព្រោះថាផ្នែកមួយនៃ *ចា-ណូ-យូ* គឺការដែលគ្មានការបន្ថែមបន្ថយនោះឯង មិនអ៊ីចឹង ? ពិតមែនហើយ លោកម្ចាស់នឹងចាញ់ លើកលែងតែលោកអាចអូសទាញលោកម្ចាស់ *គីយ៉ាម៉ា*, *អ៊ីណូស៊ី*........ ហើយនឹង *សាតាគី* អោយនៅខាងលោកបាន ។

-ក្នុងករណីនេះ លោកសរសេរនៅក្នុងមរតកសាសន៍ថា ក្រឡរជ្ជកាល *ថាង* នេះត្រូវតែបញ្ជូនដោយមានក្បួនការពារផងទៅថ្វាយព្រះចៅទៅ ។ លោកធ្វើញត្តិ សូមអោយព្រះអង្គព្រមទទួលយកដង្វាយនេះ ។ ក្រឡរជ្ជកាល *ថាង* គួរទទួលបាននូវភាពជាអាទិភាព ។

- ពិតមែនហើយ ។ នេះជាជំរើសមួយសុក្រិតបំផុត -លោកពិនិត្យពិច័យកាំបិត រួចក៏ពោលឡើងទាំងស្រងូតស្រងាត់ -ហ៊ឺ *ម៉ារីកូ-សាន*។គ្មានអ្វីដែលអាចជួយលោកម្ចាស់ *តូរ៉ាណាកា* បានសោះឡើយ ។ *កាម៉ា* របស់លោកកំនត់ជាស្រេចទៅហើយ ។ គាត់ឈ្នះ រឺ គាត់ចាញ់ ។ ហើយបើសិនជាគាត់ឈ្នះ រឺ ចាញ់ក្តី គឺពិតជានឹងមានការកាប់សំលាប់យ៉ាងធំជាមិនខាន ។

- ចាស ពិតមែន ។

ក្នុងអារម្មណ៍រវើរវាយ លោកដកភ្នែកចេញពីកាំបិត ហើយសំលឹងមើលមែកឈើដែលនៅជាប់តំនក់ទឹកភ្លៀកនៅឡើយ ។ យូរបន្តិចមកទៀត លោកពោល :

- បើសិនជាលោកម្ចាស់ចាញ់ មុននឹងខ្ញុំស្លាប់ រឺបើសិនជាខ្ញុំស្លាប់ ខ្ញុំ រឺកូនចៅណាម្នាក់របស់ខ្ញុំ នឹងសំលាប់ *អាន់ជីន-សាន* ។

នៅក្នុងភាពងងឹត ទឹកមុខនាងលេចត្រដែត ។ ខ្យល់ជំនោររំភើយៗបានមកអង្រួនផាយផាត់សក់របស់នាង ធ្វើអោយនាងមានសំរស់ប្រៀបដូចជារូបចំលាក់មួយដ៏ឯកពិតៗ ។ នាងសួរ :

- សូមលោកអភ័យទោសដល់ខ្ញុំផង តែតើលោកអាចអោយខ្ញុំដឹងផងបានទេ ថាតើមកពីហេតុអ្វីទៅ ?

- ទុកអោយវាមានជីវិតរស់នៅ គឺមានគ្រោះថ្នាក់ណាស់ ។ ចំនេះដឹងរបស់វាតំនិតរបស់វា ទោះបីជាខ្ញុំគ្រាន់តែលឺតៗពីគេមកក្តី...... វានឹងពង្វក់នគរនេះជាមិនខាន ទោះជា *វ៉ៃយទម៉ុន* ក៏ដោយ ។ លោកម្ចាស់ *តូរ៉ាណាកា* ស្ថិតនៅក្រោមមន្តអំពើរបស់វាហើយ *ទេ* ?



www.budinst.gov.kh www.elibraryofcambodia.org

- លោកម្ចាស់ *តូរ៉ាណាកា* បានទទួលចំនេញពីចំនេះដឹងរបស់គាត់ -នាងតប ។

- នៅពេលណាដែលលោកម្ចាស់ *តូរ៉ាណាកា* ស្លាប់នោះគឺជាជួងមរណៈរបស់ *អាន់ជីន-សាន* ដែរ ។ តែខ្ញុំសង្ឃឹមថា លោកម្ចាស់យើងនឹងភ្ញីភ្នែកនៅមុនពេលនោះ *-ប៊ុនតារ៉ូ* ចោលភ្នែកសំលឹងមើលនាង -តើនាងលុះដោយមន្តអំពើរបស់វាដែរ រឺ ទេ ?

- គាត់គឺជាមនុស្សម្នាក់គួរអោយចាប់អារម្មណ៍ ។ ប៉ុន្តែចិត្តគំនិតរបស់គាត់គឺខុសឆ្ងាយពីយើងណាស់....ការវាយតំលៃរបស់គាត់.......ចាស គឺពិតជាខុសឆ្ងាយពីយើង ដែលនាំអោយយើងស្ទើរមិនអាចយល់គាត់បាននៅពេលខ្លះ ។ មានម្តងនោះ ខ្ញុំសាកល្បងពន្យល់គាត់ពី *ចា-ល្វ-យូ* តែរឿងនេះគឺហួសឆ្ងាយពីការយល់ដឹងរបស់គាត់ ។

- កើតជាមនុស្សចុងស្រុក គឺពិតជាវេទនាអាក្រក់អាក្រីណាស់ *-ប៊ុនតារ៉ូ* ពោល ។

- ចាស ពិតមែនហើយ ។

ភ្នែករបស់ *ប៊ុនតារ៉ូ* សំលឹងមើលផ្ទៃគាំបិតរបស់ *ម៉ារីកូ* :

- មានអ្នកខ្លះគិតថា *អាន់ជីន-សាន* ពីជាតិមុនជាជនជាតិជប៉ុន ។ វាមិនដូចពួកចុងស្រុកឯទៀតៗទេ ហើយវា....... វាខិតខំខ្លាំងណាស់ដើម្បីរៀននិយាយ និងធ្វើអាកា:ៈ ដូចជាពួកយើង ថ្វីបើវាមិនបានទទួលជោគជ័យក៏ដោយ *ទេ* ?

- ខ្ញុំចង់អោយលោកឃើញគាត់វិះធ្វើ *សិបពូគូ* ម្ល៉េះទេ *ប៊ុនតារ៉ូ-សាន*។ ខ្ញុំ.....នោះគឺពិតជាអស្ចារ្យណាស់ ។ ខ្ញុំបានឃើញមច្ចុរាជមកដល់ខ្លួនគាត់ តែត្រូវបានដៃរបស់ *អូមី* ច្រានចេញទៅវិញ។ បើសិនជាពីជាតិមុនគាត់ជាជនជាតិជប៉ុនមែន នោះអាចអោយយើងយល់បានរឿងជាច្រើនទាក់ទិននឹងរូបគាត់ ។ លោកម្ចាស់ *តូរ៉ាណាកា* យល់ថា នៅពេលនេះគាត់មានតំលៃណាស់សំរាប់ពួកយើង ។

-ល្មមដល់ពេលដែលនាងឈប់បង្វឹកបង្ហាត់វា ហើយក្លាយខ្លួនជាជប៉ុនឡើងវិញហើយ ។

- លោកមានប្រសាសន៍ថាម៉េច ?

- ខ្ញុំគិតថា លោកម្ចាស់ *តូរ៉ាណាកា* ត្រូវមន្តអំពើរបស់វាហើយ ។ នាងក៏អីចឹងដែរ ។

- សូមលោកអភ័យទោសដល់ខ្ញុំផងចុះ ប៉ុន្តែខ្ញុំមិនអាចគិតថាខ្ញុំត្រូវមន្តអំពើនោះទេ ។



www.budinst.gov.kh www.elibraryofcambodia.org

- កាលពីយប់មួយនៅ *អាន់ជ៊ី* អាយប់ដែលមានរឿងអាក្រក់នោះ ខ្ញុំមានអារម្មណ៍ថា នាងរួមជាមួយវាប្រឆាំងនឹងខ្ញុំ។ តាមពិតនេះជាគំនិតតែផ្តេសផ្តាសទេ តែគឺខ្ញុំមានអារម្មណ៍យ៉ាងនេះមែន។

ក្រសែភ្នែកនាងបានចេញផុតពីផ្ទៃកាំបិត។ នាងសំលឹងមុខ *ប៊ុនតារ៉ូ* យ៉ាងមាំ ប៉ុន្តែនាងឥតឆ្លើយតបឡើយ ។ ចង្កៀងមួយទៀតបានឈ្ងួលឆេះមួយវិបរួចក៏រលត់ឈឹងទៅ ។ អីលូវនេះនៅក្នុងបន្ទប់មានប្រភពពន្លឺតែមួយគត់។

*ប៊ុនតារ៉ូ* បន្តក្នុងសំលេងយ៉ាងនឹងនដដែល :

- ពិតមែនហើយ នៅយប់នោះខ្ញុំសែនស្អប់វា។ ហើយខ្ញុំចង់អោយវាងាប់ទាំងនាងទាំង *ភូជីកូ-សាន* ថែមទៀត។ ធ្វូខ្ញុំបានខ្សឹបសួរសុំប្រហារជីវិត។ ហើយនៅពេលព្រឹកព្រលឹមឡើង ពេលដែលខ្ញុំឃើញវាដើរចុះកូនភ្នំជាមួយកូនកាំភ្លើងច្រមក់ដ៏កំសាកនោះ ព្រួញរបស់ខ្ញុំទទូចអង្វរសុំហុតឈាមរបស់វា។ តែខ្ញុំបានសំរេចចិត្តមិនធ្វើឃាតវា ហើយដាក់ខ្លួនរាបសារ ព្រោះខ្ញុំស្អប់ខ្លួនឯង លើសនេះទៅទៀត ដោយហេតុមកពីកង្វះសុជីវធម៌របស់ខ្ញុំ និងដោយមកពី *សាកេ* នេះឯង -ភាពនឿយហត់របស់លោកបានលេចចេញមកយ៉ាងច្បាស់ -ទាំងនាង ទាំងខ្ញុំ យើងត្រូវទទួរភាពអាម៉ាស់យ៉ាងច្រើន *នេ*?

- ចាស។

- នាងមិនចង់អោយខ្ញុំសំលាប់វាទេអ្ហី ?

- លោកត្រូវធ្វើនូវអ្វីដែលលោកដឹងថាជាភារកិច្ចរបស់លោក -នាងតប -ដូចជាខ្ញុំតែងតែធ្វើភារកិច្ចរបស់ខ្ញុំអីចឹងដែរ។

- យប់នេះ យើងស្នាក់នៅក្នុងផ្ទះសំនាក់នេះ -លោកនិយាយ។

- ចាស។

ដោយថានាងជាភ្ញៀវដ៏សុក្រឹតនៅក្នុងយប់នេះផង និងដោយ *ចា-ណូ-យូ* បានប្រកបដោយជោគជ័យបំផុតតាំងពីលោកធ្វើវាមក *ប៊ុនតារ៉ូ* ក៏ប្តូរគំនិត ហើយក៏ទុកអោយនាងនូវពេលវេលា និងភាពស្ងប់ស្ងាត់ អោយបានស្មើនឹងការដែលលោកបានទទួលពីនាងផងដែរ ។ លោក



www.budinst.gov.kh www.elibraryofcambodia.org

និយាយទៅកាន់នាង ៖

- អីលូវនេះ នាងទៅផ្ទះសំនាក់ ហើយគេងចុះ ។

លោកចាប់យកកាំបិត ហើយហុចជូនទៅនាង ៖

- នៅពេលដែលដើមឈើជ្រុះស្លឹក រឺនៅពេលណាដែលនាងវិលត្រលប់មកពី *អូសាកា* វិញ យើងនឹងចាប់ផ្តើមសាជាថ្មីឡើងវិញ ។ ក្នុងឋានៈជាប្តីប្រពន្ធ ។

- ចាស ។ សូមអរគុណលោក ។

- តើនាងយល់ព្រមដោយស្ម័គ្រស្មោះ រឺទេ ? *ម៉ារីកូ-សាន* ?

- ចាស ។ សូមអរគុណលោក ។

- នៅចំពោះមុខព្រះជាម្ចាស់របស់នាង ?

- ចាស ។ នៅចំពោះមុខព្រះជាម្ចាស់ ។

*ម៉ារីកូ* លំអោនខ្លួនគោរព ទទួលយកកូនកាំបិត ហើយយកវាទៅទុកនៅកន្ទែងអាចិកំបាំងរបស់វា រួចអោនខ្លួនគោរពម្តងទៀតទើបចេញទៅ ។

ស្នូរជើងរបស់នាងលឺឆ្ងាយទៅៗ ។ *ប៊ុនតារ៉ូ* អោនសំលឹងមើលមែកឈើដែលស្ថិតនៅក្នុងដៃរបស់ខ្លួននៅឡើយ ។ តំនក់ទឹកភ្លែកនៅជាប់លើស្លឹកឈើនៅឡើយ ។ ស្រាមដៃរបស់លោកឡើងញ័រនៅពេលដែលលោកដាក់មែកឈើយ៉ាងថ្នមៗទៅលើរងើកភ្លើងចុងក្រោយ ។ ស្លឹកឈើតូចៗដែលមានពណ៌បៃតងស្រស់ឡើងរួញ ហើយឆេះក្លាយជាធ្យូងមួយរំពេច ។ តំនក់ទឹកភ្នែកក៏រលាយបាត់ក្នុងសំលេងផ្ទុះផែសផ្ទុស ។

រួចយ៉ាងស្ងៀមស្ងាត់ លោកចាប់ផ្តើមស្រក់ទឹកភ្នែកទាំងក្តៅក្រហាយ ដោយមួយរំពេចនោះលោកប្រាកដនៅក្នុងវិញ្ញាណរបស់លោកថា នាងបានក្បត់លោកជាមួយ *អាន់ជីន-សាន* ហើយ ។

*ប្លាក់ថន* ប្រទះឃើញនាងចេញពីសួនច្បារ ហើយដើរកាត់ទីធ្លាដែលមានពន្លឺព្រោងព្រាត ។ គេស្ងើរបាត់ដង្ហើមនៅចំពោះមុខភាពដ៏បរិសុទ្ធនៃសោភ័ណភាពរបស់នាង ។ នៅឯខាងកើត មេឃភ្លឺល្អះៗហើយ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

- សួស្តី *ម៉ារីកូ-សាន*។

- អូហ៍.....សួស្តី *អាន់ជីន-សាន* ! សូមទោស..... លោកធ្វើអោយខ្ញុំលស់ព្រលឹងតែម្តង..... ខ្ញុំឥតបានឃើញលោកនៅទីនេះ ។ លោកមិនទាន់សំរាន្តទេ ?

- ទេ *តូរមេន ណាកសៃ*។ ខ្ញុំក្រោកទាន់ពេលទេ -គេញញឹម ហើយចង្អុលទៅមេឃដែលកំពុងទៀបភ្លឺ -នេះគឺជាទំលាប់ដែលខ្ញុំមាននៅពេលដើរសមុទ្ទ ។ នោះគឺក្រោកមុនព្រលឹម ដើម្បីឈរនៅលើសំពៅចាំមើលព្រះអាទិត្យ -គេញញឹមកាន់តែខ្លាំងជាងមុន -គឺនាងទេដែលមិនទាន់សំរាន្តនោះ ។

- ខ្ញុំមិនចាប់អារម្មណ៍ថា......ថារាត្រីកាលបានបញ្ចប់ទៅហើយនោះទេ ។

ពួកសាមូរ៉ៃត្រូវបានគេដាក់យាមនៅតាមគ្រប់ទ្វារចេញចូល ។ ពួកគេសំលឹងមើលអ្នកទាំងពីរក្នុងភាពងឿងឆ្ងល់ ។ *ណាកា* ក៏នៅក្នុងចំនោមនោះដែរ ។ នាងប្តូរនិយាយភាសាឡាតាំងវិញម្តង ដោយនិយាយយ៉ាងខ្សឹបៗ :

- ខ្ញុំសូមអង្វរលោក សូមលោករក្សាភ្នែករបស់លោកអោយនៅបើកជានិច្ច ។ ភាពងងឹតអន្ធការនៃរាត្រីក៏រមែងមានជាប់មកជាមួយនូវសញ្ញានៃព្រហ្មលិខិតផងដែរ ។

- សូមអធ្យាស្រ័យដល់ខ្ញុំផងចុះ ។

ស្នូរជើងសេះដែលលាន់លឺនៅច្រកទ្វារធំ បានទាញភ្នែករបស់ពួកគេទាំងពីរនាក់ចេញពីគ្នា ។ នោះគឺជាពួកថៃស្នាំង ពួកការពារ និងអ្នកដែលទៅចូលរួមបរបាញ់ ។

*តូរ៉ាណាកា* ដើរចេញមកពីខាងក្នុងប្រកបដោយទឹកមុខស្មើក ។

*ណាកា* និយាយទៅកាន់ឪពុក :

- អ្វីៗត្រូវបានរៀបចំរួចរាល់អស់ហើយលោកម្ចាស់ ។តើខ្ញុំអាចទៅជាមួយពុកបានទេ?

- ទេ ទេ អរគុណ ។ ឯងសំរាកខ្លះទៅ ។ *ម៉ារីកូ-សាន* តើ *ចា-ណូ-យូ* យ៉ាងម៉េចទៅហើយ ?

- ល្អផ្តាច់ លោកម្ចាស់ ។ចំជាល្អផ្តាច់តែម្តង ។

- *ប៊ុនតារ៉ូ-សាន* ជាកំពូលលើរឿងនេះ ។ នាងមានសំនាងមែន ។



www.budinst.gov.kh www.elibraryofcambodia.org

- ចាសលោកម្ចាស់ ។

- *អាន់ដឺន-សាន* លោកចង់ទៅបរបាញ់ទេ ? ខ្ញុំចង់រៀនពីរបៀបបង្ហោះស្ទាំងរបស់លោកម្តង ។

- លោកម្ចាស់ ?

*ម៉ារីកូ* បកអោយ *ប្លាក់ថន* ស្តាប់ ។ គេតបថា :

- បាទ សូមអរគុណ លោកម្ចាស់ ។

- ល្អ -*តូរ៉ាណាកា* ចង្អុលបង្ហាញសេះមួយ -លោកមកជាមួយខ្ញុំ ។

- បាទ លោកម្ចាស់ ។

*ម៉ារីកូ* សំលឹងមើលគេចាកចេញទៅ ។ នៅពេលដែលពួកគេបំបាយសេះឡើងចំនោតផ្លូវហើយនោះ នាងក៏ដើរតំរង់ទៅបន្ទប់របស់នាង ។ នារីបំរើរបស់នាងជួយដោះសំលៀកបំពាក់ជូតម្សៅលាបមុខ និងស្រាយសក់របស់នាង ។ បន្ទាប់មកនាងប្រាប់នារីបំរើនេះអោយនៅក្នុងបន្ទប់ជាមួយនាង និងប្រាប់មិនអោយអ្នកណាមករំខាននាងរហូតដល់ថ្ងៃត្រង់ ។

- ចាស អ្នកស្រី ។

នាងក៏ប្រាសខ្លួន បិទភ្នែក ហើយក៏បណ្តោយខ្លួនអោយលិចទៅក្នុងភាពកក់ក្តៅដ៏សែនសុខនៃកំរាលភួយ ។ នាងហត់ផង រីករាយនៅក្នុងចិត្តផង ។ *ចា-ណូ-យូ* បានរុញច្រាននាងអោយចូលទៅក្នុងស្ថានភាពដ៏ស្ងប់ស្ងាត់ផ្នែកសតិអារម្មណ៍មួយយ៉ាងចំលែកមួយ ។ អារម្មណ៍នាងត្រូវបានជម្រុះស្អាត ។ នាងមានអារម្មណ៍ដូចនាងស្ថិតនៅក្រៅពីខ្លួននាង នៅពេលដែលនាងឆ្លើយតបយ៉ាងអត់ធ្មត់ទៅនឹងសំនួររបស់ *ប៊ុនតារ៉ូ* ។ នាងទុកចិត្តច្បាស់ថា ចំលើយរបស់នាង និងអាការៈរបស់នាងគឺសុក្រឹត ។ នាងអង្គុញខ្លួននៅលើគ្រែទាំងសែនពេញចិត្តនឹងភាពស្ងប់ស្ងាត់ដែលស្ថិតមាននៅក្នុងពេលនេះ........រហូតដល់ពេលដែលឈើជ្រុះស្លឹក ។

ឱ ! ព្រះមាតាអើយ -នាងសូត្រធម៌យ៉ាងស្ងៀវស្ងាត់ -ខ្ញុំសូមអរគុណព្រះមាតាដែលបានមានចិត្តករុណាធម៌ផ្តល់អោយមានចន្លោះពេលនេះ ។ ខ្ញុំសូមអរគុណព្រះមាតា ហើយសូមគោរពព្រះមាតាយ៉ាងស្មោះស្ម័គ្រ និងអលង្ការ.........



www.budinst.gov.kh www.elibraryofcambodia.org

តើអញនឹងធ្វើយ៉ាងម៉េចទៅ -នាងដណ្ដឹងសួរខ្លួនឯងនៅក្នុងពេលដែលភាពងោកងុយបានលុកលុយទន្រ្ទានរូបនាងហើយនោះ -បើសិនជា *ប៊ុនតាវ៉ូ* សុំរួមគ្រែជាមួយអញនោះ ?

អញពិតជាប្រកែក ។

ចុះបើគាត់នៅតែទាមទារ ដោយថានេះជាសិទ្ធិរបស់គាត់នោះ ?

អញពិតជារក្សានូវពាក្យសន្យារបស់អញ ។ ពិតហើយ ។ អ្វី១ឥតមានប្រែប្រួលទេ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

# ជំពូក ៤៤

នៅវេលាយាមមមៃ ក្បួនបានឆ្លងកាត់ស្ពានម្តងទៀត។ អ្វីៗនៅដដែលដូចរាល់ដង លើក លែងតែនៅលើកនេះ *សាកាតី* និងកូនចៅរបស់គេស្លៀកសំលៀកបំពាក់ស្រាលៗ ហើយចាប់ផ្តើមដំណើរ វិស់រាប់ការប៉ះទង្គិចគ្នាវិញម្តង។ ពួកគេប្រដាប់ដោយអាវុធយុទ្ធភណ្ឌស្អាតបាត ហើយប្រកបដោយវិន័យយ៉ាងល្អ ហើយត្រៀមខ្លួនជាស្រេចដើម្បីប្រយុទ្ធស្លាប់រស់ បើសិនជាមានការប្រយុទ្ធមែននោះ។ ពួកគេរើសកន្លែងអង្គុយដោយខ្លួនឯង និងយ៉ាងមានរបៀបរៀបរយទល់មុខកងកំលាំងរបស់ *តូរ៉ាណាកា* ដែលមានចំនួនច្រើនជាងពួកគេយ៉ាងលើសលប់។ បព្វជិត *អាលវីតូ* ជាមួយ នឹង *ប្លាក់ថន* ស្ថិតនៅម្ខាង ក្នុងចំនោមទស្សនិកជនឯទៀត។

*តូរ៉ាណាកា* ស្វាគមន៍ *សាកាតី* ក្នុងពិធីការយ៉ាងនឹងនរដដែល។ ថ្ងៃនេះ *ដៃមីញ៉ូ* ទាំងពីរនៅតទល់មុខគ្នាតែពីរនាក់នៅលើរោង។ មិក់គេនៅដាច់ឆ្ងាយពីគ្នា។ *យ៉ាប៊ូ ណាកា* និង *ប៊ុនតាវ៉ូ* នៅអង្គុយលើដីព័ទ្ធជុំវិញ *តូរ៉ាណាកា* ឯទីប្រឹក្សាសង្គ្រាមរបស់ *សាកាតី* បួននាក់ក៏អង្គុយនៅពីក្រោយម្ចាស់របស់ខ្លួនដែរ។

នៅក្នុងពេលវេលាមួយដ៏សមគួរហើយនោះ *សាកាតី* ហូតយករមូរសារទីពីរចេញមក :

- ខ្ញុំមកយកចំលើយជាផ្លូវការពីលោកហើយ។

- ខ្ញុំឯកភាពទៅ *អូសាកា* ហើយនឹងទទួលដាក់ខ្លួនតាមការសំរេចរបស់ក្រុមប្រឹក្សាហើយ -*តូរ៉ាណាកា* តបក្នុងសំលេងយ៉ាងស្មើ ហើយបន្ទាប់មកលោកលំអោនខ្លួនដាក់ *សាកាតី* ថែមទៀត។

- លោកនឹងទទួលដាក់ខ្លួនជាមួយក្រុមប្រឹក្សាមែនទេ ? -*សាកាតី* មិនជឿនូវអ្វីដែលគេបានលឺនោះឡើយ។ គេចាប់ផ្តើមនិយាយ -*តូរ៉ាណាកា -ណូ- មីណូវ៉ារ៉ា* តើលោកនឹង........

- ស្តាប់ខ្ញុំណា -*តូរ៉ាណាកា* និយាយក្នុងសំលេងបញ្ជាមួយដែលលាន់ខ្ទរពេញទីវាល តែដោយមិនមានលក្ខណៈអ្វីជាការនិយាយខ្លាំងៗឡើយ-គេត្រូវតែស្តាប់តាមបញ្ជារបស់ក្រុមប្រឹក្សារាជ្យានុសិទ្ធិ ! ថ្វីត្បិតតែក្រុមប្រឹក្សានេះមិនស្របច្បាប់យ៉ាងណាក្តី ក៏ក្រុមប្រឹក្សានេះកើតមានរួចទៅហើយៗក៏គ្មាន *ដៃមីញ៉ូ* ណាម្នាក់មានសិទ្ធិហែកនគរនេះជាពីរជាបីដែរ ទោះជា *ដៃមីញ៉ូ* នោះ



www.budinst.gov.kh www.elibraryofcambodia.org

មានសច្ចធម៌នៅខាងខ្លួនយ៉ាងណាក៏ដោយ ។ នគរជាអាទិភាពដើរមុខបំផុត ។ បើសិនជា *ដៃមីញ៉ូ* ណាម្នាក់ប៉ោនបះបោរ នោះគឺជាភារកិច្ចរបស់ *ដៃមីញ៉ូ* ទាំងអស់ដែលត្រូវតែជាន់កំទេចវាចោល ។ ខ្ញុំស្បថជូនលោកម្ចាស់ *តែកូ* ថា ខ្ញុំនឹងមិនជាអ្នកទីមួយដែលនាំបំផ្លាញសន្តិភាពនោះទេ ។ ហើយខ្ញុំនឹងមិនជាអ្នកបំផ្លាញសន្តិភាពនេះមែន ថ្វីត្បិតតែមានបិសាចនៅលើទឹកដីនេះក៏ដោយ ។ ខ្ញុំទទួលយកសេចក្តីអញ្ជើញនេះ ។ ខ្ញុំនឹងចេញដំណើរនៅថ្ងៃនេះតែម្តង ។

សាមូរ៉ៃម្នាក់ៗនឹកពិចារណាទាំងភាន់ភាំងពីមូលហេតុនៃការប្រែប្រួលជំហរយ៉ាងក្រឡាប់ចាក់បែបនេះ ។ ពួកគេសុទ្ធតែច្បាស់នៅក្នុងចិត្តថា ពួកគេ បើមិនទាំងអស់គ្នាក៏ជាភាគច្រើនដែរ នឹងក្លាយខ្លួនទៅជា *រ៉ូនីន* ជាមិនខាន ។ រួមជាមួយនឹងផលវិបាកដែលបណ្តាលមកពីស្ថានភាពនេះថែមទៀតផង នោះ គឺការបាត់បង់កិត្តិយស ការបាត់បង់ចំនូល ការបាត់បង់គ្រួសារ និងការបាត់បង់អនាគត ។

*ប៊ុនតារ៉ូ* ដឹងថាខ្លួនត្រូវតែជូន *តូរ៉ាណាកា* នៅក្នុងដំណើរចុងក្រោយនេះ ក៏ដូចជារួមជោគវាសនាជាមួយម្ចាស់ខ្លួនផងដែរ នោះគឺមរណភាពសំរាប់មួយគ្រួសារ និងមួយពូជរបស់ខ្លួន ។ *អ៊ីស៊ីដូ* ជាសត្រូវប្រចាំជីវិតដ៏ធំមួយ ដែលពិបាកនឹងលើកលែងទោសដល់ខ្លួនលោកណាស់ ។ ម្យ៉ាងទៀតតើអ្នកណាចង់រស់រានមានជីវិតធ្វើអ្វីទៀត បើអម្ចាស់របស់ខ្លួនផ្ទាល់បោះបង់ការប្រយុទ្ធដ៏ពិតប្រាកដក្នុងរបៀបដ៏កំសាកញ៉ីបែបនេះនោះ ? នេះគឺ *កាម៉ា* មែន -*ប៊ុនតារ៉ូ* គិតយ៉ាងជូរចត់នៅក្នុងចិត្ត ។

*ណាកា* ក៏សែនភាន់ភាំងណាស់ដែរ ។ មិនមាន *វ៉ៃមេឃក្រហម* ទេ ? គ្មានសង្គ្រាមប្រកបដោយកិត្តិយសទេ ? គ្មានការប្រយុទ្ធស្លាប់រស់នៅលើផ្លូវភ្នំ *ស៊ុយណាហ្គូ* រឺនៅទីវាលទំនាបនៃតំបន់ *ក្យូតូ* ទេ ? គ្មានគំនរសាកសពសត្រូវដែលត្រូវជាន់ហក់ប្រយុទ្ធជាចុងក្រោយ រឺនៅក្នុងជ័យជំនះដ៏មហាស្ចារ្យមួយទេ ? គ្មានការវាយលុក ទោះជាដោយប្រើកាំភ្លើងដ៏អាក្រក់អាក្រីនេះទេ ? គ្មានអ្វីទាំងអស់ ។ មានត្រឹមតែ *សិបពូគូ* មួយ ដែលប្រហែលជាធ្វើឡើងយ៉ាងប្រញាប់ប្រញាល់គ្មានហ៊ឹកហ៊ាក់ គ្មានពិធីការ គ្មានកិត្តិយសអ្វីទាំងអស់ ហើយក្បាលគេនឹងត្រូវដោតលើចុងលំពែងដើម្បីគ្រាន់តែប្រជាជនសាមញ្ញសើចចំអកដាក់តែប៉ុណ្ណោះ ។ គឺគ្រាន់តែមានមរណភាព ហើយនឹង



www.budinst.gov.kh www.elibraryofcambodia.org

ទីបញ្ចប់នៃត្រកូល *យ៉ូស៊ី* តែប៉ុណ្ណោះ។ ព្រោះពួកគេទាំងអស់គ្នាពិតជានឹងស្លាប់។ ទាំងឪពុកគេ បងប្អូនប្រុសស្រី ទាំងអស់របស់គេ បងប្អូនជីដូនមួយ ក្មួយ និងទាំងមីងពូ អ៊ំ ទាំងអស់របស់គេ។ ភ្នែកគេផ្តោតជាប់លើរូប *សាគាគី* ។ តំលានឈាមបានទម្រាំនលុកចូលខួរក្បាលគេឥតអាក់.....

*អូមី* បិទភ្នែកព្រឹម១សំលឹងមើល *តូរ៉ាណាកា* ជាប់។ សំអប់បានមកលេបត្របាក់រូបគេទាំងមូល។ លោកម្ចាស់យើងឆ្កួតហើយ -គេគិតនៅក្នុងចិត្ត។ ហេតុអីបានជាគាត់ល្ងីល្ងើដល់ថ្នាក់ហ្នឹង ? ពួកយើងមានគ្នាមួយរយពាន់នាក់ និងកងពលមួស្តេមួយកង ហើយនៅមានហាសិបពាន់នាក់នៅជុំវិញ *អូសាកា* ថែមទៀត ! *វ៉ៃរមេឃក្រហម* គឺរាប់លានដងប្រសើរជាងផ្លូវដ៏ស្អុយគគ្រុក និងឯកោដែរ !

ដៃរបស់ *អូមី* ឡើងចូនំពាប់លើដងដាវរបស់ខ្លួន ហើយក្នុងខណៈដ៏អស្ចារ្យនោះ គេស្រមៃឃើញខ្លួនហក់ទៅមុខកាត់ផ្តាច់ក្បាលរបស់ *តូរ៉ាណាកា* ហុចទៅអោយសមាជិកក្រុមប្រឹក្សាអាជ្ញាទុសិទ្ធិ គឺ *សាគាគី* ដើម្បីបញ្ចប់ការលេងឆាកល្ខោនដ៏ថោកទាបនេះ។ រួចដើម្បីបន្ទាប់មកទៀតគេនឹងសំលាប់ខ្លួនក្នុងកិត្តិយស នៅក្នុងទីនេះ និងនៅចំពោះមុខអ្នកផងទាំងពួង។ ព្រោះរស់នៅដើម្បីអ្វីទៀតនៅពេលនេះ ? នៅពេលនេះ *គីកូ* បានរបូតចេញផុតពីដៃរបស់គេទៅហើយ។ កិច្ចសន្យារបស់នាងត្រូវបានទិញយក និងកាន់កាប់ដោយ *តូរ៉ាណាកា* ដែលបានក្បត់ពួកគេទាំងអស់គ្នានេះ។ ពីយប់ម្សិល ខ្លួនប្រាណរបស់គេទាំងមូលដូចនៅលើរងើកភ្លើងនៅពេលដែលនាងច្រៀង ។ហើយគេដឹងថាចំរៀងនោះគឺនាងច្រៀងជាសំងាត់ដើម្បីរូបគេ ហើយសំរាប់តែរូបគេម្នាក់ប៉ុណ្ណោះ។ ជាភ្លើងដែលឥតសំនងរវាងគេនឹងនាង។ តែ....ហេតុអីបានជាយើងមិនធ្វើអត្តឃាតជាមួយគ្នាដើម្បីនៅជាមួយគ្នាជាអនន្តតែម្តង។ឱ ! បើយ៉ាងនេះមែន មិនដឹងជាផូរផង់យ៉ាងណាទេ ! ព្រលឹងយើងវេញចូលគ្នាក្នុងនាមជាសក្ខីភាពនៃការស្រលាញ់ជីវិត។ តែដំបូងបង្អស់ត្រូវគិតពីអាក្បត់ *តូរ៉ាណាកា* សិន *ទេ* ?

*អូមី* ប្រឹងយ៉ាងអស់ពីកំលាំងចិត្តដើម្បីដកខ្លួនពីសុបិន្តរវើរវាយនេះ។

អ្វី១មិនប្រក្រតីសោះ -គេគិតនៅក្នុងចិត្ត។ នៅក្នុងផ្ទះអញមិនដែលបានស្ងប់ទេគឺមានតែកំហឹងកំហល់ និងការឈ្លោះប្រកែកគ្នា។ *មីដូរី* យំរាល់ថ្ងៃ ។ អញមិនទាន់ទាំងបានសងសឹកនឹង



www.budinst.gov.kh www.elibraryofcambodia.org

*យ៉ាប៊ូ* ផង។ មិនមានការត្រូវរ៉ូវគ្នាណាមួយជាមួយ *សាកាគី* សោះកាលពីយប់មិញទោះមាន *យ៉ាប៊ូ* រឺអត់ក្តី។ គ្មានអ្វីទាំងអស់។ គ្មានអីបានស្រួលបួលទៀតទេ។ សូម្បីតែនៅពេលដែល *អូមី* រកឃើញដាវទាំងពីរហើយក្តី ក៏ដាវនោះវារមូលខូចខ្ទេចខ្ទីណាស់ទៅហើយដោយសារកំលាំងដី ហើយបើអញយកដាវនេះទៅបង្ហាញ*តូរ៉ាណាកា* អញដឹងថាគាត់ច្បាស់ជាស្អប់អញមួយអាយ៉ុស។ ហើយមកដល់ពេលចុងក្រោយនេះ មានការចុះសារភាពដ៏កំសាកនេះទៀត!

*យ៉ាប៊ូ* ស្រែកជំទាលឡើង ដោយលោកច្បាស់នៅក្នុងចិត្តពីមរណភាពរបស់លោក និងពូជពង្សរបស់លោកហើយនោះ :

- លោកចុះចាញ់ហើយ ? យើងមិនធ្វើសង្គ្រាមទេអ្វី ?

- ខ្ញុំទទួលយកការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញានុសិទ្ធិហើយ -*តូរ៉ាណាកា* តប -ដូចជាលោកនឹងទទួលយកការអញ្ជើញនេះផងដែរ !

- ខ្ញុំនឹងមិន.......

*អូមី* ដកខ្លួនពីការរវើរវាយដោយនៅស្មារតីគ្រប់គ្រាន់នឹងដឹងថា គេត្រូវតែឃាត់ *យ៉ាប៊ូ* និងការពារបុរសនេះអោយគេចផុតពីមរណភាពយ៉ាងទាន់ហន់ បណ្តាលមកពីការប៉ះទង្គិចជាមួយ *តូរ៉ាណាកា* នេះ។ ប៉ុន្តែគេនៅតែខាំមាត់ជាប់ ក្នុងចិត្តគេស្រែកកញ្ជ្រៀវទាំងអំនរ ដោយគេរង់ចាំមហន្តរាយដែលនឹងធ្លាក់លើក្បាល *យ៉ាប៊ូ* នេះ។

*តូរ៉ាណាកា* សួរទៅ *យ៉ាប៊ូ* :

- លោកនឹងមិនទទួលការអញ្ជើញទេរឺ ?

- ខ្ញុំ.....ខ្ញុំ.....-ព្រលឹង *យ៉ាប៊ូ* ហិតដឹងភ្លាមពីគ្រោះថ្នាក់ដែលនៅចំពោះមុខ។ លោកពោលទាំងត្រដាបត្រដួស -ពិតណាស់ហើយ អណ្តាប់ទាំងឡាយរបស់លោកម្ចាស់នឹងទទួលតាមបញ្ជា។ បាទ....បើសិន......បើសិនជាលោកម្ចាស់សំរេចហើយ......ទោះជា.....ទោះជាលោកម្ចាស់សំរេចយ៉ាងម៉េចក៏ដោយ ខ្ញុំ.....ខ្ញុំនឹងធ្វើតាមទាំងអស់។

*អូមី* លួចជេរបញ្ឈោរ *យ៉ាប៊ូ* តែក្នុងពោះ ហើយប្រែទឹកមុខធ្វើស្ងឹឡើងវិញ។ អារម្មណ៍របស់គេនៅតែស្រលាំងកាំងនឹងការចុះសារភាពដែលគេមិននឹកស្មានដល់នេះនៅឡើយ។



www.budinst.gov.kh www.elibraryofcambodia.org

*តូរ៉ាណាកា* ទុកអោយ *យ៉ាប៊ូ* និយាយសូមទោសទាំងរញ៉ីរញ៉ៃមួយសន្ទុះទើបនិយាយកាត់យ៉ាងប្រមាថ :

- ល្អ ។

រួចលោកក៏ងាកទៅរក *សាកាគី* វិញតែដោយមិនចោលការឃ្លាំមើលរបស់លោកឡើយ :

- ប្អូនប្រុស អាស្រ័យដោយហេតុនេះ ប្អូនអាចទុកសារទីពីរទៅវិញចុះ ។ គ្មានរឿងអីទៀត ដែល........

តាមកន្ទុយភ្នែក លោកឃើញទឹកមុខប្រែប្រួលរបស់ *ណាកា* លោកក៏ងាកផាំងទៅរកភ្លាម :

- *ណាកា* !

យុវបុរសស្ទើរបាត់ព្រលឹង តែដៃរបស់គេក៏បានឃ្លាតឆ្ងាយពីដងដាវផងដែរ ។ គេតបទាំងរដិបរដុប :

- បាទ ពុក ?

- ទៅយកប្រដាប់ប្រដាសរសេររបស់ពុកមកភ្លាម ! យកមកអីលូវនេះ!

នៅពេលដែល *ណាកា* ទៅឆ្ងាយផុតពីថ្លែងដាវនោះហើយ ទើប *តូរ៉ាណាកា* ដកដង្ហើមបន្ធូរទ្រូង ដោយសារលោកបានបញ្ចៀសផុតមុនទន្ទឹងការវាយលុកទៅលើ *សាកាគី* ។ ភ្នែករបស់លោកពិនិត្យ *ប៊ុនតារ៉ូ* យ៉ាងប្រុងប្រយ័ត្ន។ រួច *អូមី* ។ ហើយចុងក្រោយបំផុត *យ៉ាប៊ូ* ។ លោកគិតយល់ថា អ្នកទាំងបីនាក់នេះម្ចាស់ការលើចិត្តរបស់ខ្លួនបានយ៉ាងគ្រប់គ្រាន់ដើម្បីចៀសវាងមិនធ្វើទំរើចំកួតលេលាណាមួយដែលនឹងនាំអោយមានការបះបោរ និងការសំលាប់រង្គាលឡើយ ។

ជាថ្មីម្តងទៀត លោកពោលទៅកាន់ *សាកាគី* :

- ខ្ញុំនឹងផ្តល់ជូនលោកនូវការទទួលយល់ព្រមរបស់ខ្ញុំជាលាយលក្ខណ៍អក្សរក្នុងពេលអីលូវនេះភ្លាម ។ ប្រការនេះនឹងអាចអោយក្រុមប្រឹក្សាអាជ្ញានុសិទ្ធិមានឱកាសគ្រប់គ្រាន់ ដើម្បីរៀបចំទស្សនកិច្ចជាផ្លូវការរបស់ខ្ញុំ-រួចលោកបន្ទាបសំលេង ដើម្បីមានតែ*សាកាគី*ម្នាក់ប៉ុននោះ



www.budinst.gov.kh www.elibraryofcambodia.org

ដែលអាចលើសដីលោកបាន -នៅក្នុងតំបន់ *អ៊ីស៊ូ* លោកឯងក៏មានសុវត្ថិភាព ។ នៅពេលណាដែល ម្ដាយរបស់ខ្ញុំមិនទាន់ចេញផុតពីកណ្ដាប់ដៃរបស់លោកឯង១មានសុវត្ថិភាព។គឺសុវត្ថិភាពត្រឹមពេលនោះទេ។ អីលូវនេះ ជំនួបនេះគឺចប់ហើយ ។

- ល្អ។ " ទស្សនកិច្ចជាផ្លូវការ " ?-*សាកាគី* បង្ហាញនូវភាពប្រមាថយ៉ាងធំហ -អីក៏លាក់ពុតម្លេះ ? ខ្ញុំមិនដែលនឹកស្មានថាមានថ្ងៃដែលខ្ញុំឃើញ *យ៉ូស៊ី-តូរ៉ាណាកា-ណូ-មីណូរ៉ាក់* លុតជង្គង់ក្រាបនៅមុខមេទ័ព *អ៊ីស៊ីដូ* សោះទេ។ លោកគ្រាន់........

- តើអ្វីដែលសំខាន់ជាង ប្អូនប្រុស ? -*តូរ៉ាណាកា* និយាយកាត់ -និរន្តរភាពនៃត្រកូលខ្ញុំ ក៏និរន្តរភាពនៃនគរ ?

☆ ☆ ☆

ភាពទុក្ខសោកបានគ្របដណ្ដប់ជ្រលងភ្នំ។ ភ្លៀងធ្លាក់ដូចគេចាក់ទឹក។ ពពកនៅប្រហែលជាហាសិបម៉ែត្រពីលើដី ហើយបាំងបិទជិតងងឹតនូវផ្លូវដែលឡើងទៅកាន់មាត់ច្រកភ្នំ។ ទីវាល និងទីធ្លាផ្ទះសំនាក់ពោរពេញទៅដោយពួកសាមូរ៉ៃដែលកំពុងក្រពុលមុខ។ សេះជញ្ជ្រាំជើងវន្ទាន់ដោយការធុញថប់។ ពួកនាយកងស្រែកបញ្ជាក្នុងភាពម៉ឺងម៉ាត់មួយដែលមិនចាំបាច់។ ពួកកងដឹកជញ្ជូនញាប់ដៃញាប់ជើងទាំងស្ងួនស្លោដើម្បីរៀបចំការចេញដំណើររបស់ក្បួន ។ នៅមិនដល់មួយម៉ោងទៀតទេ មេឃនឹងងងឹតហើយ។

*តូរ៉ាណាកា* បានសរសេរសារមួយពោរពេញដោយការបញ្ចើចបញ្ចើ រួចចុះហត្ថលេខារបស់លោក ហើយបានអោយអ្នកនាំសារយកទៅអោយ *សាកាគី* ទោះបីជាមានការអង្វរពីសំនាក់ *ប៊ុនតារ៉ូ* . *អូមី* និង *យ៉ាប៊ូ* នៅក្នុងការប្រជុំជាសំងាត់មួយយ៉ាងណាក្ដី។ លោកបានស្ដាប់រាល់ទឡ្ហីករណ៍របស់ពួកគេយ៉ាងស្ងៀមស្ងាត់។

នៅពេលដែលពួកគេនិយាយចប់ហើយ លោកពោលឡើង :

- ខ្ញុំមិនចង់មានការជជែកអ្វីទៀតទេ។ ខ្ញុំបានសំរេចពីផ្លូវដើររបស់ខ្ញុំរួចហើយ។ គោរពតាមទៅ !

រួចលោកបានប្រាប់ពួកគេទាំងនេះថា លោកនឹងវិលត្រលប់ទៅ *អាន់ជីរ៉ូ* ជាបន្ទាន់ ដើម្បី



www.budinst.gov.kh www.elibraryofcambodia.org

ប្រមែប្រមូលកូនទ័ពរបស់លោកដែលនៅសេសសល់ទាំងប៉ុន្មាននោះថែមទៀត ។ នៅវេលាស្អែក លោកនឹងធ្វើដំណើរតាមផ្លូវបណ្តោយឆ្នេរសមុទ្រខាងកើតសំដៅទៅ *អាកាមី* និង *អូដាវ៉ារ៉ា* រួច លោកនឹងឆ្លងច្រកភ្នំនៅម្តុំនោះដើម្បីទៅ*យេដូ*។ *ប៊ុនកាវ៉ូ* ជាមេដឹកនាំក្បួនដំណើរនេះ។ នៅវេលាថ្ងៃស្អែកនេះដែរ កងពលមួស្កេនឹងឡើងទូកធំនៅ *អាន់ជីរ៉ូ* ហើយចេញដំណើរតាមសមុទ្រទៅរង់ចាំនៅឯ *យេដូ* ។ *យ៉ាប៊ូ* ជាអ្នកទទួលដឹកនាំពួកនេះ។ នៅថ្ងៃបន្ទាប់ *អូមី* ត្រូវទៅអោយដល់ព្រំដែន ដោយធ្វើដំណើរតាមផ្លូវកណ្តាលជាមួយកងទ័ពដែលមានទាំងប៉ុន្មាននៅក្នុងតំបន់ *អ៊ីស៊ូ*។ *អូមី* ត្រូវជួយ *ហ៊្សី-មាត់ស៊ី* ដែលទទួលបន្ទុកជាមេបញ្ជាការរួម ហើយនឹងដើម្បីការពារកុំអោយពួកសត្រូវទាំងឡាយដូចជា *អ៊ីកាវ៉ា ជីគីយូ* ជាដើម មករារាំងដល់ការចល័តទ័ពនេះ។ *អូមី* ត្រូវបោះទីតាំងនៅ *មីស៊ីម៉ា* មួយរយៈ ដើម្បីការពារកំនាត់ផ្លូវ *តូកៃដូ* នេះផង ដើម្បីប្រមែប្រមូលត្រៃស្អែង និងសេះអោយបានគ្រប់គ្រាន់សំរាប់ *តូរ៉ាណាកា* និងអ្នកហែហមដ៏ច្រើនសន្ធឹកសន្ធាប់ដែលត្រូវរួមដំណើនៅក្នុងទស្សនកិច្ចផ្លូវការបែបនេះផង។

លោកបន្ថែមថា :

- អោយសញ្ញាទៅគ្រប់ប៉ុសដែលនៅតាមបណ្តោយផ្លូវ ហើយអោយពួកវាត្រៀមអោយស្រេចបាច់ផង។ យល់ហើយរឺនៅ ?

- បាទ ទាន?

- មើលពិនិត្យអោយជាក់ច្បាស់ថា អ្វីៗគឺអោយសុក្រឹតមែនទែន។

- បាទ ទាន។ សូមលោកម្ចាស់ទុកចិត្តលើខ្ញុំបាទចុះ ទាន។

សូម្បីតែ *អូមី* ក៏ត្រូវភ្ញាក់នឹងក្រសែភ្នែកដ៏គួរអោយខ្លាចនេះដែរ។

នៅពេលដែលអ្វីៗ ត្រូវបានរៀបចំសព្វគ្រប់សំរាប់ការចេញដំណើររបស់លោកហើយនោះ *តូរ៉ាណាកា* ក៏ដើរចេញពីបន្ទប់របស់លោកទៅយ៉ាបខាងក្រៅវិញម្តង។ ទាំងអស់គ្នាលំអោនខ្លួនគោរពជាប់។ លោកធ្វើសញ្ញាយ៉ាងជូរចត់អោយគេបន្តការងាររបស់គេបន្តទៅទៀតចុះ ហើយលោកក៏ប្រើគេទៅហៅម្ចាស់ផ្ទះសំនាក់មកជួបដើម្បីគិតលុយ ។ ថ្លៃឈ្នួលគឺសមរម្យនៅពេលដែលគេយកមកជូនលោកពិនិត្យ ។លោកងក់ក្បាលឯកភាព រួចបោះទៅអោយមេការរបស់លោក



www.budinst.gov.kh www.elibraryofcambodia.org

ដើម្បីទូទាត់លុយគាត់ ហើយលោកក៏ប្រើគេអោយទៅហៅ *ម៉ារីកូ* និង *អាន់ជីន-សាន* មកជួប ។ *ម៉ារីកូ* ត្រូវបានទទួលការអនុញ្ញាតអោយទៅ *អូសាកា* :

- ប៉ុន្តែដំបូងនាងត្រូវចេញដំណើរពីទីនេះឆ្ពោះត្រង់ទៅ *មីស៊ីម៉ា* តែម្តង ។ សូមប្រគល់សារផ្ទាល់ខ្លួននេះទៅអោយ *ហ៊ីរ៉ូ-ម៉ាត់ស៊ុ-សាន* រួចទើបនាងបន្តដំណើរទៅ *យេដូ* ជាមួយ *អាន់ជីន-សាន* ។ នាងជាអ្នកទទួលខុសត្រូវលើរូបគាត់រហូតដល់ទីនោះ ។ នាងប្រហែលជានឹងត្រូវធ្វើដំណើរទៅ *អូសាកា* តាមសមុទ្រហើយ ។ ខ្ញុំនឹងសំរេចពីរឿងនេះនៅពេលក្រោយទៀត ។ *អាន់ជីន-សាន* ! តើលោកមានបានទទួលវចនានុក្រមពីបព្វជិត-*សាន* ហើយរឺនៅ ?

- សូមទោស ? ខ្ញុំស្តាប់មិនបានទេ សូមទោស ។

*ម៉ារីកូ* ក៏បកអោយ ។

- សូមទោសផងចុះ ។ បាទ ខ្ញុំ សៀវភៅ បានហើយ ។

- នៅពេលដែលយើងជួបគ្នានៅ *យេដូ* លោកនឹងនិយាយភាសាជប៉ុនបានល្អជាងពេលនេះជាមិនខាន ។ *ភ៉ារី ម៉ាស៊ុ កា* ?

- *វ៉ៃ* ។ *គូមេនណាសៃ* ។

*តូរ៉ាណាកា* ដើរចេញទៅទីធ្លាទាំងអស់ទឹកចិត្ត ។ សាមូរ៉ៃម្នាក់កាន់ឆត្រមួយយ៉ាងធំដើម្បីការពារលោកនឹងទឹកភ្លៀង ។ ទាំងពួកសាមូរ៉ៃ ទាំងអ្នកស្នែង ទាំងអ្នកភូមិ ទាំងអស់ត្វាលំអោនខ្លួនគោរពលោកព្រម១គ្នាដូចមនុស្សតែម្នាក់ ។ *តូរ៉ាណាកា* ឥតបានយកចិត្តទុកដាក់ដល់អ្នកណាម្នាក់ឡើយ ។ លោកចូលទៅក្នុងគ្រែស្នែងដែលមានដំបូលជិតពីលើ ហើយដែលស្ថិតនៅពីខាងមុខក្បួននោះ រួចរូតរនាំងបាំងជិតស្លុងតែម្តង ។

ពួកអ្នកស្នែងប្រាំមួយនាក់ដែលមានខ្លួនអាក្រាតពាក់កណ្តាលនោះ ក៏លើកគ្រែស្នែងឡើងព្រម១គ្នា ហើយក៏រត់ចេញត្រឹក១ទៅ ។ ជើងទទេរបស់ពួកគេធ្វើអោយខ្ទាតទឹកខ្វាយ ។ ពួកសាមូរ៉ៃបំផាយសេះនាំផ្លូវទៅមុខគេបង្អស់ ហើយសាមូរ៉ៃមួយកងទៀតនៅជិះសេះព័ទ្ធជុំវិញគ្រែស្នែង ។ ពួកអ្នកស្នែងសំរាប់ជំនួស និងកងដឹកអីវ៉ាន់អីវ៉ាន់ទៅតាមពីក្រោយទាំងរបាន់ ទាំងធ្ងន់ពាប់និងទាំងភ័យខ្លាច ។ *អូមី* ជាអ្នកដឹកនាំក្បួន ។ *ប៊ុនតារ៉ូ* ជាអ្នកបញ្ជាទ័ពក្រោយ ។ *យ៉ាប៊ូ* និង *ណាកា*



www.budinst.gov.kh www.elibraryofcambodia.org

បានចេញដំណើរមុននេះ ដើម្បីទៅកាន់កងពលមូស្គេ ដែលកំពុងបង្កប់ខ្លួននៅតាមបណ្តោយផ្លូវលើកំពូលភ្នំនៅឡើយ ។ ពួកនេះនឹងត្រូវបិទគូទក្សួន ។ " បិទគូទគទប់នឹងអ្នកណា ? " *យ៉ាប៊ូ* ដណ្តឹងសួរទៅ *អូមី* នៅក្នុងមួយខណៈដែលគេនៅតែពីរនាក់ ហើយគេក៏បំផាយសេះចេញយ៉ាងលឿនទៅ ។

*ប៊ុនតារ៉ូ* វិលត្រលប់មកដល់មាត់ទ្វាររបងផ្ទះសំនាក់វិញ ដោយឥតរវីរវល់អ្វីនឹងភ្លៀងធ្លាក់ដ៏ធំនេះឡើយ :

- *ម៉ារីកូ-សាន* !

នាងរត់ចេញទៅយ៉ាងគោរព ។ ឆត្រក្រដាសពាសប្រេងពណ៌លឿងរបស់នាងត្រូវទឹកភ្លៀងធ្លាក់លើខ្ទោក១ :

- ចាស លោក ?

ភ្នែករបស់ *ប៊ុនតារ៉ូ* សំលឹងមើលមុខនាង រួចវាសទៅ *ព្លាក់ថន* ដែលកំពុងសំលឹងមើលមកពីក្រោមយ៉ាបរានហាល :

- ប្រាប់វាថា.....-រួចលោកឈប់នៅស្ងៀម ។

- លោក ?

លោកអោនសំលឹងមើលនាង :

- ប្រាប់វាថា ខ្ញុំចាត់វាជាអ្នកទទួលខុសត្រូវលើរូបនាង ។

- ចាស លោក -នាងតប -តែសូមលោកអភ័យទោសដល់ខ្ញុំផង ។ ខ្ញុំជាអ្នកទទួលខុសត្រូវលើរូប ខ្ញុំ ។

*ប៊ុនតារ៉ូ* ងាកទៅប្រមាណមើលពីចំងាយឃ្លាតគ្នារវាងរូបលោក នឹងក្បាលក្សួន ។ នៅពេលដែលលោកបែរមុខមកវិញ ទឹកមុខរបស់លោកពោរពេញទៅដោយសេចក្តីឈឺចាប់ :

- អីលូវនេះ គឺគ្មានស្នឹកឈើចាកមែកសំរាប់ចក្ខុរបស់យើងទេ *ទេ* ?

- រឿងនេះ គឺព្រះជាអ្នកសំរេចទេ លោក ។

- ទេ រឿងនេះគឺស្ថិតនៅក្នុងការសំរេចរបស់លោកម្ចាស់ *តូរ៉ាណាកា* -លោកពោលទាំង



www.budinst.gov.kh www.elibraryofcambodia.org

ក្នុងអាគារៈប្រមាថ ។

នាងងើយមុខសំលឹងតបនឹងក្រសែភ្នែកប្ដីឥតព្រិច ។ ភ្លៀងនៅតែបន្តធ្លាក់ចុះឥតដាច់ ។ តំនក់ទឹកភ្លៀងដែលហូរតាមតែមធត្រូវរបស់នាង ប្រៀបបីដូចជារនាំងទឹកភ្នែកយ៉ាងនោះដែរ ។ ភក់ខ្វាតប្រលាក់ពេញជាយគីម៉ូណូរបស់នាង ។ រួចលោកក៏ពោលឡើង :

- *សាយ៉ូណារ៉ា*.....រហូតដល់ខ្ញុំនឹងជួបនាងនៅឯ *អូសាកា* ។

- សូមទោស ?.....-នាងសែនភ្ញាក់ផ្អើលជាពន់ពេក -បើអ៊ីចឹងខ្ញុំនឹងមិនជួបលោកនៅឯ *យេដូ* ទេរឺ ? លោកច្បាស់ជាទៅទីនោះជាមួយលោកម្ចាស់ *តូរ៉ាណាកា* ដែរមែនទេ ? លោកពិតជាទៅដល់នោះដំណាលគ្នានឹងខ្ញុំដែរណឹង *នេ* ? ខ្ញុំនឹងជួបលោកនៅពេលនោះ ។

- ពិតហើយ ។ តែយើងនឹងចាប់ផ្ដើមតែនៅពេលណាដែលយើងជួបគ្នានៅ *អូសាកា* រឺនៅពេលណាដែលនាងវិលត្រលប់មកវិញតែប៉ុននោះ ។ ហើយគឺនៅពេលនោះហើយ ដែលខ្ញុំនឹងជួបនាងដោយពិតប្រាកដមែន *នេ* ?

- អូហ៍ ចាស ខ្ញុំយល់ហើយ ។ សូមអភ័យទោសដល់ខ្ញុំផង ។

- *សាយ៉ូណារ៉ា ម៉ារីកូ-សាន*។

- *សាយ៉ូណារ៉ា* លោកម្ចាស់របស់ខ្ញុំ ។

*ម៉ារីកូ* លំអោនខ្លួនគោរព ។ *ប៊ុនតារ៉ូ* គោរពតបវិញ រួចក៏ដើរកាត់ថ្លុកទឹកសំដៅទៅសេះរបស់ខ្លួន ។ លោកលោតផែលលើខ្នងសេះ ហើយបំផាយសេះចេញទៅដោយឥតងាកក្រោយឡើយ ។

- សូមព្រះជាម្ចាស់តាមថែរក្សាលោក ។

*ម៉ារីកូ*និយាយទាំងផ្ដោតភ្នែកលើរូបរាងរបស់ *ប៊ុនតារ៉ូ*ដែលឃ្លាតចេញឆ្ងាយបន្តិចម្ដង១ ។ *ប្លាក់ថន* សំលឹងមើលភ្នែករបស់ *ម៉ារីកូ* ដែលតាមមើល *ប៊ុនតារ៉ូ* ផាយសេះចេញទៅ ។ គេនៅរង់ចាំក្រោមដំបូលយ៉ាបរានបាល ។ព្រះអរុណកាន់តែបន្ថយឥទ្ធិពលបន្តិចម្ដង១ទៅហើយ ។ បន្តិចក្រោយមក ក្បាលក្បួនក៏បានកប់បាត់ទៅក្នុងពពកដែលនៅជាសឯមាត់ច្រកភ្នំ រួចបន្ទាប់មកក៏ដល់វេនត្រែស្នែងរបស់ *តូរ៉ាណាកា* ។ នៅពេលនោះទើបគេដកដង្ហើមបានធូរជាងមុន ដោយថា



www.budinst.gov.kh www.elibraryofcambodia.org

អារម្មណ៍របស់គេនៅតែរញ្ជួយញាប់ញ័រនឹង *តូវ៉ាណាកា* ហើយនឹងទិវាប្រកបដោយប្រផ្នូលអាក្រក់នេះនៅឡើយ ។

កាលពីព្រឹកមិញនេះ ការបង្ហោះស្ទាំងបានចាប់ផ្តើមទៅយ៉ាងល្អ ។គេបានជ្រើសរើសយកស្ទាំងតូច តែមានបន្ទារស្លាបវែងមួយ ហើយគេបានបង្ហោះវាឆាបបានដោយជោគជ័យនូវក្រួចអ៊ីតមួយ ។ គេបានដឹកនាំការបរបាញ់ទៅតាមបុព្វសិទ្ធិនៃឋានៈរបស់គេ ដោយបានដើររុកព្រៃតាមផ្លូវលំមួយដែលអ្នកចំការ និងអ្នកលីសែងតែងដើរកាត់ ។ គេក៏ស្រាប់តែជួបនឹងឈ្មួញលក់ប្រេងមានសេះកញ្ចាស់ដ៏ហត់នឿយមួយនៅរាំងស្ទះផ្លូវ ហើយច្រងេងច្រងាង មិនព្រមចៀសផ្លូវអោយទៀត ។ នៅក្នុងភាពសប្បាយ និងរហន់ក្នុងការបរបាញ់នេះ *ភាក់ថន* បានស្រែកគំហកអោយបុរសនេះចៀសចេញពីផ្លូវ ហើយនៅពេលដែលបុរសនេះមិនព្រមធ្វើតាមបង្គាប់ខ្លួន គេស្រែកបញ្ជោរបុរសនោះយ៉ាងចាស់ដៃ ។ ឈ្មួញប្រេងក៏មិនណាយ ក៏បានជេរបញ្ជោរតបវិញ ចំពេលដែល *តូវ៉ាណាកា* មកដល់ល្មម ។ពេលនោះ *តូវ៉ាណាកា* ចង្អុលទៅកងការពាររបស់លោកដោយនិយាយថា ៖

- *អាន់ជីន-សាន* សូមលោកអោយដាវរបស់លោកទៅវាមួយភ្លែត ។

ហើយលោកនិយាយថែមច្រើនម៉ាត់ទៀត ដែលគេស្តាប់មិនបានសោះឡើយ ។ គេទទួលធ្វើតាមបញ្ជាភ្លាម ។ នៅមុនពេលដែលគេយល់ពីរឿងអីនោះ សាមូរ៉ៃដែលទទួលដាវពីគេនោះ បានហក់ទៅរកឈ្មួញប្រេងបាត់ទៅហើយ ។ សន្ទុះដាវរបស់បុរសនេះចំជាសាហាវ និងឥតខ្ចោះ រហូតដល់ឈ្មួញប្រេងដើរបានមួយជំហានទើបដួល ដោយដាច់ខ្លួនជាពីរត្រឹម ។

*តូវ៉ាណាកា* ទះដងដាវរបស់លោកយ៉ាងរន្ធាន់ដោយការពេញចិត្តមួយរយៈ រួចលោកក៏ធ្លាក់ចុះទៅក្នុងភាពស្រងូតស្រងាត់វិញដដែល ក្នុងខណៈដែលពួកសាមូរ៉ៃឯទៀតស្រែកហ៊ោរកញ្ជៀវថ្លែងសរសើរស្នាដៃនេះ ។ បុរសការពារនេះក៏ជូតសំអាតផ្លែដាវយ៉ាងយកចិត្តទុកដាក់ដោយប្រើក្រណាត់ដែលជាខ្សែចង្កេះរបស់ខ្លួនដើម្បីថែរក្សាដែកថែបនេះអោយនៅតត់មត់ ។ គេស៊កដាវទៅក្នុងស្រោមដោយការពេញចិត្តពេញថ្លើម ហើយក៏ប្រគល់ដាវទៅ *ភាក់ថន* វិញ ដោយមានទាំងនិយាយពាក្យប៉ុន្មានម៉ាត់ ដែលនៅពេលក្រោយមកទៀត *ម៉ារីកូ* បកប្រាប់ថា ៖ " គាត់គ្រាន់តែនិយាយថា គាត់មានមោទនភាពណាស់ដែលគាត់បានទទួលការអនុញ្ញាតអោយសាកផ្លែ



www.budinst.gov.kh www.elibraryofcambodia.org

ដាវនេះ ។ លោកម្ចាស់ *តូរ៉ាណាកា* ស្នើថា លោកគួរដាក់រហស្សនាមដាវនេះថា " ឈ្មួញប្រេង " ពីព្រោះតែស្នៀតដាវរបៀបនេះ និងមុខមុតស្រួចនៃផ្លែដាវរបៀបនេះ គួរតែត្រូវបានរំលឹកក្នុងកិត្តិយស ។ ផ្លែដាវរបស់លោកនៅពេលនេះ បានក្លាយជារឿងដំណាលហើយ *ទេ* ? " ។

*ប្លាក់ថន* នៅចាំថា នៅពេលនោះគេបានងក់ក្បាលឯកភាពដោយខំប្រឹងលាក់នូវភាពរទ្ធត់ញាប់ញ័ររបស់គេ ។ អីលូវនេះគេស្នៀតដាវ " ឈ្មួញប្រេង " នៅទីងខ្លួនហើយ ។ ហើយជារៀងរហូតវានឹងជាប់ឈ្មោះជា " ឈ្មួញប្រេង " នេះ ។ ជាដាវដែល *តូរ៉ាណាកា* បានប្រគល់អោយរូបគេផ្ទាល់ ។ បើសិនជាគាត់មិនប្រគល់ដល់អញ នោះអញពេញចិត្តជាង -គេគិតនៅក្នុងចិត្ត ។ តែនេះក៏មិនមែនជាកំហុសគេទាំងស្រុងដែរទេ ។ អញក៏មានកំហុសដែរ ។ អញបានស្រែកគំហកទៅកាន់បុរសនោះ ហើយបុរសនោះក៏ច្រងេងច្រងាងបកមកវិញផងដែរ ។ គេមិនអាចច្រងេងច្រងាងដាក់សាមូរ៉ៃបានទេ ។ ទោះជាយ៉ាងនេះក្តី ក៏ការប្រហារជីវិតនេះបានដកយកនូវភាពរីករាយក្នុងការប្រមាញ់ចេញអស់ពីក្នុងសន្តានចិត្តរបស់គេ តែគេបានខិតខំលាក់យ៉ាងប្រយ័ត្ននៅក្នុងដួងចិត្តដោយថាពេញមួយថ្ងៃនេះ *តូរ៉ាណាកា* មូម៉ៅជាប់តែម្តង ។

មុនពេលថ្ងៃត្រង់ ពួកគេបានវិលត្រលប់មកវិញ ។ រួចគឺជាជំនួបជាមួយ *សាគាគី* ហើយបន្ទាប់មកទៀតការទៅចំហុយឆ្អិនខ្លួន និងធ្វើសរសៃ ។ ក្នុងខណៈនោះឯង ស្រាប់តែលេចមុខបព្វជិត *អាល់វីតូ* ផ្អើម ប្រៀបដូចជាបិសាចសងសឹក ។ សារីកពីរនាក់ប្រកបដោយទឹកមុខអរិភាពមានវត្តមានជាមួយលោកផងដែរ :

- ព្រះយេស៊ូជាម្ចាស់អើយ ទៅឯណាអោយឆ្ងាយពីខ្ញុំទៅ !

- មិនចាំបាច់ភ័យព្រួយ វីក៏ប្រមាថកាតទានព្រះជាម្ចាស់អីដែរ- *អាល់វីតូ* តប ។

- សូមព្រះដាក់បណ្តាសាព្រះតេជគុណ និងរាល់បព្វជិតកាតូលិចទាំងអស់ទៅចុះ ។

*ប្លាក់ថន* តបទាំងប្រឹងទប់ចិត្តរបស់ខ្លួន ដោយគេដឹងថា នៅពេលនេះគេស្ថិតនៅចំកន្លែងទីតាំងសត្រូវហើយ ។ មុននេះគេបានឃើញពួកសាមូរ៉ៃគ្រិស្តសាសនិកកន្លះរយនាក់ដើរឆ្លងស្ពានដើម្បីទៅចូលរួមក្នុងពិធីសូត្រធម៌ ដែល *ម៉ារីកូ* បានប្រាប់ថា ត្រូវបានរៀបចំឡើងនៅក្នុងទីធ្លានៃតៀមសំនាក់របស់បព្វជិត *អាល់វីតូ* ។ ដៃរបស់គេរាវរកដងដាវ តែគេមិនដែលដាក់វាជាប់



www.budinst.gov.kh www.elibraryofcambodia.org

នឹងសំពត់មុជទឹក រឺកាន់វាជាប់ទៅតាមទំលាប់នោះទេ ។ គេបន្ទោសខ្លួនឯងលើភាពល្ងីល្ងើនេះ ព្រោះគេមិនចូលចិត្តគេចូលមកវាក់រើដោយគ្មានអារុំជាប់នឹងខ្លួនបែបនេះទេ។

- សូមព្រះជាម្ចាស់អភ័យទោសដល់ការប្រមាថរបស់លោកនេះផងចុះ តែកុង។ សូមព្រះអង្គប្រោសលោក និងបើកភ្នែកលោកឡើង។ ខ្ញុំមិនមានបំនងអាក្រក់អីលើរូបលោកទេ។ ខ្ញុំមកនេះដើម្បីជូនអំនោយមួយដល់លោកតែប៉ុននោះ។ នេះ នែ៎។ នេះជាអំនោយរបស់ព្រះជាម្ចាស់ ណាំតែកុង។

*ប្លាក់ថន* លូកដៃយកកញ្ចប់ទាំងមិនទុកចិត្ត។ នៅពេលដែលគេបើកកញ្ចប់ហើយឃើញសៀវភៅវចនានុក្រម និងវេយ្យាករណ៍ប៉កទុយកាល់ -ឡាតាំង-ជប៉ុននោះ គេឡើងស្រៀវខ្លួនមួយរំពេច។ គេផ្ទាត់បើកមើលពីរបីទំព័រ : ការបោះពុម្ព គឺពិតជាក្នុងគុណភាពដ៏ល្អផ្ដាច់ ហើយភាពល់អិតនៃពតិមានគឺសែនអស្ចារ្យតែម្ដង។

គេពោលតបទៅ *អាល់វីតូ* វិញ :

- ពិតហើយ នេះជាអំនោយរបស់ព្រះ តែគឺលោកម្ចាស់ *តូរ៉ាណាកា* ដែលបានបញ្ជាអោយព្រះតេជគុណយកសៀវភៅនេះមកអោយខ្ញុំនោះ។

- យើងគោរពតាមតែបញ្ជារបស់ព្រះជាម្ចាស់តែប៉ុននោះ។

- ក្រែងលោកម្ចាស់ *តូរ៉ាណាកា* សុំអោយព្រះតេជគុណយកមកអោយខ្ញុំរឺ ?

- ពិតហើយ នេះជាសំនូមពររបស់គាត់មែន។

- ហើយមិនគឺ " សំនូមពរ " របស់លោកម្ចាស់ *តូរ៉ាណាកា* ជាអ្នកបញ្ជាទើររឺអី ?

- នេះក៏អាស្រ័យថាលោកជាអ្នកណា លោកធ្វើអ្វី និងតាមគំរិតនៃជំនឿរបស់លោកផងដែរ លោកមេបញ្ជាការ -តែកុង -*អាល់វីតូ* ចង្អុលទៅសៀវភៅ -បងប្អូនទៅក្នុងសហគមន៍យើងបីនាក់បានចំនាយពេលចំនួនម្ភៃប្រាំពីរឆ្នាំ ដើម្បីរៀបរៀងសៀវភៅនេះ។

- ហេតុអី បានជាព្រះតេជគុណអោយវាមកខ្ញុំ ?

- យើងទទួលតាមសំនូមពរគេ។

- ហេតុអីក៏ព្រះតេជគុណ មិនបង្វែរសំនូមពររបស់លោកម្ចាស់ *តូរ៉ាណាកា* ទៅ ? ព្រះ



www.budinst.gov.kh www.elibraryofcambodia.org

តេជគុណក្រលិចក្រលុចណាស់ដែរ ពិតជាអាចធ្វើបានហើយ ។

*អាលវិត្ត* ញាក់ស្មា ។ *ពួក់ថន* ផ្ទាត់សៀវភៅដើម្បីពិនិត្យគ្រប់ទំព័រ ។

- សៀវភៅនេះគ្រប់កំប្លេហើយ -បព្វជិត *អាលវិត្ត* ពោលប្រាប់ -យើងមិនរកស៊ីសៀវភៅពាក់កណ្តាលទេ ។

- សៀវភៅនេះមានតំលៃណាស់ មិនអាចយកមកចោលទទេៗយ៉ាងនេះទេ ។ តើព្រះតេជគុណចង់បានអ្វីជាសំនង ?

- លោកម្ចាស់ *គូរ៉ាណាកា* សុំអោយយើងយកសៀវភៅនេះមកអោយលោក ។ ព្រះតេជគុណគណៈអធិការសង្ឃក៏បានឯកភាពផងដែរ ។ អីលូវនេះ យើងប្រគល់សៀវភៅនេះដល់លោកហើយ ។សៀវភៅនេះទើបបានបោះពុម្ពនៅក្នុងឆ្នាំនេះទេ ។ វាស្អាតណាស់មែនទេ ពួកយើងគ្មានសំនូមពរអ្វីក្រៅតែពីសូមអោយលោក ថែរក្សាវាអោយបានល្អតែប៉ុននោះ ព្រោះថាសៀវភៅនេះសក្តិសមនឹងទទួលបាននូវការថែរក្សាមួយដ៏ល្អផងដែរ ។

- សៀវភៅនេះសក្តិសមនឹងថែរក្សាអស់មួយជីវិត ។ នេះជាចំនេះដឹងមួយកាត់ថ្លៃមិនបាន ។ តើព្រះតេជគុណចង់បានអ្វីជាថ្នូរ ?

- ពួកយើងឥតត្រូវការថ្នូរអ្វីទាំងអស់ ។

- ខ្ញុំរកជឿព្រះតេជគុណមិនរួចសោះតែម្តង -*ពួក់ថន* ម៉ិកទំងន់សៀវភៅទាំងក្នុងភាពសង្ស័យកាន់តែខ្លាំងថែមទៀត -ព្រះតេជគុណត្រូវតែដឹងហើយថា សៀវភៅនេះធ្វើអោយខ្ញុំស្មើនឹងព្រះតេជគុណបាន ។ សៀវភៅនេះនឹងផ្តល់អោយខ្ញុំនូវរាល់ចំនេះដឹងរបស់ព្រះតេជគុណ ហើយនឹងធ្វើអោយពួកខ្ញុំចំនេញពេលពីដប់ទៅម្ភៃឆ្នាំដែរ ។ ជាមួយនឹងសៀវភៅនេះ បន្តិចទៀតខ្ញុំអាចនិយាយបានល្អដូចព្រះតេជគុណ ។ នៅពេលនោះ ខ្ញុំអាចបង្រៀនអ្នកដទៃទៀតបានហើយ ។ នេះគឺជាសោស់រាប់ប្រទេសជប៉ុន *នេ* ? ភាសាគឺជាសោសំរាប់គ្រប់ទីកន្លែងខាងក្រៅប្រទេស *នេ* ? ក្នុងប្រាំមួយខែខ្ញុំនឹងអាចនិយាយផ្ទាល់ជាមួយ *គូរ៉ាណាកា-សាម៉ា* បានហើយ ។

- ពិតហើយ ប្រហែលជាលោកអាចនិយាយបានមែន ។ បើសិនជាលោកមានពេលប្រាំមួយខែ ។



www.budinst.gov.kh www.elibraryofcambodia.org

- ព្រះតេជគុណចង់មានប្រសាសន៍ថាម៉េច ?

- គ្មានអ្វីក្រៅពីអ្វីដែលលោកបានដឹងរួចហើយនោះទេ ។ លោកម្ចាស់ *តូរ៉ាណាកា* នឹងស្លាប់មុនផុតរយៈពេលប្រាំមួយខែនោះទៅទៀត ។

- ហេតុអី ? តើដំណឹងអ្វីដែលព្រះតេជគុណយកមកប្រាប់គាត់ ? តាំងពីគាត់ជួបជជែកជាមួយព្រះតេជគុណមក គាត់ប្រៀបដូចជាគោឡើងកដែលគេអារដាច់ពាក់កណ្តាលអីចឹង ។ តើព្រះតេជគុណមានប្រសាសន៍រឿងអីខ្លះ អ្នាស ?

- សាររបស់ខ្ញុំជាសារសំងាត់ ។ ជាសារពីព្រះតេជគុណគណៈសង្ឃចំពោះលោកម្ចាស់ *តូរ៉ាណាកា* តែប៉ុននោះ ។ អោយខ្ញុំសូមទោសទៅចុះ ។ ខ្ញុំគ្រាន់តែជាអ្នកនាំសារម្នាក់ប៉ុននោះ ។ តែលោកច្បាស់ជាដឹងហើយថា លោកមេទ័ព *អ៊ីស៊ីដូ* គ្រួតត្រា *អូសាកា* ហើយនៅពេលដែល *តូរ៉ាណាកា-សាម៉ា* ទៅដល់ *អូសាកា* នោះ អ្វីៗនឹងត្រូវបញ្ចប់ចំពោះគាត់ហើយ ។ ហើយចំពោះលោកក៏អីចឹងដែរ ។

*ប្លាក់ថន* ត្រដាក់ខ្លួនស្រេងតែម្តង :

- ហេតុអីខ្ញុំ ?

- លោកមិនអាចគេចផុតពីព្រហ្មលិខិតរបស់លោកបានទេ លោកតែគុង ។ លោកបានជួយ *តូរ៉ាណាកា* ប្រឆាំងនឹង *អ៊ីស៊ីដូ* ។ លោកភ្លេចហើយរឺ លោកបានប្រើការប្រឆាំងទាំងកំភែលទៅលើ *អ៊ីស៊ីដូ* ។ លោកបាននាំការវាយសំរុកចេញពីកំពង់ផែ *អូសាកា*។ អោយខ្ញុំសូមទោសផងទៅចុះតែទោះជាលោកនិយាយភាសាជប៉ុនបាន ទោះជាលោកមានងារ និងឋានៈជាសាមូរ៉ៃក្តី ក៏ទាំងនេះមិនអាចជួយលោកបានដែរ ។ អាចថាឋានៈជាសាមូរ៉ៃពេលនេះ រឹតតែនាំអោយយ៉ាប់ទៅទៀតផងក៏មិនដឹង ។ ពេលនេះលោកនឹងត្រូវទទួលបញ្ជាអោយធ្វើ *សិបពូគូ* តែម្តង ហើយបើលោក ប្រកែក....-បព្វជិត *អាលវីតូ* ពោលបន្ថែម ក្នុងសំលេងយ៉ាងទន់ភ្លន់ដដែល -ខ្ញុំបានប្រាប់លោក ហើយថា ពួកនេះជាប្រជាជនសាមញ្ញណាស់ ។

-ពួកអង់គ្លេសយើងក៏ជាប្រជាជនសាមញ្ញដែរ-គេតបយ៉ាងព្រហើនដដែល -កាលណាយើងស្លាប់ គឺយើងស្លាប់ហើយ ។ តែមុនស្លាប់យើងដាក់ជំនឿយើងទៅលើព្រះជាម្ចាស់ ហើយ



www.budinst.gov.kh www.elibraryofcambodia.org

រក្សារំសេវយើងអោយនៅស្ងួតជានិច្ច ។ ខ្ញុំនៅមានសល់ល្បិចខ្លះដែរសូមព្រះតេជគុណកុំបារម្ភអី ។

- អូហ៎ ខ្ញុំអត់មានបារម្ភអីទេ លោកតៃកុង ។ ខ្ញុំគ្មានខ្លាចអ្វីទាំងអស់ ។ លោកក៏ខ្ញុំមិនខ្លាច ភាពជាទមិឡរបស់លោកក៏ខ្ញុំមិនខ្លាច កាំភ្លើងរបស់លោកក៏ខ្ញុំមិនខ្លាច ។

- នេះគឺជា *កាម៉ា* ។ គឺនៅក្នុងកណ្តាប់ដៃព្រះជាម្ចាស់ រឺហៅថាម៉េចស្រេចតាមចំនួលចំនង់ចិត្តព្រះតេជគុណទៅចុះ ។ តែអាស្រ័យដោយព្រះជាម្ចាស់ខ្ញុំនឹងបានទទួលសំពៅខ្ញុំមកវិញ ហើយនៅក្នុងតែប៉ុន្មានឆ្នាំទៀតប៉ុណ្ណោះ ខ្ញុំនឹងដឹកនាំកងសំពៅមកទីនេះ ហើយនិងចាក់ពួកព្រះតេជគុណប៉ើងចេញពីអាស៊ីជាមិនខាន ។

*អាល៊ីវ៉ិតូ* តបវិញដោយនៅរក្សាភាពដ៏ស្ងប់ស្ងាត់ដ៏មហិមារបស់លោកដដែល :

- នេះគឺនៅក្នុងកណ្តាប់ដៃព្រះជាម្ចាស់ តៃកុង ។ តែនៅទីនេះ រឿងប្រហារជីវិតត្រូវបានសំរេចរួចទៅហើយ១អ្វី១ដែលលោកនិយាយនេះ នឹងមិនមានកើតឡើងឡើយ ។ គ្មានសោះ -បព្វជិត *អាល៊ីវ៉ិតូ* សំលឹងមើលទៅ *ប្លាក់ថន* ប្រៀបដូចគេជាមនុស្សស្លាប់បាត់ទៅហើយ-សូមព្រះជាម្ចាស់ប្រោសលោកផងទៅចុះ ព្រោះថា ព្រះជាម្ចាស់ជាចៅក្រមរបស់ខ្ញុំ ។ ខ្ញុំមានជំនឿថា លោកពិតជាមិនអាចចាកចេញពីកោះនេះបានជារៀងរហូត ។

*ប្លាក់ថន* ឡើងស្រៀវខ្លួនដោយគេចាំបានពីទំនុកចិត្តរបស់បព្វជិត *អាល៊ីវ៉ិតូ* នៅពេលនិយាយពាក្យនេះ ។

- លោករងារ រឺ *អាន់ជីន-សាន* ?

*ម៉ារីកូ* កំពុងតែនៅឯយ៉ាបរានហាលពីក្រោយខ្នងគេ ។ នាងរលាស់ដីនៅពីលើឆត្រ ។ តេម្ពីម្នាឆ្លើយតប :

- អូហ៎ សូមអភ័យទោស ។ ខ្ញុំអត់រងារទេ ។ ខ្ញុំកំពុងគិតពិចារណាទេតើ ។

គេចោលភ្នែកសំលឹងមើលទៅច្រកភ្នំ ។ ក្បួនដំណើរទាំងមូលបានកប់លិចបាត់ទៅក្នុងរបាំងពពកទៅហើយ ។ ភ្លៀងបានបន្ថយឥទ្ធិពលបន្តិចហើយ ប៉ុន្តែនៅតែស្រិច១និងមានភាពក្តៅឧណ្ហ១នៅឡើយ ។ អ្នកភូមិ និងអ្នកបំរើមួយចំនួនដើរប៉ិប៉ុចប៉ិប៉ាច់កាត់ភក់ត្រលប់ទៅផ្ទះវិញ ។ ទីធ្លាគ្មានមនុស្សណាម្នាក់ទៀតទេ ឯសួនច្បារវិញមានទឹកដក់ជោកជាំ ។ ចង្កៀងប្រេងត្រូវបាន



www.budinst.gov.kh www.elibraryofcambodia.org

គេដុតបំភ្លឺនៅទូទាំងភូមិ ។ នៅទាំងសងខាងស្ពានគ្មានអ្នកយាមណាម្នាក់ទៀតឡើយ ។ ទំហេង (Vacuum) ដ៏ធំមួយបាក់បានមកគ្រប់ដណ្តប់សន្ធិប្រកាស (twilight) (*) នេះតែម្តង ។

*ម៉ារីកូ* សួរ :

- ពេលយប់ស្អាតជាងមែនទេ ?

- ពិតមែនហើយ ។

គេតប ។ ពេលនេះគេដឹងថា ពួកគេទាំងពីរនាក់នៅដាច់ពីគេ ហើយប្រកបដោយសុវត្ថិភាពទៀតផង បើសិនណាជាពួកគេប្រយ័ត្នប្រយែង និងបើសិនជានាងមានបំណងដូចគេដែរនោះ ។

នារីបំរើម្នាក់បានមកយកឆត្រពីនាង និងយកស្រោមជើងស្ងួតមកអោយ ។ នារីបំរើនេះលុតជង្គង់ដើម្បីចាប់ផ្តើមសំងួតជើងនាងជាមុន ។ នាងពោលបន្ត :

- ស្អែកព្រលឹម យើងចាប់ផ្តើមចេញដំណើរហើយ *អាន់ជីន-សាន* ។

- តើយើងត្រូវប្រើពេលវេលាប៉ុន្មានទៅ ?

- ប៉ុន្មានថ្ងៃដែរ *អាន់ជីន-សាន* ។ លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ថា -នាងបែរក្រសៃភ្នែកចេញនៅពេលដែលនាងឃើញ *គីយ៉ូកូ* ដើរចេញពីក្នុងត្បៀមសំនាក់មក -លោកម្ចាស់ *តូរ៉ាណាកា* មានប្រសាសន៍ប្រាប់ខ្ញុំថា យើងមានពេលវេលាគ្រប់គ្រាន់ទេ ។

*គីយ៉ូកូ* លំអោនខ្លួនគោរពយ៉ាងទាប :

- រាត្រីសួស្តី លោកស្រី *តូដា* ។ សូមលោកស្រីអធ្យាស្រ័យចំពោះប្រការដែលខ្ញុំបានមករំខានលោកស្រីនេះផង ។

- សុខសប្បាយជាទេ *គីយ៉ូកូ-សាន* ?

- សុខសប្បាយជាទេ សូមអរគុណ ។ តែខ្ញុំចង់អោយភ្លៀងនេះឆាប់រាំងម្ល៉េះទេ ។ ខ្ញុំមិនចូលចិត្តសំណើមនេះទេ ។ តែដល់អស់ភ្លៀងតាំងក្តៅវិញម្តង ហើយនេះរឹតតែយ៉ាប់ទៅទៀត *នេ* ? តែសរទរដូវនៅមិនយូរប៉ុន្មានទៀតដែរទេ...ហ៊ឺ ពួកយើងចំជាមានសំនាងដែលត្រូវរង់ចាំសរទរដូវ និង និទាឃរដូវដ៏ល្អដូចហ៊ានសូគិនេះ *នេ* ?

---

*( * ) ពន្លឺមុនព្រះអាទិត្យរះ និងក្រោយព្រះអាទិត្យអស្តង្គត*



www.budinst.gov.kh www.elibraryofcambodia.org

*ម៉ារីកូ* ឥតមានឆ្លើយតប ។នារីបំរើចងបន្តឹងស្រោមជើងសំរាប់នាង ហើយក៏ក្រោកឈរឡើង :

- អរគុណ -*ម៉ារីកូ* អោយអ្នកបំរើត្រលប់ទៅវិញ រួចទើបនិយាយទៅកាន់នារីចំនាស់-មើល៍ *គីយ៉ូកូ-សាន* មានការងារអ្វីដែលខ្ញុំអាចជួយបានទេ ?

- *គីកូ-សាន* ចង់ដឹងថា តើលោកស្រីចង់អោយនាងនៅបំរើលោកស្រីពេលបាយល្ងាចនេះ រឺក៏រាំ រឺច្រៀងជូនលោកស្រីនៅយប់នេះទេ ? លោកម្ចាស់ *តូរ៉ាណាកា* បានផ្តាំគេអោយប្រាប់នាងថា នាងត្រូវនៅកំដរលោកស្រី បើសិនជាលោកស្រីត្រូវការនាង ។

- ចាស គាត់ប្រាប់ខ្ញុំដែរ *គីយ៉ូកូ-សាន* ។ នេះល្អម្យ៉ាងដែរ តែមិនមែនសំរាប់យប់នេះទេ ។ ស្អែកព្រលឹមយើងត្រូវចេញដំណើរ ហើយខ្ញុំក៏ហត់នឿយណាស់ផង ។ ចាំយប់ក្រោយ១ទៀតទៅ *នេ* ? សូមផ្តាំទៅនាងថា អោយខ្ញុំសូមទោសផង ។ អូហ៍ សូមផ្តាំទៅនាងផង ថាខ្ញុំរីករាយណាស់ដែលបានឃើញនាង និងអ្នកស្រីរួមដំណើរជាមួយខ្ញុំនេះ ។

*តូរ៉ាណាកា* បានបញ្ជាអោយនាងនាំនារីទាំងពីរនេះទៅជាមួយនាងផង ហើយនាងក៏បានអរគុណ *តូរ៉ាណាកា*វិញដែរដោយថា នាងក៏បានអ្នកជូនដំណើរជាផ្លូវការផងដែរ ។

- លោកស្រីចិត្តល្អណាស់ -*គីយ៉ូកូ* និយាយយ៉ាងផ្អែម -តែនេះគឺជាកិត្តិយសរបស់ពួកយើងខ្ញុំនេះវិញទេ ។ តែយើងនៅតែទៅ *យេដូ*ដដែលទេអ្វី ?

- ចាស ពិតជាអីចឹងហើយ ។ មានការអីរឺ ?

- អត់មានអីទេលោកស្រី *តូដា* ។ តែក្នុងករណីរបៀបនេះ តើពួកយើងអាចឈប់នៅ *មីស៊ីម៉ា* មួយថ្ងៃពីរបានទេ ? *គីកូ-សាន* ចង់ប្រមែប្រមូលខោអាវខ្លះ ។នាងមានអារម្មណ៍ថានាងស្លៀកពាក់មិនសមរម្យនឹងលោកម្ចាស់ *តូរ៉ាណាកា* ទេ ហើយខ្ញុំលឺគេថានៅឯ *យេដូ* នោះពេលរស្សាន្តរដូវគឺស្អុះស្អាប់ និងសំបូរមូសណាស់ ។ ពួកយើងខ្ញុំគិតថា គួរយកសំពត់អាវរបស់នាងទៅជាមួយ ទោះជាសំពត់អាវនោះមិនថ្លៃថ្នូរណាស់ណាក៏ដោយ ។

-ចាស ពិតមែនហើយ ។អ្នកទាំងពីរមានពេលវេលាហួសពីគ្រប់គ្រាន់ណាស់ទៅទៀត ។

*គីយ៉ូកូ* ឥតសំលឹងមើល *ភ្លាក់ថន* ទេ ថ្វីបើគាត់មានអារម្មណ៍ជាប់ពីវត្តមានរបស់គេក្តី ។



www.budinst.gov.kh www.elibraryofcambodia.org

- រឿងលោកម្ចាស់យើង គួរអោយអាណិតណាស់ *ទេ*?

- *កាម៉ា -ម៉ារីកូ* តបក្នុងសំលេងឥតប្រែប្រួល។ រួចនាងបន្តយ៉ាងមុត -តែគ្មានអ្វីផ្លាស់ប្តូរទេ *គីយ៉ូកូ-សាន*។ អ្នកស្រីនឹងទទួលបានលុយគ្រប់ចំនួន ជាប្រាក់សុទ្ធតាមកិច្ចសន្យានៅថ្ងៃដែលអ្នកស្រីទៅដល់ទីដៅនោះហើយ។

- អូហ៍ សូមទោស -ស្ត្រីចំនាស់តប ដោយធ្វើជាភ្ញាក់ផ្អើលយ៉ាងខ្លាំង -លោកស្រី *តូដា* រឿងលុយនោះវី ? ខ្ញុំមិនទាំងដែលបានគិតដល់ផងទេ។ អត់មានសោះហើយ។ ខ្ញុំបារម្ភតែពីរឿងអនាគតរបស់លោកម្ចាស់យើងតែមួយមុខគត់។

- លោកជាម្ចាស់លើអនាគតរបស់លោកហើយ -*ម៉ារីកូ* តបយ៉ាងផុយ ដោយទាំងលែងមានជំនឿលើសជីវរបស់ខ្លួននេះទៀតផង -តែអនាគតរបស់អ្នកស្រីគឺល្អមែនទេ ?....ទោះជាមានរឿងអ្វីកើតឡើងក៏ដោយ។ អីលូវនេះ អ្នកស្រីជាអ្នកមានហើយ។ រាល់កង្វល់របស់អ្នកស្រីលើលោកនេះលែងមានទៀតហើយដែរ។ បន្តិចទៀតនេះ អ្នកស្រីនឹងក្លាយជាអ្នកមានអំនាចមួយនៅ *យេដូ* ជាមួយនឹងពួកសាជីវកម្មបំរើភ្ញៀវរបស់អ្នកស្រី ទោះជាអ្នកណាត្រួតត្រា *ក្វាន់តូ* ក៏ដោយ។ បន្តិចទៀត អ្នកស្រីនឹងក្លាយជា *ម៉ាម៉ា-សាន* ដ៏មហិមាជាងគេទាំងអស់ ហើយទោះជាមានរឿងអីកើតឡើងក៏ដោយ ក៏ *គីកូ-សាន* នៅតែជាកូនចៅរបស់អ្នកស្រី ហើយយុវភាពរបស់នាងនឹងមិនត្រូវបានប៉ះពាល់ឡើយ។ *កាម៉ា* នាងក៏អីចឹងដែរ *ទេ*?

-កង្វល់តែមួយរបស់ខ្ញុំ គឺលោកម្ចាស់ *តូរ៉ាណាកា* តែប៉ុណ្ណោះ-*គីយ៉ូកូ* តបដោយខំរក្សាទឹកមុខម៉ឺងម៉ាត់ តែក្នុងចិត្តរបស់គាត់ គឺមហាញាប់ញ័រចំពោះទឹកប្រាក់ពីរពាន់ប្រាំរយ *កូកូ* ដែលនៅកៀកនឹងខ្លួនគាត់យ៉ាងនេះ -បើសិនជាខ្ញុំអាចជួយគាត់តាមរបៀបណាបាន ខ្ញុំនឹង........

- អ្នកស្រីចំជាមានសន្តានចិត្តសប្បុរសធម៌មែន *គីយ៉ូកូ-សាន*។ ខ្ញុំនឹងជំរាបលោកម្ចាស់ពីការសូមជួយរបស់អ្នកស្រីនេះ។ ចាស បើបន្ថយថ្លៃមួយពាន់ *កូកូ* នោះគឺពិតជាជួយបានច្រើនមែនទែន។ ខ្ញុំសូមទទួលយកក្នុងនាមរបស់លោកម្ចាស់ *តូរ៉ាណាកា* ទៅចុះ។

*គីយ៉ូកូ* បក់ផ្លិតរបស់ខ្លួនតិចៗ ដោយខំរក្សាទឹកមុខញញឹមនៅលើរង្វង់មុខខ្លួនដដែលព្រមទាំងខំទប់ចិត្តមិនជំទាលស្រែកយំ ព្រោះក្តៅក្រហាយចិត្តដែលធ្លាក់ចូលអន្ទាក់ *ម៉ារីកូ* ដូចកូន



www.budinst.gov.kh www.elibraryofcambodia.org

ក្មេងរៀនផឹកស្រា *សារក* ដំបូងយ៉ាងនេះ :

- ទេ ទេ លោកស្រី *ភូដា* ។ តើប្រាក់អាចទៅជួយចៅវ៉ាយប្រកបដោយចិត្តទូលាយបែបនេះម៉េចនឹងកើតទៅ ? ទេ ច្បាស់ណាស់ដែលថាលុយពិតជាមិនអាចជួយអីលោកម្ចាស់បានទេ -*គីយ៉ូកូ* និយាយទាំងរដាក់រដុបព្រោះតែប្រឹងទប់ចិត្តអោយបាននៅស្ងប់ស្ងាត់ឡើងវិញ -ទេ លុយជួយមិនកើតទេ។ យកល្អ គឺការផ្តល់ពត៌មាន រឺការផ្តល់នូវជំនួយសេវាអ្វីផ្សេងៗ រឺក៏ជា......

- អោយខ្ញុំសូមទោសផងទៅចុះ តើពត៌មានអីទៅ ?

- អត់មានអីទេ។ គ្មានពត៌មានអ្វីទាំងអស់ទៅពេលនេះ។ ខ្ញុំគ្រាន់តែលើកឡើងជាគំនិតតែប៉ុននោះ សូមទោស។ តែរឿងលុយវិញ.....

- ចាស អូហ៍ អោយខ្ញុំសូមទោសផងចុះ។ ចាស ខ្ញុំនឹងជំរាបលោកម្ចាស់ពីការផ្តល់ជូនរបស់លោកស្រី។ ហើយនឹងជំរាបជូនលោកផងដែរពីសប្បុរសធម៌របស់អ្នកស្រី។ ក្នុងនាមរបស់លោកម្ចាស់ ខ្ញុំសូមអរគុណអ្នកស្រីណាស់។

ដោយឃើញថា ខ្លួនត្រូវបានទទួលសញ្ញាបញ្ចប់កិច្ចសន្ទនាហើយនោះ *គីយ៉ូកូ* ក៏លំអោនខ្លួនគោរពលា ហើយវិលចូលទៅក្នុងត្រៀមសំនាក់វិញទៅ។

*ម៉ារីកូ* ផ្ទុះសំណើចខឹកៗ។

- តើនាងសើចរឿងអីហ្នឹង *ម៉ារីកូ-សាន* ?

នាងនិយាយប្រាប់ *ភ្លាក់ថុន* ពីអ្វីដែលបាននិយាយគ្នាអំបាញ់មិញនេះ។ រួចនាងសន្និដ្ឋាន:

- មួយពិភពលោកនេះពួក *ម៉ាម៉ា-សាន* ប្រហែលដូចគ្នាតែទាំងអស់ហ្នឹង។ ពួកគេខ្វល់តែពីរឿងលុយរបស់ពួកគេតែប៉ុននោះឯង។

- តើលោកម្ចាស់ *តូរ៉ាណាកា* នឹងអោយលុយទៅគាត់ទេ ទោះបីជា........

រួច *ភ្លាក់ថុន* ក៏ឈប់ទ្រឹង។ *ម៉ារីកូ* នៅរង់ចាំយ៉ាងធម្មតា ហាក់ដូចជាមិនយល់រឿងអីទាំងអស់។ *ភ្លាក់ថុន* ក៏បន្ត :

- បព្វជិត *អាល់វីតូ* និយាយថា បើលោកម្ចាស់ *តូរ៉ាណាកា* អញ្ជើញទៅ *អូសាកា* គឺជីវិតគាត់នឹងចប់ហើយ។



www.budinst.gov.kh www.elibraryofcambodia.org

- ចាស ។ ចាស ពិតជាអ៊ីចឹងមែនហើយ -នាងពោលតបទាំងទឹកមុខភ្លឺថ្លាមួយដែលមិនមាននៅក្នុងដួងចិត្តរបស់នាងឡើយ ។ រួចនាងក៏ទុក *តួរ៉ាណាកា* និង *អូសាកា* ទៅក្នុងប្រអប់ដោយឡែក១នៅក្នុងអារម្មណ៍របស់នាង ដែលធ្វើអោយនាងមានអារម្មណ៍ស្ងប់ស្ងាត់ឡើងវិញ -តែ *អូសាកា* ស្ថិតនៅឆ្ងាយពីទីនេះណាស់ ហើយយើងនៅមានពេលរាប់យាមនៅក្នុងអនាគតនេះ ។ អ្វីដែលមកដល់នឹងមកដល់ *អ៊ីស៊ីដូ* មិនអាចដឹងបានទេ បញ្ជិតសង្ឃដ៏ល្អនេះ ក៏មិនដឹងច្បាស់ដែរទេ យើងក៏មិនដឹង គ្មានអ្នកណាដឹងច្បាស់ថា តើនឹងមានអ្វីពិតប្រាកដកើតឡើងបានទេ *វទេ* ? មានតែព្រះជាម្ចាស់តែប៉ុននោះដែលអាចដឹងបាន ។ តែព្រះជាម្ចាស់លោកនឹងមិនប្រាប់យើងទេ មែនទេ ?

- ហៃ ! -*ប្លាក់ថន* សើចបន្តរតាមនាង -នាងពិតជាវាងវៃមែន ។

- សូមអរគុណ ។ ខ្ញុំសូមស្នើរឿងមួយ *អាន់ជីន-សាន* ។ នៅក្នុងរយៈពេលដែលយើងធ្វើដំណើរនេះ យើងត្រូវបំភ្លេចចោលអោយអស់រឿងរ៉ាវខាងក្រៅ ។ រឿងទាំងអស់ ណា៎ ។

☆ ☆ ☆



www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org